# សតិប្បដ្ឋានទីបនី

អធិប្បាយសេចក្តីសតិប្បដ្ឋានសូត្រ

ព្រះត្រៃបិដក លេខ ២០

៨

ពុទ្ធសករាជ ២៥៤៨
គ.ស. ២០០៥

*អារម្ភកថា*

ក្រុមបកប្រែយើងបានឃើញសេចក្ដីក្នុងព្រះត្រៃបិដក មានសេចក្ដីល្អិតជ្រាលជ្រៅដ៏ក្រៃលែង ពុំងាយនឹងយល់សេចក្ដីឱ្យបានចូលចិត្ត ក៏បានស្ម័គ្រចិត្តរួបរួមគ្នាទាំងព្រះសង្ឃ និង គ្រហស្ថ នៅខេត្តបាត់ដំបង រៀបចំបកប្រែគម្ពីរព្រះ-អដ្ឋកថា ( ដែលជាគម្ពីរអធិប្បាយសេចក្ដីរបស់ព្រះត្រៃបិដកដែលព្រះពុទ្ធឃោ-សាចារ្យរចនាឡើងក្នុងសម័យពុទ្ធសករាជ ៩០០-១.០០០ ) ពីភាសាសៀមមកជាខេមរភាសា ។

ការផ្ដើមកិច្ចការនេះ តាំងពីពុទ្ធសករាជ ២៥៤៤ ហើយក្រុមបកប្រែយើងបានកំណត់ការជួបជុំគ្នាជារៀងរាល់ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និង ថ្ងៃសីល នៅអាស្រមព្រះគន្ធកុដិ និង នៅវត្តកំផែង ដើម្បីសម្រេចកិច្ចការនេះ ។

ចាប់តាំងពីវេលាប្រែព្រះអដ្ឋកថា រហូតដល់សព្វថ្ងៃនេះ យើងរាល់គ្នាតែងមានសេចក្ដីត្រិះរិះអំពីការប្រែ រៀបសេចក្ដី ប្រយោគ យ៉ាងល្អិតល្អន់ ដើម្បីឱ្យសមតាមសំនួនភាសាជាតិផង និង ចៀសវាងការឃ្លៀងឃ្លាតអំពីគោលដើម ផងដោយផ្ទៀងផ្ទាត់តាមសំនួនប្រែរបស់ព្រះត្រៃបិដកខ្លះ អដ្ឋកថាបាលីខ្លះ ព្រមទាំងគម្ពីរផ្សេង ៗ ទៀត ដូចជា វចនានុក្រមព្រះត្រៃបិដកជាភាសាសៀម និង អង់គ្លេស , អភិធានប្បទីបិកា , វចនានុក្រមភាសាខ្មែរ ។ល។

យើងសូមជូនដំណឹងដល់អស់លោកអ្នកសិក្សាបានជ្រាបថា ត្បិតយើងទាំងអស់គ្នាប្រិតព្រៀងយ៉ាងនេះក៏ដោយចុះ នៅត្រង់សេចក្ដីខ្លះក៏មានការការលំ-បាកយល់ លំបាកចូលចិត្ត តែទោះជាយ៉ាងនេះក៏សូមអស់លោកតាំងសទ្ធាឱ្យបានមាំដើម្បីព្យាយាមសិក្សាផងចុះ ។

ម្យ៉ាងទៀត បើពុទ្ធបរិស័ទមានបំណងនឹងរៀន នឹងប្រតិបត្តិតាមសីល សមាធិ បញ្ញា ក៏មានបរិបូណ៌ក្នុងព្រះអដ្ឋកថានោះសព្វគ្រប់ ។

ព្រះអដ្ឋកថាបានប្រសូតចេញចាកផ្ទៃ គឺ បានប្រែសម្រួលមកជាខេមរ-



ភាសា អណ្តែតត្រសែតមកប្រាកដដល់ភ្នែកយើងគ្រប់គ្នា ដោយមិនលំបាកងាករកប៉ុន្មានឡើយ ។

យើងរាល់គ្នាក្នុងកម្ពុជរដ្ឋ ដែលមានសទ្ធាពេញចិត្តប្រតិបត្តិតាមឱវាទានុសាសនីបច្ចុប្បន្ន ប្រៀបដូចជាបានប្រទីប ឬ គោមធំពីរ ភ្លឺរតាំងបំភ្លឺអមតាមផ្លូវដែលជាផ្លូវដើរទៅរកទីក្សេម ជាផ្លូវដែលអ្នកឥតសំណាងមិនអាចចូលដើរច្រៀតបៀតទៅជាមួយបាន ។

ប្រទេសយើងជាប្រទេសមានភ័ព្វសំណាងយ៉ាងខ្ពស់ និងលាភដ៏ធំ ដែលមានព្រះត្រៃបិដក ជាព្រះពុទ្ធដីកា ១ ចប់ ព្រមទាំងមានសប្បុរសទាំងឡាយខិតខំខ្នះខ្នែងប្រែព្រះអដ្ឋកថាឱ្យមកជាភាសាជាតិទៀតផង ដូចជា ក្រុមប្រែខាងភ្នំគិរីរម្យ ( ប្រែអដ្ឋកថា ព្រះអភិធម្ម ) , ក្រុមប្រែរបស់ឧបាសក សៀម សារ៉េត ( ហៅ គ្រែ ) វត្តកំផែង ( ប្រែអដ្ឋកថាព្រះវិន័យ ) ។ល។ ទាំងនេះហើយដែលពុទ្ធបរិស័ទយើង ហាក់ដូចជាបានឱសថ ២ បំពង់កែវ ដែលឱសថនេះឯងនឹងអាចរំងាប់រោគច្រើនយ៉ាង មានរោគក្តៅក្រហាយ គឺ សេចក្តីវិវាទទាស់ទែងគ្នា ការលោភលន់ជាដើម និងសេចក្តីសង្ស័យមិនដាច់ស្រេច ឱ្យជាសះស្បើយបានជាប្រាកដ ។

ក្រុមប្រែយើង ឃើញប្រយោជន៍ដ៏សម្បូរនៃការមានស្មារតីរបស់ពុទ្ធបរិ- ស័ទ ទើបឆ្លៀតឱកាសដកស្រង់អដ្ឋកថាសតិប្បដ្ឋាន ធ្វើជាសៀវភៅមួយក្បាល ដោយឡែកចាកគម្ពីរអដ្ឋកថាបបញ្ចសូទនី មជ្ឈិមនិកាយ មូលបណ្ណាសកៈ ។

ដោយអានុភាពនៃបុណ្យ សូមដែនកម្ពុជា ប្រកបនូវសេចក្តីសុខចម្រើនគ្រប់ប្រការ និងសូមឱ្យព្រះពុទ្ធសាសនាមានតេជានុភាពរុងរឿងអស្ចារ្យឱឡារិករហូតកាល សូមពពួកសត្វទូទៅទាំងអនន្តចក្រវាឡ បានជួបប្រទះនឹងសេចក្តីសុខក្សេមក្សាន្តគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

បាត់ដំបង ពុទ្ធសករាជ ២៥៤៨

**** * ****

*ធាតុភាជនីយកថា*

ព្រះមហាគោតម ជាព្រះជិនស្រីប្រសើរ ទ្រង់បរិនិព្វានក្នុងនគរកុសិនារា ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះ ៗ តាមចំណែក គឺ ÷

ព្រះធាតុមួយចំណែក បានទៅព្រះបាទអជាតសត្តុ

មួយចំណែក បានទៅក្រុងវេសាលី

មួយចំណែក បានទៅក្រុងកបិលព័ស្ដុ

មួយចំណែក បានទៅដែនអល្លកប្បកៈ

មួយចំណែក បានទៅក្រុងរាមគ្រាម

មួយចំណែក បានទៅវេដ្ឋទីបកៈ

មួយចំណែក បានទៅក្រុងបាវេយ្យកមល្លៈ

ឯព្រះធាតុមួយចំណែកទៀត បានទៅអ្នកក្រុងកុសិនារា ។

ព្រាហ្មណ៍ឈ្មោះ ទោណៈ បានធ្វើស្តូបបញ្ចុះតុម្ព ( ទាំល ) , ពួកមោរិ-ជន មានចិត្តជ្រះថ្លា បានធ្វើស្តូបបញ្ចុះព្រះអង្គារ ( ធ្យូង ) ។ ព្រះស្តូបបញ្ចុះព្រះ- សារីរិកធាតុ មាន ៨ បើរាប់តុម្ពចេតិយមួយផង ជា ៩ , បើគិតទាំងព្រះស្តូប បញ្ចុះព្រះអង្គារមួយទៀត ត្រូវជា ១០ ដែលមហាជនស្ថាបនាទុកក្នុងកាលនោះ ។

ព្រះចង្កូម ១ តម្កល់ក្នុងឋានត្រៃត្រឹង្ស

ព្រះចង្កូម ១ តម្កល់ក្នុងនាគបុរី

ព្រះចង្កូម ១ តម្កល់នៅក្នុងដែនគន្ធារៈ

ព្រះចង្កូម ១ តម្កល់នៅក្នុងដែនកាលិង្គរាជ

ព្រះទន្ត ៤០ គត់ ព្រះកេសា និង ព្រះលោមាទាំងអស់ ពួកទេវតារៀង

យ

ខ្លួន បាននាំទៅមួយ ៗ កាន់ចក្រវាឡទីទៃ ៗ ។

បាត្រ ឈើច្រត់ និងចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកនៅក្នុងដែន វជីរ , ស្បង់ តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល , គ្រឿងកម្រាល តម្កល់ទុកនៅក្នុង ក្រុង ឈ្មោះសិលៈ ។ ធម្មក្រក និង កាយពន្ធ តម្កល់ទុកនៅក្នុងក្រុងបាដលីបុត្ត ឧទកសាដក តម្កល់ទុកនៅក្នុងក្រុងចម្បា , ព្រះឧណ្ណាលោម ( រោមចិញ្ចើម ) តម្កល់ទុកនៅក្នុងដែនកោសល ។ សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ឆ្នួត តម្កល់ទុកក្នុងឋានត្រៃត្រឹង្ស , ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ ទុកលើថ្ម , សំពត់នីសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ , គ្រឿងកម្រាល តម្កល់ ទុកក្នុងដែនឈ្មោះ ទេវៈ ក្នុងកាលនោះ ។ កាលនោះ ដែកភ្លើង តម្កល់ទុកក្នុង ក្រុងមិថិលា , តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ , កាំបិតកោរ និងបំពង់ម្ជុល តម្កល់ទុកនៅក្នុងឥន្ទបត្ថបុរី ។ កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ ទុកក្នុងជនបទជាទីបំផុត ។ ពួកមនុស្ស តែងបូជាចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីទ្រង់ប្រើប្រាស់ ។ ការផ្សាយទៅនៃព្រះធាតុ របស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបូរាណ ( នៃព្រះពុទ្ធទាំងឡាយ ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយ ជាខាងក្រោយ ។

( ស្រង់ចាកគម្ពីរចរិយាបិដក លេខ ៧៧ )

# សតិប្បដ្ឋានទីបនី

អធិប្បាយសេចក្តីសតិប្បដ្ឋានសូត្រ

ព្រះត្រៃបិដក លេខ ២០

៨

ពុទ្ធសករាជ ២៥៤៨

គ.ស. ២០០៥

# មាតិកាធម៌

ឈ្មោះធម៌ លេខទំព័រ

-ហេតុដូចម្តេច ទើបព្រះអង្គត្រាស់សម្តែងសតិប្បដ្ឋាន...................... ៦

-សត្វលោកចម្រើនសតិប្បដ្ឋាន ............................................ ៨

-អត្ថនៃពាក្យថា ឯកាយនៈ .................................................. ១០

-សិស្ស និង អាចារ្យសន្ទនាគ្នា ............................................ ១២

-អធិប្បាយមគ្គ ............................................................ ១៥

-ព្រះថេរៈគប់បំបាក់ជើង .................................................. ១៨

-ភិក្ខុសម្រេចព្រះអរហន្តក្នុងមាត់ខ្លា ..................................... ១៩

-ទេវតាធ្លាក់នរក .......................................................... ២២

-អធិប្បាយស័ព្ទថា យទិទំ ................................................ ២៨

-អធិប្បាយ សតិប្បដ្ឋាន .................................................. ២៨

-ហេតុដែលត្រាស់សតិប្បដ្ឋាន ៤ យ៉ាង ................................ ៣១

-អត្ថនៃពាក្យថា ភិក្ខុ ...................................................... ៣៥

-អធិប្បាយពាក្យថា កាយ ................................................. ៣៧

-ពិចារណាកាយ ............................................................ ៣៨

-អធិប្បាយបទ សតិមា អាតាបី សម្បជានោ ............................ ៤២

-អធិប្បាយបទ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ..................... ៤៣

-អធិប្បាយបទ អនុបស្សី ................................................. ៤៦

-អធិប្បាយ វេទនានុបស្សនា .............................................. ៤៨

-សមាធិ ៤ ................................................................. ៥១

-ឧបមា ចិត្តដូចជាកូនគោ ........................................ ៥២
-ទ្រង់ប្រៀបភិក្ខុ ដូចជាខ្លាដំបង ........................................ ៥៥
-ចម្រើនអានាបានស្សតិ ........................................ ៥៦
-អរិយសច្ច ៤ ក្នុងអានាបានៈ ........................................ ៦០
-ពិចារណាកាយដោយឥរិយាបថ ៤ ........................................ ៦០
-អរិយសច្ចក្នុងឥរិយាបថ ........................................ ៦៥
-ពិចារណាកាយដោយសម្បជញ្ញៈ ៤ ........................................ ៦៥
-សាត្ថកសម្បជញ្ញៈ ........................................ ៦៦
-សប្បាយសម្បជញ្ញៈ ........................................ ៦៨
-រឿងភិក្ខុកំលោះ ........................................ ៦៩
-គោចរសម្បជញ្ញៈ ........................................ ៧០
-ភិក្ខុនាំទៅ នឹងនាំត្រឡប់ ........................................ ៧០
-ភិក្ខុទាំងនាំទៅ ទាំងនាំត្រឡប់ ........................................ ៧៤
-រឿងមហាបុស្សទេវត្ថេរ ........................................ ៧៥
-រឿងព្រះមហានាគត្ថេរ ........................................ ៧៦
-រឿងភិក្ខុ ៥០ រូប ........................................ ៧៧
-អសម្មោហសម្បជញ្ញៈ ........................................ ៨០
-រឿងព្រះមហាថេរៈ ........................................ ៨៩
-បដិកូល ១០ ........................................ ៩៧
-អរិយសច្ចក្នុងសម្បជញ្ញៈ ........................................ ១០២
-បដិក្កូលមនសិការបព្វៈ ........................................ ១០៣

-ធាតុមនសិការបព្វៈ .............................. ១០០
-នវសីវថិកាបព្វៈ .............................. ១០២
-ព្រៃខ្មោច ៩ .............................. ១០៦
-វេទនានុបស្សនា .............................. ១០៨
-រឿងព្រះថេរៈមួយរូប .............................. ១១០
-រូបកម្មដ្ឋាន អរូបកម្មដ្ឋាន .............................. ១១១
-វេទនា គឺ អរូបកម្មដ្ឋាន .............................. ១១៤
-សុខវេទនាប្រែប្រួល .............................. ១១៦
-អរិយសច្ចក្នុងវេទនា .............................. ១១៩
-អធិប្បាយចិត្តានុបស្សនា .............................. ១១៩
-អធិប្បាយធម្មានុបស្សនា .............................. ១២២
-នីវរណបព្វៈ .............................. ១២៣
-អធិប្បាយអសុភនិមិត្ត .............................. ១២៤
-លះកាមច្ឆន្ទៈដោយធម៌ ៦ ប្រការ .............................. ១២៤
-អធិប្បាយបដិឃនិមិត្ត .............................. ១២៦
-លះព្យាបាទដោយធម៌ ៦ ប្រការ .............................. ១២៧
-អធិប្បាយ អរតិជាដើម .............................. ១២៨
-អធិប្បាយអារព្ភធាតុជាដើម .............................. ១២៩
-លះថីនមិទ្ធៈដោយធម៌ ៦ ប្រការ .............................. ១៣០
-អធិប្បាយឧទ្ធច្ចកុក្កុច្ចៈ .............................. ១៣១
-លះឧទ្ធច្ចកុក្កុច្ចៈដោយធម៌ ៦ ប្រការ .............................. ១៣២
-អធិប្បាយវិចិកិច្ឆា .............................. ១៣៣
-អរិយសច្ចក្នុងនីវរណៈ .............................. ១៣៦
-ខន្ធបព្វៈ .............................. ១៣៦
-អរិយសច្ចក្នុងបញ្ចក្ខន្ធ .............................. ១៣៧

**ឈ្មោះធម៌** **លេខទំព័រ**


-អាយតនបព្វៈ .......................................... ១៣៧
-ការកើតឡើងនៃសំយោជនៈ .................................. ១៣៨
-ពោជ្ឈង្គបព្វៈ ......................................... ១៤១
-អត្ថនៃពាក្យថា សម្ពោជ្ឈង្គៈ ............................... ១៤២
-ការកើតឡើងនៃសតិសម្ពោជ្ឈង្គៈ ............................. ១៤២
-ការកើតឡើងនៃធម្មវិច្ចយសម្ពោជ្ឈង្គៈ ........................ ១៤៣
-ការកើតឡើងនៃវិរិយសម្ពោជ្ឈង្គៈ ............................ ១៤៨
-រឿងព្រះមហាមិត្តត្ថេរៈ .................................... ១៥០
-ការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ ............................. ១៥៤
-ការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គៈ .......................... ១៥៦
-ការកើតឡើងនៃសមាធិសម្ពោជ្ឈង្គៈ ........................... ១៥៨
-ការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ .......................... ១៦០
-អរិយសច្ចក្នុងពោជ្ឈង្គៈ .................................. ១៦៣
-សច្ចបព្វៈ ............................................ ១៦៤
-អរិយសច្ច ក្នុងអរិយសច្ច ................................ ១៦៥
-អានិសង្សនៃការចម្រើនសតិប្បដ្ឋាន ......................... ១៦៧

## អវសានកថា

ព្រះអានន្ទទូន្មានថា ÷

សញ្ញាយ  វិបរិយេសា  ចិត្តន្តេ  បរិឌយ្ហតំ
និមិត្តំ  បរិវជ្ជេហិ  សុភំ  រាគូបសញ្ហិតំ
សង្ខារេ បរតោ បស្ស  ទុក្ខតោ មា ច អត្តតោ
និព្វាបេហិ  មហារាគំ  មាឌយ្ហិត្ថោ  បុនប្បុនំ
អសុភាយ ចិត្តំ ភាវេហិ  ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ  និព្វិទាពហុលោ ភវ
អនិមិត្តញ្ច  ភាវេហិ  មានានុសយមុជ្ជហ
តតោ មានាភិសមយា  ឧបសន្តោ ចរិស្សសិ

ចិត្តរបស់លោក ក្តៅក្រហាយព្រោះវិបល្លាសនៃសញ្ញា ចូរលោកលះបង់នូវនិមិត្តថា ល្អ ដែលអាស្រ័យនូវរាគៈ ចូរលោកពិចារណានូវសង្ខារថា ជារបស់អ្នកដទៃ គឺថា ជារបស់មិនទៀង ជាទុក្ខ កុំពិចារណាថា ជារបស់ខ្លួនឡើយ ចូរលោករំលត់នូវរាគៈធំចេញ កុំក្តៅក្រហាយញយ ៗ ឡើយ ចូរចម្រើនចិត្ត ដើម្បីអសុភចិត្តនោះ ក៏មានអារម្មណ៍តែមួយ តាំងនៅខ្ជាប់ខ្ជួនដោយប្រពៃ សតិរបស់លោក ចូរតាំងនៅក្នុងកាយ ចូរលោកធ្វើខ្លួនឱ្យជាបុគ្គលមានសេចក្តីនឿយណាយច្រើន ចូរចម្រើននូវវិបស្សនា ដែលរកនិមិត្តគ្មាន ចូរលះបង់នូវអនុស័យ គឺមានះ លោកនឹងបានជាបុគ្គលមានចិត្តស្ងប់រម្ងាប់ ព្រោះបានត្រាស់ដឹងដោយការឃើញ នឹងលះបង់នូវមានះ ក្នុងកាលជាខាងក្រោយ មិនខានឡើយ ។

# ព្រះសុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក

# អដ្ឋកថា បបញ្ចសូទនី

# មូលបរិយាយសូត្រ ទី ១

••••••••

*ឯវម្មេ សុតំ ។ បេ ។ សព្វធម្មបរិយាយំ*

**បទនមស្ការព្រះរតនត្រ័យ**

ខ្ញុំម្ចាស់សូមវន្ទាព្រះសុគតជាម្ចាស់អ្នកមានសេចក្តីងងឹត គឺ មោហៈដែលកម្ចាត់បង់ហើយដោយពន្លឺ គឺ បញ្ញា រលាស់ផុតហើយចាកគតិ ( ទាំងពួង ) មានព្រះហឫទ័យត្រជាក់ដោយព្រះករុណា ជាគ្រូរបស់សត្វលោក ទាំងមនុស្ស និងទេវតា ។

សូម្បីព្រះពុទ្ធអង្គ ទ្រង់ចូលដល់នូវព្រះធម៌ដែលប្រាសចាកមន្ទិលណា ទើបទ្រង់ធ្វើឱ្យកើត និង ធ្វើឱ្យជាក់ច្បាស់ដល់ភាពជាព្រះពុទ្ធ ខ្ញុំម្ចាស់សូមវន្ទាដល់ព្រះសទ្ធម្មដ៏ខ្ពង់ខ្ពស់ ។

ខ្ញុំម្ចាស់សូមវន្ទាព្រះអរិយសង្ឃ គឺ ជំនុំនៃព្រះអរិយបុគ្គលទាំង ៨ អ្នកជាបុត្តកើតពីព្រះឱរៈនៃព្រះសុគត អ្នកញាំញីមារ និង សេនាមារចេញបាន ។

បុណ្យដែលសម្រេចដោយការវន្ទាព្រះរតនត្រ័យ របស់ខ្ញុំម្ចាស់អ្នកមានចិត្តជ្រះថ្លា ដូច្នេះណា ដោយអានុភាពនៃបុណ្យនោះ សូមឱ្យអន្តរាយទាំងពួងវិនាសទៅដោយមិនមានសេសសល់ អដ្ឋកថាឯណាដែលព្រះអរហន្តឆ្លាតឈ្លាស ៥០០ អង្គ បានសង្គាយនា ( ចងក្រង ) ទុកតាំងអំពីខាងដើម និង ដែលព្រះសង្គីតិកាចារ្យទាំងទឡាយបានសង្គាយនាបំពេញបន្ថែមតាមក្រោយក្តី ដើម្បីប្រកាស ( អធិប្បាយ ) នូវសេចក្តីនៃព្រះសូត្រមជ្ឈិមនិកាយ ក្នុងគម្ពីរនេះដែលកំណត់ទុកដោយព្រះសូត្រខ្នាតកណ្តាល( មិនវែងមិនខ្លី) ដែលព្រះសម្ពុទ្ធ និង ព្រះសាវកសំវណ្ណនា ( ពណ៌នា ) ទុក ញ៉ាំញីនូវលទ្ធិដទៃ ក្រោយមកព្រះមហិន្ទមហាថេរៈបាននាំមកកាន់កោះសីហទឡ្ហៈ ស្ថាបនា ( ចារឹក ) ទុកជាភាសាសីហទឡ្ហៈ ដើម្បីប្រយោជន៍ដល់អ្នកកោះ ខ្ញុំព្រះអង្គនឹងនាំចេញពីភាសាសីហទឡ្ហៈ ទេឡើងកាន់ភាសាជាទីមនោរម្យ សមគួរ ដើម្បីជាបែបផែនប្រាសចាកទោស ( គឺ ភាសាមគធៈ ) ម្យ៉ាងវិញទៀត ប្រកាសសេចក្តីមិនឱ្យជំទាស់មតិរបស់ព្រះគណៈមហាវិហារដែលជាប្រទីបនៃថេរវង្ស មានការវិនិច្ឆ័យល្អិតល្អន់ដែលវៀរសេចក្តីច្រំដែលចេញខ្លះ ដើម្បីការពេញចិត្តនៃសាធុជន និង ដើម្បីការ

តាំងនៅបានយូរនៃព្រះសទ្ធម្ម ។

ចំណែកធម៌ គឺ សីលកថា ធុតធម្ម ( រឿងធុតង្គ ) កម្មដ្ឋានគ្រប់ យ៉ាង ឈានសមាបត្តិយ៉ាងពិស្តារព្រមទាំងចរិយាវិធាន ( ចរិតរបស់បុគ្គល ) អភិញ្ញាទាំងពួង ការវិនិច្ឆ័យ បញ្ញាទាំងអស់ ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ៍ អរិយសច្ចៈ ៤ ការសម្តែងបច្ចយាការ ( គឺ បដិច្ចសមុប្បាទ ) មានន័យបរិ_ សុទ្ធ ល្អិតល្អន់ ល្មមគួរនឹងយល់បាន និង វិបស្សនា ភាវនាទាំងពួង ខ្ញុំម្ចាស់ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គយ៉ាងហ្មត់ចត់ល្អ ដោយហេតុណា ហេតុនោះ ខ្ញុំម្ចាស់មិនលើកយកមកសម្តែងក្នុងទីនេះ នោះទេ ។

វិសុទ្ធិមគ្គនោះ ខ្ញុំម្ចាស់រចនាដោយគិតថា វិសុទ្ធិមគ្គនឹងត្រូវនៅកណ្តាល ក្នុងនិកាយទាំង ៤ ហើយប្រកាសសេចក្តីតាមដែលលោកភាសិតទុកក្នុងនិកាយ ទាំង ៤ នោះបាន ដូច្នោះ ហេតុនេះ អ្នកទាំងទឡាយចូរកាន់យកវិសុទ្ធិមគ្គនោះ និង អដ្ឋកថានេះ ដើម្បីជាការជ្រាបនូវសេចក្តីនៃមជ្ឈិមសង្គីតិ ( គឺ មជ្ឈិមនិ_ កាយទាំង ៣ បណ្ណាសកៈ ) ចុះ ។

សីលកថា ធុតង្គកថា កម្មដ្ឋាន សេចក្តីពិស្តាររបស់ឈាន និង ស_ មាបត្តិដែលប្រកបដោយវិធីការស្របតាមចរិត ៦ អភិញ្ញាទាំងពួង ពាក្យវិនិ_ ច្ឆ័យដែលប្រមូលទុកដោយបញ្ញា ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ៍ អរិយសច្ចៈ

៤ បច្ចយាការ ទេសនាដែលមិនក្រៅពីព្រះបាលីដែលមានឈ្មោះថា មជ្ឈិម-សង្គីតិ ក្នុងពាក្យថា **មជ្ឈិមសង្គីតិយា** នោះ សម្តែងដោយបណ្ណាសកៈបាន ដល់ការរួបរួមបណ្ណាសកៈ ៣ ពួក គឺ មូលបណ្ណាសកៈ មជ្ឈិមបណ្ណាសកៈ ឧបរិបណ្ណាសកៈ ។

សម្តែងដោយវគ្គ គឺ ការរួបរួមជាវគ្គបាន ១៥ វគ្គ ព្រោះបែងមួយបណ្ណាសកៈចេញជា ៥ សម្តែងដោយសូត្រមាន ១៥២ សូត្រ សម្តែងបទមាន ៨០.៥២៣ បទ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទើបពោលទុកថា លោកពោលកំណត់បទទុក ៨០.៥២៣ បទ យ៉ាងនេះ ។

តែសម្តែងដោយអក្សរមាន ៧៤០.០៥៣ អក្សរ សម្តែងភាណវារៈមាន ៨០ ភាណវារៈ និង កន្លះភាណវារៈមាន ២៣ បទ សម្តែងដោយអនុសន្ធិមាន
៣ អនុសន្ធិ គឺ បុច្ឆានុសន្ធិ អជ្ឈាសយានុសន្ធិ និង យថានុសន្ធិ តែពេលសម្តែងដោយពិស្តារក្នុងរឿងនេះមាន ៣.៩០០ អនុសន្ធិ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទាំងទឡាយទើបពោលទុកថា លោកបានប្រកាសន័យអនុសន្ធិនៃមជ្ឈិមនិកាយបណ្ណាសកទាំងទឡាយនោះទុក ៣.៩០០ អនុសន្ធិ ។

ក្នុងបណ្ណាសកទាំងទឡាយនេះ មូលបណ្ណាសកៈ ជាបណ្ណាសកៈដើម ក្នុងវគ្គទាំងទឡាយ មូលបរិយាយវគ្គ ជាវគ្គដើម ក្នុងសូត្រទាំងទឡាយ មូលបរិ-

# ៥ អដ្ឋកថា មូលបរិយាយសូត្រ ទី១

យាយសូត្រ ជាសូត្រដើម ។

## អធិប្បាយ និទានវចន

១ ពាក្យនិទានថា **ឯវម្មេ សុតំ** ព្រះអានន្ទពោលទុកក្នុងកាលបឋម_មហាសង្គីតិ ជាខាងដើមរបស់មូលបរិយាយសូត្រនោះ បឋមមហាសង្គីតិនេះ លោកពោលទុកដោយពិស្តារក្នុងចំណែកខាងដើមនៃអដ្ឋកថា ទីឃនិកាយឈ្មោះ សុមង្គលវិលាសិនី ។ ព្រោះដូច្នោះ បឋមមហាសង្គីតិនោះ បណ្ឌិតគប្បីជ្រាប ដោយន័យដែលបានពោលទុកដោយពិស្តារហើយ ក្នុងអដ្ឋកថាទីឃនិកាយនោះ ចុះ ។

## អធិប្បាយ ឯវម្មេ សុតំ

ពាក្យថា **ឯវម្មេ សុតំ** ជាដើមនេះ ជាពាក្យផ្ដើម ។ បណ្ដាបទទាំងឡាយនោះ បទថា **ឯវំ** ជានិបាត **មេ** ជាដើមជាបទ **នាម** ។ ក្នុងពាក្យថា **ឧក្កដ្ឋាយំ វិហរតិ** បណ្ឌិតគួរជ្រាបការចែកបទដោយន័យនេះថា **វិ** ជាបទឧបសគ្គ ។ បទថា **ហរតិ** ជាអាខ្យាត ប៉ុន្តែដោយសេចក្ដី **ឯវំ** ស័ព្ទមានសេចក្ដីចែកចេញបានជាច្រើនយ៉ាងមានជាអាទិថា ឧបមា ឧបទេស សម្បហង្សនៈ គរហណៈ វចនសម្បដិគ្គហៈ និទស្សនៈ អវធារណៈ ។

ពិតណាស់ **ឯវំ** សព្ទនេះ មានអត្ថថា **ឧបមា** ក្នុងប្រយោគមានជា

អាទិយ៉ាងនេះថា កុសលជាច្រើន សត្វដែលកើតទេឡើងហើយគួរធ្វើយ៉ាងនោះ ។

ក្នុងអត្ថថា **ឧបទេស** ក្នុងប្រយោគជាដើមថា លោកគួរឈានទៅយ៉ាងនេះ គួរត្រទឡប់មកយ៉ាងនេះ ។

ក្នុងអត្ថថា **សម្បហង្សន** ក្នុងប្រយោគជាដើមថា ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកយ៉ាងនេះ ។

មកក្នុងអត្ថថា **គរហណ** ក្នុងប្រយោគជាដើមថា បុគ្គលអន់ថយនេះពោលសរសើរគុណព្រះសមណៈក្បាលត្រងោលនេះ យ៉ាងនេះគ្រប់ ៗ ទីកន្លែងយ៉ាងនេះ ។

មកក្នុងអត្ថថា **វចនសម្បដិគ្គហ** ក្នុងប្រយោគជាដើមថា ភិក្ខុទាំងទឡាយនោះទទួលពាក្យព្រះមានព្រះភាគយ៉ាងនេះថា ព្រះករុណា ព្រះអង្គដូច្នេះ ។

មកក្នុងអត្ថថា **អាការ** ក្នុងប្រយោគជាដើមថា លោកដ៏ចម្រើនជាអ្នកជ្រាបច្បាស់ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ដោយអាការយ៉ាងនោះ ។

មកក្នុងអត្ថថា **និទស្សន** ក្នុងប្រយោគជាដើមថា ម្នាលមាណព អ្នកចូរមកចូរចូលទៅរកព្រះអានន្ទលោកជាសមណៈ ពេលចូលទៅរកហើយ

# ៧ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ចូរសួរការមិនមានជំងឺ ការមានរោគតិច ការផ្លាស់ប្តូរឥរិយាបថ កម្លាំង និង ការនៅជាសុខចំពោះព្រះអានន្ទដែលជាសមណៈតាមពាក្យរបស់យើង និង ចូរពោលយ៉ាងនេះថា សុភមាណពតោទេយ្យបុត្រ រមែងសួរដល់ការមិនមាន ជំងឺ ។ ល ។ ការនៅជាសុខរបស់ព្រះអានន្ទដ៏ចម្រើន ដូច្នេះ ។ ជាការល្អណាស់ដែលព្រះអានន្ទដ៏ចម្រើន អាស្រ័យសេចក្តីអនុគ្រោះចូលទៅរកសុភមា-ណពតោទេយ្យបុត្រ ដល់កន្លែងយ៉ាងនេះ ។

មកក្នុងអត្ថថា **អវធារណ** ក្នុងប្រយោគជាដើមថា ម្នាលកាលាម ទាំងទឡាយ ពួកអ្នកសម្គាល់សេចក្តីនោះយ៉ាងណា ?

ធម៌ទាំងទឡាយនេះជា កុសល ឬអកុសល ?

ជាអកុសល ព្រះអង្គ

មានទោស ឬ មិនមានទោស ?

មានទោស ព្រះអង្គ

បណ្ឌិតតិះដៀល ឬ មិនតិះដៀល ?

បណ្ឌិតតិះដៀល ព្រះអង្គ

ធម៌ទាំងទឡាយដែលខ្លួនសមាទានឱ្យបរិបូណ៌ រមែងប្រព្រឹត្តទៅដើម្បីវត្ថុមិនជាប្រយោជន៍ និង ជាទុក្ខ ឬ ក៏យ៉ាងណាទៅវិញនៅក្នុងសេចក្តីនេះ?

រមែងប្រព្រឹត្តទៅដើម្បីវត្ថុមិនជាប្រយោជន៍ និង ជាទុក្ខ រមែងមានដល់ខ្ញុំព្រះអង្គទាំងទឡាយក្នុងសេចក្តីនេះ ។

**ឯវំ** ស័ព្ទក្នុងទីនេះបណ្ឌិតគួរជ្រាបថា ( ប្រើ ) ក្នុងអត្ថថា **អាការ និទស្សន អវធារណ** ក្នុង ៣ យ៉ាងនោះ ព្រះអានន្ទសម្តែងសេចក្តីថា **ឯវំ** ស័ព្ទមានអាការដោយអត្ថថា អ្នកណា ៗ អាចនឹងជ្រាបព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ដែលល្អិតល្អន់ដោយន័យផ្សេង ៗ កើតទេឡើងដោយអធ្យាស្រ័យដ៏ធំទូលាយ បរិបូណ៌ដោយអត្ថ និង ព្យញ្ជនៈ មានបដិហារ្យជ្រាលជ្រៅដោយធម៌ ដោយអត្ថ និង ដោយបដិវេធ មកកាន់សោតបសាទរបស់សត្វទាំងពួងដោយសមគួរដល់ភាសារបស់ខ្លួនដោយប្រការទាំងពួង ព្រមទាំងឱ្យកើតនូវសេចក្តីប្រាថ្នាក្នុងការស្តាប់ដោយយកចិត្តទុកដាក់ ខ្ញុំព្រះអង្គបានស្តាប់មកហើយយ៉ាងនេះ គឺ ខ្ញុំព្រះអង្គបានស្តាប់មកហើយដោយអាការយ៉ាងនេះ ។ សម្តែងថា ព្រះអានន្ទត្ថេរកាលនឹងសម្តែងខ្លួន ដោយអត្ថថា ខ្ញុំព្រះករុណាមិនមែនជាសយម្ភូ សូត្រនេះខ្ញុំព្រះករុណាមិនបានធ្វើឱ្យជាក់ច្បាស់ ទើបសម្តែងសូត្រទាំងអស់ដែលនឹងត្រូវពោលក្នុងទីនេះថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ គឺថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ព្រះអានន្ទត្ថេរកាលនឹងសម្តែងនូវកម្លាំង គឺ ការទ្រទ្រង់ចាំទុករបស់ខ្លួនដែលសមគួរដល់ភាវៈដែលព្រះមានព្រះ-

# ៩ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ភាគជាម្ចាស់ទ្រង់សរសើរយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡ្បាយ បណ្តាភិក្ខុជាសាវ័ក របស់យើងដែលជាពហុស្សូត គឺ អានន្ទ បណ្តាឧបដ្ឋាកដែល មានគតិ មាន សតិ មានធិតិ គឺ អានន្ទ នឹងដែលព្រះធម្មសេនាបតីសារីបុត្តសរសើរយ៉ាង នេះថា ព្រះអានន្ទឆ្លាតក្នុងអត្ថ ក្នុងធម៌ ក្នុងព្យញ្ជនៈ ក្នុងភាសា និង ក្នុងអក្សរ ខាងដើម និង ខាងចុង ញ៉ាំងសត្វទាំងទឡ្បាយឱ្យប្រាថ្នាដើម្បីស្តាប់ ដោយអត្ថ ថា **អវធារណ** ខ្ញុំបានស្តាប់មកប៉ុណ្ណេះ និង សូត្រនោះឯង មិនលើសមិនខ្វះ ដោយអត្ថ ឬ ដោយព្យញ្ជនៈ គួរឃើញថា យ៉ាងនេះប៉ុណ្ណោះ មិនគួរឃើញថា ជាយ៉ាងដទៃ ។

**មេ** ស័ព្ទ ប្រាកដក្នុងអត្ថថា ៣ យ៉ាង ដូច្នោះ **មេ** ស័ព្ទនោះមាន សេចក្តីថា **មយា** ( យើង ) ក្នុងប្រយោគជាដើមថា ភោជនដែលបានមក ដោយការប្រគុំ យើងមិនគួរបរិភោគ ។

មានសេចក្តីថា **មយ្ហំ** ( ដល់យើង ) ក្នុងប្រយោគជាដើមថា បពិត្រ ព្រះអង្គដ៏ចម្រើន សូមប្រទានឱកាស សូមព្រះអង្គទ្រង់សំដែងធម៌ដល់ខ្ញុំព្រះ-អង្គដោយសង្ខេបចុះ ។

មានសេចក្តីថា **មម** ( របស់យើង ) ក្នុងប្រយោគជាដើមថា ភិក្ខុ ទាំងទឡ្បាយ អ្នកទាំងទឡ្បាយចូរជាធម្មទាយាទរបស់យើងចុះ ។

តែក្នុងទីនេះ **មេ** ស័ព្ទប្រើក្នុងអត្ថ ២ យ៉ាង ដែលខ្ញុំព្រះអង្គបានស្តាប់ មក និងថា **សុត** របស់យើង ។

**សុត** ស័ព្ទ ក្នុងពាក្យថា **សុតំ** នេះ មានឧបសគ្គ និង មិនមាន ឧបសគ្គ មានសេចក្តីច្រើនយ៉ាងជាដើមថា ÷

**គមន** ( ការទៅ ) **វិស្សុត** ( ប្រាកដ ) **កិលិន្ន** ( ជ្រួតជ្រាប ) **ឧបចិត** ( សន្សំ ) **អនុយោគ** ( ប្រកបរឿយ ៗ ) **សោតវិញ្ញេយ្យ** ( ដឹងតាមត្រចៀក ) **សោតទ្វារានុសារវិញ្ញាណ** ( ដឹងតាមក្រសែ គឺ ផ្លូវត្រចៀក ) ។

ពិតហើយ **សុត** ស័ព្ទនោះ មានសេចក្តីថា « ទៅ » ក្នុងប្រយោគជា ដើមថា ទៅហើយដោយសេនា ។

មានធម៌ដែលខ្លួនស្តាប់យ៉ាងច្បាស់ ក្នុងប្រយោគជាដើមថា អ្នកស្តាប់ធម៌ហើយឃើញ ( ធម៌ ) ។

មានសេចក្តីថា ទទឹកសើម របស់បុគ្គលអ្នកសើមជ្រួតជ្រាប ក្នុងប្រយោគជាដើមថា សើមជោករបស់អ្នកសើមជោក ។

មានសេចក្តីថា សន្សំ ក្នុងប្រយោគជាដើមថា បុណ្យមានមិនតិចដែលលោកទាំងទឡាយសន្សំហើយ ។

## ១១ អដ្ឋកថា មូលបរិយាយសូត្រ ទី១

មានសេចក្ដីថា ប្រកបរឿយ ៗ ក្នុងឈានរឿយ ៗ ក្នុងប្រយោគជា ដើមថា អ្នកប្រាជ្ញទាំងទឡ្បាយណា ជាអ្នកខ្វល់ខ្វាយក្នុងឈាន ។

មានសេចក្ដីថា សំទេឡងដែលគួរដឹងតាមផ្លូវសោតបសាទ ក្នុងប្រយោគជាដើមថា ឃើញហើយ ស្ដាប់ហើយ ជ្រាបហើយ ។

មានន័យថា ដឹងសេចក្ដីតាមសោតទ្វារ ក្នុងប្រយោគជាដើមថា ទ្រទ្រង់ទុកនូវសុតៈ តែក្នុងទីនេះ **សុត** ស័ព្ទនោះ សំដៅយកសេចក្ដីថា ទ្រទ្រង់ចាំ ឬការចាំ តាមក្រសែនៃសោតទ្វារ ពិតហើយ ខណៈ **មេ** ស័ព្ទនេះ មានសេចក្ដីស្មើគ្នានឹង **មយា** រមែងប្រាកដសេចក្ដីថា ខ្ញុំម្ចាស់បានស្ដាប់មក គឺចាំតាមក្រសែនៃសោតទ្វារយ៉ាងនេះ មានសេចក្ដីស្មើគ្នានឹង **មម** រមែងប្រកបសេចក្ដីថា ការស្ដាប់របស់ខ្ញុំម្ចាស់ គឺ ការចាំតាមក្រសែនៃសោតទ្វាររបស់ខ្ញុំម្ចាស់យ៉ាងនេះ ។

ក្នុងបទទាំង ៣ នោះ ដូចពោលមកនេះ ពាក្យថា **ឯវំ** ជាការសម្ដែងកិច្ចនៃវិញ្ញាណ មានសោតវិញ្ញាណជាដើម ។ ពាក្យថា **មេ** ជាការសម្ដែងដល់បុគ្គលអ្នកមានការបរិបូរណ៍ដោយវិញ្ញាណ ដូចដែលបានពោលមកហើយ ពាក្យថា **សុតំ** ជាការសម្ដែងដល់ការកាន់យកដែលមិនខុស មិនតិច មិនច្រើន ព្រោះហាមការមិនស្ដាប់ ។

ម្យ៉ាងទៀត ពាក្យថា **ឯវំ** ជាការប្រកាសការប្រព្រឹត្តិទៅក្នុងអារម្មណ៍នៃវិញ្ញាណវិថី ដែលប្រព្រឹត្តទៅតាមក្រសែនៃសោតទ្វារនោះ ដោយប្រការ ផ្សេង ៗ ។

ពាក្យថា **មេ** ជាការប្រកាសខ្លួន ។

ពាក្យថា **សុតំ** ជាការប្រកាសធម៌ ។

ពិតណាស់ ក្នុងពាក្យថា **ឯវម្មេសុតំ** នេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ខ្ញុំម្ចាស់មិនធ្វើកិច្ចដទៃនៃវិញ្ញាណវិថីដែលប្រព្រឹត្តទៅហើយក្នុងអារម្មណ៍ដោយប្រការផ្សេង ៗ តែខ្ញុំម្ចាស់ធ្វើកិច្ចនេះ ធម៌នេះខ្ញុំម្ចាស់ស្តាប់ហើយ ។

ពាក្យថា **ឯវំ** ជាការប្រកាសពាក្យដែលគួរអធិប្បាយ ពាក្យថា **មេ** ជាការប្រកាសបុគ្គល ពាក្យថា **សុតំ** ជាការប្រកាសកិច្ចនៃបុគ្គល ។ មានពាក្យអធិប្បាយដូច្នេះថា ព្រះសូត្រដែលខ្ញុំម្ចាស់នឹងសម្តែង ខ្ញុំម្ចាស់បានសម្តែងហើយ យ៉ាងនេះ ។ ម្យ៉ាងទៀត ពាក្យថា **ឯវំ** ជាការអធិប្បាយអាការផ្សេង ៗ របស់សន្តានចិត្តដែលមានការកាន់យកអត្ថ និង ព្យញ្ជនៈផ្សេង ៗ គ្នា ។

ពិតហើយ ស័ព្ទថា **ឯវំ** នេះ ជាការបញ្ញត្តិអាការ ស័ព្ទថា **មេ** ជាការសម្តែងកត្តា ( អ្នកធ្វើ ) ស័ព្ទថា **សុតំ** ជាការសម្តែងវិស័យ ដោយការ

# ១៣ អដ្ឋកថា មូលបរិយាយសូត្រ ទី១

អធិប្បាយត្រឹមប៉ុណ្ណេះ រមែងជាអ្នកធ្វើការសន្និដ្ឋានបានថា ដោយសន្តានចិត្តដែលប្រព្រឹត្តទៅដោយអាការផ្សេងគ្នា ព្រះថេរៈប្រកបដោយសន្តានចិត្តនោះទើបជាកត្តា និង ទទួលអារម្មណ៍បាន ។

ន័យម្យ៉ាងទៀតស័ព្ទថា **ឯវំ** ជាការសម្ដែងកិច្ចនៃបុគ្គល ស័ព្ទថា **សុតំ** ជាការសម្ដែងកិច្ចនៃវិញ្ញាណ ស័ព្ទថា **មេ** ជាការសម្ដែងដល់បុគ្គលដែលប្រកបដោយកិច្ចទាំង ២ ។

ក្នុងពាក្យថា **ឯវម្មេ សុតំ** នេះ មានសេចក្ដីសង្ខេបថា ខ្ញុំម្ចាស់បានស្ដាប់មកដោយវោហារនៃចំណែកវិញ្ញាណ ដោយបុគ្គលដែលបរិបូរណ៍ដោយចំណែកកិច្ច និងវិញ្ញាណកិច្ច ។

បណ្ដាបទទាំងទឡាយនោះ បទថា **ឯវំ** ជាអវិជ្ជមានប្បញ្ញត្តិដោយអត្ថថាជាក់ស្ដែង និង បទថា **មេ** ជាអវិជ្ជមានប្បញ្ញត្តិ ដោយបរមត្ថ ក្នុងសេចក្ដីនេះនៅមាន ខ ពិសេសទៀត គឺ សេចក្ដីដែលព្រះថេរៈបានអធិប្បាយថា **ឯវំ** ឬ **មេ** មានដោយបរមត្ថ ។

បទថា **សុតំ** ជាវិជ្ជមានប្បញ្ញត្តិ ។

អធិប្បាយក្នុងបទថា **សុតំ** នេះ អារម្មណ៍តាមសោតៈនេះ មានដោយបរមត្ថពិត ។

បទថា **ឯវំ** និង **មេ** ចាត់ជាឧបាទាយបញ្ញត្តិ ព្រោះព្រះថេរៈពោលសំដៅយកធម៌ដែលមកប៉ះខ្ទប់សោតៈ និង ខន្ធដែលរាប់នៅក្នុងសន្តានរបស់ខ្លួននោះ ។

បទថា **សុតំ** ជាឧបនិធាបញ្ញត្តិ ព្រោះព្រះថេរៈពោលដល់វត្ថុដែលឃើញហើយ ។

ម្យ៉ាងទៀតក្នុងសេចក្តីនេះ ព្រះថេរៈសម្តែងការមិនល្ងង់ខ្លៅដោយពាក្យ ថា **ឯវំ** អធិប្បាយថា អ្នកល្ងង់ខ្លៅ រមែងមិនអាចសម្រេចបានដោយប្រការ ផ្សេងៗ ។

ដោយពាក្យថា **សុតំ** ព្រះថេរៈសម្តែងការមិនភ្លេចភ្លាំងព្រះពុទ្ធវចនៈដែលបានស្តាប់មកហើយ អធិប្បាយថា **សុត** ជាអ្នកបានភ្លេចភ្លាំងហើយ អ្នកនោះរមែងនឹកមិនឃើញថា យើងបានស្តាប់មកហើយដោយកាលដទៃ ការសម្រេចនៃបញ្ញារបស់ព្រះថេរៈនោះ រមែងមានព្រោះការមិនល្ងង់ខ្លៅ ចំណែកការសម្រេចនៃសតិ រមែងមានបានព្រោះការមិនវង្វេង ។

បណ្តា ២ យ៉ាងនោះ សមត្ថភាពក្នុងការទ្រទ្រង់ចាំព្យញ្ជនៈ មានបានដោយសតិ មានបញ្ញាជាតួនាំ សមត្ថភាពក្នុងការយល់អត្ថដោយបញ្ញា មានសតិជាតួនាំ សេចក្តីសម្រេចនៃបុគ្គលជាឃ្លាំធម៌ ដោយអំណាចក្នុងការរក្សា

# ១៥ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ឃ្លាំងធម៌ដែលដល់ព្រមដោយអត្ថ និង ព្យញ្ជនៈ មានបានព្រោះប្រកបដោយសមត្ថភាពទាំងពីរយ៉ាងនោះ ។

ន័យម្យ៉ាងទៀត ដោយពាក្យថា **ឯវំ** ព្រះថេរៈសម្ដែងការធ្វើទុកក្នុងចិត្តដោយល្អ រមែងមិនមានការឃើញច្បាស់ដោយប្រការផ្សេង ៗ ដោយពាក្យថា **សុតំ** លោកសម្ដែងសេចក្ដីមិនរាយមាយ ព្រោះបុគ្គលមានចិត្តរាយមាយមិនស្ដាប់ សេចក្ដីពិត បុគ្គលដែលមានចិត្តរាយមាយ សូម្បីត្រូវគេប្រាប់ដោយគុណវិសេសគ្រប់យ៉ាង ក៏នៅពោលថា ខ្ញុំម្ចាស់ស្ដាប់មិនច្បាស់លាស់ សូមលោកពោលទៀត ក៏ក្នុងសេចក្ដីនេះ ព្រោះការស្ដាប់ដោយការធ្វើទុកក្នុងចិត្តដោយល្អ បុគ្គលរមែងតាំងខ្លួនដោយល្អ និង ភាពជាអ្នកធ្វើបុណ្យទុកហើយក្នុងកាលមុនឱ្យសម្រេចបាន ចំណែកបុគ្គលមិនបានតាំងខ្លួនទុកដោយល្អ និងមិនបានធ្វើបុណ្យទុកក្នុងកាលមុន មិនមានការធ្វើទុកក្នុងចិត្តដោយល្អនោះ ។

ព្រោះសេចក្ដីមិនរាយមាយ បុគ្គលទើបញ៉ាំងការស្ដាប់ធម៌ដោយល្អបាន និងការចូលទៅសេពគប់សប្បុរសឱ្យសម្រេច ។ ពិតណាស់ បុគ្គលដែលមានចិត្តរាយមាយមិនអាចនឹងស្ដាប់ធម៌បាន ហើយការស្ដាប់ធម៌រមែងមិនកើតមានដល់បុគ្គលដែលមិនចូលទៅសេពគប់សប្បុរស ។

ន័យម្យ៉ាងទៀត ព្រោះហេតុដែលលោកពោលទុកថា បទថា **ឯវំ** ជា

បទសម្តែងអាការផ្សេង ៗ របស់សន្ទានចិត្តដែលមានការទទួលយក អត្ថ និង ព្យញ្ជនៈ ដែលប្រព្រឹត្តទៅដោយប្រការផ្សេង ៗ គ្នា និង អាការដែលល្អយ៉ាងនេះ រមែងមិនមានដល់បុគ្គលដែលមិនបានតម្កល់ខ្លួនទុកដោយល្អ ឬ មិនបានធ្វើបុណ្យទុកក្នុងកាលមុន ដូច្នោះ លោកសម្តែងការដល់ព្រមនៃចក្រទាំងពីរខាងចុងរបស់ខ្លួនដោយការចម្រើននេះ ដោយបទថា **ឯវំ** លោកសម្តែងការដល់ព្រមនៃចក្រទាំងពីរ ខាងដើមរបស់ខ្លួនដោយបទថា **សុតំ** ។ ពិតហើយការស្តាប់ធម៌ រមែងមិនកើតមានដល់អ្នកនៅក្នុងប្រទេសដែលមិនសមគួរ ឬ អ្នកវៀរចាកការសេពគប់សប្បុរស ការបរិសុទ្ធិនៃអាសវក្កិលេសរមែងមិនសម្រេចមានដល់បុគ្គលនោះ ព្រោះការសម្រេចនៃចក្រទាំង ២ ខាងចុង ។

ការបរិសុទ្ធិនៃបយោគសម្បត្តិ រមែងមាន ព្រោះសេចក្តីសម្រេចនៃចក្រ ទាំង ២ ខាងដើម ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត សេចក្តីសម្រេចនៃការឆ្លាតក្នុងអធិគម (បដិវេធ) រមែងមានដល់បុគ្គលនោះ ព្រោះសេចក្តីបរិសុទ្ធិនៃអាសវក្កិលេស សេចក្តីសម្រេចនៃការឆ្លាតក្នុងអធិគម ( បរិយត្តិ ) រមែងមាន ព្រោះសេចក្តីបរិសុទ្ធិនៃបយោគ_សម្បត្តិ ( សេចក្តីព្យាយាម ) ព្រះថេរៈពេលដែលនឹងរៀបរៀង និទាន វចនៈទុកក្នុងឋានៈដែលសមគួរ ពាក្យរបស់លោកជាអ្នកដល់ព្រមដោយអាគម និង

# ១៧ អដ្ឋកថា មូលបរិយាយសូត្រ ទី១

អធិគម ជាអ្នកបរិសុទ្ធចាកអាសវក្កិលេស រមែងគួរដោយបយោគសម្បត្តិ ជាព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចរស្មីពណ៌មាស និង ប្រាក់ ផ្សាយចេញពីព្រះអាទិត្យដែលកំពុងរះ ប្រៀបដូចជាការធ្វើទុកក្នុងចិត្តដោយល្អ ជាតួនាំ ( ការធ្វើ) កុសលកម្ម ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ។

ន័យម្យ៉ាងទៀត ដោយពាក្យនេះថា **ឯវំ** ព្រះថេរៈសម្តែងភាវៈ គឺការដល់ព្រមដោយអត្ថប្បដិសម្ភិទា និង បដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្តែងដល់បដិវេធមានប្រការផ្សេង ៗ ដោយពាក្យថា **សុតំ** នេះ លោកសម្តែងសភាវៈ គឺ ការដល់ព្រមនៃធម្មប្បដិសម្ភិទា និង និរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសម្តែងដល់ការឃើញច្បាស់ប្រភេទនៃធមិ ដែលនឹងត្រូវស្តាប់ម្យ៉ាងទៀត ព្រះថេរៈកាលពោលពាក្យដែលសម្តែងដល់ការធ្វើទុកក្នុងចិត្តដោយល្អថា **ឯវំ** ដូច្នេះ ទើបសម្តែងថា ធមិទាំងនេះដែលខ្ញុំម្ចាស់តាមសម្លឹងដោយចិត្ត ជាក់ច្បាស់ដោយល្អដោយទិដ្ឋិហើយ កាលនឹងពោលពាក្យដែលសម្តែងដល់ការតាមប្រកបការស្តាប់នេះថា **សុតំ** ដូច្នេះ ទើបសម្តែងថា ធមិជាច្រើនដែលខ្ញុំម្ចាស់ស្តាប់មកហើយ ទ្រទ្រង់ចាំទុកហើយ ទន្ទេញរត់មាត់ហើយ យ៉ាង នេះ ។

ព្រះថេរៈកាលនឹងសម្តែងសេចក្តីបរិបូរណ៍នៃអត្ថ និង ព្យញ្ជនៈ ដោយ

ពាក្យទាំងពីរនោះ ទើបញ៉ាំងសេចក្តីអើពើឱ្យកើតទេឡើងក្នុងការស្តាប់ ពិតហើយ ការមិនស្តាប់ធមិដែលបរិបូណ៌ដោយអត្ថ និង ព្យញ្ជនៈ ដោយអើពើ រមែង ប្រាសចាកប្រយោជន៍យ៉ាងធំ ព្រោះដូច្នោះ គួរធ្វើសេចក្តីអើពើ ហើយស្តាប់ធមិ ដោយគោរពចុះ ។

ក៏ដោយពាក្យទាំងអស់នេះថា **ឯវម្មេ សុតំ** ( ជាការសម្តែងថា ) ព្រះអានន្ទកាលមិនដាក់ធមិដែលព្រះតថាគតសម្តែង ប្រកាសហើយទុកឱ្យនៅ ឆ្ងាយពីខ្លួន ឈ្មោះថា កន្លងភូមិនៃអសប្បុរស ប្តេជ្ញាភាពជាសាវក ឈ្មោះថា ឈានទេឡើងកាន់ភូមិនៃសប្បុរស ។ ម្យ៉ាងទៀត ដោយពាក្យទាំងអស់នេះថា **ឯវម្មេ សុតំ** ជាដើម ក៏ព្រះថេរៈរមែងញ៉ាំងចិត្តឱ្យចេញចាកអសទ្ធម្ម ឱ្យតាំង នៅក្នុងព្រះសទ្ធម្ម ព្រះថេរៈកាលសម្តែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ អង្គនោះ ខ្ញុំម្ចាស់បានស្តាប់មកដោយផ្ទាល់ចំពោះព្រះភក្ត្រ ឈ្មោះថា រមែង សម្តែងខ្លួនដោយអាងព្រះតថាគត ពិតប្រាកដហើយ នៅក្នុងព្រះតម្រាស់របស់ ព្រះជិនស្រី ប្រតិស្ឋាននេតិធមិទុក ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវម្មេ សុតំ** ព្រះថេរៈញ៉ាំងភាពជាអ្នក មិនមានសទ្ធាក្នុងធមិនេះ របស់ទេវតា និង មនុស្សទាំងពួងឱ្យអស់ទៅឱ្យកើតការ ដល់ព្រមនៃសទ្ធាដោយមិនអាងថាសូត្រនោះលោកជាអ្នកឱ្យកើតដោយខ្លួនឯង

និង ប្រកាសការស្តាប់ជាមុនថា សូត្រនេះខ្ញុំម្ចាស់បានទទួលការស្តាប់តមកពីទីចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគអង្គនោះ ជាអ្នកអង់អាចដោយវេសារជ្ជ-ធម៌ ៤ ទ្រទ្រង់ទុកនូវពលញ្ញាណ ១០ ទ្រង់តាំងទុកនៅក្នុងឋានៈជាអ្នកអាចហ៊ាន បន្លឺសីហនាទបាន ប្រសើរជាងសត្វគ្រប់ជំពូក ជាធំដោយព្រះធម៌ជាព្រះធម្មរាជា ជាព្រះធម្មាធិបតី ជាប្រទីបដោយធម៌ ជាទីពឹងដោយធម៌ជាព្រះបាទចក្រពត្តិប្រសើរដោយព្រះសទ្ធម្ម អ្នកត្រាស់ដឹងឯងដោយប្រពៃ មិនគួរធ្វើសេចក្តីសង្ស័យ ឬ សេចក្តីងឿងឆ្ងល់ក្នុងអត្ថ ក្នុងធម៌ ក្នុងបទ ឬ ក្នុងព្យញ្ជនៈក្នុងសូត្រនេះទេឡើយ ព្រោះហេតុនោះ លោកទើបពោលពាក្យនេះទុកថា « ព្រះសាវករបស់ព្រះគោតមពោលយ៉ាងនេះថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ញ៉ាំងអសទ្ធម្មឱ្យវិនាស ញ៉ាំងសទ្ធាក្នុងសាសនាឱ្យចម្រើន » ។

## អធិប្បាយ « សមយ » ស័ព្ទ

បទថា **ឯកំ** ជាបទសម្តែងដល់ចំនួនរាប់ បទថា **សមយំ** ជាបទសម្តែងវេលាដែលមិនកំណត់ពិតប្រាកដ ។

**សមយ** ស័ព្ទ ក្នុងបទថា **ឯកំ សមយំ** នោះ រមែងប្រាកដក្នុងអត្ថថា÷

**សមវាយ** ( ព្រមព្រៀង) **ខណ** **កាល** **សម្ហូហ** ( ការប្រជុំ) **ហេតុ** **ទិដ្ឋិ** **បដិលាភ** ( ការបាន) **បហាន** ( ការលះ) និង **បដិវេធ**

( កាឃើញច្បាស់ ) ។

ពិតហើយ **សមយ** ស័ព្ទនោះ មានការព្រមព្រៀងជាអត្ថក្នុងប្រយោគជាដើមយ៉ាងនេះថា សូម្បីដូច្នោះ ក្នុងថ្ងៃស្អែកនេះ ពួកយើងអាស្រ័យកាលសម័យ ( សមគួរ ) គប្បីចូលទៅរក ដូច្នេះ ។

មាន **ខណ** ជាអត្ថ ក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡាយ ក៏ខណៈ និង សម័យមួយ រមែងមានដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ដូច្នេះ ។

មាន **កាល** ជាអត្ថ ក្នុងប្រយោគជាដើមថា វេលាក្ដៅ វេលាក្ដៅខ្លាំង ដូច្នេះ ។

មានការ **ប្រជុំ** ជាអត្ថ ក្នុងប្រយោគជាដើមថា ប្រជុំធំក្នុងព្រៃធំ ។

មាន **ហេតុ** ជាអត្ថ ក្នុងប្រយោគជាដើមថា ម្នាលភទ្ទាលិ សូម្បីហេតុនោះឯងលោកមិនបានជាក់ច្បាស់ ព្រះមានព្រះភាគប្រថាប់គង់នៅក្រុងសាវត្ថី ព្រះមានព្រះភាគជាម្ចាស់នឹងដឹងយើងថា ភិក្ខុឈ្មោះថា ភទ្ទាលិមិនធ្វើការសិក្សាក្នុងព្រះសាសនារបស់ព្រះសាស្ដាឱ្យបរិបូណ៌ ម្នាលភទ្ទាលិ ហេតុនោះឯងដែលលោកមិនទាន់បានសម្រេច យ៉ាងនេះ ។

មាន **ទិដ្ឋិ** ជាអត្ថ ក្នុងប្រយោគជាដើមថា ដោយសម័យនោះឯងបរិព្វាជកឈ្មោះ **ឧគ្គាហមានះ** ជាបុត្តរបស់សមណមុណ្ឌិកា អាស្រ័យនៅក្នុង

# ២១ អដ្ឋកថា មូលបរិយាយសូត្រ ទី១

សួនផ្កាម្លិះ ដែលមានសាលាមួយជាកន្លែងបង្រៀនលទ្ធិ សម្បូរដោយដើមទន្លាប់ ។

មានការ **បានចំពោះ** ជាអត្ថ ក្នុងប្រយោគជាដើមថា អ្នកប្រាជ្ញលោកហៅថា បណ្ឌិត ព្រោះបានទទួលប្រយោជន៍ទាំងក្នុងបច្ចុប្បន្ន និង សម្បរាយ-ភព ។

មានការ **លះបង់** ជាអត្ថ ក្នុងប្រយោគជាដើមថា បានធ្វើទីបំផុត នៃទុក្ខព្រោះលះមានះបានដោយល្អ ។

មានការ **ឃើញច្បាស់** ជាអត្ថ ក្នុងប្រយោគជាដើមថា ទុក្ខមានអត្ថ ថាបៀតបៀន ត្រូវតាក់តែង ធ្វើឱ្យក្តៅក្រហាយ ប្រែប្រួល និង មានអត្ថថាគួរកំណត់ដឹង ។

តែក្នុងទីនេះ **សមយ** ស័ព្ទនោះ មាន **កាល** ជាអត្ថ ព្រោះហេតុនោះព្រះថេរៈទើបសម្តែងថា ក្នុងសម័យមួយ បណ្តាសម័យដែលចែកកាលចេញជា ឆ្នាំ រដូវ ខែ កន្លះខែ ពេលយប់ ពេលថ្ងៃ ពេលព្រឹក ពេលថ្ងៃត្រង់ ពេលល្ងាច យាមខាងដើម យាមកណ្តាល យាមខាងចុង និង មួយខណៈ ជាដើម ។

ក្នុងសេចក្តីនោះ សូត្រណា ៗ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឆ្នាំ

រដូវ ខែ បក្ខ ពេលយប់ ពេលថ្ងៃណា។ ក្នុងបណ្តាសម័យមាន ឆ្នាំជាដើម នោះ សូត្រទាំងអស់នោះ ព្រះថេរៈដឹងច្បាស់ គឺ កំណត់ទុកដោយល្អដោយបញ្ញាទៅតាមសេចក្តីពិត ព្រោះថា កាលលោកពោលយ៉ាងនេះថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ក្នុងឆ្នាំនោះ រដូវនោះ ខែនោះ បក្ខនោះ ពេលខែនោះ ពេលថ្ងៃនោះ នរណា ៗ មិនអាចចាំបានដោយងាយ មិនអាចនឹងសម្តែងដោយខ្លួនឯង ឬ ឱ្យអ្នកដទៃសម្តែងបាន ហើយនឹងត្រូវនិយាយគ្នាច្រើន ដូច្នោះ ព្រះថេរៈទើបរួបរួមសេចក្តីនោះទុកក្នុងបទតែមួយយ៉ាងនោះ ហើយពោលថា **ឯកំ សមយំ** យ៉ាងនេះ ។

ន័យម្យ៉ាងទៀត សម័យទាំងនេះ ដែលព្រះមានព្រះភាគចែកប្រភេទកាលវេលាចេញជាច្រើនដែលប្រាកដច្បាស់ ដោយច្រើនក្នុងពួកទេវតា និងមនុស្សជាដើម យ៉ាងនេះគឺ សម័យស្តេចចុះកាន់ព្រះគភ៌ សម័យប្រសូត សម័យកើតសេចក្តីសង្វេគ សម័យស្តេចចេញបួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹង សម័យនៅជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យបរិនិព្វាន ។ ព្រះថេរៈសម្តែងថា សម័យមួយ ពោលគឺ សម័យទេសនា ក្នុងបណ្តាសម័យទាំងទឡាយនោះ ។

ម្យ៉ាងទៀត ព្រះថេរៈសំដៅយកសម័យនៃកិច្ច ដែលប្រកបដោយករុណា

# ២៣ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ក្នុងបណ្តាសម័យនៃកិច្ចដែលប្រកបដោយបញ្ញា និងករុណា សម័យនៃការបដិបត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃ ។ ក្នុងបណ្តាសម័យនៃការបដិបត្តិដើម្បីប្រយោជន៍ខ្លួន និង ប្រយោជន៍អ្នកដទៃ សម័យនៃធម្មីកថា ក្នុងបណ្តាសម័យនៃករណីទាំងពីររបស់អ្នកប្រជុំគ្នា សម័យនៃទេសនា ក្នុងបណ្តាសម័យនៃការទេសនា និង ការបដិបត្តិ សម័យណាមួយក្នុងបណ្តាសម័យទាំងទឡាយនោះ ទើបពោលថា **ឯកំ សមយំ** ដូច្នេះ ។

ស្នួរថា ព្រោះហេតុអ្វី ក្នុងទីនេះលោកមិនសម្តែងដូចក្នុងអភិធម្មនោះ លោកធ្វើការសម្តែងដោយសត្តមីវិភត្តិថា **យស្មឹ សមយេ កាមាវចរំ** និងថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** ក្នុងសុត្តបទដទៃក្រៅពី គម្ពីរនេះ និងវិន័យ លោកធ្វើការសម្តែងដោយតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** តែធ្វើការសម្តែងអធិប្បាយទុតិយាវិភត្តិថា **ឯកំ សមយំ** ។

ឆ្លើយថា ព្រោះក្នុងទីនោះមានសេចក្តីយ៉ាងនោះ តែក្នុងទីនេះមានសេចក្តីជាយ៉ាងនេះ ( មានសេចក្តីម្យ៉ាងម្នាក់ ) ។

ពិតហើយ ក្នុងបណ្តាអភិធម្មជាដើមទាំងទឡាយនោះ ក្នុងអភិធម្ម និងក្នុងសុត្តបទដទៃក្រៅពីនេះ **សមយ** ស័ព្ទមានសេចក្តីក្នុងអធិករណៈ( សត្តមី_ វិភត្តិ ) និង មានសេចក្តីជាភាវលក្ខណៈដោយភាវៈ ។ ព្រោះថា **សមយ**

ជាអធិករណៈ មានកាលជាអត្ថ និង មានសមូហៈជាអត្ថ ហើយលោកកំណត់ថា ជាភាវៈនៃធម៌ទាំងទឡាយមាន ផស្សៈជាដើម ដែលលោកពោលទុកហើយក្នុងទីនោះ ៗ ដោយភាវៈនៃសម័យ ពោលគឺ ខណៈ ការរួបរួម និង ហេតុ ។ ព្រោះដូច្នោះ ដើម្បីឱ្យសេចក្ដីនោះជាក់ច្បាស់ លោកទើបសម្ដែងអធិប្បាយជាសត្តមីវិភត្តិក្នុងបទនោះ ។ ពិតហើយ សម័យនៃការបញ្ញត្តិសិក្ខាបទនោះសូម្បីព្រះសារីបុត្តជាដើម ក៏ដឹងបានដោយលំបាក ។

ព្រះមានព្រះភាគ កាលនឹងទ្រង់បញ្ញត្តិសិក្ខាបទ ដោយសម័យនោះដែលជាហេតុ និង ជាករណៈ ហើយកាលដែលទ្រង់សម្លឹងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ទ្រង់ប្រថាប់នៅក្នុងទីនោះ ៗ ព្រោះដូច្នោះ ដើម្បីនឹងឱ្យជាក់ច្បាស់សេចក្ដីនោះ ទើបព្រះអង្គធ្វើការសម្ដែងអធិប្បាយជាតតិយាវិភត្តិក្នុងបទនោះ ។ តែក្នុងទីនេះ និង ក្នុងទីដទៃដែលមានសេចក្ដីយ៉ាងនេះ **សមយ** ស័ព្ទ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។

ពិតហើយ ក្នុងសម័យណាព្រះមានព្រះភាគទ្រង់សម្ដែងព្រះសូត្រនេះ ឬ សូត្រដទៃ ក្នុងសម័យនោះ ព្រះអង្គប្រថាប់នៅដោយធម៌ជាគ្រឿងនៅ គឺ ករុណាតែម្យ៉ាង ព្រោះដូច្នោះ ដើម្បីធ្វើសេចក្ដីនោះឱ្យជាក់ច្បាស់ ទើបលោកធ្វើការសម្ដែងអធិប្បាយជាទុតិយាវិភត្តិទុកក្នុងបទនេះ ។

## ២៥ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ហេតុនោះ លោកទើបពោលពាក្យនេះទុកថា សម្ទឹងដល់សេចក្តីនោះ ៗ ហើយលោកពោល **សមយ** ស័ព្ទ ទុកក្នុងទីដទៃផងដោយសត្តមីវិភត្តិ និង តតិយាវិភត្តិ តែក្នុងទីនេះ លោកពោល **សមយ** ស័ព្ទនោះ ទុកដោយតតិយា_ វិភត្តិ ។

ចំណែកបុរាណាចារ្យទាំងទឡ្សាយពណ៌នាទុកថា **សមយ** ស័ព្ទនោះ មាន ប្រភេទដែលអាចបែងចែកការនិយាយបានដូច្នេះថា **តស្មឹ សមយេ** , **តេន សមយេ** ឬថា **តំ សមយេ** តែពោលដោយសេចក្តី ចុះក្នុងអត្ថនៃសត្តមី_ វិភត្តិក្នុងទីទាំងពួង ដូច្នេះ ។ ព្រោះដូច្នោះ សូម្បីកាលលោកពោលថា **ឯកំ សមយំ** គួរជ្រាបសេចក្តីថា **ឯកស្មឹ សមយេ** ដូច្នេះ ។

### អធិប្បាយ ភគវា

ពាក្យថា **ភគវា** ជាពាក្យពោលដោយគោរព ព្រោះបុគ្គលទាំងទឡ្សាយ ហៅគ្រូក្នុងលោកថា **ភគវា** ក៏ព្រះមានព្រះភាគនេះ ឈ្មោះថា គ្រូរបស់សត្វ គ្រប់ជំពូក ព្រោះជាអ្នកប្រសើរដោយព្រះគុណគ្រប់យ៉ាង ព្រោះដូច្នោះ គួរ ជ្រាបគ្រូថា **ភគវា** ដូច្នេះ ។

**សូម្បីបុរាណាចារ្យទាំងទឡ្សាយ លោកក៏បានពោលទុកថា**

**ពាក្យថា ភគវា ជាពាក្យដ៏ប្រសើរ ពាក្យថា ភគវា**

ជាពាក្យខ្ពង់ខ្ពស់បំផុត ព្រោះហេតុនោះទើបលោកហៅថា
អ្នកប្រកបដោយសេចក្តីគោរពកាន់យកថា ភគវា ដូច្នេះ ។
ម្យ៉ាងទៀតលោកពោលទុកថា ភគវា ព្រោះមានព្រះ
ភាគ្យ (បារមីធម៌) ព្រោះកាច់បំបាក់នូវកងកិលេស
ព្រោះប្រកបដោយបុញ្ញសិរី (ព្រោះចែកកម្ម) ព្រោះ
សោយនូវព្រហ្មវិហារធម៌ និង ព្រោះខ្ជាក់ចោលនូវការ
វិលវល់ កើតស្លាប់ក្នុងភពទាំង ៣ ។

គប្បីជ្រាបខ្លឹមសាររបស់បទថា **ភគវា** នេះ ព្រោះអំណាចគាថានេះដោយពិស្តារ ពិតហើយ ស័ព្ទថា **ភគវា** នុ៎ះ លោកពោលទុកហើយក្នុងពុទ្ធានុស្សតិ-និទ្ទេសក្នុងវិសុទ្ធិមគ្គ ។

ក្នុងអធិការនេះ ដោយពាក្យអធិប្បាយត្រឹមតែប៉ុណ្ណេះ ព្រះថេរៈកាលសម្តែងធម៌តាមដែលខ្លួនបានស្តាប់មកដោយពាក្យថា **ឯវម្មេ សុតំ** ឈ្មោះថារមែងធ្វើសរីរៈ គឺ ព្រះធម៌របស់ព្រះមានព្រះភាគឱ្យប្រចក្ស ព្រោះហេតុនោះព្រះថេរៈរមែងញុំាងជនដែលកើតការអផ្សុកព្រោះមិនឃើញព្រះសាស្តាឱ្យបានធូរចិត្តថា បាវចនៈដែលខ្វះសាស្តារមែងមិនមាន នេះជាសាស្តារបស់យើងទាំង-ទឡាយ ព្រះថេរៈកាលសម្តែងការដែលព្រះមានព្រះភាគទ្រង់មិនបានគង់នៅក្នុង

# ២៧ អដ្ឋកថា មូលបរិយាយសូត្រ ទី១

សម័យនោះ។ ពាក្យថា**ឯកំសមយំភគវា**ធ្វើការរំលត់នៃរូបកាយឱ្យស្ទុះ ទៅ។ ព្រោះហេតុនោះព្រះថេរៈរមែងញ៉ាំងជនដែលស្រវឹងក្នុងជីវិតឱ្យតក់_ស្លុតថា ÷

ព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងអរិយធម៌ មានឈ្មោះយ៉ាងនេះ ទ្រទ្រង់ទុកនូវកម្លាំង ១០ មានព្រះវរកាយដូចដុំពេជ្រ ស្តេចបរិនិព្វានហើយដោយប្រយោជន៍អ្វីដែលធ្វើសេចក្តីសង្ឃឹមក្នុងជីវិតឱ្យកើតទេឡើង និង ធ្វើសេចក្តីឧស្សាហ៍របស់ជននោះឱ្យកើតទេឡើងក្នុងព្រះសទ្ធម្ម ។

ព្រះថេរៈកាលពោលថា **ឯវំ** រមែងសម្តែងអធិប្បាយដល់សម្បត្តិ គឺ ទេសនា ។ កាលពោលថា **មេ សុតំ** រមែងសម្តែងអធិប្បាយដល់សាវក_ សម្បត្តិ ។ កាលពោលថា **ឯកំ សមយំ** រមែងសម្តែងអធិប្បាយដល់ កាលសម្បត្តិ ។ កាលពោលថា **ភគវា** រមែងសម្តែងដល់ ទេសកសម្បត្តិ ។

## ហេតុដែលនាំឱ្យមានឈ្មោះថា ក្រុងឧក្កដ្ឋា

ពាក្យថា **ឧក្កា** ក្នុងពាក្យថា **ឧក្កដ្ឋាយំ វិហរតិ** នេះ សំដៅយកដួងប្រទីប ហើយក្រុងនោះគេហៅថា **ឧក្កដ្ឋា** ព្រោះអ្នកក្រុងនាំគ្នាលើកគប់_ភ្លើងក្នុងវេលាយប់ដោយគិតថាថ្ងៃមង្គលខណៈល្អឫក្សល្អកុំឱ្យកន្លងហួស ទៅ ។ លោកអធិប្បាយទុកថា ព្រោះក្រុងនោះអ្នកស្រុកអុចប្រទីប មានគប់

បំភ្លឺជិតក្រុងឈ្មោះ **ឧក្កដ្ឋា** នោះ ។ បទថា **ឧក្កដ្ឋាយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត ។ បទថា **វិហរតិ** នេះ ជាពាក្យសម្តែងដល់ការព្រមព្រៀងនៃការនៅ ក្នុងបណ្តាការនៅដោយការផ្លាស់ប្តូរឥរិយាបថ ការរស់នៅដូចពួកទេពដូចពួកព្រហ្ម និង ការរស់នៅដូចព្រះអរិយៈបែបណាមួយដែលមិនផ្សេងគ្នា តែក្នុងទីនេះជាការសម្តែង ការប្រកបដោយឥរិយាបថណាមួយក្នុងបណ្តាឥរិយាបថ ( ទាំងបួន ) គឺ ដេក ដើរ ឈរ អង្គុយ ។ ព្រោះហេតុនោះ ព្រះមាន-ព្រះភាគជាម្ចាស់ប្រថាប់ ឈរក្តី ស្តេចយាងក្តី ស្តេចគង់ក្តី ស្តេចផ្ទំក្តីគួរជ្រាបថា ប្រថាប់នៅទាំងអស់ ។ ពិតណាស់ ព្រះមានព្រះភាគអង្គនោះទ្រង់សម្រាកនូវការឈឺចុកចាប់ ដោយការប្តូរផ្លាស់ពីឥរិយាបថមួយ ទៅឥរិ-យាបថមួយ ទ្រង់រមែងបរិហារ គឺ ធ្វើអត្តភាពឱ្យប្រព្រឹត្តទៅមិនឱ្យទ្រុឌទ្រោមព្រោះដូច្នោះ លោកទើបពោលថា ប្រថាប់នៅ ដូច្នេះ ។

## ដំណើរមករបស់ព្រៃសុភគវ័ន

ក្នុងបទថា **សុភគវនេ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ÷

ព្រៃឈ្មោះថា **សុភគ** ព្រោះស្អាត អធិប្បាយថា ស្រស់ស្អាត ព្រោះមានវត្ថុស្អាតគួរជាទីប្រាថ្នា ដោយសម្រស់របស់ព្រៃនោះ មនុស្សជាច្រើនបាននាំគ្នាយកបាយ និង ទឹកជាដើម ទៅបរិភោគលេងសប្បាយនៅក្នុងព្រៃនោះឯង

# ២៩ អដ្ឋកថា មូលបរិយាយសូត្រ ទី១

រហូតមួយថ្ងៃ ហើយធ្វើនូវសេចក្តីប្រាថ្នាចំពោះវត្ថុដែលគេចង់បានក្នុងទីនោះថា សូមឱ្យយើងខ្ញុំបាននូវកូនប្រុស-ស្រី ហើយចំពោះវត្ថុដែលគេប្រាថ្នានោះ ក៏បានសមតាមបំណង ។ ព្រៃនោះឈ្មោះថា **សុភគ** ព្រោះស្រស់ស្អាត ព្រោះមានវត្ថុស្អាតគួរជាទីប្រាថ្នា ដូចពណ៌នាមកនេះ ។ ម្យ៉ាងទៀត ឈ្មោះថា **សុភគ** ព្រោះមនុស្សជាច្រើនជាប់ចិត្ត ។ ឈ្មោះថា **វន** ( ព្រៃ ) ព្រោះអត្ថថា សត្វទាំងទឡាយចូលចិត្ត គឺ ធ្វើសត្វទាំងទឡាយឱ្យស្រឡាញ់ពេញចិត្តដោយគុណ-សម្បត្តិរបស់ខ្លួននោះឯង អធិប្បាយថាឱ្យកើតសេចក្តីស្រឡាញ់ចំពោះខ្លួនឯង ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **វន** ( ព្រៃ ) ព្រោះហៅរក អធិប្បាយថា ដូចសម្រែកអំពាវនាវរបស់ពួកសត្វបក្សី ដូចជាសត្វកោកិលា ( សត្វតាវៅ ) ជាដើម ដែលរីករាយជាមួយនឹងក្លិនផ្កាឈើ និង ពណ៌ទាំងទឡាយ ដែលមានមែកសាខា ស្លឹកចាស់-ខ្ចីរបស់ដើមឈើដែលបក់រំភើចព្រោះខ្យល់ហាក់ដូចជាចង់ឱ្យមកចុះស៊ី មកទុំ ខ្ញុំចុះ ។ ព្រៃនោះផង ភាពស្រស់ស្អាតនោះផង ដូច្នោះ ទើបឈ្មោះថា សុភគវ័ន ។ ក្នុងព្រៃសុភគវ័ននោះ ។ ធម្មតាព្រៃមាន ២ ប្រភេទ គឺ ព្រៃដាំ និង ព្រៃដុះឯង ។ ក្នុងព្រៃទាំង២ ប្រភេទនោះ ព្រៃដាំ បានដល់ ព្រៃវេឡុវ័ន និង ព្រៃជេតវ័នជាដើម ។ ព្រៃដុះឯង បានដល់

ព្រៃអន្ធវ័ន ព្រៃមហាវ័ន និង ព្រៃអញ្ជនវ័នជាដើម ។ ព្រៃសុភគវ័ន គប្បីជ្រាបថា ជាព្រៃដុះឯង ។

សូម្បីដើមរាំងភ្នំ ក្នុងពាក្យនេះថា **សាលរាជមូលេ** លោកក៏ហៅថាដើមសាលៈ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ព្រៃសាលវ័នធំ នៅមិនឆ្ងាយពីស្រុក ឬ និគម ហើយព្រៃសាលវ័ននោះដេរដាសទៅដោយដើម ល្ហុង ហើយត្រាស់ថា រវាងដើមរាំងទាំងគូ ។ សូម្បីដើមឈើដែលធំបំផុត លោកក៏ហៅថា ស្តេចឈើសមដូចដែលលោកពោលទុកថា ÷

**បពិត្រព្រះសម្មតិទេព ក្នុងផ្ទៃព្រះរាជឧទ្យាន ក្នុងព្រំដែន**

**របស់ព្រះអង្គ មានដើមឈើធំៗ ជាច្រើនដើម មានមែក**

**ត្រង់ ពណ៌ខៀវស្រងាត់ គួរជាទីមនោរម្យ ។**

សូម្បីដើមឈើណាមួយ ក៏ហៅថា ស្តេចឈើបានដែរ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ គ្រានោះឯង គ្រាប់ជ្រៃគប្បីជ្រុះទៅកាន់គល់ឈើណាមួយ ដូច្នេះជាដើម ។ តែក្នុងទីនេះ លោកសំដៅយកដើមឈើធំបំផុត ឈ្មោះថា ស្តេចឈើ ។

## អធិប្បាយ រាជ ស័ព្ទ

ចំណែក **រាជ** ស័ព្ទ នៃបទថា **សាលរាជមូលេ** នោះ រមែងញ៉ាំង

# ៣១ អដ្ឋកថា មូលបរិយាយសូត្រ ទី១

ដើមឈើនោះឯង ឱ្យក្លាយទៅជាដើមឈើធំបំផុត ដូចមានប្រយោគជាដើមថា ម្នាលព្រាហ្មណ៍ អ្នកតាំងនៅក្នុងធមិក៏ ..... ដើមជ្រៃដែលធំរឹងមាំ ស្ងួម្បី ក្នុងទីកន្លែងដទៃ ។ ក្នុងពាក្យថា **សាលរាជមូលេ** នោះ ចែកចេញជា សមាស ២ យ៉ាង ( ឆដ្ឋីតប្បុរិសសមាស ថា ) **សាលានំ រាជា** ( ស្តេច នៃដើមឈើទាំងទឡ្បាយ) ព្រោះហេតុនោះ ទើបឈ្មោះថា សាលរាជខ្លះ និងជា ( វិសេសនបុព្វបទកម្មធារយសមាសថា) **សាលោចសោឆេដ្ឋកដ្ឋេន រាជា ច** ដើមសាលៈនោះផង ជារាជា ព្រោះធំជាងគេបំផុតផង ព្រោះ ហេតុនោះ ទើបឈ្មោះថា សាលរាជា ។ បទថា **មូលំ** ប្រែថា ជិត ព្រោះថា **មូល** ស័ព្ទនេះ ប្រើក្នុងអត្ថថា ជិតគល់ ក្នុងប្រយោគជាដើមថា បុគ្គលគប្បីរំលើងគល់ ដោយទីបំផុត ស្ងួម្បីដើមស្មៅដំរី ។ **មូល** ស័ព្ទ

ប្រើក្នុងហេតុដែលមិនទូទៅ ក្នុងប្រយោគជាដើមថា សេចក្តីលោភ ជាឫសគល់ នៃអកុសល ម្យ៉ាងទៀត **មូល** ស័ព្ទ ប្រើក្នុងអត្ថថា ជិត ក្នុងប្រយោគ ជាដើមថា នៅពេលថ្ងៃត្រង់ ស្រមោលនៅចំពីលើ ដោយហេតុថា ស្រមោល របស់ដើមឈើនៅចំពីលើខ្លួនក្នុងពេលថ្ងៃត្រង់ ហើយស្លឹកឈើជ្រុះនៅពេលស្ងប់ ខ្យល់ ស្រមោលនឹងនៅចំពីលើដើមឈើ ស្លឹកឈើក៏ជ្រុះក្បែរគល់ឈើ ។ តែ ក្នុងទីនេះ **មូល** ស័ព្ទ សំដៅយកអត្ថថា **សមីប** ( ជិត) ព្រោះដូច្នោះគប្បី

ជ្រាបសេចក្តីក្នុងពាក្យថា **សាលរាជមូលេ** យ៉ាងនេះថា នៅក្បែរដើមសាល_ រាជ ។

ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា បើថា ព្រះមានព្រះភាគគង់នៅក្នុងក្រុងឧក្កដ្ឋាមុននោះសោត ក៏មិនគួរពោលថា នៅជិតដើមសាលរាជក្នុងព្រៃ **សុភគវ័ន** បើទ្រង់គង់នៅជិតដើមសាលរាជក្នុងព្រៃសុភគវ័ននោះសោត ក៏មិនគួរពោលថា នៅក្នុងក្រុងឧក្កដ្ឋា ។ ព្រោះថា ព្រះអង្គមិនគង់នៅពីរកន្លែងក្នុងពេលតែមួយនោះទេ ឆ្លើយថា ក៏ឯសេចក្តីនោះ មិនគួរយល់ឃើញយ៉ាងនេះ យើងទាំងទឡាយបានពោលទុកហើយថា សត្តមីវិភត្តិចុះក្នុងអត្ថថាជិត ។ ព្រោះដូច្នោះ ហ្វូងគោ កាលដើរជិតទន្លេគង្គា និង ទន្លេយមុនា ជាដើមរមែងត្រូវហៅថា ត្រាច់ទៅជិតទន្លេគង្គា ជិតទន្លេយមុនា យ៉ាងណា

សូម្បីក្នុងទីនេះក៏ដូច្នោះ គឺ ព្រះមានព្រះភាគគង់នៅក្នុងព្រៃសុភគវ័នជិតក្រុងឧក្កដ្ឋា ( និង ) ក្នុងទីជិតដើមសាលរាជ លោកក៏ហៅថា គង់នៅទីជិតដើមសាលរាជក្នុងព្រៃសុភគវ័នជិតក្រុងឧក្កដ្ឋា ដូច្នេះ ។ ក៏ពាក្យថា **ឧក្កដ្ឋា** ជាពាក្យប្រាប់ដល់គោចរគាម ។ សូម្បីពាក្យថា **សុភគវនំ** ជាពាក្យប្រាប់ដល់ទីកន្លែងនៅដ៏សមគួររបស់បព្វជិត ។ ក្នុងពាក្យ ២ នោះ ព្រះអានន្ទសម្តែងដល់ការដែលទ្រង់ធ្វើសេចក្តីអនុគ្រោះដល់គ្រហស្ថរបស់ព្រះមានព្រះភាគជាម្ចាស់ ដោយ

ការបញ្ជាក់ដល់ក្រុងឧក្កដ្ឋា សម្ដែងដល់ការដែលទ្រង់ធ្វើសេចក្ដីអនុគ្រោះដល់បព្វជិត ដោយការបញ្ជាក់ដល់ព្រៃសុភគវ័ន ។

ម្យ៉ាងទៀត ព្រះអានន្ទសម្ដែងនូវការវៀរចាកអត្តកិលមថានុយោគដោយទ្រង់ទទួលបច្ច័យដោយពាក្យដើម ( ឧក្កដ្ឋា ) សម្ដែងដល់ការវៀរចាកកាម-សុខល្លិកានុយោគ ដោយទ្រង់លះបង់នូវវត្ថុកាម ដោយពាក្យខាងក្រោយ , ( **សុភគវនំ** ) លោកសម្ដែងដល់ព្រះវីរិយៈ ក្នុងការដែលទ្រង់សម្ដែងព្រះធម៌ដោយពាក្យដើម សម្ដែងព្រះអធ្យាស្រ័យ ដែលបង្អោនទៅក្នុងវិវេកដោយពាក្យខាងក្រោយ , សម្ដែងការចូលដល់ព្រះករុណាគុណដោយពាក្យខាងដើម សម្ដែងការចូលដល់ព្រះបញ្ញាដោយពាក្យខាងក្រោយ , សម្ដែងដល់អធ្យាស្រ័យរបស់ព្រះអង្គដែលបង្អោនទៅក្នុងការធ្វើប្រយោជន៍ និង សេចក្ដីសុខដល់សត្វទាំងពួងដោយពាក្យខាងដើម , សម្ដែងនូវភាពជាអ្នកមិនសង្ឃឹមផលតបស្នងជំនួសក្នុងការធ្វើប្រយោជន៍ និង សេចក្ដីសុខដល់អ្នកដទៃដោយពាក្យខាងក្រោយ , សម្ដែងដល់ការនៅជាសុខ លះបង់សេចក្ដីសុខដែលពេញចិត្តធម៌ ជាគ្រឿងសម្គាល់ដោយពាក្យខាងដើម , សម្ដែងការគង់នៅយ៉ាងសុខសាន្តមានការព្យាយាមប្រកបក្នុងឧត្តរិមនុស្សធម៌ជាគ្រឿងសម្គាល់ ដោយពាក្យខាងក្រោយ , សម្ដែងភាពជាអ្នកមានឧបការៈច្រើនដល់មនុស្សដោយពាក្យខាងដើម , សម្ដែងភាពជា

អ្នកមានឧបការៈច្រើនដល់ទេវតាទាំងទឡាយដោយពាក្យខាងក្រោយ , សម្ដែងការដែលព្រះអង្គឧប្បត្តិក្នុងលោកជាអ្នកចម្រើនព្រម ( គ្រប់ទិស ) ក្នុងលោកដោយពាក្យខាងដើម , សម្ដែងភាពជាអ្នកមិនជាប់ក្នុងលោកដោយពាក្យខាងក្រោយ ព្រះអានន្ទសម្ដែងនូវការញ៉ាំងប្រយោជន៍ ដែលជាហេតុឱ្យព្រះមាន-ព្រះភាគឧប្បត្តិទេឡើងនោះឱ្យសម្រេចដោយពាក្យខាងដើម ព្រោះព្រះបាលីថា ÷

**ម្នាលភិក្ខុទាំងទឡាយ បុគ្គលឯក កាលកើតទេឡើងក្នុងលោករមែងកើតទេឡើងដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីសេចក្ដីអនុគ្រោះដល់មនុស្សលោក ដើម្បីប្រយោជន៍សុខដល់ទេវតា និង មនុស្សទាំង-ទឡាយ បុគ្គលឯក តីនរណា តី ព្រះតថាគត ជាព្រះអរហន្ត ត្រាស់ដឹងឯងដោយប្រពៃ ។**

សម្ដែងការគង់នៅដ៏សមគួរដល់ស្ថានទីដែលព្រះមានព្រះភាគឧប្បត្តិទេឡើងដោយពាក្យខាងក្រោយ ។

គប្បីជ្រាបការប្រកបសេចក្ដីក្នុងពាក្យថា **យទគ្គំ ភគវា ឧប្បន្នោ តទន្វូបរិហារំ** នោះ ដោយន័យជាដើមថា ព្រះមានព្រះភាគ ស្ដេចឧប្បត្តិទេឡើងដែលជាលោកិយ និង លោកុត្តរ តី គ្រាដំបូងនៅឯលុម្ពិនីវ័ន លើកទី ២ ត្រាស់ដឹងនៅឯពោធិមណ្ឌល ព្រោះហេតុនោះ ព្រះអានន្ទត្ថេរសម្ដែងនូវទី

គង់នៅសម្រាប់ព្រះមានព្រះភាគនោះ ក្នុងព្រៃទាំងអស់ ។

បទថា **តត្រ** ជាបទសម្ដែងដល់ស្ថានទី និង ពេលវេលា ។ អធិប្បាយថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងសម័យណា ព្រះអានន្ទត្ថេរសម្ដែងស្ថានទី និង វេលានោះថា ក្នុងសម័យនោះ នឹងទ្រង់គង់នៅក្រោមម្លប់សាលរាជព្រឹក្ស ក្នុងទីជិតដើមសាលរាជនោះ ។ ន័យម្យ៉ាងទៀត រមែងទ្រង់សម្ដែងក្នុងស្ថានទី និង វេលាដែលគួរសម្ដែង ។ ពិតណាស់ ព្រះមានព្រះភាគទ្រង់មិនសម្ដែងធម៌ក្នុងស្ថានទី ឬ ពេលវេលាមិនសមគួរ ក្នុងសេចក្ដីនេះមានពាក្យជាដើមថា ម្នាលពាហិយៈវេលានេះជាវេលាមិនសមគួរដូច្នេះនេះជាគ្រឿងសាធកៈ។ ស័ព្ទថា **ខោ** ជានិបាតចុះក្នុងអត្ថថា **បទបូរណមត្ត** ( ជាគ្រឿងបំពេញ បទ ) ខ្លះ ក្នុងអត្ថថា **អវធារណ** (ហាមសេចក្ដីដទៃ) ខ្លះ ។ ក្នុងអត្ថថា **អាទិកាល** ( កាលជាខាងដើម ) ខ្លះ ពាក្យថា **ភគវា** ជាបទសម្ដែងដល់ព្រះមានព្រះភាគជាគ្រូរបស់សត្វលោក ។

បទថា **ភិក្ខុ** ជាបទពោលដល់បុគ្គលដែលគួរនឹងបានស្ដាប់ធម្មទេសនា ម្យ៉ាងទៀត ក្នុងបទថា **ភិក្ខុ** គប្បីជ្រាបសេចក្ដីនៃពាក្យដោយន័យជាដើមថា ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ជាអ្នកសុំ គឺ ឈ្មោះថា **ភិក្ខុ** ព្រោះអត្ថថា ចូលទៅដើម្បីភិក្ខា ។

បទថា **អាមន្តេសិ** ប្រែថា ហៅ គឺ បាននិយាយជាមួយ (តែ) ក្នុងទីនេះមានសេចក្ដីយ៉ាងនេះថា ដាស់ឱ្យដឹងខ្លួន ( ចំណែក ) ក្នុងទីដទៃ រមែងចុះក្នុងអត្ថថា **ញាបន** ( ឱ្យដឹង ) ខ្លះ ។ សមដូចព្រះមានព្រះភាគ ត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ តថាគតសូមដាស់តឿនអ្នកទាំងឡាយ ម្នាល ភិក្ខុទាំងឡាយ តថាគតសូមប្រកាសឱ្យអ្នកទាំងឡាយដឹង** ដូច្នេះ ។ ចុះក្នុង អត្ថថា **ហៅ** ខ្លះ សមដូចព្រះមានព្រះភាគត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ អ្នកចូរមក ចូរទៅហៅព្រះសារីបុត្តមក តាមពាក្យតថាគត ។**

បទថា **ភិក្ខវោ** ជាបទសម្ដែងដល់អាការ ហៅមក ពិតណាស់ ពាក្យ នោះ ព្រះមានព្រះភាគត្រាស់ទុក ព្រោះសម្រេចមកពីការប្រកបគុណ គឺ ភាពជាអ្នកមានប្រក្រតីសុំ ( របស់ភិក្ខុទាំងឡាយនោះ ) អ្នកស័ព្ទសាស្ត្រទាំង-ទឡាយសម្គាល់ថា ភិក្ខុជាអ្នកប្រកបដោយគុណ គឺ ភាពជាអ្នកមានការសុំជា ប្រក្រតី ឈ្មោះថា ជាអ្នកប្រកបដោយគុណ មានភាពជាអ្នកសុំជាធម្មតាជា ដើមខ្លះ ជាអ្នកប្រកបដោយគុណ គឺ ភាពជាអ្នកមានប្រក្រតីពោលនូវពាក្យ អនុមោទនាថា « សាធុ » ក្នុងការសុំខ្លះ ។

ក៏ពាក្យដែលសម្រេចមកអំពីការប្រកបដោយគុណ ដូចភាពជាអ្នកមាន ប្រក្រតីសុំជាដើមរបស់ភិក្ខុទាំងនោះ នោះឈ្មោះថា ព្រះមានព្រះភាគប្រកាស

នូវចរិយាវត្ត ( របស់ភិក្ខុទាំងនោះ ) ដែលបុគ្គលខ្ពង់ខ្ពស់ និង បុគ្គលថោក-ទាបរាប់អានគ្នាហើយ ( ជាការ ) បង្ក្រាបនូវភាពជាអ្នកវិវាទគ្នានិងការរុញរា ចិត្ត ( របស់ពួកអ្នក ) ។ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងទឡ្ហាយនោះឱ្យបែរមុខមករកព្រះអង្គ ដោយព្រះតម្រាស់ដែលមានការទតព្រះនេត្រមើលដោយព្រះហឫទ័យដ៏ត្រជាក់ ដោយក្រសែនៃព្រះករុណាជាខាងដើម ទ្រង់ឱ្យភិក្ខុទាំង-ទឡ្ហាយនោះកើតនូវសេចក្តីប្រាថ្នានឹងស្តាប់ ដោយព្រះតម្រាស់ដែលសម្តែងដល់ការដែលព្រះអង្គប្រាថ្នានឹងត្រាស់ប្រៀនប្រដៅនោះឯង ។ ហើយទ្រង់ប្រកបភិក្ខុទាំងនោះទុក សូម្បីការតាំងចិត្តស្តាប់ដោយគោរពចំពោះព្រះតម្រាស់ដែលទ្រង់បំណងនឹងក្រើនរំលឹក ( ភិក្ខុទាំងទឡ្ហាយ ) ឱ្យដឹងខ្លួននោះឯង ព្រោះគុណសម្បត្តិនៃអត្ថរបស់ពាក្យប្រៀនប្រដៅ ទាក់ទងនឹងការតាំងចិត្តស្តាប់ដោយគោរព ។ ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី កាលបើមនុស្ស និងទេវតានៅទីនោះដែរ ហេតុអ្វី បានជាព្រះអង្គត្រាស់ហៅចំពោះតែភិក្ខុទាំងនោះមក ឆ្លើយថា ព្រោះភិក្ខុទាំងទឡ្ហាយជាអ្នកចម្រើនបំផុត ប្រសើរបំផុត នៅជិតនិង ព្រមព្រៀងគ្នាគ្រប់ពេលវេលា អធិប្បាយថា ព្រះធម៌ទេសនារបស់ព្រះ-មានព្រះភាគទូទៅដល់បរិស័ទគ្រប់ពួក ហើយភិក្ខុទាំងទឡ្ហាយឈ្មោះថា ចម្រើនបំផុតក្នុងបរិស័ទ ព្រោះជាអ្នកកើតមុនបរិស័ទដទៃ , ឈ្មោះថា ប្រសើរជា

ទីបំផុត ព្រោះសំដៅយកភាពជាបព្វជិត ជាធំ ប្រព្រឹត្តតាមព្រះសាស្តា និង ទទួលពាក្យប្រៀនប្រដៅទាំងអស់អំពីព្រះអង្គ , ឈ្មោះថា នៅជិត ព្រោះកាល អង្គុយនៅទីនោះ ឈ្មោះថា នៅក្នុងសម្នាក់ព្រះសាស្តា , ឈ្មោះថា ព្រមព្រៀង គ្នាគ្រប់កាល ព្រោះចូលទៅជិតសម្នាក់ព្រះសាស្តា ។

ម្យ៉ាងទៀត ភិក្ខុទាំងនោះឈ្មោះថា ជាភាជនៈនៃធម៌ទេសនា ព្រោះធ្វើឱ្យកើតការបដិបត្តិតាមព្រះមានព្រះភាគដែលទ្រង់ទូន្មាន និង ព្រោះជាបុគ្គលពិសេស ។ ម្យ៉ាងទៀត ទេសនារបស់ព្រះមានព្រះភាគទ្រង់សម្តែងចំពោះភិក្ខុរូបខ្លះប៉ុណ្ណោះ ព្រោះដូច្នោះ ទើបព្រះអង្គត្រាស់ហៅភិក្ខុទាំងទឡាយនោះមកដោយអាការយ៉ាងនេះ ។ ក្នុងសេចក្តីនោះគប្បីមានពាក្យសួរថា ក៏ដើម្បីប្រយោជន៍អ្វី បានជាព្រះមានព្រះភាគកាលទ្រង់នឹងសម្តែងធម៌ ទើបត្រាស់ហៅភិក្ខុទាំងទឡាយមុន ទ្រង់មិនសម្តែងធម៌តែម្តងទៅ ឆ្លើយថា ដើម្បីឱ្យកើតសតិ ព្រោះភិក្ខុទាំងទឡាយកំពុងអង្គុយគិតរឿងដទៃ អង្គុយបណ្តែតចិត្តខ្លះ អង្គុយពិចារណាធម៌ខ្លះ អង្គុយមនសិការកម្មដ្ឋានខ្លះ កាលបើព្រះមានព្រះភាគមិនត្រាស់ហៅភិក្ខុទាំងទឡាយនោះ ( មុនហើយ ) សម្តែងធម៌ ភិក្ខុទាំងនោះមិនអាចនឹងកំណត់បានថា ព្រះធម៌ទេសនានេះ មានអ្វីជាហេតុ ជាបច្ច័យ ព្រះអង្គទ្រង់សម្តែងធម៌ប្រារព្ធទៅលើហេតុអ្វី បើមិនដូច្នោះទេ អាចទទួលយកខុស

ឬថា អាចទទួលយកមិនបាន ហេតុនោះ ដើម្បីជាការដាស់តឿននូវសតិរបស់ភិក្ខុទាំងទឡាយជាមុន ហើយសម្តែងធម៌ជាក្រោយ ។

ពាក្យថា **ភទន្តេ** នោះ ជាពាក្យសម្តែងសេចក្តីគោរព ឬ ជាការថ្វាយពាក្យឆ្លើយចំពោះព្រះសាស្តា ។ ម្យ៉ាងទៀត ក្នុងរឿងនេះ ព្រះមានព្រះភាគត្រាស់ថា **ភិក្ខវោ** ឈ្មោះថា ត្រាស់ហៅភិក្ខុទាំងនោះឱ្យចូលមក ភិក្ខុទាំងនោះ ទូលថា **ភទន្តេ** ឈ្មោះថា ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រទានពាក្យហៅថា **ភិក្ខវោ** ភិក្ខុទាំងទឡាយឆ្លើយតបថា **ភទន្តេ** ។

បទថា **តេ ភិក្ខូ** សំដៅយកពួកភិក្ខុ ដែលព្រះមានព្រះភាគត្រាស់ហៅមក ។

បទថា **ភគវតោ បច្ចស្សោសុំ** មានន័យថា ( ភិក្ខុទាំងទឡាយនោះ ) ទទួលព្រះពុទ្ធដីកា អធិប្បាយថា បែរមុខមកស្តាប់ គឺ បង្អោនទទួល បាន ដល់ការទទួល ។

បទថា **ភគវា ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់សូត្រទាំងអស់នោះ គឺ ដែលនឹងត្រាស់ក្នុងពេលឥឡូវនេះ ។

ក៏និទានវចនៈណា ដែលប្រកបដោយ កាលៈ ទេសៈ អ្នកសម្តែង

រឿងរ៉ាវ បរិស័ទ និង ប្រទេស ដូចជាកំពង់ទឹកមានភូមិភាគសស្អាត ដេរដាស ដោយគ្រាប់ខ្សាច់ប្រៀបដូចជាផ្ទៃទិព្វ ពាសពេញទៅដោយកែវមុក្តា មានជណ្តើរដែលរចនាដោយថ្មាំងសិលា ដែលគេដុសខាត់រហូតប្រាសចាកមន្ទិល ដើម្បីងាយដល់ការចុះទៅកាន់ស្រះបោក្ខរណី ដែលពោរពេញទៅដោយផ្កាឈូកខៀវ មានទឹកថ្លាស្អាតរសជាតិឆ្ងាញ់ ដូចជណ្តើរដែលមានកាំល្អិតធ្វើមកអំពីភ្លុកដំរី ស្អាតរុងរឿងដែលកើតពីរស្មីនៃកែវមណី រំលេចដោយខ្សែមាស ដើម្បីងាយស្រួលដល់ការឈានទេឡើងកាន់មហាប្រាសាទ ប្រកបដោយការចាត់ចែងបានសមរម្យ បិទបាំងដោយគ្រឹះស្ថានដែលប្រកបដោយអង្គ ( មើលទៅហាក់បីដូច) រស់រវើក ដូចមានបំណងនឹងឱ្យខ្ពស់ទន្ទឹមនឹងដំណើរផ្លូវរបស់ដួងតារា ដូចមហាទ្វារដែលមានសភាពធំទូលាយ ដែលប្រតិស្ឋានទុកល្អហើយ ល្អដាច់គេ ចិញ្ចែងចិញ្ចាច ពាសទៅដោយមាស ប្រាក់ មណី មុក្តា និង កែវ_ប្រវាទឡជាដើម ដើម្បីជាការងាយស្រួលក្នុងការចូលទៅកាន់គុហារដ៏ប្រសើរដោយឥស្សរសម្បត្តិយ៉ាងឱទឡារិក ជាកន្លែងដែលខ្វាត់ខ្វែងទៅដោយមនុស្សដែលនិយាយសើចលេងដោយសំទេឡងដ៏ពីរោះ ប្រគុំដោយសំទេឡងទង្គិចរបស់គងមាសដែលពាក់តាមលំដាប់ ដែលព្រះអានន្ទពោលទុកហើយ ។ ការពណ៌នានៃនិទានវចនៈនោះ ជាការចប់បរិបូណ៌ដោយប្រការដូច្នេះ ។

## ហេតុកើតព្រះសូត្រ ៤ យ៉ាង

ឥឡូវនេះ ដល់លំដាប់ឱកាសដែលនឹងពណ៌នាព្រះសូត្រដែលព្រះមាន-ព្រះភាគ ទ្រង់លើកទេឡើងសម្តែងដោយន័យជាអាទិថា **សព្វធម្មមូលបរិយាយំ** ដូច្នេះ ។

ក៏ការពណ៌នាព្រះសូត្រនេះ ព្រោះកាលបានពិចារណាហេតុដែលទ្រង់លើកយកព្រះសូត្រទេឡើងសម្តែងហើយ ទើបអធិប្បាយបានច្បាស់លាស់ ដូច្នេះ ។ ខ្ញុំព្រះករុណានឹងពិចារណាហេតុ ដែលទ្រង់លើកយកព្រះសូត្រមកសម្តែងមុនអធិប្បាយថា ហេតុដែលទ្រង់លើកយកព្រះសូត្រមកសម្តែងមាន ៤ ប្រការ គឺ ÷

១ **អត្តជ្ឈាសយ** ប្រព្រឹត្តទៅតាមព្រះអធ្យាស្រ័យរបស់ព្រះអង្គ ។

២ **បរជ្ឈាសយ** ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់អ្នកដទៃ ។

៣ **បុច្ឆាវសិក** ប្រព្រឹត្តទៅដោយអំណាចការសួរ ។

៤ **អត្ថុប្បត្តិក** ប្រព្រឹត្តទៅតាមហេតុដែលកើតទេឡើង ។

ក្នុងបណ្តាហេតុ ៤ ប្រការនោះ ព្រះសូត្រទាំងទឡាយណាដែលអ្នកដទៃមិនបានទូលអារាធនា ព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាដោយព្រះអធ្យា-ស្រ័យរបស់ព្រះអង្គតែម្យ៉ាង មានជាអាទិយ៉ាងនេះ គឺ ÷

**អាកង្ខេយ្យសូត្រ វត្ថសូត្រ មហាសតិប្បដ្ឋានសូត្រ មហាសទឡាយត-**

**នសូត្រ** **អរិយវង្សសូត្រ** ចំណែកនៃ **សម្មប្បធានសូត្រ** ចំណែកនៃ **ឥទ្ធិបាទសូត្រ** **ឥន្ទ្រិយ** **ពល** **ពោជ្ឈង្គ** និង **មគ្គ** ព្រះសូត្រទាំងនោះឈ្មោះថា មានហេតុដែលទ្រង់លើកទេឡើងមកសម្តែង ប្រព្រឹត្តទៅតាមព្រះអធ្យាស្រ័យរបស់ព្រះអង្គ ។

មួយទៀត ព្រះសូត្រណាមួយ ដែលព្រះមានព្រះភាគទ្រង់សម្លឹងមើលអធ្យាស្រ័យ ការពេញចិត្ត ការចូលចិត្ត អភិនីហារ និង ភារៈដែលនឹងត្រាស់ដឹងបានរបស់ជនឯទៀតយ៉ាងនេះថា ធម៌អប់រំវិមុត្តិរបស់ **រាហុល** ចាស់ក្លាហើយ បើដូច្នោះ តថាគតគប្បីណែនាំរាហុលក្នុងអាសវក្ខយធម៌ឱ្យខ្ពស់ទេឡើងដូច្នេះ( ជាដើម) ហើយទើបត្រាស់ដោយអំណាចអធ្យាស្រ័យរបស់អ្នកដទៃ ( នោះ) គួយ៉ាងដូចជា ÷

**ចុល្លរាហុលោវាទសូត្រ** **មហារាហុលោវាទសូត្រ** **ធម្មចក្កប្ប-វត្តនសូត្រ** **ធាតុវិភង្គសូត្រ** ។ ព្រះសូត្រទាំងនោះឈ្មោះថា មានហេតុដែលទ្រង់លើកទេឡើងមកសម្តែង ប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់អ្នកដទៃ ។

មួយទៀត ព្រះសូត្រពួកណា ដែលពួកសត្វទាំងទឡាយ មានជាអាទិយ៉ាងនេះគឺ បរិស័ទ ៤ វណ្ណៈ ៤ ។ នាគ គ្រុឌ គន្ធព្វ អសុរ យក្ខ មហារាជទេវតាជាន់តាវត្តឹង្សជាដើម និង មហាព្រហ្ម នាំគ្នាចូលទៅគាល់

ព្រះមានព្រះភាគ ហើយទូលសួរបញ្ហា ដោយន័យមានជាអាទិថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ពោជ្ឈង្គៈ ពោជ្ឈង្គៈ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា នីវរណៈ នីវរណៈ ដូច្នេះ , បពិត្រព្រះ-អង្គដ៏ចម្រើន ឧបាទានក្ខន្ធ ៥ ទាំងនេះ , ក្នុងលោកនេះ អ្វីជាទ្រព្យដ៏ប្រសើរបំផុតរបស់មនុស្ស ។ កាលត្រូវសួរយ៉ាងនេះហើយ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ទេសនាមាន ពោជ្ឈង្គសំយុត្ត ជាដើម ។ ក៏ព្រះសូត្រសូម្បីដទៃណាមាន **ទេវតាសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត សក្កបញ្ហាសូត្រ ចុល្លវេទល្លសូត្រ មហាវេទល្លសូត្រ សាមញ្ញផលសូត្រ អាទឡ្ហវកសូត្រ សូចិលោមសូត្រ ខរលោមសូត្រ** ជាដើម ។ ព្រះសូត្រនោះ ឈ្មោះថា មានហេតុដែលទ្រង់លើកមកសម្ដែង ប្រព្រឹត្តទៅដោយអំណាចការសួរ ។

មួយទៀត ព្រះសូត្រណា ដែលព្រះមានព្រះភាគទ្រង់អាស្រ័យហេតុ-ការណ៍ដែលកើតទឡើង ត្រាស់ទេសនា តួយ៉ាងដូចជា **ធម្មទាយាទសូត្រ ចុល្លសីហនាទសូត្រ ចន្ទូបមសូត្រ បុត្តមំសូបមសូត្រ ទារុក្ខន្ធូបមសូត្រ អគ្គិក្ខន្ធូបមសូត្រ ផេណបណ្ឌូបមសូត្រ បារិច្ឆត្តកសូត្រ** ។ ព្រះសូត្រទាំងនោះ ឈ្មោះថា មានហេតុដែលទ្រង់លើកមកសម្ដែង ប្រព្រឹត្តទៅដោយហេតុដែលកើតទឡើង ។ ក្នុងបណ្ដាហេតុដែលលើកទឡើងមកសម្ដែង៩ ប្រការ

ដូចពណ៌នាមកហើយនេះ ក្នុងមូលបរិយាយសូត្រនេះ មានហេតុដែលទ្រង់លើកទេឡើងមកសម្តែង ប្រព្រឹត្តទៅដោយហេតុដែលកើតទេឡើង ។ ដោយន័យថា មូលបរិយាយសូត្រ ព្រះមានព្រះភាគជាម្ចាស់ទ្រង់លើកទេឡើងមកសម្តែង ព្រោះហេតុដែលកើតទេឡើង ។ ព្រោះហេតុដែលកើតទេឡើងយ៉ាងណា ? ព្រោះ **មានះ** ដែលកើតទេឡើងអាស្រ័យបរិយត្តិ ។

## មានះកើតព្រោះបរិយត្តិ

ដូចបានស្តាប់មក ព្រាហ្មណ៍ ៥០០ នាក់ រៀនចប់ត្រៃវេទ ខាងក្រោយបានស្តាប់ធម៌ទេសនារបស់ព្រះមានព្រះភាគ កាលឃើញទោសក្នុងកាមទាំង–ទឡាយ ឃើញអានិសង្សក្នុងការចេញបួស ទើបចេញបួសក្នុងសម្នាក់ព្រះ–មានព្រះភាគជាម្ចាស់ ។ មិនយូរប៉ុន្មាន ក៏រៀនយកព្រះពុទ្ធវចនៈទាំងអស់ព្រោះអាស្រ័យការសិក្សា ទើបកើតមានះថា ពួកយើងចេះព្រះពុទ្ធវចនៈដែលព្រះមានព្រះភាគត្រាស់ទុកបានរហ័សក្រៃពេក ព្រោះថា ព្រះមានព្រះភាគនឹងមិនត្រាស់រឿងអ្វីៗ ក្រៅអំពីលិង្គ ៣ បទ ៤ និង វិភត្តិ ៧ ។ កាលព្រះ–អង្គត្រាស់យ៉ាងនេះ ឈ្មោះថា បទដ៏អាថ៌កំបាំង ( មិនយល់ ) សម្រាប់ពួកយើងរមែងមិនមាន ដូច្នេះ ។ ភិក្ខុទាំងនោះ មិនមានសេចក្តីគោរពចំពោះព្រះមានព្រះភាគ ។ ចាប់តាំងពីពេលនោះមក ក៏មិនទៅឧបដ្ឋាក ( ធ្វើវត្ត

ចំពោះ ) ព្រះមានព្រះភាគជាម្ចាស់ខ្លះ មិនស្តាប់ធម៌ជាប្រចាំខ្លះ ។

ព្រះមានព្រះភាគ ទ្រង់ជ្រាបវារៈចិត្តនោះរបស់ភិក្ខុទាំងនោះ ទ្រង់ព្រះ_តម្រិះថា ភិក្ខុទាំងនេះនៅមិនទាន់ដកដែកគោល គឺ មានះ ក៏មិនគួរធ្វើឱ្យជាក់ច្បាស់មគ្គ_ផល ។ ទ្រង់ធ្វើមានះដែលកើតទេឡើង ព្រោះអាស្រ័យការរៀន **សុត្ត** របស់ភិក្ខុទាំងនោះជាដើម ហេតុកើតរឿង ទើបផ្តើមការសម្តែងធម្មកថា ព្រះ_មានព្រះភាគទ្រង់ឆ្លាតក្នុងការសម្តែងមូលបរិយាយសូត្រនៃធម៌ទាំងពួង ដើម្បីនឹងកាច់បំបាក់នូវមានះ ( របស់ភិក្ខុទាំងនោះ) ដូច្នេះ ។

## ខ្លឹមសាររបស់មូលបរិយាយសូត្រ និង ធម្ម

បណ្តាបទទាំងនោះ បទថា **សព្វធម្មមូលបរិយាយំ** ប្រែថា ព្រះសូត្រសម្តែងដោយហេតុដែលជាមូលដ្ឋាននៃធម៌ទាំងពួង ។ បទថា **សព្វេសំ** ប្រែ ថា មិនមានចំណែកសេសសល់ ។ ពិតណាស់ ស័ព្ទថា **សព្វ** នេះ បង្ហាញដល់សេចក្តីមិនមានចំណែកសេសសល់ ។ ស័ព្ទថា **សព្វ** នោះ រមែងសម្តែងដល់វត្ថុដែលទាក់ទងគ្នាមិនឱ្យសេសសល់ ។ ដូចយ៉ាងក្នុងប្រយោគជាដើមថា **រូបទាំងពួងមិនទៀង វេទនាទាំងពួងមិនទៀង ក្នុងបណ្តាធម៌ដែលទាក់ទងក្នុងកាយរបស់ខ្លួនទាំងអស់** ដូច្នេះ ។

ចំណែកស័ព្ទថា **ធម្ម** នេះ រមែងប្រាកដក្នុងស័ព្ទជាដើមថា **បរិយត្តិ**

**សច្ច សមាធិ បញ្ញា បកតិ សភាវ សុញ្ញតា បុញ្ញ អាបត្តិ** និង **ញេយ្យ** ។

ពិតហើយ ស័ព្ទថា **ធម្ម** រមែងប្រាកដក្នុងអត្ថថា **បរិយត្តិ** ដូចក្នុងប្រយោគជាដើមថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងរៀនធម៌ គឺ **សុត្ត គេយ្យ** ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សច្ច** ដូចក្នុងប្រយោគជាដើមថា ព្រះធម៌ដែលបណ្ឌិតឃើញហើយ គឺ ដឹងហើយ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សមាធិ** ដូចក្នុងប្រយោគជាដើមថា ព្រះមានព្រះ-ភាគជាម្ចាស់ទាំងនោះ មានធម៌យ៉ាងនេះ ។

ប្រាកដក្នុងអត្ថថា **បញ្ញា** ក្នុងប្រយោគជាដើមថា

**ម្នាលស្តេចពានរ អ្នកណាមានធម៌ ៤ យ៉ាងនេះ**
**គឺ សច្ច ធម្ម ធិតិ និង ចាគ អ្នកនោះ**
**រមែងឈានកន្លង ( មិនធ្លាក់ចុះ ) ក្នុងអំណាច**
**សត្រូវ ដូច្នេះ ។**

ប្រាកដក្នុងអត្ថថា **បកតិ** ដូចក្នុងប្រយោគជាដើមថា មានការកើតជាធម្មតា មានការចាស់ជាធម្មតា ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សភាវ** ដូចក្នុងប្រយោគជាដើមថា កុសលធម៌ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **សុញ្ញតា** ក្នុងប្រយោគជាដើមថា ក៏ក្នុងសម័យនោះ ឯង ព្រះធម៌ទាំងឡាយរមែងមាន ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា **បុញ្ញ** ( បុណ្យ ) ក្នុងប្រយោគជាដើមថា ព្រះធម៌ដែលបានប្រព្រឹត្តល្អហើយ ( សន្សំទុកបានល្អហើយ ) រមែងនាំសុខមកឱ្យ ដូច្នេះ ។

រមែងប្រាកដក្នុងអត្ថថា **អាបត្តិ** ក្នុងប្រយោគជាដើមថា ធម៌ទាំងឡាយដែលជាអនិយត ២ ប្រការ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា **ញេយ្យ** ក្នុងប្រយោគជាដើមថា ព្រះធម៌ទាំងពួងរមែងមកកាន់គន្លងក្នុងព្រះញាណរបស់ព្រះមានព្រះភាគ ដោយអាការទាំងពួង ដូច្នេះ ។

ប៉ុន្តែក្នុងទីនេះ **ធម្ម** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា **សភាវ** ។ ក្នុងពាក្យថា **ធម្ម** នោះ មានអត្ថវចនៈដូច្នេះថា សភាវៈទាំងឡាយណារមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហេតុនោះ សភាវៈទាំងនោះឈ្មោះថា **ធម្ម** ។

**មូល** សព្ទ លោកពោលទុកដោយពិស្តារហើយ ។ តែក្នុងទីនេះ

**មូល** ស័ព្ទនេះ គប្បីជ្រាបថា ចុះក្នុងអត្ថថា ហេតុដែលមិនទូទៅ ។

**បរិយាយ** ស័ព្ទ រមែងចុះក្នុងអត្ថថា ទេសនា ដូចក្នុងប្រយោគជា ដើមថា លោកចូរចាំព្រះសូត្រនោះថា មធុបណ្ឌិបរិយាយសូត្រ ដូច្នេះ ។

**បរិយាយ** ស័ព្ទ ចុះក្នុងអត្ថថា ការណៈ ( ហេតុ ) ដូចក្នុងប្រយោគ ជាដើមថា ព្រះសមណគោតមជាអកិរិយវាទី ដើម្បីត្រាស់ដោយប្រពៃ គប្បីត្រាស់នឹងយើងដោយហេតុណា ម្នាលព្រាហ្មណ៍ ហេតុនោះឯង មានហើយ ដូច្នេះ ។

ចុះក្នុងអត្ថថា **វារៈ** ក្នុងប្រយោគជាដើមថា ម្នាលអានន្ទ ថ្ងៃនេះជាវារៈរបស់អ្នកណាហ្ន៎ ដើម្បីនឹងឱ្យឱវាទដល់នាងភិក្ខុនីទាំងទឡាយ ដូច្នេះ ។

តែក្នុងទីនេះ ( បរិយាយស័ព្ទនោះ ) រមែងចុះក្នុងអត្ថថា **ការណ** ខ្លះ **ទេសនា** ខ្លះ ។ ព្រោះដូច្នោះ បរិយាយស័ព្ទ ក្នុងពាក្យនេះថា **សព្វធម្ម-មូលបរិយាយំ** ដូច្នេះ គួរជ្រាបយ៉ាងនេះថា **ការណ** ដែលធ្លាប់ដឹងថា ហេតុដែលមិនទូទៅដល់ធម៌ទាំងពួង ឬថា **ទេសនា** គឺ **ការណ** ( ហេតុ ) នៃធម៌ទាំងពួង ដូច្នេះ ។

ម្យ៉ាងទៀត សភាវធម៌ទាំងទឡាយ សូម្បីកើតក្នុងភូមិ ៤ មិនគប្បីយល់ថា ឈ្មោះថា ធម៌ទាំងពួង ព្រោះហេតុដែលសូត្រនោះមានខ្លឹមសារនឹងត្រូវណែនាំ

តែសភាវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ ដែលរាប់ចូលក្នុងសក្កាយទិដ្ឋិ គប្បីយល់ថា ធម៌ទាំងពួងដោយមិនមានចំណែកសេសសល់ ។ ក្នុងសេចក្ដីនេះ មានការអធិប្បាយដូចសម្ដែងមកយ៉ាងនេះឯង ។

## គោលការណ៍ប្រើ វោ ស័ព្ទ

**វោ** ស័ព្ទ ក្នុងបទថា **វោ** នេះ រមែងប្រើក្នុងបឋមាវិភត្តិ ទុតិយា- វិភត្តិ តតិយាវិភត្តិ ចតុត្ថីវិភត្តិ ឆដ្ឋីវិភត្តិ និង បទបូរណៈ ( ធ្វើបទឱ្យពេញ ) អធិប្បាយថា ÷

**វោ** ស័ព្ទ ប្រើក្នុងបឋមាវិភត្តិ ដូចក្នុងប្រយោគជាដើមថា ម្នាល អនុរុទ្ធ ក៏អ្នកទាំងទឡាយនៅមានសាមគ្គី រីករាយ មិនខឹងគ្នាទេឬ ដូច្នេះ ។

ប្រើក្នុងទុតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡាយ ពួកអ្នកចូរទៅ តថាគតបណ្ដេញពួកអ្នក ដូច្នេះ ។

ប្រើក្នុងតតិយាវិភត្តិ ដូចក្នុងប្រយោគជាដើមថា ពួកអ្នកមិនគួរនៅ ក្នុងសម្នាក់របស់តថាគត ដូច្នេះ ។

ប្រើក្នុងចតុត្ថីវិភត្តិ ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡាយ តថាគតនឹងសម្ដែងវនបត្ថបរិយាយសូត្រដល់ពួកអ្នក ដូច្នេះ ។

ប្រើក្នុងឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមថា ម្នាលសារីបុត្ត និង មោគ្គ-

ល្អាន នេះជាភាសិតរបស់អ្នកទាំងពួង ដូច្នេះ ។

ប្រើក្នុងអត្ថថា **ត្រឹមតែធ្វើបទឱ្យពេញ** ដូចក្នុងប្រយោគជាដើមថា ក៏ព្រះអរិយៈពួកណាមានកាយកម្មបរិសុទ្ធ ដូច្នេះ ។ តែក្នុងទីនេះ **វោ** ស័ព្ទនេះគួរជ្រាបថា ប្រើក្នុងចតុត្ថីវិភត្តិ ។

បទថា **ភិក្ខវេ** ជាការត្រាស់ហៅភិក្ខុដែលនៅចំពោះព្រះភក្ត្រម្តងហើយម្តងទៀត ដោយការឱ្យទទួលស្តាប់ ។ បទថា **ទេសេស្សាមិ** ជាការដាស់តឿនឱ្យដឹងថា នឹងសម្តែងធម៌ ។ អធិប្បាយទុកដូច្នេះថា ភិក្ខុទាំងទឡាយ តថាគតនឹងសម្តែងមូលហេតុនៃធម៌ទាំងពួងដល់អ្នកទាំងទឡាយ , តថាគតនឹងសម្តែងទេសនាដែលជាតួហេតុដោយន័យទី ២ ដល់ពួកអ្នក ដូច្នេះ ។ ពីរបទថា **តំ សុណាថ** សេចក្តីថា អ្នកទាំងទឡាយចូរស្តាប់នូវខ្លឹមសារនោះ គឺ ហេតុនោះបានដល់ ទេសនានោះដែលតថាគតនឹងសម្តែង ។ ក៏ពីរបទនេះថា **សាធុកំ សាធុ** ក្នុងពាក្យនេះថា **សាធុកំ មនសិការោថ** ដូច្នេះ មានខ្លឹមសារ តែមួយ ។

## គោលការណ៍ប្រើ សាធុ ស័ព្ទ

**សាធុ** ស័ព្ទ ប្រើក្នុងបទទាំងទឡាយមានជាដើមថា **អាយាចន** (អង្វរ) **សម្បដិច្ឆន្ន** (ទទួល) **សម្បហង្សន** (រីករាយ) **សុន្ទរ** (ល្អ) និង

**ទទឡីកម្ម** ( ធ្វើឱ្យមាំមួន ) ។ អធិប្បាយថា ÷

**សាធុ** ស័ព្ទ ប្រើក្នុអត្ថថា **អង្វរ** ដូចក្នុងប្រយោគជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមវរោកាស សូមព្រះមានព្រះភាគជាម្ចាស់មេត្តាទ្រង់សម្តែងព្រះធម៌ដល់ខ្ញុំព្រះអង្គដោយសង្ខេប ដូច្នេះ ។ ប្រើក្នុងអត្ថថា **ទទួល** ដូចក្នុងប្រយោគជាដើមថា ភិក្ខុទាំងទឡាយទាំងនោះឯងត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគថា ប្រពៃណាស់ ព្រះអង្គ ដូច្នេះ ។ ប្រើក្នុងអត្ថថា **រីករាយ** ដូចក្នុងប្រយោគជាដើមថា ប្រពៃណាស់ ៗ សារីបុត្ត ដូច្នេះ ។ ប្រើក្នុងអត្ថថា **ល្អ** ដូចក្នុងប្រយោគជាដើមថា ៖

**ព្រះរាជាអ្នកស្រទឡាញ់ធម៌ ជាបុគ្គលល្អ , បុគ្គលដែលមានបញ្ញា ( ប្រើបញ្ញាក្នុងផ្លូវល្អ) ជាបុគ្គលល្អ , បុគ្គលដែលមិនទ្រុស្តមិត្ត ជាបុគ្គលល្អ ការមិនធ្វើបាប ជាអំពើល្អ ដូច្នេះ ។**

**សាធុ** ស័ព្ទ ក៏ដូចគ្នា ប្រើក្នុងអត្ថថា **ធ្វើឱ្យមាំមួន** ប្រើក្នុងអត្ថថា **បង្គាប់ខ្លះ** ដូចក្នុងប្រយោគជាដើមថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរស្តាប់ឱ្យល្អ ដូច្នេះ ។

ក្នុងព្រះសូត្រនេះ ក៏គប្បីយល់ន័យតែម្យ៉ាងដូចគ្នានេះ ប្រើទាំងក្នុងការធ្វើឱ្យមាំមួន ទាំងក្នុងការបង្គាប់នេះឯង សូម្បីនឹងប្រើក្នុងអត្ថថា ល្អ ក៏គួរ ។

ពិតហើយ ដោយសាធុស័ព្ទដែលមានន័យថា **ធ្វើឱ្យមាំមួន** ព្រះមាន_ព្រះភាគទ្រង់សម្តែងសូម្បីពាក្យនេះថា អ្នកទាំងទឡាយចូររៀនឱ្យល្អ ចូរស្តាប់ធម៌នេះឱ្យចាំ , ដែលមានន័យថា **បង្គាប់** ទ្រង់សម្តែងសូម្បីពាក្យនេះថា អ្នកទាំងទឡាយចូរស្តាប់តាមអាណត្តិ គឺតាមពាក្យរបស់យើង ដែលមានន័យថា ល្អ ទ្រង់សម្តែងសូម្បីពាក្យនេះថា អ្នកទាំងទឡាយ ចូរស្តាប់ធម៌នេះឱ្យល្អ ឱ្យស្អាត ។

បទថា **មនសិករោថ** សេចក្តីថា ការចាប់អារម្មណ៍ គឺ ធ្វើទុកក្នុងចិត្ត អធិប្បាយថា មានចិត្តមិនរាយមាយ ពិចារណា គឺ ធ្វើទុកក្នុងចិត្ត ដូច្នេះ ។

ឥឡូវនេះ ពាក្យថា **តំ សុណាថ** នេះ ក្នុងអធិការនេះ ជាការហាមសេចក្តីរាយមាយនៃសោតិន្ទ្រិយ៍ , ពាក្យថា **សាធុកំ មនសិករោថ** ជាការហាមសេចក្តីរាយមាយនៃមនិន្ទ្រិយ៍ ដោយការប្រកបធ្វើឱ្យចាំទុកក្នុងចិត្ត ។

ម្យ៉ាងទៀត ក្នុងពីរពាក្យនេះ ពាក្យដំបូង ជាការហាមដល់ការកាន់យកខុសដោយព្យញ្ជនៈ ពាក្យក្រោយជាការហាមដល់ការកាន់យកខុសដោយអត្ថ ។ ដូចក្នុងប្រយោគជាដើមថា អ្នកប្រកបការស្តាប់ធម៌ដោយបទដំបូង ប្រកបការទ្រទ្រង់ចាំទុក និង ការពិចារណាធម៌ដែលបានស្តាប់ហើយដោយពាក្យក្រោយ ។ ម្យ៉ាងទៀត លោកសម្តែងថា ព្រះធម៌នេះដល់ព្រមដោយព្យញ្ជនៈដោយពាក្យ

ដំបូង ព្រោះដូច្នោះ ទើបជាវត្ថុគួរស្តាប់ ហើយលោកសម្តែងថា ព្រះធម៌ នេះ ដល់ព្រមដោយអត្ថដោយពាក្យក្រោយ ព្រោះដូច្នោះ ទើបជាវត្ថុដែល គប្បីយកចិត្តទុកដាក់ ។

ម្យ៉ាងទៀត ព្រោះយកបទថា **សាធុក** មកប្រកបចូលទុករួមគ្នាជាពីរ បទ បណ្ឌិតគប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ព្រោះហេតុដែលព្រះធម៌ នេះ ជាធម៌ដ៏ជ្រាលជ្រៅ និង ជាទេសនាដ៏ជ្រាលជ្រៅ ដូច្នោះ អ្នកទាំងទឡាយ ចូរស្តាប់ឱ្យបានល្អ ។ ព្រោះហេតុដែលព្រះធម៌នេះ មានអត្ថដ៏ជ្រាលជ្រៅ និង មានបដិវេធដ៏ជ្រាលជ្រៅ ដូច្នោះ អ្នកទាំងទឡាយចូរយកចិត្តទុកដាក់ឱ្យ បានល្អ ដូច្នេះ ។

បទថា **ភាសិស្សាមិ** ប្រែថា តថាគតនឹងសម្តែង គឺ នឹងសម្តែង ទេសនាដែលប្រកាសទុកក្នុងពាក្យនេះថា អ្នកទាំងទឡាយចូរស្តាប់រឿងនោះដោយ មិនរួញរាចុះ ។ ប្រការមួយទៀត នឹងមានអធិប្បាយទុកថា តថាគតនឹង ពោលរឿងនោះ សូម្បីដោយពិស្តារ ដូច្នេះ ។ ពិតណាស់ បទទាំងនេះ បញ្ជាក់អត្ថន័យដោយសេចក្តីខ្លី និង ពិស្តារ ។ សមដូចព្រះវង្គីសត្ថេរពោល ទុកថា ៖

**លោកនឹងសម្តែងសង្ខេបក៏ដោយ នឹងពោលដោយពិស្តារ**

**ក៏ដោយ សំឡេងមិនកងរំពងដូចសត្វសារិកា តែក៏សម្តែង**

**ប្រកបដោយបដិភាណ ដូច្នេះ ។**

កាលបើត្រាស់យ៉ាងនេះហើយ ភិក្ខុទាំងនោះឯង កើតមានឧស្សាហៈទទួលព្រះពុទ្ធតម្រាស់ អធិប្បាយថា ទទួលយក គឺ កាន់យកព្រះតម្រាស់របស់ព្រះសាស្តាថា ព្រះករុណា ព្រះអង្គ ។

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ពាក្យនេះ គឺ ទ្រង់បានត្រាស់ព្រះសូត្រទាំងអស់នេះ គឺ នឹងត្រូវពោលតទៅនេះ មានជាដើមថា **ឥធ ភិក្ខវេ** ដូច្នេះ ។ បទថា **ឥធ** ក្នុងពាក្យថា **ឥធ ភិក្ខវេ** នោះ ជានិបាតប្រើក្នុងការអាងដល់ស្ថានទី(ទីកន្លែង)ក្នុងទីកន្លែងខ្លះព្រះអង្គ ត្រាស់សំដៅយក **លោក** ។ សមដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា ព្រះតថាគតរមែងកើតទេឡើងក្នុងលោកនេះ ដូច្នេះ ។ ក្នុងកន្លែងខ្លះ ព្រះអង្គ ពោលសំដៅយក **សាសនា** ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាល ភិក្ខុទាំងទឡាយ សមណៈ ( ទី ១ ) ក្នុងព្រះសាសនានេះឯង មានសមណៈ ទី ២ ក្នុងព្រះសាសនានេះនៅមាន ដូច្នេះ ។ ក្នុងទីកន្លែងខ្លះ លោកពោលសំដៅយកឱកាស ដូចលោកពោលទុកថា ÷

**ម្នាលមិត្តរូមទុក្ខ កាលយើងកើតជាទេវតា**

**ក្នុងឱកាសនេះនោះឯង យើងបានទទួលអាយុ**

**បន្ថែមទៀត លោកចូរជ្រាបយ៉ាងនេះ ដូច្នោះ ។**

ក្នុងកន្លែងខ្លះ លោកពោលសំដៅយកត្រឹមតែធ្វើឱ្យពេញបទប៉ុណ្ណោះ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ក៏តថាគតបរិភោគស្រេចហើយ ហាមភត្តហើយ ដូច្នេះ ។ ប៉ុន្តែក្នុងទីនេះគួរជ្រាបថា លោកពោលសំដៅយក **លោក** ដូច្នេះ ។

បទថា **ឥធ ភិក្ខវេ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងទឡាយមកទៀត ដើម្បីទ្រង់បានសម្ដែងទេសនាតាមដែលទ្រង់បានសច្ចាបដិញ្ញាណទុក ។ សូម្បីដោយបទទាំងពីរ លោកពោលអធិប្បាយទុកថា ម្នាលភិក្ខុទាំងទឡាយ ក្នុងលោកនេះ ដូច្នេះ ។

## អត្ថន័យនៃពាក្យថា បុថុជ្ជន

ក្នុងបទថា **អស្សុត្វា បុថុជ្ជនោ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ÷

បុថុជ្ជនឈ្មោះថា **ញេយ្យ** ព្រោះមិនមានអាគម ឈ្មោះថា **អស្សុត្វា** ព្រោះមិនមានអធិគម ។ អធិប្បាយថា បុថុជ្ជនណាឈ្មោះថា មិនមានអាគមដែលកម្ចាត់សេចក្ដីមិនដឹង ព្រោះមិនដឹងហេតុដែលវៀរចាកការរៀន ការសាកសួរ និង ការវិនិច្ឆ័យក្នុង ខន្ធ អាយតនៈ ធាតុ សច្ចៈ បច្ចយាការ

និង សតិប្បដ្ឋានជាដើម ។ ឈ្មោះថា មិនមានអធិគម ព្រោះមិនបានសម្រេចធម៌ដែលគួរឃើញដោយការបដិបត្តិ បុថុជ្ជននោះទើបឈ្មោះថា **ញេយ្យ** ព្រោះមិនមានអាគម ឈ្មោះថា **អស្សុត្វា** ព្រោះមិនមានអធិគម ។

ជននេះនោះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងទឡាយ

**មានការញ៉ាំងកិលេសដ៏ក្រាស់ឱ្យកើតជាដើម ម្យ៉ាងទៀត**

**ជននេះ ឈ្មោះថា ក្រាស់ ( បុថុ ) ព្រោះនៅចុះកាន់**

**កិលេសដ៏ក្រាស់ ។**

ពិតណាស់ ជននោះឈ្មោះថា **បុថុជ្ជន** ព្រោះហេតុទាំងទឡាយមានជាអាទ×គឺ ញ៉ាំងកិលេសជាដើមដ៏ក្រាស់មានប្រការផ្សេង ៗ ឱ្យកើត ។ សមដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា ជនទាំងទឡាយឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ញ៉ាំងកិលេសដ៏ក្រាស់ឱ្យកើត , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ត្រូវសក្កាយទិដ្ឋិបៀតបៀនខ្លាំង , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ត្រូវរង់ចាំមើលព្រះសាស្តារឿយ ៗ , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា នៅមិនទាន់រួចផុតពីគតិទាំងពួងដែលក្រាស់ណែន , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា តាក់តែងគ្រឿងតាក់តែងផ្សេង ៗ ជាច្រើន , ឈ្មោះថា **បុថុជ្ជន** ត្រូវឱឃៈផ្សេង ៗ ជាច្រើនគួចយកទៅ , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ក្តៅក្រហាយដោយសេចក្តីក្រហល់ក្រហាយផ្សេង ៗ ជាច្រើន , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា

យើងក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយផ្សេង ៗ ជាច្រើន , ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា រីករាយ ជាប់ចិត្ត ងប់ងុល ស្រទន់ស្រឡាញ់ វង្វេង ទាក់ទាម ជិតដិត ក្នុងកាមគុណ ៥ ជាខ្លាំង ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ត្រូវនីវរណៈ ៥ រួបរឹត គ្របដណ្តប់ បិទបាំង គ្របសង្កត់ទុកជាច្រើន , ម្យ៉ាងទៀត ឈ្មោះ ថា **បុថុជ្ជន** ព្រោះនៅក្នុងក្រុមជនអ្នកមានធម្មចរិយាថោកទាប អ្នកបែរមុខចេញពីអរិយធម៌ មានចំនួនច្រើនរាប់មិនអស់ ដែលបែរមុខចេញពីអរិយធម៌ ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជននេះដល់ការរាប់ថា ចែកផ្សេងដោយឡែក គឺ មិនទាក់ទងនឹងព្រះអរិយទាំងឡាយ ។ អ្នកប្រកបដោយគុណ មានសីល និង សុតៈជាដើម ។ ដោយពីរបទថា **អស្សុតវា បុថុជ្ជនោ** នេះ ដូចពោលមកនេះ ។

**ក្នុងបណ្តាបុថុជ្ជន ២ ជំពូកដែលព្រះសម្ពុទ្ធជាម្ចាស់មានផៅពង្ស ដូចព្រះអាទិត្យបានត្រាស់ទុក គឺ អន្ធបុថុជ្ជនពួកមួយកល្យាណ-បុថុជ្ជនពួកមួយ គប្បីជ្រាបថា លោកពោលសំដៅដល់អន្ធបុថុជ្ជន ។**

## អរិយ - សប្បុរស

ពាក្យថា **អរិយ** ក្នុងពាក្យជាដើមថា **អរិយានំ អទស្សាវី** លោកពោលសំដៅយក ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និង ព្រះពុទ្ធសាវក ព្រោះ

ជាអ្នកឆ្ងាយចាកកិលេស មិនដើរទៅក្នុងផ្លូវវិនាស ដើរទៅក្នុងផ្លូវចម្រើន និងដែលមនុស្សលោកព្រមទាំងទេវលោកគួរគប្បីដើរតាម ។

ម្យ៉ាងទៀត ព្រះអរិយៈក្នុងទីនេះ ក៏គឺ ព្រះពុទ្ធជាម្ចាស់នោះឯង ។ សមដូចព្រះសម្ពុទ្ធត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ តថាគតហៅថា អរិយៈក្នុងលោកព្រមទាំងទេវលោក ។ល។ ។

ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធជាម្ចាស់ និង ព្រះសាវករបស់តថាគតជា ម្ចាស់គប្បីជ្រាបថា សប្បុរស ។ ក្នុងពាក្យថា **សប្បុរិសា**នេះ ។ ពិតណាស់ព្រះបច្ចេកពុទ្ធជាដើមទាំងនោះ ឈ្មោះថា សោភណបុរស ព្រោះប្រកបដោយគុណជាលោកុត្តរ ព្រោះហេតុនោះ ទើបឈ្មោះថា **សប្បុរស** ។ ម្យ៉ាង ទៀត សប្បុរសទាំងនោះទាំងអស់ លោកពោលចែកចេញជា ២ ពួក ។ ពិតហើយព្រះពុទ្ធជាម្ចាស់ទាំងទឡាយក្តី ព្រះបច្ចេកពុទ្ធក្តី និង ព្រះពុទ្ធសាវកក្តីទាំងជាព្រះអរិយៈ និង សប្បុរស សមដូចដែលលោកពោលទុកថា ÷

**បុគ្គលណាជាអ្នកប្រាជ្ញ ជាកតញ្ញូកតវេទី ជាកល្យាណមិត្ត**
**មានភក្តីមាំទាំ ធ្វើការជួយសង្គ្រោះអ្នករងទុក្ខលំបាកដោយ**
**សេចក្តីពេញចិត្ត បណ្ឌិតទាំងទឡាយហៅអ្នកនោះថា ជា**
**សប្បុរស ដូច្នេះ ។**

ពិតណាស់ ដោយមានពាក្យប្រមាណប៉ុណ្ណេះថា **កល្យាណមិត្តោ ទទឡ្ហភត្តិ ច ហោតិ** ដូច្នេះ លោកពោលសំដៅយកព្រះពុទ្ធសាវក ដោយពាក្យថា **កតញ្ញុតា** ជាដើម លោកពោលសំដៅយកព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះពុទ្ធជាម្ចាស់ ដូច្នេះឯង ។

ឥឡូវនេះ អ្នកណាមានប្រក្រតីមិនឃើញព្រះអរិយទាំងនោះ និង មិនត្រេកអរក្នុងការឃើញ អ្នកនោះគប្បីជ្រាបថា មានប្រក្រតីមិនឃើញព្រះអរិយជាម្ចាស់ទាំងទឡាយ ដូច្នេះ ។ ហើយការឃើញនោះចែកចេញជា ២ គឺ មិនឃើញដោយភ្នែក ១ មិនឃើញដោយញាណ ១ ។ ក្នុង ២ យ៉ាងនោះ ការមិនឃើញដោយញាណ លោកប្រាថ្នាយកក្នុងទីនេះ ។

ពិតណាស់ ព្រះអរិយទាំងទឡាយ សូម្បីបុគ្គលនឹងឃើញដោយមំសចក្ខុ ឬទិព្វចក្ខុ ក៏មិនទាន់ឈ្មោះថា បានឃើញ ព្រោះចក្ខុទាំងនោះទទួលយកត្រឹមតែឧបាទាយរូប មិនមែនកាន់យកភាពជាព្រះអរិយជាអារម្មណ៍ ។ ម្យ៉ាងទៀត សូម្បីឆ្កែស្រុក ឆ្កែព្រៃជាដើម រមែងឃើញព្រះអរិយទាំងទឡាយដោយចក្ខុ តែថាឆ្កែស្រុកជាដើមទាំងនោះនឹងឈ្មោះថា បានឃើញព្រះអរិយទាំងទឡាយ ក៏ទេ ។ ក្នុងសេចក្ដីនេះ មានរឿងនេះជាឧទាហរណ៍÷

## នៅជាមួយព្រះអរិយ ប៉ុន្តែមិនស្គាល់ព្រះអរិយ

ដូចបានស្តាប់មក ឧបដ្ឋាករបស់ព្រះថេរៈដែលជាខីណាស្រពនៅក្នុង **ចិត្តលតាបពិត** ។ បួសពេលចាស់ ។ នៅថ្ងៃមួយ ទៅបិណ្ឌបាតជាមួយនឹងព្រះថេរៈ ទទួលយកបាត្រ ចីវររបស់ព្រះថេរៈដើរតាមក្រោយមក សួរព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចម្រើន បុគ្គលដូចម្តេចឈ្មោះថា ព្រះអរិយៈ ព្រះថេរៈឆ្លើយថា បុគ្គលខ្លះក្នុងលោកនេះ ជាមនុស្សចាស់ ទទួលយកបាត្រ និងចីវររបស់ព្រះថេរៈ ធ្វើវត្តបដិបត្តិ សូម្បីទៅជាមួយព្រះអរិយៈ ក៏រមែងមិនស្គាល់ព្រះអរិយៈ ញោម ព្រះអរិយទាំងទឡាយដឹងបានដោយលំបាកយ៉ាងនេះ ដូច្នេះ ។ សូម្បីព្រះថេរៈ មានថេរដីកាយ៉ាងនេះ ឧបដ្ឋាកនោះក៏នៅមិនដឹង ។

ព្រោះដូច្នោះ ការឃើញដោយចក្ខុ មិនឈ្មោះថាឃើញ ។ ការឃើញដោយញាណប៉ុណ្ណោះ ឈ្មោះថា ឃើញ ។ សមដូចព្រះសម្ពុទ្ធត្រាស់ទុកថា **ម្នាលវក្កលិ** ប្រយោជន៍អ្វីដោយកាយដែលស្អុយរលួយនេះ ដែលអ្នកឃើញហើយ ។ ម្នាលវក្កលិ អ្នកណាឃើញព្រះធម៌ អ្នកនោះឈ្មោះថា ឃើញព្រះតថាគត ដូច្នេះ ។

ព្រោះដូច្នោះ បុគ្គលសូម្បីឃើញ (នូវព្រះអរិយៈ) ដោយចក្ខុ តែ

មិនឃើញអនិច្ចលក្ខណៈជាដើម ដែលព្រះអរិយជាម្ចាស់ទាំងទឡាយបានឃើញហើយដោយញាណ និង មិនសម្រេចធម៌ ដែលព្រះអរិយជាម្ចាស់បានសម្រេចហើយ គប្បីជ្រាបថា មិនឃើញព្រះអរិយជាម្ចាស់ទាំងទឡាយ ព្រោះធម៌ដែលធ្វើឱ្យជាព្រះអរិយៈ និង ភាពជាព្រះអរិយៈដែលបុគ្គលនោះ នៅមិនទាន់បានឃើញដូច្នេះ ។

ពីរបទថា **អរិយធម្មស្ស អកោវិទោ** សេចក្តីថា មិនឆ្លាតឈ្លាសក្នុងព្រះអរិយធម៌ ដែលចែកចេញជាសតិប្បដ្ឋានជាដើម ។

**ក៏ដែលឈ្មោះថា វិន័យ មាន ២ យ៉ាង តែក្នុងវិន័យមួយ ៗ នោះមាន ៥ ព្រោះការមិនមានវិន័យទាំង ២ នោះ នេះលោកហៅថា អវិនីត ក្នុងពាក្យថា អរិយធម្មេ អវិនីតោ នេះ ។**

## វិន័យ ២ យ៉ាង

ពិតណាស់ វិន័យនេះមាន ២ យ៉ាង គឺ ÷ **សំវរវិនយ ១ បហានវិនយ ១** ។ វិន័យមួយ ៗ ក្នុងវិន័យសូម្បីទាំង ២ នេះ ចែក ចេញជា ៥ ។ ពិតណាស់ សូម្បី **សំវរវិន័យ** មាន ៥ គឺ **សីលសំវរ សតិសំវរ ញាណសំវរ ខន្តិសំវរ** និង **វិរិយសំវរ** ។ សូម្បី **បហានសំវរ**

ក៏មាន ៥យ៉ាងដូចគ្នា គឺ **តទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិបស្សទ្ធិប្បហាន** និង **និស្សរណប្បហាន** ។

សំវរវិន័យទាំង ៥ នោះ សំវរដែលត្រាស់ទុកថា ភិក្ខុចូលដល់ការសង្រួមក្នុងបាតិមោក្ខ សំវរនេះ ហៅថា **សីលសំវរ** ។

សំវរដែលត្រាស់ទុកថា ភិក្ខុរមែងរក្សាចក្ខុន្ទ្រិយ៍ គឺ ដល់ការសង្រួមក្នុងចក្ខុន្ទ្រិយ៍ នេះហៅថា **សតិសំវរ** ។

សំវរដែលត្រាស់ទុកថា ÷

> **ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលអជិតៈ ក្រសែ**
>
> **( តណ្ហា ) ឯណា ក្នុងលោកនេះមាន សតិរមែង**
>
> **ជាគ្រឿងហាមក្រសែទាំងនោះ តថាគតពោលសតិថា**
>
> **ជាគ្រឿងរាំងក្រសែទាំងទឡាយ ក្រសែទាំងនោះដែល**
>
> **បុគ្គលរមែងលះបង់ដោយបញ្ញា ។**

នេះហៅថា **ញាណសំវរ** ។

សំវរដែលត្រាស់ទុកថា ភិក្ខុ រមែងអត់ធន់ចំពោះភាពត្រជាក់ និង ក្តៅ នេះហៅថា **ខន្តិសំវរ** ។

សំវរដែលត្រាស់ទុកថា ភិក្ខុ រមែងកំចាត់បង់នូវកាមវិតក្កដែលកើត

ទេឡើងហើយបាន នេះហៅថា **វីរិយសំវរ** ។

ម្យ៉ាងទៀត សំវរនេះ សូម្បីទាំងអស់ លោកហៅថា **សំវរ** ព្រោះជាគ្រឿងរាំងកាយទុច្ចរិត និង វចីទុច្ចរិតជាដើម ដែលខ្លួនត្រូវរាំងតាមតួនាទីរបស់ខ្លួន និង ហៅថា **វិនយ** ព្រោះជាគ្រឿងកម្ចាត់បង់នូវកាយទុច្ចរិត និង វចីទុច្ចរិតជាដើម ដែលខ្លួនត្រូវកម្ចាត់បង់តាមមុខនាទីរបស់ខ្លួន ។ សំវរវិន័យគប្បីជ្រាបថា ចែកចេញជា ៥ ដូចអធិប្បាយមកនេះឯង ។

## បហាន ៥

ម្យ៉ាងទៀត ការលះបង់អង្គនោះៗ រមែងមានដោយវិបស្សនាញាណ នោះៗ ព្រោះជាបដិបក្ខនឹងវិបស្សនា មាននាមរូបបរិច្ឆេទញាណជាដើម ដូចការកម្ចាត់ភាពងងឹត ព្រោះពន្លឺនៃប្រទីប ដូច្នោះ ។ គឺ លះបង់សក្កាយទិដ្ឋិដោយការកំណត់នាមរូប , លះបង់ទិដ្ឋិដែលមិនមានហេតុ និង មានហេតុមិនស្មើគ្នាដោយការកំណត់បច្ច័យ , លះបង់សេចក្តីសង្ស័យ ដោយការឆ្លងសេចក្តីសង្ស័យ ដែលជាចំណែកខាងក្រោយនៃការកំណត់បច្ច័យនោះឯង , លះបង់សេចក្តីប្រកាន់ថា យើង របស់យើង ដោយការពិចារណាកលាបៈ ( ក្រុម_កង ) , លះបង់សញ្ញាក្នុងធម៌ដែលមិនមែនជាមគ្គថា មគ្គ ដោយការកំណត់មគ្គ និង អមគ្គ , លះបង់ឧច្ឆេទទិដ្ឋិដោយការឃើញការកើតទេឡើង ,

លះបង់សស្សតទិដ្ឋិដោយការពិចារណាឃើញសេចក្តីវិនាស ។ លះបង់សេចក្តីសម្គាល់ថា មិនគួរខ្លាចក្នុងរបស់ដែលគួរខ្លាច ដោយការពិចារណាឃើញភ័យ , លះបង់សេចក្តីសម្គាល់ថា ពេញចិត្ត (ត្រេកអរ ) ដោយការពិចារណាឃើញទោស , លះបង់អភិរតិសញ្ញា (ការសម្គាល់ថា គួរត្រេកអរក្រៃលែង) ដោយនិព្វិទានុបស្សនា , លះបង់ភាពជាអ្នកមិនប្រាថ្នានឹងរួចផុត ដោយញាណ គឺភាពជាអ្នកប្រាថ្នានឹងផុតស្រទប្បះ , លះបង់ការមិនសម្លឹងដោយឧបេក្ខាញាណ , លះបង់បដិលោមក្នុងធម្មដ្ឋិតិ និង ក្នុងព្រះនិព្វាន ដោយអនុលោមញ្ញាណ , លះបង់សេចក្តីប្រកាន់និមិត្តក្នុងសង្ខារ ដោយគោត្រភូញាណ ទាំងនេះឈ្មោះ ថា **តទង្គប្បហាន** ។

ម្យ៉ាងទៀត ការលះបង់នីវរណធម៌ ជាដើមនោះ ៗ ដោយសមាធិចែកចេញជា ឧបចារសមាធិ ព្រោះហាមការប្រព្រឹត្តិទៅ (នៃនីវរណៈ ) ដូចការវែកសារាយលើផ្ទៃទឹកដោយប្រើឆ្នាំងវែក ដូច្នោះ នេះឈ្មោះថា **វិក្ខម្ភនប្បហាន** ។

ចំណែកការលះបង់កងកិលេស ក្នុងសន្តានរបស់ខ្លួនដែលរាប់បញ្ចូលក្នុងសមុទយៈ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យជាដើមថា ដើម្បីលះបង់ទិដ្ឋិទាំងទឡាយព្រមទាំងកងកិលេសនោះ ត្រូវឡប់ប្រព្រឹត្តទៅមិនបានទៀតយ៉ាង

ដាច់ខាតនៃព្រះយោគាវចរអ្នកឈ្មោះថា មានមគ្គនោះ ព្រោះហេតុដែលចម្រើនអរិយមគ្គ ៤ បានហើយ នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។

ម្យ៉ាងទៀត ការដែលកិលេសទាំងទឡាយស្ងប់រំងាប់ទៅក្នុងខណៈនៃផលនេះឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។ ព្រះនិព្វានដែលឈ្មោះថា លះបង់គ្រឿងតាក់តែងទាំងពួងបាន ព្រោះរលាស់ចោលគ្រឿងតាក់តែងទាំងពួងហើយនេះឈ្មោះថា **និស្សរណប្បហាន** ។

ម្យ៉ាងទៀត ព្រោះហេតុនៃការលះបង់ទាំងអស់នោះ ឈ្មោះថា បហានៈដោយអត្ថថា **លះ** ឈ្មោះថា វិន័យ ដោយអត្ថថា **កម្ចាត់** ដូច្នោះ លោកទើបហៅថា **បហានវិនយ** ។ ម្យ៉ាងទៀត ព្រោះការលះបង់កិលេសនោះ ផងព្រោះធ្វើឱ្យកើតមានការកម្ចាត់ (កិលេស) នោះៗ ដោយការលះបង់ទាំងអស់នោះ លោកហៅថា **បហានវិនយ** ។ សូម្បីបហានវិន័យ គប្បីជ្រាបថា ចែកចេញជា ៥ ប្រការ ដោយប្រការដូច្នេះ ។

វិន័យនេះ ដោយសង្ខេបមាន ២ និងដោយការចែកមាន ១០ ដូចបានពណ៌នាមកដូច្នេះ ។ ព្រោះហេតុដែលបុថុជ្ជនអ្នកមិនបានស្តាប់នោះមិនមានវិន័យទាំង ២ នោះ ដូច្នេះ បុថុជ្ជននេះ ព្រះមានព្រះភាគទើបត្រាស់ហៅថា **អវិនីត** ( អ្នកមិនមានវិន័យ ) ព្រោះខូះសំវរ និង ព្រោះនៅមិនទាន់លះបង់

បហាតព្វធម៌បាន ។

ក្នុងសេចក្តីថា **សប្បុរិសានំ អទស្សាវី** (មិនបានឃើញសប្បុរស) **សប្បុរិសធម្មស្ស អកោវិទោ** (មិនឈ្លាសក្នុងធម៌របស់សប្បុរស) **សប្បុ-រិសធម្មេអវិនីតោ** (មិនបានទូន្មានខ្លួនក្នុងធម៌របស់សប្បុរស) នេះ ក៏មានន័យដូចគ្នា ។

ក៏ក្នុងសេចក្តីនេះ ដោយន័យ មិនប្លែកគ្នាទេឡើយ ។ សមដូចដែលលោកសម្តែងទុកថា ព្រះអរិយៈ ក៏គឺ សប្បុរស , សប្បុរស ក៏គឺ ព្រះអរិយៈ ធម៌របស់សប្បុរស ក៏គឺ ធម៌របស់ព្រះអរិយៈ , វិន័យរបស់ព្រះអរិយៈ ក៏គឺ វិន័យរបស់សប្បុរស , វិន័យរបស់សប្បុរស ក៏គឺ វិន័យរបស់ព្រះអរិយៈ ។ ស័ព្ទថា **អរិយេ** ឬ **សប្បុរិសេ** ក្តី **អរិយធម្មេ** ឬ **សប្បុរិសធម្មេ** ក្តី **អរិយវិនិយេ** ឬ **សប្បុរិសវិនិយេ** ក្តី (ទាំងអស់) នោះក៏ដូចគ្នា មានអត្ថន័យដូចគ្នា ស្មើ គ្នា មានតម្លៃស្មើ កំណើតតែមួយដូចគ្នាទាំងអស់ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែង **សព្វធម្មមូលបរិយាយសូត្រ** ដល់ពួកអ្នក តែទ្រង់មិនសម្តែងសូត្រនោះ ទ្រង់ត្រទឡប់ជាសម្តែងបង្ហាញដល់បុថុជ្ជនយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ មិនបានស្តាប់ មិនបានឃើញ

ព្រះអរិយៈទាំងទឡ្យាយ ដូច្នេះ ។

ឆ្លើយថា ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអត្ថន័យនោះ ដោយធម្មទេសនាដែលជាបុគ្គលាធិដ្ឋាន ដូច្នេះ ។

## ទេសនា ៤ ប្រការ

ពិតណាស់ ការទេសនារបស់ព្រះមានព្រះភាគ លំដាប់ដំបូងមាន ៤ ប្រការ ដោយអំណាចធម៌ និង បុគ្គលនោះឯង គឺ ធម៌ទេសនាដែលលើកយកព្រះធម៌ជាទីតាំង (ធម្មាធិដ្ឋាន ) , បុគ្គលទេសនា ដែលលើកយកព្រះធម៌ជាទីតាំង (ធម្មាធិដ្ឋាន ) , បុគ្គលទេសនា ដែលលើកយកបុគ្គលជាទីតាំង (បុគ្គលាធិដ្ឋាន) និង ព្រះធម៌ទេសនាលើកបុគ្គលជាទីតាំង(បុគ្គលាធិដ្ឋាន)។

បណ្ដាទេសនា ៤ ប្រការនោះ ទេសនាបែបនេះថា ម្នាលភិក្ខុទាំង-ទឡ្យាយ វេទនា ៣ ពួកនេះ, វេទនា ៣ អ្វីខ្លះ គឺ សុខវេទនា ទុក្ខវេទនា និង អទុក្ខមសុខវេទនា ម្នាលភិក្ខុទាំងទឡ្យាយ វេទនាទាំង ៣ ពួកនេះឯង គប្បីជ្រាបថា ឈ្មោះថា ធម៌ទេសនាដែលជា **ធម្មាធិដ្ឋាន** ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងទឡ្យាយ បុរសនេះមានធាតុ ៦ មានផស្សាយតនៈ ៦ មានមនោបវិចារៈ ១៨ មានអធិដ្ឋានធម៌ ៤ គប្បីជ្រាប ថា ឈ្មោះថា បុគ្គលទេសនាដែលជា **ធម្មាធិដ្ឋាន** ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងទឡាយ សប្បុរសបុគ្គល ៣ ពួកនេះ មាននៅក្នុងលោក ។ ៣ ពួកអ្វីខ្លះ ? គឺ ខ្វាក់ , មានភ្នែកតែម្ខាង និង មានភ្នែកសងខាង ។ ម្នាលភិក្ខុទាំងទឡាយ ក៏បុគ្គលខ្វាក់ ដូចម្ដេច ? គប្បី ជ្រាបថា ឈ្មោះថា បុគ្គលទេសនាដែលជា **បុគ្គលាធិដ្ឋាន** ។

ទេសនាបែបនេះថា ម្នាលភិក្ខុទាំងទឡាយ ក៏ភ័យក្នុងទុគ្គតិដូចម្ដេច ? ម្នាលភិក្ខុទាំងទឡាយ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញថា កាយទុច្ចរិតនោះ ឯងនឹងមានវិបាកដ៏លាមក អភិសម្បរាយភព ។ល។ រមែងបរិហារខ្លួនដ៏ស្អាត ម្នាលភិក្ខុទាំងទឡាយ នេះហៅថា ភ័យក្នុងទុគ្គតិ គប្បីជ្រាបថា ឈ្មោះថា ធម៌ទេសនាដែលជា **បុគ្គលាធិដ្ឋាន** ។

គប្បីជ្រាបអត្ថាធិប្បាយក្នុងទីនេះ ព្រះមានព្រះភាគនោះ ដើម្បីនឹងទ្រង់ សម្ដែងដល់បុថុជ្ជន អធិប្បាយសេចក្ដីនៃទេសនាដែលជាបុគ្គលាធិដ្ឋានឱ្យច្បាស់ ទើបទ្រង់សម្ដែងបង្ហាញដល់បុថុជ្ជនយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡាយ បុថុជ្ជន ក្នុងលោកនេះ មិនបានស្ដាប់ មិនបានឃើញព្រះអរិយៈជាម្ចាស់ទាំងទឡាយ ព្រោះហេតុតែបុថុជ្ជនមិនបានកំណត់ដឹងខន្ធ និង ការសម្គាល់ដែលជាឫសគល់ របស់ធម៌ទាំងពួងដែលទ្រង់បំណងយកក្នុងទីនេះ ក៏មានការមិនកំណត់ដឹងជា ឫសគល់ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងអំពីបុថុជ្ជនយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់នឹងសម្តែងសេចក្តីសម្គាល់ក្នុងវត្ថុទាំងឡាយមាន **បឋវី** (ផែនដី ) ជាដើម ដែលឱ្យកើតធម៌ដែលរាប់បញ្ចូលក្នុងសក្កាយទិដ្ឋិទាំងអស់របស់បុថុជ្ជននោះ ទើបត្រាស់ពាក្យជាដើមថា **បឋវឹ បឋវិតោ** ដូច្នេះ ។

## បឋវី ៤ យ៉ាង

ក្នុងពាក្យថា **បឋវឹ បឋវិតោ** នោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ÷

បឋវីធាតុមាន ៤ យ៉ាង គឺ **លក្ខណបឋវី** ១ **សសម្ភារបឋវី** ១ **អារម្មណបឋវី** ១ និង **សម្មតិបឋវី** ១ ។

ក្នុងបឋវី ៤ យ៉ាងនោះ បឋវីដែលលោកពោលទុកក្នុងប្រយោគជាដើម ថា ម្នាលអ្នកដ៏មានអាយុ ក៏បឋវីធាតុខាងក្នុង ដូចម្តេច ? បានដល់ វត្ថុ ដែលរឹង (ជាលក្ខណៈ) ចំពោះខ្លួន នៅក្នុងខ្លួននោះឯង ឈ្មោះថា **លក្ខ- ណបឋវី** ។

បឋវីធាតុ ដែលលោកពោលទុកក្នុងប្រយោគជាដើមថា ភិក្ខុជីកខ្លួនឯងក្តី ឱ្យអ្នកដទៃជីកក្តី នូវផែនដី ដូច្នេះ ឈ្មោះថា **សសម្ភារបឋវី** ។

ម្យ៉ាងទៀត បឋវីធាតុ គឺ កោដ្ឋាសៈ (ចំណែក) ២០ មានសក់ ជាដើម និង វត្ថុខាងក្រៅមានដែក និង លោហៈជាដើម ព្រមទាំងគុណសម្បត្តិ

មានពណ៌ជាដើម រួមហៅថា **សសម្ភារបឋវី** ។

ចំណែកបឋវីធាតុ មកក្នុងប្រយោគជាដើមថា មនុស្សម្នាក់ដឹងច្បាស់បឋវីកសិណ ហៅថា **អារម្មណបឋវី** ។ លោកខ្លះហៅថា **និមិត្តបឋវី** ។

បឋវីធាតុ ដែលថា បុគ្គលបានឈាន មានបឋវីកសិណជាអារម្មណ៍ កើតក្នុងទេវលោក រមែងបាននាមថា បឋវីទេវតា ដោយអំណាចបឋវីកសិណជាហេតុឱ្យមក (កើត) នេះ គប្បីជ្រាបថា **សម្មតិបឋវី** ។

ក្នុងអធិការនេះ រមែងបានបឋវី សូម្បីទាំងអស់នោះ ។ បុថុជ្ជននេះរមែងសម្គាល់នូវបឋវីណាមួយក្នុងបណ្តាបឋវីទាំងនោះ ។ ដោយជាបឋវី រមែងសម្គាល់នូវបឋវីថា ជាបឋវីពិត រមែងដឹងដោយចំណែកនៃបឋវី លុះកាន់យកតាមវោហាររបស់លោកហើយ រមែងរាប់អានដោយសញ្ញាវិបល្លាសថា ជាបឋវីកាលកំណត់ចំណែកនៃបឋវីមិនបានយ៉ាងនេះឯង ។ រមែងប្រកាន់ចំណែកនៃបឋវីនោះដោយន័យជាដើមថា សត្វ ឬថា របស់សត្វ ។ ព្រោះហេតុអ្វី លោកទើបមិនគួរពោលទុកថា **ឯវំ សញ្ជានាតិ** ។ ព្រោះថា បុថុជ្ជនដូចជាមនុស្សឆ្កួត ។ គេរមែងប្រកាន់វត្ថុណាមួយ ដោយអាការយ៉ាងណាមួយ ។

ម្យ៉ាងទៀត ហេតុដែលផ្សេងដោយភាពជាអ្នកមិនបានឃើញព្រះអរិយៈទាំងឡាយជាដើមនោះឯង ចាត់ជាហេតុក្នុងការសម្គាល់នេះ ដែលព្រះមាន-

ព្រះភាគកាលនឹងត្រាស់ថា **អបរិញ្ញាតំ តស្ស** ខាងមុខក៏ជាការត្រាស់ទុកហើយ ។

បទថា **បឋវិំ បឋវិតោ សញ្ញត្វា** សេចក្តីថា បុថុជ្ជននោះ សម្គាល់ផែនដីនោះ ដោយសញ្ញាដែលវិបរិតយ៉ាងនេះហើយ តមកក៏រមែងសម្គាល់ គឺកំណត់ឱ្យផ្សេងទៅ បានដល់ ប្រកាន់ដោយប្រការផ្សេង ៗ គឺ ដោយប្រការដទៃ ដោយកិលេសជាគ្រឿងយឺតយូរ គឺ តណ្ហា មានះ និង ទិដ្ឋិដ៏មានកម្លាំង ដែលលោកពោលទុកដោយនាម (រួម) ថា **មញ្ញនា** ក្នុង ទីនេះតាមព្រះបាលីថា ក៏ចំណែកនៃកិលេសដែលជាគ្រឿងយឺតយូរ មានសញ្ញាជាដើមហេតុ ដូច្នេះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **បឋវិំ មញ្ញតិ** ដូច្នេះ ។

ក៏ដើម្បីនឹងទ្រង់សម្តែងសេចក្តីសម្គាល់ទាំងនោះរបស់គេ ដែលសម្គាល់ហើយដូច្នេះ ដោយន័យដ៏ពិស្តារ ព្រះមានព្រះភាគ ទើបត្រាស់បឋវីខាងក្នុង ២០ ប្រភេទ ដោយន័យជាដើមថា **កេសា លោមា** ត្រាស់បឋវីក្នុងគម្ពីរវិភង្គយ៉ាងនេះថា បណ្តាបឋវីធាតុ ២ យ៉ាងនោះ បឋវីធាតុខាងក្រៅ ដូចម្តេច ? គឺ វត្ថុខាងក្រៅដែលរឹងគ្រោតគ្រាត មិនមានចិត្តគ្រប់គ្រង ដូចជា ដែកលោហៈ សំណស សំណខ្មៅ រ៉ែប្រាក់ កែវមុក្តា កែវមណី កែវពៃទូរ្យ ស័ង្ខ

សិលា កែវប្រពាល ប្រាក់ (សម្រាប់ចាយ) មាសរូបវណ្ណៈ កែវក្រហម (ទទឹម ) ពេជ្រភ្នែកឆ្មារ ស្មៅ កំណាត់ឈើ ដុំគ្រួស ខ្សាច់ ក្បឿង ដែនដី ថ្ម ភ្នំ និង គ្រាស់និមិត្តផែនដី ក្នុងវត្ថុអារម្មណ៍ខាងក្នុង លោក សំដៅយក **បឋវី** នោះ ៗ ពោលការប្រកបសេចក្តីនេះទុក ។

បទថា **បឋវី មញ្ញតិ** សេចក្តីថា បុថុជ្ជនរមែងសម្គាល់ថា យើង ជាដី ថា ដីជារបស់យើង ថា បុគ្គលដទៃជាដី ថា ដីជារបស់បុគ្គលដទៃ ដូច្នេះ ដោយការសម្គាល់ ៣ យ៉ាង ។

ម្យ៉ាងទៀត រមែងសម្គាល់បឋវី (ផែនដី ) ខាងក្នុង ដោយការសម្គាល់ ដោយអំណាចតណ្ហា មានះ និង ទិដ្ឋិ ។

សម្គាល់យ៉ាងណា ?

ពិតហើយ បុថុជ្ជននេះ ញ៉ាំងឆន្ទរាគឱ្យកើតទេឡើងក្នុងសក់ជាដើម គឺ ត្រេកអរ ភ្លើតភ្លើន និយាយរឿយ ៗ វង្វេងវង្វាន់ក្នុងសក់ រោម ក្រចក ធ្មេញ ស្បែក ឬ ក៏វត្ថុដែលជាទីតាំងនៃតម្រេកណាមួយ , បុថុជ្ជន រមែងសម្គាល់បឋវី ខាងក្នុង ដោយការសម្គាល់ដែលកើតអំពីអំណាចនៃតណ្ហាយ៉ាងនេះ ។

ឬថា កើតសេចក្តីត្រេកអរក្នុងសក់ជាដើមនោះ ដោយន័យជាដើមថា សក់របស់យើងគប្បីដូច្នេះរហូតទៅ សូមរោមរបស់យើងគប្បីដូច្នេះរហូតទៅ ឬថា

តាំងចិត្តទុក ដើម្បីនឹងបានវត្ថុដែលខ្លួននៅមិនទាន់បាន ដោយន័យជាដើមថា ដោយសីល ឬ ព្រហ្មចារ្យនេះ យើងនឹងមានសក់ខ្មៅរលោងទន់ ដូច្នេះ ។ បុថុជ្ជន រមែងសម្គាល់បឋវីខាងក្នុង ( ផែនដី ) ដោយការសម្គាល់ដោយ អំណាចតណ្ហា ដូចអធិប្បាយមកនេះ ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ (ការដល់ព្រម) ឬ វិបត្តិរបស់ សក់ជាដើមរបស់ខ្លួន ហើយញ៉ាំងមានះឱ្យកើតទេឡើងថា យើងល្អជាង យើង ស្មើគ្នា ឬថា យើងអាក្រក់ជាង ដូចពោលមកនេះឈ្មោះថា សម្គាល់បឋវី ( ផែនដី ) ខាងក្នុង ដោយការសម្គាល់ដែលកើតមកពីអំណាចមានះ ។ ម្យ៉ាង ទៀត រមែងប្រកាន់មាំក្នុងសក់ថា ជាជីវៈ ដោយន័យដែលមានមកហើយថា ជីវៈនុ៎ះ សរីរៈនុ៎ះ ដូច្នេះ ។ ( សូម្បី ) ក្នុងរោមជាដើម ក៏ន័យនេះ ។ បុថុជ្ជន រមែងសម្គាល់បឋវីខាងក្នុង ( ផែនដី ) ដោយការសម្គាល់ដែលកើតមកអំពី អំណាចទិដ្ឋិដូច ពោលមក ។

ម្យ៉ាងទៀត បុថុជ្ជន រមែងប្រកាន់មាំនូវបឋវីដែលផ្សេងដោយសក់ជា ដើម ដោយន័យដែលជាសត្រូវដល់ព្រឹត្តិកម្មនេះថា ម្នាលអាវុសោ ក៏បឋវី_ ធាតុខាងក្នុងណា និង បឋវីធាតុខាងក្រៅណា ក៏បឋវីធាតុ (ទាំងពីរ) នោះ ឈ្មោះថា បឋវីធាតុដូចគ្នា មិនមែនជារបស់យើងថា របស់យើង

យើងជាន៉ុះ ន៉ុះជាអត្តារបស់យើង ឈ្មោះថា រមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដែលកើតមកអំពីអំណាចទិដ្ឋិ សូម្បីយ៉ាងនេះ ។ បុថុជ្ជន រមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ ៣ យ៉ាង ដូចពណ៌នាមកនេះ ។ គប្បីជ្រាបថា រមែងសម្គាល់បឋវីខាងក្រៅ ដូចបឋវីខាងក្នុង ។

យ៉ាងណា ? ពិតហើយ បុថុជ្ជននេះ ញ៉ាំងឆន្ទរាគៈឱ្យកើតទេឡើងក្នុង ដែក និង លោហៈជាដើម រីករាយ និយាយរឿយ ៗ រវេងរវង្វាន់ក្នុងដែក និង លោហៈជាដើម រមែងហួងហែងរក្សា ឃុំគ្រងដែកជាដើមទុក ដោយន័យជាដើមថា ដែករបស់យើង លោហៈរបស់យើង ឈ្មោះថា សម្គាល់បឋវីខាង ក្រៅ ដោយសេចក្តីសម្គាល់ព្រោះអំណាចតណ្ហា ដោយប្រការដូច្នេះ ។ ឬថា បុថុជ្ជន រមែងរីករាយក្នុងបឋវីខាងក្រៅនេះថា សូម្បីដែក និង លោហៈជា ដើមរបស់យើង គប្បីតាំងនៅយ៉ាងនេះរហូតទៅ ឬតាំងចិត្តទុកដើម្បីនឹងបាន វត្ថុដែលនៅមិនទាន់បានថា ដោយសីល ឬ ព្រហ្មចារ្យនេះ យើងនឹងជាអ្នក មានឧបករណ៍ មានដែក និង លោហៈជាដើម ដែលដល់ព្រមហើយ យ៉ាង នេះ ។ បុថុជ្ជន ឈ្មោះថា សម្គាល់បឋវីខាងក្រៅ ដោយសេចក្តីសម្គាល់ ដែលកើតមកពីអំណាចតណ្ហា សូម្បីដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ ឬ វិបត្តិនៃដែក និង លោហៈ

ជាដើម របស់ខ្លួនហើយ កើតមានះទ្បើងថា ដោយឧបករណ៍នេះ យើងទើប ល្អជាងគេ ស្មើគេ ឬ ថោកទាបជាងគេ បុថុជ្ជនឈ្មោះថា រមែងសម្គាល់បឋវី ខាងក្រៅ ដោយសេចក្ដីសម្គាល់ដែលកើតមកពីអំណាចមានះ យ៉ាងនេះ ។

ក៏បុថុជ្ជនជាអ្នកមានការសម្គាល់ក្នុងដែកថា ជីវៈ រមែងប្រកាន់មាំថា នេះជាជីវៈ ។ ន័យក្នុងលោហៈជាដើម ក៏មានន័យនេះ ។ បុថុជ្ជន ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយសេចក្ដីសម្គាល់ដែលកើតមកពីអំណាចទិដ្ឋិ ដោយប្រការដូច្នេះ ។

ប្រការមួយទៀត បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ថា ជាអត្តា គឺថា រមែងប្រកាន់មាំនូវនិមិត្តបឋវីថា អត្តា ដោយន័យដែល លោកពោលទុកក្នុងគម្ពីរបដិសម្ភិទានោះឯងថា បុថុជ្ជន រមែងពិចារណាឃើញ ខ្លឹមសារទាំងពីរ គឺ បឋវីកសិណ និង អង្គអវយវៈថា បឋវីកសិណនោះ ជាយើង យើងជាបឋវីកសិណនោះ ដូច្នេះ ឈ្មោះថា រមែងសម្គាល់បឋវីខាង ក្រៅ ដោយសេចក្ដីសម្គាល់ដែលកើតទេទ្បីងពីអំណាចទិដ្ឋិ ដោយប្រការដូច្នេះ ។

បុថុជ្ជន រមែងសម្គាល់បឋវីសូម្បីចំណែកខាងក្រៅ ដោយសេចក្ដីសម្គាល់ ៣ យ៉ាង ដូចអធិប្បាយមកនេះ ។

ក្នុងពាក្យថា **បឋវី មញ្ញតិ** នេះ គប្បីជ្រាបសេចក្ដីសម្គាល់ទាំង ៣

ដូចពណ៌នាមកនេះសិន ។ តអំពីនេះទៅ ខ្ញុំម្ចាស់នឹងពោលដោយសង្ខេប ប៉ុណ្ណោះ ។ ពាក្យថា **បឋវិយា** នេះ ក្នុងពាក្យថា **បឋវិយា មញ្ញតិ** នេះ ជាសត្តមីវិភត្តិ ។ ព្រោះដូច្នោះ ក្នុងពាក្យនេះមានអធិប្បាយដូច្នេះថា បុថុជ្ជន រមែងសម្គាល់ថា យើងមាននៅក្នុងបឋវី រមែងសម្គាល់ថា សេចក្តី កង្វល់របស់យើងមាននៅក្នុងបឋវី រមែងសម្គាល់ថា បុគ្គលដទៃមាននៅក្នុង បឋវី រមែងសម្គាល់ថា សេចក្តីកង្វល់របស់បុគ្គលដទៃក្នុងបឋវីមានហើយដូច្នេះ ម្យ៉ាងទៀត ន័យនៃខ្លឹមសាររបស់សត្តមីវិភត្តិនោះ ទីណាដែលលោកពោលទុក ថា បុថុជ្ជន រមែងពិចារណាឃើញអត្តាក្នុងរូប យ៉ាងណា ? គឺ បុថុជ្ជនខ្លះ ក្នុងលោកនេះ រមែងពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាអត្តា គេពិចារណាឃើញ អត្តាក្នុងរូបយ៉ាងនេះថា ក៏នេះឯងជាអត្តារបស់យើង អត្តារបស់យើងនេះ នោះឯង មាននៅក្នុងរូបនេះដូច្នេះ ដោយន័យនោះឯង បុថុជ្ជនទើបប្រកាន់យកវេទនាធម៌ជាដើម តពីនោះ ក៏កំណត់យកបឋវីប្រភេទ ណាមួយ ក្នុងបណ្តាបឋវីទាំងខាងក្នុង និង ខាងក្រៅ ដោយភាពជាឱកាសនៃ អត្តានោះ សម្គាល់ថា ក៏អត្តារបស់យើងនេះ នោះឯង មាននៅក្នុងបឋវីនេះ ដូច្នេះ ឈ្មោះថា រមែងសម្គាល់ក្នុងបឋវី ។ នេះឈ្មោះថា សេចក្តីសម្គាល់ ដោយអំណាចទិដ្ឋិរបស់បុថុជ្ជននេះ ។

ក៏កាលបុថុជ្ជននោះ ញ៉ាំងសេចក្ដីស្នេហាក្នុងអត្តា និង មានះ ដែលមានអត្តាជាទីតាំងឱ្យកើតទេឡើងក្នុងរូបនោះឯង គប្បីជ្រាបថា ជាសេចក្ដីសម្គាល់ដោយអំណាចនៃតណ្ហា និង មានះ ។

ប៉ុន្ដែក្នុងកាលណា បុថុជ្ជនរមែងសម្គាល់ដោយន័យនោះឯងថា ក៏អត្តារបស់អ្នកដទៃនោះឯង មាននៅក្នុងបឋវី ក្នុងកាលនោះ ការសម្គាល់នោះកើតមកពីអំណាចនៃការស្ទាបអង្អែលរបស់ទិដ្ឋិនោះឯង ។ ចំណែកសេចក្ដីសម្គាល់សូម្បីក្រៅពីនេះ លោកក៏ប្រាថ្នា (យកដូចគ្នា) ។

ក៏ពាក្យថា **បឋវិតោ** ក្នុងពាក្យថា **បឋវិតោ មញ្ញតិ** ជាបញ្ចមីវិភត្តិ ។

ព្រោះដូច្នោះ បុថុជ្ជន កាលបើសម្គាល់ការកើតទេឡើង ឬ ការប្រាសទៅរបស់បឋវី មានប្រភេទតាមដែលពោលហើយនៃខ្លួន ឬ នៃបុគ្គលដទៃ ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬ សម្គាល់ថា អត្តាដទៃពីបឋវី គប្បីជ្រាបថា ឈ្មោះថាសម្គាល់វត្ថុដទៃពីបឋវី ។ នេះជាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

ក៏កាលបុថុជ្ជននោះ ញ៉ាំងសេចក្ដីស្នេហា និង មានះឱ្យកើតក្នុងវត្ថុដែលសម្គាល់ដោយអំណាចទិដ្ឋិនោះឯង គប្បីជ្រាបថា ជាសេចក្ដីសម្គាល់ដោយអំណាចតណ្ហា និង មានះ ។ អាចារ្យពួកដទៃពោលទុកថា បុថុជ្ជនចម្រើន

បឋវីកសិណ ដែលជាបរិត្តារម្មណ៍ ហើយតពីនោះ ប្រកាន់យកអត្តាដែលមិនមានប្រមាណ ហើយសម្គាល់ថា អត្តារបស់យើង (មាន) សូម្បីក្រៅពី **បឋវី** ដូច្នេះ ឈ្មោះថា រមែងសម្គាល់ក្រៅពីបឋវី ។ ក៏សេចក្តីសម្គាល់ណាមួយដែលប្រព្រឹត្តទៅដោយន័យនេះថា បុថុជ្ជនរមែងប្រកាន់មហាបឋវីតែម្យ៉ាង ។

ក្នុងពាក្យនេះថា **បឋវឹ មេតិ មញ្ញតិ** មានវិនិច្ឆ័យដូចតទៅនេះ ÷

ក៏សេចក្តីសម្គាល់ដែលប្រព្រឹត្តទៅដោយន័យនេះថា រមែងហួងហែងមហាបឋវីដោយអំណាចតណ្ហាតែម្យ៉ាង គប្បីជ្រាបថា បានដល់ សេចក្តីសម្គាល់ដោយអំណាចតណ្ហាតែម្យ៉ាងដូចគ្នា ។ ក៏សេចក្តីសម្គាល់ដោយអំណាចតណ្ហានេះ គួរប្រកបចូលក្នុងបឋវីទាំងខាងក្នុង និង ខាងក្រៅ សូម្បីទាំងអស់ មានប្រភេទតាមដែលពោលហើយយ៉ាងនេះថា សក់របស់យើង រោមរបស់យើង ដែករបស់យើង ដូច្នេះ ។

បទថា**បឋវឹអភិនន្ទតិ**សេចក្តីថាបុថុជ្ជនរមែងភ្លើតភ្លើនអធិប្បាយថា ត្រេកអរជាប់ចិត្តក្នុងបឋវី មានប្រការតាមដែលពោលហើយនោះឯង ដោយ កិលេសមានតណ្ហាជាដើម ។

បើមានពាក្យសួរថា កាលខ្លឹមសារនេះសម្រេចហើយដោយ ២ បទនេះ

ឯងថា **បឋវឹ មញ្ញតិ** ព្រោះហេតុអ្វីទើបពោលទុកយ៉ាងនេះ ។ ឆ្លើយថា ពាក្យនោះ បុរាណាចារ្យទាំងឡាយមិនបានលើកយកមកពិចារណា ក៏មតិនេះជាចំណែកខ្លួនរបស់យើង ចាកលីលាការសម្តែង ឬ ចាកការឃើញទោស ព្រោះលោកដល់ព្រមដោយលីលានៃការសម្តែងដ៏វិចិត្រ ដោយន័យផ្សេង ៗ ព្រោះឃើញច្បាស់ធម្មធាតុណា ធម្មធាតុនោះ ព្រះមានព្រះភាគទ្រង់ប្រត្យក្សច្បាស់ដោយល្អហើយ ព្រោះដូច្នោះ លុះលោកសម្តែងការកើតទឡើងនៃកិលេសដោយអំណាចសេចក្តីសម្គាល់ក្នុងខាងដើមហើយ ឥឡូវនេះ កាលនឹងសម្តែងដោយអំណាចសេចក្តីត្រេកអរជាដើម ទើបពោលពាក្យនេះទុក ព្រោះដំណើរនៃការសម្តែងខ្លះ ។

ម្យ៉ាងទៀតបុថុជ្ជនណាសម្គាល់បឋវីសម្គាល់ក្នុងបឋវីសម្គាល់វត្ថុដទៃ ពីបឋវីសម្គាល់ថា បឋវីរបស់យើង បុថុជ្ជននេះ ព្រោះហេតុដែលខ្លួនមិនអាចនឹងលះបង់តណ្ហា ឬ ទិដ្ឋិ ដែលអាស្រ័យបឋវីបាន ដូច្នោះ ទើបត្រេកអរនឹងបឋវីតែម្យ៉ាង ។ ម្យ៉ាងទៀត បុថុជ្ជនណា ត្រេកអរនឹងបឋវី បុថុជ្ជននោះរមែងត្រេកអរនឹងទុក្ខ ហើយទុក្ខជាទោស ព្រោះដូច្នោះ លោកទើបពោលពាក្យនេះទុក ស្ងម្បីព្រោះការឃើញទោស ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា អ្នកណាត្រេកអរនឹង

បឋវី អ្នកនោះត្រេកអរនឹងទុក្ខ អ្នកណាត្រេកអរនឹងទុក្ខ អ្នកនោះរមែងមិនរួច ផុតអំពីទុក្ខ ដូច្នេះ ។

ព្រះមានព្រះភាគ លុះត្រាស់សេចក្ដីសម្គាល់ និង សេចក្ដីត្រេកអរ ដែលមានបឋវីជាទីតាំងយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់នាំហេតុដែល ជាហេតុសម្គាល់ និង ត្រេកអររបស់បុថុជ្ជននោះ ទើបត្រាស់ថា តថាគត ពោលថា ដំណើរនោះព្រោះហេតុអ្វី , ការមិនដឹងដោយជុំវិញ ជាហេតុនៃ សេចក្ដីនោះ ដូច្នេះ ។

សេចក្ដីនោះ មានខ្លឹមសារដូចតទៅនេះ ប្រសិនបើមានពាក្យសួរជៀត ចូលមកថា បុថុជ្ជននោះ រមែងសម្គាល់បឋវីនោះ ព្រោះហេតុអ្វី គឺថា ព្រោះ ហេតុអ្វី ទើបសម្គាល់ដោយសេចក្ដីត្រេកអរក្នុងបឋវីនោះ ដូច្នេះ ។ ឆ្លើយថា ( ព្រោះព្រះមានព្រះភាគត្រាស់ថា ) តថាគតពោលថា ដំណើរនោះ ដែល បុថុជ្ជននោះមិនបានកំណត់ដឹង មានអធិប្បាយថា ព្រោះហេតុដែលដំណើរ នោះ ដែលបុថុជ្ជននោះមិនបានកំណត់ដឹង ពិតហើយ បុថុជ្ជនណា រមែង កំណត់ដឹងបឋវី បុថុជ្ជននោះរមែងកំណត់ដឹងដោយបរិញ្ញា ៣ គឺ **ញាតបរិញ្ញា** **តីរណបរិញ្ញា** និង **បហានបរិញ្ញា** ។

ក្នុងបរិញ្ញា ៣ យ៉ាងនោះ **ញាតបរិញ្ញា** ដូចម្ដេច ? គឺ បុថុជ្ជន

រមែងដឹងបឋវីធាតុថា បឋវីធាតុនេះ ប្រព្រឹត្តទៅក្នុងខាងក្នុង បឋវីធាតុនេះ ប្រព្រឹត្តទៅក្នុងខាងក្រៅ នេះជាលក្ខណៈរបស់បឋវីធាតុនោះ ទាំងនេះជាកិច្ច ជាបច្ចុប្បដ្ឋាន និងជាបទដ្ឋានរបស់បឋវីធាតុនោះ ដូចពោលមកនេះ ហៅថា **ញាតបរិញ្ញា** ។

**តីរណបរិញ្ញា** ដូចម្តេច ? គឺ បុថុជ្ជនពិចារណាបឋវីធាតុ ធ្វើឱ្យជាវត្ថុដែលខ្លួនដឹងហើយយ៉ាងនេះ ដោយអាការ ៤០ ថា មិនទៀង ជាទុក្ខ ជា រោគជាដើម ដូចពោលមកនេះ ហៅថា **តីរណបរិញ្ញា** ។

**បហានបរិញ្ញា** ដូចម្តេច ? គឺ បុគ្គលពិចារណាឃើញយ៉ាងនេះហើយ រមែងលះបង់ឆន្ទរាគៈក្នុងបឋវីធាតុដោយអរហត្តមគ្គ ដូចពោលមកនេះ ហៅថា **បហានបរិញ្ញា** ។

មួយវិញទៀត ការកំណត់នាម និង រូប ឈ្មោះថា ញាតបរិញ្ញា ។ ការកំណត់ដឹង ក្នុងការពិចារណានូវកលាបៈជាខាងដើម និង អនុលោមញាណជាទីបំផុត ឈ្មោះថា តីរណបរិញ្ញា ។ ញាណក្នុងអរិយមគ្គ ឈ្មោះថា បហានបរិញ្ញា ។

បុថុជ្ជនណា រមែងកំណត់ដឹងបឋវី បុថុជ្ជននោះរមែងកំណត់ដឹងដោយ **បរិញ្ញា ៣** នេះ ។ ក៏បរិញ្ញាទាំងនោះ មិនមានដល់បុថុជ្ជននោះ ព្រោះ

ដូច្នោះ បុថុជ្ជននោះ ឈ្មោះថា រមែងសម្គាល់ (ប្រកាន់) រមែងត្រេកអរ និង បឋវី ព្រោះមិនកំណត់ដឹង ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ បុថុជ្ជនក្នុងលោកនេះមិនបានស្តាប់ ។ល។ រមែងសម្គាល់ បឋវី រមែងសម្គាល់ក្នុងបឋវី រមែងសម្គាល់ថា បឋវីពិត រមែងសម្គាល់ថា បឋវីរបស់យើង ឈ្មោះថារមែងត្រេកអរនឹងបឋវី សេចក្តីនោះ ព្រោះហេតុ អ្វី ? តថាគតពោលថា (ព្រោះ) សេចក្តីនោះ ដែលបុថុជ្ជននោះមិនបាន កំណត់ដឹង ។

( ចប់ បឋវីវារៈ )

សូម្បីក្នុងសេចក្តីនេះថា **អាបំ អាបតោ** គប្បីជ្រាបថា អាបោ ៤ យ៉ាងគឺ លក្ខណៈអាបោ សសម្ភារអាបោ អារម្មណអាបោ និង សម្មតិអាបោ ។ បណ្តាអាបោ ៤ យ៉ាងនោះ អាបោដែលពោលទុកក្នុងប្រយោគជាដើមថា បណ្តាអាបោធាតុ ២ យ៉ាងនោះ , អាបោធាតុដែលប្រព្រឹត្តទៅខាងក្នុង ដូចម្តេច ? បានដល់ វត្ថុដែលសើមជ្រួតជ្រាប ប្រមូលផ្តុំ ( ជា លក្ខណៈ ) ចំពោះខ្លួន នៅខាងក្នុងខ្លួនឯង គឺ អាបោធាតុដែលមានចិត្តគ្រប់គ្រងក្នុងខាងក្នុងរូប ឈ្មោះថា លក្ខណអាបោ ។ អាបោ ពោលទុកក្នុងប្រយោគជាដើមថា បុគ្គលរៀនយកអាបោកសិណ រមែងកាន់យកនិមិត្តក្នុងអាបោ ដូច្នេះ ឈ្មោះថា សសម្ភារអាបោ ។ ពាក្យដ៏សេសទាំងអស់ ដូចដែលពោលទុកក្នុងបឋវី នោះឯង ។ តែកាលពោលដោយន័យនៃការប្រកបសុទ្ធ ។ អាបោធាតុដែលប្រព្រឹត្តទៅក្នុងខាងក្នុង ១២ យ៉ាង ដែលលោកពោលទុកដោយន័យជាដើមថា ទឹកប្រមាត់ ស្លេស្ម ដូច្នេះជាដើម គប្បីជ្រាបថា អាបោធាតុខាងក្នុង និង អាបោធាតុដែលលោកពោលទុកយ៉ាងនេះថា បណ្តាអាបោធាតុ ២ យ៉ាង អាបោធាតុដែលប្រព្រឹត្តទៅក្នុងខាងក្រៅ ដូចម្តេច ? គឺ វត្ថុដែលសើម ជ្រួតជ្រាប កកផ្តុំ នៅខាងក្រៅ បានដល់ សភាពសើម វត្ថុដែលដល់សភាពសើម អាបោធាតុដែលមិនមាន

ចិត្តគ្រប់គ្រង ខាងក្រៅរូប គឺ រសកើតពីមើម ឫស រសកើតពីដើមឈើ រសកើតពីសំបកឈើ រសកើតពីស្លឹក រសកើតពីផ្កា រសកើតពីផ្លែ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ទឹកលើផែនដី ឬ ទឹកក្នុងអាកាស គប្បីជ្រាបថា ជាអាបោធាតុខាងក្រៅ ។ ហើយអាបោនោះ ឈ្មោះថា និមិត្តអាបោក្នុងពួក ៣ នៃអជ្ឈត្តារម្មណ៍ ។

ក្នុងបទថា **តេជំ តេជតោ** នេះ គប្បីជ្រាប សេចក្តីពិស្តារដោយន័យដែលពោលហើយ សូម្បីក្នុងវារៈនៃតេជោនោះឯង ។ តែក្នុងសេចក្តីនេះកាលពោលដោយន័យនៃការអធិប្បាយ តេជោធាតុ ៤ យ៉ាងដែលលោកពោលទុកយ៉ាងនេះថា តេជោធាតុដែលជាហេតុឱ្យរាងកាយមានកម្តៅ ទ្រុឌទ្រោមខ្វល់ខ្វាយ និង ជាហេតុដុតរំលាយអាហារ គប្បីជ្រាបថា តេជោធាតុខាង ក្នុង និង តេជោធាតុដែលលោកពោលទុកយ៉ាងនេះថា បណ្តាតេជោធាតុ ២ យ៉ាងនោះ តេជោធាតុដែលប្រព្រឹត្តទៅខាងក្រៅដូចម្តេច ? គឺ វត្ថុដែលក្តៅធ្វើឱ្យមានកម្តៅខាងក្រៅ គឺ តេជោធាតុដែលមិនមានចិត្តគ្រប់គ្រង បានដល់ភ្លើងដែលកើតអំពីឈើ ភ្លើងដែលកើតអំពីកម្ទេចឈើ ភ្លើងកើតពីស្មៅ ភ្លើងកើតពីអាចម៍គោ ភ្លើងកើតពីអង្កាម ភ្លើងកើតពីគំនរសំរាម ភ្លើងកើតពី ប្រេង ( ឥន្ទនៈ) សភាពក្តៅដែលកើតពីភ្លើង សភាពក្តៅដែលកើតពីពន្លឺ

ព្រះអាទិត្យ សភាពក្តៅកើតពីគំនរនៃកំណាត់ឈើ សភាពក្តៅកើតពីគំនរនៃស្មៅ សភាពក្តៅកើតពីគំនរនៃអង្កាម សភាពក្តៅកើតពីគំនរនៃវត្ថុទាំងទឡាយនេះ គប្បីជ្រាបថា តេជោធាតុខាងក្រៅ ។

ក៏ក្នុងន័យនៃការអធិប្បាយខ្លឹមសារ សូម្បីវារៈនេះថា **វាយំ វាយតោ** មានអធិប្បាយដូចតទៅនេះ វាយោធាតុ ដែលលោកពោលទុកយ៉ាងនេះថា ខ្យល់ដែលបក់ទេឡើងខាងលើ បក់ចុះខាងក្រោម ខ្យល់បក់ក្នុងផ្ទៃ (ពោះ) ខ្យល់បក់ក្នុងពោះវៀន ខ្យល់បក់ផ្សាយទៅតាមអវយវៈតូច_ធំ ខ្យល់មានពិសកាចដូចសស្ត្រា ខ្យល់មានពិសកាចដូចមុខកាំបិត ខ្យល់មានពិសកាចដូចទងឈូក ខ្យល់ដកដង្ហើមចេញ ខ្យល់ដកដង្ហើមចូល គប្បីជ្រាបថា **វាយោធាតុខាងក្នុង** និង ខ្យល់ដែលលោកពោលទុកយ៉ាងនេះថា បណ្តាវាយោធាតុ ២ យ៉ាងនោះ វាយោធាតុខាងក្រៅ ដូចម្តេច ? គឺ វត្ថុដែលបក់បោក កម្រើក_ញ័រខាងក្រៅ បានដល់ វាយោធាតុខាងក្រៅរបស់រូបមិនមានចិត្តគ្រប់គ្រង គឺ ខ្យល់បក់ពីទិសខាងកើត ខ្យល់បក់ពីទិសខាងលិច ខ្យល់បក់ពីទិសខាងជើង ខ្យល់បក់ពីទិសខាងត្បូង ខ្យល់បក់ធូលី ខ្យល់មិនមានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ខ្លាំង ខ្យល់កំបុតត្បូង ខ្យល់ដែលកើតពីសត្វហើរ ខ្យល់កើតពីគ្រុឌហើរ ខ្យល់កើតពីប្រមោយដំរី ខ្យល់កើតពីការបក់ផ្លិត គប្បី

ជ្រាបថា **វាយោធាតុខាងក្រៅ** ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។

កាន់យកន័យដែលឈ្មោះថា **លក្ខណ** នេះណា (ដែលមានមក ) ក្នុងនេត្តិបករណ៍ យ៉ាងនេះថា កាលពោលដល់ធម៌តែម្យ៉ាងហើយ ដោយធម៌តែម្យ៉ាងនោះ ក៏ជាការដែលពោលដល់ធម៌គ្រប់យ៉ាង ដែលមានលក្ខណៈដូចគ្នាដែរ លក្ខណៈនៃការកាន់យកន័យ លោកពោលទុកយ៉ាងនេះដូច្នេះ ជាការដែលលោកពោលទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ដោយអំណាចនៃការកាន់យកន័យនោះ ព្រោះហេតុដែលកាន់យកមហាភូតរូបទាំង ៤ ក៏រមែងជាការកាន់យកឧបាទាយរូបផងដែរ ព្រោះឧបាទាយរូបមិនកន្លងផុតលក្ខណៈរូបទៅបាន មហាភូតរូប និង ឧបាទាយរូបណា នោះជារូបក្ខន្ធដូច្នោះ ព្រះមាន_ព្រះភាគកាលត្រាស់ថា បុថុជ្ជនដែលមិនបានស្តាប់ រមែងសម្គាល់ បឋវី អាបោ តេជោ វាយោ ក៏រមែងត្រាស់ថា គេរមែងពិចារណាឃើញ រូបថា ជាអត្តាដែរ ។

កាលត្រាស់ថា បុថុជ្ជនរមែងសម្គាល់ក្នុងបឋវី អាបោ តេជោ វាយោ រមែងត្រាស់ថា បុថុជ្ជនពិចារណាឃើញ អត្តាក្នុងរូប ដូច្នេះ ។ កាលត្រាស់ ថា រមែងសម្គាល់វត្ថុដទៃពី បឋវី អាបោ តេជោ វាយោ រមែងត្រាស់ថា

រមែងពិចារណាឃើញ អត្តាមានរូប ហើយរូបក្នុងអត្តា ព្រោះសម្រេចសេចក្តី ថា អត្តាដទៃផ្សេងអំពីរូប ដូច្នេះ ។

គប្បីជ្រាបសេចក្តីសម្គាល់ដោយអំណាចនៃសក្កាយទិដ្ឋិ ដែលមានរូបជាទីតាំង ៤ ប្រការ ដូចពោលមកនេះ ។

ក្នុងសេចក្តីនេះ គប្បីជ្រាបការផ្សេងគ្នាយ៉ាងនេះថា បណ្តាទិដ្ឋិ៤ប្រការ នោះជាឧច្ឆេទទិដ្ឋិ ១ ជាសស្សតទិដ្ឋិ ៣ ដូច្នោះ ទិដ្ឋិទើបមាន ២ យ៉ាង ។ ព្រះមានព្រះភាគ លុះត្រាស់សេចក្តីសម្គាល់ដែលមានសង្ខារជាទីតាំង ដោយមានរូបជាប្រធានយ៉ាងនេះហើយ ឥឡូវនេះ សត្វទាំងឡាយណាត្រូវបញ្ញត្តទេឡើង ព្រោះអាស្រ័យសង្ខារទាំងឡាយ ព្រោះហេតុដែលបុថុជ្ជនធ្វើការសម្គាល់ស្ងប្បីក្នុងសត្វទាំងឡាយនោះ ដូច្នោះ កាលបើចង្អុលសម្តែងសត្វទាំងនោះហើយ ទើបត្រាស់មានពាក្យជាអាទិថា ឈ្មោះថា រមែងសម្គាល់ភូតទាំងឡាយដោយសភាពជាភូត ដូច្នេះ ។

## អត្ថន័យរបស់ ភូត ស័ព្ទ

ក្នុងសេចក្តីនោះ **ភូត** ស័ព្ទនេះ ប្រើក្នុងអត្ថជាដើមថា ខន្ធ ៥ , អមនុស្ស , ធាតុ , មានហើយ , ព្រះខីណាស្រព , សត្វ និង ដើមឈើ ។

ពិតហើយ **ភូត** ស័ព្ទនេះ ប្រើក្នុងអត្ថថា **ខន្ធ ៥** ដូចក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡ្បាយ អ្នកទាំងទឡ្បាយចូរពិចារណាថា នេះជាភូត ។

ប្រើក្នុងអត្ថថា **អមនុស្ស** ដូចក្នុងប្រយោគនេះថា ភូតទាំងទឡ្បាយណាមកប្រជុំគ្នាហើយក្នុងទីនេះ ដូច្នេះ ។

ប្រើក្នុងអត្ថថា **ធាតុ ៤** ដូចក្នុងប្រយោគនេះថា ម្នាលភិក្ខុទាំងទឡ្បាយ មហាភូតរូប ៤ នេះឯង ជាហេតុ ...... ដូច្នេះ ។

ប្រើក្នុងអត្ថថា **មានហើយ** ដូចក្នុងប្រយោគជាដើមថា ជាបាចិត្តិយព្រោះ ភូត (ភូតគាម) ដូច្នេះ ។

ប្រើក្នុងអត្ថថា **ព្រះខីណាស្រព** ដូចក្នុងប្រយោគថាក៏ភូតណាជា អ្នកស៊ីកាល ដូច្នេះ ។

ប្រើក្នុងអត្ថថា **សត្វ** ដូចក្នុងប្រយោគថា ភូតទាំងទឡ្បាយនេះឯង នឹងលះបង់រាងកាយទុកក្នុងលោក ដូច្នេះ ។

ប្រើក្នុងអត្ថថា **ដើមឈើ** ក្នុងប្រយោគនេះថា **ភូតគាមបាតព្យតាយ** (ធ្វើភូតគាមឱ្យវិនាស) ដូច្នេះ ។

ប៉ុន្តែក្នុងទីនេះ **ភូត** ស័ព្ទនេះ រមែងប្រើក្នុងសត្វទាំងទឡ្បាយ ។ **ភូត** ស័ព្ទនឹងប្រព្រឹត្តទៅដោយការមិនផ្សេងគ្នាក៏ទេ ព្រោះថា សត្វទាំងទឡ្បាយទាប

ជាងជាន់ចាតុម្មហារាជ លោកបំណងយក **ភូត** ក្នុងទីនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភូតេ ភូតតោ សញ្ជានាតិ** ជាដើម មានន័យដូចពោលហើយនោះឯង ។

## ការសម្គាល់ដោយអំណាច តណ្ហា មានៈ ទិដ្ឋិ

ក៏ក្នុងពាក្យជាដើមថា **ភូតេ មញ្ញតិ** គប្បីប្រកបសេចក្តីសម្គាល់សូម្បី ៣ យ៉ាង ។ យ៉ាងណា ? ពិតហើយ បុថុជ្ជននេះ ប្រកាន់យកភូតទាំង_ទឡាយថា ស្អាត មានសេចក្តីសុខ ដោយន័យដែលពោលទុកហើយថា គេ ឃើញគហបតី ឬ បុត្តគហបតី ដែលបរិបូណ៌ដោយកាមគុណ ៥ ដូច្នេះ រមែងត្រេកត្រអាល គឺ រមែងត្រេកត្រអាលនឹងភូតទាំងនោះ សូម្បីព្រោះឃើញ និង រមែងត្រេកត្រអាល សូម្បីព្រោះបានឮ បានធុំក្លិន បានលិទ្ធរស បាន ប៉ះពាល់ត្រូវ និង ជ្រាបនូវរឿង បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងទឡាយដោយ ការសម្គាល់ ព្រោះអំណាចនៃតណ្ហា ដូចពណ៌នាមកនេះ ។ រមែងតាំងចិត្ត ទុកដើម្បីបានវត្ថុដែលខ្លួននៅមិនទាន់បាន ដោយន័យជាដើមថា ធ្វើដូចម្តេច ហ្ន៎ ! យើងគប្បីចូលដល់ភាពជាសម្លាញ់នៃខត្តិយមហាសាលទាំងទឡាយ ។ បុថុជ្ជន រមែងសម្គាល់ក្នុងភូតទាំងទឡាយដោយការសម្គាល់ ព្រោះអំណាចនៃ តណ្ហា សូម្បីដោយប្រការដូច្នេះ ។

ប៉ុន្តែអាស្រ័យសម្បត្តិ និង វិបត្តិ របស់ខ្លួន និង របស់ភូតទាំងទឡាយ បុថុជ្ជនរមែងប្រកាន់ខ្លួនថា ប្រសើរជាងគេ បុថុជ្ជនរមែងសម្គាល់ភូតប្រភេទណាមួយ ក្នុងភូតទាំងទឡាយថា ថោកទាបជាងខ្លួន ឬ រមែងសម្គាល់ខ្លួនថា ថោកទាបជាងភូតប្រភេទណាមួយ រមែងសម្គាល់ភូតប្រភេទណាមួយថា ប្រសើរជាងខ្លួន ( ឬរមែងសម្គាល់ថា ខ្លួនប្រសើរជាងភូតប្រភេទណាមួយ ) រមែងសម្គាល់ខ្លួនថា ស្មើនឹងភូត ឬ រមែងសម្គាល់ភូតថា ស្មើគ្នានឹងខ្លួន ។ សមដូចដែលលោកពោលទុកថា បុគ្គលខ្លះក្នុងលោកនេះ កាលមុនប្រកាន់ថា ខ្លួនស្មើនឹងអ្នកដទៃដោយជាតិ ។ល។ ឬដោយវត្ថុណាមួយ ក្រោយមកក៏ត្រឡប់ជាសម្គាល់ថាប្រសើរជាងគេត្រឡប់មកសម្គាល់អ្នកដទៃថាថោកទាបជាង ខ្លួនមានះមានសភាពបែបនេះ លោកហៅថា **មានាតិមាន** ។ បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងទឡាយដោយការសម្គាល់ដោយអំណាចនៃមានះ ដូចពណ៌នាមកដូច្នេះ ។

បុថុជ្ជនសម្គាល់ថា ក៏ភូតទាំងទឡាយ ទៀង យឺនយូរ ឋិតថេរ មានជាធម្មតា មិនប្រែប្រួល ឬថា សត្វទាំងពួង បាណៈទាំងពួង ភូតទាំងពួង ជីវៈទាំងពួង មិនមានអំណាច មិនមានកម្លាំង មិនមានសេចក្តីព្យាយាម អ្នកបង្កើនទៅកាន់ភាវៈ ការប្រសព្វជោគអាក្រក់ ជោគល្អ រមែងសោយសុខ_

ទុក្ខក្នុងអភិជាតិ ៦ ជាតិនោះឯង ឈ្មោះថា រមែងសម្គាល់ដោយការសម្គាល់ព្រោះអំណាចនៃទិដ្ឋិ ។ បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងទឡាយដោយសេចក្តីសម្គាល់ ៣ យ៉ាង ដោយប្រការដូច្នេះ ។

បុថុជ្ជន រមែងសម្គាល់ក្នុងភូតទាំងទឡាយយ៉ាងណា ? គឺ ប្រាថ្នាការកើតទេឡើងនៃខ្លួន ឬ ការកើតសេចក្តីសុខដល់ខ្លួន ក្នុងភូតទាំងទឡាយនោះ ៗ បុថុជ្ជន រមែងសម្គាល់ក្នុងភូតទាំងទឡាយដោយសេចក្តីសម្គាល់ដោយអំណាចនៃតណ្ហាដូចពណ៌នាមកមុននេះ ។ ឬកាលសេចក្តីប្រាថ្នាការកើតទេឡើងក្នុងភូតទាំងទឡាយ ទើបឱ្យទាន សមាទានសីល រក្សាឧបោសថកម្ម , បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងទឡាយដោយសេចក្តីសម្គាល់ព្រោះអំណាចនៃតណ្ហា សូម្បីដោយប្រការដូច្នេះ ។

ក៏បុថុជ្ជន ប្រកាន់យកភូតទាំងទឡាយដោយការប្រកាន់យករួមគ្នា រមែងសម្គាល់ភូតទាំងទឡាយពួកខ្លះក្នុងបណ្តាភូតទាំងនោះថា ប្រសើរជាង ឬ សម្គាល់សត្វពួកខ្លះថា ស្មើគ្នា ឬ ថោកទាបជាងគ្នា បុថុជ្ជនរមែងសម្គាល់ក្នុងភូតទាំងទឡាយ ដោយការសម្គាល់ព្រោះអំណាចនៃមានះ ដោយប្រការដូចពោលមក នេះ ។

ម្យ៉ាងទៀត បុថុជ្ជនរមែងសម្គាល់ភូតពួកខ្លះថា ទៀង ឋិតថេរ រមែងសម្គាល់ភូតពួកខ្លះថា មិនទៀង មិនឋិតថេរ ឬ រមែងសម្គាល់ថា សូម្បីយើងក៏ជាភូតមួយប្រភេទក្នុងបណ្តាភូតទាំងទឡាយ ដូច្នេះឈ្មោះថា រមែងសម្គាល់ក្នុងភូតទាំងទឡាយ ដោយសេចក្តីសម្គាល់ព្រោះអំណាចនៃទិដ្ឋិ ដោយប្រការដូច្នេះឯង ។

ក៏ក្នុងពាក្យនេះថា **ភូតោ មញ្ញតិ** មានវិនិច្ឆ័យដូចតទៅនេះ ÷

បុថុជ្ជន កាលសម្គាល់ការកើតទេឡីងនៃខ្លួន ឬ បុគ្គលដទៃ ព្រមទាំង ទ្រព្យសផ្ទាល់ខ្លួនចាកភូតណាមួយ គប្បីជ្រាបថា រមែងសម្គាល់ចាក ភូតដូច្នេះ ។ នេះជាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបើបុថុជ្ជននោះ ញុំាងសេចក្តីស្នេហា និង មានះឱ្យកើតទេឡីងក្នុងវត្ថុដែលសម្គាល់ដោយការសម្គាល់ ព្រោះអំណាចនៃទិដ្ឋិនោះ ៗ ឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និង មានះ ផង ។

ក្នុងសេចក្តីថា **ភូតេ មេតិ មញ្ញតិ** នេះ មានការសម្គាល់ដោយអំណាចនៃតណ្ហាតែម្យ៉ាង ។ ការសម្គាល់ដោយអំណាចនៃតណ្ហានេះ នោះ

គប្បីជ្រាបថា រមែងប្រព្រឹត្តទៅដោយការប្រកាន់ថា ជារបស់យើង ដោយន័យជាដើមថា បុត្ររបស់យើង ធីតារបស់យើង សត្វពពែ និង សត្វកែះ របស់យើង មាន់ និង ជ្រូករបស់យើង ដំរី គោ ទន្សាយ និង ឆ្មា របស់យើង ដូច្នេះ ។

ពាក្យថា **ភូតេ អភិនន្ទតិ** មានន័យដូចពោលមកហើយយ៉ាងនេះ នោះឯង ។

ក្នុងសេចក្ដីថា **អបរិញ្ញាតំ តស្ស** នេះ មានវិនិច្ឆ័យដូចតទៅនេះ ÷

ការបញ្ញត្តិភូតទាំងឡាយ ព្រោះអាស្រ័យសង្ខារទាំងឡាយណា ព្រោះមិនកំណត់ដឹងនូវសង្ខារទាំងឡាយនោះ ភូតទាំងឡាយគប្បីជ្រាបថា គឺ ជាការដែលបុថុជ្ជនមិនកំណត់ដឹង ដូច្នេះ ។ ចំណែកការប្រកបសេចក្ដី ( បំភ្លឺសេចក្ដី ) គប្បីធ្វើទុកតាមន័យដូចពោលហើយនោះឯង ។

## ទេព ៣

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទីតាំងនៃសេចក្ដីសម្គាល់ដោយអំណាចនៃសង្ខារ និង ដោយអំណាចនៃសត្វ ដោយសង្ខេបយ៉ាងនេះហើយ

ឥឡូវនេះ កាលនឹងសម្ដែងទីតាំងនោះឱ្យពិស្ដារ ដោយប្រភេទជាដើមថា **ភូមិ-ពិសេស** ទើបត្រាស់ពាក្យមានជាអាទិថា **ទេវេ ទេវតោ** ដូច្នេះ ។

ក្នុងពាក្យនោះមានរូបវិគ្រោះដូច្នេះ ដែលឈ្មោះថា **ទេព** ព្រោះអត្ថថា រមែងលេង អធិប្បាយថា រីករាយ និង រុងរឿងដោយកាមគុណ ៥ ឬ ដោយឫទ្ធិរបស់ខ្លួន ។ ទេពទាំងទឡាយនោះមាន ៣ ជំពូក គឺ ÷

**សម្មតិទេព ឧប្បត្តិទេព វិសុទ្ធិទេព** ។ ព្រះរាជា ព្រះមហេសី និង ព្រះរាជកុមារ ឈ្មោះថា **សម្មតិទេព** ។ ទេពដែលខ្ពស់ជាងនោះ ផ្ដើមតាំងពីទេពជាន់ចាតុម្មហារាជ ឈ្មោះថា **ឧប្បត្តិទេព** ។ ព្រះអរហន្តខីណា-ស្រពទាំងទឡាយ ឈ្មោះថា **វិសុទ្ធិទេព** ។ ប៉ុន្តែក្នុងទីនេះគប្បីជ្រាបថា លោកបំណងយកឧប្បត្តិទេព ។ ក៏ឧប្បត្តិទេពនោះ នឹងឃើញថា មិនប្លែកគ្នាក៏ទេ គឺ វៀរមារ ព្រមទាំងបរិស័ទក្នុងទេវលោកជាន់បរនិម្មិតវសវត្តីចេញ ទេវតាជាន់កាមាវចរ ៦ ជាន់ដ៏សេស លោកបំណងយកទេពក្នុងទីនេះ ។ ការពណ៌នាខ្លឹមសារទាំងអស់ក្នុងសេចក្ដីនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងភូតវារៈនោះចុះ ។

## បជាបតី គឺជា ស្តេចមារ

ក៏ក្នុងបទថា **បជាបតិ** នេះ មារ គប្បីជ្រាបថា បជាបតី ។ តែអាចារ្យពួកខ្លះពោលថា ពាក្យថា **បជាបតិ** នេះ ជាឈ្មោះរបស់ស្តេចមហារាជជាដើម ដែលជាធំជាងស្តេចទេវតាទាំងទឡាយនោះ ៗ ។ ពាក្យនោះលោកបដិសេធទុកក្នុងមហាអដ្ឋកថា ថា មិនត្រូវ ព្រោះថា មហារាជជាដើមទាំងនោះ លោកកាន់យកដោយ **ទេវ** ស័ព្ទ នោះឯង ។ ចំណែកស្តេចមារនោះ លោកបំណងយកថា ជាបជាបតីក្នុងទីនេះ ដោយភាពជាធំជាងបជាពោលគឺពពួកសត្វ។សួរថាស្តេចមារនោះតែងនៅកន្លែងណា ទីណា ? ឆ្លើយថា រមែងរស់នៅក្នុងទេវលោកជាន់ **បរនិម្មិតវសវតី** ។ ពិតហើយស្តេចមារវសវត្តី គ្រងរាជ្យនៅក្នុងទេវលោកនោះ ។ អាចារ្យពួក ខ្លះពោលថា ស្តេចមារប្រថាប់គ្រប់គ្រងដ៏ធំក្រៃលែងក្នុងបរិស័ទរបស់ខ្លួន ក្នុងទេវលោកនៅទីកន្លែងមួយ ឬ របស់ទេវលោកនោះ ឬ ដូចរាជឱរសរបស់ព្រះរាជាដ៏ល្បីល្បាញប្រថាប់នៅជាយដែននៃរាជាណាចក្រ ដូច្នោះ ។ ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបថា លោកចាត់យកបរិស័ទមារចូលផងដោយ **មារ** ស័ព្ទ

នោះឯង ។ ចំណែកក្នុងសេចក្តីនេះ ក្នុងន័យនៃការពង្រីកសេចក្តី មានអធិ-ប្បាយដូច្នេះ បុថុជ្ជនបានឃើញក្តី បានឮក្តី នូវបជាបតីដែលមានពណ៌សម្បុរល្អ មានអាយុវែង មានសេចក្តីសុខចម្រើន រមែងប្រាថ្នារាជសម្បត្តិដោយអំណាចនៃតណ្ហា ឬ ក៏ថា សូម្បីតាំងចិត្តទុកដើម្បីនឹងបានវត្ថុដែលខ្លួននៅមិនទាន់បាន ដោយពាក្យជាដើមថា ធ្វើដូចម្តេចហ្ន៎ ! យើងគប្បីចូលដល់ភាពជាសម្លាញ់នៃបជាបតី ឈ្មោះថា រមែងសម្គាល់បជាបតីដោយការសម្គាល់ព្រោះអំណាចនៃតណ្ហា តែកាលបុថុជ្ជនដល់ភាពជាបជាបតីហើយ ក៏ញុំាងមានះឱ្យកើតទេឡើងថា យើងជាអ្នកធំ ជាអធិបតីជាងបជាទាំងទឡាយ គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់បជាបតី ដោយការសម្គាល់ព្រោះអំណាចនៃមានះ ។

តែបើបុថុជ្ជនសម្គាល់ថា បជាបតីទៀង ឋិតថេរ ឬ ដាច់សូន្យ ឬថា មិនមានអំណាច មិនមានកម្លាំង មិនមានការព្យាយាម បង្អោនទៅកាន់ការប្រសព្វជោគល្អ ជោគអាក្រក់ រមែងសោយសុខ ទុក្ខ ក្នុងអភិជាតិ៦ ជាតិនោះ ឯង គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់បជាបតីដោយការសម្គាល់ព្រោះអំណាចនៃទិដ្ឋិ ។

ប៉ុន្តែក្នុងពាក្យថា **បជាបតី** នេះ ការសម្គាល់ដោយអំណាចទិដ្ឋិមួយយ៉ាងនោះឯង រមែងត្រឹមត្រូវ ។ គប្បីជ្រាបការប្រព្រឹត្តិទៅនៃការសម្គាល់នោះយ៉ាងនេះ ។ បុគ្គលខ្លះក្នុងលោកនេះ រមែងសម្គាល់ថា ធម៌ទាំងទទ្បាយណាមាននៅក្នុងបជាបតី ធម៌ទាំងទទ្បាយនោះទៀង ឋិតថេរ ពិតប្រាកដ មិនមានការប្រែប្រួលជាធម្មតា ។ម្យ៉ាងទៀត រមែងសម្គាល់ថា បាបរមែងមិនមានក្នុងបជាបតី កម្មដ៏លាមកទាំងទទ្បាយ រមែងមិនមានក្នុងបជាបតីនោះ ។

ក្នុងពាក្យថា **បជាបតិតោ** នេះ រមែងមានការសម្គាល់សូម្បីទាំង ៣ ។ យ៉ាងណាគឺ បុគ្គលខ្លះក្នុងលោកនេះ រមែងសម្គាល់ការដែលខ្លួន ឬ អ្នកដទៃព្រមទាំងទ្រព្យសរបស់ខ្លួនកើតទេទ្បីង ឬ ប្រាសចាកពីបជាបតី នេះហៅថាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុគ្គលនោះ ។

ក៏កាលបើបុគ្គលនោះ ញ៉ាំងសេចក្តីស្នេហា និង មានះឱ្យកើតទេទ្បីងក្នុងវត្ថុដែលសម្គាល់ព្រោះការសម្គាល់ដោយអំណាចនៃទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និង មានះ ។

ក្នុងបទថា **បជាបតឹ មេ** រមែងមានការសម្គាល់ដោយអំណាច

នៃតណ្ហាមួយបែបនោះឯង ។ ការសម្គាល់ដោយអំណាចនៃតណ្ហានេះ នោះ គប្បីជ្រាបថា រមែងប្រព្រឹត្តទៅដល់បុគ្គលដែលប្រកាន់ថា របស់យើង ដោយ ន័យជាដើមថា បជាបតីជាគ្រូរបស់យើង ជានាយរបស់យើង ដូច្នេះ ។ ពាក្យ ដ៏សេសក៏មានន័យដូចដែលពោលមកហើយនោះឯង ។

*អត្ថន័យនៃពាក្យថា ព្រហ្ម*

ក្នុងបទថា **ព្រហ្មំ ព្រហ្មតោ** មានវិនិច្ឆ័យដូចតទៅនេះ ÷

ឈ្មោះថា **ព្រហ្ម** ព្រោះអត្ថថា ចម្រើនហើយដោយគុណវិសេស នោះៗ ។ ម្យ៉ាងទៀត ស្ដេចមហាព្រហ្មក្ដី ព្រះតថាគតក្ដី ព្រាហ្មណ៍ក្ដី មាតាបិតាក្ដី វត្ថុដ៏ប្រសើរបំផុតក្ដី លោកក៏ហៅថា **ព្រហ្ម** ។

ពិតហើយ ស្ដេចមហាព្រហ្ម លោកហៅថា ព្រហ្ម ( ដូច ) ក្នុង ប្រយោគជាដើមថា ព្រហ្ម ១.០០០ , ២.០០០ ។

ព្រះតថាគត លោកក៏ហៅថា ព្រហ្ម ( ដូច ) ក្នុងប្រយោគថា ម្នាល ភិក្ខុទាំងទឡាយ ពាក្យថា **ព្រហ្ម** នេះ ជាឈ្មោះរបស់តថាគតនោះឯង ។

ព្រាហ្មណ៍ លោកហៅថា ព្រហ្ម (ដូច) ក្នុងប្រយោគនេះថា ÷

**ព្រះសម្ពុទ្ធ ដែលបន្ទោបង់នូវសេចក្ដីងងឹត ជាអ្នកមាន**

**ព្រះចក្ខុបរិបូណ៌ ដល់ទីបំផុតនៃលោក ជាអ្នកឈាន**

**កន្លងភពទាំងពួង មិនមានអាសវៈ លះបង់ទុក្ខទាំងទឡាយ**

**បានហើយ ជាអ្នកពោលនូវសច្ចៈ ជាអ្នកដែលព្រហ្មបម្រើ**

**ហើយ ដូច្នេះ ។**

មាតាបិតា លោកហៅថា **ព្រហ្ម** ( ដូច ) ក្នុងប្រយោគនេះ ថា មាតាបិតាលោកហៅថា ព្រហ្ម មាតាបិតាលោកហៅថា បុព្វាចារ្យ ។

វត្ថុដ៏ប្រសើរបំផុតលោកហៅថា **ព្រហ្ម** ( ដូច ) ក្នុងប្រយោគនេះថា ព្រះមានព្រះភាគ ញុំាងចក្រដ៏ប្រសើរឱ្យប្រព្រឹត្តទៅ ដូច្នេះ ។

តែក្នុងទីនេះ លោកបំណងយកព្រហ្មដែលកើតទេឡើងក្នុងបឋមកប្ប សូម្បីព្រហ្មបុរោហិត និង ព្រហ្មបារិសជ្ជៈ គប្បីជ្រាបថា លោកកាន់យកដោយ **ព្រហ្ម** ស័ព្ទ នោះឯង ។ តែការពណ៌នាខ្លឹមសារក្នុងសេចក្តីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុង បជាបតីវារៈ នោះឯង ។

*អធិប្បាយ អាភស្សរព្រហ្ម*

ក្នុងវារៈពោលដោយ **អាភស្សរព្រហ្ម** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ÷

រស្មីផ្សាយចេញពីរាងកាយរបស់ព្រហ្មទាំងទឡាយនោះ ដូចដាច់ធ្លាក់ចេញ

ពីរាងកាយ ដូចអណ្ដាតភ្លើងដែលដាច់ធ្លាក់ចេញពីគប់ភ្លើង ដូច្នោះ ព្រោះហេតុនោះ ព្រហ្មនោះ ទើបឈ្មោះថា **អាភស្សរា** ។ ដោយការកំណត់យកអាភស្សរព្រហ្មទាំងនោះ ( ជាការប្រមូល ) ទើបជាការដែលលោកកំណត់យកភូមិរបស់ទុតិយជ្ឈានទាំងអស់ផង ។ ក៏ព្រហ្មដែលស្ថិតនៅក្នុងជាន់ដូចគ្នាសូម្បីទាំងអស់នោះឯង គប្បីជ្រាបថា (បានដល់ ) បរិត្តាភាព្រហ្ម អប្បមាណាភាព្រហ្ម អាភស្សរាព្រហ្ម ។

## *អធិប្បាយ សុភកិណ្ហព្រហ្ម*

ក្នុងវារៈពោលដោយ **សុភកិណ្ហព្រហ្ម** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

ព្រហ្មដែលឈ្មោះថា **សុភកិណ្ហ** ព្រោះមានន័យថា ចិញ្ចាចចិញ្ចែងទៅដោយពណ៌យ៉ាងល្អស្អាត គឺ ដោយរស្មីកាយដ៏សោភា ទើបភ្លឺស្អាតដូចបន្ទះមាស បញ្ចេញពន្លឺចាំងផ្លេកដែលគេរក្សាទុកក្នុងហិបមាស ។ ដោយការកំណត់យកសុភកិណ្ហព្រហ្មទាំងនោះ ( ជាការប្រមូល) ដែលលោកកំណត់យកភូមិរបស់តតិយជ្ឈាននោះទាំងអស់ផង ។ ក៏ព្រហ្មដែលស្ថិតនៅក្នុងជាន់ដូចគ្នាទាំងអស់នោះឯង គប្បីជ្រាបថា ( បានដល់) បរិត្តសុភាព្រហ្ម អប្បមាណសុភព្រហ្ម សុភកិណ្ហព្រហ្ម ។

## *អធិប្បាយ វេហប្ផលព្រហ្ម*

ក្នុងវារៈពោលដោយ **វេហប្ផលព្រហ្ម** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ÷

ព្រហ្មដែលឈ្មោះថា **វេហប្ផល** ព្រោះមានន័យថា មានផលដ៏ ក្រៃលែង លោកពោលថា បានដល់ ព្រហ្មជាន់ចតុត្ថជ្ឈាន ។ ចំណែក ការអធិប្បាយន័យប្រកបក្នុងវារៈទាំង ៣ នេះ គប្បីជ្រាបតាមន័យដែលពោល ហើយក្នុងភូតវារៈនោះឯង ។

## *អធិប្បាយ អភិភូព្រហ្ម*

ក្នុងវារៈពោលថា **អភិភូ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

ដែលឈ្មោះថា **អភិភូ** ព្រោះមានន័យថា គ្របសង្កត់។សួរថា គ្របសង្កត់អ្វី ? ឆ្លើយថា គ្របសង្កត់នូវអរូបក្ខន្ធ ៤ ។ ពាក្យថា **អភិភូ** នោះ ជាឈ្មោះរបស់អសញ្ញីភព ។ ពួកទេព ( ព្រហ្ម ) អសញ្ញីសត្វ ឋិតនៅក្នុងជាន់ជាមួយនឹងវេហប្ផលព្រហ្ម ( តែថា ញែក ) ឋិតនៅក្នុង ឱកាសមួយ , លោកកើត ( ស្លាប់ពីមនុស្ស ) ដោយឥរិយាបថណា ក៏ឋិត នៅក្នុងឥរិយាបថនោះៗឯង ដរាបអាយុក្ខ័យស្រដៀងនឹងរូបចិត្រកម្ម ក្នុងទី នេះ លោកសំដៅដល់ វេហប្ផលព្រហ្ម និង អសញ្ញីសត្វទាំងអស់នោះ

ដោយពាក្យថា **អភិភូ** ។ អាចារ្យពួកខ្លះ លើកសរសើរព្រហ្មដែលជាធំក្នុងជាន់នោះ ៗ ថា ( **អភិភូ** ) ដោយន័យមានជាអាទិយ៉ាងនេះថា ព្រហ្ម ១.០០០ ឈ្មោះថា **អភិភូ** ។ តែគប្បីជ្រាបថា ពាក្យពោលរបស់អាចារ្យពួកខ្លះនោះមិនត្រឹមត្រូវ ព្រោះព្រហ្មដែលជាធំនោះ លោកបានបញ្ជាក់កាន់យកដោយ សព្ទថា « **ព្រហ្ម** » ហើយនោះឯង ។ ម្យ៉ាងទៀត ក្នុងវារៈនេះ គប្បីជ្រាបន័យនៃការអធិប្បាយពង្រីកសេចក្តីថាបុថុជ្ជនបានស្តាប់ហើយថាព្រហ្មអភិភូមាន វណ្ណៈ ( ល្អស្អាត ) មានអាយុវែង ដូច្នេះ ហើយកើតសេចក្តីត្រេកអរពេញចិត្តក្នុងព្រហ្មអភិភូនោះ ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូ ដោយការសម្គាល់ព្រោះអំណាចតណ្ហា ឬថា សូម្បីតាំងចិត្ត ( ប្រាថ្នា) ដើម្បីឱ្យបាន ( កើតក្នុងព្រហ្មអភិភូ ) ដែលខ្លួនមិនទាន់បាន ដោយន័យជាអាទិថា ធ្វើម្តេចហ្ន៎ ! យើងនឹងគប្បីចូលដល់ភាពជាសម្លាញ់របស់ព្រហ្មអភិភូ ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូ ដោយការសម្គាល់ព្រោះអំណាចតណ្ហា , ម្យ៉ាងទៀត កាលបើសម្គាល់ខ្លួនថា ថោកទាបជាង ( ព្រហ្មអភិភូ ) ឬ សម្គាល់ថា ព្រហ្មអភិភូប្រសើរជាងខ្លួន ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូដោយការសម្គាល់ព្រោះអំណាចមានះ កាលប្រកាន់ដោយន័យមានជាអាទិថា ព្រហ្មអភិភូ ទៀង

ឋិតថេរ ឈ្មោះថា រមែងសម្គាល់ព្រហ្មអភិភូដោយការសម្គាល់ព្រោះអំណាច ទិដ្ឋិ ។ ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងបឋាបតីវារៈនោះឯង ។

## សុទ្ធាវាសភូមិ

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទេវលោកដោយលំដាប់យ៉ាងនេះ កាលទ្រង់សម្ដែងអសញ្ញីភព ដោយពាក្យថា **អភិភូ** ឥឡូវនេះ ព្រោះកថាសម្ដែងដោយវដ្ដកប្ប ហើយទេវតា គឺ ព្រះអនាគាមី និង ព្រះខីណាស្រព ជាន់សុទ្ធាវាសអ្នកតាំងនៅក្នុងចំណែកនៃវិវដ្ដកប្ប ឬ ព្រោះហេតុដែលទេវតាទាំងនោះមានអាយុតាំងពី ២.០០០ , ៣.០០០ កប្ប រមែងមានក្នុងវេលាដែលព្រះសម្ពុទ្ធស្ដេចឧប្បត្តិទេឡើងប៉ុណ្ណោះ ក៏ព្រះសម្ពុទ្ធទាំងឡាយទ្រង់មិនឧប្បត្តិទេឡើង សូម្បីរហូតអសង្ខេយ្យកប្ប ក្នុងកាលនោះ ភូមិនោះ សូន្យទទេ ភពជាន់សុទ្ធាវាស រមែងមានចំពោះ ( កាលដែល ) ព្រះសម្ពុទ្ធទាំងឡាយ ( ឧប្បត្តិប៉ុណ្ណោះ ) ដូចក្រទឡាព្រះបន្ទំទុកសម្រាប់ព្រះរាជាដូច្នោះ និង ដោយហេតុនោះ ៗ ឯង ភូមិនោះ លោកទើបមិនបានចាត់ជាវិញ្ញាណដ្ឋិតិទាំងមិនបានចាត់ថា សត្តាវាស តែការសម្គាល់យ៉ាងនេះមាននៅគ្រប់កាល ដូច្នេះ កាលទ្រង់សម្ដែងភូមិនៃការសម្គាល់ទាំងនោះ ដែលមានគ្រប់កាល ព្រះមាន_

ព្រះភាគ ទើបលះជាន់សុទ្ធាវាសហើយ ត្រាស់ពាក្យជាដើមថា **អាកាសា-នញ្ចាយតនំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អាកាសានញ្ចាយតនំ** បានដល់ ខន្ធ ៤ ដែលជាកុសលវិបាក និង កិរិយាដែលប្រព្រឹត្តទៅក្នុងអាកាសានញ្ចាយតនភូមិនោះ ហើយខន្ធទាំងទឡាយទាំងនោះ គប្បីឃើញថា កើតទឡើងក្នុងភូមិនោះឯង ព្រោះហេតុថា កថានេះជាការពោលដល់ ការកំណត់ភព ។ ក្នុងវិញ្ញាណញ្ចាយតនៈជាដើម ក៏ន័យនេះ ។ ក៏ក្នុងបណ្ដាវារៈ ៤ វារៈនោះឯង ការបរិយាយសេចក្ដី គប្បីជ្រាបដោយន័យដែលពោលទុកក្នុង អភិភូវារៈ និង ការសម្គាល់ដោយអំណាចនៃមានះ ក្នុងសេចក្ដីនេះ រមែងប្រើបាន សូម្បីដោយន័យដែលពោលហើយក្នុងបជាបតីវារៈ ។

## អធិប្បាយបទថា ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងទីតាំងនៃការសម្គាល់ដោយប្រភេទមានការផ្សេងគ្នារវាងភូមិជាដើមនោះ សូម្បីដោយពិស្ដារយ៉ាងនេះហើយ ពេលនេះ កាលនឹងប្រមូលសម្ដែងប្រភេទនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលរាប់បញ្ចូលក្នុងសក្កាយទិដ្ឋិ ដែលជាទីតាំងនៃសេចក្ដីសម្គាល់ទាំងអស់ ដោយ

ហេតុ ៤ យ៉ាង មានរូបារម្មណ៍ដែលខ្លួនឃើញហើយជាដើម ទើបត្រាស់ពាក្យជាដើមថា **ទិដ្ឋំ ទិដ្ឋតោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋំ** សំដៅដល់ វត្ថុដែលមើលឃើញដោយមំសចក្ខុខ្លះ ទិព្វចក្ខុខ្លះ ។ ពាក្យថា **ទិដ្ឋំ** នោះ ជាឈ្មោះរបស់រូបាយតនៈ ។

បណ្ដាបទទាំងនោះ បទថា **ទិដ្ឋំ មញ្ញតិ** សេចក្ដីថា បុថុជ្ជនរមែងសម្គាល់ដោយការសម្គាល់ទាំង ៣ ។ យ៉ាងណា ? គឺ បុថុជ្ជនកាលមើលរូបាយតនៈដោយសុភសញ្ញា និង សុខសញ្ញា ឈ្មោះថា រមែងញ៉ាំងឆន្ទរាគៈឱ្យកើតក្នុងរូបាយតននោះ គឺ រមែងត្រេកអរ រីករាយ ចំពោះរូបាយតនៈនោះ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ សត្វទាំងទឡាយត្រេកអរវង្វេង ជាប់ជំពាក់ចិត្តក្នុងរូបស្ត្រី សត្វទាំងនោះធ្លាក់នៅក្នុងអំណាចរបស់រូបស្ត្រី រមែងសោកសៅអស់កាលដ៏យូរដូច្នេះ ។ បុថុជ្ជនឈ្មោះថា រមែងសម្គាល់រូបារម្មណ៍ដែលខ្លួនឃើញហើយ ដោយការសម្គាល់ព្រោះអំណាចនៃតណ្ហាយ៉ាងនេះ ឬថា បុថុជ្ជនកាលប្រាថ្នារូបសម្បត្តិ រមែងឱ្យ

ទាន សេចក្តីពិស្តារដូចពោលមកនេះឯង ។ បុថុជ្ជន រមែងសម្គាល់រូបារម្មណ៍ ដែលខ្លួនឃើញហើយ ដោយការសម្គាល់ ព្រោះអំណាចនៃតណ្ហាយ៉ាងនេះ ។

ម្យ៉ាងទៀត បុថុជ្ជនរមែងសម្គាល់រូបាយតនៈថា ទៀង ឋិតថេរ រមែងសម្គាល់ថា ជាអត្តា ជាប់ក្នុងអត្តា រមែងសម្គាល់ក្នុងរូបាយតនៈ ដែលជាមង្គលថា ជាអមង្គល បុថុជ្ជនរមែងសម្គាល់រូបាយតនៈដែលខ្លួនឃើញ ដោយការសម្គាល់ ព្រោះអំណាចនៃទិដ្ឋិ ដោយប្រការដូច្នេះ ។

បុថុជ្ជនឈ្មោះថា រមែងសម្គាល់រូបាយតនៈដែលខ្លួនឃើញដោយការសម្គាល់ទាំង ៣ ដោយប្រការដូច្នេះ ។ រមែងសម្គាល់ក្នុងរូបាយតនៈ ដែលខ្លួនឃើញហើយ យ៉ាងណា ? គឺ បុថុជ្ជនកាលសម្គាល់ដោយន័យពិចារណាឃើញ អត្តាក្នុងរូប ឈ្មោះថា រមែងសម្គាល់ក្នុងរូបាយតនៈដែលខ្លួនឃើញ ។ សូម្បីសម្គាល់ថា រាគៈជាដើម រមែងកើតមានក្នុងរូប ដូចជាទឹកដោះ រមែងកើតមានក្នុងកន្សោមដោះ ដូច្នេះ ។ ឈ្មោះថា រមែងសម្គាល់ក្នុងរូបាយតនៈដែលខ្លួនឃើញ ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

ម្យ៉ាងទៀត កាលបុថុជ្ជននោះ ញុំាងសេចក្តីស្នេហា និង មានះ ឱ្យ

កើតទេឡើងក្នុងវត្ថុដែលសម្គាល់ដោយការសម្គាល់ ព្រោះអំណាចនៃទិដ្ឋិនោះឯង ។ គប្បីជ្រាបថា ជាការសម្គាល់ដោយការសម្គាល់ ព្រោះអំណាចនៃតណ្ហា និង មានះ ផង ។ បុថុជ្ជនឈ្មោះថា រមែងសម្គាល់ក្នុងរូបាយតនៈដែលខ្លួនឃើញ ដោយប្រការដូច្នេះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងបឋវីវារៈ ។

បទថា **សុតំ** សំដៅដល់ បានឮដោយមំសសោតៈខ្លះ ទិព្វសោតខ្លះ ។ ពាក្យថា **សុតំ** នោះ ជាឈ្មោះរបស់សទ្ទាយតនៈ ។

បទថា **មុតំ** នោះ បានដល់ ការជ្រាប និង ដឹងហើយទទួលយក អធិប្បាយថា ចូលទៅប៉ះខ្ទប់ទទួលយក ។ លោកពោលអធិប្បាយទុកថា ដឹងច្បាស់ព្រោះការប៉ះខ្ទប់គ្នានៃឥន្ទ្រិយ៍ និង អារម្មណ៍ទាំងទឡាយ ។

ពាក្យថា **មុតំ** នោះ ជាឈ្មោះរបស់គន្ធាយតនៈ រសាយតនៈ និង ផោដ្ឋព្វាយតនៈ ។ បទថា **វិញ្ញាតំ** ប្រែថា ដឹងផ្លូវចិត្ត ។ ហើយពាក្យថា **វិញ្ញាតំ** នោះ ជាឈ្មោះរបស់អាយតនៈ ៧ ដ៏សេស ។

ម្យ៉ាងទៀត ជាឈ្មោះ របស់ធម្មាយតនៈ ( ក៏បាន ) តែក្នុងទីនេះបាន ចំពោះអារម្មណ៍ដែលរាប់បញ្ចូលក្នុងកាយរបស់ខ្លួន ( សក្កាយទិដ្ឋិ ) ។ ក្នុង

សេចក្តីនេះ គប្បីជ្រាបសេចក្តីពិស្តារតាមន័យដែលពោលទុកហើយក្នុងទិដ្ឋិវារៈ។

## *អធិប្បាយបទថា ឯកត្តំ នានត្តំ*

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងប្រភេទនៃសក្កាយទិដ្ឋិទាំងអស់ ដោយអារម្មណ៍ ៤ ប្រការ មានរូបារម្មណ៍ដែលខ្លួនឃើញហើយជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងប្រភេទរបស់សក្កាយទិដ្ឋិនោះឯងចេញជាពីរប្រការ គឺ ដោយវារៈរបស់លោកដែលចូលសមាបត្តិ ១ របស់លោកដែលមិនបានចូលសមាបត្តិ ១ ទើបទ្រង់ត្រាស់ពាក្យជាដើមថា **ឯកត្តំ នានត្តំ** ដូច្នេះ ។ ដោយបទថា **ឯកត្តំ** នេះ ព្រះអង្គទ្រង់សម្តែងវារៈរបស់លោកអ្នកចូលសមាបត្តិ ។ ដោយបទថា **នានត្តំ** នេះ ព្រះអង្គទ្រង់សម្តែងវារៈរបស់លោកដែលមិនចូលសមាបត្តិ ។

ទាំងពីរពាក្យនោះ មានន័យចំពោះពាក្យដូចតទៅនេះ ÷

ភាវៈដែលមានន័យតែមួយ ឈ្មោះថា **ឯកត្តំ** , ភាវៈដែលផ្សេង ៗ ពីគ្នា ឈ្មោះថា **នានត្តំ** ។ ចំណែកការបរិយាយន័យក្នុងសេចក្តីនេះ បណ្ឌិតគប្បីចែកវារៈរបស់លោកអ្នកដែលចូលសមាបត្តិដោយខន្ធ ៤ និង វារៈរបស់លោកអ្នកដែលមិនចូលសមាបត្តិដោយខន្ធ ៥ ហើយពិចារណាតាមសមគួរ ដោយ

សាសនន័យ ( ព្រះបាលី ) ជាដើមថា បុថុជ្ជនរមែងឃើញរូបជាអត្តា និង តាមន័យនៃអដ្ឋកថា ដែលលោកពោលទុកក្នុងបឋវីវារៈជាដើម ។ ចំណែក អាចារ្យពួកខ្លះ រមែងពោលឯកត្តន័យ ដោយបទនេះថា **ឯកត្តំ** ។ ពោល ន័យដែលផ្សេងពីគ្នាដោយបទនេះថា **នានត្តំ** ដូច្នេះ ។ អាចារ្យពួកដទៃ ពោលនូវការប្រកាន់មាំនោះ ដោយអំណាចនៃទិដ្ឋិយ៉ាងនេះថា អត្តារមែងមាន សញ្ញាដូចគ្នា មិនដាច់សូន្យ ពេលស្លាប់ហើយ អត្តារមែងមានសញ្ញាផ្សេង គ្នា។ ពាក្យទាំងអស់នេះ មិនត្រឹមត្រូវទេឡើយ ព្រោះលោកមិនបានបំណង យកក្នុងទីនេះ ។

## *អធិប្បាយ សព្វំ សព្វតោ*

ព្រះមានព្រះភាគ លុះទ្រង់សម្តែងសក្កាយទិដ្ឋិទាំងអស់ជា ២ យ៉ាង យ៉ាងនេះហើយ ឥទឡូវនេះ កាលនឹងទ្រង់ប្រមូលសម្តែងសក្កាយទិដ្ឋិនោះឯង ឱ្យតែមួយ ទើបត្រាស់ពាក្យជាដើមថា **សព្វំ សព្វតោ** ដូច្នេះ ។

ចំណែកន័យដែលអធិប្បាយក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបដូច្នេះថា បុថុជ្ជនកាលពេញចិត្តវត្ថុទាំងពួង ឈ្មោះថា រមែងសម្គាល់វត្ថុទាំងពួងដោយ ការសម្គាល់ព្រោះអំណាចនៃតណ្ហា កាលសម្គាល់វត្ថុដែលខ្លួនសាងទេឡើងដោយ

ន័យជាដើមថា សត្វទាំងទឡាយនេះ យើងសាងទេឡើង ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់វត្ថុទាំងពួងដោយការសម្គាល់ ព្រោះអំណាចនៃមានះ កាលសម្គាល់ដោយន័យជាដើមថា វត្ថុទាំងពួង មានកម្មដែលខ្លួនធ្វើទុកក្នុងកាលមុន ជាហេតុ វត្ថុទាំងពួងមានការសាងទេឡើងដោយព្រះឥស្វរ ជាហេតុ វត្ថុទាំងពួងមិនមានហេតុមិនមានបច្ច័យវត្ថុទាំងពួងមានវត្ថុទាំងពួងមិនមាន ដូច្នេះ ឈ្មោះថា រមែងសម្គាល់វត្ថុទាំងពួងដោយការសម្គាល់ព្រោះអំណាចនៃ ទិដ្ឋិ ។

បុថុជ្ជន រមែងសម្គាល់ក្នុងវត្ថុទាំងពួងយ៉ាងណា ? គឺថា បុគ្គលពួកខ្លះក្នុងលោកនេះ មានការឃើញយ៉ាងនេះថា អត្តារបស់យើងនេះធំ បុគ្គលនោះកំណត់លោកសន្និវាសទាំងអស់ ដោយជាឱកាសនៃអត្តានោះ រមែងសម្គាល់ថា ក៏អត្តារបស់យើងនេះនោះឯង មានហើយនៅក្នុងលោកសន្និវាសទាំងពួង ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុគ្គលនោះ ។

ក៏កាលគេញ៉ាំងសេចក្ដីស្នេហាក្នុងអត្តានោះឯង ញ៉ាំងមានះដែលមានក្នុងអត្តានោះ ជាទីតាំងឱ្យកើតទេឡើងនៅក្នុងខ្លួន គប្បីជ្រាបថា សូម្បីការសម្គាល់ដោយអំណាចតណ្ហា និង មានះ ( ក៏កើតទេឡើងដែរ ) ។ ពាក្យថាដ៏សេស

គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងបឋវីវារៈ នោះឯង ។

*កែបទ និព្វានំ និព្វានតោ*

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងសក្កាយទិដ្ឋិទាំងអស់ឱ្យតែមួយយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងសក្កាយទិដ្ឋិនោះឱ្យតែម្យ៉ាងដោយន័យផ្សេងៗទៀត ទើបត្រាស់ពាក្យជាដើមថា **និព្វានំ និព្វានតោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និព្វានំ** មានន័យថា គប្បីជ្រាបបរមនិព្វានក្នុងបច្ចុប្បន្នដែលមានមកហើយដោយចំណែក ៥ ( មានហើយ ៥ យ៉ាង ) ដោយន័យជាដើមថា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុដែលអត្តាឆ្អែតបរិបូណ៌ដោយកាមគុណ៥ឱ្យគេបម្រើដោយកាមគុណ៥ ម្នាលអ្នកដ៏ចម្រើន យ៉ាង នេះឯងអត្តានេះ ទើបសម្រេចនិព្វានក្នុងបច្ចុប្បន្ន ។ ក្នុងសេចក្ដីនេះ បុថុជ្ជនកាលត្រេកអរនឹងនិព្វាន គប្បីជ្រាបថា ឈ្មោះថា រមែងសម្គាល់ដោយការសម្គាល់ព្រោះអំណាចតណ្ហា ។ បុថុជ្ជនកាលញ៉ាំងមានៈឱ្យកើតទេឡើង មានៈថាយើងរមែងសម្រេចនិព្វាន គប្បីជ្រាបថា ឈ្មោះថា តែងសម្គាល់ដោយការសម្គាល់ព្រោះអំណាចនៃមានៈ ។ កាលបើប្រកាន់ **អស្សាទ** ( សេចក្ដី

ត្រេកអរ) ដែលមិនមែននិព្វាន ថាជានិព្វាន និង ប្រកាន់និព្វានដោយ អស្សាទៈ គប្បីជ្រាបថាឈ្មោះថាតែងសម្គាល់ដោយការសម្គាល់ព្រោះអំណាច នៃទិដ្ឋិ ។

ចំណែកបុថុជ្ជន កាលប្រកាន់អត្តាផ្សេងពីនិព្វាន ហើយសម្គាល់ថា ក៏អត្តារបស់យើងនេះនោះឯង រមែងមានក្នុងនិព្វាននេះ ឈ្មោះថា រមែងសម្គាល់ក្នុងនិព្វាននេះ ជាការសម្គាល់ដោយការសម្គាល់ព្រោះអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបើបុថុជ្ជននោះ កើតសេចក្ដីស្នេហាក្នុងអត្តានោះ នោះឯង នឹងកើតមានះដែលមានអត្តានោះជាទីតាំង គប្បីជ្រាបថា សូម្បីការសម្គាល់ដោយអំណាចនៃតណ្ហា និង មានះ ( ក៏កើតទេឡើងដែរ ) ។

សូម្បីន័យក្នុងការសម្គាល់ក្រៅពីនិព្វាន ក៏មានន័យដូច្នេះ ។ ពិត ហើយសូម្បីក្នុងសេចក្ដីនេះ បុថុជ្ជនកាលប្រកាន់អត្តាថា ដទៃផ្សេងពីនិព្វាន សម្គាល់ថា នេះនិព្វាន នេះអត្តា ក៏អត្តារបស់យើងនេះនោះ ដទៃផ្សេងពី និព្វាន ឈ្មោះថា រមែងសម្គាល់ក្រៅពីនិព្វាន ។ នេះជាការសម្គាល់ដោយ

អំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។ កាលបើបុថុជ្ជនកើតសេចក្តីស្នេហាក្នុងអត្តានោះ នឹងកើតមានៈដែលមានអត្តានោះជាទីតាំង សូម្បីតណ្ហា និង មានៈ ក៏គប្បីជ្រាបថា ( កើតទេឡើងដែរ ) ប៉ុន្តែបើសម្គាល់ថា ឱ ! និព្វានរបស់យើងសុខពិតគប្បីជ្រាបថាឈ្មោះថារមែងសម្គាល់ថានិព្វានជារបស់យើង ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ។

ក៏ក្នុងសេចក្តីនេះ មានពាក្យជាគាថាប្រព័ន្ធដូចតទៅនេះ ÷

**កាយរបស់ខ្លួននេះគឺអ្វី កាលបុថុជ្ជនមិនដឹងកាយរបស់ខ្លួននោះ**

**តាមសេចក្តីពិត ការសម្គាល់(ខុស)គ្រប់យ៉ាងរមែងកើតទេឡើង**

**ក្នុងកាយរបស់ខ្លួន កាយរបស់ខ្លួននេះគួរខ្ពើមមានការបែកធ្លាយ**

**ទៅជាធម្មតា ជាទីកើតទេឡើងនៃទុក្ខ មិនមានអ្នកដឹកនាំ ។**

**បុគ្គលពាល កាលប្រកាន់កាយនោះ ដោយភាពជាសត្រូវ**

**( ដល់សេចក្តីពិត ) ឈ្មោះថា រមែងប្រកាន់ការសម្គាល់**

**( ខុស ) កាលបុថុជ្ជនពិចារណាឃើញកាយរបស់ខ្លួន ថាជា**

**របស់ស្អាតនិងជាសុខ រមែងមានការសម្គាល់ខុសដោយអំណាច**

នៃតណ្ហា ដូចការសម្គាល់ខុសក្នុងភ្លើង របស់សត្វមមាចដូច្នោះ កាលបុថុជ្ជន ប្រកាន់និច្ចសញ្ញា ឃើញសម្បត្តិរបស់កាយនៃខ្លួននោះ គេរមែងមានការសម្គាល់ខុសដោយអំណាចមានះ ដូចសុនខឃើញលាមក ហើយកើតសុភសញ្ញាក្នុងលាមក ដូច្នោះ កាលបុថុជ្ជនពិចារណាឃើញកាយរបស់ខ្លួននោះថា ជាអត្តានៅក្នុងអត្តា មិនយល់តាមសេចក្តីពិតរមែងមានការសម្គាល់ខុសដោយទិដ្ឋិ ដូចបុគ្គលសម្គាល់រូបក្នុងកញ្ចក់ដូច្នោះក៏ពាក្យថា ការសម្គាល់នេះជាពាក្យល្អិត ជាគ្រឿងចងរបស់មារធ្ងរ ប៉ុន្តែស្រាយបានដោយលំបាក ព្រោះជាគ្រឿងដែលចងបុថុជ្ជនទុក បុថុជ្ជន សូម្បីព្យាយាមរើបម្រះដោយវិធីផ្សេង ៗ ច្រើនយ៉ាង ក៏មិនកន្លងផុតកាយរបស់ខ្លួនទៅបាន រមែងត្រូវកាយរបស់ខ្លួននោះចងរឹតទុកយ៉ាងណែន ដូចសុនខដែលត្រូវចងលាមទុកជាប់នឹងបង្គោលដែលគេបោះទុកយ៉ាងល្អ បុគ្គលដ៏សេសរមែងស្រវឹងវិលវល់នៅក្នុងកាយរបស់ខ្លួន រមែងក្តៅក្រហាយជានិច្ច

ដោយជាតិ ជរា និង ទុក្ខ មានរោគជាដើមដូចត្រីជាប់សន្ទូច ដូច្នោះ ទើបយើងសូមពោលនឹងអ្នកដ៏ចម្រើនទាំងទឡាយថា អ្នកទាំងទឡាយពិចារណាកាយរបស់ខ្លួន ដែលល្អស្អាតឱ្យឃើញថា មិនគួរពេញចិត្ត មិនស្អាត មានការបែកធ្លាយទៅ ( ជាធម្មតា ) និង មិនមែនអត្តា ព្រោះកាយរបស់ខ្លួននោះមានសភាពយ៉ាងនេះ បណ្ឌិតពិចារណាឃើញកាយនេះ យ៉ាងនេះ ហើយលះបង់សេចក្ដីសម្គាល់ខុសទាំងអស់ ចេញបាន រមែងរលាស់ផុតចាកទុក្ខទាំងពួង ដូច្នេះ ។

( ចប់កថាពោលដោយន័យ ទី ១« ខ » ទី ២៤ ដោយអំណាចបុថុជ្ជន )

## សេក្ខបុគ្គល

ព្រះដ៏មានព្រះភាគ លុះទ្រង់សម្តែងនូវការប្រព្រឹត្តិទៅរបស់បុថុជ្ជន ដែលមានធម៌ គឺ សក្កាយទិដ្ឋិទាំងអស់ជាមូលក្នុងវត្ថុធាតុ មានបថវីជាដើម ដូចពណ៌នាមកនេះ ។ ឥឡូវនេះ កាលនឹងសម្តែងការប្រព្រឹត្តិទៅរបស់ព្រះ-សេក្ខបុគ្គលក្នុងវត្ថុធាតុទាំងនោះដូចគ្នា ទើបត្រាស់ពាក្យជាដើមថា **យោបិ សោ ភិក្ខុ សេក្ខោ** ដូច្នេះ។បណ្តាបទទាំងនោះពាក្យថា **យោ** ជាពាក្យ ផ្តើមទេឡើង ។ ពាក្យថា **សោ** ជាពាក្យសម្តែងអធិប្បាយ ។

**បិ** អក្សរ មានការប្រមូលមកជាអត្ថ ដូចក្នុងប្រយោគថា ធម៌ទាំងនេះ មិនទៀងដូច្នេះ ។

ក៏ដោយ **បិ** ស័ព្ទនោះរមែងប្រមូលមកនូវបុគ្គលដោយភាពស្មើគ្នា នៃអារម្មណ៍ មិនមែនប្រមូលមកដោយភាពស្មើគ្នានៃបុគ្គលទេ តែដោយកំណត់ យ៉ាងទាប បានដល់ បុគ្គលដែលមានទិដ្ឋិវិបត្តិ ក្នុងទីនេះបំណាងយកបុគ្គល ដែលសម្បូណ៌ដោយទិដ្ឋិ ភាពស្មើគ្នានៃបុគ្គលទាំងពីរនោះមិនមាន តែអារម្មណ៍ របស់បុគ្គលពួកដំបូង ( អ្នកមានទិដ្ឋិវិបត្តិ ) យ៉ាងណា អារម្មណ៍របស់បុគ្គល

ពួកក្រោយទាំងនេះ (អ្នកសម្បូណ៍ដោយទិដ្ឋិ) ក៏ដូច្នោះដូចគ្នា ដោយ ហេតុនោះ លោកទើបពោលថា រមែងប្រមូលមកនូវបុគ្គលដោយភាពស្មើគ្នា នៃអារម្មណ៍ មិនបានប្រមូលមកដោយភាពស្មើគ្នានៃបុគ្គលទេឡើយ ។

គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្តែងព្រះសេក្ខបុគ្គល ដែលនឹងគប្បីពោលក្នុងពេលនេះ ដោយពាក្យទាំងអស់នេះថា **យោបិ សោ** ។ បទថា **ភិក្ខវេ ភិក្ខុ** នេះ មានន័យដូចពោលហើយនោះឯង ។ បទថា **សេក្ខោ** មានសេចក្តីថា ដែលឈ្មោះថា **សេក្ខ** ព្រោះអត្ថថា ដូចម្តេច ? ឆ្លើយថា ដែលឈ្មោះថា **សេក្ខ** បានដល់ សេក្ខធម៌ ។ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុទាំងទឡាយទូល សួរថា បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា **សេក្ខ** ដោយធម៌ត្រឹមណា ? ព្រះសម្ពុទ្ធត្រាស់តបថា ម្នាលភិក្ខុទាំងទឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រកបដោយសម្មាទិដ្ឋិដែលជាសេក្ខៈ ។ ល ។ ជាអ្នកប្រកបដោយសម្មាសមាធិដែលជាសេក្ខៈ ភិក្ខុឈ្មោះថាសេក្ខៈ ដោយធម៌មានប្រមាណប៉ុណ្ណោះឯង ។

ម្យ៉ាងទៀត បុគ្គលឈ្មោះថា **សេក្ខ** ព្រោះអត្ថថា នៅសិក្សា ដូច្នេះ ខ្លះ ។ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុសិក្សា

ដូច្នេះឯង ដូច្នេះ លោកទើបហៅថា សេក្ខៈ, សួរថា ព្រះសេក្ខបុគ្គល រមែងសិក្សាអ្វី ? ឆ្លើយថា រមែងសិក្សាអធិសីលសិក្ខាខ្លះ អធិចិត្តសិក្ខាខ្លះ អធិប្បញ្ញាសិក្ខាខ្លះ ភិក្ខុរមែងសិក្សាយ៉ាងនេះឯង ព្រោះដូច្នេះ ទើបលោក ពោលថា **សេក្ខ** ។

បុគ្គលណា សូម្បីជាកល្យាណបុថុជ្ជន ជាអ្នកធ្វើឱ្យបរិបូណ៌ដោយអនុ-លោមបដិបទា មានសីលបរិបូណ៌ មានទ្វាររក្សាហើយក្នុងឥន្ទ្រិយ៍ទាំងទឡាយ ដឹងប្រមាណក្នុងការបរិភោគភោជន តាមប្រកបសេចក្តីព្យាយាមរបស់បុគ្គលអ្នកភ្ញាក់ តាមប្រកបភាវនានុយោគនូវពោធិបក្ខិយធម៌អស់រាត្រីនោះ និង ចុងរាត្រីដោយគិតថា យើងនឹងសម្រេចសាមញ្ញផលណាមួយក្នុងថ្ងៃនេះ ឬព្រឹក នេះ បុគ្គលនោះលោកហៅថា **សេក្ខ** ព្រោះកំពុងសិក្សា ។ តែក្នុងន័យនេះ បុគ្គលដែលសម្រេចបដិវេធប៉ុណ្ណោះ លោកបំណងយកជាសេក្ខៈ មិនបាន បំណងយកបុថុជ្ជនទេ ។

## អធិប្បាយពាក្យថា « មានស »

**មានស** ដែលបុគ្គលនោះ មិនទាន់បានសម្រេចហើយ ដូច្នោះ បុគ្គល នោះ ឈ្មោះថា អ្នកមានមានសៈដែលមិនទាន់បានសម្រេច ។ រាគៈក្តី

ចិត្តក្តី ព្រះអរហត្តក្តី ឈ្មោះថា **មានស** ។

ពិតណាស់ **រាគ** ឈ្មោះថា **មានស** ដូចក្នុងប្រយោគនេះថា មានសៈ នេះណា រមែងត្រាច់ទៅដូចជាអន្ទាក់សំណាញ់ ដែលត្រាច់ទៅក្នុងអាកាស ដូច្នោះ ។

**ចិត្ត** ឈ្មោះថា **មានស** ដូចក្នុងប្រយោគថា **ចិត្ត មនោ មានស** ។

**ព្រះអរហត្ត** ឈ្មោះថា **មានស** ដូចក្នុងប្រយោគថា បពិត្រលោកម្ចាស់ដែលជាធំជាងពពួកជន ព្រះសេក្ខៈមានព្រះអរហត្តមិនទាន់បានសម្រេច គប្បីធ្វើកាលកិរិយា ដូច្នេះ ។

ព្រះអរហត្តប៉ុណ្ណោះ លោកបំណងយក **មានស** ក្នុងទីនេះ ដោយ ហេតុនោះ ទើបមានពាក្យអធិប្បាយដែលលោកពោលទុកថា អ្នកមានព្រះ_អរហត្ត ដែលមិនទាន់បានសម្រេច ។ បទថា **អនុត្តរំ** ប្រែថា ប្រសើរបំផុត អធិប្បាយថា មិនមានធម៌អ្វីប្រៀបផ្ទឹមបាន ។ ព្រះអរហត្តប៉ុណ្ណោះ លោក បំណងយកថា ធម៌ដែលជាដែនក្សេមចាកយោគៈ ព្រោះមានន័យថា ក្សេមចាក

យោគៈ ៤ គឺ យោគៈ ៤ មិនប្រទូសរ៉ាយ ។

បទថា **បត្ថយមានោ** មានវិនិច្ឆ័យថា សេចក្តីប្រាថ្នាមានពីរយ៉ាង គឺ សេចក្តីប្រាថ្នាដោយអំណាចតណ្ហា និង សេចក្តីប្រាថ្នាដោយអំណាចឆន្ទៈ ។ ប្រាថ្នាដោយអំណាចតណ្ហា រមែងបានក្នុងប្រយោគថា ÷

**ក៏កាលបុគ្គលមានសេចក្តីប្រាថ្នាហើយ តណ្ហារមែងកើត**

**ទេឡើងខ្សឹបប្រាប់ ទាំងចិត្តក៏ជាប់ជំពាក់នៅក្នុងអារម្មណ៍ដែល**

**តណ្ហា និង ទិដ្ឋិប្រកាន់ហើយ ដូច្នេះ ។**

ភាពជាអ្នកបំណងនឹងធ្វើ គឺ សេចក្តីប្រាថ្នាដោយអំណាចឆន្ទៈដែលជាកុសលរមែងបានក្នុងប្រយោគថា ÷

**ក្រសែនៃតណ្ហារបស់បុគ្គលដែលមានចិត្ត អាក្រក់អស់ទៅ**

**ហើយ ដែលគេកម្ចាត់បានហើយ ធ្វើឱ្យវិនាសទៅហើយ**

**ម្នាលភិក្ខុទាំងទឡាយ អ្នកទាំងទឡាយចូរជាអ្នកច្រើនដោយ**

**បាមោជ្ជៈ គប្បីប្រាថ្នាធម៌ដែលជាដែនក្សេមចាកយោគៈចុះ**

**ដូច្នោះ ។**

សេចក្តីប្រាថ្នាដោយអំណាចឆន្ទៈនេះ ប៉ុណ្ណោះ លោកបំណងយកក្នុង

ទីនេះ ។

បទថា **តេន បត្ថយមានោ** មានន័យថា បុគ្គលដែលមានសេចក្តីបំណងនឹងធ្វើ គឺ ប្រាថ្នានឹងសម្រេចនូវធម៌ដែលជាដែនក្សេមចាកយោគៈនោះ គប្បីជ្រាបថា អ្នកបង្អោនទៅ ទោរទៅ ( ដើម្បីសម្រេចធម៌ដែលជាដែនក្សេមចាកយោគៈ ) ។

បទថា **វិហរតិ** មានន័យថា បំបាត់ទុក្ខដែលកើតក្នុងឥរិយាបថដទៃដោយឥរិយាបថដទៃទៀត រក្សារាងកាយមិនឱ្យទ្រុឌទ្រោម ។

ម្យ៉ាងទៀត គប្បីឃើញខ្លឹមសារក្នុងសេចក្តីនេះ ដោយនិទ្ទេសន័យជា ដើមថា បុគ្គលដែលបង្អោនចិត្តទៅដោយការពិចារណាថា សង្ខារទាំងទឡាយ មិនទៀងដូច្នេះ ឈ្មោះថា រមែងរស់នៅដោយសទ្ធា ។

បទថា **បឋវឹ បឋវិតោ អភិជានាតិ** សេចក្តីថា រមែងដឹងច្បាស់នូវ បឋវី ថាជាបឋវីគឺរមែងមិនដឹងដោយសញ្ញាដែលផ្ទុយគ្នាពីអាការទាំងពួងដូច បុថុជ្ជន។ ម្យ៉ាងទៀត រមែងដឹងដោយញាណដ៏វិសេសក្រៃលែង ។ ក្នុងបទថា **បឋវឹ** មានពាក្យដែលលោកពោលអធិប្បាយទុកថា បុគ្គលកាលបើកំណត់ដឹង

បថវីបានយ៉ាងនេះ ក៏រមែងដឹងច្បាស់បថវីនោះ យ៉ាងនេះថា មិនទៀងខ្លះ ជាទុក្ខខ្លះ ជាអនត្តាខ្លះនិងមានពាក្យដែលលោកពោលអធិប្បាយទុកទៀតថា សេក្ខបុគ្គល កាលជ្រាបនូវសភាពបថវីយ៉ាងនេះហើយ រមែងមិនប្រកាន់ បថវី ។ ក៏សេក្ខបុគ្គលនឹងពោលថា មានការប្រកាន់ក៏មិនមែន និង ពោលថា មិនមានការប្រកាន់ក៏មិនមែន ។ ក៏ក្នុងអត្ថនេះ គប្បីជ្រាបថា លោកពោល បញ្ជាក់បទនេះទុក ។

កាលមានអ្នកពោលថា ក្នុងបទនេះមានអធិប្បាយយ៉ាងណា ? ឆ្លើយ ថា ជាដំបូងព្រះមានព្រះភាគត្រាស់ដល់បុថុជ្ជនថា ប្រកាន់បថវី ( ខុស ) ព្រោះ ការប្រកាន់ ( ខុស ) គ្រប់យ៉ាងបុថុជ្ជនលះបង់មិនទាន់បាន ព្រះខីណាស្រព រមែងមិនប្រកាន់ខុស ព្រោះលោកលះបង់ការប្រកាន់ ( ខុស ) គ្រប់យ៉ាងបាន ហើយការសម្គាល់ដោយអំណាចទិដ្ឋិ ព្រះសេក្ខបុគ្គលលះបង់បាន សូម្បីការ ប្រកាន់យ៉ាងដទៃៗក៏មានការស្រាលស្តើង ដោយហេតុនោះ ព្រះសេក្ខនោះនរណាៗ ក៏មិនគួរពោលថា រមែងប្រកាន់ ( ខុស ) ដូចបុថុជ្ជន ទាំងមិនគួរ ពោលថា រមែងមិនប្រកាន់ ( ខុស ) ដូចព្រះខីណាស្រព ។

បទថា **បរិញ្ញេយ្យំ តស្ស** មានន័យថា ទីតាំងនៃការប្រកាន់ (ខុស)

នោះ ដែលព្រះសេក្ខៈនោះ គប្បីកំណត់ដឹងបានដោយបរិញ្ញាទាំង ៣ ព្រោះលោកបានចុះកាន់និយាមធម៌ហើយ និង ព្រោះមានការត្រាស់ដឹង ( ក្នុងមគ្គ ផល ) ជាន់លើជាខាងមុខ ដែលជាទីតាំងនៃការសម្គាល់ ( ខុស ) ឬ ដែលមិនទាន់កំណត់ដឹង មិនមែនលោកមិនកំណត់ដឹង ដូចជាបុថុជ្ជន ទាំងមិនមែនលោកបានកំណត់ដឹងអស់ហើយ ដូចជាព្រះខីណាស្រព ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានន័យដូចពោលមកហើយដូចគ្នា ។

**( ចប់កថា ពោលដោយន័យទី ២ ដោយអំណាចសេក្ខបុគ្គល)**

## អធិប្បាយ ព្រះអរិយបុគ្គល

ព្រះមានព្រះភាគ លុះទ្រង់សម្ដែងការប្រព្រឹត្តិទៅរបស់ព្រះសេក្ខៈក្នុង វត្ថុធាតុមានបឋវីជាដើម ដូចពណ៌នាយ៉ាងនេះហើយ ពេលនេះ កាលនឹងទ្រង់សម្ដែងការប្រព្រឹត្តិទៅរបស់ព្រះខីណាស្រព ទើបត្រាស់ពាក្យជាដើមថា **យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ **បិ** ស័ព្ទ ក្នុងបទថា **យោបិ** មានការប្រមូលមកជាអត្ថ ។ ដោយ **បិ** ស័ព្ទនោះ ព្រះមានព្រះភាគទ្រង់សម្ដែងថា ក្នុង ទីនេះរមែងបានភាពស្មើគ្នាដោយចំណែកទាំង ២ ។ អធិប្បាយថា ព្រះសេក្ខៈ ឈ្មោះថាជាអ្នកស្មើនឹងព្រះខីណាស្រព ព្រោះភាពជាព្រះអរិយបុគ្គល ដោយ ហេតុនោះលោកទើបបានភាពស្មើគ្នាដោយបុគ្គល ចំណែកភាពស្មើគ្នាដោយ អារម្មណ៍ក៏មានន័យដូចពោលហើយ ដូចគ្នា ។

បទថា **អរហំ** អ្នកមានកិលេសនៅឆ្ងាយ អធិប្បាយថា អ្នកមានកិលេសឃ្លាតឆ្ងាយ គឺ មានកិលេសដែលលោកលះបង់បានហើយ ។ សមពិតដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ភិក្ខុជាអរហន្ត យ៉ាងណា គឺ អកុសលធម៌ទាំងទឡាយដ៏លាមក សៅហ្មង

ដែលជាហេតុឱ្យកើតភពថ្មី មានការក្ដៅក្រហាយ មានផលជាទុក្ខ ដើម្បី ជាតិ ជរា និង មរណៈតទៅរបស់លោកអ្នកឃ្លាតឆ្ងាយពីកិលេស រមែងមិន មាន ម្នាលភិក្ខុទាំងទឡាយ ភិក្ខុរមែងជាអរហន្តយ៉ាងនេះឯង ។

បទថា **ខីណាសវោ** មានវិនិច្ឆ័យថា អាសវៈមាន ៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ អាសវៈទាំង ៤ នេះ របស់ព្រះអរហន្ត អស់ហើយ គឺ លោកលះបង់បាន ដកចេញបាន ស្ងប់រំងាប់ ជារបស់មិនគួរ កើតទេឡើងទៀត ដែលលោកដុតបំផ្លាញហើយដោយភ្លើង គឺ ញាណ ដោយ ហេតុនោះ ព្រះអរហន្តនោះ ទើបលោកហៅថា ព្រះខីណាស្រព ។

បទថា **វុសិតវា** សេចក្ដីថា ព្រះអរហន្តនោះនៅចប់ហើយ គឺ នៅ ចប់ហើយក្នុងធម៌ជាគ្រឿងនៅរបស់គ្រូខ្លះ ក្នុងធម៌ជាគ្រឿងនៅ គឺ អរិយមគ្គខ្លះ ក្នុងធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ១០ ប្រការខ្លះ ព្រះអរហន្តនោះ នៅហើយ គឺ នៅចប់ហើយ បានដល់ ធម៌ជាគ្រឿងនៅចប់ហើយ មានចរណៈដែល បានប្រព្រឹត្តហើយ ដូច្នោះទើបឈ្មោះថា ជាអ្នកនៅចប់ហើយ ។

បទថា **កតករណីយោ** មានន័យថា ព្រះសេក្ខៈទាំង ៧ រហូត

ដល់កល្យាណបុថុជ្ជន ឈ្មោះថា រមែងធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ កិច្ច ដែលគប្បីធ្វើគ្រប់យ៉ាង ព្រះខីណាស្រពធ្វើហើយ ធ្វើចប់ស្រេចហើយ កិច្ច ដែលនឹងគប្បីធ្វើរបស់ព្រះខីណាស្រពនោះ ដើម្បីសេចក្ដីសម្រេចការ អស់ ទៅនៃទុក្ខ រមែងមិនមាន ដូច្នោះព្រះអរហន្តនោះ អ្នកដែលមានកិច្ច ត្រូវធ្វើ ធ្វើចប់ស្រេចរៀបរយហើយ ។ សមដូចព្រះតម្រាស់ព្រះមានព្រះភាគ ត្រាស់ ទុកថា ÷

**ការសន្សំកិច្ចដែលត្រូវធ្វើ ក៏ធ្វើស្រេចហើយ របស់ភិក្ខុ**

**ដែលមានចិត្តស្ងប់ រួចផុតហើយដោយប្រពៃរមែងមិន**

**មាន ( ៦ ) កិច្ចដែលគួរធ្វើទៀតក៏មិនមាន ដូច្នេះ ។**

ក្នុងបទថា **ឱហិតភារោ** មានវិនិច្ឆ័យថា ភារៈមាន ៣ គឺ ខន្ធភារៈ កិលេសភារៈ អភិសង្ខារភារៈ , ភារៈ ៣ នេះ ព្រះអរហន្តនោះ ដាក់ចុះហើយ លើកចុះហើយ ធ្វើឱ្យធ្លាក់ទៅហើយ ដោយហេតុនេះ ព្រះអរហន្តនោះ លោក ទើបហៅថា អ្នកមានភារៈដាក់ចុះហើយ ។

បទថា **អនុបត្តសទត្ថោ** មានន័យថា អ្នកមានប្រយោជន៍របស់ខ្លួន បានសម្រេចតាមលំដាប់ហើយ អធិប្បាយថា តាមសម្រេចនូវប្រយោជន៍

របស់ខ្លួន ។ **ក** អក្សរ ផ្លាស់ជា **ទ** អក្សរ ។ ក៏ព្រះអរហត្ត គប្បីជ្រាបថា ជាប្រយោជន៍របស់ខ្លួន ។ ពិតហើយ ព្រះអរហត្តនោះ លោកហៅថា ប្រយោជន៍របស់ខ្លួន គឺ ប្រយោជន៍ខ្លួន ព្រោះអត្ថថា ទាក់ទងជាមួយនឹងខ្លួន ព្រោះអត្ថថា មិនលះបង់ខ្លួន និង ព្រោះអត្ថថា ជាប្រយោជន៍យ៉ាងក្រៃលែងរបស់ខ្លួន ។

បទថា **បរិក្ខីណភវសំយោជនោ** មានវិនិច្ឆ័យថា សំយោជនៈ ១០ គឺ **កាមរាគៈ បដិឃៈ មានៈ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគៈ ឥស្សា មច្ឆរិយៈ** និង **អវិជ្ជា** ហៅថា **សំយោជន** គ្រឿងចងសត្វទុកក្នុងភព ព្រោះសំយោជនៈទាំងនេះ រមែងចង គឺ តាមចងសត្វទាំងទឡាយទុកក្នុងភព ម្យ៉ាងទៀត រមែងដោតក្រងភព និង ភពឱ្យជាប់គ្នា សំយោជន គ្រឿងចងសត្វទុកក្នុងភពទាំងនេះរបស់ព្រះអរហន្តអស់ហើយ លោកលះបង់បានហើយ លោកដុតបំផ្លាញដោយភ្លើង គឺ ញាណ ព្រោះហេតុនោះ ព្រះខីណាស្រពនោះ ទើបឈ្មោះថា អ្នកមានសំយោជនៈគ្រឿងចងសត្វទុកក្នុងភព អស់ដោយប្រពៃហើយ ។

បទថា **សម្មទញ្ញា** ក្នុងបទថា **សម្មទញ្ញា វិមុត្តោ**នេះ មាន ន័យថា ព្រោះដឹងដោយប្រពៃ ។

លោកពោលអធិប្បាយទុក យ៉ាងណា ?

លោកពោលអធិប្បាយទុកថា ព្រោះដឹង គឺ ជ្រាប បានដល់ ការពិចារណា ត្រួតត្រា បើកបង្ហាញ ធ្វើឱ្យជាក់ច្បាស់នូវអត្ថនៃខន្ធ ថាជា ខន្ធ អត្ថនៃអាយតនៈថា ជាអាយតនៈ អត្ថនៃធាតុថា ជាធាតុ អត្ថនៃទុក្ខថា ជាការបៀតបៀន អត្ថនៃសមុទយថា ជាហេតុនាំឱ្យកើតទុក្ខ អត្ថនៃនិរោធថា ជាសេចក្ដីស្ងប់ អត្ថនៃមគ្គថា ជាទស្សនៈ មានប្រភេទយ៉ាងនេះថា សង្ខារទាំងពួងមិនទៀង ដូច្នេះ ដោយប្រពៃ គឺ តាមសេចក្ដីពិត ។

បទថា **វិមុត្តោ** មានវិនិច្ឆ័យថា វិមុត្តិមានពីរយ៉ាងគឺការរួច ស្រឡះនៃចិត្ត ១ ព្រះនិព្វាន ១ ព្រះអរហន្តឈ្មោះថា អ្នករួចស្រឡះហើយសូម្បីការរួចផុតដោយចិត្ត ព្រោះចិត្តរបស់លោករួចផុតហើយពីកិលេសទាំងពួង ឈ្មោះថា រួចផុតហើយសូម្បីក្នុងព្រះនិព្វាន ព្រោះលោកមានចិត្តបង្អោនទៅ កាន់ព្រះនិព្វាន ដោយហេតុនោះ ព្រះអរហន្ត ទើបលោកហៅថា អ្នករួច

ស្រទឡះហើយ ព្រោះដឹងដោយប្រពៃ ។

បទថា **បរិញ្ញាតន្តស្ស** សេចក្ដីថា ទីតាំងនៃសេចក្ដីប្រកាន់ ( ខុស ) នោះ ដែលព្រះអរហន្តកំណត់ដឹងដោយបរិញ្ញាទាំង ៣ ដូច្នោះ ព្រះអរហន្ត នោះ ទើបមិនប្រកាន់ទីតាំងនោះ ម្យ៉ាងទៀត អធិប្បាយថា ព្រះអរហន្ត រមែងមិនប្រកាន់នូវការប្រកាន់ ( ខុស ) នោះ ។ ពាក្យដ៏សេសមានន័យ ដូចពោលហើយនោះឯង ។

ចំណែកវារៈ ៣ ជាដើម **ខយា រាគស្ស** ដូច្នេះ លោកពោលទុក ហើយក្នុងនិព្វានវារៈ វារៈទាំងនោះក៏គួរឱ្យពិស្ដារ សូម្បីក្នុងវារៈពោលដោយ បឋវីជាដើម ។ ក៏បរិញ្ញាតវារៈនេះ ក៏គួរឱ្យពិស្ដារសូម្បីក្នុងនិព្វានវារៈ ។ ក៏ បណ្ឌិតកាលនឹងឱ្យសេចក្ដីពិស្ដារ គប្បីប្រកបពាក្យថា **បរិញ្ញាតន្តស្ស** ជាមួយ គ្រប់ ៗ បទ ហើយគប្បីប្រកបសេចក្ដីទៀតថា **ខយា រាគស្ស វីតរាគត្តា** ដូច្នេះ ក្នុងបទក្រៅពីនោះក៏ន័យនេះ ។ ក៏ទេសនាលោកសង្ខេបទុកថា ពាក្យ ដែលពោលហើយក្នុងបទមួយ ក៏ពោលហើយក្នុងគ្រប់ៗ បទ ។

ក៏ក្នុងបទថា **ខយា រាគស្ស វីតរាគត្តា** នេះ មានន័យថា ព្រោះហេតុ

ដែលអ្នកបួសក្រៅសាសនា ជាអ្នកប្រាសចាកសេចក្ដីប្រាថ្នាក្នុងកាម ( តែ ) មិនមែនព្រោះអស់រាគៈ ចំណែកព្រះអរហន្តឈ្មោះថា ជាអ្នកប្រាសចាកសេចក្ដីប្រាថ្នាក្នុងកាម ព្រោះការអស់រាគៈ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យ ថា **ខយា រាគស្ស វីតរាគត្តា** ដូច្នេះ ។ សូម្បីក្នុង ទោសៈ និង មោហៈ ក៏មានន័យនេះ ។ ដូចជា សូម្បីកាលព្រះមានព្រះភាគត្រាស់ថា តថាគត ពោលថា **បរិញ្ញាតំ តស្ស** ដូច្នេះ រមែងបានសេចក្ដីថា ព្រះអរហន្តនោះ រមែងមិនប្រកាន់វត្ថុនោះ ឬ ការសម្គាល់នោះ ព្រោះលោកបានកំណត់ដឹង ហើយយ៉ាងណា សូម្បីក្នុងទីនេះក៏ដូច្នោះ ព្រះអរហន្តនោះ បណ្ឌិតគប្បីឃើញ ថា រមែងមិនប្រកាន់វត្ថុនោះ ឬ រមែងមិនប្រកាន់នូវការសម្គាល់ ( ខុស ) នោះ ព្រោះលោកអស់រាគៈហើយ ។

ក៏ក្នុងបណ្ដាវារៈទាំងនោះ វារៈនេះថា **បរិញ្ញាតំ តស្ស** នេះ លោកពោលទុកដើម្បីសម្ដែងដល់ការដល់ព្រមនៃមគ្គភាវនា ។ វារៈក្រៅពីនេះ គប្បីឃើញថា លោកពោលទុកដើម្បីសម្ដែងដល់ការដល់ព្រមនៃការធ្វើឱ្យជាក់ច្បាស់នូវផល ។

ម្យ៉ាងទៀត ព្រះអរហន្តរមែងមិនប្រកាន់ដោយហេតុ ២ ប្រការ ព្រោះការដែលវត្ថុលោកកំណត់បានហើយ និង ព្រោះអកុសលមូល លោកដកទេឡើងបានហើយ ដោយហេតុនោះ ទើបព្រះអដ្ឋកថាសម្តែងដល់ការកំណត់ដឹងនូវវត្ថុរបស់ព្រះអរហន្តនោះដោយវារៈនៃបរិញ្ញា និង សម្តែងដល់ការដកទេឡើងនូវអកុសលមូលដោយវារៈក្រៅពីនេះ ដូច្នេះឯង ។

ក្នុងបណ្តាវារៈទាំងនោះ គប្បីជ្រាបសេចក្តីផ្សេងគ្នាក្នុងវារៈ ៣ ប្រការខាងចុងដូចតទៅនេះ។ព្រះអរហន្តនុ៎ះលោកឃើញទោសក្នុងរបស់លោភៈក្នុងវារៈ ទាំង ៣ នោះហើយ ពិចារណាឃើញទុក្ខ ជាអ្នករួចផុតដោយអប្បណិហិត- វិមោក្ខ រមែងមានរាគៈប្រាសចេញទៅ ព្រោះការអស់ទៅនៃរាគៈ ។ លោកឃើញទោសរបស់ទោសៈ ពិចារណាឃើញថា ជារបស់មិនទៀង ជាអ្នករួចផុតស្រទឡះដោយអនិមិត្តវិមោក្ខរមែងជាអ្នកមានទោសៈប្រាសទៅព្រោះអស់ ទោសៈ ។ លោកឃើញទោសរបស់មោហៈ ពិចារណាដោយភាពជាអនត្តា រួចផុតហើយដោយសុញ្ញតវិមោក្ខ រមែងប្រាសចាកមោហៈ ព្រោះអស់មោហៈ ។ ប្រសិនបើមានពាក្យសួរថា បើដូច្នោះ បុគ្គលតែម្នាក់រួចផុតហើយដោយវិមោក្ខ

៣ ( តែម្តង) មិនបាន ព្រោះដូច្នោះ មិនគួរពោល ២ វារៈទុក ។ គប្បីឆ្លើយ ថា សេចក្តីនេះមិនដូច្នេះទេ ។ ព្រោះហេតុអ្វី ? ព្រោះថា មិនទាន់បានកំណត់ពិតប្រាកដ ។

ការពិត ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដោយមិនចំពោះ ប្រាកដថា **យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ** ដូច្នេះ មិនត្រាស់ទុកថា រមែងជាអ្នករួចផុតស្រទ្បះដោយអប្បណិហិតវិមោក្ខ ឬ រួចផុតដោយវិមោក្ខក្រៅពីនេះ ដូច្នេះទេ ។ ដូច្នោះ វត្ថុណារមែងសមគួរដល់ព្រះអរហន្ត វត្ថុទាំងអស់នោះគួរពោលពិត ដូច្នេះ ។

ម្យ៉ាងទៀត កាលពោលដោយមិនប្លែកគ្នា ព្រះអរហន្តគ្រប់រូប កាល កិលេសមានរាគៈជាដើមអស់ទៅ លោកក៏ហៅថា អ្នកមានរាគៈជាដើម អស់ទៅ ព្រោះរាគៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងនូវវិបរិណា_មទុក្ខ ។ លោកហៅថា អ្នកប្រាសចាកទោសៈ ព្រោះទោសៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងទុក្ខក្នុងទុក្ខ ឈ្មោះថា អ្នកប្រាសចាកមោហៈ ព្រោះហេតុមោហៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងសង្ខារទុក្ខ ។

ម្យ៉ាងទៀត លោកឈ្មោះថា ប្រាសចាករាគៈ ព្រោះរាគៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងឥដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកទោសៈ ព្រោះទោសៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងអនិដ្ឋារម្មណ៍ ឈ្មោះថា ប្រាសចាកមោហៈ ព្រោះមោហៈអស់ទៅ ព្រោះហេតុដែលលោកកំណត់ដឹងនូវមជ្ឈត្តារម្មណ៍ ។

ម្យ៉ាងវិញទៀត លោកឈ្មោះថា ប្រាសចាករាគៈ ព្រោះរាគៈអស់ទៅ ព្រោះហេតុដែលលោកដករាគានុស័យ ក្នុងសុខវេទនាចេញបាន ឈ្មោះថា ប្រាសចាកទោសៈ និង ប្រាសចាកមោហៈ លោកដកបដិឃានុស័យ និង មោហានុស័យ ក្នុងទុក្ខវេទនា និង ឧបេក្ខាវេទនាចេញបាន ដូច្នេះឯង ដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេចក្តីផ្សេងគ្នានោះ ទើបត្រាស់ថា **ខយា រាគស្ស វីតរាគត្តា ។ បេ ។ ខយា មោហស្ស វីតមោហត្តា** ដូច្នេះ ។

**( ចប់កថាពោលដោយន័យទី ៣-៤-៥-៦ ដោយអំណាចព្រះខីណាស្រព )**

# ១៣៤ អដ្ឋកថា មូលបរិយាយសូត្រ

## *អធិប្បាយពាក្យថា តថាគត*

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងការប្រព្រឹត្តិទៅរបស់ព្រះ-ខីណាស្រពក្នុងវត្ថុធាតុទាំងទឡាយ មានបឋវីធាតុជាដើមយ៉ាងនេះហើយ ពេលនេះ កាលនឹងទ្រង់សម្តែងការប្រព្រឹត្តិទៅរបស់ព្រះអង្គឯង ទើបត្រាស់ពាក្យជាដើមថា **តថាគតោបិ ភិក្ខវេ** ដូច្នេះ ។

បណ្តាបទទាំងនោះ ក្នុងបទថា **តថាគតោ** មានវិនិច្ឆ័យដូច្នេះ ព្រះមានព្រះភាគ លោកហៅថា **តថាគត** ដោយហេតុ ៨ យ៉ាង គឺ ÷

១ ហៅថា **តថាគត** ព្រោះអត្ថថា ស្តេចមកហើយយ៉ាងនោះ ។

២ ហៅថា **តថាគត** ព្រោះអត្ថថា ស្តេចទៅហើយយ៉ាងនោះ ។

៣ ហៅថា **តថាគត** ព្រោះអត្ថថា ស្តេចមកកាន់លក្ខណៈដ៏ពិត ។

៤ ហៅថា **តថាគត** ព្រោះអត្ថថា ត្រាស់ដឹងព្រមចំពោះសច្ចធម៌តាមសេចក្តីពិត ។

៥ ហៅថា **តថាគត** ព្រោះអត្ថថា ទ្រង់ឃើញពិត ។

៦ ហៅថា **តថាគត** ព្រោះអត្ថថា ព្រោះត្រាស់វាចាពិត ។

៧ ហៅថា **តថាគត** ព្រោះអត្ថថា ព្រោះទ្រង់ធ្វើពិត ។

៨ ហៅថា **តថាគត** ព្រោះអត្ថថា គ្របសង្កត់ ។

## តថាគត « ស្តេចមកហើយយ៉ាងនោះ »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះអត្ថថា ស្តេចមកហើយយ៉ាងនោះ ដូចម្តេច ?

ឆ្លើយថា ព្រះសម្មាសម្ពុទ្ធអង្គមុន ៗ ទ្រង់ដល់នូវការខ្វាយខ្វល់ ស្តេចមកហើយដើម្បីប្រយោជន៍ដ៏ក្រៃលែងដល់សត្វលោកទាំងពួង ដោយប្រការណា ដូចយ៉ាងថាព្រះមានព្រះភាគទ្រង់ព្រះនាមថា**វិបស្សី ១** ទ្រង់ព្រះនាមថា **សិខី ១** ទ្រង់ព្រះនាមថា **វេស្សភូ ១** ទ្រង់ព្រះនាមថា **កកុសន្ធ ១** ទ្រង់ ព្រះនាមថា **កោនាគមន ១** ទ្រង់ព្រះនាមថា **កស្សប ១** ស្តេចមកហើយដើម្បីប្រយោជន៍ដ៏ក្រៃលែងដល់សត្វលោកយ៉ាងណា ( ព្រះមានព្រះភាគជា_ម្ចាស់របស់យើងនេះ ក៏ស្តេចមកដើម្បីប្រយោជន៍សុខដល់សត្វលោក ) ដូច្នោះ ដូចគ្នា ។

លោកអធិប្បាយទុក យ៉ាងណា ?

លោកអធិប្បាយទុកថា ព្រះមានព្រះភាគទាំងនោះ ស្តេចមកហើយ

ដោយអភិនីហារណា ព្រះមានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមក ដោយអភិនីហារនោះ ដូចគ្នា ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ។ល។ ព្រះ-មានព្រះភាគទ្រង់ព្រះនាមថា **កស្សបៈ** ទ្រង់បំពេញទានបារមី សីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមី ទ្រង់បានបំពេញបារមី ៣០ នេះ គឺ **បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០** ទាំងបានបំពេញ **មហាបរិច្ចាគ ៥** ប្រការ គឺ ទ្រង់បរិច្ចាគអវយវៈ ដួងព្រះនេត្រ ព្រះរាជទ្រព្យ រាជសម្បត្តិ ឱរស និង មហេសី ទ្រង់បំពេញបុព្វប្រយោគ បុព្វចរិយា ការបង្រៀនធម៌ និង ញាតត្ថចរិយាជាដើមមក រហូតដល់ទីបំផុត ដោយពុទ្ធចរិយាណា ព្រះមាន-ព្រះភាគជាម្ចាស់របស់យើង ក៏ស្តេចមកដូច្នោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ។ល។ ព្រះមាន-ព្រះភាគទ្រង់ព្រះនាមថា **កស្សប** ស្តេចមកបំពេញសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥន្ទ្រីយ៍ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គមានអង្គ ៨ យ៉ាងណា សូម្បី ព្រះមានព្រះភាគរបស់យើងទាំងឡាយ ក៏ស្តេចមកដូច្នោះ ព្រះមានព្រះភាគ

ស្ដេចមកហើយដោយប្រការនោះ យ៉ាងនេះ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **ព្រះតថាគត** ។

**ព្រះមុនីទាំងទឡាយមានព្រះវិបស្សីជាម្ចាស់ ជាដើម**

**ស្ដេចបានមកជាព្រះសព្វញ្ញូក្នុងលោកនេះ ដោយ**

**ប្រការណា សូម្បីព្រះសក្យមុនី ក៏ស្ដេចមកដោយ**

**ប្រការនោះ ដោយហេតុនោះ ព្រះមានព្រះភាគដែល**

**មានចក្ខុលោកទើបហៅថា ព្រះតថាគត ដូច្នេះឯង ។**

ព្រះមានព្រះភាគជាម្ចាស់ស្ដេចមកហើយ ដោយប្រការនោះ ដូចពណ៌នាមកយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **ព្រះតថាគត** ។

## តថាគត « ស្ដេចទៅហើយយ៉ាងនោះ »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះស្ដេចទៅហើយយ៉ាងនោះ ដូចម្ដេច ? ឆ្លើយថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ។ល។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **កស្សប** ប្រសូតបានមួយភ្លែតក៏ស្ដេចយាងទៅបាន យ៉ាងណា ព្រះមានព្រះភាគជាម្ចាស់របស់យើងក៏យាងទៅបានយ៉ាងនោះ ។

ក៏ព្រះមានព្រះភាគជាម្ចាស់របស់យើងនោះ ស្តេចយាងទៅបានយ៉ាង ណា ? ( យ៉ាងនេះគឺ ) ប្រសូតបានមួយភ្លែត ប្រថាប់ឈរលើផែនប្រថពី ដោយព្រះបាទដ៏រាបស្មើ បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ឈានព្រះបាទទៅបាន ៧ ជំហាន ដូចដែលព្រះអង្គត្រាស់ទុកថាអានន្ទព្រះពោធិសត្វប្រសូតបាន មួយខណៈ ប្រថាប់ឈរលើប្រថពីដោយព្រះបាទដ៏រាបស្មើ បែរព្រះភក្ត្រទៅកាន់ ទិសឧត្តរ ឈានព្រះបាទទៅបាន ៧ ជំហាន ដោយមានទេវតាបាំងស្វេតឆត្រ ជាប់តាម ទ្រង់សម្លឹងមើលគ្រប់ទិស ថ្លែងអាសភិវាចាថា ÷

**យើងជាអ្នកដ៏លើស ជាអ្នកចម្រើនបំផុត**

**ប្រសើរជាទីបំផុតរបស់លោក ជាតិនេះ**

**ជាជាតិចុងក្រោយ ឥឡូវនេះភពថ្មីមិន**

**មានទៀតទេឡើយ ដូច្នេះ ។**

ក៏ស្តេចយាងទៅរបស់ព្រះអង្គនោះ មានយ៉ាងនោះ មិនខុសពីនោះ ដែលជាបុព្វនិមិត្តនៃការសម្រេចគុណវិសេសយ៉ាងច្រើន ។

ការដែលព្រះអង្គប្រសូតបានមួយភ្លែត ហើយប្រថាប់ឈរលើផែនប្រថពី

ដោយព្រះបាទដ៏រាបស្មើ នោះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ ។
ការដែលព្រះអង្គបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការដែលព្រះអង្គជាអ្នកឆ្លងផុតលោកទាំងអស់ ។

ការឈានព្រះបាទទៅបាន ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺពោជ្ឈង្គៈ ៧ ប្រការ ។

ការលើកឆ្អិត ដែលពោលក្នុងបទថា ឆ្អិតមានដងជាមាសផ្សាយទៅ ដូច្នេះ ជាបុព្វនិមិត្តនៃការញាំញីពួកតិរ្ថិយ៍ទាំងអស់ ។

ការដែលទ្រទ្រង់ស្វេតឆត្រ ជាបុព្វនិមិត្តនៃការបានស្វេតឆត្រដ៏ប្រសើរប្រាសចាកមន្ទិល គឺ ការរួចផុតដោយអំណាចនៃភាពជាព្រះអរហន្ត ។

ការដែលទ្រង់សម្លឹងមើលគ្រប់ទិសនោះ ជាបុព្វនិមិត្តនៃការបានញាណដ៏ប្រសើរ គឺ ព្រះសព្វញ្ញុតញ្ញាណ ។

ការដែលទ្រង់បន្លឺនូវអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសធម្មចក្រដ៏ប្រសើរ មិនមាននរណារារាំងបាន ។

សូម្បីព្រះមានព្រះភាគជាម្ចាស់ស្ដេចទៅដោយប្រការនោះ និង ការដែលស្ដេចទៅរបស់ព្រះអង្គនោះ មានយ៉ាងនោះ មិនខុសពីនោះ ជាបុព្វនិមិត្តនៃ

ការសម្រេចគុណវិសេសច្រើន ។ ដោយហេតុនោះ ព្រះបុរាណាចារ្យ ទើបពោលទុកថា ÷

**ព្រះគោតមនោះ លុះប្រសូតហើយបានមួយភ្លែតប៉ុណ្ណោះ**

**ក៏ប្រថាប់លើផែនពសុធា ដោយព្រះបាទដ៏រាបស្មើ**

**ហើយស្តេចយាងទៅបាន ៧ ជំហាន ដូចគោមេហ្វូង**

**ដើរនាំមុខហ្វូងគោទៅដូច្នោះ ហើយពួកទេវតាទាំងទឡាយ**

**ក៏បានបាំងស្វេតឆ័ត្រថ្វាយព្រះគោតមនោះ លុះយាងទៅ**

**បាន ៧ ជំហាន ហើយទ្រង់ក្រទេឡកមើលទៅកាន់ទិស**

**ទាំងទឡាយ ដោយជុំវិញ បានបន្លឺសំទេឡងដែលប្រកប**

**ដោយអង្គ ៨ ដូចស្តេចរាជសីហ៍ឈរលើកំពូលភ្នំ បន្លឺ**

**សីហនាទដូច្នោះ ដូច្នេះ ។**

ព្រះមានព្រះភាគស្តេចយាងទៅដោយប្រការនោះ ដូចពណ៌នាមកយ៉ាង នេះដូច្នេះ ទើបព្រះអង្គទ្រង់ព្រះនាមថា **តថាគត** ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ។ល។ ព្រះមាន_ព្រះភាគទ្រង់ព្រះនាមថា **កស្សប** យ៉ាងណា ព្រះមានព្រះភាគរបស់យើង ក៏

ដូច្នោះដូចគ្នា គឺ ព្រះអង្គទ្រង់លះបង់កាមឆន្ទៈដោយនេក្ខម្មៈ ស្តេចទៅហើយ , ទ្រង់លះបង់ព្យាបាទ ដោយការមិនព្យាបាទ ទ្រង់លះបង់ថីនមិទ្ធៈ ដោយអាលោកសញ្ញា ទ្រង់លះបង់ឧទ្ធច្ចកុក្កុច្ចៈ ដោយការមិនរាយមាយ ទ្រង់លះបង់វិចិកិច្ឆា ដោយការកំណត់ធម៌ ស្តេចទៅហើយ , ទ្រង់កម្ចាត់អវិជ្ជាដោយញ្ញាណ ស្តេចទៅហើយ , ទ្រង់បន្ទោបង់សេចក្តីមិនត្រេកអរ ដោយបាមោជ្ជៈ ទ្រង់ដកចេញគ្រឿងរារាំង គឺ នីវរណធម៌ ដោយបឋមជ្ឈាន ញុំាងភាពងងឹត គឺ វិតក្ក វិចារឱ្យស្ងប់រំងាប់ ដោយទុតិយជ្ឈាន ទ្រង់លះបង់បីតិ ដោយតតិយជ្ឈាន ទ្រង់លះបង់សុខ និង ទុក្ខ ដោយចតុត្ថជ្ឈាន ទ្រង់កន្លងផុតរូបសញ្ញា បដិឃ-សញ្ញា និង នានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ទ្រង់កន្លងផុតអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទ្រង់កន្លងផុតវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទ្រង់កន្លងផុតអា-កិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ស្តេចទៅ ហើយ, ទ្រង់លះបង់និច្ចសញ្ញា ដោយអនិច្ចានុបស្សនាញាណ ទ្រង់លះបង់ សុខសញ្ញា ដោយទុក្ខានុបស្សនាញាណ ទ្រង់លះបង់អត្តសញ្ញា ដោយអនត្តា-

នុបស្សនាញាណ ទ្រង់លះបង់សេចក្តីត្រេកអរ ដោយនិព្វិទានុបស្សនាញាណ ទ្រង់លះបង់រាគៈ ដោយវិរាគានុបស្សនាញាណ ទ្រង់លះបង់សមុទ័យ ដោយនិរោធានុបស្សនាញាណ ទ្រង់លះបង់ការប្រកាន់មាំ ដោយបដិនិស្សគ្គានុបស្ស-នាញាណ ទ្រង់លះបង់ឃនសញ្ញា ដោយខយានុបស្សនាញាណ ទ្រង់លះបង់ការប្រមូលមក ដោយវយានុបស្សនាញាណ ទ្រង់លះបង់ធុវសញ្ញា ដោយវិបរិណាមានុបស្សនាញាណ ទ្រង់លះបង់និមិត្តសញ្ញា ដោយអនិមិត្តានុបស្ស-នាញាណ ទ្រង់លះបង់សេចក្តីប្រាថ្នា ដោយអប្បណិហិតានុបស្សនាញាណ ទ្រង់លះបង់អភិនិវេស ដោយសុញ្ញានុបស្សនាញាណ ទ្រង់លះបង់ការប្រកាន់ថាមានសារៈ ដោយអធិប្បញ្ញាធម្មវិបស្សនាញាណ ទ្រង់លះបង់ការប្រកាន់មាំព្រោះការវង្វេង ដោយយថាភូតញ្ញាណទស្សនញ្ញាណ ទ្រង់លះបង់ការប្រកាន់ដោយសេចក្តីអាល័យ ដោយអាទីនវានុបស្សនាញាណ ទ្រង់លះបង់ការមិនពិចារណា ដោយបដិសង្ខានុបស្សនាញាណ ទ្រង់លះបង់ការប្រកាន់មាំ ដោយអំណាចសំយោជនៈ ដោយវិវដ្តានុបស្សនាញាណ ទ្រង់កាច់បំបាក់កិលេសក្នុងបច្ចុប្បន្ន ដោយសោតាបត្តិមគ្គ ទ្រង់លះបង់នូវកិលេសយ៉ាងគ្រោតគ្រាត ដោយ

សកទាគាមិមគ្គ ទ្រង់លះបង់កិលេសដែលនៅសល់តិចតួច ដោយអនាគាមិមគ្គ ទ្រង់កាត់ផ្តាច់កិលេសគ្រប់យ៉ាង ដោយអរហត្តមគ្គ ស្តេចទៅហើយ ។ ព្រះ-មានព្រះភាគស្តេចទៅយ៉ាងនោះ ដោយអាការដូចពណ៌នាមកយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

## តថាគត « ស្តេចមកកាន់លក្ខណៈដែលពិត »

សួរថា ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចមកកាន់លក្ខណៈដែលពិតនោះ យ៉ាងណា ?

ឆ្លើយថា ព្រះមានព្រះភាគ ស្តេចមកហើយ គឺ ដល់ដោយមិនខុស បានដល់ សម្រេចតាមលំដាប់នូវលក្ខណៈរបស់បឋវីធាតុថា មានសភាពរឹងយ៉ាងត្រឹមត្រូវមិនខុស នូវលក្ខណៈនៃអាបោធាតុថា ជាគ្រឿងហូរ លក្ខណៈនៃតេជោធាតុថា ជារបស់ក្តៅ លក្ខណៈនៃវាយោធាតុថា កម្រើកញ័រ លក្ខណៈ អាកាសធាតុថា ពាល់ត្រូវមិនបាន លក្ខណៈវិញ្ញាណធាតុថា ជាគ្រឿងដឹង លក្ខណៈនៃរូបថា រមែងវិនាសទៅ លក្ខណៈនៃវេទនាថា ជាការសោយអារម្មណ៍ លក្ខណៈនៃសញ្ញាថា ការចាំបាន លក្ខណៈនៃសង្ខារ ថា ជាគ្រឿងតាក់តែង

លក្ខណៈនៃវិញ្ញាណថា ដឹងច្បាស់ លក្ខណៈនៃវិតក្កថា លើកចិត្តទៀងកាន់អារម្មណ៍ លក្ខណៈនៃវិចារៈថា ជាការពិចារណាអារម្មណ៍ លក្ខណៈបីតិថា ផ្សាយទៅ លក្ខណៈនៃសុខថា ត្រេកអរ លក្ខណៈឯកគ្គតាចិត្តថា ការមិនរាយមាយ លក្ខណៈនៃផស្សៈថា ជាការពាល់ត្រូវ លក្ខណៈរបស់សទ្ធិន្ទ្រីយ៍ថា ការបង្អោនចិត្តជឿ លក្ខណៈរបស់វីរិយិន្ទ្រីយ៍ថា ការផ្គងចិត្ត លក្ខណៈរបស់សតិន្ទ្រីយ៍ថា ការប្រាកដច្បាស់ លក្ខណៈនៃសមាធិន្ទ្រីយ៍ថា សភាពនៃចិត្តមិនរាយមាយ លក្ខណៈនៃបញ្ញិន្ទ្រីយ៍ថា ការដែលចិត្តដឹងច្បាស់ លក្ខណៈរបស់សទ្ធាពលៈថា ជាភាពដែលចិត្តមិនញាប់ញ័រក្នុងវត្ថុមិនគួរជឿ លក្ខណៈវីរិយពលៈថា ជាភាពនៃចិត្តមិនញាប់ញ័រព្រោះការខ្ជិលច្រអូស លក្ខណៈនៃសតិពលៈថា ជាភាពដែលចិត្តមិនញាប់ញ័រក្នុងសេចក្ដីវង្វេងនៃសតិ លក្ខណៈនៃ សមាធិថា ភាពដែលចិត្តមិនញាប់ញ័រព្រោះឧទ្ធច្ចៈ លក្ខណៈនៃបញ្ញាពលៈថា ភាពដែលចិត្តមិនញាប់ញ័រព្រោះអវិជ្ជា លក្ខណៈរបស់សតិសម្ពោជ្ឈង្គៈថា ភាព ប្រាកដច្បាស់ លក្ខណៈរបស់ធម្មវិចយសម្ពោជ្ឈង្គៈថា ការពិចារណា លក្ខណៈរបស់វីរិយសម្ពោជ្ឈង្គៈថា ការផ្គងចិត្តទុក លក្ខណៈរបស់បីតិសម្ពោជ្ឈង្គៈថា

ការផ្សាយចិត្តទៅ លក្ខណៈរបស់បស្សទ្ធិសម្ពោជ្ឈង្គៈថា ការស្ងប់ចិត្ត លក្ខណៈ របស់សមាធិសម្ពោជ្ឈង្គៈថា ការមិនរាយមាយរបស់ចិត្ត លក្ខណៈរបស់ឧបេក្ខា- សម្ពោជ្ឈង្គៈថា ការពិចារណា លក្ខណៈរបស់សម្មាទិដ្ឋិថា ការឃើញ លក្ខណៈ របស់សម្មាសង្កប្បៈថា ការលើកចិត្តទេឡើង លក្ខណៈរបស់សម្មាវាចាថា ការ កំណត់ចិត្ត លក្ខណៈរបស់សម្មាកម្មន្តៈថា ជាការឧស្សាហ៍ព្យាយាម លក្ខណៈ របស់សម្មាអាជីវៈថា ជាភាពផ្លូវផង់របស់ចិត្ត លក្ខណៈរបស់សម្មាវាយាមៈថា ការផ្គងចិត្ត លក្ខណៈរបស់សម្មាសតិថាភាពប្រាកដច្បាស់ លក្ខណៈរបស់ សម្មាសមាធិថា សភាពដែលចិត្តមិនរាយមាយ លក្ខណៈរបស់អវិជ្ជាថា ការ មិនដឹង លក្ខណៈរបស់សង្ខារថា ចេតនា លក្ខណៈរបស់វិញ្ញាណថា ការដឹង ច្បាស់ លក្ខណៈរបស់នាមថា ការបង្អោនចិត្តទៅ លក្ខណៈរបស់រូបថា រមែង វិនាសទៅ លក្ខណៈរបស់អាយតនៈ ៦ ថា ជាទីកើត លក្ខណៈរបស់ផស្សៈថា ជាការពាល់ត្រូវ លក្ខណៈរបស់វេទនាថា ការសោយអារម្មណ៍ លក្ខណៈរបស់ តណ្ហាថា ជាហេតុនៃទុក្ខ លក្ខណៈរបស់ឧបាទានថា ជាការប្រកាន់មាំ លក្ខណៈ របស់ភពថា ជាការប្រមូលទុក លក្ខណៈរបស់ជាតិថា ជាការកើត លក្ខណៈ របស់ជរាថា ជាការចាស់ លក្ខណៈរបស់មរណៈថា ចុតិ លក្ខណៈរបស់ធាតុថា

សោះសូន្យទទេ លក្ខណៈរបស់អាយតនៈថា ជាទីកើត លក្ខណៈរបស់សតិ-ប្បដ្ឋានថា ការប្រាកដច្បាស់ លក្ខណៈរបស់សម្មប្បធានថា ការតាំងសេចក្តីព្យាយាម លក្ខណៈរបស់ឥទ្ធិបាទថា ការសម្រេច លក្ខណៈរបស់ឥន្ទ្រីយ៍ថា ភាពជាធំ លក្ខណៈរបស់ពលៈថា ការមិនញាប់ញ័រ លក្ខណៈរបស់ពោជ្ឈង្គៈថា ធម៌ជាគ្រឿងនាំសត្វចេញចាកទុក្ខ លក្ខណៈរបស់មគ្គថា ជាហេតុឱ្យដល់សេចក្តីរលត់ទុក្ខ លក្ខណៈរបស់សច្ចៈថា ជាសេចក្តីពិត លក្ខណៈរបស់សមថៈថា ជាសេចក្តីមិនរាយមាយ លក្ខណៈរបស់វិបស្សនាថា ជាការពិចារណាឃើញ លក្ខណៈរបស់សមថៈ និង វិបស្សនាថា មានកិច្ចដូចគ្នា លក្ខណៈរបស់វត្ថុដែល ជាគូគ្នាថា មិនលះបង់គ្នា លក្ខណៈរបស់សីលវិសុទ្ធិថា ការរវាំងរក្សា លក្ខណៈ របស់ចិត្តវិសុទ្ធិថា សេចក្តីមិនរាយមាយ លក្ខណៈរបស់ទិដ្ឋិវិសុទ្ធិថា ការឃើញ លក្ខណៈរបស់ញាណក្នុងធម៌ដែលជាទីអស់ទៅថា សមុច្ឆេទ លក្ខណៈរបស់ញាណក្នុងធម៌ដែលមិនទាន់កើតទេឡើងថា ជាការស្ងប់ លក្ខណៈរបស់ឆន្ទៈថា ជាមូលហេតុ លក្ខណៈរបស់មនសិការថា ភាពឧស្សាហ៍ព្យាយាម លក្ខណៈរបស់ផស្សៈថា ជាទីរួម លក្ខណៈរបស់វេទនាថា ជាទីប្រជុំ លក្ខណៈរបស់

សមាធិថា ធម៌ដែលជាប្រធាន លក្ខណៈរបស់សតិថា ជាធំ លក្ខណៈរបស់បញ្ញាថា ខ្ពង់ខ្ពស់ជាងធម៌ទាំងអស់ លក្ខណៈរបស់វិមុត្តិថា ជាខ្លឹម លក្ខណៈរបស់និព្វានដែលចុះកាន់អមតៈថា ជាទីបំផុត ព្រះមានព្រះភាគស្ដេចមកដល់ គឺ ដល់ បានដល់ ការសម្រេចនូវលក្ខណៈដែលពិតយ៉ាងនេះ គឺ ពិតប្រាកដ មិនខុស ដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ស្ដេចមកដល់លក្ខណៈដែលពិតយ៉ាងនេះ ដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

## តថាគត « ត្រាស់ដឹងធម៌ពិត »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងព្រមចំពោះធម៌ពិត តាមសេចក្ដីពិត យ៉ាងណា ? ។

ឆ្លើយថា ដែលឈ្មោះថា ធម៌ពិត បានដល់ អរិយសច្ចៈ ៤ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ អរិយសច្ចៈ ៤ នេះ ជារបស់ពិត មិនប្រែប្រួល មិនទៅជាយ៉ាងដទៃ ។ អរិយសច្ចៈ ៤ អ្វីខ្លះ ? ម្នាលភិក្ខុទាំងទឡាយ សេចក្ដីដែលថា នេះទុក្ខ នោះជារបស់ពិត មិនប្រែប្រួល

ទៅជាយ៉ាងដទៃ ដូច្នេះជាដើម ។ សេចក្តីពិស្តារ ( អ្នកសិក្សាគប្បីពិចារណាដោយខ្លួនឯង ) ។

ក៏ព្រះមានព្រះភាគ ត្រាស់ដឹងព្រមនូវអរិយសច្ចៈ ៤ នោះ ព្រោះហេតុនោះ ទើបមានព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងព្រមចំពោះអរិយសច្ចទាំងទឡាយដែលពិត ។

ពិតណាស់ **គត** ស័ព្ទ ក្នុងពាក្យថា **តថាគតោ** នេះ មានអត្ថថា « ត្រាស់ដឹងព្រមចំពោះ » ។

ម្យ៉ាងទៀត ជរា និង មរណៈ កើតមាន ព្រោះមានជាតិជាបច្ច័យ ជាសភាវៈដែលពិត មិនប្រែប្រួល មិនទៅជាយ៉ាងដទៃ ។ល។ សង្ខារទាំង-ទឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ជាសភាវដែលពិត មិនប្រែប្រួល មិនទៅជាយ៉ាងដទៃ ។ ម្យ៉ាងទៀត អវិជ្ជា ជាបច្ច័យ ( ឱ្យកើត ) សង្ខារទាំងទឡាយ សង្ខារទាំងទឡាយ ជាបច្ច័យ ( ឱ្យកើត ) វិញ្ញាណ ។ល។ ជាតិ ជាបច្ច័យ ( ឱ្យកើត) ជរា និង មរណៈ ជាសភាវៈពិត មិនប្រែប្រួល មិនទៅជាយ៉ាង

ដទៃ ។

ព្រះមានព្រះភាគ ត្រាស់ដឹងព្រមនូវសភាវៈនោះទាំងអស់ ព្រោះ ហេតុនោះ ទើបបានទទួលព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងព្រមនូវ ធម៌ពិត តាមសេចក្តីពិត ដោយប្រការដូចពណ៌នាមកដូច្នេះ ។

## តថាគត « មានប្រក្រតីឃើញអារម្មណ៍ដែលពិត »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មាន ប្រក្រតីឃើញអារម្មណ៍ពិត យ៉ាងណា ?

ឆ្លើយថា អារម្មណ៍ណាដែលឈ្មោះថា រូបារម្មណ៍ ( អារម្មណ៍ គឺ រូប ) ដែលមកប្រាកដក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយ មិនមានប្រមាណ មានទាំងក្នុង លោក និង ទេវលោក ។ល។ ក្នុងពពួកសត្វ ទាំងទេវតា និង មនុស្ស (និង) ក្នុងលោកធាតុមិនមានប្រមាណ ( កំណត់រាប់មិនបាន ) អារម្មណ៍ នោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ដឹង គឺ ទ្រង់ឃើញដោយអាការទាំងអស់ ។

អារម្មណ៍នោះ ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹង និង ទ្រង់ឃើញ

ហើយយ៉ាងនេះ ចែកចេញទៅតាមឈ្មោះជាអនេក តាមវារៈ ១៣ វារៈ ( និង ) តាមន័យ ៥២ ន័យ ដោយន័យមានជាអាទិថា រូប គឺ រូបាយតនៈ នោះ ដូម្តេច? រូបណា ដែលអាស្រ័យមហាភូតរូប ៤ ជារូប ដែលមាន វណ្ណៈ ( ពណ៌ ) មើលឃើញបាន ពាល់ត្រូវបាន ជារូបពណ៌ខៀវ ជារូប ពណ៌លឿង ( នេះឯងហៅថា រូប ) ដោយអំណាចជារូប ដែលគួរប្រាថ្នា និង មិនគួរប្រាថ្នាជាដើមខ្លះ ដោយអំណាចដែលនឹងបាន ក្នុងរូបដែលបាន ឃើញ សំទេឡងដែលបានឮ ក្លិន រស ផោដ្ឋព្វៈដែល បានប៉ះពាល់ និង ធម្មារម្មណ៍ដែលបានដឹងច្បាស់ខ្លះ រមែងជារបស់ពិតតែម្យ៉ាង មិនប្រែប្រួល ក្នុងបណ្តាអារម្មណ៍ មានសំទេឡងជាដើមដែលមកប្រាកដក្នុងសោតទ្វារជាដើម ក៏ន័យនេះ ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដូច្នេះថា ម្នាលភិក្ខុទាំងទឡាយ អារម្មណ៍ណាដែលលោក និង ទេវលោក ។ល ។ ដែលពពួកសត្វ ទេវតា និង មនុស្សបានឃើញ បានស្តាប់ បាន ជ្រាប បានដឹងច្បាស់ បានសម្រេច បានស្វែងរក បានគិតពិចារណា តថាគត ដឹងអារម្មណ៍ តថាគតដឹងយ៉ាងពិតប្រាកដនូវអារម្មណ៍នោះ អារម្មណ៍នោះ

តថាគតដឹង , អារម្មណ៍នោះ ប្រាកដហើយក្នុងតថាគត ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីឃើញអារម្មណ៍ដែលពិត ដោយប្រការដូចពណ៌នាមកដូច្នេះ ។

ក្នុងបទថា **តថាគតោ** នោះ អ្នកសិក្សាគប្បីជ្រាបការប្រើបទថា **តថា_គតោ** ចុះក្នុងអត្ថថា អ្នកមានប្រក្រតីឃើញអារម្មណ៍ដែលពិត ។

## តថាគត « អ្នកមានប្រក្រតីត្រាស់វាទៈដែលពិត »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីត្រាស់វាទៈដែលពិត យ៉ាងណា ?

ឆ្លើយថា ការដែលព្រះមានព្រះភាគ ទ្រង់គង់លើអបរាជិតបល្ល័ង្ក ( បល្ល័ង្កដែលមារមិនអាចធ្វើសេចក្តីផ្ចាលផ្ចាញ់បាន , បល្ល័ង្ករបស់អ្នកឈ្នះ ) ខាងក្រោមដើមពោធិ ទ្រង់បំបែកក្បាលមារទាំង ៣ ហើយត្រាស់ដឹងព្រមចំពោះអនុត្តរសម្មាសម្ពោធិញ្ញាណក្តី ការដែលព្រះមានព្រះភាគស្តេចរំលត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ នៅចន្លោះដើមរាំងទាំងគូ នាពេលយប់ក្តី ក្នុងវេលា ៤៥ ឆ្នាំ ក្នុងចន្លោះនេះ ( គឺ ចន្លោះក្រោយពេលត្រាស់

ដឹង និង មុនបរិនិព្វាន ) គឺ ក្នុងវេលាបឋមពោធិកាលខ្លះ មជ្ឈិមពោធិកាលខ្លះ បច្ឆិមពោធិកាលខ្លះ ព្រះពុទ្ធវចនៈណា ដែលព្រះមានព្រះភាគត្រាស់ទុកជា សុត្តៈ គេយ្យៈ ។ ល ។ វេទល្លៈក៏ដោយ ព្រះពុទ្ធវចនៈនោះ វិញ្ញូជនពោល ទិទៀនមិនបាន ទាំងដោយអត្ថ ( ន័យ , ខ្លឹមសារ ) ទាំងដោយព្យញ្ជនៈ ( អក្សរ ) មិនខ្វះ មិនលើស បរិបូរដោយអាការគ្រប់យ៉ាង ញាំញីសេចក្តី ស្រវឹងដោយរាគៈ ញាំញីសេចក្តីស្រវឹងដោយទោសៈ និង មោហៈ ការខុសភ្លាត់ ក្នុងព្រះពុទ្ធវចនៈនោះ សូម្បីត្រឹមតែចុងរោមសត្វទ្រាយក្តី ក៏មិនមាន ទាំងអស់ នោះជារបស់ពិត មិនប្រែប្រួល ប្រៀបដូចប្រថាប់ត្រា ( បោះត្រា ) ដោយ ព្រះរាជត្រាតែមួយដូចគ្នា ប្រៀបដូចជាការវាល់ដោយនាទឡិតែមួយដូចគ្នា និង ប្រៀបដូចជាថ្លឹងដោយភ្នែកជញ្ជីងតែមួយដូចគ្នា ដូច្នោះ ។

ព្រោះហេតុនោះ ព្រះបុរាណាចារ្យទើបពោលថា ការដែលព្រះតថាគត ត្រាស់ដឹងព្រមចំពោះនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងពេលយប់ក្តី ការដែល ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ នាពេលយប់ក្តី ការដែល ព្រះតថាគតត្រាស់សន្ទនាចង្អុលបង្ហាញក្នុងចន្លោះនេះក្តី ទាំងអស់នោះជារបស់

ពិត មិនជាយ៉ាងដទៃ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា **តថាគត** ។

ពិតណាស់ **គត** ស័ព្ទ ក្នុងពាក្យថា **តថាគតោ** នេះ មានន័យ ស្មើគ្នានឹង **គទ** ( ត្រាស់ , ពោល ) ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះទ្រង់មានប្រក្រតីត្រាស់វាទៈដែលពិត ដោយប្រការដូចពណ៌នាមកដូច្នេះ ។

ការពោល ឈ្មោះថា **អាគទ** អធិប្បាយថា បានដល់ ពាក្យពោល ។ ការត្រាស់របស់ព្រះតថាគតនោះពិត គឺ មិនវិបរិត ព្រោះហេតុនោះ ទើបមានព្រះនាមថា **តថាគត** ព្រោះផ្លាស់អក្សរ **ទ** ឱ្យមកជាអក្សរ **ត** អ្នកសិក្សាគប្បីជ្រាបបទសម្រេចរូបក្នុងន័យនេះ ដូចពណ៌នាមកដូច្នេះ ។

## តថាគត « មានប្រក្រតីធ្វើពិត »

សួរថា ព្រះមានព្រះភាគទ្រង់មានព្រះនាមថា **តថាគត** ព្រោះទ្រង់ជាអ្នកមានប្រក្រតីធ្វើពិត យ៉ាងណា ?

ឆ្លើយថា ក៏កាយកម្មរបស់ព្រះមានព្រះភាគ រមែងស្របតាមវចីកម្ម ទាំងវចីកម្មក៏ស្របតាមកាយកម្ម ព្រោះហេតុនោះ ព្រះមានព្រះភាគមានប្រក្រតី

ត្រាស់យ៉ាងណា ទើបទ្រង់មានប្រក្រតីធ្វើយ៉ាងនោះ និង មានប្រក្រតីធ្វើយ៉ាង ណា ក៏ទ្រង់មានប្រក្រតីត្រាស់យ៉ាងនោះ អធិប្បាយថា វចីកម្មរបស់ព្រះមាន_ព្រះភាគនោះ ដែលទ្រង់មានយ៉ាងនេះ យ៉ាងណា សូម្បីកាយកម្មក៏ប្រព្រឹត្តទៅដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ÷

**ម្នាលភិក្ខុទាំងទឡាយ តថាគតមានប្រក្រតីពោលយ៉ាងណា ក៏មានប្រក្រតីធ្វើយ៉ាងនោះ មានប្រក្រតីធ្វើយ៉ាងណា ក៏ មានប្រក្រតីពោលយ៉ាងនោះ ព្រោះហេតុដែលមានប្រក្រតី ពោលយ៉ាងណា ទើបមានប្រក្រតីធ្វើយ៉ាងនោះ មានប្រក្រតី ធ្វើយ៉ាងណា ទើបមានប្រក្រតីពោលយ៉ាងនោះ ដូច្នោះទើប បានទទួលព្រះនាមថា តថាគត ។**

ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះជាអ្នកមានប្រក្រតី ធ្វើពិតដូចពណ៌នាមកដូច្នេះ ។

## តថាគត « ជាអ្នកគ្របសង្កត់ »

សួរថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមានន័យថា គ្របសង្កត់ យ៉ាងដូចម្ដេច ?

ឆ្លើយថា ព្រះមានព្រះភាគទ្រង់គ្របសង្កត់ ( មានអំណាចធំ ) ខាងលើតាំងអំពីភវគ្គព្រហ្មចុះមក ខាងក្រោមចាប់អំពីអវិចីនរកទេឡើងទៅ ខាងទទឹងរមែងគ្របសង្កត់ ( មានអំណាចធំលើ ) សព្វសត្វក្នុងលោកធាតុដែលរកប្រមាណមិនបាន ដោយសីលខ្លះ សមាធិខ្លះ បញ្ញាខ្លះ វិមុត្តិខ្លះ វិមុត្តិ-ញ្ញាណទស្សនៈខ្លះ ការថ្លឹង ឬ ការកំណត់វត្ត ( ព្រះគុណ មានសីលជាដើម ) របស់ព្រះមានព្រះភាគជាម្ចាស់នោះ មិនមាន ព្រះអង្គ មានព្រះគុណដែលនរណា ៗ ថ្លឹងមិនបាន ប្រមាណមិនដល់ មិនមានអ្នកណាក្រៃលែងជាង ជារាជាលើរាជា ជាទេវតាលើទេវតា ជាស្ដេចសក្កៈលើស្ដេចសក្កៈទាំងទឡាយ ជាព្រហ្មលើព្រហ្មទាំងទឡាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ÷

**ម្នាលភិក្ខុទាំងទឡាយ តថាគតអ្នកគ្របសង្កត់ ( តែ )**

**មិនមានអ្នកណាគ្របសង្កត់បាន ជាអ្នកឃើញពិត ជាអ្នកផ្សព្វផ្សាយអំណាចបានក្នុងលោក និង ទេវលោក ។ល។ ក្នុងពពួកសត្វ , ទេវតា និង មនុស្ស ។ ព្រោះហេតុនោះ ទើបបានទទួលព្រះនាមថា តថាគត ។**

ក្នុងបទថា **តថាគត** នោះ គប្បីជ្រាបបទសម្រេចរូបយ៉ាងនេះ ។

វត្ថុ ដូចឱសថ ឈ្មោះថា **អគទ** ។ ក៏ឱសថនោះ គឺអ្វី ? គឺ ការផ្លាស់ប្តូរនៃទេសនា ( តាមឧបនិស្ស័យរបស់អ្នកស្តាប់ ) និង ការពូននៃ បុណ្យ ។ ក៏ព្រោះឱសថនោះ ព្រះមានព្រះភាគទើបជាពេទ្យដែលមានអានុភាព ច្រើន ទ្រង់គ្របសង្កត់អ្នកដែលប្រកាន់លទ្ធិដទៃទាំងអស់ និង លោក ទាំង ទេវលោក ដូចជាបង្រ្កាបពស់ ( ពិស ) ដោយទិព្វឱសថ ដូច្នោះ ។ ឱសថ ក្នុងការគ្របសង្កត់លោកទាំងអស់ របស់ព្រះមានព្រះភាគនោះ សម្រេចមកពី ការផ្លាស់ប្តូរនៃទេសនា និង សម្រេចមកពីបុណ្យដែលជារបស់ពិត មិនប្រែ ប្រួល ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគបានទទួលព្រះនាម ថា **តថាគត** ព្រោះផ្លាស់អក្សរ **ទ** ជា **ត** អក្សរ ដោយប្រការដូចពោល

មកនេះ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមានន័យថា គ្របសង្កត់ ដូចពណ៌នាមកដូច្នេះ ។

## តថាគត « ជាអ្នកដល់ដោយសេចក្តីពិត »

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះមាន ន័យថា ទ្រង់ (ចូល) ដល់ដោយសេចក្តីពិតខ្លះ ទ្រង់ (ចូល) ដល់ សេចក្តីពិតខ្លះ ។ បទថា **គតោ** មានន័យថា ដល់ហើយ ផុតហើយ សម្រេចហើយ ធ្វើដំណើរទៅដល់ហើយ ។ ក្នុងពាក្យទាំងនោះ គប្បីជ្រាប

ការអធិប្បាយដូចតទៅនេះ ÷

ព្រះមានព្រះភាគទ្រង់ដល់ហើយ គឺ ទៅដល់ហើយនូវលោកទាំងអស់ ដោយសេចក្តីពិត គឺ តីរណបរិញ្ញា ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺ ផុតហើយនូវហេតុកើតទឡើង របស់លោកដោយសេចក្តីពិត គឺ បហានបរិញ្ញា ព្រោះហេតុនោះ ទើប ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺ សម្រេចហើយនូវការរលត់របស់លោកដោយសេចក្ដីពិត គឺ ការធ្វើឱ្យច្បាស់ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ទ្រង់ដល់ហើយ គឺ ធ្វើដំណើរទៅដល់ហើយនូវសេចក្ដីពិត គឺ ការបដិបត្តិដែលជាហេតុឱ្យដល់ការរលត់លោក ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រោះហេតុនោះ ពាក្យណាដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទ្បាយ លោក ដែលតថាគតត្រាស់ដឹងព្រមចំពោះហើយ តថាគតរួចផុតហើយពីលោក ម្នាលភិក្ខុទាំងទ្បាយ ហេតុកើតរបស់លោក ដែលតថាគតត្រាស់ដឹងព្រមចំពោះហើយ តថាគតលះហេតុកើតរបស់លោកបានហើយ ម្នាលភិក្ខុទាំងទ្បាយ សេចក្ដីរលត់របស់លោក ដែលតថាគតត្រាស់ដឹងព្រមចំពោះហើយ តថាគតធ្វើឱ្យច្បាស់នូវការរលត់លោកបានហើយ ម្នាលភិក្ខុទាំងទ្បាយ ការបដិបត្តិដែលជាហេតុឱ្យដល់ការរលត់លោក ដែលតថាគតត្រាស់ដឹងព្រមចំពោះហើយ តថាគតចម្រើនការបដិបត្តិ ដែលជាហេតុឱ្យដល់

ការរលត់លោកបានហើយ ម្នាលភិក្ខុទាំងទឡាយ វត្ថុណា ( មានហើយ ) ដល់លោក និង ទេវលោក វត្ថុទាំងអស់នោះ ដែលតថាគតត្រាស់ដឹងព្រម ចំពោះហើយ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា **តថាគត** អត្ថន័យនៃ ពាក្យនោះ អ្នកសិក្សាគប្បីជ្រាបយ៉ាងនេះ ។

សូម្បីពាក្យពេចន៍ដែលពោលមកនេះ ក៏ត្រឹមតែជាកថាមុខក្នុងការ សម្តែងដល់ភាវៈដែលព្រះតថាគត ជាអ្នកចូលដល់សេចក្តីពិតប៉ុណ្ណោះ ។ ក៏ ព្រះតថាគតប៉ុណ្ណោះ គប្បីពណ៌នាភាវៈដែលព្រះតថាគតជាអ្នកចូលដល់សេចក្តី ពិតបាន ដោយអាការគ្រប់យ៉ាង ។

## អធិប្បាយ អរហំ សម្មាសម្ពុទ្ធោ

ចំណែកក្នុងពីរបទថា **អរហំ សម្មាសម្ពុទ្ធោ** គប្បីជ្រាបការអធិប្បាយ ដូចតទៅ ÷

ជាដំបូង ព្រះមានព្រះភាគ គប្បីជ្រាបថា ជាព្រះអរហន្តដោយ ហេតុទាំងនេះ គឺ ÷

១ ព្រោះទ្រង់ឆ្ងាយ ( ចាកកិលេស )

២ ព្រោះទ្រង់កម្ចាត់សត្រូវទាំងទឡាយ

៣ ព្រោះទ្រង់កាច់បំបាក់កាំ ( នៃសង្សារចក្រ ) ទាំងទឡាយ

៤ ព្រោះជាអ្នកគួរដល់បច្ច័យជាដើម

៥ ព្រោះមិនមានទីកំបាំងក្នុងការធ្វើបាប

ចំណែកដែលឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួង ដោយប្រពៃ និង ដោយព្រះអង្គឯង សេចក្ដីសង្ខេបក្នុងទីនេះ មានប៉ុណ្ណេះ ។ ប៉ុន្តែបទទាំងពីរ (គឺ **អរហំ សម្មាសម្ពុទ្ធោ** ) នេះ ព្រះពុទ្ធឃោសាចារ្យ បានអធិប្បាយទុកហើយដោយពិស្តារក្នុងការពណ៌នាពុទ្ធានុស្សតិក្នុងវិសុទ្ធិមគ្គ ។

## បរិញ្ញាតវារ

ក៏ក្នុងបទថា **បរិញ្ញាតន្តំ តថាគតស្ស** នេះគប្បីជ្រាបអធិប្បាយ ថា វត្ថុ ( ដែលជាទីតាំងនៃ ) ការចាប់ប្រកាន់នោះ ព្រះតថាគតកំណត់ ដឹងហើយ ដូច្នេះក៏បាន ។ វត្ថុនោះឈ្មោះថា តថាគតកំណត់ដឹងហើយ គឺ មានវារៈដែលព្រះអង្គទ្រង់ដឹងដោយប្រពៃហើយ មានទីបំផុតដែលព្រះអង្គ ទ្រង់ដឹងដោយប្រពៃហើយ អធិប្បាយថា ទ្រង់ដឹងយ៉ាងប្រពៃមិនមានអ្វីសល់ ។

ការពិត ព្រះពុទ្ធទាំងទឡ្យាយ និង ព្រះសាវក មិនមានសេចក្ដីផ្សេងគ្នាក្នុងការលះកិលេសដោយមគ្គនោះ ៗ ក៏ពិត តែក៏នៅមានសេចក្ដីផ្សេងគ្នាក្នុងរឿងបរិញ្ញា ( ការដឹងដោយជុំវិញ ) ព្រោះថា ព្រះសាវកទាំងទឡ្យាយពិចារណាធាតុ ៤ បានត្រឹមចំណែកខ្លះប៉ុណ្ណោះ ក៏សម្រេចព្រះនិព្វានបាន តែចំណែកព្រះពុទ្ធទាំងទឡ្យាយ សង្ខារសូម្បីមានប្រមាណតិច ដែលនៅមិនទាន់បានឃើញ មិនបានពិចារណា មិនបានធ្វើឱ្យជាក់ច្បាស់ដោយព្រះញាណ រមែងមិនមាន ។

ចំណែកវារៈពោលដោយ **និព្វាន** គឺ វារៈមានជាអាទិថា **នន្ទិ** ( សេចក្ដីភ្លើតភ្លើន) ជាឫសគល់នៃទុក្ខនេះ ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុក ហើយវារៈនោះគួរអធិប្បាយឱ្យពិស្ដារ សូម្បីក្នុងវារៈពោលដោយបឋវីជាដើម ។ វារៈនេះជាវារៈពោលដោយវត្ថុដែលទ្រង់កំណត់ដឹង និង កាលបើអធិប្បាយឱ្យពិស្ដារចេញទៅ វារៈដែលថា **បរិញ្ញាតន្តំ តថាគតស្ស** គួរប្រកបចូលជាមួយនឹងបទគ្រប់បទ ( ទាំង ) ពាក្យថា **នន្ទិ** ជាឫសគល់របស់ទុក្ខជាដើម ក៏គួរប្រកបចូលមកទៀត ។ ចំណែកទេសនា ព្រះមានព្រះភាគទ្រង់សង្ខេបទុក

ដោយទ្រង់សម្គាល់ថា វត្ថុ ( ដែលជាទីតាំងនៃការចាប់ប្រកាន់ ) ជាការដែលពោលទុកបទតែមួយ ។

## កែបទ នន្ទិ ទុក្ខស្ស មូលំ

ម្យ៉ាងទៀត ក្នុងបទថា **នន្ទិ ទុក្ខស្ស មូលំ** ជាដើម គប្បីជ្រាបអធិប្បាយដូចតទៅនេះ ÷

ក្នុងបទថា **នន្ទិ** បានដល់ តណ្ហាគ្រាដំបូង ។ បទថា **ទុក្ខំ** បានដល់ បញ្ចក្ខន្ធ , បទថា **មូលំ** បានដល់ ឫសគល់ ។ បទថា **ឥតិ វិទិត្វា** សេចក្តីថា ព្រោះជ្រាបនន្ទិ ( សេចក្តីត្រេកអរ ) ក្នុងភពគ្រាដំបូងនោះយ៉ាងនេះថា ជាឫសគល់របស់ទុក្ខ ។ បទថា **ភវា** បានដល់ ព្រោះកម្មភព ។ បទថា **ជាតិ** បានដល់ វិបាកខន្ធ ( ខន្ធដែលជាវិបាក គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ ) ។ ពិតណាស់ វិបាកខន្ធទាំងនោះ ព្រោះហេតុដែលកើត ដូច្នោះ ទើបត្រាស់ហៅថា **ជាតិ** ។

ម្យ៉ាងទៀត ទេសនានេះ ព្រះមានព្រះភាគសម្តែងទុកដល់ជាតិ (ការកើតរបស់វិបាកខន្ធ) ជាមាតិកា ។ សូម្បីយ៉ាងនេះ ទើបគួរប្រកបចូលនឹង

ពាក្យនេះថា **ឥតិ វិទិត្វា** ។ ក៏ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា ក៏ព្រោះជ្រាបយ៉ាងនេះថា ព្រោះកម្មភព ( ចេតនាដែលធ្វើកម្ម ) ទើបមាន ឧបបត្តិភព ។ បទថា **ភូតស្ស** ប្រែថា របស់សត្វ ។ បទថា **ជរា_ មរណំ** ប្រែថា ជរា និង មរណៈ ។ មានពាក្យអធិប្បាយយ៉ាងនេះថា ក៏ព្រោះជ្រាបយ៉ាងនេះថា ជរា និង មរណៈ រមែងមានដល់ខន្ធរបស់សត្វ ដែលកើតមកហើយ ព្រោះឧបបត្តិភពនោះ ។

ព្រះមានព្រះភាគ ប្រថាប់គង់លើអបរាជិតបល្ល័ង្ក នៅក្រោមម្លប់ដើម_ ពោធិ ទ្រង់ពិចារណាបដិច្ចសមុប្បាទណា ទើបបានសម្រេចព្រះសព្វញ្ញុត_ញ្ញាណ ព្រោះទ្រង់ចាក់ធ្លុះនូវបដិច្ចសមុប្បាទនោះឯង កាលទ្រង់សម្តែងហេតុ នៃការមិនមាន នៃការប្រកាន់ទាំងទឡ្យាយ ទើបទ្រង់សម្តែងបដិច្ចសមុប្បាទនោះ ឯង ដែលមានសង្ខេប (ការរួបរួម ) ៤ , មានសន្ធិ ៣ , មានអទ្ធា ( កាល ) ៣ , មានអាការ ២០ ។

## អធិប្បាយ បដិច្ចសមុប្បាទ

សួរថា ក៏បដិច្ចសមុប្បាទទាំងអស់នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងហើយដោយពាក្យត្រឹមតែប៉ុណ្ណោះ យ៉ាងណា ?

ឆ្លើយថា ក៏ក្នុងពាក្យថា **នន្ទិ ទុក្ខស្ស មូលំ** នេះ មានអធិប្បាយ ថា ស័ព្ទថា **នន្ទិ** ជាសង្ខេបទី ១ **ទុក្ខ** ជាសង្ខេបទី ២ ព្រោះមាន ព្រះបាលីថា **ទុក្ខស្ស ភព** ជាសង្ខេបទី ៣ ព្រោះមានព្រះបាលីថា **ភវា , ជាតិ** ជាតិ ជរា និង មរណៈ ជាសង្ខេបទី ៤ ។ គប្បីជ្រាបសង្ខេប ៤ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ដូចពណ៌នាមកនេះ ។ ( បទថា សង្ខេប ) អធិប្បាយថា បានដល់ចំណែកទាំងទឡ្យាយ ។

រវាងតណ្ហា និង ទុក្ខ ជាសន្ធិទី ១ , រវាងទុក្ខ និង ភព ជាសន្ធិ ទី២ , រវាងភព និង ជាតិ ជាសន្ធិទី ៣ ។ គប្បីជ្រាបសន្ធិ ៣ រវាង សង្ខេប ៤ ដែលដូចគ្នានឹងចន្លោះម្រាមដៃទាំង ៤ ដូចពណ៌នាមកនេះ ។

ក្នុងបដិច្ចសមុប្បាទនោះ **នន្ទិ** ជាអតីតទ្ធា ( កាលជាអតីត ) ជាតិ ជរា និង មរណៈ ជាអនាគតទ្ធា ( កាលជាអនាគត ) ទុក្ខ និង ភព ជាបច្ចុប្បន្នទ្ធា ( កាលជាបច្ចុប្បន្ន) ។ គប្បីជ្រាប អទ្ធា ៣ ដូចពណ៌នា មកនេះឯង ។

ម្យ៉ាងទៀត ក្នុងអតីតទ្ធា ក្នុងបណ្តាអាការ ៥ ដោយពាក្យថា **នន្ទិ**

តណ្ហាទើបមកហើយ ១ សូម្បីតណ្ហានោះ នឹងមិនទាន់មក ( អាការ ៤ គឺ ) អវិជ្ជា សង្ខារ ឧបាទាន និង ភព ក៏ជាការចាត់ចូលហើយតែម្យ៉ាង ដោយលក្ខណៈដែលជាបច្ច័យ ។ ម្យ៉ាងទៀត ដោយពាក្យថា **ជាតិ ជរា** និង **មរណ** ព្រោះហេតុដែលអធិប្បាយទុកថា ខន្ធពួកណាមានជាតិ ជរា និង មរណៈនោះ ខន្ធទាំងនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយក្នុងអនាគតទ្ធា ទើបជាការដែលរួមយកវិញ្ញាណ នាមរូប សទឡាយតនៈ ផស្សៈ និង វេទនា ចូលជាមួយដូចគ្នា ។

ក្នុងកម្មភព ដែលជាភពដំបូង មានធម៌ ៥ ប្រការនេះ គឺ មោហៈ បានដល់ អវិជ្ជា , ការប្រមូលមក បានដល់ សង្ខារ , សេចក្តីប្រាថ្នា បានដល់ តណ្ហា , ការចូលទៅប្រកាន់ បានដល់ ឧបាទាន , ចេតនា បានដល់ ភព ជាបច្ច័យរបស់បដិសន្ធិក្នុងបច្ចុប្បន្នទ្ធា ព្រោះកម្មភព ជា ភពដំបូង ។

ក្នុងបច្ចុប្បន្នទ្ធា មានធម៌ ៥ ប្រការនេះ គឺ បដិសន្ធិ គឺ វិញ្ញាណ , វត្ថុដែលឈានចុះ គឺ នាមរូប , បសាទរូប គឺ អាយតនៈ , អាការដែល

ប៉ះពាល់ត្រូវ គឺ ផស្សៈ , អាការដែលសោយអារម្មណ៍ គឺ វេទនា ជាបច្ច័យរបស់កម្មដែលធ្វើទុកក្នុងកាលមុន ព្រោះឧបបត្តិភព ក្នុងបច្ចុប្បន្នទ្ធា ។

ប៉ុន្តែព្រោះក្នុងបច្ចុប្បន្នទ្ធា អាយតនៈទាំងទឡ្យាយចម្រើនបាន ទើបមានធម៌ ៥ ប្រការទាំងនេះ គឺ មោហៈ គឺ អវិជ្ជា , ការប្រមូលមក គឺ សង្ខារ , សេចក្តីប្រាថ្នា គឺ តណ្ហា , ការចូលទៅប្រកាន់ គឺ ឧបាទាន , ចេតនា គឺ កម្មភព ជាបច្ច័យរបស់បដិសន្ធិក្នុងអនាគតទ្ធា ព្រោះកម្មភពក្នុងបច្ចុ_ប្បន្នទ្ធា ។

ក្នុងអនាគតទ្ធា មានធម៌ ៥ ប្រការនេះគឺ បដិសន្ធិ គឺ វិញ្ញាណ វត្ថុដែលឈានចុះ (កើតទេឡើង ) គឺ នាមរូប បសាទរូប គឺ អាយតនៈ អាការដែលប៉ះពាល់ត្រូវ គឺ ផស្សៈ អាការដែលសោយអារម្មណ៍ គឺ វេទនា ជាបច្ច័យរបស់កម្មដែលធ្វើទុកហើយក្នុងបច្ចុប្បន្នទ្ធា ព្រោះឧបបត្តិភពក្នុងអនា_គតទ្ធា ។

គប្បីជ្រាប អាការ ២០ នេះ ក្នុងបដិច្ចសមុប្បាទនេះ ដែលមានលក្ខណៈដូចសម្តែងទុកហើយយ៉ាងនេះ ដោយប្រការដូច្នេះឯង ។

បដិច្ចសមុប្បាទ ដែលមានសង្ខេប ៤ មានសន្ធិ ៣ មានអទ្ធា ៣ (និង) មានអាការ ២០ សូម្បីទាំងអស់ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណេះថា ព្រោះជ្រាបយ៉ាងនេះថា **នន្ទិ** (សេចក្ដីត្រេកត្រអាល-ត្រេកអរ) ជាឫសគល់របស់ទុក្ខ ទើបជ្រាបតទៅថា ព្រោះភព ទើបជាតិមាន សត្វដែលកើតមកហើយ រមែងមានជរា និង មរណៈ ដោយប្រការដូចពណ៌នាមកនេះ ។

## កែបទ ខយា វិរាគា បដិនិស្សគ្គា

ឥឡូវនេះ ខ្ញុំម្ចាស់នឹងធ្វើការពណ៌នាទៅតាមលំដាប់បទ ក្នុងបទនេះថា **តស្មា តិហ ភិក្ខវេ ។បេ។ អភិសម្ពុទ្ធោតិ វទាមិ** ហើយសរុបដោយបទយោជនា ។

បទថា **តស្មា តិហ** មានអធិប្បាយថា បានដល់ **តស្មា** (ព្រោះ ហេតុនោះ) នោះឯង។ (ព្រោះថា) **តិ** អក្សរនិង **ហ** អក្សរ ជានិបាត។ ពាក្យថា **សព្វសោ** នោះ ជាពាក្យពោលមិនមានចំណែកសល់ ។ បទថា **តណ្ហានំ** បានដល់ តណ្ហាទាំងអស់ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាង

នេះថា **នន្ទិ** ។ បទថា **ខយា** ប្រែថា ព្រោះការអស់ទៅដោយប្រពៃដោយលោកុត្តរមគ្គ ។ ពាក្យថា **វិរាគ**(ប្រាសចាក) ជាដើម ជាវេវចនៈ នៃពាក្យថា **ខយ** ( ការអស់ទៅ ) ។ អធិប្បាយថា តណ្ហាណាអស់ទៅហើយ តណ្ហានោះរមែងប្រាសទៅហើយខ្លះ រលត់ហើយខ្លះ រលាស់ចោលហើយខ្លះ បោះបង់ខ្លះ ។ ម្យ៉ាងទៀត ពាក្យថា **ខយា** នោះ ជាពាក្យប្រើទូទៅដល់ កិច្ចរបស់មគ្គ ទាំង ៤ ។ ព្រោះហេតុនោះ ទើបគួរអធិប្បាយប្រកបសេចក្ដីថា ព្រោះប្រាសទៅបានហើយដោយមគ្គទី១ (សោតាបត្តិមគ្គ) មគ្គទី២ ( សកទាគាមិមគ្គ) ព្រោះលះបង់បានដោយមគ្គទី៣(អនាគាមិមគ្គ) ព្រោះលះបង់ ( ជាសមុច្ឆេទ ) ដោយមគ្គទី៤ ( អរហត្តមគ្គ ) ។

ម្យ៉ាងទៀតគប្បីធ្វើអធិប្បាយប្រកបសេចក្ដីក្នុងព្រះតម្រាស់វគ្គនេះ ( ទៀត ) យ៉ាងនេះថា បុថុជ្ជនសម្គាល់បឋវីធាតុ ថាជា បឋវីធាតុដោយតណ្ហាពួកណា ព្រោះការអស់ទៅនៃតណ្ហាទាំងនោះ បុថុជ្ជនគប្បីប្រកាន់នូវបឋវី_ធាតុដោយតណ្ហាណា ព្រោះការប្រាសទៅនូវតណ្ហានោះ បុថុជ្ជនប្រកាន់ក្នុងបឋវីធាតុដោយតណ្ហាណា ព្រោះរលាស់ចោលតណ្ហានោះចេញបាន បុថុជ្ជន

ប្រកាន់ថា បឋវីធាតុរបស់យើងដោយតណ្ហាពួកណា ព្រោះលះបង់នូវតណ្ហានោះចេញបាន បុថុជ្ជនប្រកាន់ថា បឋវីធាតុរបស់យើងដោយតណ្ហាណា ព្រោះលះបង់តណ្ហានោះចេញបាន ម្យ៉ាងទៀត បុថុជ្ជន ប្រកាន់បឋវីធាតុដោយតណ្ហាណា ព្រោះការអស់ទៅនៃតណ្ហាទាំងនោះ ។ល។ បុថុជ្ជនត្រេកអរនឹងបវីធាតុដោយតណ្ហាណា ព្រោះបោះបង់តណ្ហាទាំងនោះបាន ។ ( សេចក្ដីទាំងពីរនេះ ) មិនមានអ្វីដែលផ្សេងគ្នា ។

បទថា **អនុត្តរំ** គឺ វៀរចាកបុគ្គលដ៏ក្រៃលែងជាង បានដល់ប្រសើរជាងបុគ្គលដទៃទាំងអស់ ។

## អត្ថន័យរបស់ពាក្យថា « ពោធិ »

បទថា **សម្មាសម្ពោធឹ** ប្រែថា ការត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត (មានន័យថា ) ការត្រាស់ដឹង ដែលបណ្ឌិតសរសើរ និង ល្អប្រពៃ ។ បទថា **ពោធិ** សំដៅដល់ ដើមឈើខ្លះ មគ្គខ្លះ សព្វញ្ញុតញ្ញាណខ្លះ និព្វានខ្លះ ។ អធិប្បាយថា ដើមឈើ ហៅថា **ពោធិ** ( ដូច ) ក្នុងអាគតដ្ឋានថា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ**

( ប្រែថា ត្រាស់ដឹងដំបូង ក្រោមដើមពោធិ ) និងថា **អន្តរា ច ពោធឹ អន្តរា ច គយំ** ( ប្រែថា ចន្លោះដើមពោធិ និងស្រុកគយា ) ។ មគ្គហៅ ថា **ពោធិ** (ដូច ) ក្នុងអាគតដ្ឋាន ដែលថា **ចតុមគ្គេសុ ញាណំ** (ប្រែថា ញាណក្នុងមគ្គ ៤ ) ។ សព្វញ្ញុតញ្ញាណ ហៅថា **ពោធិ** ( ដូច ) ក្នុងអាគតដ្ឋានដែលថា **បប្បោតិពោធឹ វរភូមិ មេធសោ** ( ប្រែថា ព្រះអង្គមានបញ្ញាដ៏ប្រសើរ ជាកំពូលនៃអ្នកប្រាជ្ញ ទ្រង់សម្រេចព្រះពោធិញ្ញាណ ) ។ និព្វាន ហៅថា **ពោធិ** (ដូច) ក្នុងអាគតដ្ឋានដែលថា **បត្វាន ពោធឹ អមតំ អសង្ខតំ** ( ប្រែថា ព្រះមានព្រះភាគទ្រង់សម្រេចពោធិ ដែលជា អមតៈ មិនមានបច្ច័យតាក់តែង ) ។ តែក្នុងទីនេះ បំណងយកអរហត្ត-មគ្គញ្ញាណរបស់ព្រះមានព្រះភាគ ។ អាចារ្យខ្លះទៀតពោលថា បំណងយកសព្វញ្ញុតញ្ញាណ ដូច្នេះខ្លះ ។

សួរថា អរហត្តមគ្គរបស់ព្រះសាវកទាំងទឡាយចាត់ជាពោធិញ្ញាណ ដ៏កំពូល ឬទេ ?

ឆ្លើយថា មិនបាន

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះឱ្យសម្រេចគុណមិនបានគ្រប់យ៉ាង ។

ជាការពិត បណ្តាព្រះសាវកទាំងនោះ អរហត្តមគ្គរបស់លោកខ្លះ ឱ្យសម្រេចបានចំពោះអរហត្តផលប៉ុណ្ណោះ ។ របស់លោកខ្លះ ឱ្យសម្រេចវិជ្ជា ៣ របស់លោកខ្លះ ឱ្យសម្រេចអភិញ្ញា ៦ របស់លោកខ្លះ ឱ្យសម្រេច បដិសម្ភិទា ៤ របស់លោកខ្លះ ឱ្យសម្រេចសាវកបារមីញាណ ។ សូម្បីរបស់ព្រះបច្ចេកពុទ្ធទាំងទឡាយ ក៏ឱ្យសម្រេចចំពោះបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ចំណែកអរហត្តមគ្គរបស់ព្រះពុទ្ធទាំងទឡាយ ក៏ឱ្យសម្រេចគុណសម្បត្តិគ្រប់យ៉ាង ប្រៀបដូចជាការអភិសេក ( ក្នុងរាជសម្បត្តិ ) របស់ព្រះរាជា រមែងឱ្យសម្រេចភាពជាធំក្នុងលោកទាំងអស់ ព្រោះដូច្នោះ ពោធិញ្ញាណរបស់អ្នកណា ៗ ទើបមិនចាត់ជាកំពូលទេ ។

បទថា **អភិសម្ពុទ្ធោ** មានន័យថា ដឹងដ៏ក្រៃលែងហើយ គឺ ចាក់ធ្លុះ ហើយ អធិប្បាយថា ដល់ហើយ គឺ សម្រេចហើយ ។ បទថា **ឥតិ វទាមិ** សេចក្តីថា យើងតថាគត តែងពោល គឺ ប្រាប់ សម្តែង បញ្ញត្ត

តែងតាំង បើកបង្ហាញ ចែក ធ្វើឱ្យងាយ ដោយប្រការដូច្នេះ ។

ក្នុងពាក្យនោះ មានអធិប្បាយពង្រីកសេចក្ដីដូច្នេះថា ម្នាលភិក្ខុទាំង-ទឡាយ សូម្បីតថាគត ។ល។ រមែងមិនប្រកាន់បឋវីធាតុ ។ល។ រមែងមិនត្រេកអរក្នុងបឋវីធាតុ សេចក្ដីនោះព្រោះហេតុអ្វី ? ព្រោះដឹងច្បាស់យ៉ាងនេះថា **នន្ទិ** (សេចក្ដីភ្លើតភ្លើន-ត្រេកអរ ) ជាឫសគល់របស់ទុក្ខ ព្រោះភពទើបមានជាតិ សត្វដែលកើតមកហើយ មានជរា និង មរណៈ ។

**ឥតិ** អក្សរ ក្នុងបទថា **ឥតិ វិទិត្វា** ( ដែលមក ) ក្នុងពាក្យថា **នន្ទិ ទុក្ខស្ស មូលំ ។ បេ ។ ជរា មរណន្តិ ឥតិ វិទិត្វា** នោះមាន សេចក្ដីថា ការណៈ( ជាហេតុ) ព្រោះហេតុនោះ ទើបមានអធិប្បាយថា ព្រោះដឹងច្បាស់ គឺ ព្រោះចាក់ធ្លុះនូវបដិច្ចសមុប្បាទនេះ ។

គប្បីជ្រាបសេចក្ដីបន្ថែមបន្តិចបន្តួចទៀត ។ ព្រោះហេតុដែលព្រះ-តថាគតទ្រង់ដឹងច្បាស់បដិច្ចសមុប្បាទនេះ យ៉ាងនេះ ទើបទ្រង់លះតណ្ហាដែលត្រាស់ទុកថា **នន្ទិ** នោះបាន សូម្បីគ្រប់ប្រការ និង ព្រោះតណ្ហា ទាំងនោះអស់ទៅទាំងអស់ ព្រះតថាគត ទើបបានត្រាស់ដឹងព្រមចំពោះនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ តថាគតទើបពោលថា ព្រះ-

តថាគត រមែងមិនប្រកាន់បឋវីធាតុ ។ល។ មិនត្រេកអរនឹងបឋវីធាតុ អធិ_ប្បាយថា ព្រោះត្រាស់ដឹងព្រមចំពោះយ៉ាងនេះ តថាគតទើបពោលថា តថា_គតមិនប្រកាន់ មិនត្រេកអរ ( នូវបឋវីធាតុ ) ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះតថាគតទ្រង់ដឹងច្បាស់បដិច្ចសមុប្បាទ ដោយន័យមានជាអាទិថា នន្ទិ ជាឫសគល់របស់ទុក្ខ ទើបទ្រង់ដល់ភាពអស់ទៅនៃតណ្ហាដោយប្រការទាំងពួង ដូច្នេះឯង ភិក្ខុទាំងឡាយ តថាគតទើបពោលថា ព្រះតថាគតបានត្រាស់ដឹងព្រមចំពោះ ។ ល ។ ព្រោះការអស់ទៅនៃតណ្ហាដោយប្រការទាំងពួង ព្រោះត្រាស់ដឹងចំពោះយ៉ាងនេះ ព្រះ_ តថាគតទើបមិនប្រកាន់បឋវីធាតុ ។ល។ មិនត្រេកអរ ។ ក៏ក្នុងទីណា ៗ ព្រះមានព្រះភាគមិនបានត្រាស់ **យស្មា** (ព្រោះហេតុណា) ទុក ត្រាស់ ទុកតែ **តស្មា** ( ព្រោះហេតុនោះ ) ក្នុងទីនោះ ៗ ត្រូវនាំ **យស្មា** មក ប្រកបចូលផង ។ វិធីនេះ ជាវិធីដែល យុត្តិ ( ត្រឹមត្រូវ ) ក្នុងផ្លូវ សាសនា ។ ក្នុងគ្រប់បទក៏មានន័យតែម្យ៉ាងដូចគ្នា ។

## ហេតុ. ផល ដែលភិក្ខុមិនត្រេកអរនឹងភាសិត របស់ព្រះពុទ្ធជាម្ចាស់

បទថា **ឥទមវោច ភគវា** សេចក្ដីថា ព្រះមានព្រះភាគ កាលទ្រង់

សម្ដែងព្រះសព្វញ្ញុតញ្ញាណ មិនគប្បីបានដោយបញ្ញារបស់បុគ្គលដទៃ (បុគ្គលដទៃមិនអាចដឹងដល់ ) ទើបទ្រង់ប្រដាប់ដោយវារៈរបស់បថុជ្ជន ១ វារៈ ដោយវារៈរបស់សេក្ខបុគ្គល ១ វារៈ ដោយវារៈរបស់ព្រះខីណាស្រព ៤ វារៈ ( និង ដោយវារៈរបស់ព្រះតថាគត ២ វារៈ រួមមាន ប្រដាប់ដោយវារៈធំ) (សំខាន់ ) ៨ វារៈ ហើយក្នុងវារៈ ( ធំ ) មួយវារៈៗ ទ្រង់ប្រដាប់ដោយ វារៈក្នុងរវាង ( វារៈតូច ) ២៤ វារៈ មានវារៈពោលដោយបឋវីធាតុជាដើម ហើយបានត្រាស់ព្រះសូត្រទាំងអស់ ដែលផ្ដើមតាំងអំពីការបញ្ចប់ពាក្យផ្ដើម រហូតដល់ពាក្យថា **យាវ អភិសម្ពុទ្ធោតិ វទាមិ** ដោយបរិយត្តិចំនួន ២ ភាណវារៈ ។

ក៏ឯព្រះមានព្រះភាគ សូម្បីនឹងត្រាស់ព្រះសូត្រនេះ ដែលប្រកបដោយន័យដ៏វិចិត្រ និង អត្ថដ៏ផូរផង់នៃទេសនា ដោយព្រះសូរសៀងដូចសំទេឡងព្រហ្ម ដ៏ពីរោះដូចសំទេឡងបក្សីករវិក ( និង ) ដូចជាទ្រង់ស្រោចស្រពហឫទ័យរបស់ជនទាំងទឡាយដោយទឹកអម្រឹត ព្រោះជាទីរីករាយដល់ត្រចៀក យ៉ាងនេះ ( ភិក្ខុទាំងនោះក៏មិនត្រេកអរ_រីករាយចំពោះភាសិត ) ។

បទថា **ន តេ ភិក្ខូ ភគវតោ ភាសិតា អភិនន្ទុំ** សេចក្ដីថា ភិក្ខុ ៥០០ រូបនោះ មិនបានអនុមោទនាព្រះតម្រាស់របស់ព្រះមានព្រះភាគ នេះទេឡើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនយល់ ។ បានឮថា ភិក្ខុទាំងនោះមិនយល់សេចក្ដីនៃព្រះសូត្រនេះ ដូច្នោះទើបមិនត្រេកអរ_រីករាយ ។ ពិតហើយក្នុងសម័យនោះ ព្រះសូត្រនោះ សូម្បីនឹងប្រកបដោយន័យដ៏វិចិត្រ និង ការផ្ទួរផង់នៃទេសនាយ៉ាងនេះ ចំណែកភិក្ខុទាំងនោះ ដូចជាបុគ្គលដែលគេយកក្រណាត់សំពត់ក្រាស់មកចងមាត់ទុក ហើយយករបស់ស៊ីដែលពេញចិត្តដាក់ចំពោះមុខ ( មិនអាចស៊ីបាន ) ដូច្នោះ ។

សួរថា ក៏ព្រះមានព្រះភាគទ្រង់បំពេញបារមីមកអស់ ៤ អសង្ខេយ្យ ហើយបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ក៏ដើម្បីទូន្មានបុគ្គលដទៃឱ្យយល់ធម៌ដែលព្រះអង្គទ្រង់សម្ដែង មិនមែនឬ ? ដូចម្ដេច ទើបព្រះអង្គទ្រង់សម្ដែងធម៌ដល់ភិក្ខុទាំងនោះ ហើយភិក្ខុទាំងនោះនៅមិនយល់ ( ខ្លឹមសារ ) នេះ ?

ឆ្លើយថា ពាក្យឆ្លើយនេះ លោកពោលទុកហើយក្នុងវិចារណបទ តាំងទេឡើងរបស់ព្រះសូត្រនេះថា ព្រះមានព្រះភាគទ្រង់ផ្តើមទេសនាទុកយ៉ាងនេះថា **សព្វធម្មមូលបរិយាយំ** ក៏ដើម្បីកាច់បំបាក់នូវមានះ ( របស់ភិក្ខុទាំងនោះ ) ដូច្នោះ ក្នុងទីនេះ ទើបមិនមានអ្វីដែលត្រូវពោលដដែលទៀត ។

លុះបានស្តាប់សូត្រនេះ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដើម្បីកាច់បំបាក់នូវមានះយ៉ាងនេះហើយ ភិក្ខុទាំងនោះទើបគិតគ្នាថា បានឮថា បុថុជ្ជនមាន ( មិច្ឆាទិដ្ឋិ ) មានទិដ្ឋិជាដំណើរ រមែងសម្គាល់បឋវីនោះឯង ចំណែកព្រះសេក្ខៈ ព្រះអរហន្ត និង ព្រះតថាគត រមែងជ្រាបច្បាស់ថា វត្ថុនេះគឺអ្វី វត្ថុនេះយ៉ាងណា ដូច្នេះ ជាអ្នកអស់មានះ ដូចអសិរពិសដែលត្រូវដកចង្កូមហើយ ដូច្នោះ ដោយរលឹកបានថា កាលមុនពួកយើងរមែងដឹងទូទៅដល់ព្រះតម្រាស់ណាមួយ ដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងលឿនរហ័ស ប៉ុន្តែមកដល់ឥឡូវនេះត្រឡប់ជាមិនដឹង មិនឃើញទីបំផុត ឬ ខ្លឹមសារមូលបរិយាយសូត្រនោះទេឡើយគួរអស្ចារ្យពិត ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ( មានព្រះបញ្ញា) ដែលនរណាៗ ប្រមាណមិនបាន ទ្រង់ ( មានព្រះបញ្ញា

ដែលនរណា ៗ ថ្លឹងមិនបាន ) ដូច្នេះ ហើយបាននាំគ្នាទៅកាន់ទីឧបដ្ឋាក ព្រះពុទ្ធជាម្ចាស់ និង ទៅស្តាប់ព្រះធម៌ដោយគោរព ។

## ភិក្ខុ ៥០០ រូប បានសម្រេចអរហត្តផល

ក៏សម័យនោះ ភិក្ខុទាំងទឡ្បាយអង្គុយប្រជុំគ្នាក្នុងធម្មសភា សន្ទនាដល់រឿងនេះថា គួរអស្ចារ្យណាស់ អានុភាពរបស់ព្រះពុទ្ធជាម្ចាស់ទាំងទឡ្បាយ ព្រាហ្មណ៍ បព្វជិតទាំងនោះស្រវឹងហើយដោយសេចក្តីស្រវឹងក្នុងមានះ នឹងត្រូវធ្វើឱ្យអស់មានះបានដោយមូលបរិយាយទេសនារបស់ព្រះមានព្រះភាគ ។ និងពេលនេះ ភិក្ខុទាំងនោះសន្ទនាគ្នាបានពាក់កណ្តាល មិនទាន់ចប់ ។

លំដាប់នោះ ព្រះមានព្រះភាគចេញពីព្រះគន្ធកុដិ ទៅប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរដែលក្រាលទុកក្នុងធម្មសភា ដោយបាដិហារ្យដ៏សមគួរ ហើយខណៈនោះ បានត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងទឡ្បាយ អ្នកទាំងទឡ្បាយសន្ទនារឿងអ្វីហ្ន៎ ។ ភិក្ខុទាំងនោះ បានទូលប្រាប់សេចក្តីនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ÷

**ម្នាលភិក្ខុទាំងទឡ្បាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ**

**សូម្បីក្នុងកាលមុន តថាគតក៏បានធ្វើភិក្ខុទាំងនេះដែល**

**ដំទេឡើងបូកដោយមានះ ឱ្យអស់មានះហើយ ដូចគ្នា ។**

តពីនោះ ព្រោះកើតរឿងនេះជាហេតុ ព្រះមានព្រះភាគ ទើបទ្រង់នាំអតីតនិទាននេះមកសម្ដែងថា ÷

ភិក្ខុទាំងទឡាយ រឿងធ្លាប់មានមកហើយ ព្រាហ្មណ៍ទិសាបាមោក្ខម្នាក់អាស្រ័យនៅក្នុងក្រុងពារាណសី រៀនចប់ត្រៃវេទ ព្រមទាំងនិឃណ្ឌុសាស្ត្រ និង កេដុភសាស្ត្រ និង ប្រភេទអក្សរសម័យ មានគម្ពីរឥតិហាសៈ ជាទី ៥ ជាអ្នកជំនាញក្នុងគម្ពីរវេយ្យាករណ៍ និង មហាបុរិសលក្ខណៈ ក្នុងគម្ពីរលោកាយតិ ។ ព្រាហ្មណ៍នោះបានបង្រៀនមន្តឱ្យមាណព ៥០០ នាក់ ។ ពួកមាណពដែលជាអ្នកឆ្លាត រមែងរៀនបានច្រើន ចាំបានរហ័ស និង ស្ទាត់ ជំនាញមន្តដែលមាណពទាំងនោះរៀនហើយ មិនវិនាសបាត់បង់ទៅវិញ ទេឡើយ ។ សូម្បីព្រាហ្មណ៍នោះ ក៏មិនបានហួងហែងវិជ្ជា ដូចជាចាក់ទឹក ទៅក្នុងឆ្នាំង ឱ្យមាណពទាំងនោះរៀនសិល្បៈរហូតចប់ ហើយបានពោលនឹងមាណពទាំងនោះដូច្នេះថា សិល្បៈនេះមានត្រឹមប៉ុណ្ណោះ ជាប្រយោជន៍ទាំង

ក្នុងបច្ចុប្បន្ន និង អនាគត ។ មាណពទាំងនោះ ក៏កើតមានះទេឡើងថា អាចារ្យរបស់ពួកយើង រមែងដឹងវត្ថុណា សូម្បីពួកយើងក៏ដឹងវត្ថុនោះ ពេល នេះ សូម្បីពួកយើង ក៏ធ្វើជាអាចារ្យបានដែរ តាំងអំពីពេលនោះមក ក៏ខ្វះ ការគោរព លះបង់វត្តចំពោះអាចារ្យ ។ អាចារ្យជ្រាបហើយ គិតថា យើង នឹងធ្វើការគ្របសង្កត់មានះរបស់មាណពទាំងនោះ ។ ថ្ងៃមួយ លោកអាចារ្យ បានពោលនឹងមាណពទាំងនោះដែលមកកាន់ទីកន្លែងទំនុកបម្រុង សំពះហើយ អង្គុយនឹងពោលថា អ្នកទាំងទឡាយ ខ្ញុំ (អាចារ្យ) នឹងសួរបញ្ហាដល់ពួកអ្នក ( ត្រឹមតែមួយ ខ ) ពួកអ្នកនឹងអាចពោលដោះស្រាយបានយ៉ាងណា ?

មាណពទាំងនោះ ក៏នាំគ្នារួសរាន់ប្រាប់ក្នុងភាពជាអ្នកស្រវឹងក្នុងការ សិក្សាថា សួរចុះ លោកអាចារ្យ , សួរចុះ លោកអាចារ្យ ។ អាចារ្យ ទើបពោលថា ÷

**កាលរមែងទំពាស៊ីសព្វសត្វ ព្រមទាំងខ្លួនវា**

**តែថា សត្វណាទៅ ដែលស៊ីកាល បានដុត**

**កម្មេចតណ្ហា ដែលដុតបំផ្លាញសត្វទៅបាន?**

ហើយពោលតទៅទៀតថា អ្នកទាំងទឡាយ ពួកអ្នកចូរដោះស្រាយបញ្ហានេះចុះ ។

មាណពទាំងនោះ គិតហើយតែមិនដឹង (ពាក្យឆ្លើយ ) ទើបបាននាំគ្នាអង្គុយស្ងៀម ។ អាចារ្យទើបពោលថា ណ្ហើយចុះ អ្នកទាំងទឡាយ ថ្ងៃនេះអ្នកចូរត្រទឡប់ទៅចុះ ថ្ងៃស្អែកសឹមមកដោះស្រាយ ដូច្នេះហើយទើបប្រាប់មាណពទាំងនោះឱ្យត្រទឡប់ទៅ ។ មាណពទាំងទឡាយនោះ (កាលចេញពីអាចារ្យហើយ) ក៏ប្រជុំគ្នា ១០ នាក់ខ្លះ ២០ នាក់ខ្លះ ដើម្បីពិចារណា បញ្ហាក៏នៅតែមិនអាចយល់សេចក្តីខាងដើម មិនអាចយល់សេចក្តីខាងចុងនៃបញ្ហានោះបាន ។ ពួកគេទើបនាំគ្នាមកពោលប្រាប់អាចារ្យថា ពួកខ្ញុំមិនអាចយល់សេចក្តីនៃបញ្ហានេះទេឡីយ ។ ដើម្បីសង្កត់សង្កិនមាណពទាំងនោះអាចារ្យទើបពោលគាថានេះថា ÷

**សីរសៈរបស់មនុស្សជាច្រើន មានសក់ដ៏ក្រាស់**

**ហើយធំតាំងនៅលើ.ក ពួកគេទាំងនេះ នរណា**

**ទៅជាអ្នកមានត្រចៀក ។**

គាថា (នេះ) មានអធិប្បាយថា សីរសះរបស់បុគ្គលចំនួនច្រើនប្រាកដហើយ និង សីរសះទាំងអស់នោះក៏មានសក់ ទាំងអស់ជាសីរសះធំតាំងនៅលើ.ក ប៉ុន្តែថា ដៃឈោងចាប់មិនដល់ ដូចគ្នានឹងផ្លែត្នោត (ដែលដៃឈោងចាប់មិនដល់) ដូច្នោះ សីរសះទាំងនោះ និង សីរសះទាំងនេះមិនមានការផ្សេងគ្នា ។ តែក្នុងទីនេះ អាចារ្យពោលថា **កោចិទេវ កណ្ណវា** ដូច្នេះ សំដៅយកខ្លួនឯង ។ បទថា **កណ្ណវា** ប្រែថា អ្នកមានបញ្ញា ។ ក៏អ្នកណាទៅដែលមិនមានរន្ធត្រចៀក ?

មាណពទាំងនោះ បានស្តាប់គាថាទាំងនោះហើយ អៀនប្រៀន ដាក់ក(អង្គុយ) សំយុងមុខយកម្រាមដៃកេះដី ។ លំដាប់នោះ អាចារ្យឃើញថា មាណពមានការអៀនខ្មាស ទើបពោលថា អ្នកទាំងទឡ្យាយ ពួកអ្នកចូររៀនយកបញ្ហាចុះ ដូច្នេះហើយ បានដោះស្រាយបញ្ហា (ឱ្យមាណពទាំងនោះស្តាប់)។

បទថា **កាល** បានដល់ កាល មានជាអាទិយ៉ាងនេះ គឺ វេលាមុនអាហារខ្លះ វេលាក្រោយអាហារខ្លះ ។ ពាក្យថា **ភូតានិ** នោះ ជាឈ្មោះហៅ **សត្វ** ។ **កាល** មិនបានទំពាស៊ីនូវសាច់ និង ស្បែកជាដើម

របស់សត្វទាំងទឡាយទេ ។ ដែលពិត ក៏ត្រូវឡប់ធ្វើឱ្យអាយុ វណ្ណៈ និង ពលៈ របស់សត្វនោះអស់ទៅ ញុំាញីភាពកំលោះ_ក្រមុំ ធ្វើភាពជាអ្នកមិនមានរោគ ឱ្យវិនាសទៅ ទើបហៅថា ស៊ី គឺ ទំពាស៊ី ។

បទថា **សព្វានេវ សហត្តនា** សេចក្តីថា **កាល** កាលស៊ីយ៉ាង នោះ រមែងមិនវៀរអ្វី ៗ ទេឡើយ រមែងស៊ីទាំងអស់ មិនថា នឹងស៊ីតែសត្វ ទាំងទឡាយនោះ ដែលពិតក៏នៅស៊ីខ្លួនឯងព្រម (ទៀត) ផង (គឺ) វេលា មុនអាហារ (កន្លងទៅ) និង មកជាវេលាក្រោយអាហារ (ទៀត) មិន បាន ក្នុងវេលាក្រោយអាហារជាដើម ក៏មានន័យបែបនេះ ។

បទថា **យោ ច កាលឃសោ ភូតោ** នោះ ជាឈ្មោះរបស់ ព្រះខីណាស្រព ។ ក៏ព្រះខីណាស្រពនោះ ហៅថា អ្នកស៊ីកាល ព្រោះ លោកស៊ីបដិសន្ធិកាលក្នុងភពតទៅ រហូតអស់ ហើយតាំងនៅ ។

បទថា **សភូត បចនី បចិ** សេចក្តីថា តណ្ហានេះណា រមែង ដុតសត្វទាំងទឡាយ ក្នុងអបាយទាំងទឡាយ ព្រះខីណាស្រពនោះ ដុតតណ្ហា នោះ ដោយភ្លើង គឺ ញាណ បានដល់ ធ្វើឱ្យទៅជាផេះ ។ (ក្នុងពាក្យ

ថា **បចនី**) បាលីជា **បជ្ជនី** ក៏មាន ។ មានន័យថា ឱ្យកើត គឺ ឱ្យបង្កើត ។ លំដាប់នោះ មាណពទាំងនោះ ឃើញខ្លឹមសាររបស់បញ្ហាប្រាកដច្បាស់តាមពាក្យដោះស្រាយរបស់អាចារ្យ ដូចបុគ្គលឃើញទីរាបស្មើ និងទីក្រហេងក្រហូង ពេលយប់ដោយពន្លឺប្រទីប ១.០០០ ដួង ទើបគិតថា ពេល នេះពួកយើងនឹងនៅរួមរស់ជាមួយអាចារ្យរហូតអស់ជីវិត ដែលឈ្មោះថាអាចារ្យហើយ គឺ ជាអ្នកដ៏ធំ ក៏ពួកយើងកើតការប្រកាន់ខ្លួនថា បានសិក្សាមកច្រើន ទើបមិនដឹងន័យរបស់គាថា សូម្បីត្រឹមតែ ៤ បាទ កាលកម្ចាត់មានះបានហើយ ( បានត្រទឡប់ ) មកធ្វើវត្តបដិបត្តិដល់អាចារ្យដូចកាលមុនទៀត បានជាអ្នកមានស្មតិជាទីនៅក្នុងខាងមុខ ។ ម្នាលភិក្ខុ ទាំងទឡាយក្នុងសម័យនោះ យើងជាតថាគតបានជាអាចារ្យ ភិក្ខុទាំងនោះ បានជាមាណពសូម្បីក្នុងកាលមុន តថាគតក៏បានធ្វើឱ្យភិក្ខុទាំងនេះ ដែលមានះគ្រាច់ទៅយ៉ាងនេះ ឱ្យអស់មានះដោយប្រការយ៉ាងនេះ ។

ក៏ភិក្ខុទាំងនោះ បានស្ដាប់ជាតកយ៉ាងនេះហើយ គិតថា សូម្បីកាលមុនពួកយើងក៏ត្រូវមានះគ្របសង្កត់ហើយ ទើបកម្ចាត់មានះចេញឱ្យក្រៃលែងបាន

ទៀត ជាអ្នកមានមុខឆ្ពោះទៅរក (បដិបត្តិ) កម្មដ្ឋាន ដែលជាឧបការៈ ដល់ខ្លួន ។ តមក គ្រាមួយ ព្រះមានព្រះភាគស្តេចចារិកទៅក្នុងជនបទ ដល់ ក្រុងវេសាលី ហើយប្រថាប់នៅគោតមកចេតិយ៍ ទ្រង់ជ្រាបថា ភិក្ខុ ៥០០ រូបនោះ មានញាណចាស់ក្លាហើយ ទើបត្រាស់គោតមកសូត្រនេះថា ម្នាល ភិក្ខុទាំងទឡ្បាយ តថាគត រមែងសម្តែងធម៌ដើម្បីការដឹងដ៏ក្រៃលែង មិនមែន សម្តែងធម៌ដើម្បីការមិនដឹងដ៏ក្រៃលែងទេ តថាគតសម្តែងធម៌មានហេតុ ។ល។ ម្នាលភិក្ខុទាំងទឡ្បាយ តថាគតសម្តែងធម៌មានបាដិហារ្យ មិនមែនសម្តែងធម៌ មិនមានបាដិហារ្យ ម្នាលភិក្ខុទាំងទឡ្បាយ កាលតថាគតសម្តែងធម៌ដើម្បីសេចក្តី ដឹងដ៏ក្រៃលែង ។ល។ មិនមែនសម្តែងធម៌មិនមានបាដិហារ្យ ឱវាទទើបជា វត្ថុដែលគួរធ្វើតាម អនុសាសនីជាវត្ថុដែលគួរធ្វើតាម ម្នាលភិក្ខុទាំងទឡ្បាយ ក៏អ្នកទាំងទឡ្បាយកុំត្រេកអរ កុំរីករាយ កុំសោមនស្សថា ព្រះមានព្រះភាគត្រាស់ ដឹងយ៉ាងត្រឹមត្រូវដោយព្រះអង្គឯង ព្រះធម៌ដែលព្រះមានព្រះភាគ ត្រាស់ទុក ល្អហើយ ព្រះសង្ឃ ( សាវក របស់ព្រះមានព្រះភាគ ) បដិបត្តិល្អហើយ ។

ព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះ ក៏កាលដែលព្រះមានព្រះភាគ

ទ្រង់ត្រាស់វេយ្យាករណ៍នេះហើយ ម៉ឺនលោកធាតុ ក៏បានញាប់ញ័រ ។

ភិក្ខុ ៥០០ រូបនោះ បានស្ដាប់ព្រះសូត្រនេះហើយ បានសម្រេចជាព្រះអរហន្ត ព្រមដោយបដិសម្ភិទាក្នុងវេលាចប់ (ព្រះសូត្រ ) នោះឯង ។ ទេសនានេះ បានចប់ក្នុងទីនោះដោយអាការនេះឯង ។

**« ចប់ អដ្ឋកថាមូលបរិយាយសូត្រ »**

# *សព្វាសវសំវរសូត្រ ទី ២*

## *អធិប្បាយសេចក្តីក្នុងព្រះត្រៃបិដកលេខ ២០*

### អធិប្បាយពាក្យថា សាវត្ថី

សព្វាសវសំវរសូត្រមានពាក្យផ្តើមថា ខ្ញុំម្ចាស់បានស្តាប់ហើយយ៉ាងនេះ ។ល។ ក្រុងសាវត្ថី ។

ក្នុងសព្វាសវសំវរសូត្រនោះ មានអដ្ឋកថាអធិប្បាយតាមលំដាប់បទដូចតទៅនេះ ។ អ្នកអក្សរសាស្ត្រពិចារណាគ្នាទុកយ៉ាងនេះថា ពាក្យថា **សាវត្ថី** គឺ នគរជាទីនៅរបស់ឥសី ឈ្មោះ **សវត្ថ** ដូចពាក្យថា **កាកន្ទី មាកន្ទី** ដូច្នោះ ។ ចំណែកព្រះអដ្ឋកថាចារ្យទាំងឡាយពោលទុកថា វត្ថុគ្រឿងឧបភោគ និងបរិភោគ របស់មនុស្សគ្រប់យ៉ាង មាននៅក្នុងក្រុងនេះ ដូច្នោះ ក្រុងនេះទើបឈ្មោះថា **សាវត្ថី** ។ ក្នុងកាលយកពាក្យថា « **សត្ថ** » មករួមទុកផង ទើបឈ្មោះថា សាវត្ថី ព្រោះអាស្រ័យហេតុថា កាលត្រូវគេសួរថា មានរបស់អ្វីនៅខ្លះ ក៏ឆ្លើយថា មាន គ្រប់យ៉ាង ។

គ្រឿងឧបភោគ. បរិភោគគ្រប់យ៉ាង មករួមគ្នានៅក្នុងក្រុងសាវត្ថីគ្រប់ពេល ដូច្នោះ លោកសំដៅយកការសំបូរណ៍ដោយគ្រឿងឧបភោគ. បរិភោគគ្រប់យ៉ាង ទើបហៅ ( ក្រុងនោះ ) ថា សាវត្ថី ។ នេះជាក្រុងរបស់អ្នកដែនកោសល គួរជាទីរីករាយ គួរជាទីមនោរម្យ គួរត្រេកត្រអាលចម្រើនចិត្ត អឹងកងទៅ ដោយសំទេឡង ១០ ប្រការ ជាក្រុងសំបូរទៅដោយភោគផលធម្មជាតិ ។ ជាក្រុងដល់នូវការចម្រើនយ៉ាងសំបូរ មាំមួន ធំទូលាយ គួរជាទីរីករាយ និងឧត្តម

សំបូរដូចទេវបុរីឈ្មោះ អាលកមន្ទា ។ ក្នុងក្រុងសាវត្ថីនោះ ។

ក្នុងបទថា ជេតវនេ អធិប្បាយថា ព្រះរាជកុមារទ្រង់ព្រះនាមថា « ជេត » ព្រោះទ្រង់ច្បាំងឈ្នះសត្រូវរបស់ព្រះអង្គ ឬ ព្រោះប្រសូតិក្នុងវេលាដែលព្រះ_ជនកទ្រង់មានជ័យជម្នះលើសឹកសត្រូវរបស់ព្រះអង្គ ម្យ៉ាងទៀត ទ្រង់ព្រះនាមថា « ជេត » ព្រះនាមយ៉ាងនេះ ព្រោះព្រះរាជមាតាបិតាទ្រង់តាំងឱ្យ ដើម្បីភាពជាសិរីមង្គល ។ ឧទ្យានរបស់ព្រះរាជកុមារព្រះនាមថា «ជេត » ឈ្មោះថា «ជេតវន » ។ ព្រោះព្រះឧទ្យានជេតវ័ននោះ ដែលព្រះរាជកុមារព្រះនាមថា « ជេត » នោះ ទ្រង់ សាង និង ថែរក្សាឱ្យចម្រើនលូតលាស់ល្អ ទាំងព្រះអង្គក៏ទ្រង់ជាម្ចាស់ព្រះឧទ្យាន នេះផង ដូច្នោះទើបហៅថា ជេតវ័ន ។ ក្នុងព្រះវិហារជេតវ័ននោះ ។

ក្នុងបទថា អនាថបិណ្ឌិកស្ស អារាមេ នេះ មានអធិប្បាយថា គហបតីនោះឈ្មោះថា « សុទត្ត » ជាឈ្មោះដែលមាតាបិតាដាក់ឱ្យ តែត្រឡប់ជាមានឈ្មោះថា អនាថបិណ្ឌិក ដោយហេតុដែលបានឱ្យអាហារដល់មនុស្សអនាថាទាំងឡាយជាប្រចាំ ព្រោះជាអ្នកស្តុកស្តម្ភដោយសម្បត្តិគ្រប់យ៉ាង និង ព្រោះប្រាសចាកសេចក្តីកំណាញ់ ព្រមទាំងបរិបូរដោយគុណធម៌ មានសេចក្តីករុណាជាដើម ។ សត្វទាំងឡាយ ដោយចំពោះបព្វជិត រមែងត្រេកអរក្នុងឧទ្យាននេះ ព្រោះដូច្នោះ ទើបឈ្មោះថា អារាម ។ អធិប្បាយថា សត្វទាំងឡាយមកពីទីផ្សេង ៗ គ្នា រមែងត្រេកអរ រីករាយ នៅយ៉ាងសប្បាយ ព្រោះឧទ្យាននោះស្រស់ ស្អាតទៅដោយដើមឈើទាំងឡាយជាដើម សំបូរទៅដោយអង្គប្រកបនៃសេនា_

សនៈ ៥ ប្រការ មានមិនឆ្ងាយមិនជិត ( គោចរគ្រាម ) ពេកទេ ។ ប្រការមួយទៀត ឈ្មោះថា អារាម ព្រោះទាក់ទាញសត្វអ្នកទៅដល់ស្ថានទីនោះ ទុកខាងក្នុងបរិវេណរបស់ខ្លួននោះឯង ហើយឱ្យរីករាយទៅដោយសម្បត្តិ មានប្រការដូចពោលហើយ ។ ការពិត អារាមនោះ អនាថបិណ្ឌិកគហបតី បានថ្វាយសង្ឃមានព្រះពុទ្ធជាប្រមុខ ដោយការបរិច្ចាគទ្រព្យ ដល់ ៥៤ កោដិ គឺ បរិច្ចាគទិញដីពីព្រះហស្តរបស់ព្រះរាជកុមារទ្រង់ព្រះនាមថា « ជេត » ដោយការយកប្រាក់ ១៨ កោដិ ក្រាល ( ពេញបរិវេណផ្ទៃដី ) បរិច្ចាគតម្លៃកសាងសេនាសនៈផ្សេង ៗ ១៨ កោដិ បរិច្ចាគតម្លៃធ្វើបុណ្យឆ្លងព្រះវិហារ ១៨ កោដិទៀត ដូច្នោះទើបបានឈ្មោះថា អារាមរបស់អនាថបិណ្ឌិក ។ ក្នុងអារាមរបស់អនាថបិណ្ឌិកគហបតី នោះ ។ ពាក្យថា ជេតវនេ ក្នុងពាក្យថា ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ នោះជាពាក្យបញ្ជាក់ដល់ម្ចាស់នៃអ្នកជាដំបូង ។ ពាក្យថា អនាថបិណ្ឌិកស្ស អារាមេជាពាក្យបញ្ជាក់ដល់ម្ចាស់នៃអ្នកជាខាងក្រោយ ។

សួរថា នឹងមានប្រយោជន៍អ្វី ក្នុងការបញ្ជាក់ដល់ម្ចាស់ទាំងពីរនោះ ។

ឆ្លើយថា មានប្រយោជន៍ គឺ នឹងធ្វើឱ្យជាគម្រូរបស់អ្នកត្រូវការបុណ្យ ។

ពិតណាស់ ក្នុងសេចក្តីនោះ ព្រះអានន្ទកាលនឹងសម្តែងថា អ្នកត្រូវការបុណ្យទាំងឡាយ រមែងធ្វើបុណ្យព្រោះកិត្តិស័ព្ទរបស់អ្នកទាំងពីរនោះថា ព្រះរាជកុមារព្រះនាមថា ជេត នោះ ទ្រង់បរិច្ចាគទ្រព្យ ១៨ កោដិ ដែលព្រះអង្គបានដោយការលក់ទីដីក្នុងការសាងសង់ខ្លោងទ្វារ និង ប្រាសាទ និង ទ្រង់បរិច្ចាគ

ដើមឈើដែលមានតម្លៃច្រើនកោដិ , ( ចំណែក ) អនាថបិណ្ឌិកគហបតីបាន បរិច្ចាគទ្រព្យ ៥៤ កោដិ ដូច្នេះហើយ ក៏បបួលជនអ្នកត្រូវការបុណ្យពួកដទៃឱ្យ កាន់យកជនទាំងពីរនោះជាឧទាហរណ៍ ។

## អធិប្បាយពាក្យថា អាសវ

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ព្រះសូត្រ នេះថា សព្វាសវសំវរបរិយាយំ វោ ភិក្ខវេ ដូច្នេះ ?

ឆ្លើយថា ដើម្បីទ្រង់សម្តែងដល់ខបដិបត្តិដើម្បីការអស់អាសវៈ ផ្តើមតាំង ពីការជម្រះឧបក្កិលេសដល់ភិក្ខុទាំងនោះ ។

បណ្តាបទទាំងនោះ បទថា សព្វាសវសំវរបរិយាយំ សេចក្តីថា ជា ហេតុសង្រួម គឺថា ជាហេតុឱ្យសង្រួមរាំងអាសវៈគ្រប់យ៉ាង ។ អធិប្បាយថា ជាហេតុឱ្យអាសវៈទាំងនេះដែលភិក្ខុរាំងបិទបាំងហើយ រមែងដល់ការអស់ទៅ ពោលគឺ ការរលត់ទៅដោយមិនមានការកើតឡើង ( ទៀត ) គឺ ដែលភិក្ខុរមែង លះបាន បានដល់ រមែងមិនប្រព្រឹត្តទៅ ។ ក្នុងបទថា អាសវានំ នោះ ដែល ឈ្មោះថា អាសវ ព្រោះអត្ថថា ហូរទៅ លោកអធិប្បាយថា អាសវៈទាំងនោះ រមែងហូរទៅ គឺ ហូរចេញតាមចក្ខុខ្លះ ។ល។ តាមទ្វារចិត្តខ្លះ ដូច្នេះ ។ ម្យ៉ាងទៀត អាសវៈទាំងនោះ កាលពោលដោយធម៌ រមែងហូរទៅរហូតដល់គោត្រភូ កាល ពោលដោយឱកាសលោក រមែងហូរទៅរហូតដល់ភវគ្គព្រហ្ម ។ ព្រោះហេតុនោះ ទើបឈ្មោះថា អាសវ អធិប្បាយថា អាសវៈទាំងនោះធ្វើធម៌ទាំងនោះ និង

ឱកាសនោះ ទុកខាងក្នុង ( អំណាច ) ហើយប្រព្រឹត្តទៅ ពិតណាស់ អា អក្សរនេះ មានសេចក្តីថា ធ្វើទុកក្នុងខាងក្នុង ។ ដែលឈ្មោះថា អាសវ ព្រោះដូចជារបស់ត្រាំទុកយូរ មានទឹកស្រវឹងជាដើម ដោយសេចក្តីថា ត្រាំទុកយូរដូច្នេះខ្លះ ។ ការពិត ក្នុងផ្លូវលោក ទឹកស្រវឹងដែលត្រាំទុកយូរ យើងក៏ហៅថា អាសវ ដូច្នេះ ។ ក៏បើទឹកស្រវឹងជាដើមហៅថា អាសវ បាន ព្រោះសេចក្តីថា ត្រាំទុកយូរ កិលេសទាំងនេះ ក៏គួរនឹងដូច្នោះដូចគ្នា ។ សមដូចដែលត្រាស់ទុកថា ភិក្ខុទាំងទឡ្សាយ ខាងដើមនៃអវិជ្ជាមិនប្រាកដ ( គឺ មិនប្រាកដថា ) ក្នុងកាលមុនពីនេះ មិនបានមានអវិជ្ជា ដូច្នេះ ។ ម្យ៉ាងទៀត ដែលឈ្មោះថា អាសវ ព្រោះអត្ថថា ហូរទៅ គឺ ហូរចេញទៅកាន់សង្សារទុក្ខតទៅ ដូច្នេះខ្លះ ។ ក៏ពាក្យអធិប្បាយ ពាក្យដំបូង ១ ក្នុងរូបវិគ្រោះទាំងនេះ រមែងប្រើក្នុងទីដែលកិលេសទាំងឡាយមក ដោយឈ្មោះថា អាសវ ( ចំណែក ) ពាក្យអធិប្បាយក្រោយ ប្រើក្នុងកម្មក៏បាន ។ ក៏មិនមែនត្រឹមតែកម្មកិលេសម្យ៉ាងប៉ុណ្ណោះទេ ដែលជាអាសវៈ ដោយពិត សូម្បីឧបទ្ទវនានប្បការ ក៏ឈ្មោះថា អាសវ បាន ( ដូចគ្នា ) ការពិត ក្នុងព្រះសូត្រទាំងឡាយ កិលេសទាំងឡាយដែលជាមូលហេតុឱ្យបង្កការជម្លោះវិវាទ ក៏មកដោយឈ្មោះថា អាសវ ក្នុងពាក្យនេះថា ចុន្ទៈ យើងមិនសម្តែងធម៌ដើម្បីសំវរៈរវាំងពួកអាសវៈ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ ប៉ុណ្ណោះទេ ដូច្នេះ ។ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និង ពួកអកុសលធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា អាសវ ក្នុងពាក្យនេះថា ÷

អាសវៈទាំងឡាយរបស់យើង ដែលជាហេតុឱ្យចូលដល់
ភាពជាទេវតា ឬគន្ធព្វ ដែលហោះហើរបាន និងជាហេតុ
ឱ្យយើងទៅកាន់ភាពជាយក្ខ ភាពជាមនុស្ស និង គប្បី
ទៅកាន់ភាពជាអណ្ឌជៈកំណើត អស់ទៅហើយ ដែល
យើងកម្ចាត់ហើយ ធ្វើឱ្យវិនាសហើយ ដូច្នេះ ។

ការចូលទៅប្រទូសរ៉ាយអ្នកដទៃ ការក្តៅក្រហាយ ការសម្លាប់ និង ការចងពៀរជាដើម និង ឧបទ្ទវទានប្បការដែលជាហេតុឱ្យសត្វសោយទុក្ខក្នុងអបាយ ក៏ឈ្មោះថា អាសវ ( ដូច ) ក្នុងប្រយោគនេះថា ( តថាគតនឹងសម្តែងធម៌ ) ដើម្បីសង្រួមរវាំងអាសវៈដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ ( និង ) ដើម្បីកម្ចាត់អាសវៈដែលប្រព្រឹត្តទៅក្នុងសម្បរាយិកភព ដូច្នេះ ។ ក៏ក្នុងទីណា អាសវៈទាំងនេះមកដោយប្រការណា ក្នុងទីនោះក៏គប្បីជ្រាបដោយប្រការនោះ ។ ក៏ក្នុងព្រះវិន័យ អាសវៈទាំងឡាយនេះមានមកហើយ ២ យ៉ាង ដូចប្រយោគថា ( តថាគត នឹងសម្តែងធម៌ ) ដើម្បីការពារអាសវៈដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ ដើម្បីការពាររារាំងអាសវៈដែលប្រព្រឹត្តទៅក្នុងសម្បរាយិកភព ដូច្នោះ ។

ក្នុងសឡាយតនៈវគ្គ មានមកហើយ ៣ យ៉ាង ( ដូចក្នុងប្រយោគថា ) អ្នកមានអាយុ អាសវៈទាំងនេះ មាន ៣ យ៉ាង គឺ កាមាសវ ភវាសវ អវិជ្ជាសវ ដូច្នេះ ។ ក្នុងសុត្តន្តបិដក កន្លែងដទៃ និង ព្រះអភិធម្មបិដក អាសវៈ ៣ ពួកនោះឯង រួមជាមួយទិដ្ឋាសវៈចូលផង មានមកហើយ ៤ យ៉ាង ពោលដោយ

បរិយាយ ដែលចែកអាសវៈទាំងឡាយមានមក ៥ យ៉ាង គឺ ៖

ភិក្ខុទាំងឡាយ អាសវៈដែលជាហេតុញ៉ាំងសត្វទាំងឡាយឱ្យចូលកាន់នរកក៏មាន អាសវៈដែលជាហេតុឱ្យសត្វទៅកាន់បេតវិស័យក៏មាន អាសវៈដែលជាហេតុឱ្យទៅកាន់មនុស្សលោកក៏មាន និងអាសវៈ ដែលជាហេតុញ៉ាំងសត្វឱ្យទៅកាន់ទេវលោកក៏មាន ។

ក្នុងឆក្កនិបាត អាសវៈមានមក ៦ យ៉ាង ដោយន័យជាដើមថា ភិក្ខុទាំង-ឡាយ អាសវៈដែលត្រូវលះដោយសំវរៈនៅមានចំណែកក្នុងសូត្រនោះ អាសវៈ ៦ ពួកនោះឯង ព្រមដោយអាសវៈដែលត្រូវលះដោយទស្សនៈ មានមក ( រួម ) ជា ៧ អត្ថវចនៈ និងប្រភេទ ( នៃអាសវៈ ) ក្នុងបទថា អាសវ មានត្រឹមតែប៉ុណ្ណេះសិន ។

## អធិប្បាយសំវរ

ចំណែកក្នុងបទថា សំវរ មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា សំវរ ព្រោះអត្ថថា សង្រួម អធិប្បាយថា បិទ គឺ ហាមបានដល់ មិនឱ្យប្រព្រឹត្តទៅ ។ សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា « ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុអ្នកត្រូវការសម្រាកពេល ថ្ងៃត្រូវបិទទ្វារមុនហើយ ទើបសម្រាក ដូច្នេះ ។ ព្រះអាចារ្យពោល សំវរ ដោយអត្ថថា បិទ ក្នុងពាក្យជាដើមថា ៖

តថាគតពោល « សតិ » ថា ជាគ្រឿងហាមក្រសែទាំងនោះ
ក្រសែទាំងនោះបុគ្គល រមែងបិទបានដោយបញ្ញា ដូច្នេះ ។

សំវរៈនោះមាន ៥ យ៉ាងគឺ សីលសំវរ , សតិសំវរ , ញាណសំវរ , ខន្តិសំវរ , វីរិយសំវរ ។ បណ្តាសំវរៈទាំងនោះ សំវរៈដែលត្រាស់ទុកថា ភិក្ខុប្រកបដោយបាតិមោក្ខសំវរៈនេះ នេះឈ្មោះថា សីលសំវរ ។ ការពិតបាតិមោក្ខសីល លោកពោលថា សំវរៈក្នុងទីនេះ ។ សំវរៈ ក្នុងពាក្យជាដើមថា ភិក្ខុរមែងដល់ការសង្រួមក្នុងចក្ខុន្ទ្រិយ៍ ឈ្មោះថា « សតិសំវរ » ។ ក៏សតិលោកពោលថា សំវរ ក្នុងទីនេះ ។

សំវរៈដែលត្រាស់ទុកថា តថាគតពោលញាណថា ជាគ្រឿងបិទក្រសែទាំងនោះ បុគ្គលរមែងបិទបាំងបានដោយបញ្ញា នេះឈ្មោះថា ញាណសំវរ ។ ក៏ក្នុងទីនេះលោកពោលញាណថា សំវរ ដោយអត្ថថា បិទទុកបាន ដោយបទថា បិថីយរេ ។ ខន្តិសំវរៈ និង វីរិយសំវរៈ មកក្នុងសូត្រនេះដោយន័យជាដើមថា ភិក្ខុជាអ្នកអត់ធន់ចំពោះភាពត្រជាក់ ។ល។ រមែងមិនព្រមឱ្យវិតក្កកើតឡើងគ្របសង្កត់បាន ដូច្នេះ ។ ក៏គប្បីជ្រាបថា ខន្តី និង វីរិយៈ ឈ្មោះថា សំវរៈ ព្រោះលោកសង្គ្រោះដោយឧទ្ទេសនេះថា សព្វាសវសំវរបរិយាយំ នេះ ។

ម្យ៉ាងទៀត សំវរ សូម្បីទាំង ៥ យ៉ាងនេះ ក៏មកក្នុងសូត្រនេះ ដូចគ្នា ។ បណ្តាសំវរៈទាំង ៥ យ៉ាងនោះ ខន្តិសំវរៈ និង វីរិយសំវរៈ លោកពោលទុកមុនហើយ នោះឯង ។ ក៏សំវរៈដែលត្រាស់ទុកថា ភិក្ខុនោះពិចារណាទីដែលមិនមែន

អាសនៈនោះ និង អគោចរនោះដោយឧបាយហើយ នេះឈ្មោះថា សីលសំវរ ក្នុងទីនេះ ។ សំវរៈដែលត្រាស់ទុកថា ភិក្ខុពិចារណាដោយប្រពៃហើយ សង្រួមរវាំងចក្ខុន្ទ្រីយ៍ដូច្នេះ ឈ្មោះថា សតិសំវរ ។ ការពិចារណាដោយញាណក្នុងធម៌ទាំងពួង ឈ្មោះថា « ញាណសំវរ » ។ ចំណែកការឃើញ ការសេព ការចម្រើន ក៏ឈ្មោះថា ញាណសំវរ ដោយស័ព្ទដែលលោកមិនបានកាន់យក ។ ដែលឈ្មោះថា បរិយាយ ព្រោះជាហេតុគ្រឿងកំណត់នៃធម៌ទាំងឡាយ អធិ_ប្បាយថា ធម៌ទាំងឡាយរមែងដល់ការកើតឡើង ឬ រលត់ទៅ ។ ពាក្យណាដែលគួរពោលក្នុងពាក្យនេះថា សព្វាសំវរបរិយាយំ ពាក្យនោះលោកពោលអធិប្បាយទុក ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណោះ ។

## អធិប្បាយ ញាណទស្សន

ឥឡូវនេះគប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា ជានតោ អហំ ជាដើមដូចតទៅនេះ ។ បទថា ជានតោ គឺ ដឹង ។ បទថា បស្សតោ គឺ ឃើញ ។ បទសូម្បីទាំងពីរនេះ មានសេចក្តីដូចគ្នា ព្យញ្ជនៈប៉ុណ្ណោះដែលផ្សេងគ្នា ។ កាលបើដូច្នោះ ព្រះមានព្រះភាគជាម្ចាស់សម្តែងដល់បុគ្គល ដោយសំដៅដល់លក្ខណៈរបស់ញាណ ដោយបទថា ជានតោ ។ ការពិត ញាណ មានការដឹង ជាលក្ខណៈ ។ ទ្រង់សម្តែងបុគ្គលដោយសំដៅដល់អំណាចរបស់ញាណ ដោយ បទថា បស្សតោ ។ ការពិត ញាណមានអំណាចក្នុងការឃើញ ។ បុគ្គលអ្នកដល់ព្រមដោយញាណ

រមែងឃើញធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បើកផ្ទារទុក

ដោយញាណនោះឯង ប្រៀបដូចមនុស្សភ្នែកល្អមើលឃើញរូបដោយចក្ខុ ដូច្នោះ ។ ម្យ៉ាងទៀត ដើម្បីឱ្យយោនិសោមនសិការកើតឡើង អយោនិសោមនសិការនឹងមិនកើតឡើងដល់អ្នកឃើញ ដូចនឹងមិនកើតឡើងដល់អ្នកដឹង ដូច្នោះ ខ្លឹមសារក្នុងពាក្យទាំងពីរនេះ មានត្រឹមប៉ុណ្ណោះ ។ ចំណែកអាចារ្យពួកខ្លះពោលទុកច្រើនន័យ ។ សេចក្ដីទាំងនោះមិនសមគួរក្នុងអត្ថនេះ ។

បទថា អាសវានំ ខយំ សេចក្ដីថា ការលះបង់អាសវៈ គឺ ការកើតការអស់ទៅមិនមានសេសសល់ បានដល់ អាការ គឺ ការអស់ទៅ សេចក្ដីថា គឺការមិនមាននៃអាសវៈទាំងឡាយ ។ ខយ ស័ព្ទនេះឯង មានសេចក្ដីថា អស់អាសវៈទាំងក្នុងសូត្រនេះ និង ទាំងក្នុងប្រយោគជាដើមថា អាសវានំ ខយា អនាសវញ្ចេតោ វិមុត្តិំ ។ ចំណែកក្នុងសូត្រដទៃ សូម្បីមគ្គ ផល និព្វាន លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈ ។ ពិតយ៉ាងនោះ មគ្គ លោកហៅថា ធម៌ជាទីអស់អាសវៈ ( ដូច ) ក្នុងប្រយោគជាដើមថា ÷

« ព្រោះការអស់ទៅនៃអាសវធម៌របស់ព្រះសេក្ខបុគ្គល អ្នកកំពុងសិក្សា អ្នកដើរតាមផ្លូវត្រង់ ( គឺ មគ្គមានអង្គ ៨ ) ញាណ ( សម្មាទិដ្ឋិ ) រមែងកើតមុន តពីនោះ អរហត្តផលទើបមានក្នុងលំដាប់តទៅដូច្នេះ » ។

ផល លោកហៅថា ធម៌ជាទីអស់អាសវៈ ( ដូច ) ក្នុងប្រយោគជាដើមថា បុគ្គលជាសមណៈបាន ព្រោះការអស់ទៅនៃអាសវៈ ។

និព្វាន លោកពោលថា ធម៌ជាទីអស់ទៅនៃអាសវៈ ( ដូចមាន ) ក្នុង

ប្រយោគជាដើមថា ៖

អាសវៈទាំងឡាយ រមែងចម្រើនឡើងដល់បុគ្គលអ្នកតាមមើល
ទោសរបស់អ្នកដទៃ អ្នកមានប្រក្រតីសម្លឹងរំពៃទោសជានិច្ចនោះ
គេរមែងនៅឆ្ងាយអំពីធម៌ជាទីអស់ទៅនៃអាសវៈ ដូច្នេះ ។

បទថា នោ អជានតោ ន អបស្សតោ សេចក្តីថា ក៏អ្នកណាមិនដឹង មិនឃើញ តថាគតមិនពោលការអស់ទៅនៃអាសវៈរបស់បុគ្គលអ្នកមិនដឹង មិនឃើញទេ ។ ជនឯណា ពោលដល់សេចក្តីបរិសុទ្ធិដោយសំវរៈជាដើម សូម្បីរបស់បុគ្គលអ្នកមិនដឹង មិនឃើញ ជនទាំងនោះជាការដែលលោកជំទាស់ដោយបទថា នោ ជានតោ នោ បស្សតោ នេះ ។ម្យ៉ាងទៀត ដោយពីរបទដំបូង ( ជានតោ បស្សតោ ) ជាការដែលព្រះមានព្រះភាគបានត្រាស់ឧបាយទុក ហើយដោយពីរបទក្រោយនេះ ( នោ អជានតោ អបស្សតោ ) ជាការដែលព្រះអង្គបានត្រាស់ការបដិសេធន៍ឧបាយហើយ ព្រោះដូច្នោះ ក្នុងទីនេះញាណ ជាការដែលព្រះមានព្រះភាគទ្រង់សម្តែងថា ធម៌ជាគ្រឿងបិទបាំងនូវអាសវៈទាំងឡាយដោយសង្ខេប ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់មានព្រះបំណងនឹងសម្តែងធម៌ កាលភិក្ខុដឹង ទើបមានការអស់ទៅនៃអាសវៈទាំងឡាយ ទើបទ្រង់ផ្តើមបុច្ឆាថា កិញ្ចិ ភិក្ខវេ ជានតោ ដូច្នេះ ។ ក្នុងបទថា កិញ្ចិ ភិក្ខវេ ជានតោ នោះការដឹងមានច្រើនយ៉ាង ការពិតភិក្ខុរូបខ្លះ ដែលមានជាតិជាអ្នកឆ្លាត រមែងដឹង

វិធីធ្វើក្លស់ ភិក្ខុរូបខ្លះរមែងដឹងវិធីធ្វើចីវរជាដើមណាមួយ កាលភិក្ខុនោះតាំងនៅក្នុងការបដិបត្តិធ្វើកម្មដូច្នេះ ការដឹងដូច្នោះ មិនគួរនឹងពោលថា មិនជាបទដ្ឋានរបស់មគ្គ និង ផលទេ ។ ចំណែកភិក្ខុណាបួសក្នុងសាសនាហើយ ចេះវិធីធ្វើវេជ្ជកម្ម ជាដើម កាលភិក្ខុនោះចេះយ៉ាងនេះ អាសវៈធម៌ទាំងឡាយ រមែងចម្រើនឡើងពិត ។ ព្រោះដូច្នោះ កាលភិក្ខុចេះដឹងឃើញធម៌ណា ការអស់អាសវៈ ទើបកើតមានបាន កាលនឹងទ្រង់សម្តែងធម៌នោះឯង ព្រះមានព្រះភាគទើបត្រាស់ថា យោនិសោ ច មនសិការំ អយោនិសោ ច មនសិរការំ ដូច្នេះ ។

យោនិសោមនសិការ និង អយោនិសោមនសិការ ទាំងពីរយ៉ាងនោះ ដែលឈ្មោះថា យោនិសោមនសិការ បានដល់ ការធ្វើទុកក្នុងចិត្តដោយត្រូវទំនង ការធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវ ការនឹកគិត ការបង្អោននឹក ការចងចិត្ត ការដាក់ចិត្ត ការធ្វើទុកក្នុងចិត្ត នូវចិត្តក្នុងអនិច្ចលក្ខណៈជាដើម ដោយន័យជា ដើមថា មិនទៀង ឬដោយសច្ចានុលោមិកញ្ញាណ នេះហៅថា យោនិសោម_នសិការ , ដែលឈ្មោះថា អយោនិសោមនសិការ បានដល់ ការធ្វើទុកក្នុងចិត្តដោយខុសទំនង បានដល់ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវ គឺ ការធ្វើទុកក្នុងចិត្តដោយមិនប្រពៃ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវក្នុងរបស់ដែលមិនទៀងថាទៀង ក្នុងរបស់ដែលជាទុក្ខ ថាសុខ ក្នុងរបស់ដែលមិនមែនជាអត្តា ថាជាអត្តា ឬ ការនឹកគិត ការបង្អោនចិត្ត ការចងចិត្ត ការដាក់ចិត្ត ការធ្វើទុកក្នុងចិត្តនូវចិត្តដោយការផ្ទុយអំពីសច្ចៈ នេះហៅថា អយោនិសោមនសិការ ការអស់ទៅនៃ

អាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង ដើម្បីញ៉ាំងយោនិសោមនសិការឱ្យកើតឡើង និង ដល់ភិក្ខុអ្នកឃើញ ដោយប្រការដែលអយោនិសោមនសិការនឹងមិនកើតឡើង ដូចដែលពណ៌នាមកនេះ ។

ឥឡូវនេះ កាលនឹងទ្រង់សម្តែង ការបញ្ឈប់នៃសេចក្តីនេះ ព្រះមាន-ព្រះភាគទើបត្រាស់ថា អយោនិសោ ភិក្ខវេ ។ បេ ។ បហីយន្តិ ។

សួរថា ដោយពាក្យថា អយោនិសោ ភិក្ខវេ ។បេ។ បហីយន្តិ នោះលោកពោលអធិប្បាយទុក ដូចម្តេច ?

ឆ្លើយថា លោកអធិប្បាយទុកថា ព្រោះអាសវៈទាំងឡាយ រមែងកើតឡើងដល់ភិក្ខុអ្នកធ្វើទុកក្នុងចិត្តដោយមិនត្រូវទំនង កាលភិក្ខុធ្វើទុកក្នុងចិត្តដោយឧបាយប្រពៃ លោករមែងលះអាសវៈទាំងឡាយបាន ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ការអស់អាសវៈទាំងឡាយ រមែងមានដល់ភិក្ខុអ្នកដឹង ដើម្បីញ៉ាំងយោនិសោមនសិការឱ្យកើតឡើង និង ដល់ភិក្ខុអ្នកឃើញដោយប្រការដែលអយោនិសោមនសិការនឹងមិនកើតឡើង ដូចដែលពណ៌នាមកនេះ ។ ក្នុងសេចក្តីនេះ មានការពិចារណាដោយសង្ខេបត្រឹមប៉ុណ្ណេះសិន ។ ចំណែកសេចក្តីពិស្តារមានដូចតទៅនេះ ។ ព្រះសូត្រទាំងអស់ខាងមុខ មានការទាក់ទងគ្នានឹងពីរបទនេះ គឺ យោនិសោ អយោនិសោ សិន ។ ការពិត ព្រះសូត្រទាំងអស់ខាងមុខ លោកពោលទុកដោយអំណាចវដ្តៈ និង វិវដ្តៈ ។ ក៏វដ្តៈមានការមិនធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនងជាមូល ។ គឺ ដូចម្តេច ?

អធិប្បាយថា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង កាលដែលចម្រើន ឡើង រមែងឱ្យធម៌ ២ យ៉ាង គឺ អវិជ្ជា និង ភវតណ្ហាបរិបូណ៌ ។ ក៏កាល អវិជ្ជា សង្ខារទាំងឡាយកើតឡើង ព្រោះមានអវិជ្ជាជាបច្ច័យ ។ល។ កងទុក្ខទើប មានការកើតឡើង ។ កាលតណ្ហា ឧបាទានកើតមាន ព្រោះមានតណ្ហាជាបច្ច័យ ។ល។ កងទុក្ខទើបមានការកើតឡើង ។ ដូច្នោះបុគ្គលអ្នកច្រើនដោយការមិនធ្វើ ទុកក្នុងចិត្តដោយឧបាយត្រូវទំនងយ៉ាងនេះ រមែងវិលវល់កើតស្លាប់នៅក្នុងភព , កំណើត , គតិ , ឋិតិ , និងសត្តាវាសរឿយៗ ប្រៀបដូចទូកដែលត្រូវខ្យល់ផាត់ ធ្វើឱ្យឃ្លោង និង ប្រៀបដូចហ្វូងគោ ដែលធ្លាក់ចុះទៅក្នុងស្ទឹងហូរក្តួច និង ប្រៀប ដូចគោគេពាក់ខ្សែទាមទឹមដោយរថទុក ដូច្នោះ ។ វដ្តៈមានការមិនធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវទំនងជាមូល ដូចពោលមកនេះ ។ ចំណែកការធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវទំនង កាលចម្រើនឡើង រមែងធ្វើមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិ ជាខដំបូងឱ្យបរិបូណ៌ ព្រោះព្រះបាលីថា ភិក្ខុទាំងឡាយ ភិក្ខុអ្នកសម្បូរដោយការ ធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង គប្បីសង្ឃឹមខនេះបាន គឺ លោកក៏នឹង ចម្រើនអរិយមគ្គអង្គ ៨ និង ធ្វើឱ្យច្រើននូវអរិយមគ្គអង្គ ៨ ។ ដោយបទថា យា ច សម្មាទិដ្ឋិ សាវិជ្ជា នេះ បណ្ឌិតគប្បីជ្រាប វិវដ្តៈ ដែលមានការធ្វើទុក ក្នុងចិត្តដោយឧបាយត្រូវទំនងជាហេតុ យ៉ាងនេះថា ព្រោះវិជ្ជាកើតឡើង និង អវិជ្ជារលត់ទៅ ការរលត់នៃសង្ខារទើបកើត មានដល់ភិក្ខុនោះ ។ល។ ការរលត់ នៃកងទុក្ខទាំងមូលនេះ រមែងមានដោយអាការយ៉ាងនេះ ។ ព្រះសូត្រទាំងអស់

ខាងមុខ មានសេចក្តីជាប់ទាក់ទងគ្នាដោយ បទទាំងពីរនេះ ដូចពោលមកនេះ ។ ក៏ក្នុងសូត្រនេះ ដែលជាប់ទាក់ទងគ្នាយ៉ាងនេះ ព្រោះហេតុដែលទ្រង់សម្តែងការលះអាសវៈមុនហើយ និង ពោលការកើតឡើងខាងក្រោយ មិនសមគួរ មក អំពីថា អាសវៈដែលលះបានហើយរមែងមិន កើតឡើងទៀត ដែលត្រឹមត្រូវ ( គឺពោល ) ការលះអាសវៈទាំងឡាយដែលកើតឡើងហើយ ( ដទៃទៀត ) ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា អយោនិសោ ភិក្ខវេ មនសិករោតោ ជាដើម សូម្បីដោយបញ្ញាស់ឧទ្ទេស ។ បណ្តាបទទាំងនោះ បទថា អយោ-និសោមនសិការោតោ សេចក្តីថា ញុាំងអយោនិសោមនសិការ មានប្រការដូចពោលហើយ ឱ្យកើតឡើង ។ ក្នុងបទថា ឧប្បន្នា ចេវ អាសវា ឧប្បជ្ជន្តិ នេះ សេចក្តីថា កាលភិក្ខុបានបច្ច័យមានចីវរជាដើម ដែលខ្លួនមិនធ្លាប់បានមកពីមុន ឬបានវត្ថុដែលគួរពេញចិត្តយ៉ាងណាមួយរបស់ឧបដ្ឋាក សទ្ធិវិហារិក និងអន្តេវា-សិក ហើយមិនមានការធ្វើទុកក្នុងចិត្តដោយត្រូវទំនងនូវបច្ច័យ ឬវត្ថុនោះថា ស្អាត ជាសុខ ឬ ក៏កាលភិក្ខុ មិនធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង នូវអារម្មណ៍ ដទៃ ៗ ដែលខ្លួនមិនធ្លាប់បានសោយមកពីមុនដោយប្រការណាមួយ អាសវៈពួកណារមែងកើតឡើង ។ អាសវៈពួកនោះដែលនៅមិនទាន់កើតឡើង គប្បីជ្រាបថា រមែងកើតឡើង ដូច្នេះ ។ សេចក្តីពិត អាសវៈទាំងឡាយដែលឈ្មោះថា មិនធ្លាប់កើតឡើងក្នុងសង្សារវដ្ត ដែលមានទីបំផុតខាងដើម ដែលនរណាតាមដឹងមិនបាន និង ដោយប្រការដទៃ រមែងមិនមាន ។ អាសវៈទាំងឡាយរបស់

ភិក្ខុណា ក្នុងកាលមុនមិនកើតឡើងក្នុងវត្ថុ ឬ ក្នុងអារម្មណ៍ដែលខ្លួនមិនធ្លាប់បាន សោយមកពីមុន ដោយការបរិសុទ្ធិតាមប្រក្រតី ឬ ដោយអំណាចការឧទ្ទេស បរិបុច្ឆា បរិយត្តិ នវកម្ម និង យោនិសោមនសិការណាមួយហើយ រមែងកើតឡើងដោយឆាប់រហ័ស ដោយបច្ច័យដូច្នោះ ក្នុងពេលខាងក្រោយ អាសវៈទាំង–ឡាយរបស់ភិក្ខុនោះ គប្បីជ្រាបថា នៅមិនទាន់ ( ធ្លាប់ ) កើតឡើងហើយ រមែងកើតឡើងដូច្នេះ ។ ចំណែកអាសវៈទាំងឡាយដែលកំពុងកើតឡើងរឿយ ៗ ក្នុងវត្ថុ និងក្នុងអារម្មណ៍ទាំងនោះឯងលោកហៅថា កើតឡើងហើយរមែងចម្រើន ។ ដែលឈ្មោះថា ការចម្រើននៃអាសវៈទាំងឡាយ ដែលកើតឡើងលើកដំបូងដោយប្រការដទៃពីនេះមិនមានឡើយ ។ បទថា យោនិសោ ច ខោ ភិក្ខវេ នេះ អាសវៈទាំងឡាយរបស់ភិក្ខុណា រមែងមិនកើតឡើងដោយសេចក្តីបរិសុទ្ធិតាមប្រក្រតី ឬ ដោយហេតុមានឧទ្ទេស និង បរិបុច្ឆាជាដើម ដូចមិនកើតឡើងដល់ព្រះមហាកស្សបៈ និង នាងភទ្ទកាបិឡានី ភិក្ខុនោះរមែងដឹងច្បាស់ថាអាសវៈទាំងឡាយរបស់យើង មិនទាន់ដល់ការដកដោយមគ្គឬហ្ន៎ បើដូច្នេះយើងនឹងបដិបត្តិដើម្បីដកអាសវៈទាំងនោះ ។ តពីនោះ លោករមែងគាស់រំលើងអាសវៈទាំងអស់នោះដោយមគ្គភាវនា អាសវៈទាំងនោះរបស់លោក លោកពោលថា ដែលមិនទាន់កើត រមែងមិនកើតឡើង ។ ចំណែកភិក្ខុណា នៅដោយប្រាសចាកសតិ អាសវៈទាំងឡាយ រមែងកើតឡើងដោយឆាប់រហ័ស ព្រោះការវង្វេងភ្លេចសតិ តពីនោះ លោកនោះក៏ដល់សេចក្តីសង្វេគ ផ្តើមតាំងសេចក្តី

ព្យាយាមដោយឧបាយនៃប្រាជ្ញា រមែងភើចកន្ត្រាក់ ដកអាសវៈទាំងនោះបាន អាសវៈដែលកើតឡើងដល់ភិក្ខុនោះ ហៅថា លោករមែងលះបង់បាន ដូចព្រះ-មហាតិស្សគុត្តត្ថេរ អ្នកនៅមណ្ឌលារាម ។

បានឮថា លោករៀនឧទ្ទេសក្នុងវិហារនោះឯង គ្រានោះ កិលេសក៏កើតឡើងដល់ពេលលោកត្រាច់បិណ្ឌបាតក្នុងភូមិ ព្រោះអារម្មណ៍ដែលជាវិសភាគគ្នា ។ លោកគ្របសង្កត់អារម្មណ៍នោះដោយវិបស្សនា ហើយត្រឡប់ទៅកាន់វិហារ ។ អារម្មណ៍នោះបានប្រាកដដល់លោក សូម្បីក្នុងការយល់សប្តិ ។ លោកកើតការសង្វេគឡើងថា កិលេសនេះចម្រើនឡើងហើយ រមែងជាគ្រឿងធ្វើយើងឱ្យធ្លាក់ទៅក្នុងអបាយ ដូច្នេះហើយ ថ្វាយបង្គំលាអាចារ្យ ហើយចេញចាកវិហារទៅរៀនអសុភកម្មដ្ឋាន ដែលជាបដិបក្ខចំពោះរាគៈក្នុងសម្នាក់របស់ព្រះមហាសង្ឃ-រក្ខិតត្ថេរ ចូលទៅកាន់ចន្លោះគុម្ពោតព្រៃ ក្រាលសំពត់បង្សុកូលទ្រាប់អង្គុយកម្ចាត់នូវរាគៈដែលប្រកបដោយកាមគុណ ៥ ដោយអនាគាមិមគ្គ ក្រោកឡើងហើយថ្វាយបង្គំអាចារ្យ ក្នុងថ្ងៃស្អែកឡើងបានសម្រេចឧទ្ទេសមគ្គ ។ ក៏អាសវៈទាំងឡាយពួកណាកំពុងប្រព្រឹត្តទៅ នឹងនៅមិនទាន់កើតឡើង បានឈ្មោះថា ការលះអាសវៈទាំងឡាយពួកនោះ ដោយការបដិបត្តិរមែងមិនមាន ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់កាន់យកបទនេះថា « ឧប្បន្នា ច អាសវា បហីយន្តិ » ដូច្នេះហើយ ទ្រង់ពង្រីកទេសនាឱ្យពិស្តារ ដើម្បីនឹងទ្រង់ចង្អុលបង្ហាញហេតុនៃការលះនូវអាសវៈដែលលះបាន សូម្បីយ៉ាងដទៃដោយ

ប្រការផ្សេង ៗ ទើបត្រាស់ពាក្យជាដើមថា ភិក្ខុទាំងឡាយ អាសវៈដែលគប្បីលះដោយទស្សនៈក៏មាន ដូច្នេះ សមដូចដែលព្រះអង្គជាធម្មរាជា អ្នកឆ្លាតក្នុងប្រភេទនៃទេសនា ។ បណ្ដាបទទាំងនោះ បទថា ទស្សនា បហាតព្វា សេចក្ដី ថា គប្បីលះដោយទស្សនៈ ។ ក្នុងគ្រប់បទក៏ន័យនេះ ។

ពណ៌នាអាសវធម៌ដែលគប្បីលះដោយទស្សន

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ មានព្រះបំណងនឹងទ្រង់ធ្វើឱ្យជាក់ច្បាស់នូវបទទាំងនោះដោយលំដាប់ ទើបទ្រង់តាំងបញ្ហាថា ភិក្ខុទាំងឡាយ ក៏អាសវៈពួកណាដែលគួរលះដោយទស្សនៈ ដូច្នេះហើយ ទ្រង់ផ្ដើមទេសនាដែលជាបុគ្គលាធិដ្ឋានថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្ដាប់ក្នុងធម្មវិន័យ នេះដោយន័យដូចពោលហើយ ក្នុងអដ្ឋកថាមូលបរិយាយសូត្រ ។ បណ្ដាបទ ទាំងនោះ បទថា មនសិករណីយេ ធម្មេ នប្បជានាតិ សេចក្ដីថា រមែងមិន ដឹងច្បាស់ក្នុងធម៌ដែលគួរធ្វើទុកក្នុងចិត្ត គឺ គួរនាំមកពិចារណា ។ បទថា អមនសិករណីយេ សេចក្ដីថា រមែងមិនដឹងច្បាស់ក្នុងធម៌ដែលផ្ទុយគ្នា ។ ក្នុងបទដ៏សេសក៏ន័យនេះ ។ ក៏ព្រោះការកំណត់ដោយធម៌ថា ធម៌ពួកនេះគួរធ្វើទុកក្នុងចិត្ត ធម៌ពួកនេះមិនគួរធ្វើទុកក្នុងចិត្ត ដូច្នេះ មិនមាន តែការកំណត់ដោយអាការមាន គឺ ធម៌ទាំងឡាយដែលភិក្ខុធ្វើទុកក្នុងចិត្តដោយអាការណា ទើបជាបទដ្ឋាននៃការកើតឡើងនៃអកុសលធម៌ ភិក្ខុមិនគួរធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះដោយអាការនោះ ធម៌ទាំងឡាយដែលភិក្ខុធ្វើទុកក្នុងចិត្តដោយអាការណា ទើប

ជាបទដ្ឋាននៃការកើតឡើងនៃកុសលធម៌ ធម៌ពួកនេះភិក្ខុគប្បីធ្វើទុកក្នុងចិត្តដោយអាការនោះ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ពាក្យជាដើមថា យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា យស្ស សេចក្ដីថា អាសវៈពួកណារបស់បុថុជ្ជនអ្នកមិនបានស្ដាប់ហើយនោះ ។ បទថា មនសិករោតោ សេចក្ដីថា អ្នករពួកគឺ នាំមកពិចារណា ។ វា សព្ទ ក្នុងបទថា ឧប្បន្នោ វា កាមសវោ នេះ មានសមុច្ចយៈជាអត្ថ មិនមែនមានវិកប្បជាអត្ថទេ ។ ដូច្នោះ គប្បីឃើញខ្លឹមសារក្នុងទីនេះថា កាមាសវៈ ដែលនៅមិនទាន់កើតឡើង រមែងកើតឡើង កាមាសវៈដែលកើតឡើងហើយ ក៏រីងរឹតតែចម្រើនឡើងផង ដូចកាលព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយមិនមានជើងក៏ដោយ មានជើងពីរក៏ដោយ មានប្រមាណប៉ុនណា ។ល។ តថាគតពោលថា ស្អាមជើងដ៏រី ជាកំពូលនៃសត្វទាំងឡាយនោះ ដូច្នេះ រមែងបានសេចក្ដីថា សត្វមិនមានជើង និង សត្វជើងពីរ ។ និងដូចកាលព្រះអង្គត្រាស់ថា ដើម្បីការតាំងនៅនៃសត្វទាំងឡាយដែលកើតមកហើយខ្លះ ដើម្បីអនុគ្រោះសត្វដែលជាសម្ភវេសីខ្លះ រមែងបានសេចក្ដីថា ភូត និង សម្ភវេសី ។ និងដូចកាលព្រះអង្គត្រាស់ថា ចាកភ្លើងខ្លះ ចាកទឹកខ្លះ ចាកអំពីការខ្វះសាមគ្គីខ្លះ រមែងបានសេចក្ដីថា ចាកភ្លើង ចាកទឹក និង ចាកការខ្វះសាមគ្គី ដូច្នេះ ។ សូម្បីក្នុង បទនេះថា យស្ស ភិក្ខវេ ធម្មេ មនសិករោតោ អនុប្បន្នោ វា កាមាសវោ ក៏គប្បីឃើញខ្លឹមសារយ៉ាងនេះថា

អនុប្បន្នោ ច កាមាសវោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមាសវោ បវឌ្ឍតិ ( កាមាសវៈដែលមិនទាន់កើត រមែងកើតឡើងផង និង កាមាសវៈដែលកើតឡើងហើយ ក៏រីងរឹតតែចម្រើនឡើងផង ) ។ ក្នុងបទដ៏សេសក៏យ៉ាងនេះដូចគ្នា ។ បណ្ដាអាសវៈទាំងនោះ សេចក្ដីត្រេកអរ ដែលប្រកបដោយកាមគុណ ៥ ឈ្មោះ ថា កាមាសវៈ ។ សេចក្ដីត្រេកអរដោយសេចក្ដីពេញចិត្តក្នុងរូបភព និងការពេញចិត្តក្នុងឈាន ដែលប្រកបដោយសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ឈ្មោះថា ភវាសវ សូម្បី ទិដ្ឋាសវៈ រមែងសង្រ្គោះចូលក្នុងភវាសវៈដូចគ្នា ដោយអាការយ៉ាងនេះ ។ ការមិនដឹងក្នុងសច្ចៈទាំង ៤ ឈ្មោះថា អវិជ្ជាសវ ។ បណ្ដាអាសវៈទាំងនោះ កាមាសវៈដែលមិនទាន់កើតឡើង និង ដែលកើតឡើងហើយ រមែងចម្រើនដល់អ្នកដែលត្រេកអរពេញចិត្តក្នុងកាមគុណ ភវាសវៈដែលមិនទាន់កើតឡើង និង ដែលកើតឡើងហើយ រមែងចម្រើនឡើងដល់អ្នកដែលត្រេកអរពេញចិត្ត គឺដាក់ចិត្តក្នុងមហគ្គតធម៌ ។ អវិជ្ជាសវៈដែលមិនទាន់កើត ដែលកើតឡើងហើយ ក៏រមែងចម្រើនដល់អ្នកដែលដាក់ចិត្តក្នុងធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយធម៌ជាបទដ្ឋាននៃវិបល្លាស ៤ គប្បីជ្រាបន័យដូចពោលមកនេះ ។ ចំណែកធម៌សគួរឱ្យពិស្ដារដោយភាពផ្ទុយគ្នានឹងធម៌ តាមន័យដែលពោលហើយ ។

សួរថា ក៏ព្រោះហេតុអ្វី ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទើបត្រាស់អាសវៈទុកតែ ៣ ប៉ុណ្ណោះ ?

ឆ្លើយថា ព្រោះជាសត្រូវចំពោះវិមោក្ខ ។

សេចក្តីពិត កាមាសវៈជាបដិបក្ខដល់អប្បណិហិតវិមោក្ខ ។

ភវាសវៈ និង អវិជ្ជាសវៈ ជាបដិបក្ខចំពោះអនិមិត្តវិមោក្ខ និង សុញ្ញត-វិមោក្ខ ដូច្នោះ គប្បីជ្រាបថា ព្រះមានព្រះភាគ កាលទ្រង់នឹងសម្តែងខ្លឹមសារនេះថា ពួកជនអ្នកឱ្យអាសវៈទាំង ៣ ពួកនេះ កើតឡើង រមែងជាអ្នកមិនមានចំណែកនៃវិមោក្ខទាំង ៣ ពួកនោះ ជនដែលមិនឱ្យអាសវៈពួកនេះកើតឡើង រមែងជាអ្នកមានចំណែកនៃវិមោក្ខទាំង ៣ ដូច្នេះ ទើបត្រាស់ចំពោះវិមោក្ខទុក ៣ ប៉ុណ្ណោះ ។ ពាក្យនេះថា ម្យ៉ាងទៀត សូម្បីទិដ្ឋាសវៈ ក៏ព្រះអង្គត្រាស់ទុកហើយក្នុងអាសវកថានេះដូចគ្នា ដូច្នេះ ក៏ជាការដែលពណ៌នាទុកហើយ ។ បទថា តស្ស អមនសិករណីយានំ ធម្មានំ មនសិការា សេចក្តីថា ព្រោះហេតុនៃការធ្វើទុកក្នុងចិត្ត អធិប្បាយថា ព្រោះហេតុដែលធ្វើទុកក្នុងចិត្តនូវធម៌ទាំងនោះ សូម្បីក្នុងបទទី ២ ក៏ន័យនេះ ។ ពាក្យថា អាសវៈទាំងឡាយដែលមិនទាន់កើតឡើង រមែងកើតឡើង និង អាសវៈទាំងឡាយ ដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើន ដូច្នេះ នេះជាពាក្យពោលជដែល ។ មិនផ្សេងគ្នាពីអាសវៈទាំងឡាយដែលពោលហើយក្នុងកាលមុន ។

បុថុជ្ជនណា អ្នកមិនបានស្តាប់ ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកហើយ ដើម្បីទ្រង់ចង្អុលបង្ហាញអាសវៈដែលគប្បីលះដោយទេសនា ដែលជាបុគ្គលាធិដ្ឋាន ព្រោះហេតុដែលបុថុជ្ជននោះ ជាទីតាំងនៃអាសវៈទាំងឡាយ មានកាមាសវៈជាដើម ដែលមានការធ្វើទុកក្នុងចិត្តខុសទំនងជាបច្ច័យ ដែលត្រាស់ទុក

ដោយសាមញ្ញធម្មតាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលធ្វើទុកក្នុងចិត្ត ដោយខុសទំនង អាសវៈទាំងឡាយដែលមិនទាន់កើត រមែងកើតឡើង ដូច្នេះ លុះទ្រង់សម្តែងអាសវៈ សូម្បីទាំងនោះដោយបុគ្គលទុ៎ះ នោះឯង ដោយពាក្យត្រឹម តែបុណ្ណោះហើយ ដូច្នេះ កាលនឹងទ្រង់សម្តែងអាសវៈ ដែលគប្បីលះដោយ ទស្សនៈ ទើបត្រាស់ពាក្យជាដើមថា សោ ឯវំ អយោនិសោ មនសិករោតិ អហោសឹ នុ ខោ អហំ ដូច្នេះ ។ ក៏ក្នុងសូត្រនេះ កាលនឹងទ្រង់សម្តែង សូម្បីទិដ្ឋាសវៈ ដោយលើកយកវិចិកិច្ឆាឡើងជាប្រធាន ព្រះមានព្រះភាគទើប ទ្រង់ផ្តើមទេសនានេះ ។ ខ្លឹមសារនៃពាក្យនោះថា អាសវ ដោយន័យដែល ត្រាស់ហើយយ៉ាងនេះ រមែងកើតឡើងដល់អ្នកណា អ្នកនោះឈ្មោះថា បុថុជ្ជន ក៏បុថុជ្ជននេះណា ព្រះអង្គត្រាស់ទុកដោយន័យជាដើមថា អស្សុត្វា ដូច្នេះ បុថុជ្ជននោះ រមែងធ្វើទុកក្នុងចិត្តដោយខុសទំនង គឺ ដោយឧបាយមិនត្រឹមត្រូវ បានដល់ មិនត្រូវផ្លូវ ។

សួរថា ធ្វើទុកក្នុងចិត្ត យ៉ាងណា ?

ឆ្លើយថា គឺធ្វើទុកក្នុងចិត្តយ៉ាងនេះថា យើងមានអំពីអតីតកាលហើយ ឬហ្ន៎ ! ។ល។ សត្វនោះនឹងទៅកាន់ទីណាវិញហ្ន៎ ! ដូច្នេះ ។

សួរថា លោកអធិប្បាយទុកដូចម្តេច ?

ឆ្លើយថា លោកអធិប្បាយទុកថា បុគ្គលនោះរមែងធ្វើទុកក្នុងចិត្តដោយ ខុសទំនង ដោយប្រការដែលគេមានវិចិកិច្ឆា ១៦ យ៉ាង ដែលព្រះមានព្រះភាគ

ជាម្ចាស់ត្រាស់ទុកដោយន័យថា អហំ អហោសឹ នុ ខោ ដូច្នេះ កើតឡើង ។ បណ្ដាសេចក្ដីសង្ស័យទាំងនោះ ការសង្ស័យថា អហោសឹ នុ ខោ ន នុខោ ( យើងមានហើយឬហ្ន៎ ឬមិនមានហើយទេ ) សេចក្ដីថា បុថុជ្ជនសង្ស័យការ មាន និង មិនមាននៃអត្តាក្នុងអតីត កើតព្រោះអាស្រ័យអាការ គឺ សស្សតទិដ្ឋិ និង អាការដែលកើតឡើងរឿយ ៗ ពាក្យថា កឹ ការណំ ( ហេតុអ្វី ? ) មិនចាំបាច់ពោល ( ព្រោះ ) ពាលបុថុជ្ជនមានប្រតិកម្មម្ដងល្អ ម្ដងអាក្រក់ ដូចមនុស្សឆ្កួត ។ ម្យ៉ាងទៀត អយោនិសោមនសិការនោះឯង ជាហេតុក្នុងរឿងនេះ ។

សួរថា អ្វីជាហេតុនៃអយោនិសោមនសិការ ។

ឆ្លើយថា ភាពជាបុថុជ្ជននោះឯង ឬ កិច្ចដែលមានការមិនឃើញព្រះ_អរិយជាម្ចាស់ទាំងឡាយ ជាដើមហេតុ ។

សួរថា ក៏សូម្បីបុថុជ្ជន រមែងធ្វើទុកក្នុងចិត្តដោយត្រូវទំនង ( មានយោ_និសោមនសិការដូចគ្នា ) មិនមែនឬ ឬអ្នកណាទៅ ពោលយ៉ាងនេះថា បុថុជ្ជន មិនធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ( មិនមានយោនិសោមនសិការ )[១] ។ ភាពជាបុថុជ្ជនមិនមែនជាហេតុសំខាន់ក្នុងសេចក្ដីនោះ កម្ម គឺ ការស្ដាប់ធម៌ និង ការមានកល្យាណមិត្តជាដើម ជាហេតុសំខាន់ក្នុងសេចក្ដីនោះ ។ សេចក្ដីពិត តាមប្រក្រតីរបស់ខ្លួន សត្វ មានត្រី និង ម្រឹគ ជាដើម មិនមានក្លិនប្រអូប តែ

---

*១ បាឋ:ជា កោវ ឯវមាហ មនសិករោតីតិ តែច្បាប់កូមាជា កោ វា ឯវមាហ ន មន-សិករោតីតិ ឃើញថាត្រឹមត្រូវជាង ទើបប្រែតាមច្បាប់កូមា ។*

ក្លាយជាសត្វមានក្លិនប្រអូបបាន ព្រោះមានគ្រឿងតុបតែង ជាបច្ច័យ ។

បទថា កឹ នុ ខោ អហោសឹ សេចក្តីថា បុថុជ្ជនអាស្រ័យជាតិ ( កំណើត ) ភេទ និង ការឧប្បត្តិឡើងទើបសង្ស័យថា យើងបានជាក្សត្រហើយ ឬហ្ន៎ បានជាបណ្តាព្រាហ្មណ៍ អ្នកជំនួញ សូទ្រ គ្រហស្ថ បព្វជិត ទេវតា មនុស្សប្រភេទណាមួយហើយ ឬហ្ន៎ ។

បទថា កថំ នុ ខោ សេចក្តីថា បុថុជ្ជនអាស្រ័យអាការនៃសណ្ឋានទ្រង់ទ្រាយ ទើបសង្ស័យថា យើងបានជាមនុស្សខ្ពង់ខ្ពស់ហើយឬហ្ន៎ បានជាមនុស្សថៅកទាប មនុស្សស មនុស្សខ្មៅ មនុស្សខ្នាតល្មម មនុស្សមិនមានខ្នាតហើយឬហ្ន៎ ។ ចំណែកអាចារ្យពួកខ្លះ រមែងពោលថា បុថុជ្ជនអាស្រ័យហេតុការនិម្មិតរបស់ព្រះឥស្សរជាដើម ហើយសង្ស័យដោយហេតុថា យើងបានមាន ហើយព្រោះហេតុអ្វីហ្ន៎ ។

បទថា កឹ ហុត្វា កឹ អហោសឹ សេចក្តីថា បុថុជ្ជនអាស្រ័យជាតិ ( កំណើត ) ជាដើម រមែងសង្ស័យនូវការបន្តគ្នារបស់ខ្លួនថា យើងជាក្សត្រិយ៍ហើយ ទើបបានមកជាព្រាហ្មណ៍ឬហ្ន៎ ។ ។ល។ ជាទេវតា ហើយទើបបានមកជាមនុស្សឬហ្ន៎ ។ ពាក្យថា អទ្ធានំ ក្នុងគ្រប់ ៗ បទ ជាពាក្យដែលបញ្ជាក់ដល់កាលវេលា ។ បទថា ភវិស្សាមិ នុ ខោ ន នុខោ សេចក្តីថា រមែងសង្ស័យការដែលខ្លួននឹងមាន ឬ នឹងមិនមានក្នុងអនាគត ព្រោះអាស្រ័យអាការនៃសស្សតទិដ្ឋិ និង អាការនៃឧច្ឆេទទិដ្ឋិ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យដូច

ពោលហើយ ដូចគ្នា ។

បទថា ឯតរហិ វា បច្ចុប្បន្នំ អទ្ធានំ សេចក្ដីថា ឬប្រារព្ធយក បច្ចុប្បន្នកាល សូម្បីទាំងអស់មានបដិសន្ធិជាខាងដើម មានចុតិជាទីបំផុត ក្នុង បច្ចុប្បន្ន ។

បទថា អជ្ឈត្តំ កថំកថី ហោតិ សេចក្ដីថា បុថុជ្ជនរមែងជាអ្នកមាន សេចក្ដីសង្ស័យក្នុងខន្ធទាំងឡាយរបស់ខ្លួន ។ សង្ស័យដូចម្ដេច ? សង្ស័យ ការដែលខ្លួនមានថា ទេអញមានឬ ?

សួរថា ក៏សេចក្ដីនេះ ត្រឹមត្រូវហើយឬ ?

ឆ្លើយថា ក្នុងពាក្យថា ត្រឹមត្រូវ ឬ មិនត្រឹមត្រូវនេះ នឹងមានការគិត ( សង្ស័យ ) ធ្វើអ្វីទៅ អើ ក៏ក្នុងរឿងនេះ មានរឿងដូចតទៅនេះជាឧទាហរណ៍ ÷

បានឮថា កូនពៅរបស់ម៉ែ កោរក្បាល ( ចំណែក ) កូនច្បងរបស់ម៉ែ មិនបានកោរក្បាល លុះកូនច្បងរបស់ម៉ែនោះដេកលក់ ញាតិទាំងឡាយទើប ជួយគ្នា កោរក្បាល ។ កូនច្បងនោះលុះភ្ញាក់ឡើង ក៏គិតថា យើងជាកូនពៅ របស់ម៉ែឬ សេចក្ដីសង្ស័យថា យើងមានឬ ក៏យ៉ាងនេះឯង ។

បទថា នោ នុ ខោស្មិ បានដល់ បុថុជ្ជនរមែងសង្ស័យការដែលខ្លួន មិនមាន ។ សូម្បីក្នុងសេចក្ដីនោះ មានរឿងដូចតទៅនេះជាឧទាហរណ៍ ÷

បានឮថា អ្នកចាប់ត្រីម្នាក់គិតឃើញជង្គង់របស់ខ្លួន ដែលត្រជាក់ព្រោះ ត្រាំនៅក្នុងទឹកយូរ ថាជាត្រី ទើបបានវាយ មនុស្សម្នាក់ទៀត ដែលរក្សាស្រែ

នៅជិត ព្រៃស្មសាន ដឹងខ្លួនខ្លាចទើបដេកខៀនខ្លួន ។ គេភ្ញាក់ឡើងគិត ថាជើងរបស់ខ្លួនជាយក្ខពីរនាក់ ទើបបានវាយ ។ គេរមែងមានសេចក្ដីសង្ស័យ ថាឬថាយើងមិនមាន ( មិនមែនខ្លួនយើង ) ដូច្នេះ ។

បទថា កឹ នុខោ បានដល់ គេជាក្សត្រ ( តែ ) សង្ស័យភាពជាក្សត្ររបស់ខ្លួន ។ ក្នុងបទដ៏សេសក៏ន័យនេះ ។ ចំណែកអ្នកកើតជាទេវតា ឈ្មោះថាមិនដឹងភាពជាទេព រមែងមិនមាន សូម្បីទេវតានោះ ក៏រមែងមានការសង្ស័យភាពជាទេវតានោះ ដោយន័យជាដើមថា យើងមានរូប ឬ មិនមានរូបហ្ន៎ ។

ប្រសិនបើមានពាក្យសួរថា ក្សត្រជាដើម មិនដឹងភាពជាក្សត្រជាដើមព្រោះហេតុអ្វី ?

គប្បីឆ្លើយថា ការឧប្បត្តិក្នុងត្រកូលនោះ ៗ របស់ក្សត្រជាដើមទាំងនោះមិនប្រចក្ស ។ សូម្បីគ្រហស្ថទាំងឡាយ មានព្រាហ្មបោដ្ឋលិតៈជាដើម ក៏មានសេចក្ដីសម្គាល់ខ្លួនឯងថា ជាបព្វជិត សូម្បីបព្វជិតក៏មានសេចក្ដីសម្គាល់ខ្លួនឯង ថាជាគ្រហស្ថ ដោយន័យជាដើមថា កម្មរបស់យើងកម្រើកហើយហ្ន៎ ។ម៉្យាងទៀត សូម្បីមនុស្សទាំងឡាយ រមែងមានសេចក្ដីសម្គាល់ខ្លួនឯងថា ជា សម្មតិទេពដូចព្រះរាជា ។

បទថា កថំ នុ ខោស្មិ នេះ ក៏ន័យដូចពោលហើយនោះឯង ។ ក៏ក្នុងបទថា កថំ នុ ខោស្មិ នេះ មានសេចក្ដីអធិប្បាយថា បុថុជ្ជនកាលប្រកាន់មាំថា ក្នុងខាងក្នុងមានតែជីវៈសុទ្ធ ៗ ដូច្នេះ ហើយអាស្រ័យអាការនៃ

សណ្ឋានរបស់ជីវៈនោះ នៅសង្ស័យថា យើងជាមនុស្សខ្ពស់ឬ ឬថា យើងមាន រូបរាងតឿ ៤ ចំណែក ៦ ចំណែក ៨ ចំណែក ១៦ ចំណែកជាដើមប្រការណា ដូច្នេះ គប្បីជ្រាបថា សង្ស័យថា យើងជាយ៉ាងណាហ្ន៎ ។ ដែលឈ្មោះថា បុគ្គល អ្នកមិនដឹងសរីរៈ សណ្ឋានដែលជាបច្ចុប្បន្នមិនមានឡើយ ។

បទថា កុតោ អាគតេ សោ កុហឹ គាមី ភវិស្សតិ បានដល់ សង្ស័យទីមក និង ទីទៅរបស់អត្តភាព ។

ព្រះមានព្រះភាគជាម្ចាស់ លុះសម្តែងវិចិកិច្ឆា ១៦ យ៉ាង ដូចពណ៌នា មកដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងទិដ្ឋាសវៈណា ដោយប្រធាន គឺ វិចិកិច្ឆានេះ ព្រះអង្គបានផ្តើមទេសនានេះ កាលនឹងទ្រង់សម្តែងទិដ្ឋាសវៈនោះ ទើបត្រាស់ពាក្យជាដើមថា តស្ស ឯវំ អយោនិសោ មនសិករោតោ ឆន្នំ ទិដ្ឋីនំ ដូច្នេះ ។ មានពាក្យអធិប្បាយទុកថា វិចិកិច្ឆានេះរមែងកើតឡើងដល់ បុគ្គលនោះដោយប្រការណា បណ្តាទិដ្ឋិ ៦ យ៉ាង ទិដ្ឋិណាមួយ រមែងកើតឡើង ដល់បុគ្គលនោះឯង អ្នកមិនធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ទាក់ទើក្នុងចិត្ត សង្ស័យដោយប្រការនោះ ព្រោះអយោនិសោមនសិការដល់ភាពជាសភាពមាន កម្លាំង ។ វា ស័ព្ទក្នុងគ្រប់ ៗ បទនោះ ជាវិកប្បត្ថៈ ។ អធិប្បាយថា ទិដ្ឋិ រមែងកើតឡើងយ៉ាងនេះខ្លះ យ៉ាងនេះខ្លះ ។ ក៏ក្នុងសស្សតទិដ្ឋិ ក្នុងបទថា អត្តារបស់យើងមាន រមែងប្រកាន់មាំថា អត្តារបស់ខ្លួនមាននៅគ្រប់កាល ។ បទថា សច្ចតោ ថេតតោ សេចក្តីថា ដោយពិត និង ដោយពិត ។ អធិប្បាយ

ថា ដោយការប្រកាន់យ៉ាងមាំថា យ៉ាងនេះប៉ុណ្ណោះពិត ។ ចំណែកទិដ្ឋិនេះថា អត្តារបស់យើងមិនមាន ឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ ថា សត្វដែលមាននៅ ដាច់សូន្យក្នុងភពនោះ ៗ ។ ម្យ៉ាងទៀត ទិដ្ឋិសូម្បី ២ ដំបូង ឈ្មោះថា សស្សតទិដ្ឋិ ព្រោះប្រកាន់មាំថា មានខ្លួននៅក្នុងកាលទាំង ៣ ។ ទិដ្ឋិដែលប្រកាន់ថា វត្ថុដែលមានក្នុងបច្ចុប្បន្នប៉ុណ្ណោះ ឈ្មោះថា ឧច្ឆេទទិដ្ឋិ ។ ម្យ៉ាងទៀត ទិដ្ឋិក្រោយឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់មាំក្នុងអតីត និង អនាគតថា មិនមាន ដូចទិដ្ឋិរបស់បុគ្គលអ្នកប្រកាន់មាំ ទិដ្ឋិថា ការបូជាទាំងឡាយ មានផេះជាទីបំផុត ដូច្នោះ ( ចំណែក ) ទិដ្ឋិដែលប្រកាន់មាំក្នុងអតីតប៉ុណ្ណោះថា មិនមាន ឈ្មោះថា សស្សតទិដ្ឋិ ដូចទិដ្ឋិរបស់សត្វដែលកើតឡើងរឿយ ៗ ប៉ុណ្ណោះ ។

បទថា អត្តនា វ អត្តានំ សញ្ជានាមិ សេចក្តីថា កាលបុថុជ្ជនប្រកាន់ ខន្ធទាំងឡាយ ដោយមានសញ្ញាខន្ធជាប្រធានថា នុ៎ះអត្តា ហើយសម្គាល់ដឹងខន្ធ ដ៏សេសដោយសញ្ញា រមែងមានការយល់ថា យើងរមែងសម្គាល់ដឹងអត្តានេះ ដោយអត្តានេះ ។

បទថា អត្តនាវ អត្តានំ សេចក្តីថា កាលបុថុជ្ជនប្រកាន់សញ្ញាខន្ធនោះ ឯងថា ជាអត្តា ហើយប្រកាន់ខន្ធ ៤ ក្រៅពីសញ្ញាថា អត្តា ហើយសម្គាល់ខន្ធ ៤ នោះដោយសញ្ញា រមែងមានការយល់យ៉ាងនេះថា ( យើងសម្គាល់អនត្តាដោយ អត្តា ) ។

បទថា អនត្តនាវ អត្តានំ សេចក្តីថា កាលបុថុជ្ជនប្រកាន់សញ្ញាខន្ធថាមិនមែនខ្លួន ប្រកាន់ខន្ធ ៤ ថាខ្លួន ហើយសម្គាល់ខន្ធ ៤ នោះដោយសញ្ញារមែងមានការយល់យ៉ាងនេះថា ( យើងសម្គាល់អត្តាដោយអនត្តា ) ។ ទិដ្ឋិគ្រប់យ៉ាង ( ដូចពោលមក ) ចាត់ជាសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិទាំងអស់ ។

អាការទាំងឡាយមានជាអាទិ៍ថា វទោ វទេយ្យោ ជាអាការនៃការប្រកាន់មាំដោយសស្សតទិដ្ឋិនោះឯង ។ ក្នុង ២ ពាក្យនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ។ ដែលឈ្មោះថា វទោ ព្រោះអត្ថថា អ្នកញុះញង់ អធិប្បាយថា អ្នកធ្វើវចីកម្ម ។ ដែលឈ្មោះថា វេទេយ្យោ ព្រោះអត្ថថា ដឹង អធិប្បាយថា ទាំងដឹង ទាំង សោយ ។

សួរថា សោយនូវអ្វី ?

ឆ្លើយថា សោយផលកម្មល្អ និង កម្មអាក្រក់ក្នុងភពនោះ ៗ ។

បទថា តត្រ តត្រ សេចក្តីថា ក្នុងកំណើត គតិ ឋិតិ និវាស និង និកាយ ឬ ក្នុងអារម្មណ៍នោះ ៗ ។

បទថា និច្ចោ គឺ វៀរចាកការកើត និង ការសាបសូន្យទៅ ។

បទថា ធុវោ គឺ មាំទាំ បានដល់ ជាសារៈ ។

បទថា សស្សតោ គឺ មាននៅរហូតកាលទាំងពួង ។

បទថា អវិបរិណាមធម្មោ សេចក្តីថា មានការមិនលះបង់ភាពជាប្រក្រតីរបស់ខ្លួនជាធម្មតា គឺរមែងមិនដល់ភាពជាប្រការផ្សេង ៗ ដូចសត្វបង្កួយ ដូច្នោះ ។

បទថា សស្សតិសមំ សេចក្តីថា ព្រះច័ន្ទ ព្រះអាទិត្យ សមុទ្រ មហាប្រឹថពី និង ភ្នំ លោកហៅថា សស្សតិ ( វត្ថុដែលទៀង ) តាមវោហារ របស់មនុស្សលោក ។ ស្មើដោយវត្ថុដែលទៀងទាំងឡាយ ឈ្មោះថា សស្សតិ-សម ។ ទិដ្ឋិយ៉ាងនេះ រមែងមានដល់បុគ្គលអ្នកប្រកាន់មាំថា វត្ថុដែលទៀង ទាំងឡាយ រមែងតាំងនៅដរាបណា អត្តានេះនឹងតាំងនៅដូច្នោះ ដរាបនោះ ។

បទថា ឥទំ ក្នុងពាក្យថា ឥទំ វុច្ចតិ ភិក្ខវេ ទិដ្ឋិគតំ ដូច្នេះ ជាដើម ជាពាក្យចង្អុលបង្ហាញ ពាក្យដែលនឹងគប្បីពោលក្នុងកាលឥឡូវនេះ យ៉ាងច្បាស់ លាស់ ។ ក៏បទថា ឥទំ នេះ លោកពោលទុកដោយការអាស្រ័យនឹងទិដ្ឋិគតៈ មិនពោលទុកដោយការមិនជាប់ទាក់ទងនឹងទិដ្ឋិទេ ។ ក៏ក្នុងទីនេះ ទិដ្ឋិនោះឯង ឈ្មោះថា ទិដ្ឋិគត ដូច គូថ គត ។ ម្យ៉ាងទៀត ការប្រព្រឹត្តិទៅក្នុងទិដ្ឋិ ឈ្មោះថា ទិដ្ឋិគត ។ ទស្សនៈនេះ ព្រោះហេតុដែលចុះកាន់ក្នុងខាងក្នុងទិដ្ឋិ ៦២ ដូច្នោះទើបឈ្មោះថា ទិដ្ឋិគត ។ ម្យ៉ាងទៀត ការប្រព្រឹត្តិទៅរបស់ទិដ្ឋិ ក៏ឈ្មោះថា ទិដ្ឋិគត ។ ពាក្យថា អត្ថិមេ អត្តា ជាដើមនេះ ត្រឹមតែជាដំណើរដើរទៅនៃ ទិដ្ឋិ ។ អធិប្បាយថា អត្តា ឬនរណា ៗ ដែលទៀងមិនមានក្នុងទីនេះ ។ ម្យ៉ាងទៀត ទិដ្ឋិនេះនោះឈ្មោះថា ញៀតស្បាត ព្រោះអត្ថថា កាប់ឆ្ការបានដោយ លំបាក ឈ្មោះថា កន្តារ ព្រោះអត្ថថា ឆ្លងបានដោយលំបាក និង ព្រោះអត្ថថា មានភ័យចំពោះមុខ ដូចភាពដែលកន្តារៈ ព្រោះទុព្ភិក្ខភ័យ និង ព្រោះសត្វកាច ជាដើមដូច្នោះ ។ ទិដ្ឋិនោះ ដែលឈ្មោះថា ជាចម្រូង ព្រោះអត្ថថា ជាគ្រឿង

ចាក់ដោត ឬ ព្រោះអត្ថថា ជាគ្រឿងផ្ទុយ ពីសម្មាទិដ្ឋិ ។ ឈ្មោះថា ញាប់ញ័រ ព្រោះអត្ថថា បម្រាស់ខុសរូប ព្រោះជួនកាលប្រកាន់សស្សតទិដ្ឋិ ជួនកាលប្រកាន់ឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា សំយោជន ព្រោះអត្ថថា ជាគ្រឿងចង ។ ដោយហេតុនោះ លោកទើបពោលថា ទិដ្ឋិគហនំ ។ល។ ទិដ្ឋិសំយោជនំ ដូច្នេះ ។ ដូច្នេះកាលនឹងសម្ដែងអត្ថ គឺ ការចងនោះឯងរបស់សំយោជនៈ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ពាក្យជាដើមថា ទិដ្ឋិ សំយោជនសំយុត្តោ ដូច្នេះ សេចក្ដីនោះមានការសង្ខេបដូចតទៅនេះថា បុថុជ្ជនអ្នកប្រកបដោយទិដ្ឋិសំយោជនៈ រមែងមិនរួចចាកជាតិជាដើមទាំងនេះ ។ ម្យ៉ាងទៀត មិនចាំបាច់ត្រូវនិយាយច្រើន គឺពោលថា គេរមែងមិនរួចផុតអំពីវដ្តទុក្ខទាំងអស់ ក៏បាន ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងទិដ្ឋាសវៈដែលមាន ៦ ប្រភេទ ដូចពណ៌នាមកដូច្នេះហើយ ។ ព្រោះហេតុដែល សីលព្វតបរាមាស ព្រះអង្គសម្ដែងទុកដោយអំណាចកាមាសវៈជាដើមនោះឯង សេចក្ដីពិត សមណ ព្រាហ្មណ៍ទាំងឡាយ ក្រៅពីព្រះពុទ្ធសាសនានេះ ត្រូវអវិជ្ជាគ្របសង្កត់ រមែងនាំគ្នាប្រកាន់សីល និងវត្តដើម្បីសេចក្ដីសុខក្នុងកាម និងដើម្បីសេចក្ដីសុខក្នុងភព និងឱ្យសេចក្ដីបរិសុទ្ធិក្នុងភព ដូច្នោះ កាលមិនសម្ដែងសីលព្វតបរាមាសៈនោះ ( បន្ថែមទៀត ) ឬ មិនទ្រង់សម្ដែងសីលព្វតបរាមាសៈនោះ ព្រះអង្គទ្រង់កាន់យកដោយស័ព្ទថា ទិដ្ឋិ ហើយឥឡូវនេះដើម្បីនឹងទ្រង់សម្ដែងបុគ្គលអ្នកលះអាសវៈដែលនឹងគប្បីលះដោយទស្សនៈនោះហើយ សម្ដែងវិធីលះបង់អាសវៈទាំងនោះ ឬ ដើម្បី

នឹងទ្រង់សម្តែងការកើតឡើងនៃអាសវៈទាំងនោះរបស់បុថុជ្ជន អ្នកមិនបានធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ទើបទ្រង់សម្តែងពិធីការលះបង់របស់បុគ្គលអ្នកផ្ទុយគ្នានោះ ក្នុងឥឡូវនេះទើបត្រាស់ ពាក្យជាដើមថា សុតវា ច ខោ ភិក្ខវេ ដូច្នេះ ជាដើម ។ អត្ថនៃពាក្យនោះ បណ្ឌិតគប្បីជ្រាបដោយន័យ នៃពាក្យដែលទ្រង់សម្តែងទុកហើយក្នុងកាលមុនថា សោ ឥទំ ទុក្ខំ ដូច្នេះ និង ដោយបុគ្គលដែលផ្ទុយគ្នាអំពីបុគ្គលដែលពោលហើយ ។ ក៏បុគ្គលនេះ គប្បីជ្រាបថា ជាអរិយសាវកអ្នកបានស្តាប់ ជាអ្នកឈ្លាសក្នុងអរិយធម៌ នឹងបានទូន្មានខ្លួនល្អក្នុងអរិយធម៌ដោយបច្ចុនិកន័យ គឺ ពោលដោយភាពជាសត្រូវចំពោះបុគ្គលអ្នកមិនដឹង និង មិនបានទូន្មានខ្លួនល្អក្នុងអរិយធម៌ ដោយអការទាំងពួង ។ ម្យ៉ាងទៀត បុគ្គលនេះប្បីជ្រាបថា ជាអរិយសាវក ដោយអត្ថដ៏សមគួរដល់ហេតុនោះ តាំងពីវិបស្សនាដ៏កំពូលរហូតដល់គោត្រភូ ។

ក៏ក្នុងសេចក្តីថា សោ ឥទំ ទុក្ខន្តិ យោនិសោមនសិករោតិ ដូច្នេះជាដើមនេះ មានការបរិយាយសេចក្តីឱ្យច្បាស់លាស់ដូចតទៅនេះ ។ អរិយ_សាវកអ្នកចម្រើនកម្មដ្ឋានក្នុងសច្ចៈ ៤ នោះ ដំបូងត្រូវរៀនកម្មដ្ឋាន ប្រកបដោយសច្ចៈ ៤ ក្នុងសម្នាក់របស់អាចារ្យយ៉ាងនេះថា ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ជាទុក្ខ ព្រោះទោស គឺ តណ្ហា , តណ្ហាឈ្មោះថា ជាទីកើតនៃទុក្ខ ការមិនប្រព្រឹត្តិទៅនៃទុក្ខ និង ទុក្ខសមុទយៈ ទាំងពីរ ឈ្មោះថា និរោធ , បដិបទាឱ្យដល់ការរលត់ឈ្មោះថា មគ្គ ដូច្នេះហើយ ដោយសម័យតមក លោក

ឈានឡើងកាន់ផ្លូវនៃវិបស្សនា រមែងដាក់ចិត្តដល់ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ដោយឧបាយថា វត្ថុនេះជាទុក្ខ គឺ រមែងនឹកនៅក្នុងចិត្ត និង ពិចារណាឃើញច្បាស់ដោយឧបាយ គឺ ដោយត្រូវផ្លូវ ។ ក៏ក្នុងទីនេះ ព្រះមានព្រះភាគ_ជាម្ចាស់ ត្រាស់វិបស្សនាដោយមនសិការជាសំខាន់រហូតដល់សោតាបត្តិមគ្គ ។ ព្រះយោគាវចរ រមែងធ្វើទុកក្នុងចិត្តដោយត្រូវទំនងថា ក៏តណ្ហានេះជាសមុដ្ឋាន គឺ ជាហេតុឱ្យកើតទុក្ខនោះឯង តណ្ហានេះនោះឈ្មោះថា សមុទយៈ ។ ព្រះយោគា_វចររមែងធ្វើទុកក្នុងចិត្តដោយត្រូវទំនងថា ក៏ព្រោះទាំងទុក្ខនេះផង ទាំងសមុទយៈនេះផង លុះដល់ឋានៈនេះហើយ រមែងរលត់ទៅ គឺ មិនប្រព្រឹត្តទៅ ដូច្នោះ ឋានៈនេះទើបឈ្មោះថា និព្វាន នេះឯង ឈ្មោះថា ទុក្ខនិរោធ ។ ព្រះយោគវចររមែងធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនងដល់មគ្គមានអង្គ ៨ ដែលជាហេតុឱ្យដល់និរោធថា នេះគឺ បដិបទាឱ្យដល់ការរលត់ទុក្ខ គឺ រមែងពិចារណាឃើញច្បាស់ដោយឧបាយ គឺផ្លូវត្រូវ ។ ក្នុងខណៈនោះមានឧបាយ ( កំណត់ ) ដូច្នេះ ÷

ឈ្មោះថា ការប្រកាន់មាំរមែងមានក្នុងវដ្តៈ មិនមានក្នុងវិវដ្តៈទេ ។ ដូច្នោះ ព្រះយោគាវចរកំណត់ភូតរូប ៤ ក្នុងសន្តតិរបស់ខ្លួនដោយន័យជាដើមថា បឋវី_ធាតុ អាបោធាតុ នេះ មាននៅក្នុងកាយនេះ ដូច្នេះហើយ កំណត់ឧបាទាយរូបតាមទំនងនៃភូតរូបនោះហើយ កំណត់ថា នេះជារូបក្ខន្ធ ដូច្នេះ កាលកំណត់រូបក្ខន្ធនោះ ក៏រមែងកំណត់ធម៌ គឺ ចិត្ត និង ចេតសិក ដែលមានរូបខន្ធនោះជាអារម្មណ៍កើតឡើងហើយថា ធម៌ ៤ ប្រការនេះ ជាអរូបក្ខន្ធ តអំពីនោះរមែង

កំណត់ថា ខន្ធ ៤ បញ្ចក្ខន្ធនេះជាទុក្ខ ក៏បញ្ចក្ខន្ធនោះ ដោយសង្ខេបមាន ២ ចំណែកប៉ុណ្ណោះ គឺ នាម និង រូប ហើយនាមរូបនេះ មានហេតុបច្ច័យ កើតឡើង ព្រះយោគាវចររមែងកំណត់ហេតុ និង បច្ច័យរបស់នាមរូបនោះ មានអវិជ្ជា ភព តណ្ហា កម្ម និង អាហារជាដើមថា នេះជាបច្ច័យ ។ តអំពីនោះ ព្រះយោគាវចរកំណត់កិច្ច និងលក្ខណៈរបស់ខ្លួន តាមការពិតរបស់បច្ច័យ និងធម៌ដែលអាស្រ័យបច្ច័យកើតឡើងទាំងនោះហើយ លើកឡើងកាន់អនិច្ចលក្ខណៈថា ធម៌ទាំងនេះមានហើយត្រឡប់ជាមិនមានទៅវិញ លើកឡើងកាន់ទុក្ខលក្ខណៈថា ធម៌ទាំងនេះជាទុក្ខ ព្រោះភាពដែលត្រូវការកើតឡើង និង ការវិនាសទៅ សូន្យ ទៅបៀតបៀន លើកឡើងឆ្ពោះអនត្តលក្ខណៈថា ធម៌ទាំងនេះឈ្មោះថា អនត្តា ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ ព្រះយោគាវចរ កាលលើកធម៌ទាំងនេះឡើងកាន់ត្រៃលក្ខណ៍យ៉ាងនេះហើយ ឱ្យវិបស្សនាប្រព្រឹត្តទៅដោយលំដាប់ រមែងសម្រេចសោតាបត្តិមគ្គបាន ។ ក្នុងខណៈនោះ លោករមែងសម្រេចនូវសច្ចៈទាំង ៤ ដោយការចាក់ធ្លុះដោយញាណមួយដួងប៉ុណ្ណោះ រមែងត្រាស់ដឹងដោយអាការត្រាស់ដឹងដោយញាណ ១ ដួង រមែងចាក់ធ្លុះទុក្ខ ដោយការចាក់ធ្លុះ ដោយការកំណត់ដឹង រមែងចាក់ធ្លុះសមុទយៈ ដោយការចាក់ធ្លុះ ដោយការលះ រមែងចាក់ធ្លុះនិរោធ ដោយការចាក់ធ្លុះ ដោយការធ្វើឱ្យច្បាស់ រមែងចាក់ធ្លុះមគ្គ ដោយការចាក់ធ្លុះ ដោយការចម្រើន ។ ម្យ៉ាងទៀត លោករមែងត្រាស់ដឹងទុក្ខដោយការត្រាស់ដឹង ដោយការកំណត់ដឹង ។ល។ រមែងត្រាស់ដឹងមគ្គ ដោយការត្រាស់

ដឹង ដោយការចម្រើន មិនមែនត្រាស់ដឹងសច្ចៈមួយខទៀតដោយញាណមួយទៀតទេ ។ សេចក្តីពិត ព្រះយោគាវចរនេះ រមែងចាក់ធ្លុះ និង រមែងត្រាស់ដឹងនិរោធសច្ចៈដោយភាពជាអារម្មណ៍ និងសច្ចៈដ៏សេសដោយភាពជាកិច្ចដោយញាណមួយដួងប៉ុណ្ណោះ ។ ក៏ក្នុងសម័យនោះ លោករមែងមិនមានការគិតយ៉ាងនេះថា យើងរមែងកំណត់ទុក្ខ ដូច្នេះ ឬ ។ល។ ឬថា យើងរមែងញ៉ាំងមគ្គឱ្យចម្រើន ដូច្នេះ ។ ម្យ៉ាងទៀត លោកធ្វើឱ្យជាក់ច្បាស់នូវនិរោធ ដោយអំណាចនៃបដិវេធ ដោយធ្វើឱ្យជាអារម្មណ៍នោះឯង ញាណនោះឈ្មោះថា រមែងធ្វើនាទីកំណត់ដឹងទុក្ខខ្លះ ធ្វើនាទីលះសមុទយៈខ្លះ ធ្វើនាទីចម្រើនមគ្គខ្លះ ។ កាលលោកធ្វើទុកក្នុងចិត្តដោយត្រូវទំនងដោយឧបាយយ៉ាងនេះ លោករមែងលះសំយោជនៈបាន ៣ យ៉ាងគឺ សក្កាយទិដ្ឋិមានវត្ថុ ២០ វិចិកិច្ឆាមានវត្ថុ ៨ សីលព្វតបរាមាសៈព្រោះស្ទាបអង្អែលដោយសីល និង វត្តថា សេចក្តីបរិសុទ្ធិមានបានព្រោះសីល សេចក្តីបរិសុទ្ធិមានបានព្រោះវត្ត ។ បណ្តាអាសវៈទាំង ៤ នោះ សក្កាយទិដ្ឋិ សីលព្វតបរាមាសៈ លោកសង្គ្រោះចូលក្នុងទិដ្ឋាសវៈ គឺ ទាំងអាសវៈ ទាំងសំយោជនៈ វិចិកិច្ឆាជាសំយោជនៈតែម្យ៉ាង មិនជាអាសវៈ ។ តែឈ្មោះថា អាសវៈព្រោះមានមកក្នុងបាលីនេះថា ទស្សនា បហាតព្វា អាសវា ដូច្នេះ ។ ហេតុនោះធម៌ទាំងនេះ ទើបហៅថា បហាតព្វធម៌ ។ ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សម្តែងសក្កាយទិដ្ឋិជាដើមទាំងនេះថា ជាអាសវៈ ដែលឈ្មោះថាទស្សនប្បហាតព្វធម៌ ទើបបានត្រាស់ទុក ។ ម្យ៉ាងទៀត សក្កាយទិដ្ឋិនេះណា

ដែលលោកចែកទុកដោយសរុបនោះឯងយ៉ាងនេះថា បណ្តាទិដ្ឋិ ៦ យ៉ាង ទិដ្ឋិណាមួយកើតឡើង ដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សំដៅយកសក្កាយទិដ្ឋិនោះ ទើបត្រាស់ថា ឥមេ វុច្ចន្តិ ភិក្ខវេ ដូច្នេះ ។ ក៏ព្រោះសក្កាយទិដ្ឋិនោះ ព្រះយោគាវចរ រមែងលះបង់បានព្រមជាមួយវិចិកិច្ឆា និង សីលព្វតបរាមាសៈ ដែលកើតរួមគ្នា និង មានសេចក្តីតែម្យ៉ាងដូចគ្នាដោយការលះ ។ សេចក្តីពិតកាលព្រះយោគាវចរលះទិដ្ឋាសវៈបានហើយ កាមាសវៈក្តី អវិជ្ជាសវៈក្តី ក្នុងចិត្តដែលជាទិដ្ឋិសម្បយុត្ត ៤ ដួង ដែលកើតរួមនឹងទិដ្ឋាសវៈនោះ ព្រះយោគាវចររមែងលះបានដូចគ្នា ។ ចំណែកភវាសវៈដែលកើតឡើងបាន ដោយអំណាចនៃការសម្រេចការប្រាថ្នារបស់នាគ និង គ្រុឌជាដើម ក្នុងចិត្តដែលជាទិដ្ឋិវិប្បយុត្ត ៤ ដួងឈ្មោះថា ធម៌ដែលមានសេចក្តីតែម្យ៉ាងដូចគ្នា ដោយការលះអាសវៈទាំង ៣ ដ៏សេសយ៉ាងនេះ គឺ អវិជ្ជាសវៈដែលសម្បយុត្តដោយភវាសវៈនេះក្តី អវិជ្ជាសវៈដែលជាតួធ្វើឱ្យកើតអកុសលកម្ម មានបាណាតិបាតជាដើម ក្នុងទោមនស្សចិត្ត ២ ដួងក្តី អវិជ្ជាសវៈដែលសម្បយុត្តដោយវិចិកិច្ឆាចិត្តដូចគ្នាក្តី ព្រះយោគាវចររមែងលះបានដោយប្រការទាំងពួង ។ ព្រោះដូច្នោះ លោកធ្វើនិទ្ទេសជាពហុវចនៈទុកយ៉ាងនេះឯង ។ សេចក្តីក្នុងទីនេះ គប្បីជ្រាបដូចពោលមកនេះ ។ ពាក្យអធិប្បាយរបស់បុរាណាចារ្យក៏ដូច្នេះ ។

បទថា ទស្សនា បហាតព្វា សេចក្តីថា សោតាបត្តិមគ្គ ឈ្មោះថា ទស្សនៈ អធិប្បាយថា អាសវៈទាំងនោះ ដែលទស្សនៈនោះគប្បីលះ ។

សួរថា ព្រោះហេតុអ្វី សោតាបត្តិមគ្គទើបឈ្មោះថា ទស្សនៈ ?

ឆ្លើយថា ព្រោះឃើញព្រះនិព្វានគ្រាដំបូង ។

សួរថា គោត្រភូញាណ រមែងឃើញព្រះនិព្វានមុនសោតាបត្តិមគ្គទៀត មិនមែនឬ ?

ឆ្លើយថា គោត្រភូញាណ រមែងមិនឃើញក៏មិនមែន ។ តែថា គោត្រភូញាណនោះ កាលបើឃើញហើយ នឹងធ្វើកិច្ចដែលគួរធ្វើមិនបាន ព្រោះលះនូវសំយោជនៈមិនបាន ដូច្នោះទើបមិនគួរពោលថា រមែងឃើញ ដូច្នេះ ។ ក៏ក្នុងរឿងនេះ មានបុរសអ្នកស្រុកសូម្បីបានឃើញព្រះរាជាក្នុងទីកន្លែងខ្លះហើយថ្វាយគ្រឿងបណ្ណាការពោលថា សូម្បីក្នុងថ្ងៃនេះយើងក៏មិនបានជួបព្រះរាជា ព្រោះការសម្រេចកិច្ចខ្លួនសម្លឹងមើលមិនឃើញជាឧទាហរណ៍ ។ អាសវៈដែលលះបង់បាន

**ព្រោះសំវរៈ ។**

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងអាសវៈដែលនឹងគប្បីលះបានដោយទស្សនៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងអាសវៈដែលព្រះយោគាវចរគប្បីលះបង់ដោយសំវរ ដែលទ្រង់អធិប្បាយទុកក្នុងលំដាប់តទៅ ទើបត្រាស់ថា ភិក្ខុទាំងឡាយ ក៏អាសវៈឯណាដែលព្រះយោគាវចរគប្បីលះដោយសំវរៈ ដូច្នេះ ។ ក្នុងបទទាំងពួងគប្បីជ្រាបការសម្ពន្ធគ្នាយ៉ាងនេះ ។ ឯខាងមុខពីនេះ ខ្ញុំម្ចាស់នឹងពណ៌នាត្រឹមតែអត្ថន័យប៉ុណ្ណោះ ។

សួរថា ក៏ដែលឈ្មោះថា អាសវៈដែលព្រះយោគាវចរគប្បីលះមិនបាន

ដោយកិច្ច ២ យ៉ាងនេះគឺ ដោយទស្សនៈ និង ដោយភាវនាមិនមានមិនមែន ឬ ? បើដូច្នោះព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់សម្តែងអាសវៈដែលព្រះយោគាវចរគប្បីលះដោយកិច្ចមានសំវរៈជាដើម ទុកមួយផ្នែកទៅ ។

ឆ្លើយថា ព្រោះអាសវៈទាំងឡាយដែលព្រះយោគាវចរសង្កត់សង្កិនទុកបានក្នុងចំណែកខាងដើមដោយកិច្ច មានការសង្រួមជាដើម រមែងមានការដកឡើងដោយមគ្គ ៤ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការលះអាសវៈនេះ ក្នុងចំណែកខាងដើមនៃមគ្គនោះ ដោយការសង្កត់សង្កិនទុកដោយអាការ ៥ យ៉ាង ទើបត្រាស់យ៉ាងនេះ ។ ដូច្នោះ សោតបត្តិមគ្គចំណុចដំបូងដែលព្រះអង្គត្រាស់ទុកហើយនេះ និង មគ្គ ៣ ដែលព្រះអង្គនឹងត្រាស់ដោយឈ្មោះថាភាវនា ក្នុងឥឡូវនេះ កថាថា ដោយអាសវៈដែលគប្បីលះដោយការសង្រួមជាដើមនេះ បណ្ឌិតគប្បីជ្រាបថា ជាបុព្វភាគនៃបដិបទារបស់សោតាបត្តិមគ្គ និងរបស់មគ្គទាំង ៣ នោះ សូម្បីទាំងអស់ ។

បណ្តាបទទាំងនោះបទថា ឥធ គឺ ក្នុងសាសនានេះ ។ បទថា បដិ_សង្ខារ ប្រែថា ពិចារណាហើយ ។ សង្ខា ស័ព្ទ ក្នុងបទថា បដិសង្ខា នោះ រមែងប្រើក្នុងញាណ កោដ្ឋាស បញ្ញត្តិ និង ការរាប់ ។ អធិប្បាយថា សង្ខា ស័ព្ទ ប្រើក្នុងញាណ ( ដូច ) ក្នុងប្រយោគជាដើមថា ពិចារណាហើយ ទើបសេពបច្ច័យម្យ៉ាង ។ ប្រើក្នុងកោដ្ឋាសៈ ( ដូច ) ក្នុងប្រយោគជាដើមថា ចំណែកនៃធម៌ជាគ្រឿងយឺតយូរ មានសញ្ញាជាហេតុ រមែងផ្សាយទៅ ។ ប្រើក្នុងបញ្ញត្តិ

( ដូច ) ក្នុងប្រយោគជាដើមថា ការបញ្ញត្តិ ជាឈ្មោះរបស់ធម៌ទាំងឡាយនោះៗ ។ ប្រើក្នុងការរាប់ ( ដូច ) ក្នុងប្រយោគជាដើមថា ការរាប់មិនមែនធ្វើបានដោយងាយឡើយ ។ ចំណែកក្នុងទីនេះ គប្បីឃើញថា ប្រើក្នុង ញាណ ។

សេចក្ដីពិត បទថា បដិសង្ខា យោនិសោ សេចក្ដីថា ពិចារណា គឺ ជ្រាបបានដល់ ឃើញចំពោះដោយឧបាយ គឺ ដោយត្រូវទំនង ។ ក៏ក្នុងទីនេះ ការពិចារណាទោសក្នុងអសំវរៈ គប្បីជ្រាបថា ការពិចារណាដោយឧបាយនៃ ប្រាជ្ញា ។ ក៏ការពិចារណាទោសក្នុងអសំវរៈនោះ គប្បីជ្រាបដោយន័យ នៃអាទិត្តបរិយាយសូត្រជាដើមថា ភិក្ខុទាំងឡាយ ចក្ខុន្ទ្រីយ៍ដែលភិក្ខុចាក់ទំលុះហើយដោយលំពែងដែកស្រួចដ៏ក្ដៅ ដែលឆេះរន្ទាលច្រាលឆ្អៅដោយភ្លើង នៅប្រសើរជាង ចំណែកការកាន់យកនិមិត្ត និង អនុព្យញ្ជនៈ ក្នុងរូបដែលនឹងគប្បីដឹងដោយភ្នែក មិនប្រសើរឡើយ ។

ក្នុងបទថា ចក្ខុន្ទ្រិយសំវរ សំវុតោ វិហរតិ នេះមានអធិប្បាយថា ឥន្ទ្រីយ៍ គឺ ចក្ខុ ឈ្មោះថា ចក្ខុន្ទ្រីយ៍ ដែលឈ្មោះថា សំវរ ព្រោះឃាំងទុក អធិប្បាយថា ព្រោះបិទ គឺ ឃាំងទុកបាន ។ ពាក្យថា សំវរនេះ ជាឈ្មោះ របស់សតិ ។ ការសង្រួមក្នុងឥន្ទ្រីយ៍ គឺ ចក្ខុ ឈ្មោះថា ការសង្រួមចក្ខុន្ទ្រីយ៍ ដូចប្រយោគជាដើមថា ក្អែកនៅឯកំពង់ទឹក អណ្ដើកនៅក្នុងអណ្ដូងទឹក ក្របីនៅក្នុងព្រៃ ។

បទថា ចក្ខុន្ទ្រិយសំវរ សំវុតោ វិហរតិ នោះ ការសង្រួម ឬ ការ

មិនសង្រួមក្នុងចក្ខុន្ទ្រីយ៍ រមែងមិនមានសូម្បីក៏ពិត សូម្បីយ៉ាងនោះ សតិ ឬ ការវង្វេងភ្លេចសតិ រមែងមិនកើតឡើងព្រោះអាស្រ័យចក្ខុបសាទ ។ ម្យ៉ាងទៀត ក្នុងកាលណារូបារម្មណ៍មកកាន់គន្លងចក្ខុ ក្នុងកាលនោះ កាលភវង្គចិត្តកើតឡើង ២ ខណៈហើយរលត់ទៅ កិរិយាមនោធាតុកើតឡើង ធ្វើអាវជ្ជនកិច្ចស្រេចហើយ រលត់ទៅ តពីនោះ ចក្ខុវិញ្ញាណកើតឡើង ធ្វើទស្សនកិច្ចស្រេចហើយរលត់ទៅ តពីនោះ មនោធាតុដែលជាវិបាក កើតឡើងធ្វើសម្បដិច្ឆន្នកិច្ចស្រេចហើយ រលត់ទៅ តពីនោះ មនោវិញ្ញាណធាតុ ដែលជាអហេតុកវិបាកកើតឡើង ធ្វើសន្តីរណ-កិច្ចស្រេចហើយរលត់ទៅ តពីនោះ មនោវិញ្ញាណធាតុ ដែលជាអហេតុកកិ-រិយាកើតឡើង ធ្វើវោដ្ឋព្វនកិច្ចស្រេចហើយ រលត់ទៅ ។ ក្នុងលំដាប់នោះ ជវនចិត្តរមែងស្ទុះទៅ ។ ម្យ៉ាងទៀត ក្នុងបទថា ចក្ខុន្ទ្រិយ សំវរសំវុតោ វិហរតិ នោះ ការសង្រួម ឬ ការមិនសង្រួម រមែងមិនមានក្នុងសម័យនៃ ភវង្គចិត្ត ទាំងក្នុងសម័យនៃអាវជ្ជនចិត្តជាដើម សម័យណាមួយ ការសង្រួម ឬ ការមិនសង្រួម រមែងមិនមានដូចគ្នា ។ តែក្នុងខណៈនៃជវនចិត្ត បើទោសៈជាគ្រឿងទ្រុស្តសីល ភាពជាអ្នកវង្វេងភ្លេចសតិ ការមិនដឹង ការមិនអត់ធន់ ឬ ការខ្ជិលច្រអូសកើតឡើងសោត នេះជាការមិនសង្រួម ។ ការមិនសង្រួមនោះ សូម្បីជាយ៉ាងនេះ លោកក៏ហៅថា ការមិនសង្រួមក្នុងចក្ខុន្ទ្រីយ៍ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនមានការសង្រួមក្នុងចក្ខុន្ទ្រីយ៍នោះ ។ ទ្វារក្តី ភវង្គចិត្តក្តី

វិថីចិត្ត មានអាវជ្ជនចិត្តជាដើមក្តី រមែងជាការដែលព្រះយោគាវចរមិនបានគ្រប់គ្រងហើយ ។

ប្រៀបដូចអ្វី ?

ប្រៀបដូច កាលទ្វារទាំង ៤ ទិស ក្នុងព្រះនគរដែលបុគ្គលមិនបានគ្រប់គ្រងហើយ ខាងក្នុងទីលំនៅនៃស៊ុមទ្វារ និង បន្ទប់ជាដើម ដែលបុគ្គលឃុំគ្រងរក្សាល្អហើយសូម្បីក៏ពិត សូម្បីយ៉ាងនោះក៏ដោយ វត្ថុគ្រប់យ៉ាងក្នុងព្រះនគរជាការដែលមិនបានរក្សា មិនបានឃុំគ្រងឡើយ ។ ព្រោះចោរទាំងឡាយចូលទៅតាមទ្វារព្រះនគរ គប្បីលួចវត្ថុដែលខ្លួនប្រាថ្នាយ៉ាងណា កាលទោសៈជាគ្រឿងទ្រុស្តសីលកើតឡើងក្នុងជវនចិត្ត កាលមានការមិនសង្រួមក្នុងជវនចិត្តនោះ ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនចិត្តជាដើមក្តី ជាការដែលភិក្ខុមិនឃុំគ្រង ដូច្នោះនោះឯង ។

តែបើសីលជាដើម កើតឡើងក្នុងជវនចិត្តនោះ ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនចិត្តជាដើមក្តី រមែងជាការដែលភិក្ខុឃុំគ្រងល្អហើយ ។

ប្រៀបដូចអ្វី ?

ប្រៀបដូច កាលព្រះនគរដែលបុគ្គលឃុំគ្រងល្អហើយ ខាងក្នុងលំនៅជាដើមដែលបុគ្គលឃុំគ្រងមិនល្អសូម្បីក៏ពិត សូម្បីយ៉ាងនោះ វត្ថុគ្រប់យ៉ាងខាងក្នុងព្រះនគរជាការដែលបុគ្គលរក្សាល្អហើយ ។ ព្រោះកាលបិទទ្វារនគរហើយ ចោរទាំងឡាយក៏ចូលទៅមិនបាន យ៉ាងណា កាលបើសីលជាដើម កើតឡើងក្នុងជវន

-ចិត្ត ទ្វារក្តី ភវង្គចិត្តក្តី វិថីចិត្តមានអាវជ្ជនចិត្តជាដើមក្តី ជាការដែលភិក្ខុឃុំគ្រង ល្អហើយយ៉ាងនោះ ដូចគ្នា ។ ព្រោះដូច្នោះ សំវរៈសូម្បីដែលកើតឡើងក្នុងខណៈ នៃជវនចិត្ត លោកហៅថា ការសង្រួមក្នុងចក្ខុន្ទ្រិយ៍ ។ ក៏ក្នុងទីនេះ សតិសំវរៈ នេះគប្បីជ្រាបថា ព្រះអង្គទ្រង់សំដៅយកហើយ ។ បុគ្គលអ្នកសង្រួមហើយ ដោយការសង្រួមចក្ខុន្ទ្រិយ៍ ឈ្មោះថា ចក្ខុន្ទ្រិយសំវរសំវុតោ អ្នកចូលដល់ ហើយដោយការសង្រួមចក្ខុន្ទ្រិយ៍ ។ ពិតយ៉ាងនោះ ពាក្យណាដែលលោកពោល ទុកក្នុងវិភង្គនៃបទថា បាតិមោក្ខសំវរសំវុតោ នេះថា ភិក្ខុអ្នកចូលដល់ ។ល។ ប្រកបហើយដោយការសង្រួមក្នុងបាតិមោក្ខនេះ ពាក្យនោះ បណ្ឌិតគប្បីរួមចូល ជាមួយគ្នាហើយជ្រាបដោយន័យយ៉ាងនេះថា ភិក្ខុជាអ្នកសង្រួមដោយការសង្រួម ចក្ខុន្ទ្រិយ៍ ។ ម្យ៉ាងទៀត ដែលឈ្មោះថា អ្នកសង្រួមហើយ ព្រោះអត្ថថា សង្រួមរវាំង អធិប្បាយថា ឃាំងទុក គឺ បិទ ។ ភិក្ខុអ្នកសង្រួមរវាំងប្រយ័ត្ន ក្នុងចក្ខុន្ទ្រិយ៍ គឺ អ្នកមានចក្ខុន្ទ្រិយ៍ដែលរវាំងរក្សាហើយ អធិប្បាយថា ឃាំងទុក គឺ បិទសន្ទះទ្វារ គឺ សតិដែលហៅថា ការសង្រួមចក្ខុន្ទ្រិយ៍ក្នុងទ្វារ ដូចមនុស្ស បិទសន្ទះទ្វារផ្ទះ ដូច្នោះ ។ ក៏ក្នុងសេចក្តីនេះ សេចក្តីនេះប៉ុណ្ណោះល្អជាង ។ ពិតយ៉ាងនោះ សេចក្តីនេះនោះឯង រមែងប្រាកដក្នុង ២ បទនេះថា អ្នកមិន សង្រួមរវាំងចក្ខុន្ទ្រិយ៍ និងថា អ្នកសង្រួមរវាំងចក្ខុន្ទ្រិយ៍ ដូច្នេះឯង ។

បទថា វិហរតិ សេចក្តីថា អ្នកសង្រួមរវាំងចក្ខុន្ទ្រិយ៍យ៉ាងនេះ នៅដោយ ការនៅដោយឥរិយាបថណាមួយ ។

ក្នុងបទថា យញ្ហិស្ស ជាដើម គប្បីជ្រាបសេចក្តីយ៉ាងនេះថា កាលភិក្ខុនោះមិនសង្រួមរវាំងចក្ខុន្ទ្រិយ៍ណា គឺ មិនឃាំងទុក មិនបិទការសង្រួមរវាំងចក្ខុន្ទ្រិយ៍ ។ ម្យ៉ាងទៀត ផ្លាស់ យេ អក្សរជា យំ ក៏បាន ចំណែក ហិ អក្សរជាបទបូរណៈ សេចក្តីថា យេ អស្ស ។

បទថា ឧប្បជ្ជេយ្យុំ ប្រែថា គប្បីកើតឡើង ។

បទថា អាសវា វិឃាដបរិឡាហា បានដល់អាសវៈ ៤ និង ការក្តៅប្រហាយព្រោះកិលេស ឬ ការក្តៅប្រហាយព្រោះវិបាកដែលធ្វើការចង្អៀតចង្អល់ពួកដទៃទៀត ។ សេចក្តីពិតកាមាសវៈ រមែងកើតឡើងដល់ភិក្ខុអ្នកពេញចិត្តត្រេកអរនឹងឥដ្ឋារម្មណ៍ដែលមកប្រាកដដល់ចក្ខុទ្វារ ដោយអំណាចនៃការពេញចិត្តក្នុងកាម ភវាសវៈរមែងកើតឡើងដល់ភិក្ខុអ្នកត្រេកអរដោយសេចក្តីប្រាថ្នាក្នុងភព ថា យើងនឹងបានសម្បត្តិដូច្នេះ ក្នុងសុគតិភពសូម្បីដទៃ ទិដ្ឋាសវៈរមែងកើតឡើងដល់ភិក្ខុអ្នកប្រកាន់មាំថា ជាសត្វ ឬ ថារបស់សត្វ ការមិនដឹងដែលកើតព្រមជាមួយនឹងអាសវៈទាំងអស់នោះឯង ឈ្មោះថា អវិជ្ជាសវៈ អាសវៈ ៤ រមែងកើតឡើងដូចពោលមកនេះ ។ សូម្បីកិលេសទាំងឡាយផ្សេងទៀត ដែលសម្បយុត្តនឹងអាសវៈទាំងនោះ ការក្តៅក្រហាយអន្ទះអន្ទែងដែលធ្វើការចង្អៀត-ចង្អល់ ឬ វិបាកក្នុងភពតទៅរបស់កិលេសទាំងនោះ យ៉ាងណា ពិតណាស់ កិលេសជាដើម សូម្បីទាំងនោះ លោកពោលថា គប្បីកើតឡើងដល់ភិក្ខុអ្នកមិនសង្រួមដូចគ្នា ។

បទថា ឯវំស តេ សេចក្តីថា ដោយឧបាយនេះ អាសវៈទាំងនោះឯង មិនមានដល់ភិក្ខុសង្រួមយ៉ាងនេះទេ អធិប្បាយថា មិនមែនមានដោយប្រការ ដទៃ ។

ក្នុងបទជាដើមថា បដិសង្ខា យោនិសោ សោតិន្ទ្រិយ សំវរសំវុតោ ក៏ន័យ ( ដូចគ្នា ) នេះ ។ សេចក្តីថា ឥមេ វុច្ចន្តិ អាសវា សំវរា បហាតព្វា សេចក្តីថា អាសវៈទាំងនោះព្រោះប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ក្នុងទ្វារនីមួយ ៗ មានអាសវៈ ៤ ទើបរួមជាអាសវៈ ២៤ តថាគតពោលថា ព្រះយោគាវចរគួរលះបង់ចេញដោយសំវរៈ ។ ក៏ក្នុងទីនេះ សតិសំវរៈនោះឯង គប្បីជ្រាបថា សំវរៈក្នុងគ្រប់ ៗ បទ នោះឯង ។ អាសវៈដែលបានលះបាន ព្រោះការពិចារណា

ពាក្យដែលនឹងគប្បីពោល ក្នុងបទថា បដិសង្ខា យោនិសោ ចីវរំ ជាដើមទាំងនោះ លោកពោលទុកហើយក្នុងសីលកថា ក្នុងបករណ៍វិសេសឈ្មោះ វិសុទ្ធិមគ្គ នោះឯង ។

បទថា យញ្ហិស្ស អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ចិត្ត និង ការក្តៅក្រហាយឯណា ( គប្បីកើតឡើង ) ដល់ភិក្ខុ ( អ្នកមិនពិចារណាហើយសេព ) បច្ច័យ ឬ បណ្តាចីវរបិណ្ឌបាតជាដើមណាមួយ ។

បទថា អបដិសេវតោ សេចក្តីថា អ្នកមិន ( ពិចារណា ) ដោយឧបាយនៃប្រាជ្ញាហើយសេពយ៉ាងនេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ក៏ក្នុងទីនេះគប្បីជ្រាបការកើតឡើងនៃកាមាសវៈរបស់ភិក្ខុអ្នកប្រាថ្នាចីវរ

ជាដើមដែលខ្លួនមិនទាន់បាន ឬ អ្នកត្រេកអរក្នុងចីវរជាដើមដែលខ្លួនបានហើយតែម្យ៉ាង ។ គប្បីជ្រាបការកើតឡើងនៃភវាសវៈរបស់ភិក្ខុអ្នកត្រេកអរដោយការប្រាថ្នាក្នុងភពថា យើងនឹងបានសម្បត្តិដូច្នេះ ក្នុងសម្បត្តិភព គឺ សុគតិភពសូម្បីដទៃ គប្បីជ្រាបការកើតឡើងនៃទិដ្ឋាសវៈរបស់ភិក្ខុអ្នកតាំងចិត្តសម្គាល់ក្នុងខ្លួនថា យើងនឹងបានដូច្នេះ ឬថា វត្ថុនេះ នឹងជារបស់យើង ដូច្នេះ ។ ក៏អវិជ្ជាសវៈ កើតព្រមជាមួយនឹងអាសវៈទាំងពួង គប្បីជ្រាបការកើតឡើងនៃអាសវៈទាំង ៤ ដូចពោលមកយ៉ាងនេះឯង ។ ចំណែកការក្តៅក្រហាយព្រោះវិបាក គប្បីជ្រាបដោយការកើតឡើងនៃវេទនាថ្មី ។ សេចក្តីថា ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិ_សេវនា បហាតព្វា សេចក្តីថា អាសវៈទាំងនេះមាន ១៦ យ៉ាង ព្រោះចែកអាសវៈក្នុងបច្ច័យនីមួយ ៗ ( មានចីវរជាដើម ) ក្នុងបច្ច័យនីមួយ ៗ មានអាសវៈ ៤ អាសវៈទាំងនេះយើងពោលថា ព្រះយោគាវចរគប្បីលះបានដោយការពិចា_រណាហើយសេព ពោលគឺ ការសង្រួមដោយញាណនេះ ដូច្នេះឯង ។

## អាសវដែលលះបានដោយការអត់ធន់

ខមា បដិសង្ខា យោនិសោ ខមោ ហោតិ សីតស្ស សេចក្តីថា ភិក្ខុពិចារណាដោយឧបាយត្រូវទំនងហើយ រមែងជាអ្នកអត់ធន់ចំពោះត្រជាក់ គឺ រមែងអត់ធន់ចំពោះត្រជាក់ និង ការញ័រញាក់ ព្រោះភាពរងា សូម្បីត្រឹមតែបន្តិចបន្តួច ដូចបុរសមិនមានភាពក្លាហាន លោកមិនព្រមលះបង់ចោលកម្មដ្ឋាន ។ ម្យ៉ាងទៀត លោកត្រូវត្រជាក់ខ្លាំងក្លាពាល់ត្រូវ ក៏មិនញាប់ញ័រ រមែងដាក់ចិត្ត

ឆ្ពោះកម្មដ្ឋាន ដូចព្រះលោមសនាគត្ថេរ ដូច្នោះ ។

បានឮថា ព្រះថេរៈនៅក្នុងរោង បំពេញព្យាយាមក្នុងគុហារបិយង្គុៈ ក្នុងចេតិយបពិត , ពិចារណាលោកន្តរនរក ដែលតាំងនៅក្នុងចន្លោះ ( ទ្វីប ) ក្នុងសម័យសន្សើមធ្លាក់ មិនព្រមលះបង់ចោលកម្មដ្ឋានឡើយ ឱ្យវេលាកន្លងទៅក្នុងកណ្តាលវាល ។ សូម្បីក្នុងរដូវក្តៅជាដើម ក៏គប្បីជ្រាបការអធិប្បាយ ពង្រីកសេចក្តីយ៉ាងនេះ សេចក្តីពិត ភិក្ខុរមែងរម្ងាប់នូវភាពក្តៅ សូម្បីមានប្រមាណដ៏ក្រៃលែងបានតែម្យ៉ាង ភិក្ខុនោះបណ្ឌិតគប្បីជ្រាបថា ជាអ្នកអត់ធន់ចំពោះភាពក្តៅបាន ដូចព្រះថេរៈនោះឯង ។ បានឮថា ក្នុងវេលាក្រោយភត្តាហារក្នុងគិម្ហន្តរដូវ ព្រះថេរៈអង្គុយនៅខាងក្រៅទីចង្ក្រម ។ កាលដាក់ចិត្តដល់កម្មដ្ឋាន ញើសក៏ហូរចេញពីឃ្លៀក ។ ពេលនោះ អន្តេវាសិកនិមន្តលោកថា លោកម្ចាស់ដ៏ចម្រើន និមន្តអង្គុយក្នុងទីនេះចុះ ឱកាសនេះត្រជាក់សប្បាយ ។ ព្រះថេរៈពោលថា យើងនឹងមិនអង្គុយក្នុងទីនោះទេ ព្រោះខ្លាចការក្តៅ អ្នកមានអាយុ ដូច្នេះ ហើយអង្គុយពិចារណាអវិចីមហានរក ។ ក៏ក្នុងទីនេះ សេចក្តីក្តៅអន្ទះអន្ទែង ព្រោះភ្លើងគប្បីជ្រាបថា ឧណ្ហំ ។ ក៏រឿងនោះ លោកពោលទុក ដោយការក្តៅអន្ទះអន្ទែងដែលកើតឡើងពីព្រះអាទិត្យ ។ ក៏ភិក្ខុណា សូម្បីកាលមិនបានភត្ត ឬទឹកផឹកត្រឹមតែ ២_៣ ម៉ាត់ ហើយពិចារណាការកើតឡើងក្នុងបេតវិស័យរបស់ខ្លួនក្នុងសង្សារវដ្តដែលមានទីបំផុតខាងដើមមិនមាន ហើយមិនញាប់ញ័រ មិនលះបង់ចោលកម្មដ្ឋាន នឹងត្រូវសម្ផស្សនៃរបោម មូស និង កំដៅថ្ងៃ សូម្បីមានប្រមាណ

ក្រៃលែងពាល់ត្រូវ ក៏ពិចារណាការចូលដល់កំណើតសត្វតិរច្ឆាន មិនញាប់ញ័រ មិនលះបង់ចោលនូវកម្មដ្ឋានឡើយ ហើយសូម្បីនឹងត្រូវសម្ផស្សនៃសត្វតូច សត្វធំពាល់ត្រូវ ក៏ពិចារណាដល់អត្តភាពក្នុងកាលមុន ដែលបម្រះននៀលច្រើនវារៈ ក្នុងមាត់របស់រាជសីហ៍ និង ខ្លាធំជាដើម ក្នុងសង្សារវដ្តដែលមានទីបំផុតខាងដើមមិនមាន ហើយមិនញាប់ញ័រ មិនលះបង់ចោលកម្មដ្ឋាន ដូចព្រះបធានិយត្ថេរ ភិក្ខុនោះគប្បីជ្រាបថា ជាអ្នកអត់ធន់ ចំពោះការឃ្លាន ។ល។ សម្ផស្សនៃសត្វតូច សត្វធំជាដើម ។ បានឮថា ពស់ពិស ១ បានខាំព្រះថេរៈដែលកំពុងស្តាប់អរិយ-វង្សសូត្រ ក្នុងផ្ទះសម្រាប់បំពេញសេចក្តីព្យាយាម ឈ្មោះកណ្ណិការ ក្នុងមហាវិហារឈ្មោះ ខណ្ឌវេលៈ ។ ព្រះថេរៈ សូម្បីដឹងហើយ មានចិត្តជ្រះថ្លាអង្គុយស្តាប់ធម៌តាមប្រក្រតី ។ កម្លាំងពិសបានកើនឡើង ( តាមលំដាប់ ) ព្រះថេរៈបានពិចារណាដល់សីល ចាប់ផ្តើមពីមណ្ឌលឧបសម្ប័ទ ហើយកើតបីតិឡើងថា យើងមានសីលបរិសុទ្ធ ។ ព្រមជាមួយនឹងការកើតឡើងនៃបីតិ ពិសបានហូរត្រឡប់ចូលទៅផែនដីវិញ ។ ព្រះថេរៈបានឯកគ្គតាចិត្តក្នុងទីនោះឯង ចម្រើនវិបស្សនា ហើយសម្រេចព្រះអរហន្ត ។ ក៏ភិក្ខុណាស្តាប់ពាក្យគ្រោតគ្រាត និងពាក្យដែលសហគតដោយអត្ថិមវត្ថុ ដែលមកអំពីទីឆ្ងាយ ព្រោះជាពាក្យគ្រោត-គ្រាត ហើយពិចារណាដល់គុណរបស់ខន្តិ មិនញាប់ញ័រដោយអំណាចការជេរ ប្រទេចដូចព្រះទីឃភាណកអភយត្ថេរ ភិក្ខុនោះ បណ្ឌិតគប្បីជ្រាបថា ជាអ្នកអត់ធន់ចំពោះពាក្យសំដីគ្រោតគ្រាតដែលមកពីឆ្ងាយបាន ។ បានឮថា ព្រះថេរៈ

ពោលអំពីមហាអរិយវង្សប្បដិបទា ដើម្បីភាពជាអ្នកត្រេកអរក្នុងសេចក្ដីសន្ដោស ដោយបច្ច័យ ។ អ្នកស្រុកទាំងអស់ ម្នាក់ ៗ នាំគ្នាមក ។ មហាសក្ការៈ ទើបបានកើតមានដល់ព្រះថេរៈ ។ ព្រះថេរៈរូបខ្លះ អត់ទ្រាំក្នុងសក្ការៈនោះមិនបាន ទើបជេរដោយន័យជាដើមថា ព្រះទីឃភាណកៈបង្កការជ្រួលច្របល់ឡើងរហូត រាត្រី ដោយពោលថា យើងនឹងសម្ដែងអរិយវង្ស ។ ក៏ព្រះថេរទាំង ២ រូប ( វេលាធ្វើដំណើរ ) ត្រឡប់ទៅកាន់វិហាររៀង ៗ ខ្លួន ហើយបានដើរផ្លូវរួមគ្នា ទៅអស់ផ្លូវប្រមាណ ១ គាវុត ។ ព្រះថេរៈនោះក៏បានជេរព្រះទីឃភាណកថេរៈ ស្ទើររាល់ ៗ គាវុត ។ បន្ទាប់មក ព្រះទីឃភាណកឈ្នេរឈរនៅក្នុងកន្លែងត្រង់ផ្លូវនៃវិហារទាំងពីរបែកគ្នា ថ្វាយបង្គំព្រះថេរៈនោះ ហើយពោលថា លោកដ៏ចម្រើន នេះជាផ្លូវរបស់លោក ដូច្នេះ ។ ព្រះថេរៈដើរចេញទៅធ្វើដូចមិនបានឮ ។ ចំណែកព្រះទីឃភាណកៈទៅដល់វិហារ លាងជើងហើយអង្គុយចុះ ។ អន្តេ-វាសិក ទើបបានពោលឡើងថា លោកដ៏ចម្រើនកើតអ្វី ? ហេតុអ្វីលោក ទើប មិនពោលអ្វី ៗ ជាមួយនឹងព្រះថេរៈនោះ ដែលជេរបរិភាសលោកគ្រប់ ៗ គាវុត ។ ព្រះថេរៈឆ្លើយថា អាវុសោ សេចក្ដីអត់ធន់ជានាទីរបស់យើង ការមិនអត់ធន់ មិនជានាទីរបស់យើងទេ យើងនេះមិន ( ធ្លាប់ ) ឃើញការភ្លាំងភ្លាត់អំពីកម្មដ្ឋាន ( របស់យើង ) ស្ទើរក្នុងការលើកជើងម្ខាង ។ ក្នុងទីនេះគួរជ្រាបថា ពាក្យបន្ដិចបន្តួចនោះឯង ឈ្មោះថា ត្រូវត្រង់តាមគន្លងធម៌ ។

វេទនារាងកាយឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា ជាហេតុឱ្យដល់ទុក្ខ

ឈ្មោះថា ក្រាស់ ព្រោះអត្ថថា កកកុញ ឈ្មោះថា រឹង ព្រោះអត្ថថា គ្រោតគ្រាត ឈ្មោះថា ខ្លាំងក្លា ព្រោះអត្ថថា មុតស្រួច ឈ្មោះថា មិនគួរត្រេកអរ ព្រោះវៀរចាកសេចក្តីត្រេកអរ ឈ្មោះថា មិនគួរពេញចិត្ត ព្រោះអត្ថថា មិនជាទីចម្រើនចិត្ត ឈ្មោះថា គ្រឿងផ្តាច់ជីវិតបាន ភិក្ខុណាអត់ធន់ចំពោះវេទនានោះ បាន គឺ មិនញាប់ញ័រ បានដល់ តាំងនៅតាមប្រក្រតី ដូចព្រះបធានិយត្ថេរអ្នកនៅក្នុងចិតលដាបពិត ភិក្ខុនេះគប្បីជ្រាបថា ជាអ្នកមានប្រក្រតីអត់ធន់ចំពោះវត្ថុផ្សេង ៗ ដែលកើតឡើង ។ល។

បានឮថា កាលព្រះថេរៈឈរបំពេញព្យាយាមនៅរហូតអស់រាត្រី ខ្យល់ក្នុងពោះក៏កើតឡើង ។ លោកមិនអាចនឹងរម្ងាប់ ( អត់សង្កត់ ) ខ្យល់នោះបានទើបរមូលទៅមក ។ ព្រះថេរៈសមាទានដើរបិណ្ឌបាតជាវត្តមួយរូប ឈរនៅខាងទីចង្ក្រម ទើបពោលនឹងលោកថា អាវុសោ ធម្មតាបព្វជិតជាអ្នកមានប្រក្រតីអត់ធន់ ដូច្នេះ ។ ព្រះថេរៈនោះទទួលថា ល្អណាស់ លោកដ៏ចម្រើន ដូច្នេះហើយបានដេក ( ស្ងៀម ) មិនកម្រើក ខ្យល់បានរត់ចាក់សៀតបេះដូងរហូតដល់ផ្ចិត ។ ព្រះថេរៈគ្របសង្កត់នូវវេទនា ចម្រើនវិបស្សនាត្រឹមតែរយៈដ៏ខ្លី ក៏បានជាព្រះ-អនាគាមី ហើយបរិនិព្វាន ដូច្នេះឯង ។

បទថា យញ្ហិស្ស សេចក្តីថា ( អាសវៈទាំងឡាយរមែងកើត ) ដល់ភិក្ខុនោះអ្នកអត់ធន់ចំពោះត្រជាក់ជាដើមយ៉ាងណាមួយមិនបាន ។

បទថា អនធិវាសយតោ សេចក្តីថា អ្នកអត់ធន់មិនបាន គឺ ធន់មិន

បាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ក៏ក្នុងរឿងនេះ គប្បី ជ្រាបការកើតឡើងនៃអាសវៈយ៉ាងនេះ ។ កាមាសវៈ រមែងកើតឡើងដល់ ភិក្ខុត្រូវភាពត្រជាក់ពាល់ត្រូវ ប្រាថ្នាភាពកក់ក្ដៅ ។ នៅក្នុងបទទាំងពួងក៏ន័យ នេះ ។ អធិប្បាយថា ភវាសវៈ រមែងមានដល់ភិក្ខុអ្នកប្រាថ្នាភពថា សភាព ត្រជាក់ ឬ សភាពក្ដៅរបស់យើងក្នុងសម្បត្តិភព រមែងមិនមានដូច្នេះ សេចក្ដី ប្រកាន់មាំថា ត្រជាក់_ក្ដៅ រមែងមានដល់យើង ដូច្នេះ ឈ្មោះថា ទិដ្ឋាសវៈ អាសវៈដែលសម្បយុត្តដោយអាសវៈទាំងពួង ឈ្មោះថា អវិជ្ជាសវៈ ។ បទថា ឥមេ វុច្ចន្តិ ។ល។ អធិវាសនា បហាតព្វា សេចក្ដីថា អាសវៈទាំងនេះ មានច្រើនណាស់ ព្រោះធម៌មួយ ៗ មានអាសវៈប្រព្រឹត្តទៅដោយអំណាចនៃធម៌ មានត្រជាក់ជាដើម អាសវៈនីមួយ ៗ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា គួរ លះបង់ ដោយការអត់ធន់ ពោលគឺ ខន្តិសំវរៈ ។ ក៏ក្នុងទីនេះ ព្រោះខន្តិនេះ រមែងអត់ធន់ចំពោះ ធម៌មានត្រជាក់ជាដើមបាន គឺ លើកឱ្យនៅលើខ្លួន បានដល់ មិនមែនថា នឹងអត់ធន់មិនបានហើយលះបង់ចោលនោះទេ ដូច្នោះ ខន្តិនេះ គប្បី ជ្រាបថាជា អធិវាសនា ។

អាសវៈដែលលះបានព្រោះការវៀរ

ខថា បដិសង្ខា យោនិសោ ចណ្ឌំ ហត្ថឹ បរិវជ្ជេតិ សេចក្ដីថា ភិក្ខុមិនគប្បីឈរនៅទីជិតដំរីកាចឃោរឃៅ ដោយគិតថា យើងជាសមណៈដូច្នេះ ព្រោះថា ទាំងសេចក្ដីស្លាប់ ទាំងសេចក្ដីទុក្ខស្មើតែស្លាប់ ដោយមានដំរីនោះជាហេតុ

គប្បីមានបាន ។ ភិក្ខុពិចារណាដោយឧបាយ គឺ ដោយត្រូវទំនងយ៉ាងនេះហើយ វាងវៀរ គឺ ថយគេចពីដំរីកាច ។ ក្នុងបទទាំងពួងក៏ន័យនេះ ។

បទថា ចណ្ឌំ គឺ ដំរីដែលកាច អធិប្បាយថា អាក្រក់បំផុត ។

បទថា ខាណុំ បានដល់ ជង្គត់ឈើ មានជង្គត់ដើមគគីរជាដើម ។

បទថា កណ្ដកដ្ឋានំ សេចក្ដីថា ស្ថានទីដែលមានបន្លា អធិប្បាយថា ឱកាសដែលមានបន្លាដោយច្រើន ។

បទថា សោព្ភំ បានដល់ កន្លែងដែលមានច្រាំងចោតទូទៅទាំងអស់ ( អណ្ដូង ) ។

បទថា បបាតំ បានដល់ ស្ថានទីដែលមានច្រាំងចោតតែម្ខាង ( ជ្រោះ ) ។

បទថា ចន្ទនិកំ បានដល់ ស្ថានទីជាកន្លែងចោលរបស់ស្មោកគ្រោក មានទឹកស្អុយជាដើម ( រណ្ដៅទឹកសំអុយ ) ។

បទថា ឱទឡិគល្លំ បានដល់ ប្រឡាយទឹកសំអុយ ។ ស្ថានទីនោះជាកន្លែងដែលដេរដាស់ដោយវត្ថុមិនស្អាត សូម្បីមានប្រមាណត្រឹមក្បាលជង្គង់ ។ ឯស្ថានទីទាំងនោះ សូម្បីទាំង ២ ជាស្ថានទីអាក្រក់ថោកទាប ហាក់ដូចជាមានអមនុស្សជួច្នោះ ស្ថានទីទាំងនោះគួរវៀរចេញ ។ ឯអាសនៈដែលមិនសមគួរ ឈ្មោះថា អនាសន ។

ក្នុងបទថា អនាសនេ នេះ ដោយសេចក្ដីអាសនៈនោះគប្បីជ្រាបថា បានដល់ អាសនៈដែលលាក់ទុកនៅក្នុងទីកំបាំង មានទព្វសម្ភារៈដែលមិនពិត

ប្រាកដ ។ ក៏ទីដែលមិនគួរត្រាច់ទៅអគោចរ សូម្បីក្នុងបទថា អគោចរេ នេះ ។ ទីអគោចរនោះ មាន ៥ យ៉ាង ដោយចែកជាប្រភេទ មានស្រីពេស្យាជាដើម ។

បទថា បាបកេ មិត្តេ បានដល់ មិត្តបដិរូប ( មិត្តប្លម ) ឬ មិត្តដែលអាក្រក់ គឺ អ្នកទ្រុស្តសីល ។

បទថា ភជន្តំ ប្រែថា សេពគប់ ។

បទថា វិញ្ញូសព្រហ្មចារី សេចក្តីថា មិត្តសព្រហ្មចារីទាំងឡាយអ្នកជាបណ្ឌិត គឺ អ្នកសម្បូរដោយការចេះដឹង ។ ពាក្យនេះ ជាឈ្មោះរបស់ភិក្ខុទាំងឡាយ ។ ព្រោះថា ភិក្ខុនោះ រមែងប្រព្រឹត្តធម៌ដ៏ស្មើដូចព្រហ្ម នេះដោយគិតថា យើងនឹងជាអ្នកមានកម្មជាមួយគ្នា ហើយរៀនឧទ្ទេសជាមួយគ្នា ហើយមានភាពជាអ្នកមានសិក្ខាស្មើគ្នា ដូច្នោះ ភិក្ខុទាំងនោះលោកទើបហៅថា សព្រហ្មចារី ។

បទថា បាបកេសុ ឋានេសុ សេចក្តីថា ក្នុងស្ថានទីទាំងឡាយដ៏លាមក ។

បទថា ឱកប្បេយ្យុំ សេចក្តីថា គប្បីជឿបាន គឺ គប្បីបង្អោនចិត្តជឿបានថា លោកដ៏មានអាយុនេះបានធ្វើ ឬ នឹងធ្វើពិតប្រាកដ ដូច្នេះ ។

បទថា យញ្ញស្ស សេចក្តីថា កាលភិក្ខុនោះមិនវៀរបណ្តាអន្តរាយមានដំរីជាដើម យ៉ាងណាមួយ ។ ពាក្យដ៏សេសមានន័យដូចពាលនោះឯង ។ ក៏ក្នុងទីនេះ គប្បីជ្រាបការកើតឡើងនៃអាសវៈយ៉ាងនេះ ។ កាមាសវៈរមែងកើតឡើងដល់ភិក្ខុអ្នកជួបប្រទះទុក្ខ មានដំរីជាហេតុ ហើយប្រាថ្នានូវសេចក្តីសុខ ។ ភវាសវៈរមែងកើតមានដល់ភិក្ខុអ្នកប្រាថ្នាភពថា ទុក្ខដូច្នេះរបស់យើងមិនមានក្នុងសម្បត្តិ-

ភព គឺ ក្នុងសុគតិភព ។ ការប្រកាន់មាំថា ដីរីនឹងជាន់យើង សេះនឹងជាន់យើង ដូច្នេះ ឈ្មោះថា ទិដ្ឋាសវៈ ។ អាសវៈដែលសម្បយុត្តជាមួយអកុសលធម៌គ្រប់យ៉ាង ឈ្មោះថា អវិជ្ជាសវៈ ។

ខថា ឥមេ វុច្ចន្តិ ។ល។ បរិវជ្ជនា បហាតព្វា សេចក្ដីថា អាសវៈមានច្រើនយ៉ាង ព្រោះបំបែកអាសវៈទាំងនេះចេញជាម្យ៉ាង ៗ ៤ គប្បីជ្រាបថា ដោយអំណាចអន្តរាយមានដីរីជាដើមតែម្យ៉ាង ៗ គប្បីជ្រាបថា ព្រះ-មានព្រះភាគជាម្ចាស់ត្រាស់ថា ព្រះយោគាវចរគប្បីលះបង់ដោយការវៀរ ពោល គឺ សីលសំវរនេះ ។

## អាសវដែលលះបានព្រោះការបន្ទោបង់

សេចក្ដីថា បដិសង្ខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ សេចក្ដីថា ព្រះយោគាវចរពិចារណាឃើញទោសក្នុងកាមវិតក្ក ដោយឧបាយនៃ ប្រាជ្ញា ដោយន័យជាដើមថា វិតក្កនេះជាអកុសល សូម្បីព្រោះហេតុនេះ វិតក្កនេះមានទោស សូម្បីព្រោះហេតុនេះហើយ វិតក្កនេះឯង រមែងប្រព្រឹត្តទៅ សូម្បីដើម្បីការបៀតបៀនខ្លួនឯង ដូច្នេះ ហើយបញ្ឈប់មិនបាននូវកាមវិតក្ក ដែលកើតឡើង បានដល់ កើតឡើងក្នុងអារម្មណ៍នោះ ៗ អធិប្បាយថា លើកចិត្តឡើងហើយ ឱ្យកាមវិតក្កឈប់មិនបាន ឬ មិនឱ្យកាមវិតក្កឈប់នៅខាងក្នុងបាន ។

សួរថា ភិក្ខុកាលបញ្ឈប់មិនបាន នឹងធ្វើដូចម្ដេច ?

ឆ្លើយថា រមែងលះបង់ចោលវិតក្កនោះចេញ ។

សួរថា ភិក្ខុនឹងលះបង់ចោលវិតក្ក ដូចមនុស្សយកជាលកើបសម្រាមចោលឬ ?

ឆ្លើយថា មិនមែនទេ ។

ម្យ៉ាងទៀត ភិក្ខុរមែងបន្ទោបង់ គឺ ដក បានដល់ ចាក់ សេចក្ដីថា នាំចេញទៅនូវកាមវិតក្កនោះ ។

សួរថា ចាក់ ដូចគ្នានឹងបុគ្គលយកជន្លួញចាក់គោដែលមានកម្លាំងឬ ?

ឆ្លើយថា មិនមែនដូច្នោះទេ ។ តាមពិត នឹងធ្វើកាមវិតក្កនោះឱ្យវិនាស ទៅ គឺ ធ្វើកាមវិតក្កនោះឱ្យប្រាសចេញទៅ បានដល់ ធ្វើកាមវិតក្កនោះ ( ឱ្យជា ) ដោយដែលវាមិនសល់នៅ សូម្បីក្នុងខាងក្នុងរបស់ភិក្ខុនោះ ដោយទីបំផុត សូម្បីត្រឹមតែក្នុងភវង្គចិត្ត ( ក៏មិនមាន ) ។

សួរថា ភិក្ខុនឹងធ្វើវិតក្កនោះ ឱ្យជា យ៉ាងនោះបានដូចម្ដេច ?

ឆ្លើយថា រមែងញ៉ាំងកាមវិតក្កនោះឱ្យដល់ការមិនមាន គឺ រមែងឱ្យដល់ការមិនមានបន្តិចម្ដង ៗ មានអធិប្បាយថា រមែងធ្វើដោយប្រការដែលវិតក្កជាការដែលលោកសង្កត់សង្កិនទុកបានយ៉ាងល្អ ដោយវិក្ខម្ភនប្បហាន ។ ក្នុងព្យាបាទវិតក្ក និង វិហិង្សាវិតក្ក ក៏មានន័យដូចគ្នា ។

ឯក្នុងវិភង្គលោកពោលទុកថា ក្នុងបទថា កាមវិតក្កោ នេះ វិតក្កដែលបដិសំយុត្តដោយកាម គឺ សេចក្ដីត្រិះរិះខុសឈ្មោះថា កាមវិតក្ក ក្នុងទីដទៃ ៗ ក៏ន័យនេះ ។

បទថា ឧប្បន្នុប្បន្នេ សេចក្តីថា កើតហើយ គឺឧប្បត្តិហើយ អធិប្បាយ ថា ត្រឹមតែកើតឡើងហើយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ភិក្ខុបន្ទោបង់អកុសល-វិតក្កទាំងឡាយ ដែលកើតឡើងមួយដងបានហើយ ក្នុងវារៈទី ២ សូម្បីលោកនឹងមិនបានសម្លឹងពិនិត្យ លោកក៏រមែងបន្ទោបង់អកុសលវិតក្កទាំងឡាយដែលកើតឡើងហើយ សូម្បីទាំង ៧ ដងបាន ។

បទថា បាបកេ អកុសលេ សេចក្តីថា ដែលឈ្មោះថា អាក្រក់ ព្រោះអត្ថថា លាមក ដែលឈ្មោះថា អកុសល ព្រោះភាពជាកម្មដែលធ្វើដោយការមិនឆ្លាត មិនឈ្លាស ។

បទថា ធម្មេ បានដល់ កាមវិតក្កជាដើមទាំងនោះឯង ម្យ៉ាងទៀត បានដល់មហាវិតក្ក ៩ យ៉ាង សូម្បីទាំងអស់ ។ បណ្តាមហាវិតក្ក ៩ យ៉ាងនោះ ៣ យ៉ាងពោលទុកហើយ ។ វិតក្កដ៏សេស ៦ ទៀតទាំងនេះ បានដល់ វិតក្កដល់ញាតិ វិតក្កដល់ជនបទ វិតក្កដល់ទេវតា វិតក្កដែលប្រកបដោយភាពជាអ្នកអាណិតស្រឡាញ់ចំពោះអ្នកដទៃ វិតក្កដែលបដិសំយុត្តដោយលាភសក្ការៈ និងកិត្តិយស និង វិតក្កដែលបដិសំយុត្តដោយវត្ថុដទៃ ។

បទថា យញ្ចិស្ស សេចក្តីថា អាសវៈ និង សេចក្តីក្តៅក្រហាយព្រោះការចង្អៀតចង្អល់ចិត្ត គប្បីកើតឡើងដល់ភិក្ខុអ្នកបន្ទោបង់មិនបាននូវវិតក្កណាមួយក្នុងបណ្តាវិតក្កទាំងនោះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ក៏ក្នុងទីនេះ កាមាសវៈនោះឯង គឺ កាមវិតក្ក អាសវៈដែលផ្សេងអំពី

កាមវិតក្កនោះឈ្មោះថា ភវាសវៈ ។ អាសវៈដែលសម្បយុត្តដោយភវាសវៈនោះឯង ឈ្មោះថា ទិដ្ឋាសវៈ ។ ការមិនដឹងក្នុងវិតក្កទាំងអស់ឈ្មោះថា អវិជ្ជា-សវៈ ។ គប្បីជ្រាប ការកើតឡើងនៃអាសវៈទាំងនេះ ដោយប្រការដូចពណ៌នាមកនេះ ។

ខថា ឥមេ វុច្ចតិ ។ល។ វិនោទនា បហាតព្វា សេចក្តីថា អាសវៈមានប្រការដូចពោលហើយ ដោយអំណាចកាមវិតក្កជាដើមនេះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ភិក្ខុនឹងគប្បីលះបានដោយការបន្ទោ-បង់ ពោលគឺ វីរិយសំវរៈ ដែលសហគតដោយការពិចារណាទោសក្នុងវិតក្ក នោះ ៗ នេះ ។

## អាសវៈដែលលះបានព្រោះការចម្រើន

ខថា បដិសង្ខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ សេចក្តីថា ភិក្ខុពិចារណាឃើញទោសនៃការមិនអប់រំ និង អានិសង្សនៃការអប់រំដោយឧបាយ គឺដោយត្រូវទំនងហើយគួរចម្រើនសតិសម្ពោជ្ឈង្គៈ ។ ក្នុងបទទាំងពួងក៏ន័យ នេះ ។ ឯក្នុងអធិការនៃពោជ្ឈង្គៈនេះ ពោជ្ឈង្គៈដែលជាលោកុត្តរៈប៉ុណ្ណោះដែលកើតឡើងព្រោះបានសម្រេចមគ្គ ៣ ខាងដើម ព្រះមានព្រះភាគជាម្ចាស់ទ្រង់សំដៅយកហើយក្នុងទីនេះ សូម្បីដោយពិត ដល់យ៉ាងនោះ ដើម្បីជាក់ច្បាស់ក្នុងពោជ្ឈង្គៈទាំងឡាយរបស់ពួកភិក្ខុអ្នកធ្វើការព្យាយាមជាគ្រាដំបូង ខ្ញុំម្ចាស់នឹងពណ៌នាដោយន័យនៃពោជ្ឈង្គៈទាំងពីរប្រការ ទាំងចំណែកលោកិយ និង ទាំង

ចំណែកលោកុត្តរ ។ តែក្នុងទីនេះ ខ្ញុំម្ចាស់នឹងលះបង់ន័យដែលជាលោកិយចោល ហើយកាន់យកចំពោះន័យ ចំណែកលោកុត្តរប៉ុណ្ណោះ ។ ក្នុងអធិការនៃពោជ្ឈង្គៈនោះ បណ្ឌិតគប្បីជ្រាប វិនិច្ឆ័យបទខាងដើមទាំង ៧ ដែលលោកពោលទុកដោយន័យជាដើមថា សតិសម្ពោជ្ឈំ សិន ដោយន័យ ដោយលក្ខណៈជាដើម ដោយលំដាប់ និង ដោយមិនលើសមិនខ្វះ គឺ ការស្មើគ្នា ។ ក្នុងពោជ្ឈង្គ ៧ នោះ គប្បីជ្រាប វិនិច្ឆ័យក្នុងសតិសម្ពោជ្ឈង្គៈមុន ។ ដែលឈ្មោះថា សតិ ព្រោះអត្ថថាជាគ្រឿងរឭក ។ ក៏សតិនេះនោះ មានការប្រាកដជាលក្ខណៈ ឬ មានការ បង្ហាញជាលក្ខណៈ ។ សមពិតដូចពាក្យដែលលោកពោលទុកថា មហាបពិត្រ នាយឃ្លាំងរបស់ព្រះរាជា រមែងក្រាបទូលដល់សម្បត្តិរបស់ព្រះរាជាថា បពិត្រ មហារាជប្រាក់មានប៉ុណ្ណេះ មាសមានប៉ុណ្ណេះ សម្បត្តិទ្រព្យមានប៉ុណ្ណេះ ដូច្នេះ យ៉ាងណា មហាបពិត្រ សតិក៏ដូច្នោះដូចគ្នាដែរ កាលកើតឡើង រមែងបង្ហាញធម៌ទាំងឡាយដែលជាកុសល អកុសល , មានទោស មិនមានទោស ថោក-ទាប ប្រណីត ខ្មៅ ស និង មានចំណែកជាបដិបក្ខនឹងគ្នា ។ សេចក្តីពិស្តារថាសតិប្បដ្ឋានមាន ៤ យ៉ាង ។ សតិនោះមានការបង្ហាញឱ្យឃើញជាកិច្ច ។ ឯលក្ខណៈរបស់សតិនោះ ព្រះថេរៈពោលទុកដោយអំណាចកិច្ចសុទ្ធ ។ ម្យ៉ាង ទៀតមានការមិនវង្វេងជាកិច្ច មានការបែរមុខឆ្ពោះអារម្មណ៍ជាគ្រឿងប្រាកដ ។ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺ សតិ ឈ្មោះថា សតិពោជ្ឈង្គ ។

បទថា ពោជ្ឈង្គោ នោះ មានវិគ្រោះថា អង្គនៃការត្រាស់ដឹង ឬ ធម៌ជា

គ្រឿងត្រាស់ដឹង ដូច្នោះ ទើបឈ្មោះថា ពោជ្ឈង្គ ។ លោកពោលអធិប្បាយយ៉ាងណា ? ( លោកពោលអធិប្បាយទុកថា ) ធម្មសាមគ្គីនេះ គឺ សតិ

ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ ឧបេក្ខា ដែលជាបដិបក្ខចំពោះឧបទ្ទវៈយ៉ាងច្រើន មានការរុញរា ការរាយមាយ ការខ្ជិលច្រអូស ការប្រមូល មកកាមសុខល្លិកានុយោគ អត្តកិលមថានុយោគ ការប្រកាន់មាំថា ឧច្ឆេទទិដ្ឋិ និង សស្សតទិដ្ឋិ ដែលកើតឡើងក្នុងខណៈនៃមគ្គ ទាំងចំណែកលោកិយ និង លោកុត្តរ ដែលជាហេតុត្រាស់ដឹងនៃព្រះអរិយសាវក លោកហៅថា ពោធិ ព្រោះធ្វើអធិប្បាយដូចដែលពោលមកនេះ ។

បទថា ពុជ្ឈតិ សេចក្តីថា រមែងភ្ញាក់ពីការលក់ដោយអំណាចកិលេសដែលដេកត្រាំ អធិប្បាយថា រមែងធ្វើឱ្យចាក់ធ្លុះអរិយសច្ចទាំង ៤ ឬធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះឯង ។ ដូចដែលព្រះអង្គត្រាស់ទុកថា ចម្រើនពោជ្ឈង្គ ៧ ហើយ រមែងត្រាស់ដឹងចំពោះនូវបញ្ញាជាគ្រឿងត្រាស់ដឹងដ៏កំពូល ។ ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គរបស់បញ្ញាជាគ្រឿងត្រាស់ដឹង ពោលគឺធម្មសាមគ្គីនោះឯង ប្រៀបដូចអង្គឈាន និង អង្គមគ្គជាដើម ដូច្នោះ ។

អរិយសាវកឯណា រមែងត្រាស់ដឹងដោយធម្មសាមគ្គីនេះ មានប្រការដូចពោលហើយ ព្រោះធ្វើអធិប្បាយដូចពោលមកនេះ អរិយសាវកនោះ លោកទើបហៅថា ពោធិ ( អ្នកត្រាស់ដឹង ) ដែលឈ្មោះថា ពោជ្ឈង្គ សូម្បីព្រោះជាអង្គប្រកបរបស់ព្រះអរិយសាវកអ្នកត្រាស់ដឹងនោះ ដូចជា អង្គប្រកបនៃសេនា

និង អង្គប្រកបនៃរថ ដូច្នោះ ។ ដោយហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយទើបពោលថា ម្យ៉ាងទៀត ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គប្រកបរបស់បុគ្គលអ្នកត្រាស់ដឹង ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីតាមន័យនៃបដិសម្ភិទាមគ្គជាដើមថា ÷

សួរថា ក្នុងបទ ពោជ្ឈង្គា នេះ ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថដូចម្ដេច ?

ឆ្លើយថា ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង ។

ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា រមែងត្រាស់ដឹង ។

ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា រមែងត្រាស់ដឹងតាម ។

ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា ត្រាស់ដឹងដោយចំពោះ ។

ដែលឈ្មោះថា ពោជ្ឈង្គ ព្រោះអត្ថថា ដឹងព្រម ។

គប្បីជ្រាបវិនិច្ឆ័យ ដោយអត្ថ និង ដោយលក្ខណៈជាដើមរបស់ពោជ្ឈង្គៈប្រការដំបូង ១ សិន យ៉ាងនេះថា ពោជ្ឈង្គៈដ៏ប្រសើរ គឺ ប្រពៃ ឈ្មោះថា សម្ពោជ្ឈង្គ បើដូច្នោះ សម្ពោជ្ឈង្គៈ គឺ សតិ ឈ្មោះថា សតិសម្ពោជ្ឈង្គ ។

ក៏គប្បីជ្រាបវិនិច្ឆ័យ ក្នុងពោជ្ឈង្គៈប្រការទី ២ ជាដើមដូចតទៅនេះ ÷

ដែលឈ្មោះថា ធម្មវិចយ ព្រោះអត្ថថា ស្រាវជ្រាវរាវរកសច្ចធម៌ទាំង ៤ ប្រការ ធម្មវិចយ នោះ មានការពិចារណាជាលក្ខណៈ មានការបំភ្លឺជា កិច្ច មាន

ការមិនវង្វេងជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា វីរិយ ព្រោះភាពជាសភាវៈដែលក្លៀវក្លា និង ព្រោះធ្វើឱ្យធម៌ប្រព្រឹត្តទៅដោយត្រូវវិធី ។ វីរិយៈនោះ មានការផ្គងចិត្តជាលក្ខណៈ មានការឧបត្ថម្ភចិត្តជាកិច្ច មានការមិនរុញរាចិត្តជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា បីតិ ព្រោះអត្ថថា ឆ្អែត ។ បីតិនោះមានការផ្សាយទៅជាលក្ខណៈ ឬ មានការត្រេកអរជាលក្ខណៈ មានការឆ្អែតកាយ និង ចិត្តជាកិច្ច មានការរីកឡើងនៃកាយ និង ចិត្តនោះ ជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា បស្សទ្ធិ ព្រោះស្ងប់ការក្រវល់ក្រវាយកាយ និង ចិត្ត ។ បស្សទ្ធិ មានការចូលទៅស្ងប់ជាលក្ខណៈ មានការកម្ចាត់ភាពក្រវល់ក្រវាយនៃ កាយ និង ចិត្ត ជាកិច្ច មានការស្ងប់ត្រជាក់ ដែលកើតពីការមិនរសាប់រសល់ នៃកាយ និង ចិត្តជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា សមាធិ ព្រោះតាំងមាំ ។ សមាធិនោះមានការមិនរាយមាយជាលក្ខណៈ ឬ មានការមិនផ្សាយទៅក្នុងអារម្មណ៍ជាលក្ខណៈ មានការប្រមូលមកនូវចិត្ត និង ចេតសិក ជាកិច្ច មានការតាំងមាំនៃចិត្តជាគ្រឿងប្រាកដ ។

ដែលឈ្មោះថា ឧបេក្ខា ព្រោះប្រងើយ ។ ឧបេក្ខានោះមានការពិចារណាជាលក្ខណៈ ឬ មានការប្រព្រឹត្តិទៅដោយស្មើជាលក្ខណៈ មានការហាមភាពអន់ថយ និង ក្រៃលែងនៃចិត្តជាកិច្ច ឬ មានការមិនលំអៀងជាកិច្ច មានការដាក់

ខ្លួនជាកណ្ដាលជាគ្រឿងប្រាកដ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះ ឯង ។ គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងបទដ៏សេស ទាំងដោយអត្ថ និងដោយលក្ខណៈ

ជាដើម យ៉ាងនេះឯង ។

ក្នុងពាក្យថា កមតោ នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

សតិសម្ពោជ្ឈង្គៈ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកមុន ព្រោះសតិ_សម្ពោជ្ឈង្គៈនោះ ជាឧបការៈដល់ពោជ្ឈង្គៈដ៏សេសទាំងអស់ ព្រោះបាលីថា ភិក្ខុទាំងឡាយ តថាគតសម្ដែងសតិនោះឯងថា មានប្រយោជន៍ដល់ធម៌ទាំងពួង ដូច្នេះ ។ ខាងមុខពីនោះ ប្រយោជន៍ក្នុងការសម្ដែងពោជ្ឈង្គៈដ៏សេសទុកមុន ទុកក្រោយ បានសម្ដែងទុកហើយក្នុងសុត្តៈនោះឯង ដោយន័យជាដើមថា អ្នកមានសតិនៅយ៉ាងនោះ ពិចារណាធម៌នោះដោយបញ្ញា ដូច្នេះ ។ ក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយលំដាប់ដូចពោលមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា អនូនាធិកតោ ដូចតទៅនេះ ÷

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ពោជ្ឈង្គៈទុកត្រឹមតែ ៧ ប្រការប៉ុណ្ណោះ មិនលើសមិនខ្វះពីនោះ ?

ឆ្លើយថា ព្រោះជាបដិបក្ខចំពោះការរុញរា និង សេចក្ដីរាយមាយ និង ព្រោះជាប្រយោជន៍ដល់ពោជ្ឈង្គៈគ្រប់ប្រការ ។ អធិប្បាយថា ក្នុងអធិការនៃពោជ្ឈង្គៈនេះ ពោជ្ឈង្គៈ ៣ ប្រការ ជាបដិបក្ខចំពោះការរុញរា សមដូចព្រះមាន_ព្រះភាគជាម្ចាស់ត្រាស់ទុកថា ÷

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណាចិត្តជាធម្មជាតិរុញរា ក្នុងសម័យ នោះជាពេលសមគួរដែលនឹងចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ សមគួរនឹងចម្រើនវីរិយសម្ពោជ្ឈង្គៈ សមគួរនឹងចម្រើនបីតិសម្ពោជ្ឈង្គៈ ដូច្នេះ ។

ពោជ្ឈង្គៈ ៣ ប្រការជាបដិបក្ខចំពោះការរាយមាយ ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ថា ÷

ក្នុងសម័យណា ចិត្តជាធម្មជាតិរាយមាយ ក្នុងសម័យនោះជាពេលសមគួរនឹងចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ សមគួរនឹងចម្រើនសមាធិសម្ពោជ្ឈង្គៈ សមគួរនឹងចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ ដូច្នេះ ក៏ក្នុងបណ្តាពោជ្ឈង្គៈទាំងនោះ សតិ-សម្ពោជ្ឈង្គៈ ជាធម្មជាតិឯក ធ្វើឱ្យសម្រេចប្រយោជន៍ពោជ្ឈង្គៈគ្រប់ប្រការ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ÷

ម្នាលភិក្ខុទាំងឡាយ ក៏តថាគតសម្តែងសតិនេះថា មានប្រយោជន៍ដល់ពោជ្ឈង្គៈគ្រប់ប្រការ ដូច្នេះ ។ បាលីថា សព្វត្ថកំ ដូច្នេះក៏មាន ។ បាលីទាំង ២ ( នោះ ) សេចក្តីក៏គឺថា ចាំបាច់ត្រូវប្រាថ្នាក្នុងពោជ្ឈង្គៈគ្រប់ប្រការ ដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពោជ្ឈង្គៈនេះ សូម្បីដោយបទមិនខ្វះមិនលើសយ៉ាងនេះថា ព្រះមានព្រះភាគសម្តែងពោជ្ឈង្គៈទុក ៧ ប្រការប៉ុណ្ណោះ មិនលើសមិនខ្វះ ព្រោះ ៣ ប្រការ ជាបដិបក្ខចំពោះការរុញរា , ៣ ប្រការ ជាបដិបក្ខចំពោះការរាយមាយ និង ព្រោះសតិ ជាប្រយោជន៍ដល់ពោជ្ឈង្គៈគ្រប់ប្រការយ៉ាងនេះ ។

បណ្ឌិតកាលបើជ្រាបអត្ថពណ៌នារបស់បទទាំង ៧ ដែលពោលដោយន័យ

ជាដើមថា សតិសម្ពោជ្ឈង្គំ យ៉ាងនេះហើយ ឥឡូវនេះ គប្បីជ្រាបអត្ថពណ៌នា យ៉ាងនេះ ក្នុងប្រយោគជាដើមថា ភាវេតិ វិវេកនិស្សិតំ ដូច្នេះ ( តទៅ ) ។

បទថា ភាវេតិ សេចក្តីថា រមែងឱ្យចម្រើន អធិប្បាយថា រមែងឱ្យកើតឡើង គឺ ឱ្យកើតឡើងក្នុងចិត្តសន្តានរបស់ខ្លួនរឿយ ៗ ។

បទថា វិវេកនិស្សិតំ គឺ អាស្រ័យវិវេក ។ សេចក្តីស្ងាត់ ឈ្មោះថា វិវេក ។ វិវេកនោះមាន ៥ យ៉ាងគឺ ÷

តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និង និស្សរណវិវេក ការដែលវិវេកនោះផ្សេង ៗ គ្នា គប្បីជ្រាបដោយន័យដែលលោកពោលទុកក្នុងពាក្យនេះថា អរិយធម្មេ អវិនីតោ ដូច្នេះ ។

សេចក្តីពិត វិវេក នេះ នុ៎ះឯង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា វិន័យ ក្នុងបទថា អរិយធម្មេ អវីនិតោ នោះ ។ ក្នុងវិវេកទាំង ៥ យ៉ាងនេះ ដូចពោលមកនេះ គប្បីជ្រាបសេចក្តីដូច្នេះថា ÷

ក្នុងបទថា វិវេកនិស្សិតំ សេចក្តីថា ចម្រើនសតិសម្ពោជ្ឈង្គៈ អាស្រ័យតទង្គវិវេក អាស្រ័យសមុច្ឆេទវិវេក អាស្រ័យនិស្សរណវិវេក ។ ពិតយ៉ាងនោះ ព្រះយោគីវចរ អ្នកតាមប្រកបការចម្រើនពោជ្ឈង្គៈនេះ ក្នុងខណៈនៃវិបស្សនា រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យតទង្គវិវេកដោយកិច្ច ដែលអាស្រ័យនិស្សរណវិវេកដោយអធ្យាស្រ័យ តែក្នុងកាលនៃមគ្គ រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យសមុច្ឆេទវិវេកដោយកិច្ច និងអាស្រ័យនិស្សរណវិវេកដោយ

អារម្មណ៍ ។ អាចារ្យមួយពួកពោលថា អាស្រ័យវិវេកទាំង ៤ យ៉ាង ដូច្នេះខ្លះ ។ ព្រោះអាចារ្យទាំងនោះ មិនលើកពោជ្ឈង្គៈឡើងមកចំពោះក្នុងខណៈនៃវិបស្សនាដែលមានកម្លាំង និង ក្នុងខណៈនៃមគ្គ និង ផល តែម្យ៉ាងប៉ុណ្ណោះ តែសូម្បីក្នុងកសិណឈាន អានាបានស្សតិកម្មដ្ឋាន និង ក្នុងព្រហ្មវិហារឈាន ដែលជាបាទរបស់វិបស្សនា ក៏លើកឡើងមកដែរ ទាំងព្រះអដ្ឋកថាចារ្យទាំងឡាយ ក៏មិនបានជំទាស់ ។ ព្រោះដូច្នោះ តាមមតិរបស់អាចារ្យទាំងនោះគួរពោលថា ព្រះយោ_គាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យវិក្ខម្ភនវិវេក ដោយកិច្ចតែ ម្យ៉ាងក្នុងខណៈដែលប្រព្រឹត្តទៅនៃឈានទាំងនោះ ។ ហើយលោកពោល ថា ក្នុងខណៈនៃវិបស្សនា ព្រះយោគាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យនិស្សរណវិវេក ដោយអធ្យាស្រ័យ ដូច្នេះយ៉ាងណា ព្រះយោគាវចររមែងចម្រើនសតិសម្ពោជ្ឈង្គៈ សូម្បីដែលអាស្រ័យបដិបស្សទ្ធិក៏ដូច្នោះ ។ ក្នុងសតិសម្ពោជ្ឈង្គៈដែលអាស្រ័យវិរាគៈជាដើម ក៏ន័យនេះ ។ សេចក្តីពិត ធម៌មានវិរាគៈជាដើម ក៏មានវិវេកជាអត្ថទាំងអស់ ។ ក៏ក្នុងធម៌ទាំងឡាយមានវិរាគៈជាដើមនេះ វោសគ្គ តែម្យ៉ាង ដែលចែកចេញជា ២ យ៉ាង គឺ ការបរិច្ចាគដោយការលះបង់ ( បរិច្ចាគវោសគ្គៈ ) ១ , ការលះបង់ដោយការស្ទុះទៅ ( បក្ខន្ទនវោសគ្គៈ ) ១ , បណ្តាការលះបង់ទាំង ២ យ៉ាងនោះ ការលះបង់កិលេសដោយអំណាចតទង្គប្បហានក្នុងខណៈនៃវិបស្សនា និង ដោយសមុច្ឆេ_ទប្បហានក្នុងខណៈនៃមគ្គ ឈ្មោះថា ការលះបង់ដោយការលះបង់ ។ ចំណែក

ការស្ទុះទៅកាន់ព្រះនិព្វាន ដោយការបង្អោនទៅកាន់ព្រះនិព្វាននោះ ក្នុងខណៈនៃវិបស្សនា ឈ្មោះថា ការលះបង់ដោយការស្ទុះទៅ តែក្នុងខណៈនៃមគ្គ ការស្ទុះទៅកាន់ព្រះនិព្វាននឹងមានបាន ដោយអំណាចនៃការធ្វើឱ្យជាអារម្មណ៍ ។ សូម្បីវោសគ្គ ទាំង ២ យ៉ាងនោះ រមែងសមក្នុងន័យនៃអដ្ឋកថា ដែលលាយឡំដោយលោកិយ និង លោកុត្តរនេះ ។ ពិតណាស់ សតិសម្ពោជ្ឈង្គៈនេះ រមែងលះបង់កិលេស និង រមែងស្ទុះទៅកាន់ព្រះនិព្វានដោយប្រការតាមដែលពោលហើយ ។ ក៏ដោយពាក្យទាំងអស់នេះថា វោស្សគ្គបរិណាមី នេះ មានអធិប្បាយ ដែលលោកពោលទុកថា កំពុងបង្អោនទៅ និង បង្អោនទៅហើយ គឺ ចាស់ក្លា និង ចាស់ក្លាហើយ ដើម្បីការលះបង់ដោយដាច់ស្រេទឡះ ដូច្នេះ ។ អធិប្បាយថា ភិក្ខុនេះ អ្នកប្រកបរឿយ ៗ នូវការចម្រើនពោជ្ឈង្គៈ រមែងចម្រើនសតិសម្ពោជ្ឈង្គៈនោះ ដោយសតិសម្ពោជ្ឈង្គៈនឹងចាស់ក្លា និង ចាស់ក្លាហើយ ដើម្បីការលះបង់ដោយការលះបង់កិលេស និង ដើម្បីការលះបង់ដោយការស្ទុះទៅកាន់ព្រះនិព្វានដូច្នេះឯង ។ ក្នុងពោជ្ឈង្គៈដ៏សេស ក៏ន័យនេះ ។

តែថាក្នុងទីនេះ និព្វាន នុ៎ះឯង លោកពោលថា វិវេក ព្រោះស្ងាត់ចាកសង្ខតធម៌ទាំងពួង លោកពោលថា វិរាគ ព្រោះភាវៈនៃសង្ខតធម៌ទាំងអស់អស់ការត្រេកអរហើយ ហើយលោកពោលថា និរោធ ព្រោះភាវៈ គឺ ការរលត់ទៅនៃសង្ខតធម៌ទាំងឡាយ ។ ក៏មគ្គនុ៎ះឯង មានប្រក្រតីបង្អោនទៅដើម្បីការលះបង់ ដូច្នោះ ព្រះយោគាវចររមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យ

វិវេក ព្រោះធ្វើវិវេកឱ្យជាអារម្មណ៍ ហើយប្រព្រឹត្តទៅ ។ ព្រះយោគាវចរ រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យនិរោធក៏យ៉ាងនោះ ។ ព្រះយោគា_វចរ រមែងចម្រើនសតិសម្ពោជ្ឈង្គៈដែលចាស់ក្លាហើយ គឺ ចាស់ក្លាដោយជុំវិញ ដោយភាវៈ គឺ ការលះបង់ និង ដោយភាវៈ គឺ ការស្ទុះទៅកាន់ព្រះនិព្វាន ដោយការដកកិលេសបានជាសមុច្ឆេទ ព្រោះកើតឡើងក្នុងខណៈនៃអរិយមគ្គនុ៎ះ ឯង គប្បីឃើញន័យសេចក្ដីដូចពោលមកនេះ ។ ក្នុងពោជ្ឈង្គៈដ៏សេស ក៏ន័យ នេះ ។

បទថា យញ្ហិស្ស សេចក្ដីថា អាសវៈទាំងឡាយ និង ការក្ដៅក្រហាយ ដែលធ្វើការចង្អៀតចង្អល់ចិត្តទាំងឡាយ រមែងមានដល់ភិក្ខុអ្នកមិនចម្រើនក្នុង បណ្ដាពោជ្ឈង្គៈទាំងឡាយទាំងនោះខណានីមួយ ។ ពាក្យដ៏សេសមានន័យដូច ពោលហើយនេះ ។ ក៏ក្នុងការកើតឡើងនៃអាសវៈក្នុងសូត្រនេះ គប្បីជ្រាបន័យ ដូច្នេះ អាសវៈទាំង ៣ គឺ កាមាសវៈ ភវាសវៈ អវិជ្ជាសវៈ គប្បីកើតឡើងព្រោះ ហេតុដែលភិក្ខុមិនបានអប់រំពោជ្ឈង្គៈ ដែលសម្បយុត្តដោយមគ្គខាងក្រោមទាំង_នេះ អាសវៈទាំងនោះ រមែងមិនមានដល់ភិក្ខុនោះអ្នកចម្រើនពោជ្ឈង្គៈទាំងនោះ ដូច្នេះ ។ សេចក្ដីថា ឥមេ វុច្ចន្តិ ។បេ។ ភាវនា បហាតព្វា សេចក្ដីថា អាសវៈទាំង ៣ នោះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ដែល ភិក្ខុគប្បីលះបង់ដោយការចម្រើនពោជ្ឈង្គៈ ដែលសម្បយុត្តដោយមគ្គ ៣ នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សរសើរភិក្ខុអ្នកលះបង់

អាសវៈបានដោយអាការ ៧ យ៉ាង នេះហើយ កាលនឹងទ្រង់សម្តែងអានិសង្ស ក្នុងការលះបង់អាសវៈរបស់ភិក្ខុនោះ ហើយកាលនឹងឱ្យកើតការឧស្សាហ៍ដល់សត្វទាំងឡាយដោយការលះអាសវៈ ដោយហេតុទាំងនេះ នុ៎ះឯង ទើបត្រាស់ថា យតោ ខោ ភិក្ខវេ ។ បេ។ អន្តមកាសិ ទុក្ខស្ស ដូច្នេះ ។

បណ្តាបទទាំងនោះ តោ អក្ខរ ក្នុងពាក្យថា យតោ ខោ ប្រើក្នុង ឆដ្ឋីវិភត្តិ អធិប្បាយថា ស្មើនឹង យស្ស ខោ ( ក្នុងកាលនោះ ៗ ) ដូច្នេះ ។ ចំណែកព្រះបុរាណាចារ្យទាំងឡាយ រមែងពណ៌នាថា ស្មើនឹង យម្ហិ កាលេ ( ក្នុងកាលណា ) ដូច្នេះ ។ សេចក្តីថា យេ អាសវា ទស្សនា បហាតព្វា សេចក្តីថា អាសវៈទាំងឡាយណា ដែលភិក្ខុលះបង់បានហើយ ដោយទស្សនៈ អាសវៈទាំងឡាយនោះ ជាការដែលភិក្ខុនោះលះបង់បានហើយ ដោយទស្សនៈនោះឯង ហើយលោករមែងមានសេចក្តីសម្គាល់ក្នុងអាសវៈដែលលះមិនទាន់បាន នោះឯងថា ដែលខ្លួនលះបានហើយក៏ទេ ។ ក្នុងបទទាំងពួង មានសេចក្តីពិស្តារយ៉ាងនេះ ។

បទថា សព្វាសវសំវរសំវុតោ សេចក្តីថា ជាអ្នកបិទហើយដោយការបិទអាសវៈគ្រប់យ៉ាង ។ ម្យ៉ាងទៀត ជាអ្នកបិទហើយដោយគ្រឿងបិទនូវអាសវៈគ្រប់យ៉ាង ។

បទថា អច្ឆេជ្ជិ តណ្ហំ សេចក្តីថា ផ្តាច់ផ្តិលហើយ ឬ ដកឡើងបានហើយនូវតណ្ហាគ្រប់យ៉ាងទាំងអស់ ។

បទថា វិវត្តយិ សំយោជនំ សេចក្តីថា រមែងញុំាងនូវសំយោជនៈឱ្យប្រែប្រួលសូម្បីទាំង ១០ គឺ ធ្វើឱ្យអស់មន្ទិល ។

បទថា សម្មា គឺ ដោយហេតុ បានដល់ ដោយកាល ។

បទថា មានាភិសមយា សេចក្តីថា ព្រោះសម្រេចដោយការឃើញ និង ព្រោះសម្រេចដោយការលះបង់មានះ ។ សេចក្តីពិត អរហត្តមគ្គ រមែងឃើញច្បាស់នូវមានះដោយអំណាចកិច្ច ។ នេះជាការសម្រេចដោយការឃើញរបស់ភិក្ខុនោះ ។ ក៏អរហត្តមគ្គ ដែលភិក្ខុឃើញហើយដោយទស្សនៈនោះ ដែលលោករមែងលះបង់បានក្នុងខណៈនោះឯង ដូចការត្រឡប់បានជីវិតរបស់សត្វអ្នកត្រូវពស់ពិសខាំ ដូច្នេះ ។ នេះជាការសម្រេចដោយការលះបង់របស់ភិក្ខុនោះ ។

បទថា អន្តមកាសិ ទុក្ខស្ស សេចក្តីថា ទីបំផុត ៤ យ៉ាងនេះ គឺ ទីបំផុត គឺ ខេត្តដែនដែលមានក្នុងទីបំផុត ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ ទុកថា ចុងខ្សែក្រវ៉ាត់ចាស់ហើយ ឬ ត្រួយ ( ឈើ ) ខៀវស្រស់ ស្ថិតស្រពោន ហើយ និង ទីបំផុតដ៏អាក្រក់ជួរជាតិ ដែលព្រះមានព្រះត្រាស់ទុកថា ម្នាលភិក្ខុ ទាំងឡាយ នេះជាទីបំផុតនៃជីវិត ហើយទីបំផុត គឺ ចំណែកដែលព្រះមានព្រះ_ភាគជាម្ចាស់ត្រាស់ទុកយ៉ាងនេះថា សក្កាយ ( ទិដ្ឋិ ) ក៏ជាទីបំផុតម្យ៉ាង និង ទីបំផុតនៃការរាប់ ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកយ៉ាងនេះថា នេះជាទីបំផុតនៃទុក្ខ ព្រោះរាប់បច្ច័យគ្រប់យ៉ាង ក្នុងបណ្តាទីបំផុតទាំង ៤ យ៉ាងនោះ ភិក្ខុណាធ្វើទីបំផុតប្រការទី ៤ នៃវដ្តទុក្ខទាំងឡាយបាន ព្រោះការដែលមានះដែល

ខ្លួនឃើញហើយ លះបង់បានដោយអរហត្តមគ្គយ៉ាងនេះ ។ អធិប្បាយថា លោកបានធ្វើការផ្តាច់ផ្តិល គឺ ធ្វើឱ្យអស់ទៅ បានដល់ ធ្វើទុក្ខឱ្យអស់ទៅត្រឹមតែរាងកាយជាតិចុងក្រោយ ។

បទថា អត្តមនា តេ ភិក្ខុ សេចក្តីថា ភិក្ខុទាំងនោះមានចិត្តជារបស់ខ្លួន គឺ មានចិត្តរីករាយ ឬជាអ្នកមានចិត្តដែលសម្បយុត្តដោយបីតិ និងសោមនស្ស ។

បទថា ភគវតោ ភាសិតំ អភិនន្ទុំ សេចក្តីថា ភិក្ខុទាំងឡាយទទួលដោយសេចក្តីត្រេកអរ ហើយទូលសរសើរព្រះពុទ្ធភាសិត គឺ ព្រះតម្រាស់ដែលត្រាស់ល្អហើយ បានដល់ ដែលទ្រង់ប្រាស្រ័យហើយ មានការធ្វើទីបំផុតទុក្ខជាបរិយោសានថា ព្រះមានព្រះភាគត្រាស់នូវពាក្យនេះ យ៉ាងនេះ ព្រះសុគតត្រាស់ពាក្យនេះ យ៉ាងនេះ ដូច្នេះ ។

ពាក្យដ៏សេសឯណា ដែលខ្ញុំម្ចាស់មិនបានពោលទុកក្នុងទីនេះ ខ្ញុំម្ចាស់នឹងមិនពោលពាក្យនោះដដែល ៗ ព្រោះពោលទុកមុនហើយ និង ព្រោះយល់បានងាយ ព្រោះដូច្នោះ អ្នកសិក្សាគប្បីពិចារណាពាក្យទាំងអស់តាមលំដាប់បទដោយទំនងនៃពាក្យដែលពោលហើយនេះហោង ។

( ចប់ អដ្ឋកថា សព្វាសវសំវរសូត្រទី ២ )

# អ ដ្ឋ ក ថា
## ធម្មទាយាទសូត្រ ទី ៣

### ហេតុដែលនាំឱ្យកើតព្រះសូត្រ

ធម្មទាយាទសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ។ ក៏ព្រោះហេតុដែលធម្មទាយាទសូត្រនោះ ព្រះមានព្រះភាគទ្រង់លើកទេឡើងសម្ដែងតាមដែលមានរឿងកើតទេឡើង ដូច្នោះ ខ្ញុំម្ចាស់ ( ព្រះអដ្ឋកថាចារ្យ ) នឹងសម្ដែងហេតុដែលនាំឱ្យកើតព្រះសូត្រនោះ ហើយទើបនឹងធ្វើការពង្រីកសេចក្ដីព្រះសូត្រនោះទៅតាមលំដាប់បទ ។

សួរថា ក៏ធម្មទាយាទសូត្រនេះ ព្រះមានព្រះភាគទ្រង់លើកទេឡើងសម្ដែងព្រោះមានរឿងអ្វីកើតទេឡើងទៅ ?

ឆ្លើយថា រឿងលាភសក្ការៈ ។

ដូចបានស្ដាប់មកថា លាភសក្ការៈជាច្រើនកើតទេឡើងដល់ព្រះមាន_ព្រះភាគ ដោយដែលទ្រង់បានសន្សំទានបារមីឱ្យបរិបូរណ៍ហើយតាំងពី ៤ អសង្ខេយ្យ ពិតណាស់ ( ព្រោះ) ព្រះបារមីគ្រប់ប្រការដូចមកប្រជុំគ្នា ( ព្រមគ្នា ) ថា នឹងឱ្យផលក្នុងអត្តភាពមួយនេះឯង ដូច្នេះហើយឱ្យកើតជាអន្លង់ទឹកធំ គឺ លាភសក្ការៈ ដូចមហាពពកដែលប្រជុំគ្នាជាគូ ៗ បង្អុ

ខ្លួនទៅឡើងគ្រប់ទិសហើយ (ធ្លាក់ចុះមក) ឱ្យកើតជាអន្លង់ទឹកធំដូច្នោះ ។

ប្រជាជនវណ្ណៈផ្សេងៗ មានក្សត្រ និង ព្រាហ្មណ៍ជាដើម មានដៃកាន់បាយ ទឹក យាន សំពត់ កម្រងផ្កា គ្រឿងក្រអូប និង គ្រឿងលាភ ជាដើម មកអំពីទីនោះ ៗ ( ទីផ្សេង ៗ គ្នា ) ហើយនាំគ្នាសួររកព្រះមាន-ព្រះភាគថា ព្រះពុទ្ធជាម្ចាស់គង់នៅក្នុងទីណា ? ព្រះមានព្រះភាគគង់នៅ ក្នុងទីណា ? ព្រះជាម្ចាស់ជាទេពនៃទេព ព្រះជាម្ចាស់ជានរៈអ្នកអង់អាច ព្រះជាម្ចាស់ជាបុរសដូចរាជសីហ៍គង់នៅក្នុងទីណា ?

ពុទ្ធបរិស័ទទាំងនោះ សូម្បីប្រើរទេះទាំងច្រើនរយរទេះ ផ្ទុកបច្ច័យមកកាលមិនទាន់បានឱកាសចូលគាល់ ក៏នឹងចតរទេះរង់ចាំរៀងរាបជាប់គ្នា ដោយជុំវិញ ប្រមាណមួយគាវុត ដូចអណ្ឌកវិន្ទុទព្រាហ្មណ៍ជាដើមជាតួយ៉ាង ។ សេចក្ដីល្អិតល្អន់ទាំងអស់ អ្នកសិក្សាគប្បីជ្រាបបានតាមន័យដែលពោលមកហើយក្នុងខន្ធកៈ ( ពួក) និង ក្នុងព្រះសូត្រនោះ ។

ហើយព្រះមានព្រះភាគ មានលាភសក្ការៈកើតទៅឡើងច្រើន យ៉ាងណា ព្រះភិក្ខុសង្ឃក៏មានដូច្នោះដូចគ្នា សេចក្ដីនេះសមដូចពាក្យដែលព្រះអានន្ទ-ត្ថេរពោលទុកដូច្នេះថា ក៏ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ជាអ្នកដែលមហាជនថ្វាយសក្ការៈសម្ដែងសេចក្ដីគោរពរាប់អានបូជានមស្ការ (ហើយ) ទ្រង់

បានទទួលចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាប្រចាំ ចំណែកភិក្ខុសង្ឃ (ក៏ដូចគ្នា) គឺ ជាអ្នកដែលមហាជនធ្វើសក្ការៈ ។ល។ (ហើយ) បានទទួល ........... បរិក្ខារជាប្រចាំ ។

ព្រះមានព្រះភាគក៏ត្រាស់ទុកដូចគ្នាថា ម្នាលចុន្ទៈ ពួក ឬ គណៈ ដែលកើតទេឡើងក្នុងលោក ក្នុងកាលឥទឡូវនេះ មានចំនួនប៉ុន្មាន (បណ្ដាពួក ឬ គណៈទាំងនោះ) គណៈ ឬ ពួកដទៃ សូម្បីតែមួយពួក តថាគតក៏ពិចារណា មិនឃើញទេឡើយ ដែលនឹងបានលាភដ៏លើស និង យសដ៏លើស ដូចពួកភិក្ខុ ម្នាលចុន្ទៈ លាភសក្ការៈនេះនោះ ដែលកើតទេឡើងដល់ព្រះមានព្រះភាគ និង ភិក្ខុសង្ឃរួមគ្នាហើយ ជារបស់ប្រមាណមិនបាន ដូចទឹកនៃស្ទឹងធំ ២ ខ្សែ ដែលហូរមករួមគ្នាជាក្រសែតែមួយ ក៏ជារបស់ប្រមាណមិនបាន ដូច្នោះ ។

ភិក្ខុទាំងទឡាយ បានក្លាយជាអ្នកធ្ងន់ក្នុងបច្ច័យ ជាប់ក្នុងបច្ច័យ ងុប ងល់ក្នុងបច្ច័យ តាមលំដាប់ សូម្បីកាលវេលាក្រោយភត្ត ( ក្រោយឆាន់ អាហារហើយ ) កាលពុទ្ធបរិស័ទនាំទេយ្យធម៌មាន ប្រេង ទឹកឃ្មុំ និង ស្ករអំពៅជាដើម មកប្រគេនភិក្ខុទាំងនោះ លុះគោះរតាំងហើយ ក៏ធ្វើសំទេឡង អឺងកងលាន់ឮខ្លាំងថា ប្រគេនដល់អាចារ្យរបស់អាត្មា ប្រគេនដល់ឧបជ្ឈាយ៍ របស់អាត្មា ហើយប្រតិកម្មនោះ របស់ភិក្ខុនោះ ក៏បានប្រាកដដល់ព្រះមាន_

ព្រះភាគ លំដាប់នោះ ព្រះមានព្រះភាគទ្រង់កើតធម្មសង្វេគថា មិនសមគួរទេឡើយ ហើយទ្រង់ត្រិះរិះថា តថាគតមិនអាចនឹងបញ្ញត្តសិក្ខាបទ (ហាម) ថា បច្ច័យជារបស់មិនសមគួរ ព្រោះការបំពេញសមណធម៌របស់កុលបុត្រទាំងទឡាយត្រូវអាស្រ័យបច្ច័យ តែណ្ហើយចុះ តថាគតនឹងសម្តែងធម្មទាយាទបដិបទា ( វត្តបដិបត្តិរបស់អ្នកជាធម្មទាយាទ ) ក៏ដូចជាការបញ្ញត្តិសិក្ខាបទនៃកុលបុត្រទាំងទឡាយអ្នកប្រាថ្នាក្នុងការសិក្សា ហើយនឹងដូចជាកញ្ចក់សម្រាប់ឆ្លុះបានទូទៅដល់រាងកាយ ដែលដាក់ទុកនឹងទ្វារក្រុង ។

អធិប្បាយថា បរិស័ទ៤វណ្ណៈឃើញស្រមោល(រូប)របស់ខ្លួន ក្នុងកញ្ចក់រមែងកម្ចាត់ទោស ( របស់ដែលធ្វើឱ្យបរិសុទ្ធស្រស់ស្អាត ) ហើយត្រទឡប់ក្លាយជាអ្នកមិនមានទោសយ៉ាងណា កុលបុត្រទាំងទឡាយ អ្នកប្រាថ្នាក្នុងការសិក្សាក៏ដូច្នោះ ដូចគ្នា (គឺ) ប្រាថ្នានឹងប្រដាប់ខ្លួនដោយគ្រឿងប្រដាប់ គឺសេចក្តីព្យាយាមនឹកដល់ទេសនាដែលឧបមាដោយកញ្ចក់ ហើយម្នាក់ ៗ នាំគ្នាលះបង់អាមិសទាយាទបដិបទា បែរមកបំពេញធម្មទាយាទបដិបទា ក៏នឹង ( អាច ) ធ្វើជាតិ ជរា មរណៈឱ្យអស់ទៅបានដោយឆាប់រហ័ស ព្រះមាន-ព្រះភាគបានត្រាស់ព្រះសូត្រនេះទុក ក៏ព្រោះមានរឿងយ៉ាងនេះកើតទេឡើង ។

## ធម្មទាយាទ និង អាមិសទាយាទ

ក្នុងព្រះសូត្រនោះ ព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ អ្នកទាំងទឡាយចូរជាធម្មទាយាទរបស់តថាគតចុះ កុំជាអាមិសទាយាទទេឡើយ ដូច្នេះ មានពាក្យអធិប្បាយថា ម្នាលភិក្ខុទាំងទឡាយ សូមអ្នកទាំងទឡាយ ចូរជាទាយាទនៃធម៌របស់តថាគតចុះ កុំជាទាយាទនៃអាមិសទេឡើយ គឺ ធម៌របស់តថាគតឯណា សូមអ្នកទាំងទឡាយ ចូរជាអ្នកទទួលទុកនូវធម៌នោះចុះ ចំណែកតថាគតមានអាមិសឯណា សូមអ្នកទាំងទឡាយកុំទទួលនូវអាមិសនោះទេឡើយ ។

ក្នុងព្រះតម្រាស់នោះ សូម្បីធម៌ក៏មាន២ យ៉ាង គឺ និប្បរិបរិយាយធម៌ ( ធម៌ដោយត្រង់ ) ១ , បរិយាយធម៌ ( ធម៌ដោយអម ) ១ ចំណែកអាមិសក៏មាន ២ យ៉ាង ( ដូចគ្នា ) គឺ និប្បបរិយាយអាមិស ( អាមិសដោយត្រង់ ) ១, បរិយាយអាមិស ( អាមិសដោយអម ) ១ ។

ទាំងធម៌ និង អាមិសនោះ មានអធិប្បាយយ៉ាងណា ?

មានអធិប្បាយថា លោកុត្តរធម៌ទាំង ៩ យ៉ាង ដែលចែកប្រភេទ ជាមគ្គ ( ៤ ) , ផល ( ៤ ) និង និព្វាន ( ១ ) ឈ្មោះថា និប្បបរិយាយធម៌ គឺ ធម៌អ្នកបដិបត្តិឱ្យកើត ( ក្នុងខ្លួនបានដោយត្រង់ ) មិនមែនជាធម៌ដោយបរិយាយ ( ដោយអម ) គឺ ដោយហេតុ ឬ ដោយ

លេសអ្វីទេឡើយ ។ ចំណែកកុសលដែលអាស្រ័យវិវដ្ដៈ ( និព្វាន ) នេះ ដូច បុគ្គលខ្លះក្នុងលោកនេះ ប្រាថ្នានូវវិវដ្ដៈ ទើបឱ្យទាន សមាទានសីល រក្សា ឧបោសថ ធ្វើការបូជាព្រះរតនត្រៃដោយសក្ការៈទាំងទឡាយ មានគ្រឿងក្រអូប និង កម្រងផ្កាជាដើម ស្ដាប់ធម៌ ( និង ) សម្ដែងធម៌ ញុំាងឈាន និង សមាបត្តិឱ្យកើត គេធ្វើយ៉ាងនេះ រមែងបាននិប្បរិយាយធម៌ គឺ អមតមហា_ និព្វាន ដោយលំដាប់ ។ ក៏ធម៌ដូចពោលមកនេះឯង ឈ្មោះថា បរិយាយធម៌ ។

បច្ច័យ ៤ មានចីវរជាដើម ក៏មានទំនងដូច្នោះ ឈ្មោះថា និប្ប_ រិយាយអាមិស ដោយពិត មិនមែនជាអាមិសព្រោះបរិយាយយ៉ាងដទៃ ឬ ព្រោះហេតុយ៉ាងដទៃទេឡើយ ។ ចំណែកកុសលដែលនាំទៅកាន់វដ្ដៈ(ភព៣) នេះ ដូចបុគ្គលខ្លះក្នុងលោកនេះប្រាថ្នាវដ្ដៈ ប្រាថ្នាភព ដែលមានសម្បត្តិ ទើបឱ្យទាន ។ល។ ញុំាងសមាបត្តិឱ្យកើត គេធ្វើយ៉ាងនេះ រមែងបានទេវ_សម្បត្តិ មនុស្សសម្បត្តិដោយលំដាប់ កុសលដូចពោលមកនេះ ឈ្មោះថា បរិយាយអាមិស ។

ក្នុងរឿងធម៌ និង អាមិសនោះ ( មានអធិប្បាយបន្ថែមទៀតថា ) សូម្បីនិប្បរិយាយធម៌ ក៏ឈ្មោះថា ជាធម៌របស់ព្រះមានព្រះភាគ ព្រោះធម៌ នោះ ព្រះមានព្រះភាគត្រាស់សម្ដែងទុក ភិក្ខុទាំងទឡាយ ទើបបានសម្រេចមគ្គ

ផល និង និព្វាន សេចក្តីនេះសមដូចពាក្យដែលពោលទុកដូច្នេះថា ម្នាលព្រាហ្មណ៍ ក៏ព្រះមានព្រះភាគនោះ ទ្រង់ញ៉ាំងមគ្គដែលមិនទាន់កើតឱ្យកើតទេឡើង ។ល។ ចំណែកសាវ័កទាំងទឡាយក្នុងកាលឥទឡូវនេះ មកខាងក្រោយធ្វើដំណើរទៅតាមមគ្គ ( ដែលព្រះមានព្រះភាគឱ្យកើតហើយ ) ដូច្នេះ ហើយសម្តែងថា ម្នាលអាវុសោ ព្រះមានព្រះភាគនោះ កាល ( ទ្រង់មានព្រះបំណង ) នឹងទ្រង់ជ្រាប ក៏ជ្រាបបាន កាលទ្រង់ ( មានព្រះបំណង ) នឹងឃើញ ក៏ឃើញបាន ព្រះអង្គទ្រង់មានព្រះចក្ខុ ទ្រង់មានព្រះញាណ ទ្រង់មានធមិ ទ្រង់ជាព្រហ្ម ទ្រង់ជាអ្នកប្រាប់ ទ្រង់ជាអ្នកនាំទៅកាន់ប្រយោជន៍ ទ្រង់ប្រទានអមតៈ ទ្រង់ជាធម្មសាមី ជាព្រះតថាគត ។

សូម្បីបរិយាយធមិក៏ឈ្មោះថា ជាធមិរបស់ព្រះមានព្រះភាគដែរ ព្រោះព្រះមានព្រះភាគត្រាស់សម្តែងទុក សាវ័កទាំងទឡាយ ទើបដឹងយ៉ាងនេះថា បុគ្គលអ្នកប្រាថ្នាវិវដ្តៈហើយ ឱ្យទាន ។ល។ ញ៉ាំងសមាបត្តិឱ្យកើត រមែងបាននិព្វានដែលជាអមតៈដោយលំដាប់ ។

ចំណែកនិប្បរិយាយអាមិសក៏ឈ្មោះថា ជារបស់ព្រះមានព្រះភាគដូច គ្នា ។ ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកនោះឯង ភិក្ខុទាំងទឡាយទើបបានចីវរដ៏ប្រណីត ព្រោះទ្រង់ ( ប្រារព្ធ ) រឿងពេទ្យជីវកជាតួយ៉ាង

ព្រះមានព្រះភាគព្រះអង្គឯង ក៏ត្រាស់ទុកជាគោលដូច្នេះថា ម្នាលភិក្ខុទាំង-ទឡ្បាយ តថាគតអនុញ្ញាតគហបតីចីវរ ( ចីវរដែលគហបតីប្រគេន ) ភិក្ខុរូបណាប្រាថ្នា (នឹងសមាទាន ឬ គ្រងសំពត់បង្សុកូលជាវត្ត) ក៏ចូរជាអ្នក សមាទាន និង គ្រងសំពត់បង្សុកូលជាវត្តទៅចុះ ភិក្ខុរូបណាប្រាថ្នាគហបតីចីវរ ក៏ចូរត្រេកអរគហបតីចីវរទៅចុះ ម្នាលភិក្ខុទាំងទឡ្បាយ ប៉ុន្តែតថាគតសរសើរសេចក្ដីសន្ដោសដោយចីវរ តាមមានតាមបានណា ។

ម្យ៉ាងទៀត ក្នុងកាលមុន ភិក្ខុទាំងទឡ្បាយមិនទាន់បានបិណ្ឌបាតដ៏ប្រណីត ទើបបានសរសើរដុំបាយដែលស្វែងរកដោយស្មង ដោយការត្រាច់ទៅតាមលំដាប់ច្រកល្ហកប៉ុណ្ណោះ ព្រោះព្រះមានព្រះភាគ កាលគង់នៅក្នុងក្រុងរាជគ្រឹះ បានទ្រង់អនុញ្ញាតទុកដោយព្រះអង្គឯងយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡ្បាយ តថាគតអនុញ្ញាតសង្ឃភត្ត ឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បដិបទិកភត្ត ភិក្ខុទាំងនោះបានភោជនដ៏ប្រណីត សេនាសនៈក៏មានទំនងដូចគ្នានេះដែរ សូម្បីក្នុងកាលមុន ភិក្ខុទាំងទឡ្បាយបានអាស្រ័យនៅតាមទីផ្សេង ៗ មានជាអាទិ តាមញកភ្នំ ដែលមិនបានតុបតែង និង តាមគល់ឈើ ( ម្លប់ឈើ ) ព្រោះព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកដោយព្រះអង្គឯងយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡ្បាយ តថាគតអនុញ្ញាតសេនា-

សនៈ ៥ ប្រភេទ ភិក្ខុទាំងនោះ ទើបបានសេនាសនៈទាំងនេះ គឺ វិហារ រានហាល ប្រាសាទមានកំពូល ប្រាសាទមិនមានកំពូល ផ្ទះកំពូល និង គុហា ។

ម្យ៉ាងទៀត ក្នុងកាលមុន ភិក្ខុទាំងទឡាយបានឆាន់សម៉គ្រាំដោយទឹកមូត្រធ្វើជាថ្នាំ ព្រោះព្រះមានព្រះភាគនោះឯង ដែលទ្រង់អនុញ្ញាតទុកដោយន័យមានជាអាទិយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡាយ តថាគតអនុញ្ញាតភេសជ្ជៈ ៥ យ៉ាង គឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ភិក្ខុទាំងនោះទើបបានភេសជ្ជៈផ្សេង ៗ ។

សូម្បីបរិយាយអាមិស ក៏ឈ្មោះថា ជារបស់ព្រះមានព្រះភាគដូចគ្នា ព្រោះព្រះមានព្រះភាគបានត្រាស់សម្តែងទុក សាវកទាំងទឡាយទើបដឹងយ៉ាងនេះថា អ្នកដែលប្រាថ្នាភព ដែលមានសម្បត្តិ ឱ្យទាន សមាទានសីល ។ល។ ញ៉ាំងសមាបត្តិឱ្យកើតហើយ រមែងបានបរិយាយអាមិស គឺ ទិព្វសម្បត្តិ មនុស្សសម្បត្តិតាមលំដាប់ ។

ព្រោះហេតុដែលនិប្បរិយាយធម៌ និង បរិយាយធម៌ , និប្បរិយាយ-អាមិស និង បរិយាយអាមិស ឈ្មោះថា ជារបស់ព្រះមានព្រះភាគទាំងអស់ដូច្នោះ កាលទ្រង់សម្តែងភាវៈដែលព្រះអង្គទ្រង់ជាម្ចាស់ទាំងក្នុងធម៌ និង អាមិស

នោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាធម្មទាយាទរបស់តថាគតចុះ កុំជាអាមិសទាយាទទេឡើយ អធិប្បាយថា ធម៌ទាំងពីរយ៉ាង ដែលជារបស់តថាគតឯណា អ្នកទាំងឡាយចូរជាទាយាទនៃធម៌នោះចុះ ចំណែកអាមិសនោះណា ដែលជារបស់តថាគតដូចគ្នា អ្នកទាំង-ឡាយចូរកុំជាទាយាទនៃអាមិសនោះទេឡើយ គឺ អ្នកទាំងឡាយចូរជាម្ចាស់តែចំពោះចំណែកនៃធម៌ប៉ុណ្ណោះចុះ កុំជាចំណែកនៃអាមិសទេឡើយ ព្រោះថាភិក្ខុណាបួសក្នុងសាសនារបស់ព្រះតថាគត មានបច្ច័យជាកំពូល គឺ ឃើញតែបច្ច័យ ៤ ដែលជាហេតុនាំឱ្យកើតតណ្ហា បោះបង់ចោលធុរៈក្នុងការបដិ-បត្តិធម៌សមគួរដល់ធម៌ ភិក្ខុរូបនេះ ឈ្មោះថា អាមិសទាយាទ អ្នកទាំងឡាយចូរកុំជាបុគ្គលដូច្នោះទេឡើយ ចំណែកភិក្ខុរូបណា អាស្រ័យគុណធម៌ មានភាពជាអ្នកប្រាថ្នាតិចជាដើមក្នុងបច្ច័យ ដែលព្រះមានព្រះភាគអនុញ្ញាតទុក ឱ្យពិចារណាយ៉ាងល្អិតល្អន់សិនហើយ ទើបសេព ( បរិភោគ ) មានវត្តបដិបត្តិដ៏កំពូល ( តាំងនៅ ) ក្នុងអរិយវង្ស ៤ ភិក្ខុរូបនេះឈ្មោះថា ធម្មទាយាទ អ្នកទាំងឡាយ ចូរជាភិក្ខុដូច្នោះចុះ ។

## តថាគតអនុគ្រោះសាវក

ឥឡូវនេះ ក៏ជនពួកណាបានមានសេចក្ដីត្រិះរិះដូច្នេះថា ក្នុងអនាគត

កាលនឹងមាន ឬ មិនមាន ទេហ្ន៎ ព្រះមានព្រះភាគមិនទ្រង់ព្រះបំណងឱ្យសាវកទាំងទឡាយបានលាភ ទើបត្រាស់យ៉ាងនេះ ដើម្បីនឹងទ្រង់សម្តែងដល់ជនទាំងនោះថា ព្រះតថាគតបំណងនឹងឱ្យសាវកទាំងទឡាយបានលាភដ៏ប្រណីតក្រៃលែង ( ជាងនេះ ) ទើបពោលយ៉ាងនេះ ព្រះមានព្រះភាគទើបត្រាស់ ថា អត្ថិ មេ តុម្ហេសុ ។ បេ ។ នោ អាមិសទាយាទា ដូច្នេះ ( តថាគតមានសេចក្តីអនុគ្រោះចំពោះអ្នកទាំងទឡាយ ។ល។ កុំជាអាមិស-ទាយាទ ) ។

ព្រះពុទ្ធតម្រាស់នោះ មានអត្ថាធិប្បាយដូច្នេះថា តថាគតមានសេចក្តីអនុគ្រោះ ករុណា ប្រាថ្នាប្រយោជន៍ចំពោះអ្នកទាំងទឡាយថា ហេតុដូចម្តេចហ្ន៎ ដោយឧបាយដូចម្តេចហ្ន៎ សាវកទាំងទឡាយទើបនឹងជាធម្មទាយាទ ជាម្ចាស់នៃធម៌ កុំជាអាមិសទាយាទទេឡើយ ។

បណ្តាបទទាំងនោះ បទថា តុម្ហេបិ តេន អាទិស្សា ភវេយ្យាថ មានសេចក្តីថា សូម្បីពួកអ្នកក៏គប្បីត្រូវរង្កៀសដោយភាពជាអាមិសទាយាទនោះ មិនមែនត្រូវរង្កៀសដោយភាពជាធម្មទាយាទឡើយ មានពាក្យអធិប្បាយថា អ្នកទាំងទឡាយ រមែងត្រូវគេមើលងាយ គឺ ត្រូវធ្វើ បានដល់ កំណត់ទុកផ្សេង ( ត្រូវទុកដោយឡែក ) មានន័យថា ត្រូវវិញ្ញូជនតិះដៀល ។

តិះដៀលថា យ៉ាងណា ?

តិះដៀលថា ពួកសាវករបស់ព្រះសាស្តា សុទ្ធតែជាអាមិសទាយាទ មិនជាធម្មទាយាទទេឡើយ ។

បទថា អហម្បិ តេន អាទិស្សោ ភវេយ្យំ សេចក្តីថា ទាំង តថាគត ក៏ត្រូវអ្នកផងតិះដៀលបាន ព្រោះធ្វើឱ្យអ្នកទាំងទឡាយជាអាមិស- ទាយាទនោះ មិនមែនត្រូវតិះដៀលដោយហេតុថា អ្នកទាំងទឡាយជាធម្មទាយាទ ទេ ត្រូវតិះដៀលថា យ៉ាងណា ?

ត្រូវតិះដៀលថា ពួកសាវករបស់ព្រះសាស្តា រស់នៅសុទ្ធតែជាអាមិស- ទាយាទ មិនមែនរស់នៅដោយយកធមិជាមតិកទេឡើយ ។

ពាក្យតិះដៀលនេះ ព្រះមានព្រះភាគត្រាស់ទុក ក៏ដើម្បីធ្វើឱ្យភិក្ខុ ទាំងទឡាយទាំងនោះ ក្លាយជាអ្នកទោទន់យ៉ាងក្រៃលែង ។

ក៏ក្នុងព្រះពុទ្ធតម្រាស់នេះ មានអត្ថាធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំង- ទឡាយ បើអ្នកទាំងទឡាយនឹងវង្វេងក្នុងអាមិសត្រាច់ទៅ ព្រោះការវង្វេងរបស់ ពួកអ្នកនោះ វិញ្ញូជនទាំងទឡាយក៏នឹងនាំគ្នាតិះដៀលតថាគតថា ព្រះមានព្រះ- ភាគទ្រង់ជាសព្វញ្ញូ ( ដឹងទូទៅ ) ហេតុដូម្តេចទើបមិនអាចធ្វើពួកសាវក របស់ព្រះអង្គឱ្យជាធម្មទាយាទ កុំឱ្យជាអាមិសទាយាទបានហ្ន៎ ? ប្រៀបដូច

( កាល ) សត្វលោកឃើញភិក្ខុមានមារយាទមិនសមរម្យ រមែងតិះដៀល ដល់អាចារ្យ និង ឧបជ្ឈាយ៍ថា ភិក្ខុទាំងនេះជាសទ្ធិវិហារិករបស់នរណា ? ជាអន្តេវាសិករបស់នរណា ? ម្យ៉ាងទៀត ប្រៀបដូច ( អ្នកធំ ) ឃើញ ក្មេងប្រុស ឬ ក្មេងស្រីដែលមានត្រកូល ជាអ្នកមិនល្អ មានការប្រព្រឹត្តិខុស រមែងតិះដៀលដល់មាតា.បិតាថា ក្មេងទាំងនេះជាកូនប្រុស កូនស្រីរបស់អ្នក ណា យ៉ាងណា វិញ្ញូជនទាំងទឡាយក៏នឹងតិះដៀលតថាគត ដូច្នោះដូចគ្នា គឺ នឹងតិះដៀលថា ព្រះមានព្រះភាគទ្រង់ជាសព្វញ្ញូ ហេតុដូម្តេចទើបទ្រង់មិន អាចធ្វើពួកសាវករបស់ព្រះអង្គឱ្យជាធម្មទាយាទ កុំឱ្យជាអាមិសទាយាទបាន ?

លុះទ្រង់សម្តែងទោសក្នុងការមិនព្រមធ្វើតាមព្រះពុទ្ធោវាទនេះយ៉ាងនេះ ហើយ កាលនឹងទ្រង់សម្តែងអានិសង្សក្នុងការព្រមធ្វើតាម ព្រះមានព្រះភាគ ទើបត្រាស់ថា តុម្ហេ ច មេ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អហម្បិ តេន អាទិស្សោ ភវេយ្យំ សេចក្តីថា ឧបមាដូចសត្វលោកឃើញពួកភិក្ខុកំលោះប្រព្រឹត្តវត្តបរិបូរណ៍ដល់ ដោយឧទ្ទេស និង បរិបុច្ឆា ( ការរៀន និង ការសាកសួរ ) មានអក_ ប្បកិរិយាសមរម្យ ដូចព្រះថេរៈរយវស្សា ទើបសួរថា ភិក្ខុទាំងនេះជាសទ្ធវា_ ហារិករបស់នរណា ? ជាអន្តេវាសិករបស់នរណា ? កាលមានអ្នកប្រាប់ថា

របស់អាចារ្យ និង ឧបជ្ឈាយ៍រូបឯណោះ ក៏នឹងនាំគ្នាសរសើរថា ព្រះថេរៈអាចដាស់តឿន ប្រៀនប្រដៅ អាចារ្យ និង ឧបជ្ឈាយ៍ រមែងមិនត្រូវតិះដៀល យ៉ាងណា សូម្បីតថាគតក៏ដូច្នោះដូចគ្នា គឺ ព្រោះអ្នកទាំងទឡាយជាធម្មទាយាទនោះ មិនមែនដោយហេតុដែលអ្នកទាំងទឡាយជាអាមិសទាយាទទេ សត្វលោកក៏នាំគ្នាសួរថា សាវករបស់នរណាហ្ន៎ បដិបត្តិនាលកបដិបទា បដិបត្តិតុវដកបដិបទា បដិបត្តិចន្ទូបមបដិបទា បដិបត្តិរថវិនីតបដិបទា បដិបត្តិមហាគោសិង្គសាលបដិបទា បដិបត្តិមហាសុញ្ញតាបដិបទា ជាសក្សីក្នុងអរិយវង្ស ដែលមានសេចក្តីសន្តោសក្នុងបច្ច័យ ៤ និង មានភាវនាជាទីត្រេកអរ មានចិត្តឃ្លាតឆ្ងាយអំពីសេចក្តីត្រេកអរក្នុងបច្ច័យ ប្រៀបដូចព្រះច័ន្ទដែលផុតអំពីដុំពពក កាលមានអ្នកប្រាប់ថា សាវករបស់សមណគោតម ក៏នឹងនាំគ្នាសរសើរថា ព្រះមានព្រះភាគទ្រង់ជាសព្វញ្ញូពិតហ្ន៎ ទ្រង់អាចពិតហ្ន៎ ដែលនឹងទ្រង់ណែនាំពួកសាវកឱ្យលះបង់អាមិសទាយាទបដិបទា ហើយបែរមកបំពេញវត្តបដិបត្តិរបស់អ្នកជាធម្មទាយាទ ព្រះអង្គរមែងមិនត្រូវវិញ្ញូជនទាំងទឡាយតិះដៀលយ៉ាងនេះឯង អ្នកសិក្សាគប្បីជ្រាបពាក្យអធិប្បាយក្នុងបទនេះយ៉ាងនេះ សេចក្តីល្អិតល្អន់ដ៏សេស គប្បីជ្រាបតាមន័យដែលផ្ទុយអំពីន័យដែលពោលហើយក្នុងកណ្ហបក្ខ ( ចំណែកដែលមិនល្អ ) ។

## បវារណា ៤

លុះទ្រង់សម្តែងអានិសង្សក្នុងការព្រមធ្វើតាមព្រះឱវាទនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ប្រគល់ព្រះឱវាទនោះ ព្រះមានព្រះភាគទើបត្រាស់ថា តស្មាតិហ មេ ភិក្ខវេ ។បេ។ នោ អាមិសទាយាទា ដូច្នេះ ។

ព្រះមានព្រះភាគ លុះទ្រង់ប្រគល់ពុទ្ធោវាទនេះ យ៉ាងនេះហើយឥឡូវនេះ ដើម្បីនឹងទ្រង់សរសើរពួកភិក្ខុអ្នកបំពេញវត្តបដិបត្តិរបស់អ្នកជាធម្មទាយាទនោះ ទើបមានពុទ្ធតម្រាស់ជាអាទិថា ឥធាហំ ភិក្ខវេ ដូច្នេះ ។

ពិតណាស់ ភិក្ខុទាំងទឡាយលុះបានស្តាប់ពាក្យសរសើររបស់ព្រះមានព្រះភាគហើយ ម្នាក់ ៗ រមែងនាំគ្នាបដិបត្តិដើម្បីភាពជាយ៉ាងនោះ ។

បណ្តាបទទាំងនោះ បទថា ឥធ នេះ ជានិបាត ។

បទថា ភុត្តាវី ប្រែថា សោយស្រេចហើយ អធិប្បាយថា ទ្រង់ធ្វើភត្តកិច្ចហើយ ។

បទថា បវារិតោ ប្រែថា ( ព្រះមានព្រះភាគ ) ទ្រង់ហាមភត្ត ហើយដោយការបវារណា ( ការហាម ) កាលល្មមដល់សេចក្តីត្រូវការ ហើយអធិប្បាយថា សោយរហូតល្មមដល់សេចក្តីត្រូវការហើយ ទើបទ្រង់

ហាមភោជន ឬ ទ្រង់ឆ្អែតស្កប់ស្កល់ហើយ ។

អធិប្បាយថា បវារណា ( ព្រមឱ្យដាស់តឿន ព្រមឱ្យសូម ការហាម ) មាន ៤ យ៉ាង គឺ បវារណារបស់ភិក្ខុអ្នកនៅចាំវស្សាហើយ ១ បវារណាដោយបច្ច័យ ១ បវារណាទាំងដែលមានរបស់នៅប្រាកដ ១ បវារណាកាលល្មមដល់សេចក្តីត្រូវការហើយ ១ ។

ក្នុងបណ្តាបវារណា ៤ នោះ បវារណានេះថា ម្នាលភិក្ខុទាំង-ទឡាយតថាគតអនុញ្ញាតឱ្យភិក្ខុដែលនៅចាំវស្សាហើយបវារណាគ្នាបាន រមែងដាស់តឿនដោយហេតុ ៣ យ៉ាង ដូច្នេះ ឈ្មោះថា បវារណារបស់ភិក្ខុអ្នកនៅចាំវស្សាហើយ ។

បវារណានេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ប្រាថ្នាបវា-រណា (ព្រមឱ្យសូម) (សង្ឃដោយភេសជ្ជៈរហូត ៤ ខែ និង បវា-រណានេះគឺ បវារណាដដែលទៀត លើកលែងតែបវារណាជានិច្ច ឈ្មោះ ថា បវារណាដោយបច្ច័យ ។

បវារណានេះគឺ ភិក្ខុឈ្មោះថា (ហាមភត្ត) ហើយ គឺ ការឆាន់ប្រាកដ ១ ភោជនប្រាកដ ១ អ្នកប្រគេននៅក្នុងហត្ថបាស ១ បង្អោនរបស់ចូលទៅ ១ ការហាមប្រាកដ ១ ភិក្ខុនេះឈ្មោះថា ហាម

ភត្តហើយ ឈ្មោះថាបវារណាទាំងដែលមាននៅប្រាកដ ។

បវារណានេះគឺ ទាយកអង្គាសភិក្ខុសង្ឃឱ្យឆ្អែតស្កប់ស្កល់ដោយខា-ទនីយៈ (របស់ទំពាស៊ី) និងភោជនីយៈ (របស់ឆាន់) ដោយដៃរបស់ ខ្លួន (រហូត) ឱ្យហាម (ភត្ត) ឈ្មោះថាបវារណាកាលល្មមដល់សេចក្តី ។

បទថា បវារិតោ ប្រែថា (ព្រះមានព្រះភាគ) ទ្រង់ហាមភត្ត ហើយដោយការហាមក្នុងកាលដែលព្រះអង្គឆាន់ល្មមដល់សេចក្តីត្រូវការហើយ ។

បទថា បរិបុណ្ណោ ប្រែថា ទ្រង់បរិបូរណ៍ហើយដោយភោជន ។

បទថា បរិយោសិតោ ប្រែថា មានភោជនដែលព្រះអង្គឱ្យអស់ទីបំផុតហើយ (ឆាន់ស្រេចហើយ) (ក្នុងបទថា បរិយោសិតោ នេះ) គប្បីឃើញថា លោកលុបបទខាងក្រោយ (ភោជនៅ) ចេញ អធិ-ប្បាយថា តថាគតគប្បីឆាន់បានប៉ុណ្ណា ក៏ឆាន់ប៉ុណ្ណោះ កិរិយាគឺការឆាន់របស់តថាគតដល់ទីបំផុតហើយ ។ បទថា សុហិតោ ប្រែថា ទ្រង់ឆ្អែតស្កប់ស្កល់ហើយ ទ្រង់សប្បាយហើយ ព្រោះមិនមានសេចក្តីទុក្ខ គឺការស្រេកឃ្លាន ។ បទថា យាវទត្ថោ សេចក្តីថា សេចក្តីត្រូវការដោយភោជនរបស់តថាគតមានប្រមាណប៉ុណ្ណា សេចក្តីត្រូវការនោះទាំង-អស់តថាគតបានសម្រេច (ដល់ទីបំផុត) ហើយ ។

ក៏ក្នុងពាក្យទាំងនេះ (គឺពាក្យថា ភុត្តាវី បវារិតោ បរិបុណ្ណោ បរិយោសិតោ សុហិតោ យាវទត្ថោ) ៣ ពាក្យខាងក្រោយមានសេចក្តីស្មើនឹង ៣ ពាក្យដំបូង អធិប្បាយថា ភិក្ខុមានភោជនដែលខ្លួនឱ្យដល់ទីបំផុតហើយ ឈ្មោះថាមានភោជនដែលខ្លួនឆាន់ហើយ ភិក្ខុអ្នកឆ្អែតស្កប់ស្កល់ហើយ ឈ្មោះថាហាមភត្តហើយដោយការហាមកាលល្មមដល់សេចក្តីត្រូវការហើយ ភិក្ខុអ្នកល្មមដល់សេចក្តីត្រូវការហើយ ឈ្មោះថាបរិបូរណ៍ហើយ ម្យ៉ាងទៀត ៣ ពាក្យដំបូងមានសេចក្តីស្មើនឹង ៣ ពាក្យខាងក្រោយ ។ អធិប្បាយថា ព្រោះហេតុដែលភិក្ខុឆាន់ស្រេចហើយ ដូច្នោះ ទើបឈ្មោះថា មានភោជនដែលខ្លួនឱ្យដល់ទីបំផុតហើយ ព្រោះហេតុដែលភិក្ខុហាមភត្តហើយ ដូច្នោះ ទើបឈ្មោះថាឆ្អែតស្កប់ស្កល់ហើយ ព្រោះហេតុដែលភិក្ខុបរិបូរណ៍ហើយ ដូច្នោះ ទើបឈ្មោះថាល្មមដល់សេចក្តីត្រូវការ ដោយហេតុដែលពោលមកនេះអ្នកសិក្សាគប្បីជ្រាបចុះថា ព្រះ-មានព្រះភាគទ្រង់កំណត់ (សេចក្តីនៃ) ពាក្យគ្រប់ពាក្យទុកហើយទើបត្រាស់ទុក ។

បទថា សិយា ប្រើក្នុងអត្ថថា ជាចំណែកមួយៗ និងក្នុងអត្ថថា សង្ស័យ ។

ប្រើក្នុងអត្ថថា ជាចំណែកមួយៗគឺ (ក្នុងប្រយោគដែលសម្តែងថា) បឋវីធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា (បឋវីធាតុដែលជាចំណែកខាងក្នុងក៏មាន ដែលជាចំណែកខាងក្រៅក៏មាន) ។

ប្រើក្នុងអត្ថថា សង្ស័យ គឺ (ក្នុងប្រយោគនេះថា) សិយា អញ្ញតរស្ស ភិក្ខុនោ អាបត្តិវីតិក្កមោ គង់នឹងមានភិក្ខុណាមួយកន្លងល្មើសអាបត្តិ) ក្នុងទីនេះប្រើបានទាំងពីរន័យ ។

បិណ្ឌបាតច្រើនហួសប្រមាណនោះឯង ឈ្មោះថាជារបស់នៅសល់ច្រើនជាធម្មតា ហើយជារបស់គួរចាក់ចោលជាធម្មតា ។ អធិប្បាយថាទាំងជារបស់នៅសល់ច្រើនទាំងជារបស់គួរចាក់ចោលជាធម្មតា ទើបមិនចាំបាច់ធ្វើអ្វីយ៉ាងដទៃ ។

បទនិបាតថា អថ គឺ តម្ហិ យោគ កាលេ (ប្រែថា ក្នុងកាលនោះ) ។

បទថា ជិឃច្ឆាទុព្វល្យបរេតា សេចក្តីថា ដែលសេចក្តីស្រេកឃ្លាននិងការអស់កម្លាំងគ្របសង្កត់ហើយ គឺប្រទូសរ៉ាយហើយ បានដល់ជាប់តាមហើយ ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុរូបខ្លះសូម្បីស្រេកឃ្លានមកអស់ ៨ ថ្ងៃខ្លះ

១០ ថ្ងៃខ្លះក៏នៅមិនទាន់អស់កម្លាំង នៅអាចគ្របសង្កត់សេចក្តីស្រេកឃ្លានទុកបាន តែភិក្ខុ (២ រូប) នេះមិនដូច្នោះទេ ដើម្បីសម្តែងហេតុផលដូចពោលមកហើយនេះ ព្រះមានព្រះភាគទើបត្រាស់ទុកទាំងពីរយ៉ាង (ទាំងសេចក្តីស្រេកឃ្លាន និងការអស់កម្លាំង) ។

បទថា ត្យាហំ កាត់បទជា តេ អហំ (ប្រែថា តថាគតក៏ពោលនឹងភិក្ខុពីររូបនោះ) ។

ពាក្យកំណត់សភាពដែលប្រាសចាករបស់ខៀវស្រស់

បទថា សចេ អាកង្ខថ សេចក្តីថា បើអ្នកទាំងពីរប្រាថ្នាសោត ។

បទថា អប្បហរិតេ ប្រាសចាករបស់ខៀវស្រស់ដុះទឡើងហើយ អធិប្បាយថា ក្នុងទីដែលគ្មានស្មៅស្រស់ដែលធម្មតានឹងត្រូវស្លាប់ទៅព្រោះត្រូវដុំបាយដែលធ្លាក់ទៅសង្កត់ ក្នុងទីដែលនឹងចាក់បិណ្ឌបាតទៅសូម្បីមួយរទេះ ស្មៅទាំងទឡាយក៏មិនស្លាប់អស់ ទីនោះនឹងមិនមានស្មៅសោះក៏ដោយ មានស្មៅច្រើនក៏ដោយ រមែងជាការដែលព្រះមានព្រះភាគទ្រង់កំណត់ដល់ហើយដោយបទថា អប្បហរិតេ នោះ ។ ក៏បទថា អប្បហរិតេ នោះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីមិនឱ្យភិក្ខុកន្លងល្មើសភូតគាមសិក្ខាបទ ។

បទថា អប្បមាណកេ ប្រែថា មិនមានសត្វ គឺ ក្នុងទឹកចំនួន

ច្រើនដែលគ្មានសត្វដែលនឹងត្រូវស្លាប់ព្រោះដុំបាយដែលធ្លាក់ចុះទៅ ពិត-ណាស់ កាលទឹកតិចច្របូកច្របល់ដោយការដាក់បាយចុះទៅពួកសត្វតូចៗទើបនឹងស្លាប់ (តែ) ក្នុងទីទាំងទឡាយមានស្រះធំជាដើមពួកសត្វតូចៗនឹងមិនស្លាប់ ដើម្បីអនុរក្សសត្វមានជីវិតដូចពោលមកនេះឯង ព្រះមានព្រះ-ភាគទើបត្រាស់ទុកយ៉ាងនេះ ។

បទថា ឱបិលាបេស្សាមិ ប្រែថា នឹងចាក់ចោល សេចក្ដីថា នឹងឱ្យលិចចុះ ។

បទថា តត្រេកស្ស សេចក្ដីថា ក្នុងបណ្ដាភិក្ខុពីររូបនោះ មួយ រូប (បានគិតយ៉ាងនេះថា...) តែព្រះមានព្រះភាគត្រាស់សំដៅយកភិក្ខុ រូបនោះ គឺភិក្ខុដែលតាំងចិត្តស្ដាប់ធម្មទេសនានេះហើយនឹកដល់រឿយៗ ។

## អត្ថន័យរបស់ វុត្ត ស័ព្ទ

ក្នុងពាក្យថា វុត្តំ ហោ បនេតំ មានអធិប្បាយថា វុត្ត ស័ព្ទ នេះ (ប្រើក្នុងអត្ថផ្សេងៗគ្នា) គឺ ÷

១. ប្រើក្នុងអត្ថថា កោរសក់ (ដូច) ក្នុងប្រយោគជាដើមថា មាពណកម្លោះឈ្មោះថា កាបតិកៈ កោរក្បាលហើយ ។

២. ប្រើក្នុងអត្ថថា សាបព្រោះខ្លះ (ដូច) ក្នុងប្រយោគជាដើម

ថា ពូជដែលដុះទេឡើងក្នុងសរទកាល សាបព្រោះទៅក្នុងចំការស្រែហើយ រមែងដុះទេឡើង យ៉ាងណា ។

៣. ប្រើក្នុងអត្ថថា ពោល (ដូច) ក្នុងប្រយោគជាដើមថា ពាក្យនេះព្រះមានព្រះភាគដែលជាព្រះអរហន្តត្រាស់ទុកហើយ ។

តែក្នុងទីនេះ អ្នកសិក្សាគប្បីឃើញថា ប្រើក្នុងអត្ថថា ពោល ។ ក៏ពាក្យថា វុត្តំ ខោ បនេតំ នោះមានអធិប្បាយដូច្នេះថា កថិតំ ខោ បនេតំ ប្រែថា (តែព្រះមានព្រះភាគបានត្រាស់ពាក្យនេះទុក ហើយថា...) ។

បទថា អាមិសញ្ញតរំ សេចក្តីថា អាមិសគឺបច្ច័យឯណានិមួយ បណ្តាអាមិសគឺបច្ច័យ ៤ អធិប្បាយថា អាមិសគឺបច្ច័យម្យ៉ាង ។

បទថា យទិទំ ជានិបាត (ហើយ) មានសេចក្តីដូច្នោះឯង ក្នុងគ្រប់លិង្គ វិភត្តិ និងគ្រប់វចនៈ អ្នកសិក្សាគប្បីប្រើឱ្យត្រូវអត្ថ ក្នុងលិង្គ វិភត្តិ និងវចនៈនោះៗ ។ តែក្នុងទីនេះ បទថា យទិទំ នោះ មាន អត្ថស្មើនឹង យោ ឯសោ ។ មានពាក្យអធិប្បាយទុកថា នុ៎ះណា បិណ្ឌបាតនេះក៏ជាអាមិសមួយដែរ ។

បទថា យន្នូនាហំ បានដល់ សាធុ វតាហំ ( ប្រែថា បើ

ដូច្នោះមានតែអាត្មាអញ) ។

បទថា ឯវំ សេចក្ដីថា សូម្បីឱ្យថ្ងៃនិងយប់ (កន្លងទៅ) ដូចយ៉ាងដែលបុគ្គលបណ្ដោយខណៈនេះឱ្យកន្លងទៅក្នុងកាលឥឡូវនេះ ។

បទថា វីតិនាមេយ្យ ប្រែថា គប្បី... ឱ្យអស់ទៅ គឺគប្បីឱ្យកន្លងទៅ ។

បទថា សោ តំ បិណ្ឌបាតំ សេចក្ដីថា ភិក្ខុនោះមិនឆាន់បិណ្ឌបាតនោះ បែបដែលមនុស្សលោក ព្រមទាំងទេវលោក គប្បីទទួលទុកដោយសិរសា ដែលសល់អំពីព្រះសុគត ( សោយ ) ប្រាថ្នានូវភាពជាធម្មទាយាទ ពិចារណាដល់សេចក្ដីឧបមាដូចជាបុគ្គលដែលត្រូវភ្លើងឆេះសីរសះហើយ រមែងបណ្ដោយឱ្យថ្ងៃ និង យប់នោះ កន្លងទៅ យ៉ាងនោះដោយសេចក្ដីស្រេកឃ្លាន និង ដោយការអស់កម្លាំងនោះឯង ។

## បិណ្ឌបាតដែលមិនគួរឆាន់ ៥ យ៉ាង

ក៏ក្នុងវារៈនេះថា អថ ទុតិយស្ស មានសេចក្ដីសង្ខេបដូចតទៅ នេះបើភិក្ខុនោះ កាលនឹងគិតថា បើដូច្នោះ មានតែអាត្មាអញ ។ល។ គប្បីញុំាងថ្ងៃ និង យប់ឱ្យកន្លងទៅ ក៏គប្បីគិតយ៉ាងនេះថា ការដែលបព្ជិតនឹងស្វែងរកបិណ្ឌបាតក្នុងស្រុកដែលដេរដាសដោយសត្វកាចសាហាវ គឺ

បញ្ចកាមគុណ ជាការលំបាក ដូចជាការស្វែងរកភេសជ្ជៈក្នុងព្រៃ ដែលច្រើនទៅដោយសត្វកាច តែថា បិណ្ឌបាតនេះផុតហើយដោយប្រការទាំង-ពួងអំពីទោសក្នុងការស្វែងរក ដូចពោលមកនេះ ហើយជាបិណ្ឌបាតដែលសល់អំពីព្រះសុគត ព្រោះដូច្នោះ ទើបប្រៀបដូចជាខត្តិយកុមារអ្នកជាឧភតោសុជាតិ ( មានព្រះរាជសម្ភពល្អហើយទាំង ២ ចំណែក គឺចំណែកព្រះជនក និង ចំណែកព្រះជនី ) ។

ម្យ៉ាងទៀត បិណ្ឌបាតជារបស់មិនគួរឆាន់ ព្រោះហេតុ ៥ ប្រ ការគឺ

÷

១. ជារបស់មិនគួរឆាន់ ព្រោះបុគ្គល ( អ្នកប្រគេន ) មានវត្តបដិបត្តិគួរតិះដៀល គឺជាបិណ្ឌបាតរបស់បុគ្គលអលជ្ជី ។

២. ជារបស់មិនគួរឆាន់ ព្រោះបិណ្ឌបាតមានការកើតទេឡើងមិនបរិ-សុទ្ធ គឺកើតទេឡើងមកអំពីការណែនាំរបស់នាងភិក្ខុនី និង អំពីការសរសើរដែលមិនមានពិត ( ក្នុងខ្លួន ) ។

៣. ជារបស់មិនគួរឆាន់ ដើម្បីជាការអនុគ្រោះម្ចាស់ គឺភិក្ខុម្ចាស់បិណ្ឌបាតក៏កំពុងស្រេកឃ្លាន ។

៤. ( សូម្បី ) ភិក្ខុម្ចាស់បិណ្ឌបាតនោះឆ្អែតហើយ តែបិណ្ឌបាតក៏

នៅជារបស់មិនគួរឆាន់ ដើម្បីអនុគ្រោះអន្តេវាសិកជាដើមរបស់លោកនោះឯង ( ព្រោះ ) អន្តេវាសិក ឬ អ្នកដទៃៗដែលអាស្រ័យបិណ្ឌបាតនោះនៅស្រែក ឃ្លាន ។

៥. សូម្បីអ្នកទាំងនោះឆ្អែតស្កប់ស្កល់ហើយ តែថាបិណ្ឌបាតក៏នៅជារបស់មិនគួរឆាន់ព្រោះការមិនមានសទ្ធា គឺ ម្ចាស់បិណ្ឌបាតមិនទាន់មានសទ្ធា ។

បិណ្ឌបាតនេះក៏ផុតហើយដោយបការទាំងពួងអំពីហេតុ ៥ ប្រការនោះពិតណាស់ ព្រះមានព្រះភាគទ្រង់ជាកំពូលនៃលជ្ជីបុគ្គលទាំងទឡាយ បិណ្ឌបាតមានការកើតទេឡីងដោយបរិសុទ្ធ ហើយព្រះមានព្រះភាគក៏ទ្រង់ឆ្អែតស្កប់ស្កល់ហើយ ទាំងបុគ្គលដទៃដែលសង្ឃឹមចំពោះបិណ្ឌបាតក៏មិនមាន បុគ្គលអ្នកមានសទ្ធាក្នុងលោក ព្រះមានព្រះភាគក៏ជាកំពូលនៃបុគ្គលទាំងនោះ ដូច្នេះ ហើយ ភិក្ខុនោះលោកគិតដូច្នេះហើយ ទើបឆាន់បិណ្ឌបាតនោះ ។ល។ បណ្ដោយឱ្យ ថ្ងៃ និង យប់កន្លងទៅ ។

ដោយមានហេតុផលដូចពោលមកប៉ុណ្ណេះ សូម្បីភិក្ខុណាមិនឆាន់ ( បិណ្ឌបាតដែលសល់អំពីព្រះសុគត ) តែបំពេញសមណធម៌ ភិក្ខុនោះឈ្មោះថាមិនឆាន់បិណ្ឌបាតដែលគួរឆាន់ ចំណែកភិក្ខុណាឆាន់ហើយ ( បំពេញសមណធម៌ ) ភិក្ខុនោះឈ្មោះថាឆាន់បិណ្ឌបាតដែលគួរឆាន់ ។

សេចក្តីផ្សេងគ្នាក្នុងបិណ្ឌបាតមិនមាន តែមានសេចក្តីផ្សេងគ្នាក្នុងបុគ្គល ព្រោះដូច្នោះ កាលនឹងសម្តែងសេចក្តីផ្សេងគ្នានោះ ព្រះមានព្រះភាគទើបត្រាស់ថា កិញ្ចាបិ សោ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា កិញ្ចាបិ ជានិបាត ប្រើក្នុងអត្ថថា ព្រមទទួល និង ប្រើក្នុងអត្ថថា សរសើរ ។

សួរថា ព្រមទទួលនូវអ្វី ?

ឆ្លើយថា នូវការឆាន់ដែលមិនមានទោសរបស់ភិក្ខុនោះ ។

សួរថា សរសើរនូវអ្វី ?

ឆ្លើយថា នូវការឆាន់ហើយបំពេញសមណធម៌ ។

មានពាក្យអធិប្បាយទុកដូច្នេះថា បើភិក្ខុរូបនោះឆាន់បិណ្ឌបាតដែលគួរឆាន់ហើយបំពេញកិច្ចដែលគួរបំពេញសោត កាលពោលដោយពិតហើយ ភិក្ខុដំបូងនោះឯងរបស់តថាគត សេចក្តីថា ភិក្ខុរូបដំបូងដែលជាអ្នកបដិសេធបិណ្ឌបាតនោះហើយបំពេញសមណធម៌នោះឯងរបស់តថាគត មើលដូចជាអ្នកខ្មៀវក្លាជាងក្នុងបណ្តាសាវ័កពីររូបរបស់តថាគតដែលជាអ្នកខ្មៀវក្លា ហើយដូចជាបណ្ឌិតជាងក្នុងបណ្តាសាវ័កពីររូបដែលជាបណ្ឌិតរបស់តថាគត ឈ្មោះថា ជាអ្នកគួរបូជាជាង និង គួរសរសើរជាង មានពាក្យ

អធិប្បាយទុកថា គួរបូជា និង គួរសរសើរក្រៃលែងជាងភិក្ខុទី ២ ។

## ហេតុដែលគួរបូជាជាង និង គួរសរសើរជាង

ឥឡូវនេះ កាលនឹងលើកហេតុ ( ការណៈ ) ទេឡើងមកពង្រីកសេចក្ដីនោះ ព្រះមានព្រះភាគទើបត្រាស់ពាក្យថា តំ កិស្ស ហេតុ ដូច្នេះជាដើម ។

ពាក្យនោះមានអធិប្បាយ ( បន្ថែម ) ថា ក្នុងសេចក្ដីនោះ អ្នកទាំងទឡាយគង់មាន ( សេចក្ដីសង្ស័យ ) ថា ព្រោះហេតុអ្វី ? ភិក្ខុនោះទើបជាអ្នកគួរបូជាជាងគួរសរសើរជាងរបស់ព្រះមានព្រះភាគ ។

ពាក្យឆ្លើយក៏គឺ តញ្ហិ តស្ស សេចក្ដីថា ព្រោះការហាមបិណ្ឌបាតនោះនឹងប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ។ល។ ដើម្បីប្រារព្ធសេចក្ដីព្យាយាមអស់កាលយូរសម្រាប់ភិក្ខុនោះ ។

នឹងប្រព្រឹត្តទៅយ៉ាងណា ?

គឺភិក្ខុនោះ បើសម័យតមកកើតការចង់បាន សេចក្ដីប្រាថ្នាលាមក ឬសេចក្ដីប្រាថ្នាច្រើនក្នុងបច្ច័យទាំងទឡាយទេឡើង លំដាប់នោះ ភិក្ខុ ( ដទៃ ) ពិចារណាឃើញយ៉ាងនោះ នឹងការពារលោកទុកដោយទំពក់ គឺការហាមបិណ្ឌបាតនេះថា នេះណែលោក លោកបដិសេធស្ងួម្បីដែលជា

របស់សល់អំពីព្រះសុគត ហើយក៏នៅកើតសេចក្ដីប្រាថ្នាដូច្នេះទេឡើងទាល់តែបាន នេះជាន័យក្នុងការហាម ការមិនជុសខាត់កិលេសដែលកើតទេឡើងហើយ កាលបើដូច្នេះ ការបដិសេធបិណ្ឌបាតនោះនឹងប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច សេចក្ដីសន្ដោស ( និង ) ការជុសខាត់កិលេសសម្រាប់លោក ។

ក្នុងពាក្យថា សុភរតាយ ( ដើម្បីភាពជាអ្នកដែលគេចិញ្ចឹមងាយ ) នេះ មានការពណ៌នាដូចតទៅនេះ ÷

ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះជាអ្នកចិញ្ចឹមបានដោយលំបាក ទំនុក_បម្រុង បានដោយលំបាកទាំងដល់ខ្លួនឯងទាំងដល់ឧបដ្ឋាក ( ចំណែក ) ភិក្ខុរូបខ្លះជា អ្នកចិញ្ចឹមងាយទំនុកបម្រុងបានដោយងាយទាំងដល់ខ្លួនឯងទាំងដល់ឧបដ្ឋាក ។

ប្រព្រឹត្តទៅយ៉ាងណា ?

អធិប្បាយថា ភិក្ខុណាបានអាហារដែលប្រែជាដើមហើយនៅស្វែងរកអាហារដទៃ មានអាហារដែលមានរសមិនប្រែជាដើម ចោលរបស់ដែលបានក្នុងផ្ទះនៃបុគ្គលម្នាក់ទុកក្នុងផ្ទះនៃបុគ្គលម្នាក់ទៀត ត្រាច់ចារិកទៅរហូតវេលា ( បិណ្ឌបាត ) ហើយមានបាត្រទទេត្រទឡប់ចូលវត្តដេក ភិក្ខុរូប

នេះចាត់ថាជាអ្នកចិញ្ចឹមបានដោយលំបាកសម្រាប់ខ្លួនឯង ចំណែកភិក្ខុរូបណា សូម្បីទាយកនឹងថ្វាយបាយស្រូវសាលី និងសាច់ជាដើម រហូតពេញបាត្រហើយក៏នៅតែសម្ដែងទឹកមុខមិនស្រស់បស់ និង ការមិនពេញចិត្តក្រៃលែងជាងនោះទៅទៀត កាលនឹងមើលងាយបិណ្ឌបាតនោះចំពោះមុខបុគ្គលទាំងនោះថា ពួកលោកប្រគេនរបស់អ្វី ដូច្នេះ ទើបឱ្យដល់អនុប_សម្បន្នមានសាមណេរ និង គ្រហស្ថ ( ដទៃ ) ជាដើមទៅ ( ជាការបញ្ចោះ ) ភិក្ខុរូបនេះចាត់ថាជាអ្នកដែលគេចិញ្ចឹមបានដោយលំបាកសម្រាប់ឧបដ្ឋាកទាំងទឡ្បាយ ពួកអ្នកស្រុកឃើញលោកហើយក៏នឹងនាំគ្នាចៀស (គេចមុខ ) ចេញពីចម្ងាយ ដោយនឹកតិះដៀលថា ភិក្ខុចិញ្ចឹមបានដោយលំបាក ពួកយើងមិនអាចនឹងទំនុកបម្រុងលោកបានទេ ។

ចំណែកភិក្ខុណា បានអាហារយ៉ាងណាមួយទោះជារបស់ប្រភេទប្រណីត ឬ ប្រភេទថោកទាបក៏ដោយ មានចិត្តសន្ដោសឆាន់អាហារនោះហើយត្រឡប់ទៅកាន់វត្តធ្វើការងាររបស់ខ្លួន ( តទៅ ) ភិក្ខុរូបនេះចាត់ថាជាអ្នកចិញ្ចឹមងាយសម្រាប់ខ្លួនឯង ។ ហើយភិក្ខុណាមិនមើលងាយទានរបស់អ្នកដទៃសូម្បីតិច ឬ ច្រើនប្រណីត ឬ ថោកទាបក៏ដោយ មានចិត្តត្រេកអរ ញញឹមញញែម ស្រស់បស់ ឆាន់ចំពោះមុខទាយកទាំងនោះ

ហើយទើបទៅ ភិក្ខុរូបនេះចាត់ថាជាអ្នកចិញ្ចឹមងាយសម្រាប់ឧបដ្ឋាក ពួកអ្នកស្រុកលុះឃើញភិក្ខុរូបនោះហើយម្នាក់ៗ ក៏នាំគ្នាត្រេកអរយ៉ាងក្រៃលែងថា លោកម្ចាស់របស់ពួកយើងជាអ្នកចិញ្ចឹមងាយ សន្តោស សូម្បីដោយអា–ហារបន្តិចបន្តួចៗ ពួកយើងនឹងទំនុកបម្រុងលោក លុះសម្រេចចិត្តហើយក៏នាំគ្នាទំនុកបម្រុង ក្នុងព្រឹត្តការណ៍នោះ បើសម័យតមកលោកនឹងកើតការគិតទេឡើងក្នុងទំនងជាអ្នកដែលគេចិញ្ចឹមបានដោយលំបាក ទាំងដល់ខ្លួនឯង ឬ ឧបដ្ឋាកទាំងទឡ្បាយសោត គ្រានោះភិក្ខុដទៃពិចារណាឃើញយ៉ាងនេះ ក៏នឹងជួយការពារលោកទុកដោយទំពក់គឺការបដិសេធបិណ្ឌបាតនេះថា នេះណែលោក លោកបដិសេធបិណ្ឌបាតដែលសល់អំពីព្រះសុគតហើយនៅកើតការគិតដូច្នេះទេឡើងទាល់តែបាន ។ កាលបើយ៉ាងនេះការបដិសេធបិណ្ឌបាត ក៏នឹងប្រព្រឹត្តទៅដើម្បីភាពជាអ្នកដែលគេចិញ្ចឹមបានដោយងាយសម្រាប់លោក ។

ម្យ៉ាងទៀត បើលោកនឹងកើតការខ្ជិលច្រអូសទេឡើង ភិក្ខុរូបដទៃក៏នឹងជួយការពារលោកទុកដោយទំពក់នោះដូចគ្នាថា នេះណែលោក លោកបដិសេធបិណ្ឌបាតដែលសល់អំពីព្រះសុគតហើយ គ្រានោះសូម្បីនឹងសេចក្តីស្រេកឃ្លាន និង ការអស់កម្លាំគ្របសង្កត់ហើយ ក៏នៅបំពេញសមណធមិ

បាន ( ដូចម្ដេច ) ថ្ងៃនេះទើបបែរមករកភាពខ្ជិលច្រអូសទៅវិញ កាលបើដូច្នេះ ការបដិសេធបិណ្ឌបាតនឹងប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យា-យាមសម្រាប់លោក ការបដិសេធបិណ្ឌបាតនេះរបស់ភិក្ខុនោះនឹងប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ។ល។ ដើម្បីការប្រារព្ធសេចក្ដីព្យាយាមរហូតអស់កាលយូរដូចពោលមកនេះ ។

## គុណ ៥ ប្រការ

គុណ ៥ នេះ ( សេចក្ដីប្រាថ្នាតិច សេចក្ដីសន្ដោស ការជុសខាត់កិលេស ភាពជាអ្នកដែលគេចិញ្ចឹមងាយ និងការប្រារព្ធនូវសេចក្ដីព្យា-យាម ) របស់ភិក្ខុនោះបរិបូរណ៍យ៉ាងនេះហើយក៏នឹងជួយឱ្យកថាវត្ថុ ១០ បរិបូរណ៍យ៉ាងណា ?

អធិប្បាយថា ក្នុងចំនួនគុណធម៌ទាំង ៥ នោះ កថាវត្ថុ ៣ ប្រការគឺភាពជាអ្នកប្រាថ្នាតិច សន្ដោស និងការប្រារព្ធនូវសេចក្ដីព្យាយាមដែលមានមកក្នុងព្រះបាលីនេះនោះឯង រួមចូលនឹងសល្លេខធម៌ ។ ព្រោះ ថាសល្លេខធម៌នេះ ជាឈ្មោះនៃកថាវត្ថុដូចគ្នាគ្រប់ប្រការ សមដូចព្រះ-តម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទ ក៏កថានេះនោះជាគ្រឿងជុសខាត់កិលេសយ៉ាងក្រៃលែង ស្រួលដល់ការបើកផ្សាយចិត្ត

( ចេញចាកកិលេស ) ប្រព្រឹត្តទៅដើម្បីនិព្វិទាដោយចំណែកមួយ ដើម្បីវិរាគៈ ( ការប្រាសចាកកិលេស ) ដើម្បីនិរោធៈ ( ការរំលត់កិ_លេស ) ដើម្បីឧបសមៈ ( ការស្ងប់រម្ងាប់កិលេស ) ដើម្បីអភិញ្ញា ( ការដឹងដ៏ក្រៃលែង ) ដើម្បីសម្ពោធៈ ( ការត្រាស់ដឹងដ៏ប្រពៃ ) ដើម្បីព្រះនិព្វាន ( ការរលត់ស្និទ្ធនៃកិលេស ) កថានេះនោះគឺអ្វី ? បានដល់ អប្បិច្ឆកថា ( កថាពោលដល់សេចក្ដីប្រាថ្នាតិច ) ។

សេចក្ដីពិស្ដារដូចពោលមកនេះ គុណ ៥ ប្រការបរិបូរណ៍ហើយក៏នឹងជួយឱ្យកថាវត្ថុ ១០ បរិបូរណ៍យ៉ាងនេះ ។

កថាវត្ថុ ១០ ក៏នឹងជួយឱ្យសិក្ខា ៣ បរិបូរណ៍ ។

យ៉ាងណា ?

អធិប្បាយថា ក្នុងកថាវត្ថុទាំង ១០ នោះ កថា ៤ នេះ គឺ អប្បិច្ឆកថា ( កថាពោលអំពីសេចក្ដីប្រាថ្នាតិច ) សន្តោសកថា ( កថាពោលអំពីសេចក្ដីសន្តោស ) អសំសគ្គកថា ( កថាពោលអំពីការមិនច្រឡូកច្រឡំដោយពួកគណៈ ) សីលកថា ( កថាពោលអំពីសីល ) សង្គ្រោះចូលក្នុងអធិសីលសិក្ខាប៉ុណ្ណោះ កថា ៣ នេះ គឺ បវិវេកកថា ( កថាពោលអំពីការស្ងាត់ ) វីរិយារម្ភកថា ( កថាពោលអំពីការប្រារព្ធ

នូវសេចក្តីព្យាយាម ) សមាធិកថា ( កថាពោលអំពីសមាធិ ) សង្គ្រោះចូលក្នុងអធិចិត្តសិក្ខា ៣ នេះគឺ បញ្ញាកថា ( កថាពោលអំពីបញ្ញា ) វិមុត្តិកថា ( កថាពោលអំពីវិមុត្តិ ) វិមុត្តិញាណទស្សនកថា ( កថាពោលអំពីវិមុត្តិញាណទស្សនៈ ) សង្គ្រោះចូលក្នុងអធិបញ្ញាសិក្ខា កថា_វត្ថុ ១០ បរិបូរណ៍នឹងជួយឱ្យសិក្ខា ៣ បរិបូរណ៍យ៉ាងនេះ ។ សិក្ខា ៣ បរិបូរណ៍នឹងធ្វើឱ្យគំនរនៃអសេក្ខធម៌ ៤ យ៉ាងបរិបូរណ៍ ។

យ៉ាងណា ?

អធិប្បាយថា អធិសីលសិក្ខាបរិបូរណ៍ក៏នឹងជាពួកសីលដែលជាអសេក្ខៈ អធិចិត្តសិក្ខាបរិបូរណ៍ក៏នឹងជាពួកសមាធិដែលជាអសេក្ខៈ បញ្ញាសិក្ខាបរិបូរណ៍ក៏នឹងជាពួកនៃបញ្ញាវិមុត្តិ និង វិមុត្តិញាណទស្សនៈដែលជាអសេក្ខៈ រួមសេចក្តីថា សិក្ខា ៣ បរិបូរណ៍ហើយនឹងធ្វើឱ្យពួកនៃអសេក្ខធម៌ ៥ បរិបូរណ៍យ៉ាងនេះ ។ ( ហើយ ) ពួកនៃអសេក្ខធម៌ ៥ បរិបូរណ៍ក៏នឹងធ្វើឱ្យអមតមហានិព្វានបរិបូរណ៍ ។ ប្រៀបដូចដុំពពកធំបង្កើតជាទឹកភ្លៀងធ្លាក់ស្រោចលើកំពូលភ្នំហូរចុះមកពេញញកភ្នំ ជ្រោះភ្នំ អូរ ។ ញកភ្នំ ជ្រោះភ្នំ អូរទាំងនោះពេញហើយ ក៏ហូរហៀចេញមកពេញប្រទឡាយ ប្រទឡាយពេញហើយ ក៏ហូរហៀចេញមកពេញបឹង បឹង

ពេញហើយក៏ហូរចេញមកពេញស្ទឹងតូច ស្ទឹងតូចពេញហើយ ក៏ហូរចេញមកពេញស្ទឹងធំ ស្ទឹងធំពេញហើយ ក៏ហូរចេញមកពេញសមុទ្រសាគរយ៉ាងណា គុណ ៥ ប្រការនេះរបស់ភិក្ខុនោះក៏ដូច្នោះដូចគ្នា គឺ បរិបូរណ៍ហើយក៏នឹងធ្វើឱ្យគុណធមចាប់តាំងពីកថាវត្ថុ ១០ រហូតដល់អមតនិពានឱ្យបរិបូរណ៍ ភិក្ខុនេះបដិបត្តិបដិទានៃធម្មទាយាទហើយនឹងបានជាធម្មទាយាទយ៉ាងកំពូល ដោយប្រការដូចពោលមកនេះ ព្រះមានព្រះភាគទ្រង់ឃើញប្រយោជន៍យ៉ាងនេះឯងទើបបានត្រាស់ទុកថា តំ កិស្ស ហេតុ តញ្ហិ តស្ស ភិក្ខវេ ភិក្ខុនោ ដូច្នេះជាដើម ( ប្រែថា សេចក្តីនោះព្រោះហេតុអ្វី ព្រោះនឹងប្រព្រឹត្តទៅដើម្បី... សម្រាប់ភិក្ខុនោះណាម្នាលភិក្ខុទាំង_ទឡាយ ) ។

ព្រះមានព្រះភាគលុះទ្រង់លើកហេតុដែលធ្វើឱ្យភិក្ខុនោះជាអ្នកគួរបូ_ជា និងគួរសរសើរជាងទេឡើងមកអធិប្បាយប្រកបយ៉ាងនេះហើយ ឥទឡូវនេះកាលនឹងទ្រង់គម្រោមភិក្ខុទាំងនោះដើម្បីឱ្យជាយ៉ាងនោះ ទើបត្រាស់ថា តស្មាតិហ មេ ភិក្ខវេ ដូច្នេះជាដើម ។

ត្រាស់ទុកថាយ៉ាងណា ត្រាស់ទុកថា ព្រោះហេតុដែលភិក្ខុអ្នកឆាន់បិណ្ឌបាតនោះហើយ បំពេញសមណធមិ ជាអ្នកឆ្ងាយចាកគុណធមិ

ដែលជាឫសគល់ ៥ ប្រការនេះ ចំណែកភិក្ខុអ្នកមិនឆាន់ហើយបំពេញសមណធម៌ នឹងជាអ្នកមានចំណែកនៃគុណធម៌ទាំងនេះ ដូច្នោះឯង ម្នាលភិក្ខុទាំងទឡាយ អ្នកទាំងទឡាយចូរជាធម្មទាយាទរបស់តថាគតចុះ កុំអាមិសទាយាទទេឡើយ ។

បទថា ឥទមវោច ភគវា សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ពាក្យនេះគឺ ឧបទេសនៃព្រះសូត្រថា តាំងពីខាងចុងនិទានរហូតដល់កុំជាអាមិសទាយាទ ។

បទថា ឥទំ វត្វាន សុគតោ សេចក្តីថា ហើយលុះត្រាស់ឧបទេសនៃព្រះសូត្រនេះហើយ ព្រះមានព្រះភាគទើបបានទទួលការថ្វាយព្រះនាមថា ព្រះសុគតនោះឯង ព្រោះទ្រង់ដំណើរទៅដោយបដិបទាដ៏ល្អ ។

បទថា ឧដ្ឋាយាសនា វិហារំ បវិសិ សេចក្តីថា ស្តេចក្រោកទេឡើងចាកបវរពុទ្ធាសនៈ ដែលមានអ្នកក្រាលថ្វាយទុកហើយក៏ស្តេចយាងចូលទៅកាន់ព្រះវិហារ គឺ មហាគន្ធកុដិរបស់ព្រះអង្គ ។

ហេតុដែលនាំឱ្យព្រះពុទ្ធក្រោកចាកអាសនៈយាងទៅមុន

សួរថា ក្នុងកាលបរិស័ទមិនទាន់បែកគ្នាត្រទឡប់ទៅនៅទេឡើយ ព្រោះហេតុអ្វី ( ព្រះមានព្រះភាគ ទើបក្រោកចាកពុទ្ធាសនៈចូលទៅកាន់វិហារ

ទៅ ) ?

ឆ្លើយថា ដើម្បីនឹងទ្រង់សរសើរព្រះធម៌ បានស្តាប់មកថា ព្រះពុទ្ធទាំងទឡាយកាលនឹងស្តេចក្រោកចាកអាសនៈ ចូលទៅកាន់វិហារក្នុងកាលទេសនាមិនទាន់ចប់ ក៏នឹងស្តេចចូលទៅដោយហេតុពីរប្រការ គឺ ដើម្បីនឹងទ្រង់សរសើរបុគ្គល ១ ដើម្បីនឹងទ្រង់សរសើរព្រះធម៌ ១ ។

កាលស្តេចចូលទៅដើម្បីទ្រង់សរសើរបុគ្គល និងត្រិះរិះយ៉ាងនេះថា ពួកភិក្ខុអ្នកទទួលយកធម៌រៀនយកឧទ្ទេសដែលតថាគតសម្តែងដោយដោយ-សង្ខេបហើយ តែមិនទាន់បានចំណែកឱ្យពិស្តារ និងនាំគ្នាចូលទៅព្រះអានន្ទ ឬក៏ព្រះមហាកច្ចាយនៈ អ្នកទាំងពីរនោះក៏នឹងអធិប្បាយស្របតាមព្រះញាណរបស់តថាគត តអំពីនោះ ពួកភិក្ខុអ្នកទទួលយកធ៌ នឹងត្រទឡប់មកសួរតថាគតទៀត តថាគតក៏នឹងសរសើរអ្នកទាំងពីរនោះ ចំពោះពួកភិក្ខុអ្នកទទួលយកធម៌នោះយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡាយ អានន្ទអធិប្បាយល្អហើយ កច្ចាយនៈក៏អធិប្បាយល្អហើយ សេចក្តីនេះសូម្បីអ្នកទាំងទឡាយនឹងគប្បីមកសួរតថាគតសោត តថាគតក៏នឹងអធិប្បាយសេចក្តីនុ៎ះដូច្នោះដែរ តអំពីនោះភិក្ខុទាំងទឡាយក៏នឹងកើតការគោរពចំពោះអ្នកទាំងពីរហើយនាំគ្នា-ទៅរក ។ សូម្បីអ្នកទាំងពីរ ក៏នឹងណែនាំអ្នកទាំងទឡាយទុកក្នុងអត្ថនិងធម៌

ភិក្ខុទាំងនោះដែលអ្នកទាំងពីរនោះណែនាំហើយក៏នឹងនាំគ្នាបំពេញសិក្ខា ៣ ធ្វើទីបំផុតទុក្ខបាន ។

កាលនឹងស្តេចចូលទៅដើម្បីសរសើរព្រះធមិ និងទ្រង់ព្រះតម្រិះដូចដែលបានទ្រង់ព្រះតម្រិះក្នុងទីនោះឯងថា កាលតថាគតចូលទៅកាន់វិហារហើយ ព្រះសារីបុត្រអង្គុយនៅក្នុងកណ្តាលបរិស័ទនោះឯង នឹងសម្តែងធមិតិះដៀលអាមិសទាយាទ ហើយសរសើរធម្មទាយាទនោះដូចគ្នា ទេសនានេះដែលយើងទាំងពីរសម្តែងហើយយ៉ាងនេះតាមមតិដែលប្រព្រឹត្តទៅក្នុងន័យ-តែមួយ និងជាទេសនាដ៏ប្រសើរនិងធ្ងន់ ( មានសេចក្តីសំខាន់ ) ដូចឆ័ត្រថ្ម និងដូចទូកដែលចតនៅហ្នឹងកំពង់ហើយ ព្រោះអត្ថថា ឆ្លងឱឃៈ ៤ បាន ហើយដូចរថទឹមដោយសេះអាជនេយ្យ ៤ ព្រោះអត្ថថា ជាហេតុឱ្យទៅកាន់ស្ថានសួគ៌ ។

ម្យ៉ាងទៀត ប្រៀបដូចកាលព្រះរាជាទ្រង់ចេញព្រះរាជាបញ្ញាក្នុងទីប្រជុំថា អ្នកដែលធ្វើខុសយ៉ាងនេះត្រូវពិន័យប៉ុណ្ណេះ ហើយស្តេចក្រោកព្រះរាជអាសនៈទឡើងកាន់ប្រាសាទ សេនាបតីដែលអង្គុយក្នុងទីនោះឯងនឹងរក្សាការណ៍ឱ្យប្រព្រឹត្តទៅតាមព្រះរាជបញ្ញត្តនោះយ៉ាងណា ទេសនាដែលតថាគតសម្តែងហើយក៏ដូច្នោះដូចគ្នា សារីបុត្រអង្គុយនៅក្នុងទីប្រជុំនោះឯង

នឹងសម្ដែសរសើរ ។ ទេសនាដែលតថាគត និងសារីបុត្រសម្ដែងហើយតាមមតិរបស់យើងទាំងពីរនឹងរុងរឿងហើយមានកម្លាំង ដូចព្រះអាទិត្យពេលថ្ងៃត្រង់ដូច្នោះ ។

កាលទ្រង់សរសើរធម៌ក្នុងទីនេះយ៉ាងនេះ ព្រះមានព្រះភាគទើបស្ដេចក្រោកចាកពុទ្ធាសនៈចូលទៅកាន់វិហារ ។

ម្យ៉ាងទៀត ក្នុងខណៈដូច្នេះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់បាត់ព្រះអង្គអំពីលើពុទ្ធាសនៈដែលគង់នោះឯង ស្ដេចចូលទៅកាន់វិហារដោយការយាងទៅដោយអំណាចចិត្ត ព្រោះបើព្រះមានព្រះភាគនឹងគប្បីស្ដេចយាងទៅដោយការទៅដោយព្រះកាយសោត បរិស័ទទាំងអស់ ( ក្នុងទីប្រជុំនោះ ) ក៏គង់នឹងនាំគ្នាហែហមព្រះមានព្រះភាគ ។ បរិស័ទ ( ក្នុងទីប្រជុំ ) នោះ បែកពួកម្ដងហើយ ក៏លំបាកនឹងមកជុំគ្នាបានទៀត ( ព្រោះដូច្នោះ ) ព្រះមានព្រះភាគទើបស្ដេចចូលទៅ ដោយការទៅដោយអំណាចនៃចិត្តនោះឯង ( បាត់ព្រះអង្គទៅ ) ។

## ព្រះសារីបុត្តត្ថេរសម្ដែងធម៌

លុះកាលព្រះមានព្រះភាគស្ដេចចូលទៅ ( កាន់វិហារ ) ដោយអាការយ៉ាងនោះហើយ ព្រះសារីបុត្រ ( គង់ ) នៅក្នុងទីនោះឯងប្រាថ្នា

នឹងសរសើរធម៌នោះឱ្យស្របនឹងព្រះបំណងរបស់ព្រះមានព្រះភាគ ទើបបាន ពោលពាក្យនេះ ។

បណ្ដាបទទាំងនោះ បទថា អាយស្មា ជាពាក្យហៅអ្នកដែលជាទីស្រឡាញ់ ។

ពាក្យថា សារិបុត្តោ ជានាមរបស់ព្រះថេរៈនោះ នាមនោះបាន មកអំពីចំណែកខាងមាតា មិនមែនបានមកអំពីចំណែកខាងបិតាទេ ព្រោះ ព្រះថេរៈនោះជាបុត្ររបស់ព្រាហ្មណីឈ្មោះរូបសារី ដូច្នោះ ទើបឈ្មោះថា សារីបុត្រ ។

ពាក្យថា អចិរបក្កន្តស្ស ទ្រង់ព្រះពុទ្ធដំណើរទៅមិនយូរប៉ុន្មាន ។

ក៏ក្នុងពាក្យថា អាវុសោ ភិក្ខវេ នេះ មានវិនិច្ឆ័យដូច្នេះ ព្រះ មានព្រះភាគទាំងឡាយកាលនឹងទ្រង់ហៅសាវ័ក ( របស់ព្រះអង្គ ) ក៏ នឹងទ្រង់ហៅថា ភិក្ខវេ ( ម្នាលភិក្ខុទាំងឡាយ ) ចំណែកសាវ័ក ទាំងឡាយគិតថា យើងទាំងឡាយចូរកុំស្មើនឹងព្រះពុទ្ធទាំងឡាយទឡើយ ដូច្នេះហើយ ( កាលនឹងហៅគ្នា ) ក៏ហៅថា អាវុសោ ( ប្រែថា ម្នាលអ្នកមានអាយុ ) សិនហើយ ទើបហៅថា ភិក្ខវេ ( ម្នាលភិក្ខុ ទាំងឡាយ ) ខាងក្រោយ ។ម្យ៉ាងទៀត ភិក្ខុសង្ឃដែលព្រះពុទ្ធទាំង_

ទទ្បាយត្រាស់ហៅហើយ ក៏នឹងទទួលថា ភន្តេ ( ព្រះករុណាព្រះអង្គ ) ភិក្ខុសង្ឃដែលសាវ័កទាំងទទ្បាយហៅហើយ ក៏នឹងឆ្លើយថា អាវុសោ ( ម្នាល អ្នកមានអាយុ ) ។

ពាក្យថា កិត្តាវតា ក្នុងបទថា កិត្តាវតា នុខោ អាវុសោ នេះ ជាពាក្យសម្តែងការកំណត់ ប្រែថា ដោយហេតុប៉ុន្មានយ៉ាង ? នុ អក្សរ ប្រើក្នុងអត្ថនៃពាក្យសួរ ។ ខោ អក្សរត្រឹមតែជានិបាត ។

បទថា សត្ថុ បវិវិត្តស្ស វិហរតោ សេចក្តីថា កាលព្រះសាស្តា ទ្រង់គង់នៅដោយវិវេក ៣ គឺ កាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។

វិវេកមនុសិក្ខន្តិ សេចក្តីថា មិនសិក្សានូវវិវេកទាំង ៣ សូម្បីតែ វិវេកណានីមួយ ។

បទថា អាមិសទាយាទាវ ហោន្តិ សេចក្តីថា ព្រះសារីបុត្រ សួរសេចក្តីនេះនឹងភិក្ខុទាំងទទ្បាយ ។ សូម្បីក្នុងសុក្កបក្ស ( ចំណែកដែល ល្អ ) ក៏ន័យនេះ ។ កាលព្រះថេរៈពោលយ៉ាងនេះហើយ ភិក្ខុទាំង_ ទទ្បាយប្រាថ្នានឹងស្តាប់សេចក្តីនោះទើបបានពោលថា ទូរតោបិ ខោ ដូច្នេះ ជាដើម ។

បណ្តាបទទាំងនោះ បទថា ទុរតោបិ សេចក្តីថា អំពីខាងក្រៅ

ដែនខ្លះ អំពីខាងក្រៅជនបទខ្លះ អធិប្បាយថា អំពីទីឆ្ងាយរាប់បានច្រើនរយយោជន៍ខ្លះ ។

បទថា សន្តិកេ ប្រែថា ក្នុងទីជិត ។

បទថា អញ្ញាតុំ ប្រែថា ដើម្បីដឹង គឺ ដើម្បីយល់ ។

បទថា អាយស្មន្តំយេវ សារីបុត្តំ បដិភាតុ សេចក្តីថា ចូរជានាទីរបស់ព្រះសារីបុត្រចុះ អធិប្បាយថា សូមឱ្យព្រះសារីបុត្រជួយចែក ( ពន្រ្ទីកសេចក្តី ) ឱ្យជាចំណែកនៃខ្លួនផងចុះ ។

ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះថា ការពន្រ្ទីកសេចក្តីជានាទីរបស់ព្រះសារីបុត្រ ចំណែកការស្តាប់ជានាទីរបស់ពួកខ្ញុំករុណា ពាក្យអធិប្បាយសមនឹងលក្ខណៈនៃស័ព្ទ ។ ចំណែកអាចារ្យពួកខ្លះពោលថា បទថា បដិភាតុ គឺ ទិស្សតុ ( ចូរសម្តែង ) ។ អាចារ្យមួយពួកទៀតពោលថា ឧបដ្ឋាតុ ( ចូរប្រាកដ ) ។

បទថា ធារិស្សន្តិ ( នឹងចងចាំទុក ) បានដល់ នឹងរៀន ។

លំដាប់នោះ ព្រះថេរៈប្រាថ្នានឹងសម្តែងធម៌ដល់ភិក្ខុទាំងឡាយនោះ ទើបពោលពាក្យថា តេនហិ ដូច្នេះជាដើម ។

ក្នុងពាក្យថា តេនហិ នោះ មានអធិប្បាយថា បទថា តេន

ជាតតិយាវិភត្តិ ។ ហិ អក្សរជានិបាត ។ មានពាក្យអធិប្បាយថា ព្រោះហេតុដែលអ្នកទាំងទឡាយប្រាថ្នានឹងស្តាប់ហើយប្រាប់ឱ្យជាភារៈរបស់ខ្ញុំ ដូច្នោះ សូមអ្នកទាំងទឡាយចូរស្តាប់ចុះ ។ ពួកភិក្ខុទទួលពាក្យរបស់ព្រះថេរៈហើយ ព្រោះហេតុនោះ លោកទើបពោលថា ឯវមាវុសោ ។បេ។ បច្ចស្សោសុំ ដូច្នេះ ។

លំដាប់នោះ ព្រះសារីបុត្រ កាលនឹងសម្តែងសេចក្តីដែលព្រះមានព្រះភាគទ្រង់តិះដៀលភាពជាអាមិសទាយាទ ត្រាស់ទុកហើយដោយអាការដូចគ្នានោះឯងថា សូម្បីអ្នកទាំងទឡាយក៏នឹងត្រូវតិះដៀលគ្នាដោយភាពជាអាមិសទាយាទនោះ ដូច្នេះ ដោយអាការ ៣ យ៉ាង ដល់ភិក្ខុទាំងនោះ ទើបបានពោលពាក្យនេះថា ឥធាវុសោ ។បេ។ សាវកា វិវេកំ នានុសិក្ខន្តិ ។ ដោយពាក្យត្រឹមតែប៉ុណ្ណេះ ព្រះថេរៈបានពោលទុកហើយ ថា ព្រះមានព្រះភាគកាលទ្រង់តិះដៀលបដិបទារបស់អ្នកជាអាមិសទាយាទ ឯណា សូម្បីអ្នកទាំងទឡាយក៏នឹងត្រូវតិះដៀលដោយបដិបទារបស់ជាអាមិសទាយាទនោះ ។ ហើយព្រះថេរៈបានសួរសំណួរណាដោយខ្លួនឯងថា កិត្តាវតា នុ ខោ ។បេ។ នានុសិក្ខន្តិ សេចក្តីនៃពាក្យសួរនោះបែបពិស្តារជាការដែលព្រះថេរៈបានចែកទុកល្អហើយ ។

ក៏ប៉ុន្តែថា សេចក្តីនោះមិនបានសម្តែងថា ព្រះមានព្រះភាគនឹងត្រូវតិះដៀលផងទេឡើយ ។ ព្រោះពុទ្ធតម្រាស់ដែលត្រាស់ទុកហើយថា អហម្បិ តេន អាទិស្សោ ភវិស្សាមិ ( សូម្បីតថាគតក៏នឹងត្រូវតិះដៀលដោយភាពជាអាមិសទាយាទដែរ ) ជាព្រះតម្រាស់ដែលត្រឹមត្រូវហើយរបស់ព្រះមានព្រះភាគព្រះអង្គឯង ដែលទ្រង់ប្រាថ្នានឹងអនុគ្រោះសាវ័ក មិនមែនជាពាក្យរបស់ព្រះសាវ័ក ។ សូម្បីក្នុងចំណែកល្អ ( សុក្កបក្ស ) ក៏ន័យ នេះ ក្នុងន័យនេះមានយោជនា ( ការប្រកបសេចក្តី ) លំដាប់នៃអនុសន្ធិប៉ុណ្ណោះសិន ។

ចំណែកការពង្រីកសេចក្តីក្នុងរឿងនេះ មានដូចតទៅនេះ ÷

បទថា ឥធ ប្រែថា ក្នុងសាសនានេះ ។

បទថា សត្ថុ បវិវិត្តស្ស សេចក្តីថា កាលព្រះសាស្តាទ្រង់មានសេចក្តីស្ងប់ស្ងាត់ហើយយ៉ាងពិតដោយវិវេក ៣ ។

បទថា វិវេកំ នានុសិក្ខន្តិ សេចក្តីថា មិនតាមសិក្សា គឺមិនបំពេញឱ្យបរិបូរណ៍នូវកាយវិវេក ក៏ប្រសិបបើព្រះថេរៈនឹងគប្បីពោលសម្តៅដល់វិវេកទាំង ៣ សោត ពាក្យសួរក៏គង់មិនមានអ្វីពិសេស ព្រោះថា វិវេកក្នុងពាក្យថា វិវេកំ នានុសិក្ខន្តិ នេះ ជាចំណែកនៃពាក្យព្យាករណ៍

ហើយ ព្រោះដូច្នោះ លោកទើបសម្តែងកាយវិវេកដោយបទនេះថា ( វិវេកំ នានុសិក្ខន្តិ ) សម្តែងចិត្តវិវេកដោយបទថា យេសញ្ច ធម្មានំ ហើយសម្តែងឧបធិវិវេកដោយបទថា ពាហុល្លិកា ដូច្នេះជាដើម ក្នុងន័យនេះ គប្បីជ្រាបសេចក្តីដោយសង្ខេបដូចពណ៌នាមកដូច្នេះ ។

ដោយបទថា យេសញ្ច ធម្មានំ ព្រះថេរៈពោលសំដៅយកអកុសលធម៌មានលោភៈជាដើម ដែលនឹងពោលដល់ខាងមុខដោយន័យជាដើមថា ម្នាលអាវុសោ បណ្តាអកុសលធម៌ទាំងនោះ លោភៈជាបាបធម៌ ។

បទថា នប្បជហន្តិ បានដល់ មិនលះបង់ អធិប្បាយថា មិនបំពេញឱ្យបរិបូរណ៍នូវចិត្តវិវេក ។ បទថា ពាហុល្លិកា ប្រែថា បដិបត្តិដើម្បីភាពជាអ្នកជាប់ជំពាក់ក្នុងបច្ច័យមានចីវរជាដើម ។ ភិក្ខុទាំងនោះឈ្មោះថា សាថលិកា ព្រោះរាប់អានសាសនាបែបធូរ ៗ ។

បទថា ឱក្កមនេ បុព្វង្គមា នេះ មានអធិប្បាយថា នីវរណៈ ៥ ហៅថា ឱក្កមន ព្រោះជាហេតុឱ្យធ្លាក់ទៅកាន់ទីទាប ភិក្ខុទាំងនោះចាត់ថាជាប្រធាន ( នាំ ) ដោយការធ្វើនីវរណៈ ៥ ឱ្យបរិបូរណ៍នោះ ។

បទថា បវិវេកេ គឺ បានដល់ក្នុងនិព្វាន ។

បទថា និក្ខិត្តធុរា សេចក្តីថា មានធុរៈដែលដាក់ចុះហើយ គឺ

មិនធ្វើការព្យាយាមដើម្បីសម្រេចនិព្វាននោះ ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ជាការដែលលោកពោលទុកហើយថា មិនបំពេញឧបធិវិវេកឱ្យបរិបូរណ៍ ។ ព្រះមានព្រះភាគ លុះពោលដោយមិនកំណត់ពិតប្រាកដដោយពាក្យមានប្រមាណបុណ្ណោះហើយ ឥទឡូវនេះ កាលនឹងកំណត់ទេសនាឱ្យពិតប្រាកដទើបពោលពាក្យថា តត្រាវុសោ ដូច្នេះជាដើម ។

សួរថា ព្រោះហេតុអ្វី ? កាលព្រះថេរៈពោលមិនកំណត់ពិតប្រាកដទៅយ៉ាងនេះថា សាវ័កទាំងទឡ្បាយ ( រមែងត្រូវតិះដៀល ) ដោយហេតុ ៣ ស្ថាន ភិក្ខុទាំងនោះរមែងនាំគ្នាសួរថា រឿងនោះព្រះថេរៈស្តីថាអ្នកដទៃមិនបានថា ពួកយើង ។ តែកាលព្រះថេរៈពោលពិតប្រាកដទៅយ៉ាងនេះ ថា ថេរា ( សាវ័កដែលជាថេរៈ ) នវា ( សាវ័កដែលជានវកៈ ) មជ្ឈិមា ( សាវ័កដែលមានវស្សាកណ្តាល ) ភិក្ខុទាំងនោះនាំគ្នាធ្វើ ការអើពើថា រឿងនេះព្រះថេរៈពោលចំពោះពួកយើង ។

ឆ្លើយថា ឧបមាដូចកាលពួករាជអាមាត្យសូម្បីនឹងប្រាប់ថាប្រជាជនត្រូវគ្នាធ្វើការសម្អាតថ្នល់ក្នុងក្រុង ម្នាក់ ៗនាំគ្នាសង្ស័យថា អ្នកណាត្រូវធ្វើការសម្អាត ហើយមិន ( មាននរណា ) ចុះដៃធ្វើការសម្អាត កាលវាយស្គរប្រកាសថា ប្រជាជនត្រូវធ្វើការសម្អាតទ្វារផ្ទះរបស់ខ្លួន ៗ អ្នកក្រុង

ទាំងអស់ក៏នឹងជួយធ្វើការសម្អាត និងប្រដាប់តុបតែងឱ្យស្រស់ស្អាតដោយប្រើវេលាត្រឹមតែមួយភ្លែតយ៉ាងណា ឧបមេយ្យក៏គប្បីជ្រាបដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា តត្រ បានដល់ តេសុ យោគសាវកេសុ ( បណ្ដាសាវកទាំងនោះ ) ។

ភិក្ខុទាំងទឡ្យាយដែលត្រូវហៅថាជាព្រះថេរៈ ព្រោះសម្ដៅយកអ្នកមានវស្សា ១០ ទេឡើងទៅ ។

## ឋានសព្ទប្រើក្នុងអត្ថផ្សេង ៗ

បទថា តីហិ ឋានេហិ បានដល់ ដោយហេតុ ៣ យ៉ាង ។

ក៏ឋានសព្ទនេះ ប្រើក្នុងអត្ថថា ដំណែង (ឥស្សរិយៈ ) គោល ដៅ ទីតាំង ( ឋិតិ ) ខណៈ និង ហេតុ ( ការណ៍ ) ( មានតួយ៉ាងដូចតទៅនេះ ) ÷

ឋានសព្ទ ប្រើក្នុងអត្ថថា ដំណែង ( ដូច ) ក្នុងប្រយោគជាដើមថា ក៏សក្កទេវរាជនេះធ្វើកម្មអ្វីទុកទើបបានទទួលដំណែងនេះ ) ។

ឋានសព្ទប្រើក្នុងអត្ថថា គោលដៅ ( ដូច ) ក្នុងប្រយោគជាដើមថា ជាអ្នកឆ្លាតក្នុងគោលដៅ ជាអ្នកបាញ់ទាន់ផ្លេកបន្ទោរ បាញ់មិនដាច់រយៈ ។

ឋានសព្ទប្រើក្នុងអត្ថថា ខណៈ ( ដូច ) ក្នុងប្រយោគជាដើម ថា ក៏ពាក្យនេះជាក់ច្បាស់ចំពោះព្រះមានព្រះភាគដោយខណៈ ( ដោយឆាប់រហ័ស ) ។

ឋានសព្ទប្រើក្នុងអត្ថថា ហេតុ ( ដូច ) ក្នុងប្រយោគជា ដើមថា ស្គាល់ហេតុដែលប្រព្រឹត្តបានដោយហេតុដែលប្រព្រឹត្តទៅបាន ។

តែក្នុងទីនេះប្រើក្នុងអត្ថថា ហេតុប៉ុណ្ណោះ ។ អធិប្បាយថា ហេតុហៅថាឋានៈព្រោះជាទីតាំងនៅនៃផល ដោយមានការប្រព្រឹត្តទៅទាក់ទងគ្នានឹងផលនោះ ។ ដោយហេតុទី ១ នេះ ព្រះថេរៈរមែងសម្តែងថា បទថា គារយ្ហា ក្នុងពាក្យថា ថេរា ភិក្ខូ គារយ្ហា នេះ ប្រែថា រមែងត្រូវតិះដៀល ។ ព្រះថេរៈទាំងទឡ្បាយនឹងត្រូវតិះដៀលយ៉ាងនេះថា ឈ្មោះថាជាព្រះថេរៈហើយនៅមិនទាន់ចូលទៅកាន់សេនាសនៈ ដែលនៅ ក្នុងព្រៃ គឺ ដែលស្ងាត់ក្នុងព្រៃមិនព្រមលះបង់សេនាសនៈជិតស្រុក នៅ ច្រទឡ្លុកច្រទឡំដោយពួកគណៈ មិនបំពេញកាយវិវេកសោះ ក្នុងកាលដែលនៅ ជាភិក្ខុនវកៈ និង មជ្ឈិមលោកទាំងនេះ ( ប្រព្រឹត្ត ) យ៉ាងណាមក ហើយ ? គឺព្រះថេរៈទាំងទឡ្បាយរមែងបានទទួលពាក្យនិន្ទានេះណា ម្នាល អ្នកមានអាយុ ។

សូម្បីក្នុងបទថា ទុតិយេន ( ដោយហេតុទី ២ ) នេះ ព្រះថេរៈទាំងទឡ្បាយនឹងត្រូវនិន្ទយ៉ាងនេះថា ភិក្ខុទាំងនេះសូម្បីនឹងជាព្រះថេរៈ តែក៏មិនព្រមលះបង់ធម៌ មានការលោភជាដើមដែលព្រះសាស្តាត្រាស់ឱ្យលះបង់ គង់ក្នុងទីដ៏សមគួរមួយហើយក៏មិនបានឯកគ្គតានៃចិត្តសូម្បីមួយផ្ទាត់ក្រចក ក្នុងកាលដែលនៅជាភិក្ខុនវកៈ និង មជ្ឈិម លោកទាំងនេះ ( ប្រព្រឹត្ត ) យ៉ាងណាមកហើយ ? គឺប្រះថេរទាំងទឡ្បាយបានទទួលពាក្យនិន្ទានេះណា អ្នកដ៏មានអាយុទាំងទឡ្បាយ ។ គួរធ្វើការប្រកបសេចក្តីដូចពណ៌នាយ៉ាងមកនេះ ។

សូម្បីក្នុងបទថា តតិយេន ( ដោយហេតុទី ៣ ) នេះ ព្រះថេរៈរមែងសម្តេងថា អាវុសោ ព្រះថេរៈទាំងទឡ្បាយនឹងត្រូវតិះដៀលយ៉ាងនេះថា ភិក្ខុទាំងនេះសូម្បីជាព្រះថេរៈហើយក៏ដោយ ក៏មិនញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយបច្ច័យតាមមានតាមបាន នៅតែរវល់ប្រដាប់តុបតែងចីវរ បាត្រ សេនាសនៈ និង រាងកាយដែលស្អុយ មិនព្រមបំពេញឧបធិវិវេក ក្នុងកាលដែលនៅជាភិក្ខុនវកៈ និង មជ្ឈិម លោកទាំងនេះប្រព្រឹត្តយ៉ាងណាមកហើយ ? គឺព្រះថេរៈទាំងទឡ្បាយរមែងបានទទួលពាក្យនិន្ទានេះណា ម្នាលអាវុសោទាំងទឡ្បាយ អ្នកសិក្សាគប្បីជ្រាបការប្រកបសេចក្តីដូចពណ៌នាមកនេះ ។

ក្នុងវារៈដែលជាមជ្ឈិមភិក្ខុ និង នវកភិក្ខុក៏ន័យនេះ ។

ចំណែកសេចក្តីប្លែកគ្នាមានដូចតទៅនេះ ÷

ភិក្ខុទាំងទឡាយដែលឈ្មោះថា មជ្ឈិម ព្រះថេរៈពោលសម្តៅយកភិក្ខុដែលវស្សា ៥ វស្សារហូតដល់ភិក្ខុមានវស្សាគ្រប់ ៩ វស្សា ដូច្នេះ ភិក្ខុទាំងទឡាយដែលឈ្មោះថា នវកៈ ព្រះថេរៈពោលថា បានដល់ភិក្ខុដែលមានវស្សា ៥ ចុះមកដូច្នេះ ។ ដូចយ៉ាងថា កាលនៅជាព្រះថេរៈនោះលោកពោលថាភិក្ខុទាំងទឡាយដែលជាថេរៈ ក្នុងកាលដែលនៅជានវកភិក្ខុ និង មជ្ឈិមភិក្ខុបានប្រព្រឹត្តយ៉ាងណាមកហើយយ៉ាងណា ក្នុងវេលានេះក៏ដូច្នោះ គឺភិក្ខុកណ្តាល និង ភិក្ខុថ្មីគប្បីប្រកបអធិប្បាយថា ក្នុងកាលដែលនៅជាភិក្ខុថ្មីបានប្រព្រឹត្តយ៉ាងណាមកហើយ ក្នុងកាលដែលជាថេរៈនឹងជាយ៉ាងណា ក្នុងកាលជាមជ្ឈិមភិក្ខុ និង ជាព្រះថេរៈនឹងជាយ៉ាងណា ? ហើយសេចក្តីក្នុងសុក្កបក្ស ( ចំណែកល្អ ) ក៏គប្បីជ្រាបតាមន័យដែលផ្ទុយអំពីន័យដែលពោលមកហើយក្នុងកណ្ហបក្ស ( ចំណែកមិនល្អ ) នេះ ចំណែកក្នុងទីនេះមានសេចក្តីសង្ខេបដូចទៅនេះ ÷

ម្យ៉ាងទៀត ព្រះថេរៈទាំងទឡាយរមែងជាអ្នកគួរសរសើរ គឺ រមែងបានទទួលការសរសើរដោយហេតុទី ១ នេះថា ភិក្ខុទាំងនេះ សូម្បីជា

ព្រះថេរៈ តែក៏នៅក្នុងសេនាសនៈដែលតាំងនៅក្នុងប្រៃឃ្លាតឆ្ងាយអំពីគ្នាជាយោជន៍ៗ សូម្បីកាលដែលនឹងគួរចូលទៅកាន់សេនាសនៈជិតស្រុកក៏មិនចូលទៅ សូម្បីមានរាងកាយជរាយ៉ាងនេះ ក៏នៅស៊ូទ្រាំប្រារព្ធសេចក្តីព្យាយាម ធ្វើឱ្យអ្នកប្រគេនបច្ច័យកើតសេចក្តីជ្រះថ្លា ក្នុងកាលដែលនៅជានវកភិក្ខុ និង មជ្ឈិមភិក្ខុបានជាយ៉ាងណាមកហើយ ដូច្នេះ , លោកទាំងនោះរមែងលះបង់អកុសលធម៌មានលោភៈជាដើម បំពេញចិត្តវិវេកឱ្យបរិបូរណ៍ ។

ដោយហេតុទី ២ នេះ ភិក្ខុទាំងទឡាយដែលជាថេរៈរមែងជាអ្នកគួរសរសើរ គឺ រមែងបានទទួលការសរសើរថា ភិក្ខុនេះសូម្បីជាព្រះថេរៈធំដោយវ័យដូច្នេះ ជាវេលាគួរនឹងគង់ឱ្យសទ្ធិវិហារិក និង អន្តេវាសិកចោមរោមបានហើយ ឆាន់ស្រេចហើយក៏នៅចូល ( បន្ទប់បំពេញធម៌ ) ពេលរសៀលទើបចេញមក ចូលទៅពេលរសៀលហើយពេលព្រឹកទើបចេញមក ធ្វើបរិកម្មកសិណឱ្យសមាបត្តិកើត សម្រេចមគ្គផល បំពេញចិត្តវិវេកឱ្យបរិបូរណ៍ដោយប្រការទាំងពួង ។

ដោយហេតុទី ២ នេះ ព្រះថេរៈរមែងជាអ្នកគួរសរសើរ គឺរមែងបានទទួលការសរសើរថា ក្នុងកាលដែលព្រះថេរៈគួរ ( ប្រើ ) ចីវរស្រាល

ដែលមានសម្បុរស្រស់ប្រាយដូចសំពត់ធម្មតា សំពត់ធ្វើដោយសំបកឈើ និង សំពត់ព្រៃជាដើម ព្រះមហាថេរៈនេះក៏នៅស្លៀកដណ្ដប់សំពត់បង្សុកូល ។ លោកកាន់សាសនាយ៉ាងតឹងរឹង ប្រាសចាកនីវរណៈចូលផលសមាបត្តិ បំពេញឧបធិវិវេកឱ្យបរិបូរណ៍ ( ក្នុងកាលឥឡូវនេះ នៅបដិបត្តិបានដល់កម្រិតនេះ ) ក្នុងកាលដែលនៅជានវកភិក្ខុ និង មជ្ឈិមភិក្ខុ បានជា ( បដិបត្តិយ៉ាងណាមកហើយ) ។ក្នុងខណៈដែលជាមជ្ឈិមភិក្ខុ ក៏មាន ន័យដូច្នេះ ។

សួរថា ក្នុងបទថា តត្រាវុសោ មានអនុសន្ធិ ( ការបន្តនៃរឿង ) ជាយ៉ាងណា ?

ឆ្លើយថា ព្រះសារីបុត្តត្ថេរ កាលតិះដៀលបដិបទារបស់អ្នកដែលជាអាមិសទាយាទដោយអាការ ៩ យ៉ាង ( ហើយ ) សរសើរបដិបទារបស់អ្នកជាធម្មទាយាទដោយអាការ ៩ យ៉ាង ញ៉ាំងធម្មទេសនាឱ្យចប់ទៅដោយអាការ ១៨ យ៉ាងនេះហើយ ដើម្បីនឹងសម្ដែងដល់ធម៌ដែលគួរលះ ដែលលោកបានពោលទុកយ៉ាងនេះថា ព្រះសាស្ដាត្រាស់ការលះបង់ធម៌ពួកណាទុក ធម៌ទាំងនោះ ភិក្ខុមិនទាន់បានលះបង់ ដល់ភិក្ខុទាំងនោះ ដោយសរុបថា បានដល់ ធម៌ទាំងនេះនោះ ទើបបានពោលពាក្យនេះទុកថា

តត្រាវុសោ លោភោ ច ដូច្នេះជាដើម នេះគឺអនុសន្ធិ ( ក្នុងបទពីរ នោះ ) ។ម្យ៉ាងទៀត ធម៌ទាំងទឡាយ លោកបានពោលទុកដោយអម ហើយក្នុងខាងដើមនោះឯង ។ ចំណែកអាមិស ក៏បានពោលទុកហើយ ទាំងដោយអម ទាំងដោយត្រង់ ។

ឥឡូវនេះ ដើម្បីនឹងពោលធម៌ដោយត្រង់ គឺ លោកុត្តរមគ្គ ព្រះថេរៈទើបបានពោលពាក្យនេះទុក ហើយក្នុងពាក្យនេះ ក៏មានអនុសន្ធិដូចតទៅនេះ ÷

បទថា តត្រ ជាបទសម្ដែងដល់ទេសនាដែលកន្លងមកហើយ ។ មានពាក្យអធិប្បាយថា ក្នុងទេសនាដែលព្រះមានព្រះភាគសម្ដែងទុកដោយន័យជាដើមថា កាលព្រះសាស្ដាទ្រង់នៅដោយសេចក្ដីស្ងប់ស្ងាត់ ពួកសាវកត្រឡប់ជាមិនសិក្សាតាមនូវវិវេក ( ការនៅយ៉ាងស្ងប់ស្ងាត់ ) ។ ដោយពាក្យថា លោភៈជាបាបធម៌ ទោសៈជាបាបធម៌ ព្រះថេរៈរមែងសម្ដែងថា ធម៌ទាំងពីរប្រការនេះជាបាប គឺ អាក្រក់ថោកទាប ដូច្នោះ ធម៌ទាំងនេះទើបត្រូវលះបង់ ។

ក្នុងបណ្ដាលោភៈ និង ទោសៈ ទាំងពីរនោះ លោភៈ មានលក្ខណៈចង់បាន ទោសៈ មានលក្ខណៈប្រទូសរ៉ាយចិត្ត ។

ក្នុងចំនួនលោភៈ និង ទោសៈនោះ , លោភៈ មានដល់ភិក្ខុអ្នកជាអាមិសទាយាទ ព្រោះការបានបច្ច័យទាំងឡាយ ។ ចំណែកទោសៈមានព្រោះអលាភ គឺ ត្រូវការរបស់ដែលមិនទាន់បាន ( មិនត្រូវការរបស់ដែលបានហើយ ) ឬមានព្រោះទោសៈ ( ដោយត្រង់ ) គឺ កាលមិន បាន ក៏នាំសេចក្ដីចង្អៀតចង្អល់ចិត្តមកឱ្យ ។

លោភៈមាន ព្រោះទេយ្យធម៌ ( វត្ថុសម្រាប់ធ្វើបុណ្យ ) ។ ចំណែកទោសៈមាន ព្រោះបុគ្គលដែលមិនថ្វាយ ឬ ព្រោះបុគ្គលដែលថ្វាយរបស់មិនត្រូវចិត្ត ។ ព្រោះលោភៈ ទើបធ្វើឱ្យ ( អកុសល) ធម៌ដែលមាន តណ្ហា ៩ យ៉ាង ជាមូលបរិបូរណ៍ ។ ព្រោះទោសៈ ទើបធ្វើឱ្យមច្ឆរិយៈ ៥ យ៉ាង បរិបូរណ៍ ។

ឥឡូវនេះ កាលនឹងសម្ដែងឧបាយ ដែលជាគ្រឿងលះបង់លោភៈ និង ទោសៈទាំងនោះ ព្រះសារីបុត្តត្ថេរទើបពោលថា លោភស្ស ច ទោសស្ស ច បហានាយ ដូច្នេះ ជាដើម ។ ពាក្យព្រះថេរៈនោះ មានអធិប្បាយថា ក៏វត្តបដិបត្តិជាកណ្ដាល ដើម្បីលះបង់លោភៈ ទោសៈនោះមាន ។ ពាក្យនេះ ព្រះថេរៈពោលសំដៅដល់មគ្គ ។

ព្រោះថា មគ្គ នឹងមិនចូលជិត គឺ មិនចូលទៅជិតទីបំផុតទាំង_

ពីរនេះ គឺ លោភៈក៏ជាទីបំផុត ១ , ទោសៈក៏ជាទីបំផុត ១ ផុតហើយដោយអាការទាំងពួង អំពីទីបំផុតទាំងពីរនេះ ព្រោះដូច្នោះ ទើបហៅថា មជ្ឈិមាបដិបទា ( បដិបទាជាកណ្ដាល ) ។ ដែលឈ្មោះថា មជ្ឈិមា ព្រោះនៅក្នុងរវាងទីបំផុតទាំងពីរនោះ ដែលឈ្មោះថា បដិបទា ព្រោះបុគ្គលអ្នកត្រូវការនិព្វាន គប្បីបដិបត្តិ ។

ម្យ៉ាងទៀត កាមសុខល្លិកានុយោគ ជាទីបំផុត ១ , អត្តកិលមថានុយោគ ក៏ជាទីបំផុត ១ , សស្សតទិដ្ឋិ ក៏ជាទីបំផុត ១ , ឧច្ឆេទទិដ្ឋិ ក៏ជាទីបំផុត ១ ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើឱ្យពិស្ដារតាមន័យដំបូងនោះចុះ ។

## ផលរបស់មជ្ឈិមាបដិបទា

ក៏ព្រះសារីបុត្តត្ថេររមែងសរសើរបដិបទានោះឯង ដោយពាក្យថា ចក្ខុករណី ជាដើម ព្រោះថា បដិបទានោះរមែងប្រព្រឹត្តទៅដើម្បីការឃើញសច្ចៈទាំងទឡាយ ដោយសេចក្ដីថា ជាប្រធានក្នុងការឃើញ ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខុករណី , រមែងប្រព្រឹត្តទៅដើម្បីដឹងនូវសច្ចៈទាំងទឡាយ ដោយសេចក្ដីថា ជាហេតុធ្វើឱ្យដឹងច្បាស់ ព្រោះហេតុនោះ ទើបឈ្មោះថា ញាណករណី ។

ម្យ៉ាងទៀត ដែលឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ ព្រោះធ្វើឱ្យកិលេសជាដើមស្ងប់ ឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីអភិញ្ញា ( ការដឹងដ៏ក្រៃលែង ) ព្រោះជាហេតុឱ្យឃើញថា សច្ចៈទាំងបួន ជាធម៌ដែលគួរដឹងដ៏ក្រៃលែង ។

មគ្គ ឈ្មោះថា សម្ពោធៈ ( ការត្រាស់ដឹង ) មជ្ឈិមាបដិបទា រមែងប្រព្រឹត្តទៅដើម្បីសម្ពោធៈ ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់មគ្គនោះ , ពិតណាស់ មគ្គនោះឯង រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់មគ្គ ។

ធម្មជាតិដែលឈ្មោះថា ព្រះនិព្វាន ព្រោះធ្វើកិច្ចដែលមគ្គត្រូវធ្វើតែបដិបទា លោកពោលថា ឈ្មោះថា ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះប្រព្រឹត្តទៅដើម្បីធ្វើឱ្យជាក់ច្បាស់ គឺ ធ្វើឱ្យប្រចក្សច្បាស់នូវព្រះនិព្វាន លោកទើបពោលថា ប្រព្រឹត្តទៅដើម្បីនិព្វាន ។ សេចក្ដីសំខាន់ក្នុងរឿង នេះមានប៉ុណ្ណេះ ។ ការពណ៌នាយ៉ាងដទៃក្រៅអំពីនេះនឹងធ្វើឱ្យយឺតយូរ ។

ឥឡូវនេះ ព្រះថេរៈប្រាថ្នានឹងសម្ដែងបដិបទានោះដោយសរុប ទើបសួរថា កតមា វុសោ ដូច្នេះហើយ វិសជ្ជនាដោយន័យជាដើមថា អយ_មេវ ។

បណ្ដាបទទាំងនោះ បទថា អយមេវ ( ប្រែថា នេះប៉ុណ្ណោះ ) ជាពាក្យអវធារណៈ ( ហាមពាក្យពាក្យដទៃ ) ។ ព្រះថេរៈពោលពាក្យនេះទុកដើម្បីជាការបដិសេធមគ្គ ( ផ្លូវទៅកាន់និព្វាន ) ដទៃ ដើម្បីនឹងបានសម្ដែងថា មគ្គនោះជារបស់មានទូទៅដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះពុទ្ធ ។ សេចក្ដីនេះ សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា ÷

មគ្គ ( ផ្លូវ ) នេះប៉ុណ្ណោះ មិនមាន
មគ្គដទៃ ដើម្បីសេចក្ដីបរិសុទ្ធនៃទស្សនៈ ។

## អត្ថរបស់មគ្គ

មគ្គនេះនោះ ឈ្មោះថា អរិយៈ ព្រោះធ្វើកិលេសឱ្យនៅឆ្ងាយខ្លះ ព្រោះប្រព្រឹត្តទៅដើម្បីកម្ចាត់បង់សត្រូវ ( កិលេស ) ខ្លះ ព្រោះជាមគ្គដែលព្រះអរិយៈសម្ដែងទុកខ្លះ ព្រោះប្រព្រឹត្តទៅដើម្បីឱ្យបានភាពជាព្រះ-អរិយៈខ្លះ ។ មគ្គ ដែលឈ្មោះថា មានអង្គ ៨ ព្រោះប្រកបដោយអង្គ ៨ ហើយនឹងផុតអំពីអង្គក៏ទេ ប្រៀបដូចជាគ្រឿងដូរ្យតន្ត្រីប្រកបដោយអង្គ ៥ ជាដើមដូច្នោះ ។

ដែលឈ្មោះថា មគ្គ ព្រោះអត្ថថា សម្លាប់កិលេស ព្រោះអត្ថថា

ដំណើរទៅកាន់ព្រះនិព្វាន ព្រោះអត្ថថា ដែលបុគ្គលអ្នកត្រូវការនិព្វានគប្បីស្វែងរក ព្រោះអត្ថថា ដែលបុគ្គលអ្នកត្រូវការនិព្វានទាំងនោះដំណើរទៅ គឺបដិបត្តិ ។

បទថា សេយ្យថីទំ ជានិបាត ។ និបាតថា សេយ្យថីទំ នោះមានអត្ថស្មើនឹង កតមោ សោ ( ប្រែថា មគ្គនុ៎ះ គឺ ធ្វើខ្លះ ) ឬមានអត្ថស្មើនឹង កតមានិ តានិ អដ្ឋង្គានិ ( ប្រែថា អង្គ ៨ នុ៎ះ គឺអ្វីខ្លះ ) ។

ពិតណាស់ អង្គនីមួយ ៗ ក៏គឺ មគ្គនោះឯង ។ សមដូចពាក្យដែលលោកពោលទុកថា សម្មាទិដ្ឋិ ជាមគ្គផង ជាហេតុផង សូម្បីបុរាណាចារ្យក៏ពោលទុកថា សម្មាទិដ្ឋិ ជាផ្លូវ ជាហេតុ ឱ្យឃើញ , សម្មាសង្កប្ប ជាផ្លូវ ជាហេតុ ឱ្យកប់ចិត្ត ( ក្នុងអារម្មណ៍ ) ។ល។ សម្មាសមាធិ ជាផ្លូវ ជាហេតុ មិនឱ្យរាយមាយ ។

ម្យ៉ាងទៀត ក្នុងបណ្តាអង្គមគ្គទាំងទឡាយ មានសម្មាទិដ្ឋិជាដើមនេះ សម្មាទិដ្ឋិ មានការឃើញដ៏ប្រពៃជាលក្ខណៈ , សម្មាសង្កប្ប មានការលើកចិត្តទេឡីងកាន់អារម្មណ៍ដោយប្រពៃជាលក្ខណៈ , សម្មាវាចា មានការហួងហែងដោយប្រពៃជាលក្ខណៈ , សម្មាកម្មន្ត មានការតាំងទេឡីងព្រមដោយធម៌ជាលក្ខណៈ , សម្មាអាជីវ មានការផ្ទូរផង់ដោយប្រពៃជា

លក្ខណៈ , សម្មាវាយាម មានការផ្គង ( ចិត្ត ) ដោយប្រពៃជាលក្ខណៈ , សម្មាសតិ មានការប្រាកដដោយប្រពៃជាលក្ខណៈ , សម្មាសមាធិ មានការតាំងមាំនៃចិត្តជាលក្ខណៈ សូម្បីវិគ្រោះមគ្គទាំងនោះ គប្បីជ្រាបដោយន័យនោះដូចគ្នាថា ដែលឈ្មោះថា សម្មាទិដ្ឋិ ព្រោះឃើញដោយប្រពៃ ។

ក្នុងចំនួនមគ្គទាំងនោះ ÷

១ សម្មាទិដ្ឋិ កាលកើតទេឡើងរមែងលះបង់មិច្ឆាទិដ្ឋិ កិលេសដែលជាសត្រូវចំពោះសម្មាទិដ្ឋិនោះ និង អវិជ្ជាបាន ធ្វើនិព្វានឱ្យជាអារម្មណ៍ ឃើញសម្បយុត្តធម៌ទាំងទឡាយ ហើយឃើញសម្បយុត្តធម៌ទាំងនោះដោយមិនស្រពិចស្រពិល មិនមែនឃើញដោយភាពជាអារម្មណ៍ ព្រោះដូច្នោះទើបហៅថា សម្មាទិដ្ឋិ ។

២ សម្មាសង្កប្ប កាលកើតទេឡើងរមែងលះបង់មិច្ឆាសង្កប្ប និង កិលេសដែលជាសត្រូវចំពោះសម្មសង្កប្បនោះបាន ធ្វើនិព្វានឱ្យជាអារម្មណ៍ និង តំកល់សម្បយុត្តធម៌ទុកក្នុងចិត្តដោយប្រពៃ ព្រោះដូច្នោះ ទើបឈ្មោះ ថា សម្មាសង្កប្ប ។

៣ សម្មាវាចា កាលកើតទេឡើងរមែងលះបង់មិច្ឆាវាចា និង កិលេសដែលជាសត្រូវចំពោះសម្មាវាចានោះ បានធ្វើនិព្វានឱ្យជាអារម្មណ៍ រក្សា

សម្បយុត្តធម៌ទាំងឡាយដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា សម្មា-វាចា ។

៤ សម្មាកម្មន្ត កាលកើតឡើងរមែងលះបង់មិច្ឆាកម្មន្ត និង កិ-លេសដែលជាសត្រូវចំពោះសម្មាកម្មន្តនោះបាន ធ្វើនិព្វានឱ្យជាអារម្មណ៍ ហើយញ៉ាំងសម្បយុត្តធម៌ឱ្យតាំងឡើងដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា សម្មាកម្មន្ត ។

៥ សម្មាអាជីវ កាលកើតឡើងរមែងលះបង់មិច្ឆាអាជីវ និង កិ-លេសដែលជាសត្រូវចំពោះសម្មាអាជីវនោះបាន ធ្វើនិព្វានឱ្យជាអារម្មណ៍ ហើយរមែងញ៉ាំងសម្បយុត្តធម៌ឱ្យផូរផង់ដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា សម្មាអាជីវ ។

៦ សម្មាវាយាម កាលកើតឡើងរមែងលះបង់មិច្ឆាវាយាម និង កិលេសដែលជាសត្រូវចំពោះសម្មាវាយាមនោះ និង សេចក្ដីខ្ជិលច្រអូសបាន ធ្វើនិព្វានឱ្យជាអារម្មណ៍ ហើយរមែងទទួលទុកដោយប្រពៃនូវសម្បយុត្តធម៌ទាំងឡាយ ព្រោះដូច្នោះ ទើបហៅថា សម្មាវាយាម ។

៧ សម្មាសតិ កាលកើតឡើង រមែងលះបង់មិច្ឆាសតិ និង កិលេសដែលជាសត្រូវចំពោះសម្មាសតិនោះ បានធ្វើនិព្វានឱ្យជាអារម្មណ៍

ហើយរមែងញុំាងសម្បយុត្តធម៌ឱ្យប្រាកដដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា សម្មាសតិ ។

៨ សម្មាសមាធិ កាលកើតទេឡើងរមែងលះបង់មិច្ឆាសមាធិ និងកិលេសដែលជាសត្រូវចំពោះសម្មាសមាធិនោះ និង ការរាយមាយនោះបានធ្វើនិព្វានឱ្យជាអារម្មណ៍ ហើយរមែងធ្វើសម្បយុត្តធម៌ឱ្យតាំងមាំដោយប្រពៃ ព្រោះដូច្នោះ ទើបហៅថា សម្មាសមាធិ ។

ឥឡូវនេះ ព្រះថេរៈកាលនឹងពោលបដិបទានោះឯងទៀត ទើបពោលថា អយំ ខោ សា អាវុសោ ដូច្នេះជាដើម ពាក្យដែលពោល នោះមានអធិប្បាយថា មគ្គមានអង្គ ៨ នេះ ដែលព្រះមានព្រះភាគត្រាស់រួមលោកុត្តរមគ្គទាំង ៤ ចូលជាមួយគ្នាថា ម្នាលអាវុសោ មគ្គមាន អង្គ ៨ នេះឯង គឺ មជ្ឈិមាបដិបទានោះ រមែងប្រព្រឹត្តទៅព្រម ។ល។ ដើម្បីនិព្វាន ។

## ធម៌ដែលត្រូវលះ ពួកដទៃទៀត

លុះសម្តែងលោភៈ ទោសៈ និង ឧបាយជាគ្រឿងលះបង់លោភៈទោសៈនោះ ក្នុងចំនួនធម៌ទាំងឡាយដែលត្រូវលះបង់យ៉ាងនេះហើយ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងធម៌ដែលត្រូវលះបង់ដទៃទៀត និង

ឧបាយជាគ្រឿងលះបង់ធម៌ទាំងនោះ ទើបពោលពាក្យថា តត្រាវុសោ កោធោ ច ដូច្នេះជាដើម បណ្តាធម៌ដែលត្រូវលះបង់ទាំងនោះ ។

១ កោធោ មានលក្ខណៈ គឺ ការក្តៅក្រហាយ ឬ ការប្រទូ-ស្សរ៉ាយ មានកិច្ច គឺ ចងអាឃាត ( ហើយ ) ផលដែលប្រាកដចេញ មក គឺ ការប្រទូស្សរ៉ាយ ។

២ ឧបនាហ មានលក្ខណៈ គឺ ការចងសេចក្តីក្រោធ មាននាទី គឺ មិនព្រមរលាស់ចោលពីការចងពៀរ ( ហើយ ) ផលដែលប្រាកដ ចេញមក គឺ ក្រោធជាប់តគ្នារឿយ ៗ សមដូចពាក្យបុរាណាចារ្យពោល ទុកយ៉ាងនេះថា ក្រោធកើតមុន ឧបនាហទើបកើតជាខាងក្រោយជាដើម។

៣ មក្ខ មានលក្ខណៈ គឺ លប់គុណអ្នកដទៃ មានកិច្ច គឺ ធ្វើគុណរបស់អ្នកដទៃឱ្យវិនាស ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការបិទបាំងគុណរបស់អ្នកដទៃនោះ ។

៤ បទឡាស មានលក្ខណៈ គឺ ការចាប់យកជាគូប្រណាំងប្រជែង ( ការវ៉ៃឫក្សស្មើ ) មាននាទី គឺ ការធ្វើគុណរបស់ខ្លួនឱ្យស្មើនឹងគុណ របស់អ្នកដទៃ ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការប្រាកដ ដោយការពេញចិត្តប្រមាណ ( វ៉ៃតម្លៃ ) ប្រៀបគុណរបស់អ្នកដទៃ ។

៥ ឥស្សា មានលក្ខណៈ គឺ ការឈ្នានីសចំពោះសម្បត្តិអ្នកដទៃ ឬក៏ទ្រាំមិនបានចំពោះសម្បត្តិអ្នកដទៃនោះ មាននាទី គឺ ការមិនត្រេកអរនឹងសម្បត្តិរបស់អ្នកដទៃនោះ ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការបែរមុខចេញអំពីសម្បត្តិរបស់អ្នកដទៃ ។

៦ មច្ឆេរ មានលក្ខណៈ គឺ ការលាក់លៀមសម្បត្តិរបស់ខ្លួន មាននាទី គឺ ការមិនសប្បាយចិត្ត ក្នុងកាលសម្បត្តិរបស់ខ្លួនមានអ្នកដទៃរួមប្រើប្រាសជាមួយ ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការចង្អៀតចង្អល់ចិត្ត ។

៧ មាយា មានលក្ខណៈ គឺ ការបិទបាំងបាបដែលខ្លួនឯងធ្វើ ហើយ មាននាទី គឺ លាក់លៀមបាបដែលខ្លួនឯងធ្វើហើយនោះ ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការបិទបាំងបាបដែលខ្លួនឯងធ្វើនោះ ។

៨ សាថេយ្យ មានលក្ខណៈ គឺ ការពេញចិត្តបើកបង្ហាញគុណដែលខ្លួនឯងមិនមាន មាននាទី គឺ ការប្រមូលមកនូវគុណដែលខ្លួនឯងមិនមានទាំងនោះ ( ហើយ ) ផលដែលប្រាកដចេញមក គឺ ធ្វើគុណដែលខ្លួនឯងមិនមានទាំងនោះឱ្យប្រាកដចេញមក ស្ទើរដោយអាការតាមផ្លូវកាយ ។

៩ ថម្ភ មានលក្ខណៈ គឺ ការដែលចិត្តរឹងត្អឹង មាននាទី គឺ

ព្រឹត្តិការដែលមិនកោតក្រែង ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការមិនទន់ភ្លន់ ។

១០ សារម្ភ មានលក្ខណៈ គឺ ការធ្វើល្អឱ្យលើគេ មាននាទី គឺ សម្តែងខ្លួនឱ្យជាសត្រូវនឹងអ្នកដទៃ ( ហើយ ) ផលដែលប្រាដកចេញមក គឺ ការមិនមានសេចក្តីគោរព ។

១១ មានះ មានលក្ខណៈ គឺ កាក្រេអើត មាននាទី គឺ ការប្រកាន់ខ្លួនថា ជាយើង ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការក្រអើតក្រទម ។

១២ អតិមានះ មានលក្ខណៈ គឺ មានការក្រអើតក្រទមយ៉ាងក្រៃលែង មាននាទី គឺ ការប្រកាន់ខ្លួនថា ជាយើងខ្លាំង ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការក្រអើតក្រទមក្រៃលែង ។

១៣ មទ មានលក្ខណៈ គឺ ការស្រវឹង មាននាទី គឺ ការប្រកាន់ខ្លួនដោយការស្រវឹង ( ហើយ ) ផលដែលប្រាកដចេញមក គឺ ការជាប់ជំពាក់ចិត្ត ។

១៤ បមាទ មានលក្ខណៈ គឺ ការបណ្តោយចិត្តឱ្យប្រព្រឹត្តទៅក្នុងបញ្ចកាមគុណ មាននាទី គឺ ការដាស់តឿនឱ្យបណ្តោយចិត្តក្រៃលែង

ទេឡើង ( ហើយ) ផលដែលប្រាកដចេញមក គឺ ការមិនមានសតិ ។

អ្នកសិក្សាគប្បីជ្រាបដល់លក្ខណៈជាដើម នៃធម៌ទាំងនេះដូចពោលមកនេះចុះ ដែលពោលមកនេះជាសេចក្តីសង្ខេបក្នុងទីនេះ ចំណែកសេចក្តីពិស្តារអ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងគម្ពីរវិភង្គនោះឯងថា តត្ថ កតមោ កោធោ ដូច្នេះជាដើម ។

## គួរយ៉ាងព្រឹត្តិកម្មដែលកើតអំពីបាបធម៌ទាំងនោះ

ម្យ៉ាងទៀត ក្នុងធម៌ដែលត្រូវលះបង់ទាំងនេះ គប្បីជ្រាបសេចក្តីដោយពិសេសទៅទៀត ដូចតទៅនេះ ÷

ភិក្ខុដែលជាអាមិសទាយាទ រមែងក្រោធខឹងដល់អ្នកដទៃដែលបានលាភ ព្រោះខ្លួនឯងមិនបាន សេចក្តីក្រោធដែលកើតទេឡើងម្តងរបស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ឈ្មោះថា ក្រោធតែម្យ៉ាង សេចក្តីក្រោធដែលកើតទេឡើងច្រើនជាងមួយដងទេឡើងទៅ ឈ្មោះថា ឧបនាហៈ ។

ភិក្ខុដែលជាអាមិសទាយាទនោះឯង កាលក្រោធហើយផង និងចងសេចក្តីក្រោធទុកផង រមែងលប់គុណរបស់អ្នកដទៃដែលមានលាភ និងប្រកាន់យកជាគូប្រណាំងប្រជែង ហើយថា សូម្បីយើងក៏ត្រូវជាមនុស្សដូច្នោះ ឱ្យទាល់តែបាន នេះជាមក្ខៈ ( ការលប់គុណ ) និង បទឡាសៈ

( វៃប្ញកស្មើ ) របស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ។

ភិក្ខុអ្នកជាអាមិសទាយាទនោះ មានប្រក្រតីលប់គុណ មានប្រក្រតីវៃប្ញកស្មើ ដូចពោលមកនេះ រមែងឈ្នានីស រមែងប្រទូសរ៉ាយ ចំពោះលាភ និង សក្ការៈជាដើម របស់អ្នកមានលាភនោះថា ភិក្ខុនេះ នឹងមានប្រយោជន៍ដោយរបស់នេះ នេះជាឥស្សា ( ការឈ្នានីស ) ។

ក៏ប្រសិនបើលោកមានសម្បត្តិយ៉ាងណាមួយ រមែងទ្រាំមិនបានក្នុងកាលដែលសម្បត្តិនោះ មានអ្នកដទៃរួមប្រើប្រាស នេះជាមច្ឆេរៈ ( សេចក្ដីកំណាញ់ ) របស់ភិក្ខុដែលជាអាមិសទាយាទនោះ ។

ក៏ព្រោះលាភជាហេតុពិត ៗ លោករមែងបិទបាំងទោសដែលនៅមាន នេះជាមាយារបស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ។

លោករមែងអួតគុណដែលខ្លួនមិនមាន នេះជាសាថេយ្យៈ ( ការអួតអាង ) របស់ភិក្ខុដែលជាអាមិសទាយាទនោះ ។

លោកបដិបត្តិយ៉ាងនេះហើយ ប្រសិនបើបានលាភតាមបំណង រមែងជាអ្នករឹងតឹងមានចិត្តមិនទន់ភ្លន់ព្រោះលាភនោះ ជាអ្នកដែលនរណាៗ មិនអាចទូន្មានបានថា លោកមិនគួរធ្វើកម្មនេះ យ៉ាងនេះ នេះជាថម្ភៈ ( ការរឹងតឹង ) របស់លោក ។

តែប្រសិនបើមាននរណាពោលអ្វីនឹងលោកថា លោកមិនគួរធ្វើកម្មនេះយ៉ានេះ លោកជាអ្នកមានចិត្តផ្តើមពោលពាក្យនោះ ធ្វើមុខក្រញូវជ្រួញចិញ្ចើម និយាយគំរាមថា លោកជាអ្វីនឹងខ្ញុំ នេះជាសារម្ភៈ ( ការប្រណាំងប្រជែងវាសនា) របស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ។

តអំពីនោះទៅ ព្រោះថម្ភៈ ( ការចចេសមុខរឹង ) លោកនឹងសម្គាល់ខ្លួនថា យើងនេះឯង ល្អជាងអ្នកដទៃ ជាអ្នកប្រកាន់ខ្លួនព្រោះសារម្ភៈ លោកក៏ត្រទឡប់មើលងាយអ្នកដទៃថា ពួកនេះជាអ្នកណា ជាអ្នកប្រកាន់ខ្លួន នេះជាមានះ ( ការប្រកាន់ខ្លួន ) និង អតិមានះ ( ការមើលងាយគេ ) របស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ។

ព្រោះមានះ និង អតិមានះទាំងនេះ លោករមែងកើតការស្រវឹងច្រើនបែប មានការស្រវឹងក្នុងជាតិ ( កំណើតត្រកូល ) ជាដើម លោកស្រវឹងហើយ រមែងប្រមាទ ( វង្វេងភ្លេចសតិ ) ក្នុងវត្ថុទាំងឡាយ ចែកប្រភេទចេញ មានកាមគុណជាដើម នេះជាមទៈ ( ការស្រវឹង ) និងបមាទៈ ( ការធ្វេសប្រហែស) របស់ភិក្ខុអ្នកជាអាមិសទាយាទនោះ ។

រួមសេចក្តីថា ដោយហេតុដូចពោលមកនេះ លោករមែងមិនផុតអំពីភាពជាអាមិសទាយាទទៅបាន អ្នកសិក្សាគប្បីជ្រាបធម៌ដែលត្រូវលះ

ក្នុងភាពជាអាមិសទាយាទ ដោយធម៌ដែលជាបាបទាំងនេះ និង ដោយធម៌យ៉ាងដទៃបែបនេះ យ៉ាងនេះសិន ចំណែកឧបាយដែលជាហេតុលះបង់ ពោលដោយបាលី និង សេចក្ដីហើយ ក៏មិនមានអ្វីពិសេសទេឡើយ ក្នុងធម៌គ្រប់ប្រការ ។

## សេចក្ដីផ្សេងគ្នា លំដាប់ និង វិធីនៃការចម្រើន

តែដើម្បីការជាក់ច្បាស់នៃការប្រមូលសេចក្ដីដឹង អ្នកសិក្សាគួរជ្រាបសេចក្ដីផ្សេងគ្នា លំដាប់ និង វិធីនៃការចម្រើន ក្នុងឧបាយជាគ្រឿងលះបង់ដូចតទៅនេះ ÷

បណ្ដាសេចក្ដីផ្សេងគ្នា លំដាប់ និង វិធីនៃការចម្រើនទាំងនោះ នឹងអធិប្បាយដល់សេចក្ដីផ្សេងគ្នាមុន ក៏មជ្ឈិមាបដិបទានេះ បានដល់ មគ្គ គ្រាខ្លះក៏មានអង្គ ៨ គ្រាខ្លះក៏មានអង្គ ៧ ព្រោះថា មគ្គនេះ កាលកើតទេឡើងដោយអំណាចបឋមឈានដែលជាលោកុត្តរ រមែងមានអង្គ ៨ , កាលកើតទេឡើងដោយអំណាចឈានដ៏សេស រមែងមានអង្គ ៧ តែក្នុងទីនេះជាការអធិប្បាយសេចក្ដីថ្នាក់ខ្ពស់បំផុត លោកទើពោលថា មគ្គមានអង្គ ៨ ។ ក៏អង្គមគ្គ ដែលលើសអំពីនោះមិនមាន អ្នកសិក្សាគប្បីជ្រាបសេចក្ដីផ្សេងគ្នាក្នុងទីនេះប៉ុណ្ណេះ ។ ក៏ព្រោះហេតុដែលសម្មាទិដ្ឋិប្រសើរជាទីបំផុតក្នុង

បណ្ដាកុសលទាំងពួង ដូចដែលលោកពោលទុកថា បណ្ឌិតទាំងទឡាយពោលថា បញ្ញានេះឯង ប្រសើរជាទីបំផុត ។ ហើយសម្មាទិដ្ឋិនោះ ក៏ជាប្រធាន ( អ្នកដឹកនាំ ) ក្នុងវារៈនៃការធ្វើកុសល ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ក៏សម្មាទិដ្ឋិ ជាប្រធានយ៉ាងណា ? គឺ ( ជាប្រធាន ព្រោះ ) ដឹងច្បាស់នូវសម្មាទិដ្ឋិថា ជាសម្មាទិដ្ឋិ នូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ ដូច្នេះ ហើយសម្ដែងថា ម្នាលភិក្ខុទាំងទឡាយ វិជ្ជា ជាប្រធាននៃកុសលទាំងទឡាយ ក្នុងសមាបត្តិ ដូច្នេះ ។

ម្យ៉ាងទៀត អង្គ ( មគ្គ ) ដ៏សេសទាំងទឡាយកើតទឡើង ក៏ព្រោះមានសម្មាទិដ្ឋិនោះកើតមុន ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា អ្នកមានសម្មាទិដ្ឋិ រមែងមានសម្មាសង្កប្បៈ ។ល។ និង អ្នកដែលមានសម្មា_ សតិ រមែងមានសម្មាសមាធិ ។ ដូច្នោះ អង្គទាំងទឡាយនេះ ទើបលោកពោលទុកហើយដោយលំដាប់ដូច្នេះ អ្នកសិក្សាគប្បីជ្រាបលំដាប់ ( នៃអង្គមគ្គ ) ក្នុងឧបាយដែលជាគ្រឿងលះបង់នេះ យ៉ាងនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វិធីនៃការចម្រើន ( សមថៈ និងវិបស្សនា ) តទៅ ។ ព្រះយោគាវចរខ្លះ ចម្រើនវិបស្សនាមានសមថៈនាំមុខ បុគ្គលខ្លះ ចម្រើនសមថៈមានវិបស្សនានាំមុខ ចម្រើនយ៉ាងណា ?

( ចម្រើនយ៉ាងនេះ គឺ ) ព្រះយោគាវចររូបខ្លះក្នុងសាសនានេះ ធ្វើសមថ-ឧបចារសមាធិ ឬ អប្បនាសមាធិឱ្យកើតទេឡើង នេះជាសមថៈ ( តមក ) ព្រះយោគាវចរនោះ ពិចារណាឃើញនូវសមាធិនោះ និង ធម៌ដែលសម្បយុត្ត ជាមួយនឹងសមាធិនោះ ដោយភាវៈទាំងទឡាយ មានភាពជារបស់មិនទៀង ជាដើម នេះជាវិបស្សនា យ៉ាងនេះ សមថៈកើតមុន វិបស្សនាកើតក្រោយ យ៉ាងនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ចម្រើនវិបស្សនា មានសមថៈនាំមុខ ។

កាលលោកចម្រើនវិបស្សនា មានសមថៈនាំមុខ មគ្គរមែងកើត លោកសេព ចម្រើន ធ្វើឱ្យច្រើននូវមគ្គនោះ រមែងលះបង់សំយោជនៈ ទាំងនោះបាន អនុស័យទាំងទឡាយរមែងអស់ទៅ យ៉ាងនេះ ព្រះយោគា-វចរ ឈ្មោះថា ចម្រើនវិបស្សនាបែបមានសមថៈនាំមុខ ។

ប៉ុន្តែថា ព្រះយោគាវចរក្នុងសាសនានេះ មិនទាន់ញ៉ាំងសមថៈមាន ប្រការដូចពោលហើយឱ្យកើតទេឡើង ពិចារណាឧបាទានក្ខន្ធ ៥ ដោយភាវៈ មានភាពជារបស់មិនទៀងជាដើម នេះជាវិបស្សនា ។ ឯកគ្គតានៃចិត្ត នឹងកើតទេឡើងអំពីអារម្មណ៍ គឺ ការរលាស់ចោលធម៌ដែលកើតទេឡើងក្នុង វិបស្សនានោះ ព្រោះការបរិបូរណ៍នៃវិបស្សនារបស់លោក នេះជាសមថៈ

យ៉ាងនេះ វិបស្សនាកើតមុន សមថៈកើតក្រោយ ព្រោះហេតុនោះ ព្រះ_មានព្រះភាគទើបត្រាស់ថា ចម្រើនវិបស្សនា មានសមថៈនាំមុខ កាលលោកចម្រើនសមថៈមានវិបស្សនានាំមុខ មគ្គ រមែងកើត លោកសេពចម្រើន ធ្វើឱ្យច្រើននូវមគ្គនោះ កាលលោកសេព មគ្គនោះ ។ល។ អនុស័យរមែងអស់ទៅ យ៉ាងនេះឯង ព្រះយោគាវចរឈ្មោះថា ចម្រើនសមថៈមានវិបស្សនានាំមុខ ចម្រើនវិបស្សនាមានសមថៈនាំមុខ ក៏កាលលោកចម្រើនវិបស្សនាមានសមថៈនាំមុខក្តី ចម្រើនសមថៈមានវិបស្សនានាំមុខក្តី ក្នុងខណៈនៃលោកុត្តរមគ្គហើយ សមថៈ និង វិបស្សនារមែងនៅជាមួយគ្នា ( មិនប្រាសចាកគ្នា ) អ្នកសិក្សាគប្បីជ្រាបន័យនៃការចម្រើន ( សមថៈ និង វិបស្សនា ) ក្នុងទីនេះ យ៉ាងនេះឯង ។

( ចប់ អដ្ឋកថាធម្មទាយាទសូត្រ ទី ៣ )

# អ ដ្ឋ ក ថា
# ភយភេរវសូត្រ ទី ៤

ភយភេរវសូត្រ មានពាក្យផ្ដើមទេឡើងថា ខ្ញុំម្ចាស់បានស្ដាប់មកហើយយ៉ាងនេះ ។

## អត្ថនៃពាក្យថា « ព្រាហ្មណ៍ »

ក្នុងភយភេរវសូត្រនោះ មានការពណ៌នាតាមលំដាប់បទដូចតទៅនេះ ÷

ស័ព្ទថា **អថ** ជានិបាតប្រើក្នុងអត្ថថា **អវិច្ឆេទន** (មិនដាច់ខ្សែជាប់តមក) ស័ព្ទថា **ខោ** ជានិបាត (ដូចគ្នា) ប្រើក្នុងសេចក្ដីថា **អវ-ធារណ** ហាមឃាត់អត្ថដទៃ ៗ ។ អធិប្បាយថា ព្រះមានព្រះភាគជាម្ចាស់គង់ប្រថាប់ក្នុងក្រុងសាវត្ថីជាប់មិនដាច់ ។ ពាក្យថា **ជាណុស្សោណី** នោះមិនមែនឈ្មោះដែលមាតា-បិតារបស់ព្រាហ្មណ៍នោះដាក់ឱ្យទេ តែថា ជាឈ្មោះដែលបានមកអំពីការបានតំណែង ។ បានឮមកថា តំណែងជាណុស្សោណីនោះ ជាដំណែងបុរោហិត ។ ព្រះរាជាបានព្រះរាជទានដំណែងបុរោហិតឱ្យដល់គាត់ ដូច្នោះ មនុស្សទាំងទឡាយ ទើបហៅគាត់ថា **ជាណុស្សោណី** ។

បុគ្គលដែលឈ្មោះថា **ព្រាហ្មណ៍** ព្រោះមានអត្ថថា បន្លឺសំទេឡងថា **ព្រហ្ម** អធិប្បាយថា បានដល់ ស្វាធ្យាយមន្ត ។ ក៏ពាក្យថា ព្រាហ្មណ៍នោះ

ជាភាសាហៅបុគ្គលដែលជាព្រាហ្មណ៍ដោយកំណើត ។ ចំណែកព្រះអរិយៈទាំងទឡាយលោកក៏ហៅថា **ព្រាហ្មណ៍** ព្រោះបន្សាត់បាបបានហើយ ។

## សម្មោទនីយកថា - សារាណីយកថា

ពាក្យថា **យេន** ក្នុងពាក្យថា **យេន ភគវា តេនុបសង្កមិ** ជាតតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះដូច្នោះ គប្បីឃើញអត្ថក្នុងពាក្យនេះ យ៉ាងនេះថា **យត្ថ ភគវា ឧបសង្កមិ** ( ប្រែថា ព្រះមាន-ព្រះភាគជាម្ចាស់គង់ប្រថាប់ទីណា ជាណុស្សោណិព្រាហ្មណ៍ក៏ចូលសំដៅទៅគាល់ហើយ ក្នុងទីនោះ ) ។ ម្យ៉ាងទៀត គប្បីឃើញក្នុងអត្ថនេះយ៉ាងនេះថា ព្រះមានព្រះភាគជាម្ចាស់ ដែលទេវតា និង មនុស្សទាំងទឡាយគប្បីចូលទៅគាល់យ៉ាងណា ជាណុស្សោណិព្រាហ្មណ៍ ក៏ចូលទៅគាល់ហើយដោយហេតុ នោះ ។

សួរថា ក៏ព្រះមានព្រះភាគជាម្ចាស់ដែលទេវតា និង មនុស្សទាំងទឡាយគប្បីចូលទៅគាល់ដោយហេតុអ្វីទៅ ?

ឆ្លើយថា ដោយបំណងនឹងសម្រេចគុណវិសេសនានា ដោយប្រការ ណា ឧបមាដូចដើមឈើធំដែលបញ្ចេញផ្លែជាប់ជានិច្ច ដែលពួកបក្សីចូល ទៅទំក៏ដោយបំណងនឹងស៊ីផ្លែឈើដែលមានរសឆ្ងាញ់ ដូច្នោះ ។

ហើយពាក្យថា **ឧបសង្កមិ** មានអធិប្បាយថា ទៅហើយ ។ បទកិរិយាថា **ឧបសង្កមិត្វា** ជាបទសម្តែងដល់ការចូលទៅគាល់ បានដល់ទីបំផុតហើយ ។ ម្យ៉ាងទៀត (បទកិរិយាថា **ឧបសង្កមិត្វា**) នឹងអធិប្បាយ ថា ទៅកាន់ទីជិតជាងនោះ គឺ ទីជិតព្រះមានព្រះភាគជាម្ចាស់ ដូច្នេះក៏បាន ។

បទថា **ភគវតា សទ្ធឹ សម្មោទិ** សេចក្តីថា ព្រះមានព្រះភាគជា- ម្ចាស់កាលត្រាស់សួរដល់សុខទុក្ខជាដើម ឈ្មោះថា ទ្រង់មានសេចក្តីរីករាយព្រះទ័យរួមជាមួយនឹងព្រាហ្មណ៍នោះយ៉ាងណា សូម្បីព្រាហ្មណ៍នោះក៏មានសេចក្តីរីករាយចិត្តជាមួយនឹងព្រះមានព្រះភាគជាម្ចាស់ផងដែរ គឺ បានដល់សេចក្តីរីករាយចិត្ត បានដល់ ការស្និទ្ធស្នាលជាមួយនឹងព្រះមានព្រះភាគជា-ម្ចាស់ ប្រៀបដូចជាទឹកត្រជាក់ និង ទឹកក្តៅលាយចូលជាមួយគ្នាបាន ដូច្នោះ ។

ម្យ៉ាងទៀត ព្រាហ្មណ៍នោះរីករាយចិត្ត (ជាមួយនឹងព្រះមានព្រះ-ភាគជាម្ចាស់ ) ដោយពាក្យណាមានជាអាទិថា **យន្ត** គឺ វរកាយរបស់ព្រះ-គោតមដ៏ចម្រើនល្មមអត់ទ្រាំបានឬទេ ? ព្រះមានព្រះភាគដ៏ចម្រើនល្មមញុំាងសរីរយន្ត គឺ ព្រះវរកាយឱ្យប្រព្រឹត្តទៅបានឬទេ ? ព្រះគោតមដ៏ចម្រើន និងពួកសាវករបស់ព្រះគោតមគង់មានអាពាធបន្តិចបន្តួច មានរោគបន្តិចបន្តួច ឈរដើរបានរហ័សរហួន រឹងប៉ឹង ( និង ) មានការរស់នៅជាសុខឬ ?

ពាក្យនោះឈ្មោះថា **សម្មោទនីយ** ( ជាហេតុឱ្យរីករាយចិត្ត ) ព្រោះឱ្យកើតការរីករាយចិត្តយ៉ាងក្រៃលែង ពោលគឺ បីតិ និង បាមោជ្ជៈ និង ព្រោះជាពាក្យសម្តីដើម្បីសេចក្តីរីករាយចិត្ត ឈ្មោះថា **សារានីយ** (ជាហេតុឱ្យរឭកដល់គ្នានិង គ្នា) ព្រោះជាពាក្យសម្តីសមគួរដែលនឹងឱ្យ (អ្នកស្តាប់រឭក ដល់) អស់កាលសូម្បីដ៏យូរ គឺ ឱ្យប្រព្រឹត្តទៅបាន មិនសាបសូន្យបាត់ទៅ ព្រោះជាពាក្យសម្តីដែល ( អ្នកនិយាយ ) ក៏ត្រូវរឭកដល់ផង ឈ្មោះថា **សម្មោទនីយ** ព្រោះកាលបានស្តាប់ក៏ជាសុខ មួយប្រការទៀត ឈ្មោះថា **សម្មោទនីយ** ព្រោះមានព្យញ្ជនៈច្បាស់លាស់ ឈ្មោះថា **សារាណីយ** ព្រោះមានអត្ថច្បាស់លាស់ ព្រាហ្មណ៍ក៏បានញ៉ាំងពាក្យដែលជា សម្មោទនីយៈ សារាណីយៈ ឱ្យឆ្លងផុតទៅ គឺ ឱ្យអស់ទៅ បានដល់ ឱ្យចប់ទៅដោយបរិយាយជាអនេក ដូចពណ៌នាមកយ៉ាងនេះហើយ ប្រាថ្នានឹងសួរដល់បំណងដែលជាហេតុឱ្យខ្លួនត្រូវមក ទើបអង្គុយក្នុងទីដ៏សមគួរ ( សិន ) ។

បទថា **ឯកមន្តំ** ជាបទសម្តែង **ភាវនបុំសក** (កិរិយាវិសេស ) ត្លូយ៉ាងដូចក្នុងប្រយោគជាដើមថា **វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ** ព្រះច័ន្ទនិងព្រះអាទិត្យគោចរមិនស្មើគ្នាដូច្នេះ ព្រោះដូច្នោះ គប្បីឃើញសេចក្តីសុខក្នុងចំណុចនេះយ៉ាងនេះថា ព្រាហ្មណ៍នោះអង្គុយ ដូចគេអង្គុយក្នុង

ទីដ៏សមគួរ ។ម្យ៉ាងទៀត បទថា **ឯកមន្តំ** នេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។

## ការអង្គុយដែលមានទោស ៦ យ៉ាង

បទថា **និសីទិ** ប្រែថា ចូលទៅអង្គុយជិត ។ ព្រោះថា បុគ្គលដែលជាបណ្ឌិតចូលទៅរកបុគ្គលអ្នកតាំងនៅក្នុងឋានៈជាគ្រូហើយ រមែងអង្គុយក្នុងទីដ៏សមគួរមួយ ព្រោះភាពជាអ្នកឆ្លាតក្នុងទីអង្គុយ ហើយព្រាហ្មណ៍នេះក៏ជាបណ្ឌិតម្នាក់ ក្នុងចំនួនបណ្ឌិតទាំងនោះ ។ ព្រោះដូច្នោះទើបអង្គុយក្នុងទីដ៏សមគួរមួយ ។

សួរថា ក៏បុគ្គលអង្គុយដូចម្ដេច ទើបឈ្មោះថា អង្គុយក្នុងទីដ៏សមគួរ?

ឆ្លើយថា អង្គុយវៀរចាកទោស ៦ យ៉ាង

សួរថា ទោសក្នុងការអង្គុយ ៦ យ៉ាង មានអ្វីខ្លះ ?

ឆ្លើយថា មានដូចតទៅនេះ ÷

**១. អតិទូរំ** = អង្គុយឆ្ងាយពេក

**២. អច្ចាសន្នំ** = អង្គុយជិតពេក

**៣. ឧបរិវាតំ** = អង្គុយក្នុងទីលើខ្យល់

**៤. ឧន្នតប្បទេសំ** = អង្គុយលើទីខ្ពស់

**៥. អតិសម្មុខំ** = អង្គុយត្រង់មុខពេក

**៦. អតិបច្ឆា** = អង្គុយហួសទៅខាងក្រោយពេក

អធិប្បាយថា មនុស្សដែលអង្គុយក្នុងទីឆ្ងាយពេកប្រសិនបើប្រាថ្នានឹងនិយាយក៏ត្រូវនិយាយដោយសំទេឡងខ្លាំង ៗ ។ អង្គុយក្នុងទីជិតពេកក៏នឹងត្រូវប្រជ្រៀតលោក អង្គុយក្នុងទីលើខ្យល់ក៏នឹងរំខានលោកដោយក្លិនខ្លួន អង្គុយលើទីខ្ពស់ក៏នឹងជាការសម្តែងសេចក្តីមិនគោរព អង្គុយត្រង់ចំពេក ប្រសិន- បើប្រាថ្នានឹងមើល (មុខ ) ក៏នឹងត្រូវសម្លឹងមើលភ្នែកគ្នា អង្គុយហួសទៅខាងក្រោយពេក ប្រសិនបើប្រាថ្នានឹងមើលនឹងអើតកទៅ (ក្រទេឡក ) មើល។ ព្រោះហេតុនេះ ព្រាហ្មណ៍នេះ ទើបអង្គុយវៀរចាកទោសនៃការ អង្គុយ ៦ យ៉ាង នេះ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរមួយ ។

## កុលបុត្រ ២ ជំពួក

បទថា **យេមេ** កាត់បទជា **យេ ឥមេ** ប្រែថា កុលបុត្រទាំង នេះ។

បទថា **កុលបុត្តា** បានដល់កុលបុត្រ២ពួកគឺកុលបុត្រដោយ កំណើតមួយ កុលបុត្រដោយអាចារៈមួយ ក្នុងកុលបុត្រពីរពួកនោះ កុលបុត្រ

កើតក្នុងត្រកូលខ្ពស់ (ដែលមានមក ) យ៉ាងនេះថា ក៏ដោយសម័យនោះឯង កុលបុត្រឈ្មោះ រដ្ឋបាលជាកូនប្រុសរបស់ **អគ្គកុលិកសេដ្ឋី** ក្នុង **ចុល្ល-កោដ្ឋិតគ្រាម** នោះឯង ដូច្នេះឈ្មោះថា កុលបុត្រដោយកំណើត ។ ចំណែកកុលបុត្រ ដែលនឹងកើតក្នុងត្រកូលណាក៏ដោយ ជាអ្នកបរិបូរណ៍ទៅដោយអាចារៈ ដែលមានមកយ៉ាងនេះថា កុលបុត្រពួកណាចេញចាកផ្ទះបួសជាអនាគារិកៈដោយសទ្ធា ដូច្នេះ ឈ្មោះថា កុលបុត្រដោយអាចារៈ ។ តែក្នុងទីនេះ លោកប្រាថ្នាយកកុលបុត្រដោយហេតុពីរយ៉ាង (នោះ) ។

បទថា **សទ្ធា** ប្រែថា ដោយសទ្ធា

បទថា **អគារស្មា** ប្រែថា ចាកផ្ទះ

បទថា **អនគារិយំ** បានដល់បព្វជ្ជា និង ឧសម្ប៉ទ ។ ដោយថាសូម្បីបព្វជ្ជាក៏ឈ្មោះថា **អនគារិយា** ព្រោះក្នុងបព្វជ្ជានេះមិនមានការងារដែលជាប្រយោជន៍ដល់ការគ្រប់គ្រងផ្ទះ ។ អធិប្បាយថា ក្នុងបព្វជ្ជានេះមិនមានកសិកម្ម (សាបព្រោះ ) និង គោរក្ខកម្ម (ការចិញ្ចឹមសត្វ ) ជាដើមដែលជាប្រយោជន៍ដល់ការគ្រប់គ្រងផ្ទះ ។ ចំណែកភិក្ខុក៏ឈ្មោះថា **អនា-គារ** ព្រោះលោកមិនមានផ្ទះ ភាវៈនៃការមិនមានផ្ទះឈ្មោះថា **អនគារិយ** ។

បទថា **បព្វជិតា** ប្រែថា ចូលដល់ ។ អធិប្បាយថា ចូលដល់បព្វជ្ជា

និង ភិក្ខុភាវៈ ពោលគឺ ការងារដែលមិនមានប្រយោជន៍ដល់ការគ្រប់គ្រងផ្ទះ សូម្បីដោយប្រការទាំងពួង ដូចពណ៌នាមកនេះ ។

RB¼manRB¼PaKRTg´CaGñknaMkulbuRt 2 BYkena¼

បទថា **បុព្វង្គមោ** ប្រែថា ជាអ្នកទៅខាងមុខ គឺ ជាអ្នកណែនាំ ។

បទថា **ពហុការោ** ប្រែថា ជាអ្នកមានឧបការៈច្រើន ព្រោះធ្វើប្រយោជន៍ឱ្យ ។

ពាក្យថា **ភវន្តេសំ គោតមោ សមាទបេតា** សេចក្តីថា ព្រះ-គោតមដ៏ចម្រើនញ៉ាំងកុលបុត្រទាំងនោះឱ្យទទួល គឺ ឱ្យសិក្សានូវសិក្ខាផ្សេង ៗ មានអធិសីលជាដើម ។

បទថា **សា ជនតា** ប្រែថា ពួកជននោះ ។

បទថា **ទិដ្ឋានុគតឹ អាបជ្ជតិ** យកតម្រាប់តាម ។ អធិប្បាយថា ព្រះគោតមដ៏ចម្រើនមានទិដ្ឋិដូចម្តេច សូម្បីកុលត្រទាំងនោះក៏មានទិដ្ឋិដូច្នោះ មានការចូលចិត្តដូច្នោះ មានការពេញចិត្តដូច្នោះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រាហ្មណ៍នេះទើបពោលដូច្នោះ ?

ឆ្លើយថា បានឮថា កាលមុនឃើញកុលបុត្រចំនួនច្រើននៅក្នុងលោក ដែលជាអ្នកគ្រប់គ្រងផ្ទះ បានទទួលបម្រើដោយបញ្ចកាមគុណប្រហែលថា ជា

ទេវបុត្រ បានទទួលគ្រប់គ្រងយ៉ាងល្អទាំងខាងក្នុងផ្ទះ ក្រៅផ្ទះ សម័យតមក បានឃើញកុលបុត្រទាំងនោះ បានស្តាប់ព្រះធម៌ទេសនាដ៏ពីរោះរបស់ព្រះសម្មា-សម្ពុទ្ធជាម្ចាស់ហើយ ចេញចាកផ្ទះបួសដោយសទ្ធា (ត្រឡប់ក្លាយមកជា) អ្នកសន្តោសក្នុងបច្ច័យទាំងទឡាយយ៉ាងក្រៃលែង សូម្បីនឹងមិនមានអ្នកណាគ្រប់គ្រងការពារឱ្យ ( ដូចពេលមុន ) ក៏មិនបានញញើតកោតក្រែងរីករាយត្រេកអរចិត្តក្នុងសេនាសនៈនៅក្នុងព្រៃ ព្រាហ្មណ៍លុះឃើញហើយក៏រំពឹងគិតបានថា ការនៅយ៉ាងនេះរបស់កុលបុត្រទាំងនេះ រាប់ថា ជាការនៅយ៉ាងសុខហើយ ការនៅយ៉ាងសុខនេះកើតទេឡើងព្រោះអាស្រ័យអ្នកណា ក៏បានទទួលពាក្យឆ្លើយថា ព្រោះអាស្រ័យព្រះគោតម ទើបមានសេចក្តីជ្រះថ្លានឹងព្រះមានព្រះភាគជាម្ចាស់ ដើម្បីប្រកាសសេចក្តីជ្រះថ្លានោះ គាត់ទើបបានមកកាន់សម្នាក់ព្រះមានព្រះភាគជាម្ចាស់ ដូច្នោះ គាត់ទើបពោលដូចដែលពោលមកហើយនេះ ។

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់ទទួល និង ទ្រង់គាំទ្រពាក្យរបស់ព្រាហ្មណ៍នោះ ទើបត្រាស់ពាក្យជាអាទិថា **ឯវមេតំ ព្រា- ហ្មណ** សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ ព្រាហ្មណ៍ ។

ក៏ក្នុងពាក្យថា **ឯវមេតំ ព្រាហ្មណ** នេះ មានអធិប្បាយដូច្នេះថា ÷

បទថា **ឯវំ** នេះជាបាត ប្រើទុកក្នុងសេចក្ដីថា ទទួលអះអាង និង អនុមោនាពាក្យ (របស់អ្នកដទៃ) ។

បទថា **មមំ ឧទ្ទិស្ស** ប្រែថា ចំពោះតថាគត ។

ដោយបទថា **សទ្ធា** ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកហេតុផ្សេង ៗ មានជាអាទិថា ដោយសទ្ធានោះឯងមានមែន ( បួស ) ព្រោះជំពាក់ប្រាក់គេ មិនមែនព្រោះសេចក្ដីខ្លាច ។ ព្រោះថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជាប្រធានរបស់បុត្រដូច្នេះប៉ុណ្ណោះ មិនមែនពួកដទៃ ៗ ទេ ។

## សេនាសនៈព្រៃ

បទថា **ទូរភិសម្ភវានិ ហិ** សេចក្ដីថា កម្រនឹងនៅបានដោយល្អ គឺទ្រាំរស់នៅបានដោយកម្រ អធិប្បាយថា ភិក្ខុអ្នកមានសក្តិតូចមិនអាចនឹងនៅអាស្រ័យបាន ។

បទថា **អរញ្ញវនបត្ថានិ** បានដល់ ព្រៃជិត និង ព្រៃឆ្ងាយ ។

ក្នុងបទថា **អកញ្ញវនបត្ថានិ** នេះ មានអធិប្បាយថា ÷

ពោលតាមត្រង់ក្នុងអភិធម្មហើយ សេនាសនៈក្រៅពីសសរខឿនទៅទាំងអស់លោកហៅថា « ព្រៃ » ក៏ពិត ។ សូម្បីយ៉ាងនោះគប្បីជ្រាបថាសេនា-សនៈណាដែលឱ្យសម្រេចអរញ្ញិកធុតុង្គបាន ដែលលោកពោលទុកថា ខាងចុង

ទីបំផុតប្រមាណ ៥០០ ធ្នូរធ្នូ លោកប្រាថ្នាយកសេនាសនៈនោះប៉ុណ្ណោះ ។ បទថា **វនបត្ថំ** បានដល់ស្ថានទីដែលហួសចុងភូមិទៅ មិនមាន មនុស្សទៅមកជារឿយ ៗ ជាទីដែលមិនមានការភ្ជួររាស់-សាបព្រោះ ។

សេចក្ដីនេះសមដូចពាក្យដែលលោកពោលទុកដូច្នេះថា ÷

ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់សេនាសនៈឆ្ងាយ ។

ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ដងព្រៃ ។

ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ស្ថានទីគួរខ្លាច ។

ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ស្ថានទីដែលធ្វើឱ្យមានការព្រឺរោម

ពាក្យថា **វនបត្ថំ** ជាឈ្មោះរបស់ស្ថានទីដែលនៅជាយដែន ។

ពាក្យថា **វនបត្ថំ** មិនមែនជាឈ្មោះរបស់សេនាសនៈដែលមានមនុស្សទៅមករឿយៗ ។

ហើយក្នុងទីនេះ ក្រៅពីសេចក្ដីនេះតែម្យ៉ាងថា ស្ថានដែលនៅជាយ ដែន គប្បីយល់ថា ព្រៃដែលនៅជាយដែន តាមសេចក្ដីដ៏សេស ។

បទថា **បន្តានិ** បានដល់ ស្ថានទីដែលនៅជាយដែន គឺ ស្ថានទីដែលនៅឆ្ងាយណាស់ ។

បទថា **ទុក្ករំ បវិវេកំ** សេចក្ដីថា កាយវិវេក ជារបស់ដែលធ្វើ

បានដោយកម្រ ។

បទថា **ទូរភិរមំ** ប្រែថា មិនងាយនឹងត្រេកអរទេឡើយ ។

បទថា **ឯកត្តេ** ប្រែថា ក្នុងភាពម្នាក់តែឯង (ក្នុងការរស់នៅតែម្នាក់ ឯង) ។

សួរថា ព្រះពុទ្ធតម្រាស់ដែលត្រាស់មកនេះសម្ដែងដល់អ្វី ?

ឆ្លើយថា សម្ដែងដល់ថា សូម្បីនឹងបំពេញកាយវិវេកបានហើយ ការដែលនឹងញុំាងចិត្តឱ្យត្រេកអរក្នុងវិវេកនោះ ក៏ជារបស់ដែលធ្វើបានដោយកម្រ ។ ព្រោះសត្វលោកនេះច្រើនត្រេកអរក្នុងការរស់នៅជាគូ ។

បទថា **ហរន្តិ មញ្ញេ** សេចក្ដីថា ហាក់ដូចជាដឹកនាំទៅ គឺ ហាក់ដូចជាចាប់អូសទាញទៅ ។

បទថា **មនោ** ប្រែថា នូវចិត្ត ។

បទថា **សមាធឹ អលភមានស្ស** សេចក្ដីថា ( របស់ភិក្ខុ ) អ្នកមិនបានឧបចារសមាធិ ឬ អប្បនាសមាធិ ។

សួរថា ព្រះពុទ្ធតម្រាស់ដែលត្រាស់មកនេះសម្ដែងដល់អ្វី ?

ឆ្លើយថា សម្ដែងដល់ថា ហាក់ដូចជានឹងធ្វើចិត្តរបស់ភិក្ខុអ្នកមិនបានឧបចារសមាធិ ឬ អប្បនាសមាធិឱ្យរាយមាយដោយសំទេឡុងទាំងទឡ្បាយមាន

សំទេឡងស្មៅ និង សំទេឡងស្លឹកឈើ និង សំទេឡងសត្វជាដើម និង (រួមទាំង) អារម្មណ៍ដែលគួរខ្លាចផ្សេងៗ ។ ពាក្យទាំងអស់ដែលពោលមកនេះ ព្រាហ្មណ៍ ដែលកើតការអស្ចារ្យក្នុងចិត្ត នឹងការនៅព្រៃរបស់កុលបុត្រទាំងទឡាយអ្នកបួស ដោយសទ្ធាពោលទុកហើយ ។

## អត្ថន័យពាក្យថា « ព្រះពោធិសត្វ »

គ្រានោះព្រះមានភាគជាម្ចាស់ លុះទ្រង់ទទួល និង អនុមោទនាដោយ ពាក្យរបស់ព្រាហ្មណ៍នោះ ដោយព្រះពុទ្ធតម្រាស់មានជាអាទិថា **ឯវមេតំ ព្រាហ្មណ** តាមន័យដំបូងនោះឯង ទើបបានត្រាស់ពាក្យមានជាអាទិថា **មយ្ហំបិ ខោ** ដើម្បីនឹងទ្រង់សម្តែងថា សេនាសនៈប្រភេទនុ៎ះ ក៏ជាសេនាសនៈ ដែលនៅបានដោយកម្រ សម្រាប់ព្រះអង្គឯង ព្រោះសេនាសនៈប្រភេទនុ៎ះ ជាសេនាសនៈដែលលំបាករស់នៅសម្រាប់ភិក្ខុទាំងទឡាយ អ្នកត្រូវអារម្មណ៍រំខាន ព្រោះហេតុ ១៦ យ៉ាង តែមិនជាទីនៅលំបាកទេឡើយ សម្រាប់ភិក្ខុអ្នកប្រកប ដោយការគ្របសង្កត់អារម្មណ៍បាន ព្រោះហេតុទាំងនោះហើយ ព្រះអង្គឯង សូម្បីកាលនៅជាព្រះពោធិសត្វ ក៏ទ្រង់នៅក្នុងទីសេនាសនៈដូច្នោះ ។

បទថា **បព្វេវ សម្ពោធា** សេចក្តីថា ក្នុងកាលមុនពីការត្រាស់ដឹង អធិប្បាថា ក្នុងពេលដទៃអំពីពេលដែលអរិយមគ្គកើតទេឡើងនោះឯង ។

បទថា **អនភិសម្ពុទ្ធស្ស** បានដល់ មិនទាន់ត្រាស់ដឹងនូវអរិយសច្ចៈ ទាំង ៤ ។

បទថា **ពោធិសត្តស្សេវ សតោ** ប្រែថា អ្នកនឹងត្រាស់ដឹង គឺ សត្វដែលគួរនឹងត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ម្យ៉ាងទៀត សេចក្តីថា សត្វអ្នកជាប់ គឺ អ្នកជាប់ជំពាក់នៅក្នុងព្រះពោធិញ្ញាណ ។

ព្រោះថា រាប់ចាប់ផ្តើមតាំងពី អភិនិហារ សម្រេចទៅដោយការប្រជុំ នៃធម៌ ៨ ប្រការ ទៀបព្រះយុគលបាទរបស់ព្រះមានព្រះភាគជាម្ចាស់ទ្រង់ព្រះ នាមថា « **ទីបង្ករ** » ព្រះតថាគតដែលជាព្រះពោធិសត្វ ឬ ជាសត្វអ្នកជាប់ជំពាក់នៅក្នុងពោធិញ្ញាណ ប្តេជ្ញាថា ពោធិញ្ញាណនេះ តថាគតត្រូវត្រាស់ដឹងឱ្យទាល់តែបាន មិនព្រមលះបង់ចោលសេចក្តីព្យាយាមដើម្បីការត្រាស់ដឹងពោធិញ្ញាណនោះទេឡើយ ព្រោះដូច្នោះទើបថា « ព្រះពោធិសត្វ » ។

បទថា **តស្ស មយ្ហំ** សេចក្តីថា សម្រាប់តថាគតនោះ គឺ អ្នកជាព្រះពោធិសត្វយ៉ាងនេះ នុ៎ះឯង ។

បទថា **យេ ខោ កេចិ សមណា វា ព្រាហ្មណា វា** សេចក្តីថា សមណៈ ឬ ព្រាហ្មណ៍ណាមួយ គឺលោកអ្នកចូលដល់ការបព្វជ្ជា ឬ បុគ្គលអ្នកមានប្រក្រតី ពោលថា « **ភោ** » ( ប្រែថា អ្នកចម្រើន ) ។

បទថា **អបរិសុទ្ធកាយកម្មន្តា** សេចក្ដីថា ប្រកបដោយកាយកម្មដែលមិនបរិសុទ្ធ មានបាណាតិបាតជាដើម ។

បទថា **អបរិសុទ្ធកាយកម្មន្តសន្ទោសហេតុ** សេចក្ដីថា ព្រោះហេតុនៃទោសរបស់ខ្លួន ពោលគឺ កាយកម្មដែលមិនបរិសុទ្ធ អធិប្បាយថា ព្រោះហេតុនៃកាយកម្មដែលមិនស្អាត ។

បទថា **ហវេ** ជានិបាតប្រើក្នុងសេចក្ដីថា ដោយចំណែកមួយ ។

បទថា **អកុសលំ** បានដល់ វត្ថុមានទោស និង មិនរួចអំពីភ័យ ។

បទថា **ភយភេរវំ** ភ័យ និង វត្ថុដែលគួរខ្លាច ។

បទថា **ភយភេរវំ** នេះ ជាឈ្មោះហៅសេចក្ដីតក់ស្លុតនៃចិត្ត និង អារម្មណ៍ដែលគួរខ្លាច ។

បណ្ដាភ័យ និង វត្ថុដែលគួរខ្លាចទាំង ២ យ៉ាងនោះ ភ័យគប្បីជ្រាបថា ជាអកុសល ព្រោះអត្ថថា មានទោស , វត្ថុដែលគួរខ្លាច គប្បីជ្រាបថា ជាអកុសល ព្រោះអត្ថថា មានភ័យ ។

បទថា **អវ្ហាយន្តិ** ប្រែថា រមែងហៅមក ។

សួរថា រមែងហៅមកដូចម្ដេច ?

ឆ្លើយថា ក៏សមណព្រាហ្មណ៍ទាំងនោះ លុះធ្វើបាបកម្មមានបាណាតិបាត

ជាដើមហើយ គិតថា យើងធ្វើខុសហើយ ប្រសិនបើមនុស្សដែលយើងធ្វើខុសចំពោះគេ ៗ ស្គាល់យើង (ថាជាខ្លួនធ្វើ ) សោត ក៏នឹងត្រូវជាប់តាមមកដោះស្រាយគំនុំយើងឥឡូវនេះឯង ទើបគេចចូលទៅក្នុងព្រៃ អង្គុយឯបនៅចន្លោះគុម្ពឈើ ឬ គុម្ពោតព្រៃ លុះគេបានឮសំឡេងស្មៅ ឬ សំទេឡងស្លឹកឈើស្ងួម្បីត្រឹមបន្តិចបន្តួចក៏ភ័យញាប់ញ័រដោយគិតថា ស្រេចហើយយើងគ្រានេះ គេ( ដឹងខ្លួន ) ហាក់ដូចជាត្រូវអ្នកដទៃមកព័ទ្ធ និង ដូចជាត្រូវគេតាមចាប់ សម្លាប់ដូច្នោះ ។ កាលបើដូច្នោះ សមណព្រហ្មណ៍ទាំងឈ្មោះថា អំពាវនាវ គឺហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចនុះ ចូលមករកខ្លួន ។

ពាក្យថា **ន ខោ បនាហំ ។បេ។ បដិសេវាមិ** សេចក្តីថា យើងនេះឯងជាអ្នកមានកាយកម្មមិនបរិសុទ្ធ ទើបអាស្រ័យនៅសេនាសនៈ ស្ងាត់ដែលជាព្រៃ និង ព្រៃគួរខ្លាចបាន ។

បទថា **វោ** ក្នុងពាក្យថា **យេហិ ខោ** ត្រឹមតែជានិបាត ។ ព្រះពុទ្ធជាម្ចាស់ទាំងទឡាយ និង ព្រះសាវករបស់ព្រះពុទ្ធជាម្ចាស់ទាំងទឡាយ លោកហៅថា « **ព្រះអរិយ** » ។

បទថា **បរិសុទ្ធកាយកម្មន្តា** សេចក្តីថា (ព្រះអរិយៈជាម្ចាស់ទាំង_ ទឡាយ ) ដូច្នោះ ។

បទថា **អហំ តេសំ អញ្ញតរោ** សេចក្តីថា សូម្បីតថាគតក៏ជាមនុស្ស ម្នាក់ គឺជាព្រះអរិយៈ ក្នុងបណ្តាព្រះអរិយៈជាម្ចាស់ទាំងនោះ ។ ដែលពឹងព្រះពោធិសត្វ មិនថាជាគ្រហស្ថ មិនថាជាបព្វជិត រមែងជាអ្នកមានកាយកម្មបរិសុទ្ធទាំងអស់ ។

បទថា **ភិយ្យោ** ជានិបាត ប្រើក្នុងអត្ថថា យ៉ាងក្រៃលែង ។

បទថា **បល្លោមំ** ប្រែថា ភាពជាអ្នកមានរោម (មិនព្រឺរោម ) អធិប្បាយថា រួចផុតអំពីភ័យ គឺ សួស្តី ។

បទថា **អាបាតឹ** ប្រែថា ដល់ហើយ អធិប្បាយថា ដល់សួស្តីច្រើន ឬ សួស្តីដោយអាការច្រើនយ៉ាង ។

ពីបទថា **អរញ្ញេ វិហារាយ** ដើម្បីប្រយោជន៍ដល់ការនៅក្នុងព្រៃ ។

( ចប់កថាពោលដោយវារៈនៃកាយកម្ម )

## វចីកម្ម មនោកម្ម អាជីវៈ

គ្រប់បទមានន័យដូច្នេះ ។ តែថា ដែលប្លែកមានដូចតទៅនេះ ÷

នឹងពោលទុកក្នុងវារៈ ពោលដោយវចីកម្មមុន ។ បទថា **អបរិសុទ្ធ-វចីកម្មន្តា** សេចក្តីថា ប្រកបដោយវចីដែលមិនបរិសុទ្ធ មានមុសាវាទជា ដើម ។

សួរថា សមណព្រហ្មណ៍អ្នកមានវចីកម្មដែលមិនបរិសុទ្ធិទាំងនោះ នឹងហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចមកយ៉ាងណា ?

ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ លុះធ្វើឱ្យវិនាសប្រយោជន៍អ្នកដទៃដោយការនិយាយកុហក បំបែកមិត្តដោយការញុះញង់ ក៏បំបែកសេចក្តីស្រទន្បាញ់របស់អ្នកដទៃដោយពាក្យគ្រោតគ្រាតកណ្តាលបរិស័ទ ធ្វើឱ្យការងាររបស់អក្នដទៃវិនាសទៅដោយពាក្យឥតប្រយ្រោជន៍ ហើយគិតថា យើងធ្វើខុសហើយ បើបុគ្គលដែលយើងធ្វើខុសចំពោះគេ ៗ ដឹងថា ( យើងជាអ្នកធ្វើ ) ក៏គង់នឹងតាមមកដោះស្រាយគំនុំនឹងយើងឥទឡូវនេះឯង ទើបគេចចូលទៅព្រៃអង្គុយក្នុងចន្លោះគុម្ពឈើ ឬ គុម្ពោតព្រៃ លុះគេបានឮ សំទេឡូងស្មៅ ឬ ឮសំទេឡូងស្លឹកឈើ ស្ងួម្បីបន្តិចបន្តួច ក៏ភ័យញាប់ញ័រដោយគិតថា ស្រេចហើយ យើងគ្រានេះ គេ ( ដឹងខ្លួន ) ហាក់ដូចជាមានអ្នកដទៃមកទេឡាមព័ទ្ធ និង

ហាក់ដូចជាត្រូវចាប់សម្លាប់ដូច្នោះ។សមណព្រាហ្មណ៍ទាំងនោះឈ្មោះថា ហៅ គឺ ហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចឱ្យចូលមករកខ្លួន ។

នឹងពោលក្នុងវារៈ ពោលដោយមនោកម្ម ។ បទថា **អបរិសុទ្ធ-មនោកម្មន្តា** សេចក្តីថា ប្រកបដោយមនោកម្មដែលមិនបរិសុទ្ធ មានអភិជ្ឈា ជាដើម ។

សួរថា សមណព្រាហ្មណ៍អ្នកមានមនោកម្មដែលមិនបរិសុទ្ធិទាំងនោះ នឹងហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចមកដូចម្តេច ?

ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ លុះកើតសេចក្តីលោភមួយប្រភេទ ដែលមិនប្រពៃតាមធម៌ បានដល់ អភិជ្ឈា ( ការសំទឡឹងរំពៃចង់បានរបស់អ្នកដទៃ ) ក្នុងរបស់ដែលអ្នកដទៃហួងហែងរក្សាហើយ , ការក្រោធខឹង ( ព្យាបាទ ) អ្នកដទៃ និង ឱ្យអ្នកដទៃយល់ខុសផង ហើយគិតថា យើងធ្វើខុសហើយ ។ល។ ឈ្មោះថា ហៅ គឺ ហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចឱ្យចូលមករកខ្លួន ។

នឹងពោលក្នុងវារៈ ពោលដោយអាជីវៈ ។ បទថា **អបរិសុទ្ធាជីវា** សេចក្តីថា ប្រកបដោយអាជីពដែលមិនបរិសុទ្ធ ចែកប្រភេទជាអនេសនា ២១ យ៉ាង មាននាទីជាពេទ្យព្យាបាលរោគ ជាទូតនាំសារ និង ការជួញរកកម្រៃ

ជាដើម ។

សួរថា សមណព្រាហ្មណ៍អ្នកមានអាជីពដែលមិនបរិសុទ្ធពួកនោះ នឹងហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចមកបានដូចម្តេច ?

ឆ្លើយថា សមណព្រាហ្មណ៍ទាំងនោះ កាលបើចិញ្ចឹមជីវិតយ៉ាងនោះបានស្តាប់ដំណឹងថា ពួកភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដក ដែលមាននាទីជម្រះរៀបចំព្រះសាសនាឱ្យបរិសុទ្ធ កំពុងចេញទៅរៀបចំព្រះសាសនាថ្ងៃនេះ ឬ ថ្ងៃស្អែកនេះ ក៏នឹងធ្វើដំណើរមកដល់ទីនេះ (បានឮយ៉ាងនេះហើយ ) ទើបគេចចូលទៅព្រៃអង្គុយឯបចន្លោះគុម្ពឈើ ឬ គុម្ពោតព្រៃ ។ ល ។ គេតក់ស្លុត ( ញាប់ញ័រ) ហាក់ដូចជាភិក្ខុពួកនោះមកទេឡាមព័ទ្ធចាប់ និង ហាក់ដូចជាត្រូវ ( ចាប់ផ្សឹក ) ឱ្យស្លៀកសំពត់ស ។ ពាក្យដ៏សេស ក៏ដូចពាក្យដែលពោលមកហើយនោះឯង ។

ក្នុងពាក្យថា **ឥតោ បរំ អភិជ្ឈាលុ** ជាដើម មានអធិប្បាយថា អភិជ្ឈា និង ព្យាបាទ សង្គ្រោះចូលក្នុងមនោកម្មក៏ពិត សូម្បីយ៉ាងនោះគប្បី ជ្រាបថា លោកពោលដដែលទៀតដោយអំណាចនីវរណៈ ។

**GFib,aynIvrN 5**

បណ្តាបទទាំងនោះ បទថា **អភិជ្ឈាលុ** បានដល់ អ្នកមានប្រក្រតី

សំទឡឹងរំពៃចង់បានរបស់អ្នកដទៃ ។ បទថា **កាមេសុ តិព្វសរាគា** បានដល់អ្នកមានកិលេស គឺ រាគៈយ៉ាងខ្លាំងក្លាក្នុងវត្ថុកាមទាំងទឡាយ ។

សួរថា សមណព្រាហ្មណ៍អ្នកមានកិលេស គឺ រាគៈយ៉ាងខ្លាំងក្លានោះ តែងហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចមកបានដូចម្តេច ?

ឆ្លើយថា សមណព្រាហ្មណ៍ពួកនោះ មិនបានពិចារណាអារម្មណ៍ឱ្យល្អិតល្អន់ កាលបើគេមិនបានកំណត់ពិចារណាអារម្មណ៍ឱ្យល្អិតល្អន់ដោយយកចិត្តទុកដាក់សូម្បីនៅក្នុងព្រៃ វត្ថុដែលឃើញក្នុងពេលថ្ងៃរមែងប្រាកដជាភ័យ និង ជារបស់គួរខ្លាចក្នុងពេលយប់ លោកមានចិត្តជាអកុសល (ហើយ) រមែងនឹងតក់ស្លុតដោយភ័យ និង វត្ថុដែលគួរខ្លាចសូម្បីត្រឹមតែបន្តិចបន្តួច គឺ ឃើញខ្សែ ឬ វល្លិក៏សម្គាល់ថា ពស់ ឃើញដង្គត់ឈើសម្គាល់ថា ជាយក្ស ឃើញទីទួល ឬ ភ្នំក៏សម្គាល់ថា ជាដំរី ដូចត្រូវសត្វកាច មានពស់ជាដើម បៀតបៀនដូច្នោះ ។ ពាក្យដ៏សេស ក៏ដូចនឹងពាក្យដែលពោលមកហើយនោះឯង ។

បទថា **ព្យាបន្នចិត្តា** ប្រែថា មានចិត្តវិបត្តិទៅ ព្រោះលះបង់ភាពប្រក្រតីចេញ ។ ជាការពិត ចិត្តដែលច្រទឡូកច្រទឡំជាមួយនឹងកិលេស រមែងលះបង់ភាពជាប្រក្រតី ត្រទឡប់ក្លាយជាចិត្តវិបត្តិប្រែប្រួល ដូចបាយ និង ម្ហូប

ដែលផ្អូមដូច្នោះ ។

បទថា **បទុដ្ឋមនសង្កប្បា** ប្រែថា មានចិត្តគិតទៅក្នុងផ្លូវមិនល្អ អធិប្បាយថា ប្រកបដោយសេចក្តីត្រិះរិះនៃចិត្តដែលមិនល្អ គឺ ធ្វើមនុស្សដ៏ទៃឱ្យវិនាសប្រយោជន៍ ។

សួរថា សមណព្រាហ្មណ៍ ដែលមានចិត្តវិបត្តិគិតទៅក្នុងផ្លូវដែលមិនល្អទាំងនោះ ដែលហៅរកភ័យ និង អារម្មដែលគួរខ្លាចមកបានដូចម្តេច ?

ឆ្លើយថា រាប់តាំងតែពីនេះទៅ ការហៅរកភ័យ និង អារម្មណ៍ដែលគួរ ខ្លាច គប្បីជ្រាបតាមន័យដែលពោលហើយក្នុវារៈដែលពោលដោយ **អភិជ្ឈាលុ** នោះឯង ។ តែថាទុកក្នុងទីណានឹងមានសេចក្តីប្លែក ខ្ញុំម្ចាស់ក៏នឹងបានពោលអធិប្បាយទុកក្នុងទីនោះ ។

ក៏ក្នុងព្រះតម្រាស់ផ្នែកនេះថា **ន ខោ បនាហំ ព្យាបន្នចិត្តោ** ព្រះមានព្រះភាគទ្រង់សម្តែងថា តថាគតមានចិត្តប្រកបទៅដោយមេត្តា មានចិតគិតអនុគ្រោះចំពោះសត្វលោក ។ ជាធម្មតាព្រះពោធិសត្វទាំងទឡាយរមែងមានអធ្យាស្រ័យដូច្នេះ (ទាំងនោះ) បណ្ឌិតគប្បីពណ៌នាគុណរបស់ព្រះពោធិសត្វ ដោយអំណាចនៃការផ្ទុយគ្នានឹងទោសដែលពោលទុកក្នុងគ្រប់បទយ៉ាងនេះ ។

បទថា **ថីនមិទ្ធបរិយុដ្ឋិតា** ប្រែថា ថីនៈ (ការរុញរា-ការច្រអូសចិត្ត ) ដែលជាការពិការរបស់ចិត្ត និង មិទ្ធៈ (សេចក្ដីងោកងក់ ) ដែលជាការពិការរបស់កងនាមខន្ធដ៏សេស រួបរិត ( វេទនា សញ្ញា សង្ខារ) អធិប្បាយថា គ្របសង្កត់ គឺ គ្រប់គ្រង ។ សមណព្រាហ្មណ៍ដែលត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ តែងតែពេញចិត្តនឹងលោក ។

បទថា **ឧទ្ធតា** ប្រែថា មានប្រក្រតីរាយមាយ គឺ មានចិត្តរើបំរាស់ អធិប្បាយថា ចិត្តរមែងរើបំរាស់ចេញអំពីអារម្មណ៍មួយដោយឧទ្ធច្ចៈ ដូចសំពត់ ( ដែលធ្វើជាទង់ ) បក់បោក (ចុង) និងដងទង់ ព្រោះខ្យល់ ដូច្នោះ ។

បទថា **អវូបសន្តចិត្តា** ប្រែថា ចិត្តមានអារម្មណ៍មិនរលត់ (មិនស្ងប់) ក្នុងទីនេះនឹងសំដៅដល់ កុក្កុច្ចៈ (សេចក្ដីខ្វល់ខ្វាយ) ក៏បាន ។

ក្នុងព្រះពុទ្ធវចនៈនេះថា **កង្ខី វិចិកិច្ឆី** ជាបទតែមួយដូចគ្នា (ព្រោះ ) នីវរណៈប្រការទី៥ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **កង្ខា**(សេចក្ដី-សង្ស័យ ) ព្រោះសង្ស័យចំពោះអារម្មណ៍ថា អារម្មណ៍នេះ ជាយ៉ាងនេះឬហ្ន៎ ត្រាស់ហៅថា **វិចិកិច្ឆា** ព្រោះមិនអាចកាត់សម្រេចសេចក្ដីបានថា អារម្មណ៍ នេះ ជាយ៉ាងនេះ ។ សមណព្រាហ្មណ៍អ្នកប្រកបដោយកង្ខា និង វិចិកិច្ឆានោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **កង្ខី វិចិកិច្ឆី** ( អ្នកមានសេចក្ដីសង្ស័យ

មិនអាចកាត់ក្ដីអារម្មណ៍បាន ) ។

បទថា **អត្តុក្កំសកា បរវម្ភិ** សេចក្ដីថា សមណព្រាហ្មណ៍ពួកណា លើកតំកើងខ្លួនទេឡើង បានដល់ ការតម្កល់ខ្លួនខ្ពស់ និង ជិះជាន់ គឺ មើលងាយ បានដល់ ការបន្តុះបង្អាប់អ្នកដទៃ សេចក្ដីថា ទុកអ្នកដទៃឱ្យទាប (ជាងខ្លួន ) , ពីរបទនោះ ( **អត្តុក្កំសកា បរវម្ភី** ) ជាពាក្យហៅសមណព្រាហ្មណ៍ទាំងនោះ ។

សួរថា សមណព្រាហ្មណ៍អ្នកលើកតម្កើងខ្លួន បន្តុះបង្អាប់អ្នកដទៃនោះ នឹងហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចមកបានដូចម្ដេច ?

ឆ្លើយថា ការហៅរកភ័យរបស់សមណព្រាហ្មណ៍អ្នកលើកតម្កើងខ្លួន បន្តុះបង្អាប់អ្នកដទៃនោះ បណ្ឌិតគប្បីជ្រាបឱ្យពិស្ដារ ដូចក្នុងកាយកម្មថា សមណព្រាហ្មណ៍អ្នកលើកតម្កើងខ្លួន បន្តុះបង្អាប់អ្នកដទៃទាំងនោះ ត្រូវអ្នកដទៃតាមចាប់ដោយការចោទប្រកាន់ថា បានជ្រាបថា លោកឈ្មោះនោះ និង ឈ្មោះនោះលើកតម្កើងខ្លួន តិះដៀលពួកយើងធ្វើឱ្យដូចជាទាសៈ ចូរចាប់វាឱ្យបាន ដូច្នេះ គេចចូលទៅក្នុងព្រៃហើយអង្គុយឯបនៅក្នុងចន្លោះគុម្ពឈើ ឬ ក្នុងគុម្ពោតព្រៃ ។

បទថា **ឆម្ភី** ប្រែថា ប្រកបដោយសេចក្ដីតក់ស្លុត ដែលធ្វើឱ្យ

កាយបសាទ និង ព្រឺរោម ។

បទថា **ភីរុកជាតិកា** ប្រែថា ច្រើនទៅដោយសេចក្ដីខ្លាច អធិប្បាយ ថា មិនធ្លាប់ក្លាហានដូចក្មេងអ្នកស្រុកដែលចូលចិត្តខ្លាច ដូច្នោះ ។

ក្នុងបទថា **លាភសិការសិលោភោនិ** នេះ មានអធិប្បាយថា ដែលឈ្មោះថា លាភ ព្រោះអត្ថថា ដែលបុគ្គលរមែងបាន ពាក្យថា លាភ នោះ ជាឈ្មោះរបស់បច្ច័យ ៤ ។

បទថា **សក្ការោ** ប្រែថា សក្ការៈដែលល្អ ។ អធិប្បាយថា បច្ច័យទាំងឡាយដែលគេតាក់តែងធ្វើឱ្យប្រណីត ប្រណីត និង វិសេស ហៅថា សក្ការៈ បានដល់ ការដែលអ្នកដទៃគេធ្វើសេចក្ដីគោរពខ្លួន ឬ បូជាដោយគ្រឿងបូជា មានផ្កាឈើជាដើម ។

បទថា **សិលោកា** ប្រែថា សរសើរគុណ លាភមួយ សក្ការៈមួយ ការសរសើរមួយ នោះ ឈ្មោះថា លាភសក្ការៈ និង សិលោកៈ ។

បទថា **និកាមយមនា** ប្រែថា ប្រាថ្នា ។

ការហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាច ដូចដែលពោលក្នុងផ្នែកពោលដោយ **អភិជ្ឈាសុ** នោះឯង ។ ចំណែកក្នុងទីនេះ ព្រះបុរាណាចារ្យទាំងឡាយបានពោលដល់រឿង **ព្រះបិយតាមិក** ជាតួយ៉ាងក្នុងរឿងនោះទុក

ថា ÷

## បិយគាមិកភិក្ខុ

បានស្តាប់មកថា ភិក្ខុមួយរូបឈ្មោះ បិយគាមិកៈ ឃើញលាភរបស់ភិក្ខុអ្នកសមាទានធុតង្គហើយ ក៏គិតថា យើងនឹងសមាទានធុតង្គ ធ្វើលាភឱ្យកើតទេឡើងខ្លះ ដូច្នេះ ហើយក៏សមាទានសោសានិកង្គៈធុតង្គ (ធុតង្គរបស់ភិក្ខុអ្នកកាន់យកការនៅក្នុងព្រៃស្មសានជាវត្ត ) ហើយក៏នៅក្នុងព្រៃខ្មោច ។ ថ្ងៃមួយគោចាស់មួយក្បាលដែលម្ចាស់ឈប់ប្រើប្រាស់ហើយ (លេងចោល ) ពេលថ្ងៃទៅរកស៊ី ពេលយប់ (ចូលទៅ ) ក្នុងព្រៃស្មសាននោះ បានឈរហើយបះរោមច្រាង ត្បុលក្បាលនៅត្រង់គុម្ពផ្កា ។ ព្រះបិយគាមិកៈ ចេញចាកទីចង្ក្រម ទៅក្នុងពេលយប់ បានឮសំទេឡងរបស់គោនោះហើយ ក៏យល់ថា សក្កទេវរាជគង់នឹងជ្រាបយើងថា ភិក្ខុនេះប្រាថ្នានូវលាភទើបមកនៅក្នុងព្រៃស្មសាន ដូច្នេះ ហើយមកដើម្បីធ្វើអន្តរាយដល់យើងពិតប្រាកដ ។ លោកទើបឈរប្រណមដៃសំពះថ្វាយបង្គំខាងមុខគោចាស់ អង្វរកររហូតមួយយប់ទាល់ភ្លឺ បពិត្រសក្កទេវរាជអ្នកដែលជាសប្បុរស សូមព្រះអង្គចូរអត់នូវទោសឱ្យអាត្មាភាពមួយយប់នេះចុះ តាំងតែពីថ្ងៃស្អែកនេះទៅ អាត្មានឹងមិនធ្វើយ៉ាងនេះទៀតទេ តមកលុះព្រះអាទិត្យរះទេឡើង លោកក៏បានឃើញមេគោចាស់នោះ

(មិនមែនសក្កទេវរាជ ) ទើបយករំពាត់ដេញទៅព្រមទាំងពោលពាក្យជាខាងក្រោយថា ឯងធ្វើឱ្យយើងខ្លាចអស់មួយយប់ ។

## សតិ ជាមួយនឹង បញ្ញា

បទថា **កុសីតា** ប្រែថា ធ្លាក់ទៅក្រោមអំណាចសេចក្តីខ្ជិលច្រអូស ។

បទថា **ហីនវីរិយា** សេចក្តីថា វិនាស គឺ វៀរ បានដល់ ប្រាសចាកសេចក្តីព្យាយាម អធិប្បាយថា មិនមានសេចក្តីព្យាយាម ។ ក្នុងបុគ្គល ២ ជំពូកនោះ មនុស្សដែលខ្ជិលច្រអូស រមែងវៀរចាកការផ្តើមសេចក្តីព្យាយាមផ្លូវកាយ មនុស្សដែលគ្មានសេចក្តីព្យាយាម រមែងវៀរចាកការផ្តើមសេចក្តីព្យាយាមផ្លូវចិត្ត (សរុបហើយ ) មនុស្សទាំង ២ ជំពូកនោះ រមែងមិនអាចនឹងធ្វើ សូម្បីត្រឹមតែការកំណត់អារម្មណ៍បាន ។ ពាក្យទាំងអស់ថា **តេសំ អវវត្ថិតារម្មណានំ** ( មានអត្ថ ) ដូចសេចក្តីដែលបានពោលមកហើយ ។

បទថា **មុដ្ឋស្សតី** ប្រែថា ការវង្វេងភ្លេចសតិ ។

បទថា **អសម្បជានា** ប្រែថា ការប្រាសចាកបញ្ញា ក៏ព្រោះព្រះពុទ្ធ-តម្រាស់ថា តថាគតជាអ្នកមានសតិតាំងមាំហើយ ក្នុងសេចក្តីដែលផ្ទុយគ្នានឹងពាក្យនេះថា **មុដ្ឋស្សតី** ព្រះតម្រាស់ថា **អសម្បជានា** នេះ ទើបជាបទបរិយាយសតិប៉ុណ្ណោះ ។ ចំណែកបញ្ញាក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់

ត្រាស់ទុកដើម្បីសម្ដែងដល់សតិដែលខ្វះកម្លាំង ។ ព្រោះថា សតិមាន ២ យ៉ាង គឺ សតិដែលប្រកបដោយបញ្ញា ១ សតិមិនប្រកបដោយបញ្ញា ១ ។ ក្នុងសតិទាំង ២ នោះ សតិដែលប្រកបដោយបញ្ញារមែងមានកម្លាំង សតិដែលមិនប្រកបដោយបញ្ញារមែងមិនមានកម្លាំង ។ ព្រោះដូច្នោះ ព្រះមាន-ព្រះភាគជាម្ចាស់ទើបត្រាស់ថា **អសម្បជានា** ( មិនមានបញ្ញា ) ដើម្បីសម្ដែងសេចក្ដីនេះថា សូម្បីវេលាដែលភិក្ខុទាំងនោះមានសតិ ក៏នៅឈ្មោះថាមានសតិវង្វេងនោះឯង ព្រោះមិនមានបញ្ញា ព្រោះថា សតិដែលខ្សោយកម្លាំងនឹងធ្វើនាទីរបស់សតិមិនបាន ។ ភិក្ខុពួកនោះវង្វេងភ្លេចសតិ មិនមានសម្បជញ្ញៈ (បញ្ញា ) ដូចពោលមកនេះ រមែងមិនអាចនឹងធ្វើ សូម្បីត្រឹមតែការកំណត់អារម្មណ៍បានទេឡើយ ។ ពាក្យ ( ដ៏សេស ) ទាំងអស់ (មានន័យ) ដូចសេចក្ដីដែលបានពោលមកនេះហើយ ។

## ចិត្ត ជាមួយនឹង បញ្ញា

បទថា **អសមាហិតា** ប្រែថា វៀរចាកឧបចារសមាធិ និង អប្បនា សមាធិ ។

បទថា **វិព្ភន្តចិត្តា** មានចិត្តប្រាសចេញអំពីផ្លូវ គឺ ចិត្តរមែងត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ ព្រោះវៀរចាកសមាធិ បានដល់ ព្រោះលោកទាំង-

នោះមិនមានសមាធិ ព្រោះហេតុដែលឧទ្ធច្ចៈបានឱកាស ប្រៀបដូចស្វាក្នុងព្រៃលោតទៅមកតាមមែកឈើក្នុងព្រៃដូច្នោះ ភិក្ខុទាំងនោះជាអ្នកមានចិត្តតាំងមាំនៅក្នុងអារម្មណ៍ សូម្បីតែមួយ គឺ មានចិត្តត្រាច់ទៅកាន់អារម្មណ៍ ផ្សេងៗ តាមន័យដែលពោលមកហើយក្នុងខាងដើមនេះ ព្រោះឧទ្ធច្ចៈ (សេចក្ដីរាយមាយជាហេតុ ) រមែងមិនអាចនឹងធ្វើត្រឹមតែការកំណត់អារម្មណ៍បានទេឡើយ ។

ពាក្យ (ដ៏សេស ) ទាំងអស់ មាន (ន័យ ) ដូចសេចក្ដីដែលបានពោលមកហើយក្នុងខាងដើម ។

បទថា **ទុប្បញ្ញា** នេះ ជាពាក្យសម្រាប់ហៅមនុស្សដែលមិនមានបញ្ញា តែបញ្ញាដែលឈ្មោះថា ថោកទាបមិនមានជាពិតប្រាកដ ។

បទថា **ឯលមូគា** ប្រែថា មានមាត់ពេញទៅដោយទឹកមាត់ លោក ផ្លាស់ «ខ» អក្សរឱ្យជា «គ» អក្សរ (ទើបសម្រេចរូបជា ឯលមូគា) អធិប្បាយថា មានទឹកមាត់ហូរមិនដាច់ ព្រោះថា កាលមនុស្សអប្បឥតបញ្ញា និយាយទឹកមាត់នឹងហូរចេញមកអំពីមាត់ ។ ហើយទឹកមាត់ហៅថា **ឯល** ។ ដូចដែលលោកពោលទុកថា **បស្សេលមូគំ ឧរគំ ទុជិវ្ហំ** លោកចូរមើលមាត់ពស់មានទឹកមាត់ហូរមិនដាច់ ( កំពុងតែលៀនអណ្ដាត) មានអណ្ដាត

២ ។ ព្រោះដូច្នោះ ភិក្ខុអ្នកអប្បឥតបញ្ញាទាំងនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ហៅថា **ឯលមូគា** បាឋៈថា **ឯលមុខា** ដូច្នេះក៏មាន ។ អាចារ្យពួកខ្លះពោលថា **ឯលមុកា** ខ្លះ ។ ( តែ ) អាចារ្យមួយពួកទៀតត្រទឡប់ពោលថា **ឯមុខា** ដូច្នេះក៏នៅមាន ។ (ដល់យ៉ាងណា) ក្នុង គ្រប់ ៗ បទក៏មានសេចក្ដីថា **ឯលមុកា** មាត់មានទឹកមាត់ហូរមិនដាច់ ។

សួរថា ភិក្ខុដែលមានបញ្ញាអន់ថយទាំងនោះ រមែងហៅរកភ័យ និងអារម្មណ៍ដែលគួរខ្លាចបានដូចម្ដេច ?

ឆ្លើយថា ភិក្ខុអ្នកអប្បឥតបញ្ញា មានទឹកមាត់ហូរមិនដាច់ទាំងនោះនឹងមិនអាចធ្វើសូម្បីត្រឹមតែការកំណត់អារម្មណ៍ កាលលោកកំណត់អារម្មណ៍មិនបាន នៅក្នុងព្រៃ វត្ថុដែលឃើញក្នុងវេលាថ្ងៃ ដល់វេលាយប់នឹងប្រាកដជាភ័យនឹងអារម្មណ៍ដែលគួរខ្លាច លោកមានចិត្តមិនស្ងប់ រមែងភ័យតក់ស្លុតសូម្បីនឹងអារម្មណ៍បន្តិចបន្តួចឃើញខ្សែ ឬ វល្លិហើយ រមែងសម្គាល់ថាជាពស់ ឃើញដង្គត់ឈើ រមែងសម្គាល់ថាជាយក្ស ឃើញដំបូក ឬ ទីទួល ឬ ភ្នំរមែងសម្គាល់ថា ជាដំរី ( រមែងភ័យខ្លាច ) ដូចជាត្រូវសត្វសាហាវមានពស់ជាដើមប្រទូសរ៉ាយហើយ ដូច្នោះ ។ ភិក្ខុអ្នកមានបញ្ញាអន់ថយទាំងនោះ ឈ្មោះ ថា ហៅ គឺ ហៅរកភ័យ និង អារម្មណ៍ដែលគួរខ្លាចនោះឱ្យចូលមករកខ្លួន

ដូចពណ៌នាមកដូច្នេះ ។

ក្នុងពាក្យថា **បញ្ញាសម្បន្នោហមស្មិ** មានអធិប្បាយថា អ្នកដល់ ព្រម គឺ អ្នកប្រកបព្រមដោយបញ្ញា ។ តែមិនមែនដោយវិបស្សនាបញ្ញា មិនមែនដោយមគ្គបញ្ញាដោយពិតហើយ ប្រកបដោយបញ្ញា និង គ្រឿងកំណត់អារម្មណ៍ ព្រោះហេតុ ១៦ ប្រការនេះ ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយគ្រប់ ៗ បទនោះឯង ។

( ចប់ការកំណត់អារម្មណ៍ព្រោះហេតុ ១៦ ប្រការ )

បទថា **តស្ស មយ្ហំ** មានអនុសន្ធិ (ការបន្តលំដាប់សេចក្តី) ដូចម្តេច ?

បានឮថា ព្រះពោធិសត្វកំណត់អារម្មណ៍ ១៦ យ៉ាងនេះ លុះមើលមិនឃើញភ័យ និង អារម្មណ៍ដែលគួរខ្លាច (នោះ) ត្រិះរិះថា ធម្មតាសេចក្តីខ្លាច និង អារម្មណ៍ដែលគួរខ្លាច រមែងនឹងប្រាកដក្នុងសេនាសនៈយ៉ាងនេះ ក្នុងរាត្រី ដូច្នេះ ណ្ហើយចុះយើងនឹងស្វែងរកមើលសេចក្តីខ្លាច និង អារម្មណ៍ដែលគួរ ខ្លាចនុះក្នុងសេនាសនៈយ៉ាងនោះ ក្នុងរាត្រីដូច្នោះ ទើបបានស្វែងរកភ័យ និង អារម្មណ៍ដែលគួរខ្លាច ។ ដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសេចក្តីនេះដល់ព្រាហ្មណ៍ ទើបត្រាស់ពាក្យថា **តស្ស មយ្ហំ** ដូច្នេះ

ជាដើម ។

## រាត្រី កំណត់តិថីនៃបក្ខ

បណ្ដាបទទាំងនោះ បទថា **យា តា** ជាពាក្យលើករាត្រីតែម្យ៉ាងទេឡើងសម្ដែង ។ ស័ព្ទថា **អភិ** ក្នុងបទថា **អភិញ្ញាតា** គប្បីជ្រាបថា រាត្រីទាំងទឡាយ លោកកំណត់ដោយលក្ខណៈទាំងទឡាយ មានអាទិយ៉ាងនេះថា ព្រះច័ន្ទពេញវង់ ព្រះច័ន្ទដែលអស្ដង្គត ។

(ចំណែក ) ស័ព្ទថា **អភិ** ក្នុងបទថា **អភិលក្ខិតា** ត្រឹមតែជាឧបសគ្គប៉ុណ្ណោះ ព្រោះដូច្នោះ ទើបមានសេចក្ដីថា **អភិលក្ខិតា** ក៏គឺ **លក្ខណីយា** (គប្បីកំណត់ ) នោះឯង ។ ពង្រីកសេចក្ដីថា រាត្រីទាំងទឡាយដែលបណ្ឌិតគប្បីកំណត់អធិប្បាយ គប្បីកំណត់ដោយល្អ គឺ គប្បីកំណត់ឱ្យហ្មត់ចត់ ដើម្បីធ្វើកិច្ចមានការសមាទានឧបោសថ ការស្ដាប់ធម៌ និង ការបូជាសក្ការជាដើម ។

ដែលឈ្មោះថា **ចាតុទ្ទសី** បានដល់ រាត្រីមួយដែលធ្វើឱ្យគ្រប់ ១៥ ថ្ងៃ ចាប់ផ្ដើមតាំងតែពីថ្ងៃនៃបក្ស ។ **បញ្ចទសី** និង **អដ្ឋមី** ក៏ (មាន សេចក្ដី) យ៉ាងនោះដូចគ្នា បទថា **បក្ខស្ស** បានដល់ នៃ សុក្កបក្ស និង កណ្ហបក្ស ។ ព្រោះរួមរាត្រីទាំងនោះចូលជាមួយនឹងបក្សនីមួយ ៗ មាន

៣ រាត្រី ទើបជា ៦ រាត្រី ដូច្នោះ ទើបគួរប្រកបពាក្យថា «បក្ស» ចូល ទុកក្នុងបទថា **បក្ខស្ស ចតុទ្ទសី** តិថីទី ១៥ នៃបក្ស , **បក្ខស្ស បញ្ចសីទ** តិថីទី ៨ នៃបក្ស ។

សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកមិនចាត់តិថីគតិទី ៥ ចូលផង ?

ឆ្លើយថា ព្រោះតិថីគតិទី ៥ មិនមានរហូតកាល បានឮមកថា ក្នុងកាលមុន ៗ កាលព្រះមានព្រះភាគជាម្ចាស់ ស្តេចនៅមិនទាន់ឧប្បត្តិទេឡើងក្តី ស្តេចឧប្បត្តិទេឡើងហើយនៅមិនទាន់បរនិព្វានក្តី តិថីទី ៥ លោកមិនបានកំណត់ទុកទេឡើយ លុះកាលព្រះមានព្រះភាគរំលត់ខន្ធបរិនិព្វានហើយ ព្រះធម្មសង្គាហកត្ថេរទាំងទឡាយទើបនាំគ្នាគិតថា ការស្តាប់ព្រះធម៌នឹងមាន ក៏យូរ ៗម្តង ។ ពេលនោះទើបសម្មតិកំណត់តិថីទី៥ឱ្យជាថ្ងៃធម្មស្សវនៈ រាប់តាំងពីនោះមក តិថីទី ៥ ទើបក្លាយជាថ្ងៃដែលលោកកំណត់ទុកហើយ ព្រោះហេតុដែលតិថីទី ៥ មិនមានរហូតកាលយ៉ាងនេះឯង ទើបលោកមិនចាត់រួមទុកក្នុងទីនេះ ។

បទថា **តថារូបាសុ** ក៏គឺ **តថាវិធាសុ** (យ៉ាងនោះ) ។

## ចេតិយ៍

បទថា **អារាមចេតិយានិ** សេចក្តីថា ភូមិដែលជាទីរីករាយទាំងទឡាយ

ដូចសួនផ្កា សួនផ្លែឈើ ជាដើមនោះឯង ឈ្មោះថា **អារាមចេតីយ** ព្រោះ ថា ស្ថានទីទាំងនោះទាំងនោះហៅថា ចេតីយ៍ ព្រោះអត្ថថា ជាទីកោតក្រែង អធិប្បាយថា ព្រោះអត្ថថា ជាស្ថានទីដែលបុគ្គលគប្បីបូជា ។

បទថា **វនចេតិយានិ** សេចក្តីថា ព្រៃទាំងទឡាយ ដងព្រៃសម្រាប់ នាំគ្រឿងសែនព្រេនទៅសែនដល់ ( ទេវតា ) ព្រៃសុភគវ័ន និង ព្រៃដែលជាទី រីករាយរបស់ទេវតាជាដើមនោះឯង ឈ្មោះថា **វនចេតីយ៍** ។

បទថា **រុក្ខចេតិយានិ** សេចក្តីថា ដើមឈើដែលគួរបូជាតាមទ្វារស្រុក និង និគមជាដើមនោះឯងឈ្មោះថា **រុក្ខចេតីយ៍** ។

ព្រោះសត្វលោកសម្គាល់ថា ទេវតាស្ថិតនៅខ្លះ មានសេចក្តីសម្គាល់ ក្នុងស្ថានទីនេះឯងថា ជាទិព្វខ្លះ ទើបនាំគ្នាធ្វើការគោរព គឺ បូជាព្រៃនិងដើម ឈើទាំងទឡាយ ដូច្នោះ ព្រៃនិងដើមឈើទាំងអស់ទើបនាំគ្នាហៅថា ចេតីយ៍ ។

បទថា **ភិសនកានិ** ប្រែថា ឱ្យកើតសេចក្តីខ្លាច គឺ ញុំាងសេចក្តីខ្លាច ឱ្យកើតដល់អ្នកឃើញ និង ដល់អ្នកស្តាប់ ។

បទថា **អប្បេវ នាម បស្សេយ្យំ** សេចក្តីថា ធ្វើដូចម្តេចហ្ន៎ យើងនឹងគប្បីបានប្រសព្វនឹងភ័យ និង អារម្មណ៍ដែលគួរខ្លាចនោះខ្លះ ។

បទថា **អបរេន សមយេន** សេចក្តីថា ដោយកាលដទៃអំពីកាល

ដែលគិតទុកហើយយ៉ាងនេះថា ( តថាគតនោះ ) មានការគិតដូច្នេះថា ធ្វើដូចម្តេច តថាគត ។

បទថា **តត្ថ ច មេ ព្រាហ្មណ វិហរតោ** (ម្នាលព្រាហ្មណ៍ ក៏កាលតថាគតនៅក្នុងស្ថានទីទាំងនោះ ) សេចក្តីថា បណ្តាសេនាសនៈទាំងនោះ សេនាសនៈណា ៗ ដែលជាកន្លែងនៅរបស់យក្ស ដែលមនុស្សទាំងទឡាយគួរបន់ស្រន់នាំគ្រឿងសែនព្រេនទៅថ្វាយ មានធរណីពាសពេញទៅដោយគ្រឿងបូជា និង គ្រឿងសែនព្រេនទាំងទឡាយ ដូចផ្កាឈើ ធូប សាច់ ឈាម ទឹកដោះរាវ ទឹកដោះខាប់ លំពែង ស្រោចសុរា និង មេរ័យជាដើម ដូចជាទីកន្លែងដែលរួមប្រជុំគ្នារបស់ពួកយក្សកាច និង បិសាច ដែលមនុស្សទាំងទឡាយមកឃើញក្នុងពេលថ្ងៃ នឹងធ្វើឱ្យរន្ធត់ចិត្តរហូតស្លាប់ ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សំដៅកន្លែងនុះទើបត្រាស់ថា**តត្ថចមេព្រាហ្មណ វិហរតោ** ។

## អត្ថនៃពាក្យថា មិគ និង មោរ

បទថា **មិគោ វា អាគច្ឆតិ** សេចក្តីថា ម្រឹគដែលចែកប្រភេទឈ្លូស ក្តាន់ ប្រើស ខ្លាដំបង និង ជ្រូកព្រៃជាដើម ដើរអួសស្អែង ឬ ដើរទាត់ ក្រចកគ្នាមក ក៏ពាក្យថា **មិគោ** ក្នុងទីនេះ ជាឈ្មោះសត្វជើង ៤ គ្រប់

ប្រភេទ ។ តែក្នុងកន្លែងខ្លះ **មិគ** (ម្រឹគ) លោកពោលថា បានដល់ឆ្កែចចកខ្លាក់ភ្នែកខ្លះ ។ ដូចដែលសត្វពោល (អួតសរសើរឆ្កែចចកខ្លាក់ភ្នែក) ថា ÷

កររបស់លោក ល្អសង្ហាដូចកគោ ឧសភៈ និង ដុចកររបស់

រាជសីហ៍ដូច្នោះ បពិត្រស្តេចម្រឹគខ្ញុំសូមនមស្ការចំពោះលោក

ពួកយើងនឹងធ្វើអ្វីខ្លះទេ ?

បទថា **មោរោ វា កដ្ឋំ បាតេតិ** សេចក្តីថា សត្វក្ងោកធ្វើមែកឈើស្ងួតឱ្យធ្លាក់ចុះពីដើមឈើហើយ និង ដោយស័ព្ទថា **មោរ** ក្នុងពាក្យនេះ លោកបានសំដៅបក្សីគ្រប់ជំពូក ។ ព្រោះហេតុនោះ លោកទើបដោះស្រាយថា បានដល់ **យោ កោចិ បក្ខី** សត្វណានិមួយក៏ដោយ ។ ម្យ៉ាងទៀត ដោយ **វា** ស័ព្ទក្នុងពាក្យថា **មោរោ វា** លោកឆ្លើយថា បានដល់ បក្សីប្រភេទដទៃ ៗ ឬ ជាប់ខ្លួន ។ សូម្បីក្នុង **មិគ**ស័ព្ទ ដែលជាស័ព្ទដំបូង ( ស័ព្ទមុនថា **មោរោ** ) ក៏មានន័យនេះ ។

បទថា **វាតោ វាបណ្ណកសដំ ឯរេតិ** សេចក្តីថា ខ្យល់ក៏បក់ផាត់ស្លឹកឈើ និង សម្រាម ។

បទថា **ឯតំ នូន តំ ភយភេរវំ អាគច្ឆតិ** សេចក្តីថា វត្ថុណា

រមែងមក (ប្រាកដ) វត្ថុនោះចាត់ជាភ័យ និង អារម្មណ៍ដែលគួរខ្លាចពិតប្រាកដ ហើយតាំងពីឥទឡូវនេះទៅ អារម្មណ៍នោះឯង គប្បីជ្រាបថា ជាភ័យ និង អារម្មណ៍ដែលគួរខ្លាច ព្រោះមានភ័យទាំងតិចតួច និង ប្រមាណក្រៃ-លែងជាអារម្មណ៍ អារម្មណ៍ទើបឈ្មោះថា ភ័យ និង វត្ថុដែលគួរខ្លាច ប្រៀបដូចរូបដែលមានសេចក្ដីសុខជាអារម្មណ៍ ក៏ឈ្មោះថា ជាសុខដែរ ដូច្នោះ ។

បទថា **កន្នុខោ អហំ អញ្ញទត្ថុំ ភយបាដិកង្ខី វិហរាមិ** សេចក្ដីថា តថាគតសង្ស័យ គឺ ប្រាថ្នានូវអ្វីជាភ័យដោយចំណែកមួយនោះឯង ទើបនៅ ។

បទថា **យថាភូតស្ស យថាភូតស្ស** សេចក្ដីថា នៅ គឺ ប្រព្រឹត្តទៅ ឬសម្រេចដោយឥរិយាបថណា ៗ ។

បទថា **មេ** គឺ ក្នុងសម្នាក់របស់តថាគត ។

បទថា **យថាភូតស្ស យថាភូតស្ស វា** សេចក្ដីថា នៅ គឺ ប្រព្រឹត្តទៅ ឬសម្រេចដោយឥរិយាបថនោះ ៗ ឯង ។

បទថា **សោ ខោ អហំ ។ បេ ។ បដិវិនេមិ** សេចក្ដីថា បានឮថា កាលព្រះពោធិសត្វកំពុងចង្រ្កម លុះកាលអារម្មណ៍ដែលគួរភ័យ និង វត្ថុដែលគួរខ្លាចមានប្រភេទជាស្នែងម្រឹគ និង សំទេឡងក្រចកជើងជាដើមមកប្រាកដ អង្គព្រះមហាសត្វមិនឈរ (ស្ងៀម) មិនអង្គុយ មិនដេក ។

ស្តេចខំចង្ក្រមតទៅ ពិចារណា ពិនិត្យពិគ្រោះ ( ដរាបទាល់តែ ) មើលមិនឃើញថា ជាភ័យ និង វត្ថុដែលគួរខ្លាច ឃើញត្រឹមតែជាស្នែងម្រឹគ និង សំទេឡងក្រចកជើងជាដើមប៉ុណ្ណោះ ។ កាលជ្រាបអារម្មណ៍នោះថា នុះជារបស់នេះ មិនមែនជាភ័យ និង វត្ថុដែលគួរខ្លាចទេ ដូច្នេះហើយ បន្ទាប់ពីនោះទៅ ព្រះអង្គទើបឈប់ ឈរ អង្គុយ ឬ ដេក ។

កាលនឹងទ្រង់សម្តែងសេចក្តីយ៉ាងនេះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ពាក្យថា **សោ ខោ អហំ** ដូច្នេះជាដើម ។ ក្នុងគ្រប់ៗ បេយ្យាលក៏មានដូច្នេះដែរ ។

## សេចក្តីឆ្លាតឈ្លាសក្នុងការចេញចាកសមាបត្តិ

តអំពីនេះទៅ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ឥរិយាបថទុកតាមលំដាប់ទីជិតគ្នា មិនបានត្រាស់ទុកតាមលំដាប់នៃឥរិយាបថ ។ អធិ_ប្បាយថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកតាមលំដាប់ទីជិតគ្នានៃឥរិយាបថនោះ ៗ យ៉ាងនេះថា ក៏កាលដែលតថាគតកំពុងចង្ក្រម កាលភ័យ និង អារម្មណ៍ដែលគួរខ្លាចមកប្រាកដ តថាគតក៏មិនឈប់ឈរ មិនអង្គុយ មិនដេកសូម្បីកាលតថាគតប្រថាប់ឈរ កាលភ័យ និង អារម្មណ៍ដែលគួរខ្លាចមក ប្រាកដ តថាគតក៏មិនដើរចង្ក្រម ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងការដែលព្រះអង្គមិនមានភ័យ និងអារម្មណ៍ដែលគួរតក់ស្លុតយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងទ្រង់សម្តែងការដែលព្រះអង្គរស់នៅដោយការមិនវង្វេង ក្នុងឋានៈជាទីតាំងនៃសេចក្តីឈ្លក់វង្វេងរបស់បុគ្គលអ្នកបានឈានទាំងឡាយ ទើបត្រាស់ពាក្យថា **សន្តី ខោ បន ព្រាហ្មណ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សន្តិ** ស្មើនឹង **អត្ថិ** មានហើយ គឺ **សំវិជ្ជន្តិ** មាននៅព្រម បានដល់ **ឧបលព្ភន្តិ** បានយ៉ាងពិតប្រាកដ ។

បទថា **រត្តិំយេវ សមានំ** ប្រែថា វេលាដែលជាពេលយប់ ។

បទថា **ទិវាតិ សញ្ជានន្តិ** ប្រែថា សម្គាល់ថា វេលានេះជា វេលាថ្ងៃ ។

បទថា **ទិវាយេវ សមានំ** ប្រែថា វេលាដែលជាពេលថ្ងៃ ជាពេល យប់ ។

បទថា **រត្តីតិ សញ្ជានន្ត** ប្រែថា សម្គាល់ថា វេលានេះជាពេល យប់ ។

សួរថា ក៏ព្រោះហេតុអ្វី បុគ្គលអ្នកបានឈានយ៉ាងនេះ ទើបមានការសម្គាល់យ៉ាងនេះ ?

ឆ្លើយថា ព្រោះមិនមានការឆ្លាតឈ្លាសក្នុងការចេញចាកឈាន ឬព្រោះសំទេឡងសត្វយំ ។

សួរថា ជាយ៉ាងណា ?

ឆ្លើយថា បុគ្គលអ្នកបានឱទាតកសិណខ្លះក្នុងលោកនេះ កើតមនសិការៈទេឡីងថា យើងធ្វើបរិកម្មក្នុងពេលថ្ងៃ ចូល (ឈាន ) ក្នុងវេលាថ្ងៃនឹងចេញវេលាថ្ងៃនោះឯង តែថា លោកក៏មិនឈ្លាសក្នុងការកំណត់វេលាចេញនោះឯង លោកទើបចូលឈានកន្លងហួសពេលថ្ងៃចេញក្នុងវេលាយប់ និងដោយអំណាចនៃការផ្សាយទៅនៃឱតទាកសិណ កសិណរបស់លោកទើបផូរផង់ថែងចាំងភ្លឺច្បាស់ លោកក៏សម្គាល់យប់នោះឯងថា ថ្ងៃ ព្រោះហេតុដែលកើតមនសិការថា នឹងចេញក្នុងពេលថ្ងៃ និង ព្រោះការផ្សាយទៅនៃឱទាតកសិណដែលផូរផង់ ថែងចាំង ភ្លឺច្បាស់ ។ តែបុគ្គលអ្នកបាននីល_កសិណខ្លះ ក្នុងលោកនេះកើតមនសិការថា យើងធ្វើបរិកម្មក្នុងពេលយប់ចូលក្នុងពេលថ្ងៃហើយ នឹងចេញក្នុងពេលយប់នោះឯង តែលោកមិនឆ្លាត_ឈ្លាសក្នុងការកំណត់វេលា (ចេញ ) លោកទើប (ចូលឈាន ) កន្លងហួសពេលយប់ទៅចេញក្នុងពេលថ្ងៃ និង ដោយអំណាចការផ្សាយទៅនៃនីលកសិណកសិណរបស់លោកមិនផូរផង់ មិនភ្លឺច្បាស់ លោកក៏សម្គាល់ថ្ងៃនោះឯងថា

យប់ ព្រោះហេតុដែលកើតមនសិការថា នឹងចេញក្នុងពេលយប់ និង ព្រោះការផ្សាយទៅហើយនៃនីលកសិណមិនថ្លូវផង់ មិនភ្លឺច្បាស់ ។ ព្រោះមិនមានការឆ្លាតឈ្លាសក្នុងការចេញ (ចាកឈាន ) យ៉ាងនេះ បុគ្គលបានឈានទើបមានសេចក្ដីសម្គាល់ដូចពណ៌នាមកដូច្នេះ ។

ចំណែកដែលពោលថា ព្រោះសំទេឡងសត្វយំ (មានយ៉ាងនេះ ) គឺ បុគ្គលអ្នកបានឈាន កន្លងបុគ្គលក្នុងលោកនេះ អង្គុយក្នុងសេនាសនៈ ទីនោះ សត្វព្រៃទាំងទឡាយមានបក្សី និង ក្អែកជាដើម ដែលយំស្រែកក្នុងពេលថ្ងៃ សម្គាល់ថា ជាពេលថ្ងៃ ព្រោះពន្លឺព្រះច័ន្ទ ទើបបញ្ចេញសំទេឡងស្រែកក្នុងពេលយប់ ឬ បញ្ចេញសំទេឡងស្រែកព្រោះហេតុដទៃ ។ លោកបានឮសំទេឡងរបស់សត្វព្រៃទាំងនោះហើយសម្គាល់វេលាយប់នោះឯងនោះឯងថាជាថ្ងៃ។ តែថា បុគ្គលអ្នកបានឈានកន្លងបុគ្គលក្នុងលោកនេះ អង្គុយនៅក្នុងល្អាងភ្នំបិទបាំងដោយព្រៃស្អុក ដែលនៅជ្រៅក្នុងចន្លោះភ្នំ ក្នុងពេលដែលមានពន្លឺថ្ងៃបាត់ទៅក្នុងរដូវភ្លៀងធ្លាក់រហូតដល់ ៧ ថ្ងៃ សត្វព្រៃទាំងទឡាយ មានបក្សីដែលយំស្រែកក្នុងពេលយប់ និង សត្វទីទុយជាដើម ស្រងាកចិត្តនៅក្នុងទីងងឹតនោះៗ សូម្បីក្នុងវេលាថ្ងៃត្រង់ហើយ បញ្ចេញសំទេឡងស្រែកយំដោយសម្គាល់ ( ខុស ) ថា ជាពេលយប់ ឬ ដោយហេតុដទៃ ។ បុគ្គលអ្នកបានឈាន

នោះ បានឮសំទេឡងរបស់សត្វព្រៃទាំងទឡាយនោះ រមែងសម្គាល់រមែងថ្ងៃពិត ៗ ថាជាពេលយប់ ។ ព្រោះសំទេឡងសត្វយំដូចពណ៌នាមកយ៉ាងនេះ បុគ្គលអ្នកបានឈានទើបមានសេចក្ដីសម្គាល់យ៉ាងនេះឯង ។

## បទេសញ្ញាណ ( ញ្ញាណជាគ្រឿងកំណត់វេលា )

បទថា **ឥមេហិ** សេចក្ដីថា តថាគតរមែងពោលវត្ថុនេះ គឺ ការកំណត់សម្គាល់យ៉ាងនេះ ។

បទថា **សម្មោហវិហារស្មឹ វទាមិ** មានអធិប្បាយថា តថាគតរមែង ពោល ( ការកំណត់សំគាល់ ) ថា ជាការនៅដែលប្រកបដោយការវង្វេង គឺ ចាត់នៅក្នុងការវង្វេងភាន់ស្មារតី បានដល់ ពោលថាជាការនៅវង្វេងភាន់ស្មារតីណានីមួយ ។

បទថា **អហំ ខោ បន ព្រាហ្មណ ។ល។ សញ្ជានាមិ** សេចក្ដីថា ការកំណត់ពេលយប់ ពេលថ្ងៃ របស់ព្រះពោធិសត្វប្រាកដហើយ សូម្បីក្នុងវេលាដែលភ្លៀងធ្លាក់ជោកជាំរហូតអស់ ៧ ថ្ងៃ ព្រះច័ន្ទ និង ព្រះអាទិត្យមិនបញ្ចេញពន្លឺ ព្រះពោធិសត្វក៏រមែងដឹងបានឯងថា រយៈពេលប៉ុណ្ណេះជាវេលាអាហារព្រឹក រយៈពេលវេលាប៉ុណ្ណេះដែលជាវេលាក្រោយភត្ត រយៈវេលាប៉ុណ្ណេះដល់បឋមយាម រយៈពេលវេលាប៉ុណ្ណេះដល់មជ្ឈិមយាម ព្រោះហេតុ

នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ទុកហើយយ៉ាងនោះ ក៏មិនគួរអស្ចារ្យទេឡើយដែលព្រះពោធិសត្វអ្នកមានបារមីបំពេញមកហើយនឹងដឹងយ៉ាងនេះ ។

សូម្បីពួកព្រះអរិយសាវក ដែលឋិតនៅក្នុងប្រទេសញ្ញាណក៏ប្រាកដថា ការកំណត់វេលាយប់ និង វេលាថ្ងៃបាន ។ មានរឿងដំណាលថា **ព្រះគោ-ទត្តត្ថេរ** នៅក្នុងកល្យាណីមហាវិហារ ទទួលភត្ត ក្នុងវេលា ២ អង្គុលី ហើយឆាន់ក្នុងវេលា ២ អង្គុលី (នោះឯង ) កាលព្រះអាទិត្យមិនទាន់ប្រាកដ ក៏ចូលទៅក្នុងសេនាសនៈពីព្រលឹម ។ ចេញមកក្នុងវេលា (ជាមួយគ្នា ) នោះ ។ ថ្ងៃមួយពួកអ្នកបម្រើវត្តគិតថា ពួកយើងនឹងបានជួបលោកក្នុងវេលាដែលលោកចេញមកថ្ងៃស្អែកនេះ ទើបចាត់ចែងភត្តហើយ អង្គុយ (រង់ចាំ ) នៅទីជិតបង្គោលប្រាប់វេលា ( បង្គោលវាស់ស្រមោលថ្ងៃ ) ព្រះថេរៈចេញមកនៅក្នុងវេលា ២ អង្គុលី ដូចដើម បានឮមកថា តាំងពីពេលនោះមក ព្រះអាទិត្យនៅមិនទាន់ប្រាកដ ពួកអ្នកបម្រើវត្ត ក៏នឹងវាយស្គរ ជាសញ្ញាដែលព្រះថេរៈចេញមក ។

សូម្បីនៅក្នុង **ធជាគរវិហារ ព្រះកាលិទេវត្ថេរ** គោះរគាំងប្រាប់យាមក្នុងវស្សា ការគោះរគាំងប្រាប់យាមនោះ ជាកិច្ចវត្តប្រចាំថ្ងៃរបស់ព្រះថេរៈតែថា ព្រះថេរៈមិនព្រមប្រើនាទទ្បិកាគ្រឿងចក្រ ។ ចំណែកពួកភិក្ខុដទៃប្រើ ។

កាលតមកបឋមយាមកន្លងផុតទៅល្មមពេលព្រះថេរៈកាន់ឈើគោះ (រគាំង) លោកបានគោះរគាំងតែ ២ ដងប៉ុណ្ណោះ នាឡិកាគ្រឿងចក្រ ក៏រោទិ ។ យ៉ាងនេះឯង ព្រះថេរៈទើបបំពេញសមណធម៌ក្នុងយាមទាំង ៣ ហើយចូលទៅក្នុងភូមិពីព្រលឹមដើម្បីទទួលបិណ្ឌបាត ត្រទឡប់មកវត្ត ក្នុងវេលានឹងឆាន់ ក៏កាន់យកបាត្រទៅកាន់ទីសម្រាកពេលថ្ងៃ បំពេញសមណធម៌ ។ ភិក្ខុទាំងទឡាយឃើញបង្គោលប្រាប់ពេលហើយបានបញ្ជូនភិក្ខុទៅ ដើម្បីត្រូវការ (ក្នុងការនិមន្ត ) ឱ្យព្រះថេរៈមក ។ ភិក្ខុ ( ដែលទៅ ) នោះ បានជួបព្រះថេរៈ (ខណៈ ) កំពុងចេញមកអំពីទីសម្រាកពេលថ្ងៃខ្លះ ក្នុងចន្លោះផ្លូវខ្លះ សូម្បីពួកព្រះសាវកដែលឋិតនៅក្នុងបទេសញ្ញាណ រមែងកំណត់វេលាថា ជាពេលយប់ និង ពេលថ្ងៃបានយ៉ាងនេះ ក៏នឹងចាំបាច់ពោលថ្វីដល់ព្រះពោធិសត្វទាំងទឡាយ ។

## តថាគតឧប្បត្តិមកដើម្បីប្រយោជន៍សុខ

ក៏ក្នុងពាក្យថា **យំ ខោ តំ ។បេ។ វទេយ្យ** នេះ អ្នកសិក្សាគប្បីជ្រាបបទសម្ពន្ធ (ការតបទ ) យ៉ាងនេះថា ម្នាលព្រាហ្មណ៍នរណា ៗ កាលនឹងពោលពាក្យណាថា សត្វអ្នកមានសភាពមិនវង្វេងជាធម្មតា ឧប្បត្តិទេឡើងក្នុងលោក ។ល។ ដើម្បីសេចក្ដីសុខដល់ទេវតា និង មនុស្សទាំងទឡាយ ទើប

នឹងឈ្មោះថា ពោលដោយប្រពៃ គឺ ជាអ្នកពោលយ៉ាងត្រឹមត្រូវ ពោលមិនឃ្លាងឃ្លាត កាលគេពោលពាក្យនោះចំពោះតថាគតប៉ុណ្ណោះ ទើបនឹងឈ្មោះ ថា ពោលដោយប្រពៃ គឺ ជាអ្នកពោលយ៉ាងត្រឹមត្រូវ ពោលមិនឃ្លាងឃ្លាត ។

បណ្ដាបទទាំងនោះ បទថា **អសម្មោហធម្មោ** ប្រែថា មានការមិនវង្វេងជាសភាវៈ ។

បទថា **លោកេ** បានដល់ ក្នុងមនុស្សលោក ។

បទថា **ពហុជនហិតាយ** ប្រែថា ដើម្បីប្រយោជន៍ដ៏ក្រៃលែងដល់ជនចំនួនច្រើន អធិប្បាយថា ( សត្វនោះ ) ជាអ្នកសម្ដែងនូវប្រយោជន៍ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងសម្បរាយិកភពដោយការដល់ព្រមនៃបញ្ញា ។

បទថា **ពហុជនសុខាយ** ប្រែថា ដើម្បីប្រយោជន៍សុខដល់ជនជា ច្រើន អធិប្បាយថា (សត្វនោះ) ជាអ្នកឱ្យនូវសម្បត្តិដែលជាឧបករណ៍នៃ សេចក្ដីសុខដោយការដល់ព្រមនៃចាគៈ (ការលះបង់) ។

បទថា **លោកានុកម្បាយ** ប្រែថា ដើម្បីប្រយោជន៍អនុគ្រោះលោក អធិប្បាយថា (សត្វនោះ ) ជាអ្នករក្សា ជាអ្នកឃុំគ្រងលោក ដូចមាតាបិតា (គ្រប់គ្រងបុត្រ) ដោយការដល់ព្រមនៃមេត្តាករុណា ។

និងដោយស័ព្ទថា “ **ទេវមនុស្ស** ” ក្នុងពាក្យថា **អត្ថាយ ហិតាយ**

**សុខាយ ទេវមនុស្សានំ** នេះ អ្នកសិក្សាគប្បីជ្រាបថា ព្រះមានព្រះភាគ-ជាម្ចាស់ទ្រង់សំដៅយកចំពោះតែវេនេយ្យសត្វអ្នកជាភព្វបុគ្គល ( បុគ្គលដែលគួរនឹងត្រាស់ដឹង ) ហើយសម្តែងការឧប្បត្តិរបស់ព្រះអង្គ ក៏ដើម្បីត្រូវការឱ្យវេនេយ្យសត្វទាំងនោះបានសម្រេចមគ្គ ផល និព្វាន ។ កាលព្រះមានព្រះ-ភាគជាម្ចាស់ត្រាស់ថា **អត្ថាយ** (ដើម្បីប្រយោជន៍ ) រមែងសំដៅដល់ថាដើម្បីប្រយោជន៍ដល់បរមត្ថ គឺ ដើម្បីនិព្វាន ។ កាលដែលព្រះមានព្រះមាន-ភាគជាម្ចាស់ត្រាស់ថា **ហិតាយ** (ដើម្បីប្រយោជន៍ដ៏ក្រៃលែង ) រមែងសំដៅដល់ថា ដើម្បីប្រយោជន៍ដល់មគ្គជាគ្រឿងឱ្យសម្រេចនិព្វាននោះ ។ ព្រោះថាដែលឈ្មោះថា ប្រយោជន៍ដ៏ក្រៃលែងជាងមគ្គជាគ្រឿងឱ្យសម្រេចនិព្វាន មិនមានទេឡើយ កាលព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **សុខាយ** (ដើម្បីសេចក្តីសុខ ) រមែងសំដៅដល់ថា ដើម្បីប្រយោជន៍ដល់សេចក្តីសុខ ដែលកើតអំពីផលសមាបត្តិ ។ ព្រោះថា មិនមានសេចក្តីសុខ (ដទៃ ) ដែលក្រៃលែងជាងសេចក្តីសុខ ដែលកើតអំពីផលសមាបត្តិនោះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគជាម្ចាស់ទុកដូច្នេះថា សមាធិនេះអំណោយសេចក្តីសុខដែលជាបច្ចុប្បន្ន និង នៅមានសេចក្តីសុខដែលជាវិបាកតទៅ ។

## បដិបទាគ្រឿងសម្រេចអសម្មោហវិហារ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងការនៅដោយការមិនវង្វេង ( **អសម្មោហវិហារំ** ) របស់ព្រះអង្គ ដែលមានការបានសម្រេចគុណនៃពុទ្ធៈជាទីបំផុតដូចពណ៌នាមកដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងបដិបទាជាហេតុឱ្យសម្រេចការនៅដោយការមិនវង្វេង ដែលដល់ទីបំផុតហើយនោះតាំងពីវេលាដំបូង ទើបត្រាស់ពាក្យថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ** ដូច្នេះជាដើម ។

ចំណែកអាចារ្យពួកខ្លះពោលថា ព្រាហ្មណ៍បានស្ដាប់ការរស់នៅដោយការមិនវង្វេងនេះហើយ បានកើតការគិតទេឡីងយ៉ាងនេះថា ព្រះសមណគោតមសម្រេចការនៅដោយការមិនវង្វេងនេះ ដោយបដិបទាអ្វីហ្ន៎ ព្រះមានព្រះភាគទ្រង់ជ្រាបការគិតរបស់ព្រាហ្មណ៍នោះហើយ កាលនឹងទ្រង់សម្ដែងថា តថាគតបានសម្រេចការនៅដោយការមិនវង្វេងដោយខ្ពស់បំផុតដោយបដិបទានេះ ទើបត្រាស់ទុកយ៉ាងនេះ ។

បណ្ដាបទទាំងនោះបទថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ** មានអធិប្បាយថា ម្នាលព្រាហ្មណ៍ ការរស់នៅប្រកបដោយស្មារតីដ៏ខ្ពង់ខ្ពស់នេះ មិនមែនតថាគតខ្ជិលច្រអូស វង្វេងភ្លេចសតិ មានកាយ_

រសាប់រសល់អន្ទះអន្ទែង ឬ មានចិត្តរាយមាយហើយបានសម្រេចមកទេ ពិតហើយ តថាគតបានប្រារព្ធសេចក្តីព្យាយាម ដើម្បីសម្រេចការរស់នៅដោយការមិនវង្វេងនោះ គឺ តថាគតអង្គុយក្រោមម្លប់ពោធិ បានប្រារព្ធនូវសេចក្តីព្យា-យាមដែលប្រកបដោយអង្គ ៤ ឱ្យប្រព្រឹត្តទៅដោយមិនធូរថយ ។ ក៏ព្រោះប្រារព្ធហើយនោះឯង សេចក្តីព្យាយាមប្រកបដោយអង្គ ៤ នុះ របស់តថាគតទើបមិនធូរថយ ។

បទថា **ឧបដ្ឋិតា សតិ អប្បមុដ្ឋា** សេចក្តីថា ហើយមិនមែនតែសេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះទេ កាលសតិរបស់តថាគតក៏តាំងមាំដោយភាវៈដែលឆ្ពោះមុខទៅរកអារម្មណ៍និងព្រោះតាំងមាំហើយនោះឯងទើបមិន វង្វេង ។

បទថា **បស្សទ្ធោ កាយោ អសារទ្ធោ** សេចក្តីថា ព្រោះមានកាយ និងចិត្តស្ងប់ សូម្បីកាយរបស់តថាគតក៏ស្ងប់ដែរ ។ ក្នុងបទនោះអធិប្បាយថា ព្រោះហេតុដែលនាមកាយស្ងប់ សូម្បីរូបកាយក៏រមែងស្ងប់ដូចគ្នាដែរ ដូច្នោះព្រះមានភាគជាម្ចាស់ទើបត្រាស់ ( រួម ៗ ) ថា កាយស្ងប់ ដោយមិនបានត្រាស់ចែកថា នាមកាយ រូបកាយ ។

បទថា **អសារទ្ធោ** សេចក្តីថា ក៏ព្រោះស្ងប់ហើយនោះឯង កាយនុះ

ទើបឈ្មោះថា មិនរសាប់រសល់ អធិប្បាយថា ប្រាសចាកការប្រវល់ក្រវាយ ។

បទថា **សមាហិតំ ចិត្តំ ឯកគ្គំ** សេចក្តីថា សូម្បីចិត្តដែលតថាគតតាំងទុកដោយប្រពៃហើយ គឺ ដូចជា (ចាប់ ) ចាប់ដាក់ទុកដោយល្អហើយ ព្រោះតាំងទុកដោយប្រពៃហើយនោះឯង ទើបមានឈ្មោះថា មានអារម្មណ៍មូលតែមួយដ៏ប្រសើរដ៏ក្រៃលែង មិនញាប់ញ័រ មិនរើបំរះ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់បដិបទា ដែលជាចំណែកខាងដើមនៃឈានទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

RbeyaCn_rbs´Qan 4

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ នឹងទ្រង់សម្តែងនៅគុណវិសេសផ្តើមតាំងពីបឋមឈានរហូតដល់វិជ្ជា ៣ ជាទីបំផុត ដែលព្រះអង្គទ្រង់សម្រេចហើយដោយបដិបទានេះ ទើបត្រាស់ពាក្យថា **សោ ខោ អហំ** ដូច្នេះជា ដើម ។ ក្នុងពាក្យតម្រាស់នោះ ពាក្យណាដែលនឹងត្រូវពោលក្នុងវារៈនេះថា **វិវិច្ចេវ កាមេហិ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ វិហាសឹ** ពាក្យ នោះទាំងអស់បានពោលទុកហើយក្នុងវគ្គដែលពោលដោយបឋវីកសិណ ក្នុង គម្ពីរវិសុទ្ធិមគ្គ ។ ការពិត មានសេចក្តីប្លែកគ្នាតែមួយកន្លែងប៉ុណ្ណោះ ដូច្នេះ (គឺ ) ក្នុងគម្ពីរវិសុទ្ធិមគ្គនោះ បទកិរិយាសម្តែងមកថា **ឧបសម្បជ្ជ វិហរតិ**

(តែ) ក្នុងទីនេះសម្តែងមកថា **វិហាសិ** ។

ស្ួរថា ក៏ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ធ្វើយ៉ាងណា ទើបចូលឈានទាំងនោះបាន ។

ឆ្លើយថា ទ្រង់ចម្រើនកម្មដ្ឋាន

ស្ួរថា កម្មដ្ឋានប្រការយ៉ាងណា ?

ឆ្លើយថា អានាបានសតិកម្មដ្ឋាន

ក៏ឈាន ៤ នេះ សម្រាប់បុគ្គលខ្លះមានភាពតែមួយនៃចិត្ត ជាផលសម្រាប់បុគ្គលខ្លះជាបាទ (ជាទីតាំង) នៃការចម្រើនវិបស្សនា សម្រាប់បុគ្គល ខ្លះជាបាទនៃការបានអភិញ្ញា សម្រាប់បុគ្គលខ្លះ ជាបាទនៃការចូលនិរោធ (ព្រះ_និព្វាន) សម្រាប់បុគ្គលខ្លះ មានឈានចុះកាន់ភពជាផល ។

បណ្តាលបុគ្គលទាំងនោះ សម្រាប់ព្រះខីណាស្រព ឈាន ៤ មានភាពតែមួយនៃចិត្តជាផល ព្រោះថា ព្រះខីណាស្រពទាំងនោះ ធ្វើបរិកម្មកសិណយ៉ាងនេះថា យើងនឹងចូលឈានមានចិត្តមានភាពតែមួយនៅជាសុខរហូតអស់មួយថ្ងៃ ដូច្នេះ ហើយធ្វើសមាបត្តិ ៨ ឱ្យកើតទេឡើង ។

ចំណែកព្រះសេក្ខៈ និង បុថុជ្ជនគិតថា យើងចេញចាកសមាបត្តិហើយមានចិត្តជាសមាធិ នឹងឃើញច្បាស់ ដូច្នេះ ហើយធ្វើវិបស្សនាឱ្យកើតទេឡើង

( យ៉ាងនេះ) ឈានរមែងឈ្មោះថា ជាបាទនៃការចម្រើនវិបស្សនា ។

ចំណែកឈានលាភីបុគ្គលពួកណាធ្វើសមាបត្តិ ៨ ឱ្យកើតទឡើង ហើយចូលឈានដែលជាបាទនៃអភិញ្ញា ចេញចាកសមាបត្តិហើយ ប្រាថ្នាអភិញ្ញាដែលមានន័យដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកហើយថា សូម្បីជាមនុស្សម្នាក់ ក៏ធ្វើឱ្យជាមនុស្សច្រើននាក់បាន ដូច្នេះ ហើយធ្វើអភិញ្ញាកើតចំពោះឈានលាភីបុគ្គលនោះ ឈាន រមែងជាបាទនៃអភិញ្ញា ។

ចំណែកព្រះអរិយបុគ្គលពួកណាធ្វើសមាបត្តិ ៨ ឱ្យកើតបានហើយ ចូលនិរោធសមាបត្តិបានគិតថា យើងនឹងសម្រេចនិរោធ គឺ ព្រះនិព្វានក្នុងបច្ចុប្បន្ននៅជាសុខដោយមិនមានចិត្តសង្ខារ រហូតដល់ ៧ ថ្ងៃ ដូច្នេះ ហើយធ្វើសមាបត្តិឱ្យកើត ឈានរបស់ព្រះអរិយបុគ្គលពួកនោះ រមែងឈ្មោះថា ជាបាទនៃការចូលនិរោធ ។

ចំណែកព្រះអរិយបុគ្គលពួកណាធ្វើសមាបត្តិ ៨ ឱ្យកើតទឡើងបាន គិតថា យើងនឹងជាអ្នកមានឈានមិនវិនាសកើតក្នុងព្រហ្មលោក ដូច្នេះ ធ្វើសមាបត្តិឱ្យកើតទឡើង (យ៉ាងនេះ) ឈានរបស់បុគ្គលពួកនោះរមែងមាន ការឈានចុះកាន់ភពជាផល ។

ក៏ចតុត្ថជ្ឈាននេះ ដែលព្រះមានព្រះភាគជាម្ចាស់ធ្វើឱ្យកើតទឡើងហើយ

ក្រោមម្លប់ពោធិព្រឹក្ស ចតុត្ថជ្ឈាននោះរបស់ព្រះមានព្រះភាគជាម្ចាស់នោះ បាន ជាបាទនៃការចម្រើនវិបស្សនា ជាបាទនៃការចម្រើនអភិញ្ញា និង ឱ្យសម្រេចកិច្ច គ្រប់យ៉ាង ទើបគប្បីជ្រាបថា ផ្តល់គុណប្រយោជន៍ដែលជាលោកិយ និង លោ_ កុត្តរឱ្យបានគ្រប់យ៉ាង ។ ហើយចតុត្ថជ្ឈាននោះបានផ្តល់គុណប្រយោជន៍អ្វីខ្លះ ឱ្យព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងត្រឹមតែចំណែកខ្លះ (ឯក_ទេស) នៃគុណទាំងនោះ ទើបត្រាស់ពាក្យថា **សោ ឯវំ សមាហិតេ ចិត្តេ** ដូច្នេះជាដើម ។

## បុព្វេនិវាសានុស្សតិញ្ញាណ

វិជ្ជា ២ ក្នុងព្រះសូត្រនោះ ( គឺ បុព្វេនិវាសានុស្សតិញ្ញាណ និង ចុតូ_ ប្បាតិញ្ញាណ ) មានការពិណនាទៅតាមបទនៃវិធីចម្រើន បានពោលទុកហើយ យ៉ាងពិស្តារក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ពិតណាស់ ក្នុងគម្ពីរវិសុទ្ធិមគ្គ និង ក្នុងទីនេះ មានសេចក្តីប្លែកគ្នាមួយកន្លែងប៉ុណ្ណោះដូច្នេះ គឺ ក្នុងវិសុទ្ធិមគ្គនោះ លោកពោល បទកិរិយាទុកថា **សោ ឯវំ សមាហិតេ ចិត្តេ ។បេ។ អភិនិន្នាមេតិ** ( តែ) ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់បទកិរិយាទុកថា **អយំ ខោ មេ ព្រាហ្មណ** ក៏មិនបានមកក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ។

បណ្តាបទទាំងនោះ បទថា **សោ** គឺ **សោ អហំ** តថាគតនោះ ។

បទថា **អភិនិន្នាមេសឹ** ប្រែថា នាំទៅចំពោះ ។ ព្រោះព្រះតម្រាស់ ថា **អភិនិន្នាមេសឹ** ក្នុងពាក្យថា **សោ** នេះ ទើបគប្បីជ្រាបន័យយ៉ាងនេះថា **សោ អហំ** យើងតថាគតនោះ ។

ក៏ព្រោះដែលហេតុបុព្វេនិវាសានុស្សតិញ្ញាណនេះ មកហើយ ដោយអំណាចរបស់ព្រះមានព្រះភាគជាម្ចាស់ ដូច្នោះ ទើបគប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះក្នុងពាក្យថា តថាគតនោះចុតិចាកភពនោះហើយ មកឧប្បត្តិក្នុងភពនេះ ។ គប្បីជ្រាប ( អធិប្បាយបន្ថែមទៀត ) ថា ពាក្យថា តថាគតនោះចុតិចាកភពនោះហើយ ជាការពិចារណារបស់ព្រះពោធិសត្វអ្នកពិចារណាត្រទឡប់មកវិញ ព្រោះដូច្នោះ គប្បីជ្រាបសេចក្តីថា ក្នុងពាក្យថា **ឥធូបបន្នោ** ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកភព **តុសិត** ថា តថាគតឧប្បត្តិក្នុងភពតុសិតឯណោះ មុននឹងមកឧប្បត្តិក្នុងភពនេះ ។

បទថា **តត្រាបាសឹ ឯវំនាមោ** សេចក្តីថា សូម្បីក្នុងភពតុសិតនោះ តថាគតជាទេវបុត្រនាមថា **សេតកេតុ** ។

បទថា **ឯវំគោត្តោ** គឺ មានគោត្រតែមួយជាមួយនឹងទេវតាទាំងនោះ ។

បទថា **ឯវំវណ្ណោ** គឺ មានសម្បុរផ្សូរផង់ដូចមាស ។

បទថា **ឯវមាហារោ** គឺ មានទិព្វសុធាហារ ។

បទថា **ឯវំ សុខទុក្ខបដិសំវេទី** សេចក្តីថា ជាអ្នកមានប្រក្រតីសោយទិព្វសុខយ៉ាងនេះ ចំណែកទុក្ខមានត្រឹមតែទុក្ខប្រចាំសង្ខារប៉ុណ្ណោះ ។

បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា មានអាយុ ៥៧ កោដិ ៦ លានឆ្នាំ ។

បទថា **សោ តតោ ចុតោ** សេចក្តីថា តថាគតនោះចុតិចាកភព នោះ គឺភពតុសិត ។

បទថា **ឥធូបបន្នោ** សេចក្តីថា កើតទេឡើងក្នុងភពនេះ គឺ ក្នុងព្រះគភ៌ព្រះនាងសិរិមហាមាយាទេវី ។

បទថា **មេ** ក្នុងពាក្យថា **អយំ ខោ មេ ព្រាហ្មណ** ជាដើម គឺ **មយា** ។

បទថា **វិជ្ជា** សេចក្តីថា ដែរឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា ធ្វើឱ្យដឹង ច្បាស់ ។

សួរថា **វិជ្ជា** ធ្វើឱ្យដឹងច្បាស់នូវអ្វី ?

ឆ្លើយថា នូវខន្ធ ( ភព ) ដែលធ្លាប់នៅអាស្រ័យក្នុងជាតិមុន ។

បទថា **អវិជ្ជា** សេចក្តីថា ព្រោះអត្ថថា មិនធ្វើឱ្យដឹងច្បាស់នូវខន្ធដែលអាស្រ័យនៅក្នុងជាតិមុន **អវិជ្ជា** ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់

ហៅថា **មោហ** ( សេចក្តីវង្វេង ) បិទបាំងនូវខន្ធដែលអាស្រ័យនៅក្នុងជាតិមុននោះ ។

បទថា **តមោ** សេចក្តីថា មោហៈនោះឯង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **តម** ( សេចក្តីងងឹត ) ព្រោះសេចក្តីថា បិទបាំង ។

បទថា **អាលោកោ** សេចក្តីថា វិជ្ជានោះឯង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា អាលោកៈ (ពន្លឺ) ព្រោះអត្ថថា ធ្វើឱ្យភ្លឺច្បាស់ ។

ក៏ក្នុងព្រះតម្រាស់ដែលត្រាស់មកនេះ មានសេចក្តីដូច្នេះថា **វិជ្ជា អធិគតា** ប្រែថា វិជ្ជាតថាគតបានសម្រេចហើយ ពាក្យដ៏សេសជាពាក្យ ពោលសរសើរ ។ ម្យ៉ាងទៀត ព្រះតម្រាស់វារៈនេះ មានការប្រកបសេចក្តី ដូច្នេះថា វិជ្ជានេះឯងតថាគតបានសម្រេចហើយ កាលតថាគតបានសម្រេច វិជ្ជាហើយ អវិជ្ជាទើបត្រូវបានខ្ចាត់បាត់ អធិប្បាយថា វិនាសទៅ ។

សួរថា ព្រោះហេតុអ្វី អវិជ្ជាទើបវិនាសទៅ ?

ឆ្លើយថា ព្រោះអវិជ្ជាកើតទេឡើង ។

សូម្បីក្នុងពីរបទក្រៅពីនេះ ក៏ដូចន័យនេះ ។

បទថា **យថា** ក្នុងពាក្យថា **យថាតំ** ប្រើក្នុងសេចក្តីថា ឧបមា ( ប្រៀបធៀប ) ។

បទថា **តំ** ជានិបាត ។ បុគ្គលដែលឈ្មោះថា មិនប្រមាទ ព្រោះការនៅមិនប្រាសចាកសតិ ឈ្មោះថា មានសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ដោយធមិជាគ្រឿងធ្វើកិលេសឱ្យក្តៅរោលរាលទូទៅ គឺ វិរិយៈឈ្មោះថា មានខ្លួន (ចិត្ត ) ដែលបញ្ជូនទៅហើយ ព្រោះមិនមានការហួងហែងក្នុងរាងកាយ និងជីវិត ។

បទថា **បហិតត្តស្ស** សេចក្តីថា មានខ្លួនដែលបញ្ជូនទៅហើយ មានអធិប្បាយ (បន្ថែម ) ដូច្នេះថា កាលព្រះយោគាវចរបុគ្គលមិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតនូវកិលេស មានខ្លួនបញ្ជូនទៅហើយ អវិជ្ជាគប្បីត្រូវកម្ចាត់ វិជ្ជាគប្បីកើតទេឡើង ភាពងងឹតគប្បីត្រូវកម្ចាត់ ពន្លឺគប្បីកើតទេឡើង យ៉ាងណា ចំណែកតថាគតក៏យ៉ាងនោះដូចគ្នា អវិជ្ជាត្រូវកម្ចាត់ហើយ វិជ្ជាក៏កើតទេឡើង សេចក្តីងងឹតត្រូវកម្ចាត់ហើយ ពន្លឺក៏កើតទេឡើង តថាគតបានផលដែលសមគួរដល់ការបំពេញព្យាយាមនោះ ។

( កថាពោលដោយបុព្វេនិសានុស្សតិញ្ញាណ ចប់ )

## កថាពោលដោយចុតូបបាតញ្ញាណ

ក្នុងកថាពោលដោយចុតូបបាតញ្ញាណ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ក៏ព្រោះហេតុដែលក្នុងទីនេះ បាលីមកហើយដោយអំណាចព្រះមានព្រះភាគ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា **បស្សាមិ បជានាមិ** ( យើងតថាគតឃើញហើយ ដឹងហើយ ) ។ សេចក្តីប្លែកគ្នាមានប៉ុណ្ណោះ ។ ពាក្យដ៏សេសបានពោលទុកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ក៏ក្នុងកថានេះ បទថា **វិជ្ជា** បានដល់ **វិជ្ជា** គឺ ទិព្វចក្ខុញ្ញាណ ។

បទថា **អវិជ្ជា** បានដល់ អវិជ្ជាដែលបិទបាំង ចុតិ និង បដិសន្ធិរបស់សត្វទាំងទឡាយ ។ ពាក្យដ៏សេស ដូចពាក្យដែលពោលមកហើយនោះឯង ។

ក៏ព្រោះហេតុដែលព្រះមហាសត្វទាំងទឡាយ បានបំពេញបារមីមកហើយ ទើបមិនមានការចាំបាច់ធ្វើបរិកម្ម ព្រោះថា លោកទាំងនោះលុះបង្អោនចិត្តទៅប៉ុណ្ណោះ ក៏នឹងរឭកដល់ខន្ធដែលអាស្រ័យនៅក្នុងកាលមុនបានសន្ទឹកសន្ទាប់ និង ឃើញសត្វទាំងទឡាយដោយទិព្វចក្ខុ ដូច្នោះ វិធីចម្រើនវិជ្ជាទាំងនោះ ផ្តើមតាំងពីធ្វើបរិកម្មដែលពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ទើបមិនចាំបាច់នាំមកសម្តែងក្នុងទីនេះ ។

## កថាពោលដោយអាសវក្ខយញ្ញាណ

ក្នុងវិជ្ជាទី ៣ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ÷

ក្នុងពាក្យថា **សោ ឯវំ សមាហិតេ ចិត្តេ** តថាគតនោះ កាលចិត្តតាំងមាំយ៉ាងនេះហើយ ចិត្តដែលតាំងមាំនោះគប្បីជ្រាបថា គឺ ចតុត្ថជ្ឈានដែលជាបាទសម្រាប់ចម្រើនវិបស្សនា ។

បទថា **អាសវានំ ខយញ្ញាណាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ។ ពិតណាស់ អរហត្តមគ្គហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងទឡាយ ព្រោះធ្វើអាសវៈឱ្យវិនាស ហើយញាណនេះ រមែងមានក្នុងអរហត្តមគ្គនោះ ព្រោះកើតក្នុងអរហត្តមគ្គនោះ ។

ពីរបទថា **ចិត្តំ អភិនិន្នាមេសឹ** គឺ បង្អោនចិត្តដែលសម្បយុត្តដោយវិបស្សនា ។

ក្នុងពាក្យមានជាអាទិថា **សោ ឥទំ ទុក្ខំ** អ្នកសិក្សាគប្បីជ្រាបសេចក្តីយ៉ាងនេះថា តថាគតបានជ្រាប គឺ ដឹង បានដល់ ការចាក់ធ្លុះនូវទុក្ខសច្ចសូម្បីទាំងអស់ថា ទុក្ខមានចំនួនប៉ុណ្ណេះ មិនមានក្រៃលែងជាងនេះតាមសេចក្តីពិត ដោយការចាក់ធ្លុះនូវទុក្ខលក្ខណៈពិត បានជ្រាប គឺ បានដឹងបានដល់ ការចាក់ធ្លុះនូវតណ្ហា ដែលញ៉ាំងទុក្ខឱ្យកើតទេឡើងថា នេះជាទុក្ខ

សមុទយៈ បានជ្រាប គឺ បានដឹង បានដល់ ការចាក់ធ្លុះនូវទីដែលទុក្ខ និង សមុទយៈ ទាំង ២ មកដល់ហើយរលត់ទៅ បានដល់ និព្វានដែលជាដែនដែលទុក្ខ និង សមុទយៈទាំង ២ នោះ មិនប្រព្រឹត្តទៅ ថានេះ ជាទុក្ខនិរោធ បានជ្រាប គឺ បានដឹង បានដល់ ចាក់ធ្លុះនូវអរិយមគ្គ ឱ្យសម្រេចនិព្វាននោះថា នេះជាទុក្ខនិរោធគាមិនីបដិបទា តាមសេចក្ដីពិតថា ពោលដោយការចាក់ធ្លុះលក្ខណៈដែលពិត ។

## មគ្គ , ផល , បច្ចវេក្ខណញ្ញាណ

លុះទ្រង់សម្ដែងសច្ចៈទាំងទឡាយដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងសច្ចៈទាំងទឡាយដោយអម ដោយអំណាចកិលេស ព្រះ-មានព្រះភាគជាម្ចាស់ ទើបត្រាស់ពាក្យថា **ឥមេ អាសវា** ដូច្នេះជាដើម ។

បទថា **តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ** ប្រែថា កាលតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ។ ( ដោយពាក្យនេះ ) ព្រះមានព្រះភាគជាម្ចាស់ត្រាស់ដល់មគ្គដែលដល់ទីបំផុតព្រមទាំងវិបស្សនា ។

បទថា **កាមាសវា** ប្រែថា ចាកកាមាសវៈ ។ ដោយបទថា រួចផុតហើយនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែងខណៈនៃផល ព្រោះថា ចិត្តកំពុងរួចផុតក្នុងខណៈនៃមគ្គ ។ ចាត់ថា រួចផុតហើយក្នុងខណៈនៃផល

ដោយពាក្យថា ការរួចផុតហើយ ក៏ដឹងថា រួចផុតហើយ ព្រះមានព្រះភាគទ្រង់សម្តែងបច្ចវេក្ខណញ្ញាណ ។ ដោយពាក្យថា ជាតិអស់ហើយ ដូច្នេះជាដើម ព្រះមានព្រះភាគជាម្ចាស់ រមែងទ្រង់សម្តែងភូមិរបស់បច្ចវេក្ខញ្ញាណនេះ ។ ទើបទ្រង់ជ្រាបថា ជាតិអស់ហើយ ដូច្នេះជាដើម ។

សួរថា ក៏ជាតិណារបស់ព្រះមានព្រះភាគជាម្ចាស់អស់ហើយ ហើយព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបជាតិនោះបាន ដូចម្តេច ?

ឆ្លើយថា មិនមែនជាតិអតីតរបស់ព្រះអង្គអស់ទៅទេ ព្រោះជាតិអតីតនោះអស់ទៅហើយ មិនមែនជាតិអនាគតរបស់ព្រះអង្គអស់ទៅទេ ព្រោះព្រះអង្គមិនមានសេចក្តីព្យាយាមក្នុងអនាគត មិនមែនជាតិបច្ចុប្បន្នអស់ទៅទេ ព្រោះជាតិបច្ចុប្បន្នមាន តែថា ជាតិ (ការកើត ) ណាដែលចែកប្រភេទជា (ការកើតរបស់ ) ខន្ធ ១ ក្នុងឯកវោការភព , ខន្ធ ៤ ក្នុងចតុវោការភព និងខន្ធ ៥ ក្នុងបញ្ចវោការភពនឹងគប្បីកើតទេឡើងបាន ព្រោះនៅមិនទាន់បាន ធ្វើ( អរិយៈ ) មគ្គឱ្យកើត ជាតិនោះ (ឯង) ចាត់ថា អស់ទៅហើយ ព្រោះដល់ភាពជាសភាវៈដែលមានការមិនកើតជាធម្មតា ហេតុដែលបានធ្វើ ( អរិយៈ) មគ្គឱ្យកើតមានហើយ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបជាតិនោះ ដោយទ្រង់ពិចារណា

កិលេសដែលលះបានហើយដោយមគ្គភាវនា (ការធ្វើមគ្គឱ្យកើតមាន) ហើយទ្រង់ជ្រាបថា កាលកិលេសមិនមាន , កម្ម គឺ អំពើសូម្បីនឹងនៅ ក៏នឹងមិនបង្កឱ្យមានបដិសន្ធិទៀតតទៅ ដូច្នេះឯង ។

បទថា **វុសិតំ** ប្រែថា នៅហើយ គឺ នៅចប់ហើយ អធិប្បាយថា ធ្វើហើយ គឺ ប្រព្រឹត្តហើយ បានដល់សម្រេចហើយ ។

បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ព្រះសេខៈ ៧ ជំពូក រួមទាំងកល្យាណបុថុជ្ជន ឈ្មោះថា កំពុងប្រព្រឹត្តព្រហ្មចរិយៈ ព្រះខីណាស្រព ជាអ្នកមានការប្រព្រឹត្តិព្រហ្មចរិយៈចប់ហើយ ព្រោះដូច្នោះ ព្រះមានព្រះភាគ-ជាម្ចាស់ ទ្រង់ពិចារណាដល់ការប្រព្រឹត្តិព្រហ្មចរិយៈរបស់ព្រះអង្គ ទើបទ្រង់ជ្រាបថា ប្រហ្មចរិយធម៌របស់តថាគតចប់ហើយ ។

បទថា **កតំ ករណីយំ** សេចក្ដីថា កិច្ចទាំង ១៦ យ៉ាង គឺ បរិញ្ញា ការកំណត់ដឹង , បហានៈ ការលះ , សច្ឆិកិរិយា ការធ្វើឱ្យជាក់ច្បាស់ និង ភាវនា ការធ្វើឱ្យកើតមានដោយមគ្គ ៤ ក្នុងសច្ចៈ ៤ ដែលតថាគតធ្វើឱ្យសម្រេចហើយ ។ ព្រោះថា ព្រះសេក្ខៈ ៧ ជំពូក រួមទាំងកល្យាណបុថុជ្ជន កំពុងធ្វើកិច្ចនុះ (ចំណែក) ព្រះខីណាស្រពមានកិច្ចដែលគួរធ្វើនោះ ធ្វើស្រេចហើយ ព្រោះដូច្នោះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ពិចារណាដល់កិច្ចដែលគួរ

ធ្វើរបស់ព្រះអង្គ ទើបទ្រង់ជ្រាបថា កិច្ចដែលគួរធ្វើ តថាគតបានធ្វើស្រេចហើយ ។

បទថា **នាបរំ ឥត្ថត្តាយ** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ ជ្រាបថា ឥឡូវនេះ កិច្ចដោយការធ្វើមគ្គឱ្យកើតមាន ដើម្បីភាពជាយ៉ាងនេះ ទៀត គឺ ដើម្បីកិច្ច១៦ យ៉ាង ឬ ដើម្បីការអស់កិលេសយ៉ាងនេះទៀត របស់ តថាគតមិនមាន ។

ម្យ៉ាងទៀត បទថា **ឥត្ថត្តាយ** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបថា ខន្ធសន្តាន (ការបន្តគ្នានៃខន្ធ) យ៉ាងដទៃអំពីភាពជាយ៉ាងនេះ គឺ អំពីប្រការយ៉ាងនេះ បានដល់ ការបន្តគ្នានៃខន្ធដែលប្រព្រឹត្តទៅ នៅក្នុងពេលនេះរបស់តថាគតមិនមាន តែខន្ធ ៥ នេះ ដែលតថាគតកំណត់ដឹងយ៉ាងប្រពៃហើយ តាំងនៅដូចដើមឈើដាច់ឫសដូច្នោះ ព្រោះវិញ្ញាណដួងចុងក្រោយរលត់ទៅ ខន្ធ ៥ នោះ ក៏នឹងរលត់ដូចភ្លើងអស់ឧស ដូច្នោះ ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងការបានសម្រេចញាណដែលជាទីអស់ទៅនៃអាសវៈទាំងទឡាយនោះ ដែលព្រះអង្គទ្រង់កំណត់ហើយដោយបច្ចវេក្ខណញ្ញាណយ៉ាងនេះ ដល់ព្រាហ្មណ៍ ទើបត្រាស់ពាក្យថា **អយំ ខោ មេ ព្រាហ្មណ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **វិជ្ជា** បានដល់ វិជ្ជាក្នុងអរហត្តមគ្គ-ញ្ញាណ ។ បទថា **អវិជ្ជា** បានដល់ អវិជ្ជាដែលបិទបាំងសច្ចៈ ៤ ។ ពាក្យដ៏សេសមានន័យដូចដែលបានពោលមកហើយនោះឯង ។

ក៏ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសសង្គ្រោះគុណភាពជាសព្វញ្ញូសម្បីទាំងអស់ដោយវិជ្ជា ៣ យ៉ាងនេះ ទ្រង់សង្គ្រោះ **អតីតង្សញ្ញាណ** ដោយបុព្វេនិវាសានុស្សតិញ្ញាណ ទ្រង់សង្គ្រោះ **បច្ចុប្បន្នង្សញ្ញាណ** និង **អនាគតង្សញ្ញាណ** ដោយទិព្វចក្ខុ ( និង ) ទ្រង់សង្គ្រោះលោកុត្តរគុណទាំងអស់ដោយអាសវក្ខយញ្ញាណ ដោយព្រះតម្រាស់ដូចពោលមកនេះ ចាត់ថា បានទ្រង់សម្ដែងការនៅប្រកបដោយសតិ (ធមិជាគ្រឿងនៅដោយការមិនវង្វេង ) របស់ព្រះអង្គដល់ព្រាហ្មណ៍ ។

## ប្រយោជន៍នៃការនៅព្រៃ ២ យ៉ាង

បានឮថា កាលព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍គិតថា ព្រះសមណគោតមទ្រង់ប្ដេជ្ញាភាពជាសព្វញ្ញូ តែសូម្បីក្នុង ថ្ងៃនេះ ព្រះអង្គក៏មិនទាន់បោះបង់ចោលការនៅក្នុងព្រៃ កិច្ចដែលគួរធ្វើអ្វី ៗ សូម្បីយ៉ាងដទៃទៀតរបស់ព្រះអង្គនៅមាន ឬទេហ្ន៎ ។ លំដាប់នោះ ព្រះមាន-

ព្រះភាគជាម្ចាស់ទ្រង់ជ្រាបអធ្យាស្រ័យព្រាហ្មណ៍នោះហើយ បានត្រាស់ពាក្យថា **សយា ខោ បន តេ** ដូច្នេះជាដើម ដើម្បីស្របតាមអធ្យាស្រ័យ ។

បណ្តាបទទាំងនោះ បទថា **សិយា ខោ បន តេ ព្រាហ្មណ ឯវមស្ស** សេចក្តីថា ម្នាលព្រាហ្មណ៍ពេលខ្លះ អ្នកគប្បីមានការគិតយ៉ាងនេះ ។

បទថា **ន ខោ បនេតំ ព្រាហ្មណ ឯវំ ទដ្ឋព្វំ** សេចក្តីថា ម្នាលព្រាហ្មណ៍ ក៏កាលបើយ៉ាងដូច្នេះ អ្នកមិនគប្បីឃើញយ៉ាងនេះថា ការនៅក្នុងសេនាសនៈដ៏ស្ងាត់របស់តថាគតមាន ព្រោះសាហេតុ មានរាគៈដែលនៅមិនទាន់អស់ជាដើម ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់បដិសេធវត្ថុដែលមិនមាន ( ដូចពោលមកនេះ ) ក្នុងការនៅក្នុងសេនាសនៈដ៏ស្ងាត់យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងដល់ហេតុ (ខ្លះ ) ទើបត្រាស់ពាក្យថា **ទ្វេ ខោ អហំ** ដូច្នេះជាដើម ។ ប្រយោជន៍នោះឯងក្នុងពាក្យថា **អត្ថវសេ** នោះ ឈ្មោះថា អំណាចនៃប្រយោជន៍ ព្រោះដូច្នោះ ក្នុងពាក្យថា **ទ្វេ ខោ អហំ ព្រាហ្មណ អត្ថវសេ** ទើបមានពាក្យអធិប្បាយថា ម្នាលព្រាហ្មណ៍ តថាគតឃើញនូវប្រយោជន៍ ២ យ៉ាង គឺ ហេតុ ២ យ៉ាង ។

ក្នុងពាក្យថា **អត្តនោ ច ទិដ្ឋធម្មសុខវិហារំ** (ការនៅជាសុខក្នុង

បច្ចុប្បន្នរបស់ខ្លួន ) អត្តភាពដែលឃើញប្រច័ក្សនេះ ឈ្មោះថា ទិដ្ឋធម៌ ការនៅដោយឥរិយាបថទាំង ៤ យ៉ាងសប្បាយ ឈ្មោះថា សុខវិហារ (ការនៅជាសុខ ) គប្បីជ្រាបអធិប្បាយនេះថា ព្រោះមនុស្សម្នាក់ ៗ មានឥរិយាបថដទៃ ៗ ទាំងអស់ដោយទីបំផុតការបន្ទោបង់ឧច្ចារៈ_បស្សាវៈងាយស្រួល ព្រោះដូច្នោះ ការនៅយ៉ាងនេះ ជាសុខរបស់អត្តភាពដែលឃើញប្រច័ក្សហើយ ទើបឈ្មោះថា **ទិដ្ឋធម្មសុខវិហារ** ។

ពាក្យថា **បច្ឆិមំ ជនតំ អនុកម្បមានោ** (អនុគ្រោះដល់ពពួកជនជំនាន់ក្រោយ) គប្បីជ្រាបអធិប្បាយដូចតទៅនេះ ÷

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់អនុគ្រោះពពួកជនជំនាន់ក្រោយដោយការនៅព្រៃយ៉ាងណា ?

អធិប្បាយថា កុលបុត្រទាំងឡាយដែលបួសដោយសទ្ធា ឃើញការនៅព្រៃរបស់ព្រះមានព្រះភាគជាម្ចាស់ហើយ នាំគ្នាគិតថា សូម្បីតែព្រះមាន_ព្រះភាគ ដែលមិនមានទុក្ខសច្ចត្រូវកំណត់ដឹង មិនមានសមុទយសច្ចដែលត្រូវលះ មិនមានមគ្គសច្ចដែលត្រូវធ្វើឱ្យកើតមាន មិនមាននិរោធសច្ចដែលត្រូវធ្វើឱ្យជាក់ច្បាស់ ក៏នៅមិនទាន់លះបង់សេនសនៈព្រៃទេឡើយ ក៏នឹងចាំបាច់ពោលថ្វីដល់យើងទាំងឡាយ ដូច្នេះ ហើយនឹងនាំគ្នាសម្គាល់សេនាសនៈព្រៃ

ថា ដែលខ្លួនគួរនៅយ៉ាងពិត ដោយអាការយ៉ាងនេះពួកគេក៏នឹងធ្វើទុក្ខឱ្យអស់ទៅបានដោយឆាប់រហ័ស ព្រះមានព្រះភាគជាម្ចាស់ឈ្មោះថា ទ្រង់អនុគ្រោះដល់ពពួកជនជំនាន់ក្រោយយ៉ាងនេះឯង ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសេចក្តីនេះទើបត្រាស់ថា **បច្ឆិមញ្ច ជនតំ អនុកម្បមានោ** ដូច្នេះ ។

## ន័យរបស់ស័ព្ទថា អភិកន្ត

ព្រាហ្មណ៍បានស្តាប់ព្រះតម្រាស់នោះហើយ ពេញចិត្ត ទើបបានពោលពាក្យថា **អនុកម្បិតរូបា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អនុកម្បិតរូបា** ប្រែថា ជាចំណែកដែលព្រះគោតមដ៏ចម្រើនអនុគ្រោះហើយ គឺ ជាអ្នកដែលព្រះគោតមដ៏ចម្រើនអនុគ្រោះហើយជាសភាព ។

បទថា **ជនតោ** ប្រែថា ប្រជុំជន , ពួកជន ។

បទថា **យថាតំ អរហតា សម្មាសម្ពុទ្ធេន** សេចក្តីថា (ពួកជនជំនាន់ក្រោយ ) ដែលព្រះគោតមដ៏ចម្រើនអនុគ្រោះហើយ ដូចជាអ្នកដែលព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់នឹងគប្បីអនុគ្រោះ ។

ក៏ព្រាហ្មណ៍ លុះពោលយ៉ាងនេះហើយ កាលនឹងសម្តែងសេចក្តីកោត-

សរសើរព្រះធម្មទេសនានោះរបស់ព្រះមានភាគជាម្ចាស់ទៀត ទើបបានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះតម្រាស់របស់ព្រះអង្គពីរោះជាប់ចិត្តដ៏ក្រៃលែង ព្រះតម្រាស់របស់ព្រះអង្គពីរោះជាប់ចិត្តដ៏ក្រៃលែង ។

ក្នុងពាក្យថា **អភិក្កន្តំ ភោ គោតម** ជាដើមនោះ **អភិក្កន្ត** ស័ព្ទ នេះប្រើក្នុងសេចក្តីថា «**ខយ** » (ដូច ) ក្នុងប្រយោគជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីកន្លងទៅហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយ (រង់ចាំ) យូរហើយ ។

ប្រើក្នុងសេចក្តី **សុន្ទរ** (ដូច ) ក្នុងប្រយោគដើមថា បណ្តាបុគ្គល ៤ នាក់នេះ អ្នកនេះល្អជាង ហើយប្រណីតជាង ។

ប្រើក្នុងន័យថា « **អភិរូប** » (ដូច ) ក្នុងប្រយោគជាដើមថា នរណារុងរឿងដោយឫទ្ធិ និង យស មានសម្បុរស្រស់ស្អាត ធ្វើទិសទាំងពួងឱ្យភ្លឺ ច្បាស់ (មក) ក្រាបទៀបព្រះបាទារបស់តថាគត ។

ប្រើក្នុងសេចក្តីថា « **អព្ភនុមោទន** » (ដូច ) ក្នុងប្រយោគជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះតម្រាស់របស់ព្រះអង្គពីរោះជាប់ចិត្តក្រៃលែង ។

សូម្បីក្នុងទីនេះ **អភិក្កន្ត** ស័ព្ទ ប្រែក្នុងសេចក្តីថា «**អព្ភនុមោទន**»

« លើកសរសើរ ត្រេកអរ » ដូចគ្នា ។ ក៏ព្រោះហេតុដែល **អភិកន្ត** ស័ព្ទប្រើក្នុងសេចក្ដីនៃ **អព្ភនុមោទន** ដូច្នោះ ទើបគួរជ្រាបថា ( ពាក្យថា **អភិកន្តំ ភោ គោតម** ) លោកអធិប្បាយទុកថា បានដល់ **សាធុ សាធុ ភោ គោតម** បពិត្រព្រះគោតមដ៏ចម្រើន ព្រះតម្រាស់របស់អង្គប្រពៃហើយ ប្រពៃ ហើយព្រះអង្គ ! ។

## ហេតុ_ផលដែលប្រើអភិកន្តស័ព្ទ ២ ដង

( អ្នកប្រាជ្ញបានពោលគាថាប្រព័ន្ធនេះទុកថា )

អ្នកប្រាជ្ញគប្បីធ្វើការពោលដដែល ៗ ក្នុង ( ពាក្យសម្ដែង )
សេចក្ដីខ្លាច ( **ភយេ** ) សេចក្ដីក្រោធ ( **កោធេ** ) ការសរសើរ
( **បសំសាយំ** ) ការប្រញាប់ប្រញាល់ ( **តុរិតេ** ) ការភ្ញាក់ផ្អើល
( **កោតុហលេ** ) ការអស្ចារ្យក្នុងចិត្ត ( **អច្ឆរេ** ) សេចក្ដី
សោមនស្សរីករាយ ( **ហាសេ** ) សេចក្ដីសោក ( **សោកេ** )
និង សេចក្ដីជ្រះថ្លា ( **បាសាទេ** ) ។

និង ដោយលក្ខណៈ ( ហេតុ_ផលដូចពោលមក ) នេះ អភិកន្តស័ព្ទនេះគប្បីជ្រាបថា ព្រាហ្មណ៍ពោលទុកដល់ ២ ដង ក្នុងទីនេះ ក៏ដោយអំណាចសេចក្ដីជ្រះថ្លា និង សេចក្ដីសរសើរ ។

ម្យ៉ាងទៀត បទថា **អភិក្កន្តំ** ប្រែថា គួរប្រាថ្នាយ៉ាងក្រៃលែង គឺគួរប្រាថ្នាយ៉ាងក្រៃលែង អធិប្បាយថា គួរពេញចិត្តយ៉ាងក្រៃលែង គឺត្រេកអរយ៉ាងក្រៃលែង ។ ក្នុងអភិក្កន្តស័ព្ទទាំង ២ នោះ ព្រាហ្មណ៍សរសើរទេសនាផង អភិក្កន្តស័ព្ទ ( ដែលមានន័យ ) ម្យ៉ាង , ប្រកាសសេចក្តីជ្រះថ្លារបស់ខ្លួនផង អភិក្កន្តស័ព្ទ ( ដែលមានន័យ ) ម្យ៉ាងទៀត ។

ក៏ក្នុងសេចក្តីទាំង ២ នេះ មានអធិប្បាយដូច្នេះថា ព្រះធម្មទេសនារបស់ព្រះគោតមដ៏ចម្រើនពីរោះគួរចាប់ចិត្តណាស់ សេចក្តីជ្រះថ្លារបស់ខ្ញុំព្រះអង្គអាស្រ័យព្រះធម៌ទេសនារបស់ព្រះគោតមដ៏ចម្រើន ក៏គួរពេញចិត្តក្រៃលែងណាស់ ឬ ក៏ព្រាហ្មណ៍នេះបំណងប្រើន័យទាំង ២ ( ទៅក្នុងការ ) សរសើរព្រះតម្រាស់ព្រះមានព្រះភាគជាម្ចាស់តែម្យ៉ាង ។ គឺ ( សរសើរថា ) ព្រះ_តម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង ព្រោះញុំាងទោសឱ្យវិនាសទៅ រាប់ថា គួរចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះឱ្យសម្រេចគុណ ម្យ៉ាងទៀត អ្នកសិក្សាគប្បីប្រកប ( ពាក្យថា ) ( **ភោតោ គោតមស្ស វចនំ អភិក្កន្តំ** ) ចូលជាមួយនឹងបទទាំងឡាយមានជាអាទិយ៉ាងនេះថា ÷

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន រាប់ថា ពីរោះចាប់ចិត្តដ៏ក្រែ_

លែងណាស់ ព្រោះធ្វើឱ្យកើតសទ្ធា រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះធ្វើឱ្យកើតបញ្ញា ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃ-លែងណាស់ ព្រោះបរិបូរណ៍ដោយអត្ថ (សេចក្តី) រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះដល់ព្រមដោយព្យញ្ជនៈ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះមានបទងាយ រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះមានអត្ថដ៏ជ្រាលជ្រៅ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះ(ស្តាប់ហើយ) ពីរោះត្រចៀក រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃ-លែងណាស់ ព្រោះ (ស្តាប់ហើយ) ត្រជាក់ត្រចៀក ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះមិនលើកតម្កើងខ្លួន រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះមិនបន្តុះបង្អាប់អ្នកដទៃ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែងណាស់ ព្រោះត្រជាក់ដោយព្រះករុណា រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង

ណាស់ ព្រោះផ្លូវផង់ដោយបញ្ញា ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង ណាស់ ព្រោះជាទីមនោរម្យតាមគន្លង រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង ណាស់ ព្រោះអត់ធន់ចំពោះការចោមវាយ ។

ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើនរាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង ណាស់ ព្រោះស្តាប់ហើយក៏នៅជាសុខ រាប់ថា ពីរោះចាប់ចិត្តដ៏ក្រៃលែង ណាស់ ព្រោះពិចារណាហើយ ក៏ជាប្រយោជន៍ ។

## ឧបមា ៤ យ៉ាង

តអំពីនោះ ព្រាហ្មណ៍បានសរសើរព្រះធម៌ទេសនានោះឯង ដោយ ឧបមា ៤ យ៉ាង ។

បណ្តាបទទាំងនោះ បទថា **និកុជ្ជិតំ** បានដល់ ភាជនៈដែលមាន មាត់ផ្កាប់ចុះ ឬ មានមាត់នៅខាងក្រោម ។

បទថា **ឧក្កុជ្ជេយ្យ** បានដល់ គប្បីផ្ងាមាត់ទេឡើង ។

បទថា **បដិច្ឆន្នំ** បានដល់ ដែលគេបិទទុកដោយស្មៅ និង ដោយ ស្លឹកឈើជាដើម ។

បទថា **វិវរេយ្យ** ប្រែថា គប្បីបើក ។

បទថា **មុទឡ្ហស្ស** បានដល់ (បុគ្គល) អ្នកវង្វេងទិស ។

បទថា មគ្គំ អាចិក្ខេយ្យ សេចក្ដីថា គប្បីចាប់ត្រង់ដៃហើយ ប្រាប់ថា នេះផ្លូវ ។

បទថា **អន្ធការេ** គឺ ក្នុងការងងឹតមានអង្គ ៤ (គឺ ងងឹត) ព្រោះថ្ងៃ ១៤ រោច ព្រោះជាវេលាពាក់កណ្ដាលអាធ្រាត ព្រោះព្រៃក្រាស់ និង ព្រោះពពកក្រាសបាំងបាត់ ។

អត្ថនៃបទដែលមិនងាយមានប៉ុណ្ណេះសិន ។

ចំណែកពាក្យអធិប្បាយប្រកបសេចក្ដី មានដូចតទៅនេះថា ÷

ព្រះគោមតដ៏ចម្រើន ជាអ្នកញ៉ាំងខ្ញុំព្រះអង្គអ្នកងាកមុខចេញអំពីសទ្ធម្ម ធ្លាក់ទៅក្នុងអសទ្ធម្ម ឱ្យផុតអំពីអសទ្ធម្ម ដូចជាគេផ្ងារបស់ដែលផ្កាប់ទេឡើង ដូច្នោះ ជាអ្នកបើកបង្ហាញសាសនាដែលត្រូវបិទបាំងទុកដោយព្រៃស្គុក គឺ មិច្ឆាទិដ្ឋិ ចាប់ផ្ដើមអំពីសាសនារបស់ព្រះមានព្រះភាគទ្រង់ព្រះនាមថា **កស្សប** អន្តរធានទៅ ដូចជាគេបើករបស់ដែលត្រូវបិទបាំងចេញដូច្នោះ ជាអ្នកប្រាប់ផ្លូវឋានសួគ៌ និង ព្រះនិព្វានដល់ខ្ញុំព្រះអង្គដែលជាអ្នកដើរវង្វេង ទៅកាន់ផ្លូវទាបថោក គឺ ផ្លូវដែលខុស ដូចជាគេប្រាប់ផ្លូវដល់មនុស្ស ដែលវង្វេងផ្លូវដូច្នោះ ឈ្មោះថា ទ្រង់បានប្រកាសធម្មៈទុកហើយដោយអនេក បរិយាយទាំងនេះ ដោយទ្រង់បញ្ចោញពន្លឺ

ស្វាងស្វៃ គឺ ព្រះធម្មទេសនា ដែលកម្ចាត់ចេញហើយ នូវសេចក្តីងងឹត គឺ មោហៈដែលបិទបាំងព្រះរតនត្រៃនោះទុកដល់ខ្ញុំព្រះអង្គ ជាអ្នកវង្វេងដើរទៅផ្លូវងងឹត គឺ មោហៈមើលមិនឃើញរូបព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើម ដូចជាគេទ្រោលភ្លើងបំភ្លឺក្នុងទីងងឹតដូច្នោះ ។

ព្រាហ្មណ៍ លុះសរសើរព្រះធម្មទេសនាយ៉ាងនេះហើយ មានចិត្តជ្រះ-ថ្លាក្នុងព្រះរតនត្រ័យ ព្រោះទេសនានេះ កាលនឹងទ្រង់ធ្វើអាការរបស់បុគ្គលអ្នកមានសេចក្តីជ្រះថ្លាទើបពោលថា **ឯសាហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯសាហំ** កាត់បទជា **ឯសោ អហំ** ( ខ្ញុំព្រះអង្គនោះ ) ។

ច្រើនបទថា **ភវន្តំ គោតមំ សរណំ គច្ឆាមិ** សេចក្តីថា ខ្ញុំម្ចាស់ សូមដល់ សូមសេពគប់ សូមចូលទៅអង្គុយជិតព្រះគោតមដ៏ចម្រើន ដោយសេចក្តីប្រាថ្នានេះថា សូមព្រះគោតមដ៏ចម្រើនចូរជាទីរឭក ជាទីពឹង ជាអ្នកទំលាយសេចក្តីទុក្ខ និង ជាអ្នកសាងស្ងួតិប្រយោជន៍សុខ ដល់ខ្ញុំព្រះអង្គផងចុះ ម្យ៉ាងទៀតសេចក្តីថា ខ្ញុំព្រះអង្គដឹង គឺ ជ្រាបហើយយ៉ាងនេះ ។ ព្រោះថា ធាតុពួកណា ប្រែថា « ទៅ » ធាតុទាំនោះក៏រមែងប្រែថា « ដឹង » បានដែរ ។ ព្រោះដូច្នោះ បទថា **គច្ឆាមិ** នេះ ព្រះអដ្ឋកថាចារ្យ ទើប

ពោលទុកដូច្នេះថា **ជានាមិ ពុជ្ឈាមិ** ( ដឹងហើយ , ជ្រាបហើយ ) ។

ក៏ក្នុងពាក្យថា **ធម្មញ្ច ភិក្ខុសង្ឃញ្ច** នេះ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ÷

ដែលឈ្មោះថា ធម៌ ព្រោះមានសេចក្ដីថា ទ្រទ្រង់នូវបុគ្គលទាំងទឡាយអ្នកបានសម្រេច ( អរិយ ) មគ្គ អ្នកធ្វើឱ្យជាក់នូវនិរោធហើយ (និង ) ប្រតិបត្តិតាមពាក្យដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រៀនប្រដៅជាប្រចាំ មិនឱ្យធ្លាក់ទៅក្នុងអបាយ៤។ធម៌នុះ កាលពោលដោយអត្ថន័យ ក៏បានដល់ អរិយមគ្គ និង ព្រះនិព្វាន សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ទុកដូច្នេះថា ម្នាលភិក្ខុទាំងទឡាយ ធម៌ដែលជាសង្ខតៈ ( ត្រូវបច្ច័យប្រជុំ តាក់តែង ) មាននៅប៉ុនណា អរិយមគ្គមានអង្គ ៨ តថាគតសម្ដែងថា ជាកំពូលនៃធម៌ដែលជាសង្ខតៈទាំងនោះ សេចក្ដីពិស្ដារដូចពោលមកនេះ ។ និងមិនមែនតែអរិយមគ្គ និង ព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះទេ ( ដែលឈ្មោះ ថា ធម៌) ។ ដោយពិតប្រាកដ សូម្បីបរិយត្តិធម៌ព្រមទាំងអរិយផលទាំងទឡាយ ( ក៏ឈ្មោះថា ធម៌ ដែរ ) ។ សមពិតដូចពាក្យដែលទេវបុត្រពោលទុកក្នុង ឆត្តមាណវកវិមានវត្ថុថា ÷

លោកចូរដល់នូវធម៌នេះ ដែលជាធម៌សម្រាប់រំលត់រាគៈ

មិនឱ្យកម្រើកញាប់ញ័រ មិនមានសេចក្តីសោក មិនត្រូវ
បច្ច័យប្រជុំតាក់តែង មិនបដិកូល ជាធម៌ពីរោះ ដែល
ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជំនាញហើយ ទាំងទ្រង់
ចែកទុករៀបរយល្អ ដើម្បីជាទីរឭក ជាទីពឹងចុះ ។

ក្នុងគាថានេះគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

បទថា ជាធម៌ប្រាសចាករាគៈ គឺ ទេវបុត្រពោលដល់ មគ្គ ។

បទថា ជាធម៌មិនកម្រើកញាប់ញ័រ មិនមានសេចក្តីសោក គឺ ទេវ_បុត្រពោលដល់ ផល ។

បទថា ជាធម៌មិនត្រូវបច្ច័យប្រជុំតាក់តែង គឺ ទេវបុត្រពោលដល់ព្រះនិព្វាន ។

បទថា មិនបដិកូល ជាធម៌ពីរោះ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ជំនាញហើយ ទាំងទ្រង់ចែកទុកត្រឹមត្រូវហើយនេះ គឺ ទេវបុត្រពោលដល់ព្រះធម្មក្ខន្ធ័ទាំងអស់ ដែលទ្រង់ចែកទុកជាព្រះត្រៃបិដក ។

ដែលឈ្មោះថា **សង្ឃ** (សង្ឃ ) ព្រោះមានសេចក្តីថា រួមគ្នាដោយគ្រឿងរួម គឺ ទិដ្ឋិ និង សីល សង្ឃនោះ កាលពោលដោយអត្ថ គឺ ពួកព្រះអរិយបុគ្គល ៨ ជំពូក ។ សមពិតដូចពាក្យដែលទេវបុត្រពោលទុកក្នុងគម្ពីរ

វិមានវត្ថុនោះឯងថា ÷

បណ្ឌិតពោលនូវទានដែលបុគ្គលគប្បីថ្វាយហើយ ក្នុងបុគ្គល
៤ គូណា ដែលជាគូបុគ្គលដ៏ស្អាត បុគ្គល ៤ គូទាំងនោះ
គឺ បុគ្គល ៨ ជំពូក ដែលជាអ្នកឃើញធម៌ សូមលោកចូរ
ចូលដល់ព្រះសង្ឃនេះ ដើម្បីជាទីរឮក ជាទីពឹងចុះ ។

ពួកនៃភិក្ខុទាំងទឡាយឈ្មោះថា ភិក្ខុសង្ឃ ព្រាហ្មណ៍បានប្រកាសការដល់សរណៈទាំង ៣ ដោយពាក្យមានត្រឹមប៉ុណ្ណេះ ។

## សរណគមន៍

ឥទឡូវនេះ ដើម្បីភាពជាអ្នកឆ្លាតក្នុងសរណគមន៍ទាំងនោះ ទើបគួរជ្រាបវិធីនេះ គឺ សរណៈ ការដល់សរណៈ អ្នកដល់សរណៈ ប្រភេទនៃការដល់ សរណៈ ផលនៃការដល់សរណៈ **សង្កិលេស** (សេចក្តីសៅហ្មង ) និង **ភេទ** (ការបែកធ្លាយ) ។

សួរថា វិធីនេះមានសេចក្តីដូចម្តេចខ្លះ ?

ឆ្លើយថា គួរជ្រាបន័យដោយសេចក្តីចំពោះបទមុន។ដែលឈ្មោះថា **សរណ** ព្រោះសេចក្តថា បៀតបៀន អធិប្បាយថា រមែងកម្ចាត់ គឺ ធ្វើ សេចក្តីខ្លាច សេចក្តីភ័យតក់ស្លុត សេចក្តីទុក្ខ កិលេសដែលជាហេតុឱ្យទៅ

កាន់ទុគតិរបស់បុគ្គលអ្នកដល់សរណៈ ឱ្យវិនាសទៅដោយការដល់សរណៈនោះឯង ។ ពាក្យថា **សរណ** នោះ ជាឈ្មោះហៅព្រះរតនត្រ័យ ។

ម្យ៉ាងទៀត ដែលឈ្មោះថា **ពុទ្ធ** ព្រោះសេចក្តីថា កម្ចាត់នូវភ័យរបស់សត្វទាំងទឡាយ ដោយធ្វើឱ្យសត្វទាំងទឡាយប្រព្រឹត្តទៅនៅក្នុង ប្រយោជន៍ និង ថយត្រទឡប់អំពីអំពើដែលមិនមែនជាប្រយោជន៍ ។

ដែលឈ្មោះថា **ធម្ម** ព្រោះធ្វើសត្វទាំងទឡាយឱ្យឆ្លងផុតចាកកន្តារៈ គឺ ភព និង ព្រោះឱ្យសេចក្តីស្រាលចិត្តដល់សត្វទាំងទឡាយ ដែលឈ្មោះថា **សង្ឃ** ព្រោះធ្វើសក្ការៈទាំងទឡាយ សូម្បីជារបស់បន្តិចបន្តួចក៏បានទទួលផលបរិបូរណ៍ ព្រោះដូច្នោះ ព្រះរតនត្រ័យ ទើបឈ្មោះថា **សរណ** ដោយបរិយាយនោះឯង ។

**ចិត្តុប្បាទ** ( ការកើតទេឡីងនៃចិត្ត ) ដែលមានកិលេស ដែលត្រូវកម្ចាត់ហើយ ដោយភាពជាអ្នកគោរពជ្រះថ្លាក្នុងសរណៈនុះ ដែលប្រព្រឹត្តទៅដោយអាការដែលមានសេចក្តីគោរពជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ជាខាងមុខ ឈ្មោះថា សរណគមន៍ ។

សត្វអ្នកបរិបូណ៌ដោយសរណគមន៍នោះ ឈ្មោះថា ដល់សរណគមន៍ អធិប្បាយថា រមែងចូលដល់រតនៈទាំង ៣ ឈ្មោះថា ជាសរណៈ (ជាទីរឭក ជាទីពឹង ) ថាជា បរាយនៈ (គ្រឿងនាំផ្លូវ) ដោយចិត្តុប្បាទមានប្រការដូច

ពោលហើយ ។ អ្នកសិក្សាគប្បីជ្រាប សរណៈ ការដល់សរណៈ និង ជាអ្នកដល់សរណគមន៍ ទាំង ៣ យ៉ាង នេះសិន ។

RbePTénkardl´srNKmn_

ចំណែកក្នុងប្រភេទនៃការដល់សរណគមន៍ ( ការដល់សរណគមន៍មានប៉ុន្មានប្រភេទ) គប្បីជ្រាបអធិប្បាយដូចតទៅនេះ ។ ការដល់សរណគមន៍ មាន ២ យ៉ាងគឺ ការដល់សរណគមន៍ដែលជាលោកុត្តរ ១ ការដល់សរណ-គមន៍ដែលជាលោកិយ ១ ។ ក្នុង ២ យ៉ាងនោះ ការដល់សរណគមន៍ដែលជាលោកុត្តរអ្នកឃើញសច្ចៈហើយ កាលពោលដោយអារម្មណ៍ រមែងមានព្រះនិព្វានជាអារម្មណ៍ កាលពោលដោយកិច្ច រមែងសម្រេចបានក្នុងព្រះរតន-ត្រៃសូម្បីទាំងអស់ ព្រោះកាត់ផ្តាច់កិលេសដែលជាហេតុរារាំងការដល់សរណ-គមន៍បានក្នុងខណៈនៃមគ្គ ។ ( ចំណែក ) ការដល់សរណគមន៍ដែលជាលោកិយរបស់បុថុជ្ជន កាលពោលដោយអារម្មណ៍ រមែងព្រះពុទ្ធគុណជាដើមជាអារម្មណ៍ សម្រេចបានដោយការគ្របសង្កត់កិលេសដែលជាហេតុរារាំងការដល់សរណគមន៍ ។ ការដល់សរណគមន៍នោះ កាលពោលដោយសេចក្តីបានដល់ ការមានសទ្ធាក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើម និងសម្មាទិដ្ឋិដែលមានសទ្ធា (ក្នុងព្រះរតនត្រៃនោះ) ជាមូលដ្ឋាន លោកហៅថា

**ទិដ្ឋុជុកម្ម** (ការធ្វើការយល់ឃើញឱ្យត្រង់) (ដែលនៅ) ក្នុងបុញ្ញកិរិយាវត្ថុ ១០ ។

ការដល់សរណគមន៍បែបនេះនោះ មាន ៤ យ៉ាងគឺ (ការដល់) ដោយការថ្វាយខ្លួន ១ ដោយការមានព្រះរតនត្រៃនោះជាគ្រឿងនាំផ្លូវ ១ ដោយព្រមធ្វើជាសិស្ស១ ដោយការថ្វាយបង្គំ(ការលើកដៃប្រណមធ្វើសេចក្តីគោរព១)។

ក្នុង ៤ យ៉ាងនោះ ដែលឈ្មោះថា ការថ្វាយខ្លួន បានដល់ ការលះបង់ខ្លួនដល់ព្រះរតនត្រ័យមានព្រះពុទ្ធជាម្ចាស់ជាដើម (ដោយការពោល) យ៉ាងនេះថា ចាប់ផ្តើមតាំងពីថ្ងៃនេះទៅ ខ្ញុំម្ចាស់សូមខ្លួនដល់ព្រះពុទ្ធជាម្ចាស់ ដល់ព្រះធម៌ និង ដល់ព្រះសង្ឃ ។

ដែលឈ្មោះថា ការមានព្រះរតនត្រ័យនោះជាគ្រឿងនាំផ្លូវ បានដល់កាលដែលមានព្រះរតនត្រ័យនោះជាទីទៅក្នុងខាងមុខ ( ដោយការនិយាយ ) យ៉ាងនេះថា ចាប់ផ្តើមតាំពីថ្ងៃនេះទៅ សូមលោកទាំងទឡាយចាំទុកខ្ញុំម្ចាស់ថាខ្ញុំម្ចាស់សូមមានព្រះពុទ្ធជាអ្នកនាំផ្លូវ សូមមានព្រះធម៌ជាអ្នកនាំផ្លូវ សូមមានព្រះសង្ឃជាអ្នកនាំផ្លូវ ។

ដែលឈ្មោះថា ការសំពះ បានដល់ ការឱនលំទោនយ៉ាងខ្ពស់ក្នុងព្រះរតនត្រ័យមានព្រះពុទ្ធជាម្ចាស់ជាដើម (ដោយការនិយាយ) យ៉ាងនេះថា

ចាប់អំពីថ្ងៃនេះទៅ សូមលោកទាំងទឡាយចូលចាំខ្ញុំម្ចាស់ថា ខ្ញុំម្ចាស់សូមធ្វើការក្រាបសំពះ ការក្រោកទទួល ការប្រណម្យអញ្ជលី ការធ្វើការនមស្ការដល់ព្រះរតនត្រ័យ មានព្រះពុទ្ធម្ចាស់ដើមនោះឯង ។

ក៏បុគ្គល កាលធ្វើអាការយ៉ាងណានីមួយ ក្នុងបណ្តាអាការទាំង ៤ យ៉ាងនេះ ចាត់ថា បានទទួលការដល់សរណៈហើយ ។

ម្យ៉ាងទៀត គប្បីជ្រាបការថ្វាយខ្លួន (ដោយការនិយាយ) សូម្បីយ៉ាង នេះថា ខ្ញុំម្ចាស់សូមលះបង់ខ្លួនដល់ព្រះមានព្រះភាគជាម្ចាស់ ដល់ព្រះធម៌ ( និង ) ដល់ព្រះសង្ឃ ខ្ញុំម្ចាស់សូមលះបង់ជីវិតដល់ព្រះមានព្រះភាគជាម្ចាស់ ដល់ព្រះធម៌ (និង ) ដល់ព្រះសង្ឃ ខ្ញុំម្ចាស់សូមលះបង់ខ្លួនហើយ តែម្តងដល់ព្រះមានព្រះភាគជាម្ចាស់ ដល់ព្រះធម៌ (និង ) ដល់ព្រះសង្ឃ ខ្ញុំម្ចាស់សូមដល់ព្រះពុទ្ធជាម្ចាស់ (ព្រះធម៌ និង ព្រះសង្ឃ ) ថា ជាសរណស្មើដោយជីវិត សូមព្រះពុទ្ធជាម្ចាស់ ( ព្រះធម៌និងព្រះសង្ឃ) ចូរជាទីពឹងទីរឭក ជាទី អាស្រ័យ ជាទីការពាររបស់ខ្ញុំព្រះអង្គ ។

គប្បីឃើញការចូលភាពជាសិស្ស (ការប្រគល់ខ្លួនជាសិស្ស ) ដូចការចូលដល់ភាពជាសិស្ស ក្នុងការដល់សរណៈរបស់ព្រះមហាកស្សបៈ (ដោយនិយាយ ) សូម្បីយ៉ាងនេះថា សូមឱ្យខ្ញុំម្ចាស់គប្បីបានជួបព្រះសាស្តា គប្បី

បានជួបព្រះមានព្រះភាគជាម្ចាស់ សូមឱ្យខ្ញុំបានជួបព្រះសុគត គប្បីបានជួបព្រះមានភាគជាម្ចាស់ សូមឱ្យខ្ញុំម្ចាស់គប្បីបានជួបព្រះសម្មាសម្ពុទ្ធជាម្ចាស់ គប្បីបានជួបព្រះមានព្រះភាគជាម្ចាស់ ។

គប្បីជ្រាប ការដែលមានព្រះរតនត្រ័យនោះជាគ្រឿងនាំផ្លូវ (ជាខាង មុខ) ដូចការដល់សរណគមន៍របស់ជនទាំងទឡ្យាយ មានអាទឡ្ហវកយក្សជាដើម (ដោយការនិយាយ ) សូម្បីយ៉ាងនេះថា ខ្ញុំម្ចាស់នឹងចេញអំពីស្រុក (នេះ ) ទៅកាន់ស្រុក ( ឯណោះ) ចេញអំពីក្រុង ( នេះ) ទៅកាន់ក្រុង ( ឯណោះ) ដើម្បីនមស្ការព្រះសម្មាសម្ពុទ្ធជាម្ចាស់ ភាពជាធម៌ដ៏ល្អនៃព្រះធម៌ ( និង ភាពជាសង្ឃដ៏ល្អនៃព្រះសង្ឃ) ។

គប្បីឃើញការថ្វាយបង្គំ សូម្បីយ៉ាងនេះថា កាលនោះឯង ព្រាហ្មណ៍ឈ្មោះ **ព្រហ្មាយុ** ក្រោកទេឡីងពីទីអង្គុយធ្វើសំពត់ឆៀងស្មាម្ខាងហើយ ឱនក្បាលចុះទៀបព្រះបាទាព្រះមានព្រះភាគជាម្ចាស់ ជញ្ជក់ព្រះបាទព្រះមានព្រះ-ភាគជាម្ចាស់ដោយមាត់ ច្របាច់ដោយបាទដៃហើយប្រកាសឈ្មោះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ឈ្មោះ **ព្រហ្មាយុ** បពិត្រព្រះ-គោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ឈ្មោះ **ព្រហ្មាយុ** ។

ក៏ការថ្វាយបង្គំនោះមាន ៤ យ៉ាង គឺ ( ថ្វាយបង្គំដោយប្រណម្យដៃ)

ព្រោះជាញាតិ ព្រោះការខ្លាច ព្រោះជាអាចារ្យ និង ព្រោះជាទក្ខិណេយ្យ-បុគ្គល ។ បណ្តាការថ្វាយបង្គំ ៤ យ៉ាងនោះ ការដល់សរណៈមានបាន ដោយការថ្វាយបង្គំ ព្រោះជាទក្ខិណេយ្យបុគ្គល មិនមែនដោយហេតុ ៣ យ៉ាង ក្រៅពីនេះ ។

ព្រោះថា សរណៈដែលបុគ្គលរមែងទទួលបាន ដោយបុគ្គលអ្នកប្រសើរ ជាទីបំផុតនិងដាច់ទៅ(ក៏ដាច់)ដោយអំណាចបុគ្គលអ្នកប្រសើរជាទីបំផុត ដូចគ្នា ។ព្រោះដូច្នោះ បុគ្គលណានឹងមានវង្សជាសក្យៈឬជាកោលិយៈក៏ដោយ ថ្វាយបង្គំ(ព្រះពុទ្ធជាម្ចាស់ ) ដោយសម្គាល់ថា ព្រះពុទ្ធជាម្ចាស់ជាញាតិរបស់ យើងទាំងទឡាយ បុគ្គលនោះនៅមិនទាន់ចាត់ថា បានទទួលសរណគមន៍ទេឡើយ។ ឬថា បុគ្គលណាថ្វាយបង្គំព្រះសម្មាសម្ពុទ្ធជាម្ចាស់ដោយការខ្លាចថា ព្រះសម-ណគោតមដែលព្រះរាជាបូជាហើយ មានអានុភាពច្រើន កាលយើងមិនថ្វាយ បង្គំ នឹងធ្វើសេចក្តីអន្តរាយឱ្យយើងបាន បុគ្គលនោះក៏នៅមិនទាន់ចាត់ថា បាន ទទួលសណគមន៍ដូចគ្នា ។ សូម្បីបុគ្គលណា រឭកដល់ពាក្យប្រៀនប្រដៅខ្លះ ដែលបានរៀនក្នុងសម្នាក់របស់ព្រះមានព្រះភាគជាម្ចាស់ កាលព្រះអង្គនៅជា ព្រះពោធិសត្វ ឬ ក្នុងពុទ្ធកាល បានរៀនពាក្យប្រៀនប្រដៅទំនងយ៉ាងនេះថា÷

បុគ្គលគួរប្រើប្រាស់ ចិញ្ចឹមជីវិតដោយទ្រព្យមួយចំណែក ដាក់

ទុនធ្វើការងារដោយទ្រព្យពីរចំណែក និង មួយចំណែកទៀតគួរ
ទុកដាក់ (ព្រោះវានឹងអំណោយប្រយោជន៍បាន) កាលយើង
មានការចាំបាច់ត្រូវប្រើ ។

( កើតសេចក្តីជ្រះថ្លា ) ថ្វាយបង្គំដោយការសម្គាល់ថា ព្រះអង្គជាអាចារ្យរបស់យើង បុគ្គលនោះក៏ឈ្មោះថា នៅមិនទាន់ចាត់ថា បានទទួលសរណៈដូចគ្នា ។

ចំណែកបុគ្គល ថ្វាយបង្គំដោយសេចក្តីសម្គាល់ថា ព្រះពុទ្ធជាម្ចាស់ជាអគ្គទក្ខិណេយ្យបុគ្គលក្នុងលោក បុគ្គលនោះឯងចាត់ថា បានទទួលសរណគមន៍ពិត ។ ឧបាសក ឬ ឧបាសិកាអ្នកបានទទួលសរណគមន៍យ៉ាងនេះហើយ នឹងថ្វាយបង្គំញាតិសូម្បីបួសក្នុងសម្នាក់អញ្ញអន្តិរិយ៍ ដោយសេចក្តីសម្គាល់ថា លោកនេះជាញាតិរបស់យើង ដូច្នេះ ការដល់សរណគមន៍ ក៏នៅមិនទាន់អស់សភាពទៅ ( មិនដាច់ ) ចាំបាច់ពោលទៅថ្វីដល់បុគ្គល ឬ ឧបាសិកាអ្នកថ្វាយបង្គំញាតិដែលនៅមិនទាន់បួស ។

ចំណែកឧបាសក ឬ ឧបាសិកា អ្នកថ្វាយបង្គំព្រះរាជាក៏ដូចគ្នា គឺថ្វាយបង្គំដោយអំណាចការខ្លាចថា ព្រះរាជាអង្គនោះ ព្រោះជាអ្នកដែលអ្នកដែនបូជាហើយ កាលយើងមិនថ្វាយបង្គំ ក៏នឹងទ្រង់ធ្វើសេចក្តីវិនាសឱ្យដល់

យើងបាន ដូច្នេះ ការដល់សរណគមន៍ក៏នៅមិនទាន់អស់សភាពទៅ ( នៅមិនទាន់ដាច់ ) ដូចកាលបុគ្គល សូម្បីថ្វាយបង្គំត្រឹយ៍អ្នកឱ្យការសិក្សា សិល្បៈយ៉ាងណាមួយដោយគិតថា នេះជាអាចារ្យរបស់យើង ការដល់សរណៈក៏នៅមិនទាន់អស់សភាពទៅ ដូច្នោះ អ្នកសិក្សាគប្បីជ្រាបប្រភេទនៃការដល់សរណ–គមន៍យ៉ាងនេះឯង ។

ក៏ការដល់សរណដែលជាលោកុត្តរក្នុងទីនេះ មានសាមញ្ញផល ៤ ជាវិបាកផល មានការអស់ទៅនៃទុក្ខទាំងពួង ជាអានិសង្សផល ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកដូច្នេះថា ÷

ក៏បុគ្គលណាដល់ព្រះពុទ្ធជាម្ចាស់ ព្រះធម៌និងព្រះសង្ឃថាជា
សរណៈ (ទីរឮកទីពឹង) បុគ្គលនោះរមែងឃើញសច្ចៈ ៤ ដោយ
បញ្ញាដ៏ប្រពៃ គឺ រមែងឃើញទុក្ខ ហេតុនាំឱ្យកើតទុក្ខ សេចក្តី
រលត់ទុក្ខ និង អរិយមគ្គមានអង្គ ៨ ដែលជាផ្លូវឱ្យចូលដល់
សេចក្តីរំលត់ទុក្ខ សរណៈ ( ទីរឮកទីពឹង) យ៉ាងនោះឯងទើប
នឹងជាសរណៈដ៏ក្សេម ជាសរណៈដ៏ខ្ពស់បំផុត ព្រោះអាស្រ័យ
សរណៈនោះ បុគ្គលទើបរួចផុតចាកអំពីទុក្ខទាំងពួងបាន ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្សផលនៃការដល់សរណៈនោះ សូម្បីដោយ

ដោយអំណាចនៃហេតុ មានការមិនចូលទៅប្រកាន់ ដោយភាពជារបស់ទៀង ជាដើម ។ សមពិតដូចព្រះតម្រាស់ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកដូច្នេះថា ÷

ម្នាលភិក្ខុទាំងទឡាយ មិនមែនជាឋានៈ មិនមែនឱកាស ( ប្រព្រឹត្ត ទៅមិនបានទេឡើយ ) ដែលបុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ នឹងគប្បីចូលទៅប្រកាន់សង្ខារណា ៗ ថា ទៀង ថាជាសុខ នឹងគប្បីចូលទៅប្រកាន់ធម៌ណា ៗ ថាជា អត្តា នឹងគប្បីផ្តាច់ជីវិតមាតា នឹងគប្បីផ្តាច់ជីវិតបិតា នឹងគប្បីផ្តាច់_ ជីវិតព្រះអរហន្ត នឹងគប្បីជាអ្នកមានចិត្តអាក្រក់ ញុំាងលោហិតរបស់ព្រះ_ តថាគតឱ្យពុះពង នឹងគប្បីបំបែកសង្ឃ នឹងកិរិយាងាកចិត្តទៅកាន់សាសនា_ ដទៃ ឋានៈយ៉ាងនេះ នឹងប្រព្រឹត្តទៅមិនបាន ។

ចំណែកការដល់សរណៈដែលជាលោកិយ រមែងមានភពសម្បត្តិ និង ភោគសម្បត្តិជាផលដូចគ្នា ។ សមពិតដូចព្រះតម្រាស់ដែលព្រះពុទ្ធជាម្ចាស់ ត្រាស់ទុកដូច្នេះថា ៖

បុគ្គលដែលដល់ព្រះពុទ្ធថាជាសរណៈ នឹងមិនទៅកាន់អបាយ_ **ភូមិ លុះដែលលះបង់រាងកាយជាមនុស្សហើយ នឹងញុំាងកាយ ទិព្វឱ្យបរិបូរណ៍ ( កើតក្នុងពួកទេវតា ) ។**

សូម្បីរឿងដទៃ លោកក៏ពោលទុក ។ ( គឺ ) គ្រានោះឯង សក្កៈ_

ទេវរាជ ព្រមទាំងទេវតា ៨០.០០០ បានចូរទៅរក ព្រះមហាមោគ្គលាន ។ ព្រះមហាមោគ្គលាន បានពោលនឹង សក្កៈទេវរាជ ដែលឈរក្នុងទីសម-គួរមួយ ដូចនេះថា សូមថ្វាយព្រះពរមហាបពិត្រដែលជាធំទេវតា ការដល់-ព្រះពុទ្ធជាម្ចាស់ថាជាសរណៈ ជាការល្អពិត ព្រោះការដល់ព្រះពុទ្ធជាម្ចាស់ថាជាសរណៈ ជាហេតុ សត្វពួកខ្លះក្នុងលោកនេះស្លាប់ហើយ ទើបបានទៅកើតក្នុងសុគតិទេវលោកយ៉ាងនេះ សត្វទាំងនោះ ( កើតជាទេវតាហើយ ) រមែងប្រសើរជាងទេវតាពួកដទៃដោយឋានៈ ១០ គឺ ដោយអាយុដ៏ជាទិព្វ វណ្ណៈដ៏ជាទិព្វ សុខៈដ៏ជាទិព្វ យសដ៏ជាទិព្វ ភាពជាធំដ៏ជាទិព្វ រូបដ៏ជាទិព្វ សំឡេងដ៏ជាទិព្វ ក្លិនដ៏ជាទិព្វ រសដ៏ជាទិព្វ ផោដ្ឋព្វៈដ៏ជាទិព្វ ។ ក្នុង (ការដល់) ព្រះធម៌ និង ព្រះសង្ឃថា ជាសរណៈ ក៏ន័យនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបផលដ៏សំខាន់នៃការដល់សរណៈ សូម្បីដោយអំណាចនៃសូត្រមាន-វេណាមសូត្រជាដើម ។ គប្បីជ្រាបផលនៃការដល់សរណៈ យ៉ាងនេះ ។

ក្នុងការដល់សរណៈ ២ យ៉ាងនោះ ការដល់សរណៈដែលជាលោ-កិយៈរមែងសៅហ្មងដោយហេតុទាំងឡាយមានការមិនដឹង ការសង្ស័យ និង ការដឹង ( ការយល់ ) ខុសជាដើមក្នុងព្រះរតនត្រៃ ជាការដល់សរណៈ ដែលមិនមានភពរុងរឿង មិនធំធេង ។ (ចំណែក) ការដល់សរណៈ

ដែលជាលោកុត្តរៈមិនមានសេចក្តីសៅហ្មង ។

ការដល់សរណៈដែលជាលោកិយៈមានការដាច់ដោយហេតុ ២ យ៉ាង គឺ ការដាច់ (ភេទោ ) បែបមានទោស ១ ការដាច់បែបមិនមានទោស ១ ។ ក្នុងការដាច់ដោយហេតុទាំង ២ នោះ ការដាច់បែបមានទោសរមែង_មានដោយហេតុទាំងទឡ្បាយ មានការថ្វាយខ្លួនដល់សាស្តាដទៃជាដើម ការ_ដាច់បែបនោះមានផលមិនគួរប្រាថ្នា ។ ការដាច់បែបមិនមានទោសព្រោះ_ការធ្វើកាលកិរិយា ការដាច់បែបនោះមិនមានផលព្រោះមិនមានវិបាក ។ តែការដល់សរណៈបែបលោកុត្តរៈ មិនមានការដាច់ទេឡើយ ។ ពិតមែនហើយ ព្រះអរិយសាវ័ក (ស្លាប់ហើយទៅកើត ) សូម្បីក្នុងភពដទៃក៏នឹងមិនព្រម_លើកតម្កើងមនុស្សដទៃថាជសាស្តា (ជំនួសព្រះពុទ្ធជាម្ចាស់) ។ គប្បីជ្រាប ការសៅហ្មង និងការដាច់នៃការដល់សរណៈ ដូចពណ៌នាមកដូច្នេះ ។

ឧបាសក

បទថា **ឧបាសកំ មំ ភវំ គោតមោ ធារេតុ** សេចក្តីថា សូមព្រះគោតមដ៏ចម្រើនចូរចាំ អធិប្បាយថា ចូលជ្រាបនូវខ្ញុំម្ចាស់យ៉ាងនេះថា អ្នកនេះជាឧបាសក ។

ក៏ក្នុងទីនេះ ដើម្បីភាពជាបុគ្គលឆ្លាតក្នុងវិធីថ្វាយខ្លួនជាឧបាសក ទើប

គួរជ្រាបសេចក្ដីសង្ខេបនេះថា **ឧបាសកគឺនរណា ? ព្រោះហេតុអ្វី ទើបហៅថា ឧបាសក ? ឧបាសកនោះមានសីលដូចម្ដេច ? មានអាជីវៈជាយ៉ាងណា ? មានវិបត្តិដូចម្ដេច ? មានសម្បត្តិដូចម្ដេច ?**

ក្នុងសេចក្ដីសង្ខេបទាំងនោះ ដែលថា **ឧបាសក គឺ នរណា ?** បាន ដល់គ្រហស្ថណាមួយដែលដល់នូវត្រៃសរណៈ ។ សមពិតដូចព្រះតម្រាស់ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកដូចនេះថា ម្នាលមហានាម កាលណាឧបាសកដល់ព្រះពុទ្ធ ព្រះធម៌ ( និង ) ព្រះសង្ឃ ថាជាសរណៈ ម្នាលមហានាម បុគ្គលរមែងជាឧបាសកដោយអាការប៉ុណ្ណោះឯង ។

ដែលសួរថា **ព្រោះហេតុអ្វី ទើបហៅថា ឧបាសក ?** បានដល់ព្រោះចូលទៅអង្គុយជិតព្រះរតនត្រៃ ។ ពិតហើយ បុគ្គលនោះឈ្មោះថា **ឧបាសក** ព្រោះចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ (និង) ព្រះសង្ឃ ។

ដែលសួរថា **ឧបាសកនោះមានសីលដូចម្ដេច ?** បានដល់ចេតនាជាគ្រឿងវៀរចាកនូវពៀរ ៥ យ៉ាង ។ សមពិតដូចដែលព្រះសម្ពុទ្ធត្រាស់ទុកដូច្នេះថា ម្នាលមហានាម កាលណា ឧបាសកជាអ្នកវៀរចាកបាណាតិបាត ចាកអទិន្នាទាន ចាកកាមេសុមិច្ឆាចារ ចាកមុសាវាទ (និង ) ចាកឋានៈជាទីតាំងនៃសេចក្ដីប្រមាទ គឺ ទឹកស្រវឹង បានដល់ សុរានិងមេរ័យ

ម្នាលមហានាម ឧបាសក រមែងជាអ្នកមានសីលដោយហេតុត្រឹមតែប៉ុណ្ណេះឯង ។

ដែលសួរថា **មានអាជីវៈយ៉ាងណា ?** បានដល់ ការលះបង់ ជំនួញខុស ៥ យ៉ាង ហើយចិញ្ចឹមជីវិតដោយធម៌ដ៏ប្រពៃ សមពិតដូចព្រះ-តម្រាស់ដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកដូចនេះថា ម្នាលភិក្ខុទាំងទឡាយ ការជួញ ៥ យ៉ាងនេះ ដែលឧបាសកមិនធ្វើ , ៥ យ៉ាងមានអ្វីខ្លះ គឺ ការជួញសស្ត្រាវុធ ១ ការជួញសត្វ ១ ការជួញសាច់ ១ ការជួញទឹក ស្រវឹង ១ ការជួញថ្នាំពិស ១ ម្នាលភិក្ខុទាំងទឡាយ ការជួញ ៥ យ៉ាង នេះឯង ឧបាសកមិនគួរធ្វើ ។

ដែលសួរថា **មានវិបត្តិដូចម្ដេច ?** បានដល់ ការវិបត្តិនៃសីល និង អាជីវៈរបស់ឧបាសកនោះឯង នេះជាសេចក្ដីវិបត្តិរបស់ឧបាសកនោះ ។ ម្យ៉ាងវិញទៀត ឧបាសកនោះជាមនុស្សចណ្ឌាល និង សៅហ្មង ដោយមន្ទិល ផ្សេង ៗ ដោយវិបត្តឯណា សូម្បីវិបត្តិនោះ ក៏គប្បីជ្រាបថា ជាវិបត្តិរបស់ឧបាសកនោះ ៗ ។ ហើយភាពជាមនុស្សចណ្ឌាលនោះ កាលពោលដោយសេចក្ដីក៏បានដល់ធម៌ ៥ ប្រការ មានភាពជាអ្នកមិនមានសទ្ធាជាដើម ។ ដូចដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ឧបាសកប្រកប

ដោយធម៌ ៥ យ៉ាង រមែងជាឧបាសកចណ្ឌាល ជាឧបាសកមានមន្ទិល ជាឧបាសកមានសេចក្ដីសៅហ្មង និង ជាឧបាសកលាមក ។ ធម៌ ៥ ប្រការ អ្វីខ្លះ (គឺ) ជាអ្នកមិនមានសទ្ធា ( ក្នុងព្រះរតនត្រៃ ) ១ ជាមនុស្ស ទុស្សីល ១ ជាមនុស្សជឿមង្គលភ្ញាក់ផ្អើល គឺ ជឿមង្គល ( ឫក្ស យាម ) មិនជឿកម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គលក្រៅពីសាសនានេះ ( ពុទ្ធសាសនា ) ១ បំពេញកុសលក្នុងសាសនានោះ ១ ។

ដែលសួរថា **មានសម្បត្តិដូចម្ដេច ?** បានដល់ ការដល់ព្រមដោយសីល និង ការដល់ព្រមដោយអាជីវៈរបស់ឧបាសកនោះ ឈ្មោះថាសម្បត្តិ ។ ម្យ៉ាងទៀត ធម៌ ៥ ប្រការ មានសទ្ធាក្នុងព្រះរតនត្រ័យជាដើមរបស់ឧបាសកនោះ ទាំងទឡាយណា ធម៌ ៥ ប្រការទាំងនោះ ឈ្មោះថាសម្បត្តិ ។ ដូចយ៉ាងដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ឧបាសកដែលប្រកបដោយធម៌ ៥ យ៉ាង រមែងជាឧបាសកកែវ ជាបទុម_ឧបាសក និង ជាបុណ្ឌរិកឧបាសក ។ ធម៌ ៥ យ៉ាងមានអ្វីខ្លះ ( គឺ ) ជាអ្នកមានសទ្ធា ( ក្នុងព្រះរតនត្រ័យ ) ១ ជាអ្នកមានសីល ១ ជាអ្នកមិនជឿមង្គលភ្ញាក់ផ្អើល គឺ ជឿកម្ម មិនជឿមង្គល ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលក្រៅព្រះពុទ្ធសាសនានេះ ១ បំពេញកុសលក្នុងពុទ្ធសាសនានេះ ១ ។

**អត្ថន័យរបស់** « អគ្គ » ស័ព្ទ

**អគ្គ** ស័ព្ទនេះក្នុងពាក្យថា **អជ្ជតគ្គេ** នេះ រមែងប្រើក្នុងអត្ថថា **ខាងដើម** ( អាទិ ) **ខាងចុង** (កោដ្ឋិ) **ចំណែក** (កោដ្ឋាស) និង **ប្រសើរទើបបំផុត** (សេដ្ឋ) ។ ក៏ **អគ្គ** ស័ព្ទប្រើក្នុងអត្ថថា

**ខាងដើម** ( ដូច ) ក្នុងប្រយោគជាដើមថា នែ៎ឆ្មាំទ្វារសំលាញ់ តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមបិទទ្វារសំរាប់ពួកនិគ្រន្ថ ។

**ខាងចុង** ( ដូចជា ) ក្នុងប្រយោគជាដើមថា បុគ្គលគប្បីស្ទាប-អង្អែលចុងអំពៅ ចុងឬស្សី ដោយចុងម្រាមដៃនោះឯង ។

ចំណែក ( ដូចជា ) ក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡាយ តថាគតអនុញ្ញាតឱ្យចែកពីរចំណែករបស់ដែលមានរសជូ ដែលមានរសផ្អែម ឬ ចំណែករបស់ដែលមានរសល្វីងតាមចំណែកវិហារ ឬ តាមចំណែកបរិវេណ ។

**ប្រសើរជាទីបំផុត** ( ដូចជា ) ក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងទឡាយ សត្វទាំងទឡាយចំនួនប៉ុណ្ណា ដែលមិនមានជើងក៏ដោយ ។ ល ។ ព្រះតថាគត បណ្ឌិតពោលថា ជាបុគ្គលដ៏ប្រសើរជាទីបំផុតជាងសត្វទាំងនោះ។

តែក្នុងទីនេះ **អគ្គ** ស័ព្ទនេះគប្បីឃើញថា ចុះក្នុងអត្ថថា **ខាងដើម** ។ ព្រោះដូច្នោះ ក្នុងពាក្យថា **អជ្ជតគ្គេ** នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា ចាប់ផ្តើមតាំងពីថ្ងៃនេះជាដើមទៅ ។

បទថា **អជ្ជតំ** បានដល់ **អជ្ជភាវំ** ( ប្រែថា ការមានក្នុងថ្ងៃនេះ ) ។ បាលីថា **អជ្ជតគ្គេ** ដូច្នេះក៏មាន ។ **ទ** អក្សរ (ជាអាគម) ធ្វើនាទី ភ្ជាប់ បទ ( រវាង **អជ្ជ** និង **អគ្គេ**) ។ ប្រែថា ចាប់ផ្តើមតាំងពីថ្ងៃនេះ ។

បទថា **បាណុបេតំ** ប្រែថា ចូរដល់ដោយជីវិត ។ អធិប្បាយថា សូមព្រះគោតមដ៏ចម្រើន ចូលទ្រង់ចាំ គឺ ចូលទ្រង់ជ្រាបខ្ញុំព្រះអង្គទុកថា ជាឧបាសក គឺ វេយ្យាវច្ចករ ( អ្នកបម្រើព្រះសង្ឃ ) ដល់សរណៈ ដោយត្រៃសរណគមន៍បែបមិនមានសាស្តាដទៃ ( ក្រៅអំពីព្រះគោតម ) រហូតកាលដែលជីវិតរបស់ខ្ញុំព្រះអង្គនៅប្រព្រឹត្តទៅ ព្រោះថា ខ្ញុំព្រះអង្គ សូម្បីបុគ្គល ណាៗ នឹងគប្បីប្រើកាំបិតដ៏មុតកាត់សីសៈរបស់ខ្ញុំព្រះអង្គសោត ក៏សូមមិនពោលព្រះពុទ្ធថា មិនមែនព្រះពុទ្ធ ព្រះធម៌ថា មិនមែនព្រះធម៌ ( និង ) ព្រះសង្ឃថា មិនមែនព្រះសង្ឃ ។ ព្រាហ្មណ៍ លុះដល់សរណៈដោយការថ្វាយខ្លួនយ៉ាងនេះហើយ និង បវារណាដោយបច្ច័យ ៤ ក្រោកទេឡើងអំពីទីអង្គុយ ថ្វាយបង្គំ **ព្រះមានព្រះភាគជាម្ចាស់** ហើយដើរប្រទក្សិណ ( វិលទៅខាងស្តាំ ) ( ជុំវិញ **ព្រះមានព្រះភាគជាម្ចាស់** ) ៣ ជុំ ហើយចៀសចេញទៅដូច្នោះឯង ៕

**( ចប់ អដ្ឋកថាភយភេរវសូត្រ ទី ៤ )**

# អ ដ្ឋ ក ថា

## អនង្គណសូត្រ ទី ៥

អនង្គណសូត្រមានពាក្យផ្ដើមថា ខ្ញុំម្ចាស់ ( ព្រះអានន្ទ ) បានស្ដាប់មកហើយយ៉ាងនេះ ព្រះសារីបុត្ត .......... ។

ការបរិយាយសេចក្ដី ( ចំពោះ ) បទដែលលំបាកក្នុងព្រះសូត្រនេះ និងក្នុងព្រះសូត្រគ្រប់សូត្រ ក៏នឹងដូចក្នុងព្រះសូត្រនេះ ព្រោះដូច្នោះ តអំពី នេះទៅ ខ្ញុំម្ចាស់នឹងមិនពោលចំពោះប៉ុណ្ណោះ តែនឹងធ្វើការបរិយាយបទដែលមិនធ្លាប់បរិយាយសេចក្ដីមកអំពីមុន ។

បទថា ចត្តារោ ជាការកំណត់រាប់។បទថាបុគ្គលា បានដល់ សត្វ មនុស្សនិងបុរស ។ ដោយពាក្យត្រឹមប៉ុណ្ណោះ ( បុគ្គល ) មិនគួរប្រកាន់ថា ព្រះមហាថេរៈ ( សារីបុត្ត ) មានប្រក្រតីពោលនិយមបុគ្គល ( ពួកបុគ្គល- និយម ) ព្រោះលោកអង្គនេះប្រសើរជាទីបំផុត ក្នុងបណ្ដាព្រះសាវ័កដែលជា ពុទ្ធបុត្តទាំងទឡ្ហាយ លោកទេសនាមិនជំទាស់នឹងព្រះធម្មទេសនារបស់ព្រះមាន-ព្រះភាគជាម្ចាស់ទេឡើយ ។

## ទេសនា២ យ៉ាង

ព្រះធម្មទេសនារបស់ព្រះមានព្រះភាគមាន ២ យ៉ាង គឺ សម្មតិទេសនា

( ទេសនាទាក់ទិននឹងសម្មតិ ) ១ , បរមត្ថទេសនា ( ទេសនាទាក់ទិននឹង បរមត្ថ) ១ ។

ក្នុងចំនួនទេសនាទាំង ២ យ៉ាងនេះ សម្មតិទេសនា មានសេចក្ដីយ៉ាង នេះថា បុគ្គល សត្វ ស្រី ប្រុស ក្សត្រ ព្រាហ្មណ៍ ទេព មារ ជាដើម ។

ចំណែក **បរមត្ថទេសនា** មានសេចក្ដីយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតន សតិប្បដ្ឋាន** ជាដើម ។ ក្នុងចំនួន ទេសនាទាំង ២ យ៉ាងនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែងសម្មតិទេសនា ដល់ពុទ្ធវេនេយ្យ អ្នកដែលស្ដាប់ព្រះធម្មទេសនាពោលដោយរឿងសម្មតិហើយ យល់សេចក្ដី ចាក់ធ្លុះ អាចលះបង់មោហៈ សម្រេចគុណវិសេសបាន ចំណែក មនុស្សពួកណា ស្ដាប់ព្រះធម្មទេសនាពោលដោយរឿងបរមត្ថ ហើយយល់ សេចក្ដី ចាក់ធ្លុះ អាចលះបង់មោហៈ សម្រេចគុណវិសេសបាន ព្រះអង្គ ក៏ទ្រង់សម្ដែងបរមត្ថទេសនាឱ្យគេស្ដាប់ ។

## ប្រៀបធៀបសេចក្ដី

ក្នុងការដែលទ្រង់សម្ដែងព្រះធម្មទេសនាទាំង ២ យ៉ាងនោះ មានសេចក្ដី ប្រៀបធៀបដូចតទៅនេះ ។ ឧបមាដូចអាចារ្យអ្នកបរិយាយត្រៃវេទ ចេះភាសា ប្រទេស កាលនិយាយភាសាទមិទឡ អ្នករៀនពួកណាយល់សេចក្ដី ក៏នឹងប្រាប់

គេទាំងនោះដោយភាសាទមិទឡ ។ តែបើពួកណាយល់សេចក្តីដោយភាសាណាមួយ ក្នុងចំនួនភាសាទាំងទឡាយ មានភាសាអន្ធកៈជាដើម ក៏នឹងប្រាប់គេទាំងនោះដោយភាសានោះ ។ កាលបើដូច្នោះ មាណព ( អ្នករៀន ) ទាំងនោះបានអាស្រ័យអាចារ្យដែលឆ្លាតឈ្លាស នឹងរៀនសិល្បៈបានឆាប់រហ័ស ពិតយ៉ាងណា ក្នុងសេចក្តីឧបមេយ្យនោះ ក៏ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ គប្បីជ្រាបថា ដូចអាចារ្យព្រះត្រៃបិដក ដែលនៅក្នុងភារៈដែលនឹងទ្រង់ត្រូវ ប្រៀនប្រដៅ ដូចត្រៃវេទ , ព្រះប្រីជាឆ្លាតក្នុងសម្មតិ និង បរមត្ថ ដូចការ ឆ្លាតក្នុងភាសាប្រទេស វេនេយ្យសត្វអ្នកអាចចាក់ធ្លុះដោយសម្មតិទេសនា និង បរមត្ថទេសនា ដូចមាណព ( អ្នករៀន ) អ្នកនិយាយភាសាផ្សេង ៗ ព្រះធម្ម_ទេសនាពោលដោយសម្មតិ និង បរមត្ថរបស់ព្រះមានព្រះភាគ ដូចការប្រាប់ ( ត្រៃវេទ ) ដោយភាសាទមិទឡជាដើមរបស់អាចារ្យ ។

ហើយក្នុងការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងសម្មតិទេសនា និង បរមត្ថទេសនានេះ ព្រះបុរាណាចារ្យបានពោលទុកថា ÷

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រសើរជាងអាចារ្យទាំងទឡាយ បានត្រាស់សច្ចៈទុក ២ យ៉ាង គឺ សម្មតិសច្ចៈ ១ បរមត្ថសច្ចៈ ១ មិនមានសច្ចៈយ៉ាងទី ៣ ព្រះពុទ្ធតម្រាស់ទាក់ទងនឹងសម្មតិ (សង្កេត) ឈ្មោះថា

ជាសច្ចៈ ព្រោះហេតុ នៃការសម្មតិរបស់សត្វលោក ចំណែកព្រះពុទ្ធតម្រាស់ទាក់ទងនឹងបរមត្ថ ឈ្មោះថា ជាសច្ចៈ ព្រោះជាហេតុពិត នៃធម៌ទាំងទឡាយ ព្រោះដូច្នោះ សម្រាប់ព្រះលោកនាថសាស្តា ដែលទ្រង់ឆ្លាតក្នុងវោហារទេសនាត្រាស់ដល់សម្មតិមុសាវាទ ទើបមិនកើតទេឡើង(មិនជាការពោលកុហក) ដូច្នេះ ។

## ហេតុដែលទ្រង់ត្រាស់បុគ្គលកថា ៨ ប្រការ

ម្យ៉ាងទៀត ព្រះមានព្រះភាគបានត្រាស់បុគ្គលកថា ( ពាក្យបញ្ជាក់ បុគ្គល ) ដោយហេតុ ៨ ប្រការ គឺ ÷

១ ដើម្បីទ្រង់សម្តែងដល់ហិរិ និង ឱត្តប្បៈ

២ ដើម្បីទ្រង់សម្តែងដល់សត្វដែលមានកម្មជារបស់ខ្លួន ៗ

៣ ដើម្បីទ្រង់សម្តែងដល់ការធ្វើរបស់បុគ្គលដោយចំពោះខ្លួន

៤ ដើម្បីទ្រង់សម្តែងដល់អនន្តរិយកម្ម

៥ ដើម្បីទ្រង់សម្តែងដល់ព្រហ្មវិហារធម៌

៦ ដើម្បីទ្រង់សម្តែងដល់បុព្វេនិវាសានុស្សតិញ្ញាណ

៧ ដើម្បីទ្រង់សម្តែងដល់ទក្ខិណាវិសុទ្ធិ

៨ ដើម្បីមិនទ្រង់លះបង់សម្មតិរបស់លោក

## បរិយាយសេចក្ដីនៃហេតុ ៨ ប្រការ

កាលព្រះអង្គត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងទឡាយ ខ្មាសបាប ខ្លាចបាប មហាជននឹងមិនយល់ នាំគ្នាងឿងឆ្ងល់ ជជែកគ្នាថា ស្អី ! ខន្ធ ធាតុ អាយតនៈទាំងទឡាយ ខ្មាសបាប ខ្លាចបាប ឬ ? ដូច្នេះ តែកាល ព្រះអង្គត្រាស់ថា បុរស ក្សត្រ ព្រាហ្មណ៍ ទេព មារ ( ខ្មាសបាប ខ្លាចបាប ) ដូច្នេះ ។ មហាជននឹងយល់ មិនងឿងឆ្ងល់ មិនជជែកគ្នា ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថា ដើម្បីសម្ដែង ដល់ហិរិ និង ឱត្តប្បៈ ។ សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងទឡាយ ជាអ្នកមានកម្មជារបស់ខ្លួន ដូច្នេះ ក៏ន័យដូចគ្នានុ៎ះឯង ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថា ដើម្បីទ្រង់ សម្ដែងដល់សត្វដែលមានកម្មជារបស់ខ្លួន ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា មហាវិហារ មានព្រះវេឡុវ៉នជាដើម ខន្ធ ធាតុ អាយតនៈទាំងទឡាយសាងទុក ដូច្នោះ ក៏ន័យដូចគ្នានុ៎ះឯង ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្ដែងដល់ការធ្វើរបស់ បុគ្គលដោយចំពោះ ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធធាតុ អាយតនៈ ទាំងទឡាយ

ផ្ដាច់ជីវិតមាតាបិតា ព្រះអរហន្ត ធ្វើលោហិតុប្បាទកម្ម (ប្រទុសរ៉ាយឱ្យពុរពង ព្រះលោហិត) (និង) បំបែកសង្ឃឱ្យបែកគ្នា ដូច្នេះ ។ ក៏ន័យដូចគ្នា នុ៎ះឯង ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថាដើម្បី ទ្រង់សម្ដែងដល់អនន្តរិយកម្ម ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងទឡាយ រមែងមេត្តា (ស្រទឡាញ់សត្វទាំងទឡាយ) ដូច្នេះ ក៏ន័យដូចគ្នានុ៎ះឯង ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់បុគ្គលកថាដើម្បីទ្រង់សម្ដែងដល់ព្រហ្ម-វិហារធម៌ ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងទឡាយ រលឹកជាតិដែលធ្លាប់នៅពីមុនរបស់យើងបាន ដូច្នេះ ក៏ន័យដូចគ្នានុ៎ះឯង ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថា ដើម្បីទ្រង់សំដែងដល់ការ រលឹកជាតិដែលរស់នៅអំពីមុនបាន ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងទឡាយ ទទួលទាន ដូច្នេះ មហាជននឹងមិនយល់ នាំគ្នាងឿងឆ្ងល់ ជជែកគ្នាថា ស៊ី! ខន្ធ ធាតុ អាយតនៈទាំងទឡាយទទួលទានឬ ? ដូច្នេះ តែកាលត្រាស់ថា បុគ្គលអ្នកមានសីល មានកល្យាណធម៌ ទទួលទាន ដូច្នេះ មហាជនក៏យល់

មិនងឿងឆ្ងល់ មិនជជែកគ្នា ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្ដែងដល់សេចក្ដីបរិសុទ្ធិនៃទក្ខិណាទាន ។

ព្រោះថា ធម្មតា ព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ នឹងមិនទ្រង់លះបង់សម្មតិរបស់លោក ទ្រង់តាំងនៅក្នុងពាក្យរបស់សត្វលោក ក្នុងភាសានៃសត្វ លោកក្នុងការចរចាររបស់សត្វលោកនោះឯង ទ្រង់សម្ដែងធម៌ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់បុគ្គលកថាទុក ដើម្បីមិនលះបង់សម្មតិរបស់លោក ។

ដូច្នោះ ព្រះថេរៈអង្គនេះ ( ព្រះសារីបុត្តត្ថេរ ) កាលនឹងមិនឱ្យជំទាស់នឹងព្រះធម្មទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ ទើបបានតាំងនៅក្នុងសម្មតិរបស់លោក ហើយពោលពាក្យមានជាអាទិថា ម្នាលអ្នកមានអាយុទាំងឡាយ បុគ្គល ៤ ប្រភេទនេះ ដូច្នេះ ព្រោះហេតុ ជាអ្នកឆ្លាតក្នុងវោហាររបស់លោក ព្រោះដូច្នោះ បុគ្គលក្នុងទីនេះ មេត្តាជ្រាបតាមសម្មតិប៉ុណ្ណោះ មិនបានសំដៅ ដល់បរមត្ថ ។

បទថា សន្តោ សំវិជ្ជមានា ( តែងមាននៅក្នុងលោក ) គឺ តែងមានរកបានតាមវោហាររបស់លោក ។ ពាក្យថា ក្នុង លោក គឺ ក្នុងសត្វលោក ។

## អធិប្បាយពាក្យថា កិលេសដូចជាទីទួល ៣ យ៉ាង

ក្នុងកន្លែងខ្លះ កិលេស ព្រះអង្គត្រាស់ហៅថា អង្គណា (ដូចជាទីទួល) ក្នុងពាក្យមានជាអាទិថា សង្គណោវ សមានោ ។ ដូចដែលត្រាស់ទុកថា បណ្ដាកិលេសដូចជាទីទួលនោះ កិលេសដូចជាទីទួល តើដូចម្ដេច ? គឺ កិលេសដូចជាទីទួល, បានដល់ រាគ កិលេសដូចជាទីទួល បានដល់ ទោស កិលេសដូចជាទីទួល បានដល់ មោហ កិលេសដូចជាទីទួល ក្នុងកន្លែងខ្លះសំដៅដល់មន្ទិលណាមួយ ឬ ភក់ល្បាប់ ដូចដែលត្រាស់ទុកថា ព្យាយាមដើម្បីនឹងលះបង់មន្ទិល ឬ ភក់ល្បាប់ នោះឯង ។ តែក្នុងកន្លែងខ្លះ សំដៅដល់ផ្ទៃដីបែបនោះ ( ទីទួល ) ផ្ទៃដីនោះ គប្បីជ្រាបតាមពាក្យដែល និយាយគ្នា ដូចជា ទួលដើមពោធិ ទួលចេតិយ ជាដើម ។ តែក្នុង ព្រះសូត្រនេះ ព្រះសារីបុត្តប្រាថ្នាយកកិលេសដ៏ក្ដៅប្រការផ្សេងៗថាកិលេស ដូចជាទីទួល ។

ពិតណាស់ ព្រះសារីបុត្ត ពោលថា លោកដ៏មានអាយុ ពាក្យថា អង្គណ នេះ ជាឈ្មោះរបស់អកុសលធមិ៍ដ៏លាមក មានសេចក្ដីប្រាថ្នាជា អារម្មណ៍ ។ ជាអ្នកប្រព្រឹត្តទៅជាមួយនឹងកិលេសដូចជាទីទួល ឈ្មោះថា មានកិលេសដូចជាទីទួល ។

បទថាសង្គណោវ សមានោអ្នកមានកិលេសដូចជាទីទួលនោះឯង មាននៅ ។

សេចក្តីថា អត្ថិ មេ អជ្ឈត្តំ អង្គណំ ( បុគ្គលខ្លះមិនដឹងតាម សេចក្តីពិតថា កិលេសដូចជាទីទួលរបស់យើង នៅមានក្នុងខាងក្នុង ) សេចក្តី ថា មិនដឹងថា កិលេសមាននៅក្នុងខ្លួនយើង គឺ ក្នុងចិត្តសន្តានរបស់យើង គឺ មិនដឹងដោយពិតយ៉ាងនេះថា ធម្មតាកិលេសទាំងនេះ គ្រោតគ្រាត កាច សាហាវ គួរលះបង់ចោលមិនគួរទុក ដូចជាកូនសរលាបថ្នាំពិស ដូច្នោះ ។

ចំណែកអ្នកណាដឹងថា មានផង ដឹងយ៉ាងនេះផង (ដឹងថា អាក្រក់ ) អ្នកនោះ ព្រះសារីបុត្តហៅថា ដឹងតាមសេចក្តីពិតថា កិលេសដូចជាទីទួល ខាងក្នុងខ្លួនរបស់យើង នៅមាន ។ តែកិលេសដែលនឹងដកបានដោយមគ្គ នៅមិនទាន់កើតទេឡើងដល់អ្នកណា ព្រោះគ្របសង្កត់ទុកបានដោយវិធីណាមួយ ក៏ដោយ អ្នកនេះ ( នោះឯង ) ព្រះសារីបុត្តត្ថេរប្រាថ្នាយកថា ជាអ្នកមិនមាន កិលេសដូចជាទីទួល ក្នុងព្រះសូត្រនេះ ។

សេចក្តីថា នត្ថិ មេ អជ្ឈត្តំ អង្គណន្តិ យថាភូតំ នប្បជានាតិ ( មិនដឹងតាមសេចក្តីពិតថា កិលេសដូចជាទីទួលក្នុងខ្លួនរបស់យើងមិនមាន ) សេចក្តីថា មិនដឹងថា កិលេសទាំងទឡ្បាយរបស់យើងមិនមាន ព្រោះលះបង់

ដោយវិធីណាមួយ មិនមែនមិនមាន ព្រោះដកបានដោយមគ្គ គឺ មិនយល់ដោយពិតយ៉ាងនេះថា កិលេសទាំងនោះ កាលកើតទេឡើង នឹងធ្វើសេចក្ដីវិនាសយ៉ាងធំ( ព្រោះថា) ជាកិលេសគ្រោតគ្រាត កាចសាហាវ គួរលះបង់ មិនគួរទុកដូចកូនសរលាបថ្នាំពិស ដូច្នោះ ។

ចំណែកអ្នកណាដឹងថា មិនមាន ព្រោះហេតុនេះផង ដឹងយ៉ាងនេះផង ( ដឹងថាគ្រោតគ្រាត ) អ្នកនោះ ព្រះសារីបុត្តហៅថា ដឹងតាមសេចក្ដីពិតថា កិលេសដូចជាទីទួលខាងក្នុងខ្លួនរបស់យើងមិនមាន ដូច្នេះ ។

បទថា តត្រ ស្មើនឹង តេសុ យោគ ចតូសុ បុគ្គលេសុ ក្នុងបុគ្គល ៤ ពួកនោះ ឬថា យោគ ទ្វីសុ សង្គណេសុ ក្នុងបុគ្គលអ្នកមាន កិលេសដូចជាទីទួលទាំង ២ នោះ ។

បទថា យ្វាយំ កាត់បទជា យោ+ អយំ( ប្រែថាបុគ្គលនេះ) បាឋ ( បាលីដើម ) ជា យាយំ ដូច្នេះក៏បាន ។

## មនុស្សល្អ-មនុស្សអាក្រក់

ព្រះមោគ្គល្លានសួរដល់ហេតុម្យ៉ាងប៉ុណ្ណោះឯង តែប្រើពាក្យសួរដោយពាក្យទាំងគូថា ព្រះសារីបុត្តដ៏មានអាយុ អ្វីហ្ន៎ ជាហេតុ ជាបច្ច័យ ? ដូច្នេះ ។

គប្បីជ្រាបការសម្ពន្ធគ្នាក្នុងបទថា យេនិមេសំ ជាដើមយ៉ាងនេះថា បណ្ដាបុគ្គលទាំង ២ ប្រភេទនោះ បុគ្គលម្នាក់ លោកហៅថា ជាបុគ្គលប្រសើរ តែបុគ្គលម្នាក់ទៀត លោកហៅថា ជាបុគ្គលថោកទាប ព្រោះហេតុណា ព្រោះបច្ច័យណា ហេតុនោះ គឺអ្វី បច្ច័យនោះ គឺអ្វី ?

ក្នុងរឿងហេតុ និង បច្ច័យទាំង ២ យ៉ាងនោះ សូម្បីថា ពាក្យថា ការ ទទួលដឹង និង ការមិនដឹង ទាំងគូនេះឯង ដែលព្រះសារីបុត្តពោលទុកថា មិនដឹង ទាំងជាហេតុ ទាំងជាបច្ច័យក៏ពិត សូម្បីយ៉ាងនោះ ព្រះថេរៈបាន ពោលដដែលទៀតថា ម្នាលអ្នកមានអាយុ ក្នុងចំនួនបុគ្គល ២ ប្រភេទនោះ ដូច្នេះជាដើម ដើម្បីសម្ដែងហេតុនោះឱ្យច្បាស់ជាងពីមុន ព្រោះហេតុដែលខ្លួនមានបដិភាណស្រួចស្រាវ ។

បណ្ដាបទទាំងនោះ បទថា តស្សេតំ បាដិកង្ខំ (គេសង្ឃឹមបាននូវ ហេតុនោះ) ដូច្នេះ អធិប្បាយថា បុគ្គលនោះ គប្បីសង្ឃឹមបាននូវហេតុនោះ គឺគប្បីកំណត់បានថា បុគ្គលនោះនឹងប្រសព្វហេតុនេះឯង មិនមែនហេតុយ៉ាង ដទៃ សេចក្ដីថា ជារបស់ដែលមានបានពិតប្រាកដ ។ ព្រះសារីបុត្តពោល សំដៅយក ការមិនញ៉ាំងឆន្ទៈឱ្យកើតទេឡើងជាដើម ដែលលោកបានពោលទុក ដោយន័យមានជាអាទិថា គេនឹងមិនញ៉ាំងឆន្ទៈឱ្យកើតទេឡើង ។

សូម្បីក្នុងចំនួនសេចក្តីទាំងនោះ សេចក្តីថា គេនឹងឱ្យឆន្ទៈកើតទេឡើង គឺ គេកាលមិនដឹង ក៏នឹងមិនញុំាងឆន្ទៈឱ្យកើតទេឡើង ដើម្បីនឹងលះបង់កិលេស ដូចជាទីទួលនោះ ។

បទថា ន វាយមិស្សតិ ប្រែថា មិនព្យាយាម គឺ នឹងមិនធ្វើសេចក្តី ព្យាយាមឱ្យមានកម្លាំងខ្លាំងជាងនោះទេឡើយ ។

សេចក្តីថា ន វីរិយំ អារភិស្សតិ ( មិនប្រារព្ធសេចក្តីព្យាយាម) សេចក្តីថា មិនប្រារព្ធសេចក្តីព្យាយាម ដែលជាតួកម្លាំងទេឡើយ អធិប្បាយថា មិនញុំាងសេចក្តីព្យាយាមឱ្យប្រព្រឹត្តទៅ ។

បទថា សង្គណោ ( កិលេសដូចជាទីទួល ) គឺ មានកិលេសដូចជា ទីទួល ដោយទីទួលទាំងទឡាយ មានរាគៈជាដើមទាំងនេះ ។

បទថា សង្កិលិដ្ឋចិត្តោ ( ជាអ្នកមានចិត្តសៅហ្មងហើយ ) គឺ ជាអ្នក មានចិត្តសៅហ្មង បានដល់ មានចិត្តកករល្អក់ ព្រោះទីទួល គឺ កិលេស ទាំងនោះឯង បានដល់ ជាអ្នកមានចិត្តត្រូវកិលេសដូចជាទីទួលទាំងនោះ បៀតបៀន មានចិត្តត្រូវកិលេសដូចជាទីទួលទាំងនោះ ដុតរោល ។

បទថា កាលំ ករិស្សតិ ( នឹងមរណភាព) គឺ នឹងស្លាប់ ។

បទថា សេយ្យថាបិ គឺ សេយ្យថា នាម ប្រៀបដូចថា ។

បទថា កំសបាតិ ភាជនៈសំរឹទ្ធិ គឺ ភាជនៈដែលធ្វើដោយសំរឹទ្ធិ ។

បទថា អាភតា គឺ ទើបយកមក ។

បទថា អាបណា វា កម្មារកុលា វា ( អំពីផ្សារ ឬ ត្រកូល ជាងលោហៈ) គឺ អំពីផ្សារ ឬ អំពីផ្ទះជាងលោហៈ អ្នកធ្វើភាជនៈសំរឹទ្ធិ ។

បទថា រជេន ( ត្រូវល្អង ) គឺ ត្រូវល្អងដែលចរមក មានធូលី ជាដើម ( មកប្រទឡាក់ ) ។

បទថា មលេន ( ត្រូវស្នឹមចាប់ ) គឺ ត្រូវស្នឹមលោហៈដែលកើតនៅនឹងភាជនៈសំរឹទ្ធិនោះឯង ( ចាប់) ។

បទថា បរិយោនទ្ធា (ចាប់) គឺ ប្រទឡាក់ដោយធូលី និង ស្នឹម ទូទៅ ។

បទថា ន ច បរិយោទបេយ្យុំ ( មិនបានដុសខាត់ ) គឺ មិនបានធ្វើការសំអាតដោយវិធីលាង និង ខាត់ពណ៌ជាដើម ។

បទថា រជាបថេ ( ផ្លូវធូលី ) គឺ ក្នុងទីដែលមានល្អងធូលី ។ម្យ៉ាងទៀត បាឋៈ ( បាលីក្នុងព្រះត្រៃបិដក ) ក៏យ៉ាងនោះដូចគ្នា ។ អធិ_ប្បាយថា ដាក់ក្នុងទីដែលល្អងធូលីអណ្តែតត្រសែតមកដល់ គឺ ក្នុងទីដែល ល្អងធូលីផ្សាយមក ឬ ដាក់ទុកក្រោមគ្រែ ឬ ជង្រុកអង្កាម ឬ ខាងក្នុង

ភាជនៈ ដូចយកល្អងធូលីរោយដាក់ ។

ក្នុងសេចក្ដីថា សង្កិលិដ្ឋតរា អស្ស មលគ្គហិតា (រឹតតែ សៅហ្មង) នេះ មានពាក្យអធិប្បាយថា រឹតតែសៅហ្មងជាងដើម ព្រោះរក្សាទុកក្នុងផ្លូវដែលមានល្អងធូលី គឺ ត្រូវស្នឹមចាប់ច្រើនជាងដើម ព្រោះមិនបានប្រើប្រាស់ និង មិនបានធ្វើការសំអាត មិនមែនឬ ?

ក៏ពាក្យថា (រឹតតែសៅហ្មងមានស្នឹមចាប់ច្រើន មិនមែនឬ) នេះ ជាពាក្យសួរ។ ព្រោះដូច្នោះ គប្បីជ្រាបអត្ថាធិប្បាយពាក្យសួរនោះ ដូចតទៅ នេះថា អាវុសោ ( មោគ្គល្លាន ) ភាជនៈសំរិទ្ធិនោះ ដែលគេធ្វើយ៉ាងនេះ ដល់សម័យខាងក្រោយមក រឹតតែសៅហ្មងជាងដើម ហើយនឹងមានស្នឹមចាប់ ច្រើនជាងដើម រហូតលំបាកដែលនឹងដឹងបាន ឬ ដឹងមិនបានថា ជាភាជនៈដី ឬ ជាភាជនៈសំរិទ្ធិ ។ ព្រះថេរៈកាលនឹងទទួលពាក្យនេះ ទើបពោលថា ជាយ៉ាងនោះហើយអាវុសោ ។

ព្រះធម្មសេនាបតី ( សារីបុត្ត ) កាលនឹងបញ្ជាក់សេចក្ដីឧបមាម្ដង ទៀត ទើបបានពោលពាក្យមានជាអាទិទុកថា ឯវមេវ ខោ(ក៏ដូចគ្នា នោះឯង ) ។

ក្នុងពាក្យនោះ គួរជ្រាបការប្រៀបធៀបពាក្យឧបមា និងពាក្យឧបមេយ្យ

ដូចតទៅនេះ ÷

បុគ្គលដែលនៅមានកិលេសដូចជាទីទួល ប្រៀបដូចភាជនៈសំរឹទ្ធិ ដែល សៅហ្មង ការដែលបុគ្គលនោះ កាលនឹងបានបួសក៏ត្រទឡប់បានបួសក្នុងសម្នាក់របស់បុគ្គលអ្នកខ្វល់ខ្វាយក្នុងអនេសនាទាំងទឡាយមានវេជ្ជកម្ម ( ធ្វើពេទ្យ ) ជា ដើម ប្រៀបដូចការទុកដាក់ភាជនៈសំរឹទ្ធិដែលសៅហ្មងហើយ ក្នុងផ្លូវដែលមាន ល្អងធូលី , ព្រោះមិនបានប្រើប្រាស់ជាដើម ។ ការធ្វើអនេសនា មានវេជ្ជកម្ម ជាដើមរបស់បុគ្គលនោះ អ្នកពេញចិត្តតាមអាចារ្យឬឧបជ្ឈាយ៍ តាមលំដាប់ ( ហើយ ) ការធ្វើមរណភាពទាំងដែលនៅមានកិលេសដូចជាទីទួលរបស់បុគ្គលអ្នកតាំងនៅក្នុងវិតិក្កមទោស គឺ ការធ្វើអនេសនា មានវេជ្ជកម្មជាដើម ( ធ្វើពេទ្យដូចអាចារ្យ ) ប្រៀបដូចភាវៈនៃភាជនៈសំរឹទ្ធិដែលសៅហ្មងហើយ ត្រទឡប់សៅហ្មងក្រៃលែងទឡើងលើសដើមទៀត ។

ម្យ៉ាងទៀត មរណភាពទាំងដែលនៅមានអង្គណៈរបស់គេ អ្នកតាំងនៅក្នុងវិតិក្កមទោសនេះតាមលំដាប់ គឺ ការត្រូវអាបត្តិទុក្កដ និង ទុព្ភាសិត ( ប្រៀបដូចភាវៈនៃភាជន៍សំរឹទ្ធិដែលសៅហ្មងហើយ រឹតតែសៅហ្មងទឡើងទៅ ទៀត) ។ ម្យ៉ាងទៀត ការធ្វើមរណភាពទាំងដែលនៅមានកិលេសដូចជាទីទួលរបស់គេអ្នកតាំងនៅក្នុងវិតិក្កមទោសនេះតាមលំដាប់ គឺ ការត្រូវអាបត្តិ

បាចិត្តិយ និង ថុល្លច្ច័យ ការត្រូវអាបត្តិសង្ឃាទិសេស ការត្រូវអាបត្តិបារាជិក និង ការធ្វើអនន្តរិយកម្ម មានការសម្លាប់មាតាជាដើម ( ប្រៀបដូចភាវៈនៃភាជន៍សំរិទ្ធិដែលសៅហ្មងហើយត្រទឡប់ជាសៅហ្មងក្រៃលែងទេឡីងទៅទៀត )។

តែក្នុងសេចក្ដីនេះថា នឹងជាអ្នកមានចិត្តសៅហ្មងធ្វើមរណកាលមិនគួរ ឃើញអត្ថាធិប្បាយយ៉ាងនេះថា នឹងមរណភាពដោយអកុសលចិត្ត ។ ព្រោះ សត្វគ្រប់គ្នាស្លាប់ដោយប្រក្រតីចិត្ត គឺ ដោយភវង្គចិត្តទាំងអស់ តែបុគ្គលនេះ មិនទាន់ជម្រះចិត្តសន្តានឱ្យស្អាតជាមុនហើយ ទើបស្លាប់ ដូច្នេះឯង គប្បីជ្រាប អត្ថាធិប្បាយថា ព្រះសារីបុត្ត ពោលសេចក្ដីទុកយ៉ាងនេះ សំដៅយក អត្ថាធិប្បាយនេះ ។

ក្នុងទុតិយវារៈមានវិនិច្ឆ័យ ដូចតទៅនេះ ÷

បទថា បរិយោទបេយ្យុំ ( គួរដុសខាត់ ) សេចក្ដីថា ធ្វើឱ្យស្អាត គឺ ឱ្យដូចជាកញ្ចក់ឆ្លុះមុខ ដោយការលាង ការដុសខាត់ និង ការជូត ដោយផេះល្អិតជាដើម ។

សេចក្ដីថា ន ច នំ រជាបថេ ( មិនគួរទុកដាក់ក្នុងផ្លូវដែលមាន ធូលី ) សេចក្ដីថា មិនគួរទុកដាក់ក្នុងទីដូចដែលពោលមកហើយ តែគួរទុកដាក់ ក្នុងប្រអប់ ឬហិប ឬខ្ទប់ ហើយព្យួរទុកត្រង់ឈើសម្រាប់ព្យួររបស់ (នាគ_

ទន្តៈ) ។ពាក្យដ៏សេសគួរកាន់យកតាមន័យដែលបានពោលមកហើយនោះ ចុះ ។

តែក្នុងទុតិយវារៈនេះ គួរជ្រាបការប្រៀបធៀបរវាងសេចក្ដីឧបមា និង ឧបមេយ្យដូចតទៅនេះថា ភព្វបុគ្គល ( អ្នកគួរសម្រេចមគ្គ-ផលបាន ) ដែលនៅមានកិលេសដូចជាទីទួល ប្រៀបដូចភាជន៍សំរឹទ្ធិដែលសៅហ្មង ការដែលបុគ្គលនោះ ត្រូវទទួលបានប្បសក្នុងសម្នាក់របស់ភិក្ខុដែលមានសីលជាទីស្រឡាញ់ ដូចជាធ្វើការប្រើប្រាស់ភាជន៍សំរឹទ្ធិដែលសៅហ្មងជាដើម ហើយទុកដាក់ក្នុងទីដែលស្អាត ។ អាចារ្យ និង ឧបជ្ឈាយ៍ពួកណាដាស់តឿនប្រៀនប្រដៅ ( គេ ) ឃើញសេចក្ដីប្រមាទសូម្បីត្រឹមតិចតួច ក៏ធ្វើទណ្ឌកម្ម ហើយឱ្យយកចិត្តទុកដាក់រឿយ ៗ ការធ្វើមរណភាពខណៈដែលមិនមានកិលេសដូចជាទីទួលនៃអ្នកយកចិត្តទុកដាក់តាមអាចារ្យ និង ឧបជ្ឈាយ៍នោះ តាំងនៅក្នុងគុណធម៌នេះ គឺ ការប្រព្រឹត្តិបដិបត្តិដ៏ប្រពៃតាមលំដាប់ ដូចជាភាវៈនៃភាជន៍សំរឹទ្ធិដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាលខាងក្រោយ ។

ម្យ៉ាងទៀត ការធ្វើមរណភាពខណៈដែលមិនមានកិលេសដូចជាទីទួលនៃអ្នកតាំងនៅក្នុងការប្រុងប្រយ័ត្ននៅក្នុងសីលដ៏បរិសុទ្ធ ការរៀនយកនូវព្រះ-ពុទ្ធវចនៈសមល្មមសម្រាប់ខ្លួនហើយ សមាទានធុតង្គ ទទួលយកព្រះកម្មដ្ឋាន

ដែលសមគួរដល់ចរិតរបស់ខ្លួន លះបង់ការនៅក្នុងសេនាសនៈជិតស្រុក ហើយនៅក្នុងសេនាសនៈដែលស្ងាត់នេះតាមលំដាប់ ប្រៀបដូចភាជន៍សំរិទ្ធិដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាលខាងក្រោយ ។

ម្យ៉ាងទៀត ការធ្វើមរណភាពខណៈដែលមិនមានកិលេសដូចជាទីទួលក្នុងជាតិចុងក្រោយនោះឯង ( បរិនិព្វាន ) នៃលោកដែលតាំងនៅក្នុងការធ្វើបរិកម្មកសិណហើយគ្របសង្កត់បាន ដោយការញ៉ាំងសមាបត្តិទាំង ៨ ឱ្យកើតទឡើង ការចេញចាកឈានដែលជាបាទរបស់វិបស្សនា ហើយគ្របសង្កត់កិលេសទុកបានដោយតទង្គប្បហាន ( ការលះបង់កិលេសខ្លះបានដោយអង្គ នោះ ៗ ដូចលះបង់សុភារម្មណ៍បានដោយការពិចារណាអសុភៈជាដើម ) ទើបសម្រេចសោតាបត្តិផលដោយវិបស្សនា ។ល។ ហើយធ្វើអរហត្តឱ្យជាក់ច្បាស់ ដល់ខ្លួន ( ប្រៀបដូចជាភាជន៍នៃភាជន៍ដែលសៅហ្មង តែស្អាតបរិសុទ្ធក្នុងកាល ខាងក្រោយ ) ។

ក្នុងតតិយវារៈមានវិនិច្ឆ័យ ដូចតទៅនេះ ÷

បទថា សុភនិមិត្តំ បានដល់ អារម្មណ៍ដែលគួរប្រាថ្នាជាទីតាំង នៃរាគៈ ។

បទថា មនសិ ករិស្សតិ ( នឹងធ្វើទុកក្នុងចិត្ត ) សេចក្តីថា កាល

សុភនិមិត្តនោះមាននៅ គេក៏នឹងរលឹកដល់និមិត្តនោះ ។

បទថា តស្ស សុភនិមិត្តស្ស មនសិការា (ព្រោះការធ្វើទុកក្នុងចិត្តនូវសុភនិមិត្តរបស់គេ ) បានដល់ ព្រោះហេតុនៃការធ្វើទុកក្នុងចិត្តនូវសុភនិមិត្តរបស់បុគ្គលនោះ ។

បទថា អនុទ្ធំសេស្សតិ (នឹងតាមកម្ចាត់) គឺ នឹងបៀតបៀន បានដល់នឹងគ្របសង្កត់ ( ចិត្តរបស់គេ ) ។ អធិប្បាយថា រាគះ គប្បី ជ្រាបថា កាលកើតទេឡើង ក៏កាត់ផ្តាច់ការបដិបត្តិកុសល ជាអកុសលជវនៈតាមកម្ចាត់កុសលចិត្តហើយស្ថិតនៅ ។

ពាក្យដ៏សេស គួរកាន់យកតាមក្រសែនៃន័យដែលបានពោលមកហើយ នោះចុះ ។

តែក្នុងតតិយវារៈនេះ គួរជ្រាបការប្រៀបធៀបគ្នារវាងឧបមេយ្យដូចតទៅ នេះថា បុគ្គលអ្នកមិនមានកិលេសដូចជាទីទួល មានកិលេសតិចតាមប្រក្រតី ប្រៀបដូចភាជន៍សំរឹទ្ធិដែលស្អាត ។ ការដែលបុគ្គលនោះនឹងបានបួស ( ក៏ត្រូវឡប់បានបួសក្នុងសម្នាក់របស់បុគ្គលអ្នកខ្វល់ខ្វាយក្នុងអនេសនា មានវេជ្ជ-កម្មជាដើម ) ដូចការមិនធ្វើការប្រើប្រាស់ជាដើម ចំពោះភាជន៍សំរឹទ្ធិដែលស្អាតហើយ ថែមទាំងទុកដាក់នៅក្នុងទីដែលមានធូលី ( ទៀត ) ។ តទៅ

អំពីនេះ គ្រប់ពាក្យដូចក្នុងបឋមវារៈទាំងអស់ ។

ក្នុងចតុត្ថវារៈមានវិនិច្ឆ័យ ដូចតទៅនេះ ÷

សេចក្តីថា សុភនិមិត្តំ ន មនសិ ករិស្សតិ ( នឹងមិនធ្វើទុកក្នុងចិត្តចំពោះសុភនិមិត្ត ) សេចក្តីថា នឹងមិនរលឹកដល់និមិត្តនោះ ព្រោះមិនមានការប្រាសចាកសតិ ព្រោះនិមិត្តនោះ ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យនៃទុតិយវារៈចុះ ។ ពាក្យមានជាអាទិថា ម្នាលអាវុសោ បុគ្គលនេះឯងមានន័យដូចដែលបានពោលទុកក្នុងពាក្យមានជាអាទិថា យតោ នុខោ នោះ ឯង ។

## អង្គណ គឺអ្វី ?

ឥឡូវនេះ ព្រះសារីបុត្ត ត្រូវព្រះមហាមោគ្គល្លានដែលប្រាថ្នានឹងឱ្យលោកអធិប្បាយពាក្យថា កិលេសដូចជាទីទួលនោះឱ្យច្បាស់ ដោយប្រការ ផ្សេង ៗ សួរហើយ ដោយន័យមានជាអាទិថា ពាក្យដែលលោកហៅថា អង្គណៈអង្គណៈនេះជាឈ្មោះនៃវត្ថុអ្វី ? ដូច្នេះ កាលនឹងឆ្លើយពាក្យសួរនុ៎ះ ទើបបានពោលពាក្យមានជាអាទិថា ម្នាលអាវុសោ ពាក្យថា អង្គណៈនេះជាឈ្មោះនៃអកុសលធម៌ដ៏លាមក ដែលគ្របសង្កត់ចិត្តដោយអំណាចនៃសេចក្តីប្រាថ្នា ។

បណ្តាបទទាំងនោះ បទថា ឥច្ឆាវចរានំ ( ជាដែនរបស់ឥច្ឆា ) មានសេចក្តីថា ( អកុសល ) ជាទីត្រាច់ទៅនៃសេចក្តីប្រាថ្នា គឺ សេចក្តីក្រោធ និង សេចក្តីតូចចិត្តប្រការផ្សេង ៗ ដែលធ្លាក់ចុះ គឺ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃសេចក្តីប្រាថ្នា ។

សេចក្តីថា យំ ឥធេកច្ចស្ស ( ហេតុដែលនាំឱ្យសេចក្តីប្រាថ្នាកើតទេឡើងដល់ភិក្ខុរូបខ្លះក្នុងព្រះសាសនានេះ ) មានអត្ថាធិប្បាយថា សេចក្តីប្រាថ្នា នេះ គប្បីកើតទេឡើងដល់ភិក្ខុរូបខ្លះដោយហេតុយ៉ាងណា ហេតុនុ៎ះ ដែលជាហេតុនៃសេចក្តីប្រាថ្នានោះមាន គឺ នៅមាន បានដល់ ស្វែងរកបាន ។

បទថា អាបន្នោ អស្សំ ស្មើនឹង អាបន្នោ ភវេយ្យំ ប្រែថា ជាអ្នកត្រូវអាបត្តិមែនហើយ ។

ប្រយោគថា ន ច ភិក្ខូ ជានេយ្យុំ ស្មើនឹង ភិក្ខូ ច មំ ន ជានេយ្យុំ ( ប្រែថា ហើយសុំកុំឱ្យភិក្ខុទាំងទឡាយដឹងថា យើងត្រូវអាបត្តិ ។

ក្នុងរឿងដែលមិនឱ្យភិក្ខុទាំងទឡាយដឹងនេះ មានអ្វីជាហេតុ ?

មានការដែលលោកជាអ្នកមានសេចក្តីត្រូវការលាភ ជាហេតុ ។

អធិប្បាយថា ភិក្ខុអ្នកមានសេចក្តីត្រូវការលាភតាមប្រក្រតីហើយ ក៏ជាអ្នកធ្វើបុណ្យទុកហើយ ជាអ្នកដែលមនុស្សទាំងទឡាយនាំគ្នាធ្វើសក្ការៈ ធ្វើ

សេចក្ដីគោរព ទើបគិតយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិហើយ ព្រះថេរៈទាំងទឡ្បាយដឹងហើយ នឹងប្រាប់ដល់ព្រះភិក្ខុកណ្ដាលទាំងទឡ្បាយ ភិក្ខុកណ្ដាលទាំងទឡ្បាយ នឹងប្រាប់ដល់ភិក្ខុទាំងទឡ្បាយដែលបួសថ្មី ភិក្ខុថ្មីទាំងទឡ្បាយ នឹងប្រាប់ដល់មនុស្សទាំងទឡ្បាយ មានមនុស្សរក្សាវិហារជាដើម ( មនុស្សស៊ីដែលក្នុងវិហារ ) មនុស្សរក្សាវិហារទាំងនោះ នឹងប្រាប់ដល់ភិក្ខុនីទាំងទឡ្បាយអ្នកមកទទួលឱវាទ បរិស័ទទាំង ៤ ក៏នឹងដឹងទៅតាមលំដាប់យ៉ាងនេះ កាលបើយ៉ាងនេះហើយ អន្តរាយនៃលាភ ក៏នឹងមានដល់យើងនោះ គួរឱ្យខ្លាសពិត ? សូម្បីយើង នឹងត្រូវអាបត្តិមែនហើយ សូមភិក្ខុទាំងទឡ្បាយកុំដឹងយើងទេឡើយ ។

សេចក្ដីថា យំ តំ ភិក្ខុំ ភិក្ខូ ជានេយ្យុំ ( ហេតុដែលភិក្ខុទាំងទឡ្បាយគប្បីដឹងភិក្ខុនោះ ) សេចក្ដីថា ហេតុដែលនឹងឱ្យភិក្ខុពួកដទៃដឹងរឿងភិក្ខុនោះមានពិត គឺ មានពិត មិនមែនមិនមាន ព្រោះថា ព្រះថេរៈទាំងទឡ្បាយដឹងហើយ ក៏នឹងប្រាប់ដល់ភិក្ខុកណ្ដាលទាំងទឡ្បាយ ។ កាលបើយ៉ាងនេះ លោកក៏នឹងជាអ្នកប្រាកដក្នុងបរិស័ទទាំង ៤ ដោយន័យដែលបានពោលមកហើយ ។ ហើយលោកប្រាកដយ៉ាងនេះ នឹងជាអ្នកអប្បយស ចូលទៅកាន់ស្រុកទាំង ១០០ ស្រុក ជួតជើងត្រង់ធរណីទ្វារទាំង ១០០ កន្លែង ក៏នឹងចេញមកដោយបាត្រទទេ ។ តអំពីនោះទៅ ភិក្ខុទាំងទឡ្បាយក៏នឹងដឹង

យើងថា ជាអ្នកត្រូវអាបត្តិ ។ ម្យ៉ាងទៀត លោកលុះគិតថា យើងត្រូវព្រះភិក្ខុទាំងនោះធ្វើឱ្យវិនាសទៅហើយ ដោយអាការយ៉ាងនេះ ក៏នឹងជាអ្នកខឹងក្រោធព្រោះហេតុយ៉ាងនេះ ។

## សេចក្តីក្រោធ គឺ សេចក្តីមិនត្រេកអរ ជាអង្គណ

បទថា អប្បតិតោ ( នឹងជាអ្នកមិនត្រេកអរ ) គឺ លោកនឹងជាអ្នក ក្រោធខឹងបានដល់ ត្រូវសេចក្តីក្រោធគ្របសង្កត់ផង និង ជាអ្នកមិនត្រេកអរ គឺត្រូវសេចក្តីមិនត្រេកអរគ្របសង្កត់ផង ព្រោះហេតុនេះ ។ ក្នុងសេចក្តីថា យោ ចេវ ខោ អាវុសោ កោបោ យោ ច អប្បច្ចយោ ឧភយមេតំ អង្គណំ ( ម្នាលអាវុសោ សេចក្តីខឹងក្រោធ និង សេចក្តីមិន ត្រេកអរ ទាំងពីរនេះ ឈ្មោះថា អង្គណ ) នេះ គួរជ្រាបអត្ថាធិប្បាយ យ៉ាងនេះថា ម្នាលអាវុសោ ការខឹងក្រោធដែលសង្គ្រោះចូលក្នុងសង្ខារ_ខន្ធផង

សេចក្តីមិនត្រេកអរដែលសង្គ្រោះចូលក្នុងវេទនាខន្ធផង ទាំងពីរនេះឯង ឈ្មោះថា អង្គណ ហើយពាក្យនេះលោកពោលទុកដោយអំណាចនៃបុគ្គលអ្នក ដូច្នោះតែសេចក្តីលោភ លោកពោលទុកដោយអំណាចជាចំណែកខាងដើម នៃអង្គណៈនេះ ។ ចំណែកមោហៈជាការកាន់យកហើយដូចគ្នា ដោយអំណាចនៃការប្រកបចូលជាមួយគ្នា ( និង លោភៈ ) ។

បទថា អនុរហោ មំ ( គួរចោទអាត្មាអញក្នុងទីស្ងាត់) មានសេចក្តីថា ភិក្ខុរូបនេះ ដូចនឹងភិក្ខុរូបដំបូង ( ដែលត្រូវអាបត្តិ ) ប្រាថ្នាឱ្យភិក្ខុទាំងទឡាយ នាំខ្លួនចូលទៅកាន់សេនាសនៈខាងចុងវិហារ បិទទ្វារហើយ ទើបចោទ ។

បទថា ឋានំ ខោ បនេតំ ( ក៏សេចក្តីនេះឯងជាហេតុ ) សេចក្តីថា ហេតុនេះមានបាន គឺ ភិក្ខុទាំងទឡាយដែលឆ្លាត បានទទួលការណែនាំហើយ គួរនាំភិក្ខុនោះទៅកាន់កណ្តាលបរិស័ទទាំង ៤ ហើយ ទើបចោទដោយន័យ មានជាអាទិថា លោកធ្វើវេជ្ជកម្មក្នុងទីឯណោះ ។ ចំណែកសេចក្តីថា លោកនឹងជាអ្នកប្រាកដក្នុងបរិស័ទទាំង ៤ នឹងប្រាកដយ៉ាងនេះផង ត្រូវការអប្បយស គ្របសង្កត់ហើយផង ទាំងអស់ដូចសេចក្តីក្នុងខាងដើមនោះឯង ។

## បុគ្គលស្មើគ្នា

បទថា សប្បដិបុគ្គលោ ( បុគ្គលស្មើគ្នា ) គឺ បុគ្គលផ្ទុយគ្នា ។

ពាក្យថា ស្មើគ្នា គឺ ត្រូវអាបត្តិដូចគ្នា ។

ពាក្យថា បុគ្គលផ្ទុយគ្នា គឺ អ្នកចោទ ។ ភិក្ខុនេះត្រូវការ ឱ្យចោទដោយភិក្ខុដែលត្រូវអាបត្តិដូចគ្នា ( ព្រោះថា) លោកយល់ថា អាចនឹងនិយាយ ( ជំទាស់ ) បានថា លោកឯងក៏ត្រូវអាបត្តិនេះដែរ លោកចូរសម្តែងអាបត្តិនោះមុនសិន ខាងក្រោយទើបចោទខ្ញុំ ។ ម្យ៉ាងទៀត បុគ្គលស្មើគ្នា

សូម្បីដោយជាតិជាដើម ឈ្មោះថា បុគ្គលស្មើគ្នា ។ អធិប្បាយថា ភិក្ខុនេះត្រូវការឱ្យចោទដោយភិក្ខុស្មើគ្នា ដោយគុណសម្បត្តិទាំងទឡ្យាយ សូម្បីមានជាអាទិយ៉ាងនេះ គឺ ដោយជាតិ ដោយត្រកូល ដោយភាពជាពហុស្សូត ដោយការឆ្លាត ( និង ) ធុតង្គរបស់ខ្លួន ( លោក ) យល់ថា ទុក្ខយ៉ាងក្រៃលែងដែលបុគ្គលដូច្នោះពោលហើយ រមែងមិនមាន ។ បុគ្គលផ្ទុយគ្នា ( ចោទក៏ ) ដែលមិនមែនជាគូគ្នា ឈ្មោះថា បុគ្គលដែលមិនស្មើគ្នា ក្នុងពាក្យនេះថា មិនមែនបុគ្គលដែលមិនស្មើគ្នា មានអធិប្បាយថា បុគ្គលដែលជាគូសត្រូវជាគូប្រឆាំង ឈ្មោះថា មិនគួរជាអ្នកចោទ ព្រោះមិនស្មើគ្នាដោយអាបត្តិជាដើមទាំងនេះ ។

សេចក្តីថា ឥតិ សោ កុបិតោ ( ព្រោះហេតុយ៉ាងនេះ គេនឹងជាអ្នកខឹងក្រោធ ) មានសេចក្តីថា ព្រោះហេតុយ៉ាងនេះ គេនឹងជាអ្នកខឹងក្រោធយ៉ាងនេះ ព្រោះការចោទនៃបុគ្គលមិនស្មើគ្នានេះ ។

ក្នុងចតុត្ថវារៈ (វារៈពោលដោយឥច្ឆាវចរទី៤) មានវិនិច្ឆ័យដូច តទៅនេះ ÷

ស័ព្ទ អហោ វត ( ឱហ្ន៎ ) ប្រាកដក្នុងពាក្យតិះដៀលក៏មាន ដូច ពាក្យថា អើយ ! គួរឱ្យខ្មាសហ្ន៎ លោកជាបណ្ឌិតរបស់ពួកយើង គឺថា

អើយ ! គួរឱ្យខ្មាសពិតហ្ន៎ លោកជាពហុស្សូត និង ជាអ្នកសម្រេចវិជ្ជា ៣ របស់យើងទាំងទឡាយ ។ ប្រាកដក្នុងសេចក្តីប្រាថ្នា ( ក៏មាន ) ដូចពាក្យថា គួររីករាយចិត្តពិត មនុស្សទាំងទឡាយនឹងត្រូវអភិសេកយើងដែលនៅកំលោះ នៅក្មេងពិត ទុកក្នុងរាជសម្បត្តិ ។ ក្នុងទីនេះប្រាកដក្នុងសេចក្តីប្រាថ្នាប៉ុណ្ណោះ ។

ពាក្យថា បុច្ឆិត្វា បុច្ឆិត្វា ( ត្រាស់សួរហើយ ) គឺ ត្រាស់សួរហើយ ត្រាស់សួរទៀត ។ ភិក្ខុអ្នកមានសេចក្តីត្រូវការលាភនេះ ចង់ឱ្យព្រះមានព្រះភាគ ទ្រង់សួរខ្លួន តែត្រូវការឱ្យសួរបញ្ហានោះ ដោយពាក្យដើម្បីឱ្យស្របតាម មិនមែនត្រាស់សួរដល់មគ្គ_ផល ឬ វិបស្សនា ធ្វើឱ្យមានចន្លោះ ។ ព្រោះថា ភិក្ខុរូបនេះ ឃើញព្រះមានព្រះភាគជាម្ចាស់ទ្រង់សួរព្រះមហាថេរៈទាំងទឡាយមាន ព្រះសារីបុត្តជាដើម ក្នុងកណ្តាលបរិស័ទយ៉ាងនេះថា សារីបុត្ត មោគ្គល្លាន កស្សប រាហុល អ្នកយល់សេចក្តីនោះថា យ៉ាងណា ? គឺ ចក្ខុទៀង ឬ មិនទៀង ហើយទ្រង់សម្តែងធម៌ ឃើញពួកមនុស្សពោលសរសើរគុណរបស់ ព្រះថេរៈទាំងនោះថា ព្រះថេរៈដែលជាបណ្ឌិតទាំងទឡាយ ព្រះសាស្តាទ្រង់ ពេញព្រះទ័យ ដូច្នេះ ហើយឃើញពួកទាយកនាំលាភសក្ការៈទៅថ្វាយព្រះថេរៈ ទាំងនោះ ព្រោះដូច្នោះ លោកកាលប្រាថ្នាលាភសក្ការៈនោះ លុះគិតយ៉ាង នេះហើយ ចេញទៅឈរចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគជាម្ចាស់ ដូច

កំណាត់ឈើដែលដាក់ទុក ។

បទថា សោ កុបិតោ ( លោកខឹងក្រោធហើយ ) សេចក្តីថា ជាខាងក្រោយព្រះមានព្រះភាគជាម្ចាស់មិនពេញព្រះទ័យលោកទេឡើយ តែត្រាស់សួរព្រះថេរៈរូបដទៃហើយ ក៏ទ្រង់សម្តែងធម៌ ព្រោះដូច្នោះ លោកទើបក្រោធខឹងទាំងព្រះមានព្រះភាគជាម្ចាស់ និង ព្រះថេរៈ ។

ក្រោធខឹងព្រះមានព្រះភាគជាម្ចាស់ យ៉ាងណា ?

ក្រោធខឹងព្រះមានព្រះភាគជាម្ចាស់ យ៉ាងនេះថា យើងតាំងអំពីបួសមិនស្គាល់ការចេញទៅខាងក្រៅបរិវេណព្រះគន្ធកុដិ គ្រប់ពេលមិនដែលឃ្លាតឆ្ងាយប្រៀបដូចស្រមោល សូម្បីត្រឹមតែនឹងត្រាស់សួរយើង ហើយទ្រង់សម្តែងធម្មទេសនាក៏មិនមាន ទ្រង់សួរព្រះថេរៈ ដែលទ្រង់ឃើញត្រឹមមួយរំពេចប៉ុណ្ណោះ ហើយក៏ទ្រង់សម្តែងធម៌ ។

ក្រោធខឹង ព្រះថេរៈ យ៉ាងណា ?

ក្រោធខឹងព្រះថេរៈយ៉ាងនេះថា ភិក្ខុចាស់រូបនេះ អង្គុយចំពោះព្រះភក្រ្តព្រះមានព្រះភាគជាម្ចាស់ ដូចគល់ឈើ កាលណាព្រះថេរៈដែលជាធម្មកម្មិកៈ ( ធ្វើការងារទាក់ទងនឹងធម៌ ) និង ឱ្យភិក្ខុចាស់រូបនេះដល់ឋានៈនៃអភព្វបុគ្គល ( អ្នកមិនគួរសម្រេចមគ្គផល ) ហើយបណ្តេញចេញ ( ចាកពួកគណៈ)

ព្រោះថា បើមិនមានភិក្ខុរូបនេះក្នុងវិហារនេះសោត ព្រះមានព្រះភាគជាម្ចាស់នឹងទ្រង់ចចារជាមួយនឹងយើងជាពិតប្រាកដ ។

## ភិក្ខុក្រោធ

បទថា បុរក្ខត្វា បុរក្ខត្វា (ធ្វើទុកខាងមុខ ធ្វើទុកខាងមុខ) គឺ ធ្វើ (ឱ្យនៅ) ខាងមុខ មានពាក្យអធិប្បាយថា ចោមរោម (ទាំងខាងមុខ និង ខាងក្រោយ) ។

សូម្បីភិក្ខុរូបនេះ ក៏ជាអ្នកប្រាថ្នាលាភដូចគ្នា ។ ព្រោះថា ភិក្ខុរូបនេះ ឃើញភិក្ខុទាំងទឡាយដែលជាពហុស្សូតចូលកាន់ស្រុក ព្រមជាមួយនឹងភិក្ខុដែលជាបរិវារ កំពុងថ្វាយបង្គំព្រះចេតិយ ហើយឃើញឧបាសកទាំងទឡាយអ្នកមានសេចក្ដីជ្រះថ្លានឹង ( ភិក្ខុទាំងនោះ ) ព្រោះឃើញគុណធមិនោះ របស់លោកទាំងនោះ សម្ដែង ( ធ្វើ ) អាការរបស់អ្នកជ្រះថ្លា ព្រោះដូច្នោះ លោកទើបត្រូវការយ៉ាងនេះ ។

បទថា កុបិតោ ( ក្រោធខឹងហើយ ) មានន័យថា ភិក្ខុសូម្បីរូបនេះ ក្រោធខឹងព្រោះហេតុ ២ ស្ថាន គឺ ក្រោធខឹងដល់ភិក្ខុទាំងទឡាយ និង ព្រះថេរៈ ។

ក្រោធខឹងដល់ភិក្ខុទាំងទឡាយ យ៉ាងណា ?

ក្រោធខឹងភិក្ខុទាំងទឡាយយ៉ាងនេះថា ភិក្ខុទាំងនេះកាន់យកចំពោះចីវរ ឬ បិណ្ឌបាត ដែលកើតទេឡីងដល់យើងនោះបរិភោគ តែអ្នកនឹងមកខាងក្រោយទទួលបាត្រចីវររបស់យើងក៏មិនមាន ។

ក្រោធខឹងព្រះថេរៈ យ៉ាងណា ?

ក្រោធខឹងព្រះថេរៈថា ព្រះថេរៈចាស់រូបនេះ (ទៅ) ប្រាកដខ្លួនក្នុង ទីនោះ ៗ កាលណាហ្ន៎ ព្រះធម្មកម្មិក នឹងចាប់គេចេញទៅ កាលមិនមាន ភិក្ខុចាស់រូបនេះ ភិក្ខុទាំងទឡាយក៏នឹងហែហមយើងម្នាក់ជាពិតប្រាកដ ។

បទថា ភត្តគ្គេ (រោងឆាន់) គឺ កន្លែងសំរាប់ឆាន់ (រោងឆាន់) ។

បទថា អគ្គេសនំ(អាសនៈដ៏ប្រសើរ) អាសនៈសម្រាប់ព្រះសង្ឃ- ថេរៈ ។

បទថា អគ្គោទកំ ( ទឹកដ៏ប្រសើរ ) គឺ ទក្ខិណោទក ( ទឹកដែលថ្វាយដោយសេចក្ដីគោរព ) ។

បទថា អគ្គបិណ្ឌំ ( បិណ្ឌបាតដ៏ប្រសើរ ) គឺ បិណ្ឌបាតសំរាប់ព្រះ- សង្ឃថេរៈ ។

ម្យ៉ាងទៀត ក្នុងទីគ្រប់កន្លែង ពាក្យថា ប្រសើរ នេះ ជាពាក្យប្រើហៅរបស់ដ៏ប្រណីត ។

បណ្ដាសេចក្ដីប្រាថ្នាទាំង ២ យ៉ាងនេះ សេចក្ដីប្រាថ្នាថា យើងតែម្នាក់ប៉ុណ្ណោះគួរបាន ដូច្នេះ មិនមានទោសធ្ងន់ប៉ុន្មាន ។ តែសេចក្ដីប្រាថ្នា ថា ភិក្ខុឯទៀតមិនគួរបាន ដូច្នេះ មានទោសធ្ងន់ណាស់ ។

ភិក្ខុអ្នកត្រូវការលាភរូបនេះ ជាអ្នកដែលគួរជ្រះថ្លា ដោយការគ្រង ចីវរជាដើម គ្រាខ្លះក៏បួស គ្រាខ្លះក៏សឹក ព្រោះហេតុនោះ លោកកាលខាងក្រោយមិនបានអាសនៈជាដើម ដែលខ្លួនធ្លាប់បានអង្គុយមកហើយក្នុងកាលមុន ទើបគិតយ៉ាងនេះថា ភិក្ខុនោះមិនគួរនឹងបាន ។ ភិក្ខុរូបនោះក្រាលអាសនៈដ៏ប្រសើរជាដើមដល់ព្រះថេរៈទាំងទឡាយ ( ព្រះថេរៈគង់ហើយ ) សម្រាប់ភិក្ខុកណ្ដាល និង ភិក្ខុថ្មីពួកដទៃ ក៏ទំនងដូចគ្នានោះ គ្រាខ្លះក៏បានអាសនៈធម្មតា ឬ អាសនៈដ៏ទាបជាងអាសនៈទាំងអស់ ឬ មិនបានទេឡើយ ។

បទថា កុបិតោ ( ក្រោធខឹងហើយ) គឺ ភិក្ខុរូបនេះឯងក្រោធខឹង ព្រោះហេតុ ២ យ៉ាង គឺ ( ក្រោធខឹង) មនុស្សទាំងទឡាយនិង ព្រះថេរៈ ទាំងទឡាយ ។

ក្រោធខឹងមនុស្សទាំងទឡាយ យ៉ាងណា ?

( ក្រោធខឹង ) មនុស្សទាំងទឡាយយ៉ាងនេះថា មនុស្សទាំងនេះអាស្រ័យ យើងទើបបានភិក្ខុទាំងទឡាយ ( មក) ក្នុងកិច្ចការជាដើម ( កាលមុន)

គេនាំគ្នានិយាយថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ករុណានាំភិក្ខុចំនួនប៉ុណ្ណោះ ( ទៅ ) ធ្វើសេចក្ដីអនុគ្រោះដល់ខ្ញុំទាំងទឡាយចុះ ឥទឡូវនេះគេបាននិមន្តព្រះថេរៈចាស់ អ្នកត្រឹមតែឃើញមួយភ្លែតទៅ រឿងនេះណ្ហើយចុះ តទៅនេះកាលកិច្ចរបស់គេទាំងនេះកើតទឡើង យើងនឹងដឹង ( ដោះ ដៃ ) ។

ក្រោធខឹងព្រះថេរៈ យ៉ាងណា ?

ក្រោធខឹងព្រះថេរៈយ៉ាងនេះថា បើធម្មតាមិនមានព្រះថេរៈទាំងនេះសោត មនុស្សទាំងទឡាយនឹងត្រូវនិមន្តចំពោះយើងប៉ុណ្ណោះ ។

បទថា អនុមោទេយ្យំ ( គួរបានអនុមោទនា ) គឺ គួរធ្វើអនុមោទនា ។ សូម្បីភិក្ខុរូបនេះជាអ្នកមានសេចក្ដីត្រូវការលាភ ចេះការអនុមោទនាបន្តិចបន្តួចរបៀបធម្មតា ៗ ។ លោកគិតប្រាថ្នាយ៉ាងនេះថា នៅក្នុងកន្លែងដែលអនុមោទនាអ្នកស្រុកនឹងនាំគ្នាមកច្រើន ពួកគេចាំយើងបានហើយ តទៅនឹងថ្វាយភិក្ខាហារជាថាស ៗ ។

បទថា ឋានំ (ហេតុ ) សេចក្ដីថា ការអនុមោទនា ជាភារៈរបស់ភិក្ខុទាំងទឡាយអ្នកជាពហុស្សូត ព្រោះដូច្នោះ លោកទើបពោលអធិប្បាយទុក ថា ភិក្ខុអ្នកជាពហុស្សូតគួរអនុមោទនា ។

បទថា កុបិតោ (ក្រោធខឹងហើយ) មានន័យថា ភិក្ខុរូបនេះឯងនឹង ក្រោធខឹងព្រោះហេតុ ៣ យ៉ាង គឺ ក្រោធខឹងមនុស្សទាំងទឡាយ ១ ក្រោធខឹងព្រះថេរៈ ១ ក្រោធខឹងព្រះធម្មកថិក ១ ។

ក្រោធខឹងមនុស្សទាំងទឡាយ យ៉ាងណា ?

ក្រោធខឹងមនុស្សទាំងទឡាយយ៉ាងនេះថា កាលមុនមនុស្សទាំងនេះចូលមករកយើងម្នាក់ហើយសូមអង្វរថា សូមនិមន្ត ព្រះនាគថេរ របស់យើងទាំងទឡាយសូមអនុមោទនា សូមនិមន្ត ព្រះសុមនថេរ របស់យើងទាំងទឡាយសូមអនុមោទនា តែថ្ងៃនេះមិននិយាយ (មិននិមន្ត) ។

ក្រោធខឹងព្រះថេរៈ យ៉ាងណា ?

ក្រោធខឹងព្រះថេរៈយ៉ាងនេះថា ព្រះសង្ឃថេរៈរូបនេះមិនពោលថា អ្នកទាំងទឡាយចូរនាំគ្នាចូលទៅរក ព្រះនាគថេរ ព្រះសុមនថេរ អ្នកជាភិក្ខុប្រចាំត្រកូលរបស់អ្នកទាំងទឡាយ លោកនេះនឹងអនុមោទនា ។

ក្រោធខឹងព្រះធម្មកថិក យ៉ាងណា ?

ក្រោធខឹងព្រះធម្មកថិកយ៉ាងនេះថា លុះព្រះថេរៈសម្តែងចប់ប៉ុណ្ណោះ ឃើញ (ព្រះធម្មកថិក ) ក្តៅក្រហាយ ដូចមាន់ដែលត្រូវគេវាយ អ្នកនឹងចាប់អូសភិក្ខុរូបនេះចេញទៅ ក៏មិនមាន ព្រោះថា កាលមិនមានភិក្ខុរូបនេះ

យើងម្នាក់ត្រូវអនុមោទនា ។

បទថា អារាមគតានំ (អ្នកមកកាន់អារាម) គឺ អ្នកប្រជុំគ្នានៅក្នុង វិហារ ។

សូម្បីភិក្ខុរូបនេះ អ្នកមានសេចក្តីត្រូវការលាភ ចេះធម្មកថាជាផ្នែក ៗ បែបធម្មតា ៗ លោកឃើញភិក្ខុទាំងទឡាយដែលអង្គុយប្រជុំគ្នាស្តាប់ធម៌ជានិច្ច រហូតទល់ភ្លឺតាំងពី២_៣ រយយោជន៍ក្នុងទីដូច្នោះ នាំគ្នាពេញចិត្តឬឃើញ ភិក្ខុកំលោះ ឬ សាមណេរកំពុងឱ្យសាធុការដោយសំទេឡងខ្លាំង ៗ ថា សាធុ សាធុ ឧបាសក_ឧបាសិកាទាំងទឡាយ នាំគ្នាសួរភិក្ខុទាំងទឡាយដែលទៅក្នុង ស្រុកក្នុងថ្ងៃទី ២ តអំពីនោះថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ភិក្ខុពួកណា សម្តែងធម៌ ភិក្ខុទាំងនោះពោលថារូបឯណោះរូបឯណោះ មនុស្សទាំងទឡាយ បានឮដូច្នោះហើយ ជ្រះថ្លានឹងនាំគ្នាធ្វើសក្ការៈដល់ព្រះធម្មកថិកច្រើន ។ ភិក្ខុរូបនេះកាលប្រាថ្នាលាភនោះ រមែងគិតយ៉ាងនេះ ។

បទថា ឋានំ (ហេតុទីតាំង) សេចក្តីថា ការសម្តែងធម្មទេសនាជា ភារៈរបស់ ( ភិក្ខុទាំងទឡាយ ) អ្នកជាពហុស្សូត អ្នកឆ្លាតក្នុងការវិនិច្ឆ័យ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយទុកថាភិក្ខុអ្នកជាពហុស្សូតគួរសម្តែង ធម៌ ។

បទថា កុបិតោ ( ក្រោធខឹងហើយ ) សេចក្តីថា កាលមិនបានឱកាសពោលត្រឹមគាថាដែលប្រកបដោយបទ ៤ បទ ក៏នឹងក្រោធខឹងខ្លួនឯងដែលជាមនុស្សល្ងង់ថា ព្រោះយើងល្ងង់ខ្លៅបញ្ញាតិចពេលណានឹងបានសម្តែងធម៌ ។

បទថា ភិក្ខុនីនំ ( ភិក្ខុនីទាំងទឡាយ ) សេចក្តីថា ដល់ភិក្ខុនីទាំងទឡាយអ្នកមកកាន់អារាមហើយប្រជុំគ្នាដើម្បីទទួលឱវាទ ដើម្បីឧទ្ទេស ដើម្បីការដកពិសោធន៍ ឬ ដើម្បីធ្វើការបូជា ។

សូម្បីភិក្ខុរូបនេះអ្នកមានសេចក្តីត្រូវការលាភ លោកនឹងមានសេចក្តីគិតយ៉ាងនេះថា ភិក្ខុនីទាំងនេះបួសអំពីត្រកូលធំ កាលពួកលោកចូលទៅអង្គុយក្នុងត្រកូលទាំងទឡាយ មនុស្សទាំងទឡាយនឹងនាំគ្នាសួរថា លោកទាំងទឡាយនាំគ្នាទទួលឱវាទ ឬឧទ្ទេស ឬសាកសួរ ក្នុងសម្នាក់របស់អ្នកណា អំពីការសួរ នោះភិក្ខុនីទាំងទឡាយនឹងប្រាប់ថា ព្រះគុណម្ចាស់ឈ្មោះឯណោះអ្នកជាពហុស្សូតលោកទាំងទឡាយចូរថ្វាយ (គ្រឿង) ធ្វើ (សក្ការៈ) ដល់លោក ព្រោះហេតុនោះសេចក្តីត្រូវការយ៉ាងនេះ ទើបកើតទេឡើងដល់លោក ។

បទថា ឋានំ ( ហេតុទីតាំង ) សេចក្តីថា ជាធម្មតាកិច្ចវត្ត មានការឱ្យឱវាទជាដើម ជាភារៈរបស់ភិក្ខុទាំងទឡាយដែលជាពហុស្សូត ព្រោះដូច្នោះលោកទើបពោលអធិប្បាយទុកថា ភិក្ខុដែលជាពហុស្សូតគួរសម្តែង ។

បទថា កុបិតោ ( ក្រោធខឹងហើយ ) មានអធិប្បាយថា ភិក្ខុនេះក្រោធខឹងព្រោះហេតុ ២ យ៉ាង គឺ ក្រោធខឹងភិក្ខុនីទាំងនោះថា ភិក្ខុនីទាំងនេះកាលមុនអាស្រ័យយើង ទើបបានឧបោសថ និង បវារណាជាដើម តែឥឡូវនេះភិក្ខុនីទាំងនោះ បានទៅកាន់សម្នាក់របស់ព្រះថេរៈចាស់អ្នកត្រឹមតែបានឃើញមួយភ្លែត នឹងក្រោធខឹងព្រះធម្មកថិកថា ព្រះធម្មកថិករូបនោះ បានឱ្យឱវាទដល់ភិក្ខុនីទាំងនោះ ។

បទថា ឧបាសកានំ (ដល់ឧបាសកទាំងទឡាយ) មានអធិប្បាយថា ធម្មតាឧបាសកទាំងទឡាយអ្នកទៅវត្ត ជាឧបាសកធំ លះបង់ការងារហើយ គេទាំងនោះប្រគល់ការងាឱ្យកូន_ប្អូនហើយ ទៅរកស្តាប់ធម៌ ។ ភិក្ខុរូបនេះត្រូវការសម្តែងធម៌ដល់ឧបាសកទាំងនោះ ។

ព្រោះហេតុអ្វី ? ព្រោះមនុស្សទាំងនេះ ជ្រះថ្លានឹងភិក្ខុទាំងនេះហើយ នឹងប្រាប់ឱ្យឧបាសិកាទាំងទឡាយជ្រាបខ្លះ តទៅឧបាសិកាទាំងទឡាយក៏នឹងនាំគ្នា នាំលាភ និង សក្ការៈមកថ្វាយយើងតែម្នាក់គត់ ព្រោះដូច្នោះ គួរប្រកបហេតុជាទីតាំងចូលជាមួយនឹងអ្នកដទៃជាពហុស្សូតផង ។

បទថា កុបិតោ ( ក្រោធខឹងហើយ ) មានសេចក្តីថា ភិក្ខុរូបនេះនឹងក្រោធខឹងព្រោះហេតុ ២ យ៉ាង គឺ ក្រោធខឹងនឹងឧបាសកទាំងទឡាយថា ឧបា_

សកទាំងនោះស្តាប់ ( ធម៌ ) កន្លែងដទៃមិនមកវត្តយើង ដោយការតាំងចិត្ត ថាពួកយើងនឹងស្តាប់ ( ធម៌ ) ក្នុងសម្នាក់របស់ភិក្ខុប្រចាំត្រកូលរបស់ពួកយើង សេចក្តីនោះ មិនអីទេ តទៅនេះ យើងនឹងដឹងទុកក្នុងកាលពួកគេមានកិច្ចកើត ទេឡើងនឹងក្រោធខឹងព្រះធម្មកថិកថាលោករូបនេះសម្តែងធម៌ឱ្យមនុស្សទាំងនេះ ស្តាប់ ។

បទថា ឧបាសិកានំ ( ដល់ឧបាសិកាទាំងទឡាយ ) សេចក្តីថា ធម្មតាឧបាសិកាទាំងទឡាយអ្នកមកវត្ត បានប្រជុំគ្នាដើម្បីក្រាលអាសនៈ និង ធ្វើការបូជាជាដើម ឬ ដើម្បីស្តាប់ធម៌ក្នុងថ្ងៃឧបោសថ ។

ពាក្យដ៏សេសអំពីទីដែលបានអធិប្បាយមក មានន័យដូចដែលបានពោលហើយក្នុងវារៈពោលដោយឧបាសក ។

បទថា សក្កច្ចំ គឺ គួរធ្វើដោយគោរពផង ធ្វើឱ្យល្អផង ។ ដោយ ពាក្យថា គួរសក្ការៈនេះ លោកប្រាថ្នាការដែលធ្វើក្នុងខ្លួនដោយគោរព និង ដោយល្អ ។

បទថា គរុករេយ្យុំ ( គួរគោរព ) គឺ គួរធ្វើឱ្យធ្ងន់ ។ ដោយពាក្យថា គួរគោរព នេះ លោកប្រាថ្នានឹងឱ្យភិក្ខុទាំងទឡាយតាំងខ្លួនលោកទុកក្នុងឋានៈជា គ្រូ ។

បទថា មានេយ្យំ (រាប់អាន) គឺ ស្រឡាញ់រាប់អាន ។

បទថា បូជេយ្យុំ (បូជា) សេចក្តីថា លោកប្រាថ្នាការបូជាដោយ បច្ច័យថា មនុស្សទាំងឡាយកាលធ្វើសក្ការៈគោរពរាប់អានយើង ក៏ត្រូវបូជាយើងដោយបច្ច័យទាំងឡាយយ៉ាងនេះ ។

បទថា ឋានំ ( ហេតុទីតាំង ) សេចក្តីថា ភិក្ខុដែលជាពហុស្សូត និងជាអ្នកមានសីល មានប្រការដូចដែលពោលហើយថា ជាទីស្រឡាញ់ ជាទី គោរព ជាទីរាប់អាន សមគួរនឹងវិធីនេះ ព្រោះដូច្នោះ លោកទើបអធិប្បាយ ទុកថា ភិក្ខុទាំងឡាយគួរធ្វើបែបនេះ គឺ យ៉ាងនេះ ។

បទថា កុបិតោ ( ក្រោធខឹងហើយ ) សេចក្តីថា សូម្បីភិក្ខុរូបនេះនឹងក្រោធខឹង ព្រោះហេតុ ២ យ៉ាង គឺ ក្រោធខឹងនឹងភិក្ខុទាំងឡាយថា ភិក្ខុទាំងនេះធ្វើសក្ការៈភិក្ខុនោះ ហើយក្រោធខឹងព្រះថេរៈថា កាលមិនមានព្រះថេរៈ រូបនេះ ភិក្ខុទាំងឡាយត្រូវសក្ការៈយើងតែម្នាក់ប៉ុណ្ណោះ ។ ក្នុងវារៈដទៃ ៣ ទៀតតអំពីនេះ ក៏មានន័យនេះ ។

បទថា បណីតានំ ចីវរានំ ( ចីវរប្រណីត ) បានដល់ សំពត់ចីវរដែលមានតម្លៃខ្ពស់ សាច់ល្អិត មានសម្ផស្សទន់ ( ដណ្តប់ស្រួល ) មានសំពត់ធម្មតា សំពត់សំបកឈើ សំពត់សូត្រដែលជំរះហើយ និង សំពត់សូត្រ

ធម្មតាជាដើម ។

សេចក្តីប្រាថ្នាថា យើងប៉ុណ្ណោះ គួរមានលាភ មិនឈ្មោះថា មានទោសច្រើនក្នុងទីនេះទេឡើយ ។ តែមានទោសច្រើន គឺ ប្រាថ្នាថា សូមកុំឱ្យមនុស្សដទៃមានលាភ ។

បទថា បណីតានំ បិណ្ឌបាតានំ ( បិណ្ឌបាតប្រណីត ) គឺ បិណ្ឌបាតដែលល្អបំផុតបរិបូណ៌ទៅដោយទឹកដោះថ្លា រសប្រេង និង រសសាច់ជាដើម ។

បទថា បណីតានំ សេនាសនានំ (សេនាសនៈប្រណីត) គឺ ទីអង្គុយទីដេកមានគ្រែ និង តាំងជាដើម ដែលមានតំលៃច្រើនសែន ។

បទថា បណីតានំ គិលានប្បច្ចយភេសជ្ជ បរិក្ខារានំ (បរិក្ខារ គឺ ថ្នាំដែលជាបច្ច័យដល់អ្នកជម្ងឺ) គឺ ថ្នាំកែរោគប្រភេទខ្ពស់ មានទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និង ទឹកអំពៅជាដើម ។ សូម្បីគ្រប់វារៈ គួរប្រកបហេតុជាទីតាំងចូលជាមួយអ្នកជាពហុស្សូត និង អ្នកមានបុណ្យទាំងទឡាយ ។

បទថា កុបិតោ ( ខឹង ) បានដល់ ខឹងព្រោះហេតុ ២ យ៉ាង គឺ ក្រោធខឹងមនុស្សទាំងទឡាយថា ដែលឈ្មោះថា មនុស្សទាំងនេះមិនមានការអប់រំសន្សំ ( បុញ្ញបារមី ) សោះ យើងនៅរួមគ្នាមករហូតកាលយូរ សូម្បីនឹងដើរទៅតាមលំដាប់ផ្ទះដើម្បីត្រូវការសំពត់បង្សុកូល ឬថាដើម្បីត្រូវការបិណ្ឌបាត

ឬ ព្រោះហេតុនៃទឹកដោះថ្លា និង ប្រេងជាដើម មនុស្សទាំងនេះក៏មិនថ្វាយ បច្ច័យ ៤ ដ៏ប្រណីតអ្វី សូម្បីតែមួយថ្ងៃ តែលុះឃើញព្រះថេរៈអ្នកជាភ្ញៀវ មកប៉ុណ្ណោះ ក៏នាំគ្នាថ្វាយវត្ថុដែលលោកត្រូវការ ហើយក្រោធខឹងព្រះថេរៈ យ៉ាងនេះថា ព្រះថេរៈរូបនេះ ដើរសម្តែងខ្លួនឱ្យមនុស្សទាំងនោះឃើញ កាលណាភិក្ខុអ្នកជាធម្មកម្មិកៈនឹងចាប់អូសលោកចេញទៅ កាលមិនមានព្រះថេរៈ រូបនេះ យើងតែម្នាក់ត្រូវមានលាភ ។

បទថា ឥមេសំ ខោ អាវុសោ ( ទាំងនេះឯង ) មានន័យថា ( អកុសលធម៌ទាំងទឡាយ ) នេះ ដែលជាដែនរបស់ឥច្ឆា ដែលបានពោលអំពីខាងដើមដោយវារៈ ១៩ វារៈ ។

បទថា ទិស្សន្តិ ចេវ សុយ្យន្តិ ច ( បានឃើញច្បាស់ និង ឮ ច្បាស់ ) មានន័យថា បាបអកុសលដែលជាឥច្ឆាវចរៈ ( ជាដែនឥច្ឆា ) មិនមែនឃើញឮបានដោយចក្ខុ មិនមែនឮបានដោយសោត ។ តែកាលបានឃើញកាយកម្មរបស់បុគ្គលអ្នកដែលមិនលះបង់បាបអកុសល ដែលជាឥច្ឆាវចរៈទាន់ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃអកុសលដែលជាឥច្ឆាវចរៈ ក៏ដូចជាបានឃើញហើយ ហើយកាលបានឮវចីកម្មរបស់បុគ្គលអ្នកដែលមិនលះបាបអកុសលដែលជាឥច្ឆាវចរៈទាន់ ដែលប្រព្រឹត្តទៅដោយអំណាចអកុសលដែលជាឥច្ឆា_

វចរៈ ក៏ដូចជាបានឮហើយ ព្រោះជាអារម្មណ៍របស់មនោវិញ្ញាណ ។ ព្រោះ ដូច្នោះ ព្រះសារីបុត្តថេរៈ ទើបបានពោលទុកថា ដែលឃើញច្បាស់ និង បានឮច្បាស់ ។ អធិប្បាយថា ឃើញរហូតកាលដែលនៅប្រចក្ស (ចំណែក ) បានឮក្នុងពេលដែលកន្លងមកហើយថាបានឮថាភិក្ខុរូបឯណោះក៏ដូចភិក្ខុរូប នេះ ។

បទថា កិញ្ចាបិ (បើទុកជា) ជាដើម ជាការពោលសរសើរ និង ការទិតៀន ។ ដោយពាក្យនោះ លោកសរសើរការនៅព្រៃជាវត្ត ( និង ) ទិតៀនការមិនលះបង់បាបអកុសលដែលជាឥច្ឆាវចរៈមិនបាន ។

ក្នុងសេចក្តីនោះ មានការប្រកបសេចក្តីដូច្នេះថា ភិក្ខុនោះដល់សូម្បីថា នឹងហាមសេនាសៈចុងភូមិ នៅព្រៃជាប្រចាំ នៅក្នុងសេនាសនៈដែលស្ងប់ត្រង់ជាយដែនក៏ពិត តែថា បាបអកុសលដែលជាឥច្ឆាវចរៈទាំងនេះ គឺ ប្រមាណ ប៉ុណ្ណេះ លោកមិនលះបង់ តែសូម្បីលោកនឹងបដិសេធភត្តទាំង ១៥ សមាទានបិណ្ឌបាតិកធុតង្គជាប្រចាំខ្លះ និង សមាទានចារិកធុតង្គបិណ្ឌបាតជាប្រក្រតីខ្លះ និង បដិសេធចីវរដែលអ្នកស្រុកថ្វាយបម្រើតែសំពត់បង្សុកូលជាប្រចាំខ្លះក៏ពិត ( តែលោកមិនលះបាបអកុសលដែលជាឥច្ឆាវចរៈទាំងនេះ ) ។

ចំណែកពាក្យថា សៅហ្មង ក្នុងពាក្យថា លូខចីវរធរោ ( គ្រងចីវរ

សៅហ្មង ) នេះ គប្បីជ្រាបថា សៅហ្មង ព្រោះហេតុ ៣ ប្រការ គឺ សៅហ្មងព្រោះសស្ត្រា ១ សៅហ្មងព្រោះអំបោះ ១ សៅហ្មងព្រោះជ្រលក់ ពណ៌ ១ ។

ក្នុងចំនួន ៣ យ៉ាងនេះ សំពត់កាត់ឱ្យដាច់ជាចំណែកតូច ៗ ដោយ សស្ត្រា ឈ្មោះថា សៅហ្មងព្រោះសស្ត្រា សំពត់នោះនឹងខូចតម្លៃ ។

សំពត់ដែលត្បាញដោយអំបោះគគ្រើម និង វែង ឈ្មោះថា សៅហ្មង ព្រោះអំបោះ សំពត់នោះសម្ផស្សមិនល្អ សម្ផស្សរឹង (រុំសាកសព) ។

សំពត់ដែលជ្រលក់ពណ៌ដោយពណ៌ជ្រលក់សំពត់ ( ទឹកចត់ ) ឈ្មោះថា សៅហ្មងព្រោះពណ៌ជ្រលក់ សំពត់នោះនឹងខូចពណ៌ មានពណ៌មិនស្អាត ។

ដល់ភិក្ខុនោះនឹងគ្រងចីវរសៅហ្មងព្រោះសាស្ត្រា សៅហ្មងព្រោះអំបោះ ឬ សៅហ្មងព្រោះពណ៌ជ្រលក់ក៏ពិត ។ តែថា អកុសលដែលជាឥច្ឆាវចរៈ ទាំងនេះ លោកមិនលះបង់ មនុស្សដែលឃើញ និង បានឮ ដោយច្បាស់ ពិតប្រាកដ ហើយអ្នកប្រព្រឹត្តព្រហ្មចរិយៈជាមួយគ្នា ដែលជាបញ្ញាជន (វិញ្ញូ ) នឹងមិនសក្ការៈបូជាលោកទេឡើយ ។

ពាក្យថា តំ ក្នុងពាក្យថា តំ កិស្ស ហេតុ នេះ ត្រឹមតែជានិបាត ។

ពាក្យថា កិស្ស ហេតុ គឺ កឹការណា ប្រែថា ព្រោះហេតុអ្វី ?

មានពាក្យអធិប្បាយទុកថា ព្រោះថា អំពើទាំងនោះរបស់លោក ដែលបាន ឃើញច្បាស់ និង បានឮច្បាស់ផង គឺ ព្រោះអកុសលធម៌ដ៏លាមកទាំងនោះ របស់លោកដែលបានឃើញច្បាស់ផង និង បានឮច្បាស់ផង ។ ព្រោះអកុ-សលធម៌ទាំងនេះដែលជាឥច្ឆាវចរៈ លោកលះបង់មិនទាន់បាន ដែលពោល មកនេះ ជាពាក្យអធិប្បាយថា ព្រោះហេតុអ្វីនេះ ។

តទៅនេះ ព្រះសារីបុត្ត កាលនឹងអធិប្បាយសេចក្តីនោះឱ្យប្រាកដ (ឱ្យច្បាស់) ដោយសេចក្តីឧបមាទើបបានពោលពាក្យមានជាអាទិថា សេ- យ្យថាបិ (ស្ងួម្បីយ៉ាងណា) ។ បណ្តាបទទាំងនោះ បទថា កុណបំ (សាកសព) បានដល់ សាកសពរបស់សត្វដែលស្លាប់ហើយ សាកសព- របស់ពស់ ឈ្មោះថា សាកសពពស់ ។ (សាកសពរបស់សុនខ និង របស់ អមនុស្ស) ក្រៅអំពីនេះក៏ដូចគ្នា ។ ហើយសាកសពទាំង ៣ នេះ នោះឯង គប្បីជ្រាបថា ព្រះសារីបុត្ត ពោលទុកហើយក្នុងពាក្យឧបមានេះ ព្រោះភាព ជារបស់បដិក្កូល និង គួរខ្ពើមហួសប្រមាណ ។ សេចក្តីពិត សាកសពរបស់ សត្វដទៃមានសត្វចិញ្ចឹម និង ជ្រូកជាដើម មនុស្សទាំងទឡាយផ្សំជាមួយគ្រឿង ទេសជាដើម ( គ្រឿងសម្ល ) ទទួលទានក៏មាន ។ ប៉ុន្តែសាកសពរបស់ សុនខ និង អមនុស្សទាំងនេះ ស្ងួម្បីនឹងនៅថ្មី មនុស្សទាំងទឡាយក៏នៅរង្គាស

នឹងពោលទៅថ្មីដល់សាកសពដែលកន្លងវេលាទៅហើយ ដែលរលួយហើយ មិនត្រូវនិយាយដល់ ។

បទថា រចយិត្វា ( ដាក់ទុក) គឺ ដាក់ចូលទៅ សំដៅសេចក្ដីថា ដាក់ឱ្យពេញ ។ មានពាក្យអធិប្បាយថា គេយកសាកសពនោះដាក់ពេញក្នុង ភាជន៍សំរឹទ្ធិ ។

បទថា អញ្ញិស្សំ ប្រែថា ( ដោយភាជន៍សំរឹទ្ធិដទៃ ) ។

បទថា បដិកុជ្ជិត្វា ( គ្រប ) គឺ បិទ ។

បទថា អន្តរាបណំ ( ចន្លោះផ្សារ ) គឺ មាត់ច្រកដែលមានមហាជនកុះករក្នុងទីផ្សារ ។

បទថា បដិបជ្ជេយ្យុំ ( គប្បីដំណើរទៅ) គឺ ហើយដើរទៅ ។

បទថា ជញ្ញជញ្ញំ វិយ (ហាក់ដូចជាទីពេញចិត្ត ) សេចក្ដីថា ហាក់ដូចជាក្រៃលែង គឺ ហាក់ដូចជាទីពេញចិត្តក្រៃលែង ។ ដូចនឹងគួរពេញចិត្ត ពេញថ្លើម ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ហាក់ដូចជាស្រីក្រមុំនាំគ្រឿង បណ្ណាការមក ។ សេចក្ដពិត ស្រីក្រមុំ គេហៅថា ស្ត្រី ។ បណ្ណាការដែលស្រីក្រមុំនោះកំពុងនាំមកជារបស់ដែលគួរឱ្យពេញចិត្តក្រៃលែង លោកទើបបានពោលដដែលទុកក្នុងពាក្យទាំងគូដោយអំណាចនៃការអើពើខ្លះ ដោយអំណាច

នៃការសរសើរខ្លះ ។ បាឋៈថា ជញ្ញំ ជញ្ញំ វិយ ដូច្នេះក៏មាន ។

បទថា អបាបុរិត្វា ( មិនបិទ) គឺ បើក ។

សេចក្តីថា តស្ស សហ ទស្សនេន អមនាបតា ច សណ្ឋ- ហេយ្យ( ការដែលគេមិនពេញចិត្តព្រមនឹងការបានឃើញក៏តាំងទេឡើង) សេចក្តីថា ការដែលមនុស្សនោះមិនពេញចិត្ត ព្រមនឹងការបានឃើញសាកសព នោះនុ៎ះឯង ក៏តាំងទេឡើង ។ ក៏ពាក្យថា អមនាបតា ភាពជារបស់មិនគួរ ពេញចិត្តនេះ ជាឈ្មោះរបស់ចិត្ត និង ចេតសិកដែលកើតទេឡើងហើយថា នេះ ជារបស់ដែលមិនគួរពេញចិត្ត ។

ក្នុងភាពបដិក្កូល និង គួររង្កៀស ក៏មានន័យនេះ ។

ពាក្យថា ជិឃច្ឆិតានម្បិ ( សូម្បីអ្នកហេវហើយ) គឺ សូម្បីអ្នកស្រេក ឃ្លានហើយ ។

សេចក្តីថា ន ភោត្តុកម្យតា អស្ស (សេចក្តីត្រូវការនឹងបរិភោគ គង់មិនមាន) សេចក្តីថា សេចក្តីប្រាថ្នានឹងបរិភោគគង់មិនមាន ។

ក្នុងពាក្យថា បគេវ សហិតានំ ( នឹងចាំបាច់ពោលទៅថ្វីដល់អ្នក បរិភោគឆ្អែតហើយ) មានពាក្យអធិប្បាយថា ប៉ុន្តែសម្រាប់មនុស្សដែល ស្រេកឃ្លាន ក៏គង់មិនមានចំណង់បរិភោគទេឡើយ ។ ក្នុងរឿងនោះ មានការ

ប្រៀបធៀបសេចក្តីឧបមាដូចតទៅនេះ ( គឺ ) ភេទបព្វជ្ជារបស់បុគ្គលនេះ ប្រៀបដូចភាជន៍សំរឹទ្ធិដ៏ស្អាត ការលះឥច្ឆាវចរៈនៅមិនទាន់បាន ប្រៀបដូចការដាក់សាកសព ការបិទបាំងឥច្ឆាវចរៈទុកដោយការនៅព្រៃជាប្រចាំជាដើម ប្រៀបដូចការយកភាជន៍សំរឹទ្ធិដទៃគ្របទុក , ការមិនធ្វើសក្ការៈជាដើម របស់មិត្រព្រហ្មចារីទាំងឡាយ ព្រោះឃើញឥច្ឆាវចរៈ ( របស់លោក ) ដោយមិនអើពើដល់ធុតង្គ មានអរញ្ញិកង្គជាដើម ប្រៀបដូចការមិនពេញចិត្តរបស់មនុស្ស ព្រោះបើកភាជន៍សំរឹទ្ធិហើយ ឃើញសាកសព ។

ចំណែកក្នុងធមិស គប្បីជ្រាបអត្ថាធិប្បាយ ដូចតទៅនេះ ។

ពាក្យថា កិញ្ចាបិ ជាដើម ទាំងជាពាក្យលើកទឹកចិត្ត ទាំងជាពាក្យ សរសើរ ។ ដោយពាក្យថា កិញ្ចាបិ នោះ ព្រះសារីបុត្តសរសើរការនៅ ព្រៃជាប្រចាំ សរសើរការលះឥច្ឆាវចរៈ ។

បទថា នេមន្តិកោ (អ្នកទទួលនិមន្ត) គឺ បដិគាហកៈអ្នកទទួលនិមន្ត។

បទថា វិចិតកាឡកំ (សស្អាត) គឺ ប្រាសចាកពណ៌ខ្មៅ ។

ក្នុងពាក្យថា មានសម្ល និង ម្ហូបក្រៀមច្រើនមុខច្រើនយ៉ាង ម្ហូបនេះ វត្ថុដែលនាំទៅបានដោយដៃហៅថា « ស្ងូប » ( សម្ល ) ពាក្យថា សម្ល គឺ សម្លកគូរ ។ ដោយពាក្យទាំង ២ នោះ លោកបានពោលពាក្យអធិប្បាយ

ទុកថា សម្លច្រើនយ៉ាងមានសម្ល គឺ ត្រី សាច់ និង សណ្តែកខៀវជាដើម ម្ហូបក្រៀមច្រើនបែប មានម្ហូបក្រៀមសាច់ជាដើម ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយនោះចុះ ។ ហើយគួរជ្រាបអត្ថាធិប្បាយ ក្នុងការប្រៀបធៀបពាក្យឧបមេយ្យ និង ពាក្យឧបមា ( តទៅ ) ការលះឥច្ឆាវចរៈ បាន ដូចការចាត់ចែងបាយស្រូវសាលីដាក់ពេញក្នុងភាជន៍សំរិទ្ធ ការបិទ គឺ ការលះឥច្ឆាវចរៈដោយការនៅវត្តជាយភូមិជាដើម ដែលជាសមុដ្ឋាននៃសេចក្តីប្រាថ្នាតិច ដូចការគ្របដោយភាជន៍សំរិទ្ធដទៃ គួរជ្រាបការធ្វើសក្ការៈជាដើមរបស់មិត្តព្រហ្មចារី ព្រោះមិនត្រេកអរនឹងការនៅវត្តខាងក្នុងស្រុកជាដើម ហើយលះឥច្ឆាវចរៈបាន ដូចការពេញចិត្តរបស់មនុស្ស ព្រោះបានបើកភាជន៍សំរិទ្ធ ឃើញបាយស្រូវសាលីដាំយ៉ាងល្អ ។

សេចក្តីថា ឧបមា មំ អាវុសោ សារីបុត្ត បដិភាតិ ( បពិត្រព្រះសារីបុត្តឧបមាជាក់ច្បាស់ដល់ខ្ញុំ ) សេចក្តីថា បពិត្រព្រះសារីបុត្ត ឧបមាប្រាកដដល់ខ្ញុំ មានអធិប្បាយថា ខ្ញុំប្រាថ្នានឹងពោលឧបមាមួយខ ( ថ្វាយ ) ។

បទថា បដិភាតុ តំ ( ចូរជាក់ច្បាស់ដល់លោកចុះ ) គឺ ចូរជាក់ ច្បាស់បានដល់ ប្រាកដដល់លោកចុះ អធិប្បាយថា និមន្តពោលចុះ ។

ពាក្យថា ឥទ ក្នុងពាក្យថា ឯកមិទាហំ ត្រឹមតែជានិបាត ។

មានពាក្យអធិប្បាយទុកថា សម័យមួយខ្ញុំ ។

ពាក្យថា ឯកំ នេះ ជាទុតិយាវិភត្ត ។ ប្រើក្នុងអត្ថនៃសត្តមីវិភត្ត ។

បទថា រាជគ្រឹះ ក្នុងពាក្យថា រាជគហេ វិហរាមិ គិរិព្វជេ នេះ ជាឈ្មោះរបស់នគរនោះ ។ នគររាជគ្រឹះ មនុស្សហៅថា គិរិពជ ព្រោះតាំងនៅដូចក្រោល ដោយមានភ្នំព័ទ្ធជុំវិញ ។ ព្រះមោគ្គល្លានពោលទុកថា ខ្ញុំនៅក្នុងនគរនោះ គឺ អាស្រ័យនៅនគរនោះ ។

បទថា អថខ្វាហំ កាត់បទជា អថខោ អហំ ( ប្រែថា គ្រានោះ ឯង ខ្ញុំ )។ និងពាក្យថា អថ ក្នុងពាក្យថា អថខ្វាហំ នេះ ជានិបាត ប្រើក្នុងពាក្យផ្ដើម និងនិយាយរឿងដទៃៗ ។ ស័ព្ទថា ខោ ក៏ជានិបាត ប្រើក្នុងសេចក្ដីត្រឹមតែធ្វើបទឱ្យពេញ ។

បទថា បុព្វណ្ហសមយំ ( ក្នុងបុព្វណ្ហសម័យ ) មានអធិប្បាយថា វេលាចំណែកខាងដើមនៃថ្ងៃ គឺ ក្នុងចំណែកព្រឹក ។

ម្យ៉ាងទៀត ពេលដំបូងនៃថ្ងៃ ឈ្មោះថា បុព្វណ្ហសម័យ មានពាក្យអធិប្បាយថា មួយជួរខណៈក្នុងពេលព្រឹក ។ ដោយអាការយ៉ាងនេះ នឹងបានទុតិយាវិភត្តិក្នុងអច្ចន្តសំយោគ ។

បទថា និវាសេត្វា ( ស្លៀកហើយ ) គឺ គ្រងសំពត់ហើយ ពាក្យថា

ស្លៀកហើយនោះ គប្បីជ្រាបដោយអំណាចនៃការផ្លាស់ប្ដូរសំពត់ស្លៀកក្នុងវត្ត នោះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបដោយអំណាចនៃការឈរស្លៀក ដើម្បី ត្រូវការនឹងចូលភូមិ មិនមែនថា មុននេះលោកមិនបានស្លៀកទេឡើយ ។

បទថា បត្តចីវរមាទាយ ( ប្រដាប់ដោយបាត្រនិងចីវរ ) សេចក្ដីថា ដៃកាន់បាត្រ រាងកាយគ្រងចីវរ ។

បទថា បិណ្ឌាយ (ដើម្បីបិណ្ឌបាត) សេចក្ដីថា ដើម្បីត្រូវការ បិណ្ឌបាត ។

បទថា សមីតិ ជាឈ្មោះបុត្ដរបស់ជាងរថម្នាក់ ។

បទថា យានការបុត្តោ ( បុត្ដរបស់ជាងយាន ) គឺ កូនរបស់ជាង រថ ។

បទថា បណ្ឌុបុត្តោ (បណ្ឌុបុត្ត)បានដល់កូនរបស់អ្នកបួស ត្រងោល ។

បទថា អាជីវកោ បានដល់ អ្នកបួសស្រាត ។

បទថា បរាណយានការបុត្តោ ( បុត្តរបស់ជាងរថជាន់ចាស់ ) បានដល់ កូនរបស់ត្រកូលជាងរថជាន់ចាស់ ។

បទថា បច្ចុបដ្ឋិតោ ( ប្រាកដខ្លួន ) គឺ ចូលទៅឈរជិត ( ឱ្យ

ឃើញ) ។ កោងម្ខាងឈ្មោះ ង ។ វៀច ដូចផ្លូវពស់លូន (គន្លងពស់) ។

បទថា ទោសំ (ទោស ) បានដល់ ឈើដែលជាប់ស្រោយ និង មានពករដិបរដុបជាដើម ។

បទថា យថា យថា ជានិបាតប្រើក្នុងសេចក្ដីបញ្ជាក់ដល់កាលវេលា មានពាក្យអធិប្បាយថា កាលណា ៗ គឺ ក្នុងកាលណា ៗ ។

បទថា តថា តថា នេះ ក៏មានសេចក្ដីបញ្ជាក់ដល់កាលដូចគ្នា ។ មានពាក្យអធិប្បាយទុកថា ក្នុងកាលនោះ ៗ ។ អាជីវកនោះ គិតដោយអនុលោមតាមដែលបានសិក្សាមកអំពីមនុស្សម្នាក់ទៀត ( នាយសមីតិ ) ចាំងត្រង់កន្លែងដែលអាជីវកគិតនោះឯង ក្នុងខណៈដែលគេគិត ។

បទថា អត្តមនោ ( ពេញចិត្ត ) គឺ ត្រូវចិត្តខ្លួន បានដល់ សប្បាយ ចិត្ត សេចក្ដីថា មានបីតិ និង សោមនស្សចាប់ចិត្ត ។

បទថា អត្តមនវាចំ និច្ឆារេសិ ( បន្លឺវាចាសម្ដែងសេចក្ដីពេញចិត្ត ) គឺ បន្លឺ បានដល់ ពោល អធិប្បាយថា បញ្ចេញវាចាដោយសេចក្ដីពេញចិត្ត ឬ វាចាដែលគួរដល់សេចក្ដីសប្បាយចិត្ត ។

សេចក្ដីថា ហទយា ហទយំ បញ្ញេ អញ្ញាយ (ដូចដឹងចិត្ត ដោយចិត្ត) សេចក្ដីថា ដូចជាដឹងចិត្ត (យើង) ដោយចិត្ត ( គេ) ។

បទថា អស្សទ្ធា ( មិនមានសទ្ធា) គឺ ប្រាសចាកការជឿក្នុងព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ។

បទថា ជីវិកត្ថា ( ជាអ្នកត្រូវការចិញ្ចឹមជីវិត) គឺ ត្រូវភ័យ មាន បំណុលជាដើម បៀតបៀន មិនអាចចេញរកស៊ីខាងក្រៅបាន ទើបត្រូវការ ចិញ្ចឹមជីវិតក្នុងសាសនានេះ ។

បទថា ន សទ្ធា (មិនមានសទ្ធា) គឺ មិនបានបួសដោយសទ្ធា ។

បទថា សឋា មាយាវិនោ ( ជាមនុស្សអួតអាងមានមាយា ) គឺ ប្រកបដោយមាយាសាថេយ្យ (មនុស្សមានមាយា ច្រើនអួតអាង) ។

បទថា កេដ្ឋភិនោ ( អ្នកបោកប្រាស ) គឺ អ្នកបានសិក្សាកលល្បិច មកហើយ មានពាក្យអធិប្បាយថា អ្នកសម្រេចការអួតអាងតាមកម្លាំង ។ អធិប្បាយថា ការអួតអាង គេហៅថា កេរាដិយ ( កលល្បិច ) ព្រោះធ្វើព្រមគ្នានឹងការសម្ដែងគុណមិនពិត ដោយការសម្ដែងគុណវិសេសដែលមិនមាន ពិត ។

បទថា ឧន្នទឡ្ហា (ប្រកាន់ខ្លួន) គឺ លើកខ្លួនទេឡើង មានពាក្យអធិ_ ប្បាយថា លើកមានៈទទេទេឡើង ។

បទថា ចបលា ( ឃ្លេងឃ្លោង ) គឺ ប្រកបដោយការក្រវល់ក្រវាយ

មានការតុបតែងបាត្រ និង ចីវរជាដើម ។

បទថា មុខរា ( មានមាត់រឹង ) គឺ មាត់រឹង មានអធិប្បាយថា មានពាក្យនិយាយចចេស ។

បទថា វិកិណ្ណវាចា ( មានសំដីផ្តេសផ្តាស) គឺ មានការនិយាយ មិនសង្រួមបានដល់ ការនិយាយគ្នាអស់ថ្ងៃ ក៏មានតែពាក្យឥតប្រយោជន៍ ។

បទថាឥន្ទ្រិយេសុ អគុត្តទ្វារា ( មានទ្វារមិនបានឃុំគ្រងក្នុងឥន្ទ្រីយ៍ ទាំងទឡាយ )គឺមានទ្វារសម្រាប់ធ្វើកម្មមិនបានរវាំងប្រយ័ត្នក្នុងឥន្ទ្រីយ៍ ទាំង ៦ ។

បទថា ភោជនេ អមត្តញ្ញុនោ ( មិនស្គាល់ប្រមាណក្នុងការ បរិភោគ) គឺ មិនស្គាល់ប្រមាណក្នុងការបរិភោគ ដែលល្មមឱ្យរាងកាយ ប្រព្រឹត្តទៅបាន គឺ ភាពជាអ្នកមានការស្គាល់ប្រមាណក្នុងការបរិភោគដែល គួរដឹង ។

បទថា ជគរិយំ អននុយុត្តា (មិនប្រកបដោយសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រលឹក)គឺមិនប្រកបដោយសេចក្តីព្យាយាមដែលធ្វើឱ្យភ្ញាក់រលឹក ខ្លួន ។

បទថា សាមញ្ញោ អនបេក្ខវន្តោ (មិនប្រាថ្នាសមណភាវៈ) មានអត្ថា_

ធិប្បាយថា ក្រទេឡកមើលសមណធម៌ គឺ វៀរចាកការបដិបត្តិធម៌សមគួរដល់ ធម៌ ។

បទថា សិក្ខាយ ន តិព្វគារវា ( មិនគោរពយ៉ាងខ្លាំងក្នុងសិក្ខា ) គឺ មិនមានសេចក្តីគោរពក្នុងសិក្ខាបទទាំងទឡាយ បានដល់ ការច្រើនទៅដោយការត្រូវអាបត្តិ ។

បទថា ពាហុល្លិកា ( ជាប់ជំពាក់ក្នុងបច្ច័យច្រើន ) ជាដើម ខ្ញុំម្ចាស់បានពោលទុកហើយក្នុង (អដ្ឋកថា) ធម្មទាយាទសូត្រ ។

បទថា កុសីតា ( អ្នកខ្ជិលច្រអូស ) ជាដើម ខ្ញុំម្ចាស់ពោលទុកហើយ ក្នុង ( អដ្ឋកថា) ភយភេរវសូត្រ ។

បទថា ធម្មបរិយាយេន ( ដោយបរិយាយ ) គឺ ដោយធម្មទេសនា ។

បទថា សទ្ធា អគារស្មា ( ចេញចាកផ្ទះបួសដោយសទ្ធា) ជាដើម មានន័យថា តាមប្រក្រតីហើយ អ្នកបួសដោយសទ្ធា ឈ្មោះថា អ្នកមានសទ្ធា ចេញចាកផ្ទះបួសជាអនាគារិយបុគ្គល ( អ្នកមិនមានផ្ទះសម្បែង) ។

សេចក្តីថា បិវន្តិ មញ្ញេ ឃសន្តិ មញ្ញេ ( គង់នឹងផឹក គង់នឹង បរិភោគ ) មានន័យថា ហាក់ដូចបានផឹក ហាក់ដូចលេប គឺ កាលបន្លឺវាចាដោយសេចក្តីពេញចិត្ត ក៏ដូចជាផឹកដោយវាចា កាលអនុមោទនាដ៏ក្រៃលែង

ទៀង ក៏ដូចជាបរិភោគដោយចិត្ត ។

បទថា សាធុ វត ( សាធុទាន) គឺ ប្រពៃហើយទាន ។

បទថា សព្រហ្មចារី ជារស្មេះក៏បាន ជាទីយះក៏បាន កាលបើរស្មេះខាងមុខនឹងមាន សារីបុត្ត កាលបើទីយះខាងមុខនឹងមាន សព្រហ្មចារី កាលណាខាងមុខមាន សារីបុត្ត កាលនោះនឹងមានសេចក្តីថា ម្នាលមិត្តព្រហ្មចារី ព្រះសារីបុត្ត ឱ្យយើងទាំងទឡាយឱ្យចេញចាកអកុសលហើយ ។ កាលណាមាន សព្រហ្មចារី នៅខាងមុខ កាលនោះនឹងមានខ្លឹមសារថា ព្រះសារីបុត្ត ឱ្យមិត្តសព្រហ្មចារីទាំងទឡាយចេញចាកអកុសលហើយ ( ឱ្យតាំងនៅក្នុងកុសល) ។

បទថា ទហរោ គឺ នូវកម្លាំង ។

បទថា យុវា គឺ នៅក្នុងវ័យកំលោះ_ក្រមុំ ។

បទថា មណ្ឌនកជាតិកោ ( ពេញចិត្តតុបតែងខ្លួន ) សេចក្តីថា មានសភាពពេញចិត្តតុបតែងខ្លួន ( ប្រក្រតីពេញចិត្តតុបតែងខ្លួន) ។

បណ្តាមនុស្សទាំង ២ ប្រភេទនោះ មនុស្សខ្លះសូម្បីនៅជំទង់ ប៉ុន្តែនៅមិនទាន់កំលោះក្រមុំ ដូចកំលោះក្រមុំ ។ ប៉ុន្តែមនុស្សខ្លះ សូម្បីកំលោះក្រមុំក៏មិនពេញចិត្តតាក់តែងខ្លួន ដូចអ្នកដែលមានសេចក្តីស្ងប់ជាសភាព ឬ ត្រូវសេចក្តីខ្ពិលច្រអូស ឬ សេចក្តីវិនាសគ្រប់សង្កត់ ចំណែកក្នុងទីនេះ ប្រាថ្នាយក

មនុស្សទាំងនៅជំទង់ ទាំងនៅកំលោះក្រមុំនឹងពេញចិត្តតុបតែងខ្លួន ។ ព្រោះ ដូច្នោះ ព្រះមហាមោគ្គល្លាន ទើបពោលទុកយ៉ាងនេះ ។ ពាក្យថា ប្រកាន់ ខ្លួន ជាដើម លោកពោលទុកព្រោះជាសម្មតិរបស់លោក ។

បទថា ឥតិហ តេ ស្មើនឹង ឯវំ តេ ( ប្រែថា ដោយប្រការដូចដែលពោលមកហើយនោះ លោកទាំងពីរនោះ) ។

បទថា ឧភោ មហានាគា ( មហានាគទាំងគូ) សំដៅដល់អគ្គសាវ៉ក ទាំង ២ អង្គ ។ ព្រោះអគ្គសាវ៉កទាំង ២ អង្គនេះ ពុទ្ធបរិស័ទទាំងទឡាយ ហៅថា មហានាគ ។

ក្នុងពាក្យថា មហានាគ នោះ មានអត្ថវចនៈ ដូចតទៅនេះ ÷

អ្នកមិនលំអៀងដោយអគតិទាំងទឡាយ មានឆន្ទាគតិជាដើមឈ្មោះថា នាគ ។

អ្នកមិនត្រទឡប់មកកាន់កិលេសដែលលះបានដោយមគ្គនោះៗ ហើយ ឈ្មោះថា នាគ ។

អ្នកមិនធ្វើបាប ( សេចក្ដីអាក្រក់ដែលជាហេតុឱ្យត្រទឡប់មក ) មាន ប្រការផ្សេងៗ ឈ្មោះថា នាគ ។

នេះជាសេចក្ដីសង្ខេបក្នុងពាក្យថា នាគ ។ ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបតាមន័យដែលបានពោលទុកក្នុងមហានិទ្ទេសនោះចុះ ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីក្នុងកថានេះ យ៉ាងនេះថា ÷

អ្នកមិនធ្វើបាបអ្វីទុកទេឡើយក្នុងលោក ជម្រះកិលេសគ្រឿង
ប្រកបសត្វទុកក្នុងភពគ្រប់យ៉ាង និង គ្រឿងចងទាំងទឡ្បាយ
បាន មិនជាប់នៅក្នុងភពទាំងពួង ជាអ្នករួចផុតហើយ
ជាអ្នកនឹងធឹង លោកហៅ នាគ ព្រោះភាពជាយ៉ាង
នោះ ។

នាគធំ ឈ្មោះមហានាគ ។ អធិប្បាយថា មហានាគនោះ គួរបូជា ជាង នឹងគួរសរសើរជាង នាគដែលជាខីណាស្រពពួកដទៃ ។

បទថា អញ្ញមញ្ញស្ស ( នៃគ្នានឹងគ្នា ) សេចក្តីថា មួយអង្គសរសើរ មួយអង្គទៀត ។

បទថា សមនុមោទឹសុ (អនុមោទនាព្រម) កាត់បទជា សមំ អនុមោទឹសុ ប្រែថា អនុមោទនាស្មើ ៗ គ្នា ។ ក្នុងពាក្យអនុមោទនានោះ ព្រះធម្មសេនាបតី ពោលថា ព្រះមហាមោគ្គលាន អនុមោទនាដោយ ឧបមានេះថា លោកម្ចាស់ សេចក្តីនោះចូរជាក់ច្បាស់ ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រះថេរៈទាំង ២ អនុមោទនាពាក្យសុភាសិតរបស់គ្នា
នឹងគ្នា ។

**( ចប់ អដ្ឋកថាអនង្គណសូត្រ ទី ៥ )**

# អ ដ្ឋ ក ថា
# អាកង្ខេយ្យសូត្រ ទី ៦

អាកង្ខេយ្យសូត្រមានពាក្យផ្តើមទេឡើងថា **ឯវម្មេ សុតំ** ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្បន្នសីលា** សេចក្តីថា ការដល់ព្រម មាន ៣ យ៉ាង ការបរិបូរណ៍ ការព្រមព្រៀង និង ការផ្តេម ។

## ការដល់ព្រម ៣ យ៉ាង

បណ្តាការដល់ព្រមទាំង ៣ យ៉ាង ការដល់ព្រមដែលមកហើយថា ÷

ម្នាលកោសិយៈ សត្វសេកទាំងទឡាយ រមែងបរិភោគក្តួរស្រូវសាលីដែលសំបូរហើយ ម្នាលព្រាហ្មណ៍ យើងសូមប្រាប់លោកថា យើងមិនអាចហាមសេកនោះបាន ដូច្នេះ នេះឈ្មោះថា ការដល់ព្រម គឺ ការបរិបូរណ៍ ។

ការដល់ព្រមនេះថា ភិក្ខុជាអ្នកចូលដល់ហើយ ចូលដល់ព្រមហើយ ចូលទៅជិតហើយ ចូលទៅជិតព្រមហើយ ចូលដល់ហើយ សម្បូរហើយ ប្រកបហើយដោយបាតិមោក្ខសំវរៈនោះ ដូច្នេះ ឈ្មោះថា ការដល់ព្រម គឺ ការព្រមព្រៀង ។

ការដល់ព្រមនេះថា ម្នាលលោកដ៏ចម្រើន ផ្ទៃទាបបំផុតនៃមហាប្រឹថពី មានរសផ្អែមគួរឱ្យពេញចិត្ត ដូចទឹកឃ្មុំដែលមិនមានទោស ដូច្នោះ ដូច្នេះ ឈ្មោះថា ការដល់ព្រមគឺការផ្អែម ។

តែក្នុងសូត្រនេះគួរបានដល់ការដល់ព្រម គឺ ការបរិបូរណ៍ខ្លះ ការដល់ ព្រម គឺ សេចក្តីព្រមព្រៀងគ្នាខ្លះ ព្រោះដូច្នោះ ក្នុងបទថា សម្បន្នសីលា គប្បីជ្រាបសេចក្តីយ៉ាងនេះថា ÷

បទថា សម្បន្នសីលា សេចក្តីថា ជាអ្នកមានសីលបរិបូរណ៍ ដូច្នេះខ្លះ ជាអ្នកដល់ព្រមដោយសីល ដូច្នេះខ្លះ ។

## អត្ថរបស់សីល

បទថា សីលំ សេចក្តីថា ដែលឈ្មោះថា សីល ព្រោះអត្ថថាដូចម្តេច ? ដែលឈ្មោះថា សីល ព្រោះអត្ថថា ជាទីតាំងមាំ ។ សេចក្តីពិស្តារនៃបទថា សីលនោះ បានពោលទុកហើយក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ ។ សូម្បីក្នុង បករណ៍ពិសេសឈ្មោះ វិសុទ្ធិមគ្គនោះ ដោយអត្ថនេះថា បរិបុណ្ណសីលា នេះ ជាការដែលបានពោលភាពបរិបូរណ៍នៃសីលទុកហើយ ព្រោះប្រាសចាក ទោសរបស់សីល ដូចលោកពោលភាពបរិបូរណ៍នៃស្រែទុក ព្រោះប្រាសចាក ទោសរបស់ស្រែដូច្នោះ ។

## ទោសរបស់ស្រែមាន ៤ យ៉ាង

ដូចយ៉ាងថា ស្រែដែលប្រកបដោយទោស ៤ យ៉ាង គឺ ពូជមិនល្អ ១ ការសាបព្រោះមិនល្អ ១ ទឹកមិនល្អ ១ ទីដីមិនល្អ ១ រមែងធ្វើឱ្យស្រែមិនបរិបូរបាន ។

បណ្ដាទោស ៤ យ៉ាងនោះ ពូជដែលមិនពេញគ្រាប់ ឬ ស្អុយក្នុងចន្លោះ ណា ៗ មាននៅក្នុងស្រែណា ស្រែនោះឈ្មោះថា ស្រែមានពូជមិនល្អ ។

ជនទាំងទឡាយសាបពូជទាំងនោះ ចុះក្នុងស្រែណា , សំណាបរមែងមិនដុះទេឡើងក្នុងស្រែនោះ ស្រែក៏ចាត់ថា ជាស្រែដែលមិនល្អ ។

អ្នកស្រែដែលមិនឆ្លាត កាលសាបពូជ រមែងសាបឱ្យធ្លាក់ទៅជាល្បោះ ៗ ក្នុងស្រែណា ស្រែនោះឈ្មោះថា មានការសាបពួជមិនល្អ ។ ព្រោះកាលសាបពួជយ៉ាងនេះ សំណាបរមែងមិនដុះលូតលាស់ទេឡើងទូទៅគ្រប់កន្លែង ស្រែក៏ចាត់ថាជាស្រែមិនល្អ ។

ក្នុងស្រែកន្លែងខ្លះ មានទឹកច្រើនពេកទៅ ឬ មិនមានសោះ ស្រែនោះ ឈ្មោះថា ខ្វះទឹក ព្រោះថា សំណាបមិនដុះទេឡើងសូម្បីក្នុងស្រែនោះ ស្រែក៏ចាត់ ថា ជាស្រែមិនល្អ ។ ក្នុងផ្ទៃដីខ្លះ អ្នកស្រែយកនង្គ័លភ្ជួរផ្ទៃដីដល់ ៤ _ ៥ លើក ឱ្យផ្ទៃដីជ្រៅពេកទៅ តពីនោះដីនឹងកើតមានរសប្រៃ ស្រែនោះឈ្មោះថា មាន

ផ្ទៃដីមិនល្អ ។ ព្រោះថា ក្នុងស្រែដែលមិនល្អនោះ សំណាបរមែងមិនលូតលាស់ ទឡើង ស្រែក៏ចាត់ថាជាស្រែមិនល្អ ។ ហើយស្រែដូច្នោះ នឹងមិនមានផល ច្រើន ព្រោះថា សូម្បីក្នុងស្រែនោះនឹងសាបព្ធជចុះទៅច្រើនក៏បានទទួល ផលតិច ។

តែថា ស្រែដែលចាត់ថា ជាស្រែបរិបូរ ព្រោះប្រាសចាកទោស ៤ យ៉ាងនេះ ។ ហើយស្រែដូច្នោះ ចាត់ជាស្រែដែលមានផលច្រើន យ៉ាងណា សីលដែលប្រកបដោយទោស ៤ យ៉ាង គឺ ដាច់ ធ្លុះ ពព្រុះ ពពាល នឹងចាត់ជាសីលដែលបរិសុទ្ធមិនបានដូច្នោះ ដូចគ្នា ។ ហើយសីលដូច្នោះ ជាសីលដែលមានផលតិច តែសីលនឹងចាត់ថាជាសីលដែលបរិបូណ៌បាន ក៏ព្រោះប្រាសចាកទោស ៤ យ៉ាងនេះ ។ ក៏សីលដូច្នោះចាត់ថាជាសីលដែល មានផលានិសង្សច្រើន ។

## សីលសម្បូរដោយហេតុ ២ ប្រការ

ក៏ដោយអត្ថនេះថា សីលសមង្គិនោ ជាការដែលព្រះមានព្រះភាគត្រាស់ អធិប្បាយទុកថា អ្នកទាំងទឡាយ ចូរជាអ្នកបរិបូណ៌ គឺ ជាអ្នកដល់ព្រម បានដល់ ប្រកបដោយសីលចុះ ដូច្នេះ ។

ក្នុងបទថា សម្បន្នសីលា នោះ ភាពជាអ្នកមានសីលបរិបូណ៌ រមែង

មានបានដោយហេតុពីរប្រការគឺ ព្រោះឃើញទោសក្នុងការវិបត្តិនៃសីល ១ ព្រោះឃើញអានិសង្សក្នុងការដល់ព្រមនៃសីល ១ ។

គុណជាតិទាំងពីរយ៉ាងនេះ លោកបានពោលពិស្តារហើយក្នុងបករណ៍វិសេស ឈ្មោះថា វិសុទ្ធិមគ្គ ។

ព្រះសុមនត្ថេរ អ្នកស្រុកទីបវិហារពោលទុកថា បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់លើកចតុប្បារិសុទ្ធិសីលទេឡើងសម្តែងដោយព្រះតម្រាស់ មានប្រមាណប៉ុណ្ណេះថា សម្បន្នសីលា ក្នុងបណ្តាបទទាំងនេះ ហើយទ្រង់សម្តែង សីលដែលជាប្រធានក្នុងបណ្តាសីលទាំងនោះ យ៉ាងពិស្តារដោយបទនេះថា បាតិមោក្ខសំវរ សំវុតា ដូច្នេះ ។

ចំណែកព្រះចូទឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ដែលជាអន្តេវាសិករបស់ព្រះសុមនត្ថេរនោះ ពោលថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់នូវបាតិ-មោក្ខសំវរសីលទុកក្នុងព្រះបាលី ២ កន្លែង បាតិមោក្ខសំវរៈប៉ុណ្ណោះ ឈ្មោះ ថាសីល ( តែអាគតដ្ឋាន ) ដែលពោលអះអាងទុកថា សីល ៣ យ៉ាង ក្រៅពីនេះជាសីលក៏មាន លោកកាលមិនឃើញ ទើបពោលជំទាស់ទុកហើយ ពោល ( តទៅ ) ថា គុណ ត្រឹមតែការរក្សាទ្វារ « ៦ » ក៏ឈ្មោះថា ឥន្ទ្រិយសំវរ គុណត្រឹមតែការបង្កើតទេឡើងនៃបច្ច័យដោយធមិដ៏ប្រពៃ ក៏ឈ្មោះថា អាជីវបារិសុទ្ធិ-

សីល គុណ ត្រឹមតែការពិចារណាបច្ច័យជាដើមដែលខ្លួនបានមកហើយ វត្ថុនេះ មាន ដូច្នេះហើយទើបបរិភោគក៏ឈ្មោះថា បច្ចយសន្និស្សិតសីល ។

តែពោលដោយត្រង់បាតិមោក្ខសំវរប៉ុណ្ណោះឈ្មោះថា សីល បាតិមោ-ក្ខសំវរសីលនោះរបស់អ្នកណាដាច់ហើយ អ្នកនោះ នរណាៗ « មិនគួរពោលថា អ្នកនេះនឹងរក្សាសីលដ៏សេសទុកបាន ដូច្នេះ , ប្រៀបដូចបុរសដែលមានក្បាល ដាច់ហើយក៏មិនអាចនឹងរក្សាដៃ និង ជើងទុកបានដូច្នោះ ។ តែថា បាតិមោក្ខ-សំវរសីលនេះរបស់អ្នកណា មិនពុះ មិនពពាល អ្នកនេះរមែងអាចរក្សាសីល ដ៏សេសឱ្យតាំងនៅតាមប្រក្រតីបាន ប្រៀបដូចបុរសដែលមានក្បាលមិនដាច់ក៏ អាចរក្សាជីវិតទុកបានដូច្នោះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ លើក បាតិមោក្ខសំវរសីលទេឡើងសម្ដែងដោយបទថា សម្បន្នសីលា ដូច្នេះ ហើយត្រាស់ពាក្យដែលជាវេវចនៈនៃពាក្យ សម្បន្នសីលា នោះថា សម្បន្ន-បាតិមោក្ខា ដូច្នេះ កាលនឹងទ្រង់សម្ដែងពាក្យដែលជាវេវចនៈនោះឱ្យពិស្តារ ទើបត្រាស់ពាក្យ ជាដើមថា បាតិមោក្ខសំវរសំវុតា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា បាតិមោក្ខសំវរសំវុតា សេចក្ដីថា ប្រកប ដោយបាតិមោក្ខសំវរសីល ។

បទថា អាចារគោចរសម្បន្នា សេចក្ដីថា មានអាចារ និង គោចរ

ដ៏បរិបូណ៌ ។

បទថា អនុមត្តេសុ ប្រែថា មានប្រមាណតិចតួច ។

បទថា វជ្ជេសុ គឺ ក្នុងធម៌ចំណែកអកុសលទាំងទឡាយ ។

បទថា ភយទស្សាវី ប្រែថា អ្នកមានប្រក្រតីឃើញភ័យ ។

បទថា សមាទាយ សេចក្ដីថា កាន់យកដោយល្អ ។

បទថា សិក្ខថ សិក្ខាបទេសុ សេចក្ដីថា ពួកអ្នកចូរសមាទានកាន់យកសិក្ខាបទនោះដោយល្អ ហើយសិក្សាចុះ ។

ម្យ៉ាងទៀត ក្នុងបទថា សមាទាយ សិក្ខថ សិក្ខាបទេសុ នេះមានសេចក្ដីសង្ខេបថា វត្ថុណានីមួយ មិនថា នឹងប្រព្រឹត្តទៅតាមផ្លូវកាយ ឬ វាចា ក៏ដោយដែលគួរសិក្សាក្នុងសិក្ខាបទ គឺ ក្នុងចំណែកនៃសិក្ខាបទ ពួកអ្នកចូរកាន់យកវត្ថុនោះទាំងអស់ដោយល្អ ហើយសិក្សាចុះ ។

ចំណែកបទទាំងទឡាយ មានបទថា បាតិមោក្ខសំវរា ជាដើមទាំងអស់ នោះបានពោលទុកហើយក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គយ៉ាងពិស្ដារ ។

## សេចក្ដីប្រាថ្នាទី ១

សួរថា ពាក្យថា អាកង្ខេយ្យ ចេ នេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកព្រោះហេតុអ្វី ?

ឆ្លើយថា ដើម្បីនឹងទ្រង់សម្តែងអានិសង្សរបស់សីល ។

ក៏ប្រសិនបើអ្នកបួសថ្មី ឬ អ្នកអប្បឥតបញ្ញា គប្បីមានការគិតយ៉ាងនេះ ថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ពួកអ្នកចូរបំពេញសីល ពួកអ្នក ចូរបំពេញសីល ដូច្នេះ អ្វីហ្ន៎ ជាអានិសង្ស អ្វីជាសេចក្តីវិសេស អ្វីជាការ ចម្រើនក្នុងការបំពេញសីល ដូច្នេះ ។ ដើម្បីនឹងទ្រង់សម្តែងអានិសង្ស ១៧ ប្រការ ដល់ភិក្ខុអ្នកបួសថ្មីជាដើមនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ យ៉ាងនេះ ។ ភិក្ខុទាំងទឡាយ បានស្តាប់អានិសង្សដែលមានភាពជាទីស្រទឡាញ់ ជាទីពេញចិត្តរបស់ពួកសព្រហ្មចារីទាំងទឡាយជាខាងដើម មានការអស់ទៅនៃអាសវៈជាទីបំផុតនោះ ហើយទើបបំពេញសីលឱ្យបរិបូណ៌ ដូចឈ្មួញស្លុរអំពៅ ដូច្នោះ ធម្មតាឈ្មួញស្លុរអំពៅលោកហៅថា អ្នកលក់ទឹកអំពៅ ។

តំណាលមកថា ឈ្មួញនោះយករទេះផ្ទុកស្លុរអំពៅ និង ស្លុរត្នោតជាដើម ទៅកាន់ជាយដែន ហើយឃោសនាថា ពួកលោកចូរទិញថ្នាំពិស និង បន្លា ពួកលោកចូរទិញថ្នាំពិស និង បន្លា ដូច្នេះ ពួកអ្នកស្រុកបានស្តាប់ពាក្យនោះ ក៏គិតថា ធម្មតាថ្នាំពិសជារបស់កាចសាហាវណាស់ អ្នកណាបានបរិភោគវាចូល ទៅ អ្នកនោះក៏នឹងត្រូវស្លាប់ សូម្បីបន្លាចាក់ហើយរមែងធ្វើឱ្យមនុស្សយើងស្លាប់ បាន វត្ថុទាំងពីរយ៉ាងនេះជារបស់កាចសាហាវណាស់ នឹងមានអានិសង្សអ្វីក្នុង

ការទិញនេះ ដូច្នេះហើយក៏បិទទ្វារផ្ទះ និង ដេញក្មេងឱ្យជៀសចេញទៅ ។ ឈ្មួញឃើញហេតុនោះ ទើបគិតថា អ្នកស្រុកទាំងនេះជាអ្នកមិនឆ្លាតក្នុងការទិញ លក់ណើ្ហយចុះ យើងនឹងប្រើឧបាយឱ្យអ្នកស្រុកទាំងនោះទិញ ដូច្នេះ ។ ទើប ស្រែកលក់ថា ពួកលោកចូរទិញរបស់ដែលផ្អែម ពួកលោកចូរទិញរបស់ល្អ លោកនឹងបានស្ករអំពៅ ស្ករត្នោត ដែលមានតម្លៃថ្លៃ ពួកលោកនឹងទិញបាន ដោយមាសកៈក្លែងក្លាយ និង កហាបណៈក្លែងក្លាយ ដែលមានតម្លៃថោក ៗ ដូច្នេះ ។ ពួកអ្នកស្រុកបានស្តាប់ពាក្យនោះ ម្នាក់ ៗ រីករាយត្រេកអរ នាំគ្នា ទៅឱ្យតម្លៃសូម្បីថ្លៃ ក៏ទទួលយករបស់នោះទៅ ។

ព្រះតម្រាស់របស់ព្រះមានព្រះភាគជាម្ចាស់ ក្នុងពាក្យនោះថា ÷

សម្បន្នសីលា ភិក្ខវេ វិហរថ ។ ល ។ សមាទាយ សិក្ខាបទេសុ នោះក៏ដូចជាពាក្យឃោសនារបស់ឈ្មួញថា វិសកណ្ឌកំ គណ្ហថ សិក្ខថ ដូច្នេះ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ពួកអ្នក ចូរជាអ្នកមានសីលបរិបូណ៌ចុះ ដូច្នេះ ពួកភិក្ខុរមែងគិតថា ធម្មតាថា សីលនេះជារបស់គ្រោតគ្រាត ជាសត្រូវ ដល់ការសើច និង ការលេងជាដើម នឹងមានអានិសង្សអ្វីខ្លះហ្ន៎ ដល់ភិក្ខុអ្នក មានសីលបរិបូណ៌ ដូច្នេះ ក៏ដូចជាអ្នកស្រុកមានការគិតថា ថ្នាំពិស និង បន្លា

ជារបស់គ្រោតគ្រាត នឹងមានអានិសង្សអ្វីក្នុងការទិញថ្នាំពិសជាដើម ដូច្នោះ កាលដូច្នោះ គប្បីជ្រាបព្រះតម្រាស់ខាងដើមរបស់ព្រះមានព្រះភាគជាម្ចាស់ថា អាកង្ខេយ្យ ចេ ដូច្នេះ ជាប្រយោជន៍ដល់ការប្រកាសអានិសង្ស ១៧ ប្រការ ដែលមានភាពជាទីស្រទឡាញ់ ជាទីគាប់ចិត្ត របស់ពួកសព្រហ្មចារីជាខាងដើម មានការអស់ទៅនៃអាសវៈជាទីបំផុត ដូចពាក្យខាងដើមរបស់ឈ្មួញនោះថា ពួកលោកចូរទិញរបស់ឆ្ងាញ់ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អាកង្ខេយ្យ ចេ សេចក្តីថា ប្រសិនបើអ្នកទាំងទឡាយសង្ឃឹម គឺ ប្រសិនបើអ្នកទាំងទឡាយប្រាថ្នា ។

បទថា បិយោ ច អស្សំ សេចក្តីថា អាត្មាអញគប្បីជាអ្នកដែលបុគ្គលដទៃគប្បីសម្លឹងមើលដោយចក្ខុជាទីស្រទឡាញ់ អធិប្បាយថា អាត្មាអញគប្បីជាអ្នកជាបទដ្ឋាននៃការកើតទេឡីងនៃសេចក្តីស្រទឡាញ់ ដូច្នេះ ។

បទថា មនាបោ សេចក្តីថា អាត្មាអញគប្បីជាទីពេញចិត្តនៃជនទាំង_ នោះ ។ ម្យ៉ាងទៀត អធិប្បាយថា អាត្មាអញគប្បីជាទីត្រូវចិត្តនៃជនទាំងនោះ គឺ គប្បីប្រើជនទាំងនោះផ្សាយមេត្តាចិត្តទៅ ។

បទថា គរុ សេចក្តីថា អាត្មាអញគប្បីជាទីធ្ងន់នៃជនទាំងនោះ ដូច ឆ័ត្រ ។

បទថា ភាវនីយោ សេចក្តីថា អាត្មាអញគប្បីជាអ្នកដែលជនទាំងនោះគប្បីសរសើរយ៉ាងនេះថា លោករូបនេះ កាលដឹងក៏ដឹងពិត កាលឃើញក៏ឃើញពិតប្រាកដ ដូច្នេះ ។

បទថា សីលេស្វេវស្ស បរិបូរិការី សេចក្តីថា គប្បីជាអ្នកធ្វើឱ្យ បរិបូណ៌ក្នុងចតុប្បារិសុទ្ធិសីល នោះឯង អធិប្បាយថា គប្បីប្រកបដោយអាការដែលធ្វើឱ្យបរិបូណ៌មិនដាច់ មិនធ្លុះ មិនពព្រុះ មិនពពាល ។

បទថា អជ្ឈត្តំ ចេតោសមថមនុយុត្តោ សេចក្តីថា ជាអ្នកប្រកបក្នុងការហ្វឹកហាត់ចិត្ត រំងាប់ចិត្តរបស់ខ្លួន ។

ព្រោះពាក្យថា អជ្ឈត្តំ ឬ អត្តនោ ក្នុងពាក្យថា អជ្ឈត្តំ ចេតោ–សមថមនុយុត្តោនេះ ដូចគ្នា គឺ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ប៉ុណ្ណោះ ។

បទថា សមថំ នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ដោយ បទឧបសគ្គ នេះថា អនុ ក៏ជាការសម្រេចក្នុងការប្រកបសេចក្តីបាន ។

បទថា អនិរាកតជ្ឈានោ សេចក្តីថា អ្នកមានឈាន ដែលអ្វី ៗ នាំចេញទៅខាងក្រៅមិនបាន ឬ មានឈានដែលអ្វី ៗ ធ្វើឱ្យសាបសូន្យមិនបាន ។ សេចក្តីពិតឈ្មោះថា និរាករណៈនេះ ប្រើក្នុងអត្ថន័យថា នាំចេញទៅ និង ធ្វើ

ឱ្យវិនាស ។ ក៏គប្បីឃើញការប្រកបសេចក្ដីនៃនិរាករណៈនោះ ដូចក្នុងប្រយោគជាដើមថា បុគ្គលគួរកម្ចាត់ភាពរឹងរូសចេញហើយ គប្បីជាអ្នកមានការប្រព្រឹត្តិបន្ទាបខ្លួន ដូច្នេះ ។

បទថា វិបស្សនាយ សមន្នាគតោ សេចក្ដីថា អ្នកប្រកបដោយ អនុបស្សនា ៧ យ៉ាង ។ ធម្មតាអនុបស្សនា ៧ យ៉ាង គឺ អនិច្ចានុបស្សនា ១ ទុក្ខានុបស្សនា ១ អនត្តានុបស្សនា ១ និព្វិទានុបស្សនា ១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ ។ អនុបស្សនាទាំងនេះ មានពិស្ដារហើយក្នុងបករណ៍វិសេសឈ្មោះ វិសុទ្ធិមគ្គ ។

បទថា ព្រូហេតា សុញ្ញាគារំ សេចក្ដីថា ជាអ្នកញ៉ាំងសុញ្ញាគារឱ្យចម្រើន ។

ក៏ក្នុងបទថា ព្រូហេតា សុញ្ញាគារានំ នេះ ភិក្ខុរៀនយកកម្មដ្ឋានដោយអំណាចសមថៈ និង វិបស្សនា ហើយចូលទៅកាន់ផ្ទះស្ងាត់ អង្គុយនៅទាំង យប់ទាំងថ្ងៃ គប្បីជ្រាបថា ជាអ្នកចម្រើនសុញ្ញាគារ ចំណែកភិក្ខុសូម្បីធ្វើសេចក្ដីព្យាយាមក្នុងប្រាសាទមួយជាន់ជាដើម មិនគប្បីឃើញថា ជាអ្នកចម្រើនសុញ្ញាគារទេឡើយ ។

ក៏ដោយពាក្យត្រឹមតែប៉ុណ្ណេះ ទេសនានេះ សូម្បីព្រះមានព្រះភាគជា

ម្ចាស់នឹងទ្រង់ផ្ដើម ដោយអំណាចការលើកអធិសីលសិក្ខានោះ សម្ដែងមុនក៏ ដោយ ក៏គប្បីជ្រាបថា ជាទេសនាដែលទាក់ទងក្នុងត្រៃសិក្ខាដោយលំដាប់ ព្រោះ រួមសមថៈ និង វិបស្សនាចូលគ្នា ព្រោះសមថៈ និង វិបស្សនា មានសីលជា បទដ្ឋាន ដូចជាការទេសនាធម៌ដែលជាសឹកសត្រូវរបស់តណ្ហា សូម្បីព្រះមាន- ព្រះភាគ ទ្រង់ផ្ដើមដោយអំណាចការលើកតណ្ហាទឡើងសម្ដែងមុន ក៏គប្បីជ្រាប ថា ជាទេសនាដែលរាប់ចូលក្នុងពួក ៣ នៃធម៌ដែលជាគ្រឿងយឺតយូរដោយ លំដាប់ ព្រោះរួមមានះនិងទិដ្ឋិចូលគ្នា ព្រោះមានះ និងទិដ្ឋិ មាន តណ្ហាជាបទដ្ឋាន ។

ក៏ក្នុងបណ្ដាពាក្យទាំងនោះ ដោយពាក្យត្រឹមតែប៉ុណ្ណេះថា សីលេ-ស្វេវស្ស បរិបូរិការី ជាការដែលត្រាស់អធិសីលសិក្ខា ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិ-រាកតជ្ឈានោ ជាការដែលត្រាស់អធិចិត្តសិក្ខា ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា វិបស្សនាយ សមន្នាគតោ ជាការ ដែលត្រាស់អធិប្បញ្ញាសិក្ខា ។

ក៏ដោយបទថា ព្រូហេតា សុញ្ញាគារានំ នេះ ជាការដែលត្រាស់រួម សិក្ខា សូម្បីទាំងពីរយ៉ាងនេះ គឺ អធិចិត្តសិក្ខាក្នុងការចម្រើនសុញ្ញាគារ ដោយ

អំណាចសមថៈ , អធិប្បញ្ញាសិក្ខា ដោយអំណាចវិបស្សនា ។

ក៏ក្នុងទីនេះដោយបទទាំងនេះថា អជ្ឈត្តំ ចេតោសមថមនុយុត្តោ អនិរាកតជ្ឈានោ ព្រះអង្គទ្រង់ត្រាស់ដល់ការដែលចិត្តជាឯកគ្គតាថា រក្សាសីលទុកបាន ។

ដោយបទថា វិបស្សនាយ នេះ ព្រះអង្គទ្រង់ត្រាស់កំណត់នូវសង្ខារថា រក្សាសីលទុកបាន ។

សួរថា ការដែលចិត្តជាឯកគ្គតា និង រក្សាសីលទុកបានយ៉ាងណា ។

ឆ្លើយថា ក៏អ្នកណាមិនមានចិត្តជាឯកគ្គតា អ្នកនោះកាលព្យាធិកើតទេឡើងរមែងក្តៅក្រហាយ គេត្រូវព្យាធិគ្របសង្កត់ និង ការក្រវល់ក្រវាយធ្វើឱ្យសីលដាច់ ទើបនឹងមិនធ្វើព្យាធិនោះឱ្យស្ងប់ទៅបាន ចំណែកអ្នកណាមានចិត្តជាឯកគ្គតា អ្នកនោះក៏មានការគ្របសង្កត់ព្យាធិទុកបាន ចូលសមាបត្តិក្នុងខណៈដែលគេចូលសមាបត្តិ ទុក្ខរមែងប្រាសទៅ សេចក្តីសុខដែលមានកម្លាំងច្រើនជាងនឹងកើតទេឡើង ។ ការដែលចិត្តជាឯកគ្គតា រមែងរក្សាសីលបាន ដោយប្រការយ៉ាងនេះ ។

សួរថា ការកំណត់សង្ខារ រមែងតាមរក្សាសីលបានយ៉ាងណា ។

ឆ្លើយថា ក៏អ្នកណាមិនមានការកំណត់សង្ខារអ្នកនោះ រមែងមានសេចក្តី

ស្រទឡាញ់យ៉ាងខ្លាំងក្នុងអត្តភាពថា រូបរបស់យើង វិញ្ញាណរបស់យើង ដូច្នេះអ្នកនោះ កាលប្រឈមមុខចំពោះទុព្ភិក្ខភ័យ និង ព្យាធិភ័យជាដើមបែបនោះរមែងទម្លាយសីលហើយរក្សាអត្តភាព ។ ចំណែកអ្នកណាមានការកំណត់សង្ខារអ្នកនោះរមែងមិនមានការស្រទឡាញ់យ៉ាងខ្លាំងឬសេចក្ដីស្នេហាក្នុង អត្តភាព ក៏កាលគេប្រឈមមុខចំពោះទុព្ភិក្ខភ័យ និង ព្យាធិភ័យជាដើមបែបនោះ សូម្បីថាពោះវៀនធំរបស់គេនឹងលូនហូរចេញមកខាងក្រៅ គេនឹងស្គមស្លេក_ស្លាំង ឬដាច់ចេញជាកំណាត់ ៗ ទាំងរយកំណាត់ ពាន់កំណាត់ គេក៏មិនទម្លាយសីលហើយរក្សាអត្តភាពទុកទេឡើយ ការកំណត់សង្ខារ រមែងរក្សាសីលបានយ៉ាង នេះ ។ ក៏ដោយបទថា ព្រូហេតា សុញ្ញាគារានំនេរ ព្រះអង្គទ្រង់សម្ដែង ការកពូនការចម្រើន និង ការធ្វើឱ្យជាប់តគ្នាដោយហេតុទាំងពីរយ៉ាងនោះ ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកយ៉ាងនេះថា ព្រោះបើភិក្ខុអ្នកប្រាថ្នានូវគុណធមិ ៤ ប្រការនេះ គឺ អាត្មាអញគប្បីជាទីស្រទឡាញ់ ជាទីពេញចិត្ត ជាទីគោរពរាប់អាន ជាទីសរសើររបស់ពួកសព្រហ្មចារីទាំងទឡាយ មិនមានកិច្ចដែលនឹងត្រូវធ្វើអ្វីដទៃ ( តែ ) គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើមដោយ ពិតព្រោះថាភិក្ខុដែលប្រកបដោយគុណមានសីលជាដើមដូច្នេះរមែងជា ទីស្រទឡាញ់ផងជាទីពេញចិត្តផង ជាទីគោរពរាប់អានផង ជាទីសរសើរផង

របស់ពួកសព្រហ្មចារីទាំងទឡាយ ។ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះ-ភាគជាម្ចាស់ត្រាស់ទុកថា ៖

ជនរមែងធ្វើអ្នកសំបូរដោយសីល និង ទស្សនៈ អ្នកតាំងនៅក្នុងធម៌អ្នកមានប្រក្រតីនិយាយពាក្យពិត អ្នកធ្វើការងាររបស់ខ្លួនឱ្យជាទីស្រឡាញ់ ដូច្នេះ ។

## សេចក្ដីសង្ខេប ទី ២

ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់លុះត្រាស់ថា ម្នាលភិក្ខុទាំង- ទឡាយ ប្រសិនបើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រទឡាញ់ ។ ល ។ ជាទីពេញចិត្តរបស់ពួកព្រហ្មចារីទាំងទឡាយ ដូច្នេះអ្នកទាំងទឡាយគប្បីជាអ្នកធ្វើឱ្យបរិ-បូរក្នុងសីលទាំងទឡាយ ។ល។ អ្នកទាំងទឡាយគប្បីចម្រើនសុញ្ញាគារស្ថាន ដូច្នេះ ហើយឥទឡូវនេះ ព្រោះហេតុដែលភិក្ខុប្រាថ្នាបច្ច័យមានលាភជាដើម គប្បីធ្វើកិច្ចនេះតែម្យ៉ាង មិនគប្បីធ្វើកិច្ចអ្វីដទៃក្រៅពីនេះទេ ដូច្នេះ ទើបបានត្រាស់ពាក្យមានជាអាទិទុកថា ម្នាលភិក្ខុទាំងទឡាយ ប្រសិនបើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាអ្នកមានលាភ ដូច្នេះជាដើម ។

ក៏ក្នុងទីនេះកុំយល់ថា ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ការបំពេញសីល ជាដើមដែលមានលាភជានិមិត្តទុក ព្រោះព្រះមានព្រះភាគទ្រង់ជាអ្នកត្រាស់បដិសេធការស្វែងរកលាភ មិនត្រាស់ព្រះវាចាដែលទាក់ទងដល់ ( លាភ )

ទ្រង់មានព្រះឱវាទដល់ពួកសាវកយ៉ាងនោះ ។ ព្រះអង្គនឹងត្រាស់ការបំពេញ គុណមានសីលជាដើម ដែលមានលាភជានិមិត្តបាន យ៉ាងណា ?

តែថា ពាក្យនោះ ព្រះអង្គត្រាស់ទុកដោយអំណាចអធ្យាស្រ័យរបស់ បុគ្គល ។ អធិប្បាយថា ភិក្ខុពួកណាគប្បីមានអធ្យាស្រ័យយ៉ាងនេះថា ប្រសិនបើយើងមិនត្រូវលំបាកដោយបច្ច័យ ៤ សោត យើងអាចដើម្បីនឹងបំពេញសីលជាដើមឱ្យបរិបូរបាន ដូច្នេះ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកយ៉ាងនេះ ដោយអំណាចអធ្យាស្រ័យរបស់ជនទាំងទឡាយនោះ ។

ម្យ៉ាងទៀត ឈ្មោះថា បច្ច័យ ៤ នេះ នោះជាអានិសង្សពិតរបស់សីល ។ ពិតយ៉ាងនោះ មនុស្សអ្នកជាបណ្ឌិតទាំងទឡាយ នាំរបស់ដែលខ្លួនទុកដាក់ក្នុងជង្រុកជាដើមចេញមក ទាំងបុត្រជាដើមក៏មិនឱ្យ ទាំងខ្លួនឯងក៏មិនបានប្រើប្រាស់ តែរមែងបង្អោនថ្វាយដល់អ្នកមានសីល ពាក្យដូចពោលមកនេះ លោកពោលទុកដើម្បីសម្តែងអានិសង្សពិតរបស់សីល ។

## សេចក្តីសង្ខេប ទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៣ ដូចតទៅ ÷*

បទថា យេសាហំ កាត់បទថា យេសំ អហំ ។

បទថា តេសន្តេ ការា សេចក្តីថា សក្ការៈគឺការថ្វាយបច្ច័យទាំងនោះ

ទេវតា ឬ មនុស្សបានធ្វើហើយក្នុងខ្លួនយើង សេចក្ដីពិត ទេវតាទាំងទឡាយរមែងថ្វាយបច្ច័យដល់លោកអ្នកដែលប្រកបដោយគុណ មានសីលជាដើម និង មានចំពោះមនុស្សតែម្យ៉ាងប៉ុណ្ណោះក៏ទេ ដូចដែលសក្កទេវរាជបានថ្វាយដល់ព្រះម_ហាកស្សប ។

ពាក្យទាំងពីរនេះថា មហប្ផលា មហានិសំសា ពោលដោយសេចក្ដី ហើយមានអត្ថដូចគ្នា ផ្សេងត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ។ សក្ការៈដែលឈ្មោះថា មានផលច្រើន នាំមកនូវលោកិយសុខយ៉ាងច្រើនឱ្យ ។ ឈ្មោះថា មានអានិសង្ស ច្រើន ព្រោះជាបច្ច័យនៃការបានលោកុត្តរសុខយ៉ាងធំ ។ សេចក្ដីពិត ភិក្ខាមួយ វែកក្ដីបណ្ណសាលាលើផ្ទៃដីវែងប្រមាណ ៥ ហត្ថក្ដី ដែលបុគ្គលថ្វាយដល់លោកអ្នកប្រកបដោយគុណ មានសីលជាដើម រមែងរក្សាគេមិនឱ្យធ្លាក់ទៅកាន់ ទុគ្គតិវិនិបាត បានច្រើនសែនកប្ប ។ ហើយក្នុងដំណាក់កាលចុងក្រោយនៅជាបច្ច័យនៃការរំលត់កិលេសដោយអមតធាតុ ។

ក៏ក្នុងរឿងនេះ មានរឿងជាដើមថា យើងបានថ្វាយទឹកដោះ និង បាយ ជាដើម មានបេតវត្ថុ និង វិមានវត្ថុទាំងមូលជាគ្រឿងសាធកៈ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់សម្ដែងថា ភិក្ខុសូម្បីប្រាថ្នានឹងឱ្យសក្ការៈ

ដែលអ្នកថ្វាយបច្ច័យដល់ខ្លួននោះ មានផលច្រើន គប្បីជាអ្នកប្រកបដោយគុណមានសីលជាដើមនោះឯង ។

## សេចក្ដីសង្ខេប ទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៤ ដូចតទៅ ÷

ពួកជនអ្នកទាក់ទងខាងចំណែកឱពុកក្មេក និង ម្ដាយក្មេក ឈ្មោះថា ញាតិ។ បិតា និង ជីតាជាដើម អ្នកដែលទាក់ទងដោយសាច់សាលោហិតគ្នា និងគ្នា ឈ្មោះថា ញាតិសាលោហិត ។

អ្នកដល់ភាពជាអ្នកលះទៅហើយ ឈ្មោះថា បេត ។

បទថា កាលកតា ប្រែថា ស្លាប់ហើយ ។

បទថា តេសន្តំ សេចក្ដីថា ការដែលជនទាំងនោះមានចិត្តជ្រះថ្លាចំពោះ យើង ឬ ការរលឹកដល់យើង ដោយចិត្តជ្រះថ្លានោះ របស់ជនទាំងនោះ ។ ការពិត បិតា ឬ មាតារបស់ភិក្ខុរូបណាស្លាប់ទៅហើយ មានចិត្តជ្រះថ្លារមែង រលឹកដល់ភិក្ខុនោះថា ព្រះថេរៈអ្នកមានសីល មានធម៌ដ៏ស្អាតនេះជាញាតិ របស់យើង ដូច្នេះ សេចក្ដីជ្រះថ្លានៃចិត្តនោះ របស់គេនោះក្ដី ហេតុត្រឹមតែការ រលឹកដល់នោះក្ដី មានផលច្រើនមានអានិសង្សច្រើន ។

ហេតុត្រឹមតែការរលឹកដល់នោះ ជាធម្មជាតិដែលអាចដើម្បីនឹងញុំាង

ពួកសត្វឱ្យឆ្លងផុតចាកទុគតិអស់ច្រើនសែននៃកប្ប ហើយឱ្យដល់អមតមហា- និព្វាន ក្នុងទីបំផុតនោះឯង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ ទុកថា ម្នាលភិក្ខុទាំងទឡាយ ភិក្ខុពួកណា សំបូរដោយសីល សំបូរដោយ សមាធិ សំបូរដោយបញ្ញា វិមុត្តិ និង វិមុត្តិញ្ញាណទស្សនៈ ម្នាលភិក្ខុទាំងទឡាយ ក៏តថាគតពោល ការឃើញ ការស្តាប់ ការរលឹកដល់ ការបួសតាម ការចូល ទៅរក ការចូលទៅអង្គុយជិតភិក្ខុទាំងនោះថា មានឧបការៈច្រើន ដូច្នេះ , ព្រោះដូច្នោះ ទើបព្រះអង្គទ្រង់សម្តែងថា ភិក្ខុសូម្បីប្រាថ្នានូវសេចក្តីជ្រះថ្លានៃ ចិត្តក្នុងខ្លួន និង ការរលឹកដល់ ( ខ្លួន ) ញាតិ និង សាច់សាលោហិតទាំង- ទឡាយនឹងឱ្យមានផលច្រើន គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើម នោះឯង ។

## សេចក្តីសង្ខេប ទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៥ ដូចតទៅ ÷

បទថា អរតិរតិសហោ អស្សំ សេចក្តីថា អាត្មាអញគប្បីជាអ្នកគ្រប- សង្កត់សេចក្តីអផ្សុក និង សេចក្តីត្រេកអរ គឺ កុំគប្បីជាអ្នកត្រូវសេចក្តីអផ្សុក ជាដើម គ្របសង្កត់ទេឡើយ ។

ក៏ក្នុងបទថាអរតិរតិសហោ នេះសេចក្តីអផ្សុកក្នុងធម៌ដែលជាអធិ_កុសល (និង ) ក្នុងសេនាសនៈដ៏ស្ងាត់ឈ្មោះថា អរតិ សេចក្តីត្រេកអរ ក្នុងកាមគុណទាំង ៥ ឈ្មោះថា រតិ ។

បទថា ន ច មំ អរតិ សហេយ្យ សេចក្តីថា ក៏សេចក្តីអផ្សុក កុំគប្បីគ្របសង្កត់ គឺ ញាំញី បានដល់ បៀតបៀនយើងមិនបាន ។

បទថា ឧប្បន្នំ សេចក្តីថា កើតហើយ គឺ កើតទឡើងហើយ ។

ព្រោះថា ភិក្ខុអ្នកប្រកបដោយគុណមានសីលជាដើម រមែងអត់ទ្រាំ គឺ គ្របសង្កត់បានដល់ការញាំញីនូវសេចក្តីអផ្សុកនិងសេចក្តីត្រេកអរបាន ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបទ្រង់ត្រាស់សម្តែងទុកថាភិក្ខុសូម្បី នឹងប្រាថ្នាឱ្យខ្លួនដូច្នោះ គប្បីជាអ្នកប្រកបដោយគុណ មានសីលជាដើម ។

## សេចក្តីសង្ខេប ទី ៦

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៦ ដូចតទៅ ÷

ការស្លុតចិត្តក្តី អារម្មណ៍ក្តី ឈ្មោះថា ភ័យ ( សេចក្តីខ្លាច ) អារម្មណ៍នោះឯងឈ្មោះថា ភេរវំ ( ការខ្លាច ) ពាក្យដ៏សេសមានន័យ ដូចពោលទុកហើយក្នុងវារៈទី ៥ ។

សេចក្តីពិត ភិក្ខុអ្នកប្រកបដោយគុណមានសីលជាដើម រមែងអត់ទ្រាំ

គឺ រមែងគ្របសង្កត់ បានដល់ ការញាំញី សេចក្ដីខ្លាច និង សេចក្ដីស្ញើបនោះ ដូចព្រះមហាទត្តត្ថេរអ្នកស្រុកអរិយកោដិយវិហារ ។

## ទេវតាដេញភិក្ខុ

បានឮថា ព្រះថេរៈធ្វើដំណើរទៅតាមផ្លូវបានជួបប្រទះព្រៃដែលជាទីតាំងនៃសេចក្ដីជ្រះថ្លាមួយកន្លែង ទើបគិតថា ថ្ងៃនេះយើងនឹងបំពេញសមណធម៌ក្នុង ទីនេះហើយទើបនឹងទៅ ដូច្នេះហើយ ទើបគេចចេញអំពីផ្លូវ ក្រាលសំពត់ សង្ឃាដីហើយអង្គុយពែនភ្នែនទៀបគល់ឈើនោះ ។

ក្មេង ៗ របស់រុក្ខទេវតា មិនអាចនឹងតាំងនៅតាមសភាវៈរបស់ខ្លួនបានដោយតេជនៃសីលរបស់ព្រះថេរៈ ទើបស្រែកយំទេឡើង សូម្បីទេវតាក៏អង្រួនដើមឈើគ្រប់ដើម , ព្រះថេរៈក៏អង្គុយស្ងៀមមិនញាប់ញ័រ ទេវតានោះ ទើបគ្រវីគប់ភ្លើងឱ្យឆេះសន្ធោសន្ធៅទេឡើង ( សូម្បីជាយ៉ាងនោះ ) ក៏មិនអាចធ្វើឱ្យព្រះថេរៈញាប់ញ័របាន ។

តអំពីនោះ ទេវតាទើបនិម្មិតខ្លួនជាឧបាសក ដើរមកថ្វាយបង្គំព្រះថេរៈហើយបានឈរនៅក្នុងទីដ៏សមគួរមួយ ត្រូវព្រះថេរៈសួរថា អ្នកណានោះ ទើបបានពោលថា លោកដ៏ចម្រើន ខ្ញុំជាទេវតាដែលស្ថិតនៅនឹងដើមឈើនេះ ព្រះថេរៈសួរថា លោកបានធ្វើវត្ថុបន្លាចយើងឬ? ទេវតាឆ្លើយថា ពិតមែន ។

ក៏ទេវតានោះត្រូវព្រះថេរៈសួរថា ព្រោះហេតុអ្វីទើបលោកធ្វើ ? ទើបឆ្លើយថា លោកដ៏ចម្រើន ដោយតេជនៃសីលរបស់លោកនោះឯង ពួកក្មេង ៗ មិនអាចនឹងតាំងនៅតាមសភាវៈរបស់ខ្លួនបាន ទើបបាននាំគ្នាស្រែកយំទ្បើង ខ្ញុំនោះបានធ្វើយ៉ាងនេះ ដើម្បី ( បំណង ) នឹងឱ្យលោកចៀសចេញទៅ ។ ព្រះថេរៈ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វីលោកទើប ( បំណង ) នឹងឱ្យយើង គេចចេញទៅ ? ទេវតាឆ្លើយថា លោកដ៏ចម្រើន សុំលោកកុំនៅក្នុងទីនេះ ទេទ្បីយ ខ្ញុំមិនបានសេចក្ដីសុខទេ ដូច្នេះ ព្រះថេរៈទើបពោលថា ហេតុអ្វីក៏លោកមិនប្រាប់យើងពីមុន តែឥទទ្បូវនេះលោកកុំនិយាយអ្វី ៗ ទេទ្បីយ យើងខ្មាសចំពោះពាក្យដែលមនុស្សនឹងនិយាយថា ព្រះអរិយកោដិយមហាទត្ត គេចចេញទៅព្រោះខ្លាចចំពោះអមនុស្ស ដូច្នោះ យើងនឹងនៅទីនេះឯង តែក្នុងថ្ងៃនេះត្រឹមតែមួយថ្ងៃ លោកចូរនៅក្នុងទីណាមួយ ( សិន ) ចុះ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែងថា ភិក្ខុអ្នកប្រកបដោយគុណមានសីលជាដើម រមែងជាអ្នកកម្ចាត់ភ័យដែលគួរឱ្យខ្លាចបាន ព្រោះដូច្នោះ ភិក្ខុសូម្បីប្រាថ្នាឱ្យខ្លួនជាយ៉ាងនេះ គប្បីជាអ្នកប្រកបដោយគុណមានសីលជាដើម ដូច្នេះ ។

## *សេចក្តីសង្ខេប ទី ៧*

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៧ ដូចតទៅ ÷

ចិត្តដែលបរិសុទ្ធផូរផង់ ព្រះអង្គទ្រង់ត្រាស់ហៅថា អភិចិត្ត ក្នុងពាក្យថា អាភិចេតសិកានំ ។ម្យ៉ាងទៀត ចិត្តដ៏ក្រៃលែង ព្រះអង្គត្រាស់ហៅថា អភិចិត្ត ឈានទាំងទឡាយដែលកើតទេឡីងក្នុងអភិចិត្ត ឈ្មោះថា អភិចេតសិក ម្យ៉ាងទៀត ឈានទាំងទឡាយដែលអាស្រ័យអភិចិត្ត ដូច្នោះ ឈានទាំងទឡាយនោះ ទើបឈ្មោះថា អភិចេតសិក ។

បទថា ទិដ្ឋធម្មសុខវិហារានំ សេចក្តីថា ជាគ្រឿងនៅជាសុខក្នុង ទិដ្ឋធម៌ អត្តភាពដែលឃើញបានដោយប្រចក្ស ហៅថា ទិដ្ឋធម៌ អធិប្បាយថា ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌នោះ ។

ពាក្យថា ទិដ្ឋធម្មសុខវិហារានំ ជាឈ្មោះរបស់រូបាវចរឈាន ពិតណាស់ ជនទាំងទឡាយអង្គុយសម្លឹងឈាននោះយ៉ាងស៊ប់ រមែងប្រសព្វនេក្ខម្មសុខដែលមិនសៅហ្មងក្នុងអត្តភាពនេះ ព្រោះដូច្នោះ ជនទាំងនោះ លោកទើបហៅថា អ្នកមានប្រក្រតីនៅជាសុខក្នុងទិដ្ឋធម៌ ។

បទថា និកាមលាភី សេចក្តីថា ជាអ្នកបានតាមសេចក្តីត្រូវការ គឺ ជាអ្នកបានតាមសេចក្តីប្រាថ្នារបស់ខ្លួន អធិប្បាយថា រមែងជាអ្នកអាចដើម្បីនឹង

ចូលឈានបានក្នុងខណៈដែលខ្លួនប្រាថ្នាៗ ។

បទថា អកិច្ឆលាភី មានសេចក្ដីថា ជាអ្នកអាចដើម្បីនឹងគ្របសង្កត់នូវធម៌ដែលជាសឹកសត្រូវហើយចូលឈានបានដោយស្រួល ។

បទថា អកសិរលាភី សេចក្ដីថា ជាអ្នកបានដោយមិនលំបាក គឺ យ៉ាង ស្រួល អធិប្បាយថា ជាអ្នកអាចដើម្បីនឹងចេញបានក្នុងវេលាតាមដែលកំណត់ ទុកនុ៎ះឯងពិតណាស់ ភិក្ខុរូបខ្លះជាអ្នកបានឈាន តែមិនអាចនឹងចូលឈានបានក្នុងខណៈដែលខ្លួនត្រូវការ ។ អង្គខ្លះអាចនឹងចូលក្នុងខណៈដែលខ្លួនប្រាថ្នា តែគ្របសង្កត់ធម៌ដែលជាសឹកសត្រូវចំពោះវសីបានដោយលំបាក ។ អង្គខ្លះរមែងចូលបានក្នុងខណៈដែលខ្លួនត្រូវការ ហើយគ្របសង្កត់ធម៌ដែលជាសឹក-សត្រូវចំពោះវសីបានដោយមិនលំបាក តែមិនអាចដើម្បីនឹងចេញក្នុងខណៈដែលខ្លួនកំណត់ទុកបាន ដូចនាទឡិកា ។ ក៏ភិក្ខុណាប្រាថ្នាការបានហេតុទាំង ៣ យ៉ាងនេះ ភិក្ខុនោះគប្បីជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

## សេចក្ដីសង្ខេប ទី ៨

កាលព្រះមានព្រះភាគជាម្ចាស់ត្រាស់ឈាន ដែលជាបាទរបស់អភិញ្ញាយ៉ាងនេះហើយ ក៏មកដល់វារៈរបស់អភិញ្ញាសូម្បីដោយពិត តែសូម្បីយ៉ាងនោះព្រះមានព្រះភាគជាម្ចាស់ក៏មិនបានទ្រង់កាន់យកអភិញ្ញានោះ ដើម្បីនឹងទ្រង់រួម

សម្តែងធមិទាំងអស់នោះ ព្រោះថា មិនត្រឹមតែឈានដែលជាបាទរបស់អភិញ្ញា និង អភិញ្ញាតែម្យ៉ាងប៉ុណ្ណោះទេ ដែលជាអានិសង្សរបស់សីល ដោយពិត អរូបឈានទាំង ៤ និង អរិយមគ្គទាំង ៣ ខាងដើមក៏ជាអានិសង្សរបស់សីល ដូចគ្នា ដូច្នោះ ទើបត្រាស់ពាក្យមានជាដើមថា អាកង្ខេយ្យ ចេ ។ល។ យេ តេ សន្តា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា សន្តា សេចក្តីថា វិមោក្ខទាំងទឡាយ ឈ្មោះថា ជាធម្មជាតិស្ងប់ ព្រោះមានអង្គស្ងប់ និង ព្រោះមានអារម្មណ៍ស្ងប់។

បទថា វិមោក្ខា សេចក្តីថា វិមោក្ខទាំងទឡាយឈ្មោះថា ស្ងប់ ព្រោះរួច ផុតចាកធមិដែលជាសឹកសត្រូវ និង ព្រោះបង្អោនទៅក្នុងអារម្មណ៍ ។

បទថាអតិក្កម្មរូបេសេចក្តីថាឈានកន្លងនូវរូបាវចរជ្ឈានភ្ជាប់បទថា វិមោក្ខ និង ឈ្មោះថា ស្ងប់បាន ព្រោះឈានកន្លងរូបាវចរជ្ឈាន ដូច្នេះ ។

ពិតណាស់ កាលនឹងពោលដោយប្រការដទៃ វិមោក្ខទាំងទឡាយឈាន កន្លងរូបាវចរហើយ ក៏មិនគប្បីប្រាកដថា នឹងធ្វើអ្វី ។

បទថា អារុប្បា សេចក្តីថា កន្លងហួសរូបាវចរជ្ឈានទាំងដោយអារម្មណ៍ និង ដោយវិបាក ។

បទថា កាយេន ផុសិត្វា សេចក្តីថា ពាល់ត្រូវនាមកាយ អធិប្បាយថា

សម្រេចហើយ ។

ពាក្យដ៏សេស មានសេចក្តីច្បាស់ហើយ មានពាក្យអធិប្បាយដែលលោកពោលទុកថា ភិក្ខុរូបណា ប្រាថ្នានឹងពាល់ត្រូវវិមោក្ខហើយ សូម្បីភិក្ខុនោះគប្បីជាអ្នកធ្វើឱ្យបរិបូរណ៍ក្នុងសីលទាំងទឡាយពិតប្រាកដ ដូច្នេះឯង ។

## សេចក្តីសង្ខេប ទី ៩

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ៩ ដូចតទៅ ÷

បទថា តិណ្ណំ សំយោជនានំ សេចក្តីថា នៃគ្រឿងចង ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ។ ពិតណាស់ គ្រឿងចង ទាំងនោះ រមែងប្រកបខន្ធ គតិ និង ភពជាដើមចូលនឹងខន្ធ គតិ និង ភព ជាដើម ម្យ៉ាងទៀត រមែងប្រកបកម្មចូលជាមួយនឹងផល ដូច្នោះ គ្រឿងចង ទាំងនោះ លោកទើបហៅថា សំយោជនៈ អធិប្បាយថា គ្រឿងចង ។

បទថា បរិក្ខយា ប្រែថា ព្រោះការអស់ទៅនៃគ្រឿងចងដោយជុំវិញ ។

បទថា សោតាបន្នោ បានដល់ ក្រសែ ក៏ពាក្យថា សោតាជាឈ្មោះរបស់មគ្គ ។ ពាក្យថា សោតាបន្នោ ជាឈ្មោះរបស់បុគ្គលអ្នកដល់ព្រមដោយមគ្គនោះ ។

ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលសារីបុត្រ ដែលតថាគត

ពោលថា សោតោ សោតោ ដូច្នេះ សារីបុត្រ ក្រសែ បានដល់ អ្វី?

ព្រះសារីបុត្រទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្រសែនេះឯង បានដល់ អរិយមគ្គមានអង្គ ៨ គឺ សម្មាទិដ្ឋិ សម្មាសង្កប្ប ។ល។ សម្មាសមាធិ ។

ម្នាលសារីបុត្រ ក៏ដែលតថាគតពោលថា សោតាបន្នោ សោតាបន្នោ ដូច្នេះ សារីបុត្រ ព្រះសោតាបន្ន បានដល់ បុគ្គលយ៉ាងដូចម្តេច ?

ព្រះសារីបុត្រទូលថា បពិតព្រះអង្គដ៏ចម្រើន ក៏បុគ្គលដែលប្រកបដោយមគ្គមានអង្គ ៨ នេះឯង ព្រះអង្គត្រាស់ហៅថា ជាព្រះសោតាបន្ននោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ដូច្នេះឯង តែក្នុងទីនេះ ផលមានឈ្មោះ តាមមគ្គ ដូច្នេះ បុគ្គលអ្នកតាំងនូវក្នុងផល គប្បីជ្រាបថា ជាព្រះសោតាបន្ន ។

បទថា អវិនិបាតធម្មោ មានវិគ្រោះថា ធមិដែលឈ្មោះថា វិនិបាត ព្រោះអត្ថថា រមែងញ៉ាំងសត្វឱ្យធ្លាក់ចុះទៅកាន់ទីដ៏អាក្រក់ ដែលឈ្មោះថា អវិនិបាតធម្ម ព្រោះជាធមិដែលមិនញ៉ាំងឱ្យធ្លាក់ទៅកាន់ទីដ៏អាក្រក់ អធិប្បាយ ថា ជាធមិដែលមិនញ៉ាំងខ្លួនឱ្យធ្លាក់ទៅក្នុងអបាយទាំងទឡាយជាសភាវៈ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះធមិដែលមានការញ៉ាំងសត្វឱ្យធ្លាក់ទៅក្នុងអបាយទាំង_ ទឡាយ លោកលះបង់បានហើយ ។

បញ្ញាដែលជាគ្រឿងត្រាស់ដឹង គឺ ជាគតិរបស់ព្រះសោតាបន្ននោះ ដូច្នេះ លោកទើបឈ្មោះថា មានបញ្ញាជាគ្រឿងត្រាស់ដឹងដែលប្រព្រឹត្តទៅខាងមុខ អធិប្បាយថា ជាអ្នកសម្រេចមគ្គ ៣ ខាងលើពិតប្រាកដ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកបានសោតាបត្តិមគ្គហើយ ។

បទថា សីលេស្វេវ សេចក្តីថា ភិក្ខុសូម្បីប្រាថ្នានឹងឱ្យខ្លួនជាយ៉ាងនេះ គប្បីជាអ្នកធ្វើឱ្យបរិបូរណ៍ក្នុងសីលទាំងទឡាយចុះ ។

## សេចក្តីសង្ខេប ទី ១០

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ១០ ដូចតទៅ ÷

សំយោជនៈ ៣ ដែលព្រះយោគាវចរលះបង់បានដោយសោតាបត្តិមគ្គ លោកក៏ពោលទុកដើម្បីប្រយោជន៍ដល់ការពណ៌នា សកទាគាមិមគ្គ ។

បទថា **រាគទោសមោហានំ តនុត្តា** សេចក្តីថា ព្រោះភាវៈដែល រាគទោសមោហទាំងនោះមានសភាពស្រាលស្តើងអធិប្បាយថាព្រោះធ្វើ រាគទោសមោហទាំងនោះឱ្យស្រាលស្តើងទៅ ។ ក្នុងពាក្យនោះ គប្បី ជ្រាបដល់រាគៈជាដើមនោះជាធម្មជាតិស្រាលស្តើងក៏ដោយហេតុ២ប្រការគឺ ព្រោះកើតទឡើងម្តងម្កាល និង ព្រោះបរិយុដ្ឋានកិលេសមានកំលាំងខ្សោយ ។

ពិតណាស់ កិលេសទាំងទឡាយរមែងមិនកើតទេឡើងដល់ព្រះសកទាគាមីរឿយ ៗ ដូចកើតដល់មហាជនដែលត្រាច់រង្គាត់ទៅក្នុងវដ្តៈ រមែងកើតទេឡើងជាចន្លោះ ៗ ក្នុងគ្រាខ្លះ ដូចជាពូជក្នុងស្រែដែលគេព្រោះស្តើង ៗ ហើយសូម្បីកាល កើត ទេឡើង រមែងមិនកើតទេឡើងញាំញី ផ្សាយទៅ បិទបាំង ធ្វើភាពងងឹតអន្ធការ ដូចកើតដល់មហាជនដែលវិលវល់នៅក្នុងវដ្តៈ រមែងកើតទេឡើងស្រាលស្តើង គឺ ជាធម្មជាតិស្រាលស្តើងកើតទេឡើង ដូចស្រទាប់នៃពពក ( ដែលអណ្តែតទេឡើង តាមលំដាប់) និង ដូចឃ្មុំដែលប៉ះពាល់ផ្កាឈើ ( មិនញាំញីឱ្យជាំខូច) ដូច្នេះ។

ក្នុងរឿងនោះព្រះថេរៈពួកខ្លះបានពោលទុកថា កិលេសទាំងទឡាយ យូរ ៗ ទើបកើតទេឡើងដល់ព្រះសកទាគាមីក៏ពិត សូម្បីយ៉ាងនោះក៏កើតទេឡើងយ៉ាងក្រាស់ ណែន ព្រោះលោកនៅមានបុត្រធីតា តែពាក្យនោះមិនជាប្រមាណ ព្រោះ បុត្រធីតា គ្រាខ្លះក៏កើតមានដល់មាតាបិតាដោយហេតុត្រឹមតែការស្ទាបអង្អែល អវយវៈដូច្នោះ គប្បីជ្រាបចំពោះកិលេសរបស់ព្រះសកទាគាមីនោះ ជាធម្មជាតិ ស្រាលស្តើងដោយហេតុ ២ យ៉ាងប៉ុណ្ណោះ គឺ ព្រោះការកើតទេឡើងម្តងម្កាល និង ព្រោះបរិយុដ្ឋានកិលេសរបស់លោកស្រាលស្តើង ។

បទថា សកទាគាមី សេចក្តីថា អ្នកមានការត្រទឡប់មកកាន់លោកនេះ ត្រឹមតែមួយដងប៉ុណ្ណោះ ដោយអំណាចបដិសន្ធិ ។

ក៏សូម្បីអ្នកណាចម្រើនសកទាគាមីមគ្គក្នុងលោកនេះហើយ បរិនិព្វានក្នុងលោកនេះ សូម្បីអ្នកនោះ លោកមិនចាត់ចូលក្នុងទីនេះទេ ។ សូម្បីអ្នកណាចម្រើនមគ្គក្នុងលោកនេះហើយ បានកើតក្នុងទេវលោក ហើយបរិនិព្វានក្នុងទេវលោក នោះ អ្នកនោះក៏មិនចាត់ចូលក្នុងទីនេះដែរ ។ អ្នកណាចម្រើនមគ្គក្នុងទេវលោក ហើយត្រឡប់មកកើតហើយ បរិនិព្វានក្នុងមនុស្សលោកនេះ អ្នកនោះក៏មិនចាត់ចូលក្នុងទីនេះដែរ ។ សូម្បីអ្នកណាចម្រើនមគ្គក្នុងលោកនេះហើយ បានកើតក្នុងទេវលោក តាំងនៅក្នុងទេវលោកនោះដល់អស់អាយុហើយ បានកើតក្នុងទេវលោកនោះទៀត ហើយបរិនិព្វាន អ្នកនោះឯងគប្បីជ្រាបថា លោកកាន់យកក្នុងពាក្យនេះ ។

បទថា ទុក្ខស្សន្តំ ករេយ្យំ សេចក្តីថា យើងគប្បីធ្វើការកំណាត់វដ្តទុក្ខ។

បទថា សីលេស្វេវ សេចក្តីថា ភិក្ខុសូម្បីប្រាថ្នាឱ្យខ្លួនជាយ៉ាងនេះ គប្បីជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

## សេចក្តីសង្ខេប ទី ១១

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈ ទី ១១ ដូចតទៅ ÷

បទថា បញ្ចន្នំ ជាការកំណត់ដោយការរាប់ ។

បទថា ឱរម្ភាគិយានំ សេចក្តីថា ខាងក្រោម លោកហៅថា ឱរ

បានដល់ ចំណែកខាងក្រោម អធិប្បាយថា ជាបច្ច័យនាំឱ្យមានការកើតទេឡើង ក្នុងលោកចំណែកកាមាវចរ ។

បទថា សញ្ញោជនានំ បានដល់ កិលេសជាគ្រឿងចង កិលេសជាគ្រឿងចងទាំងនោះ គប្បីជ្រាបថា បានដល់ សំយោជនៈដែលលោកពោលទុកក្នុងកាលមុន ( គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ) ព្រមទាំង សំយោជនៈ គឺ កាមរាគៈ និង ព្យាបាទ ។ ពិតណាស់ សំយោជនៈទាំងនោះ បើបុគ្គលណាមិនទាន់បានលះបង់ទេនោះ សូម្បីអ្នកនោះ នឹងកើតទេឡើងក្នុងភវគ្គ-ព្រហ្មក៏ពិត កាលបើដូច្នោះ សូម្បីយ៉ាងនោះក៏ដោយ ក៏គេមិនរួចផុតអំពីកាមភព ដែរ គេក៏រមែងនឹងត្រូវទទ្បប់មកកាន់កាមាវចរទៀត ព្រោះអស់អាយុ បុគ្គលនេះគប្បីជ្រាបថា មានឧបមាដូចត្រីដែលជាប់ផ្លែសន្ទូច និង មានឧបមាដូចបក្សី ជាប់ខ្សែស្និតនឹងជើង ។ ដូច្នោះ ក៏ក្នុងអធិការនេះ គប្បីជ្រាបថា លោកពោល ពាក្យនេះទុកដើម្បីប្រយោជន៍ដល់ការពណ៌នាព្រះអរិយបុគ្គលដែលលោក ពោលទុកអំពីមុន ៗ ។

ពាក្យថា ឱបបាតិកោ ជាពាក្យពោលបដិសេធកំណើតដ៏សេស ។

បណ្ដាបទទាំងនោះ បទថា បរិនិព្វាយិ សេចក្ដីថា បរិនិព្វានក្នុងព្រហ្ម-លោកនុ៎ះឯង ។

បទថា អនាវត្តិធម្មោ តស្មា លោកា សេចក្តីថា មានការមិនត្រឡប់មកអំពីព្រហ្មលោកនោះដោយអំណាចបដិសន្ធិទៀតជាសភាវៈ ។

បទថា សីលេស្វេវ សេចក្តីថា បើភិក្ខុប្រាថ្នាដូច្នេះ គប្បីជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងឡាយចុះ ។

## សេចក្តីប្រាថ្នា ទី ១២

កាលព្រះមានព្រះភាគជាម្ចាស់ត្រាស់អនាគាមិមគ្គ យ៉ាងនេះហើយ សូម្បីនឹងមកដល់វារៈនៃមគ្គ ទី ៤ ក៏ពិត ដល់យ៉ាងនោះ ព្រះមានព្រះភាគជាម្ចាស់ក៏មិនទ្រង់កាន់យកអរហត្តមគ្គនោះ ព្រោះមិនមែនតែអភិញ្ញា គឺ ការអស់ទៅនៃអាសវៈជាអានិសង្សរបស់សីលតែម្យ៉ាងប៉ុណ្ណោះទេ តាមពិតអភិញ្ញាប្រាំប្រការដែលជាលោកិយ ( ក៏ជាអានិសង្សរបស់សីលដូចគ្នា ) ដូច្នោះ ដើម្បីនឹងទ្រង់សម្តែងអភិញ្ញាទាំងនោះហើយ ព្រោះកាលព្រះអង្គត្រាស់ដល់ការអស់ទៅនៃអាសវៈ ទេសនាក៏ជាការចប់ហើយ ក៏កាលបើដូច្នេះ ការពោលយ៉ាងនេះក៏ឈ្មោះថា ពោលដល់អភិញ្ញាសុទ្ធ ព្រោះនៅមិនទាន់បានពោលដល់គុណរបស់អភិញ្ញាទាំងនោះ ដូច្នោះ ដើម្បីនឹងទ្រង់សម្តែងអភិញ្ញាយ៉ាងបរិបូណ៌ ហើយព្រោះការសម្តែងឫទ្ធិ រមែងសម្រេចដល់បុគ្គលអ្នកតាំងនៅក្នុងអនាគាមិមគ្គដោយងាយ ហើយព្រះអនាគាមី រមែងជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីល និង

សមាធិ ព្រោះលោកដកកាមរាគៈនិងព្យាបាទ ដែលជាសត្រូវរបស់សមាធិ បានហើយ ដូច្នោះ ដើម្បីនឹងទ្រង់សម្តែងលោកិយអភិញ្ញាទាំងទឡាយក្នុងឋានៈ ដែលគួរ , ព្រះអង្គទើបត្រាស់ពាក្យមានជាអាទិយ៉ាងនេះថា អាកង្ខេយ្យ ចេ ។ ល ។ អនេកវិហិតំ ដូច្នេះ នេះឯងជាអនុសន្ធិ ។ ការពណ៌នាបាលីនៃ លោកិយអភិញ្ញា សូម្បីទាំង ៥ ដែលមកហើយដោយន័យជាដើមថា អនេក_វិហិតំ ឥទ្ធិវិធឹ ក្នុងបាលីនោះ លោកពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គព្រម ទាំងវិធីធ្វើឱ្យអភិញ្ញាកើត ។

## សេចក្តីសង្ខេប ទី ១៣

គប្បីជ្រាបវិនិច្ឆ័យក្នុងអភិញ្ញា ទី ៦ ដូចតទៅនេះ ÷

បទថា អាសវានំ ខយា សេចក្តីថា ព្រោះការអស់ទៅនៃកិលេស គ្រប់យ៉ាងដោយអរហត្តមគ្គ ។

បទថា អនាសវំ សេចក្តីថា មិនមានអាសវៈ , ក៏ក្នុងពាក្យថា ចេតោវិមុត្តិ បញ្ញាវិមុត្តិ នេះ សមាធិដែលសម្បយុត្តដោយអរហត្តផល លោក ពោលដោយបទថា ចេតោ , បញ្ញា ដែលសហគតដោយអរហត្តមគ្គនោះ លោកពោលទុកដោយពាក្យថា បញ្ញា ។

ក៏ក្នុងសមាធិ និង បញ្ញានោះ សមាធិ គប្បីជ្រាបថា ឈ្មោះថា

ចេតោវិមុត្តិ ព្រោះរួចផុតអំពីរាគៈ , បញ្ញាគប្បីជ្រាបថា ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះរួចផុតអំពីអវិជ្ជា ។ សមពិតដូចពាក្យដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ សមាធិណាគប្បីមាន សមាធិនោះគប្បីជាសមា_ ធិន្ទ្រីយ៍ ម្នាលភិក្ខុទាំងទឡាយ បញ្ញាណាគប្បីមាន បញ្ញានោះគប្បីជាបញ្ញិន្ទ្រីយ៍ ម្នាលភិក្ខុទាំងទឡាយ ឈ្មោះថា ចេតោវិមុត្តិ ព្រោះរួចផុតអំពីរាគៈ ឈ្មោះថា បញ្ញាវិមុត្តិ ព្រោះរួចផុតអំពីអវិជ្ជា យ៉ាងនេះឯង ។

ម្យ៉ាងទៀត ក្នុងអធិការនេះ ផលរបស់សមថៈ គប្បីជ្រាបថា ជាចេតោ_ វិមុត្តិ ផលរបស់វិបស្សនា គប្បីជ្រាបថា ជាបញ្ញាវិមុត្តិ ។

បទថា ទិដ្ឋេវ ធម្មេ បានដល់ ក្នុងអត្តភាពនេះឯង ។

បទថា សយំ អភិញ្ញា សច្ឆិកត្វា សេចក្តីថា ធ្វើឱ្យប្រត្យក្សដោយបញ្ញាខ្លួនឯង អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជាបច្ច័យ ។

បទថា ឧបសម្បជ្ជ វិហរេយ្យំ សេចក្តីថា យើងគប្បីសម្រេច គឺ ឱ្យដល់ព្រម ។

បទថា សីលេស្វេវ សេចក្តីថា ភិក្ខុសូម្បីប្រាថ្នានឹងឱ្យអាសវៈទាំងនោះដល់នូវការរលត់យ៉ាងនេះ បានធ្វើឱ្យជាក់ច្បាស់នូវចេតោវិមុត្តិ និង បញ្ញា_ វិមុត្តិ គប្បីជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងសីលទាំងទឡាយចុះ ។

ព្រះមានព្រះភាគជាម្ចាស់ លុះត្រាស់ពាក្យពណ៌នាអានិសង្សរបស់ សីលរហូតដល់ព្រះអរហត្តយ៉ាងនេះហើយ កាលនឹងទ្រង់រួមសម្តែងអានិសង្សរបស់សីលនោះ សូម្បីទាំងអស់ ទើបត្រាស់ពាក្យចុងក្រោយថា សម្បន្នសីលា ភិក្ខវេ ។ បេ ។ ឥទមេតំ បដិច្ចវុត្តំ ដូច្នេះ ពាក្យចុងក្រោយនោះមានសេចក្តីសង្ខេបដូចតទៅនេះថា ÷

បទថា សម្បន្នសីលា ភិក្ខវេ វិហរថ ។បេ។ សិក្ខាបទេសូតិ ឥតិ យន្តំ វុត្តំ សេចក្តីថា ពាក្យណាដែលតថាគតបានពោលទុកហើយ យ៉ាងនេះក្នុងកាលមុន ពាក្យនោះទាំងអស់ តថាគតពោលសំដៅ គឺ ចំពោះ ( ការដែល ) ភិក្ខុអ្នកសំបូរដោយសីលជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើររបស់ពួកសព្រហ្មចារី ជាអ្នកបានបច្ច័យ , អ្នកធ្វើទាយកដែលថ្វាយបច្ច័យឱ្យមានផលច្រើន ជាអ្នកធ្វើចេតនា គឺ ការរលឹកដល់ខ្លួននៃបុព្វញាតិឱ្យមានផលច្រើន ជាអ្នកគ្របសង្កត់ចំពោះភ័យ និង អារម្មណ៍ដែលគួរស្ញើច ជាអ្នកបានរូបាវចរឈាន និង អរូបាវចរឈាន ជាអ្នកធ្វើឱ្យច្បាស់នូវគុណ ទាំងនេះ គឺ សាមញ្ញផល ៣ ខាងក្រោម លោកិយអភិញ្ញា ៥ អាសវក្ខ-យញ្ញាណ ដោយអភិញ្ញា ដោយខ្លួនឯង ។

ព្រះមានព្រះភាគជាម្ចាស់បានត្រាស់ពាក្យនេះហើយ ភិក្ខុទាំងទឡាយមួយ

អង្គ ៗ ក៏មានចិត្តត្រេកអររីករាយ ក្នុងភាសិតរបស់ព្រះមានព្រះភាគជាម្ចាស់ ដូច្នេះឯង ។

( ចប់ អដ្ឋកថា អាកង្ខេយ្យសូត្រទី ៦ )

# អ ដ្ឋ ក ថា

## វត្ថូបមសូត្រ[១] ទី៧

វត្ថូបមសូត្រ មានពាក្យផ្ដើមថា ឯវម្មេ សុតំ ខ្ញុំម្ចាស់បានស្ដាប់មកហើយយ៉ាងនេះ ) ។

បណ្ដាពាក្យទាំងនោះ ពាក្យនេះថា ភិក្ខវេ យថា វត្ថំ ក្នុងពាក្យ ថា សេយ្យថាបិ ភិក្ខវេ វត្ថំ ជាពាក្យឧបមា ។ ក៏ព្រះមានព្រះភាគ ជាម្ចាស់ កាលនឹងទ្រង់ឧបមា ក្នុងកន្លែងខ្លះទ្រង់សម្ដែងឧបមាមុន ហើយទើបទ្រង់សម្ដែងឧបមេយ្យ ( សេចក្ដី ) ខាងក្រោយ ក្នុងកន្លែងខ្លះទ្រង់សម្ដែងឧបមេយ្យមុនហើយ ទើបទ្រង់សម្ដែងឧបមាខាងក្រោយ ក្នុងកន្លែងខ្លះទ្រង់នាំឧបមាមកសម្ដែងប្រកបឧបមេយ្យ ដើម្បីទ្រង់នាំឧបមេយ្យសម្ដែងប្រកបឧប_ មា ។ ពិតយ៉ាងនោះ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ កាលនឹងទ្រង់ សម្ដែងទេវទូតសូត្រសូម្បីទាំងអស់សម្ដែងឧបមាមុន ហើយសម្ដែងឧបមេយ្យ ក្នុងខាងក្រោយទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ ប្រៀបដូចផ្ទះ ២ ខ្នង មានទ្វារតែមួយ បុគ្គលអ្នកមានភ្នែកល្អ ឈរនៅត្រង់កណ្ដាល រមែងសម្លឹង ឃើញក្នុងផ្ទះ ២ ខ្នងនោះបាន ( រហូត ) ។

---

១ អដ្ឋកថា ហៅថា វត្ថសូត្រ

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងឧបមេយ្យ ( សេចក្តី ) ដែលជាឥទ្ធិវិធីសូម្បីទាំងអស់មុន ហើយសម្តែងឧបមាក្នុងខាង ក្រោយ ទើបត្រាស់ដោយន័យជាដើមថា អ្នកមានឫទ្ធិរមែងដើរទម្លុះចេញខាង ក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំក៏បាន ប្រៀបដូចដើរទៅក្នុងអាកាស (ទី វាល) ដូច្នោះ ។

ម្យ៉ាងទៀត កាលនឹងទ្រង់យកឧបមាមកហែហម (សម្តែងប្រកប) ឧប_មេយ្យ ទើបបានត្រាស់ចុល្លសារោបមសូត្រសូម្បីទាំងអស់ ដោយន័យជាដើមថា ម្នាលព្រាហ្មណ៍ ប្រៀបដូចបុគ្គលអ្នកមានសេចក្តីត្រូវការខ្លឹមឈើ ទើបស្វែងរក ខ្លឹមឈើ ដូច្នោះ ។ ម្យ៉ាងទៀត កាលនឹងទ្រង់យកឧបមេយ្យ ( សេចក្តី ) មកព័ទ្ធ ( សម្តែងប្រកប ) ឧបមា ទើបត្រាស់សូត្រទាំងទឡ្បាយមានអលគទ្ទ_ សូត្រ និង មហាសារោបមសូត្រ ជាដើម សូម្បីទាំងអស់ដោយន័យជាដើម ថា ម្នាលភិក្ខុទាំងទឡ្បាយ កុលបុត្រពួកខ្លះក្នុងលោកនេះ រមែងរៀនយកធម៌ គឺ សុត្តៈ ។ ល ។ ប្រៀបដូចបុរស អ្នកមានសេចក្តីត្រូវការដោយអាសិរពិស ដូច្នោះណា ភិក្ខុទាំងទឡ្បាយ ។ ព្រះមានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់សម្តែង ពាក្យឧបមាមុនក្នុងទីនេះ ហើយទ្រង់សម្តែងឧបមេយ្យក្នុងខាងក្រោយ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់សម្តែង

យ៉ាងនេះ ?

ឆ្លើយថា ព្រោះអធ្យាស្រ័យរបស់បុគ្គល ឬ ព្រោះទ្រង់ផ្លាស់ប្តូរទេសនា ។

ពិតណាស់ បុគ្គលពួកណាយល់ឧបមេយ្យដែលព្រះអង្គត្រាស់សម្តែងឧបមាទុកមុនបានដោយងាយ ព្រះមានព្រះភាគជាម្ចាស់ រមែងទ្រង់សម្តែងឧបមាមុនដល់កុលបុត្រទាំងនោះ ។ គ្រប់ ៗ បទក៏ន័យនេះ ។ ម្យ៉ាងទៀត ព្រោះទ្រង់ចាក់ធ្លុះធម្មធាតុណាដោយល្អ ព្រះមានព្រះភាគជាម្ចាស់ទើបឈ្មោះ ថា ទ្រង់ជំនាញក្នុងការផ្លាស់ប្តូរទេសនាធម្មធាតុនោះ ដែលព្រះអង្គទ្រង់ចាក់ធ្លុះដោយល្អហើយ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះ ទើបទ្រង់ជា ធម្មិស្សរធម្មរាជា ជំនាញក្នុងការផ្លាស់ប្តូរព្រះធម៌ទេសនា ព្រះអង្គរមែងទ្រង់សម្តែងធម៌បានតាមដែលទ្រង់ប្រាថ្នា ដោយប្រការដូចពោលមកនេះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់រមែងទ្រង់សម្តែង ( ធម៌ ) យ៉ាងនេះ គឺទាំងព្រោះ( តាម) អធ្យាស្រ័យរបស់បុគ្គល ទាំងព្រោះទ្រង់ប្តូរទេសនានេះ ។

បណ្តាបទទាំងនោះ បទថា វត្ថំ បានដល់ សំពត់ស្អាតតាមប្រក្រតី ។

បទថា សង្កិលិដ្ឋំ មលគ្គហិតំ សេចក្តីថា ឈ្មោះថា សៅហ្មង ហើយ ព្រោះគ្រឿងសៅហ្មង មានផង់ធូលីជាដើម ដែលរសាត់មកទំ និង ឈ្មោះថា ដែលមន្ទិលកាន់ហើយ ព្រោះត្រូវមន្ទិលមានដំណក់ញើសជាដើម

ជាប់ហើយ ។

វង្គជាត ក្នុងបទថា វង្គជាតេ នេះ បានដល់ ទឹកជ្រលក់នោះឯង ។

បទថា ឧបសំហរេយ្យ ប្រែថា គប្បីបង្អោនចូលទៅ ។

បទថា យទិ នីលកាយ លោកពោលអធិប្បាយទុកថា ដើម្បីត្រូវការឱ្យមានពណ៌ខៀវ ។ គ្រប់ ១ បទក៏យ៉ាងនេះ ។ ពិតណាស់ ជាងជ្រលក់ កាលនឹងនាំសំពត់ទៅជ្រលក់ ដើម្បីត្រូវការឱ្យមានពណ៌ខៀវ ក៏នឹងនាំសំពត់ទៅដាក់ត្រាំក្នុងទឹកជ្រលក់ពណ៌ខៀវ មានពណ៌ខ្មៅសម្រិត និង ពណ៌ខៀវ ស្លឹកឈើជាដើម កាលនឹងនាំយកសំពត់ទៅជ្រលក់ ដើម្បីត្រូវការឱ្យជា ពណ៌លឿង ក៏នឹងនាំយកសំពត់ទៅដាក់ត្រាំក្នុងទឹកជ្រលក់ពណ៌លឿង ដូចជា ផ្កាកណ្ណិការ៍ កាលនឹងនាំយកសំពត់ទៅជ្រលក់ដើម្បីត្រូវការឱ្យជាពណ៌ក្រហម , ក៏នឹងនាំយកសំពត់ទៅដាក់ត្រាំក្នុងទឹកជ្រលក់ពណ៌ក្រហម ដូចជាផ្កាចម្បា កាលនាំយកសំពត់ ទៅជ្រលក់ដើម្បីត្រូវការឱ្យជាពណ៌ហង្សបាទ ក៏នឹងនាំយកសំពត់ទៅដាក់ត្រាំក្នុង ទឹកជ្រលក់ពណ៌ហង្សបាទ ដូចជាផ្កាកណវីរៈ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា យទិ នីលកាយ ។បេ។ យទិ មញ្ជេដ្ឋិកាយ ដូច្នេះ ។

បទថា ទុរត្តវណ្ណមេវស្ស បានដល់ សំពត់នោះក៏នៅតែមានពណ៌

មិនល្អ មានពណ៌មិនស្អាតដដែល ។

បទថា អបរិសុទ្ធវណ្ណមេវស្ស សេចក្តីថា សូម្បីពណ៌ខៀវរបស់សំពត់នោះក៏មិនស្រស់ស្អាត សូម្បីពណ៌លឿង ( ក៏មិនស្រស់ស្អាតដូចគ្នា ) ។ ជាការពិត សំពត់ដូច្នោះ សូម្បីគេដាក់ត្រាំទៅក្នុងឆ្នាំងទឹកជ្រលក់ពណ៌ខៀវក៏មិនជាពណ៌ខៀវសុទ្ធ ។ សូម្បីដាក់ត្រាំទៅក្នុងឆ្នាំងទឹកជ្រលក់ដ៏សេស ក៏នឹងមិនជាពណ៌សុទ្ធ មានពណ៌លឿងសុទ្ធជាដើម រមែងមានពណ៌ខៀវស្លេក ពណ៌ស្មៅកន្ទុយដំរីក្រៀម ពណ៌ផ្កាកណ្ណិការក្រៀម ពណ៌ផ្កាចំប៉ាក្រៀម និងពណ៌ផ្កាកណវីរៈក្រៀមប៉ុណ្ណោះ ។

បទថា តំ កិស្ស ហេតុ សេចក្តីថា សំពត់នោះដូច្នេះ ព្រោះ ហេតុអ្វី គឺព្រោះមានអ្វីជាហេតុ ម្យ៉ាងទៀត ទឹកជ្រលក់សំពត់នោះដូច្នេះ គឺ មានពណ៌មិនស្អាតមិនស្រស់ស្អាត ព្រោះហេតុអ្វី ? ក៏ព្រោះផ្ទាំងសំពត់ នោះមិនស្អាតនុ៎ះឯងជាហេតុក្នុងសេចក្តីនេះ មិនមែនហេតុអ្វីដទៃ ដូច្នោះព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា អបរិសុទ្ធត្តា ភិក្ខវេ វត្ថស្ស ដូច្នេះ ។ ពាក្យថា **ឯវមេវ** ជាពាក្យឧបមេយ្យ ។

ពីរបទថា ចិត្តេ សង្កិលិដ្ឋេ សេចក្តីថា កាលបើចិត្តសៅហ្មង ហើយ ។

ប្រសិនបើមានពាក្យសួរជ្រៀតចូលមកថា ក៏ព្រោះហេតុអ្វី ព្រះមាន-ព្រះភាគជាម្ចាស់ ទើបបានទ្រង់ធ្វើពាក្យឧបមាទុកដោយសំពត់ដែលសៅហ្មង ។

ឆ្លើយថា ដើម្បីទ្រង់សម្តែងថា ការព្យាយាមមានផលច្រើន ។ ប្រៀបដូចសំពត់ដែលសៅហ្មង ព្រោះមន្ទិលដែលរសាត់មកកាន់ កាលបោកម្តង ទៀតរមែងសស្អាត ព្រោះតាមប្រក្រតីជារបស់សស្អាតហើយ ការព្យាយាម ក្នុង ( ការបោក ) សំពត់នោះនឹងឥតផល ដូចការព្យាយាមក្នុង ( ការបោក សំអាត ) រោមចៀមដែលខ្មៅពីធម្មជាតិ ( ឱ្យសស្អាត ) ក៏ទេ យ៉ាងណា ។ សូម្បីចិត្តដែលសៅហ្មងព្រោះកិលេសទាំងទឡាយដែលចរមក ក៏ដូច្នោះ ( គឺ ) ក៏តាមប្រក្រតី ចិត្តនោះរមែងជាធម្មជាតិដែលស្អាតក្នុងវារៈបដិសន្ធិចិត្ត និងភវង្គចិត្ត ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ចិត្តនេះជាធម្មជាតិបរិសុទ្ធ ក៏ចិត្តនុ៎ះឯងសៅហ្មងទៅព្រោះឧបកិលេសដែលចរមក ចិត្តនោះ កាលបានទទួលការជម្រះឱ្យបរិសុទ្ធិ បុគ្គលក៏អាចធ្វើឱ្យបរិសុទ្ធក្រៃលែងទេឡើងទៀតបាន សេចក្តីព្យាយាមក្នុងការជម្រះចិត្តនោះ រមែងមិនឥតផលទេឡើយ ។ ព្រះមានព្រះភាគ បណ្ឌិតគប្បីជ្រាប ថាទ្រង់ធ្វើពាក្យឧបមាដោយសំពត់ដែលសៅហ្មង ដើម្បីនឹងទ្រង់សម្តែងថា ការព្យាយាមមានផលច្រើនដោយប្រការដូច្នេះ ។

បទថា ទុគ្គតិ បាតិកង្ខា សេចក្តីថា កាលចិត្តជូច្នេះ ទុគ្គតិជាការដែលបុគ្គលគប្បីសង្ឃឹមបាន លោកអធិប្បាយទុកថា ទុគ្គតិជាគតិដែលគេគប្បីសង្ឃឹមបានយ៉ាងនេះថា អ្នកនេះនឹងដល់ទុគ្គតិពិតប្រាកដ មិនដល់គតិ ដទៃដូច្នេះ គឺ ទុគ្គតិជាគតិដែលគេមានចំណែករួមយ៉ាងនេះ ។ ក៏ឈ្មោះថាទុគ្គតិនេះនោះ មាន ២ យ៉ាងគឺ បដិបត្តិទុគ្គតិ និង គតិទុគ្គតិ ។ សូម្បីបដិបត្តិទុគ្គតិក៏មាន ២ យ៉ាងគឺ អាគារិយបដិបត្តិទុគ្គតិ និង អនាគារិយ-បដិបត្តិទុគ្គតិ ។ អធិប្បាយថា គ្រហស្ថមានចិត្តសៅហ្មង រមែងសម្លាប់សត្វ ខ្លះរមែងលួចទ្រព្យខ្លះ រមែងប្រព្រឹត្តអកុសលកម្មបថ ១០ ទាំងអស់ខ្លះ នេះឈ្មោះថាអាគារិយបតិបត្តិទុគ្គតិ របស់គ្រហស្ថនោះ ។ គ្រហស្ថនោះតាំងនៅក្នុងអត្តភាពនោះហើយ លុះកាយបែកធ្លាយ ( ស្លាប់ទៅ ) រមែងទៅកាន់នរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ ប្រេតវិស័យខ្លះ នេះឈ្មោះថា គតិ-ទុគ្គតិរបស់គ្រហស្ថនោះ ។ ចំណែកបព្វជិត បួសក្នុងសាសនានេះហើយ មានចិត្តសៅហ្មង យកអាសារទទួលបម្រើអ្នកដទៃ ធ្វើខ្លួនជាពេទ្យ ព្យាយាមបំបែកសង្ឃ ទម្លាយចេតិយស្ថាន ចិញ្ចឹមជីវិតដោយការឱ្យឫស្សីជាដើម ប្រព្រឹត្តអានាចារ និង ត្រាច់ទៅកាន់ទីអគោចរសូម្បីទាំងអស់ នេះឈ្មោះថា អានា-គារិយបដិបត្តិទុគ្គតិ របស់បព្វជិតនោះ ។ បព្វជិតនោះ តាំងនៅក្នុងអត្តភាព

នោះហើយ លុះកាយបែកធ្លាយ ( មរណភាព ) រមែងទៅកាន់នរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ ប្រេតវិស័យខ្លះ ឈ្មោះថា ជាសមណយក្ស សមណ–ប្រេត មានកាយឆេះសន្ធោសន្ធៅដោយសំពត់សង្ឃាដិជាដើម ដែលត្រូវភ្លើង ឆេះហើយ មានសម្លេងស្រែកថ្ងូរយំ ត្រាច់ទៅ ឈ្មោះថា គតិទុគ្គតិ របស់ បព្វជិតនោះ ។

បទថា សេយ្យថាបិ សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ផ្តើម សម្តែងធមិស ( សុគតិ ) ។ សេចក្តីនៃធមិសនោះ គប្បីជ្រាបដោយធមិ ផ្ទុយគ្នា ដែលលោកពោលទុកហើយក្នុងធមិខ្មៅ ( ទុគ្គតិ ) នោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា សុគតិ សូម្បីក្នុងទីនេះក៏មាន ២ យ៉ាងគឺ បដិបត្តិ– សុគតិ និង គតិសុគតិ ។ សូម្បីបដិបត្តិសុគតិក៏មាន ២ យ៉ាងគឺ អាគារិយបដិបត្តិសុគតិ និង អនាគារិយបដិបត្តិសុគតិ ។ អធិប្បាយថា គ្រហស្ថមានចិត្តបរិសុទ្ធ រមែងវៀរចាកការសម្លាប់សត្វខ្លះ ចាកការលួចទ្រព្យ ខ្លះ បំពេញកុសលកម្មបថ ១០ ទាំងអស់ខ្លះ នេះឈ្មោះថា អគារិយ–បដិបត្តិសុគតិរបស់គ្រហស្ថនោះ ។ គ្រហស្ថនោះ តាំងនៅក្នុងអត្តភាពនោះ ហើយ លុះកាយបែកធ្លាយ ( ស្លាប់ទៅ ) រមែងចូលដល់ភាពជាធំក្រៃលែង ក្នុងពួកមនុស្សខ្លះ ភាពជាធំក្រៃលែងក្នុងពួកទេវតាខ្លះ នេះឈ្មោះថា គតិ–

សុគតិរបស់គ្រហស្ថនោះ ។ ចំណែកបព្វជិតបួសក្នុងសាសនានេះ មានចិត្ត បរិសុទ្ធិ រក្សាបារិសុទ្ធិសីល ៤ បរិសុទ្ធ សមាទានធុតង្គ ១៣ រៀនយកកម្មដ្ឋានដែលសមគួរដល់ខ្លួនក្នុងអារម្មណ៍ ៣៨ នៅក្នុងសេនាសនៈដ៏ស្ងាត់ ធ្វើបរិកម្មកសិណ ( រហូត) ឱ្យកើតឈានសមាបត្តិ បានសម្រេចសោតា_បត្តិមគ្គ ។ ល ។ បានសម្រេចអនាគាមិមគ្គ នេះឈ្មោះថា អនាគារិយ_ បដិបត្តិសុគតិរបស់បព្វជិតនោះ ។ បព្វជិតនោះតាំងនៅក្នុងអត្តភាពនោះ ហើយកាលកាយបែកធ្លាយ ( មរណភាព ) រមែងកើតក្នុងត្រកូលធំ ៣ ត្រកូលក្នុងមនុស្សលោកខ្លះ ក្នុងទេវតាជាន់កាមាវចរ ៦ ជាន់ខ្លះ ក្នុងភព នៃព្រហ្ម ១០ ជាន់ខ្លះ ក្នុងជាន់សុទ្ធាវាស ៥ ជាន់ខ្លះ ក្នុងអរូបភព ៤ ខ្លះ នេះឈ្មោះថា គតិសុគតិ របស់បព្វជិតនោះ ។

ព្រះមានព្រះភាគជាម្ចាស់ លុះត្រាស់ថា កាលបើចិត្តសៅហ្មងទុគ្គតិនឹងមានប្រាកដ ហើយកាលបើចិត្តមិនសៅហ្មង សុគតិនឹងមានប្រាកដ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងឧបក្កិលេសទាំងឡាយដែលជាហេតុឱ្យចិត្តសៅហ្មង ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ក៏ឧប_ក្កិលេសនៃចិត្តតើដូចម្ដេច ? គឺ វិសមលោភៈ ដូច្នេះ ។ បណ្ដាឧបកិ_លេសទាំងនោះ ការស្រេកឡាញ់ ការពេញចិត្តក្នុងភណ្ឌៈរបស់ខ្លួន ឈ្មោះថា

អភិជ្ឈា ការស្រេទឡាញ់ ការពេញចិត្តក្នុងភណ្ឌៈរបស់អ្នកដទៃ ឈ្មោះថា វិសមលោភៈ ។ម្យ៉ាងទៀត ការស្រេទឡាញ់ ការពេញចិត្តក្នុងភណ្ឌៈរបស់ ខ្លួន ឬ របស់អ្នកដទៃចូរលើទុក ការស្រេទឡាញ់ ការពេញចិត្តក្នុងឋានៈដែល ត្រូវ ដែលគួរ ឈ្មោះថា អភិជ្ឈា ការស្រេទឡាញ់ ការពេញចិត្តក្នុងឋានៈ ដែលមិនត្រូវ មិនគួរ ឈ្មោះថា វិសមលោភៈ ។ ចំណែកព្រះថេរៈពោល ទុកថា លោភៈគ្រប់យ៉ាងនឹងមិនឈ្មោះថា វិសមៈក៏ទេ ព្រោះព្រះបាលីថា ពួកលោកធ្វើការបែងចែកទៅធ្វើអ្វី ? នឹងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលសម_គួរ ឬ មិនសមគួរក៏ដោយ រាគៈក៏ជាវិសមៈ ទោសៈក៏ជាវិសមៈ មោហៈក៏ជា វិសមៈដូចគ្នា ព្រោះដូច្នោះ លោភៈនេះ នុះឯង ឈ្មោះថា អភិជ្ឈា ព្រោះអត្ថថា សម្លឹងរំពៃ ឈ្មោះថា វិសមៈ ព្រោះអត្ថថា មិនស្មើ ( មិន ប្រពៃតាមធម៌ ) ពាក្យថា អភិជ្ឈា និង វិសមៈ នេះ មានសេចក្តីដូចគ្នា ផ្សេងគ្នាត្រឹមតែព្យញ្ជនៈប៉ុណ្ណោះ ។ ក៏អភិជ្ឈាវិសមលោភៈនេះនោះ កើត ទឡើងហើយ រមែងប្រទុសរ៉ាយចិត្ត គឺ មិនឱ្យចិត្តថ្លាបរិសុទ្ធ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ។ ដូចយ៉ាងថា អភិជ្ឈាវិសមលោភៈនេះយ៉ាងណា ព្យាបាទដែលកើតអំពីអាឃាត វត្ថុ ( ហេតុជាទីតាំងនៃអាឃាត ) ៩ យ៉ាង សេចក្តីក្រោធដែលកើតមក

អំពីអាឃាតវត្ថុ ១០ យ៉ាង ការចងសេចក្តីក្រោធ ដែលគ្របដណ្តប់ចិត្ត រឿយ ៗ ក៏ដូច្នោះ ការលុបគុណ ដែលធ្វើគុណដែលគេធ្វើល្អហើយឱ្យវិនាស ទៅ មិនថារបស់គ្រហស្ថ ឬ របស់បព្វជិត ( មានលក្ខណៈដូចគ្នា ) អធិប្បាយថា ពួកគ្រហស្ថ ( ដើមទី ) ជាមនុស្សខ្វះខាត ( លុះក្រោយ មក ) អ្នកមានករុណាខ្លះ បានលើក ( គេ ) ទុកក្នុងឋានៈខ្ពង់ខ្ពស់ តមក ( គេត្រទទ្បប់ពោលថា ) លោកធ្វើអ្វីខ្លះឱ្យខ្ញុំម្ចាស់ ឈ្មោះថា ទម្លាយសេចក្តី ល្អដែលអ្នកមានករុណានោះធ្វើទុកហើយឱ្យវិនាសទៅ ចំណែកបព្វជិតវិញ ចាប់ផ្តើមតាំងតែសម័យនៅជាសាមណេរតូច ដែលអាចារ្យ ឬ ឧបជ្ឈាយ៍ អង្គណាមួយអនុគ្រោះដោយបច្ច័យ ៤ និង ដោយឧទ្ទេស និង បរិបុច្ឆា ដាស់តឿនឱ្យសិក្សាដើម្បីភាពជាអ្នកឆ្លាតក្នុងបករណ៍ជាដើម ដោយធម្មកថា សម័យតមកជាអ្នកដែលព្រះរាជា និង រាជមហាអាមាត្យជាដើម ធ្វើសក្ការៈ-បូជាគោរពហើយ ( លោក ) ត្រទទ្បប់ខ្វះការគោរពកោតក្រែងក្នុងអាចារ្យ និង ឧបជ្ឈាយ៍ទៅវិញ ដែលអាចារ្យជាដើមពោលថា អ្នកនេះកាលគេនៅ ក្មេង យើងទាំងទទ្បាយជួយអនុគ្រោះ និង លើកស្ទួយឱ្យឈានទៅមុខយ៉ាងនេះ ក៏ប៉ុន្តែថា ឥទទ្បូវនេះ គេមិនគួរស្រទទ្បាញ់ទេឡើយ ហើយក៏ពោល ( ឆ្លើយ ) ថា ពួកលោកធ្វើអ្វីដល់ខ្ញុំ ដូច្នេះ ឈ្មោះថា ទម្លាយសេចក្តីល្អដែលឧបជ្ឈាយ៍

និង អាចារ្យទាំងនោះធ្វើទុកហើយឱ្យវិនាសទៅ ការលប់បគុណចំពោះអំពើល្អដែលលោកធ្វើទុកហើយឱ្យវិនាសទៅរបស់បព្វជិតនោះ រមែងកើតទឡើងប្រទុស-រ៉ាយចិត្ត គឺ មិនឱ្យចិត្តបរិសុទ្ធិផូរផង់ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ធមិជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ ។ ការលប់គុណនេះជាឧបក្កិលេសយ៉ាងណា ការវាយបូកស្មើ ( ដែលបានដល់ ) ការប្រកាន់ជាគូរប្រជែងក៏ដូច្នោះ កើតទឡើងរាលដាលទៅអាងដល់បុគ្គល សូម្បីជាពហុស្សូត ដោយន័យជាដើមថា លោកជាពហុស្សូតដូច្នេះ នៅមានគតិមិនពិតប្រាកដ ( ហើយ ) លោក និង ខ្ញុំមានអ្វីពិសេសទៅ ។ ឥស្សា បានដល់ការច្រណែនសក្ការៈជាដើមរបស់អ្នកដទៃ ។ សេចក្តីកំណាញ់ បានដល់ ( ការដែល ) ទ្រាំមិនបានដល់សម្បត្តិរបស់ខ្លួន ព្រោះមាន អ្នកដទៃរួមប្រើប្រាស់ ។ មាយា បានដល់ កិរិយាដែលជាការប្រព្រឹត្តិបោក- បញ្ឆោត ។ ការអួតអាងកើតទឡើងដោយ ( ធ្វើឱ្យ ) ជាអ្នកនិយាយច្រើន ។ ពិតហើយ អ្នកនិយាយច្រើនរមែងដូចជាត្រីអានន្ទ ។

ដំណាលមកថា ត្រីអានន្ទឃើញពួកត្រីមកក៏បង្ហាញកន្ទុយថា យើងជាត្រីដូចគ្នា ឃើញពួកពស់មកក៏បង្ហាញក្បាលថា យើងជាពស់ដូចគ្នា ។ បុគ្គលអ្នកអួតអាងក៏ដូច្នោះដូចគ្នា ចូលទៅរកអ្នកព្រះសូត្រ ឬ អ្នកអភិធម្ម

ណា ៗ រមែងពោលនឹងលោកនោះយ៉ាងនេះថា ខ្ញុំប្រព្រឹត្តប្រយោជន៍ដើម្បីអ្នកទាំងទឡាយ អ្នកទាំងទឡាយត្រូវអនុគ្រោះខ្ញុំ ខ្ញុំនឹងមិនចោលពួកអ្នកទេ ដូច្នេះ ។ កាលដូច្នេះឯង អ្នកព្រះសូត្រ និង អ្នកអភិធម្មទាំងនោះ ក៏នឹងសម្គាល់ ( លោក) ថា អ្នកនេះមានការគោរពកោតក្រែងចំពោះយើង ទាំងទឡាយ ការអួតអាងនេះឯងរបស់បុគ្គលនោះ កាលកើតទេឡីងដោយ ( ធ្វើ ឱ្យ ) ជាមនុស្សនិយាយច្រើន រមែងកើតទេឡីងប្រទុសរ៉ាយចិត្ត គឺ មិនឱ្យចិត្ត បរិសុទ្ធផូរផង់ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ធម៌ជា គ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ ។ ដូចយ៉ាងថា ការអួតអាងនេះយ៉ាងណា សេចក្ដីរឹងថ្អឹងក៏ដូច្នោះ ជាតួធ្វើមិនឱ្យប្រព្រឹត្តឱនលំទោន ងើយក្បាល ព្រោះ ជាអ្នករឹងថ្អឹង ប្រៀបដូចផ្លោកស្បែកដែលពេញដោយខ្យល់ ។ ការប្រណាំង ប្រជែង មានការធ្វើអំពើឱ្យក្រៃលែងជាងនោះ , ការប្រណាំងប្រជែងនោះ ចែកចេញជា ២ ប្រភេទ គឺ ចំណែកអកុសល និង កុសល ។ ក៏ក្នុង បណ្ដាការប្រណាំងប្រជែង ២ ប្រភេទនោះ សម្រាប់គ្រហស្ថ ការប្រទឡង ប្រណាំងកើតទេឡីង ព្រោះបានឃើញគ្រឿងប្រដាប់ ជាដើម ដែលអ្នកដទៃ ប្រដាប់ហើយ ហើយធ្វើឱ្យជាទ្វេគុណ ៗ ទេឡីងទៅជាងនោះ ៗ ចាត់ជា អកុ_សល , ចំណែកបព្វជិត ( ខណៈដែល) បព្វជិតដទៃ រៀនសូធ្យ ឬ

ពោលធម៌មានប្រមាណប៉ុណ្ណា ៗ ការប្រណាំងប្រជែងដែលកើតទេឡើងដោយការធ្វើឱ្យទ្វេគុណ ៗ ទៅជាងនោះ ៗ ដោយអំណាចនៃមានះ ចាត់ជាអកុ_សល ។ ចំណែកគ្រហស្ថ ការប្រណាំងប្រជែងដែលកើតទេឡើង ព្រោះបានឃើញអ្នកដទៃថ្វាយសាលាកភត្ត ១ សម្រាប់ ហើយខ្លួនឯងប្រាថ្នានឹងថ្វាយ ២ ឬ ៣ សម្រាប់ចាត់ជាកុសល ។ ចំណែកបព្វជិត កាល ( បានជ្រាប ថា ) ភិក្ខុដទៃរៀនបាន ១ និកាយហើយ ការប្រណាំងប្រជែងកើតទេឡើងដោយមិនអាស្រ័យមានះ ( តែ ) ព្រោះបានឃើញភិក្ខុដទៃនោះ ( រៀនបាន ១ និកាយហើយ ) ហើយប្រាថ្នានឹងគ្របសង្កត់ការខ្ជិលច្រអូសរបស់ខ្លួនតែ ម្យ៉ាង រៀនយកឱ្យបាន ២ និកាយ ចាត់ជាកុសល ។ តែក្នុងទីនេះប្រាថ្នាយកការប្រណាំងប្រជែងដែលជាអកុសល ។ ព្រោះថា ការប្រណាំងប្រជែងដែលជាអកុសលនេះ រមែងកើតទេឡើងប្រទុសរ៉ាយចិត្ត គឺ មិនឱ្យចិត្តផ្សរផង់ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ជាគ្រឿងសៅ_ហ្មងនៃចិត្ត ។ ម្យ៉ាងទៀត ការប្រណាំងប្រជែងនេះយ៉ាងណា ការប្រកាន់ខ្លួនក៏យ៉ាងនោះ ប្រព្រឹត្តទៅដោយអំណាចការពង្រីកឱ្យធំទេឡើងនៃចិត្ត ព្រោះអាស្រ័យជាតិ ( កំណើត ) ជាដើម មានះដែលប្រព្រឹត្តទៅដោយអំណាចការពង្រីកឱ្យធំទេឡើងក្រៃលែងនៃចិត្ត ឈ្មោះថា អតិមានះ អាការដែលទទួល

យកដោយការស្រវឹង ឈ្មោះថា មទ មទៈដែលកើតទេឡើងដោយអំណាចការបណ្តោយចិត្តទៅក្នុងកាមគុណទាំងទឡាយ ឈ្មោះថា បមាទ បមាទៈរមែងកើតទេឡើងប្រទុស្តរ៉ាយចិត្ត គឺ មិនឱ្យចិត្តបរិសុទ្ធផ្សរផង់ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ធម៌ជាគ្រឿងសៅហ្មងនៃចិត្ត ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងឧបក្កិលេស ទើបទ្រង់សម្តែងលោភៈទុកជាលំដាប់ដំបូង ។

ឆ្លើយថា ព្រោះលោភៈនោះកើតទេឡើងមុនគេបង្អស់ ។

ពិតណាស់ កាលសត្វទាំងពួងកើតទេឡើងក្នុងភពណាមួយ ដោយទី បំផុតសូម្បីក្នុងភូមិសុទ្ធាវាស លោភៈរមែងកើតទេឡើងមុនគេបង្អស់ដោយអំណាចសេចក្តីត្រេកអរក្នុងភព តពីនោះ ឧបក្កិសេលក្រៅពីនេះមានព្យាបាទជាដើម រមែងកើតតាមសមគួរដល់បច្ច័យ ព្រោះអាស្រ័យបច្ច័យដែលសមគួរដល់ខ្លួន ហើយមិនមែនដល់តែឧក្កិលេសរបស់ចិត្ត ១៦ យ៉ាងនេះ ប៉ុណ្ណោះទេដែលកើតទេឡើង តែគប្បីជ្រាបថា ការពោលដោយន័យនេះ រមែងជាការដែលរួមយកកិលេសសូម្បីទាំងអស់ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងកិលេសជាគ្រឿងសៅហ្មងដោយពាក្យអធិប្បាយត្រឹមប៉ុណ្ណោះហើយ ឥទឡូវនេះ កាលនឹងទ្រង់សម្តែង

ភាពបរិសុទ្ធិ ទើបត្រាស់ពាក្យជាដើមថា ស ខោ សោ ភិក្ខវេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ឥតិ វិទិត្វា ប្រែថា លុះដឹងយ៉ាងនេះ ។

បទថា បជហតិ សេចក្តីថា លះបង់ ( ឧបក្កិលេសនៃចិត្ត ) ដោយអរិយមគ្គដោយអំណាចនៃសមុច្ឆេទប្បហាន ។

ក្នុងបទថា បជហតិ នោះ គប្បីជ្រាបការលះបង់មាន ២ យ៉ាង គឺ ( លះបង់ ) តាមលំដាប់កិលេស និង តាមលំដាប់មគ្គ ។ ( នឹង អធិប្បាយការលះបង់ ) តាមលំដាប់កិលេសមុន , កិលេស ៦ យ៉ាងនេះ គឺ អភិជ្ឈាវិសមលោភៈ ( សេចក្តីលោភដោយមិនប្រពៃ គឺ ការសម្លឹងរំពៃ) ថម្ភ ( ចចេសមុខរឹង) សារម្ភ ( ប្រណាំងប្រជែង) មានះ ( ប្រកាន់ ខ្លួន) អតិមានះ ( មើលងាយគេ) មទ ( ស្រវឹង) រមែងលះបង់ បានដោយអរហត្តមគ្គ ។ កិលេស ៤ ពួកនេះ គឺ ព្យាបាទ ( ការព្យាបាទ) កោធ ( សេចក្តីក្រោធ) ឧបនាហ ( ការចងសេចក្តីក្រោធទុក) បមាទ ( ការធ្វេសប្រហែស) រមែងលះបង់ដោយអនាគាមិមគ្គ ។ កិលេស ៦ យ៉ាងនេះ គឺ មក្ខ ( លុបគុណគេ ) បលាស ( ការវាយឫកស្មើ ) ឥស្សា ( ការច្រណែន) មច្ឆរិយ ( កំណាញ់ស្វិត) មាយា ( មារយា លាក់ពុត , បោកប្រាស់ ) សាថេយ្យ ( អួតអាង ) រមែងលះបង់

## ៥៣៧ អដ្ឋកថា វត្ថូបមសូត្រ ទី៧

ដោយសោតាបត្តិមគ្គ ។ ចំណែកការលះបង់តាមលំដាប់មគ្គ នឹងអធិប្បាយដូចតទៅនេះ ÷

កិលេស ៦ យ៉ាងនេះ គឺ មក្ខ ( បំភ្លេចគុណគេ ) បលាស ( វាយឫកស្មើ ) ឥស្សា ( ការច្រណែន ) មច្ឆរិយ ( កំណាញ់ ស្វិត) មាយា ( មាយាលាក់ពុត , បោកប្រាស់ ) សាថេយ្យ ( អួត អាង ) រមែងលះបង់ដោយសោតាបត្តិមគ្គ ។ កិលេស ៤ យ៉ាងនេះ គឺ ព្យាបាទ ( ការព្យាបាទ) កោធ ( ការក្រោធ ) ឧបនាហ ( ការ ចងសេចក្ដីក្រោធទុក) បមាទ ( ការធ្វេសប្រហែស) រមែងលះបង់ ដោយអនាគាមិមគ្គ ។ កិលេស ៦ យ៉ាងនេះ គឺ អភិជ្ឈាវិសមលោភៈ សេចក្ដីលោភដោយមិនប្រពៃ គឺ ការសម្លឹងរំពៃ ថម្ភ (រឹងថ្អឹង) សារម្ភ (ការប្រណាំងប្រជែង) អតិមានះ (មើលងាយគេ) មទ ( ស្រវឹង ) រមែងលះបង់ដោយអរហត្តមគ្គ ។ តែក្នុងទីនេះ កិលេសទាំងនោះនឹងត្រូវ សម្លាប់ដោយសោតាបត្តិមគ្គ ឬ ត្រូវសម្លាប់ដោយមគ្គដ៏សេសក៏ដោយ ដូច្នេះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ពាក្យជាដើមថា បុគ្គលរមែង លះបង់អភិជ្ឈាវិសមលោភៈដែលជាគ្រឿងសៅហ្មងនៃចិត្ត ដូច្នេះ ទ្រង់សំដៅយកការលះបង់ដោយអនាគាមិមគ្គនោះឯង ។ នេះជាការកើត (នៃផល)

ដែលមកហើយតាមមគ្គ ដែលបន្តគ្នាក្នុងទីនេះ ។ ក៏ព្រោះព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្ដែងមគ្គទី ៤ ទុកក្នុងលំដាប់ថ្នាក់ខ្ពស់បំផុតហើយ ការកើតនៃផលនោះទើបនឹងត្រូវឧបក្កិលេស មានវិសមលោភៈជាដើមដ៏សេសពីឧបក្កិលេសដែលលះបង់បានហើយដោយតតិយមគ្គ រមែងជាការដែលលះបង់បានដោយមគ្គទី ៤ នោះ ។ កិលេសដ៏សេសរមែងជាការដែលលះបង់បានដោយមគ្គទី ៤ នេះ ដូចគ្នា ។ ព្រោះថា ឧបក្កិលេស មានមក្ខៈជាដើមសូម្បីពួកណា រមែងលះបានដោយសោតាបត្តិមគ្គ ឧបក្កិលេសសូម្បីពួកនោះរមែងជាការដែលលះបង់បានដាច់ជាសមុច្ឆេទហើយ ដោយអនាគាមិមគ្គនុ៎ះឯង ព្រោះចិត្តដែលជាសមុដ្ឋាននៃឧបក្កិលេសមានមក្ខៈជាដើមនោះ នៅមិនទាន់បានលះបង់ដាច់ជាសមុច្ឆេទ ( ដោយសោតាបត្តិមគ្គ ) ។ តែក្នុងអធិការនេះអាចារ្យពួកខ្លះពណ៌នាការលះបង់បានដោយបឋមមគ្គនុ៎ះឯង ។ ពាក្យនោះមិនសមនឹងពាក្យដើមនិងពាក្យចុង ។ អាចារ្យពួកខ្លះពណ៌នាវិក្ខម្ភនបហានទុកក្នុងអធិការនេះ ។ ពាក្យនោះត្រឹមតែមតិរបស់អាចារ្យពួកនោះប៉ុណ្ណោះ ។

បទថា យតោ ក្នុងពាក្យថា យតោ ខោ ភិក្ខវេ នេះ ប្រែថា ក្នុងកាលណា ។ ដោយបទថា បហីនោ ហោតិ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកការលះបង់ក្នុងខណៈនៃអនាគាមិមគ្គ ។

បទថា សោ ពុទ្ធេ អវេច្ចប្បសាទេន នេះ គប្បីប្រកបចូលនឹង បទនីមួយៗ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណាភិក្ខុលះបង់ វិសមលោភៈបាន ក្នុងកាលនោះ ភិក្ខុនោះរមែងប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធជាម្ចាស់ ។ ពិតណាស់ ភិក្ខុរូបនេះមានសេចក្តីជ្រះថ្លាដែលជាលោកុត្តរៈមកហើយដោយអនាគាមិមគ្គ សម័យតមក កាលភិក្ខុនេះរឭកដល់នូវព្រះគុណរបស់ព្រះពុទ្ធជាម្ចាស់ របស់ព្រះធម៌ និង របស់ព្រះសង្ឃសេចក្តីជ្រះថ្លាដែលជាលោកិយរមែងកើតទឡើងបាន ។ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសេចក្តីជ្រះថ្លាទាំងដែលជាលោកិយ និង លោកុត្តរទាំងអស់នោះរបស់ភិក្ខុនោះ ទើបត្រាស់ពាក្យជាដើមថា ពុទ្ធេ អវេ_ច្ចប្បសាទេន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អវេច្ចប្បសាទេន សេចក្តីថា ដោយសេចក្តីជ្រះថ្លា ឈ្មោះថា មិនញាប់ញ័រ គឺ ពិតប្រាកដច្បាស់លាស់ ព្រោះដឹងពុទ្ធគុណ ធម្មគុណ និង សង្ឃគុណតាមសេចក្តីពិត ។ កាលភិក្ខុនោះរឭកដល់សេចក្តីជ្រះថ្លាដែលមិនញាប់ញ័រនោះកើតទឡើងហើយ ដោយវិធីណាឥឡូវនេះ កាលនឹងទ្រង់សម្តែងវិធីនោះ ទើបទ្រង់ញ៉ាំងឋានៈដែលជាទីតាំងនៃអនុស្សតិ ៣ ឱ្យពិស្តារ ដោយន័យជាដើមថា ឥតិបិ សោ ភគវា ដូច្នេះ ។

ការពណ៌នាសេចក្តីនៃទីតាំង អនុស្សតិទាំងនោះ ព្រះពុទ្ធឃោសាចារ្យពោលទុកហើយយ៉ាងល្អិតក្នុងអនុស្សតិកថាក្នុងវិសុទ្ធិមគ្គ ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងសេចក្តីជ្រះថ្លាទាំងដែលជាលោកិយ និងលោកុត្តរៈរបស់ព្រះអនាគាមីនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងការលះបង់កិលេស និង អានិសង្ស មានសោមនស្សជាដើម ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ បានកើតទេឡើងដល់ព្រះអនាគាមីអ្នកពិចារណា ទើបត្រាស់ពាក្យជាដើមថា យថោធិ * ខោ បនស្ស ដូច្នេះ ។ ពាក្យនោះមានអធិប្បាយថា ពិតណាស់ សោមនស្សដ៏ខ្លាំងក្លា រមែងកើតទេឡើងដល់ព្រះអនាគាមីអ្នកពិចារណាដល់ការលះបង់កិលេសរបស់ខ្លួនថា កិលេស ទាំងនេះ ៗ យើងលះបង់បានហើយ ប្រៀបដូចសោមនស្សដ៏ខ្លាំងក្លាកើតទេឡើងដល់ព្រះរាជាអ្នកទ្រង់បង្ក្រាបអន្តរាយ គឺ ចោរដែលពពាក់ពពូនតាមបរិវេណជាយដែនឱ្យស្ងប់ហើយ ស្តេចត្រទឡប់មកប្រថាប់ពិចារណាព្រះរាជកិច្ចនោះនៅក្នុងមហានគរនោះ ដូច្នោះ ។ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងសោមនស្សនោះ ទើបត្រាស់ពាក្យជាដើមថា យថោធិ ខោ បនស្ស ដូច្នេះ ។ ពាក្យនោះមានអធិប្បាយថា ព្រះអនាគាមីនេះបានពិចារណាយ៉ាង

---

* បាឋៈជា **យតោធិ** ច្បាប់ភូមាជា **យថោធិ** ប្រែតាមច្បាប់ភូមា

នេះថា ព្រះអរិយសាវកជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុង ព្រះពុទ្ធជាម្ចាស់ ។ ល ។ ព្រះធម៌ ។ ល ។ និង ព្រះសង្ឃ ។ ល ។ ជាបុញ្ញខេត្តដ៏កំពូលរបស់សត្វលោក កិលេសនោះជាការដែលព្រះអនាគាមី លះបង់ហើយ រលាស់ចោលហើយតាមចំណែកនោះ បានដល់ លះបង់តាម អំណាចចំណែករបស់ខ្លួន ៗ នុ៎ះឯង កិលេសនោះ ៗ ជាការដែលព្រះអនាគាមី នោះខ្ជាក់ចេញហើយ បន្សាត់ចេញហើយ លះបង់បានហើយ រលាស់ចោល ហើយ ។

បទថា សកសកឱធិវសេន សេចក្តីថា ចំណែកមាន ២ គឺ ចំណែក នៃកិលេស និង ចំណែកនៃមគ្គ ។ បណ្តាចំណែក ២ នោះ ពោលដោយ អំណាចចំណែកនៃកិលេស ( មុន ) កិលេសពួកណាដែលបុគ្គលគប្បីសម្លាប់ ដោយមគ្គណា កិលេសទាំងនោះមិនច្រទឡំនឹងកិលេសដែលមគ្គដទៃគប្បីសម្លាប់ រមែងជាការដែលព្រះអនាគាមីលះបង់បានហើយ ដោយចំណែករបស់ខ្លួននុ៎ះ ឯង ។ ពោលដោយចំណែកនៃមគ្គ កិលេសពួកណាដែលបុគ្គលគប្បីលះបង់ ដោយមគ្គណា កិលេសទាំងនោះឯង រមែងជាការដែលលះបង់ហើយដោយ មគ្គនោះ។កិលេសនោះ ៗ រមែងជាការដែលលោកលះបង់ហើយ រលាស់ ចោលហើយ ដោយអំណាចចំណែករបស់ខ្លួន ដោយប្រការ ដូច្នេះ ។ សេចក្តី

ថា លោកពិចារណាដល់កិលេសដែលលះបង់បានហើយនោះ ជាអ្នកមាន សោមនស្ស , លោករមែងមានសេចក្ដីត្រេកអរក្នុង អត្ថ ( ផល ) ក្រៃលែង ជាងនោះថា យើងជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះ_ពុទ្ធជាម្ចាស់ ។ បាឋៈថា យថោធិ ខោ ដូច្នេះ ក៏បាន ។ ដោយអំណាច បាឋៈនោះមានសេចក្ដីដូចតទៅនេះ ។ ក៏ព្រោះហេតុដែលកិលេសរមែងជាការ ដែលភិក្ខុនោះលះបង់បានហើយ រលាស់ចោលហើយ ។

បណ្ដាបទទាំងនោះ បទថា យតោ ជាតតិយាវិភត្តិ ។ មាន អធិប្បាយថា យស្មា ( ព្រោះហេតុអ្វី ) ។ មគ្គ ៣ ខាងក្រោមលោក ហៅថា « ឱធិ » ព្រោះហេតុអ្វី ? ព្រោះមគ្គ ៣ ខាងក្រោមនោះធ្វើ ( កិលេស ) ឱ្យជាចំណែក គឺ ឱ្យជាផ្នែក ( កោដ្ឋាសៈ ) ហើយរមែងលះបង់ ( កិលេស ) បាន វៀរកិលេសដែលគប្បីលះបង់ដោយមគ្គខាងលើៗ ដូច្នោះ មគ្គ ៣ ខាងក្រោម ទើបលោកហៅថា ឱធិ ដូច្នេះ ។ ចំណែកអរហត្តមគ្គ រមែងលះបង់កិលេសគ្រប់យ៉ាងមិនឱ្យសេសសល់ ព្រោះហេតុនោះ ទើបលោក ពោលថា អនោធិ ដូច្នេះ ។ មួយវិញទៀត ភិក្ខុរូបនេះលះបង់កិលេស បានហើយដោយមគ្គ ៣ ខាងក្រោម ។ ព្រោះដូច្នោះ ព្រះមាន ព្រះភាគ ទើបត្រាស់ថា យតោធិ ខោ បន ចត្តំ ហោតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ខោ បទ ត្រឹមតែជានិបាត ។ ចំណែកសេចក្តីនេះជាការរួម ។ ក៏ព្រោះកិលេសដែលឈ្មោះថា ឱធិ ជាការដែលភិក្ខុរូបនោះលះបង់ហើយ រលាស់ចោលហើយដូច្នោះ ទើបគួរពង្រីកសេចក្តីតាមព្រះបាលីថា ភិក្ខុរូបនោះពិចារណាដល់កិលេសដែលលះបង់បានហើយនោះ រមែងកើតសោមនស្ស លោករមែងបាននូវការដឹងច្បាស់នូវអត្ថ ( ផល ) ស្ងប់ក្រៃលែងជាងនោះថា យើងជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះពុទ្ធជាម្ចាស់ ។

បណ្តាបទទាំងនោះ បទថា ចត្តំ នេះ លោកពោលដោយអំណាចការលះបង់ភាវៈរបស់ខ្លួន ។

ចំណែកបទ វន្តំ នេះ លោកពោលទុកដោយអំណាចការសម្តែងភាវៈ គឺការមិនប្រកាន់មាំ ។

បទថា មុត្តំ នេះ លោកពោលដោយអំណាចការរួចផុតពីសន្តតិ។

បទថា បហីនំ នេះ លោកពោលដោយអំណាចការសម្តែងកិលេសស្ងប់ដែលលះបង់បានហើយមិនតាំងនៅក្នុងទីណា ៗ ។

បទថា បដិនិស្សដ្ឋំ នេះ លោកពោលដោយអំណាចការសម្តែងការលះបង់កិលេសដែលធ្លាប់ប្រកាន់មាំក្នុងកាលមុន ឬ ដោយអំណាចការសម្តែង

ភារៈនៃកិលេសដែលខ្លួនរលាស់ចោលហើយចំពោះមុខ លោកពោលអធិប្បាយ ថា ដោយអំណាចការសម្តែងភារៈនៃកិលេស ដែលខ្លួនគ្របសង្កត់ដោយ កម្លាំងនៃភាវនា បន្ទាត់បង់ហើយ ដូច្នេះ ។ ក្នុងសេចក្តីដែលថា រមែង បានន្ទូវសេចក្តីត្រេកអរក្នុងអត្ថ ( ផល ) បានន្ទូវសេចក្តីត្រេកអរក្នុងធម៌ ( ហេតុ ) នេះ មានអធិប្បាយថា សេចក្តីជ្រះថ្លាដែលមិនញាប់ញ័រក្នុងព្រះ_ រតនត្រ័យ មានព្រះពុទ្ធជាម្ចាស់ជាដើម នុ៎ះឯង ឈ្មោះថា អត្ថ ព្រោះបុគ្គល គួរដំណើរការ អធិប្បាយថា គប្បីចូលទៅឱ្យដល់ ។ ឈ្មោះថាធម៌ ព្រោះ ជាសភាវៈ ទ្រទ្រង់ទុក មានអធិប្បាយថា មិនឱ្យធ្លាក់ទៅកាន់ទីទាប ។

បទថា វេទ សំដៅយកគម្ពីរខ្លះ សំដៅយកញាណខ្លះ សំដៅយកសោមនស្សខ្លះ ។ គម្ពីរ លោកហៅថា វេទ ( ដូច) ក្នុងប្រយោគជាដើម ថា ដល់ត្រើយនៃវេទ ៣ ដូច្នេះ ។ ញាណ លោកហៅថា វេទ ( ដូច ) ក្នុងប្រយោគជាដើមថា ÷

ព្រាហ្មណ៍ណាដល់នូវវេទ មានការដឹងដ៏ក្រៃលែង មិនមាន

កិលេសដែលជាគ្រឿងកង្វល់ មិនជាប់នៅក្នុងភព ដូច្នេះ ។

សោមនស្ស លោកហៅថា វេទ ( ដូច ) ក្នុងប្រយោគជាដើមថា ជនពួកណាកើតការត្រេកអររមែងត្រាច់ទៅក្នុងលោក ដូច្នេះ ។ តែក្នុងទីនេះ

លោកប្រាថ្នាយកសោមនស្ស និង ញាណដែលប្រកបដោយសោមនស្ស ព្រោះ ដូច្នោះ ក្នុងសេចក្តីនេះគប្បីជ្រាបសេចក្តីយ៉ាងនេះថា ÷

បទថា លភតិ អត្ថវេទំ លភតិ ធម្មវេទំ សេចក្តីថា រមែងបាន សោមនស្ស ដែលមានសេចក្តីជ្រះថ្លាមិនញាប់ញ័រជាអារម្មណ៍ និង ញាណ ដែលសម្រេចដោយសោមនស្ស ។ ម្យ៉ាងវិញទៀត គប្បីជ្រាបសេចក្តីក្នុង ចំណុចនេះសូម្បី យ៉ាងនេះថា ÷

បទថា អត្ថវេទំ សេចក្តីថា ( រមែងបាន ) នូវការដឹង ( វេទ ) មានប្រការដូចពោលនុ៎ះឯង ដែលកើតទេឡើងហើយដល់លោកអ្នកពិចារណានូវ សេចក្តីជ្រះថ្លាដែលមិនកម្រើកញាប់ញ័រ ។

បទថា ធម្មវេទំ សេចក្តីថា ( រមែងបាន ) នូវការដឹង ( វេទ ) មានប្រការដូចពោលហើយនុ៎ះឯង ដែលកើតទេឡើងហើយដល់អ្នកពិចារណានូវ ការលះបង់កិលេសដោយជាចំណែក ព្រោះហេតុនៃសេចក្តីជ្រះថ្លាដែលមិន កម្រើកញាប់ញ័រ ។ សមពិតដូចពាក្យដែលលោកពោលទុកថា ញាណ ក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ញាណក្នុងផលរបស់ហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ដូច្នេះ ។

បទថា ធម្មូបសញ្ហិតំ បាមោជ្ជំ សេចក្តីថា ( រមែងបាន ) នូវ

សេចក្តី ត្រេកអរដែលកើតទេឡើងហើយដល់អ្នកពិចារណានូវអត្ថ និង ធម៌នុ៎ះឯង ហើយការដឹងនូវ ( វេទ ) ដែលជាអានិសង្សកើតមកពីការដឹងអត្ថ និង ធម៌ នោះ ។ ពិតណាស់ បាមោជ្ជនោះ លោកពោលថា ប្រកបដោយធម៌ដែល ជាការប្រព្រឹត្តិទៅដោយអាការពិចារណាចំពោះលក្ខណៈដែលមិនមានទោស ។

បទថា បមុទិតស្ស បីតិ ជាយតិ សេចក្តីថា បីតិដែលមិនលាយ ដោយអាមិស រមែងកើតដល់អ្នកត្រេកអរដោយបាមោជ្ជនេះ ។

បទថា បីតិនមស្ស សេចក្តីថា អ្នកមានចិត្តឆ្អែតដោយបីតិនោះ ។

បទថា កាយោ បស្សម្ភតិ សេចក្តីថា សូម្បីកាយក៏ជាការដែលស្ងប់ រម្ងាប់ គឺ មានការក្រវល់ក្រវាយដែលស្ងប់រំងាប់ហើយ ។

បទថា បស្សទ្ធកាយោ សុខំ សេចក្តីថា អ្នកមានសេចក្តីក្រវល់ក្រ វាយផ្លូវកាយស្ងប់ហើយយ៉ាងនេះ រមែងសោយសុខតាមផ្លូវចិត្ត ។

បទថា ចិត្តំ សមាធិយតិ សេចក្តីថា ចិត្តរមែងតម្កល់មាំដោយ ប្រពៃ គឺ តាំងនៅមិនញាប់ញ័រ ដូចដល់អប្បនា ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងអានិសង្ស មានសោមនស្ស ជាដើម ដែលកើតទេឡើងដល់ភិក្ខុរូបនោះ អ្នកពិចារណានូវការលះបង់កិលេស ដែលប្រកបដោយសេចក្តីជ្រះថ្លា ដែលមិនញាប់ញ័រយ៉ាងនេះហើយ ឥឡូវនេះ

## ៥៤៧ អដ្ឋកថា វត្ថូបមសូត្រ ទី៧

កាលនឹងទ្រង់ប្រកាសអាការដែលប្រព្រឹត្តទៅហើយ នៃការពិចារណារបស់ភិក្ខុ នោះ ដោយវារៈថា យតោធិ ខោ បន មេ ដូច្នេះ ហើយសម្តែង ពលានុភាពនៃ អនាគាមិមគ្គនុ៎ះឯង ទើបត្រាស់ពាក្យថា ស ខោ សោ ភិក្ខវេ ដូច្នេះ ជាដើម ។

បណ្តាបទទាំងនោះ បទថា ឯវំសីលោ សេចក្តីថា ព្រះមានព្រះភាគ រមែងទ្រង់សម្តែងសីលខន្ធដែលប្រកបដោយអនាគាមិមគ្គរបស់ភិក្ខុរូបនោះ ។

បទថា ឯវំធម្មោ ឯវំបញ្ញោ សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ រមែងទ្រង់សម្តែងសមាធិខន្ធ និង បញ្ញាខន្ធដែលប្រកបដោយអនាគាមិមគ្គនុ៎ះ ឯង ។

បទថាសាលីនំសេចក្តីថានៃស្រូវសាលីប្រភេទផ្សេងៗមានស្រូវ សាលីក្រហម និង ស្រូវសាលីក្រអូប ជាដើម ។

បទថា បិណ្ឌបាតំ បានដល់ បាយ ។

បទថា វិចិតកាទឡ្ហកំ សេចក្តីថា នាំចំណែកនៃពណ៌ខ្មៅ (ខ្លូច) ចេញ ។

បទថា នេវស្ស តំ ហោតិ អន្តរាយ សេចក្តីថា ការឆាន់បិណ្ឌបាត មានប្រការដូចពោលនោះ របស់ភិក្ខុបែបនោះ រមែងមិនមានអន្តរាយដល់មគ្គ

ឬ ផល ។ ពិតណាស់ ការឆាន់នោះ របស់ភិក្ខុអ្នកបាន ( សម្រេច ) គុណ- ធម៌ហើយ នឹងធ្វើអន្តរាយអ្វីបាន សូម្បីថា លោកនៅមិនទាន់បានសម្រេច អរហត្តមគ្គ និង អរហត្តផល (តែ) (នៅក្នុងរយៈ) ចម្រើនវិបស្សនា ដើម្បីសម្រេចមគ្គ-ផលនោះ ការឆាន់នោះ ក៏មិនចាត់ជាអន្តរាយទេឡើយ គឺ មិនអាចនឹងធ្វើអន្តរាយបានទេឡើង ។ ព្រោះហេតុអ្វី ? ព្រោះលោកមានចិត្ត បរិសុទ្ធដោយមគ្គដែលប្រមូល សីលធម៌ និង បញ្ញា មានប្រការដូចពោល ទុកហើយ ។ ក៏ព្រោះក្នុងសេចក្តីដែលមានហេតុនេះ នុ៎ះឯង ដូច្នោះ កាលនឹងទ្រង់សម្តែងសេចក្តីឧបមាដ៏សមគួរដល់ហេតុនុ៎ះ ទើបត្រាស់ពាក្យជា ដើមថា សេយ្យថាបិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អច្ឆំ សេចក្តីថា ថ្លាស្អាត ព្រោះប្រាសចាក មន្ទិល ផ្លូវផង់ ព្រោះប្រភស្សរ ។

បទថា ឧក្កាមុខំ សេចក្តីថា ឆ្នាំងរំលាយមាសរបស់ជាងមាស ព្រោះ ក្នុងទីនេះ ឆ្នាំងរបស់ជាងមាសលោកហៅថា ឧក្កា ។ តែក្នុងទីដទៃ សូម្បី ប្រទីបជាដើម លោកក៏ហៅថា ឧក្កា ។ ពិតណាស់ ប្រទីបលោកហៅថា ឧក្កា ( គប់ភ្លើង ) ក្នុងអាគតដ្ឋានថា ឧក្កា ធារិយមានាសុ ដូច្នេះ ។ ឆ្នាំងលោកហៅថា ឧក្កា ( ឆ្នាំងរំលាយមាស ) ក្នុងអាគតដ្ឋានថាជាងមាស

គប្បីធ្វើឆ្នាំងរំលាយមាស កាលធ្វើស្រេចហើយ គប្បីឆាបមាត់ឆ្នាំងរំលាយ មាស ដូច្នេះ ចង្ក្រានជាងមាស លោកក៏ហៅថា ឧក្កា ក្នុងអាគតដ្ឋានថា ដូចយ៉ាងចង្ក្រានភ្លើងរបស់ជាងមាស ភ្លើងនៅឆេះ ( តែ ) ខាងក្នុងមិនរាល ដាលចេញមកខាងក្រៅ ។ កម្លាំងខ្យល់ លោកក៏ហៅថា ឧក្កា ក្នុង អាគតដ្ឋានថា កម្លាំងខ្យល់ ( ឧក្កាបាត ) នឹងមានផលយ៉ាងនេះ ដូច្នេះ ។ តែក្នុងទីនេះ និង ក្នុងទីដទៃដែលមានលក្ខណៈនេះដូចគ្នា ឆ្នាំងរបស់ជាងមាស គប្បីជ្រាបថា ឧក្កា ក្នុងអាគតដ្ឋានថា ជាងមាសយកដង្កាប់គាបមាស ស៊កចូលទៅក្នុងមាត់ឆ្នាំង ដូច្នេះ ។ ក្នុងសេចក្តីនោះ មានការប្រៀបធៀប ដោយឧបមាដូចតទៅនេះ ។ ក៏ចិត្តរបស់ភិក្ខុនេះ ក្នុងវេលាដែលនៅជាបុថុជ្ជន ប្រទឡាក់ដោយមន្ទិលមានកាមរាគៈជាដើម គប្បីឃើញដូចសំពត់ដែលសៅហ្មង និង ដូចមាសដែលសៅហ្មងដូច្នោះ។អនាគាមិមគ្គ គប្បីឃើញដូចទឹកដែល ថ្លាស្អាត និង ដូចមាត់ឆ្នាំង ដូច្នោះ ។ ការដែលភិក្ខុរូបនោះ មានចិត្ត- បរិសុទ្ធិ ព្រោះអាស្រ័យអានាគាមិមគ្គដែលប្រមូលមកនូវ សីល ធមិ និង បញ្ញា មានប្រការដូចពោលហើយ គប្បីឃើញដូចសំពត់សស្អាត និង មាស បរិសុទ្ធិ ព្រោះអាស្រ័យទឹក និង មាត់ឆ្នាំងដូច្នោះ ដូច្នេះឯង ។

បទថា សោ មេត្តាសមាគតេន ចេតសា សេចក្តីថា ព្រះធម្ម-

ទេសនាមកហើយតាមអនុសន្ធិ ។ ពិតណាស់ អនុសន្ធិមាន ៣ គឺ បុច្ឆា- នុសន្ធិ អជ្ឈាសយានុសន្ធិ និង យថានុសន្ធិ ។ ក្នុងអនុសន្ធិ ៣ នោះ គប្បីជ្រាប បុច្ឆានុសន្ធិ ដោយអំណាចព្រះសូត្រ ដែលទ្រង់វិសជ្ជនា ហើយដល់ភិក្ខុទាំងទឡាយអ្នកទូលសួរយ៉ាងនេះ ( ដូចក្នុងប្រយោគជាដើម ) ថា កាលព្រះមានព្រះភាគជាម្ចាស់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបបានក្រាបទូល និង ព្រះមានព្រះភាគជាម្ចាស់ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីខ្លាច តក់ស្លុតព្រោះមិនមានសតិក្នុងខាងក្រៅនោះ មានឬហ្ន៎ ព្រះមានព្រះភាគបាន ត្រាស់ឆ្លើយថា មាន ភិក្ខុ ។ គប្បីជ្រាប អជ្ឈាសយានុសន្ធិ ដោយ អំណាចសូត្រដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបអធ្យាស្រ័យរបស់អ្នកដទៃ ហើយត្រាស់ទុកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ គប្បីមានឬហ្ន៎ អ្នកគប្បីមាន ការគិតយ៉ាងនេះថា សូម្បី ( រហូត ) ថ្ងៃនេះ ព្រះសមណគោតមក៏នៅមិន ទាន់អស់រាគៈពិតប្រាកដ ។ ចំណែក យថានុសន្ធិ គប្បីជ្រាប (ដោយ អំណាច) សូត្រទាំងទឡាយដែលជាទីមកនៃទេសនាថ្នាក់ខ្ពស់ ( ទេឡើងតាម លំដាប់ ) ដោយអំណាចធម៌ដែលសមគួរ និង ជាបដិបក្ខចំពោះធម៌ដែលជា ហេតុឱ្យទេសនាកើតទេឡើងក្នុងពេលដំបូង ដូចក្នុងអកង្ខេយ្យសូត្រទេសនាដោយ រឿងសីលធម៌ ( ទេសនា ) ថ្នាក់ទាប , អភិញ្ញា៦ មក ( ជាទេសនា)

ថ្នាក់ខ្ពស់ ក្នុងកកចូបមសូត្រ ទេសនាពោលដោយការមិនអត់ធន់កើតទេឡើង ( ជាទេសនា ) ថ្នាក់ទាប ឱវាទឧបមាដោយរណារ ( ជាទេសនា ) ថ្នាក់ខ្ពស់ ។ ក្នុងអលគទ្ទសូត្រ ទេសនាពោលដោយការសម្ដែងទិដ្ឋិកើតទេឡើង ( ជាទេសនា ) ថ្នាក់ទាប ការប្រកាសសុញ្ញតាមក ( ជាទេសនា ) ថ្នាក់ខ្ពស់ ។ ក្នុងចុល្លអស្សបុរសូត្រ ទេសនាពោលដោយសេចក្ដីមិនអត់ធន់ កើតទេឡើង ( ជាទេសនា ) ថ្នាក់ទាប ព្រហ្មវិហារមក ( ជាទេសនា ) ថ្នាក់ខ្ពស់ ។ ក្នុងកោសម្ពិកសូត្រ ទេសនាពោលដោយការឈ្លោះទែងគ្នាកើតទេឡើង ( ជាទេសនា) ថ្នាក់ទាប សារាណីយធម៌មក ( ជាទេសនា) ថ្នាក់ខ្ពស់ ។ សូម្បីក្នុងវត្ថសូត្រ នេះការសម្ដែងរឿងកិលេសកើត( ជាទេសនា) ថ្នាក់ទាបព្រហ្មវិហារមក ( ជាទេសនា ) ថ្នាក់ខ្ពស់ ។ ព្រោះហេតុនោះ ទើបលោកពោលថា យថានុសន្ធិវសេន ទេសនា អាគតា ដូច្នេះ ។ ចំណែកក្នុងព្រហ្មវិហារធម៌ លោកពោលការពណ៌នាតាមលំដាប់បទនិង ន័យនៃការការចម្រើនទាំងអស់ ទុកក្នុងគម្ពីរវិសុទ្ធិមគ្គគ្រប់យ៉ាង ។ ព្រះមានព្រះភាគ លុះទ្រង់សម្ដែងការ ចម្រើនព្រហ្មវិហាររបស់អនាគាមីនោះ ដែលជាបដិបក្ខចំពោះឧបក្កិលេសមាន អភិជ្ឈាជាដើម ឈ្មោះថា បានបទដ្ឋានហើយព្រោះកម្ចាត់ធម៌ដែលជាសត្រូវ ដោយការលះបង់កាមរាគៈ ព្យាបាទ ដោយប្រការទាំងពួងយ៉ាងនេះហើយ

ឥឡូវនេះ ដើម្បីនឹងសម្តែងវិបស្សនា ដើម្បីភាពជាព្រះអរហន្តនៃព្រះអនាគាមីនោះហើយ ទ្រង់ក៏សម្តែងការសម្រេចព្រះអរហត្ត ( របស់លោក ) ទើបត្រាស់ពាក្យជាដើមថា សោ អត្ថិ ឥទំ ដូច្នេះ ។ ពាក្យនោះមានសេចក្តីថា ព្រះអនាគាមីនុ៎ះ បានចម្រើនព្រហ្មវិហារយ៉ាងនេះ ហើយចេញចាកព្រហ្មវិហារប្រការណាមួយក្នុងបណ្តាព្រហ្មវិហារទាំងនោះហើយ កំណត់ធម៌ គឺ ព្រហ្មវិហារទាំងនោះឯង ថាជានាម ( និង ) កំណត់ធម៌ គឺ ភូតរូប និង ឧបាទាយរូប ថាជារូប ដោយន័យជាដើមថា ហទយវត្ថុជាទីអាស្រ័យរបស់ព្រហ្មវិហារធម៌ ទាំងនោះ ភូតរូបជាទីអាស្រ័យរបស់ហទយវត្ថុ ដូច្នេះហើយភិក្ខុនោះរមែងដឹង ច្បាស់ថា ទុក្ខសច្ចៈនេះ នៅមាន ដូច្នេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ រមែងជាការដែលព្រះអនាគាមីនេះធ្វើការកំណត់ ទុក្ខសច្ចៈហើយ ។ តពីនោះ លោកកាលចាក់ធ្លុះទុក្ខសមុទ័យ រមែងដឹងច្បាស់ថា សមុទយសច្ចៈ ដែលគួរលះបង់ នៅមាន ដូច្នេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ រមែងជាការដែលលោកធ្វើការកំណត់សមុទ័យហើយ តអំពីនោះ លោកកាលពិចារណាដល់ឧបាយដែលជាគ្រឿងលះបង់សមុទយសច្ចៈនោះ រមែងដឹងច្បាស់ថា មគ្គសច្ចៈដ៏ប្រសើរក៏នៅមាន ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ ជាការដែលព្រះអនាគាមី នេះធ្វើការកំណត់មគ្គសច្ចៈហើយ ។ តអំពីនោះ លោកកាលពិចារណា

ឋានៈដែលគប្បីសម្រេចដោយមគ្គនោះ រមែងដឹងច្បាស់ថា វិធីដែលជាគ្រឿងរលាស់ចោលនូវសញ្ញានេះនៅមានទៀត ។ អធិប្បាយថា រមែងដឹងច្បាស់យ៉ាងនេះថា ព្រះនិព្វានជាគ្រឿងរលាស់ចោលនូវព្រហ្មវិហារសញ្ញានេះ ដែលយើងសម្រេចហើយដ៏ក្រៃលែងនៅមាន ដូច្នេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះអនាគាមីនេះ រមែងធ្វើការកំណត់និរោធសច្ចៈហើយ ។

បទថា ឯវំ ជានតោ ឯវំ បស្សតោ សេចក្តីថា កាលព្រះអនាគាមីនោះដឹងច្បាស់នូវសច្ចៈ ៤ ដោយអាការ ៤ យ៉ាងនេះ ដោយវិបស្សនាបញ្ញា ឃើញយ៉ាងនេះដោយមគ្គប្បញ្ញា ចិត្តរមែងរួចផុតស្ទូម្បីអំពី អាសវៈ ដោយន័យដែលពោលទុកហើយក្នុងភយភេរវសូត្រ ។

បទថា ឥត្ថត្តាយាតិ បជានាតិ សេចក្តីថា ព្រះមានព្រះភាគទ្រង់ញុំាំងទេសនាឱ្យចប់ទៅរហូតដល់ព្រះអរហត្តយ៉ាងនេះហើយ ឥទឡូវនេះ ព្រោះហេតុដែលព្រាហ្មណ៍អ្នកមានការឃើញថា សេចក្តីបរិសុទ្ធិមានបានព្រោះការ ងូតទឹកអង្គុយនៅក្នុងបរិស័ទនោះ ( ហើយ ) ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍នុ៎ះឯង បានស្តាប់ការពណ៌នាចំពោះសេចក្តីបរិសុទ្ធិ ( មាន ) ព្រោះការងូតទឹក ( ដែលតថាគត ) សម្តែង បួសហើយនឹងសម្រេចព្រះអរហត្ត ដូច្នេះ ដូច្នោះ ដើម្បីប្រាថ្នានឹងដាស់តឿនព្រាហ្មណ៍នោះ ទើបត្រាស់អនុសន្ធិ

ដូច្នេះថា អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ សិនាតោ អន្តរេន សិនានេន ម្នាលភិក្ខុទាំងទឡាយ ភិក្ខុនេះ តថាគតពោលថា លាងជម្រះហើយដោយគ្រឿងសម្រាប់លាងជម្រះ លាងជម្រះនូវកិលេសខាងក្នុងដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អន្តរេន សិនានេន សេចក្តីថា ដោយការលាងជម្រះ គឺ ការចេញចាកកិលេសដែលមានក្នុងខាងក្នុង ។

បទថា សុន្ទរិកភារទ្វាជោ បានដល់ ព្រាហ្មណ៍នោះឈ្មោះថា ភារទ្វាជៈ ដោយអំណាចគោត្ររបស់ខ្លួន ។ ក៏ព្រាហ្មណ៍នោះ មានការ យល់ឃើញដូច្នេះថា អ្នកដែលងូតទឹកក្នុងស្ទឹងសុន្ទរិកា រមែងលះបង់បាបបាន ព្រោះដូច្នោះ ទើបត្រូវហៅថា សុន្ទរិកភារទ្វាជ ដូច្នេះ ។ ព្រាហ្មណ៍នោះ បានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគហើយគិតថា សូម្បីពួកយើងរមែងសរសើរ សេចក្តីបរិសុទ្ធិព្រោះការងូតទឹក ចំណែកព្រះសមណគោតមក៏រមែងសរសើរសេចក្តីបរិសុទ្ធិ ព្រោះការងូតទឹកនោះដូចគ្នា ឥឡូវនេះ ព្រះសមណ-គោតមនេះ មានការយល់ឃើញដូចពួកយើងដែរ ។ លំដាប់នោះ ព្រាហ្មណ៍សម្គាល់ព្រះដ៏មានព្រះភាគថា ដូចជាធ្លាប់ស្តេចយាងទៅកាន់ស្ទឹងពាហុកា លាងជម្រះបាបក្នុងទឹកស្ទឹងនោះ ហើយស្តេចយាងមក ទើបក្រាបទូលថា ក៏ព្រះគោតមដ៏ចម្រើន ព្រះអង្គធ្លាប់យាងទៅកាន់ស្ទឹងពាហុកាដើម្បីទ្រង់លាង

ជម្រះបាបដែរឬ ?

ព្រះមានព្រះភាគជាម្ចាស់មិនត្រាស់ថា ទៅ ឬ មិនបានទៅទេ ( តែ ) ទ្រង់មានព្រះបំណងនឹងដកការយល់ឃើញ ( ខុស ) របស់ព្រាហ្មណ៍នោះ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រយោជន៍អ្វីដោយស្ទឹងពាហុកា ស្ទឹងពាហុកានឹងធ្វើអ្វីឱ្យ ដូច្នោះ ។ ពាក្យនោះមានសេចក្ដីថា ប្រយោជន៍អ្វីស្ទឹងពាហុកា ។ ស្ទឹងពាហុកានោះនឹងធ្វើអ្វីឱ្យ ស្ទឹងពាហុកានោះ មិនអាចផ្ដល់ប្រយោជន៍អ្វីឱ្យទេឡើយ យើងនឹងទៅកាន់ស្ទឹងនោះធ្វើអ្វី ។ លំដាប់នោះ ព្រាហ្មណ៍កាលនឹងសរសើរសេចក្ដីនោះ ទើបពោលពាក្យជាដើមថា លោក្ខសម្មតា ។

បណ្ដាបទទាំងនោះ បទថា លោក្ខសម្មតា សេចក្ដីថា ស្ទឹងពាហុកាដែលមានជនច្រើនគ្នាសន្មតហើយថា ជាស្ទឹងបរិសុទ្ធិ អធិប្បាយថា ដែលសត្វលោកសន្មតគ្នាយ៉ាងនេះថា រមែងឱ្យផុតអំពីបាប គឺ ការរួចផុតចាកបាប បានដល់សេចក្ដីបរិសុទ្ធិ ។ បាឋៈថា លោក្យសម្មតា ដូច្នេះខ្លះ ។ បាឋៈ នោះមានសេចក្ដីថាដែលសត្វលោកសន្មតគ្នាយ៉ាងនេះថារមែងឱ្យដល់លោក ដ៏ប្រសើរជាទីផុត ។

បទថា បុញ្ញសម្មតា បានដល់ ដែលសត្វលោកជាច្រើនយល់ឃើញ ថាជាបុណ្យ ដូច្នេះ ។

បទថា បវាហេតិ សេចក្តីថា បណ្តែតទៅ គឺ ធ្វើឱ្យស្អាត ។

បទថា គាថាហិ អជ្ឈភាសិ សេចក្តីថា បានត្រាស់ដោយព្រះគាថាទាំងទឡាយ ។ ពិតណាស់ ព្រះគាថាទាំងទឡាយ កាលព្រះមានព្រះភាគត្រាស់រមែងត្រាស់ដល់បុគ្គលអ្នកពេញចិត្តគាថា ដើម្បីទ្រង់សម្តែងសេចក្តីនោះប៉ុណ្ណោះ ឬ ដើម្បីសម្តែងសេចក្តីសំខាន់ ។ តែក្នុងទីនេះ ព្រះគាថាទាំងនោះគប្បីជ្រាបថា ត្រាស់ទុកដើម្បីសម្តែងសេចក្តីទាំងពីរ ។

ពិតណាស់ បទថា ពាហុកំ នេះ ន៎ុះឯង ជាបទសម្តែងសេចក្តីនោះ ក្នុងទីនេះ ។ បទដ៏សេសជាបទសម្តែងសេចក្តីប្រកាន់ ។ ដូចយ៉ាងថា សុន្ទរិកភារទ្វាជព្រាហ្មណ៍ រមែងទៅកាន់ស្ទឹងពាហុកាដើម្បីបណ្តែតបាបដោយការងូតទឹក យ៉ាងណា សត្វលោកជាច្រើនក៏រមែងទៅកាន់ស្ថានទីមានកំពង់ទឹកអធិកក្កាជាដើម ដើម្បីបណ្តែតបាបដោយការងូតទឹកដូច្នោះ ។ បណ្តាសត្វលោកទាំងនោះ ជនពួកណា នៅជិតស្ថានទីទាំងនោះ ជនទាំងនោះ រមែង ងូតទឹក ១ ថ្ងៃ ៣ ដង ។ ជនពួកណានៅឆ្ងាយ ជនទាំងនោះ រមែង ងូតទឹក ១ ថ្ងៃ ២ ដង ១ ដង រៀងរាល់ថ្ងៃតាមលំដាប់យ៉ាងនេះ រហូតទៅដល់មួយឆ្នាំទៅមួយឆ្នាំ ។ ចំណែកជនពួកណា មិនអាចនឹងទៅបាន សោះ ជនទាំងនោះក៏ប្រើអ្នកដទៃឱ្យយកឆ្នាំងដងទឹកអំពីទីនោះមកងូត ។ ក៏

## ៥៥៧ អដ្ឋកថា វត្ថូបមសូត្រ ទី៧

ពាក្យទាំងអស់នេះមិនមានប្រយោជន៍ ។ ព្រោះដូច្នោះ កាលនឹងទ្រង់សម្តែងសេចក្តីប្រកាន់នេះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា អធិកក្កាទីនិបិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា អធិកក្កំ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកកំពង់ទឹកមួយដែលបានរៀបហារ ( យ៉ាងនោះ ) ដោយអំណាចជាឧបករណ៍ក្នុងការងូតទឹក ។

បទថា គយា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដៅដល់កំពង់ ទឹកមានសណ្ឋានដូចស្រះមូលនោះឯង ។

សូម្បីបទថា បយាគា នេះ ព្រះមានព្រះភាគជាម្ចាស់ ក៏ត្រាស់សំដៅដល់កំពង់ណាមួយនៃស្ទឹងគង្គា ដែលជាស្ថានទីត្រង់មុខជណ្តើរប្រាសាទរបស់ព្រះមហាបនាទ ដែលលិចចុះទៅក្នុងស្ទឹងគង្គាហើយ ។ ចំណែកប្រទឡ្លាយទឹកទាំងនោះ គឺ ពាហុកា សុន្ទរិកា សរស្សតី ពាហុមតី ជាស្ទឹង ៤ ខ្សែ ។

បទថា ពាលោ បានដល់ អ្នកអប្បឥតបញ្ញា ។

បទថា បក្ខន្នោ ប្រែថា ចូលទៅ ។

បទថា ន សុជ្ឈតិ ប្រែថា មិនសម្រេចដល់សេចក្តីបរិសុទ្ធិចាក

កិលេស ។ គេរមែងបណ្តែតបានតែកម្មេចធូលីតែម្យ៉ាងប៉ុណ្ណោះ ។

បទថា កឹ សុន្ទរិកា ករិស្សតិ សេចក្តីថា ស្ទឹងសុន្ទរិកានឹងធ្វើអ្វី ឱ្យបាន ដោយការលាងជម្រះកិលេស ។ អធិប្បាយថា មិនអាចនឹងធ្វើអ្វី ឱ្យបានទេឡើយ ។ ក្នុងកំពង់បយាគា និង ស្ទឹងពាហុកាក៏មានន័យនេះ ។ ក៏ដោយបទទាំង ៣ នេះ ដែលលោកពោលទុកហើយ ក៏រមែងជាការដែល លោកពោល ៨ បទក្រៅនេះទុក ដូចគ្នា ។ ព្រោះដូច្នោះ គប្បីជ្រាបថា សូម្បីកំពង់ទឹក អធិកក្កា ជាដើម ក៏ធ្វើអ្វីឱ្យមិនបាន ដូចគ្នានឹងស្ទឹងសុន្ទរិកា សូម្បីស្ទឹងបយាគា និង ស្ទឹងពាហុកាធ្វើអ្វីឱ្យមិនបាន ដូច្នោះ ។

បទថា វេរឹ ប្រែថា អ្នកប្រកបដោយពៀរទាំង ៥ មានបាណា_តិបាត ជាដើម ។

បទថា កតកិព្វិសំ គឺ អ្នកបានធ្វើកម្មដ៏អាក្រក់ទុកហើយ ។

បទថា ន ហិ នំ សោធយេ លោកពោលអធិប្បាយទុកថា ស្ទឹង សុន្ទរិកា កំពង់ទឹកបយាគា ឬ ស្ទឹងពាហុកា ក៏ធ្វើឱ្យគេបរិសុទ្ធមិនបានទេឡើយ។

បទថា បាបកម្មិនំ សេចក្តីថា ប្រកបដោយកម្មដែលជាបាប គឺ កម្មដ៏អាក្រក់គ្រោតគ្រាតដែលជាពៀរ ឬ ប្រកបដោយកម្មដ៏លាមក លោកពោលអធិប្បាយទុកថា ប្រកបដោយបាបសូម្បីតិចតួច ដែលមិនទាន់ដល់ភាពជា

ទោស គឺ ពៀរ ។

បទថា សុទ្ធស្ស ប្រែថា អស់កិលេស ។

បទថា សទា ផគ្គុ បានដល់ សូម្បីបុណ្យនក្ខត្តឫក្សប្រចាំខែ ៤ ដែលមានជាប្រចាំ ។ បានឮថា ព្រាហ្មណ៍នោះមានទិដ្ឋិយ៉ាងនេះថា ក្នុងខែ ៤ អ្នកណាងូតទឹក ក្នុងថ្ងៃខាងខ្នើតនៃខែ ៤ អ្នកនោះរមែងលាងជម្រះបាបដែលខ្លួនធ្វើអស់មួយឆ្នាំបាន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់បដិសេធទិដ្ឋិរបស់ព្រាហ្មណ៍នោះទើបត្រាស់ថាសម្រាប់អ្នកបរិសុទ្ធ ហើយខែ៤ មាននៅគ្រប់កាល ចំណែកអ្នកអស់កិលេសហើយបុណ្យនក្ខត្តឫក្ស ប្រចាំខែ ៤ តែងមានសព្វ ៗ កាល ដល់បុគ្គលដែលបរិសុទ្ធ កំពង់ទឹកក្រៅពីនេះនឹងលាងជម្រះបានយ៉ាងណា ដូច្នេះ ។

បទថា ឧបោសថោ សទា សេចក្តីថា ក៏បុគ្គលអ្នកបរិសុទ្ធហើយ សូម្បីនឹងមិនបានសមាទានអង្គឧបោសថក្នុងថ្ងៃ ១៤ កើត ១៥ កើត នៃឧបោសថ ក៏ដោយ ឧបោសថតែងមានសព្វៗ កាល ដល់បុគ្គលដែលបរិសុទ្ធពិតៗ ។

បទថា សុទ្ធស្ស សុចិកម្មស្ស ប្រែថា ដែលឈ្មោះថា អ្នកស្អាតហើយ ព្រោះជាអ្នកអស់កិលេស និង ជាអ្នកប្រកបដោយកាយកម្មជាដើមដ៏ស្អាត ។

បទថា សទា សម្បជ្ជតេ វតំ សេចក្តីថា ក៏សូម្បីការសមាទានវត្ត

ដែលប្រកបដោយកុសលរបស់បុគ្គល ដូច្នេះ រមែងដល់ព្រមជាប្រចាំពិត ។

បទថា ឥធេវ សិនាហិ លោកពោលអធិប្បាយទុកថា ព្រះមានព្រះភាគ ត្រាស់ថា អ្នកចូរងូតទឹកក្នុងសាសនារបស់តថាគតនេះវិញចុះ ។

លោកពោលអធិប្បាយទុកទៀតថា បើអ្នកប្រាថ្នានឹងលាងជម្រះមន្ទិល គឺកិលេសខាងក្នុងសោត ចូរងូតដោយទឹក គឺ មគ្គមានអង្គ ៨ ក្នុងសាសនារបស់តថាគតនេះវិញព្រោះថាក្នុងទីដទៃទឹកគឺមគ្គមានអង្គ៨ដូច្នេះមិនមាន ដូច្នេះ ។

ឥទខ្សូវ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងសេចក្ដីបរិសុទ្ធិក្នុងទ្វារ សូម្បីទាំង ៣ ដោយអំណាចទេសនា ដែលសមដល់ព្រាហ្មណ៍នោះ ទើបត្រាស់ ពាក្យជាដើមថា សព្វភូតេសុ ករោហិ ខេមតំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា ខេមតំ បានដល់ ការមិនមានភ័យ គឺ សេចក្ដីក្សេម អធិប្បាយថា បានដល់ មេត្តា ។ ដោយបទនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីបរិសុទ្ធិតាមមនោទ្វារដល់ព្រាហ្មណ៍នោះ ។

ដោយបទថា សចេ មុសា ន ភណសិ នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីបរិសុទ្ធិតាមវចីទ្វារ ។

ដោយបទទាំងនេះថា សចេ បាណំ ន ហឹសសិ សចេ អទិន្នំ

នាទិយសិ ( រមែងជាការ ) ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងសេចក្តីបរិសុទ្ធតាមកាយទ្វារ ។

ក៏ដោយបទទាំងនេះថា សទ្ទហានោ អមច្ឆរី ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកបព្រាហ្មណ៍នោះ អ្នកមានទ្វារបរិសុទ្ធហើយយ៉ាងនេះទុកក្នុងសទ្ធាសម្បទា និង ចាគសម្បទា ។ ចំណែកបាលីនេះថា កឹ កាហសិ គយំ គន្ត្វា ឧទបានោបិ តេ គយា ត្រឹមតែកន្លះគាថា ។ គប្បីប្រកបសេចក្តី យ៉ាងនេះថា ប្រសិនបើអ្នកនឹងធ្វើសេចក្តីក្សេមក្សាន្តចំពោះពួកសត្វទាំងពួង មិន និយាយកុហក មិនសម្លាប់សត្វ មិនលួចទ្រព្យ មានចិត្តជឿ មិនមានសេចក្តី កំណាញ់ អ្នកចាំបាច់ទៅកាន់ស្ទឹងគយាធ្វើអ្វីទៀត ស្ទឹងគយាក៏ ( ត្រឹមតែ ) ជាអណ្តូងទឹកសម្រាប់អ្នក ព្រោះថា កាលអ្នកងូតទឹកក្នុងស្ទឹងគយាក្តី ក្នុងអណ្តូង ទឹកក្តី សេចក្តីបរិសុទ្ធិចាកកិលេសនឹងមានបាន ក៏ដោយការបដិបត្តិនេះប៉ុណ្ណោះ ចំណែកសេចក្តីបរិសុទ្ធិចាកមន្ទិលរាងកាយមានបានដូចគ្នាក្នុងទីទាំង ២ កន្លែង ។ បណ្ឌិតគប្បីជ្រាបសេចក្តីថា ក៏ព្រោះថា ស្ទឹងគយាដែលជនជាច្រើនស្គាល់ក្នុងលោក ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ សូម្បីត្រូវព្រាហ្មណ៍នោះ ក្រាបទូល សួរថា ក៏ព្រះគោតមដ៏ចម្រើន ធ្លាប់ស្តេចយាងទៅកាន់ស្ទឹងពាហុកាដែរឬ ? មិនត្រាស់ថា អ្នកទៅកាន់ស្ទឹងពាហុកានឹងធ្វើអ្វីបាន (តែ) ត្រាស់ថា អ្នក

ទៅកាន់ស្ទឹងគយានឹងធ្វើអ្វីបាន ដូច្នេះ ។

ពាក្យជាដើមយ៉ាងនេះថា ឯវំ វុត្តេ រាប់ថា ជាក់ច្បាស់ហើយដែរ ព្រោះលោកពោលទុកហើយក្នុងភយភេរវសូត្រ ។

ក៏ក្នុងបទជាដើមថា ឯកោ វូបកដ្ឋោ គប្បីជ្រាបអធិប្បាយដូច្នេះ ព្រាហ្មណ៍ឈ្មោះថា ម្នាក់ឯងដោយកាយវិវេក ឈ្មោះថា ចៀសចេញទៅហើយ ( ចាកការច្រទឡូកច្រទឡំដោយនីវរណៈ ) ដោយចិត្តវិវេក ឈ្មោះថា មិនប្រមាទ ដោយការមិនលះបង់សតិក្នុងកម្មដ្ឋាន ឈ្មោះថា មានសេចក្ដីព្យាយាម ដោយសេចក្ដីព្យាយាមដុតកិលេស ពោលគឺ ការព្យាយាមផ្លូវកាយ និង ការព្យាយាម ផ្លូវចិត្ត ឈ្មោះថាអស់អាល័យក្នុងខ្លួនហើយព្រោះមិនមានការហួងហែងក្នុង កាយ និង ជីវិត ឈ្មោះថា នៅដោយការនៅក្នុងឥរិយាបថយ៉ាងណាមួយ ( ក្នុងបណ្ដាឥរិយាបថទាំង ៤ ) ។

បទថា ន ចិរស្សេវ លោកពោលដល់ ការបព្វជ្ជា ។

បទថា កុលបុត្តា បានដល់ កុលបុត្រមាន២ចំពូកគឺកុលបុត្រ ដោយជាតិ ( កំណើត ) និង កុលបុត្រដោយអាចារៈ ។ ក៏ព្រាហ្មណ៍នេះ ជាកុលបុត្រ សូម្បីដោយប្រការទាំង ២ ។

បទថា អគារស្មា ប្រែថា ចេញចាកផ្ទះ ។

ក្នុងបទថា អនគារិយំ គប្បីវិនិច្ឆ័យដូច្នេះ ការងារដែលជាហេតុបង្កើនទ្រព្យសម្បត្តិ មានកសិកម្មនិងគោរក្ខកម្មជាដើម ដែលជាប្រយោជន៍ឧបត្ថម្ភ ដល់ ( ការ ) គ្រប់គ្រងផ្ទះ លោកហៅថា អគារិយ ការងារដែលឧបត្ថម្ភដល់ការគ្រប់គ្រងផ្ទះក្នុងការបព្វជ្ជានេះ មិនមាន ហេតុនោះ ការបព្វជ្ជានេះទើបឈ្មោះថា អនគារិយំ ពាក្យថា អនគារិយំ នោះ ជាឈ្មោះនៃការបួស។

បទថា បព្វជន្តិ ប្រែថា ចូលទៅជិត គឺ ចូលទៅកាន់ផ្នួស ។

បទថា តទនុត្តរំ កាត់បទជា តំ អនុត្តរំ (ប្រែថាផលដ៏ កំពូលនោះ ) ។

បទថា ព្រហ្មចរិយបរិយោសានំ បានដល់ ទីបំផុតនៃមគ្គព្រហ្មចរិយៈ លោកពោលអធិប្បាយទុកថា ( បានដល់ ) អរហត្តផល ដូច្នេះ ។ ពិតណាស់ ពួកកុលបុត្របួស ក៏ដើម្បីប្រយោជន៍ដល់អរហត្តផលនោះ ។

បទថា ទិដ្ឋេវ ធម្មេ ប្រែថា ក្នុងអត្តភាពនេះ នុ៎ះឯង ។

បទថា សយំ អភិញ្ញា សច្ឆិកត្វា សេចក្តីថា ធ្វើឱ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួន ដោយខ្លួនឯង ។ អធិប្បាយថា ដឹងដោយមិនមានអ្នកដទៃជា បច្ច័យ ដូច្នេះ ។

បទថា ឧបសម្បជ្ជ វិហាសិ សេចក្តីថា ចាក់ធ្លុះ គឺ ឱ្យសម្រេច ។

ក៏ព្រះសុន្ទរិកាភារទ្វាជៈ កាលនៅដោយអាការយ៉ាងនោះ ក៏បានជ្រាបច្បាស់ថា ជាតិអស់ហើយ ។ ល ។ ដូច្នេះ ព្រះអានន្ទត្រេរសម្តែងដល់ភូមិនៃបច្ច-វេក្ខណញ្ញាណរបស់លោកដោយពាក្យនោះ ។

សួរថា ក៏ជាតិណារបស់លោកអស់ទៅហើយ ហើយលោកដឹងជាតិដែលអស់ទៅនោះ យ៉ាងណា ?

ខ្ញុំម្ចាស់នឹងឆ្លើយតទៅ ÷

ក៏សេចក្តីនោះ បានពោលទុកហើយក្នុងភយភេរវសូត្រក៏ពិត។តែសូម្បី យ៉ាងនោះក្នុងទីនេះ ខ្ញុំម្ចាស់នឹងពោលសេចក្តីនោះដដែលទៀតដោយសង្ខេប ដើម្បីនឹងសម្តែងន័យនៃការអធិប្បាយប្រកបសេចក្តីដោយអំណាច បឋមបុរស ។ ជាតិដែលជាអតីតរបស់ព្រះសុន្ទរិកភារទ្វាជៈនោះ មិនឈ្មោះថា អស់ទៅហើយ ទេ ( ក្នុងទីនេះ ) ព្រោះជាតិនោះអស់ទៅហើយ ក្នុងកាលមុន នុ៎ះឯង ។ ជាតិដែលជាអនាគត ក៏មិនឈ្មោះថា អស់ទៅហើយដែរ ព្រោះលោកមិនមានសេចក្តីព្យាយាមក្នុងជាតិដែលជាអនាគតនោះ ។ ជាតិដែលជា បច្ចុប្បន្ន ក៏មិនឈ្មោះថា អស់ទៅហើយដែរ ព្រោះជាតិបច្ចុប្បន្ននៅមាន ក៏ជាតិណា ចែកប្រភេទជាខន្ធ ១ ខន្ធ ៤ និង ខន្ធ ៥ ក្នុងឯកវោការភព ចតុវោការភព និង បញ្ចវោការភព គប្បីកើតទេឡើង ព្រោះនៅមិនទាន់បានចម្រើនមគ្គឱ្យកើត

ទេឡើង ជាតិនោះឈ្មោះថា អស់ទៅហើយ ព្រោះដល់ភាពជាជាតិដែលមានការមិនកើតទេឡើងជាធម្មតា ព្រោះហេតុ ដែលលោកបានចម្រើនមគ្គឱ្យកើតទេឡើងហើយ ។ ព្រះសុន្ទរិកភារទ្វាជៈនោះ ពិចារណាដល់កិលេស ដែលមគ្គភាវនាលះបង់បានហើយ ដឹងថា កាលមិនមានកិលេស កម្មសូម្បីមាននៅ ក៏រមែងមិនឱ្យបដិសន្ធិតទៅ ឈ្មោះថា រមែងដឹងជាតិដែលអស់ទៅហើយនោះ ។

បទថា វុសិតំ សេចក្តីថា នៅហើយ គឺ នៅចប់ហើយ អធិប្បាយថា ធ្វើហើយ ប្រព្រឹត្តហើយ ឱ្យចប់ហើយ ។

បទថា ព្រហ្មចរិយ បានដល់ មគ្គព្រហ្មចរិយៈ ។

បទថា កតំ ករណីយ សេចក្តីថា កិច្ចទាំង ១៦ គឺ បរិញ្ញាកិច្ច បហានកិច្ច សច្ឆិកិរិយាកិច្ច និង ភាវនាកិច្ច ដែលលោកឱ្យសម្រេចហើយ ដោយមគ្គ ៤ ក្នុងសច្ចៈទាំង ៤ ។

បទថា នាបរំ ឥត្ថត្តាយ សេចក្តី ការចម្រើនមគ្គដើម្បីភាពជាយ៉ាងនេះ ទៀត គឺ ដើម្បីកិច្ច១៦យ៉ាងឬដើម្បីការអស់កិលេសយ៉ាងនេះមិនមាន ក្នុងឥទឡូវនេះ ។

ប្រការមួយទៀត បទថា ឥត្ថត្តាយ សេចក្តីថា ការបន្តគ្នានៃខន្ធដទៃអំពីភាពជាយ៉ាងនេះ គឺ អំពីខន្ធសន្តានដែលប្រព្រឹត្តទៅក្នុងឥទឡូវនេះ យ៉ាងនេះ

មិនមាន ។ ក៏ព្រះសុន្ទរិកភារទ្វាជៈនោះ បានដឹងហើយថា ខន្ធ ៥ នេះ ដែលខ្លួនកំណត់ដឹងហើយតាំងនៅ ប្រៀបដូចដើមឈើដែលត្រូវកាត់ឫសកែវហើយ ដូច្នោះ ។

បទថា អញ្ញតរោ មានសេចក្តីស្មើនឹង ឯកោ ( ប្រែថា មួយ) ។

បទថា អរហតំ គឺ អរហន្តានំ ។ អធិប្បាយថា លោកជាព្រះអរហន្ត មួយអង្គក្នុងបណ្តាព្រះអរហន្តជាសាវកព្រះមានព្រះភាគជាម្ចាស់ ដូច្នេះ ។

( ចប់ អដ្ឋកថាវត្ថសូត្រ ទី ៧ )

# អ ដ្ឋ ក ថា

## សល្លេខសូត្រ ទី ៨

សល្លេខសូត្រមានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ( ព្រះសូត្រនេះខ្ញុំម្ចាស់ ( ព្រះអានន្ទ ) បានស្ដាប់មកហើយយ៉ាងនេះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហាចុន្ទ** ជានាមរបស់ព្រះថេរៈអង្គនោះ ។

បទថា **សាយណ្ហសមយំ** ( ក្នុងសាយណ្ហសម័យ ) គឺ ក្នុងវេលា រសៀល ។

ទីពួនសំងំ គឺ គេចចេញពីសត្វនិង សង្ខារទាំងទឡាយនោះៗ ឈ្មោះថា ទីពួនសំងំ ក្នុងពាក្យថា **បដិសល្លានា វុដ្ឋិតោ** ( ចេញអំពីទីពួនសំងំ ) នេះ មានពាក្យអធិប្បាយទុកថា បានដល់ តែម្នាក់ឯង គឺ ការស្ងាត់ ។ អ្នកដែលចេញអំពីទីនោះឈ្មោះថា ជាអ្នកចេញអំពីទីពួនសំងំ ។ តែព្រះចុន្ទត្ថេរ នេះ ព្រោះចេញអំពីផលសមាបត្តិដ៏ខ្ពង់ខ្ពស់ជាងការពួនសំងំ ( ធម្មតា ) ព្រោះ ដូច្នោះ ព្រះអានន្ទទើបបានពោលថា ចេញអំពីទីពួនសំងំហើយ ។

បទថា **ភគវន្តំ អភិវាទេត្វា** ( លុះថ្វាយអភិវាទព្រះមានព្រះភាគ ហើយ ) សេចក្ដីថា លុះថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ដោយសិរសាប្រកបដោយការលើកម្រាមដៃគ្រប់ទាំង ១០ ទេឡើងប្រណម្យហើយ ឬ

លុះថ្វាយអភិវាទព្រះមានព្រះភាគហើយ ព្រះអង្គទ្រង់បន្លឺព្រះតម្រាស់យ៉ាងនេះ ថា ចូរជាសុខចុះចុន្ទ ៗ ។

## ធម្មទំនៀមរបស់ព្រះពុទ្ធ

បានឮមកថា ព្រះមានព្រះភាគ កាលមានអ្នកថ្វាយបង្គំ ទ្រង់លើកព្រះកដែលដូចស្គរមាសទេឡើងហើយ ទ្រង់បន្លឺព្រះសូរសៀង ដូចសម្លេងព្រហ្មដ៏ពីរោះត្រចៀក ជាទីចាប់ចិត្ត ដូចស្រោចស្រប់ដោយទឹកអម្រិតត្រាស់បញ្ជាក់ឈ្មោះរបស់អ្នកនោះ ៗ ថា ចូរជាសុខ ៗ ចុះ ដូច្នេះ នេះជាធម្មទំនៀមរបស់ព្រះពុទ្ធទាំងទឡាយ ។

ក្នុងរឿងនោះមានព្រះសូត្រដែលលើកមកជាគ្រឿងអាងបាន ដូចតទៅ នេះ ( គឺសក្កបញ្ហាសូត្រ ) ។ កាលបញ្ចសិក្ខទេវបុត្រក្រាបទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន សក្កទេវរាជព្រមទាំងទេពអាមាត្យ ទេពបរិវារ សូមថ្វាយបង្គំព្រះយុគលបាទរបស់សម្តេចព្រះមានព្រះភាគដោយសិរសា ម្នាលបញ្ចសិក្ខ-ទេវបុត្រ សូមឱ្យសក្កទេវរាជព្រមទាំងទេវអាមាត្យ ទេវបរិវារ ចូរទ្រង់មានសេចក្តីសុខ ព្រោះថា ទេព្តា និង មនុស្សទាំងទឡាយ អាសុរ នាគ គន្ធព្វ និង សត្វដទៃដែលមានកាយគ្រោតគ្រាតប្រាថ្នាសេចក្តីសុខ ព្រោះដូច្នោះ កាលបើ ដូច្នេះ ព្រះតថាគតទាំងទឡាយនឹងទ្រង់ថ្វាយព្រះពរដល់ទេព្តាប្រភេទនោះ អ្នក

មានសក្តិធំ អ្នកគួរបូជា ដូចដែលពោលមកហើយនោះ ។

បទថា **យា ឥមា** សេចក្តីថា ព្រះចុន្ទ បានពោលដល់ទិដ្ឋិដែលត្រូវពោលដល់ ក្នុងកាលឥឡូវនេះ ដូចធ្វើឱ្យនៅចំពោះមុខ ។

បទថា **អនេកវិហិតា** (មានច្រើនយ៉ាង) បានដល់ មានច្រើនប្រការ។

បទថា **ទិដ្ឋិយោ** ( ទិដ្ឋិទាំងឡាយ ) បានដល់ មិច្ឆាទិដ្ឋិ ។

បទថា **លោកេ ឧប្បជ្ជន្តិ** ( កើតឡើងក្នុងលោក ) សេចក្តីថា ប្រាកដនៅក្នុងពួកសត្វលោក ។

បទថា អត្តវាទបដិសំយុត្តា ( ប្រកបដោយអត្តវាទ ) សេចក្តីថា មិច្ឆាទិដ្ឋិទាំងនេះដែលប្រកបដោយអត្តវាទ ( ប្រារព្ធខ្លួន ) ប្រព្រឹត្តទៅហើយដោយន័យមានជាអាទិថា រមែងតាមឃើញរូបដោយភាពជាអត្តា មាន ២០ យ៉ាង ។

បទថា **លោកវាទបដិសំយុត្តា** ( ប្រកបដោយលោកវាទ និយាយប្រារព្ធលោក ) សេចក្តីថា ប្រព្រឹត្តទៅហើយដោយន័យមានជាអាទិថា អត្តា និងលោកទៀង ។

## មិច្ឆាទិដ្ឋិ៨ យ៉ាង

មិច្ឆាទិដ្ឋិប្រារព្ធអត្តា និង លោកនោះមាន ៨ ប្រការ ដែលប្រព្រឹត្ត

ទៅហើយយ៉ាងនេះថា ÷

១. អត្តា និងលោកទៀង

២. អត្តា និងលោកមិនទៀង

៣. អត្តា និងលោកទៀងខ្លះ មិនទៀងខ្លះ

៤. អត្តា និងលោកទៀងក៏មិនមែន មិនទៀងក៏មិនមែន

៥. អត្តា និងលោកមានទីបំផុត

៦. អត្តា និងលោកមិនមានទីបំផុត

៧. អត្តា និងលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ

៨. អត្តា និងលោកមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន

ក្នុងពាក្យមានជាអាទិថា **អាទិមេវ** ( ខាងដើមនេះប៉ុណ្ណោះ ) មានអត្ថាធិប្បាយយ៉ាងនេះថា ( ព្រះចុន្ទត្ថេរទូលសួរព្រះមានព្រះភាគ ) ថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើភិក្ខុមនសិការធមិតែម្យ៉ាង គឺ សូម្បីមិនទាន់សម្រេចសោតាបត្តិមគ្គ មនសិការចំពោះធមិជាខាងដើមប៉ុណ្ណោះ ដែលលាយដោយ វិបស្សនា តើលះបង់ និងរលាស់ចោលទិដ្ឋិទាំងនោះយ៉ាងនេះ គឺ ទិដ្ឋិទាំងនេះ ដោយឧបាយយ៉ាងនេះប៉ុណ្ណោះបានឬទេ ? ក៏ព្រះថេរៈសូម្បីខ្លួនលោកនឹងមិនមានអធិមានះ ( សម្គាល់ថា ខ្លួនបានសម្រេចមគ្គផល ) តែក៏គប្បីជ្រាបថា

ដូចជាអ្នកមានអធិមានះ សួរបញ្ហានេះដើម្បីលះបង់អធិមានះ សម្រាប់ភិក្ខុទាំង-ទឡាយអ្នកមានអធិមានះ ។

## នាទីរបស់ទិដ្ឋិ

លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងឧបាយសម្រាប់លះបង់ទិដ្ឋិទាំងនោះដល់លោក ទើបបានត្រាស់ពាក្យមានជាអាទិថា **យា ឥមា** ( ទិដ្ឋិ ) ទាំងទឡាយមានច្រើនប្រការណា ។ ក្នុងពាក្យទាំងនោះមានសេចក្តី ពិស្តារថា ពាក្យមានជាអាទិថា **យត្ថ ចេតា ទិដ្ឋិយោ ឧប្បជ្ជន្តិ** ( ទិដ្ឋិទាំងនោះកើតទេឡើងក្នុងទីណា ) ដូច្នេះ ព្រះអង្គត្រាស់សម្តៅយកបញ្ចក្ខន្ធ ។ អធិប្បាយថា ទិដ្ឋិទាំងនោះកើតទៃឡើងក្នុងបញ្ចក្ខន្ធទាំងនោះ ដូចដែលត្រាស់ទុក ថា ម្នាលភិក្ខុទាំងទឡាយ កាលរូបមាន ព្រោះការប្រកាន់រូប កើតទិដ្ឋិទេឡើងយ៉ាងនេះថា យើងគឺអត្តា និងលោក លះបង់លោកនេះទៅហើយនឹងមាន ( ព្រោះថា ) អត្តានោះ លោកនោះ ជារបស់ទៀង ឋិតថេរ ជាប់តគ្នាមានការមិនប្រែប្រួលទៅជាធម្មតា ។ តែព្រះអង្គត្រាស់ទុកជាឯកវចនៈថា **យត្ថ ច** ( ប្រែថា ក្នុងអារម្មណ៍ណា ) ដោយអំណាចនៃអារម្មណ៍ មានអធិប្បាយ ទុកថា ទិដ្ឋិទាំងទឡាយកើតទេឡើងក្នុងអារម្មណ៍ណា ។ម្យ៉ាងទៀត ក្នុងពាក្យថា **យត្ថ ច** ជាដើមនេះ គួរជ្រាបដល់ទិដ្ឋិទាំងនោះ ធ្វើ ( នាទី ) ផ្សេងៗ

គ្នាយ៉ាងនេះ គឺ កើតទេឡើង ១ ដេកសម្ងំ ១ ផុសផុលទេឡើង ១ អធិប្បាយថា ទិដ្ឋិទាំងនោះមានការធ្វើ ( នាទី ) ផ្សេងគ្នាដូច្នេះ គឺ ទិដ្ឋិទាំងទឡាយដោយជាតិ ( របស់វា ) ដែលមិនទាន់កើតទេឡើង កាលកើតទេឡើងព្រះអង្គត្រាស់ហៅថា កំពុងកើតទេឡើង , ដែលសេពរឿយ ៗ រហូតមានកម្លាំង កម្ចាត់មិនទាន់បាន ព្រះអង្គត្រាស់ហៅថា ដេកសម្ងំ , ចំណែកដែលប្រជួប ( កន្លងចេញមកតាម ) កាយទ្វារ និងវចីទ្វារ ព្រះអង្គត្រាស់ហៅថា ផុសផុលទេឡើង ។

ក្នុងពាក្យទាំងទឡាយមានពាក្យជាអាទិថា **តំ នេតំ មម** ( នេះមិនមែនរបស់យើង ) គួរជ្រាបអធិប្បាយនៃបទយ៉ាងនេះមុនថា អារម្មណ៍ដែលចែកប្រភេទជាបញ្ចក្ខន្ធនេះនោះ មិនមែនរបស់យើង ៗ សូម្បីយើងក៏មិនមែនរបស់ នោះ សូម្បីរបស់នោះក៏មិនមែនអត្តារបស់យើង ភិក្ខុឃើញច្បាស់បញ្ចក្ខន្ធនោះ តាមសេចក្តីពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ( មានការលះបង់ ការរលាស់ចោលទិដ្ឋិទាំងនោះបាន ។

តែព្រោះការប្រកាន់ដោយធម៌ ៣ យ៉ាងនេះ កាលប្រកាន់ ៗ ដោយអំណាចតណ្ហាថា នុ៎ះរបស់យើង ក៏ឈ្មោះថា ប្រកាន់ដោយតណ្ហាដែលជាបបញ្ចធម៌ចែកប្រភេទចេញជាតណ្ហាវិប្បរិត ១០៨ ប្រការ កាលប្រកាន់ ៗ ដោយអំណាចមានះថា នុ៎ះជាយើង ឈ្មោះថាប្រកាន់មានះដែលជាគ្រឿងយឺត

យូរ ចែកប្រភេទចេញជាមានះ ៩ ប្រការ ហើយកាលប្រកាន់ ៗ ដោយអំណាចទិដ្ឋិថា នុ៎ះមិនមែនអត្តារបស់យើង ឈ្មោះថាប្រកាន់ដោយទិដ្ឋិដែលជាបបញ្ចធម៌ ចែកប្រភេទចេញជាទិដ្ឋិ ៦២ ប្រការ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់កាលត្រាស់ថា នុ៎ះមិនមែនរបស់យើង ក៏ឈ្មោះថាទ្រង់បដិសេធតណ្ហាដែលជាធម៌ធ្វើឱ្យមានការយឺតយូរ ចែកប្រភេទតាមដែលពោលហើយ កាលត្រាស់ថា នុ៎ះមិនមែនជាយើង ក៏ឈ្មោះថាទ្រង់បដិសេធមានះដែលជាធម៌ធ្វើឱ្យមានការយឺតយូរ ហើយកាលត្រាស់ថា នុ៎ះមិនមែនអត្តារបស់យើង ក៏ឈ្មោះថាទ្រង់បដិសេធទិដ្ឋិដែលជាធម៌ធ្វើឱ្យមានការយឺតយូរ ។ ម្យ៉ាងទៀត ក្នុងរឿងតណ្ហា ទិដ្ឋិ មានះ ទាំង ៣ យ៉ាងនេះ តណ្ហា និងមានះ គប្បីជ្រាបថាតាំងនៅក្នុងពួកមួយជាមួយនឹងទិដ្ឋិនោះឯង ។

បទថា **ឯវមេតំ** ( ឃើញរបស់នោះយាងនេះ ) គឺ ឃើញច្បាស់បញ្ចក្ខន្ធនោះដោយអាការមានជាអាទិថា ។

បទថា **យថាភូតំ** ( តាមសេចក្តីពិត ) គឺតាមសភាវៈ មានពាក្យអធិប្បាយទុកថា តាមដែលមាន ។ អធិប្បាយថា ពិតណាស់ ខន្ធបញ្ចកៈ ( ពួក៥នៃខន្ធ ) មានដោយអាការយ៉ាងនោះឯង តែខន្ធបញ្ចកៈដែលប្រកាន់ដោយន័យមានជាអាទិថារបស់យើង រមែងមិនមានដោយអាការយ៉ាងនោះឯង។

បទថា **សម្មប្បញ្ញាយ** ( ឃើញដោយបញ្ញាដ៏ប្រពៃ ) សេចក្ដីថា ឃើញដោយល្អ ដោយវិបស្សនាបញ្ញា ដែលមានសោតាបត្តិមគ្គបញ្ញាជាបរិ-យោសាន ។

បទថា **ឯវមេតាសំ** ( លះបង់ទិដ្ឋិទាំងនោះយ៉ាងនេះ ) បានដល់ ( លះបង់ ) ទិដ្ឋិទាំងនេះ ដោយឧបាយនេះ ។ ពាក្យថា ការលះបង់ ការរលាស់ចោល ពាក្យទាំង ២ នេះ ជាឈ្មោះនៃការលះបង់កិលេសបានដោយដាច់ជាសមុច្ឆេទនោះឯង ។

ព្រះមានព្រះភាគ ដែលព្រះមហាចុន្ទត្ថេរ សួរបញ្ហាដោយអំណាចនៃបុគ្គលអ្នកមានអធិមានះថា ការលះបង់ទិដ្ឋិទាំងទឡាយ មានបានដោយការធ្វើទុកក្នុងចិត្តជាដំបូងប៉ុណ្ណោះ ឬក៏មិនមែនទេ ? លុះទ្រង់សម្ដែងការលះបង់ដោយសោតាបត្តិមគ្គហើយ ឥទឡូវនេះ កាលនឹងទ្រង់ចំណែកឈានរបស់អ្នកអធិមានះដោយព្រះអង្គឯង ទើបបានត្រាស់ពាក្យមានជាអាទិថា ហេតុនេះតែងមានជាប្រាកដ ។ អ្នកមានអធិមានះកើតទេឡីង ដោយសម្គាល់ថា បានសម្រេចហើយក្នុងធមិដែលខ្លួនមិនទាន់បានសម្រេច ឈ្មោះថាអ្នកមានធិមានះ ក្នុងពាក្យថា **អធិមានិកានំ** ន៑ុះ ។ ក៏តែថា អធិមានះ ( មានះដ៏ក្រៃលែង ) នេះ កាលនឹងកើតទេឡីង នឹងមិនកើតទេឡីងដល់ពាលបុថុជ្ជន អ្នករពួកដល់លោកានុវត្តន៍

រឿយ ៗ ទេឡើយ នឹងមិនកើតយទេឡើងដល់អរិយសាវកទាំងទឡាយ ។ អធិប្បាយ ថា អធិមានៈថា យើងជាសកទាគាមី នឹងមិនកើតមានដល់ព្រះសោតាបន្ន អធិមានៈថា យើងជាព្រះអានាគាមី នឹងមិនកើតមានដល់ព្រះសកទាគាមី អធិមានៈថា យើងជាព្រះអរហន្ត នឹងមិនកើតមានដល់អនាគាមី តែនឹងកើត ចំពោះការកបុគ្គលប៉ុណ្ណោះ អ្នកគ្របសង្កត់កិលេសទុកបានដោយអំណាចសមថៈ ឬដោយអំណាចវិបស្សនា អ្នកប្រារព្ធវិបស្សនាហើយព្យាយាមជានិច្ច ។ ពិត ណាស់ ការកបុគ្គលនោះ កាលមិនឃើញការផុសផុលទេឡើងនៃកិលេសដែល គ្របសង្កត់ទុកបានដោយសមថៈ ឬ ដែលគ្របសង្កត់ទុកបានដោយវិបស្សនា អធិមានៈថា យើងជាព្រះសោតាបន្នខ្លះ យើងជាព្រះសកទាគាមីខ្លះ យើងជា អនាគាមីខ្លះ យើងជាព្រះអរហន្តនឹតកើតទេឡើង ដូចព្រះថេរៈទាំងទឡាយ ដែល ព្រះទិន្នត្ថេរ អ្នកអាស្រ័យនៅឯតលង្គរតិស្សបពិត បានដាស់តឿនហើយ ។

## រឿងព្រះធម្មទិន្នត្ថេរដាស់តឿនសិស្ស

បានឮថា ភិក្ខុច្រើនរូបបានតាំងខ្លួនទុកក្នុងឱវាទរបស់ព្រះថេរៈអ្នកឧប_ សម្បទាហើយមិនយូរប៉ុន្មានក៏បានសម្រេចគុណវិសេស ភិក្ខុសង្ឃអ្នកស្រុកតិស្ស មហាវិហារ បានជ្រាបព្រឹត្តិកម្មនោះហើយ យល់ឃើញថាព្រះថេរៈប្រកបក្នុង រឿងដែលប្រព្រឹត្តទៅមិនបាន លោកទាំងទឡាយចូរនាំព្រះថេរៈមក ហើយបាន

បញ្ជូនភិក្ខុច្រើនរូបទៅ ។ ភិក្ខុទាំងនោះទៅដល់ហើយ បានប្រាប់ថា ព្រះ-ធម្មទិន្ន ភិក្ខុសង្ឃហៅរកលោក ។ លោកពោលថា ម្នាលអាវុសោដ៏ចម្រើន លោកទាំងទឡាយស្វែងរកខ្លួនឬអ្នកដទៃ ។ ភិក្ខុទាំងទឡាយប្រាប់ថា ភិក្ខុទាំង-ទឡាយប្រាប់ថា យើងទាំងទឡាយស្វែងរកខ្លួន ។ ព្រះថេរៈបានឱ្យកម្មដ្ឋានដល់ភិក្ខុទាំងនោះភិក្ខុទាំងនោះបានសម្រេចអរហត្តទាំងអស់គ្រប់រូប ។ ភិក្ខុសង្ឃទើបបានបញ្ជូនភិក្ខុដទៃទៅទៀត ។ ភិក្ខុដែលសង្ឃបញ្ជូនទៅយ៉ាងនេះដល់ ៣ ដង ក៏បានសម្រេចព្រះអរហត្តដូចគ្នាទាំងអស់ហើយនៅ ( ជាមួយនឹងព្រះថេរៈ នោះ ) ។ តអំពីនោះមក ព្រះសង្ឃឃើញថា ភិក្ខុដែលទៅហើយ ៗ មិន ត្រទឡប់មក ទើបបានបញ្ជូនភិក្ខុចាស់មួយរូបទៅទៀត ។

ភិក្ខុចាស់នោះលុះទៅដល់ហើយ បាននិយាយថា បពិត្រព្រះធម្មទិន្ន ភិក្ខុសង្ឃសំណាក់តិស្សមហាវិហារ បញ្ជូនភិក្ខុមកកាន់សំណាក់លោកដល់ ៣ ដង តែលោកមិនធ្វើសេចក្តីគោរពអាណត្តិសង្ឃ មិន ( ទៅតាមពាក្យបញ្ជា ) ។ ព្រះថេរៈឆ្លើយថា មានការអ្វី ? ហើយឱ្យភិក្ខុចាស់នោះទទួលយកបាត្រ និង ចីវរដោយមិនចាំបាច់ចូលបណ្ណសាលាហើយចេញទៅភ្លាមក្នុងខណៈនោះឯង ។ បានចៀសទៅកាន់ហង្គណវិហារក្នុងរវាងផ្លូវ ។ ហើយក្នុងហង្គណវិហារនោះ មានមហាថេរៈមួយអង្គមានវស្សា ៦០ ប្លាយហើយ ប្តេជ្ញាខ្លួនថាជាព្រះអរហន្ត

ដោយអធិមានះ ។ ព្រះថេរៈចូលទៅរកលោកថ្វាយបង្គំ ធ្វើបដិសណ្ឋារៈ និងសួរដល់គុណធម៌ដែលបានសម្រេច ។ ព្រះថេរៈពោលថា អើ ! ធម្មទិន្នកិច្ចដែលបព្វជិតគប្បីធ្វើ ខ្ញុំបានធ្វើស្រេចយូរហើយ ឥឡូវនេះ ខ្ញុំក៏មានវស្សា ៦០ ឬឆ្លាយហើយ ។ ព្រះធម្មទិន្នសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ប្រើឫទ្ធិ ខ្លះដែរឬទេ? លោកឆ្លើយថា ប្រើ ធម្មទិន្ន ។ ព្រះធម្មទិន្នឆ្លើយថា ល្អហើយ លោកម្ចាស់ សូមនិមន្តលោកម្ចាស់និម្មិតដំរីដែលកំពុងដើរមករកលោកម្ចាស់_មើល៍ ។ ព្រះថេរៈទទួលពាក្យនិមន្តហើយ បាននិម្មិតដំរីមួយយ៉ាងធំ ជាទីថិតនៅនៃគជលក្ខណៈ ៧ ប្រការ ចុះប្រេងខ្លាំងក្លា ត្រចៀកន្ទុយស៊កប្រមោយចូល មាត់សម្រុកចូលរកព្រះថេរៈដូចយកភ្លុកទាំងពីរចាក់ ព្រះថេរៈឃើញដំរីដែលខ្លួននិម្មិតទេឡើងដោយខ្លួនឯងនោះ ខ្លាចផ្អើមនឹងរត់ចៀស ក្នុងពេលនោះឯងលោកក៏ដឹងខ្លួនថា យើងមិនទាន់បានជាព្រះអរហន្ត ទើបអង្គុយច្រហោងទៀបបាទមូលរបស់ព្រះធម្មទិន្នហើយពោលថា សូមលោកចូរជាទីពឹងដល់ខ្ញុំចុះ ។ ព្រះធម្មទិន្នបាននិយាយលួងលោមព្រះថេរៈថា បពិត្រលោកដ៏ចម្រើន លោកកុំសោកសៅ កុំខូចចិត្តទេឡើយ ព្រោះអធិមានះនឹងកើតមានចំពោះការកបុគ្គលទាំងឡាយប៉ុណ្ណោះ ហើយបានឱ្យកម្មដ្ឋាន ( ដល់ព្រះថេរៈ ) ។ ព្រះថេរៈតាំងនៅក្នុងឱវាទរបស់ព្រះធម្មទិន្នហើយបានសម្រេចព្រះអរហត្ត ។

សូម្បីព្រះថេរៈ ( មួយរូបទៀត ) ក៏ដូចគ្នា នៅឯចិត្តលបពិត ។ ព្រះធម្មទិន្នចូលទៅរកលោក ហើយសួរយ៉ាងនោះដូចគ្នា ។ ទាំងលោកក៏បានព្យាករណ៍ដូចគ្នា ។ បន្ទាប់អំពីនោះ ព្រះធម្មទិន្ន ក៏បានពោលនឹងលោកថា លោកបានប្រើឫទ្ធិខ្លះដែរឬទេ ? ព្រះថេរៈឆ្លើយថា ប្រើ ធម្មទិន្ន ។ ព្រះធម្មទិន្នប្រាប់លោកថា បពិត្រលោកដ៏ចម្រើន ល្អហើយ សូមលោកនិម្មិតស្រះ-បោក្ខរណីមួយចុះ ព្រះថេរៈបាននិម្មិត ( តាមដែលព្រះធម្មទិន្នសូម ) ព្រះ-ធម្មទិន្នប្រាប់ថា សូមលោកម្ចាស់និម្មិតគុម្ពឈូកទេឡើងក្នុងស្រះនេះផងចុះ ។ ព្រះថេរៈក៏និម្មិតគុម្ពឈូកទេឡើង ( តាមពាក្យដែលសុំ ) ព្រះធម្មទិន្នសូមឱ្យលោកនិម្មិតរូបស្ត្រីម្នាក់ឈរច្រៀងរាំដោយសម្លេងដ៏ពីរោះលើផ្កាឈូកនោះចុះ ។ ព្រះថេរៈក៏និម្មិតស្ត្រីនោះ ( តាមពាក្យដែលសុំ ) ។ ព្រះធម្មទិន្នទើបប្រាប់ថា សូមលោកសម្លឹងពិនិត្យមើលស្ត្រីនោះឱ្យរឿយ ៗ ហើយខ្លួនលោកក៏ចូលកាន់ប្រាសាទ កាលព្រះថេរៈសម្លឹងមើលរូបស្ត្រីដែលនិម្មិតនោះ កិលេសដែលគ្របសង្កត់ទុក អស់ ៦០ ឆ្នាំក៏កម្រើកញាប់ញ័រ ។ ក្នុងគ្រានោះលោកដឹងខ្លួន ទើបសូមរៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះធម្មទិន្នត្ថេរ ហើយបានសម្រេចព្រះអរហត្តដូចព្រះថេរៈមុន ។

ចំណែកព្រះធម្មទិន្ន ក៏បានទៅកាន់តិស្សមហាវិហារតាមលំដាប់ ។

ហើយក្នុងវេលានោះ ព្រះថេរៈទាំងឡាយបោសលានព្រះចេតិយ៍ហើយគង់ចំរើនកម្មដ្ឋាន ញ៉ាំងបីតិមានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតទេឡើង ។ ការធ្វើយ៉ាងនេះជាកិច្ចវត្តរបស់លោកទាំងនោះ ។ ព្រោះហេតុនោះ ទើបមិនមានព្រះថេរៈសូម្បីតែមួយរូប បណ្តាព្រះថេរៈទាំងនោះនឹងប្រាប់នឹងសួរព្រះធម្មទិន្នថា លោកចូរដាក់បាត្រ និងចីវរត្រង់នេះ ។ តែក៏ដឹងខ្លួនថា នុ៎ះគង់ជាព្រះធម្មទិន្ន ទើបបាននាំគ្នាសួរបញ្ហានឹងលោក លោកឆ្លើយកាត់បញ្ហាដែលសួរមក ៗ ដូចប្រើដាវដ៏មុតកាត់បាច់ផ្កាកោនុទៈឱ្យដាច់ក្បិលដូច្នោះហើយយកម្រាមជើងចុច មហាបឋវីហើយនិយាយថា បពិត្រលោកដ៏ចម្រើនមហាបឋវីនេះសូម្បីនឹងមិន មានចិត្តគង់ដឹងគុណព្រះធម្មទិន្នតែលោកទាំងទឡាយមិនដឹងទើបបានពោល គាថានេះថា

បពិត្រលោកដ៏ចម្រើន ផែនដីនេះមិនមានចិត្ត គង់នៅដឹងគុណ
តូចធំ ចំណែកអ្នកទាំងទឡាយមានចិត្ត តែមិនដឹងគុណតូចធំ ។

## សល្លេខធម៌គឺឈាន - វិបស្សនា

ហើយក្នុងពេលភ្លាមនោះឯង លោកក៏បានហោះទេឡើងទៅលើអាកាស ទៅកាន់តលង្គតិស្សបពិតនោះឯង ។

អធិមានះ រមែងកើតទេឡើងដល់ការកបុគ្គលប៉ុណ្ណោះ ដូចដែលពោល

មកហើយនេះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់ចំណែកឈាន ដោយអំណាចនៃភិក្ខុទាំងទឡាយអ្នកមានអធិមានះដូចនោះ ទើបបានត្រាស់ពាក្យ មានជាអាទិទុកថា « **ឋានំ ខោ បន** » ។

បទថា **ឋានំ ខោ បន** នោះ មានអត្ថាធិប្បាយថា ហេតុនេះតែង មានជាពិតប្រាកដ មិនមែនមិនមានទេ គឺភិក្ខុពួកខ្លះក្នុងសាសនានេះស្ងាត់ចាក កាមទាំងទឡាយ ។ល។ ចូលបឋមជ្ឈានដែលជាសាធារណៈដល់បរិព្វាជកខាង ក្រៅសាសនាទាំងទឡាយ ។

ប៉ុន្តែពាក្យណាដែលសម្តែងថា សេចក្តីថា **តស្ស ឯវមស្ស សល្លេខេន វិហរាមិ** ( អ្នកមានការយល់ឃើញយ៉ាងនេះថា យើងនៅដោយសល្លេខធមិ ធមិជាគ្រឿងជុសខាត់កិលេស ) សេចក្តីថា វិធីបដិបត្តិណារមែងជុសខាត់ កិលេសបាន យើងនៅដោយវិធីបដិបត្តិនោះ ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះ ថា ឈានរបស់ភិក្ខុអ្នកមានអធិមានះមិនមែនជាសល្លេខធមិ ឬ សល្លេខ_បដិបទា ។

ព្រោះហេតុអ្វី ? ព្រោះមិនមែនជាបាទរបស់វិបស្សនា ។ អធិប្បាយ ថា លោកចូលឈាន លុះចេញចាកឈានហើយ ក៏មិនបានពិចារណាសង្ខារ ទាំងទឡាយ ។ ចំណែកឈានក៏ធ្វើត្រឹមតែឱ្យចិត្តរបស់លោកជាឯកគ្គតាប៉ុណ្ណោះ

លោកក៏ជាអ្នកនៅសប្បាយក្នុងបច្ចុប្បន្ន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ-ជាម្ចាស់ កាលនឹងទ្រង់ត្រាស់សម្តែងសេចក្តីនោះ ទើបបានត្រាស់ថា ម្នាល ចុន្ទ ឈានធម៌ទាំងនោះតថាគតមិនហៅថា ជាសល្លេខធម៌ក្នុងវិន័យរបស់ព្រះអរិយៈទេឡើយ តែឈានធម៌ទាំងនោះ តថាគតហៅថា ទិដ្ឋធម្មសុខវិហារធម៌ (ធម៌គ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន) ក្នុងវិន័យរបស់ព្រះអរិយៈជាម្ចាស់ ។

ពាក្យថា **ឯតេ** (ទាំងនោះ ) ក្នុងព្រះពុទ្ធវចនៈនោះ គប្បីជ្រាបថា ជាពហុវចនៈដោយអំណាចនៃឈាន ។ មានពាក្យអធិប្បាយថា **ឯតេ យោគ បឋមជ្ឈានធម្មា** ប្រែថា (ធម៌ គឺ បឋមជ្ឈានទាំងនោះ ) ម្យ៉ាងទៀត ( ជាពហុវចនៈ ) ដោយអំណាចនៃសមាបត្តិ ។ អធិប្បាយថា បឋមជ្ឈាន សូម្បីឈានតែមួយ តែប្រព្រឹត្តទៅដោយការចូលរឿយ ៗ ក៏ដល់ភាពជារបស់ច្រើនបាន ។ ម្យ៉ាងទៀត ជាពហុវចនៈដោយអំណាចនៃអារម្មណ៍ ។ អធិ- ប្បាយថា បឋមជ្ឈានសូម្បីឈានតែមួយ ក៏ដល់ភាពជារបស់ច្រើនបាន ដោយការប្រព្រឹត្តិទៅក្នុងអារម្មណ៍ទាំងទឡាយ មានបឋវីកសិណជាដើម ។ ក្នុងទុតិ- យជ្ឈាន តតិយជ្ឈាន និង ចតុត្ថជ្ឈាន ក៏ន័យនេះដូចគ្នា ។

តែក្នុងអរូបឈានទាំងទឡាយ ( ពាក្យថា ទាំងនោះ ) គប្បីជ្រាបថា ជាពហុវចនៈដោយអំណាចនៃហេតុទាំង ២ ក្នុងឈានមុន (ចតុត្ថជ្ឈាន) នោះឯង

ព្រោះមិនមានសេចក្ដីផ្សេងគ្នានៃអារម្មណ៍ ។ ក៏ព្រោះហេតុដែល ទាំងអង្គ ទាំងអារម្មណ៍របស់អរូបឈានទាំងនោះ ស្ងប់ អធិប្បាយថា ទាំងរំលត់ស្និទ្ធ ទាំងល្អិត ព្រោះដូច្នោះ ទាំងអង្គ ទាំងអារម្មណ៍នោះ គប្បីជ្រាបថា ព្រះអង្គត្រាស់ទុក យ៉ាងនេះថា ឈានធមិទាំងនោះ ជាធមិដ៏ស្ងប់ ជាធមិគ្រឿងនៅដ៏ស្ងប់ ( សន្ត-វិហារធមិ ) ។ នេះជាការពង្រីកសេចក្ដីទូទៅរបស់អរូបឈានទាំង ៤ នោះមុន សិន ។ ចំណែកការពង្រីកសេចក្ដីដ៏វិសេសគួរពោល ( អធិប្បាយ) តាមទំនង បទជាដើមថា ព្រោះឈានកន្លងនូវរូបសញ្ញាហើយ ដោយប្រការទាំងពួង ។ ការពង្រីកសេចក្ដីនោះបានពោល( អធិប្បាយ) ទុកគ្រប់យ៉ាងក្នុងគម្ពីរវិ- សុទ្ធិមគ្គហើយ ។

ព្រោះហេតុដែលវិហារធមិ គឺ ឈានរបស់ភិក្ខុអ្នកមានអធិមានះមិនជា សល្លេខវិហារធមិ ព្រោះមិនជាបាទរបស់វិបស្សនា ដោយថា លោកចូលឈាន លុះចេញចាកឈានហើយ មិនបានពិចារណាសង្ខារទាំងឡាយទេ តែទិដ្ឋធម្ម- សុខវិហារធមិរបស់លោក ( ត្រឹមតែ ) ធ្វើឱ្យចិត្តជាឯកគ្គតាយ៉ាងនេះ ព្រោះ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្ដែងសេចក្ដីនោះ ទើបទ្រង់ ចែករូបឈាន និង អរូបជ្ឈានទុក ។ ហើយតទៅនេះ កាលនឹងទ្រង់សម្ដែង រឿងនោះ និង សល្លេខធមិនោះ ដោយអាការ ៤៤ យ៉ាង ទើបបានត្រាស់

ពាក្យមានជាអាទិទុកថា **ឥធ ខោ បន វោ** ដូច្នេះ ។

បាទរបស់វិបស្សនា

ហេតុដូចម្ដេចបានជាធម៌ទាំងទឡាយ មានវិហិង្សាជាដើមប៉ុណ្ណោះ ក្រៅពីសមាបត្តិទាំង ៨ យ៉ាង ព្រះមានព្រះភាគទើបត្រាស់ថា ជាសល្លេខធម៌ ?

ព្រោះធម៌ទាំងទឡាយមានអវិហិង្សាជាដើម ជាបាទរបស់វិបស្សនា ដែលជាលោកុត្តរៈបាន ។

ពិតណាស់ សមាបត្តិទាំង ៨ របស់បុគ្គលខាងក្រៅ ( ពុទ្ធសាសនា ) ទាំងទឡាយ ជាបាទរបស់វដ្ដៈប៉ុណ្ណោះ ។ តែក្នុងសាសនាព្រះ ( ពុទ្ធ ) សូម្បីសរណគមន៍ ក៏គប្បីជ្រាបថា ជាបាទរបស់លោកុត្តរធម៌បាន តាមព្រះសូត្រនេះ ដោយចំពោះនឹងចាំបាច់ពោលទៅថ្វីដល់ធម៌ទាំងទឡាយមានអវិហិង្សាជាដើម ទៅ ( ដែលនឹងប្រព្រឹត្តទៅមិនបាន ) ។

ម្យ៉ាងទៀត ទានដែលបុគ្គលថ្វាយដល់អ្នកដល់ព្រះរតនត្រ័យជាសរណៈក្នុងសាសនាព្រះ ( ពុទ្ធ ) មានផលច្រើនជាងទានដែលឱ្យដល់មនុស្សក្រៅសាសនាដែលបានសមាបត្តិ ៨ សូម្បីមានអភិញ្ញា ៥ ក៏ដោយ ។ ព្រោះថាក្នុងទក្ខិណាវិភង្គសូត្រ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះ ទើបបានត្រាស់ទុកថា ទក្ខិណាមានផលមួយសែនកោដិ ទាយកគប្បីសង្ឃឹមបាន ព្រោះ

ឱ្យទានដល់បុគ្គលក្រៅសាសនា អ្នកប្រាសចាកសេចក្ដីត្រេកអរក្នុងកាមទាំង-ទឡ្បាយ , តែទក្ខិណាមានផលរាប់មិនបាន ប្រមាណមិនត្រូវ ទាយកគប្បី សង្ឃឹមបាន ព្រោះឱ្យទានដល់អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិ-ផល ។ នឹងចាំបាច់ពោលទៅថ្វីដល់ព្រះសោតាបន្ន ។

សេចក្ដីពិត អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ក្នុងទក្ខិណាវិភង្គសូត្រនោះ ព្រះអង្គទ្រង់ប្រាថ្នាយកតាំងពីការដល់សរណៈជាដើម ទៅ ។ នេះជាការប្រកបសេចក្ដីតាមព្រះបាលីក្នុងសូត្រនេះសិន ។

ចំណែកការពណ៌នាតាមលំដាប់បទ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

បទថា **ឥធ** នេះជាពាក្យសម្ដែងរឿង មានការមិនបៀតបៀន ជាដើម ។

ពាក្យថា **ខោ បន** ត្រឹមតែជានិបាត ។

ពាក្យថា **វោ** ជា ឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ ។

ក៏ក្នុងពាក្យថា **ឥធ** ជាដើមនេះ មានសេចក្ដីសង្ខេបដូចតទៅនេះ ។ ម្នាលចុន្ទ អ្នកទាំងទឡ្បាយគួរធ្វើការជុសខាត់កិលេស ( សល្លេខ ) ក្នុងរឿងនៃការមិនបៀតបៀនជាដើមនេះនោះ ដែលតថាគតពោលទុកដោយន័យមានជាអាទិថា ពួកជនដទៃនឹងជាអ្នកបៀតបៀនគ្នា ។ ព្រះមានព្រះភាគជាម្ចាស់លុះ

ត្រាស់ដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងពង្រីកសេចក្ដីឱ្យពិស្ដារ ទើបបានត្រាស់ពាក្យមានជាអាទិថា ជនពួកដទៃនឹងជាបៀតបៀនគ្នា តែយើងទាំងទឡាយនឹងជាអ្នកមិនបៀតបៀនគ្នាក្នុងរឿងនេះ អ្នកទាំងទឡាយគួរបំបេញសល្លេខធម៌ដូចដែលពោលមកនេះ ។

ក្នុងចំនួនពាក្យទាំងនោះ ពាក្យថា **បរេ** ( ពួកជនទាំងទឡាយដទៃ ) បានដល់អ្នកណាៗ ក៏ដោយ ដែលប្រកបសល្លេខធម៌នេះរឿយៗ ។

សេចក្ដីថា **វិហឹសកា ភវិស្សន្តិ** (នឹងជាអ្នកបៀតបៀន) សេចក្ដី ថា នឹងជាអ្នកបៀតបៀនសត្វទាំងទឡាយដោយគ្រឿងបៀតបៀនទាំងទឡាយ មានបាទដៃ ឬ ដុំដីជាដើម ។

សេចក្ដីថា **មយមេត្ថ អវិហឹសកា ភវិស្សាម** ( យើងទាងំឡាយនឹងជាអ្នកមិនបៀតបៀនគ្នាក្នុងរឿងនេះ ) សេចក្ដីថា ចំណែកយើងទាំងទឡាយនឹងជាអ្នកមិនបៀតបៀនគ្នា ក្នុងរឿងដែលជាហេតុឱ្យអ្នកដទៃបៀតបៀនគ្នាយ៉ាងនេះប៉ុណ្ណោះ គឺ យើងទាំងទឡាយនឹងនៅដោយមិនឱ្យកើតការបៀតបៀនគ្នាទេឡើយ ។

បទថា **ឥតិ សល្លេខោ ករណីយោ** ( ព្រោះហេតុយ៉ាងនេះ ការជុសខាត់កិលេសជារបស់ដែលគួរធ្វើ) សេចក្ដីថា អ្នកទាំងទឡាយគួរបំពេញ

សល្លេខធម៌យ៉ាងនេះ ។ ហើយការមិនបៀតបៀនគ្នានោះឯង គប្បីជ្រាបថាជាសល្លេខធម៌ក្នុងទីនេះ ។ ព្រោះថាការមិនបៀតបៀនគ្នា និងជុសខាត់ គឺផ្តាច់ការបៀតបៀនគ្នាបាន ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា សល្លេខ ។ ក្នុងសេចក្តីគ្រប់យ៉ាងក៏មានន័យនេះ ។ តែមានសេចក្តីប្លែកគ្នាយ៉ាងនេះ (គឺ) ទិដ្ឋិក្នុងពាក្យថា **បរេ មិច្ឆាទិដ្ឋិ** ( អ្នកដទៃនឹងជាអ្នកមានការឃើញខុស ) នេះគប្បីជ្រាបថា ព្រះអង្គត្រាស់ទិដ្ឋិទុកដោយទ្រង់រួមមិច្ឆាទិដ្ឋិប្រការខាងចុងបំផុតនៃកម្មបថ ( អកុសលកម្មបថ ១០ ) និងមិច្ឆាទិដ្ឋិខាងដើម នៃមិច្ឆត្តៈ ( ការយល់ខុស ) ចូលជាមួយគ្នា ។ ម្យ៉ាងទៀត សម្មាទិដ្ឋិក្នុងឋានៈដែលត្រាស់ទុកថា យើងទាំងទឡ្ហាយនឹងជាអ្នកមានការឃើញត្រូវក្នុងរឿងនេះ និងកម្មបថក្នុងពាក្យថា យើងទាំងទឡ្ហាយនឹងជាអ្នកវៀរចាកបាណាតិបាត ក្នុងរឿង នេះជាដើម នេះនឹងមានសេចក្តីជាក់ច្បាស់ក្នុងសម្មាទិដ្ឋិសូត្រដោយពិស្តារ ចំណែកមិច្ឆាទិដ្ឋិក្នុងមិច្ឆត្តៈ ជាដើម នឹងជាក់ច្បាស់ក្នុង **ទ្វេធាវិតក្កសូត្រ** ( ខាងមុខ ) ។

## កម្មបថ - មិច្ឆត្តៈ

តែសេចក្តី ( ដែលនឹងពោលតទៅ ) នេះជាសេចក្តីក្នុងកម្មបថ និងមិច្ឆត្តៈនេះ ។

ចំណែកជនទាំងទឡាយណា ញុាំងសត្វដែលមានជីវិតឱ្យធ្លាក់ចុះកន្លងទៅ ព្រោះហេតុនោះ ជនទាំងទឡាយនោះឈ្មោះថា **បាណាតិបាតី** អធិប្បាយថា ជាអ្នកសម្លាប់សត្វមានជីវិត ។

ចំណែកជនទាំងទឡាយណា កាន់យកវត្ថុដែលគេមិនបានឱ្យ ព្រោះហេតុ នោះ ជនទាំងទឡាយនោះឈ្មោះថា **អទិន្នាទាយី** អធិប្បាយថា អ្នកលួច ទ្រព្យអ្នកដទៃ ។

ចំណែកជនទាំងទឡាយណា ប្រព្រឹត្តធម៌មិនប្រសើរ (មិនដូចព្រហ្ម ) គឺ ធម៌ថោកទាប បានដល់ ធម៌អាក្រក់ ព្រោះហេតុនោះ ជនទាំងទឡាយ នោះ ឈ្មោះថា **អព្រហ្មចារី** អធិប្បាយថា ជាអ្នកសេពមេថុនធម្ម ។

ចំណែកជនទាំងទឡាយណា ប្រព្រឹត្តធម៌ប្រសើរ គឺ បដិបទាប្រសើរ ជាទីបំផុត ព្រោះហេតុនោះ ជនទាំងទឡាយនោះ ឈ្មោះថា **ព្រហ្មចារី** អធិប្បាយថា ជាអ្នកវៀរចាកមេថុនធម្ម ។ ហើយព្រហ្មចារីគប្បីជ្រាបថា ជាសល្លេខធម៌ក្នុងពាក្យថា យើងទាំងទឡាយនឹងជាអ្នកប្រព្រឹត្តព្រហ្មចារី ព្រោះ ហេតុនេះ ។ ព្រោះថា ព្រហ្មចារី ( ការប្រព្រឹត្តិធម៌ដ៏ប្រសើរ ) រមែងជុស ខាត់កម្ចាត់អព្រហ្មចារី ( ការប្រព្រឹត្តិធម៌មិនប្រសើរ) បាន ។

ជនពួកណានិយាយកុហក ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា

មុសាវាទី អធិប្បាយថា អ្នកនិយាយវាចាទទេ គឺ ទេឡះទេឡាះដែលធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ។

ពួកជនអ្នកឈ្មោះថា មាន មិសុណវាចា ព្រោះមានវាចាស៊កសៀត។

ពួកជនអ្នកឈ្មោះថា មាន ផរុសវាចា ព្រោះមានវាចាត្រគោះបោះ បោកកម្ទាត់ចេញនូវវត្ថុដែលជាទីស្រឡាញ់របស់អ្នកដទៃ ។

ពួកជនណានិយាយច្រើន គឺ ឥតប្រយោជន៍ ព្រោះហេតុនោះ ជនទាំងទឡាយនោះឈ្មោះថា សម្ផប្បលាបី ( អ្នកនិយាយច្រើនឥតប្រយោជន៍ ) ។

ពួកជនណារមែងគយគន់ ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា មាន អភិជ្ឈា ជាប្រក្រតី អធិប្បាយថា ជាអ្នកសម្លឹងរំពៃចង់បានទ្រព្យអ្នក ដទៃ ។

ពួកជនអ្នកមានឈ្មោះថា មានចិត្តព្យាបាទ ព្រោះមានចិត្តព្យាបាទ គឺជាចិត្តខូច ។

ពួកជនអ្នកឈ្មោះថា មានការឃើញខុស ព្រោះឃើញឃ្លាងឃ្លាត គឺ លាមកបានដល់ដែលសប្បុរសតិះដៀល អធិប្បាយថា អ្នកប្រកបដោយ ( នត្ថិកទិដ្ឋិ ) មានជាអាទិថា ទានដែលឱ្យហើយមិនមានផល ដែលជា ( អកុសល ) កម្មបថ និង ទិដ្ឋិដែលមិននាំសត្វចេញចាកវដ្តៈ ដែលជាមិច្ឆតៈ

( មានសភាពខុស ) ។

តែពួកជនអ្នកឈ្មោះថា មានការឃើញត្រូវ ព្រោះមានការឃើញប្រពៃ គឺស្អាត បានដល់ដែលអ្នកប្រាជ្ញសរសើរ អធិប្បាយថា ប្រកបដោយការឃើញ ថា សត្វមានកម្មជារបស់ខ្លួន មានជាអាទិថា ទានដែលឱ្យហើយ មានផល ដែលជា ( កុសល) កម្មបថ និង ការឃើញក្នុងមគ្គដែលជា សម្មត្តៈ ( មានសភាពត្រូវ ) ។

បទថា **មិច្ឆាសង្កប្បា** បានដល់ ការត្រិះរិះក្នុងអកុសលដែលមិនប្រព្រឹត្តទៅតាមសេចក្តីពិត និងមិនជាគ្រឿងនាំសត្វចេញចាកវដ្តៈ ។

សូម្បីក្នុងមិច្ឆាវាចាជាដើមក៏មានន័យនេះ ។ តែមានសេចក្តីប្លែកគ្នាដូចតទៅនេះ ÷

សេចក្តីពិត ធម្មតាមិច្ឆាសតិក៏ដូចគ្នានឹងមិច្ឆាសង្កប្បៈជាដើម មិនមានអង្គធម៌តែមួយដោយចំពោះ គឺ មិនមានអង្គធម៌អ្វី ៗ ។ តែពាក្យថា មិច្ឆា_ សតិនេះ ជាឈ្មោះរបស់ខន្ធដែលជាអកុសលទាំង ៤ ដែលប្រព្រឹត្តទៅហើយ សម្រាប់អ្នកគិតដល់អតីតៈ ។ សូម្បីពាក្យណាដែលព្រះមានព្រះភាគត្រាស់ទុក ថា ម្នាលភិក្ខុទាំងទឡាយ តថាគតពោលថា អនុស្សតិនោះមាន មិនមែនមិន មានទេ ដែល បានដល់ អនុស្សតិរបស់អ្នកតាមរឭកដល់ការបានបុត្រ តាមរឭក

ដល់ការបានលាភ ឬ តាមរឭកដល់ការបានយស ណាភិក្ខុទាំងឡាយ ។ សូម្បីពាក្យនោះ គប្បីជ្រាបថា ព្រះអង្គត្រាស់សំដៅយកការកើតទេឡើងដោយការមិនមានសតិរបស់អ្នកគិតដល់រឿងនោះៗ ។

ក៏មោហៈដែលកើតទេឡើងដោយអំណាចការគិតដល់ឧបាយ ក្នុងការធ្វើបាបទាំងឡាយ និង ដោយអាការៈនៃការធ្វើអាក្រក់ ហើយពិចារណាថា យើងធ្វើល្អហើយ គប្បីជ្រាបថា ជាមិច្ឆាញាណក្នុងពាក្យថា **មិច្ឆាញាណី** អ្នកមានការដឹងខុស នេះ ។

បុគ្គលទាំងឡាយអ្នកប្រកបដោយមិច្ឆាញាណនោះ ឈ្មោះថា **មិច្ឆាញាណី** ។ ចំណែកបច្ចវេក្ខណញាណញែកចេញជា ៧៩ យ៉ាង ព្រះអង្គត្រាស់ហៅថា សម្មាញាណៈ ក្នុងពាក្យថា **សម្មាញាណី** (អ្នកមានការដឹង ប្រពៃ) នេះ ។ បុគ្គលទាំងឡាយអ្នកប្រកបដោយ សម្មាញាណៈ នោះ ឈ្មោះថា **សម្មាញាណី** ។

ពាក្យថា **មិច្ឆាវិមុត្តី** អ្នកមានការរួចផុតខុស គឺមិនទាន់រួចផុតតែមានការសម្គាល់យ៉ាងនេះថា យើងទាំងឡាយរួចផុតហើយ ឬមានការសម្គាល់ថាការមិនរួចផុតថាជាការរួចផុត ។

ក្នុងមិច្ឆាវិមុត្តិនោះ មានអត្ថដូចតទៅនេះ ÷

ពួកជនអ្នកមានឈ្មោះថា **មិច្ឆាវិមុត្តី** ( អ្នកមានការរួចផុតខុស ) ព្រោះមានការរួចផុតខុស គឺអាក្រក់ថោកទាប បានដល់វិបរិត ។ ម្យ៉ាងទៀត ពាក្យថា **មិច្ឆាទិដ្ឋិ** នេះ ជាឈ្មោះរបស់ខន្ធដែលជាអកុសល ដែលប្រព្រឹត្តទៅដោយអាការៈដូចដែលពោលមកហើយ ។ ចំណែកធមិ៏សេសដែលសម្បយុត្តជាមួយនឹងផលវៀរអង្គទាំង ៨ មានសម្មាទិដ្ឋិជាដើម គប្បីជ្រាបថា **វិមុត្តិ** ។ ហើយវិមុត្តិនោះ គប្បីជ្រាបថា ជាសល្លេខធមិ ព្រោះដុសខាត់កម្ចាត់មិច្ឆា-វិមុត្តិហើយស្ថិតនៅបាន ។

ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់ឱ្យភិក្ខុទាំងទឡាយប្រកបក្នុងសម្មាវិមុត្តិនោះ ទើបត្រាស់ពាក្យមានជាអាទិទុកថា យើងទាំងទឡាយនឹងជាអ្នកមានសម្មាវិមុត្តិក្នុងរឿងនេះ អ្នកទាំងទឡាយគួរបំពេញសល្លេខធមិយ៉ាងនេះ អកុសលទាំង ៣ តអំពីនេះទៅ ព្រះអង្គត្រាស់ទុកដោយអំណាចនៃនីវរណៈ តែព្រោះព្រះមានព្រះភាគត្រាស់ទុកហើយក្នុងកម្មបថទាំងទឡាយយ៉ាងនេះថា អ្នកគយគន់ចង់បានទ្រព្យអ្នកដទៃ អ្នកមានចិត្តព្យាបាទ ទើបគួរជ្រាបថា ព្រះអង្គត្រាស់នីវរណៈ២ ប្រការដំបូងទុកក្នុងពាក្យ នេះហើយ ។ ក្នុងចំនួននីវរណៈ ទាំង ៣ នោះ ពួកជនអ្នកត្រូវថីនមិទ្ធៈរួប រិតហើយ គឺ គ្របសង្កត់ហើយ ដូច្នោះ ទើបឈ្មោះថា **ថីនមិទ្ធបរិយុដ្ឋិតា** ( អ្នកត្រូវសេចក្តីងងុយងោកងក់

បៀតបៀនហើយ) ។

ពួកជនអ្នកឈ្មោះថា **ឧទ្ធតា** ( មានការរាយមាយ ) ព្រោះប្រកប ដោយការរាយមាយ ។

ពួកជនដែលឈ្មោះថា មាន **វិចិកិច្ឆា** ព្រោះនៅស្ទាក់ស្ទើរសង្ស័យ គឺ មិនអាចធ្វើសេចក្តីសម្រេចចិត្តបាន ។

អកុសលទាំង ១០ មានសេចក្តីក្រោធជាដើម ព្រះអង្គត្រាស់ទុកដោយ អំណាចនៃឧបក្កិលេស ។ ក្នុងចំនួនកិលេសទាំងទឡាយមានសេចក្តីក្រោធ ជា ដើមនោះ ពាក្យដែលគួរនឹងពោល ( អធិប្បាយ ) ទាំងអស់ ខ្ញុំម្ចាស់ពោល ទុកហើយក្នុងធម្មទាយាទសូត្រ និងវត្ថសូត្រ ។

តែក្នុងសូត្រនេះមានអត្ថវចនៈដូចតទៅនេះ ÷

ពាក្យថា **កោធនា** (ច្រើនក្រោធ) គឺមានសេចក្តីក្រោធជាប្រក្រតី ។

ពាក្យថា **ឧបនាហី** ( ចងសេចក្តីក្រោធ ) គឺមានការចងសេចក្តី ក្រោធជាប្រក្រតី ម្យ៉ាងទៀត ឈ្មោះថា **ឧបនាហី** ព្រោះអ្នកទាំងនោះមាន ការចងសេចក្តីក្រោធ ។ **មក្ខី** (អ្នកលុបគុណគេ) **បលាសី** (អ្នកវាយ ឫកស្មើ) ក៏ដូច្នោះដូចគ្នា ។

ពួកជនដែលឈ្មោះថា **ឥស្សុកី** ព្រោះច្រើនដោយសេចក្តីច្រណែន ។

ពួកជនដែលឈ្មោះថា **មច្ឆរី** ព្រោះច្រើនទៅដោយសេចក្តីកំណាញ់ ។ ម្យ៉ាងទៀត ជនទាំងនោះមានសេចក្តីកំណាញ់ ។

ពួកជនអ្នកអួតអាង ជនទាំងនោះឈ្មោះថា **សឋា** ( អ្នកអួតអាង ) មានពាក្យអធិប្បាយទុកថា មិននិយាយដោយប្រពៃ ( ធមិ ) ពាក្យថា **សឋា** នេះ ជាឈ្មោះរបស់ពួកជនអ្នកប្រកបដោយហេតុដែលធ្វើឱ្យថោកទាប ។

មាយារបស់ជនទាំងនោះមាន ដូច្នោះ ទើបជនទាំងនោះ ឈ្មោះថា **មាយាវី** ( អ្នកមានមាយា ) ។

ពួកជនអ្នកឈ្មោះថា **ថទ្ធា** (មានភាពរឹងត្អឹង ) ព្រោះប្រកបដោយភាពរឹងត្អឹង ។ ពួកជនអ្នកឈ្មោះថាមានមានះក្រៃលែង ព្រោះប្រកបដោយការប្រមាទមើលងាយគេ ។ ចំណែកធមិដែលជាចំណែកសុក្កធមិ គប្បីជ្រាបដោយន័យនៃធមិផ្ទុយគ្នា ដូចដែលបានពោលទុកហើយ ។

ពាក្យថា ជាអ្នកប្រដៅក្រ សេចក្តីថា ជាអ្នកលំបាកនឹងប្រដៅបាន គឺត្រូវប្រដៅយ៉ាងណាហើយក៏អត់ធន់មិនបាន ។ ពួកជនអ្នកផ្ទុយគ្នានឹង ប្រដៅ ក្រនោះ ឈ្មោះថាជាអ្នកប្រដៅងាយ ។

ពួកជនដែលឈ្មោះថា មានមិត្តអាក្រក់ ព្រោះមានមិត្តអាក្រក់ ដូចព្រះទេវទត្តជាដើម ។

ពួកជនដែលឈ្មោះថា មានកល្យាណមិត្ត ព្រោះមានមិត្តល្អ គឺ ព្រះ-ពុទ្ធជាម្ចាស់ ឬ សាវ័កទាំងឡាយដូចព្រះសារីបុត្រជាដើម ជាមិត្ត ។

ពួកជនដែលផ្ទុយគ្នានឹងអ្នកមិនប្រមាទហើយ ដោយអំណាចនៃការបណ្តោយចិត្តទៅក្នុងកាយទុច្ចរិតជាដើម គប្បីជ្រាបថា ជាអ្នកប្រមាទហើយ។

ទាំង ៣ យ៉ាងនេះព្រះអង្គត្រាស់ទុកដោយភាពជាបកិណ្ណកៈ ចំណែក៧ យ៉ាងមានភាពជាអ្នកមិនមានសទ្ធាជាដើម ព្រះអង្គត្រាស់ទុកដោយភាពជា អសទ្ធម្ម ។ ក្នុងចំនួន ៧ យ៉ាងនោះ ពួកជនដែលឈ្មោះថា មិនមានសទ្ធា ព្រោះមិនមានការជឿក្នុងវត្ថុទាំង ៣ ( ព្រះរតនត្រ័យ ) ។ ក្នុងធម៌ដែលជាចំណែកសុក្កធម៌ គប្បីជ្រាបអធិប្បាយដូច្នេះ ជនពួកណាជឿដូច្នោះ ជនពួកនោះឈ្មោះថា ជាអ្នកជឿ ឬ ឈ្មោះថាមានសទ្ធា ព្រោះមានការជឿ ពួកជនដែលឈ្មោះថា **អហិរិកៈ** ព្រោះមិនមានសេចក្តីខ្មាស់បាប ។

ពាក្យថា **អហិរកៈ** នេះជាឈ្មោះរបស់អ្នកមិនខ្ពើមរអើមចំពោះការបដិបត្តិអកុសលធម៌ ។

ពួកជនដែលឈ្មោះថា មានសេចក្តីខ្មាស់ដល់ចិត្ត ព្រោះមានសេចក្តីខ្មាស់ក្នុងចិត្ត ឬ មានចិត្តប្រកបដោយសេចក្តីខ្មាស់ ។

ជនពួកណាមិនតក់ស្លុត (ចំពោះបាប) ដូច្នោះ ទើបជនពួកនោះ

ឈ្មោះថា មិនមានឱត្តប្បៈ មានពាក្យអធិប្បាយទុកថា មិនខ្លាចចំពោះការប្រព្រឹត្តិអកុសលធម៌ ។ ប៉ុន្តែអ្នកដែលផ្ទុយគ្នានឹងគេ ឈ្មោះថា ជាអ្នកមាន ឱត្តប្បៈ ( ក្រែងខ្លាចបាប ) ។

ពួកជនដែលឈ្មោះថា ខ្វះការសិក្សា ព្រោះមានការសិក្សាតិច តែ ការតិចមិនគួរយល់ថាបានដល់ការតិចតួច ។ ត្រូវយល់ថាមិនមានការ សិក្សាសោះ ។ ព្រោះថា អ្នកមិនមានការសិក្សា ( សុតៈ ) ។ គឺគ្មានការ សិក្សាព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា អ្នកខ្វះការសិក្សា ( សុតៈ ) ។

ប៉ុន្តែពួកជនដែលឈ្មោះថា ជាពហូសូត ព្រោះមានការសិក្សា ( សុតៈ ) ច្រើន ។

ពាក្យថា **ពហុស្សុតា** នេះ ជាឈ្មោះរបស់ពួកជនដែលចេះចាំព្រះពុទ្ធភាសិត គឺ កថាសូម្បីរឿងមួយដោយច្បាស់ហើយបដិបត្តិធម៌សមគួរដល់ ធម៌ ។

ពួកជនដែលឈ្មោះថា ខ្ជិលច្រអូស ព្រោះលិចចុះ ( កាន់ភារៈដែល គួរខ្ពើម ) ពាក្យនេះជាឈ្មោះរបស់អ្នកសាបសូន្យសេចក្ដីព្យាយាមហើយ ។

ពួកជនដែលឈ្មោះថា ប្រារព្ធសេចក្ដីព្យាយាមហើយ ព្រោះមានសេចក្ដីព្យាយាមដែលប្រារព្ធហើយ ពាក្យនេះជាឈ្មោះរបស់ពួកជន ដែលប្រកបដោយ

សេចក្តីព្យាយាមដ៏ប្រពៃ ។

ពួកជនដែលឈ្មោះថា មានសតិវង្វេងហើយ ព្រោះមានសតិភាន់ភាំង ហើយមានពាក្យអធិប្បាយទុកថា មានសតិវិនាសហើយ ។

ពួកជនដែលឈ្មោះថា អ្នកតម្កល់សតិបានហើយ ព្រោះមានសតិដែលខ្លួនតម្កល់ទុកជិតស្និទ្ធហើយ ។ ពាក្យថា **ឧបដ្ឋិតស្សតី** នេះជាឈ្មោះរបស់អ្នកបដិបត្តិទាំងទឡាយ ដែលមានសតិប្រឈមមុខនឹងអារម្មណ៍ជានិច្ច ។

ពួកជនដែលឈ្មោះថា អ្នកអាប់ឥតបញ្ញា ព្រោះគ្មានបញ្ញា មានពាក្យអធិប្បាយទុកថា មានបញ្ញាវិនាសហើយ ។ ពួកជនដែលឈ្មោះថា មានបញ្ញាសម្បូរព្រោះដល់ព្រមដោយបញ្ញា ។

តែបញ្ញាក្នុងទីនេះ គប្បីជ្រាបថា បានដល់ វិបស្សនាបញ្ញា ។ ព្រោះ ថាអង្គប្រកបរបស់វិបស្សនាមានមកគ្រប់ចំនួនក្នុងទីនេះ ព្រោះដូច្នោះ បូរាណទើបមានបង្គាប់ទុកថា បញ្ញានេះ គឺ វិបស្សនាបញ្ញាប៉ុណ្ណោះ ។ តទៅនេះកាលនឹងទ្រង់ត្រាស់សម្តែងទិដ្ឋិដែលជាធមិមិននាំសត្វចេញចាកវដ្តៈ នឹងធ្វើអន្តរាយដល់គុណធមិដែលជាលោកុត្តរៈដោយអាការៈ ៣ យ៉ាង ទើបត្រាស់ពាក្យមានជាអាទិទុកថា **សន្ទិដ្ឋិបរាមាសី** អ្នកស្ទាប អង្អែលទិដ្ឋិរបស់ខ្លួន ( ប្រកាន់តាមការយល់ឃើញ) ។

ក្នុងពាក្យថា **សន្ទិដ្ឋិបរាមាសី** ជាដើមនោះ គប្បីជ្រាបអធិប្បាយ ដូច្នេះថា ៖

ពួកជនដែលឈ្មោះថា **សន្ទិដ្ឋិបរាមាសី** ព្រោះប្រកាន់ទិដ្ឋិរបស់ខ្លួន។

ពួកជនដែលឈ្មោះថា **អាធានគាហី** ព្រោះប្រកាន់ទុកមាំ សេចក្ដីប្រកាន់មាំ លោកហៅថា អាធានៈ អធិប្បាយថា អ្នកប្រកាន់មាំ ។

ពួកជនដែលឈ្មោះថា ជាអ្នករលាស់ចោល ព្រោះឃើញហេតុដ៏ត្រឹមត្រូវហើយ ក៏លះបង់ ( លទ្ធិចាស់ ) ចោល ។ តែពួកជនដែលឈ្មោះថា **ទុប្បដិនិស្សគ្គី** ព្រោះ (លះបង់បាន) ដោយកម្រ គឺ ដោយលំបាក បានដល់តឹង អធិប្បាយថា ឃើញហេតុច្រើនសន្ទឹកសន្ធាប់ ក៏មិនអាចលះបង់ បាន ។ ពាក្យថា **ទុប្បដិនិស្សគ្គី** នេះជាឈ្មោះរបស់ពួកជនដែលប្រកាន់មាំនូវទិដ្ឋិដែលកើតទេឡើងដល់ខ្លួនថា វត្ថុនេះប៉ុណ្ណោះពិត សូម្បីព្រះពុទ្ធជាដើមនឹងទ្រង់សម្ដែងហេតុផលឱ្យស្ដាប់ក៏មិនលះបង់ចោល ។ អធិប្បាយថា បុគ្គលប្រភេទនោះ ស្ដាប់រឿងណាៗមក ទោះជារឿងធម្មៈ ឬ មិនមែនធម្មៈក៏ដោយ ប្រមូលរឿងទាំងអស់នោះទុកខាងក្នុង ( ខួរក្បាល ) នោះឯងថា អាចារ្យរបស់យើងទាំងទឡាយពោលទុកយ៉ាងនេះ យើងទាំងទឡាយបាន ស្ដាប់មកយ៉ាងនេះ ។ ដូចអណ្ដើកលាក់អវយវៈទាំងទឡាយទុកខាងក្នុងស្នូករបស់ខ្លួន គឺ ប្រកាន់ ( ទិដ្ឋិ

ទុក ) មិនព្រលែងចោល ដូចការត្របាក់របស់ក្រពើ ។ ចំណែកសុក្កធម៌គប្បីជ្រាបដោយបរិយាយផ្ទុយគ្នានឹងសេចក្តីដែលពោលមកហើយ ។

ព្រះមានព្រះភាគ លុះទ្រង់ត្រាស់សម្តែងសល្លេខធម៌ដោយអាការ ៤៤ ប្រការយ៉ាងនេះហើយ ដើម្បីនឹងទ្រង់ត្រាស់សម្តែងថា សូម្បីការកើតទេឡើងនៃចិត្តក្នុងសល្លេខធម៌នោះក៏ជាធម៌មានឧបការៈច្រើន ទើបបានត្រាស់ពាក្យមានជាអាទិទុកថា សូម្បីការកើតទេឡើងនៃចិត្ត តថាគត...

ពាក្យថា **ចិត្តុប្បាទម្បិ ខោ អហំ** ជាដើមនោះ មានសេចក្តីថា ម្នាលចុន្ទ សូម្បីការកើតទេឡើងនៃចិត្តក្នុងកុសលធម៌ទាំងទឡាយ តថាគតក៏ពោល ថា មានឧបការៈច្រើន នឹងពោលទៅថ្វីក្នុងការចាត់ចែងធ្វើដោយកាយ និង ដោយវាចា គឺ ធ្វើធម៌ទាំងនោះ និងបង្គាប់ដោយវាចាថា អ្នកទាំងទឡាយចូរនាំ គ្នាធ្វើ ឬ ការរៀន ការសាកសួរជាដើម ដូចចិត្តដួងដំបូងដែលកើតទេឡើង ព្រោះថា ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងទុកថា ការចាត់ចែងធ្វើនោះមានឧបការៈច្រើនដោយចំណែកមួយនោះឯង ។

សួរថា ក៏ហេតុដូចម្តេច សូម្បីការកើតទេឡើងនៃចិត្តក្នុងកុសលធម៌ទាំង នោះ ទើបមានឧបការៈច្រើន ។

ឆ្លើយថា ព្រោះនាំប្រយោជន៍ និងសេចក្តីសុខមកឱ្យដោយចំណែកមួយ

ផង ព្រោះជាហេតុនៃការចាត់ចែងធ្វើតាមលំដាប់ផង ។

ពិតណាស់ការកើតទេឡើងនៃចិត្តថាយើងនឹងថ្វាយទានដោយកម្លាំង របស់ខ្លួន វាក៏ជាហេតុនាំមកនូវប្រយោជន៍ និង សេចក្ដីសុខមកឱ្យដោយ ចំណែកមួយ ហើយទាំងជាហេតុឱ្យចាត់ចែងធ្វើតាមលំដាប់ផង ។ ក៏ព្រោះកើត ការគិតទេឡើងយ៉ាងនេះ ( ក្នុងថ្ងៃដំបូង ) នោះឯង ក្នុងថ្ងៃទី ២ ទើបបិទថ្នល់ធំ កសាងបារាំធំ ហើយថ្វាយទានដល់ភិក្ខុ១០០រូបឬ ១០០០រូបបានប្រាប់ មិត្តជិតខាងថា ចូរនិមន្ត ចូរបូជា ចូរអង្គាសព្រះភិក្ខុសង្ឃចុះ ដូច្នេះ ការកើត ទេឡើងនៃចិត្តថា យើងនឹងថ្វាយចីវរ សេនាសនៈ និង ភេសជ្ជៈដល់ព្រះសង្ឃ យ៉ាងនេះ ដោយកម្លាំរបស់ខ្លួន វាក៏ជាហេតុនាំប្រយោជន៍ និង សេចក្ដីសុខមក ឱ្យបានដោយចំណែកមួយ ទាំងជាហេតុឱ្យចាត់ចែងធ្វើតាមលំដាប់ដោយប្រការ ដូច្នេះ ។ ពិតណាស់ ព្រោះមានចិត្តកើតទេឡើងយ៉ាងនេះនោះឯង ទើបមនុស្ស ចាត់ចែងត្រៀមចីវរជាដើម នាំគ្នាថ្វាយទាន ។

ក្នុងការដល់សរណៈជាដើមក៏មានន័យដូច្នោះ ។ អធិប្បាយថា បុគ្គល កើតការគិតទេឡើង ( មុន ) ថា យើងនឹងដល់សរណៈ ខាងក្រោយទើបទទួល សរណៈដោយកាយ ឬ ដោយវាចា ម្យ៉ាងទៀត បុគ្គលកើតការគិតទេឡើង ( មិន) ថា យើងសមាទានសីលមានអង្គ ៥ មានអង្គ ៨ ឬ អង្គ ១០ ហើយ

ទើបសមាទានដោយកាយ ឬ ដោយវាចា ។ នឹងអ្នកបួសហើយក៏កើតការគិតទេឡើង ( មុន ) ដូចគ្នាថា យើងនឹងតាំងមាំនៅក្នុងសីលទាំង ៤ ហើយទើបញុំាងសីលដែលគួរឱ្យបរិបូរណ៍ដោយកាយ និង វាចាឱ្យបរិបូរណ៍ ។

អ្នកកើតការគិតទេឡើង ( មុន ) ថា យើងរៀនព្រះពុទ្ធវចនៈហើយ ទើបនឹងរៀនព្រះពុទ្ធវចនៈបាន១និកាយ២និកាយ៣និកាយ៤និកាយឬ ៥ និកាយ ។

គួរនាំ ( រឿងចិត្តុប្បាទមកសម្តែងយ៉ាងនេះ ) ដោយអំណាចនៃការសមាទានធុតង្គ ការរៀនព្រះកម្មដ្ឋាន ការបរិកម្មកសិណ ការចូលឈាន ការ ( ចម្រើន) វិបស្សនា មគ្គ ផល បច្ចេកពោធិញាណ និង សម្មាសម្ពោធិញាណ ព្រោះថាការកើតការគិតទេឡើងថា យើងនឹងជាព្រះពុទ្ធ ដោយកម្លាំងរបស់ខ្លួននោះក៏ជាហេតុនាំប្រយោជន៍ និង សេចក្តីសុខមកឱ្យបានដោយចំណែកមួយហើយនោះជាហេតុឱ្យចាត់ចែងធ្វើតាមលំដាប់ផង ។ អធិប្បាយថា ព្រោះកើតការគិតទេឡើងយ៉ាងនេះឯង សម័យតមក ( ព្រះពោធិសត្វ ) ទើបបំពេញបារមីដោយកាយ និង វាចា រហូតវេលា ៤ អសង្ខេយ្យកម្រៃមួយសែនកប្ប ហើយ ( បានត្រាស់ដឹង ) ស្តេចយាងប្រោសសត្វលោក ព្រមទាំងទេវលោក ឱ្យឆ្លងផុត ( ឱ្យឆ្លងផុតឱយសង្សារ ) សូម្បីកើតការគិតទេឡើងក្នុងកុសលធម៌

គ្រប់យ៉ាងក៏មានឧបការច្រើនដូចដែលពណ៌នាមកនេះ តែការចាត់ចែងធ្វើតាមលំដាប់ដោយកាយ និង វាចា គប្បីជ្រាបថា មានឧបការច្រើនក្រៃលែងពិត ។ ព្រះមានព្រះភាគលុះទ្រង់សម្ដែងចិត្តុប្បាទទាំងនោះ ទើបបានត្រាស់ពាក្យមានជាអាទិទុកថា ម្នាលចុន្ទ ព្រោះហេតុនោះឯង ។ ពាក្យនោះដោយខ្លឹមសារប្រាកដច្បាស់ហើយ ។

## អវិហិង្សាដូចកំពង់ទឹកដែលរាបស្មើ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងចិត្តុប្បាទក្នុងសល្លេខធម៌ដែលព្រះអង្គទ្រង់សម្ដែងហើយដោយអាការៈ ៤៤ យ៉ាង ថាមានឧបការច្រើនយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងសល្លេខធម៌នោះឯងថាជាផ្លូវនៃការសម្រេចប្រយោជន៍ ទើបបានត្រាស់ពាក្យមានជាអាទិទុកថា **សេយ្យថាបិ** ( សូម្បីដូច្នេះ ) ។ ពាក្យនោះមានអធិប្បាយថា ម្នាលចុន្ទ ឧបមាដូចជាមានផ្លូវដែលរដិបរដុបទៅដោយដង្គត់ឈើបន្លា និង ថ្មត្រូវមានផ្លូវដទៃដែលរាបស្មើដូចផ្ទៃដីដែលពង្រាបទុកល្អហើយដើម្បីចៀសវាង គឺ ដើម្បីត្រូវការវៀរផ្លូវដែលរដិបរដុបមិនស្មើនោះយ៉ាងណា ម្យ៉ាងទៀត មានកំពង់ទឹកដែលមិនរាបស្មើមានគល់ឈើ មានថ្ម និង ក្រទឡុករណ្ដៅពោរពេញទៅដោយអន្តរាយមានក្រពើ និងឆ្លាមករជាដើម ត្រូវមានកំពង់ទឹកដែលរាបស្មើជ្រេចុះទៅតាមលំដាប់ដូច

កាំជណ្ដើរដើម្បីគេច គឺ ដើម្បីត្រូវការចៀសវាងកំពង់ទឹកដែលមិនរាបស្មើនោះ ដែលបុគ្គលដើរទៅហើយឈៀងចុះកាន់ស្ទឹង ឬ ស្រះហើយងូតទឹក ឬ ទេឡើងមក បានដោយស្រួលយ៉ាងណា ។ ម្នាលចុន្ទ អវិហិង្សាក៏ដូច្នោះដូចគ្នានោះឯង ដូចផ្លូវដែលរាបស្មើ និង កំពង់ដែលរាបស្មើ មានដើម្បីចៀសវាងបុគ្គលមាន វិហិង្សា អ្នកប្រកបដោយការបៀតបៀន ដែលដូចជាកំពង់ដែលមិនរាបស្មើ ។ ពិតណាស់ ផ្លូវដែលរាបស្មើ និង កំពង់ទឹកតុបតែងហើយ មានទុកដើម្បីចៀសវាងផ្លូវដែលមិនរាបស្មើ និង កំពង់ដែលមិនរាបស្មើ យ៉ាងណាមិញ អ្នកបដិបត្តិដើម្បីត្រូវការចៀសវាងវិហិង្សា និង ដើម្បីកែលម្អ ( ខ្លួន ) ដោយអវិហិង្សាក៏ដូច្នោះដូចគ្នា និង ទាញយកគតិមនុស្ស ឬ គតិទេព សោយសម្បត្តិ ឬ ឆ្លងផុតលោកបានដោយងាយ ។ គ្រប់ៗ បទគួរប្រកបដោយទំនងនេះដូចគ្នា ។

## អធោភាវង្គមនីយឧបរិភាវង្គមនីយៈ

ព្រះមានព្រះភាគជាម្ចាស់លុះទ្រង់សម្ដែងសល្លេខធម៌ថា ជាផ្លូវនៃការជួបប្រសព្វប្រយោជន៍យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ត្រាស់សម្ដែងភាវៈដែលសល្លេខធម៌ឱ្យដល់ភាពខ្ពង់ខ្ពស់ ទើបបានត្រាស់ពាក្យមានជាអាទិទុកថា **សេយ្យថាបិ** ( សូម្បីយ៉ាងណា ) ទុក ។ ពាក្យនោះមានអត្ថាធិប្បាយថា ម្នាល ចុន្ទ ដូចយ៉ាងថា អកុសលធម៌ដែលឱ្យកើតបដិសន្ធិ ឬ មិនឱ្យកើតក៏ដោយ

សូម្បីកាលឱ្យបដិសន្ធិហើយ និងឱ្យកើតវិបាក ឬ មិនឱ្យកើតក៏ដោយ ទាំងអស់នោះពោលដោយជាតិហើយ នឹងមានឈ្មោះយ៉ាងនេះថា **អធោភាវង្គមនីយ** ( ជាធម៌ឱ្យដល់ភាពថោកទាប ) ព្រោះអកុសលធម៌ទាំងនោះក្នុងវេលាឱ្យវិបាក ជាវិបាកដែលមិនគួរប្រាថ្នា មិនគួរពេញចិត្ត យ៉ាងណា ចំណែកកុសលធម៌ដែលឱ្យកើតបដិសន្ធិ ឬ មិនឱ្យកើតក៏ដោយ សូម្បីកាលឱ្យបដិសន្ធិហើយនឹងឱ្យកើតវិបាក ឬ មិនឱ្យកើតក៏ដោយ ទាំងអស់នោះពោលដោយជាតិហើយនឹងមានឈ្មោះយ៉ាងនេះថា **ឧបរិភាវង្គមនីយ** ( ជាធម៌ឱ្យដល់ភាពខ្ពង់ខ្ពស់ ) ព្រោះកុសលធម៌ទាំងនោះ ក្នុងវេលាឱ្យវិបាក ជាវិបាកដែលគួរប្រាថ្នា គួរពេញ ចិត្ត យ៉ាងណា ។ ម្នាលចុន្ទ អវិហិង្សាក៏ដូច្នោះដូចគ្នា មានដើម្បីភាពខ្ពង់ខ្ពស់នៃបុគ្គលអ្នកមានវិហិង្សា ។ ក្នុងរឿងនោះមានការប្រៀបធៀបរវាងឧបមា និងឧបមេយ្យដូចតទៅនេះ ។ អកុសលធម៌ទាំងអស់នោះជាធម៌ញ៉ាំងសត្វឱ្យធ្លាក់ទៅកាន់ទីថោកទាប យ៉ាងណា សូម្បីវិហិង្សាតែមួយដែលជាធម៌ញ៉ាំងខ្លួនឱ្យធ្លាក់ទៅកាន់ទីថោកទាប សម្រាប់អ្នកមានវិហិង្សាក៏ដូច្នោះ ។ ចំណែកកុសលធម៌ទាំងអស់ ជាធម៌តែងញ៉ាំងសត្វឱ្យទេឡើងទៅកាន់ទីខ្ពស់ យ៉ាងណា សូម្បីអវិ-ហិង្សាតែមួយ ជាធម៌តែងញ៉ាំងខ្លួនឱ្យទេឡើងទៅកាន់ទីខ្ពង់ខ្ពស់សម្រាប់អ្នកមិនមានវិហិង្សាក៏ដូច្នោះ ។ គួរប្រៀបធៀបអកុសល និងអកុសល កុសល និងកុសល

ដោយឧបាយនេះនោះឯង ។ បានជ្រាបថា ក្នុងរឿងនេះមានអធិប្បាយដូចត ទៅនេះ ÷

## បញ្ចកាមគុណគឺភក់

ព្រះមានព្រះភាគលុះទ្រង់សម្តែងសល្លេខធម៌ថា ជាធម៌តែងញ៉ាំងសត្វ ឱ្យទៀងទៅទីខ្ពង់ខ្ពស់យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងថា សល្លេខធម៌ ជាធម៌អាចក្នុងការញ៉ាំងកិលេសរបស់គេឱ្យរលត់ទៅដោយជុំវិញ (ឱ្យដល់ព្រះ និព្វាន ) ទើបបានត្រាស់ពាក្យជាអាទិទុកថា **សោ វត ចុន្ទ** ( ម្នាលចុន្ទៈ នោះហ្ន៎ ) ។

បណ្តាបទទាំងនោះ បទថា **សោ** ( នោះ ) សម្តែងដល់បុគ្គល ប្រភេទដែលពោលមកហើយ ។

គួរជ្រាបដល់ការនាំយកពាក្យឧទ្ទេសនេះថា **យោ** នៃបទថា **សោ** នោះ មកភ្ជាប់គ្នាគ្រប់បទយ៉ាងនេះថា បុគ្គលណាមុជចុះក្នុងភក់ គឺ កាម_ គុណដោយខ្លួនឯងហើយ បុគ្គលនោះឯងនឹងជួយស្រង់បុគ្គលដទៃដែលមុជចុះ ក្នុងភក់គឺកាមគុណដូចគ្នា ហេតុដូច្នេះនេះ មិនដែលមានទេ អ្នកលិចចុះក្នុង ភក់ដ៏ជ្រៅ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅថា **បលិបបលិបន្នោ** ( អ្នក មុជចុះក្នុងភក់ ) តែមិនមែនហៅក្នុងអរិយវិន័យទេ ។ ចំណែកក្នុងអរិយវិន័យ

ព្រះអង្គទ្រង់ហៅបញ្ចកាមគុណថា **បលិប** ( ភក់ ) ពាលបុថុជ្ជនមុជចុះក្នុងបញ្ចកាមគុណនោះ ឈ្មោះថា **បលិបន្ន** ( អ្នកមុជចុះក្នុងបញ្ចកាមគុណ ) ។

ព្រោះដូច្នោះ គួរជ្រាបការប្រកបសេចក្តីក្នុងពាក្យនេះថា **សោ វត ចុន្ទ** ជាដើមនេះ ( តទៅ ) ម្នាលចុន្ទៈ បុគ្គលខ្លះមុជចុះក្នុងភក់ដ៏ជ្រៅរហូត ដល់ចុងច្រមុះនឹងចាប់ដៃ ឬ ក្បាលបុគ្គលម្នាក់ទៀតដែលមុជចុះក្នុងភក់នោះ ហើយទាញទេឡើងមក សេចក្តីនេះមិនជាហេតុដែលប្រព្រឹត្តទៅបានទេ អធិ- ប្បាយថា ហេតុដែលគេនឹងជួយទាញបុគ្គលនោះឱ្យទេឡើងទៅឈរនៅលើគោក បានយ៉ាងណា។ អ្នកដែលមុជចុះក្នុងភក់ គឺ បញ្ចកាមគុណដោយខ្លួនឯង ក៏ ដូច្នោះដូចគ្នា នឹងលើកបុគ្គលដទៃដែលមុជចុះក្នុងភក់ក្នុងទីនោះ ដូចគ្នាទេឡើងមកហេតុនោះសេចក្តីនេះ ទើបជាហេតុដែលប្រព្រឹត្តទៅមិនបាន ។

ក្នុងរឿងនោះ គប្បីមានពាក្យសួរថា ពុទ្ធតម្រាស់នោះគង់មិនត្រឹមត្រូវ ព្រោះថាជនទាំងទឡាយ បានស្តាប់ធម៌ទេសនារបស់ភិក្ខុ ភិក្ខុនី ឧបាសក និង ឧបាសិកាទាំងទឡាយដែលនៅជាបុថុជ្ជនហើយបានសម្រេចធម៌ មានដែរទេតើ ព្រោះហេតុដូច្នោះអ្នកមុជចុះក្នុងភក់ ទើបឈ្មោះថាលើក ( អ្នកដទៃដែលមុជចុះក្នុងភក់ដូចគ្នា) ទេឡើងបាន ។

គួរវិសជ្ជនាថា ពាក្យនោះ មិនគួរឃើញយ៉ាងនោះទេ ។ ពិតណាស់

ព្រះមានព្រះភាគជាម្ចាស់ប៉ុណ្ណោះ ទ្រង់លើកទេឡើងបានក្នុងរឿងដែលពោលនោះ ចំណែកព្រះធម្មកថិកទាំងទឡាយនឹងបានទទួលត្រឹមតែពាក្យសរសើរប៉ុណ្ណោះ ដូចអ្នកដែលអានព្រះរាជហត្ថលេខាដែលព្រះរាជាទ្រង់បញ្ជូនទៅ ដូច្នោះ ។ ពិត ណាស់ ព្រះរាជហត្ថលេខាដែលព្រះរាជាទ្រង់បញ្ជូនទៅកាន់ជនបទជាយដែន អ្នកដែលនៅទីនោះអានព្រះរាជហត្ថលេខានោះមិនបាន ក៏នឹងឱ្យអ្នកដែលអានបានអាន ហើយនាំគ្នាស្តាប់សេចក្តីនៃព្រះរាជហត្ថលេខានោះ ហើយទទួលយកដោយគោរពថា ជាព្រះបរមរាជឱង្ការ ហើយគេទាំងនោះមិនបានមានការគិត ថា នេះជាពាក្យបញ្ញារបស់អ្នកអាន ចំណែកអ្នកអានព្រះរាជហត្ថលេខាក៏នឹងបានទទួលត្រឹមតែពាក្យសរសើរប៉ុណ្ណោះថា អានដោយពាក្យពីរោះ មិនរអាក់ រអួលយ៉ាងណា។ព្រះធម្មកថិកទាំងទឡាយ ចាប់ផ្តើមអំពីព្រះសារីបុត្រសម្តែង ធម៌បានក៏ពិតសូម្បីយ៉ាងនោះក៏ដោយ លោកទាំងនោះក៏ដូច្នោះដូចគ្នា គឺ ប្រៀបដូចអ្នកអានរាជហត្ថលេខា ចំណែកព្រះធម៌ទេសនានោះក៏ជាព្រះធម៌ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់នោះឯង ដូចព្រះបរមរាជឱង្ការ ។ ម្យ៉ាងទៀត ជនពួកណាស្តាប់ធម៌ទេសនាហើយ បានសម្រេចធម៌ព្រះមានព្រះភាគជាម្ចាស់ នោះឯង គប្បីជ្រាបថា ទ្រង់លើកបុគ្គលទាំងនោះទេឡើង ( ឱ្យផុតអំពីភក់ ) ចំណែកព្រះធម្មកថិក នឹងបានក៏ត្រឹមតែពាក្យសរសើរប៉ុណ្ណោះថា សម្តែងធម៌

ដោយពាក្យពីរោះក្បោះក្បាយ មិនរអាក់រអួល ព្រោះដូច្នោះព្រះពុទ្ធតម្រាស់នេះទើបត្រឹមត្រូវដោយពិត ។ ចំណែកធម្មៈដែលជាសុក្កបក្ខ គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នានឹងធម៌ ដែលពោលមកហើយ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា **អទន្តោ** ( អ្នកមិនបានទទួលការទូន្មាន) **អវិនីតោ** (អ្នកមិនបានទទួលការណែនាំ) **អបរិ_និព្វុតោ** ( អ្នករំលត់កិលេសមិនទាន់បាន ) អ្នកដែលឈ្មោះថា មិនទាន់បាន ទទួលការទូន្មាន ព្រោះជាអ្នកមិនទាន់អស់យស ។ អ្នកដែលឈ្មោះថា មិនបាន ទទួលការប្រដៅ ព្រោះមិនបានសិក្សាវិន័យ អ្នកដែលឈ្មោះថា រំលត់កិលេស មិនទាន់បាន ព្រោះនៅមានកិលេសដែលនៅមិនទាន់រំលត់បាន បុគ្គលប្រភេទ នោះ ៗ នឹងទូន្មានអ្នកដទៃ គឺនឹងធ្វើឱ្យអ្នកដទៃអស់យស និង ណែនាំអ្នកដទៃ គឺនឹងឱ្យអ្នកដទៃសិក្សាត្រៃសិក្ខា ឬ នឹងឱ្យអ្នកដទៃរំលត់កិលេស គឺ នឹងឱ្យកិ_លេសទាំងទឡាយរបស់អ្នកដទៃរលត់ទៅ សេចក្ដីដែលពោលមកនេះ ជាហេតុដែលប្រព្រឹត្តទៅមិនបាន តែធម៌ដែលជាចំណែកស គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នាដូចដែលពោលមកហើយ ។

ចំណែកអធិប្បាយក្នុងពាក្យនេះថា ម្នាលចុន្ទ អវិហិង្សាមានទុកដើម្បីការរំលត់កិលេសរបស់បុរសបុគ្គលអ្នកមានវិហិង្សា ក៏ដូច្នោះដូចគ្នា គប្បីជ្រាប

យ៉ាងនេះ ។

ដូចយ៉ាងថា អ្នកមិនមុជចុះក្នុងភក់ នឹងស្រង់អ្នកដទៃដែលមិនមុជចុះក្នុងភក់ទេឡើងបាន អ្នកទូន្មានខ្លួនហើយនឹងទូន្មាននឹងទូន្មានអ្នកដទៃបាន អ្នកបានទទួលការប្រៀនប្រដៅហើយ នឹងប្រដៅអ្នកដទៃបាន អ្នករំលត់កិលេសបានហើយនឹងរំលត់កិលេសរបស់អ្នកដទៃបាន សេចក្ដីដែលពោលមកនេះ ទើបជាហេតុដែលប្រព្រឹត្តទៅបាន ។

សួរថា ក៏ហេតុនោះគឺអ្វី ?

ឆ្លើយថា គឺការមិនមុជចុះក្នុងភក់ ការហ្វឹកហាត់ហើយ ការបានទទួលពាក្យប្រៀនប្រដៅហើយ និងការរំលត់កិលេសបានហើយយ៉ាងណា ម្នាលចុន្ទ អវិហិង្សាមានដើម្បីរំលត់កិលេសរបស់បុគ្គលអ្នកមានវិហិង្សាដូច្នោះដូចគ្នា ។

មានពាក្យអធិប្បាយទុកដូចម្ដេច ?

( មានទុកថា ) អវិហិង្សារបស់អ្នកមិនបៀតបៀនដោយខ្លួន ដើម្បីរំលត់ការបៀតបៀនអ្នកដទៃ របស់អ្នកដែលមានវិហិង្សា ព្រោះថាអ្នកមិនបៀតបៀនខ្លួនឯង នឹងរំលត់ចេតនាគ្រឿងបៀតបៀនរបស់អ្នកដទៃបាន ព្រោះដូច្នោះ សេចក្ដីនោះ ទើបជាហេតុដែលប្រព្រឹត្តទៅបាន ។

សួរថា ហេតុនោះគឺអ្វី ?

ឆ្លើយថា ហេតុនោះគឺភាពជាអ្នកមិនបៀតបៀននោះឯង ។ ដោយសេចក្តីថា អ្នកដែលសម្រេចការមិនបៀតបៀនដល់ខ្លួនឯង ទើបនឹងអាចដឹកនាំអ្នកដទៃឱ្យជាយ៉ាងនោះបាន ។

ម្យ៉ាងទៀត អ្នកមិនមុជចុះក្នុងភក់ ហ្វឹកហាត់ហើយ បានទទួលការណែនាំហើយ រំលត់កិលេសបានហើយដោយខ្លួនឯង នឹងស្រង់អ្នកដទៃដែលមុជចុះក្នុងភក់ទេឡើងបាន នឹងទូន្មានអ្នកដែលមិនបានទូន្មាន នឹងណែនាំអ្នកដែលមិនទាន់បានទទួលការណែនាំ ហើយនឹងស្រង់អ្នករំលត់កិលេសមិនទាន់បានឱ្យរំលត់កិលេសបានដូច្នោះ សេចក្តីនេះ ទើបជាហេតុដែលប្រព្រឹត្តទៅបានយ៉ាង- ណាអវិហិង្សាដែលកើតទេឡើងដល់អ្នកចម្រើនមគ្គ ដើម្បីលះវិហិង្សាក៏ដូច្នោះ ដូចគ្នាដើម្បីរំលត់ ( វិហិង្សា ) របស់បុរសបុគ្គលអ្នកមានវិហិង្សា អធិប្បាយ ថាអវិហិង្សាចេតនា (ចេតនាដែលមិនបៀតបៀន) នឹងអាចរំលត់វិហិង្សា- ចេតនា ( ចេតនាគិតបៀតបៀន ) បាន , ដូចអ្នករំលត់ កិលេសបានហើយអាចញ៉ាំងអ្នករំលត់កិលេសមិនទាន់បានឱ្យរំលត់បាន ដូច្នោះ ព្រះមានព្រះភាគដើម្បីនឹងទ្រង់សម្តែងសេចក្តីដែលពណ៌នាមកយ៉ាងនេះហើយ ទើបត្រាស់ពាក្យមានជាអាទិទុកយ៉ាងនេះថា **ឯវមេវ ខោ ចុន្ទ** ( ដូច្នោះដូចគ្នានោះឯង ចុន្ទ ) ដូច្នោះ អ្នកសិក្សាគប្បីឃើញអត្ថាធិប្បាយក្នុងរឿងនេះ ដូចដែលពណ៌នា

មកនេះចុះ ។ តែការប្រកបសេចក្ដីតាមលំដាប់បទគ្រប់ ៗ បទមិនបានធ្វើទុកដូចក្នុងបទវិហិង្សា និង អវិហិង្សា នេះ ព្រោះក្រែងថានឹងយឺតយូរពេក ។

## បរិយាយនៃសល្លេខធម៌

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងសល្លេខធម៌នោះថា អាចក្នុងការរំលត់កិលេសបានយ៉ាងប្រពៃនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់បញ្ជាក់ព្រះធម្មទេសនានោះប្រកប ( អ្នកស្ដាប់ ) ក្នុងការបដិបត្តិធម៌ ទើបបានត្រាស់ពាក្យមានជាអាទិទុកថា **ឥតិ ខោ ចុន្ទ** ( ម្នាលចុន្ទ ព្រោះហេតុដូច្នោះឯង ) ។

បណ្ដាបទទាំងនោះ បទថា **សល្លេខបរិយាយោ** ( បរិយាយនៃ សល្លេខធម៌ ) បានដល់ហេតុនៃសល្លេខធម៌ ។ គ្រប់បទក៏មានន័យនេះ ។ កុ-សលធម៌ទាំងទឡាយមានអវិហិង្សាជាដើមនោះឯង ក្នុងសល្លេខសូត្រនេះ គប្បីជ្រាបថា ឈ្មោះថាហេតុនៃសល្លេខធម៌ ព្រោះដុសខាត់កម្ចាត់អកុសលធម៌ មានវិហិង្សាជាដើម ឈ្មោះថា ជាហេតុនៃចិត្តុប្បាទ ព្រោះចិត្តដែលបុគ្គលគប្បីឱ្យកើតទេឡើងដោយអំណាចនៃអវិហិង្សាជាដើមនោះ ឈ្មោះថា ជាហេតុនៃការចៀសវាង ព្រោះជាហេតុនៃការចៀសវាងអំពី វិហិង្សា ជាដើម ឈ្មោះថា ជាហេតុនៃភាពខ្ពង់ខ្ពស់ ព្រោះញ៉ាំងភាពខ្ពង់ខ្ពស់ឱ្យសម្រេច ឈ្មោះថា ជាហេតុនៃការញ៉ាំងកិលេសឱ្យរលត់បាន ព្រោះញ៉ាំងវិហិង្សាជាដើមឱ្យរំលត់បាន ។

បទថា **ហិតេសិនា** សេចក្តីថា ជាអ្នកស្វែងរកប្រយោជន៍ ។

បទថា **អនុកម្បកេន** ( ជាអ្នកអនុគ្រោះ ) គឺ អ្នកទ្រង់មានព្រះទ័យករុណាអាណិតអាសូរ ។

បទថា **អនុកម្បំ ឧបាទាយ** ( ទ្រង់អាស្រ័យសេចក្តីអនុគ្រោះ ) គឺទ្រង់កំណត់សេចក្តីអនុគ្រោះដោយព្រះទ័យ មានពាក្យអធិប្បាយថា ទ្រង់អាស្រ័យ ( សេចក្តីអនុគ្រោះ ) ដូច្នេះខ្លះ ។ សេចក្តីថា **កតំ វោ តំ មយា** ( កិច្ចនោះតថាគតបានធ្វើហើយដល់អ្នកទាំងទឡាយ ) សេចក្តីថា កិច្ចនោះតថាគតអ្នកសម្តែងហេតុ ៥ ប្រការនេះ បានធ្វើហើយដល់អ្នកទាំងទឡាយ ។ អធិប្បាយ ថា កិច្ចមានប្រមាណប៉ុណ្ណេះប៉ុណ្ណោះឯង ជានាទីរបស់សាស្តាដែលទ្រង់អនុ_គ្រោះបានដល់ការដែលទ្រង់សម្តែងធមិដោយល្អ ( ព្រះអង្គទ្រង់ធ្វើហើយ ) ចំណែកអំពីនេះទៅ ធម្មតាថាការបដិបត្តិជានាទីរបស់សាវ័កទាំងទឡាយ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបបានត្រាស់ទុកថា ម្នាលចុន្ទ នោះគល់ឈើទាំងទឡាយ ។ ល ។ ជាអនុសាសនីរបស់តថាគត ។ ក៏ក្នុងចំនួនស្ថានទី ៣ កន្លែងនោះ ដោយបទថា **រុក្ខមូល** នេះ ព្រះអង្គទ្រង់សម្តែងដល់ទីអង្គុយ ទី ដេក គឺគល់ឈើ ។ ដោយពាក្យថា **សុញ្ញាគារ** ( ផ្ទះស្ងាត់ ) នេះ ទ្រង់សម្តែងដល់ស្ថានទីដែលស្ងាត់ចាកមនុស្ស ។ម្យ៉ាងទៀត ដោយពាក្យទាំង ២ នេះ ទ្រង់

ប្រាប់សេនាសនៈដែលសមរម្យនឹងសេចក្តីព្យាយាម គឺ ទ្រង់ប្រគល់ភាពជាទាយាទឱ្យ ។ ពាក្យថា អ្នកទាំងទឡាយចូរពិចារណា សេចក្តីថា ចូរចូលទៅសម្លឹងអារម្មណ៍ ៣៨ ប្រការដោយអារម្មណូបនិជ្ឈាន ( ការសម្លឹងអារម្មណ៍ ) ហើយសម្លឹងខន្ធ និង អាយតនៈជាដើម ដោយភាពមិនទៀងជាដើម ដោយលក្ខណូបនិជ្ឈាន (ការសម្លឹងលក្ខណៈ) មានពាក្យអធិប្បាយថា ចម្រើន សមថៈ និង វិបស្សនា ។

សេចក្តីថា **មា បមាទត្ថ** ( អ្នកទាំងទឡាយកុំប្រមាទ ) សេចក្តីថា អ្នកទាំងទឡាយកុំមានសេចក្តីប្រមាទ គឺ កុំក្តៅក្រហាយស្តាយក្នុងកាលជាខាង ក្រោយ ។ អធិប្បាយថា ជនពួកណាកាលមុន គឺ ក្នុងកាលនៅកម្លោះក្នុងកាលមិនមានរោគ ក្នុងកាលប្រសព្វសេចក្តីសប្បាយ ៧ យ៉ាងជាដើម និង ក្នុងកាលដែលនៅមានព្រះសាស្តានៅចំពោះមុខ វៀរចាកយោនិសោមនសិការៈ សោយសេចក្តីសុខអំពីការដេក និង សេចក្តីសុខអំពីការលក់ ជាចំណីរបស់ សង្កើច ប្រមាទទាំងយប់ទាំងថ្ងៃ ជនទាំងនោះខាងក្រោយ គឺ ក្នុងកាលជរា កាលមានរោគ កាលនឹងស្លាប់ កាលវិបត្តិ និងវេលាដែលព្រះសាស្តាបរិនិព្វាន ហើយរឭកដល់ការនៅដោយសេចក្តីប្រមាទក្នុងកាលមុននោះ ហើយពិចារណា ឃើញការបដិសន្ធិ និង សេចក្តីស្លាប់របស់ខ្លួនថា ជាភារៈ (រឿងដែលត្រូវនាំ)

ទើបជាអ្នកមានសេចក្តីក្តៅក្រហាយស្តាយក្រោយ ចំណែកអ្នកទាំងទឡាយកុំដូចជាមនុស្សប្រភេទនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សម្តែងសេចក្តី នោះដូចដែលពោលមកនេះ ទើបបានត្រាស់ថា អ្នកទាំងទឡាយកុំបានក្តៅក្រហាយស្តាយក្រោយទេឡើយ ។

បទថា **អយំ វោ អម្ហាកំ អនុសាសនី** ( នេះជាអនុសាសនីពាក្យទូន្មានរបស់តថាគតសម្រាប់អ្នកទាំងទឡាយ ) សេចក្តីថា នេះជាអនុសាសនីមានពាក្យអធិប្បាយថា ជាឱវាទដើម្បីអ្នកទាំងទឡាយអំពីសំណាក់របស់តថាគត ថាចូរពិចារណា ( ដុតកិលេស ) ចូរកុំប្រមាទដូច្នេះឯង ៕

( ចប់ អដ្ឋកថាសល្លេខសូត្រសូត្រទី ៨ )

# អ ដ្ឋ ក ថា
## សម្មាទិដ្ឋិសូត្រ ទី ៩

សម្មាទិដ្ឋិសូត្រមានពាក្យផ្ដើមថា ខ្ញុំម្ចាស់ បានស្ដាប់មកហើយយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាទិដ្ឋិសូត្រនោះ ដូចតទៅនេះ ÷

ពាក្យសួរដែលព្រះថេរៈ ( សារីបុត្រ ) ពោលទុយ៉ាងនេះថា ម្នាលអាវុសោ ដែលហៅថា សម្មាទិដ្ឋិ ដោយហេតុមានប៉ុន្មានយ៉ាងហ្ន៎ ? ដូច្នេះ ឬថាអកុសល តើដូចម្ដេច ? ម្នាលអាវុសោ ដូច្នេះគ្រប់ប្រការ ជាកថេតុកម្យតាបុច្ឆា ( សួរដើម្បីឆ្លើយខ្លួនឯង ) ប៉ុណ្ណោះឯង ។

ព្រោះថា ក្នុងពាក្យសួរទាំងនោះ បុគ្គលទាំងទឡាយយល់ក្នុងសម្មាទិដ្ឋិនោះក៏មាន មិនយល់ក៏មាន ជាបុគ្គលក្រៅសាសនាក៏មាន ក្នុងសាសនាក៏មាន ពោល ថា សម្មាទិដ្ឋិដោយអំណាចដែលបានស្ដាប់តាមគ្នាមកក៏មាន ដោយបានប្រចក្សដោយខ្លួនឯងមកក៏មាន ដូច្នេះ ទើបព្រះសារីបុត្របានពោលសម្ដៅយកពាក្យសួររបស់បុគ្គលចំណែកច្រើននោះបញ្ជាក់ដល់ ២ ជង ថា ម្នាលអាវុសោ ដែលហៅ ថា សម្មាទិដ្ឋិដែលពិតក្នុងរឿងនេះមានអធិប្បាយដូចតទៅនេះ សូម្បីអាចារ្យពួកដទៃក៏ហៅថា សម្មាទិដ្ឋិ ។

ព្រះសារីបុត្រនេះនោះ កាលពោលយ៉ាងនេះ បានពោលថា ដោយហេតុ

ប៉ុន្មានយ៉ាងហ្ន៎ ? ម្នាលអាវុសោ អរិយសាវ័កទើបឈ្មោះថា មានការឃើញត្រូវ ដូច្នេះ សម្ដៅដល់អត្ថៈ និង លក្ខណៈ ( របស់សម្មាទិដ្ឋិ ) ។

## អធិប្បាយពាក្យថា សម្មាទិដ្ឋិ

បណ្ដាបទទាំងនោះ បទថា សម្មាទិដ្ឋិ សេចក្ដីថា ដែលឈ្មោះថា ជាអ្នកប្រកបដោយការឃើញទាំងល្អទាំងប្រសើរ ។

ក៏កាលណា ស័ព្ទថា សម្មាទិដ្ឋិនេះប្រើក្នុងធម្មៈប៉ុណ្ណោះ កាលនោះគប្បីជ្រាបអត្ថនៃស័ព្ទនោះយ៉ាងនេះថាទិដ្ឋិទាំងល្អទាំងប្រសើរឈ្មោះថា សម្មា- ទិដ្ឋិ ។ ហើយសម្មាទិដ្ឋិនេះនោះ មាន២ យ៉ាង គឺ លោកិយសម្មាទិដ្ឋិ ១ លោកុត្តរសម្មាទិដ្ឋិ ១ ។

ក្នុងចំនួនសម្មាទិដ្ឋិទាំង ២ យ៉ាងនោះ កម្មស្សកតាបញ្ញា ( ប្រាជ្ញាដឹងច្បាស់ថា សត្វមានកម្មជារបស់ខ្លួន ) និង សច្ចានុលោមិកញ្ញាណ ( ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ចៈ ) ឈ្មោះថា លោកិយ-សម្មាទិដ្ឋិ ។ ចំណែកបញ្ញាដែលសម្បយុត្តដោយអរិយមគ្គ អរិយផល ឈ្មោះថា លោកុត្តរសម្មាទិដ្ឋិ ។ តែបុគ្គលដែលមានសម្មាទិដ្ឋិ មាន ៣ ប្រភេទ គឺ បុថុជ្ជន ១ សេក្ខបុគ្គល ( អ្នកនៅសិក្សា ) ១ អសេក្ខបុគ្គល ( អ្នកចប់កិច្ចសិក្សា ) ១ ។

ក្នុងចំនួនបុគ្គល ៣ ប្រភេទនោះ បុថុជ្ជនមាន ២ ប្រភេទ គឺ ពាហិរ-

កជន (បុគ្គលក្រៅសាសនា) ១ , សាសនិកជន ( បុគ្គលក្នុងសាសនា )១។ ក្នុងចំនួន ២ ប្រភេទនោះ ពាហិរកបុថុជ្ជនអ្នកជាកម្មវាទី ( ជឿកម្ម) ឈ្មោះថា ជាអ្នកមានការឃើញត្រូវ ( ជាសម្មាទិដ្ឋិកបុគ្គល ) ដោយការឃើញថាសត្វមានកម្មជារបស់ខ្លួន មិនមែនដោយការឃើញថ្នាក់សច្ចានុលោមញាណ ចំណែកសាសនិកបុថុជ្ជន ឈ្មោះថា មានការឃើញត្រូវ ( ជាសម្មាទិដ្ឋិកបុគ្គល ) ដោយការឃើញទាំង ២ យ៉ាង ( កម្មស្សកតា និង អនុលោមញាណ ព្រោះនៅស្ទាបអង្អែលការឃើញរឿងអត្តា និង លះសក្កាយទិដ្ឋិមិនទាន់បាន ) ។

សេក្ខបុគ្គល ឈ្មោះថា មានការឃើញប្រពៃ ព្រោះមានការឃើញប្រពៃពិតប្រាកដ ។ ចំណែកអសេក្ខបុគ្គលឈ្មោះថា មានការឃើញប្រពៃ ព្រោះអស់កិច្ចសិក្សា ។ តែក្នុងទីនេះប្រាថ្នាយកអ្នកប្រកបដោយសម្មាទិដ្ឋិដែលជាលោកុត្តរកុសលដ៏ទៀងទាត់ គឺជាគ្រឿងនាំសត្វចេញចាកទុក្ខថា អ្នកមានការឃើញប្រពៃ

ព្រោះហេតុនោះឯង ទើបព្រះសារីបុត្របានពោលទុកថា ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងធម៌ បានមកកាន់ព្រះសទ្ធម្មនេះហើយ ។ អធិប្បាយថា សម្មាទិដ្ឋិដែលជាលោកុត្តរកុសលប៉ុណ្ណោះ ជាការឃើញដ៏ត្រង់ ព្រោះទៅតាមផ្លូវត្រង់មិនជាប់នៅនឹងទីបំផុតទាំង ២ យ៉ាង ឬ កាត់ផ្តាច់ភាពកោងគ្រប់យ៉ាង មានការកោងផ្លូវកាយជាដើម ហើយទៅត្រង់ ហើយអ្នកប្រកប

ដោយទិដ្ឋិនោះឯង ឈ្មោះថា ជាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងធម៌ គឺ ដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងលោកុត្តរធម៌ ៩ ប្រការ អរិយសាវ័កកាលលះបង់ការប្រកាន់មាំដោយទិដ្ឋិគ្រប់យ៉ាង លះបង់កិលេសទាំងអស់ហើយចេញចាកសង្សារវដ្ដ គឺ ជាតិ សម្រេចអស់ការបដិបត្តិ លោកហៅថា អ្នកបានមកកាន់ព្រះសទ្ធម្ម ពោលគឺ ព្រះនិព្វានដែលញ៉ាំងចុះកាន់អមតធម៌ដែលព្រះ-សម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ប្រកាសហើយដោយអរិយមគ្គ ។

ពាក្យថា យតោ ខោ នេះជាពាក្យកំណត់កាលវេលា មានអធិប្បាយ ថាក្នុងកាលណា ។

សេចក្ដីថា អកុសលញ្ច បជានាតិ សេចក្ដីថា ដឹងច្បាស់នូវអកុសល ពោលគឺ អកុសលកម្មបទ ១០ ប្រការ គឺ កាលចាក់ធ្លុះថា វត្ថុនេះជាទុក្ខដោយអំណាចនៃកិច្ចញាណ ឈ្មោះថា ដឹងច្បាស់នូវអកុសល ព្រោះការដឹងច្បាស់ដែលមាននិរោធជាអារម្មណ៍ ។

សេចក្ដីថា អកុសលមូលញ្ច បជានាតិ សេចក្ដីថា ដឹងច្បាល់នូវឫសគល់របស់អកុសលថាជាឫសគល់ ជាបច្ច័យនៃអកុសលនោះ គឺ ការចាក់ធ្លុះថានេះជាហេតុឱ្យកើតទុក្ខដោយប្រការដូច្នោះឯង ( ឈ្មោះថា ដឹងច្បាស់នូវឫសគល់របស់អកុសល ) ។

សូម្បីក្នុងពាក្យនេះថា កុសល និង ឫសគល់របស់កុសលនេះ ក៏មាន ន័យនេះ ។

ក្នុងគ្រប់វារៈតអំពីវារៈនេះទៅ ក៏ដូចវារៈនេះ គួរជ្រាបការដឹងច្បាស់នូវ វត្ថុ ដោយអំណាចនៃកិច្ចញាណនោះឯង ។

បទថា ឯត្តាវតាបិ សេចក្តីថា ដោយហេតុត្រឹមប៉ុណ្ណោះ គឺ សូម្បីការដឹងច្បាស់នូវអកុសលជាដើមនេះ ។

បទថា សម្មាទិដ្ឋិ ហោតិ សេចក្តីថា ជាអ្នកប្រកបដោយលោកុត្តរសម្មា_ទិដ្ឋិ មានប្រការដូចពោលមកហើយ ។

ដោយពាក្យត្រឹមប៉ុណ្ណោះថា អរិយសាវ័កនោះមានទិដ្ឋិត្រង់ ។ល។ ហើយបានមកកាន់ព្រះសទ្ធម្មនេះ ជាការដែលព្រះសារីបុត្របញ្ចប់ការសម្តែងដោយសង្ខេបហើយ ។ ការសម្តែង ( របស់លោក ) នេះ សូម្បីនឹងសង្ខេប តែក៏គួរជ្រាបដោយការចាក់ធ្លុះដោយមនសិការដ៏ប្រពៃ ដោយអំណាចនៃសេចក្តីពិស្តារនោះឯង សម្រាប់ភិក្ខុទាំងនោះ ។

ចំណែកក្នុងទុតិយវារៈសូម្បីការសម្តែង ( និងបង្រួញ ) ក៏គួរជ្រាបដល់ការចាក់ធ្លុះដោយមនសិការដ៏ប្រពៃយ៉ាងពិស្តារថា បានប្រព្រឹត្តទៅហើយដោយពិស្តារនោះឯង ។

ភិក្ខុទាំងទឡ្បាយបានពោលថា បណ្តាការសម្តែងទំាង ២ យ៉ាងនោះ ដោយការសម្តែងយ៉ាងសង្ខេប ព្រះសារីបុត្របានពោលដល់មគ្គខាងក្រោមទាំង ២ យ៉ាង ដោយការសម្តែងយ៉ាងពិស្តារ ព្រះសារីបុត្របានពោលដល់មគ្គខាងលើ ២ យ៉ាង

ក្នុងទីបំផុតនៃការសម្តែងយ៉ាងពិស្តារ ភិក្ខុទាំងទឡ្បាយពិចារណាឃើញពាក្យមានជាអាទិថា ព្រោះលះរាគានុស័យបាន ដោយប្រការទាំងពួង ។ តែព្រះថេរៈបានពោលថា មគ្គទាំង ៤ បានពោលទុកហើយ ដោយជាពួក ដោយការសម្តែងយ៉ាងសង្ខេបក៏មាន ដោយការសម្តែងយ៉ាងពិស្តារក៏មាន ។

ម្យ៉ាងទៀតការសម្តែងទាំងដោយសង្ខេបទាំងដោយពិស្តារនេះជាការ សម្តែងដែលខ្ញុំម្ចាស់បានធ្វើការពិចារណាទុកដោយល្អិតល្អន់ជាក់ច្បាស់ហើយ ក្នុងទីនេះការសម្តែងនោះគប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងទីនេះ គ្រប់ ៗ វារៈចុះ ។ ព្រោះថា តអំពីនេះទៅ ខ្ញុំម្ចាស់នឹងធ្វើត្រឹមតែការបរិយាយសេចក្តីចំពោះបទដែលលំបាក ដែលនៅមិនទាន់បាន ( អធិប្បាយ ) ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងការសម្តែងដោយពិស្តារនូវបឋមវារៈក្នុងចំនួនវារៈទាំងនោះមុន ។

ក្នុងពាក្យទាំងទឡ្បាយមានជាអាទិថា ម្នាលអាវុសោ បាណាតិបាតនោះឯងជាអកុសល ។ អកុសល ព្រោះអត្ថថា ប្រព្រឹត្តទៅដោយការមិនឆ្លាត

( គឺ កើតអំពីការមិនឆ្លាត ) អកុសលនោះគប្បីជ្រាបដោយ ( ជាធម៌ ) ផ្ទុយគ្នានឹងកុសលដែលនឹងត្រូវពោលខាងមុខ ឬ ដោយលក្ខណៈ គប្បីជ្រាប( ថា ជា) វត្ថុដែលមានទោស និង មានវិបាកជាទុក្ខ ជាវត្ថុដែលសៅហ្មង ។ នេះជាការបរិយាយបទទូទៅក្នុងអកុសលវារៈប៉ុណ្ណេះសិន ។

## អធិប្បាយ បាណាតិបាត

ចំណែកក្នុងបទចំពោះ ( មិនទូទៅ ) គប្បីជ្រាបវិនិច្ឆ័យថា ការញ៉ាំងសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងទៅ ឈ្មោះថា បាណាតិបាត បានដល់ ការសម្លាប់សត្វដែលមានជីវិត អធិប្បាយថា ការទំលាយសត្វដែលមានជីវិត ។ ក៏ពាក្យថា បាណៈ ក្នុងពាក្យថា បាណាតិបាតោ នេះ ពោលដោយវោហារ បានដល់ សត្វ តែបើពោលដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ៍ ។

ចំណែកចេតនា ដែលនឹងសម្លាប់របស់អ្នកមានការសម្គាល់ក្នុងសត្វមានជីវិតនោះថា ជាសត្វមានជីវិត ដែលជាសមុដ្ឋាននៃការព្យាយាមដែលនឹងចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយ៍ ដែលប្រព្រឹត្តទៅតាមកាយទ្វារ ឬ វចីទ្វារ ទ្វារណាមួយ ឈ្មោះថា បាណាតិបាត ។

បាណាតិបាតនោះ គប្បីជ្រាបថា មានទោសតិច ព្រោះសត្វមានជីវិតនោះមានខ្លួនតូច ក្នុងចំនួនសត្វមានជីវិតទាំងទឡាយ មានតិរច្ឆានជាដើម ដែល

ប្រាសចាកគុណ តែគប្បីជ្រាបថា មានទោសច្រើន ព្រោះសត្វដែលមានជីវិតមានខ្លួនធំ ។

ព្រោះហេតុអ្វី ?

ព្រោះមានប្រយោគធំ ( មានវិធីការច្រើន ) ។

សូម្បីកាលមានប្រយោគស្មើគ្នា បាណាតិបាតគប្បីជ្រាបថា មានទោស ច្រើន ព្រោះវត្ថុធំ ( សត្វធំ ) ។

ក្នុងជំពូកសត្វមានគុណ មានមនុស្សជាដើម ព្រោះសត្វមានគុណតិច បាណាតិបាតគប្បីជ្រាបថា មានទោសតិច , ព្រោះសត្វមានគុណច្រើន គប្បីជ្រាបថាមានទោសច្រើន ។ តែកាលសរីរៈ និង គុណមានការស្មើគ្នា បាណា_តិបាតគប្បីជ្រាបថាមានទោសតិចព្រោះកិលេសនិងការព្យាយាមទន់ខ្សោយគប្បីជ្រាបថាមានទោសច្រើនព្រោះកិលេស និង ការព្យាយាមខ្លាំងក្លា ។

បាណាតិបាតនោះមានអង្គ៥គឺសត្វមានជីវិត១សេចក្តីដឹងថាសត្វ មានជីវិត១គិតនឹងសម្លាប់១ការព្យាយាមនឹងសម្លាប់១សត្វស្លាប់ដោយ សេចក្តីព្យាយាមនោះ១ ។

ប្រយោគនៃការសម្លាប់មាន ៦ គឺ សាហត្ថិកប្រយោគ ( សម្លាប់ដោយដៃខ្លួនឯង ) ១ អាណត្តិកបយោគ ( ប្រើឱ្យអ្នកដទៃសម្លាប់) ១ និស្សគ្គិយ_

បយោគ(សម្លាប់ដោយសស្ត្រាវុធដែលពួយ ឬ ចោលចេញទៅ) ១ ថាវរ_បយោគ សម្លាប់ដោយគ្រឿងឧបករណ៍ មានអន្ទាក់ក៏ដាក់នៅនឹងកន្លែង ១ វិជ្ជាមយប្រយោគ ( សម្លាប់ដោយអំណាចវិជ្ជា) ១ ឥទ្ធិមយបយោគ ( សម្លាប់ដោយឫទ្ធិ ) ១ ។

តែលុះនឹងអធិប្បាយ បយោគនេះឱ្យពិស្តារក្នុងបឋមវារៈនេះ ក៏នឹងយឺតយ៉ាវពេក ព្រោះហេតុដូច្នេះ នឹងសូមមិនអធិប្បាយបយោគនោះនឹងយ៉ាងដទៃដែលជាបែបនេះឱ្យពិស្តារ ចំណែកអ្នកមានសេចក្តីត្រូវការ គប្បីត្រួតមើលសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យចុះ ។

## អធិប្បាយពាក្យថា អទិន្នាទាន

ការកាន់យកព្រទ្យដែលគេមិនបានឱ្យ ឈ្មោះថា អទិន្នាទាន ការលួចព្រទ្យរបស់អ្នកដទៃ ឈ្មោះថា ថេយ្យ អធិប្បាយថា ជាកិរិយារបស់ចោរ ។

បទថា អទិន្នំ បានដល់ ទ្រព្យដែលអ្នកដទៃហួងហែង ដែលអ្នកដទៃ ( ម្ចាស់ទ្រព្យ ) កាលប្រើប្រាស់តាមដែលត្រូវការក៏មិនគួរបានទទួលទណ្ឌៈ និងមិនត្រូវតិះដៀល ។

ចំណែកចេតនាដែលនឹងលួច របស់អ្នកមានការសម្គាល់ក្នុងទ្រព្យដែលអ្នកដទៃហួងហែងនោះថា ជាទ្រព្យដែលគេហួងហែង ដែលជាសមុដ្ឋាននៃ

ការព្យាយាម និង កាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យនោះ ឈ្មោះថា អទិន្នាទាន ។

អទិន្នាទាននោះ មានទោសតិច ព្រោះទ្រព្យរបស់អ្នកដទៃថោកថយ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យរបស់អ្នកដទៃប្រណីត ។

ព្រោះហេតុអ្វី ?

ព្រោះថា ជារបស់ប្រណីត ។

កាលមានការស្មើគ្នានៃទ្រព្យ ឈ្មោះថា មានទោសច្រើន ព្រោះទ្រព្យដែលមាននៅនោះ ជារបស់អ្នកមានគុណក្រៃលែង ។

អទិន្នាទាននោះ ឈ្មោះថា មានទោសតិច ព្រោះទ្រព្យដែលមាននៅជារបស់អ្នកមានគុណធម៌ទាបជាងនោះ ព្រោះប្រៀបធៀបនឹងអ្នកមានគុណធម៌ខ្ពស់នោះ ។

អទិន្នាទាននោះ មានអង្គប្រកប ៥ ប្រការ គឺ ទ្រព្យដែលអ្នកដទៃហួងហែង១ សេចក្តីដឹងថាជាទ្រព្យដែលអ្នកដទៃហួងហែង១ ចិត្តគិតនឹងលួច ១ សេចក្តីព្យាយាម ( នឹងលួច) ១ លួចទ្រព្យបានមកដោយសេចក្តីព្យាយាម នោះ ១ ។

ក៏ប្រយោគការ ( ប្រកបអទិន្នាទាន) មាន ៦ យ៉ាង មានសាហត្ថិក_

បយោគជាដើម ក៏បយោគទាំងនោះឯងប្រព្រឹត្តទៅហើយ ដោយអំណាច នៃអាវហា ( ការលួច ) ទាំងនេះ គឺ ថេយ្យាវហារ ( លួចដោយវោហារ ) ១ បសយ្ហាវហារ ( លួចដោយការឆបោក ) ១ បដិច្ឆិន្នាវហារ ( លួចដោយការគ្របបិទទ្រព្យទុក ) ១ បរិកប្បាវហារ ( លួចដោយការកំណត់ទ្រព្យ ឬពេលវេលា ) ១ កុសាវហារ ( លួចដោយប្តូរស្លាក ) ១ សេចក្តីដូចដែលបានពោលមកហើយនេះ ជាសេចក្តីសង្ខេបក្នុងអវហារនេះ ។ ចំណែកសេចក្តីពិស្តារបានពោលទុកហើយក្នុងអដ្ឋកថាឈ្មោះ សមន្តប្បាសាទិកា ។

## អធិប្បាយពាក្យថា កាមេសុមិច្ឆាចារ

ក៏បទថា កាមេសុ ក្នុងសេចក្តីថា កាមេសុមិច្ឆាចារោ នេះ បានដល់មេថុនសមាចារ ។ ការប្រព្រឹត្តិដ៏លាមកដែលបណ្ឌិត តិះដៀលដោយចំណែក មួយឈ្មោះថា មិច្ឆាចារ ។ តែដោយលក្ខណៈចេតនាដែលប្រព្រឹត្តកន្លង អគមនីយដ្ឋាន ( ស្ត្រីដែលត្រូវហាម ) ដែលប្រព្រឹត្តទៅតាមកាយទ្វារ ដោយសេចក្តីប្រាថ្នាចំពោះអសទ្ធម្ម ឈ្មោះថា កាមេសុមិច្ឆាចារ ។

ស្ត្រីដែលឈ្មោះថា អគមនីយដ្ឋាន ( ស្ត្រីដែលត្រូវហាម ) សម្រាប់បុរសក្នុងកាមេសុិច្ឆាចារនេះ បានដល់ ស្ត្រី ២០ ចំពូក គឺ ស្ត្រីដែលមានមាតារក្សាជាដើម ។

ស្ត្រី ១០ ចំពួក គឺ ស្ត្រីដែលមានមាតារក្សា ១ ស្ត្រីដែលបិតារក្សា ១ ស្ត្រីដែលមានមាតានិងបិតារក្សា ១ ស្ត្រីដែលមានបងប្រុសប្អូនប្រុសរក្សា ១ ស្ត្រីដែលញាតិរក្សា ១ ស្ត្រីដែលគោត្ររក្សា ១ ស្ត្រីដែលធម៌រក្សា ១ ស្ត្រីដែលមានការអារក្ខា ( ស្ត្រីដែលមានការរក្សាអាជ្ញាជុំវិញ) ( នៅក្នុងច្បាប់រាំង ) ១ ។

និងស្ត្រី១០ ចំពួកទៀត មានស្ត្រីដែលលោះមកដោយទ្រព្យជាដើម ទាំងនេះ គឺ ភរិយាដែលលោះមកដោយទ្រព្យ ( ភរិយាលោះដោយទ្រព្យ ) ១ ភរិយាដែលនៅជាមួយគ្នាព្រោះការពេញចិត្ត ១ ដែលនៅជាមួយគ្នាព្រោះ ភោគៈ ១ ដែលនៅជាមួយគ្នាព្រោះគ្រឿងស្លៀកដណ្តប់ ១ ដែលអ្នកគ្រប់គ្រងពេញចិត្តលើកឱ្យ ១ ដែលបុរសលើកមកុដដាក់លើសីសៈ ១ ដែលទាំងជាភរិយាទាំងជាទាសៈ ១ ដែលទាំងជាភរិយាទាំងជាកូនឈ្នួល ១ ដែលជាឈ្លើយសឹក ១ ដែលនៅជាមួយគ្នាមួយគ្រា ១ ។

ចំណែកបុរសដទៃក្រៅអំពីស្វាមីរបស់ខ្លួន ឈ្មោះថា ជាអគមនីយដ្ឋាន ( បុរសត្រូវហាម) សម្រាប់ស្ត្រី ១២ ចំពួក គឺ ២ ចំពួកសម្រាប់ស្ត្រីមាន អារក្ខានិងស្ត្រីមានអាជ្ញាគ្រប់គ្រង និង ១០ ចំពួកសម្រាប់ភរិយាដែលលោះមក ដោយទ្រព្យជាដើម។ក្នុងចំនួនស្ត្រីទាំងទឡាយ(១០ចំពួក) សម្រាប់ ភរិយា ។

ម្យ៉ាងទៀត មិច្ឆាចារនេះនោះ ឈ្មោះថា មានទោសតិច ព្រោះអគមនីយដ្ឋាន ( អ្នកត្រូវហាម ) ប្រាសចាកគុណធម៌ មានសីលជាដើម ឈ្មោះថា មានទោសច្រើន ព្រោះដល់ព្រមដោយគុណធម៌មានសីលធម៌ជាដើម ។

កាមេសុមិច្ឆាចារនោះមានអង្គ ៤ យ៉ាង គឺ ជាបុគ្គលត្រូវហាម ១ ចិត្តគិតនឹងសេពក្នុងបុគ្គលត្រូវហាមនោះ ១ ការប្រកបការសេព ១ ការញ៉ាំងមគ្គឱ្យដំណើរទៅក្នុងមគ្គ ឬឈប់នៅ ១ ប្រយោគមានតែមួយ គឺ សាហត្ថិកបយោគប៉ុណ្ណោះ ។

## អធិប្បាយពាក្យថា មុសាវាទ

កាយបយោគ ឬ វចីបយោគដែលធ្វើឱ្យវិនាសប្រយោជន៍ ( អ្នកដទៃ ) របស់អ្នកប្រាថ្នានឹងនិយាយឱ្យខុស ឈ្មោះថា មុសា ។ ចេតនារបស់អ្នកនិយាយឱ្យខុសចំពោះអ្នកដទៃដោយប្រាថ្នានឹងឱ្យគេយល់ខុស មានកាយបយោគ និង វចីបយោគជាសមុដ្ឋាន ឈ្មោះថា មុសាវាទ ។

ម្យ៉ាងទៀត រឿងមិនពិត មិនមែនឈ្មោះថា មុសា( រឿងកុហក)។ ការឱ្យ ( អ្នកដទៃ ) ដឹងរឿងកុហកនោះ ថាជារឿងពិត រឿងមែន ឈ្មោះថា វាទៈ ( ការនិយាយ ) តែពោលដោយលក្ខណៈ ចេតនារបស់អ្នកប្រាថ្នានឹងឱ្យអ្នកដទៃដឹងរឿងដែលមិនពិតថា ជារឿងពិត ដែលជាសមុដ្ឋាននៃវិញ្ញត្តិ ( ការ

កម្រើក) យ៉ាងនោះ ឈ្មោះថា មុសាវាទ ( ការនិយាយកុហក ) ។

មុសាវាទនោះ ឈ្មោះថា មានទោសតិច ព្រោះប្រយោជន៍ដែលខ្លួនធ្វើឱ្យវិនាសមានចំនួនតិច ឈ្មោះថា មានទោសច្រើន ព្រោះប្រយោជន៍ដែលខ្លួនធ្វើឱ្យវិនាសមានចំនួនច្រើន ។

ម្យ៉ាងទៀត សម្រាប់គ្រហស្ថមុសាវាទដែលប្រព្រឹត្តទៅហើយ ដោយន័យមានជាអាទិថា មិនមានព្រោះប្រាថ្នានឹងឱ្យរបស់ ៗ ខ្លួន ( ដល់អ្នកដទៃ ) មានទោសតិច ដែលពោលធ្វើជាសាក្សីដើម្បីធ្វើឱ្យវិនាសប្រយោជន៍ ( របស់គូភាគី ) មានទោសច្រើន , សម្រាប់បព្វជិត មុសាវាទដែលប្រព្រឹត្តទៅហើយដោយន័យនៃបូរណាកថា ( និយាយឱ្យពេញសេចក្តី ឬ លេងសើច ) ថាថ្ងៃនេះប្រេងក្នុងស្រុកប្រហែលនឹងហូរទៅជាស្ទឹង ហើយមើលទៅដោយសេចក្តីប្រាថ្នានឹងឱ្យសើច ព្រោះបានប្រេង ឬ ទឹកដោះថ្លាតិចពេកមានទោសតិច តែរបស់អ្នកនិយាយដោយន័យមានជាអាទិ ថាវត្ថុដែលមិនបានឃើញ ថាបានឃើញមានទោសច្រើន ។

មុសាវាទនោះ មានអង្គប្រកប ៤ យ៉ាង គឺ រឿងមិនពិត ១ តាំងចិត្តនិយាយឱ្យខុស ១ ព្យាយាមនិយាយ ១ អ្នកដទៃដឹងច្បាស់សេចក្តីនោះ ១ ។ ប្រយោគ មានប្រយោគ ១ គឺ សាហត្ថិកប្បយោគប៉ុណ្ណោះ ។ ប្រយោគនោះ

គប្បីឃើញថា បានដល់ការសម្តែងកិរិយារបស់អ្នកនឹងនិយាយឱ្យខុសចំពោះអ្នកដទៃដោយកាយ ដោយរបស់ជាប់នឹងកាយ ឬ ដោយវាចា ។

ប្រសិនបើអ្នកដទៃដឹងសេចក្តីនោះ ដោយកិរិយានោះ កិរិយានេះឈ្មោះថា ជាប់ដោយមុសាវាទកម្មក្នុងខណៈនៃចេតនា ដែលមានកិរិយាជាសមុដ្ឋាននោះឯង ។

## អធិប្បាយពាក្យថា បិសុណាវាចា

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា បិសុណាវាចា ជាដើម ។ វាចាដែលជាហេតុឱ្យបេះដូងរបស់បុគ្គលអ្នកដែលខ្លួននិយាយជាមួយ កើតសេចក្តីស្រទន់ឡាញ់ខ្លួន និងស្អប់ខ្ពើមអ្នកដទៃ ឈ្មោះថា បិសុណាវាចា ។

ចំណែកវាចាដែលជាហេតុធ្វើឱ្យខ្លួនឯងខ្លះ អ្នកដទៃខ្លះ គ្រោតគ្រាត និងវាចាដែលគ្រោតគ្រាតខ្លួនឯង គឺមិនពីរោះត្រចៀក ឬ មិនសប្បាយចិត្ត ( អ្នកស្តាប់ ) នេះឈ្មោះថា ផរុសវាចា ។

វាទៈដែលជាហេតុនៃការនិយាយរោយរាយ គឺឥតប្រយោជន៍ ឈ្មោះ ថា សម្ផប្បលាប សូម្បីចេតនាដែលជាសមុដ្ឋាននៃការពោលពាក្យទ្រគោះ និងពាក្យរោយរាយទាំងនោះ ក៏បាននាមថា បិសុណាវាចា ជាដើមនោះឯង ។ ហើយក្នុងទីនេះក៏ប្រាថ្នាយកចេតនានោះឯង ។

ចេតនារបស់អ្នកមានចិត្តសៅហ្មង ដែលជាសមុដ្ឋាននៃកាយបយោគ និង វចីបយោគដើម្បីបំបែកបំបាក់ពួកជនដទៃ ឬ ដើម្បីប្រាថ្នានឹងធ្វើខ្លួនឱ្យជាទីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា បិសុណាវាចា ក្នុងវចីកម្មនោះ ។

បិសុណាវាចា នោះឈ្មោះថា មានទោសតិច ព្រោះអ្នកដែលត្រូវធ្វើឱ្យបែកបាក់នោះ មានគុណធម៌តិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណធម៌ច្រើន ។

បិសុណាវាចានោះមាន អង្គប្រកប ៤ ប្រការ គឺ មានអ្នកដទៃដែលខ្លួនប្រាថ្នាបំបែក ១ ប្រាថ្នាឱ្យគេបែកបាក់គ្នា ឬ ប្រាថ្នាឱ្យខ្លួនជាទីស្រឡាញ់របស់គេ ១ មានសេចក្តីព្យាយាមដែលកើតចិត្តនោះ ១ អ្នកដទៃ ជឿពាក្យញុះញង់នោះ ១ ។

## អធិប្បាយ ផរុសវាចា

ចេតនាដ៏គ្រោតគ្រាតដោយចំណែកមួយ ដែលជាសមុដ្ឋាននៃកាយបយោគ និង វចីបយោគ ដែលជាហេតុកាត់ផ្តាច់សេចក្តីស្រឡាញ់របស់អ្នកដទៃ ឈ្មោះថា ផរុសវាចា ដើម្បីការជាក់ច្បាស់នៃផរុសវាចានោះ ត្រូវសាធករឿងនេះ ។

បានឮមកថា ក្មេងម្នាក់មិនជឿពាក្យរបស់មាតា ( ចចេស) ចូល

ព្រៃទៅ ។ មាតាកាលមិនអាចនឹងឱ្យគេត្រឡប់បាន ទើបជេរថា សូមឱ្យមេក្របីកាចចូរដេញជល់ ។ ខាងក្រោយមក មេក្របីបានប្រាកដដល់គេដូចដែលម៉ែជេរនោះឯង ។

ក្មេងទើបធ្វើសច្ចកិរិយាថា ម៉ែរបស់ខ្ញុំម្ចាស់ពោលយ៉ាងណាដោយមាត់សូមកុំជាយ៉ាងនោះ តែគិតយ៉ាងណាដោយចិត្ត សូមឱ្យជាយ៉ាងនោះចុះ ។ មេក្របីបានឈប់ងើយនៅក្នុងទីនោះឯង ដូចត្រូវគេចង ។

វចីបយោគ សូម្បីជាហេតុកាត់ផ្តាច់នូវពាក្យស្រឡាញ់ ( ពាក្យដែលអាស្រ័យដល់វត្ថុដែលជាទីស្រឡាញ់ ) ដូចដែលពណ៌នាកមនេះក៏មិនជាផរុស-វាទ ព្រោះអ្នកនិយាយមានចិត្តទន់ភ្លន់ ។ ពិតណាស់ គ្រាខ្លះ ពុកម៉ែជេរស្តី កូន ៗ យ៉ាងនេះថា សូមឱ្យពួកចោរកាត់ពួកឯងឱ្យដាច់ជាកំណាត់ ៗទៅចុះ សូម្បីយ៉ាងនោះ សូម្បីត្រឹមតែត្របកផ្កាឧប្បលក៏មិនប្រាថ្នានឹងឱ្យធ្លាក់ចុះលើខាងលើរបស់ពួកគេទេឡើយ ។ ហើយគ្រាខ្លះអាចារ្យ និង ឧបជ្ឈាយ៍ស្តីបន្ទោសអន្តេវាសិក និង សទ្ធិវិហារិក អ្នកនៅអាស្រ័យទាំងឡាយថា ពួកនេះនឹងនិយាយអ្វីក៏មិនមានអៀនខ្មាស មិនមានការខ្លាចក្រែងអ្វីទាំងអស់ អ្នកទាំងឡាយចូរបណ្តេញវាទៅ ។ សូម្បីតែដូច្នេះអាចារ្យនិងឧបជ្ឈាយ៍ទាំងនោះក៏នៅប្រាថ្នាសម្បត្តិ គឺ អាគម ( បរិយត្តិ ) និង អធិគម ( បដិវេធ ) ដល់អន្តេវាសិក

និង សទ្ធិវិហារិក ទាំងនោះ ។

ម្យ៉ាងទៀត វចីបយោគដែលមិនមែនជាផរុសវាចា ព្រោះអ្នកនិយាយមានចិត្តទន់ភ្លន់យ៉ាងណា និងមិនជា ផរុសវាចា ព្រោះអ្នកនិយាយមានពាក្យនិយាយផ្អែមល្ហែមដូច្នេះក៏ទេ ព្រោះថាពាក្យនិយាយរបស់អ្នកប្រាថ្នានឹងឱ្យគេស្លាប់ថា ឯងចូរឱ្យមនុស្សម្នាក់នេះដេកឱ្យសប្បាយចុះ ដូច្នោះ មិនមែនមិនជាផរុសវាចាទេ តែវាចានេះជាផរុសវាចាពិត ព្រោះអ្នកនិយាយមានចិត្តគ្រោត-គ្រាត ។

ផរុសវាចានេះ ឈ្មោះថា មានទោសតិច ព្រោះអ្នកដែលជាផរុស- វាទីបុគ្គលនិយាយសំដៅដល់អ្នកមានគុណតិច ឈ្មោះថា មានទោសច្រើន ព្រោះមានគុណច្រើន ។

ផរុសវាចានោះ មានអង្គប្រកប ៣ ប្រការ គឺ អ្នកដែលនឹងត្រូវជេរជាអ្នកដទៃ ១ ចិត្តខឹងក្រោធ ១ ការជេរ ១ ។

## អធិប្បាយពាក្យថា សម្ផប្បលាប

ចេតនាដែលជាអកុសល ដែលជាសមុដ្ឋាននៃកាយបយោគ និង វចី-បយោគដែលញ៉ាំងអ្នកដទៃឱ្យយល់ពាក្យនិយាយ ដែលឥតប្រយោជន៍ ឈ្មោះថា សម្ផប្បលាប សម្ផប្បលាបនោះ មានទោសតិច ព្រោះអ្នកនិយាយមាន

អាសេវនខ្សោយ ( សេពតិច ) ឈ្មោះថា មានទោសច្រើន ព្រោះអ្នកនិយាយមានអាសេវនច្រើន ( សេពច្រើន ) ។

សម្ផប្បលាបនោះមានអង្គប្រកប ២ ប្រការ គឺ ការប្រាថ្នាដែលនឹងនិយាយពាក្យឥតប្រយោជន៍ មានរឿងសង្គ្រាមភារតៈ និង រឿងការលួចនាំនាងសីតា ( រឿងរាមកេរ្តិ៍ ) ជាដើម ១ ការពោលពាក្យប្រភេទនោះ ១ ។

## អធិប្បាយ អភិជ្ឈា

ចេតនាដែលឈ្មោះថា អភិជ្ឈា ព្រោះសម្លឹងរំពៃ អធិប្បាយថា រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកឆ្ពោះមុខសម្លឹងរំពៃចំពោះភណ្ឌៈរបស់អ្នកដទៃ ហើយបង្អោនភណ្ឌៈនោះមក ។ អភិជ្ឈានោះមានលក្ខណៈសម្លឹងរំពៃភណ្ឌៈរបស់អ្នកដទៃយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ របស់នេះនឹងគប្បីជារបស់យើង ។ អភិជ្ឈា នោះឈ្មោះថា មានទោសតិច និង មានទោសច្រើនដូច អទិន្នាទាន ។

អភិជ្ឈានោះ មានអង្គប្រកប ២ ប្រការ គឺ ទ្រព្យរបស់អ្នកដទៃ ១ បង្អោនវត្ថុនោះមកដើម្បីខ្លួន ១ ។

អធិប្បាយថា សូម្បីនឹងកើតការលោភ ដែលមានភណ្ឌៈរបស់អ្នកដទៃជាទីតាំងទឡើង កម្មបថក៏នៅមិនទាន់ដាច់ ដរាបណាដែលនៅមិនទាន់បានបង្អោនមកដើម្បីខ្លួនថា ធ្វើដូចម្តេចហ្ន៎ របស់នេះនឹងគប្បីជារបស់យើង ។

## អធិប្បាយពាក្យថា ព្យាបាទ

បាបធម៌ដែលឈ្មោះថា ព្យាបាទ ព្រោះញុំាងប្រយោជន៍ និង សេចក្ដីសុខឱ្យដល់សេចក្ដីវិនាស ។

ព្យាបាទនោះមានលក្ខណៈប្រទូសរ៉ាយ ដើម្បីសេចក្ដីវិនាសរបស់អ្នក ដទៃ ។ ព្យាបាទនោះឈ្មោះថា មានទោសតិច និង មានទោសច្រើនដូច ផរុសវាចា ។

ព្យាបាទនោះមានអង្គប្រកប ២ ប្រការ គឺសត្វដទៃ ១ ការគិតដែលនឹងឱ្យសត្វនោះវិនាស ១ ។

អធិប្បាយថា សូម្បីនឹងកើតសេចក្ដីក្រោធដែលមានសត្វដទៃជាអារម្មណ៍ក៏ដោយ កម្មបថក៏នៅមិនទាន់ដាច់ ដរាបណាដែលអ្នកក្រោធនៅមិនទាន់បានគិតឱ្យសត្វនោះវិនាសថា ដូចម្ដេចហ្ន៎ សត្វនោះនឹងគប្បីដាច់សូន្យវិនាសទៅ ។

## អធិប្បាយពាក្យថា មិច្ឆាទិដ្ឋិ

ចេតនាដែលឈ្មោះថា មិច្ឆាទិដ្ឋិ ព្រោះឃើញខុស ដោយមិនមានការកាន់យកតាមសេចក្ដីពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈឃើញខុសដោយន័យមានជាអាទិថា ទានដែលឱ្យហើយ មិនមានផល ។ មិច្ឆាទិដ្ឋិនោះ ឈ្មោះ ថា មានទោសតិច និង មានទោសច្រើន ដូចសម្ផប្បលាប ។ ម្យ៉ាងទៀត

អនិយតមិច្ឆាទិដ្ឋិ ( មិនទៀង ) ឈ្មោះថា មានទោសតិច ជានិយតៈ ( ទៀង ) ឈ្មោះថា មានទោសច្រើន ។

មិច្ឆាទិដ្ឋិនោះមានអង្គប្រកប ២ ប្រការ គឺ ការដែលរឿងខុសអំពីអាការដែលប្រកាន់ ១ ការប្រាកដទេឡើងនៃរឿងនោះ ដោយមិនមានដូចយ៉ាងដែលមិច្ឆាទិដ្ឋិកបុគ្គលប្រកាន់ ១ ។៕

## វិនិច្ឆ័យដោយអាការ ៥ យ៉ាង

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យអកុសលកម្មបថទាំង ១០ យ៉ាងនេះ ដោយអាការ ៥ យ៉ាង គឺដោយធម៌ ( ធម្មតោ) ១ ដោយកោដ្ឋាសៈ ( កោដ្ឋាសតោ) ១ ដោយអារម្មណ៍ ( អារម្មណតោ ) ១ ដោយវេទនា ( វេទនតោ ) ១ ដោយមូល ( មូលតោ ) ១ ។

បណ្ដាបទទាំងនោះ បទថា ធម្មតោ មានសេចក្ដីថា សេចក្ដីពិតក្នុងចំនួនកម្មបថ១០យ៉ាងនេះ កម្មបថ៧យ៉ាង តាមលំដាប់( កាយកម្ម ៣ វចីកម្ម ៤ ) ជាចេតនាធម៌ ចំណែកកម្មបថ ៣ យ៉ាង មានអភិជ្ឈាជាដើម ជាធម៌ប្រកបនឹងចេតនា ។

បទថា កោដ្ឋាសតោ សេចក្ដីថា កម្មបថ ៧ ប្រការ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ១ ទៀត រួមជា ៨ ប្រការនេះ ជាកម្មបថតែម្យ៉ាង មិនជាមូល

( ឫសគល់នៃអកុសល ) ចំណែកអភិជ្ឈា និង ព្យាបាទ ( ២ ប្រការនេះ ) ទាំងជាកម្មបថ ទាំងជាមូល ( ឫសគល់របស់អកុសល ) ។ អធិប្បាយថា ព្រោះជាឫសគល់ អភិជ្ឈាទើបជាលោភអកុសលមូល ព្យាបាទជាទោសអកុសលមូល ។

បទថា អារម្មណតោ សេចក្តីថា បាណាតិបាត មានសង្ខារជា អារម្មណ៍ ព្រោះមានជីវិតិន្ទ្រីយ៍ជាអារម្មណ៍ អទិន្នាទាន មានសត្វជាអារម្មណ៍ ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ មិច្ឆាចារមានសង្ខារជាអារម្មណ៍ដោយអំណាចនៃ ផោដ្ឋព្វៈ អាចារ្យពួកមួយពោលថា មានសត្វជាអារម្មណ៍ក៏មាន ។ មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ បិសុណាវាចាក៏ដូចគ្នានឹង ផរុសវាចា មានសត្វជាអារម្មណ៍តែម្យ៉ាង សម្ផប្បលាបៈមានសត្វជាអារម្មណ៍ ខ្លះ ដោយអំណាចនៃរូបដែលបានឃើញហើយ សម្លេងដែលបានឮហើយ ក្លិន រស និង ផោដ្ឋព្វៈដែលបានជ្រាបហើយ និងធម្មារម្មណ៍ដែលបាន ដឹងហើយ ។

អភិជ្ឈាក៏ដូចគ្នា ( តែ ) ព្យាបាទ មានសត្វជាអារម្មណ៍តែម្យ៉ាង (ចំណែក )មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែល ប្រព្រឹត្តទៅក្នុងភូមិ ៣ ។

## ៦៣៦ អដ្ឋកថា សម្មាទិដ្ឋិសូត្រ ទី ៩

បទថា វេទនតោ សេចក្តីថា បាណាតិបាត មានវេទនាជាទុក្ខ ។ ព្រោះថា ព្រះរាជាទាំងទឡាយទ្រង់ឃើញចោរហើយសូម្បីនឹងទ្រង់ញញឹមបណ្តើរ ទទួលបញ្ជាបណ្តើរថា យកវាទៅសម្លាប់ ដូច្នេះក៏ពិត តែចេតនាដែលជាអ្នកប្រើឱ្យសម្លាប់ជីវិតសត្វក្នុងព្រះហឫទ័យរបស់ព្រះរាជាទាំងនោះ ជាចេតនាដែលប្រកបដោយទុក្ខវេទនា ។

អទិន្នាទាន មានវេទនា ៣ មិច្ឆាចារ មានវេទនា ២ ដោយអំណាចនៃសុខវេទនា និង ឧបេក្ខាវេទនា ។ តែមិនមែនមានវេទនាជាឧបេក្ខា ព្រោះចិត្តជាអ្នកឱ្យសម្រេច ។ មុសាវាទ មានវេទនា ៣ ។ បិសុណាវាចាក៏ដូចគ្នា ។ ផរុសវាចា មានវេទនាជាទុក្ខតែម្យ៉ាង ។ សម្ផប្បលាបៈ មានវេទនា ៣ ។ អភិជ្ឈា មានវេទនា ២ ដោយអំណាចនៃ សុខវេទនា និង ឧបេក្ខាវេទនា ។ មិច្ឆាទិដ្ឋិក៏ដូចគ្នា ។ (តែ) ព្យាបាទមានវេទនាជាទុក្ខ ។

### អធិប្បាយ អកុសលមូល

បទថា មូលតោ សេចក្តីថា បាណាតិបាត មានអកុសល ២ យ៉ាង ជាមូលដោយអំណាចនៃទោសៈ និង មោហៈ ។

អទិន្នាទាន (មានអកុសល ២ យ៉ាងជាមូល) ដោយអំណាចនៃ ទោសៈ និង មោហៈ ឬ ដោយអំណាចនៃលោភៈ និង មោហៈ មិច្ឆាចារ

( មានអកុសល ២ យ៉ាងជាមូល ) ដោយអំណាចនៃលោភៈ និង មោហៈ ។ មុសាវាទ ដោយអំណាចនៃទោសៈ និង មោហៈ ឬ លោភៈ និង មោហៈ ។

បិសុណាវាចា និង សម្ផប្បលាបៈ ក៏ដូចគ្នា (នឹងមុសាវាទ) ។ ផរុសវាចា ដោយអំណាចនៃទោសៈ និង មោហៈ ។ អភិជ្ឈា មានអកុសល តែមួយជាមូល ដោយអំណាចនៃមោហៈ ។

ព្យាបាទក៏ដូចគ្នា ( នឹងអភិជ្ឈា) ។ ( តែ ) មិច្ឆាទិដ្ឋិ មានអកុសល ២ យ៉ាងជាមូល ដោយអំណាចនៃលោភៈ និង មោហៈ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា លោភោ អកុសលមូលំ ជាដើម ( ដូចតទៅនេះ ) ។

អកុសលធម៌ដែលឈ្មោះថា លោភៈ ព្រោះចង់បាន ។ ដែល ឈ្មោះថា ទោសៈ ព្រោះប្រទូសរ៉ាយ ។ ដែលឈ្មោះថា មោហៈ ព្រោះវង្វេង ។

ក្នុងចំនួនអកុសលធម៌ទាំង ៣ យ៉ាងនោះ លោភៈឈ្មោះថា ជាអកុសលមូល ព្រោះខ្លួនវាជាអកុសល ព្រោះអត្ថថា មានទោស និងមានទុក្ខជាវិបាក ទាំងជាឫសគល់របស់អកុសលធម៌ទាំងនេះ មានបាណាតិបាត ជាដើម ព្រោះអត្ថថា ជាសភាពនៃសម្បយុត្តធម៌របស់អកុសលពួកខ្លះ ហើយព្រោះអត្ថថាជាឧបនិស្សយបច្ច័យរបស់អកុសលពួកខ្លះ ។ សមពិតដូចពាក្យដែលព្រះ-

សារីបុត្តបានពោលទុកថា បុគ្គលអ្នកត្រេកអរខ្លាំងហើយ ត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តត្រូវរាគៈរួបរិតហើយ រមែងសម្លាប់សត្វមានជីវិតបាន ដូច្នេះជាដើម សូម្បីក្នុងការដែលទោសៈ និង មោហៈជាអកុសលមូល ក៏មានន័យនេះដូចគ្នា ។

## អធិប្បាយ កុសលកម្មបថ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា បាណាតិបាតា វេរមណី កុសលំ ( ចេតនាវៀរចាកបាណាតិបាតជាកុសល ) ជាដើម ដូចតទៅនេះ អកុសល-កម្មបថទាំងទឡាយ មានបាណាតិបាតជាដើម មានអធិប្បាយដូចដែលខ្ញុំម្ចាស់បានពោលមកហើយនោះឯង ។

ចេតនាដែលឈ្មោះថា វេរមណី ព្រោះញាំញីពៀរ អធិប្បាយ ថា លះបង់ពៀរបាន ។ ម្យ៉ាងទៀត បុគ្គលវៀរចាកពៀរបានព្រោះចេតនានេះជាហេតុ ព្រោះហេតុនោះ ចេតនានោះទើបឈ្មោះថា វេរមណី ដោយផ្លាស់ វិ អក្សរ ឱ្យជា វេ អក្សរទៅ ។ នេះជាការបរិយាយសេចក្តីក្នុងពាក្យថា វេរមណី នេះដោយព្យញ្ជនៈមុន ។ ចំណែកការបរិយាយសេចក្តីក្នុងអត្ថ ( សេចក្តី) គប្បីជ្រាបថា វិរតិដែលសម្បយុត្តជាមួយនឹងកុសលចិត្ត ឈ្មោះថា វេរមណី ។ វិរតិរបស់អ្នកវៀរចាកបាណាតិបាត ដែលត្រាស់ទុកយ៉ាងនេះថា ការវៀរចាក

បាណាតិបាតក្នុងសម័យនោះ ដូច្នេះ ឈ្មោះថា វិរតិដែលសម្បយុត្តជាមួយនឹង កុសលចិត្ត ។

## អធិប្បាយ វិរតិ ៣

វិរតិនោះចែកប្រភេទចេញជា ៣ យ៉ាង គឺ សម្បត្តវិរតិ ១ សមាទាន-វិរតិ ១ សមុច្ឆេទវិរតិ ១ ។

ក្នុងចំនួនវិរតិទាំង ៣ នោះ វិរតិ ដែលកើតទឡើងដល់អ្នកមិនបាន សមាទានសិក្ខាបទទាំងឡាយ ( មកពីមុន ) តែបានពិចារណាដល់ជាតិ វ័យ និងភាពជាពហុស្សូតជាដើមរបស់ខ្លួនហើយ ឃើញថា មិនសមគួរដល់យើងមាន ការធ្វើយ៉ាងនេះ ហើយមិនកន្លងនូវវត្ថុដែលប្រាកដនៅចំពោះមុខ គប្បីជ្រាប ថាជាសម្បត្តវិរតិ ដូចវិរតិរបស់ចក្កនៈឧបាសកក្នុង សីហទ្បទ្វីប ។

## និទាន ប្រកបសម្បត្តវិរតិ

បានឮថា ក្នុងពេលគេនៅកម្លោះនោះឯង មាតារបស់គេកើតរោគ ហើយពេទ្យប្រាប់គេថា គួរនឹងបានសាច់ទន្សាយស្រស់ ៗ ។ ( មកផ្សំថ្នាំ ) ។ លំដាប់នោះ បងប្រុសរបស់ចក្កនៈបញ្ជាថា ឯងចូលទៅស្រែនោះ ។ គេក៏បាន ទៅកាន់ស្រែនោះ ។ ហើយពេលនោះមានទន្សាយមួយមកស៊ីស្មៅខ្ចី ។ ទន្សាយ ឃើញហើយប្រញាប់រត់គេចចេញទៅ តែរត់ទៅជាប់វល្លិ ទើបបញ្ចេញសម្លេង

ស្រែកគ្រែក ៗ ( កិរិ កិរិ ) ទេឡើង ។ ចក្កនៈទៅតាមសម្លេងនោះចាប់ទន្សាយបាន តាំងចិត្តថានឹងយកវាមកធ្វើជាថ្នាំឱ្យម៉ែ តែក៏គិតទេឡើងមកថា មិនជាការសមគួរ សម្រាប់យើងដែលនឹងសម្លាប់ជីវិតសត្វដទៃប្តូរយក ជីវិតម៉ែរបស់យើង ។ ទើប និយាយថា ទៅចុះឯងចូរទៅបរិភោគស្មៅ និងទឹករួមជាមួយនឹងទន្សាយទាំង-ទឡាយក្នុងព្រៃចុះ ហើយក៏ប្រលែងវាទៅ កាលត្រទឡប់មកដល់ផ្ទះ គេត្រូវបង ប្រុសសួរថា យ៉ាងណាហើយប្អូន បានទន្សាយទេ ? ទើបបានប្រាប់ការប្រព្រឹត្តិ ទៅនោះឱ្យជ្រាប ។ ពេលនោះ បងប្រុសក៏បាន ស្តីបន្ទោសគេ ។ គេចូល ទៅរកម៉ែហើយ បានឈរតាំងសច្ចាធិដ្ឋានថា ខ្ញុំម្ចាស់តាំងពីកើតមករហូតមិន ធ្លាប់មានចិត្តសម្លាប់សត្វផ្តាច់ជីវិតទេឡើយ ។ គាប់ជួនពេលនោះ ម៉ែរបស់គេក៏ បានជាសះស្បើយអំពីរោគ ។

តែវិរតិដែលកើតទេឡើងដល់អ្នកបានសមាទានសិក្ខាបទមកហើយ សូម្បី នឹងលះជីវិតរបស់ខ្លួនក្នុងពេលសមាទានសិក្ខាបទ និងពេលបន្ទាប់អំពីនេះទៅក៏ មិនកន្លងវត្ថុ គប្បីជ្រាបថា ជាសមាទានវិរតិ ដូចវិរតិរបស់ឧបាសកអ្នកភ្នំឧត្តរ-វឌ្ឍមានៈ ។

## និទាន ប្រកបសមាទានវិរតិ

បានឮមកថា ឧបាសកនោះ ទទួលសិក្ខាបទក្នុងសម្នាក់របស់ព្រះ-

បិង្គលពុទ្ធរក្ខិតត្ថេរ អ្នកស្រុកអម្ពរយវិហារ ហើយទៅភ្ជួរស្រែ ។ តមក គោរបស់គាត់បាត់ទៅ ។ គាត់កាលតាមរកវា បានទេឡើងលើភ្នំឧត្តរវឌ្ឍមានៈ ។ ពស់ធំបានរំព័ទ្ធគាត់នៅភ្នំនោះ ។ គាត់គិតថា នឹងយកកាំបិតដ៏មុតនេះកាត់ក្បាលវាចោល តែក៏បានគិតទៀតថា ការដែលសមាទានសិក្ខាបទក្នុងសំណាក់របស់គ្រូអ្នកគួរឱ្យរាប់អានហើយ ទម្លាយចោលមិនសមគួរទេឡើយ ។ លុះគិតយ៉ាងនេះដល់ ៣ ដង ហើយក៏កាត់ចិត្តថា យើងនឹងលះបង់ជីវិត មិនព្រមលះបង់សិក្ខាបទ ( សីល ) ហើយបានក្រវែងកាំបិតដ៏មុតដែលលីមកនៅលើស្មាចូលព្រៃទៅ ។ ភ្លាមនោះឯង ពស់ដ៏ធំក៏បានស្រាយខ្លួនចេញ ហើយលូនទៅ ។

## អធិប្បាយ សមុច្ឆេទវិរតិ និង កុសលកម្មបថ

ចំណែកវិរតិដែលសម្បយុត្តដោយអរិយមគ្គគួរជ្រាបថា ជាសមុច្ឆេទវិរតិដែលចាប់ផ្ដើមពីកើតហើយ ព្រះអរិយៈទាំងទឡាយ មិនធ្លាប់សូម្បីតែនឹងកើតការគិតថា យើងនឹងសម្លាប់សត្វមានជីវិត ដូច្នេះ ។

តែវិរតិនេះនោះ លោកហៅថា កុសល ព្រោះប្រព្រឹត្តទៅជាមួយនឹងការឆ្លាតឈ្លាស ម្យ៉ាងទៀត លោកហៅថា កុសល ព្រោះកាត់ផ្ដាច់នូវភាពជាអ្នកទ្រុស្តសីល ដែលបានវោហារថា កុសៈ ព្រោះជាទីកាត់ផ្ដាច់នូវបាបអកុសលដ៏លាមក ។ តែមិនបានហៅថា កុសល ព្រោះមិនសមនឹងបញ្ហានេះថា ម្នាល

អាវុសោ កុសលតើដូចម្ដេច ?

## វិនិច្ឆ័យដោយអាការ ៥ យ៉ាង

ម៉្យាងទៀត កុសលកម្មបថទាំងនេះ ក៏គួរជ្រាបវិនិច្ឆ័យដោយអាការ ៥ យ៉ាង គឺ ដោយធម៌ ( ធម្មតោ ) ១ ដោយកោដ្ឋាសៈ ( កោដ្ឋាសតោ ) ១ ដោយអារម្មណ៍ (អារម្មណតោ) ១ ដោយវេទនា (វេទនតោ) ១ ដោយ មូល ( មូលតោ ) ១ ដូចអកុសលកម្មបថទាំងទឡាយដែរ ។

បណ្ដាបទទាំងនោះ បទថា ធម្មតោ សេចក្ដីថា ក្នុងចំនួនកុសលកម្មបថ សូម្បីទាំងនេះ កម្មបថ ៧ ប្រការ តាមលំដាប់ជាតួចេតនា វិរតិទាំង ៣ ប្រការ ចុងក្រោយ ( មនោកម្ម ៣) ជាធម៌សម្បយុត្តជាមួយនឹងចេតនា ។

បទថា កោដ្ឋាសតោ សេចក្ដីថា កុសលធម៌ ៧ ប្រការតាមលំដាប់ ជាកម្មបថតែម៉្យាងមិនជាមូល ។ ( តែ ) កុសលធម៌ ៣ ប្រការខាងចុងទាំង ជាកម្មបថទាំងជាមូល ។ អធិប្បាយថា អនភិជ្ឈា ដែលដល់កម្មបថហើយ ទើបឈ្មោះថាជា អលោភកុសលមូល ។ តែអព្យាបាទ ឈ្មោះថាជាអទោស-កុសលមូល ។ ចំពោះសម្មាទិដ្ឋិ ឈ្មោះថា ជាអមោហកុសលមូល ។

បទថា អារម្មណតោ សេចក្ដីថា អារម្មណ៍ទាំងទឡាយ មានបាណា-តិបាតជាដើមនោះឯង ជាអារម្មណ៍របស់វេរមណី (ចេតនាវៀរចាកបាណាតិបាត

ជាដើម ) ទាំងនោះព្រោះថា វេរមណីនឹងមានបាន ក៏ដោយបានប្រសព្វនឹងវត្ថុដែលនឹងត្រូវឈានកន្លងប៉ុណ្ណោះ ឧបមាដូចអរិយមគ្គ ( ត្រូវ ) មាននិព្វានជាអារម្មណ៍ ទើបនឹងលះបង់កិលេសបាន យ៉ាងណា កម្មបថទាំងនេះក៏គប្បីជ្រាបថា ដូច្នោះដូចគ្នា ( ត្រូវ ) មានជីវិតិន្ទ្រិយ៍ជាដើម ជាអារម្មណ៍ ទើបនឹងលះការទ្រុស្តសីល មានបាណាតិបាតជាដើមបាន ។

បទថា វេទនាតោ សេចក្តីថា កុសលកម្មបថទាំងអស់ប្រកបនឹងសុខ_វេទនាខ្លះ ប្រកបនឹងឧបេក្ខាវេទនាខ្លះ ព្រោះថាដល់កុសលហើយ នឹងមិនមានទុក្ខវេទនា ( កម្មបថចំណែកកុសលមិនមានឱ្យផលជាទុក្ខ ) ។

បទថា មូលតោ សេចក្តីថា កម្មបថ ៧ នឹងមាន ។

មូល ៣ តាមអំណាចនៃអលោភៈ អទោសៈ និងអមោហៈ សម្រាប់អ្នកវៀរចាកដោយចិត្តសម្បយុត្តដោយញាណ តែមានមូល ២ សម្រាប់អ្នកវៀរចាកដោយចិត្តប្រាសចាកញាណ ។ អនភិជ្ឈាមានមូល ២ សម្រាប់អ្នកវៀរចាកដោយចិត្តសម្បយុត្តដោយញាណ មានមូល ១ សម្រាប់អ្នកវៀរចាកដោយចិត្តដែលប្រាសចាកញាណ តែអលោភៈតួខ្លួនឯងជាមូលរបស់ខ្លួនឯងមិនបាន ។ សូម្បីក្នុងអព្យាបាទ ក៏ទំនងដូចគ្នានេះឯង ។

សម្មាទិដ្ឋិមានមូល ២ ដូចគ្នាតាមអំណាចនៃអលោភៈ និង អទោសៈ

ដូច្នោះ ។

កុសលធម៌ឈ្មោះថា អលោភៈ ក្នុងពាក្យថា អលោភោ កុសលមូលំ ជាដើម ព្រោះមិនលោភ ។ ពាក្យថា អលោភ នេះ ជាឈ្មោះរបស់ធម៌ដែលជាបដិបក្ខនឹងលោភៈ ។ សូម្បីអទោសៈ និង អមោហៈ ក៏មានទំនងដូចគ្នា នេះឯង ។

ក្នុងចំនួនកុសលមូលទាំង ៣ យ៉ាងនោះ អលោភៈ ដែលឈ្មោះថាជាកុសលមូល ព្រោះខ្លួនឯងក៏ជាកុសល ហើយឈ្មោះថាជាមូលរបស់កុសលធម៌ទាំងទឡាយ មានការវៀរចាកបាណាតិបាតជាដើម ទាំងនេះផង ព្រោះអត្ថថាជាបច្ច័យនៃសម្បយុត្តធម៌របស់កុសលពួកខ្លះ ហើយព្រោះអត្ថថា ជាឧបនិស្ស-យប្បច្ច័យរបស់កុសលធម៌ពួកខ្លះ ។

ក្នុងការដែលអទោសៈ និង អមោហៈ ជាកុសលមូលក៏ន័យនេះឯង ។

## អរិយសច្ចក្នុងកម្មបថ

ឥទទ្បូវនេះ ព្រះសារីបុត្តកាលនឹងបញ្ចាក់សេចក្តីនោះទាំងអស់ដែលលោកបានសម្តែងទុកហើយ ទាំងដោយសង្ខេប និង ដោយពិស្តារម្តងទៀត ទើបបានពោលអប្បនាវារៈទុក មានជាអាទិថា យតោ ខោ អាវុសោ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ឯវំ អកុសលំ បជានាតិ សេចក្តីថា

ដឹងច្បាស់អកុសល ដោយអំណាចនៃអកុសលកម្មបថ ១០ តាមដែលសម្តែងទុកហើយយ៉ាងនេះ សូម្បីក្នុងបទមានជាអាទិថា ឯវំ អកុសលមូលំ ក៏ន័យនេះឯង ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ គឺដោយន័យដូចគ្នា ជាការដែលព្រះសារីបុត្តបានពោលដល់កម្មដ្ឋានដែលជាហេតុនាំសត្វចេញ ( ចាកភព ) រហូតដល់ព្រះអរហត្ត សម្រាប់អ្នកបំពេញកម្មដ្ឋាន មានចតុរារិយសច្ចជាអារម្មណ៍។

ពោលទុកដូចម្តេច ?

ពោលទុកថា ការពិតអកុសលកម្មបថ ១០ និង កុសលកម្មបថ ១០ វៀរអភិជ្ឈា ( លោកពោលថា) ជាទុក្ខសច្ចក្នុងកម្មបថវារៈនេះ ចំណែកធម៌ ទាំង ២ យ៉ាងនេះ គឺ អភិជ្ឈា ១ លោភៈដែលជាអកុសលមូល ១ ( លោក ពោលថា) ជាសមុទយសច្ចដោយត្រង់ ។ តែកម្មបថទាំងអស់ ( លោកពោល ថា ) ជាទុក្ខសច្ចដោយអម ។ កុសលមូល និង អកុសលទាំងអស់ ( លោក ពោលថា ) ជាសមុទយសច្ច ។

ការមិនប្រព្រឹត្តទៅនៃកុសល និង អកុសលមូលទាំង ២ ( លោកពោល ថា ) ជានិរោធសច្ច ។ កាលកំណត់ដឹងទុក្ខ ការលះបង់សមុទ័យ ការដឹង ច្បាស់និរោធ អរិយមគ្គ ( លោកពោលថា) ជាមគ្គសច្ច សច្ចៈទាំង ២ លោក

បានពោលទុកហើយដោយសរុប ដូចដែលពណ៌នាមកនេះ ។ ចំណែកសច្ចៈ ២ យ៉ាង ( និរោធ មគ្គ ) គប្បីជ្រាបដោយអំណាចនៃការមិនវិលត្រឡប់ ។

បទថា សោ សព្វសោ រាគានុសយំ បហាយ ( លោកលះបង់រាគា-នុស័យបានដោយប្រការទាំងពួង ) សេចក្តីថា លោកដឹងច្បាស់អកុសលជាដើមយ៉ាងនេះ នឹងលះបង់រាគានុស័យបានដោយអាការគ្រប់យ៉ាង ។

បទថា បដិឃានុសយំ បដិវិនោទេត្វា ( បន្ទោបង់បដិឃានុស័យ ) មានពាក្យដែលលោកពោលទុកថា នាំបដិឃានុស័យចេញបានដោយប្រការទាំងពួងដោយពាក្យត្រឹមតែប៉ុណ្ណេះព្រះថេរៈបានពោលដល់អនាគាមិមគ្គ។

បទថា អស្មីតិ ទិដ្ឋិមានានុសយំ សមូហនិត្វា ( ដកទិដ្ឋិមានានុ-ស័យថា យើងមានចេញ ) សេចក្តីថា ដកទិដ្ឋិមានានុស័យដ៏ប្រព្រឹត្តទៅដោយអាការប្រកាន់រួមគ្នានេះថា យើងមាន ដោយធ្វើធម៌ប្រការខ្លះក្នុងខន្ធ ៥ មិនឱ្យធ្លាក់ទាប ។

បណ្តាបទទាំងនោះ បទថា ទិដ្ឋិមានានុសយំ លោកអធិប្បាយទុកថាបានដល់មានានុស័យដែលប្រហែលនឹងទិដ្ឋិ ។ ព្រោះថា មានានុស័យនេះប្រហែលគ្នានឹងទិដ្ឋិ ព្រោះមានលក្ខណៈប្រព្រឹត្តទៅថា យើងមាន ព្រោះហេតុដូច្នេះ ទើបលោកបានពោលទុកយ៉ាងនេះ ។ម្យ៉ាងទៀត អ្នកប្រាជ្ញានឹងយល់

អស្មិមានះនេះដោយពិស្តារសូមគ្រូតមើល ខេមកសូត្រ ក្នុងខន្ធកវគ្គចុះ ។

បទថា អវិជ្ជំ បហាយ សេចក្តីថា លះអវិជ្ជាដែលជាឫសគុលរបស់ វដ្តៈ ។

បទថា វិជ្ជំ ឧប្បាទេត្វា សេចក្តីថា ញុំាងវិជ្ជាគឺព្រះអរហត្តមគ្គដែលបំផ្លាញអវិជ្ជានោះឱ្យកើតទេឡើង ។ ដោយពាក្យត្រឹមប៉ុណ្ណោះព្រះសារីបុត្តបានពោលដល់អរហត្តមគ្គ ។

សេចក្តីថា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតិ ( ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះ ) សេចក្តីថា ជាអ្នកធ្វើការកាត់ផ្តាច់វដ្តទុក្ខក្នុងអត្តភាពនេះឯង ។

ព្រះសារីបុត្តញុំាងទេសនាឱ្យចប់ទៅដោយពាក្យថា ឯត្តាវតាបិ ខោ អាវុសោ អធិប្បាយថា សូម្បីដោយអំណាចនៃការចាក់ធ្លុះដោយមនសិការដូចដែលពោលហើយក្នុងការសំដែងកម្មបថនេះ ។ ពាក្យដ៏សេសមានន័យដូចដែលបានពោលមកហើយនោះឯង ។

ព្រះសារីបុត្រថេរៈបានបញ្ចប់ទេសនាទៅដោយអនាគាមិមគ្គ និង អរហត្តមគ្គ ដូចដែលបានពណ៌នានេះឯង ។

ចប់កថា ពោលដោយកម្មបថ ភិក្ខុទាំងទឡាយត្រេកអរអនុមោទនា

ភាសិតរបស់ព្រះសារីបុត្រ ។

ក្នុងពាក្យថា សាធាវុសោ ខោ ។ល។ អាគតោ ឥមំ សទ្ធម្មំ មានពាក្យអធិប្បាយទុកថា ភិក្ខុទាំងនោះ លុះបានស្តាប់ធម្មទេសនាពោលអំពីសច្ចៈទាំង ៤ របស់ព្រះសារីបុត្រ ដោយប្រធានគឺកុសលនិងអកុសលយ៉ាងនេះហើយ ទើបត្រេកអរអនុមោទនាចំពោះភាសិតរបស់ព្រះសារីបុត្រ ដោយពាក្យនេះថា ម្នាលអាវុសោ ប្រពៃហើយ ហើយអនុមោទនាដោយចិត្តដែលជាសមុដ្ឋាននៃពាក្យនេះនោះឯង ទទួលយកដោយវាចា រីករាយដោយចិត្ត ។

ឥឡូវ ព្រោះហេតុដែលព្រះថេរៈជាអ្នកអាចដែលនឹងសម្តែងធម៌ទេសនាពោលដោយចតុរារិយសច្ចបានដូចដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រអាចនឹងប្រាប់ នឹងសម្តែងអរិយសច្ច ៤ បានដោយពិស្តារ ។ ឬព្រោះហេតុដែលព្រះសារីបុត្រត្រូវការនឹងសម្តែងធម៌ឱ្យខ្ពស់ទៅឡើងទៅហើយទើបបានពោលថា ឯត្តាវតាបិ ខោ អាវុសោ ( ដោយហេតុត្រឹមតែប៉ុណ្ណេះឯងម្នាលអាវុសោទាំងឡាយ ) ព្រោះហេតុនោះ ភិក្ខុទាំងនោះ អ្នកប្រាថ្នានឹងស្តាប់សច្ចទេសនាដោយន័យសូម្បីយ៉ាងដទៃ ទើបបានសួរបញ្ហាខ្ពស់ទៅឡើងទៅនឹងព្រះសារីបុត្រ ។ ភិក្ខុទាំងនោះ ទើបបានសួរបញ្ហាដទៃដែលខ្ពង់ខ្ពស់ទៅឡើងទៅដោយន័យនេះថា លោកម្ចាស់នៅមានទៀតឬបរិយាយសូម្បីយ៉ាងដទៃ គឺ ហេតុ

សូម្បីយ៉ាងដទៃដែលល្អជាងបញ្ហាដែលលោកម្ចាស់បានសួរខ្លួនឯង ឆ្លើយខ្លួនឯងមកហើយ ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ភិក្ខុទាំងនោះបាននាំគ្នាសួរបញ្ហាក្នុងចំណែកដែលល្អជាងបញ្ហាមុនទេឡើងទៅ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ភិក្ខុទាំងទឡាយបានសួរបញ្ហាដំបូងឱ្យខ្ពង់ខ្ពស់ទេឡើងទៅទៀត ។

បន្ទាប់ពីនោះ ព្រះថេរៈ កាលនឹងព្យាករណ៍បញ្ហាឱ្យភិក្ខុទាំងនោះស្តាប់ទើបបានពោលពាក្យមានជាអាទិថា សិយា អាវុសោ ម្នាលអាវុសោទាំងទឡាយ ( នៅមានទៀត) ដូច្នេះ ។

កថាពណ៌នា អាហារវារៈ ភូត សម្ភវេសី

ក្នុងបណ្តាបទទាំងនោះ ពាក្យអធិប្បាយតទៅនេះនឹងជាពាក្យអធិប្បាយចំពោះបទដែលលំបាក ។

ពាក្យថា អាហារ បានដល់បច្ច័យ ។ ព្រោះបច្ច័យនាំផលមកឱ្យខ្លួនដូច្នោះ បច្ច័យទើបហៅថា អាហារ ។

ពួកសត្វដែលកើតហើយ ឈ្មោះថា ភូត ក្នុងពាក្យទាំងទឡាយមានជាអាទិថា ភូតានំ វា សត្តានំ ។ ពួកសត្វដែលស្វែងរក គឺ ស្វែងរកការសម្ភព គឺការកើត បានដល់ការកើតទេឡើង ឈ្មោះថា សម្ភវេសី ។

បណ្ដាកំណើតទាំង ៤ យ៉ាងនោះ ពួកសត្វដែលកើតក្នុងពង និងដែលកើតក្នុងពពុះទឹក ដរាបណាដែលនៅមិនទាន់ទម្លាយក្រសោមពង និង ស្រោមសម្រាល ( ចេញមក ) ដរាបនោះក៏នៅឈ្មោះថា សម្ភវេសី កាលទម្លាយក្រ-សោមពង និង ស្រោមសម្រាលចេញមកខាងក្រៅហើយ ទើបឈ្មោះថា ភូត ។

ចំណែកសត្វដែលជាសំសេទជកំណើត និង ឧបបាតិកកំណើតក្នុងខណៈនៃចិត្តដួងដំបូង ឈ្មោះថា សម្ភវេសី តាំងពីខណៈនៃចិត្តដួងទី ២ ទៅ ឈ្មោះ ថា ភូត ។

ម្យ៉ាងទៀត សត្វទាំងទឡាយនឹងកើតដោយឥរិយាបថណាក៏ដោយ ដរាបណានៅមិនទាន់ផ្លាស់ប្តូរឥរិយាបថមួយទៅឥរិយាបថមួយនោះ ដរាបនោះឈ្មោះថា សម្ភវេសី ផ្លាស់ប្តូរឥរិយាបថនោះទៅ ទើបឈ្មោះថា ភូត ។ ម្យ៉ាងទៀត ពួកសត្វដែលកើតហើយ គឺ កើតទេឡើងហើយ ( សម្រេចហើយ ) ឈ្មោះថា ភូត ព្រះខីណាស្រពពួកណា អ្នកជាព្រះអរិយជាម្ចាស់ហើយនោះឯង រាប់ថានឹងមិនកើតទៀត ពាក្យថា ភូត នេះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។

សត្វពួកណាកំពុងស្វែងរកទីកើត សត្វពួកនោះឈ្មោះថា សម្ភវេសី ពាក្យថា សម្ភវេសី នេះ ជាឈ្មោះរបស់ព្រះសេក្ខៈ និង បុថុជ្ជនអ្នកកំពុងស្វែងរកការកើតតទៅ ព្រោះលះបង់សំយោជនៈក្នុងភពមិនទាន់បាន ។

កាលបើដូច្នេះ ដោយ ២ បទនេះ សូម្បីក្នុងទីគ្រប់កន្លែង ( សេចក្តី ) ទើបសំដៅដល់សត្វគ្រប់ប្រភេទ ។ ហើយ វា សព្ទ ក្នុងពាក្យថា ភូតានំ វា សត្តានំ នេះជាសម្បិណ្ឌនត្ថ ( មានសេចក្តីរួម មិនមែនជាវិកប្បត្ថ )។ ព្រោះហេតុដូច្នោះ អ្នកសិក្សាគប្បីជ្រាប ( ថាស្មើនឹង ) សេចក្តីនេះថា ភូតានំ ច សម្ភវេសីនញ្ច (ទាំងភូតទាំងសម្ភវេសី ) ។

បទថា ឋិតិយា បានដល់ដើម្បីឋិតនៅ ។

បទថា អនុគ្គហាយ បានដល់ដើម្បីអនុគ្រោះគឺដើម្បីឧបការៈ។

ទាំងពីរបទគឺ ភូតានំ វា សម្ភវេសីនំ នោះ មានការផ្សេងគ្នាតែ ព្យញ្ជនៈប៉ុណ្ណោះ តែសេចក្តីនៃបទទាំងពីរនោះដូចគ្នា ។

បទថា ឋិតិយា ( ដើម្បីតាំងនៅ ) គឺដើម្បីមិនឱ្យធម៌ទាំងទឡាយដែលកើតទេឡើងហើយដល់សត្វនុះៗដាច់ជាចំណែកទៅ ដោយមិនអាចជាប់តគ្នាបាន។

បទថា អនុគ្គហាយ ដើម្បីអនុគ្រោះ បានដល់ដើម្បីឱ្យធម៌ដែលនៅមិនទាន់កើតបានកើតទេឡើង ។

ហើយទាំង ២ បទនេះ គួរប្រើក្នុងសេចក្តីទាំងពីរយ៉ាងនេះថា ដើម្បីការតាំងនៅ និង ដើម្បីអនុគ្រោះភូតទាំងទឡាយផង ដើម្បីការតាំងនៅ និង ដើម្បីអនុគ្រោះសម្ភវេសីទាំងទឡាយផង ។

## កវឡិង្ការាហារ

អាហារដែលនឹងត្រូវធ្វើឱ្យជាពំនូតៗទៅហើយទំពាស៊ី ឈ្មោះថា កវ-លិង្ការាហារ។ពាក្យថាកវឡិង្ការាហារនេះជាឈ្មោះរបស់ឱជៈដែលមាន បាយ និង នំស្រស់ ( កុម្មាស) ជាដើមជាទីតាំង ។

ពីរបទថា ឱឡារិកោ វា សុខុមោ វា សេចក្តីថា(អាហារ)ឈ្មោះ ថា ឱឡារៈ ព្រោះជារបស់ដែលគ្រោតគ្រាតដោយវត្ថុ ឈ្មោះថា សុខុម ព្រោះជារបស់ដែលល្អិតដោយវត្ថុ ។

តែដោយសភាវៈ កវឡិង្ការាហារ ឈ្មោះថា ជារបស់ល្អិតពិត ព្រោះជាសុខុមរូប ។ សូម្បីថាការដែលអាហារនោះនឹងជារបស់គ្រោតគ្រាត និងជារបស់ល្អិតដោយវត្ថុ ក៏ត្រូវដឹងបានព្រោះឧបាទាយរូប ។ ពិតណាស់ អាហាររបស់សត្វក្ងោកក៏ឈ្មោះថាជារបស់ល្អិតព្រោះប្រៀបធៀបនឹងអាហារសត្វ ក្រពើ។ បានឮថា ពួកសត្វក្រពើលេបដុំថ្មចូលទៅ ហើយដុំថ្មទាំងនោះធ្លាក់ដល់ផ្ទៃពោះរបស់ក្រពើប៉ុណ្ណោះក៏រលាយអស់ ( រលាយទៅ ) ។ ពួកសត្វក្ងោកចឹកស៊ីសត្វមានជីវិតដូចជាពស់ និង ខ្ទួយជាដើម ។ តែអាហាររបស់សត្វឆ្កែឈ្មោះថាជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហាររបស់សត្វក្ងោក ។

បានឮថា ឆ្កែទាំងនោះកកេរឆ្អឹង (សត្វ) ដែលបោះចោលអស់ ៣

ឆ្នាំបាន ក៏ស្អែង និង ឆ្អឹងសត្វទាំងនោះ លុះតែសើមទឹកមាត់របស់វាប៉ុណ្ណោះ ក៏ផុយរលួយដូចមើមដំទឡូង ។

អាហាររបស់ពួកសត្វដំរី ឈ្មោះថា ជារបស់ល្អិត ព្រោះប្រៀបធៀបនឹងអាហាររបស់ឆ្កែ ពួកវាបរិភោគមែកឈើផ្សេង ៗ ។ អាហាររបស់សត្វទាំងទន្សាយដូចជាគោព្រៃ រមាស និង ម្រឹគជាដើម ឈ្មោះថា ជារបស់ល្អិតជាងអាហារដំរី ។ បានជ្រាបថា ពួកវានាំគ្នាស៊ីស្លឹកឈើផ្សេង ៗ ជាដើមដែលមិនរឹង ( មិនមានខ្លឹម ) ។ អាហាររបស់ពួកគោ ឈ្មោះថា ជាអាហារល្អិតជាងអាហាររបស់សត្វរមាសជាដើមទាំងនោះ ។ ពួកវាស៊ីស្មៅស្រស់និងស្មៅស្ងួត ។ អាហាររបស់សត្វទន្សាយជាអាហារល្អិតជាងអាហាររបស់ពួកសត្វគោ ។ អាហាររបស់ពួកបក្សីល្អិតជាងអាហាររបស់ទន្សាយ ។ អាហាររបស់អ្នកជាយដែន ល្អិតជាងអាហាររបស់បក្សី ។ អាហាររបស់មេស្រុកល្អិតជាងអាហាររបស់អ្នកជាយដែន ។ អាហាររបស់ព្រះរាជា និង មហាមាត្យរបស់ព្រះរាជាល្អិតជាងអាហាររបស់មេស្រុក ។ ព្រះក្រយាហាររបស់ព្រះចៅចក្រពត្តិល្អិតជាងអាហាររបស់មនុស្សស្ងួម្បីទាំងនោះ ។ អាហាររបស់ពួកទេវតាជាន់ចាតុម្មហារាជិកាល្អិតជាងអាហាររបស់ពួកភុម្មទេវតា ។ អាហារ ( របស់ពួកទេវតាជាន់ផ្សេង ៗ ) ក៏គួរពង្រីកឱ្យពិស្តារយ៉ាងនេះទៅរហូតដល់ពួកទេវតាជាន់បរនិម្មិតវសតី ។ អាហាររបស់ពួកទេវតា

ជាន់ទាំងនោះត្រូវយល់ថា ជាអាហារល្អិតទាំងអស់ ។ ម្យ៉ាងទៀត ក្នុងវត្ថុគ្រោតគ្រាតនេះឱជាក៏តិច មានកម្លាំងតិច ។ ក្នុងវត្ថុល្អិតឱជាមាន កម្លាំងខ្ពស់ ។ ពិតយ៉ាងនោះ អ្នកហុតយាគូទាំងពេញបាត្រមួយភ្លេតប៉ុណ្ណោះក៏ហេវ ចង់នឹងទំពាស៊ីរបស់ណាមួយនោះឯង ។ ចំណែកអ្នកផឹកទឹកដោះថ្លាសូម្បី ត្រឹមតែមួយទូកដៃក៏មិនចង់ស៊ី ( មិនហេវ ) រហូតមួយថ្ងៃ ។ ក្នុងចំនួនវត្ថុ និងឱជា ២ យ៉ាង នោះវត្ថុបន្ទោបង់ភាពក្រវល់ក្រវាយ ( ហេវ ) បាន តែមិនអាចរក្សា ( ជីវិត ) ទុកបាន ។ ( ចំណែក ) ឱជារក្សាជីវិតទុកបាន តែមិនអាចបន្ទោបង់ភាពក្រវល់_ក្រវាយ ( ហេវ ) បាន ។ តែទាំង ២ យ៉ាងនោះរួមចូលគ្នាហើយបន្ទោបង់ ភាពក្រវល់ក្រវាយ ( ហេវ ) បានផង រក្សា ( ជីវិត ) បានផង ដូច្នេះឯង ។

### ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ

បទថា ផស្សោ ទុតិយោ សេចក្តីថា ផស្សៈទាំង ៦ យ៉ាង មានចក្ខុសម្ផស្សៈជាដើម គប្បីជ្រាបថា ជាអាហារប្រភេទទី ២ ក្នុងចំនួនអាហារ ៤ យ៉ាងនោះ ។ ក៏ន័យនេះជាន័យនៃទេសនាប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបមិនគួរស្វែងរកពាក្យនេះថា អាហារទី ២ និងទី ៣ ក្នុងអាហារវារៈនេះ ។

ចេតនានោះឯង លោកហៅថា មនោសញ្ចេតនាហារ ។

ចិត្តដួងណាមួយ ឈ្មោះថា វិញ្ញាណ ។

ក្នុងរឿងនេះ ព្រះសារីបុត្របានពោលទុកថា បើមានពាក្យសួរថា សត្វតាំងនៅបានព្រោះបច្ច័យ តាំងនៅបានព្រោះអាហារ កាលបើដូច្នោះ ហេតុអ្វីកាលបច្ច័យរបស់សត្វទាំងទឡាយសូម្បីយ៉ាងដទៃមាន ទើបព្រះអង្គត្រាស់អាហារទុក ៤ យ៉ាងនេះ ប៉ុណ្ណោះ ។

ខ្ញុំនឹងពោលឆ្លើយថា ព្រះអង្គត្រាស់ទុកព្រោះជាបច្ច័យពិសេសនៃសន្តតិដែលប្រព្រឹត្តទៅខាងក្នុង ។ អធិប្បាយថា កវឡិង្ការាហារ ជាបច្ច័យពិសេសរបស់រូប កាយរបស់សត្វទាំងទឡាយអ្នកមានកវឡិង្ការាហារជាអាហារ ផស្សាហារជាបច្ច័យពិសេសរបស់វេទនាក្នុងពួកនាម មនោសញ្ចេតនាហារជាបច្ច័យពិសេសរបស់វិញ្ញាណ វិញ្ញាណជាបច្ច័យពិសេសរបស់នាមរូប ដូចដែលព្រះមានព្រះភាគបានត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ រាងកាយនេះអាស្រ័យអាហារទើបតាំងនៅបាន មិនមានអាហារតាំងនៅមិនបាន យ៉ាងណា ។ ដូចយ៉ាងវេទនាកើតមានព្រោះផស្សៈជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ។

សួរថា ក៏ក្នុងអាហារវារៈនេះ អាហារអ្វី នាំអ្វីមកឱ្យ ?

ឆ្លើយថា កវឡិង្ការាហារ នាំរូបមានឱជា ជាទី ៨ មកឱ្យ ( អវិនិព្ភោគ រូប ៨ ) ផស្សាហារនាំវេទនា ៣ មកឱ្យ មនោសញ្ចេតនាហារ នាំភពទាំង

៣ មកឱ្យ វិញ្ញាណនាំ នាមរូបក្នុងបដិសន្ធិមកឱ្យ ។

នាំមកឱ្យ ដូចម្តេច ?

( នាំឱ្យកើតយ៉ាងនេះ ) គឺ កវឡិង្ការាហារ ត្រឹមតែដាក់ក្នុងមាត់ប៉ុណ្ណោះ ក៏ជាសមុដ្ឋាននៃរូបទាំង ៨ ( សាងរូបទាំង ៨ ទឡើង ) ចំណែកដុំបាយមួយដុំៗ ដែលធ្មេញទំពាឱ្យល្អិតលេបចូលទៅ នឹងជាសមុដ្ឋាននាំឱ្យកើតរូបទឡើងមួយដុំៗ ៨ រូបប៉ុណ្ណោះ ។ កវឡិង្ការាហារ នាំរូបមានឱជាជាទី ៨ មកឱ្យយ៉ាងនេះ ។ ចំណែកផស្សាហារ គឺ ផស្សៈដែលនឹងឱ្យកើតសុខវេទនា កាលកើតទឡើងនឹងនាំសុខវេទនាមកឱ្យ ។ ផស្សៈដែលនឹងឱ្យកើតទុក្ខវេទនាក៏ដូច្នោះ គឺ នឹងនាំទុក្ខ-វេទនាមកឱ្យ ។ ដែលនឹងឱ្យកើតអទុក្ខមសុខវេទនាក៏នឹងនាំអទុក្ខមសុខមកឱ្យ ។ ផស្សាហារនឹងនាំវេទនាទាំង ៣ មកឱ្យដោយប្រការទាំងពួង ដូចដែលពណ៌នាមកនេះ ។

មនោសញ្ចេតនាហារ គឺ កម្មដែលនឹងឱ្យចូលដល់កាមភព និង នាំកាមភពមកឱ្យ ។ ដែលនឹងឱ្យចូលដល់រូបភព និង អរូបភព ក៏នឹងនាំរូបភព និង អរូបភពមកឱ្យ ។ មនោសញ្ចេតនាហារ នឹងនាំភពទាំង ៣ មកឱ្យយ៉ាងនេះ សូម្បីដោយប្រការទាំងពួង ។

តែវិញ្ញាណាហារ លោកពោលថា នឹងនាំខន្ធទាំង ៣ ដែលសម្បយុត្ត

ដោយវិញ្ញាណនោះនិងរូប ៣០ យ៉ាងដែលកើតទេឡើងដោយអំណាចនៃសន្តតិ ៣ មកឱ្យដោយន័យនៃបច្ច័យមានសហជាតប្បច្ច័យជាដើម ក្នុងបដិសន្ធិ- ខណៈ ។ វិញ្ញាណាហារនាំនាមរូបក្នុងបដិសន្ធិខណៈមកឱ្យយ៉ាងនេះ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងអាហារវារៈនេះ កុសលចេតនា និង អកុសលចេតនា ដែលនៅមានអាសវៈនោះឯង លោកពោលទុកថា មនោសញ្ចេតនាហារនឹងនាំភពទាំង ៣ មកឱ្យ បដិសន្ធិវិញ្ញាណនោះឯង លោកពោលទុកថា វិញ្ញាណនឹងនាំនាមរូបក្នុងបដិសន្ធិខណៈមកឱ្យ ។ តែអាហារ ៣ យ៉ាងនេះ គប្បីជ្រាបថាជាអាហារដោយមិនប្លែកគ្នា ។

ព្រោះនាំមកនូវធម៌ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ និង ធម៌ដែលជាសមុដ្ឋាននៃវិញ្ញាណនោះ ។

ក្នុងចំនួនអាហារ ៤ យ៉ាងនោះ កវទេឡិង្ការាហារកាលឧបត្ថម្ភគាំទ្រ ( ជីវិត ) ទុករមែងឱ្យសម្រេចកិច្ចគឺការនាំ ( រូប ) មក ។ ផស្សៈ កាលពាល់ត្រូវនោះឯង ( រមែងឱ្យសម្រេចកិច្ចគឺការនាំវេទនាមក ) ។ មនោសញ្ចេតនា ការប្រមូលមកនោះឯង ( រមែងឱ្យសម្រេចកិច្ច គឺ ការនាំភពមក ) ។ វិញ្ញាណការដឹងច្បាស់នោះឯង( រមែងឱ្យសម្រេចកិច្ចគឺការនាំនាមរូបក្នុងបដិសន្ធិខណៈ មក ) ។

យ៉ាងណា ?

( យ៉ាងនេះគឺ ) ពិតណាស់ កវឡិង្ការាហារ កាលឧបត្ថម្ភគាំទ្រ ( ជីវិត ) នោះឯង នឹងមានការធ្វើឱ្យសត្វទាំងទឡាយតាំងនៅបាន ដោយការឧបត្ថម្ភរាង-កាយឱ្យប្រព្រឹត្តទៅ ព្រោះថា រាងកាយនេះសូម្បីកម្មនឹងតាក់តែងឱ្យកើត កវ-ឡិង្ការាហារក៏ឧបត្ថម្ភគាំទ្រទុក ទើបតាំងនៅបានរហូតដល់កំណត់អាយុ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ដូចទារកដែលមាតាឱ្យកើតហើយ មេដោះឱ្យផឹកទឹកដោះជាដើម ចិញ្ចឹមថែរក្សា ទើបតាំងនៅបានយូរ ។ ដូចផ្ទះដែលប្រើឈើទល់ ទល់ទុក ។

សមពិតតាមព្រះពុទ្ធវចនៈថា សូមថ្វាយព្រះពរមហាបពិត្រ កាលផ្ទះនឹង រលំ មនុស្សទាំងទឡាយនឹងយកឈើដទៃមកទល់ ផ្ទះនោះដែលត្រូវឈើដទៃទល់ ទប់តម្រង់ខ្លួននៅបាន កាលបើដូច្នោះ ផ្ទះនោះនឹងមិនរលំដួល យ៉ាងណា សូមថ្វាយព្រះពរមហាបពិត្រព្រះរាជសម្ភាររាងកាយនេះ ក៏ដូច្នោះដូចគ្នានោះឯង តាំងនៅបានព្រោះអាហារ អាស្រ័យអាហារទើបតាំងនៅបាន ។ កវឡិង្ការាហារ កាលឧបត្ថម្ភគាំទ្ររាងកាយយ៉ាងនេះ រមែងឈ្មោះថា ឱ្យសម្រេចនាទីរបស់អា- ហារ ( ការនាំរូបមក ) ហើយសូម្បីកាលឱ្យសម្រេចអាហារកិច្ចយ៉ាងនេះ កវ-ឡិង្ការាហារក៏ឈ្មោះថាជាបច្ច័យរបស់រូបសន្តតិ ២ យ៉ាង គឺ ជាបច្ច័យរបស់រូបដែលមានអាហារជាសមុដ្ឋានផង រូបដែលតណ្ហា និង ទិដ្ឋិកាន់យកហើយផង ។

កវឡិង្ការាហារជាអ្នកតាមរក្សាកម្មជរូប ( រូបកើតអំពីកម្ម ) ហើយជាអ្នកឱ្យកំណើតដល់រូបដែលមានអាហារជាសមុដ្ឋាន ។

ចំណែកផស្សៈ កាលពាល់ត្រូវអារម្មណ៍ដែលជាទីតាំងនៃសេចក្ដីសុខជាដើមនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការរំលវល់ទៅនៃសុខវេទនាជាដើម ។

មនោសញ្ចេតនា ការប្រមូលមក ដោយអំណាចនៃកុសលកម្ម និងអកុសលកម្មនោះនោះឯង ឈ្មោះថា មានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការញ៉ាំងឫសគល់របស់ភពឱ្យសម្រេច ។

វិញ្ញាណ ការដឹងច្បាស់នោះឯង ឈ្មោះថាមានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ដោយការប្រព្រឹត្តិទៅនៃនាមរូប ។

## ភ័យក្នុងអាហារ ៤

ក្នុងអាហារ ៤ យ៉ាងនេះ ដែលឱ្យសម្រេចអាហារកិច្ច ដោយអំណាចនៃការឧបត្ថម្ភជាដើម គួរឃើញភ័យ ៤ ប្រការយ៉ាងនេះ គឺ ក្នុងកវឡិង្ការាហារ បានដល់ភ័យ គឺការប្រាថ្នា ( ចំណង់ ) ក្នុងផស្សាហារ បានដល់ ភ័យ គឺការជាប់ជំពាក់ ( ជាប់ ) នោះឯង ក្នុងមនោសញ្ចេតនាហារ បានដល់ ភ័យ គឺការប្រមូលមក (សន្សំ) នោះឯង ក្នុងវិញ្ញាណាហារ បានដល់ ភ័យ គឺការធ្លាក់

ចុះចំពោះ ( ការកាន់យកកំណើត ) ។

ព្រោះហេតុអ្វី ?

ព្រោះថាសត្វទាំងទឡ្លាយសាងភ័យ គឺ សេចក្តីប្រាថ្នាក្នុងកវឡិង្ការាហារ ត្រូវប្រឈមមុខចំពោះភាពរងាជាដើម ធ្វើការងារមានការរាប់ដោយម្រាមដៃជាដើម ដើម្បីត្រូវការអាហាររមែងចូលដល់ទុក្ខមិនមែនតិច ។ ហើយបុគ្គលចំពួកខ្លះសូម្បីនឹងបួសក្នុងព្រះសាសនានេះក៏ស្វែងរកអាហារ ដោយការស្វែងរកដែលមិនសមគួរ មានវេជ្ជកម្មជាដើម និងជាអ្នកត្រូវរិះគន់តិះដៀលក្នុងបច្ចុប្បន្ននេះ។

សូម្បីក្នុងសប្បរាយិកភព ក៏នឹងជាសមណប្រេត ដោយន័យដែលបានពោលទុកហើយក្នុងលក្ខណសំយុត្តមានជាអាទិថា សូម្បីសង្ឃាដិរបស់លោកត្រូវភ្លើងឆេះសន្ធោសន្ធៅហើយ ហើយការប្រាថ្នាក្នុងកវឡិង្ការាហារនោះឯង គប្បីជ្រាបថាជាភ័យ ព្រោះហេតុនោះសិនចុះ ។

ជនទាំងទឡ្លាយអ្នកមានអស្សាទៈក្នុងផស្សៈ សូម្បីកាលបានជួបប្រទះនឹងផស្សៈ ក៏នឹងបៀតបៀនរបស់ទាំងទឡ្លាយមានប្រពន្ធជាដើម របស់អ្នកដទៃដែលគេរក្សា ។ អ្នកម្ចាស់ទ្រព្យនឹងចាប់គេព្រមដោយរបស់កាប់ឱ្យដាច់ជាកំណាត់ ៗ ចោលត្រង់គំនរសម្រាម ឬ ប្រគល់ខ្លួនដល់ព្រះរាជា ។ តពីនោះ ព្រះរាជាក៏នឹងត្រាស់បញ្ជាឱ្យពួកគេធ្វើការងារផ្សេង ៗ ( ដាក់ទោស) ។ ហើយព្រោះកាយបែក

ធ្លាយទៅ ពួកគេបានទទួលភ័យ គឺ ទុគ្គតិ ។ កម្មដែលមានអស្សាទៈក្នុងផស្សៈជាមូលដ្ឋាន ជាហេតុឱ្យប្រសព្វភ័យទាំងក្នុងបច្ចុប្បន្ន និង សម្បរាយិកភពដោយពិតដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ការប្រាថ្នាក្នុងផស្សាហារនោះឯងគប្បីជ្រាបថាជាភ័យ ។ តែភ័យក្នុងទាំងភព ៣ ដែលមានកុសល និង អកុសលកម្មនោះជាមូលដ្ឋាន នឹងមានមកទាំងអស់ហើយព្រោះការប្រមូលមកនូវកុសលកម្ម និង អកុសលកម្មនោះឯង ។ ព្រោះហេតុនេះ ការប្រមូលមកក្នុងមនោសញ្ចេតនាហារនោះឯង គប្បីជ្រាបថាជាភ័យ ។

ចំណែកបដិសន្ធិវិញ្ញាណក៏នឹងទទួលយកបដិសន្ធិនាមរូបនោះឯង កើតទេឡើងក្នុងទីដែលកាន់យកកំណើត ហើយកាលបដិសន្ធិវិញ្ញាណនោះកើតទេឡើងហើយភ័យគ្រប់យ៉ាងក៏ជាការកើតទេឡើងដូចគ្នា ព្រោះមានបដិសន្ធិនោះជាមូលដ្ឋាន ព្រោះហេតុដូចដែលបានពណ៌នាមកហើយនោះឯង ការកាន់យកកំណើត (ធ្លាក់ចុះចំពោះ) គប្បីជ្រាបថាជាភ័យក្នុងវិញ្ញាណាហារដូច្នេះឯង ។

តែក្នុងចំនួនអាហារទាំង ៤ យ៉ាងនេះ ដែលជាភ័យយ៉ាងនេះ ដើម្បីនឹងឱ្យគ្រប់សង្កត់សេចក្តីប្រាថ្នាក្នុងកវឡិង្ការាហារ ព្រះសម្មាសម្ពុទ្ធទើបទ្រង់សម្តែងការប្រៀបធៀបដោយសាច់បុត្រ ដោយន័យមានជាអាទិថា ម្នាលភិក្ខុទាំងទឡាយប្តីប្រពន្ធទាំងពីរស្វាម្បីយ៉ាងណា ។

ដើម្បីឱ្យគ្របសង្កត់ចំណង់ក្នុងផស្សាហារ ទើបទ្រង់សម្តែងការប្រៀប-ធៀបដោយមេគោដែលត្រូវពន្លះស្បែក ដោយន័យមានជាអាទិថា ម្នាលភិក្ខុទាំងទឡាយ មេគោដែលត្រូវគេពន្លះស្បែកចេញហើយ សូម្បីយ៉ាងណា ។

ដើម្បីឱ្យគ្របសង្កត់សេចក្តីប្រាថ្នា ក្នុងមនោសញ្ចេតនាហារ ទើបទ្រង់សម្តែងការប្រៀបធៀបដោយរណ្តៅរងើកភ្លើង ដោយន័យមានជាអាទិថា ម្នាលភិក្ខុទាំងទឡាយ រណ្តៅរងើកភ្លើងសូម្បីយ៉ាងណា។

ដើម្បីឱ្យគ្របសង្កត់សេចក្តីប្រាថ្នាក្នុងវិញ្ញាណាហារ ទើបទ្រង់សម្តែងការប្រៀបធៀបដោយការចាក់ដោយលំពែង ៣០០ លំពែងដោយន័យមានជាអាទិថា ម្នាលភិក្ខុទាំងទឡាយដែលចោរ អ្នកប្រព្រឹត្តអាក្រក់ សូម្បីយ៉ាងណា ។

នេះជាការប្រកបសេចក្តីដោយសង្ខេប ដោយអធិប្បាយសេចក្តីឱ្យជាក់ច្បាស់ក្នុងអាហារវារៈនោះ ។

## ប្រៀបធៀប ស្វាមីភរិយាស៊ីសាច់បុត្ត

បានឮមកថា ពីរនាក់ប្តីប្រពន្ធពបុត្រដើរផ្លូវកន្តារ ១០០ យោជន៍ ដោយស្បៀងបន្តិចបន្តួច ។ កាលគេដើរទៅបាន ៥០ យោជន៍ ស្បៀងក៏អស់ទៅ។

គេទាំងពីររសាប់រសល់ព្រោះការហេវហត់ នាំគ្នាអង្គុយក្រោមម្លប់នៃដើមឈើដែលមានស្លឹករើង ៗ បន្ទាប់អំពីនោះ ខាងបុរសបាននិយាយនឹងភរិយា

ថា នាងអើយរយៈផ្លូវ ៥០ យោជន៍ជុំវិញៗ នេះ មិនមានស្រុក ឬ និគមទេឡើយ ព្រោះហេតុដូច្នោះ ឥឡូវនេះ បងមិនអាចនឹងធ្វើការងារដ៏ច្រើនដែលបុរសនឹងគប្បីធ្វើបាន មានការធ្វើស្រែ និង ចិញ្ចឹមគោជាដើមបាន ណ្ហើយនាង ចូរសម្លាប់បងហើយបរិភោគសាច់មួយចំណែក មួយចំណែកទៀតយកធ្វើជាស្បៀងដើរឆ្លងផ្លូវកន្តារ ទៅជាមួយនឹងកូនចុះ ។

ចំណែកនាងបាននិយាយជាមួយនឹងស្វាមីថា បងអើយបង ឥឡូវនេះ អូនមិនអាចនឹងធ្វើការងារ ដែលស្ត្រីនឹងធ្វើមានការរវៃអំបោះជាដើមដ៏ច្រើនបាន ណ្ហើយបង ចូរសម្លាប់អូនហើយបរិភោគសាច់មួយចំណែក មួយចំណែកទៀតយកទៅធ្វើជាស្បៀងធ្វើដំណើរឆ្លងផ្លូវកន្តារទៅជាមួយនឹងកូនចុះ ។

ចំណែកបុរសដែលជាប្តីបាននិយាយនឹងភរិយាទៀតថា អូនអើយ ព្រោះមេផ្ទះស្លាប់ ការស្លាប់នឹងប្រាកដដល់យើងទាំងពីរនាក់ឪពុកកូន ព្រោះកូនក្មេងតូចវៀរមាតាហើយនឹងមិនអាចមានជីវិតនៅបាន តែបើយើងទាំងពីរនាក់នៅមានជីវិតក៏នឹងបានកូនទៀត ណ្ហើយចុះ ឥឡូវនេះ យើងនឹងសម្លាប់កូនយកសាច់បរិភោគឆ្លងផ្លូវកន្តារ ។

លំដាប់នោះ ម្តាយបាននិយាយជាមួយនឹងកូនថា កូនអើយចូរកូនទៅរកឪពុកចុះ ។ កូនក៏ទៅ ( រកឪពុក ) ។ បន្ទាប់ពីនោះ ឪពុករបស់កូននិយាយ

ថា បងបានសោយទុក្ខមកមិនមែនតិច ព្រោះការធ្វើស្រែចំការចិញ្ចឹមគោដោយសង្ឃឹមថានឹងចិញ្ចឹមកូន ទើបបងមិនអាចនឹងសម្លាប់កូនបានទេ នាងនោះឯងចូរសម្លាប់កូននាងចុះដូច្នេះហើយបានប្រាប់កូនថាកូនអើយចូរកូនទៅរកម៉ែឯង ចុះ។ កូនក៏បានទៅ ( រកម៉ែ ) សូម្បីម៉ែរបស់កូននោះក៏បាននិយាយថា ខ្ញុំកាលចង់បានកូន បានសោយទុក្ខមិនតិច ដោយការប្រព្រឹត្តិខ្លួនដូចជាគោ ប្រព្រឹត្តខ្លួនដូចជាសុនខ ហើយអង្វរសូមចំពោះទេវតាជាដើម មិនចាំបាច់និយាយថ្វីដល់ការបីបាច់រក្សាគភ៌ ទើបខ្ញុំមិនអាចនឹងសម្លាប់កូនបាន ហើយបានប្រាប់កូនថាកូនអើយ កូនឯងចូរទៅរកឪពុកចុះ ។ កូននោះកាលដើរទៅដើរមកក្នុងរវាងឪពុកម្តាយទាំងពីរយ៉ាងនេះក៏បានស្លាប់ទៅ ។

ពីរនាក់ប្តីប្រពន្ធនោះ ឃើញកូនស្លាប់ នាំគ្នាទួញយំយកសាច់កូនមកបរិភោគហើយ ចៀសចេញទៅតាមន័យដែលបានពោលទុកហើយតាំងពីដើម ។

គេទាំង២នាក់នោះ មិនបានយកសាច់បុត្របរិភោគជាអាហារដើម្បី លេងមិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់តុបតែង មិនមែនដើម្បីតាក់_តែងតែដើម្បីត្រូវការឆ្លងឱ្យផុតផ្លូវកន្តារតែម្យ៉ាងប៉ុណ្ណោះឯង ព្រោះជារបស់ បដិកូលដោយហេតុ ៩ ប្រការ ។

ប្រសិនបើនឹងសួរថា បដិកូលដោយហេតុ ៩ ប្រការនោះតើអ្វីខ្លះ ?

ឆ្លើយថា គឺព្រោះជាសាច់ដែលកើតអំពីខ្លួន ១ ព្រោះជាសាច់របស់ញាតិ ១ ព្រោះជាសាច់របស់កូន ១ ព្រោះជាសាច់របស់កូនជាទីស្រឡាញ់ ១ ព្រោះជាសាច់របស់ក្មេងខ្ចី ១ ព្រោះជាសាច់ឆៅ ១ ព្រោះជាសាច់ដែល មិនមែនសម្រាប់បរិភោគ ១ ព្រោះមិនបានដាក់អំបិល ១ ព្រោះមិនបានអាំង ១ ។

ព្រោះហេតុដូច្នោះ ភិក្ខុណាឃើញកវឡិង្ការាហារដូចជាសាច់កូន យ៉ាងនេះ លោកនឹងគ្របសង្កត ( បន្ទោបង់ ) ការជាប់ជំពាក់ក្នុងកវឡិង្ការាហារនោះបាន ។ នេះជាការប្រកបសេចក្តីក្នុងសេចក្តីឧបមាដោយសាច់បុត្តដូច្នេះឯង ។

## ការប្រៀបធៀប មេគោដែលត្រូវពន្លះស្បែក

ចំណែកក្នុងសេចក្តីប្រៀបធៀបដោយមេគោដែលពន្លះស្បែក គប្បីជ្រាបអធិប្បាយដូចតទៅនេះ មេគោនោះគេពន្លះស្បែកតាំងពីករហូតដល់ក្រចកចេញទៅហើយប្រលែងចោល វានឹងត្រូវសត្វមានជីវិតខាំនៅក្នុងទីដែលវាអាស្រ័យ ។ នឹងមានតែរឿងទុក្ខប៉ុណ្ណោះ យ៉ាងណា។ សូម្បីផស្សៈក៏ដូច្នេះដូចគ្នា អាស្រ័យ វត្ថុឬអារម្មណ៍ណាៗ ឋិតនៅនឹងមានតែរឿងទុក្ខដែលបានសោយហើយប៉ុណ្ណោះ ដែលកើតអំពីវត្ថុ និង អារម្មណ៍នោះ ៗ ។

ព្រោះដូច្នោះ ភិក្ខុណាឃើញនូវផស្សាហារថាដូចជាមេគោដែលគេពន្លះស្បែកយ៉ាងនេះ ភិក្ខុនោះនឹងគ្របសង្កត់ការជាប់ជំពាក់ក្នុងផស្សាហារនោះបាន។

នេះជាការប្រកបសេចក្ដីក្នុងការប្រៀបធៀបដោយមេគោដែល គេពន្លះស្បែក ។

## ប្រៀបធៀប រណ្ដៅរងើកភ្លើង

តែក្នុងការប្រៀបធៀបដោយរណ្ដៅរងើកភ្លើង គប្បីជ្រាបអត្ថាធិប្បាយដូចតទៅនេះ ភពទាំង ៣ ដូចរណ្ដៅរងើកភ្លើង ព្រោះអត្ថថា ក្ដៅគគុក មនោសញ្ចេតនាដូចជាបុរស ២ នាក់ ម្នាក់ៗ នាំគ្នាចាប់ដៃទាញទម្លាក់ក្នុងរណ្ដៅរងើកភ្លើងនោះ ព្រោះអត្ថថា អូសកន្ត្រាក់ចូលទៅកាន់ភពទាំងទឡាយ ។

ព្រោះដូច្នោះ ភិក្ខុណាពិចារណាឃើញមនោសញ្ចេតនាហារថា ដូចជារណ្ដៅរងើកភ្លើងយ៉ាងនេះ ភិក្ខុនោះនឹងគ្របសង្កត់ការជាប់ជំពាក់ក្នុង មនោសញ្ចេតនាហារបាន ។ នេះជាការប្រកបសេចក្ដីក្នុងការប្រៀបធៀប ដោយរណ្ដៅរងើកភ្លើង ។

## ប្រៀបធៀប ការចាក់ដោយលំពែង

ចំណែកក្នុងការប្រៀបធៀប ការត្រូវចាក់ដោយលំពែង ៣០០ លំពែង គប្បីជ្រាបអត្ថាធិប្បាយដូចតទៅនេះ ក្នុងវេលាព្រឹកបុរសម្នាក់ក្ដៅក្រហាយព្រោះលំពែង ១០០ លំពែងទាំងទឡាយណា ។ លំពែងទាំងទឡាយនោះ ចាក់រាងកាយរបស់គេឱ្យមានមុខដំបៅដល់ទៅ ១០០ កន្លែង ធ្លុះទៅមិនឈប់នៅក្នុងចន្លោះហើយក្នុងកាលតមកក៏ជ្រុះចេញទៅ ។ លំពែង ១០០ លំពែងផ្សេងៗ ទៀតក៏

យ៉ាងនោះ កាលបើដូច្នេះ ទើបឆ្អុះធ្លាយពេញរាងកាយ ព្រោះលំពែងច្រើនដែលបាញ់ចេញទៅមិនត្រូវកន្លែងដែលលំពែង១០០ ( គ្រាមុន) នោះចាក់ហើយទេ។

ទុក្ខរបស់បុរសនោះដែលកើតទឡើង ព្រោះមុខរបួសសូម្បីមុខរបួសតែមួយក៏រកប្រមាណមិនបានទៅហើយ ។ នឹងចាំបាច់ពោលទៅថ្វីដល់ទុក្ខដែលកើតទេឡើងព្រោះមុខរបួស ៣០០ កន្លែង ។

បណ្តាហេតុការណ៍ទាំងនោះ បដិសន្ធិដូចពេលដែលលំពែងធ្លាក់ត្រូវ ។ ការកើតទេឡើងនៃខន្ធដូចជាការកើតមុខរបួស

ការកើតទេឡើងនៃទុក្ខនានាដែលមាន

វដ្តៈជាមូលមានបានព្រោះខន្ធទាំងទឡាយដែលកើតហើយ ដូចជាការកើតទេឡើងនៃទុក្ខវេទនា ព្រោះមុខរបួសទាំងទឡាយ ។

ម្យ៉ាងទៀត បដិសន្ធិវិញ្ញាណដូចបុរសអ្នកប្រព្រឹត្តអាក្រក់ ។ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ ដូចមុខរបួសដែលកើតទេឡើងដល់បុរសនោះ ព្រោះត្រូវលំពែងទាំងទឡាយចាក់ហើយ ។ គប្បីឃើញការកើតទេឡើង នៃទុក្ខមានប្រការផ្សេង ៗ សម្រាប់វិញ្ញាណ ព្រោះមាននាមរូបជាបច្ច័យដោយអំណាចនៃកម្មករណ៍ ៣២ ប្រការ និង រោគ ៩៨ ប្រភេទជាដើម ដូចការកើតទេឡើងនៃទុក្ខធ្ងន់ដល់បុរសនោះ ព្រោះមានមុខរបួសជាបច្ច័យ ។

ព្រោះហេតុនោះ ភិក្ខុណាពិចារណាឃើញវិញ្ញាណាហារថា ដូចជាត្រូវ

ចាក់ដោយលំពែង ៣០០ យ៉ាងនេះ ភិក្ខុនោះគ្រប់សង្កត់ការជាប់ជំពាក់ក្នុងវិញ្ញាណាហារបាន ។ នេះជាការប្រកបសេចក្តីក្នុងការប្រៀបធៀបដោយការត្រូវចាក់ដោយលំពែង ៣០០ លំពែង ។

លោកកាលគ្របសង្កត់ការជាប់ជំពាក់ក្នុងអាហារទាំងនេះ យ៉ាងនេះថាឈ្មោះថា រមែងកំណត់ដឹងអាហារទាំង ៤ យ៉ាង ។ ក៏ការកំណត់ដឹងអាហារទាំងនោះហើយវត្ថុដែលកំណត់ដឹងសូម្បីទាំងអស់ក៏ជាការដែលកំណត់ដឹង ហើយដូចគ្នា ។

សមពិតតាមដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ កាលបើអ្នកទាំងទឡាយកំណត់ដឹងកវឡិង្ការាហារ ហើយរាគៈដែលអា-ស្រ័យបញ្ចកាមគុណ ក៏ជាការដែលកំណត់ដឹងហើយដែរ ការកំណត់ដឹងរាគៈដែលអាស្រ័យបញ្ចកាមគុណហើយនឹងមិនមានសំយោជនៈ ( កាមរាគសំយោ-ជនៈ) ដែលជាហេតុឱ្យអរិយសាវកអ្នកប្រកបហើយ មកកាន់លោកនេះទៀត ។

ម្នាលភិក្ខុទាំងទឡាយ កាលបើអ្នកកំណត់ដឹងផស្សាហារហើយ វេទនាទាំង ៣ ក៏ជាការដែលអ្នកទាំងទឡាយកំណត់ដឹងហើយដែរ ។ កាលអ្នកទាំងទឡាយកំណត់ដឹងវេទនាទាំង ៣ ហើយតថាគតពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលនឹងត្រូវធ្វើឱ្យក្រៃលែងតទៅទេឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលកំណត់ដឹងមនោសញ្ចេតនាហារហើយ តណ្ហា ៣ ក៏ជាការដែលកំណត់ដឹងហើយដែរ ។ កាលកំណត់ដឹងតណ្ហា ៣ ហើយ តថាគតពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលនឹងត្រូវធ្វើឱ្យក្រៃលែងជាងនោះទៅទៀត ។

ម្នាលភិក្ខុទាំងឡាយ កាលកំណត់ដឹងវិញ្ញាណាហារហើយ នាមរូបក៏ជាការដែលកំណត់ដឹងហើយ កាលកំណត់ដឹងនាមរូបហើយ តថាគតក៏ពោលថា អរិយសាវកនឹងមិនមានកិច្ចអ្វីដែលត្រូវធ្វើឱ្យក្រៃលែងជាងនេះទៀតទេឡើយ ។

## តណ្ហាកើត អាហារទើបកើត

បទថា តណ្ហាសមុទយា អាហារសមុទយោ មានសេចក្តី ព្រោះតណ្ហាពីអតីតៈកើតទេឡើង សមុទយៈ( ហេតុឱ្យកើត) គឺ ការកើតទេឡើងនៃអាហារទាំងទឡាយដែលមានមកអំពីបដិសន្ធិរមែងមានទេឡើង ។

មានដូចម្តេច ?

( មានយ៉ាងនេះគឺ ) ព្រោះក្នុងខណៈនៃបដិសន្ធិនឹងមានឱជាដែលកើតទេឡើងហើយ ក្នុងខាងក្នុងរូបចំនួន ៣០ ដែលកើតទេឡើងដោយអំណាចនៃសន្តតិ ៣ នេះគឺ ករទឡិង្គារាហារដែលជាឧបាទិន្នកៈ( មានចិត្តគ្រប់គ្រង) កើតទេឡើងហើយព្រោះតណ្ហាជាបច្ច័យ ។ ចំណែកផស្សាហារ មានមនោសញ្ចេតនាហារ និង

វិញ្ញាណាហារដែលជាឧបាទិន្នកៈទាំងនេះ គឺ ផស្សៈ និង ចេតនាដែលសម្បយុត្តជាមួយនឹងបដិសន្ធិចិត្ត និង វិញ្ញាណ គឺ តួចិត្តនោះឯងកើតទេឡើងហើយ ព្រោះមានតណ្ហាជាបច្ច័យ ដូច្នេះឯង ។

គប្បីជ្រាបការកើតទេឡើងនៃអាហារទាំងទឡាយដែលមានមកតាំងពីបដិសន្ធិ ព្រោះតណ្ហាកាលមុនកើតទេឡើង ដូចដែលពណ៌នាមកដូច្នេះឯង។

តែព្រោះហេតុដែលក្នុងអាហារវារៈនេះ ព្រះសារីបុត្តពោលដល់អាហារលាយគ្នា ទាំងអាហារដែលជាឧបាទិន្នកៈ ( ដែលមានចិត្តគ្រប់គ្រង ) និងដែលជាអនុបាទិន្នកៈ ( ដែលមិនមានវិញ្ញាណគ្រប់គ្រង ) ដូច្នោះ ទើបគួរជ្រាបការកើតទេឡើងនៃអាហារ ព្រោះតណ្ហាកើតទេឡើងយ៉ាងនេះ ចំណែកអាហារទាំងទឡាយដែល ជាអនុបាទិន្នកៈគប្បីដឹង ( ដូចតទៅនេះ ) ÷

ពិតណាស់ ឱជាមាននៅក្នុងរូបទាំងទឡាយ ដែលកើតទេឡើងអំពីចិត្តសហគតដោយលោភៈ ៨ ដួងនេះ គឺ កវឡិង្ការាហារដែលជាអនុបាទិន្នកៈដែលកើតទេឡើងហើយ ព្រោះតណ្ហាដែលកើតទេឡើងព្រមគ្នាជាបច្ច័យ ចំណែកផស្សៈ ១ ចេតនាដែលសម្បយុត្តជាមួយនឹងចិត្ត ដែលសហគតដោយលោភៈ ១ វិញ្ញាណគឺតួចិត្ត ១ រួមទាំង ( ៣ យ៉ាង) នេះបានដល់ផស្សាហារ មនោសញ្ចេតនាហារ និងវិញ្ញាណាហារដែលជាអនុបាទិន្នកៈកើតទេឡើងហើយ ព្រោះមានតណ្ហាជា

បច្ច័យ ដូច្នេះឯង ។

## តណ្ហារលត់ អាហារទើបរលត់

ពីរបទថា តណ្ហានិរោធា អាហារនិរោធោ សេចក្តីថា ការរលត់ទៅនៃអាហាររមែងប្រាកដ ព្រោះការរលត់ទៅនៃតណ្ហាដែលជាបច្ច័យរបស់អាហារទាំងទឡាយ ទាំងដែលជាឧបាទិន្នកៈ ទាំងដែលជាអនុបាទិន្នកៈនេះ ។

ពាក្យដ៏សេស ( ក្រៅអំពីពាក្យដែលបានអធិប្បាយនេះ ) មានន័យដូចដែលបានពោលទុកហើយនោះឯង ។

ក្នុងអាហារវារៈនេះ ព្រះសារីបុត្តបានពោលដល់សច្ចៈទាំង ៤ ទុកដោយសរុបហើយ ។ ហើយក្នុងគ្រប់វារៈក្រៅអំពីនេះ លោកក៏បានពោលទុកដូចក្នុងអាហារវារៈនេះដែរ ព្រោះហេតុនោះឯង អ្នកសិក្សាដែលមិនវង្វេងគួរលើកសច្ចៈទាំងទឡាយទេឡើងគ្រប់វារៈ ។ ហើយការប្រមូលទេសនាគ្រប់វារៈ ។ ឯត្តាវតាបិខោ អាវុសោ នេះគួរប្រកបដោយអំណាចនៃធម៌ដែលសម្តែងហើយក្នុងវារៈនោះៗ ។ នេះជាការប្រកបសេចក្តីនោះក្នុងវារៈនេះ ដូច្នេះ ។

បទថា ឯត្តាវតាបិ នេះ សេចក្តីថា ការសម្តែងអំពីអាហារនេះ មានអធិប្បាយថា សូម្បីដោយអំណាចនៃការចាក់ធ្លុះដោយមនសិការៈ ដែលពោលមកហើយ ។ សូម្បីក្នុងគ្រប់បទក៏ទំនង ( ន័យ ) នេះ ។

( ចប់កថាពណ៌នាអាហារវារៈ )

..................

## កថាពណ៌នា សច្ចវារៈ

ឥឡូវនេះ ភិក្ខុទាំងនោះ លុះត្រេកអរអនុមោទនាភាសិតរបស់ព្រះថេរៈនោះ ដោយន័យដែលបានពោលទុកហើយក្នុងកាលមុនថា សាធាវុសោ ហើយបានសួរបញ្ហាខ្ពស់ៗ តទៅទៀត ហើយព្រះថេរៈក៏បានឆ្លើយបញ្ហាដោយទំនងសូម្បីយ៉ាងដទៃដល់ភិក្ខុទាំងនោះ ។ ក្នុងគ្រប់វារៈ សូម្បីក្រៅអំពីវារៈនេះក៏មានន័យនេះ ។

ព្រោះដូច្នោះ តអំពីនេះទៅខ្ញុំម្ចាស់នឹងពង្រីកសេចក្ដីនៃចម្លើយដែលព្រះថេរៈបានឆ្លើយទុកហើយ មិនទាក់ទងដល់ពាក្យបែបនេះ ។ តែដោយការសម្ដែងដោយសង្ខេបនូវវារៈនេះ ព្រះថេរៈបានសម្ដែងទុក្ខសច្ចទុកថា ពាក្យថា ទុក្ខញ្ច ជាតិ ។ ចំណែកក្នុងការសម្ដែងដោយពិស្ដារ ពាក្យដែលនឹងត្រូវពោលទាំងអស់បានពោលទុកហើយក្នុងសច្ចនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

( ចប់កថាពណ៌នាសច្ចវារៈ )

..................

## កថាពណ៌នា ជរាមរណវារៈ

តអំពីនេះទៅ ជាទេសនាពោលដោយបដិច្ចសមុប្បាទ ។

ក្នុងចំនួនវារៈទាំងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងជរាមរណវារៈថា

បទថា តេសំ តេសំ នេះ ជាការសម្តែងទូទៅដល់សត្វចំនួនច្រើនទុកដោយសង្ខេប ។ ព្រោះថា ការសម្តែងអស់មួយថ្ងៃយ៉ាងនេះថា ការចាស់របស់ព្រះទេវទត្ត ការចាស់របស់សោមទត្ត ដូច្នេះ សត្វទាំងទឡាយនឹងមិនត្រូវជរាមរណៈគ្របដណ្តប់ ( ជរាមរណៈនឹងមិនគ្របដណ្តប់ដល់សត្វទាំងអស់មិនមាន ) ។ តែដោយបទទាំងពីរនេះ ( តេសំ តេសំ ) សត្វណាមួយនឹងមិនត្រូវជរាមរណៈគ្របដណ្តប់មិនមាន ( ជរាមរណៈគ្របដណ្តប់សត្វគ្រប់ប្រភេទ ) ។ ព្រោះដូច្នោះខ្ញុំម្ចាស់ទើបពោលទុកថា បទនេះ ជាការសម្តែងទូទៅដល់សត្វចំនួនច្រើនទុកដោយសង្ខេប ។

បទទាំង ២ ថា តម្ហិ តម្ហិ នេះ ជាការសម្តែងទូទៅដល់ពួកសត្វចំនួនច្រើនដោយអំណាចនៃការកើតក្នុងគតិ ។

បទថា សត្តនិកាយេ ជាការសម្តែងសរុបដល់សត្វដែលបានសម្តែងទុកហើយដោយសាធារណនិទ្ទេស ។

ក៏បទថា ជរា ក្នុងពាក្យទាំងទឡាយមានអាទិថា ជរា ជីរណតា

ជាការសម្តែងដល់សភាវធម៌ ។

បទថា ជីរណតា ជាការសម្តែងដល់អាការ ។

បទទាំងទឡាយមាន ខណ្ឌិច្ចំ ជាដើម ជាការសម្តែងដល់នាទី(របស់ ជរា ) ព្រោះកន្លងកាលវេលាទៅ ។

ពីរបទក្រោយជាការសម្តែងដល់ ( នាទី ) តាមប្រក្រតី ព្រោះថាជរានេះ ព្រះសារីបុត្តសម្តែងទុកដោយសភាវៈ ដោយបទថា ជរា ព្រោះដូច្នោះ បទនេះ ទើបជាបទសម្តែងដល់សភាវៈរបស់ជរានោះ ។

ដោយបទថា ជីរណតា នេះ ព្រះថេរបានសម្តែងទុកដោយអាការៈ ។ ព្រោះដូច្នោះ បទនេះទើបជាបទ សម្តែងដល់អាការរបស់ជរានោះ ។

ដោយបទថា ខណ្ឌិច្ចំ នេះ ព្រះថេរបានសម្តែងដោយកិច្ចគឺការធ្វើភាវៈ នៃធ្មេញ និង ក្រចក ឱ្យបាក់ជាកំណាត់ៗ ព្រោះកន្លងកាលវេលាទៅ ។

ដោយបទថា បាលិច្ចំ នេះ ព្រះថេរៈបានសម្តែងដោយកិច្ចគឺការធ្វើភាវៈ នៃសក់ និង រោមឱ្យស្កូវ ។ ដោយបទថា វលិតតចតា នេះ ព្រះថេរៈបាន សម្តែងសូម្បីដោយកិច្ចគឺការធ្វើឱ្យសាច់ស្បែកយុរយា។ដោយហេតុនោះស័ព្ទ ទាំង ៣ មាន ខណ្ឌិច្ចំ ជាដើមនេះ ទើបជាស័ព្ទសម្តែងដល់កិច្ចរបស់ជរានោះ ព្រោះកន្លងកាលវេលាទៅ ដោយស័ព្ទទាំង ៣ នោះ ព្រះថេរៈបានសម្តែងដល់ជរា

ដែលប្រាកដ គឺ ជាវត្ថុដែលប្រាកដដោយអំណាចឃើញភាព ពិការទាំងនេះ បាន ។

ឧបមាដូចថា ផ្លូវដើរនៃទឹកប្រាកដ ( ឱ្យឃើញបាន ) ព្រោះបក់ស្មៅ និង ដើមឈើជាដើមឱ្យរលំរាប ឬផ្លូវដើររបស់ភ្លើងប្រាកដ ( ឱ្យឃើញបាន ) ព្រោះស្មៅ និង ដើមឈើជាដើមឆេះ ។ ហើយផ្លូវដើរ ( របស់ទឹកជាដើម ) ក៏មិនមែនទឹកជាដើមនោះទេឡើយ ។ ( ម្យ៉ាងម្នាក់ ) យ៉ាងណា ។ ផ្លូវដើររបស់ជរាក៏ដូច្នោះដូចគ្នា ជាធម្មជាតិប្រាកដ ( ឱ្យឃើញ ) ក្នុងអវយវៈទាំងទឡាយមានធ្មេញជាដើម ដោយអំណាចនៃភាពពិការទាំងទឡាយ មានការបាក់ធ្មេញជាដើម មនុស្សសូម្បីបើកភ្នែកមើលហើយក៏ចាប់ពាល់បាន ។ ហើយផ្លូវដើររបស់ជរា នោះ ដោយអំណាចនៃភាពពិការទាំងទឡាយ មានការបាក់ជាដើម ក៏មិនមែន ជរា ។ ព្រោះជរាជាធម្មជាតិមិនអាចដឹងបានដោយចក្ខុទេឡើយ ។ ( ត្រូវដឹងបាន ដោយបញ្ញា ) ។

តែដោយបទទាំងនេះថា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ ព្រះថេរបានសម្តែងជរាតាមប្រក្រតី ព្រោះការអស់ទៅនៃអាយុ ជារបស់ដែលដឹងបានអំពីការចាស់នៃឥន្ទ្រីយ៍ មានចក្ខុជាដើម ព្រោះការឈានកន្លងកាលវេលាប៉ុណ្ណោះ ព្រោះហេតុដែលលោកជាអ្នកឆ្លាតក្រៃលែង ។

ព្រោះដូច្នោះ អាការៈ២ ខាងក្រោយនេះ គប្បីជ្រាបថា ជាការសម្ដែង ( អាការៈ) តាមប្រក្រតីរបស់ជរានោះ ។

បណ្ដាអាយុ និង ឥន្ទ្រីយ៍ទាំង ២ យ៉ាងនោះ ព្រោះហេតុដែលអាយុរបស់អ្នកដល់ការចាស់ រមែងអស់ទៅ ( ច្រើនទេឡើង ) ដូច្នោះ ទើបលោកបានពោលជរាទុកដោយជិតចំពោះផល ( ជិតចំពោះសេចក្ដីស្ងប់ ) ថា បានដល់ ការអស់ទៅនៃអាយុ អាយុច្រើន ។

តែព្រោះហេតុដែលកាលនៅកម្លោះ ឥន្ទ្រីយ៍ទាំងទឡាយមានភ្នែកជាដើមនៅស្រស់ថ្លាអាចទទួលយកអារម្មណ៍ ( មានរូបជាដើម ) របស់ខ្លួនសូម្បីដ៏ល្អិតបានដោយងាយ កាលចូលដល់ជរាហើយ និង ចាស់ ស្រវាំង ស្រអាប់ មិនស្រស់ថ្លា អារម្មណ៍របស់ខ្លួនសូម្បីជារបស់គ្រោតគ្រាតក៏មិនអាចនឹងទទួលបាន ដូច្នោះ ជរា ទើបព្រះថេរៈលោកពោលទុកដោយការជិតចំពោះផលថា ការចាស់នៃឥន្ទ្រីយ៍ទាំងទឡាយខ្លះ ។

## ជរា ២ យ៉ាង

ម្យ៉ាងទៀត ជរានេះនោះ គឺជរាទាំងអស់ដែលសម្ដែងមកហើយ យ៉ាង នេះមាន ២ យ៉ាងគឺ បាកដជរា ( ការចាស់ដែលប្រាកដ )១ ។ បដិច្ឆន្ន- ជរា ( ការចាស់ដែលមិនប្រាកដ ) ១ ។ ក្នុងចំនួនជរាទាំង ២ យ៉ាងនោះ

ការដែលរូបធម៌ទាំងទឡាយចាស់ ឈ្មោះថា បាកដជរា ព្រោះសម្ដែងភាពវិការៈ មានការបាក់ជាដើម ក្នុងអវយវៈទាំងទឡាយ មានធ្មេញជាដើមឱ្យឃើញ ចំណែកក្នុងអរូបធម៌ ឈ្មោះថា បដិច្ឆន្នជរា ព្រោះមិនសម្ដែងអាការវិការដូច្នោះឱ្យឃើញ ។

មានជរា ២ យ៉ាងដទៃទៀត យ៉ាងនេះគឺ អវីចិជរា (ជរាមិនមានស្នាមឱ្យឃើញ) ១ សវីចិជរា (មានស្នាមឱ្យឃើញ) ១ ក្នុងចំនួនជរា ២ យ៉ាង នោះ ជរារបស់កែវមណី មាស ប្រាក់ កែវប្រវាទឡ ព្រះច័ន្ទ និង ព្រះអាទិត្យ ជាដើម គប្បីជ្រាបថា ឈ្មោះថា អវីចិជរា អធិប្បាយថា ឈ្មោះថា ជរា មិនមានស្នាមរវាងចន្លោះ (មិនមានស្នាមប្រាកដឱ្យឃើញ) ព្រោះការបែកធ្លាយរបស់ពណ៌ជាដើមក្នុងចន្លោះៗ ដឹងបានដោយលំបាក ដូចការបែកធ្លាយនៃពណ៌ជាដើម ក្នុងចន្លោះៗ របស់សត្វមានអាយុក្នុងវ័យមន្ទទសកៈ (វ័យ១០ឆ្នាំ) ជាដើម និងដូចការបែកធ្លាយនៃពណ៌ជាដើម ក្នុងចន្លោះៗ នៃវត្ថុដែលមិនមានវិញ្ញាណក្នុងដើមឈើ ផ្លែឈើ និង ស្លឹកឈើជាដើម ។ តែជរាក្នុងវត្ថុដទៃក្រៅអំពីនោះតាមដែលពោលមកហើយ ឈ្មោះថា សវីចិជរា ព្រោះការបែកធ្លាយនៃពណ៌ជាដើមក្នុងចន្លោះៗ ជាវត្ថុដែលគប្បីដឹងបានងាយ ។

តអំពីនេះទៅ បទថា តេសំ តេសំ ជាដើម គប្បីជ្រាបដោយន័យ

ដែលបានពោលមកហើយនោះឯង ។

ក៏បទថា ចុតិ ក្នុងពាក្យទាំងទឡាយមានជាអាទិថា ចុតិ ចវនតា ជាដើម ព្រះថេរៈពោលទុកដោយអំណាចនៃសត្វអ្នកឃ្លាតទៅ ។

ពាក្យថា ចុតិ នេះ ជាពាក្យទូទៅសម្រាប់ខន្ធ ១ ខន្ធ ៤ និង ខន្ធ ៥ ។

ពាក្យថា ចវនតា ជាពាក្យសម្ដែងដល់លក្ខណៈ ( របស់ខន្ធ ) ដោយការឃ្លាតចាកភាវៈ ។

ពាក្យថា ភេទោ ជាពាក្យសម្ដែងដល់ការបែកធ្លាយ និង ការកើតទេឡើងនៃខន្ធទាំងទឡាយដែលចុតិ ។

ពាក្យថា អន្តរធានំ ជាពាក្យសម្ដែងដល់ភាវៈនៃការឃ្លាតចាកអំពីទីឋានដោយបរិយាយណាមួយ នៃចុតិខន្ធទាំងទឡាយដែលបែកធ្លាយទៅ ដូចក្អមដែលបែកហើយដូច្នោះ ។ ការស្លាប់ពោលគឺ មច្ចុ ឈ្មោះថា មច្ចុមរណៈ ។

ដោយស័ព្ទថា មច្ចុមរណំ នោះ ព្រះថេរៈបដិសេធសមុច្ឆេទមរណៈជាដើម ( ការស្លាប់ដោយការកាត់ផ្ដាច់នូវជាតិជាដើម ) ។ មច្ចុរាជអ្នកធ្វើនូវទីបំផុត ( ទីបញ្ចប់ ) ឈ្មោះថា កាលៈ ការធ្វើកាលៈនោះ ឈ្មោះថា កាលកិរិយា ( ការដល់ការចាស់កម្ម ) ។ ដោយស័ព្ទថា កាលកិរិយា ដោយពាក្យថា កាល_កិរិយានេះ ព្រះថេរៈសម្ដែងដល់ការស្លាប់តាមសម្មតិរបស់សត្វលោក ។ តទៅនេះ

ដើម្បីនឹងសម្ដែងដល់សេចក្ដីស្លាប់ដោយបរមត្ថ ព្រះអង្គ ទើបបានពោលពាក្យមានជាអាទិថា ខន្ធានំ ភេទោ ទុក ។

ពិតណាស់ ដោយបរមត្ថ ខន្ធទាំងទឡាយប៉ុណ្ណោះបែកធ្លាយ មិនមែនសត្វណាៗស្លាប់ទេឡើយ កាលខន្ធទាំងទឡាយកំពុងបែកធ្លាយ សត្វក៏ឈ្មោះថាកំពុងស្លាប់ កាលបែកធ្លាយហើយ ក៏មានវោហារថា សត្វស្លាប់ហើយ ។

ក្នុងជរាមរណវារៈនេះ ការបែកធ្លាយនៃខន្ធទាំងទឡាយ មានបានដោយចតុវោការភព ( នាមខន្ធ ៤ ) ការដាក់ចុះសាកសព មានបានដោយឯកវោ-ការភព ( រូបខន្ធ ១ ) ឬការបែកធ្លាយនៃខន្ធទាំងទឡាយ គប្បីជ្រាបដោយចតុ-វោការភព ( ចំណែក ) ការដាក់ចុះនូវសាកសព គប្បីជ្រាបដោយអំណាចនៃភពទាំង ២ ដ៏សេស ( ឯកវោការភព និង បញ្ចវោការភព ) ។

ព្រោះហេតុអ្វី ?

ព្រោះសាកសពពោលគឺរូបកាយកើតទេឡើងចំពោះក្នុងភព ២ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលខន្ធទាំងទឡាយក្នុងទេវលោក និង ព្រហ្ម-លោក មានចាតុម្មហារាជិកាជាដើម បែកធ្លាយទៅតែម្យ៉ាង មិនមានបោះបង់អ្វី ទុក ដូច្នេះ ការបែកធ្លាយនៃខន្ធទាំងទឡាយ គប្បីជ្រាបដោយអំណាចនៃខន្ធទាំង-ទឡាយក្នុងទេវលោក និង ព្រហ្មលោក មានចាតុម្មហារាជិកាជាដើមទាំងនោះ ។

( ចំណែក ) ការដាក់ចុះនូវសាកសព មាននៅក្នុងសត្វទាំងឡាយមានមនុស្សជាដើម ។ ការស្លាប់ដោយការដាក់ចុះនូវសាកសព ព្រះថេរៈពោលថា ការដាក់ចុះនូវសាកសព ។ គប្បីជ្រាបអត្ថាធិប្បាយយ៉ាងនេះថា ទាំងជរាទាំងមរណៈ នេះគប្បីជ្រាបដូចដែលពណ៌នាមកនេះ ។ សេចក្តីថា ឥទំ វុច្ចតាវុសោ សេចក្តីថា ជរា និង មរណៈទាំង ២ យ៉ាងនេះ ព្រះថេរៈពោលរួមគ្នាថា ជរា_មរណៈ ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះឯង។

( ចប់ កថាពណ៌នាជរាមរណវារៈ )

.......................

## កថាពណ៌នា ជាតិវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យទាំងឡាយមានអាទិ ជាតិ សញ្ជាតិ ក្នុងជាតិវារៈ ( ដូចតទៅនេះ ) ÷

ដែលឈ្មោះថា ជាតិ ព្រោះអត្ថថា ( ផ្ដើម ) កើត ។ ជាតិនោះប្រកបហើយដោយអំណាចនៃអាយតនៈមិនទាន់បរិបូណ៌ ។

ដែលឈ្មោះថា សញ្ជាតិ ព្រោះអត្ថថា កើតគ្រប់ហើយ ។ សញ្ជាតិនោះប្រកបគ្រប់ហើយ ដោយអំណាចនៃអាយតនៈបរិបូណ៌ហើយ ។

ដែលឈ្មោះថា ឱក្កន្តិ ព្រោះអត្ថថា ឈានចុះ ( កាន់គភ៌ ) ។ ឱក្កន្តិនោះប្រកបដោយអណ្ឌជកំណើត ( កើតក្នុងស៊ុត ) និង ជលាពុជកំណើត ( កើតជា គភ៌ ) ។ អធិប្បាយថា សត្វទាំងនោះឈានចុះ គឺចាប់បដិសន្ធិដូចការឈានចូលទៅកាន់កន្ទ្រោមពង និង ស្បូន ។

ដែលឈ្មោះថា អភិនិព្វត្តិ ព្រោះអត្ថថា កើតដោយការផុសទេឡើងថា អភិនិព្វត្តិនោះប្រកបដោយសំសេទជកំណើត ( កើតក្នុងញើសក្អែល ) និង ឱប-បាតិកកំណើត ( កើតដោយការផុសទេឡើង ) អធិប្បាយថា សត្វទាំងនោះកើតប្រាកដទេឡើងតែម្ដង ។ នេះជាទេសនាតាមវោហារ តទៅនេះ ទើបជាទេសនាដោយបរមត្ថ អធិប្បាយថា ពោលដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះឯង

ប្រាកដទេឡើង មិនមែនសត្វប្រាកដ ។

បណ្ដាបទទាំងនោះ បទថា ខន្ធានំ គប្បីជ្រាបថា សម្ដៅយកខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព និង ខន្ធ ៥ ខ្លះ ក្នុងបញ្ច_ វោការភព ។

ការឧប្បត្តិ ឈ្មោះថា បាតុភាវោ ។ គប្បីជ្រាបការសង្គ្រោះដោយអាយតនៈ ដែលកំពុងកើតទេឡើងក្នុងភពនោះៗ ចូលក្នុងពាក្យថា អាយត_ នានំ នេះ ។

ការប្រាកដទេឡើងក្នុងសន្ដតិនោះឯង ឈ្មោះថា បដិលាភោ អធិប្បាយថា អាយតនៈទាំងនោះ ដែលប្រាកដនោះឯង រមែងឈ្មោះថា ជាការដែលសត្វទាំងទឡាយត្រទឡប់បានហើយ ។

ដោយបទនេះថា អយំ វុច្ចតាវុសោ ជាតិ ព្រះថេរៈពោលបញ្ចាក់ដល់ជាតិដែលបានសម្ដែងមកហើយ ទាំងដោយវោហារ ទាំងដោយបរមត្ថដូច្នេះឯង ។

ក៏អ្នកសិក្សាគប្បីជ្រាបកម្មភព ដែលជាបច្ច័យនៃជាតិ ក្នុងពាក្យថា ភវសមុទយា នេះ ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាជាតិវារៈ )

..................

## កថាពណ៌នា ភវវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងភវវារៈដូចតទៅនេះ ÷

កម្មភព និង ឧបបត្តិភព ឈ្មោះថា កាមភព ។ បណ្តាភពទាំង ២ យ៉ាងនោះ កម្មដែលជាហេតុឱ្យចូលដល់កាមភពនោះឯង ឈ្មោះថា កម្មភព ។

អធិប្បាយថា កម្មនោះឯងលោកពោលថា ភពដោយការពោលដល់ ផល ដូចពាក្យទាំងទឡាយមានជាអាទិថា ការឧប្បត្តិទេឡីងនៃព្រះពុទ្ធជាម្ចាស់ ជាហេតុនាំមកនូវសេចក្តីសុខ ការសន្សំបាបជាហេតុមកនូវទុក្ខដូច្នេះ ព្រោះកម្មភពនោះជាហេតុនៃឧបបត្តិភព ។ ខន្ធបញ្ចកៈដែលតណ្ហា និង ទិដ្ឋិចាប់យកហើយកើតទេឡីងហើយដោយកម្មនោះ ឈ្មោះថា ឧបបត្តិភព ។ ព្រោះថាខន្ធបញ្ចកៈនោះ លោកពោលថាភព ព្រោះមានវិគ្រោះថា ជាទីកើត (នៃបដិសន្ធិ- ចិត្ត) ។

កាលបើយ៉ាងនេះ ទាំង ២ យ៉ាងនេះ គឺ កម្មភពនេះ ១ ឧបបត្តិភព ១ លោកពោលថា ជាកាមភពសូម្បីដោយប្រការទាំងពួង ។ ក្នុងរូបភព និង អរូបភពក៏ទំនងនេះ ។ តែឧបាទានក្នុងពាក្យនេះថា ឧបាទានសមុទយា នេះ ជាបច្ច័យរបស់កម្មភពដែលជាកុសល ។ ដោយឧបនិស្សយប្បច្ច័យនោះឯង ។ ឧបាទានជាបច្ច័យរបស់កម្មភព ដែលជាអកុសល ដោយឧបនិស្សយប្បច្ច័យខ្លះ

ដោយសហជាតប្បច្ច័យជាដើមខ្លះ តែជាបច្ច័យរបស់ឧបបត្តិភព របស់កម្មភពទាំងដែលជាកុសល និង អកុសលទាំងអស់ដោយឧបនិស្សយប្បច្ច័យ ។ ពាក្យដ៏សេសមានន័យដូចដែលមកហើយនោះឯង ដូច្នេះ ។

( ចប់ កថាពណ៌នាភវវារៈ )

..................

## កថាពណ៌នា ឧបាទានវារៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យទាំងទឡាយ មានជាអាទិថា កាមុបាទានំ ក្នុងឧបាទានវារៈ ។

កិលេសជាតិ ឈ្មោះថា កាមុបាទាន ព្រោះវិគ្រោះថា ជាហេតុប្រកាន់មាំក្នុងវត្ថុកាម ឬ ព្រោះប្រកាន់វត្ថុកាមនោះឯង ។ ម្យ៉ាងទៀត កាមនោះផង ជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា កាមុបាទាន ។

ការប្រកាន់មាំនូវលោកហៅថា ឧបាទាន ។ ព្រោះថា ឧប ស័ព្ទក្នុងពាក្យថា ឧបាទានំ នេះមានសេចក្តីថា មាំដូច ឧប ស័ព្ទ ក្នុងពាក្យទាំងទឡាយ មានជាអាទិថា ឧបាយាស និង ឧបកដ្ឋ ។

ពាក្យថា កាមុបាទាន នេះ ជាឈ្មោះរបស់រាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ។ នេះជាសេចក្តីសង្ខេបក្នុងកាមុបាទាននេះ ។

តែពោលដោយពិស្តារកាមុបាទាននេះ គប្បីជ្រាបដោយន័យដែលបានត្រាស់ទុកហើយថា បណ្តាឧបាទានទាំងនោះ កាមុបាទាន តើដូចម្តេច? បាន ដល់សេចក្តីពេញចិត្ត ដោយអំណាចការជាប់ជំពាក់ក្នុងកាមទាំងទឡាយ ។

ទិដ្ឋុបាទាន ក៏យ៉ាងនោះ គឺ ទិដ្ឋិនោះផង ជាឧបាទានផង ព្រោះដូច្នោះ ទើបឈ្មោះថា ទិដ្ឋុបាទាន ។ ម្យ៉ាងទៀត កិលេសជាតិ ឈ្មោះថា ទិដ្ឋុបាទាន ។

ព្រោះប្រកាន់មាំនូវទិដ្ឋិ ។ ឬឈ្មោះថា ទិដ្ឋុបាទាន ព្រោះមាន វិគ្រោះថា ជាហេតុឱ្យប្រកាន់មាំនូវទិដ្ឋិ ។ អធិប្បាយថា កិលេសជាតិណារមែងប្រកាន់មាំនូវទិដ្ឋិខាងដើមក្នុងពាក្យទាំងទឡាយមានជាអាទីថា ទាំងអត្តា ( អាត្មន ) ទាំងលោកជារបស់ទៀង ព្រោះដូច្នោះ កិលេសជាតិនោះ ទើបឈ្មោះថាយ៉ាងនោះ ( ទិដ្ឋុបាទាន ) ។ ដែលដូចត្រាស់ទុកមានជាអាទិថា ទាំងអត្តា ( អាត្មាន ) ទាំងលោកជារបស់ទៀង វត្ថុនេះប៉ុណ្ណោះជាសត្យ ( របស់ពិត ) ដទៃជាមោឃៈ ( ឥតប្រយោជន៍ ) ។ ពាក្យថា ទិដ្ឋុបាទាននេះជាឈ្មោះរបស់ទិដ្ឋិទាំងអស់វៀរតែសីលសព្វត្តុបាទាន និង អត្តវាទុបាទាន ។ នេះជាសេចក្ដីសង្ខេបក្នុងទិដ្ឋុ-បាទាននេះ ។ តែដោយពិស្ដារទិដ្ឋុបាទាននេះ គប្បីជ្រាបដោយន័យដែលបានត្រាស់ទុកហើយនោះឯងថា បណ្ដាឧបាទានទាំងនោះ ទិដ្ឋុបាទានតើដូចម្ដេច ? ( ទិដ្ឋុបាទានគឺ ) ទានដែលបុគ្គលឱ្យហើយ មិនមានផល ។

បណ្ដាឧបាទានទាំងនោះ ឈ្មោះថា សីលព្វត្តុបាទាន ព្រោះជាហេតុប្រ-កាន់មាំនូវសីល និង វត្តខ្លះ ព្រោះសីល និង វត្តនោះ ប្រកាន់មាំដោយខ្លួនឯងខ្លះ ព្រោះសីល និង វត្តនោះផង ជាឧបាទានផង ខ្លះ ។

អធិប្បាយថា ការប្រកាន់មាំដោយខ្លួនឯងនោះឯង ដោយការជឿមាំថា សីល និង វត្តទាំងទឡាយមានសីលរបស់គោ និង វត្តរបស់គោជាដើម ជា

របស់បរិសុទ្ធដោយអាការយ៉ាងនេះ ព្រោះដូចោះ ទើបឈ្មោះថាយ៉ាងនោះ ( សីលព្វត្តុបាទាន ) ។ នេះ សេចក្តីសង្ខេបក្នុងសីលព្វត្តុបាទាននេះ ។

តែដោយពិស្តារសីលព្វត្តុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកហើយថា បណ្តាឧបាទានទាំងនោះ សីលព្វត្តុបាទានតើដូចម្តេច ? គឺសេចក្តីបរិសុទ្ធដោយសីលរបស់សមណព្រាហ្មណ៍ទាំងទឡាយជាខាងក្រៅសាសនានេះ ។ ឈ្មោះថា វាទៈ ព្រោះជាហេតុពោលក្នុងឥទឡូវនេះ ។ ដែលឈ្មោះថា ឧបាទាន ព្រោះជាហេតុឱ្យប្រកាន់មាំ ។

សួរថា ពោល ឬ ប្រកាន់មាំនូវអ្វី ?

ឆ្លើយថា ពោល ឬ ប្រកានមាំនូវអត្តា ( អាត្ម័ន ) ។

ការប្រកាន់មាំនូវវាទៈរបស់ខ្លួន ឈ្មោះថា អត្តវាទុបាទាន ។ ម្យ៉ាងទៀត ឈ្មោះថាអត្តវាទុបាទាន ព្រោះជាហេតុប្រកាន់មាំត្រឹមតែវាទៈរបស់ខ្លួនប៉ុណ្ណោះថាជាអាត្មា ( អាត្ម័ន ) ។ ពាក្យថាអត្តវាទុបាទាន នេះជាឈ្មោះរបស់សក្កាយ_ទិដ្ឋិដែលមានវត្ថុ ២០ ។ នេះជាសេចក្តីសង្ខេបអត្តវាទុបាទាននេះ ។

ចំណែកដោយពិស្តារអត្តវាទុបាទាននេះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកហើយថា បណ្តាឧបាទានទាំងនេះ អត្តវាទុបាទានតើដូចម្តេច ? អត្ត_វាទុបាទាន គឺ បុថុជ្ជនក្នុងព្រះសាសនានេះ មិនបានស្តាប់ មិនឃើញព្រះ_

អរិយៈជាម្ចាស់ទាំងឡាយដូច្នេះ ។

តណ្ហាក្នុងពាក្យថា តណ្ហាសមុទយា នេះជាបច្ច័យរបស់កាមុបាទាន ដោយឧបនិស្សយបច្ច័យ ឬ ដោយអនន្តរបច្ច័យ សមនន្តរបច្ច័យ នត្ថិបច្ច័យ និង អសេវនបច្ច័យ តែជាបច្ច័យរបស់ឧបាទានដ៏សេស គឺសូម្បីដោយសហ-ជាតបច្ច័យជាដើមខ្លះ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ដូច្នេះ។

( ចប់ កថាពណ៌នាឧបាទានវារៈ )

......................

## កថាពណ៌នា តណ្ហាវារៈ

តណ្ហា ១០៨

គប្បីជ្រាបវិនិច្ឆ័យក្នុងតណ្ហាវារៈ ( តទៅ ) ÷

តណ្ហាដែលប្រព្រឹត្តទៅហើយដោយជវនវិថី មានឈ្មោះតាមអារម្មណ៍ដែលស្រដៀងនឹងបិតា ( អ្នកឱ្យកំណើត ) ថារូបតណ្ហា ។ល។ ធម្មតណ្ហាដូច ( មនុស្ស) មានឈ្មោះតាមបិតាក្នុងពាក្យទាំងទឡ្បាយ មានជាអាទិថា សេដ្ឋី- បុត្រ ព្រាហ្មណបុត្រ ជាដើម ។

ក៏ក្នុងតណ្ហាវារៈនេះ តណ្ហាមាន ៣ ប្រការ យ៉ាងនេះ គឺ តណ្ហាដែលមានរូបជាអារម្មណ៍ គឺ តណ្ហាក្នុងរូប ព្រោះដូច្នោះ ទើបឈ្មោះថារូបតណ្ហា រូបតណ្ហានោះការត្រេកអរប្រព្រឹត្តទៅដោយភាពជាកាមរាគៈឈ្មោះថាកាម-តណ្ហា ។

ការត្រេកអរនឹង ( រូប ) ប្រព្រឹត្តទៅយ៉ាងនេះថា រូបទៀង គឺ ឋិតថេរ បានដល់ ជាប់តគ្នាទៅមិនដាច់ដោយភាពជារាគៈ ដែលកើតរួមជាមួយនឹង សស្សតទិដ្ឋិ ឈ្មោះថា ភវតណ្ហា ។

ការត្រេកអរនឹង ( រូប ) ប្រព្រឹត្តទៅយ៉ាងនេះថា រូបដាច់សូន្យ គឺ បាត់ទៅ បានដល់ លះលោកនេះទៅហើយ នឹងមិនមានដោយភាពជារាគៈ

កើតរួមនឹងឧច្ឆេទទិដ្ឋិ ឈ្មោះថា វិភវតណ្ហា ។ ហើយសទ្ទតណ្ហាជាដើម ក៏ដូច រូបតណ្ហា ដូច្នោះ ទើបរួមជាតណ្ហាវិចរិត ១៨ ប្រការ ។ តណ្ហាវិចរិតទាំងនោះ ចែកចេញជា ១៨ ក្នុងអាយតនៈទាំងទឡាយ មានរូបខាងក្នុងជាដើម ( នឹង) ចែក ចេញជា ១៨ ក្នុងអាយតនៈទាំងទឡាយមានរូបខាងក្រៅជាដើម ទើបរួមជា ៣៦ ប្រការចែកជាអតីតៈ ៣៦ ជាអនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការយ៉ាង នេះ ១០៨ ប្រការ ។

ម្យ៉ាងទៀត តណ្ហាវិចរិត ១៨ ប្រការ អាស្រ័យរូបដែលប្រព្រឹត្តទៅ ខាងក្នុង ជាដើម មានជាអាទិយ៉ាងនេះថា ព្រោះអាស្រ័យរូបខាងក្នុង មាន តណ្ហាថា យើងមានព្រោះរូបនេះ ( ហើយ ) ថា កាលយើងមាន យើងក៏ជា ទីប្រាថ្នា ដូច្នោះ ទើបរួមជាតណ្ហា ៣៦ បែងជាអតីតៈ ៣៦ អនាគត ៣៦ បច្ចុប្បន្ន ៣៦ ដោយប្រការយ៉ាងនេះ រួមជាតណ្ហាវិចរិត ១០៨ ដូចដែល ពណ៌នាមកនេះឯង ។

កាលធ្វើការសង្គ្រោះចូលគ្នាទៀត តណ្ហាក៏មាន ៦ ពួក ប៉ុណ្ណោះក្នុង អារម្មណ៍ទាំងទឡាយមានរូបជាដើម ដោយអត្ថដែលលោកសម្តែងទុកយ៉ាងនេះថា តណ្ហាមាន ៣ យ៉ាងប៉ុណ្ណោះ មានកាមតណ្ហាជាដើម អ្នកប្រាជ្ញគប្បីជ្រាបតណ្ហា ដោយការសង្គ្រោះសេចក្តីដែលពិស្តារ ចូលជាមួយគ្នាទៀត អំពីសេចក្តីពិស្តារ

ដែលសម្តែងទុហើយ ដូច្នេះ ។

ក៏វេទនាដែលជាវិបាកព្រះថេរៈប្រាថ្នាយកហើយថា វេទនា ក្នុងពាក្យថា វេទនា សមុទយា នេះ ។ បើនឹងមានពាក្យសួរថា វេទនានោះជាបច្ច័យនៃតណ្ហាក្នុងទ្វារ ៦ ដូចម្តេច ?

ឆ្លើយថា ជាបច្ច័យព្រោះវេទនា ជាវត្ថុដែលគួរត្រេកអរ ។ អធិប្បាយថា កាលសត្វទាំងឡាយប្រកាន់វេទនាថាជារបស់យើង ។ ដោយការពេញចិត្តសុខ-វេទនា គេនឹងជាអ្នកញុាំងសេចក្តីប្រាថ្នាក្នុងវេទនាឱ្យកើតទេឡើងហើយ ត្រេកអរហើយដោយការត្រេកអរចំពោះវេទនា ប្រាថ្នារូបដែលបានឃើញហើយនោះឯងលុះបានរូបនោះហើយ ក៏ពេញចិត្ត ទាំងធ្វើសក្ការៈដល់ជាងគំនូរជាដើម អ្នកឱ្យអារម្មណ៍ ។

ក្នុងសោតទ្វាជាដើមក៏ដូចគ្នា សត្វទាំងទឡាយរមែងប្រាថ្នាសម្លេងជាដើមដែលជាទីគួរប្រាថ្នា លុះបានហើយក៏ពេញចិត្តនឹងសម្លេងជាដើមទាំងនោះ ទាំងធ្វើការសក្ការៈ អ្នកដេញពិណ ជាងផ្សំទឹកក្រអូប ជាងត្បាញ និង អ្នកសម្តែងសិល្បៈនានា ជាដើម ។

ដូចអ្វី ?

ដូចម្តាយដែលស្រឡាញ់កូន ធ្វើសក្ការៈដល់មេនំ គឺ ឱ្យគេផឹក និង បរិ-

ភោគទឹកដោះថ្លានិងទឹករដោះដ៏ឆ្ងាញ់ជាដើម ព្រោះសេចក្តីស្នេហាចំពោះ កូន , ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។

( ចប់ កថាពណ៌នាតណ្ហាវារៈ )

.......................

## កថាពណ៌នា វេទនាវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងវេទនាវារៈ ( តទៅ ) ÷

ពួកវេទនា ឈ្មោះថា វេទនាកាយៈ ។

ពាក្យថា ចក្ខុសម្ផស្សជាវេទនា ។បេ។ មនោសម្ផស្សជា_ វេទនា នេះ ជាឈ្មោះរបស់វេទនាទាំងដែលជាកុសលទាំងជាអកុសល និង អព្យាកតៈ ដែលប្រព្រឹត្តទៅហើយក្នុងចក្ខុទ្វារជាដើមតាមវត្ថុ ( ទីតាំង ) ដែល ស្រដៀងម៉ែ ដូចជាឈ្មោះ ( របស់កូន ) តាមម៉ែក្នុងពាក្យទាំងទឡាយមានជាអាទិ ថា សារីបុត្រ ( កូននាងសារី ) មន្តានីបុត្រ ( កូននាងមន្តានី ) ព្រោះមកហើយ ក្នុងគម្ពីរវិភង្គយ៉ាងនេះថា វេទនាកើតអំពីចក្ខុសម្ផស្ស ជាកុសលក៏មាន ជាអកុ_ សលក៏មាន ជាអព្យាក្រិតក៏មាន ក្នុងពាក្យមានជាអាទិថា ចក្ខុសម្ផស្សជាវេទនា នេះមានអត្ថថា វេទនាដែលកើតទេឡើងព្រោះចក្ខុសម្ផស្សជាហេតុ ឈ្មោះថា ចក្ខុ សម្ផស្សជាវេទនា ក្នុងគ្រប់ទ្វារមានសោតៈជាដើមក៏ទំនងនេះ ។ នេះជាកថា ដែលពោលដោយការសង្គ្រោះចូលគ្នាគ្រប់យ៉ាងក្នុងវេទនាវារៈនេះ ដូច្នេះ ។

តែថា វេទនាគប្បីជ្រាបដោយវេទនាដែលសម្បយុត្តដោយធម៌ទាំងនេះ គឺ ក្នុងចក្ខុទ្វារជាវិបាកវិញ្ញាណ ២ ដួង មនោធាតុ ២ ដួង មនោវិញ្ញាណធាតុ ៣ ដួង ។ ក្នុងសោតទ្វារជាដើមក៏ទំនងនេះ ។ ចំណែកមនោទ្វារ គប្បីយល់ថា

ជាវេទនាដែលសម្បយុត្តជាមួយនឹងមនោវិញ្ញាណធាតុ ។

ក៏ក្នុងពាក្យថា ផស្សសមុទយា នេះ គប្បីជ្រាបវិនិច្ឆ័យក្នុងទ្វារទាំង ៥ វេទនាអាស្រ័យវត្ថុទាំង ៥ មានការកើតទេឡើងព្រោះចក្ខុសម្ផស្ស ដែលកើតទេឡើងរួមគ្នាជាដើមកើតទេឡើង ។ ចក្ខុសម្ផស្សជាដើម ទើបជាបច្ច័យរបស់វេទនាដ៏សេសទាំងទឡ្បាយដោយភាពជាឧបនិស្សយប្បច្ច័យជាដើម វេទនាក្នុងតទាលម្ព_ណខណៈ ក្នុងមនោទ្វារ និង វេទនាក្នុងបដិសន្ធិខណៈ ភវង្គខណៈ និងចុតិ_ខណៈដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ មានការកើតទេឡើង ព្រោះការកើតទេឡើងនៃមនោសម្ផស្សដែលកើតទេឡើងរួមគ្នា ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាវេទនាវារៈ )

• • • • • • • • • • •

## កថាពណ៌នា ផស្សវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងផស្សវារៈ ( តទៅ ) ÷

ផស្សៈក្នុងចក្ខុ ឈ្មោះថា ចក្ខុសម្ផស្ស ។ ក្នុងគ្រប់ទ្វារក៏ទំនងនេះ ។ ហើយដោយពាក្យត្រឹមតែប៉ុណ្ណេះថា ចក្ខុសម្ផស្សោ ។ បេ ។ កាយសម្ផស្សោ ជាការដែលព្រះថេរៈបាន ពោលដល់សម្ផស្សៈទាំង ១០ មានវត្ថុ ៥ ទាំងដែល ជាកុសលវិបាក និង អកុសលវិបាក ។

ដោយពាក្យថា មនោសម្ផស្សោ នេះ ជាការដែលព្រះថេរៈបានពោល ដល់ផស្សៈ ដែលសម្បយុត្តជាមួយនឹងលោកិយវិបាកដ៏សេស ២២ យ៉ាង ។

បទថា សឡាយតន សមុទយា សេចក្តីថា ព្រោះអាយតនៈ ៦ យ៉ាង មានចក្ខុជាដើមកើតទេឡើង ផស្សៈសូម្បីទាំង ៦ យ៉ាងនេះ ក៏មានការ កើតទេឡើងដែរ ។ ពាក្យដ៏សេសមានន័យដូចពោលមកហើយនោះឯង ។

( ចប់ កថាពណ៌នាផស្សវារៈ )

..................

## កថាពណ៌នា សឡាយតនវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងសឡាយតនៈវារៈ ( តទៅ ) ថា អាយតនៈទាំងអស់ដែលគួរនឹងពោលក្នុងពាក្យទាំងឡាយមានជាអាទិថា ចក្ខាយតនំ មានន័យដូចដែលបានពោលទុកហើយក្នុងខន្ធនិទ្ទេស និង អាយតននិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

តែថា ក្នុងពាក្យថា នាមរូបសមុទយា នេះ អ្នកសិក្សាគប្បីជ្រាបការកើតទេឡើងនៃសឡាយតនៈ ព្រោះនាមរូបកើតដោយន័យដែលបានពោលទុកហើយក្នុងនិទ្ទេសនៃបដិច្ចសមុប្បាទ ក្នុងគម្ពីរវិសុទ្ធិមគ្គ ដោយអំណាចនៃអាយ-តនៈដែលមានរូប ( តែម្យ៉ាង ) និងនាម ( តែម្យ៉ាង ) និង ទាំងនាមទាំងរូបជាបច្ច័យ ។ ពាក្យដ៏សេសមានប្រការដូចដែលពោលមក ហើយនោះឯង ។

( ចប់ កថាពណ៌នាសឡាយតនៈ )

•••••••••••••••

## កថាពណ៌នា នាមរូបវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងនាមរូបវារៈ ( តទៅ ) ÷

នាមមានការបង្អោនទៅជាលក្ខណៈ។រូបមានការបែកធ្លាយទៅជា លក្ខណៈ។ តែថា ក្នុងវារៈនៃវិត្ថារន័យរបស់នាមរូបនោះ គប្បីជ្រាបថា វេទនា បានដល់ វេទនាខន្ធ សញ្ញាបានដល់សញ្ញាខន្ធ ចេតនា ផស្សៈ មនសិការៈ បានដល់ សង្ខារខន្ធ ។សូម្បីនឹងមានពួកធម៌យ៉ាងដទៃដែលសង្គ្រោះចូលក្នុង សង្ខារខន្ធក៏ពិត តែធម៌ ៣ យ៉ាងនេះ មាននៅក្នុងចិត្តដែលមានកម្លាំងខ្សោយ គ្រប់ដួង ព្រោះដូច្នោះ ក្នុងនាមរូបវារៈនេះព្រះថេរៈក៏បានសម្តែងសង្ខារខន្ធទុក ដោយអំណាចនៃធម៌ ៣ យ៉ាងនេះនោះឯង ។

ពាក្យថា ចត្តារិ ក្នុងពាក្យថា ចត្តារិ មហាភូតានិ នេះ ជាការកំណត់ការរាប់ ( ជាចំនួនរាប់ ) ។

ពាក្យថា មហាភូតានិ ជាឈ្មោះរបស់ដី ទឹក ភ្លើង ខ្យល់ តែហេតុដែលនាំឱ្យហៅវត្ថុទាំង ៤ នោះថា មហាភូត និងន័យនៃការវិនិច្ឆ័យយ៉ាងដទៃ ក្នុងនាមរូបនេះទាំងអស់ បានពោលទុកហើយក្នុងនិទ្ទេសនៃរូបខន្ធ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ចំណែកពាក្យថា ចតុន្នំ ក្នុងពាក្យថា ចតុន្នញ្ច មហាភូតានំ ឧបា_

ទាយ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ មានអធិប្បាយថា អាស្រ័យនូវមហាភូតរូបទាំង ៤ ។

បទថា ឧបាទាយ សេចក្តីថា ចូលទៅតោង គឺ ចាប់ទុក ។ អាចារ្យពួកខ្លះពោលថា និស្សាយ ( អាស្រ័យ ) ក៏មាន ។

ក៏សព្ទថា វត្តមានំ នេះ ជាបាឋៈដែលលើស ។ ម្យ៉ាងទៀត ពាក្យថា វត្តមានំ នេះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថថា ជំនុំ ព្រោះហេតុនោះ គប្បីជ្រាបអត្ថាធិប្បាយនេះថា រូបដែលអាស្រ័យការជំនុំមហាភូតរូបទាំង ៤ ប្រព្រឹត្តទៅ ។

កាលបើយ៉ាងនេះ សូម្បីក្នុងទីគ្រប់កន្លែង មហាភូតរូប ៤ មានបឋវីជាដើម និង រូប ២៣ យ៉ាង ដែលអាស្រ័យមហាភូតរូប ៤ យ៉ាងប្រព្រឹត្តទៅដែលត្រាស់ទុកក្នុងព្រះបាលីនោះឯង ក្នុងគម្ពីរអភិធម្ម ដោយចែកប្រភេទជាចក្ខាយតនំ ជាដើម សូម្បីទាំងអស់គប្បីជ្រាបថា ឈ្មោះថារូប ។

ក៏ក្នុងពាក្យថា វិញ្ញាណសមុទយា នេះ វិញ្ញាណណាជាបច្ច័យរបស់ នាម (តែម្យ៉ាង) ផង របស់រូបសុទ្ធ (តែម្យ៉ាង) ផង ទាំងជាបច្ច័យដល់ នាមនិងរូបផង ព្រោះដូច្នោះ ដោយអំណាចនៃនាម នៃរូប និង ទាំងនាមទាំងរូបដែលមានវិញ្ញាណជាបច្ច័យនោះ អ្នកសិក្សាគប្បីជ្រាបការកើតទេឡើងនៃនាម_រូបព្រោះវិញ្ញាណកើតទេឡើងតាមន័យដែលបានពោលទុកហើយក្នុងនិទ្ទេសនៃ

បដិច្ចសមុប្បាទក្នុង គម្ពីរវិសុទ្ធិមគ្គ នោះចុះ ក្នុងពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នានាមរូបវារៈ )

......................

## កថាពណ៌នា វិញ្ញាណវារៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិញ្ញាណវារៈ ( តទៅ ) ៖

វិញ្ញាណក្នុងចក្ខុ ឈ្មោះថា ចក្ខុវិញ្ញាណ ម្យ៉ាងទៀត វិញ្ញាណដែលកើតទេឡើងហើយអំពីចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា ចក្ខុវិញ្ញាណ សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណក៏យ៉ាងនេះដូចគ្នា ។ តែវិញ្ញាណនេះបានដល់មនោនោះឯងព្រោះដូច្នោះទើបឈ្មោះថាមនោ-វិញ្ញាណ។ ពាក្យថា មនោវិញ្ញាណនេះ ជាឈ្មោះរបស់វិបាកចិត្តដែលប្រព្រឹត្ត ទៅក្នុងភូមិ ៣ វៀរទ្វិបញ្ចវិញ្ញាណ ។

តែក្នុងពាក្យថា សង្ខារសមុទយា នេះ អ្នកសិក្សាគប្បីជ្រាបការកើតទេឡើងនៃវិញ្ញាណ ព្រោះសង្ខារកើតតាមន័យដែលបានពោលទុកហើយក្នុង គម្ពីរវិសុទ្ធិមគ្គនោះឯង ដោយវិញ្ញាណដែលមានសង្ខារជាបច្ច័យ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នាវិញ្ញាណវារៈ )

.......................

## កថាពណ៌នា សង្ខារវារៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសង្ខារវារៈ ( តទៅ ) ÷

សង្ខារមានការតាក់តែងជាលក្ខណៈ ។ តែថាក្នុងវារៈនៃវិត្ថារន័យរបស់សង្ខារនោះ សង្ខារដែលប្រព្រឹត្តហើយតាមកាយទ្វារ ឈ្មោះថា កាយសង្ខារ ។

ពាក្យថា កាយសង្ខារ នេះ ជាឈ្មោះរបស់កាយសញ្ចេតនា ២០ ដួង គឺដែលនៅក្នុងមហាកុសល ៨ ដួង និង អកុសល ១២ ដួង ដែលប្រព្រឹត្ត ទៅហើយដោយការកម្រើកកាយទ្វារ ។

ពាក្យថា វចីសង្ខារ នេះ ជាឈ្មោះរបស់វចីសញ្ចេតនា ២០ ដួងដូចគ្នាដែលប្រព្រឹត្តទៅហើយដោយការកម្រើកវាចាក្នុងវចីទ្វារ ។

សង្ខារដែលប្រព្រឹត្តហើយតាមមនោទ្វារ ឈ្មោះថា ចិត្តសង្ខារ

ពាក្យថា ចិត្តសង្ខារ នេះ ជាឈ្មោះរបស់មនោសញ្ចេតនា ១៩ ដួងដោយលោកិយកុសល និង លោកិយអកុសលដែលប្រព្រឹត្តទៅហើយ ( កើតទេឡើង ) ដល់អ្នកអង្គុយគិតនៅក្នុងទីកំបាំងដោយមិនបានធ្វើការកម្រើកកាយ និងវាចា ។ ក៏ក្នុងពាក្យថា អវិជ្ជាសមុទយា នេះ គប្បីជ្រាបវិនិច្ឆ័យថា អវិជ្ជារបស់សង្ខារ ដែលជាកុសលដោយឧបនិស្សយប្បច្ច័យខ្លះ របស់សង្ខារដែលជាអកុសល ដោយសហជាតប្បច្ច័យជាដើមខ្លះ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នាសង្ខារវារៈ )

## កថាពណ៌នា អវិជ្ជាវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងអវិជ្ជាវារៈ ( តទៅ ) ÷

ការមិនដឹងទុក្ខសច្ច ឈ្មោះថាការមិនដឹងទុក្ខ ។ ពាក្យថា ទុក្ខេអញ្ញាណំ នេះ ជាឈ្មោះរបស់មោហៈ ។ ក្នុងពាក្យទាំងទឡាយមានជាអាទិថា សមុទយេ អញ្ញាណំ ក៏មានន័យដូច្នេះដែរ ។

ក្នុងចំនួនសច្ចៈទាំង ៤ នោះ ការមិនដឹងទុក្ខ គប្បីជ្រាបបានដោយហេតុ៤ប្រការ គឺ ដោយការញ៉ាំងចុះកាន់ខាងក្នុង១ ដោយឋាន( ទីតាំង) ១ ដោយអារម្មណ៍១ ដោយការបិទបាំងទុក១ ។ ពិតណាស់ ការមិនដឹង ទុក្ខនោះ ឈ្មោះថា ញ៉ាំងចុះកាន់ក្នុងខាងក្នុងទុក្ខព្រោះសង្គ្រោះចូលក្នុងទុក្ខ-សច្ចៈ ទុក្ខសច្ចៈឈ្មោះថាជាឋាន ( ទីតាំង ) ព្រោះជានិស្សយបច្ច័យនៃការមិនដឹងទុក្ខនោះ ឈ្មោះថា ជាអារម្មណ៍ ព្រោះជាអារម្មណបច្ច័យ ( នៃការមិនដឹងទុក្ខនោះ) ហើយទុក្ខសច្ចៈ រមែងបិទបាំងការមិនដឹងទុក្ខ នោះទុក ។

ក្នុងអធិការនៃអវិជ្ជាវារៈ ការមិនដឹងសមុទយៈ គប្បីដឹងបានដោយហេតុ ៣ ប្រការ គឺ ដោយឋាន ១ ដោយអារម្មណ៍ ១ ដោយការបិទបាំង ១ ព្រោះសមុទយនោះរារាំងការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិត និង ព្រោះមិនប្រគល់ឱ្យនូវការប្រព្រឹត្តិទៅនៃញាណ ។ ការមិនដឹងនិរោធ និងបដិបទាគប្បីជ្រាបបាន

ដោយហេតុតែមួយប៉ុណ្ណោះ គឺ ដោយការបិទបាំងទុក ។ ក៏ការមិនដឹងដែលបិទបាំងទុក ។ ក៏ការមិនដឹងដែលបិទបាំងនិរោធនិងបដិបទាទុកនោះឯង គប្បីជ្រាបបានព្រោះហាមឃាត់នូវការចាក់ធ្លុះលក្ខណៈតាមសេចក្តីពិតនៃនិរោធសច្ចៈ និង បដិបទាទាំងនោះ និង ព្រោះការមិនប្រគល់ឱ្យនូវការប្រព្រឹត្តិទៅនៃញាណក្នុងសច្ចៈទាំងពីរនោះ ។ តែការមិនដឹងសច្ចទាំងពីរនោះ មិនជាការញ៉ាំងចុះកាន់ក្នុងខាងក្នុងសច្ចៈទាំង ២ នោះទេ ។ ព្រោះមិនសង្គ្រោះចូលក្នុងសច្ចៈទាំងពីរនោះ សច្ចៈទាំងពីរនោះ ក៏មិនជាទីតាំងនៃការមិនដឹងសច្ចៈទាំងពីរនោះ ព្រោះមិនជាធម៌កើតរួមគ្នា ( និង ) មិនជារម្មណ៍ ព្រោះមិនប្រារព្ធសច្ចទាំងពីរប្រព្រឹត្តទៅ ។

អធិប្បាយថា សច្ចៈ ២ ខាងក្រោយ ឃើញបានលំបាក ព្រោះជ្រាល ជ្រៅ តែក្នុងរឿងនេះការមិនដឹង មិនមែនដោយការខ្វាក់ទើបប្រព្រឹត្តទៅ ។ ចំណែកសច្ចៈពីរខាងដើមជ្រាលជ្រៅ ព្រោះលក្ខណៈរបស់សភាវៈឃើញបានលំបាក ដោយសេចក្តីថា ជាសត្រូវនឹងគ្នា ទើបប្រព្រឹត្តទៅដោយការដល់វិបល្លាសក្នុងសច្ចៈទាំងពីរនោះ ។

ម្យ៉ាងទៀត ដោយពាក្យត្រឹមតែប៉ុណ្ណេះថា ទុក្ខេ ព្រះថេរៈបានសម្តែងអវិជ្ជាទុក ដោយការសង្គ្រោះចូលជាមួយគ្នា ទាំងដោយឋាន ( ទីតាំង ) ដោយអារម្មណ៍ និង ដោយកិច្ច ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា ទុក្ខសមុទយេ លោកសម្តែងទុកដោយ ឋានៈ ( ទីតាំង ) ដោយរម្មណៈ និង ដោយកិច្ច ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះថា ទុក្ខនិរោធេ ទុក្ខនិរោធគាមិនិយា បដិបទាយ លោកសម្តែងទុកដោយកិច្ច ។ តែបើពោលដោយសរុបហើយ អវិជ្ជាគប្បីជ្រាបថា លោកសម្តែងទុកដោយសភាវៈ ដោយពាក្យថា អញ្ញាណំ នេះ ក៏កាមាសវៈ ភវាសវៈ ក្នុងពាក្យថា អាសវសមុទយា នេះជាបច្ច័យ នៃអវិជ្ជាដោយអំណាចនៃសហជាតបច្ច័យជាដើម ។ អវិជ្ជាសវៈ គប្បីជ្រាប ថា ក៏អវិជ្ជាដែលកើតទ្បើងមុនជាបច្ច័យនៃអវិជ្ជា ដែលកើតក្រោយៗ ដោយ ឧបនិស្សយប្បច្ច័យនោះឯង ឈ្មោះថា អវិជ្ជាសវៈ ក្នុងពាក្យថា អាសវស_ មុទយា នេះ ។ អវិជ្ជាសវនោះ នឹងជាឧបនិស្សយប្បច្ច័យរបស់អវិជ្ជាដែលកើត ទ្បើងក្នុងកាលតមក ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះ ឯង ដូច្នេះឯង ។

( ចប់ កថាពណ៌នាអវិជ្ជាវារៈ )

....................

## កថាពណ៌នា អាសវវារៈ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសវៈ ( តទៅ ) ÷

អវិជ្ជាក្នុងពាក្យថា អវិជ្ជាសមុទយា នេះ ជាបច្ច័យដោយសហជាតប្បច្ច័យជាដើម របស់កាមាសវៈ និង ភវាសវៈហើយជាបច្ច័យនៃអវិជ្ជាសវៈដោយឧបនិស្សយប្បច្ច័យនោះឯង តែក្នុងពាក្យថា អវិជ្ជាសមុទយា នេះ អវិជ្ជាដែលកើតទេឡើងក្នុងកាលតៗមក គប្បីជ្រាបថាជាអវិជ្ជាសវៈ ។ អវិជ្ជានោះឯង ដែលកើតទេឡើងក្នុងកាលមុន និង ជាឧបនិស្សយបច្ច័យរបស់អវិជ្ជាដែលកើតទេឡើងក្នុងកាលតៗមក ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះនោះឯង ដូច្នេះឯង ។

វារៈនេះ លោកពោលទុកហើយ ដោយការសម្តែងបច្ច័យរបស់អវិជ្ជា នេះដែលជាប្រធានក្នុងបទបដិច្ចសមុប្បាទទាំងទឡាយ ។ ដោយវារៈដែលលោកពោលទុកយ៉ាងនេះ ដែលសម្រេចការដែលសង្សារវដ្តមានទីបំផុតខាងដើមដែលគ្មាននរណា អាចដឹងបាន ។

សួរថា មិនដឹងយ៉ាងណា ? ឆ្លើយថា ( មិនដឹងយ៉ាងនេះគឺ ) ព្រោះថាការកើតទេឡើងនៃអវិជ្ជាមានព្រោះការកើតទេឡើងនៃអាសវៈការកើតទេឡើងនៃអាសវៈមាន សូម្បីព្រោះការកើតទេឡើងនៃអវិជ្ជា អាសវៈជាបច្ច័យនៃអវិជ្ជា សូម្បី

អវិជ្ជាក៏ជាបច្ច័យនៃអាសវៈ ព្រោះអធិប្បាយដូចដែលពោលមកហើយនេះ ទីបំផុតខាងដើមទើបមិនប្រាកដ ភាវៈដែលសង្សារមានទីបំផុតខាងដើម ដែលគ្មាននរណាអាចដឹងបានហើយ ជាការដែលសម្រេចហើយ ព្រោះខាងដើមរបស់អវិជ្ជានោះមិនប្រាកដ ។

វារៈទាំងនេះ គឺ កម្មបថវារៈ ១ អាហារវារៈ ១ ទុក្ខវារៈ ១ ជរាមរណវារៈ ១ ជាតិវារៈ ១ ភវវារៈ ១ ឧបាទានវារៈ ១ តណ្ហាវារៈ ១ វេទនាវារៈ ១ ផស្សវារៈ ១ សឡាយតនវារៈ ១ នាមរូបវារៈ ១ វិញ្ញាណ វារៈ ១ សង្ខារវារៈ ១ អវិជ្ជាវារៈ ១ អាសវវារៈ ១ រួម ១៦ វារៈ ព្រះថេរៈបានពោលទុកហើយក្នុងព្រះសូត្រនេះ ដូចដែលពណ៌នាមកនេះ ។

ព្រោះក្នុងចំនួនវារៈទាំង ១៦ វារៈនោះ មួយវារៈៗ លោកសម្តែងទុក ២ យ៉ាង ដោយសង្ខេប និង ពិស្តារទើបជា ៣២ ស្ថាន ។ ដោយហេតុដូច្នេះ ក្នុងព្រះសូត្រនេះទើបជាការដែលព្រះថេរៈបានពោលសច្ចទុក ៤ យ៉ាង ក្នុង ២២ ស្ថាននេះ ។

ព្រះថេរៈបានពោលអរហត្តទុកក្នុងទី ១៦ ស្ថានដែលពោលទុក ហើយដោយពិស្តារ ក្នុងបណ្តាយ៉ាងសង្ខេប និង យ៉ាងពិស្តារនោះឯង ។ តែតាមមតិរបស់ព្រះថេរៈលោកបានពោលដល់សច្ចៈទាំង ៤ និង មគ្គ ទាំង ៤ ទុកក្នុង ៣២

ស្ថានប៉ុណ្ណោះ ព្រោះហេតុដូចដែលពោលមកហើយនេះឯង ក្នុងព្រះពុទ្ធវចនៈ ដែលព្រះធម្មសង្គាហកាចារ្យបានរួបរួមទុកក្នុងនិកាយធំទាំង ៥ និកាយ ទាំងអស់ ទើបមិនមានសូត្រដែលប្រកាសសច្ចៈ ៤ យ៉ាង ទុកដល់ ៣២ ដង និង ប្រកាស អរហត្តទុកដល់ ២៣ ដង ក្រៅអំពីសម្មាទិដ្ឋិសូត្រនេះឯង ។

ពាក្យថា ឥទមវោចាយស្មា សារិបុត្តោ មានសេចក្តីថា ព្រះសារី- បុត្ត បានពោលសម្មាទិដ្ឋិសូត្រនេះ ពោរពេញទៅដោយហេតុ ៦៤ យ៉ាងគឺ ដោយការបរិយាយអរិយសច្ចៈ ៤ ទុក ៣២ យ៉ាង និង បរិយាយព្រះអរហត្តទុក ៣២ យ៉ាង ។

ភិក្ខុទាំងនោះ ពេញចិត្តត្រេកអរ អនុមោទនាភាសិតរបស់ព្រះសារីបុត្ត ដូច្នេះឯង ។

( ចប់ អដ្ឋកថាសម្មាទិដ្ឋិសូត្រ ទី ៩ )

●●●●●●●●●●●●

# អ ដ្ឋ ក ថា
# សតិប្បដ្ឋានសូត្រទី ១០

សតិប្បដ្ឋានសូត្រ មានពាក្យអធិប្បាយថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ។

## ពាក្យថា កុរុ

បណ្តាបទទាំងនោះ បទថា **កុរូសុ វិហរតិ** សេចក្តីថា សូម្បីជនបទមួយជាទីនៅនៃរាជកុមារអ្នកនៅក្នុងជនបទឈ្មោះថា **កុរុ** គេហៅថា **កុរូ** ដោយរុទ្ឋិ ស័ព្ទ ( ពាក្យដែលបែកចេញអំពីពាក្យដើម ) ( ព្រះមានព្រះភាគជាម្ចាស់ស្តេចទ្រង់គង់នៅ ) ក្នុង កុរុជនបទនោះ ។

តែព្រះអដ្ឋកថាចារ្យទាំងទឡាយពោលទុកថា ក្នុងរជ្ជសម័យរបស់ព្រះបាទមន្ធាតុរាជ មនុស្សក្នុងទ្វីបទាំង ៣ បានឮ ( ពាក្យនិយាយត ៗ គ្នា ) ថា ដែលឈ្មោះថា ជម្ពូទ្វីប ជាដែន ជាទីឧប្បត្តិទេឡើងនៃកំពូលមនុស្ស ( ឧត្តមបុរស ) ចាប់ផ្តើមអំពីព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និង ស្តេចចក្រពត្តិទាំងទឡាយ ជាតំបន់អភិរម្យឧត្តមទ្វីប ទើបបាននាំគ្នាមកព្រមជាមួយនឹងព្រះចៅចក្រពត្តិមន្ធាតុរាជ ដែលទ្រង់បង្វិលចក្ររតន៍ចេញទៅខាងមុខហើយ ស្តេចជាប់តាមមកកាន់ទ្វីបទាំង ៤ ។

តអំពីនោះមក ព្រះរាជាបានត្រាស់សួរបរិនាយកកែវថា តើនៅមានស្ថានដែលជារមណិយដ្ឋានដ៏ក្រៃលែងជាងមនុស្សលោកនេះដែរឬទេ ?

បរិនាយកកែវបានក្រាបទូលថា បពិត្រព្រះមហារាជ ទេវលោកគួរមនោរម្យជាង មហាបពិត្រ ។

## ២ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ព្រះរាជាទើបទ្រង់បង្វិលចក្ររតន៍ទៅមុនហើយ ស្ដេចក៏បានយាងទៅទី នោះ ។ ស្ដេចចាតុម្មហារាជបានជ្រាបថា ព្រះបាទមន្ធាតុរាជស្ដេចមក ហើយ ទ្រង់ត្រិះរិះថា ព្រះរាជាអ្នកសម្បូរឫទ្ធិច្រើន ( ស្ដេចមកហើយ ) យើងមិនអាចនឹងតទល់បានដោយការច្បាំង ទើបបានប្រគល់រាជសម្បត្តិរបស់ខ្លួនថ្វាយ ។

ព្រះអង្គទ្រង់ទទួលរាជសម្បត្តិនោះហើយ បានត្រាស់សួរទៀតថា នៅមានស្ថានដែលជាទីមនោរម្យដ៏ក្រៃលែងជាងនេះដែរឬទេ ?

ស្ដេចចាតុម្មហារាជ បានក្រាបទូលដល់តាវត្តិង្សពិភពចំពោះព្រះអង្គថា ( ព្រះករុណាថ្លៃវិសេស ) តាវត្តិង្សពិភពជារមណីយដ្ឋានក្រៃលែងជាង ( នេះ ) ។ នៅតាវត្តិង្សពិភពនោះ មហារាជទាំង ៤ នេះ ជាអ្នកបម្រើ ( បរិចារិកា ) របស់សក្កទេវរាជនោះ នឹងប្រថាប់ឈរត្រង់ទ្វារ សក្កទេវរាជទ្រង់មានឫទ្ធិច្រើន ទ្រង់មានអានុភាពច្រើន និង ព្រះអង្គមានទេវស្ថាន សម្រាប់ប្រើប្រាស់ទាំងនេះ គឺ វេជយន្តប្រាសាទកម្ពស់ ១ យោជន៍ សុធម្មាទេវសភា កម្ពស់ ៥០០ យោជន៍ វេជយន្តរថ កម្ពស់ ១៥០ យោជន៍ ដំរីឰរាវ័ណ ក៏ខ្ពស់ប៉ុណ្ណោះដែរ ឧទ្យាននន្ទវ័ន ឧទ្យានចិត្តលតាវ័ន ឧទ្យានបារុសកវ័ន ឧទ្យានមិសកវ័នប្រដាប់ដោយទិព្វព្រឹក្សាចំនួន ១ ពាន់ដើម ដើមឈើសួគ៌ ឈ្មោះបារិច្ឆត្តកៈកម្ពស់ ១០០ យោជន៍ ខាងក្រោមដើមបារិច្ឆត្តកៈនោះ មានព្រះទីនាំងបណ្ឌុកម្ពលសិលា_អាសនៈ មានពណ៌ដូចផ្កាសិរមាន់ បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ ដ៏ទន់ល្មើយ កាលសក្កទេវរាជទ្រង់ប្រថាប់គង់ ព្រះវរកាយនឹងលិចចុះពាក់កណ្ដាលព្រះអង្គ ។ លុះទ្រង់ស្ដាប់ពាក្យក្រាបបង្គំទូលនោះហើយ ព្រះរាជាមានព្រះរាជបំណងនឹងស្ដេចយាងទៅកាន់តាវត្តិង្សពិភពនោះ ទើបទ្រង់បោះចក្រកែវទឡើងទៅ ។ ចក្រកែវនោះប្រតិស្ឋាននៅលើអាកាស ព្រមដោយ

ចតុរង្គសេនា ។ តមក ចក្រកែវក៏រមៀលចុះអំពីពាក់កណ្ដាលទេវលោកទាំង ២ ប្រតិស្ឋាននៅត្រង់ផែនដី ព្រមដោយចតុរង្គសេនា មានបរិនាយកកែវជាប្រ_ មុខ ។ ព្រះរាជា ស្ដេចបានទៅកាន់តាវត្តិង្សពិភពតែមួយព្រះអង្គឯងប៉ុណ្ណោះ ។

សក្កទេវរាជលុះបានទ្រង់ជ្រាបថា ព្រះបាទមន្ធាតុស្ដេចយាងមកប៉ុណ្ណោះ ក៏ស្ដេចយាងក្រោកទទួលរាក់ទាក់ ព្រះអង្គក្រាបទូលថា សូមតេជបារមីក្រោមលម្អងធូលីព្រះបាទដោយត្បូង ព្រះមហាករុណាទិគុណ ដ៏ប្រសើរអស្ចារ្យក្រៃ_ លែងនៅក្រោមលម្អងធូលីព្រះបាទ ស្ដេចយាងមក ( នេះជា ) រាជសម្បត្តិរបស់លម្អងធូលីព្រះបាទនោះឯង សូមទ្រង់យាងគ្រប់គ្រងចុះព្រះអង្គ ដោយ សិរសាដោយក្រោមនៃតេជះ ហើយបានទ្រង់ចែកទេវរាជសម្បត្តិចេញជា ២ ចំណែក ព្រមដោយទេពធីតារបាំបានបង្អោនថ្វាយ ១ ចំណែក ព្រះរាជាមន្ធាតុត្រឹមតែស្ដេចប្រថាប់នៅនឹងតាវត្តិង្សពិភពប៉ុណ្ណោះ ភាពជាមនុស្សក៏បាត់ទៅ ភាពជាទេវតាក៏ប្រាកដទេឡើងជំនួស ។ បានជ្រាបថា ព្រះអង្គប្រថាប់លើព្រះទីនាំងបណ្ឌុកម្ពលសិលាអាសនៈរួមជាមួយនឹងសក្កទេវរាជ ដោយហេតុត្រឹមតែបើកព្រះនេត្រទេឡើងទើបនឹងប្រាកដភាពផ្សេងគ្នា ។ ពួកទេព្តា កាលទៅសង្កេតព្រះអង្គក៏នឹងច្រទឡំក្នុងភាពផ្សេងគ្នារវាងសក្កទេវរាជ និង ព្រះអង្គ ។ ព្រះអង្គកាលទ្រង់សោយទិព្វសម្បត្តិក្នុងតាវត្តិង្សពិភពនោះ ទ្រង់គ្រប់គ្រងទេវរាជសម្បត្តិរហូតសក្កទេវរាជស្ដេចឧប្បត្តិហើយចុតិដល់ទៅ ៣៦ ព្រះអង្គ ក៏មិនទ្រង់ឆ្អែតដោយកាម_ គុណទេឡើយ លុះទ្រង់ធ្លាក់ចាកទេវលោកនោះហើយ ក៏ទ្រង់ស្ថិតនៅក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ មានព្រះវរកាយត្រូវខ្យល់ និង កម្ដៅថ្ងៃប៉ះខ្ទប់ ទើបបានសោយទិវង្គត ។ ក៏កាលចក្រកែវប្រតិស្ឋានលើផែនដី បរិនាយកកែវក៏ប្រថាប់ស្នាមព្រះបាទរបស់ព្រះបាទមន្ធាតុនៅនឹងផែនមាស ហើយបង្អោនថ្វាយរាជ_

## ៤ អដ្ឋកថា សតិប្បដ្ឋានសូត្រ

សម្បត្តិថា នេះជារាជសម្បត្តិរបស់ព្រះបាទមន្ធាតុ ។ មនុស្សដែលមកអំពីទ្វីបទាំង ៣ សូម្បីទាំងនោះ មិនអាចនឹងទៅបានទៀត បាននាំគ្នាចូលទៅរកបរិនាយកកែវ ហើយប្រាប់ថា ក្រោមល្អងធូលីព្រះបាទ ពួកខ្ញុំព្រះអង្គមកដោយព្រះបរមរាជា-នុភាព ឥឡូវនេះ មិនអាចនឹងទៅបាន សូមក្រោមល្អងធូលីព្រះបាទ ករុណាផ្តល់ទីលំនៅដល់ពួកខ្ញុំព្រះអង្គផងចុះ ។ បរិនាយកកែវ បានប្រគល់ជនបទឱ្យដល់គេទាំងនោះ ដើម្បីប្រយោជន៍ដល់ការនៅ ម្នាក់ ៗ មួយកន្លែង ។

ក្នុងចំនួនជនបទទាំងនោះ តំបន់ដែលមានមនុស្សមកអំពីបុព្វវិទេហទ្វីបអាស្រ័យនៅ បានទាមថា **វិទេហរដ្ឋ** តាមឈ្មោះចាស់នោះឯង ។ តំបន់ដែលមានមនុស្សមកអំពីអមរគោយានទ្វីបអាស្រ័យនៅ បាននាមថា អបរន្ត-ជនបទ ។ តំបន់ដែលមានមនុស្សមកអំពីឧត្តរកុរុទ្វីបអាស្រ័យនៅ បាននាមថា **កុរុរដ្ឋ** ។ តែមនុស្សទាំងទឡាយហៅដោយពហុវចនៈ ដោយសំដៅដល់ស្រុក និងនិគមចំនួនច្រើន ព្រោះហេតុដូចដែលពោលមកហើយនេះ ទើបព្រះអានន្ទពោលថា ទ្រង់គង់នៅក្នុងដែនកុរុទាំងទឡាយ ( ជាពហុវចនៈ ) ដូច្នេះ ។

### ទីមកនៃពាក្យថា កម្មាសធម្ម

ក្នុងបទថា **កម្មាសធម្មំ** ក្នុងបណ្តាពាក្យថា **កម្មាសធម្មំ នាមកុរូនំ និគមោ** នេះ អាចារ្យពួកខ្លះ ពោលអត្ថាធិប្បាយសេចក្តីដោយ ( ផ្លាស់ ) **ធ** ជា **ទ** ។ ស្ថានដែលឈ្មោះថា **កម្មាសធម្ម** ព្រោះជាកន្លែងត្រូវទូន្មានមនុស្សមានជើងពពាល ។ ព្រះបាទបោរិសាទ ដែលមានព្រះបាទពពាល គេហៅថា **កម្មាស** ( ព្រះអង្គម្ចាស់ពពាល ) ។

តំណាលមកថា ដំបៅកើតត្រង់ព្រះបាទក្នុងទីដែលត្រូវគល់ឈើចាក់ដុះទេឡើងស្រដៀងឈើមានធ្នូត ព្រោះដូច្នោះ ទើបប្រាកដថា មានព្រះបាទ

ពពាល ។ ហើយក្នុងឱកាសនោះ ព្រះអង្គត្រូវទូន្មាន ហើយត្រូវហាមចាកភាពជាមនុស្សស៊ីមនុស្ស ។

នរណា ទូន្មាន ?

ព្រះបរមពោធិសត្វ ។

សួរថា ក្នុងជាតកអ្វី ?

ឆ្លើយថា ព្រះថេរៈមួយពួក ( អាងថា មានមក ) ក្នុង **សុត្តសោម ជាតក** ។

ប៉ុន្តែព្រះថេរៈទាំងនេះប្រាប់ថា មានមកក្នុង **ជយទិសជាតក** ។ ពិត ណាស់ ព្រះបរមពោធិសត្វទ្រង់បានទូន្មានព្រះបាទបោរិសាទដែលមានព្រះបាទ ពពាល ។ ដូចដែលលោកពោលទុកថា ÷

**កាលយើងជាព្រះបរមឱរសាធិរាជ របស់ព្រះបាទជយទិស ដែល ជារាជាធិបតីនៃបញ្ចាលរដ្ឋ បានលះបង់ជីវិត ប្តូរយកព្រះរាជបិតា ហើយ ម្យ៉ាងទៀត យើងបានធ្វើឱ្យព្រះបាទបោរិសាទ ដែលមាន ព្រះបាទពពាលជ្រះថ្លាហើយ ដូច្នោះ ។**

តែអាចារ្យខ្លះ អត្ថាធិប្បាយដោយ **ធ** អក្សរ តែម្យ៉ាង ។ ដូចដែលតំណាលមកថាអ្នក **កុរុរដ្ឋ** មានទំនៀមទម្លាប់ប្រចាំកុរុរដ្ឋ តែកើតការពព្រុះពពាលទេឡើងក្នុងធម្មទំនៀមនោះ ព្រោះដូច្នោះ ទីដែលពព្រុះពពាលនោះ ទើបត្រូវហៅថា **កម្មាសធម្ម** ព្រោះមានធមិ គឺ ការពព្រុះពពាលកើតទេឡើង ។

សួរថា ហេតុដូចម្តេច ទើបលោកមិនពោលឈ្មោះនិគម ដែលនៅអាស្រ័យគ្នានេះ ប៉ុណ្ណោះ ទុកដោយសត្តមីវិភត្តិក្នុងពាក្យថា **កម្មាសធម្ម** នោះ ?

ឆ្លើយថា ព្រោះ ( ព្រះមានព្រះភាគ ) មិនមានឱកាសដែលនឹងគង់

ប្រថាប់ ។

បានជ្រាបថា មិនមានវិហារអ្វីដែលជាឱកាសឱ្យព្រះមានព្រះភាគទ្រង់ គង់ក្នុងនិគមនោះទេឡើយ ។ តែឆ្ងាយពីនិគមទៅ មានព្រៃសណ្ឌៈធំក្នុងភូមិភាគមួយកន្លែង សម្បូណ៌ដោយទឹក ជារមណិយដ្ឋាន ។ ព្រះមានព្រះភាគស្ដេចប្រថាប់ត្រង់មហាព្រៃសណ្ឌៈនោះ ទ្រង់យកនិគមនោះជា **គោចរគ្រាម** ( ស្រុកទទួលបិណ្ឌបាត ) ។ ព្រោះដូច្នោះ គួរជ្រាបសេចក្ដីក្នុងរឿងនេះថា ព្រះមានព្រះភាគស្ដេចគង់នៅដែនកុរុ ទ្រង់យកនិគមរបស់អ្នកកុរុ ដែលឈ្មោះ **កម្មាសធម្ម** ជាគោចរគ្រាម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខវេ មគ្គោ** ដូចតទៅនេះ ÷

## ហេតុដូចម្ដេច ទើបត្រាស់សតិប្បដ្ឋានសូត្រនៅក្នុងកុរុរដ្ឋ

សួរថា ហេតុដូចម្ដេចព្រះមានព្រះភាគ ទើបបានត្រាស់ព្រះសូត្រនេះនៅក្នុងដែនកុរុរដ្ឋនោះ ?

ឆ្លើយថា ព្រោះអ្នកកុរុអាចនឹងទទួលយកព្រះធម្មទេសនា ដ៏ជ្រាលជ្រៅ បាន ។

បានជ្រាបថា ភិក្ខុ ភិក្ខុនី ឧបាសក និង ឧបាសិកាទាំងទឡាយអ្នកដែនកុរុរដ្ឋ ជាអ្នកមានរាងកាយ និង សប្បាយជានិច្ច ដោយអំណាចនៃបច្ច័យ គឺ រដូវជាទីសប្បាយ ព្រោះរដ្ឋនោះសម្បូរដោយបច្ច័យ គឺ រដូវ ។ មនុស្សទាំងនោះមានកម្លាំងបញ្ញាដែលអាស្រ័យការសប្បាយចិត្ត និង រាងកាយ អនុគ្រោះហើយ និង ជាអ្នកអាចទទួល ( ស្ដាប់ ) ពាក្យដ៏ជ្រាលជ្រៅបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគកាលទ្រង់ពិចារណាឃើញថា មនុស្សទាំងនោះអាចនឹងទទួល

## ៧ អដ្ឋកថា សតិប្បដ្ឋានសូត្រ

( ស្តាប់ ) ព្រះធម្មទេសនាដ៏ជ្រាលជ្រៅនេះបាន ទើបបានត្រាស់ **សតិប្បដ្ឋាន-សូត្រ** ដែលមានអត្ថដ៏ជ្រាលជ្រៅនេះ ដោយបំពេញព្រះកម្មដ្ឋានចូលក្នុងព្រះ-អរហត្ត ក្នុងឋានៈ ១៩ យ៉ាង ។

ឧបមាដូចបុរសបានប្រអប់មាសហើយ បញ្ចុះផ្កាឈើប្រភេទផ្សេង ៗ ទុកក្នុងប្រអប់មាសនោះ ឬ បានហិបមាសហើយទុកដាក់រតនៈទាំង ៧ ( ក្នុងនោះ ) យ៉ាងណា ។ ព្រះមានព្រះភាគក៏ដូច្នោះ លុះទ្រង់បានអ្នកកុរុរដ្ឋបរិស័ទ ទើបបានទ្រង់សម្តែងព្រះធម្មទេសនាដ៏ជ្រាលជ្រៅ ។ ដោយហេតុនោះនុ៎ះឯង ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកនេះ ទើបបានទ្រង់សម្តែងព្រះសូត្រដែលមានខ្លឹមសារជ្រាលជ្រៅទុកម្យ៉ាងក្នុងទីឃនិកាយ ទ្រង់បានសម្តែងទុកម្យ៉ាងទៀត គឺ **មហា-**និទានសូត្រ ១ មហាសតិប្បដ្ឋានសូត្រ ១ ( ហើយ ) ក្នុងមជ្ឈិមនិកាយនេះ ទ្រង់បានសម្តែងទុកម្យ៉ាងទៀត គឺ សារោបមសូត្រ ១ រុក្ខូបមសូត្រ ១ រដ្ឋ-បាលសូត្រ ១ មាគន្ទិយសូត្រ ១ អានញ្ជសប្បាយសូត្រ ១ ។

ម្យ៉ាងទៀត ក្នុងជនបទនោះ តាមសភាពប្រក្រតី បរិស័ទទាំង ៤ នាំគ្នាប្រកបសេចក្តីព្យាយាមរឿយ ៗ នៅក្នុងសតិប្បដ្ឋានភាវនា ដោយទីបំផុតសូម្បីពួកទាសៈ កម្មករ និង បរិវារជន ក៏និយាយចរចាគ្នាទាក់ទងសតិប្បដ្ឋាននោះ ។ សូម្បីតែត្រង់កំពង់ទឹក និង ស្ថានទីរវៃអំបោះជុំគ្នាជាដើម ដែលឈ្មោះថា ការនិយាយគ្នាក្នុងរឿងឥតប្រយោជន៍នឹងប្រព្រឹត្តទៅ មិនមានទេឡើយ ។

បើស្ត្រីណាមួយត្រូវសួរថា អ្នកម៉ែម្ចាស់ អ្នកម៉ែមនសិការសតិប្បដ្ឋាន-ភាវនាប្រការណា ? ហើយឆ្លើយថា មិនបានមនសិការប្រការណាទេឡើយ។ មនុស្សទាំងទឡាយនឹងតិះដៀលថា ជីវិតរបស់នាងឥតប្រយោជន៍ នាងមានជីវិតរស់នៅដូចជាមនុស្សស្លាប់ហើយ ។ ទើបបានឱ្យឱវាទនាងថា ចាប់តាំងពីពេលនេះទៅ

កុំធ្វើយ៉ាងនេះទេឡើយ ហើយឱ្យរៀនយកសតិប្បដ្ឋានប្រការណាមួយ ។ តែ ( បើ ) ស្ត្រីណានិយាយថា ខ្ញុំមនសិការសតិប្បដ្ឋានឈ្មោះឯណោះ ។ មនុស្សទាំងទឡ្យាយនឹងនាំគ្នាឱ្យសាធុការថា **សាធុ សាធុ** ហើយសរសើរដោយពាក្យទាំងទឡ្យាយមានជាអាទិថា ជីវិតរបស់នាងជាជីវិតដ៏ល្អហើយ នាងឈ្មោះថា ជាមនុស្សប្រសើរហើយ ព្រះសម្មាសម្ពុទ្ធស្តេចឧប្បត្តិទេឡើងមកដើម្បីប្រយោជន៍ដល់នាង ។ ក៏ក្នុងរឿងនេះមិនចំពោះតែមនុស្សជាតិតែម៉្យាងប៉ុណ្ណោះទេ ដែលនាំគ្នាប្រកបមន-សិការសតិប្បដ្ឋាន សូម្បីតែពួកសត្វតិរច្ឆានដែលនៅអាស្រ័យគេ ក៏មនសិការសតិប្បដ្ឋាន ក្នុងការមនសិការ សតិប្បដ្ឋានរបស់សត្វនោះ មានរឿងតំណាលដូចតទៅនេះ ÷

## សត្វសេកចម្រើនសតិប្បដ្ឋាន

តំណាលមកថា អ្នករបាំម្នាក់ដើរចាប់កូនសេកមកហ្វឹកហាត់ ។ នាងនៅអាស្រ័យភិក្ខុនី វេលាទៅក៏ទៅ ( តែខ្លួន ) ភ្លេចកូនសេក ពួកសាមណេរីក៏ចាប់វាមកចិញ្ចឹមទុក ។ ដាក់ឈ្មោះឱ្យវាថា **ពុទ្ធរក្ខិតៈ** ( ពុទ្ធរក្សា ) ។ ថ្ងៃមួយព្រះថេរីឃើញវាទំនៅខាងមុខ ទើបហៅថា ពុទ្ធរក្ខិតៈ ។

វាឆ្លើយថា អ្វីចាំ ម៉ែម្ចាស់ ព្រះថេរីសួរមានមនសិការភាវនាអ្វីខ្លះទេ ? បក្សីឆ្លើយថា មិនមានទេ ម៉ែម្ចាស់ ។

ព្រះថេរីនិយាយថា ឯងអើយ ធម្មតាអ្នកនៅក្នុងសម្នាក់បព្វជិតមិនគួរនឹងរស់នៅដោយបណ្តោយអត្តភាពចោល ( បណ្តោយខ្លួន ) គួរប្រារព្ធមនសិការឯណាមួយ ហើយបានប្រាប់ថា តែយ៉ាងដទៃឯងមិនអាច ( ធ្វើបាន )ចូរស្វាធ្យាយ ( បរិកម្ម ) ថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ វាតាំងនៅក្នុងឱវាទរបស់ព្រះថេរីគ្រាច់ស្វាធ្យាយថា **អដ្ឋិ អដ្ឋិ** ឆ្អឹង ឆ្អឹង ។ ថ្ងៃមួយ ពេលព្រឹកវាទំនៅ

## ៩ អដ្ឋកថា សតិប្បដ្ឋានសូត្រ

លើចុងសសរហាលកម្តៅថ្ងៃ បក្សីមួយបានយកក្រញាំក្រចកឆាបយកទៅ ។ វាស្រែកឮសំទេឡូង ចេច ចេច ។ សាមណេរីទាំងទឡាយបានឮសំទេឡូងស្រែក ទើបនិយាយថា ព្រះម៉ែម្ចាស់ ពុទ្ធរក្ខិតៈ ត្រូវខ្លែងឆាបយកទៅហើយ នាងទៅជួយឱ្យវាព្រលែង ហើយនាំគ្នាកាន់យកដុំដីជាដើមដេញតាមទៅ ឱ្យវាព្រលែងទាល់តែ បាន ។ ព្រះថេរីសួរវា ដែលគេជួយនាំមក ទំនៅខាងមុខថា ពុទ្ធរក្ខិតៈ វេលាបក្សីឆាបយកទៅ ឯងគិតដូចម្ដេច ?

វាឆ្លើយថា ព្រះម៉ែម្ចាស់ នាងខ្ញុំមិនបានគិតយ៉ាងដទៃទេ នាងខ្ញុំគិតដល់គំនរឆ្អឹងប៉ុណ្ណោះ យ៉ាងនេះថា គ្រោងឆ្អឹងនេះឯងឆាបយកគ្រោងឆ្អឹងទៅ គ្រោងឆ្អឹងនឹងបែកធ្លាយខ្ចាត់ខ្ចាយទៅ ។ មិនថា សូម្បីក្នុងទីណា ។

ល្អហើយ ល្អហើយ ពុទ្ធរក្ខិតៈ ( ការមនសិការយ៉ាងនោះ ) នឹងជាបច្ច័យនៃការអស់ទៅនៃភពរបស់អ្នកក្នុងអនាគត ។

សូម្បីសត្វតិរច្ឆានក្នុងជនបទនោះ ក៏ប្រកបមនសិការក្នុងសតិប្បដ្ឋានដូចដែលពោលមកហើយនេះ ព្រោះដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់ញ៉ាំងការចម្រើនក្នុងសតិប្បដ្ឋាននោះឯង ឱ្យកើតដល់គេទាំងនោះ ទើបបានត្រាស់ព្រះសូត្រនេះទុក ។

### អត្ថនៃពាក្យថា ឯកាយន

បណ្ដាបទទាំងនោះ បទថា **ឯកាយនោ** ប្រែថា ផ្លូវឯក ។ ព្រោះថា **ផ្លូវមានឈ្មោះច្រើនយ៉ាង គឺ មគ្គ , បន្ថ បថ , បជ្ជ , អញ្ជស , វដុម , អាយតន , នាវា , ឧត្តរសេតុ , កុល្ល , ភិសិ** និង **សង្កម** ។

ក្នុង **សតិប្បដ្ឋានសូត្រ** នេះ ព្រះអង្គត្រាស់ផ្លូវនេះទុកដោយឈ្មោះថា **អយន** ។ ព្រោះដូច្នោះ ក្នុងពាក្យថា **ឯកាយនោ អយំ ភិក្ខុវេ មគ្គោ**

## ១០ អដ្ឋកថា សតិប្បដ្ឋានសូត្រ

( ម្នាលភិក្ខុទាំងទឡាយ ផ្លូវនេះ ជាផ្លូវមូលតែមួយ ) នេះ គួរយល់សេចក្តីយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡាយ ផ្លូវនេះជាផ្លូវមួយខ្សែ មិនមែនជាផ្លូវ ២ ខ្សែទេឡើយ។

ម្យ៉ាងទៀត ផ្លូវដែលឈ្មោះថា **ឯកាយន** ព្រោះមនុស្សម្នាក់ប៉ុណ្ណោះគប្បីទៅ ។ ពាក្យថា ម្នាក់ឯង គឺ គួរលះបង់ការនៅច្រទឡូកច្រទឡំដោយពួកគណៈ ចៀសចេញទៅកាន់ទីស្ងាត់ ដំណើរទៅ គឺ បដិបត្តិ ( ម្នាក់ឯង ) ឬ ដែលឈ្មោះថា **អយន** ព្រោះជាហេតុដំណើរទៅ គឺ ទៅអំពីវដ្តសង្សារ ដល់ ព្រះនិព្វាន។

ផ្លូវដើររបស់អ្នកជាឯក ឈ្មោះថា **ឯកាយន** ពាក្យថា អ្នកជាឯក បានដល់អ្នកប្រសើរជាទីបំផុតជាង ។ ហើយអ្នកដែលប្រសើរជាទីបំផុតជាង សព្វសត្វ គឺ ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបមានអធិប្បាយថា បានដល់ ( ផ្លូវយាង ) របស់ ព្រះមានព្រះភាគ ។

ពិតណាស់ សូម្បីអ្នកដទៃក៏ដើរទៅតាមផ្លូវនោះបាន តែសូម្បីយ៉ាងនោះក៏ដោយ ផ្លូវនោះ ក៏ឈ្មោះថា ជាផ្លូវដំណើររបស់ព្រះមានព្រះភាគ ព្រោះព្រះអង្គទ្រង់សាងទឡើង ។ ដូចដែលលោកបានពោលទុកថា ម្នាលព្រាហ្មណ៍ ពិតណាស់ ព្រះមានព្រះភាគអង្គនោះ ទ្រង់ញ៉ាំងផ្លូវដែលនៅមិនទាន់កើតឱ្យកើតទឡើងហើយ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ដែលឈ្មោះថា **អយន** ព្រោះទៅ គឺ ដំណើរទៅ អធិប្បាយថា ប្រព្រឹត្តទៅ ។ មានអធិប្បាយថា ទៅក្នុងទីតែមួយ គឺ ប្រព្រឹត្តទៅក្នុងធម្មវិន័យ ( សាសនា ) នេះប៉ុណ្ណោះ មិនមែនទៅទីដទៃ ។ ដូចដែលត្រាស់ទុកថា ម្នាលសុភទ្ទ **អរិយមគ្គមានអង្គ ៨** ស្វែងរកបានក្នុងព្រះធម្មវិន័យ ( សាសនា ) នេះឯង ។ សេចក្តីពិត ខ្លឹមសារទាំង ២ នេះ ផ្សេងគ្នាត្រឹមតែទេសនា ( វោហារ ) ប៉ុណ្ណោះ ប៉ុន្តែក៏មានសេចក្តីដូចគ្នា ។

# ១១ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ម្យ៉ាងទៀត ដែលឈ្មោះថា **ឯកាយន** ព្រោះទៅកាន់ទិសដៅតែមួយ មានអធិប្បាយថា ក្នុងខាងដើម សូម្បីនឹងប្រព្រឹត្តទៅដោយន័យនៃភាវនា ដែលជាគោលផ្សេងគ្នា ប៉ុន្តែខាងក្រោយ ក៏នឹងទៅកាន់ព្រះនិព្វានតែម្យ៉ាងនោះឯង ដូចដែលសហម្បតីព្រហ្ម បានពោលទុកថា ÷

**ព្រះមានព្រះភាគ ព្រះអង្គទ្រង់ឃើញទីបំផុតនៃការអស់ទៅនៃជាតិ ទ្រង់អនុគ្រោះ ( ទ្រង់មានព្រះករុណាទិគុណ ) ទ្រង់ជ្រាបផ្លូវទៅកាន់ទីកន្លែងមួយ ( ព្រះនិព្វាន ) ដោយផ្លូវនេះ ដែលមនុស្សទាំងទឡាយបានធ្លាប់ឆ្លងឱឃៈ អន្លង់ទឹកមកហើយ កំពុងឆ្លង និង ឆ្លងតទៅ ។**

ប៉ុន្តែអាចារ្យពួកខ្លះពោលថា ដែលឈ្មោះថា **ឯកាយន** ព្រោះទៅដល់និព្វានមួយដងតាមន័យនៃសេចក្តីថា មិនទៅដល់ត្រើយ ( គឺ ព្រះនិព្វាន ) ដល់ ២ ដង ។ ពាក្យនោះមិនត្រឹមត្រូវ ។ ព្រោះថា អត្ថ (សេចក្តី ) យ៉ាងនេះ ព្យញ្ជនៈគួរនឹងជាយ៉ាងនេះថា **សកឹ អយនោ** ( មិនមែន **ឯកាយនោ** ) ។ តែបើនឹងពោលប្រកបសេចក្តីយ៉ាងនេះថា ផ្លូវនោះ មានផ្លូវទៅតែម្យ៉ាង គឺ មានតែមួយគត់ បានដល់ មានការប្រព្រឹត្តិទៅតែម្យ៉ាង ដូច្នេះព្យញ្ជនៈក៏ប្រើ បាន ។ តែអត្ថ ប្រើមិនបានទាំង ២ យ៉ាង ។

ព្រោះហេតុអ្វី ?

ព្រោះក្នុងទីនេះ ទ្រង់ប្រាថ្នាយកមគ្គដែលជាបុព្វភាគ ។

អធិប្បាយថា ក្នុងទីនេះ ព្រះអង្គទ្រង់ប្រាថ្នាយកមគ្គជាទីតាំងនៃសតិ ( សតិប្បដ្ឋាន ) ដែលជាចំណែកខាងដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង ៤ មានកាយជាដើម ។ មិនមែនមគ្គដែលជាលោកុត្តរ ។ ហើយមគ្គដែលជាចំណែក

ខាងដើមនោះ ក៏កើតបានមិនមែនមួយដងដែរ ទាំងមានការកើតមិនមែនតែមួយ

## សិស្ស និង អាចារ្យសន្ទនាគ្នា

ម្យ៉ាងទៀត សូម្បីកាលមុនក្នុងបទនេះ ព្រះមហាថេរៈទាំងទឡាយក៏មានការសន្ទនាមកហើយ ដូចគ្នា ។ ( គឺ ) ព្រះត្រៃបិដកចុល្លនាគត្ថេរបានពោលទុកថា ជាផ្លូវ គឺ សតិប្បដ្ឋានដែលជាបុព្វភាគ ។ ប៉ុន្តែអាចារ្យ របស់លោក គឺព្រះត្រៃបិដកចុល្លសុមនត្ថេរ បានពោលទុកថា ជាមិស្សកមគ្គ ( ទាំងលោកិយ និង លោកុត្តរ ) ។

ព្រះត្រៃបិដកចុល្លនាគត្ថេរពោលថា ជាបុព្វភាគ លោកម្ចាស់ !

ព្រះត្រៃបិដកចុល្លសុមនត្ថេរ ប្រកែកថា ជាមិស្សកមគ្គ អាវុសោ !

កាលអាចារ្យពោលដដែលហើយដដែលទៀត សិស្សក៏នៅស្ងៀមមិនជំ ទាស់ ។ ( ទាំង ២ នាក់ ) ក៏ក្រោកទេឡើងដោយមិនវិនិច្ឆ័យឱ្យ ( ដាច់ស្រេច ) បញ្ហាទេឡើយ ។ ក្រោយមក ព្រះថេរៈជាអាចារ្យទៅកាន់បន្ទប់ងូតទឹក គិតថា យើងនិយាយថាជាមិស្សកមគ្គ ( ទាំងជាលោកិយមគ្គ និង ទាំងជាលោកុត្តរ- មគ្គ ) ប៉ុន្តែ អាវុសោ ចុល្លនាគសម្តែងថា ជាផ្លូវខាងដើម ក្នុងបញ្ហានេះនឹងមានវិនិច្ឆ័យគ្នាយ៉ាងណាហ្ន៎ ទើបស្វាធ្យាយព្រះសូត្រតាំងអំពីដើមទៅ កំណត់ ( បញ្ឈប់ ) ត្រង់នេះថា **យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិ- ប្បដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ** ( ម្នាលភិក្ខុទាំងទឡាយអ្នកណាមួយ ក៏ដោយចម្រើនសតិប្បដ្ឋានទាំង ៤ យ៉ាងនេះរហូត ៧ ឆ្នាំ ) ដូច្នេះ លោកក៏ដឹង ថាធម្មតាលោកុត្តរមគ្គ កាលកើតទេឡើងហើយនឹងដំអក់នៅរហូត ៧ ឆ្នាំ មិនមានមគ្គដែលជាមិស្សកៈ ដែលយើងពោលហើយនោះមិនត្រឹមត្រូវទេឡើយ ចំណែកមគ្គដែលជាបុព្វភាគ ដែលអាវុសោចុល្លនាគសម្តែងហើយនោះ ទើបត្រឹមត្រូវ

ទើបបានទៅក្នុងទីដែលសម្រាប់ប្រកាសក្នុងថ្ងៃធម្មស្សវនៈ ៨ រោច ។

បានជ្រាបថា ព្រះថេរៈក្នុងកាលមុនពេញចិត្តស្តាប់ធម៌ ។ លុះបានឮសំទេឡងប៉ុណ្ណោះ ក៏គិតថា យើង ( នឹងស្តាប់ ) មុន ( នឹងស្តាប់ ) មុន ហើយដាក់ចិត្តស្តាប់ដោយសេចក្តីគោរពយ៉ាងខ្លាំងក្លា ។ ហើយថ្ងៃនោះក៏ជាវារៈ របស់ព្រះចុល្លនាគត្ថេរ កាលលោកអង្គុយលើធម្មាសនៈ ចាប់ផ្លិត ហើយពោល **អារម្ភបទ** ( បុព្វកថា ) ព្រះថេរៈដែលឈរនៅក្រោយ អាសនៈ បានមានការគិត ថា យើងអង្គុយក្នុងទីកំបាំង មិននិយាយ ( អ្វី ) ។ ព្រោះថា ព្រះថេរៈក្នុង កាលមុនជាអ្នកស្តាប់ ។ នឹងមិនលើកដាក់ការពេញចិត្ត របស់ខ្លួនទេឡើងជាធំតែ ម្យ៉ាង ប្រៀបដូចមនុស្ស លីបាច់អំពៅដូច្នោះ ប្រកាន់ហេតុផលម្យ៉ាង ។ លះបង់ វត្ថុដែលមិនមាន ហេតុផលចោល ព្រោះដូច្នោះ ទើបព្រះថេរៈនិយាយថា អា_វុសោ ចុល្លនាគ ។

ព្រះ ( ចុល្លនាគ ) សង្ស័យថា យីសំទេឡងនេះ ដូចជាសំឡេងរបស់លោកអាចារ្យ ក៏បានបញ្ឈប់ការសម្តែងធម៌ ហើយសួរថា មានការអ្វីលោកម្ចាស់ ?

ព្រះថេរៈឆ្លើយថា អាវុសោ ចុល្លនាគ មគ្គផ្សំដែលខ្ញុំពោលមកនោះ មិនត្រឹមត្រូវទេ ប៉ុន្តែ មគ្គ គឺ សតិប្បដ្ឋានដែលជាបុព្វភាគ ដែលអាវុសោ ពោលនោះ ត្រឹមត្រូវហើយ ។

ព្រះថេរៈ ( ចុល្លនាគ ) គិតថា អាចារ្យរបស់យើងរៀនបរិយត្តិទូទៅដល់ចាំព្រះត្រៃបិដកទុក បានជាសុតពុទ្ធ បញ្ហានេះនៅជាអាថ៌កំបាំងសម្រាប់ព្រះភិក្ខុប្រភេទនេះ ( ឋានៈជាអាចារ្យ ) ភិក្ខុនៅកំលោះក្នុងអនាគតនឹងសង្ស័យ បញ្ហានេះជាពិតប្រាកដ យើងនឹងលើកយកព្រះសូត្រមកអធិប្បាយ បញ្ហានេះឱ្យបានច្បាស់លាស់ ។ ចាកគម្ពីរ **បដិសម្ភិទាមគ្គ បុព្វភាគសតិប្បដ្ឋានមគ្គ**

លោកហៅថា **ឯកាយនមគ្គ** ។ ព្រះថេរៈបាននាំយកព្រះសូត្រមកសម្ដែងថា ÷

**បណ្ដាផ្លូវទាំងទឡាយ ផ្លូវមានអង្គ ៨ ប្រសើរជាទីបំផុត បណ្ដាសច្ចៈ ទាំងទឡាយ បទ គឺ (សច្ចៈ ) ទាំង ៤ ប្រសើរជាទីបំផុត បណ្ដា ធម៌ទាំងទឡាយ វិរាគធម៌ប្រសើរជាទីបំផុត បណ្ដាសត្វជើង ២ ទាំង ទឡាយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានបញ្ញាចក្ខុប្រសើរជាទីបំផុត ផ្លូវនេះប៉ុណ្ណោះមិនមានផ្លូវដទៃ ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធិ នៃញាណទស្សនៈ ។ អ្នកទាំងទឡាយ ចូរដើរផ្លូវនោះចុះដែលជាទី ញ៉ាំងមារ និង សេនាមារឱ្យវង្វេង ។ ព្រោះថា អ្នកទាំងទឡាយ ដើរទៅតាមផ្លូវនោះហើយ នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។**

## អធិប្បាយ មគ្គ

ផ្លូវដែលឈ្មោះថា មគ្គ ព្រោះអត្ថដូចម្ដេច ?

ព្រោះអត្ថថា ជាហេតុឱ្យដល់ព្រះនិព្វាន និង ព្រោះអត្ថថា អ្នកមាន សេចក្ដីត្រូវការព្រះនិព្វាន នឹងដើរទៅ ។

បទថា **សត្តានំ វិសុទ្ធិយា** ( ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងទឡាយ ) សេចក្ដីថា ដើម្បីប្រយោជន៍ដល់សេចក្ដីបរិសុទ្ធិនៃសត្វទាំងទឡាយ អ្នកមានចិត្ត សៅហ្មងហើយ ព្រោះមន្ទិលទាំងទឡាយមានរាគៈជាដើម និង ព្រោះឧបក្កិលេស ទាំងទឡាយមានអភិជ្ឈាវិសមលោភៈជាដើម ។

ពិតណាស់ ក៏សត្វទាំងនេះ គឺ **ព្រះសម្មាសម្ពុទ្ធជាម្ចាស់** ចំនួនច្រើន ព្រះអង្គ ចាប់ផ្ដើមអំពីព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា **តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ** ដែលស្ដេចបានឧប្បត្តិហើយក្នុងកប្បមួយជាមួយគ្នានោះ ឯង ។ មុនអំពីកប្បនេះទៅ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប រហូតដល់

## ១៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

**ព្រះសក្យមុនី** ជាទីបំផុតក្តី **ព្រះបច្ចេកសម្ពុទ្ធជាម្ចាស់** ច្រើនរយព្រះអង្គក្តី **ព្រះអរិយសាវក** ដែលរាប់មិនបានប្រមាណមិនត្រូវក្តី ទ្រង់បានបណ្តេត និង បន្សាត់មន្ទិលរបស់ចិត្តទាំងមូលហើយទ្រង់សម្រេច និង សម្រេចភាពបរិសុទ្ធិដ៏កំពូល ក៏ដោយសារផ្លូវនេះ ។ ប៉ុន្តែដោយអំណាចនៃមន្ទិលរបស់រូប និង មិនមានការបញ្ញត្តិការសៅហ្មង និង ភាពផូរផង់ទេឡើយ ។ ពិតណាស់

**ព្រះមហាឫសី ( ព្រះពុទ្ធជាម្ចាស់ ) មិនបានត្រាស់ទុកថា មាណព ( បុគ្គល ) ទាំងទឡាយសៅហ្មង ព្រោះរូបសៅហ្មង បរិសុទ្ធព្រោះរូបបរិសុទ្ធ ប៉ុន្តែព្រះមហាឫសីបានត្រាស់ទុកយ៉ាងនេះថា មាណព ( បុគ្គល ) ទាំងទឡាយស្មៅហ្មង ព្រោះចិត្តសៅហ្មង បរិសុទ្ធព្រោះចិត្តបរិសុទ្ធ ។**

ដូចដែលព្រះអង្គបានត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ សត្វទាំងទឡាយសៅហ្មង ព្រោះចិត្តសៅហ្មង , ផូរផង់ ព្រោះចិត្តផូរផង់ ។ ហើយភាពផូរផង់របស់ចិត្តនោះ មានបានព្រោះផ្លូវគឺ សតិប្បដ្ឋាននេះឯង ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ទុកថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងទឡាយ ។

បទថា **សោកបរិទេវានំ សមតិក្កមាយ** ( ដើម្បីលះបង់នូវសេចក្តី សោក និង សេចក្តីខ្សឹកខ្សួលទាំងទឡាយ ) សេចក្តីថា ដើម្បីរំងាប់ អធិប្បាយ ថា ដើម្បីលះបង់នូវសេចក្តីសោក និង សេចក្តីខ្សឹកខ្សួលទាំងទឡាយ ។

ព្រោះថា មគ្គនេះ បុគ្គលអប់រំហើយ ប្រព្រឹត្តទៅដើម្បីលះបង់នូវសេចក្តីសោកសៅ ( របស់មនុស្សទាំងទឡាយបាន ) ដូចសន្តតិមហាមាត្យជាដើម នឹងលះបង់នូវសេចក្តីខ្សឹកខ្សួល ( របស់មនុស្សទាំងទឡាយ ) បាន ដូចបដាចារ_

ថេរីជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ទុកថា **សោកបរិទេវានំ សមតិក្កមាយ** ( ដើម្បីឈានកន្លងនូវសេចក្តីសោក និង បរិទេវៈទាំងទឡាយ ) ។

សេចក្តីពិត សន្តតិមហាមាត្យ សូម្បីនឹងបានស្តាប់ព្រះគាថានេះថា ÷

**អ្នកចូរធ្វើសេចក្តីសោក ក្នុងកាលមុន ( សោក មានអារម្មណ៍ ជាអតីត ) ឱ្យរីងស្ងួតទៅ អ្នកកុំមានសេចក្តីកង្វល់ចិត្តក្នុងកាល ជាខាងក្រោយទេឡើយ ( មិនកង្វល់ចំពោះអារម្មណ៍ជាអនាគត ) បើអ្នកមិនប្រកាន់ចំពោះធម៌ជាកណ្តាល គឺ បច្ចុប្បន្ន អ្នកនឹងជា បុគ្គលស្ងប់ត្រាច់ទៅ ដូច្នេះ ។**

សន្តតិមហាមាត្យ បានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។

បដាចារាថេរី បានស្តាប់ព្រះគាថានេះថា ÷

**មានបុត្តទុកដើម្បីជួយក៏មិនបាន បិតាក៏មិនបាន ពួកភូមិផង ក៏មិនបាន កាលសេចក្តីស្លាប់គ្របសង្កត់ហើយ ញាតិទាំង-ទឡាយក៏ជួយមិនបាន ។**

ហើយបានតាំងនៅក្នុងសោតាបត្តិផល ផងដែរ ។ ប៉ុន្តែថា ព្រោះដែលឈ្មោះថា **ភាវនា** ហើយ នឹងមិនទាក់ទងនឹងធម៌ឯណានីមួយក្នុង **កាយ** , **វេទនា** , **ចិត្ត** , **ធម៌** មិនមាន ព្រោះដូច្នោះ សូម្បីអ្នកទាំង ២ នោះ ក៏ត្រូវជ្រាបទុកផងថា ការឈានកន្លង **សោកៈ បរិទេវៈ** ទៅបាននោះ ព្រោះមគ្គនេះ ដូចគ្នា ។

បទថា **ទុក្ខទោមនស្សានំ អត្ថង្គមាយ** ( ដើម្បីរំងាប់នូវទុក្ខទាំង-ទឡាយ ) សេចក្តីថា ដើម្បីរំងាប់ អធិប្បាយថា ដើម្បីរំលត់នូវទុក្ខទាំង ២

យ៉ាងនេះ គឺ **ទុក្ខផ្លូវកាយ ១ ទោមនស្សផ្លូវចិត្ត ១** ។ ដោយថា មគ្គនេះ បុគ្គលអប់រំហើយ នឹងប្រព្រឹត្តទៅដើម្បីរំលត់នូវទុក្ខនៃសត្វទាំងទឡាយ ដូចសេចក្តីទុក្ខរបស់ **ព្រះតិស្សត្ថេរ** ជាដើម និង ដើម្បីរំលត់ទោមនស្សនៃសត្វទាំងទឡាយ ដូចទោមនស្សរបស់សក្កទេវរាជជាដើម ។ ក្នុងរឿងនោះមានការសម្តែងសេចក្តីដូចតទៅនេះ ÷

## ព្រះថេរៈគប់បំបាក់ជើង

តំណាលមកថា ក្នុងក្រុងសាវត្ថី បុត្ររបស់កុដុម្ពីឈ្មោះ **តិស្សៈ** លះបង់នូវទ្រព្យសម្បត្តិ ៤០ កោដិ ចេញបួស នៅតែម្នាក់ឯងក្នុងព្រៃមិនមានផ្ទះ ។ ភរិយារបស់ប្អូនប្រុសលោកបានបញ្ជូនចោរ ៥០០ នាក់ ទៅសម្លាប់លោកចោល ពួកចោរបានទឡាមព័ទ្ធព្រះថេរៈ ព្រះថេរៈសួរថា ឧបាសកនាំគ្នាមកធ្វើអ្វី ? ចោរប្រាប់ថា ពួកខ្ញុំនឹងសម្លាប់លោកឯងហ្នឹងណា៎ ។ ព្រះថេរៈសុំអង្វរថា ឧបាសកទាំងទឡាយ ចូរកាន់យកខ្លួនអាត្មាភាពទុកជាគ្រឿងធានាហើយ ឱ្យជីវិតដល់អាត្មាមួយយប់នេះចុះ ។

ពួកចោរសួរថា សមណៈ នរណានឹងជាអ្នកប្រាកដប្រជាឱ្យលោកនៅក្នុងទីនេះ ?

ព្រះថេរៈ ក៏ចាប់ដុំថ្មមួយដុំធំ គប់ឆ្អឹងស្មងជើងទាំងពីរឱ្យបាក់ រួចពោលថា ឧបាសកអើយ មនុស្សដែលត្រូវគេចាប់យកទុកជាថ្នូរ ( ម្នាក់នេះ ) សមគួរ ( ឬទេ ) ? ពួកចោរក៏នាំគ្នាចៀសចេញទៅបង្កាត់ភ្លើង ដេកនៅត្រង់ខាងដើមផ្លូវចង្រ្កម ( របស់លោក ) ។

កាលព្រះថេរៈគ្របសង្កត់វេទនាទុកហើយ ពិចារណាសីល ព្រោះអាស្រ័យសីលដ៏បរិសុទ្ធិ បីតិ និង បាមោជ្ជៈ ទើបកើតទឡើង លំដាប់តអំពី

នោះ លោកក៏ចម្រើនវិបស្សនា បំពេញសមណធម៌រហូតពេញមួយយប់ គ្រប់យាមទាំងបី លុះអរុណរះទេឡើង បានសម្រេចអរហត្ត ហើយបានបន្លឺឧទានថា ÷

**យើងគប់ជើងទាំងពីរ ជាការទប់ស្កាត់ចំពោះចោរទាំងឡាយ**
**យើងអៀនខ្មាសចំពោះសេចក្ដីស្លាប់ ទាំងដែលនៅមានរាគៈ**
**យើងគិតយ៉ាងនេះហើយ ក៏ឃើញច្បាស់តាមសេចក្ដីពិត**
**ដល់ពេលអរុណរះ យើងក៏បើកនូវរនាំង ដល់នូវការអស់**
**កិលេសពុំមានសេសសល់ ។**

## ភិក្ខុបានសម្រេចព្រះអរហត្តក្នុងមាត់ខ្លា

ភិក្ខុ ៣០ អង្គ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះមានព្រះភាគជាម្ចាស់ ហើយចាំវស្សាក្នុងអរញ្ញវិហារ បានសន្យាគ្នាថា យើងគួរធ្វើសមណធម៌ពេញមួយយប់ក្នុងយាមទាំងបី យើងមិនគួរមកកាន់សម្នាក់របស់គ្នា និង គ្នា រួចហើយភិក្ខុទាំង ៣០ អង្គ ក៏នៅកន្លែងផ្សេង ៗ គ្នា ។ កាលភិក្ខុទាំងនោះធ្វើសមណធម៌ពេលជិតភ្លឺក៏ងោកងក់លក់មិនដឹងខ្លួន ខ្លាធំមួយក៏មកចាប់ភិក្ខុទៅស៊ីជាអាហារម្ដងមួយអង្គ ៗ ភិក្ខុណា ៗ ក៏មិនបានស្រែក សូម្បីគ្រាន់តែវាចាថា ខ្លាចាប់ខ្ញុំហើយ ក៏អត់ដែរ ។

ភិក្ខុត្រូវខ្លាចាប់ស៊ីអស់ ១៥ អង្គ ដោយអាការយ៉ាងនេះ ដល់ថ្ងៃឧបោ_សថ ភិក្ខុដែលនៅសល់ បាននិមន្តមកជួបជុំគ្នា លុះដឹងរឿងហើយក៏បានប្រាប់គ្នាថា អង្គណាត្រូវខ្លាចាប់ គួរប្រាប់គ្នា ហើយក៏នៅផ្សេងគ្នាដូច មុនទៀត ។

ក្រោយមក ខ្លាក៏ចាប់ភិក្ខុកំលោះមួយអង្គរបៀបដូចមុន លោកក៏ស្រែក ថា ខ្លាចាប់ខ្ញុំករុណាហើយទាន ភិក្ខុទាំងឡាយក៏កាន់ឈើច្រត់ និង គប់ភ្លើងដេញតាម ដោយគិតថា ឱ្យខ្លាវាព្រលែងលោកមកវិញ ប៉ុន្តែខ្លាវាបានលោត

ទេឡើងទៅកាន់ទីដាច់មួយនៃភ្នំ ដែលភិក្ខុទាំងទឡាយមិនអាចតាមទៅបាន ហើយវាក៏ចាប់ផ្ដើមស៊ីភិក្ខុនោះ ចាប់ពីម្រាមជើងទេឡើងទៅ ។

ភិក្ខុទាំងទឡាយដែលតាមខ្លាទៅនោះ ក៏បានត្រឹមតែពោលថា សប្បុរស ឥឡូវនេះ កិច្ចដែលពួកយើងនឹងត្រូវធ្វើមិនមានទេឡើយ ដែលឈ្មោះថា សេចក្ដីពិសេសរបស់ភិក្ខុទាំងទឡាយ រមែងប្រាកដក្នុងឋានៈដូច្នេះ ។

ភិក្ខុកំលោះដែលត្រូវខ្លាខាំស៊ីនោះ នៅក្នុងមាត់ខ្លា ខំប្រឹងអត់ទ្រាំចំពោះទុក្ខវេទនា ហើយចម្រើនវិបស្សនា ពេលខ្លាស៊ីដល់កជើង បានជាព្រះសោតា_បន្ន ពេលស៊ីដល់ក្បាលជង្គង់ បានជាព្រះសកទាគាមី ពេលខ្លាស៊ីទៅដល់ពោះរបស់លោក ក៏បានជាព្រះអនាគាមី ពេលខ្លាស៊ីជិតដល់បេះដូង លោកក៏បានសម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទា ទើបបន្លឺឧទាន ដូច្នេះថា ÷

**យើងមានសីល ដល់ព្រមដោយវត្ត មានបញ្ញា មានចិត្តតម្កល់ស្មើ**
**ល្អហើយ អាស្រ័យសេចក្ដីប្រមាទមួយភ្លែត ទាំងដែលមានចិត្តមិន**
**គិតប្រទូស្តចំពោះខ្លា វាក៏ចាប់ក្នុងក្រញាំក្រចក ហើយនាំទៅកាន់**
**លើផែនថ្ម ខ្លាស៊ីយើងដល់ឆ្អឹង និង សរសៃ ទៅតាមសេចក្ដីប្រាថ្នា**
**របស់វា យ៉ាងណាក៏ដោយ យើងនឹងធ្វើកិលេសឱ្យអស់ទៅ នឹងបាន**
**ពាល់ត្រូវនូវវិមុត្តិ គឺ ការរួចចាកទុក្ខ ។**

## រឿងព្រះថេរៈដែលត្រូវចាក់ដោយលំពែងបានសម្រេចព្រះអរហត្ត

ភិក្ខុមួយអង្គទៀត ព្រះនាម **បីតិមល្លត្ថេរ** កាលដែលនៅជាគ្រហស្ថ នោះលោកបានទង់មកកាន់កោះលង្កា លោករមែងចូលទៅគាល់ព្រះរាជារហូតបីរជ្ជកាលមកហើយ ទទួលបាននូវព្រះរាជានុគ្រោះ ។

ថ្ងៃមួយលោកបានធ្វើដំណើរទៅកាន់ទ្វារសាលា ដែលមានកន្លែងអង្គុយ

ក្រោយដោយកន្ទេល បានស្តាប់ **នតុម្ហាកវគ្គ** ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ( **នតុម្ហាកំ** ថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជារបស់អ្នកទាំងឡាយ អ្នកទាំងឡាយចូរលះបង់នូវរូបនោះចេញ រូបនោះដែលអ្នកទាំងឡាយលះបង់បានហើយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលជាអង្វែង ។

លោកបានគិតថា មិនមែនចំពោះតែរូបប៉ុណ្ណោះទេ វេទនាក៏មិនមែនជារបស់ខ្លួនដែរ លោកធ្វើបាលីនោះ ឱ្យជាគោលហើយ ចេញទៅកាន់មហាវិហារសូមបព្វជ្ជាឧបសម្បទា លោកធ្វើមាតិកាទាំងពីរឱ្យជាទីតាំងយ៉ាងស្ទាត់ ជំនាញ « **រូបំ នតុម្ហាកំ វេទនា នតុម្ហាកំ** » ហើយបាននាំភិក្ខុ ៣០ អង្គទៅកាន់ទីលានតំបន់ **គវបរបាលី** ធ្វើសមណធម៌ ។

លុះព្រះថេរៈនិមន្តដោយបាទជើងមិនបាន លោកក៏លុតជង្គង់ដើរចង្ក្រមក្នុងយាមនោះ មានព្រានម្រឹគម្នាក់សម្គាល់លោកថា ជាម្រឹគ ក៏ពួយលំពែងសំដៅទៅរកលោក លំពែងបានទម្លុះកាយលោកធ្លាយចុងទៅម្ខាង ។

ព្រះថេរៈឱ្យគេជួយដកលំពែង យកស្មៅញាត់មុខរបួស រួចហើយឱ្យគេជួយគ្រាហ៍លោកក្រោកអង្គុយស្រួលបួលនៅលើផែនថ្ម ឱ្យគេបើកឱកាសចម្រើនវិបស្សនា បានសម្រេចនូវព្រះអរហត្តព្រមដោយបដិសម្ភិទា រួចហើយបានព្យាករណ៍ដល់ភិក្ខុទាំងឡាយដែលនាំគ្នានិមន្តមកក្នុងទីនោះ ដោយឧទាន ថា ÷

> **ព្រះពុទ្ធជាម្ចាស់ ទ្រង់ជាបុគ្គលប្រសើរបំផុត ដែលអ្នកប្រាជ្ញទាំងឡាយនាំគ្នាសរសើរថា ទ្រង់ជាកំពូលលើលោកទាំងពួង ព្រះអង្គបានត្រាស់នូវភាសិតថា ម្នាលភិក្ខុទាំងឡាយ រូបនេះមិនមែនជារបស់អ្នកទាំងឡាយទេឡើយ អ្នកទាំងឡាយគប្បីលះបង់នូវរូបនោះ**

**ចេញ ។ សង្ខារទាំងទឡាយមិនទៀងហ្ន៎ មានការកើតទេឡើង និង វិនាសទៅវិញជាធម្មតា លុះកើតទេឡើងហើយ ក៏រលត់ទៅវិញ ការស្ងប់រំងាប់នូវសង្ខារទាំងនោះ គឺ ព្រះនិព្វាន ទើបជាសុខ ។**

គ្រានោះ ភិក្ខុទាំងទឡាយបាននិយាយនឹងលោកថា បើព្រះសម្មាសម្ពុទ្ធជាម្ចាស់មិនទ្រង់ប្រឈួនទេនោះ ព្រះអង្គទ្រង់នឹងលាតព្រះហស្ថ ( ឆ្លងសមុទ្រ ) មកស្ទាបសិរសាលោកយ៉ាងពិតប្រាកដ ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ **មគ្គនេះ** រមែងប្រព្រឹត្តទៅដើម្បីរំលត់ទុក្ខរបស់សត្វទាំងទឡាយ ដូចយ៉ាងទុក្ខរបស់ព្រះតិស្សត្ថេរជាដើម ។

## សក្កទេវរាជចុតិហើយ ឧប្បត្តិភ្លាម

ក៏សក្កទេវរាជ លុះទ្រង់ឃើញបុព្វនិមិត្ត ៥ យ៉ាង របស់ព្រះអង្គហើយ ទ្រង់ត្រូវមរណភ័យគ្របសង្កត់ កើតទោមនស្ស ទើបចូលទៅគាល់ព្រះមាន-ព្រះភាគជាម្ចាស់ ទ្រង់សួរបញ្ហា ។ ក្នុងអវសាននៃការវិសជ្ជនាបញ្ហា ព្រះអង្គបានសម្រេចសោតាបត្តិផល ព្រមដោយទេវតា ៨ ម៉ឺនអង្គ ស្តេចទ្រង់ ( ចុតិហើយ ) បានស្តេចឧប្បត្តិទេឡើងជាថ្មី ប្រក្រតីដូចដើមទៀត ។

## ទេវតាធ្លាក់នរក

សូម្បី **សុព្រហ្មទេវបុត្រ** មានទេពអប្សរមួយពាន់ជាបរិវារ សោយសួគ៌សម្បត្តិ បណ្តានាងទេពអប្សរមួយពាន់នោះ ទេពអប្សរ ៥០០ អង្គ កំពុងបេះផ្កាអំពីដើម ក៏ចុតិ ហើយកើតក្នុងនរក ។ សុព្រហ្មទេវបុត្ររំពឹងគិតថា ដូចម្តេចហ្ន៎ ទេពអប្សរបេះផ្កាទាំងនេះ ទើបមានការយឺតយូរម្លេះ ទ្រង់បានដឹង ថា ពួកនាងចុតិកើតក្នុងនរក ហើយទ្រង់ពិចារណាឃើញថា អាយុរបស់យើងតើប៉ុន្មានហើយហ្ន៎ ! ស្រាប់តែទ្រង់ជ្រាបព្រះជន្មាយុរបស់ព្រះអង្គ ក៏នឹងត្រូវអស់

ទៅដូចគ្នា ក៏ទ្រង់ឃើញថា ព្រះអង្គនឹងទ្រង់កើតក្នុងនរកនោះឯង ទើបរន្ធត់ព្រះទ័យ ទ្រង់ទោមនស្សយ៉ាងខ្លាំងក្លា ទ្រង់ត្រិះរិះថា ព្រះសាស្ដានឹងទ្រង់បន្ទោបង់ទោមនស្សរបស់យើងនេះបាន អ្នកដទៃកម្ចាត់មិនបាន ហើយបានទ្រង់នាំទេពអប្សរ ៥០០ ដែលនៅសេសសល់ ទៅគាល់ព្រះមានព្រះភាគជាម្ចាស់ ទូលសួរបញ្ហាថា ÷

**ចិត្តនេះតក់ស្លុតជានិច្ច ចិត្តនេះរន្ធត់ជានិច្ច ទាំងក្នុងកិច្ចដែលមិនទាន់កើត ទាំងក្នុងកិច្ចដែលកើតទេឡើងហើយ បើសេចក្ដីមិនរន្ធត់តក់ស្លុតមាន ខ្ញុំព្រះអង្គសូមទូលសួរ សូមព្រះអង្គសម្ដែងប្រាប់នូវការមិនរន្ធត់តក់ស្លុតនោះ ដល់ខ្ញុំព្រះអង្គ ។**

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់ប្រាប់ដល់សុព្រហ្មទេវបុត្រថា ÷

**ក្រៅអំពីអង្គធម៌ជាគ្រឿងត្រាស់ដឹង តបៈជាគ្រឿងដុតបង់នូវបាប ក្រៅអំពីការសង្រួមឥន្ទ្រីយ៍ ក្រៅអំពីលះបង់នូវសង្ខតធម៌ទាំងពួង បានដល់ ព្រះនិព្វាន តថាគតរកមើលមិនឃើញនូវសួស្ដីរបស់សត្វទាំងទឡាយទេឡើយ ។**

ក្នុងវេលាចប់ព្រះធម៌ទេសនា សុព្រហ្មទេវបុត្រតាំងនៅក្នុងសោតាបត្តិផលព្រមដោយទេពអប្សរ ទ្រង់ធ្វើទិព្វសម្បត្តិនោះឱ្យមានស្ថេរភាព ហើយស្ដេចទៅកាន់ទេវលោកដូចដើម ។

**មគ្គនេះ** បុគ្គលអ្នកចម្រើនហើយ គប្បីយល់ថា ប្រព្រឹត្តទៅដើម្បីរំលត់ទោមនស្សរបស់សត្វទាំងទឡាយ ដូចទោមនស្សរបស់សក្កទេវរាជជាដើម ដូចដែលពណ៌នាមកនេះ ។

## ២៣ អដ្ឋកថា សតិប្បដ្ឋានសូត្រ

អរិយមគ្គមានអង្គ ៨ នោះ លោកហៅថា **ញាយ** ក្នុងពាក្យថា **ញាយស្ស អធិគមាយ** ដើម្បីចាក់ធ្លុះ អធិប្បាយថា ដើម្បីដល់អរិយមគ្គ នោះ ។ ព្រោះថា **មគ្គសតិប្បដ្ឋាន** ដែលជាលោកិយក្នុងខាងដើមនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបាន **លោកុត្តរមគ្គ** ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ញាយស្ស អធិគមាយ** ។

បទថា **និព្វានស្ស សច្ឆិកិរិយាយ** ( ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះ និព្វាន ) សេចក្តីថា ដើម្បីធ្វើឱ្យជាក់ច្បាស់ លោកពោលអធិប្បាយទុកថា ដើម្បីប្រចក្សដោយខ្លួនឯងនូវ **អមតធម៌** ដែលបាននាមថា **ព្រះនិព្វាន** ព្រោះវៀរចាកតណ្ហាជាគ្រឿងរួបរឹត ។ ព្រោះថា **មគ្គនេះ** ដែលបុគ្គលអប់រំហើយ ឱ្យសម្រេចការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានតាមលំដាប់ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **និព្វានស្ស សច្ឆិកិរិយាយ** ។

បណ្តាពាក្យទាំងនោះ កាលព្រះអង្គត្រាស់ថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងទឡាយ ពាក្យថា ឈានកន្លងនូវសេចក្តីសោកជាដើម ក៏ជាការដែលសម្រេចសេចក្តីទៅហើយក៏ពិតមែន ប៉ុន្តែក៏នៅមិនទាន់ប្រាកដដល់អ្នកដទៃក្រៅអំពីអ្នកឆ្លាតក្នុងសេចក្តីបញ្ចប់នៃសាសនា ។ ហើយព្រះមានព្រះភាគ ទ្រង់មិនបានធ្វើឱ្យបុគ្គលជាអ្នកឆ្លាតក្នុងសេចក្តីបញ្ចប់នៃសាសនាមុន ហើយទើបទ្រង់សម្តែងធម៌ខាងក្រោយ ។ តែទ្រង់ឱ្យយល់ផលដែលត្រូវការនោះ ៗ ដោយសូត្រនោះ ៗ ប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងសតិប្បដ្ឋានសូត្រនេះ កាលព្រះអង្គទ្រង់នឹងសម្តែងផលដែលត្រូវការនូវ **ឯកាយនមគ្គ** នឹងឱ្យសម្រេចបាន ឱ្យ ប្រាកដទើបបានត្រាស់ទុកថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បីកម្ចាត់បង់នូវសេចក្តីសោក និង បរិទេវៈទាំងទឡាយ ដូច្នេះ ជាដើម ។

## ២៤ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ម្យ៉ាងទៀត ព្រោះសេចក្ដីបរិសុទ្ធិនៃសត្វទាំងទឡាយនឹងប្រព្រឹត្តទៅព្រមក៏ដោយ **ឯកាយនមគ្គ** សេចក្ដីបរិសុទ្ធិនឹងមានបាន ព្រោះឈានកន្លងនូវ **សោកៈ បរិទេវៈ** ការឈានកន្លង **សោកៈ បរិទេវៈ** នឹងមានបាន ព្រោះ **ទុក្ខទោមនស្ស** រលត់ទៅ ការរំលត់ **ទុក្ខទោមនស្ស** នឹងមានបាន ព្រោះបាន សម្រេចញាយធម៌ ការសម្រេច **ញាយធម៌** នឹងមានបាន ព្រោះការធ្វើឱ្យ ជាក់ច្បាស់នូវព្រះនិព្វាន ដូច្នោះ ព្រះអង្គកាលទ្រង់សម្ដែងលំដាប់នេះ ហើយ ទើបត្រាស់ថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងទឡាយ ហើយបានត្រាស់ពាក្យមានជាអាទិនេះទុកថា **សោកបរិទេវានំ សមតិក្កមាយ** ដើម្បីរំលត់បង់នូវសេចក្ដីសោក និង បរិទេវៈ ។

ម្យ៉ាងទៀត ពាក្យថា **សត្តានំ វិសុទ្ធិយា** ជាដើមនេះ ជាពាក្យពោលសរសើរ **ឯកាយនមគ្គ** ដូចយ៉ាងថា ព្រះមានព្រះភាគជាម្ចាស់បានត្រាស់សរសើរទេសនា ៦ ពួក មួយពួក ១ ៦ ប្រការ ដោយបទ ៨ បទថា ម្នាលភិក្ខុទាំងទឡាយ តថាគតនឹងសម្ដែងធម៌លម្អបទដើម លម្អបទកណ្ដាល លម្អបទចុង និង ប្រកាសព្រហ្មចារ្យ ( សាសនា ) ដ៏បរិសុទ្ធ បរិបូរ សព្វគ្រប់ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ គឺ ព្រហ្មចារ្យ ៦ ពួក មួយ ១ ៦ ប្រការដល់អ្នកទាំងទឡាយហើយបានត្រាស់សរសើរ **អរិយវង្សទេសនា** ទុក ដោយបទ ៩ បទ ថា ម្នាលភិក្ខុទាំងទឡាយ អរិយវង្ស ៤ យ៉ាងនេះ ជារបស់ដែលអ្នកប្រាជ្ញស្គាល់ថា ដ៏ប្រសើរ ស្គាល់មកជាយូរ ដឹងថា ជាវង្ស ( នៃព្រះអរិយៈជាម្ចាស់ ) ជារបស់ចាស់ មិនឃ្លៀងឃ្លាត មិនធ្លាប់ឃ្លៀងឃ្លាត មិនត្រូវសង្ស័យ មិនត្រូវសមណព្រាហ្មណ៍ដែលជាបណ្ឌិតជំទាស់យ៉ាងណា ។ ព្រះអង្គក៏ បានត្រាស់សរសើរ **ឯកាយនមគ្គ** នេះទុក ដោយបទ ៧ បទ

មានបទថា ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងទឡាយជាដើម ដូច្នោះ ។

ប្រសិនបើនឹងសួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ដើម្បីនឹងឱ្យកើតឧស្សាហៈដល់ភិក្ខុទាំងនោះ ។

ដោយថា ភិក្ខុទាំងនោះ លុះបានស្តាប់ការត្រាស់សរសើរហើយ នឹងកើតឧស្សាហៈទេឡើងថា **មគ្គនេះ** នឹងនាំឧបទ្ទវៈទាំង ៤ ចេញទៅ គឺ

**សេចក្តីសោក ដែលជាវត្ថុដុតរោលចិត្ត ១ សេចក្តីសោកខ្សឹកខ្សួលរំជួលចិត្ត ដែលជាការពណ៌នាផ្លូវវាចា ១ សេចក្តីទុក្ខដែលជាការមិនសប្បាយ ផ្លូវកាយ ១ ទោមនស្សដែលជាការមិនស្រស់ស្រាយផ្លូវចិត្ត ១ ។**

( និង ) នាំគុណវិសេស ៣ យ៉ាង មកឱ្យ គឺ **វិសុទ្ធិ សេចក្តីបរិសុទ្ធិ ១ ញាយធម៌ ដែលគួរដឹង ១ និព្វាន ការរំលត់ ( កិលេស ) ១** ដូច្នេះហើយ នឹងសម្គាល់ព្រះធម៌ទេសនានេះថា ត្រូវរៀន ត្រូវទន្ទេញ ត្រូវទ្រ- ទ្រង់ចាំ ត្រូវបង្ហាត់បង្រៀន ហើយសម្គាល់ **មគ្គនេះថា** ត្រូវចម្រើន (ដំណើរ ) ព្រះមានព្រះភាគបានត្រាស់សរសើរ ( **ឯកាយនមគ្គ** ) ដើម្បីឱ្យភិក្ខុទាំងនោះ កើតឧស្សាហៈ ដោយប្រការដូចដែលពណ៌នាមកនេះ ដូចអ្នកជំនួញសំពត់ពោលសរសើរគុណភាពសំពត់កម្ពលជាដើមដូច្នោះ ។

សេចក្តីពិស្តារថា កាលអ្នកជំនួញសំពត់រោមសត្វពណ៌លឿង (បណ្ឌុ-កម្ពល ) តម្លៃមួយសែន ឃោសនាថា សូមអញ្ជើញទិញសំពត់រោមសត្វទាន មនុស្សទាំងទឡាយនៅមិនទាន់ជ្រាបមុនថា ជាសំពត់កម្ពលប្រភេទឯណោះ ។ ព្រោះថា សូម្បីសំពត់ **កេសកម្ពល** និង សំពត់ **ផាលកម្ពល** ជាដើម ដែលមានក្លិនស្អុយ សាច់គ្រោតគ្រាត ( សម្រាប់រុំសាកសព ) គេក៏ហៅថា

សំពត់កម្ពលដូចគ្នា ។ ប៉ុន្តែកាលណាគេឃោសនាថា សំពត់ **កម្ពលក្រហម** មកអំពី **គន្ធាររដ្ឋ** សាច់ល្អិត ត្រជាក់ ស្លៀកដណ្តប់ទន់ល្អ ។

កាលនោះ មនុស្សដែលមានទ្រព្យសមល្មម ក៏នឹងទទួល ( ទិញ ) ចំណែកមនុស្សដែលមានទ្រព្យមិនល្មម ក៏ចង់មើលដែរ ។ សូម្បីកាលព្រះអង្គត្រាស់ថា **មគ្គនេះ** ជាមគ្គឯក ក៏នៅមិនទាន់ជាក់ច្បាស់ថា ជាមគ្គនុ៎ះដូច្នោះ ដូចគ្នា ។ ព្រោះថា ផ្លូវដែលមិននាំចេញចាកទុក្ខប្រការផ្សេង ៗ គេក៏ហៅថា ផ្លូវដូចគ្នា ។ តែកាលត្រាស់ពាក្យមានជាអាទិថា **សត្តានំ វិសុទ្ធិយា** ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងទឡាយ ភិក្ខុទាំងទឡាយក៏នឹងកើតឧស្សាហៈថា បានជ្រាបថា មគ្គនេះនាំឧបទ្ទវៈទាំង ៤ ចេញទៅ នាំគុណវិសេស ៣ ប្រការមកឱ្យ និងសម្គាល់ព្រះធម៌ទេសនានេះថា ត្រូវរៀន ត្រូវទន្ទេញ ត្រូវទ្រទ្រង់ ត្រូវបង្ហាត់បង្រៀន និង សម្គាល់មគ្គនេះថា ត្រូវចម្រើន ( ប្រព្រឹត្តតាម ) ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់សរសើរ ( **ឯកាយនមគ្គ** ) ទើបបានត្រាស់ទុកថា **សត្តានំ វិសុទ្ធិយា** ។

ហើយក្នុងរឿងនេះ គួរនាំសេចក្តីប្រៀបធៀប នឹងឈ្មួញមាសជម្ពូនុទពណ៌ក្រហម ឈ្មួញកែវមណី ទឹកថ្លាស្អាត ឈ្មួញមុក្តាហារ ថ្លាស្អាត និង ឈ្មួញកែវប្រវាទឡដែលថ្មៃហើយ ជាដើមមក ដូចសេចក្តីប្រៀបធៀប នឹងឈ្មួញបណ្ឌុកម្ពលតម្លៃមួយសែន ដូច្នោះ ។

## អធិប្បាយស័ព្ទថា យទិទំ

ស័ព្ទថា **យទិទំ** ជានិបាត មានន័យស្មើនឹង **យេ ឥមេ** ។ ស័ព្ទថា **ចត្តារោ** ជាការកំណត់រាប់ ( ចំនួនរាប់ ) ។ ដោយស័ព្ទនោះ ព្រះអង្គទ្រង់សម្តែងដល់ការកំណត់ ( ចំនួន ) **សតិប្បដ្ឋាន** ថា មានមិនតិច

មិនច្រើនជាងចំនួននោះ ។

## អធិប្បាយ សតិប្បដ្ឋាន

បទថា **សតិប្បដ្ឋាន** បានដល់ សតិប្បដ្ឋាន ៣ យ៉ាង គឺ អារម្មណ៍របស់សតិ ១ ការដែលព្រះសាស្តាមិនទ្រង់សោមនស្ស និង ទោមនស្ស ក្នុងកាលសាវ័កទាំងទឡាយបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង ១ , សតិ ១ ។

អធិប្បាយថា អារម្មណ៍របស់សតិលោកហៅថា **សតិប្បដ្ឋាន** ( ដូច ) ក្នុងព្រះពុទ្ធវចនៈទាំងទឡាយមានជាអាទិថា **ម្នាលភិក្ខុទាំងទឡាយ តថាគតនឹងសម្តែងការកើត និង ការរលត់ទៅនៃសតិប្បដ្ឋាន ៤ យ៉ាង អ្នកទាំងទឡាយចូរស្តាប់ទេសនានោះ ។ ល ។ ម្នាលភិក្ខុទាំងទឡាយក៏ការកើតទេឡើងនៃកាយ តើដូចម្តេច ? ការកើតនៃអាហារ គឺ ការកើតទេឡើងនៃកាយ ។**

ម្យ៉ាងទៀត អារម្មណ៍របស់សតិ លោកហៅថា **សតិប្បដ្ឋាន** (ដូច ) ក្នុងពាក្យទាំងទឡាយមានជាអាទិថា **កាយ** ជាទីចូលទៅតាំង ( នៃសតិ ) មិនមែនតួសតិ សតិជាទីតាំងផង ជាតួសតិផង ( ឈ្មោះថា សតិប្បដ្ឋាន ) ដូច្នេះខ្លះ ។

សតិប្បដ្ឋាននោះ មានអត្ថថា ឈ្មោះថា **បដ្ឋាន** ព្រោះជាទីតាំង ។ អ្វីតាំង ? សតិតាំង ។ ទីតាំងរបស់សតិ ឈ្មោះថា **សតិប្បដ្ឋាន** ។ ម្យ៉ាង ទៀត ស្ថានទីជាទីចត ( ប្រធាន ) ដូច្នេះ ទើបឈ្មោះថា **បដ្ឋាន** ។ ស្ថានទីជាទីចតនៃសតិនោះ ឈ្មោះថា **សតិប្បដ្ឋាន** ដូចគ្នានឹងស្ថានទីឈរនៃដំរី និង ស្ថានទីឈរនៃសេះជាដើម ដូច្នោះ ។

**សតិប្បដ្ឋាន ៣ យ៉ាង** គឺ ការដែលព្រះសាស្តាមិនទ្រង់សោមនស្ស និង ទោមនស្ស ព្រោះសាវ័កទាំងទឡាយអ្នកបដិបត្តិក្នុងសតិប្បដ្ឋាន ៣ យ៉ាង

លោក ហៅថា **សតិប្បដ្ឋាន** (ដូច ) ក្នុងព្រះពុទ្ធវចនៈយ៉ាងនេះថា ព្រះសាស្ដាទ្រង់ជាព្រះអរិយៈជាម្ចាស់ កាលទ្រង់សេពវត្ថុដែលព្រះអរិយៈជាម្ចាស់សេព គួរតាមបង្រៀនពួកគណៈ ដូច្នេះ ។ សេចក្ដីនោះមានន័យថា ឈ្មោះថា **បដ្ឋាន** ព្រោះគួរឱ្យផ្ដើមតាំងទុក អធិប្បាយថា ព្រោះគួរឱ្យប្រព្រឹត្តទៅ ( ប្រព្រឹត្ត ) ។

ព្រោះគួរឱ្យអ្វីតាំង ?

គួរឱ្យសតិតាំង ការតាំងសតិ ឈ្មោះថា **សតិប្បដ្ឋាន** ដូច្នេះ ។

ក៏សតិនោះឯង លោកហៅថា **សតិប្បដ្ឋាន** ក្នុងពាក្យទាំងឡាយមានជាអាទិថា សតិប្បដ្ឋានដែលអប់រំហើយ ធ្វើឱ្យច្រើនហើយ នាំឱ្យពោជ្ឈង្គៈ ៧ ប្រការ បរិបូណ៌បាន ។ ក្នុងសេចក្ដីនោះមានន័យថា ឈ្មោះថា **បដ្ឋាន** ព្រោះតាំងទុក អធិប្បាយថា ចូលទៅតាំងទុក គឺ ឈានចុះ ស្ទុះទៅ ប្រព្រឹត្តទៅ ។ **បដ្ឋាន** គឺ សតិនោះឯង ទើបឈ្មោះថា **សតិប្បដ្ឋាន** ។

ម្យ៉ាងទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា រឭក ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ចូលទៅតាំងទុក សតិនោះផង ការតាំងទុកផង ដូច្នោះ ទើបឈ្មោះថា **សតិប្បដ្ឋាន** ដោយប្រការដូច្នេះខ្លះ ។ ក្នុង **សតិប្បដ្ឋានសូត្រ** នេះ លោកសំដៅយក **សតិប្បដ្ឋាន** ប្រការនេះឯង ។

សួរថា បើយ៉ាងនោះ ហេតុដូចម្ដេច ពាក្យថា **សតិប្បដ្ឋាន** ទើបជាពហុវចនៈ ?

ព្រោះសតិមានច្រើន ។

ពិតណាស់ ពោលដោយប្រភេទនៃអារម្មណ៍សតិនោះមានច្រើន ។

កាលបើដូច្នោះ ហេតុអ្វីពាក្យថា **មគ្គ** ( ដែលមានច្រើនដូចគ្នា ) ទើបជាឯកវចនៈ ។

ព្រោះមានតែម្យ៉ាង ដោយអត្ថថា នឹងត្រូវធ្វើដំណើរទៅ ។

ពិតណាស់ សតិទាំងនោះសូម្បីនឹងមាន ៤ យ៉ាង ប៉ុន្តែដល់ភាពតែ ម្យ៉ាង ដោយអត្ថថា ត្រូវធ្វើដំណើរទៅ ។ សមពិតដូចដែលលោកពោលទុកថា ផ្លូវដែលឈ្មោះថា **មគ្គ** ព្រោះអត្ថដូចម្តេច ?

ព្រោះអត្ថថា ជាគ្រឿងទៅកាន់និព្វាន និង ព្រោះអត្ថថា អ្នកមានសេចក្តីត្រូវការនិព្វាន និង ត្រូវធ្វើដំណើរទៅ ។

ក៏សតិសូម្បីទាំង ៤ យ៉ាង នោះ កាលញ៉ាំងកិច្ចឱ្យសម្រេចក្នុងអារម្មណ៍ទាំងទឡាយ មានកាយជាដើម ( រហូត ) ដល់និព្វានក្នុងកាលខាងក្រោយ និងអ្នកប្រាថ្នានិព្វាន ក៏ធ្វើដំណើរទៅតាំងអំពីនោះ ព្រោះហេតុដូចដែលពោលមកហើយនោះ លោកទើបពោលទុកថា សតិសូម្បីទាំង ៤ យ៉ាង ជាផ្លូវមួលតែមួយ ។

កាលបើដូច្នោះ ទើបមានទេសនាដែលមានការបន្តគ្នាមកតាមលំដាប់ ដោយការបន្តពាក្យគ្នាមក ដូចក្នុងព្រះពុទ្ធវចនៈទាំងទឡាយមានជាអាទិថា ៖

**ម្នាលភិក្ខុទាំងទឡាយ តថាគតនឹងសម្តែងផ្លូវសម្រាប់**
**ញ៉ាំញីមារ ព្រមទាំងសេនាមារ អ្នកទាំងទឡាយចូរ**
**ស្តាប់ ។ ល ។ ម្នាលភិក្ខុទាំងទឡាយ ក៏ផ្លូវសម្រាប់**
**ញ៉ាំញីមារ និងសេនាមារ គឺអ្វី ? គឺ ពោជ្ឈង្គៈ ៧**
**( អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ) ទាំងផ្លូវសម្រាប់**
**ញ៉ាំញីមារ និង ពោជ្ឈង្គៈ ៧ មានអត្ថដូចគ្នា ផ្សេងគ្នា**
**តែព្យញ្ជនៈប៉ុណ្ណោះ យ៉ាងណា ឯកាយនមគ្គ និង**
**សតិប្បដ្ឋាន ៤ ក៏ដូច្នោះ ។**

មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ ព្រោះដូច្នោះ គប្បី យល់ថា ( មគ្គ ) ជាឯកវចនៈ ព្រោះអត្ថថា នឹងត្រូវដំណើរទៅ ( ហើយ ) គប្បីយល់ ( សតិប្បដ្ឋាន ) ថា ជាពហុវចនៈ ព្រោះសតិមានច្រើនដោយប្រភេទ នៃអារម្មណ៍ ។

## ហេតុដែលត្រាស់សតិប្បដ្ឋានទុក ៤ យ៉ាង

ប៉ុន្តែហេតុដូចម្តេច បានជាព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ **សតិ-ប្បដ្ឋាន** ទុក ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ( ជាងនោះ ) ?

ព្រោះព្រះអង្គទ្រង់អនុគ្រោះដល់វេនេយ្យសត្វ ។

អធិប្បាយថា បណ្តាវេនេយ្យសត្វទាំងទឡាយ **ពួកតណ្ហាចរិត ពួក ទិដ្ឋិចរិត ពួកសមថយានិក និង ពួកវិបស្សនាយានិក** ដែលប្រព្រឹត្តទៅដោយ ចំណែកទាំង ២ គឺ បញ្ញាទន់ខ្សោយ និង បញ្ញាចាស់ក្លា អ្នកមានតណ្ហាចរិតបញ្ញា ទន់ខ្សោយ មាន **កាយានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍គ្រោតគ្រាត ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ប៉ុន្តែអ្នកមានតណ្ហាចរិត មានបញ្ញាចាស់ក្លា មាន **វេទនានុបស្សនាសតិប្បដ្ឋាន** ដ៏ល្អិតជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ សូម្បីអ្នកមាន ទិដ្ឋិចរិតមានបញ្ញាទន់ខ្សោយ មាន **ចិត្តានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍ ចែកចេញមិនច្រើនពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ តែអ្នកមាន **ទិដ្ឋិចរិត** បញ្ញាចាស់ក្លា មាន **ធម្មានុបស្សនាសតិប្បដ្ឋាន** ដែលមានអារម្មណ៍ចែក ចេញទៅជាច្រើនប្រភេទ ជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។ ហើយ **សតិប្បដ្ឋាន** ប្រការដំបូង ដែលមាននិមិត្ត នឹងដែលគប្បីប្រសព្វបានមិនលំបាក ជាផ្លូវនៃ សេចក្តីបរិសុទ្ធិនៃ **សមថយានិកបុគ្គល** ប្រភេទបញ្ញាទន់ខ្សោយ ។ ខទី ២ ជាផ្លូវនៃ **វិសុទ្ធិសមថយានិកបុគ្គល** ប្រភេទបញ្ញាចាស់ក្លា ។ ព្រោះលោកតាំងនៅ

បានមិនមាំទាំក្នុងអារម្មណ៍ដែលគ្រោតគ្រាត ។ ខទី ៣ ដែលមានអារម្មណ៍ចែកចេញទៅមិនច្រើនប្រភេទពេក ជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់ **វិបស្សនា-យានិកបុគ្គល** ប្រភេទបញ្ញាទន់ខ្ចី ។ ខទី ៤ ដែលមានអារម្មណ៍ចែកចេញទៅច្រើនប្រភេទ ជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់ **វិបស្សនាយានិកបុគ្គល** ប្រភេទបញ្ញាចាស់ក្លា ។ **សតិប្បដ្ឋាន** ទើបត្រាស់ទុក ៤ យ៉ាង ប៉ុណ្ណោះ មិនលើសមិនខ្វះ ដោយប្រការដូចដែលពោលមកនេះ ដូច្នេះ ។

ម្យ៉ាងទៀត ( ដែលទ្រង់សម្ដែងទុក ៤ យ៉ាងប៉ុណ្ណោះ ) ដើម្បីលះ **វិបល្លាស** គឺ សភាពស្អាត សេចក្ដីសុខ សភាពទៀង និង សភាពជា ខ្លួនជាដើម សេចក្ដីពិត កាយ ជារបស់មិនស្អាត ប៉ុន្តែសត្វទាំងទឡាយតាំង នៅយ៉ាងវិបរិត សម្គាល់ខុសក្នុងកាយនោះថា ស្អាត ។ **សតិប្បដ្ឋាន** ខទី ១ ត្រាស់ទុកសម្រាប់សត្វទាំងនោះ ដើម្បីឱ្យលះបង់សុភវិបល្លាសនោះ ដោយការឃើញថា មិនស្អាតក្នុងកាយនោះ ។ ហើយក្នុងវេទនាជាដើម សូម្បីសត្វទាំងទឡាយប្រកាន់មាំថា ជា **សុខ ទៀង** ជា **អត្តា** ( ក៏មានន័យនេះ គឺ ) **វេទនាជាទុក្ខ ចិត្តមិនទៀង ធម៌ទាំងទឡាយជាអនត្តា** ប៉ុន្តែសត្វទាំងទឡាយតាំងនៅយ៉ាងវិបរិត សម្គាល់ខុសក្នុងវេទនា ចិត្ត និង ធម៌ទាំងនោះថា **ជា សុខ ទៀង** និង **ជាអត្តា** ។ ត្រាស់ ៣ យ៉ាង ដ៏សេសទុកសម្រាប់សត្វ ទាំងនោះ ដើម្បីឱ្យលះវិបល្លាសដ៏សេសទាំងនោះ ដោយការឃើញវេទនាជា ដើមទាំងនោះថា ជាទុក្ខ ជាដើម ដូច្នេះ ។

កាលបើដូច្នោះ **សតិប្បដ្ឋាន** ក៏គួរយល់ថា ព្រះអង្គត្រាស់ទុក ៤ យ៉ាងប៉ុណ្ណោះ មិនលើសមិនខ្វះ ក៏ដើម្បីឱ្យលះ **សុភវិបល្លាស សុខវិបល្លាស និច្ចវិបល្លាស និង អត្តវិបល្លាស** ។ ហើយមិនត្រឹមតែត្រាស់ទុកដើម្បីឱ្យលះ

វិបល្លាសតែម្យ៉ាងប៉ុណ្ណោះទេ ប៉ុន្តែគួរយល់ថា ត្រាស់ទុក ៤ យ៉ាងប៉ុណ្ណោះ ក៏ដើម្បីឱ្យលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ និង ឧបាទាន ទាំង ៤ និង អគតិ ៤ ផង ដើម្បីឱ្យកំណត់ដឹងអាហារទាំង ៤ ផង ។ នេះជាន័យតាមបករណ៍ ដូច្នេះ ។

## មតិរបស់អដ្ឋកថា

ចំណែកក្នុងអដ្ឋកថា លោកពោលទុកប៉ុណ្ណោះឯងថា បើពោលដោយការរឭក និង ដោយការប្រមូលចុះកាន់ទីតែមួយជាមួយគ្នាហើយ សតិប្បដ្ឋានក៏មានតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែពោលតាមអារម្មណ៍មាន ៤ យ៉ាង ។ ឧបមាថា ក្នុងព្រះនគរដែលមានទ្វារ ៤ អ្នកដែលមកអំពីទិសខាងកើត កាន់យកវត្ថុដែលមាននៅក្នុងទិសខាងកើតហើយ ចូលកាន់ព្រះនគរនោះឯង តាមខ្លោងទ្វារទិសខាងកើត , អ្នកដែលមកអំពីទិសខាងត្បូង , ទិសខាងលិច , ទិសខាងជើង កាន់យករបស់ដែលមាននៅក្នុងទិសឧត្តរហើយ ចូលទៅកាន់ព្រះនគរនោះឯង តាមទ្វារទិសឧត្តរ យ៉ាងណា សេចក្តីឧបមេយ្យ ដែលឱ្យឧបមាដល់ព្រមនេះ ក៏គួរជ្រាបដូច្នេះ ។

## សេចក្តីប្រៀបធៀប

ពិតណាស់ **ព្រះនិព្វាន** ប្រៀបដូចព្រះនគរ ។

**លោកុត្តរមគ្គប្រកបដោយអង្គ ៨** ប្រៀបដូចទ្វារព្រះនគរ ។

**កាយជាដើម** ប្រៀបដូចទិសខាងកើតជាដើម ។

ព្រះយោគាវចរទាំងទឡាយ កាលមកដោយអំណោច **កាយានុបស្សនា** ចម្រើន **កាយានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ១៤ យ៉ាងហើយ នឹងទៅរួមចុះកាន់ទីតែមួយជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ។ ដោយអរិយមគ្គ

ដែលកើតទេឡើងដោយអានុភាពនៃកាយានុបស្សនា ដូចមនុស្សទាំងទឡាយដែលមកអំពីទិសខាងកើត គឺ នាំយករបស់ដែលមាននៅក្នុងទិសខាងកើតហើយ ក៏ចូលកាន់ព្រះនគរបានដូចគ្នា តាមទ្វារព្រះនគរទិសខាងកើតបាន ដូច្នោះ ។

ព្រះយោគាវចរ កាលដំណើរតាមផ្លូវ **វេទនានុបស្សនា** ចម្រើន **វេទនានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ៩ យ៉ាង ក៏ទៅរួមចុះកាន់ទីតែមួយជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតទេឡើងដោយអានុភាពនៃវេទនានុបស្សនាសតិប្បដ្ឋាន ដូចអ្នកមកអំពីទិសខាងត្បូង កាន់យករបស់ដែលមាននៅក្នុងទិសខាងត្បូង ក៏ចូលដល់ព្រះនគរដូចគ្នា តាមទ្វារព្រះនគរទិសខាងត្បូង ដូច្នេះ ។

ព្រះយោគាវចរទាំងទឡាយ កាលធ្វើដំណើរមកតាមផ្លូវ **ចិត្តានុបស្សនា** ចម្រើន **ចិត្តានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ១៦ យ៉ាង នឹងទៅរួមត្រង់កន្លែងមួយជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតទេឡើងដោយអានុភាពនៃចិត្តានុបស្សនាសតិប្បដ្ឋាន ដូចអ្នកមកអំពីទិសខាងលិច កាន់យករបស់ដែលមាននៅក្នុងទិសខាងលិច ក៏ចូលដល់ព្រះនគរដូចគ្នា តាមខ្លោងទ្វារព្រះនគរទិសខាងលិច ដូច្នេះ ។

ព្រះយោគាវចរទាំងទឡាយ កាលធ្វើដំណើរមកតាមទ្វារ **ធម្មានុបស្សនា** ចម្រើន **ធម្មានុបស្សនាសតិប្បដ្ឋាន** ដោយវិធី ៥ យ៉ាងហើយ នឹងទៅរួមត្រង់កន្លែងជាមួយគ្នា គឺ **ព្រះនិព្វាន** នោះឯង ដោយអរិយមគ្គ ដែលកើតទេឡើងដោយអានុភាពនៃធម្មានុបស្សនាសតិប្បដ្ឋាន ដូចអ្នកដែលមកអំពីទិសខាងជើង កាន់យករបស់ដែលមាននៅក្នុងទិសខាងជើង ក៏ចូលទៅដល់ព្រះនគរដូចគ្នា តាមទ្វារព្រះនគរទិសខាងជើងបាន ដូច្នេះ ។

**សតិប្បដ្ឋាន** គប្បីជ្រាបថា ត្រាស់ទុកតែម្យ៉ាងប៉ុណ្ណោះ ដោយការរពូក និង ដោយការរួមចុះកាន់ទីតែមួយជាមួយគ្នា គប្បីជ្រាបថា ត្រាស់ទុក ៤ យ៉ាងនោះឯង តាមអារម្មណ៍ ដោយប្រការដូច្នេះ ។

**អត្ថនៃពាក្យថា ភិក្ខុ**

បទថា **កតមេ ចត្តារោ** ( ៤ យ៉ាង គឺអ្វីខ្លះ ) ជា **កថេតុកម្យ_តាបុច្ឆា** ( ពាក្យសួរ ដើម្បីនឹងឆ្លើយខ្លួនឯង ) ។

បទថា **ឥធ** បានដល់ **ឥមស្មឹ** ផ្លាស់ជា **សាសនេ** ប្រែថា ក្នុងសាសនានេះ ពាក្យថា **ភិក្ខវេ** នេះ ជាពាក្យហៅបុគ្គលអ្នកទទួលធម្មៈ ។

ពាក្យថា **ភិក្ខុ** ជាពាក្យសម្តែងដល់បុគ្គលអ្នកនឹងញ៉ាំងវត្តបដិបត្តិឱ្យដល់ព្រម ម្យ៉ាងទៀត ទេវតា និង មនុស្សសូម្បីពួកដទៃ ក៏ញ៉ាំងវត្តបដិបត្តិ ឱ្យដល់ព្រមបានដូចគ្នា ។ ប៉ុន្តែព្រះអង្គត្រាស់ហៅថា **ភិក្ខុ** ព្រោះជាអ្នក ប្រសើរ និង ព្រោះទ្រង់សម្តែងដល់ **ភិក្ខុភាវ** ដោយវត្តបដិបត្តិ ។

ព្រោះថា កាលភិក្ខុទាំងទឡាយបដិបត្តិតាមអនុសាសនីរបស់ព្រះមាន_ព្រះភាគជាម្ចាស់ហើយ ភិក្ខុទាំងទឡាយក៏នឹងជាអ្នកប្រសើរជាទីបំផុត ព្រោះ ( ដូចជា ) ភាជនៈ ( សម្រាប់ទទួល ) អនុសាសនីគ្រប់ប្រការ ។ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា **ភិក្ខុ** ព្រោះជាអ្នកប្រសើរជាទីបំផុត ។

ក៏ទ្រង់បញ្ញាក់ដល់ភិក្ខុទាំងនោះហើយ ទេវតា និង មនុស្សដ៏សេស ក៏ជាការដែលទ្រង់បញ្ញាក់ដល់ផងដែរ ដូចគ្នា ដូចបរិស័ទដ៏សេសត្រូវបញ្ញាក់ដល់ដោយរាជស័ព្ទក្នុងកិច្ចទាំងទឡាយ មានការដែលស្តេចព្រះរាជដំណើរជាដើម ។

ហើយអ្នកណាបដិបត្តិ វត្តបដិបត្តិនេះ អ្នកនោះក៏ឈ្មោះថា **ភិក្ខុ** ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ថា **ភិក្ខុ** ព្រោះទ្រង់សម្តែងដល់ **ភិក្ខុភាវ**

ដោយវត្តបដិបត្តិខ្លះ ។ អ្នកបដិបត្តិនឹងជាទេវតា ឬ មនុស្សក៏ដោយ ចូលដល់ការរាប់ថា **ភិក្ខុ** ទាំងអស់ ។ សមដូចដែលត្រាស់ទុកថា ÷

**សូម្បីអ្នកដែលតាក់តែងហើយ ប្រសិនបើប្រព្រឹត្តធម៌ស្មើ**
**ស្ងប់ហើយ ទូន្មានហើយ មានគតិដ៏ទៀងទាត់ ប្រព្រឹត្ត**
**ព្រហ្មចារ្យ គេដាក់ចុះនូវអាជ្ញាចំពោះសត្វទាំងពួង អស់**
**ហើយរមែងឈ្មោះថាជាព្រាហ្មណ៍ ជាសមណៈ ជាភិក្ខុ ។**

## អធិប្បាយពាក្យថា កាយ

បទថា **កាយេ** បានដល់ ក្នុងរូបកាយ ។ ពិតណាស់ **រូបកាយ** ព្រះអង្គទ្រង់សម្តែងថា **កាយ** ក្នុងព្រះសូត្រនេះ ដូចកាយដំរី និង កាយសេះជាដើម ។ ព្រោះអត្ថថា ជាទីប្រជុំនៃអវយវៈតូច_ធំ និង ជាទីប្រជុំនៃរូបធម៌ទាំងទឡាយ មានសក់ជាដើម ។

ក៏ ( រូបកាយ ) ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំ ( នៃ អវយវៈតូច_ធំទាំងទឡាយ ) យ៉ាងណា ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាទីមកនៃរបស់ដែលគួរខ្ពើមទាំងទឡាយ គឺ របស់ដែលគួរឱ្យខ្ពើមរអើមយ៉ាងក្រៃលែង ដូច្នេះ ។

ព្រោះថា រូបកាយនោះ ជាទីមកដល់នៃរបស់ដែលគួរខ្ពើមទាំងទឡាយ គឺ របស់ដែលគួរខ្ពើមយ៉ាងក្រៃលែង ព្រោះដូច្នោះ ទើបឈ្មោះថា **កាយ** ។

បទថា **អាយោ** បានដល់ ដែនកើត ( របស់គួរខ្ពើម ) ក្នុងបទថា **កាយោ** នោះ មានវចនត្ថដូចតទៅនេះ ÷

ឈ្មោះថា **អាយ** ព្រោះជាដែនកើត ។

អ្វីកើត ?

អវយវៈទាំងទឡាយ មានសក់ជាដើម ដែលគួរខ្ពើមកើត ឈ្មោះថា **កាយ** ព្រោះជាដែនកើតនៃរបស់ដែលគួរខ្ពើមទាំងទឡាយ ដោយប្រការយ៉ាងនេះ ។

បទថា **កាយានុបស្សី** បានដល់ អ្នកពិចារណាឃើញកាយរឿយ ៗ ជាប្រក្រតី ឬ អ្នកពិចារណាឃើញរឿយ ៗ នូវកាយ ។

គួរជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ សូម្បីត្រាស់ហើយថា **កាយេ** តែក៏ទ្រង់ធ្វើ ( ត្រាស់ ) កាយស័ព្ទ ទុកជាលើកទី ២ ទៀតថា **កាយា_នុបស្សី** ដើម្បីនឹងទ្រង់សម្ដែងដល់ការបំបែកដុំ ( **ឃនសញ្ញា** ) ចេញទៅ ដោយការកំណត់ដោយ **ចតុធាតុវវដ្ឋានកម្មដ្ឋាន** ដោយមិនឱ្យច្រឡូកច្របល់ គ្នា ព្រះយោគាវចរមិនមែនជាអ្នកពិចារណាឃើញវេទនាក្នុងកាយ ឬ ពិចារណាឃើញចិត្ត និង ធម៌ ក្នុងកាយ ។ ដែលពិត ជាអ្នកពិចារណាឃើញកាយ ( ក្នុងកាយ ) នោះឯង ។ ព្រោះដូច្នេះ ដោយបទថា **កាយានុបស្សី** នោះ ទើបជាការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងដល់ការកំណត់ ដោយមិនឱ្យលាយទឡំគ្នា ដោយទ្រង់សម្ដែងចំពោះអាការ គឺ ការពិចារណាឃើញកាយ ក្នុងវត្ថុ ពោលគឺ កាយនោះឯង ។

មួយវិញទៀត មិនមែនជាអ្នកពិចារណាឃើញធម៌យ៉ាងដទៃសូម្បីតែ មួយ៉ាង ក្រៅអំពីអវយវៈតូច_ធំក្នុងកាយ ទាំងមិនមែនជាអ្នកពិចារណាឃើញ ស្ត្រី ឬ បុរស ក្រៅអំពីសក់ រោម ជាដើម ក្នុងកាយ ។

## ពិចារណាកាយ

ក្នុងពាក្យថា **កាយេ កាយានុបស្សី** នេះ មិនមែនពិចារណាឃើញ ធម៌យ៉ាងដទៃសូម្បីតែម្យ៉ាងក្រៅអំពី ( **មហា** ) **ភូតរូប** និង **ឧបាទាយរូប** សូម្បីក្នុងកាយ ពោលគឺ ប្រជុំនៃ ( **មហា** ) **ភូតរូប** និង **ឧបាទាយរូប** មាន

សក់ រោម ជាដើម ។ ដោយពិត ក៏ជាអ្នកពិចារណាឃើញការប្រជុំនៃចំណែកផ្សេង ៗ ដូចអ្នកសម្លឹងមើលឃើញគ្រឿងប្រកបនៃរថដូច្នោះ ជាអ្នកពិចារណាឃើញការប្រជុំនៃសក់ រោម ជាដើម ដូចអ្នកឃើញចំណែកផ្សេង ៗ នៃទីក្រុងដូច្នោះ ហើយជាអ្នកពិចារណាឃើញការប្រជុំនៃ ( **មហា** ) **ភូតរូប** និង **ឧបា-ទាយរូប** នោះឯង ដូចអ្នកបកស្រទបចេកចេញអំពីដើមចេកដូច្នោះ និង ដូចអ្នកលាដៃក្ដាប់ទទេចេញយ៉ាងនោះឯង ព្រោះដូច្នោះ ដោយទ្រង់សម្ដែងវត្ថុ ពោលគឺកាយ ដោយអំណាចនៃការប្រជុំដោយប្រការផ្សេង ៗ នោះឯង ជាការដែលព្រះអង្គទ្រង់សម្ដែងកាយ បំបែកឃនសញ្ញាចេញហើយ ។ ព្រោះថា ក្នុងពាក្យ ថា **កាយេ កាយានុបស្សី** នេះ នឹងមិនឃើញជាស្ត្រី ជាបុរស ឬ ជាធម៌អ្វីដទៃក្រៅអំពីការប្រជុំនៃធម៌តាមដែលពោលហើយ ។ តែសត្វទាំងទឡាយធ្វើការប្រកាន់ខុស ៗ យ៉ាងនេះយ៉ាងនោះ ក្នុងសភាវៈត្រឹមតែការប្រជុំនៃធម៌ តាមដែល

ពោលហើយប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះបុរាណាចារ្យទើបបានពោលទុកថា ÷

**របស់ណាដែលបុគ្គលកំពុងឃើញ របស់នោះមិនមែនរបស់ដែល**
**គេបានឃើញហើយទេ របស់ណាដែលបុគ្គលបានឃើញហើយ**
**របស់នោះ មិនមែនរបស់ដែលគេកំពុងឃើញ កាលមិនឃើញ**
**( តាមសេចក្ដីពិត ) ទើបវង្វេងជាប់នៅ កាល ( វង្វេង )**
**ជាប់នៅរមែងមិនរួចផុត ។**

មានអធិប្បាយថា ដើម្បីសម្ដែងដល់ការបំបែកភាពជាដុំ ( **ឃន-សញ្ញា** ) ចេញទៅ ជាដើម ។

ដោយអាទិស័ព្ទ ក្នុងពាក្យថា **ឃនវិនិព្ភោគាទិទស្សនត្ថំ** នេះ ក៏គួរ

ជ្រាបអត្ថាធិប្បាយដូចតទៅនេះ ÷

សេចក្តីពិត ព្រះយោគាវចរនេះ ពិចារណាឃើញកាយតែម្យ៉ាងប៉ុណ្ណោះ មិនមែនពិចារណាឃើញធម៌យ៉ាងដទៃ ។

មានអត្ថាធិប្បាយទុកយ៉ាងណា ?

មានអត្ថាធិប្បាយទុកថា មនុស្ស ( ទូទៅ ) មើលឃើញថ្ងៃបណ្តើរ កូន ដែលមិនមែនទឹកសោះ ថា ជាទឹកយ៉ាងណា ព្រះយោគាវចរមិនមែន
ដូចយ៉ាងនោះ គឺ មិនឃើញកាយនេះ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា និង មិនស្អាតសោះ ថា ជារបស់ទៀង ជាសុខ ជាអត្តា និង ជារបស់ស្អាតទៅវិញទេ ដោយពិតហើយ ពិចារណាឃើញ ( ត្រឹមតែ ) **កាយ** គឺ ពិចារណាឃើញថា ជាទីប្រជុំនៃកាយដែលមិនទៀង ជាទុក្ខ ជាអនត្តា និង ជារបស់មិនស្អាត ប៉ុណ្ណោះ ។

ម្យ៉ាងទៀត គួរជ្រាបសេចក្តីសូម្បីយ៉ាងនេះថា កាយនេះណា មាន ខ្យល់ចេញ-ចូលជាខាងដើម មានឆ្អឹងដែលក្លាយទៅជាម្សៅម៍ដ្ឋផ្សរផង់ទៅជា ទីបំផុត ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកមុនហើយដោយន័យមានជា អាទិថា **ម្នាលភិក្ខុទាំងទឡាយ ភិក្ខុក្នុងសាសនានេះទៅកាន់ ព្រៃ ឬ ។ល។ ភិក្ខុនោះមានសតិដកដង្ហើមចេញ** និង កាយណាដែលព្រះសារីបុត្រពោលទុក ក្នុង **បដិសម្ភិទាមគ្គ** ថា **ព្រះយោគាវចររូបខ្លះក្នុងសាសនានេះ ពិចារណា ឃើញកាយ គឺ ដី , កាយ គឺ ទឹក , កាយ គឺ ភ្លើង , កាយ គឺ ខ្យល់ , កាយ គឺ សក់ , កាយ គឺ រោម , កាយ គឺ សម្បុរ , កាយ គឺ ស្បែក , កាយ គឺ សាច់ , កាយ គឺ ឈាម , កាយ គឺ សរសៃ , កាយ គឺ ឆ្អឹង , និង កាយ គឺ ខួរក្នុងឆ្អឹង ដោយ**

**ជារបស់មិនទៀង ព្រោះពិចារណាឃើញកាយនោះទាំងអស់ ក្នុងកាយនេះ** នុ៎ះឯង ព្រះយោគាវចរ ទើបឈ្មោះថា ពិចារណាឃើញកាយក្នុងកាយ ។

ម្យ៉ាងទៀត គួរជ្រាបអត្ថយ៉ាងនេះថា ពិចារណាឃើញកាយ ពោល គឺ ទីប្រជុំរូបធម៌ មានសក់ជាដើម ក្នុងកាយផ្សេង ៗ ព្រោះមិនឃើញរបស់ណាមួយក្នុងកាយ ដែលនឹងត្រូវប្រកាន់មាំយ៉ាងនេះថា យើង ឬ របស់យើង តែព្រោះពិចារណាឃើញការប្រជុំនៃរូបធម៌ផ្សេងៗ នោះៗ ឯងមានសក់ និង រោមជាដើម ។

ម្យ៉ាងទៀត គួរយល់អត្ថយ៉ាងនេះថា ជាអ្នកពិចារណាឃើញកាយក្នុង កាយ ព្រោះពិចារណាឃើញកាយ ពោលគឺ ការប្រជុំអាការមាន **អនិច្ច_លក្ខណៈ** ជាដើម ទូទៅគ្រប់យ៉ាងក្នុងកាយនេះ មានន័យដូចដែលមានមក ហើយក្នុង **បដិសម្ភិទាមគ្គ** ដោយន័យមានជាអាទិថា ពិចារណាឃើញដោយ ភាពជារបស់មិនទៀង មិនមែនឃើញដោយភាពជារបស់ទៀង ។

ពិតណាស់ ភិក្ខុអ្នកបដិបត្តិ **កាយេ កាយានុបស្សនាបដិបទា** ( ខ បដិបត្តិពោលដោយការពិចារណាកាយក្នុងកាយ ) នេះ គប្បីជ្រាបថា នឹងពិចារណាឃើញកាយនេះ ដោយអំណាចនៃអនុបស្សនា ៧ ប្រការ មាន **អនិច្ចានុបស្សនា** ជាដើម គឺ នឹងពិចារណាឃើញដោយភាពជារបស់មិន ទៀង មិនមែនពិចារណាឃើញដោយភាពជារបស់ទៀង និង ពិចារណាឃើញដោយភាពជាទុក្ខ មិនមែនពិចារណាឃើញដោយភាពជាសុខ និង ពិចារណាឃើញដោយភាពជាអនត្តា មិនមែនពិចារណាឃើញដោយភាពជាអត្តា នឹងនឿយណាយ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរ នឹងប្រាសចាកតម្រេក មិនមែនត្រេកអររីករាយ នឹងរលត់ ( តណ្ហា ) មិនមែននឹងឱ្យកើត ( តណ្ហា )

នឹងរលាស់ចេញ មិនមែនប្រកាន់មាំ លោកកាលពិចារណាឃើញកាយនោះដោយសភាពមិនទៀងក៏នឹងលះ **និច្ចសញ្ញា** បាន កាលពិចារណាឃើញដោយសភាពជាទុក្ខ ក៏នឹងលះ **សុខសញ្ញា** បាន កាលពិចារណាឃើញដោយភាពជាអនត្តាក៏នឹងលះ **អត្តសញ្ញា** បាន កាលនឿយណាយ ក៏នឹងលះ **នន្ទិធម៌** សេចក្តីភ្លើតភ្លើនបាន កាលប្រាសចាកតម្រេកក៏នឹងលះ **រាគ** បាន កាលរំលត់ ( តណ្ហា ) ក៏នឹងលះ **សមុទយ** បាន កាលរលាស់ចេញបានក៏នឹងលះការប្រកាន់មាំបាន ។

## អធិប្បាយបទ អាតាបី សតិមា សម្បជានោ

បទថា **វិហរតិ** បានដល់ ដំណើរទៅ ។

ក្នុងបទថា **អាតាបី** គប្បីជ្រាបវិគ្រោះដូច្នេះ ដែលឈ្មោះថា **អាតាប** ព្រោះអត្ថថា រមែងដុតកម្ទេចកិលេសក្នុងភព ៣ ។ ពាក្យថា **អាតាប** នេះជាឈ្មោះនៃវិរិយៈ ។ **អាតាប** នៃភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះទើបឈ្មោះថា **អាតាបី** ។

បទថា **សម្បជានោ** បានដល់ ប្រកបដោយញាណ ពោលគឺ **សម្បជញ្ញ** ។

បទថា **សតិមា** គឺ ប្រកបដោយសតិដែលប្រើកំណត់កាយ ។

ក៏ធម្មតាថា **អនុបស្សនា** នេះ នឹងមិនមានដល់អ្នកប្រាសចាកសតិ ទេឡើយ ព្រោះព្រះយោគាវចរមានសតិជាគ្រឿងកំណត់អារម្មណ៍ហើយ ទើបពិចារណាឃើញ ( កាយជាដើម ) ដោយបញ្ញា ព្រោះហេតុនោះឯង ព្រះ-មានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ តថាគតពោលដល់ សតិថា មានប្រយោជន៍ដល់ធម៌ទាំងពួង ព្រោះដូច្នេះ ក្នុងព្រះសូត្រនេះ ទើប

## ៤១ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ព្រះអង្គ ត្រាស់ទុកថា **កាយេ កាយានុបស្សី វិហរតិ** ( ពិចារណាឃើញកាយ ក្នុងកាយ ) ។ ដោយពាក្យត្រឹមតែប៉ុណ្ណោះ ជាការដែលព្រះអង្គត្រាស់ **កាយានុបស្សនាសតិប្បដ្ឋានកម្មដ្ឋាន** ។

ម្យ៉ាងទៀត ព្រោះហេតុដែលអ្នកមិនមានសេចក្ដីព្យាយាម ការរួញរាចិត្តខាងក្នុង រមែងធ្វើអន្តរាយឱ្យបាន អ្នកដែលមិនមានសម្បជញ្ញៈ រមែងជាអ្នកវង្វេងភ្លេចសតិក្នុងការកំណត់ឧបាយ និង ក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ គឺ ជាអ្នកមិនអាចក្នុងការកំណត់ឧបាយ និងក្នុងការរលាស់ចោលនូវវត្ថុដែលមិនមែនឧបាយ ( ហើយ ) កម្មដ្ឋាននោះ នឹងមិនសម្រេចដល់លោកដោយវិធីនោះ ដូច្នោះ គប្បីជ្រាបថា ដើម្បីនឹងទ្រង់សម្ដែងធម៌ទាំងទឡាយដែលមានអានុភាព ជាហេតុឱ្យសម្រេចនៃកម្មដ្ឋាននោះ ទើបព្រះអង្គត្រាស់ពាក្យនេះទុកថា **អាតាបី** មានសេចក្ដីព្យាយាម **សម្បជានោ** មានសម្បជញ្ញៈ **សតិមា** មានសតិ ។

### អធិប្បាយបទ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្ដែងកាយានុបស្សនាសតិប្បដ្ឋាន និងវិធីប្រកបកាយានុបស្សនាសតិប្បដ្ឋាននោះ ដោយប្រការយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងអង្គនៃការលះកិលេស ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** គប្បីកម្ចាត់បង់នូវ **អភិជ្ឈា** និង **ទោម_នស្ស** ក្នុងលោកចេញ ។

បណ្ដាបទទាំងនោះ បទថា **វិនេយ្យ** បានដល់ កម្ចាត់បង់ដោយការគ្របសង្កត់ទុក ។

បទថា **លោកេ** បានដល់ ក្នុងកាយនោះ ៗ ឯង ។

# ៤២ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ពិតណាស់ **កាយ** ព្រះអង្គទ្រង់ប្រាថ្នាយកថា **លោក** ក្នុងទីនេះ ព្រោះអត្ថថា បែកធ្លាយ ។ ប៉ុន្តែព្រោះហេតុដែលលោកមិនមែននឹងលះបង់ **អភិជ្ឈា** និង **ទោមនស្ស** បាន ចំពោះតែក្នុងកាយប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបានដូចគ្នា ដូច្នោះ ទើបលោកពោលទុកក្នុងគម្ពីរវិភង្គថា **លោក** គឺ ឧបាទានក្ខន្ធទាំង ៥ ។

ម្យ៉ាងទៀត ព្រោះធម៌ទាំងនោះត្រូវរាប់ថាជា **លោក** ពាក្យថា លោកនុ៎ះ ទើបលោកពោលទុកដោយ **អត្ថុទ្ធារន័យ** ( ដោយការពង្រីក សេចក្តី ) ចែកពាក្យណាដែលលោកពោលទុកថា ក្នុងធម៌ទាំងនោះណាជា លោក កាយនុ៎ះឯង ជា **លោក** ។ នេះជាសេចក្តីអត្ថាធិប្បាយក្នុងពាក្យនេះ ។ គប្បីឃើញការសម្ព័ន្ធសេចក្តីយ៉ាងនេះថា **កម្ចាត់អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោកនោះចេញបាន ។

ក៏ព្រោះហេតុដែលក្នុងសូត្រនេះ **កាមឆន្ទ** សង្គ្រោះចូលក្នុងស័ព្ទថា **អភិជ្ឈា** **ព្យាបាទ** សង្គ្រោះចូលក្នុងស័ព្ទថា **ទោមនស្ស** ដូច្នោះ គប្បីជ្រាប ថា ការលះបង់ **នីវរណ** ជាការដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុក ហើយ ដោយការសម្តែងធម៌ពីរយ៉ាង ដែលមានកម្លាំង ទាក់ទង ( នឹង ការលះ ) **នីវរណ** ប៉ុន្តែពោលដោយពិសេសហើយ ក្នុងសូត្រនេះ ព្រះមាន_ ព្រះភាគជាម្ចាស់ត្រាស់ការលះបង់សេចក្តីត្រេកអរ ដែលមានកាយសម្បត្តិជា មូល ដោយការកម្ចាត់ **អភិជ្ឈា** ( និង ) សេចក្តីមិនត្រេកអរ ដែលមាន
កាយវិបត្តិជាមូលទៀតផង ដោយការកម្ចាត់ **ទោមនស្ស** មួយទៀតត្រាស់ការលះបង់សេចក្តីត្រេកអរក្នុងកាយ ដោយការកម្ចាត់ **អភិជ្ឈា** ( និង ) សេចក្តីមិនត្រេកអរក្នុងការចម្រើន **កាយភាវនា** ដោយការកម្ចាត់ **ទោមនស្ស**

ត្រាស់ការលះបង់ការបន្ថែមភាពស្អាត និង សេចក្ដីសុខជាដើម ដែលមិនមាន ពិតក្នុងកាយដោយការកម្ចាត់ **អភិជ្ឈា** និង ការនាំចេញនូវភាពមិនស្អាត និងភាពជាទុក្ខ ដែលមាននៅពិតក្នុង **កាយ** ដោយការកម្ចាត់ **ទោមនស្ស** ។

ដោយពាក្យថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** នោះ ជាការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងអានុភាពនៃការបំពេញសេចក្ដីព្យាយាម និង ភាពជាអ្នកអាចក្នុងការបំពេញសេចក្ដីព្យាយាមរបស់ព្រះយោ_គាវចរទុកហើយ ។ ការពិត អានុភាពនៃសេចក្ដីព្យាយាមនោះ បានដល់ការដែលព្រះយោគាវចរជាអ្នកប្រាសចាកសេចក្ដីត្រេកអរ និង សេចក្ដីមិន ត្រេកអរជាអ្នកគ្របសង្កត់សេចក្ដីត្រេកអរ និង សេចក្ដីមិនត្រេកអរបាន និងជាអ្នកវៀរចាកការបំពេញវត្ថុដែលមិនពិតចូលទៅ និង នាំវត្ថុដែលពិតចេញ មក ។ ក៏ព្រះយោគាវចរនេះកាលប្រាសចាកសេចក្ដីត្រេកអរ និង សេចក្ដី មិនត្រេកអរគ្របសង្កត់បាននូវសេចក្ដីត្រេកអរ និង សេចក្ដីមិនត្រេកអរ មិនបំពេញវត្ថុដែលមិនពិតចូលទៅ និង នាំវត្ថុដែលពិតចេញមក រមែងឈ្មោះថា ជាអ្នកអាចក្នុងការបំពេញសេចក្ដីព្យាយាមនោះឯង ។

ន័យម្យ៉ាងទៀតគប្បីជ្រាបថា ព្រះអង្គត្រាស់កម្មដ្ឋានទុកដោយ **អនុ_បស្សនា** (ការពិចារណារឿយ ៗ ) ក្នុងបទថា **កាយេ កាយានុបស្សី** នេះ ។ ត្រាស់ការបរិហារកាយទុក សម្រាប់អ្នកបំពេញកម្មដ្ឋានដោយការសម្រាក ដូចដែលពោលទុកហើយក្នុងបទថា **វិហរតិ** ។

ក្នុងបទថា **អាតាបី** ជាដើម ព្រះអង្គត្រាស់ **សម្មប្បធាន** ( សេចក្ដីព្យាយាមប្រពៃ ) ទុកដោយ **អាតាប** ( សេចក្ដីព្យាយាមជាហេតុឱ្យកិលេសក្ដៅរោលរាល ) ត្រាស់កម្មដ្ឋាន ដែលឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ឬ ឧបាយ

សម្រាប់បរិហារកម្មដ្ឋានទុកដោយ **សតិសម្បជញ្ញ** ។ ម្យ៉ាងទៀត ត្រាស់ **សមថៈ** ដែលបានមកហើយដោយអំណាច **កាយានុបស្សនា** ទុកដោយ សតិ ។ ត្រាស់ **វិបស្សនា** ដោយ **សម្បជញ្ញ** ។ ត្រាស់ កម្លាំងនៃ **ភាវនា** ទុកដោយការកម្ចាត់ **អភិជ្ឈា** និង **ទោមនស្ស** ចេញ ។

## អធិប្បាយបទ អនុបស្សី

ប៉ុន្តែក្នុង **គម្ពីរវិភង្គ** ព្រះអង្គត្រាស់ទុកថា បទថា **អនុបស្សី** សេចក្តីថា បណ្តាធម៌ទាំងនោះ **អនុបស្សនា** គឺ អ្វី ?

គឺ **បញ្ញា** ការដឹងទូទៅដល់ ។ល។ **សម្មាទិដ្ឋិ** នេះហៅថា **អនុ-បស្សនា** ។ ភិក្ខុចូលដល់ ចូលដល់រៀបរយល្អហើយ ចូលមកដល់ហើយ ចូលមកដល់រៀបរយល្អហើយ ចូលទៅដល់ហើយ ដល់ព្រមហើយ ប្រកប ហើយដោយ **អនុបស្សនា** នេះ ព្រោះហេតុនោះ ទើបត្រាស់ហៅថា **អនុបស្សី** អ្នកពិចារណាឃើញរឿយ ៗ ។

បទថា **វិហរតិ** សេចក្តីថា រមែងផ្លាស់ប្តូរ ប្រព្រឹត្តទៅរក្សាទុក ដំណើរទៅឯង ឱ្យ ( រាងកាយ ) ដំណើរទៅ នាំទៅ សម្រាក ដោយ ហេតុនោះ ទើបត្រាស់ហៅថា **វិហរតិ** ។

បទថា **អាតាបី** សេចក្តីថា បណ្តាធម៌ទាំងនោះ **អាតាបៈ** ( សេចក្តីព្យាយាម ) គឺអ្វី ?

គឺ ការប្រារព្ធសេចក្តីព្យាយាមផ្លូវចិត្ត ។ ល ។ សេចក្តីព្យាយាម ប្រពៃនេះហៅថា **អាតាប** ភិក្ខុជាអ្នកចូលដល់ហើយ ។ ល ។ ប្រកបព្រម ហើយដោយ **អាតាប** នេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **អាតាបី** ។

បទថា **សម្បជានោ** សេចក្តីថា បណ្តាធម៌ទាំងនោះ **សម្បជញ្ញ**

គឺអ្វី ?

គឺ **បញ្ញា** សេចក្តីដឹងទូទៅ ។ ល ។ **សម្មាទិដ្ឋិ** នេះហៅថា **សម្បជញ្ញ** ។ ភិក្ខុជាអ្នកចូលដល់ហើយ ។ ល ។ ប្រកបព្រមហើយដោយ **សម្បជញ្ញ** នេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **សម្បជានោ** ។

បទថា **សតិមា** សេចក្តីថា បណ្តាធម៌ទាំងនោះ **សតិ** គឺអ្វី ?

គឺ **សតិ** សេចក្តីរឭកបាន **អនុស្សតិ** ការរឭកឃើញរឿយ ៗ ។ ល ។ **សម្មាសតិ** ការរឭកប្រពៃ នេះហៅថា **សតិ** ។ ភិក្ខុជាអ្នកចូលដល់ហើយ ។ ល ។ ប្រកបព្រមហើយដោយសតិនេះ ដោយហេតុនោះ ទើបត្រាស់ហៅថា **អ្នកមានសតិ** ។

បទថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** សេចក្តីថា បណ្តាធម៌ទាំងនោះ **លោក** គឺអ្វី ?

កាយនោះឯង ឈ្មោះថា **លោក** លោកគឺ **ឧបាទានក្ខន្ធ** ទាំង ៥ នេះហៅថា **លោក** ។

បណ្តាធម៌ទាំងនោះ **អភិជ្ឈា** គឺអ្វី ?

គឺ ការត្រេកត្រអាល ការត្រេកត្រអាលខ្លាំងក្លា ការត្រេកអរតាមសេចក្តីភ្លើតភ្លើន ការត្រេកត្រអាលដោយអំណាចសេចក្តីភ្លើតភ្លើន ការត្រេកត្រអាលខ្លាំងក្លានៃចិត្ត នេះហៅថា **អភិជ្ឈា** ។

បណ្តាធម៌ទាំងនោះ **ទោមនស្ស** គឺអ្វី ?

គឺ ការមិនត្រេកអរផ្លូវចិត្ត សេចក្តីទុក្ខផ្លូវចិត្ត ការមិនត្រេកអរ ទុក្ខវេទនាកើតអំពីមនោសម្ផស្ស នេះហៅថា **ទោមនស្ស** ។

ទាំង **អភិជ្ឈា** ទាំង **ទោមនស្ស** ក្នុងលោក គឺ កាយនេះ ជា

ការដែលត្រូវកម្ចាត់ហើយ ត្រូវកម្ចាត់ចេញហើយ ស្ងប់ហើយ ស្ងាត់ស្ងៀម ហើយ រម្ងាប់ហើយ ដល់ការរលត់ហើយ ដល់ការតាំងនៅមិនបានហើយ ដល់ការរលត់សូន្យទៅហើយ អស់គ្រេកអរហើយ រីងស្ងួតហើយ ស្ងិតស្រពោន ហើយ ធ្វើឱ្យវិនាសហើយ ដោយហេតុនោះ ទើបព្រះអង្គត្រាស់ថា កម្ចាត់បង់ បាននូវ **អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោក គឺ កាយ , សេចក្តីនៃបទ ទាំងនោះ ខ្ញុំម្ចាស់បានពោលទុកហើយដូចដែលពណ៌នាមកនេះ អ្នកសិក្សាគប្បី ជ្រាបន័យនៃអដ្ឋកថានេះព្រមដោយន័យនោះ ដោយការប្រៀបធៀបគ្នាចុះ ។

នេះជា កថាពណ៌នាសេចក្តីនៃឧទ្ទេសរបស់ **កាយានុបស្សនាសតិប្ប-ដ្ឋាន** ដូច្នេះ ។

## អធិប្បាយ វេទនានុបស្សនា

ឥឡូវនេះ អ្នកសិក្សាគប្បីជ្រាបប្រយោជន៍ក្នុងការពោលដដែល ៗ នូវ **វេទនា** ជាដើម ក្នុងពាក្យមានជាអាទិយ៉ាងនេះថា **វេទនាសុ វេទនានុបស្សី វិហរតិ** ( ដែលមានរួម នៅក្នុងពាក្យនេះថា **វេទនាសុ ចិត្តេ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ល ។ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ដោយន័យដូចដែលបាន ពោលទុកហើយក្នុង **កាយានុបស្សនា** ។

ក៏ក្នុងពាក្យថា **វេទនាសុ វេទនានុបស្សី វិហរតិ ចិត្តេ ចិត្តា-នុបស្សី ធម្មេសុ ធម្មានុបស្សី** នេះ ពាក្យថា **វេទនា** បានដល់ វេទនា ៣ ហើយវេទនានោះ ជា **លោកិយ** តែម្យ៉ាង សូម្បីចិត្តក៏ដូចគ្នា ជា **លោកិយ** ។ **ធម៌** ក៏ដូច្នោះដូចគ្នា ( ជា **លោកិយ** ) ។ ការចែកវេទនា ជាដើមទាំងនោះនឹងប្រាកដក្នុង **និទ្ទេសវារៈ** ។ ប៉ុន្តែក្នុងទីនេះគប្បីជ្រាបការ ចែកវេទនាសុទ្ធ ៗ ទុកថា វេទនាត្រូវពិចារណាឃើញ យ៉ាងណា ព្រះយោ-

គាវចរ កាលបើពិចារណាឃើញយ៉ាងនោះ ក៏ឈ្មោះថា ពិចារណាឃើញវេទនាក្នុងវេទនា ។ ក្នុង **ចិត្តានុបស្សនា** និង **ធម្មានុបស្សនា** ក៏ន័យនេះដូចគ្នា ។

សួរថា ក៏វេទនាគួរពិចារណាឃើញ ដូចម្តេច ?

ឆ្លើយថា មុនដំបូង **សុខវេទនា** គួរពិចារណាឱ្យឃើញដោយភាព ជាទុក្ខ **ទុក្ខវេទនា** គួរពិចារណាឱ្យឃើញថា ដូចជា **កូនសរ** , **អទុក្ខ_មសុខវេទនា** ( វេទនាមិនទុក្ខមិនសុខ ) គួរពិចារណាឱ្យឃើញថា ជា របស់មិនទៀង ។ ដូចដែលត្រាស់ទុកថា ÷

**ភិក្ខុរូបណាបានឃើញសេចក្តីសុខដោយភាពជាទុក្ខ បានឃើញ**
**សេចក្តីទុក្ខថា ដូចជាកូនសរ បានឃើញសេចក្តីមិនទុក្ខមិនសុខ**
**ដែលមាននៅ ដោយជារបស់មិនទៀងហើយ ភិក្ខុរូបនោះជា**
**អ្នកឃើញប្រពៃ និង ជាអ្នកស្ងប់ ត្រាច់ទៅ ។**

ក៏វេទនាគ្រប់យ៉ាងនេះ គួរពិចារណាឱ្យឃើញថា ជាទុក្ខ ។ សមពិតតាមដែលព្រះមានព្រះភាគជាម្ចាស់បានត្រាស់ទុកថា ធម្មជាតិឯណានីមួយដែលបានសោយហើយ តថាគតពោលធម្មជាតិនោះទាំងអស់ថា ( រួមចុះក្នុង ) ទុក្ខ ,

ម្យ៉ាងទៀត **សុខវេទនា** ក៏គួរពិចារណាឱ្យឃើញថា ជាទុក្ខ ។ ដូចដែលត្រាស់ទុកថា វេទនានេះជាសុខ សុខក្នុងពេលដែលតាំងនៅ , ជា **វិបរិណាមទុក្ខ** ទុក្ខ ព្រោះប្រែប្រួល ព្រោះដូច្នោះ គួរធ្វើឱ្យពិស្តារគ្រប់ ប្រការ ។

ម្យ៉ាងទៀត វេទនាក៏គួរពិចារណាឱ្យឃើញសូម្បីដោយ **អនុបស្សនា** ទាំង ៧ មាន **អនិច្ចានុបស្សនា** ជាដើម ។ ពាក្យដ៏សេសនឹងមានប្រាកដ ក្នុង **និទ្ទេសវារៈ** នោះឯង ។

សូម្បីបណ្តាចិត្ត និង ធម៌ ចិត្តក៏គួរពិចារណាឱ្យឃើញដោយការចែកចេញទៅជាចិត្ត មានរាគៈជាដើម ដែលមានមកហើយក្នុងនិទ្ទេសវារៈនៃ **អនិច្ចានុបស្សនា** ជាដើម ដែលចែកចេញផ្សេង ៗ គ្នា **មានអារម្មណ៍ អធិបតី សហជាត ធម៌ ភូមិ កម្ម វិបាក** និង **កិរិយា** ជាដើម ។

( ធម៌ ) ក៏គួរពិចារណាឱ្យឃើញដោយលក្ខណៈរបស់ខ្លួន ( វិសេសលក្ខណៈ ) និង លក្ខណៈដែលស្មើគ្នា ( សាមញ្ញលក្ខណៈ ) របស់ធម៌ ។ ដោយ **សុញ្ញតធម៌** ដោយ **អនុបស្សនាទាំង ៧** មាន **អនិច្ចានុបស្សនា** ជាដើម និង ដោយចែកចេញជា **សន្តធម៌** ( ធម៌ដែលស្ងប់ ) និង **អសន្តធម៌** ( ធម៌ដែលមិនស្ងប់ ) ជាដើម ដែលមកហើយក្នុងនិទ្ទេសវារៈ ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយ នោះឯង ។

ក៏ក្នុងការលះ **អភិជ្ឈា** និង **ទោមនស្ស** ជាដើមនេះ អ្នកណា កម្ចាត់បង់ **អភិជ្ឈា** និង **ទោមនស្ស** ក្នុងលោក ពោលគឺកាយបាន ហើយអ្នកនោះក៏លះ **អភិជ្ឈា** និង **ទោមនស្ស** សូម្បីក្នុងលោក គឺ វេទនាជាដើម បាននោះឯងក៏ពិតតែព្រះអង្គក៏បានត្រាស់គ្រប់ ៗ និទ្ទេសវារៈ ដោយបុគ្គលផ្សេងគ្នា និងដោយ **សតិប្បដ្ឋានភាវនា** ដែលប្រាកដទេឡើង ក្នុងខណៈចិត្តផ្សេងគ្នា ។ ម្យ៉ាងទៀតគប្បីជ្រាបថា ដោយហេតុដែល អភិជ្ឈា និង ទោមនស្ស ដែលលះបានក្នុងវារៈមួយហើយ ជាការដែលលះបាន សូម្បីក្នុងវារៈដ៏សេសនោះឯង ដើម្បីទ្រង់សម្តែងការលះ អភិជ្ឈា និងទោមនស្សទុកក្នុងវារៈនោះ ទើបបានត្រាស់ទុកយ៉ាងនេះ ដូច្នេះឯង ។

**( ចប់ អដ្ឋកថាពោលដោយឧទ្ទេសវារៈ )**

## សមាធិ ៤

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់មានពុទ្ធបំណងនឹងឱ្យសត្វទាំងឡាយ សម្រេចគុណវិសេសច្រើនប្រការ ដោយព្រះធម៌ទេសនាពោលដោយ **សតិ-ប្បដ្ឋាន** ទើបទ្រង់ចែក **សម្មាសមាធិ** ចេញជា ៤ តាមអារម្មណ៍ ដោយ មានន័យជាអាទិថា **សតិប្បដ្ឋាន** មាន ៤ យ៉ាង , ៤ យ៉ាង តើអ្វីខ្លះ ? គឺ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនះ ពិចារណាឃើញកាយក្នុងកាយ ដូច្នេះហើយ តទៅ កាលនឹងទ្រង់លើកយក **សតិប្បដ្ឋាន** នីមួយ ៗ មកចែក ចេញទៅ ( ទៀត ) ទើបបានទ្រង់ប្រារព្ធដើម្បីត្រាស់និទ្ទេសវារៈទុក ដោយន័យ មានជាអាទិថា **កថញ្ច ភិក្ខវេ** ( ម្នាលភិក្ខុទាំងឡាយ តើដូចម្តេច ? ) ឧបមាដូចជាងតម្បាញដែលឆ្លាត ប្រាថ្នានឹងធ្វើគ្រឿងប្រើប្រាស់មានកន្ទេល កក់ កន្ទេលចែងម៉ែង ក្លាក់ ហិប និង កញ្ច្រែង ជាដើម , បានឫស្សីធំ ១ ដើមមក ពុះចេញជា ៤ ចម្រៀក , យកតែមួយចម្រៀកមក ( ពុះឱ្យជាបន្ទះ ) ហើយត្បាញជាគ្រឿងប្រើប្រាស់ ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **កថញ្ច** ជាដើម ជាពាក្យសួរ ដោយ ទ្រង់បំណងនឹងត្រាស់ឆ្លើយឱ្យពិស្តារដោយព្រះអង្គឯង ។ ក៏ក្នុងបទនេះ មាន អត្ថាធិប្បាយដោយសង្ខេប ដូចតទៅនេះ ម្នាលភិក្ខុទាំងឡាយ ដោយប្រការ ដូចម្តេច ? ភិក្ខុទើបជាអ្នកពិចារណាឃើញកាយក្នុងកាយ ។ ន័យនេះមាននៅ ក្នុងគ្រប់វារៈនៃពាក្យសួរ ។

បទថា **ឥធ ភិក្ខវេ ភិក្ខុ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង សាសនានេះ ។ ព្រោះថា **ឥធ** សព្ទនេះ ក្នុងពាក្យថា **ឥធ ភិក្ខវេ ភិក្ខុ** នេះ បញ្ជាក់ដល់សាសនា ដែលជាទីពំនាក់អាស្រ័យរបស់បុគ្គលអ្នកឱ្យកើត **កា-**

**យានុបស្សនា** គ្រប់ប្រការ និង បដិសេធសាសនាដទៃថា មិនជាយ៉ាងនោះ ។ សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ក្នុងសាសនានេះប៉ុណ្ណោះ មានសមណៈ , សាសនាដទៃ ( បរប្បវាទៈ លទ្ធិ ដទៃ ) សាបសូន្យចាកសមណៈពួកដទៃ ។ ដោយហេតុនោះ ទើបព្រះអង្គ ត្រាស់ទុកថា ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា **អរញ្ញគតោ វា ។ បេ ។ សុញ្ញាគារគតោ វា** ( ទៅ កាន់ព្រៃ ។ ល ។ ឬ ទៅកាន់ផ្ទះស្ងាត់ ) នេះជាពាក្យសម្តែងដល់ការទ្រង់កំណត់សេនាសនៈ ដ៏សមគួរដល់ការបំពេញ **សតិប្បដ្ឋាន** ទុក ។

## ឧបមា ចិត្តដូចកូនគោ

ព្រោះថា ចិត្តរបស់ភិក្ខុនេះ ដែលត្រាច់ទៅក្នុងរូបារម្មណ៍ជាដើមមកជាយូរហើយ មិនប្រាថ្នានឹងចូលគន្លងកម្មដ្ឋាន រត់ចេញក្រៅផ្លូវតែម្យ៉ាងប៉ុណ្ណោះ ដូចរថដែលទឹមដោយគោខូចក៏ដូចគ្នា ព្រោះដូច្នោះ ទើបឧបមាថា អ្នកចិញ្ចឹម គោ ( ម្ចាស់គោ ) កាលប្រាថ្នានឹងហ្វឹកហាត់កូនគោខូច ដែលផឹកទឹកដោះគ្រប់តំណក់អំពីមេគោខូច ធំធាត់ទេឡើងមកត្រូវពង្រាត់ ( វា ) ចេញពីមេ ដាំបង្គោលធំមួយទុកក្នុងទីដ៏សមគួរហើយ យកខ្សែចង ( វា ) ទុកនឹងបង្គោលនោះ ។ លុះកូនគោនោះ ស្ទុះលោតទៅខាងនោះ ខាងនេះ ក៏មិនអាចគេចចេញទៅបាន នឹងត្រូវឈរជិត ឬ ដេកជិតបង្គោល នោះឯង យ៉ាងណា ។ ភិក្ខុរូបនេះឯង ក៏ដូច្នោះដូចគ្នា កាលប្រាថ្នានឹងទូន្មានចិត្តខូចរបស់ខ្លួន ដែលចម្រើនទេឡើងអំពីការក្រេបរសរូបារម្មណ៍ ជាដើមមកជាយូរហើយ ត្រូវពង្រាត់វាអំពីរូបារម្មណ៍ជាដើមចូលទៅកាន់ព្រៃ ឬ រុក្ខមូល ឬ ផ្ទះស្ងាត់ យកខ្សែ គឺ សតិចងវាទុកនឹងបង្គោល គឺ អារម្មណ៍របស់ **សតិប្បដ្ឋាន** នោះ ។ ចិត្តរបស់ភិក្ខុ

នោះសូម្បីនឹងរើបម្រះទៅខាងនោះ ខាងនេះ យ៉ាងនេះ កាលមិនបានអារម្មណ៍ដែលធ្លាប់សេពមកពីមុន មិនអាចនឹងទំលាយខ្សែ គឺ សតិ ( ឱ្យដាច់ ) ហើយគេចចេញទៅ ក៏នឹងដួលជ្រប់ ហើយស្ងៀមនៅនឹងអារម្មណ៍នោះឯង ដោយ **ឧបចារសមាធិ** ។ ដោយហេតុនោះ ព្រះបុរាណាចារ្យ ទើបបានពោលទុក ថា ÷

> **ព្រះយោគាវចរ ( អ្នកបំពេញសេចក្ដីព្យាយាម ) ត្រូវយក**
> **សតិចងចិត្តរបស់ខ្លួនទុកនឹងអារម្មណ៍ ( កម្មដ្ឋាន ) ឱ្យមាំ**
> **ដូចមនុស្សក្នុងលោកនេះ កាលនឹងហ្វឹកហាត់គោ ត្រូវចងគោ**
> **ដែលនឹងត្រូវហ្វឹកហាត់ទុកនឹងបង្គោល ដូច្នោះ ។**

សេនាសនៈនោះ ជាសេនាសនៈសមគួរដែលនឹងបំពេញ ( កម្មដ្ឋាន ) សម្រាប់លោក ដោយប្រការដូចដែលពណ៌នាមកនេះ ។ ដោយហេតុនោះ ព្រះអង្គទើបបានត្រាស់ថា **អរញ្ញគតោ វា ។ បេ ។ សុញ្ញាគារគតោ វា** នេះ បញ្ជាក់ដល់ការកំណត់សេនាសនៈដ៏សមគួរដល់ការបំពេញ **សតិប្បដ្ឋាន** ។

## សំទេឡងជាសត្រូវចំពោះឈាន

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះយោគាវចរលះបង់សេនាសនៈចុងស្រុកដែលគឹកកង ដោយសំទេឡងស្ត្រី សំទេឡងបុរស សំទេឡងដំរី សំទេឡងសេះជាដើម មិនបាននឹងញ៉ាំងអានាបានស្សតិកម្មដ្ឋាន ដែលជាកំពូលនៃកាយានុ-បស្សនា ជាហេតុជិតនៃការសម្រេចគុណវិសេស និង **ទិដ្ឋធម្មសុខវិហារធម៌របស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និង ព្រះសាវកគ្រប់ ៗ ព្រះអង្គនេះ ឱ្យសម្បូណ៌ មិនមែនរបស់ដែលនឹងធ្វើបានងាយ** ព្រោះឈានមានសំទេឡងជាសត្រូវ ( ឧបសគ្គ ) ។ តែក្នុងព្រៃដែលមិនមានភូមិ ការកំណត់យកព្រះ

កម្មដ្ឋាននេះហើយ ញុំាងឈានទី ៤ មានអានាបានស្សតិជាអារម្មណ៍ ធ្វើឈាននោះឯងឱ្យជាបាទ ( របស់វិបស្សនា ) ពិចារណាសង្ខារធម៌ហើយ បានសម្រេចអរហត្ត ដែលជាផលដ៏កំពូល ជារបស់ដែលព្រះយោគាវចរធ្វើ បានងាយ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្ដែងសេនាសនៈដ៏សមគួរដល់ព្រះ_យោគាវចរនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ដូច្នេះ ជាដើម ។

ដោយថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ដូចជាអាចារ្យអ្នកដែលចេះជ័យភូមិ ( អ្នកត្រួតមើលភូមិ ឬ អ្នកធរណីវិទ្យា ) ។ ព្រះអង្គលុះទ្រង់ពិចា_រណាឃើញសេនាសនៈដែលសមគួរដល់ព្រះយោគាវចរយ៉ាងនេះហើយ ទើបទ្រង់បង្ហាញថា គួរបំពេញព្រះកម្មដ្ឋានក្នុងទីនេះ តអំពីនេះទៅ ព្រះយោគី ( ភិក្ខុអ្នកបំពេញព្យាយាម ) បំពេញកម្មដ្ឋាន កាលបានសម្រេចព្រះអរហត្តតាមលំដាប់ហើយ ព្រះអង្គទ្រង់ទទួលសក្ការៈយ៉ាងច្រើនសន្ធឹកសន្ធាប់ ដោយពាក្យសរសើរថា ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនោះ ទ្រង់ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ( ពិត ៗ ) ហ្ន៎ ដូចអាចារ្យដែលចេះជ័យភូមិមើលផ្ទៃដីដែលនឹងត្រូវសាងព្រះនគរហើយ ពិចារណាមើលសព្វគ្រប់ហើយចង្អុលប្រាប់ថា អ្នកទាំងទឡាយចូរសាងព្រះនគរក្នុងទីនេះ ហើយកាលព្រះនគរសាងសម្រេចដោយសិរីសួស្ដី ( រៀបរយ ) ហើយ នឹងបានទទួលព្រះរាជទានសក្ការៈច្រើនសន្ធឹកសន្ធាប់ អំពីព្រះរាជត្រកូល ដូច្នោះ ។

## ទ្រង់ប្រៀបភិក្ខុដូចខ្លាដំបង

តែភិក្ខុរូបនេះ លោកពោលថា ដូចជាខ្លាដំបង អធិប្បាយថា ស្ដេចខ្លាធំអាស្រ័យក្នុងព្រៃក្រាស់ ឬ ព្រៃស្មៅក្រាស់ក្នុងព្រៃ ពួនចាំចាប់ពួកម្រឹគមានក្របីព្រៃ ក្ដាន់ និង ជ្រូកព្រៃជាដើម ( ស៊ី ) យ៉ាងណាមិញ ភិក្ខុនេះ

ក៏ដូច្នោះដូចគ្នា បំពេញកម្មដ្ឋានរឿយ ៗ ក្នុងព្រៃជាដើម និង សម្រេចអរិយ- មគ្គ ៤ អរិយផល ៤ តាមលំដាប់ ។ ព្រោះដូច្នោះ ព្រះបុរាណាចារ្យ ទើបបានពោលទុកថា ÷

**ភិក្ខុអ្នកជាពុទ្ធបុត្រ បំពេញវិបស្សនា ប្រកបសេចក្តី**
**ព្យាយាមនេះ ចូលទៅកាន់ព្រៃ ហើយសម្រេចព្រះអរ-**
**ហត្តផល ដូចខ្លាដំបងព្ធួនចាំចាប់ម្រឹគស៊ី ដូច្នោះ ។**

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែង សេនាសនៈក្នុងព្រៃ ដែលជាសេនាសនៈដ៏សមគួរដល់ការប្រញាប់ប្រញាល់ក្នុង ការប្រកបសេចក្តីព្យាយាមដល់ភិក្ខុនោះ ទើបបានត្រាស់ទុកថា **អរញ្ញគតោ វា** ដូច្នេះ ជាដើម ។

តអំពីនេះទៅ ពាក្យណា ដែលខ្ញុំម្ចាស់នឹងត្រូវពោល ( អធិប្បាយ ) ក្នុង **អានាបានបព្វៈ** នេះ ពាក្យនោះ ខ្ញុំម្ចាស់បានពោលទុកក្នុង **គម្ពីរវិសុទ្ធិមគ្គ** នោះហើយ ។

## ចម្រើនអានាបានស្សតិ

ក៏កាលព្រះយោគាវចរនោះ សិក្សាដោយអំណាចនៃខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញទាំងនេះ ដែលព្រះមានព្រះភាគជាម្ចាស់បានត្រាស់ ទុកយ៉ាងនេះថា ភិក្ខុសិក្សាថា កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឈានទាំង ៤ នឹងកើតទឡើង ព្រោះក្នុង **និមិត្ត** គឺ **អស្សាស** និង **បស្សាស** ។

លោកចេញចាកឈានហើយ កំណត់ខ្យល់ដកដង្ហើមចេញ ខ្យល់ដក- ដង្ហើមចូល ឬ កំណត់អង្គឈាន, ក្នុងចំនួន **អស្សាសបស្សាសៈ** និង អង្គ

ឈានទាំង ២ យ៉ាងនោះ ។ ( បើ ) ជាអ្នកកំណត់ **អស្សាសបស្សាសៈ** ជាអារម្មណ៍ ក៏កំណត់រូបយ៉ាងនេះថា **អស្សាសបស្សាសៈ** អាស្រ័យនឹងអ្វី ? អាស្រ័យនឹង **វត្ថុ** , **ករជកាយ** ឈ្មោះថា **វត្ថុ** ។ **មហាភូតរូប ៤** និង **ឧបាទាយរូប ( ២៤ )** ឈ្មោះថា **ករជកាយ** ។

តមក កំណត់នាមរូបយ៉ាងនេះថា នាមមាននៅក្នុងអារម្មណ៍នោះ មានផស្សៈជាទី ៥ កាលស្វែងរកបច្ច័យរបស់នាមរូបនោះ នឹងឃើញ **បដិច្ច-សមុប្បាទ** មាន **អវិជ្ជា** ជាដើម ឆ្លងសេចក្ដីសង្ស័យបានថា នេះត្រឹមតែ
ជាបច្ច័យ និង ធម៌ដែលអាស្រ័យបច្ច័យកើតទេឡើងប៉ុណ្ណោះ មិនមានសត្វ ឬ បុគ្គលដទៃផ្សេង ( ពី **អស្សាសបស្សាស** នោះ ) លើកយកនាមរូបព្រមទាំងបច្ច័យទេឡើងកាន់ត្រៃលក្ខណ៍ ចម្រើន **វិបស្សនា** សម្រេចព្រះអរហត្តផលតាមលំដាប់ ។

នេះជាផ្លូវនៃការចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្តរបស់ភិក្ខុមួយរូប ។

ចំណែកអ្នកកំណត់ឈានជាអារម្មណ៍ និង កំណត់នាមរូបថា អង្គឈានទាំងទឡាយទាំងនេះ អាស្រ័យនឹងអ្វី ? អាស្រ័យនឹងវត្ថុ , ករជកាយឈ្មោះថា **វត្ថុ** អង្គឈាន ជានាម , **ករជកាយ** ជារូប កាលស្វែងរកបច្ច័យនៃនាមរូបនោះនឹងឃើញ **បច្ចយាការ** មាន **អវិជ្ជា** ជាដើម កន្លងសេចក្ដីសង្ស័យចេញបានថា នេះត្រឹមតែជាបច្ច័យ និង ធម៌ដែលអាស្រ័យបច្ច័យកើតទេឡើងប៉ុណ្ណោះ មិនមានសត្វ ឬ បុគ្គលផ្សេង ( អំពី នាមរូបនោះ ) លើកយកនាមរូបព្រមទាំងបច្ច័យទេឡើងកាន់ត្រៃលក្ខណ៍ ចម្រើន **វិបស្សនា** សម្រេចអរហត្តតាមលំដាប់ , នេះជាផ្លូវនៃការចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្តរបស់

## ៥៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ភិក្ខុមួយរូប ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ គឺ ខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូលរបស់ខ្លួន យ៉ាងនេះ ។

បទថា **ពហិទ្ធា វា** សេចក្តីថា ឬ ( ពិចារណាឃើញកាយ ) ក្នុង កាយ គឺ ខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូលរបស់អ្នកដទៃ ។

បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្តីថា ក្នុងកាយ គឺ ដកដង្ហើមចេញ ដកដង្ហើមចូលរបស់ខន្ធ ( និង ) របស់អ្នកដទៃតាមកាលវេលា យ៉ាងនេះ ។

ដោយបទថា **អជ្ឈត្តពហិទ្ធា វា** នេះ ព្រះអង្គត្រាស់ដល់កាលវេលាដែលខ្យល់ដកដង្ហើមនោះ ចេញ ៗ ចូល ៗ ដោយមិនបញ្ឈប់កម្មដ្ឋានដែលស្ទាត់ជំនាញទុក ។ តែទាំង ២ យ៉ាងនេះ នឹងមានក្នុងវេលាតែមួយជាមួយគ្នាមិនបាន ។

បទថា **សមុទយធម្មានុបស្សី វា** សេចក្តីថា ឧបមាដូចស្នប់របស់ ជាងមាសទាំងដងស្នប់ និង សេចក្តីព្យាយាមដែលកើតអំពីរបស់ ទាំង ២ យ៉ាងនោះ ( ស្នប់ និង ដងស្នប់ ) ខ្យល់ទើបកើត ដើរទៅមកបាន យ៉ាងណា_មិញ ។ កាយ គឺ **អស្សាសបស្សាស** របស់ភិក្ខុក៏ដូច្នោះ អាស្រ័យ **ករជកាយ ក្តោងច្រមុះ** និង **ចិត្ត** ទើបសញ្ចរទៅមកបាន ។ ធម៌ទាំងទឡាយ មានកាយជា ដើម ជាសមុទយៈ ភិក្ខុកាលពិចារណាធម៌ទាំងនោះ ហៅថា ពិចារណាឃើញ រឿយ ៗ នូវធម៌ដែលប្រជុំកើតទេឡើងក្នុងកាយ ។

បទថា **វយធម្មានុបស្សី វា** សេចក្តីថា កាលកាយបែកធ្លាយ ក្តោងច្រមុះត្រូវកម្ចាត់ហើយ និង កាលចិត្តរលត់ ដែលឈ្មោះថា កាយ គឺ អស្សាសៈ និង បស្សាសៈ នឹងសញ្ចរមិនបាន ដូចកាលស្នប់ត្រូវនាំចេញទៅហើយ កាល

ផងស្ងប់បាក់ និង កាលមិនមានសេចក្តីព្យាយាមដែលកើតអំពីស្ងប់ និង ផង ស្ងប់នោះ ខ្យល់នោះនឹងមិនដើរដូច្នោះ ព្រោះដូច្នោះ ខ្យល់ដកដង្ហើមចេញ និង ដកដង្ហើមចូលរលត់ទៅ ព្រោះកាយជាដើមបែកធ្លាយទៅ ភិក្ខុកាលពិចា-រណាឃើញយ៉ាងនេះ ទើបព្រះអង្គត្រាស់ហៅថា ពិចារណាឃើញរឿយ ៗ នូវធម៌ដែលសូន្យទៅក្នុងកាយ ។

បទថា **សមុទយវយធម្មានុបស្សី** សេចក្តីថា ពិចារណាឃើញការកើតតាមកាលវេលា រលត់ទៅតាមកាលវេលា ។

បទថា **អត្ថិ កាយោតិ វា បនស្ស** សេចក្តីថា **សតិ** ជាកាលដែលលោកចូលទៅតាំងទុកយ៉ាងនេះថា កាយមានមែន តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ដែលជាប់ដោយខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនអ្នកណា មិនមែនរបស់អ្នកណា ។

ពាក្យថា **យាវទេវ** នេះ ជាពាក្យកំណត់ការបង្ហាញប្រយោជន៍ ។ មានពាក្យអធិប្បាយថា **សតិ** ដែលចូលទៅតាំងទុកនោះ មិនមែនដើម្បីប្រយោជន៍យ៉ាងដទៃ ។ ដោយពិត ត្រឹមតែដើម្បីការដឹងប៉ុណ្ណោះ គឺ ដើម្បីប្រយោជន៍ដល់ញាណដ៏ក្រៃលែងជាប្រមាណនៃការដឹងដ៏ក្រៃលែង ៗ និង ដើម្បីត្រូវការសតិជាប្រមាណ អធិប្បាយថា ដើម្បីត្រូវការឱ្យសតិ និង សម្បជញ្ញៈចម្រើនទៀង ។

បទថា **អនិស្សិតោ ច វិហរតិ** សេចក្តីថា ជាអ្នកមិនអាស្រ័យ ( អ្វី ) ដោយអំណាចនៃ **តណ្ហានិស្សយ** និង **ទិដ្ឋិនិស្សយ** សេចក្តីថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ** ( ហើយលោកមិនប្រកៀកប្រកាន់អ្វីតិចតួច

ក្នុងលោក ) សេចក្ដីថា លោកនឹងមិនប្រកាន់អ្វី គឺ រូប ។ ល ។ ឬ វិញ្ញាណ ក្នុងលោកថា នេះជាខ្លួន ឬ របស់ដែលជាប់ដោយខ្លួន របស់យើង ។

**បិ** អក្សរ ក្នុងពាក្យថា **ឯវំបិ** ប្រើក្នុងសេចក្ដីថា រួមយកសេចក្ដីខាងមុខមកទុក ។ម្យ៉ាងទៀត ដោយបទនេះ ព្រះមានព្រះភាគទ្រង់សម្ដែងព្រះធម្មទេសនាពោលដោយ **អានាបានបព្វ** ប្រគល់ឱ្យ ( សាវ័កទាំងទឡាយ ) ដូច្នេះឯង ។

## អរិយសច្ច ៤ ក្នុងអានាបាន

បណ្ដា **សច្ច** ទាំងនោះ **សតិ** ដែលកំណត់ **អស្សាស** និង **បស្សាស** ជា **ទុក្ខសច្ច** តណ្ហាដែលមានមកអំពីមុនជាសមុដ្ឋានរបស់សតិនោះជា **ទុក្ខ-សមុទយសច្ច** ការមិនប្រព្រឹត្តិទៅនៃ **សតិ** និង **តណ្ហា** ទាំងពីរយ៉ាងនោះជា **និរោធសច្ច** អរិយមគ្គដែលមានការកំណត់ដឹងទុក្ខ មានការលះ **សមុទយ-សច្ច** មាន **និរោធសច្ច** ជាអារម្មណ៍ ជា **មគ្គសច្ច** ។

លោកខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចព្រះ ( និព្វាន ) ដូច្នោះ សេចក្ដីនេះទើបជាផ្លូវនៃការចេញចាក ( ទុក្ខ ) រហូតដល់អរហត្តរបស់ភិក្ខុអ្នកមិនប្រកាន់មាំ ដោយអំណាច **អស្សាស** និង **បស្សាស** មួយរូប ។

**( ចប់ អានាបានបព្វៈ )**

..........

## ពិចារណាកាយដោយឥរិយាបថ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកការពិចារណាមើលកាយដោយអស្សាសៈ និង បស្សាសៈយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយឥរិយាបថ ទើបត្រាស់ពាក្យមានជាអាទិទុកថា **បុន ច បរំ** ។

នឹងវិនិច្ឆ័យក្នុងបទទាំងនោះតទៅ ÷

## ការដឹង ដែលជាសតិប្បដ្ឋានភាវនា

សូម្បីឆ្កែស្រុក និង ឆ្កែចចក កាលដើរទៅ ក៏ដឹងដោយពិតថា យើងកំពុងដើរ ។ តែការដឹងនោះ ព្រះអង្គមិនបានត្រាស់សំដៅយកការដឹងបែប នេះទេ ។ ព្រោះថា ការដឹងបែបនេះលះ **សត្តូបលទ្ធិ** ( ការប្រកាន់ថា ជាសត្វ ) មិនបាន ។ ដក **អត្តសញ្ញា** ( សេចក្តីសម្គាល់ថា ជាអត្តា ) មិនបាន ។ មិនជា **កម្មដ្ឋាន** ឬ **សតិប្បដ្ឋានភាវនា** ។

តែការដឹងរបស់ភិក្ខុនេះលះ **សត្តូបលទ្ធិ** បាន ដក **អត្តសញ្ញា** បាន **ជាកម្មដ្ឋាន** ឬ **ជាសតិប្បដ្ឋានភាវនា** ។

សេចក្តីពិត ការដឹងនេះ ព្រះអង្គត្រាស់សំដៅយកការដឹងខ្លួនយ៉ាងនេះ ថា នរណាដើរ ? ការដើររបស់នរណា ? ដើរបានព្រោះអ្វី ? សូម្បីក្នុង ការឈរក៏ន័យនេះដូចគ្នា ។

បណ្តាបទទាំងនោះ បទថា **នរណាដើរ** សេចក្តីថា មិនមែនសត្វ ណា ឬ បុគ្គលណាដើរ ។

បទថា **ការដើររបស់នរណា** សេចក្តីថា មិនមានការដើររបស់ សត្វណា ៗ ទេឡើយ ។

បទថា **ដើរបានព្រោះអ្វី** សេចក្តីថា ដើរទៅបានព្រោះការផ្សាយទៅនៃ

វាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត ។

## វាយោធាតុកើតអំពីចិត្ត

ព្រោះដូច្នោះ ភិក្ខុនេះ នឹងដឹងច្បាស់ ( ឥរិយាបថ ) យ៉ាងនេះថា ចិត្ត ( ការគិត ) កើតទេឡើងថា យើងនឹងដើរ ចិត្តនោះនឹងឱ្យវាយោកើត នឹងឱ្យការកម្រើកវាយោកើត ។ ការកម្រើកកាយទាំងអស់ទៅខាងមុខ ដោយការផ្សាយទៅនៃវាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការដើរ** ។ សូម្បីក្នុងការឈរជាដើម ក៏មានន័យនេះដូចគ្នា ។

សូម្បីក្នុងការឈរជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ចិត្ត ( ការគិត ) កើតទេឡើងថា យើងនឹងឈរ ចិត្តនោះនឹងឱ្យវាយោកើត នឹងឱ្យការកម្រើកវាយោកើត ។

ភាវៈដែលកាយទាំងអស់ តាំងពីទីបំផុត (គឺ ពីក្បាលដល់ចុងជើង ) ទាញទេឡើងដោយការផ្សាយនៃវាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការឈរ** ។

ចិត្តកើតទេឡើងថា យើងនឹងអង្គុយ ចិត្តនោះនឹងឱ្យវាយោកើត នឹងឱ្យការកម្រើកវាយោកើត ការបត់កាយចំណែកខាងក្រោមចូល ទាញកាយចំណែកខាងលើទេឡើង ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការអង្គុយ** ។

ចិត្តកើតទេឡើងថា យើងនឹងដេក ចិត្តនឹងឱ្យវាយោនោះកើត នឹងឱ្យការកម្រើកវាយោកើត ។ ការសណ្ដូករាងកាយទាំងអស់ចេញទៅខាងបណ្ដោយ ដោយការផ្សាយទៅនៃវាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត ហៅថា **ការ ដេក** ។

កាលភិក្ខុនោះដឹងច្បាស់យ៉ាងនេះ រមែងមានការគិតឃើញយ៉ាងនេះថា គេហៅថា **សត្វដើរ សត្វឈរ** ។

សួរថា មានសត្វណាដើរឬ ឈរឬ ?

ឆ្លើយថា មិនមាន ។

តែដូចពាក្យដែលហៅថា រទេះទៅ រទេះឈប់ ។ ក៏មិនមានអ្វីដែលឈ្មោះថា រទេះនឹងទៅ ឬ នឹងឈប់ ។ តែកាលសារថីអ្នកឈ្លាសវៃទឹមគោ ៤ បរទៅ ក៏នឹងមានត្រឹមតែការសន្មតិគ្នាថា រទេះទៅ រទេះឈប់ យ៉ាងណា ។ កាយដូចរទេះ ព្រោះអត្ថថា មិនដឹង ខ្យល់ដែលកើតអំពីចិត្ត ដូចគោ , ចិត្តដូចសារថី កាលចិត្តកើតទេឡើងថា យើងនឹងដើរ វាយោធាតុដែលនឹងឱ្យកើត វិញ្ញត្តិក៏នឹងកើតទេឡើង ការដើរទៅជាដើម នឹងប្រព្រឹត្តទៅដោយការផ្សាយរបស់វាយោធាតុដែលកើតអំពីកិរិយារបស់ចិត្ត នឹងមានត្រឹមតែការសន្មតិគ្នាថា សត្វដើរ សត្វឈរ ខ្ញុំទៅ ខ្ញុំឈរ ដូច្នោះដូចគ្នា ។

> **ទូកស្ទុះទៅបាន ព្រោះកម្លាំងរបស់ខ្យល់ កូនសរស្ទុះទៅបាន ព្រោះកម្លាំងរបស់ខ្សែ យ៉ាងណា រាងកាយនេះក៏ដូច្នោះ ដើរទៅបាន ព្រោះខ្យល់ ( ខាងក្នុង ) បក់ ។ សូម្បីសរីរយន្តនេះ ដែល ( នាយជាង គឺ តណ្ហាសាងទុក ) ដើរ ឈរ អង្គុយបានដោយអំណាចនៃខ្សែញាក់ គឺចិត្ត , ដូចរូបទីងមោងកម្រើកបាន ដោយអំណាចរបស់ខ្សែញាក់ ។ ក្នុងរឿងនេះ នឹងមានសត្វណា ក្រៅអំពីហេតុបច្ច័យដែលឈរ ឬ ដើរទៅ ដោយអានុភាពរបស់ខ្លួន ។**

ព្រោះដូច្នោះ ព្រះយោគាវចរនោះ កំណត់នូវឥរិយាបថដើរជាដើម

ដែលប្រព្រឹត្តទៅ ដោយហេតុ និង បច្ច័យប៉ុណ្ណោះយ៉ាងនេះ គប្បីជ្រាបចុះថា បុគ្គលនោះកាលដើរ ក៏ដឹងច្បាស់ថា យើងដើរ ( កាលឈរ អង្គុយ ឬ ដេក ) ក៏ដឹងច្បាស់ថា យើងឈរ អង្គុយ ឬ ដេក ។

ពាក្យថា **យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតិ** ( ឬក៏ថា លោករមែងដឹងច្បាស់ កាយនោះ តាមដែលខ្លួនតម្កល់នៅ ដោយអាការយ៉ាងណា ៗ ហើយ ) នេះ ជាពាក្យប្រមូលឥរិយាបថគ្រប់យ៉ាងទុក ។

មានពាក្យអធិប្បាយទុកដូចតទៅនេះថា កាយរបស់លោកស្ថិតនៅហើយ ដោយអាការណា ៗ លោកក៏ដឹងច្បាស់កាយនោះ ដោយអាការនោះ ៗ គឺ ដឹងច្បាស់កាយដែលស្ថិតនៅដោយអាការដែលដើរថា កំពុងដើរ ដឹងច្បាស់កាយដែលតាំងនៅដោយអាការដែលឈរ អង្គុយ ឬ ដេក ថា ( កំពុង ) ដេក ជាដើម ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ឬ លោកពិចារណាឃើញកាយក្នុងកាយ ដោយការពិចារណាឥរិយាបថទាំង ៤ របស់ខ្លួនយ៉ាងនេះ ។

បទថា **ពហិទ្ធា វា** សេចក្តីថា ឬ ដោយការកំណត់ឥរិយាបថទាំង ៤ របស់អ្នកដទៃ ។

បទថា **អជ្ឈត្តពហិទ្ធា វា** សេចក្តីថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថទាំង ៤ របស់ខ្លួន ( ឬ ) របស់អ្នកដទៃតាមកាលវេលា ។

ចំណែកក្នុងបទថា **សមុទយធម្មានុបស្សី វា** ជាដើម អ្នកសិក្សាគួរនាំយកការកើតទឡើង និង ការរលត់ទៅនៃរូបខន្ធដោយអាការ ៥ យ៉ាងមក

ដោយន័យមានជាអាទិថា ព្រោះអវិជ្ជាកើត រូបខន្ធទើបកើត ។

ពិតណាស់ ពាក្យថា **សមុទយធម្មានុបស្សី វា** នេះ ក្នុងឥរិយាបថ-បព្វៈនេះ ព្រះអង្គត្រាស់សំដៅយកពាក្យនោះ ។

ពាក្យថា **អត្ថិ កាយោតិ វា បនស្ស** ជាដើម ក៏ដូចគ្នានឹងពាក្យដែលពោលមកហើយ នោះឯង ។

## អរិយសច្ចក្នុងឥរិយាបថ

តែក្នុងឥរិយាបថបព្វៈនេះ សតិដែលកំណត់ឥរិយាបថទាំង ៤ **ជាទុក្ខ- សច្ច** តណ្ហាចាស់ដែលជាសមុដ្ឋានរបស់សតិជា **សមុទយសច្ច** ការមិនប្រព្រឹត្តិ ទៅនៃសតិ និង តណ្ហាទាំង ២ យ៉ាងនោះ ជា **និរោធសច្ច** អរិយមគ្គ ដែលកំណត់ដឹងទុក្ខ ដែលលះ **សមុទយ** ដែលមាន **និរោធជាអារម្មណ៍ ជាមគ្គសច្ច** ។

ព្រះយោគាវចរ ខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយ នឹងសម្រេចដល់ទីរំលត់ទុក្ខ ( និព្វាន ) ។ ពាក្យដូចដែលពណ៌នា មកនេះ ជាផ្លូវនៃការនាំចេញ ( ចាកទុក្ខ ) រហូតដល់ព្រះអរហត្តរបស់ភិក្ខុអ្នកកំណត់ឥរិយាបថ ៤ មួយរូប ដូច្នេះឯង ។

**( ចប់ ឥរិយាបថបព្វ )**

* * * * * *

## ពិចារណាកាយដោយសម្បជញ្ញ ៤

ព្រះមានព្រះភាគ លុះទ្រង់ចែកនូវការពិចារណាឃើញកាយក្នុងកាយដោយឥរិយាបថយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងទ្រង់ចែកដោយ **សម្បជញ្ញ** ៤ ទើបត្រាស់ពាក្យមានជាអាទិថា **បុន ចបរំ** ទុក ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **អភិក្កន្តេ បដិក្កន្តេ** នេះ ការដើរ ទៅ ព្រះអង្គត្រាស់ហៅថា **អភិក្កន្ត** , ការដើរត្រឡប់ ត្រាស់ហៅថា **បដិក្កន្ត** ។ សូម្បីទាំង ២ យ៉ាងនោះ បានក្នុងឥរិយាបថទាំង ៤ ។

( នឹងថា ) **ក្នុងការដើរមុន** កាលយោកកាយទៅខាងមុខ ក៏ឈ្មោះ ថា ឈានទៅ ។ កាលបែរត្រឡប់ ក៏ឈ្មោះថា ថយត្រឡប់ ។ សូម្បី ក្នុងការឈរ អ្នកឈរនោះឯង កាលយោកកាយទៅខាងមុខ ក៏ឈ្មោះថា ឈានទៅ កាលបែរខ្លួនមកខាងក្រោយ ក៏ឈ្មោះថា ថយត្រឡប់ ។ ក្នុងការអង្គុយ អ្នកអង្គុយនោះឯង កាលផ្អៀងខ្លួនផ្អែកទៅខាងមុខ ចំពោះ មុខអាសនៈ ឈ្មោះថា ឈានទៅ កាលយោករាងកាយផ្អែកខាងក្រោយ ឈ្មោះថា ថយត្រឡប់ ។ សូម្បីក្នុងការដេក ក៏មានន័យនេះដូចគ្នា ។

បទថា **សម្បជានការី ហោតិ** សេចក្ដីថា ជាអ្នកប្រកបកិច្ចគ្រប់យ៉ាងដោយ **សម្បជញ្ញ** ( សេចក្ដីដឹងខ្លួន ) ជាប្រក្រតី ឬ ជាអ្នកធ្វើសេចក្ដីដឹងខ្លួននោះឯងជាប្រក្រតី ព្រោះថា លោកធ្វើសេចក្ដីដឹងខ្លួនក្នុងការឈានទៅខាងមុខជាដើម មិនថា ក្នុងឥរិយាបថណា ៗ ក៏មិនវៀរចាក **សម្បជញ្ញ** ។

## សម្បជញ្ញ ៤

សម្បជញ្ញៈក្នុងពាក្យថា **សម្បជានការី** នោះមាន ៤ យ៉ាង គឺ **សាត្ថកសម្បជញ្ញ ១ សប្បាយសម្បជញ្ញ ១ គោចរសម្បជញ្ញ ១**

**អសម្មោហសម្បជញ្ញ ១ ។**

## ១. សាត្ថកសម្បជញ្ញ

បណ្តាសម្បជញ្ញៈទាំង ៤ យ៉ាងនោះ ការមិនទៅតាមអំណាចការគិតដែលកើតទេឡើងនោះឯង ក្នុងកាលគិតនឹងឈានទៅ ការកំណត់ប្រយោជន៍ និង មិនមានប្រយោជន៍ ( ជាមុន ) ថា ការទៅទីនោះនឹងមានប្រយោជន៍ដល់ យើង ឬ មិនមានប្រយោជន៍ ហើយកាន់យកតែប្រយោជន៍ឈ្មោះថា **សាត្ថ_កសម្បជញ្ញ** ។

ក៏បណ្តា **អត្ថ** និង **អនត្ថ** ( ប្រយោជន៍ និង មិនមែនប្រ_យោជន៍ ) ទាំង ២ យ៉ាងនោះ ការចម្រើនផ្លូវធមិដោយបានឃើញព្រះចេតីយ៍ បានឃើញដើមពោធ× បានឃើញព្រះសង្ឃ បានឃើញព្រះថេរៈ និង បានឃើញ អសុភារម្មណ៍ជាដើម ឈ្មោះថា **អត្ថ** ។ ព្រោះថា សូម្បីបានឃើញព្រះចេតីយ៍ ហើយ ញ៉ាំងបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតទេឡើងបាន ( និង ) ព្រោះ បានឃើញព្រះសង្ឃ ក៏ញ៉ាំងនូវបីតិដែលមានព្រះសង្ឃជាអារម្មណ៍ឱ្យកើតទេឡើង បាន ហើយកាលពិចារណាអារម្មណ៍នោះឯង ដោយការអស់ទៅ និង សូន្យទៅ ក៏នឹងសម្រេចព្រះអរហត្ត ។ បានឃើញព្រះថេរៈទាំងទឡាយហើយ តាំងនៅក្នុង ឱវាទរបស់លោក បានឃើញអសុភារម្មណ៍ហើយ ញ៉ាំងបឋមជ្ឈានឱ្យកើតក្នុង អសុភារម្មណ៍នោះទេឡើងបាន កាលពិចារណាអសុភារម្មណ៍នោះឯង ដោយការ អស់ទៅ និង ការសូន្យទៅ ក៏នឹងសម្រេចព្រះអរហត្ត ។ ព្រោះដូច្នោះ ការឃើញវត្ថុទាំងនោះ ទើបឈ្មោះថា មានប្រយោជន៍ ។ តែអាចារ្យពួកខ្លះ ពោលថា ការចម្រើនផ្នែកខាងអាមិស ក៏ឈ្មោះថា ជាប្រយោជន៍ ( ផល ) បានដូចគ្នា ព្រោះអាស្រ័យប្រយោជន៍ នោះហើយ បានបដិបត្តិ ( ធមិ )

ដើម្បីអនុគ្រោះព្រហ្មចរិយៈ ។

## ២. សប្បាយសម្បជញ្ញ

ចំណែកការកំណត់ **សប្បាយ** និង **អសប្បាយ** ( សេចក្តីសប្បាយ ឬ មិនសប្បាយ ) ក្នុងការដើរនោះ ហើយកំណត់យក **សប្បាយ** ឈ្មោះថា **សប្បាយសម្បជញ្ញ** ។

បានដល់អ្វី ?

បានដល់ ការឃើញព្រះចេតិយ៍ ឈ្មោះថា មានប្រយោជន៍ ក៏បើបរិស័ទប្រជុំគ្នារយៈ ១០ ឬ ១២ យោជន៍ ដើម្បីបូជាមហាចេតិយ៍ ជាការ ប្រជុំធំ ស្រ្តីខ្លះ បុរសខ្លះ តែងខ្លួនដោយគ្រឿងប្រដាប់តាមសមគួរដល់សម្បត្តិ របស់ខ្លួន ( តាមឋានានុរូប ) ដើរជាមួយគ្នាទៅ ដូចភាពវិចិត្រកម្ម ( រូបគំនូរ ) សោត លោកក៏នឹងកើតចំណង់ ( លោភ ) ក្នុង **ឥដ្ឋារម្មណ៍** នោះ នឹងកើតការទាស់ចិត្តក្នុង **អនិដ្ឋារម្មណ៍** នឹងកើតសេចក្តីវង្វេងទេឡើងក្នុងការមើលមិនសមរម្យ ។ នឹងត្រូវអាបត្តិ **កាយសំសគ្គ** ( ចាប់ពាល់កាយស្រ្តី ) ឬនឹងមានអន្តរាយដល់ជីវិត និង ព្រហ្មចរិយៈ ។ ស្ថានទីដូចដែលពណ៌នាមកនេះនោះ ឈ្មោះថា ជា **អសប្បាយ** ។ សូម្បីការឃើញព្រះសង្ឃដែលជា **សប្បាយ** ឈ្មោះថា មានប្រយោជន៍ ព្រោះមិនមានអន្តរាយ មានប្រការដូចដែល ពោលមកហើយ ។

តែបើកាលមនុស្សនាំគ្នាសាងបារាំធំ ទុកខាងក្នុងភូមិហើយ ស្តាប់ធម្មទេសនារហូតមួយយប់ ការប្រជុំរបស់ប្រជាជន និង អន្តរាយ ក៏នឹងមានដោយប្រការដូចដែលពោលមកហើយ នោះឯង ។ ស្ថានទីដូចពោលមកហើយនេះ នោះជាអសប្បាយៈ ( តែ ) ជាសប្បាយៈ បាន ព្រោះមិនមានអន្តរាយ

សូម្បីក្នុងការឃើញព្រះថេរៈទាំងទឡាយអ្នកមានបរិស័ទច្រើន ក៏មានន័យនេះដូចគ្នា ។ សូម្បីការឃើញអសុភារម្មណ៍ ក៏ឈ្មោះថា មានប្រយោជន៍ ។ នឹងមានរឿងដូចតទៅនេះ ជាការសម្តែងសេចក្តីនោះ ( ជាតួយ៉ាង ) ÷

## រឿងភិក្ខុកំលោះ

តំណាលមកថា ភិក្ខុកំលោះមួយរូប នាំសាមណេរទៅរកឈើជម្រះ ធ្មេញ ។ សាមណេរគេចចេញអំពីផ្លូវដើរហួសទៅមុខឃើញ **អសុភារម្មណ៍** ហើយញ៉ាំងបឋមជ្ឈានឱ្យកើតទេឡើង ធ្វើបឋមជ្ឈាននោះឯងឱ្យជាបាទ **ពិចារណាសង្ខារ** ធ្វើផលទាំង ៣ ឱ្យជាក់ច្បាស់ហើយ បានឈរកំណត់កម្មដ្ឋានដើម្បីផលប្រយោជន៍ដល់មគ្គជាន់ខ្ពស់ ( អរហត្តមគ្គ ) ។ ភិក្ខុកំលោះកាលមិនឃើញសាមណេរនោះ ទើបស្រែកហៅថា សាមណេរ ។ សាមណេរនោះគិតថា តាំងអំពីបួសហើយយើងមិនដែលឱ្យភិក្ខុហៅដល់ ២ ដងទេឡើយ យើងនឹងឱ្យគុណវិសេសជាន់ខ្ពស់កើតទេឡើងក្នុងថ្ងៃដទៃចុះ ដូច្នេះហើយទើបឆ្លើយថា មានការអ្វីលោកម្ចាស់ ? ហើយសាមណេរនោះ ដែលភិក្ខុកំលោះប្រាប់ថា មកណេះសាមណេរ ត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះក៏មក ហើយបាននិយាយថា លោកម្ចាស់សូមមេត្តាដើរទៅតាមផ្លូវនេះសិន ហើយឈរបែរមុខសម្លឹងមើលទៅទិសខាងកើតមួយសន្ទុះ ក្នុងឱកាសដែលខ្ញុំឈរ ។ លោកបានធ្វើតាមសាមណេរនោះហើយ បានសម្រេចគុណវិសេស ដែលសាមណេរនោះបានហើយសម្រេចហើយ ។ អសុភារម្មណ៍មួយ បានកើតប្រយោជន៍ដល់បុគ្គល ២ នាក់ ដូចដែលពណ៌នាមកនេះ ។

ក៏អសុភារម្មណ៍នេះ សូម្បីនឹងមានប្រយោជន៍ដូចដែលពណ៌នាមកនេះ ( តែ ) **អសុភារម្មណ៍** គឺ **ស្ត្រី** ក៏ជា **អសប្បាយរបស់បុរស** ហើយ

**អសុភារម្មណ៍** គឺ **បុរស** ក៏ជា **អសប្បាយរបស់ស្ត្រី** ។ អសុភារម្មណ៍ដែលជាសភាគៈនឹងគ្នាប៉ុណ្ណោះ ទើបនឹងជា **សប្បាយ** ព្រោះដូច្នោះ **ការកំណត់សប្បាយ** យ៉ាងនេះ ឈ្មោះថា **សប្បាយសម្បជញ្ញ** ។

## ៣. គោចរសម្បជញ្ញ

តែការរៀនយក **គោចរ** ពោលគឺ កម្មដ្ឋានដែលជាទីពេញចិត្តរបស់ ខ្លួនក្នុងចំនួនកម្មដ្ឋាន ៣៨ ប្រការ ហើយទទួលយកកម្មដ្ឋាននោះដើរទៅក្នុងទីគោចរដើម្បីភិក្ខាចារ ឈ្មោះថា **គោចរសម្បជញ្ញ** សម្រាប់អ្នកមានសប្បាយៈដែលមានប្រយោជន៍ ដែលកំណត់ហើយយ៉ាងនេះ ។

ដើម្បីសេចក្ដីជាក់ច្បាស់នៃ **គោចរសម្បជញ្ញ** នោះ អ្នកសិក្សាគួរ ជ្រាប **សម្បជញ្ញ ៤ ពួក** ដូចតទៅនេះ គឺ ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅមិននាំត្រទឡប់ រូបខ្លះមិននាំទៅ មិននាំត្រទឡប់ រូបខ្លះទាំងនាំទៅ ទាំងនាំត្រទឡប់ ។

## ភិក្ខុនាំទៅ នាំត្រទឡប់

បណ្ដាភិក្ខុទាំង ៤ ពួកនោះឯង ភិក្ខុរូបណា ជម្រះចិត្តឱ្យផូរផង់ចាក **នីវរណធម៌** ដោយការចង្ក្រម ដោយការអង្គុយរហូតមួយថ្ងៃ រហូតបឋមយាមនៃរាត្រីក៏ដូច្នោះ ក្នុងមជ្ឈិមយាមលោកសឹង សូម្បីក្នុងបច្ឆិមយាមក៏ឱ្យវេលាកន្លងទៅដោយការអង្គុយ ការចង្ក្រម នឹងពោលទៅថ្មីដល់ការនឹងធ្វើវត្ត ទីលានព្រះចេតីយ៍ លានព្រះពោធិព្រឹក្ស និង ស្រោចទឹកដើមពោធ× និង តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ទុក សមាទានបដិបត្តិវត្តក្នុងគម្ពីរខន្ធកៈគ្រប់យ៉ាង មានអាចរិយវត្ត និង ឧបជ្ឈាយវត្តជាដើម លោកធ្វើធុរៈទាក់ទងនឹងរាងកាយហើយចូលទៅកាន់ទីអង្គុយ ទីដេក និង អង្គុយពែនភ្នែន ចម្រើនកម្មដ្ឋាន ក្រោក

ទេឡើងក្នុងវេលាភិក្ខាចារ កាន់យកបាត្រ និង ចីវរចេញអំពីសេនាសនៈ មនសិការកម្មដ្ឋានដោយមាតិកាកម្មដ្ឋាននោះឯង ដើរទៅកាន់លានព្រះចេតីយ៍ ហើយបើមានព្រះកម្មដ្ឋាន មានពុទ្ធានុស្សតិជាអារម្មណ៍សោត ក៏កុំបោះបង់កម្មដ្ឋាននោះចោល ចូលទៅកាន់លានព្រះចេតីយ៍ ។ បើមានកម្មដ្ឋានយ៉ាងដទៃសោត គួរបញ្ឈប់កម្មដ្ឋាននោះទុក ដូចយកដៃចាប់វត្ថុដាក់ទុកលើជើងជណ្តើរ ហើយកំណត់បីតិ មានព្រះពុទ្ធជាអារម្មណ៍ ទេឡើងទៅកាន់លានព្រះចេតីយ៍ ( បើ ) ចេតីយ៍ធំ គួរធ្វើប្រទក្សិណ ៣ ជុំហើយ ថ្វាយបង្គំទាំង ៤ ទិស ( បើ ) ចេតីយ៍តូច គួរធ្វើប្រទក្សិណយ៉ាងនោះដូចគ្នា ហើយថ្វាយបង្គំទាំង ៨ ទិស ។ លុះថ្វាយបង្គំព្រះចេតីយ៍ហើយ ទៅដល់លានព្រះពោធិព្រឹក្ស គួរធ្វើវន្ទនកិច្ចព្រះពោធិព្រឹក្ស សម្តែងសេចក្តីកោតក្រែង ដូចនៅចំពោះព្រះភក្ត្រព្រះមាន_ព្រះភាគជាម្ចាស់ ។ លោកថ្វាយបង្គំព្រះចេតីយ៍ និង ដើមពោធិព្រឹក្សយ៉ាងនេះហើយ ទៅកាន់ទីដែលខ្លួនបង្អាក់កម្មដ្ឋានទុក ទទួលយកកម្មដ្ឋានដែលបង្អាក់ ទុក ( រក្សាទុកបណ្តោះអាសន្ន ) ដូចយកដៃចាប់យកវត្ថុដែលខ្លួនរក្សាទុក ដូច្នោះហើយឃ្លុំចីវរក្នុងទីជិតស្រុក ដោយមានកម្មដ្ឋានជាសំខាន់នោះឯង ចូលទៅស្រុកដើម្បីបិណ្ឌបាត ។

លុះមនុស្សទាំងទឡាយឃើញលោកហើយ បានប្រាប់គ្នាថា លោកម្ចាស់របស់យើងមកហើយ នាំគ្នាក្រោកទទួលលោក ទទួលយកបាត្រហើយឱ្យលោកគង់លើសាលាឆាន់ ឬ លើផ្ទះ ថ្វាយយាគូ លាងជើងលាបដោយប្រេងហើយថ្វាយដល់លោក លុះលោកធ្វើភត្តកិច្ចស្រេចហើយ នាំគ្នាអង្គុយខាងមុខ ខ្លះក៏សួរបញ្ហា ខ្លះក៏ត្រូវការស្តាប់ធម៌ ។ តែបើគេនឹងឱ្យសម្តែង ( ធម្មកថា ) ព្រះអដ្ឋកថាចារ្យពោលទុកថា ដែលឈ្មោះថា **ធម្មកថា គួរសម្តែងដោយពិត**

**ដើម្បីសង្គ្រោះប្រជាជន** ។ ព្រោះដែលឈ្មោះថា **ធម្មកថា** នឹងក្រៅចាក កម្មដ្ឋានមិនមាន ព្រោះដូច្នោះ លុះលោកសម្តែង **ធម៌** ដោយមានកម្មដ្ឋានជា សំខាន់នោះឯង ឆាន់អាហារដោយមានកម្មដ្ឋានជាសំខាន់នោះឯង ធ្វើអនុមោ_ ទនាហើយ កាលគេឱ្យត្រទឡប់ ក៏ឱ្យត្រទឡប់តាមគេទៅ ហើយត្រទឡប់ក្នុងទី នោះឯង ហើយទើបធ្វើដំណើរតទៅ ។ លុះសាមណេរ និង ភិក្ខុកំលោះដែល ចេញទៅមុន ឆាន់ស្រេចហើយ ឃើញលោក ទើបនាំគ្នាទៅទទួលបាត្រ និង ចីវររបស់លោក ។

បានជ្រាបថា ភិក្ខុចាស់មើលមុខ ឃើញថា មិនមែនឧបជ្ឈាយាចារ្យរបស់ ខ្លួនហើយ ធ្វើ ( អាគន្តុកៈ ) វត្ត តែធ្វើតាមកំណត់ដែលមកជួបគ្នាប៉ុណ្ណោះ ។ ភិក្ខុទាំងនោះនឹងសួរលោកថា បុគ្គលទាំងនោះជាអ្វីនឹងលោក ទាក់ទងគ្នាខាង ញោមស្រី ឬ ខាងចំណែកញោមប្រុស ?

លោកនឹងឆ្លើយថា ពួកលោកឃើញអ្វី ទើបសួរ ?

សាមណេរ និង ភិក្ខុកំលោះទាំងនោះប្រាប់ថា បុគ្គលទាំងនោះមាន សេចក្តីស្រទឡាញ់រាប់អានចំពោះខ្ញុំព្រះករុណាយ៉ាងខ្លាំង ។

លោកម្ចាស់ វត្ថុណាសូម្បីតែញោមស្រី ញោមប្រុស ( របស់ខ្ញុំ ) ក៏ធ្វើបានលំបាក អ្នកទាំងនោះធ្វើរបស់នោះឱ្យខ្ញុំ សូម្បីបាត្រ និង ចីវររបស់ខ្ញុំ ក៏ជារបស់អ្នកទាំងនោះដូចគ្នា ( ថ្វាយ ) ដោយអានុភាពរបស់អ្នកនោះ កាល មានភ័យ ខ្ញុំក៏មិនស្គាល់ភ័យទេឡើយ កាលមានសេចក្តីស្រេកឃ្លាន ខ្ញុំក៏មិនស្គាល់ ការស្រេកឃ្លាន ដែលឈ្មោះថា ពួកជនអ្នកមានឧបការៈដល់ខ្ញុំដូច្នេះ នឹងមិន មាន លោកនិយាយដល់គុណរបស់មនុស្សទាំងនោះយ៉ាងនេះ ដើរទៅ ភិក្ខុនេះ លោកហៅថា ឈ្មោះថា **នាំទៅ មិននាំត្រទឡប់** ។

តែថានឹងពោលថ្វីដល់ ភិក្ខុមិននាំទៅ មិននាំត្រទឡប់ កាលភិក្ខុណាធ្វើវត្តបដិបត្តិមានប្រការដូចដែលពោលមកហើយ តេជៈធាតុដែលកើតអំពីកម្មនឹងសម្ដែងចេញ និង លែង **អនុបាទិន្នកសង្ខារ** ចាប់យក **ឧបាទិន្នកសង្ខារ** ញើសនឹងហូរចេញអំពីរាងកាយ នឹងមិនទេឡើងកាន់វិថីនៃកម្មដ្ឋាន ។ នឹងចាំបាច់ពោលថ្វី សូម្បីភិក្ខុនោះនឹងកាន់យកបាត្រ និង ចីវរ នឹងប្រញាប់ទៅថ្វាយបង្គំព្រះចេតីយ៍ ចូលស្រុកដើម្បីបាយយាគូ និង ភិក្ខុក្នុងវេលាដែលគោទាំងទឡាយចេញទៅ ( រកស៊ី ) នោះឯង បានបាយយាគូហើយ ទៅកាន់អាសនៈសាលា ( រោងឆាន់ ) ហើយឆាន់ ។ ខាងក្រោយដោយហេតុត្រឹមតែការឆាន់បាយយាគូ ២ - ៣ ម៉ាត់របស់លោកប៉ុណ្ណោះ តេជៈ ( ភាពក្ដៅ ) ដែលកើតអំពីកម្ម នឹងលែង **ឧបាទិន្នកសង្ខារ** ចាប់យក **អនុបាទិន្នកសង្ខារ** ។ លោកនឹងរំលត់ការក្រវល់ក្រវាយដែលកើតអំពី **តេជោធាតុ** ដូចងូតទឹកមួយរយឆ្នាំង ឆាន់បាយយាគូដោយមានកម្មដ្ឋានជាសំខាន់ លាងបាត្រ និង ខ្ពុរមាត់ហើយ មនសិការកម្មដ្ឋានក្នុងរវាងភត្ត ត្រាច់ទៅបិណ្ឌបាតក្នុងទីដ៏សេស ឆាន់អាហារដោយមានកម្មដ្ឋានជាសំខាន់ តាំងពីនោះទៅ នឹងទទួលយកកម្មដ្ឋានដែលប្រាកដទេឡើងជាប់តគ្នាទៅ ហើយដើរទៅ ភិក្ខុនេះហៅថា **មិននាំទៅ ប៉ុន្តែនាំ-ត្រទឡប់** ។ ក៏ដែលឈ្មោះថា ភិក្ខុទាំងទឡាយអ្នកឆាន់យាគូ ប្រារព្ធវិបស្សនា ហើយសម្រេចព្រះអរហត្តក្នុងព្រះពុទ្ធសាសនាដូច្នេះ រាប់ចំនួនមិនបាន ។ ក្នុង **កោះសីហទឡៈ** នោះឯង លើអាសនៈសាលា អាសនៈសម្រាប់អង្គុយឆាន់យាគូ ក៏មិនមានភិក្ខុដែលឆាន់យាគូហើយ សម្រេចអរហត្តក៏មិនមាន ។ ប៉ុន្តែភិក្ខុណាជាអ្នករស់នៅដោយការប្រមាទជាប្រក្រតី បោះបង់ចោលធុរៈ ទម្លាយវត្តគ្រប់យ៉ាង មានចិត្តជាប់ជំពាក់នឹង **ចេតោខីលធម៌ ៥ ប្រការ** មិនធ្វើសញ្ញា

ទុកខ្លះថា ដែលឈ្មោះថា កម្មដ្ឋានមាននៅ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ត្រាច់ទៅច្រទឡូកច្រទឡំដោយការច្រទឡូកច្រទឡំនឹងគ្រហស្ថ ដែលមិនសមគួរនឹង ឆាន់ ហើយ ( មានបាត្រ ) ទទេចេញទៅ ភិក្ខុនេះហៅថា **មិននាំទៅ និង មិននាំត្រទឡប់** ។

## ភិក្ខុទាំងនាំទៅ ទាំងនាំត្រទឡប់

ចំណែកភិក្ខុនេះណា ដែលពោលថា នាំទៅផង នាំត្រទឡប់ផង ភិក្ខុនោះគប្បីជ្រាបបានដោយគតប្បច្ចាគតិវត្តរបស់ភិក្ខុអ្នកដើរត្រទឡប់ទៅ ត្រទឡប់មក ព្រោះថា កុលបុត្រទាំងទឡាយអ្នកប្រាថ្នាប្រយោជន៍ បួសក្នុងសាសនាហើយ កាល នឹងនៅដោយម្នាក់ឯងចំនួន ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ នៅដោយធ្វើកតិកាវត្តទុកថា លោកម្ចាស់ទាំងទឡាយ មិនមែនបួសគេចបំណុល មិនមែនបួសគេចភ័យ មិនមែនបួសចិញ្ចឹមជីវិត ប៉ុន្តែប្រាថ្នានឹងរួចផុតចាកទុក្ខ ទើបបានបួសក្នុងព្រះពុទ្ធសាសនានេះ ព្រោះដូច្នោះ ក្នុងខណៈដើរនោះឯង លោកទាំងទឡាយចូរគ្របសង្កត់កិលេសដែលកើតទេឡើងក្នុងវេលាដើរ ក្នុងខណៈឈរ ក៏គ្របសង្កត់កិលេសដែលកើតទេឡើងក្នុងវេលាឈរ ក្នុងខណៈអង្គុយ ក៏ចូរគ្របសង្កត់កិលេសដែលកើតទេឡើងក្នុងវេលាអង្គុយ ក្នុងខណៈដេកនោះឯង ក៏ចូរគ្របសង្កត់កិលេសដែលកើតទេឡើងក្នុងវេលាដេក ។ ភិក្ខុទាំងនោះ លុះធ្វើកតិកាវត្តទុកយ៉ាងនេះហើយ កាលត្រាច់ទៅភិក្ខាចារ ក៏ដើរទៅ មានមនសិការកម្មដ្ឋានតាមសញ្ញានោះ ប្រសិនបើកិលេសកើតទេឡើងដល់នរណា ក្នុងខណៈដើរក្នុងរវាងកន្លះឧសភៈ មួយឧសភៈ កន្លះគាវុត ឬ មួយគាវុត មានដុំថ្មភិក្ខុនោះនឹងគ្របសង្កត់កិលេសនោះ ក្នុងទីនោះឯង កាលមិនអាច ( គ្របសង្កត់បាន ) យ៉ាងនោះ ក៏នឹងឈប់ឈរ ។ បន្ទាប់ពីនោះ ភិក្ខុ ( រូបដទៃ ) សូម្បីតាមពីក្រោយលោក

មក ក៏នឹងឈប់ឈរតាមលោក នឹងដាស់តឿនខ្លួនឯងថា ភិក្ខុនេះដឹងវិតក្កដែលកើតដល់យើងហើយ សេចក្ដីនេះមិនសមគួរដល់ឯងទេ ហើយចម្រើនវិបស្សនាឈានចុះកាន់អរិយភូមិក្នុងទីនោះ នុ៎ះឯង ក្នុងពាក្យថា **កាលមិនអាចយ៉ាង នោះ** លោកក៏នឹងអង្គុយ បន្ទាប់ពីនោះ ភិក្ខុអ្នកមកខាងក្រោយលោកក៏នឹង អង្គុយតាមក៏មានន័យនោះដូចគ្នា ។ សូម្បីមិនអាចឈានចុះកាន់អរិយភូមិបានក៏នឹងគ្របសង្កត់កិលេសនោះទុក ដើរមនសិការតែម្យ៉ាង មិនលើកជើងទៅឡើងទាំងដែលមានចិត្តប្រាសចាកកម្មដ្ឋាន បើលើក ( ដោយមានចិត្តប្រាសចាកកម្ម-ដ្ឋាន ) ក៏នឹងត្រឡប់ទៅកាន់កន្លែងដើមនោះឯង ដូច **មហាបុស្សទេវត្ថេរ** អ្នកស្រុក **អាលិន្ទកៈ** ។

## រឿងព្រះមហាបុស្សទេវត្ថេរ

តំណាលមកថា លោកបានបំពេញ **គតប្បច្ចាគតិកវត្ត** ( វត្តរបស់អ្នកដើរត្រឡប់ទៅ ត្រឡប់មក ) នៅកន្លែងតែមួយអស់វេលា ១៩ វស្សា ។ បានឮថា សូម្បីមនុស្សទាំងឡាយកំពុងភ្ជួរ កំពុងសាបព្រោះ កំពុងច្រូតបាច់ ធ្វើការជាមួយគ្នា ឃើញព្រះថេរៈដើរយ៉ាងនោះ ទើបសន្ទនាគ្នាថា ព្រះថេរៈរូបនេះដើរត្រឡប់ទៅ ត្រឡប់មក គង់នឹងវង្វេងផ្លូវ ឬ ភ្លេចអ្វីទេដឹង ? លោកមិនយកចិត្តទុកដាក់ក្នុងពាក្យទាំងនោះ ធ្វើសមណធម៌ដោយទាំងចិត្តដែលប្រកបដោយកម្មដ្ឋាននោះឯង បានសម្រេចអរហត្តខាងក្នុងវស្សាទី ២០ ។ ក្នុងថ្ងៃដែលលោកបានសម្រេចព្រះអរហត្តនោះឯង ទេវតាដែលស្ថិតនៅខាងចុងផ្លូវចង្ក្រមរបស់ លោកបានឈរលើកម្រាមដៃជំនួសប្រទីប សូម្បី **មហារាជទាំង ៤ សក្ក ទេវរាជ** និង **សហម្បតីព្រហ្ម** ក៏បាននាំគ្នាមកកាន់សម្នាក់របស់ ( លោក ) ។ ហើយ **ព្រះវនវាសីតិស្សមហាថេរ** ឃើញពន្លឺនោះហើយ ក្នុងថ្ងៃទី ២ ទើបបាន

សួរ **មហាបុស្សត្ថេរ** អ្នកស្រុក **អាលិន្ទក** ថា វេលារាត្រី ក្នុងសម្នាក់របស់លោក បានមានពន្លឺ ពន្លឺនុះជាពន្លឺអ្វី ? ព្រះថេរៈកាលនឹងពោលបង្កប់សេចក្តីទើបបាននិយាយពាក្យមានជាអាទិយ៉ាងនេះថា ធម្មតាពន្លឺ ក៏គង់ជាពន្លឺរបស់ប្រទីបខ្លះ ជាពន្លឺរបស់កែវមុនីខ្លះ ។ តមក លោកបញ្ឆាក់ **ព្រះវនវាសីតិស្សមហាថេរ** ថា លោកចូរបិទបាំងទុក ដឹងថាលោកទទួលពាក្យហើយ ទើប ប្រាប់ ។ ហើយដូច **ព្រះមហានាគត្ថេរ** អ្នកស្រុក **កាលវល្លិមណ្ឌប** ។

## រឿងព្រះមហានាគត្ថេរ

បានជ្រាបថា សូម្បីព្រះថេរៈរូបនោះ កាលបំពេញគតប្បច្ចាគតិវត្ត បានអធិដ្ឋានចង្រ្កមតែម្យ៉ាង អស់វេលា ៧ ឆ្នាំ ថា យើងនឹងបូជាសេចក្តីព្យាយាមដ៏ធំក្រៃលែងរបស់ព្រះមានព្រះភាគជាម្ចាស់ជាបឋមមុន បានបំពេញគតប្បច្ចា–គតិកវត្ត ១៦ ឆ្នាំទៀត ទើបបានសម្រេចព្រះអរហត្ត លោកមានចិត្តប្រកបដោយព្រះកម្មដ្ឋាននោះឯង លើកជើងទឡើងថយត្រទឡប់ ក្នុងខណៈលើក ( ជើង ) ទឡើងដោយចិត្តប្រាសចាកកម្មដ្ឋាន ដើរទៅជិតស្រុក ឈរឃ្លុំចីវរ ក្នុងទីដែលធ្វើឱ្យមនុស្សសង្ស័យថា មេគោ ឬ ភិក្ខុ ? ប្រើទឹកអំពីទីចន្លោះដើមជ្រៃលាងបាត្រ ហើយក៏បៀមទឹកទុកក្នុងមាត់ ។ ព្រោះហេតុអ្វី ? ព្រោះលោកគិតថា សូមយើងកុំបានបោះបង់ចោលកម្មដ្ឋាន សូម្បីដោយហេតុដែលនិយាយនឹងមនុស្សដែលមកថ្វាយភិក្ខា ឬ មនសិការថា សូមមានអាយុយឺនយូរចុះ ។ តែ ( បើ ) ត្រូវសួរដល់ថ្ងៃថា ថ្ងៃនេះជាថ្ងៃអ្វី លោកម្ចាស់ ឬ សួរចំនួនភិក្ខុ សួរបញ្ហា ក៏នឹងលេបទឹកហើយប្រាប់ ប្រសិនបើមិនមានអ្នកសួរដល់ថ្ងៃជាដើមវេលាចេញទៅ ក៏ខ្ពុរទឹកចេញ ( អំពីមាត់ ) ត្រង់ខ្លោងទ្វារស្រុកហើយ ទើបទៅដូចភិក្ខុ ៥០ រូប ដែលចាំវស្សា ឯ **កលម្ពតិត្ថវិហារ** ។

## រឿងភិក្ខុ ៥០ រូប

បានឮមកថា ក្នុងថ្ងៃ **អាសាឍបុណ្ណមី** ( ពាក់កណ្តាលខែ ៨ ) លោកទាំងនោះ បានធ្វើកតិកាវត្តទុកថា បើពួកយើងមិនទាន់សម្រេចព្រះអរហត្តទេ នឹងមិននិយាយជជែកគ្នា ។ ហើយកាលនឹងចូលកាន់ស្រុកបិណ្ឌបាត ( មួយ រូប ៗ ) ក៏បៀមទឹកហើយ ទើបចូលទៅ កាលត្រូវសួរដល់ថ្ងៃជាដើម ក៏បដិ-បត្តិដូចដែលពោលមកហើយនោះឯង ។ មនុស្សទាំងទឡាយឃើញស្នាមខ្ពុរទឹកក្នុងទីនោះហើយ ក៏ដឹងថា ថ្ងៃនេះភិក្ខុមកមួយរូប ថ្ងៃនេះមក ២ រូប ទើបគិតគ្នាយ៉ាងនេះថា លោកទាំងនេះមិននិយាយរកចំពោះតែពួកយើង ឬ យ៉ាងណា ? ឬសូម្បីពួកគ្នាលោកក៏មិននិយាយដែរ ? ប្រសិនបើលោកមិននិយាយគ្នា លោកនឹងវិវាទគ្នាជាពិតប្រាកដ ណ្ហើយចុះ យើងទាំងទឡាយនឹងឱ្យលោកសូមខមាទោសគ្នាគ្រប់អង្គទើបនាំគ្នាទៅវត្ត ក៏មិនបានឃើញព្រះភិក្ខុក្នុងទីតែមួយដល់ ២ រូប ក្នុងចំនួនភិក្ខុ ៥០ រូប ។ តមក បណ្តាមនុស្សទាំងទឡាយនោះ អ្នកមានបញ្ញាល្អក៏និយាយថា អ្នកទាំងទឡាយអើយ មនុស្សឈ្លោះប្រកែកគ្នានឹងមិនមានឱកាសដូច្នេះ លានព្រះចេតីយ៍ លានព្រះពោធិព្រឹក្សក៏បោសយ៉ាងស្អាត អំបោសក៏រក្សាទុកយ៉ាងល្អ ទឹកឆាន់ ទឹកប្រើប្រាស់ ក៏ចាត់ចែងទុកយ៉ាងល្អ ។ តពីនោះពួកមនុស្សទាំងនោះក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ។ ក្នុងខាងក្នុងព្រះវស្សានោះឯង ព្រះភិក្ខុសូម្បីទាំងនោះ ក៏សម្រេចអរហត្តក្នុងថ្ងៃ **មហាបវារណា** ទើបបវា-រណាគ្នាដោយ **វិសុទ្ធិបវារណា** ។

ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋាននោះឯង លើកជើងទឡើង ( ដើរទៅ ) សូម្បីជិតដល់ស្រុកហើយបៀមទឹកទុកក្នុងមាត់ ពិចារណាមើលផ្លូវច្រើនខ្សែដែលមិនមានមនុស្សឈ្លោះគ្នា មិនមានអ្នកលេងសុរា និង អ្នកលេងល្បែងភ្នាល់

## ៧៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ជាដើម ឬ មិនមានដីរកាច សេះកាច ជាដើម ហើយដើរទៅផ្លូវនោះ ដូច **ព្រះនាគត្ថេរ** អ្នកស្រុក **កាលវល្លិមណ្ឌប** និង ដូចភិក្ខុចាំវស្សាក្នុង **កលម្ពតិត្ថវិហារ** ដូចដែលបានពណ៌នាមកនេះ លោកកាលនឹងត្រាច់ទៅ បិណ្ឌបាតក្នុងស្រុកនោះ ក៏មិនដើរលឿន ដូចមនុស្សប្រញាប់ប្រញាល់ ។ ព្រោះ

ថា មិនមានធុតង្គអ្វីដែលមានឈ្មោះថា ជាធុតង្គសម្រាប់អ្នកដើរបិណ្ឌបាត លឿន ។ តែថា ដើរមិនគ្រលែងកាយដូចរទេះផ្ទុកទឹកពេញ ( ទៅ ) ដល់ផ្ទៃដីដែលរាបស្មើ ។ ហើយចូលទៅតាមលំដាប់ផ្ទះ ( ឈរ ) រង់ចាំពេលវេលាដ៏សមគួរដើម្បីសង្កេតមើលថា គេប្រាថ្នានឹងថ្វាយ ( ដាក់បាត្រ ) ឬ មិនប្រាថ្នានឹងថ្វាយ ទទួលភិក្ខាហើយ ( នៅ ) ក្នុងស្រុក ឬ ក្រៅស្រុក ឬ មកកាន់វិហារនោះឯង អង្គុយក្នុងឱកាសដែលសមគួរតាមសប្បាយហើយ មនសិការកម្ម- ដ្ឋានកំណត់បដិកូលសញ្ញាក្នុងអាហារ ពិចារណាដោយប្រៀបធៀបនឹងប្រេងបន្តក់ភ្លៅរទេះ សំពត់រុំដំបៅ និង សាច់កូន នាំអាហារដែលប្រកបដោយអង្គ ៨ មក ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យថ្វូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ នឹងឆាន់ហើយរៀបចំទុកដាក់ទឹក ( ឆាន់ , លាង ) ស្រេចហើយ រំងាប់សេចក្តីលំបាកដែលកើតអំពីអាហារ ( ស្រវឹងបាយ ) មួយភ្លែតហើយ ទើបមនសិការកម្មដ្ឋាននោះឯង ក្នុងវេលាក្រោយពីឆាន់ ដូចវេលាមុនឆាន់ហើយ ក្នុងវេលាបច្ឆិមយាម ដូចវេលាបឋមយាម ។ ភិក្ខុរូបនេះ ហៅបានថា **ទាំងនាំទៅ និង នាំត្រទទ្បប់** ។

ក៏លោកកាលបំពេញ **គតប្បច្ចាគតិកវត្ត** ពោលគឺ ការនាំទៅ និង នាំត្រទទ្បប់នេះ បើមានឧបនិស្ស័យសម្បូណ៌សោត ក៏នឹងសម្រេចអរហត្តក្នុងបឋមយាមនោះឯង ប្រសិនបើមិនសម្រេចក្នុងបឋមយាម តទៅក៏នឹងសម្រេច

ក្នុងមជ្ឈិមយាម ប្រសិនបើក្នុងមជ្ឈិមយាមមិនសម្រេចសោត តទៅនឹងសម្រេចក្នុងមរណសម័យ ប្រសិនបើក្នុងមរណសម័យមិនសម្រេចសោត តទៅក៏នឹងជាទេវបុត្រហើយសម្រេច ប្រសិនបើជាទេវបុត្រហើយក៏នៅមិនបានសម្រេចសោត កាលព្រះពុទ្ធជាម្ចាស់ស្ដេចមិនទាន់ឧប្បត្តិ នឹងកើតទេឡើងហើយ ធ្វើឱ្យជាក់ច្បាស់នូវ **បច្ចេកពោធិញ្ញាណ** បើមិនធ្វើឱ្យជាក់ច្បាស់ជា **បច្ចេកពោធិញ្ញាណ** សោត តទៅនឹងជាអ្នកត្រាស់ដឹងដោយឆាប់រហ័ស ( ខិប្បាភិញ្ញាបុគ្គល ) ចំពោះព្រះភក្រ្តរបស់ **ព្រះពុទ្ធជាម្ចាស់ទាំងទឡាយ** ដូច **ព្រះពាហិយទារុចិរិយត្ថេរ** , នឹងមានបញ្ញាច្រើនដូច **ព្រះសារីបុត្រ** និង មានឫទ្ធិច្រើនដូច **ព្រះមហាមោគ្គល្លានត្ថេរ** និង ជាអ្នកប្រាប់ធុតង្គដូច **ព្រះមហាកស្សបត្ថេរ** និង ជាអ្នកមានទិព្វចក្ខុដូច **ព្រះអនុរុទ្ធត្ថេរ** និង ជាព្រះវិន័យធរដូច **ព្រះឧបលិត្ថេរ** និង ជាព្រះធម្មថិកដូច **ព្រះបុណ្ណមន្តានីបុត្រត្ថេរ** និង ជាអ្នកនៅព្រៃជាប្រចាំដូច **ព្រះរេវតត្ថេរ** និង ជាពហូស្សូតដូច **ព្រះអានន្ទត្ថេរ** ឬ នឹងជាអ្នកប្រាថ្នាការសិក្សាដូច **ព្រះរាហុលត្ថេរពុទ្ធបុត្ត** ដូច្នេះ ។

ភិក្ខុអ្នកនាំទៅ និង នាំត្រទឡប់ក្នុង ៤ វារៈនេះ នឹងមាន **គោចរសម្បជញ្ញ** ដល់កំពូល ( វិបស្សនា ) ដោយប្រការដូចដែលពណ៌នាមកនេះ ។

## ៤. អសម្មោហសម្បជញ្ញ

ចំណែកការមិនវង្វេង ក្នុងការឈានទៅមុខជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញ** , **អសម្មោហសម្បជញ្ញ** នោះ គប្បីជ្រាបយ៉ាងនេះ ។ ភិក្ខុក្នុងព្រះសាសនានេះ កាលឈានទៅខាងមុខ ឬ ថយត្រទឡប់ នឹងមិនវង្វេងដូច **អន្ធបុថុជ្ជន** ( វង្វេង ) ថា ខ្លួនឈានទៅខាងមុខ ខ្លួនឱ្យកើតការឈានទៅខាងមុខ ឬថា យើងឈានទៅខាងមុខ យើងឱ្យកើតការឈានទៅខាងមុខក្នុង

## ៧៧ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ការឈានទៅខាងមុខជាដើម កាលកើតការគិត ( ចិត្ត ) ទេឡើងថា យើងនឹងមិនវង្វេងឈានទៅខាងមុខ **វាយោធាតុ** ដែលមានចិត្តជាសមុដ្ឋាន កាលឱ្យកើតវិញ្ញត្តិទេឡើង នឹងកើតទេឡើងព្រមជាមួយចិត្តដួងនោះ ៗ ឯង ។ គ្រោងឆ្អឹងដែលសម្មតិថា កាយនេះនឹងឈានទៅខាងមុខដោយអំណាចនៃការផ្សាយទៅនៃ **វាយោធាតុ** ដែលកើតអំពីកិរិយារបស់ចិត្តដោយប្រការយ៉ាងនេះ កាលគ្រោងឆ្អឹងនោះ ៗ ឯង ឈានទៅខាងមុខ ក្នុងការលើកជើងតែម្ខាងទេឡើង ធាតុ ២ ប្រភេទ គឺ **បឋវីធាតុ** និង **អាបោធាតុ** នឹងតិច នឹងថយចុះ ។ ធាតុ ២ យ៉ាងទៀតក្រៅអំពីនេះ ( តេជោធាតុ ) នឹងមានកម្លាំងខ្លាំងក្រៃលែងទេឡើង ។ ក្នុងការឈានទៅ និង ការបន្តជំហានទៅ **តេជោធាតុ វាយោធាតុ** ( ដែលប្រព្រឹត្តទៅហើយ ) ក្នុងការគ្រវី ( ជើង ) ចេញទៅ នឹងតិច នឹងថយចុះ ។ ធាតុ ២ យ៉ាងទៀតក្រៅអំពីនេះ ( **បឋវី** , **អាបោ** ) នឹងមានកម្លាំងខ្លាំងក្រៃលែងទេឡើង ។ ក្នុងការជាន់ និង ការទប់ **រូបធម៌ និង អរូបធម៌** ដែលប្រើក្នុងការលើក ( ជើង ) ទេឡើងនោះ ក៏ជាយ៉ាងនោះ មិនដល់ការឈានទៅក្នុងទីដែលប្រើក្នុងការឈានជើងទៅក៏ទំនងដូចគ្នា មិនដល់ការបន្តជំហាន ទៅមិនដល់ការបោះ ( ជើង ) ចេញ មិនប្រើក្នុងការបោះ ( ជំហាន ) ចេញ ទៅក៏មិនមានដល់ការជាន់ដែលប្រើក្នុងការជាន់ ក៏មិនដល់ការទប់ ។ កដៃកជើងគ្រប់យ៉ាង និង ទី.ត គ្រប់កន្លែង ប្រព្រឹត្តទៅតាមទំនងក្នុងទីនោះនុ៎ះឯងនឹងលាន់ឮប្រេះប្រោះ ដូចគ្រាប់ល្ងដែលបោះចុះក្នុងខ្ទះដែលក្តៅ ។ ក្នុងរឿងនោះនឹងមាននរណាម្នាក់ឈានទៅ ឬ នឹងមានការឈានទៅរបស់នរណាម្នាក់ ទៅការពិត ( ពោល ) ដោយបរមត្ថហើយ គឺ ការដើររបស់ធាតុប៉ុណ្ណោះ ការឈរ , ការអង្គុយ ការដេក , ក៏របស់ធាតុ ( មិនមែនរបស់នរណា ) ។

**ព្រោះថា ក្នុងចំណែកនោះ ៗ ចិត្តដួងដទៃកើត ដួងដទៃរលត់ព្រមជាមួយនឹងរូប ( មួយដួង ៗ មិនមែនដួងដូចគ្នា ) ដូចក្រសែទឹកដែលហូរជាប់តគ្នាទៅ មានរលក ដូច្នោះ ដូច្នេះឯង ។**

ការមិនវង្វេងក្នុងការឈានទៅខាងមុខជាដើម ដូចដែលពណ៌នាមកនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញ** ដូច្នេះឯង ។ ជាការដែលបញ្ចប់ការអធិប្បាយថា ជាអ្នកធ្វើសេចក្តីដឹងខ្លួនក្នុងការឈានទៅមុខ និង ការថយក្រោយ ។ ក៏ការសម្លឹងមើលទៅខាងមុខ ឈ្មោះថា **អាលោកិត** ( ការក្រទេឡកមើលទៅខាងមុខ ) ក្នុងពាក្យថា **អាលោកិតេ វិលោកិតេ** នេះ ការសម្លឹងមើលទៅតាមអនុទិស ( ទិសឆៀង ) ឈ្មោះថា **វិលោកិត** ( ការងាកមើលខាងឆ្វេង-មើលខាងស្តាំ ) មានឥរិយាបថសូម្បីយ៉ាងដទៃទៀត ឈ្មោះថា ឱនចុះ ការងើយទេឡើង និង ការបែរទៅ-មក ដោយការសម្លឹងមើលខាងក្រោម សម្លឹងមើលខាងលើ សម្លឹងសងខាង ។ ឥរិយាបថទាំងនេះ មិនទ្រង់កាន់យកក្នុងទី នេះ ។ តែដោយការសមគួរ ទ្រង់កាន់យក ២ យ៉ាងនេះ ប៉ុណ្ណោះ ឬ ដោយសេចក្តីសំខាន់ ( មុខ ) នេះ ទ្រង់កាន់យកសូម្បីទាំងអស់នោះឯង ដូច្នេះ ។

បណ្តា **សម្បជញ្ញ** ទាំងនោះ ការគិតដល់ប្រយោជន៍ដោយមិនសម្លឹងមើលដោយអំណាចនៃចិត្តប៉ុណ្ណោះ កាលកើតការគិតទេឡើងថា យើងនឹងសម្លឹងមើល ឈ្មោះថា **សាត្ថកសម្បជញ្ញ** ។ **សាត្ថកសម្បជញ្ញ** នោះ គួរជ្រាបដោយលើកយក **ព្រះនន្ទ** អ្នកមានកាយជាសាក្សី ( មកជាតួយ៉ាង ) ។ សមពិតដូចដែលព្រះមានព្រះភាគជាម្ចាស់បានត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ ប្រសិនបើ **ព្រះនន្ទ** ចាំបាច់សម្លឹងមើលទិសខាងកើតសោត **ព្រះនន្ទ** ក៏នឹងប្រមូល

យកវត្ថុគ្រប់យ៉ាងដោយចិត្ត ហើយទើបសម្លឹងមើលទិសខាងកើត ដោយគិត ថា កាលយើងសម្លឹងមើលទិសខាងកើតយ៉ាងនេះហើយ អភិជ្ឈាទោមនស្ស គឺ អកុសលកម្មដ៏លាមកនឹងមិនគ្របសង្កត់យើង ។ ដោយប្រការដូច្នេះ ភិក្ខុ ក្នុងធម្មវិន័យនេះ នឹងជាអ្នកមានសេចក្ដីដឹងខ្លួន ក្នុងសាត្ថកសម្បជញ្ញៈនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ **ព្រះនន្ទ** នឹងត្រូវសម្លឹងមើលទិសខាងលិច ទិសខាងជើង ទិសខាងត្បូង ទិសខាងលើ ទិសខាងក្រោម និង ទិសឆៀង ទាំងឡាយសោត **ព្រះនន្ទ** ក៏នឹងប្រមូលយកគ្រប់យ៉ាងដោយចិត្ត ហើយ ទើបនឹងសម្លឹងមើលទិសឆៀងទាំងឡាយ ដោយគិតថា កាលយើងសម្លឹងមើល ទិសឆៀងទាំងឡាយ យ៉ាងនេះ ។ ល ។ នឹងជាអ្នកមានសេចក្ដីដឹងខ្លួនក្នុង **សាត្ថកសម្បជញ្ញ** នោះ ។

ក៏ម្យ៉ាងទៀត សូម្បីក្នុងសម្បជញ្ញបព្វៈនេះគួរនឹងជ្រាប **សាត្ថកសម្ប-ជញ្ញ** និង **សប្បាយសម្បជញ្ញ** ដោយការឃើញព្រះចេតីយ៍ ដែលបាន ពោលមកហើយក្នុងខាងដើមជាដើមចុះ ។

ចំណែកការមិនលះបង់កម្មដ្ឋាននោះឯង ឈ្មោះថា **គោចរសម្ប-ជញ្ញ** ព្រោះដូច្នោះ អ្នកចម្រើនកម្មដ្ឋាន មានខន្ធ ធាតុ និង អាយតនៈជា អារម្មណ៍ គួរធ្វើការក្រទេឡកមើលខាងមុខ និង ការក្រទេឡកឆ្វេងស្ដាំដោយ អំណាចកម្មដ្ឋានរបស់ខ្លួនប៉ុណ្ណោះ ឬថា អ្នកចម្រើនកម្មដ្ឋានមានកសិណជាដើម ( ជាអារម្មណ៍ ) គួរធ្វើការក្រទេឡកមើលខាងមុខ និង ការក្រទេឡកមើលឆ្វេង ស្ដាំ ដោយអាការមានកម្មដ្ឋានជាការសំខាន់ដូចគ្នា ។

ធម្មតា អត្តាក្នុងខាងក្នុងឈ្មោះថា ជាអ្នកក្រទេឡកមើលទៅខាងមុខ និង ងាកឆ្វេងស្ដាំមិនមាន តែកាលកើតការគិតទេឡីងថា យើងនឹងក្រទេឡកមើលទៅ

ខាងមុខ **វាយោធាតុ** ដែលកើតអំពីចិត្ត កាលនឹងឱ្យវិញ្ញាណកើត ក៏នឹងកើតទេឡើងព្រមជាមួយនឹងចិត្តដួងនោះ ៗ ឯង ។ ដោយប្រការដូច្នេះ សំបកភ្នែក ( ត្របកភ្នែក ) ខាងក្រោមក៏នឹងបង្អិតចុះខាងក្រោម សំបកភ្នែកខាងលើក៏នឹងបើកទេឡើងខាងលើ ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ។ មិនមាននរណាដែលឈ្មោះថា បើក ( ត្របកភ្នែក ) ដោយគ្រឿងយន្តកែច្នៃ ។

តពីនោះទៅ ចក្ខុវិញ្ញាណនឹងកើតទេឡើងធ្វើ **ទស្សនកិច្ច** ( ការឃើញ ) ក៏សេចក្តីដឹងខ្លួនដូចដែលពណ៌នាមកនេះ ឈ្មោះថា **អសម្មោហសម្បជញ្ញ** ក្នុងអធិការនៃ **សម្បជញ្ញ** នេះ ។

ម្យ៉ាងទៀត ក្នុងរឿងសម្បជញ្ញៈនេះ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** សូម្បីដោយអំណាចជា **មូលបរិញ្ញា** ( ការកំណត់ដឹងថ្នាក់ដើម ) ជា **អា-គន្តុកៈ** ( ជាភ្ញៀវ ) និងជា **តាវកាលិក** ( ប្រព្រឹត្តទៅមួយគ្រា ) ។ គួរជ្រាប **អសម្មោហសម្បជញ្ញ** ដោយអំណាច **មូលបរិញ្ញា** ( ដូចតទៅនេះ ) ÷

**ភវង្គ ( ចិត្តនៅក្នុងភវង្គ ) ១ , អាវជ្ជន ( ការរពួកដល់អារម្មណ៍ ) ១ , ទស្សន ( ការឃើញអារម្មណ៍ ) ១ ,**

**សម្បដិច្ឆន្ន ( ការទទួលអារម្មណ៍ ) ១ , សន្តីរណ ( ការ-ពិចារណាអារម្មណ៍ ) ១ , វោដ្ឋព្វន ( ការកាត់ក្តីអារម្មណ៍ ) ១ , ទី ៧ គឺ ជវន ១ ។**

## នាទីរបស់ចិត្ត មួយខណៈ ៗ

បណ្តាចិត្តទាំង ៧ នោះ ភវង្គធ្វើកិច្ច គឺ **ជាហេតុនៃឧបបត្តិភព ឱ្យសម្រេច** កិរិយាមនោធាតុញុំាងភវង្គនោះឱ្យវិលត្រទឡប់ ហើយធ្វើអាវជ្ជនកិច្ច

ឱ្យសម្រេច ព្រោះ **អាវជ្ជនកិច្ច** នោះរលត់ទៅ **ចក្ខុវិញ្ញាណ** នឹងធ្វើ **ទស្សន- កិច្ច** ឱ្យប្រព្រឹត្តទៅ ព្រោះ **ទស្សនកិច្ច** នោះរលត់ទៅ **វិបាកមនោធាតុ** នឹងធ្វើ **សម្បដិច្ឆន្នកិច្ច** ឱ្យប្រព្រឹត្តទៅ ព្រោះ **សម្បដិច្ឆន្នកិច្ច** រលត់ទៅ **មនោវិញ្ញាណធាតុ** ដែលជាវិបាកធ្វើ **សន្តីរណកិច្ច** ព្រោះ **សន្តីរណកិច្ច** នោះរលត់ទៅ **មនោវិញ្ញាណធាតុ** ដែលជាកិរិយានឹងឱ្យ **វោដ្ឋព្វនកិច្ច** ប្រព្រឹត្តទៅ ព្រោះ **វោដ្ឋព្វនកិច្ច** នោះ រលត់ទៅ **ជវន** នឹងស្ទុះទៅ ៧ ខណៈ បណ្តា **ជវន** ទាំង ៧ នោះ ចំពោះ **ជវន** ដំបូង ការសម្លឹងមើល និង ការ ងាកឆ្វេង- ស្តាំដោយអំណាចសេចក្តីត្រេកអរ និង ការថ្មាំងថ្មាក់ និង សេចក្តី វង្វេងថា នេះជាស្រី នេះជាប្រុស និង មិនមានក្នុងជវនទី ២ ក្តី ។ ល ។ ក្នុងជវនទី ៧ ក្តី ( ក៏នឹងមិនមាន ) ។ តែកាល **វិថីចិត្ត** ទាំងនេះបែកធ្លាយទៅហើយដោយអំណាចចិត្តដួងដំបូងរហូតដល់ចិត្តដួងចុងក្រោយ ។ ដូចទា- ហានក្នុងសមរភូមិ កាលក្រទេឡកមើលទៅខាងមុខ និង ការក្រទេឡកឆ្វេង-ស្តាំ ដោយអំណាចសេចក្តីប្រកាន់ជាដើមថា នេះជាស្ត្រី នេះជាបុរសក៏នឹងមាន ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** ដោយអំណាចជា **មូលបរិញ្ញា** ក្នុង **ឥរិយាបថបព្វ** នេះ ដូចដែលពណ៌នាមកនេះមុន ។

ក៏កាលរូបប្រាកដក្នុងចក្ខុទ្វារហើយ តអំពី **ភវង្គចលន** ( ភវង្គ- ញ័រ ) ទៅ កាលវិថីចិត្តមាន **អាវជ្ជន** ជាដើម កើតទេឡើងហើយរលត់ទៅ ដោយអំណាចធ្វើកិច្ចរបស់ខ្លួនឱ្យសម្រេចក្នុងទីបំផុត ជវនក៏កើតទេឡើង ជវននោះនឹងដូចបុរសដែលជាភ្ញៀវរបស់ **វិថីចិត្ត** មានអាវជ្ជនៈជាដើមដែលកើតទេឡើងមុន ( មកដល់ ) ទ្វារ គឺ ភ្នែក ( ចក្ខុទ្វារ ) ដែលប្រៀបដូចផ្ទះ សូម្បីកាលវិថីចិត្តមានអាវជ្ជនៈជាដើម មិនត្រេកអរ មិនអាក់អន់ចិត្ត មិនវង្វេងក្នុង **ចក្ខុទ្វារ**

ដែលដូចផ្ទះរបស់អាវជ្ជនៈជាដើម ជវនៈនោះ នឹងត្រេកអរ នឹងថ្នាំងថ្នាក់ចិត្ត នឹង វង្វេងក៏មិនត្រូវ ដូចជាបុរសដែលជាភ្ញៀវចូលទៅសុំអ្វី ៗ ក្នុងផ្ទះអ្នកដទៃ កាល ម្ចាស់ផ្ទះអង្គុយស្ងៀម នឹងធ្វើការបង្គាប់ក៏មិនត្រូវដូច្នោះ គប្បីជ្រាប **អសម្មោ–ហសម្បជញ្ញ** ប្រៀបដូចជាភ្ញៀវ ដូចដែលពណ៌នាមកនេះ ។

ម្យ៉ាងទៀត ចិត្តមាន **វោដ្ឋព្វន** ជាទីបំផុតដែលកើតទេឡើងក្នុងចក្ខុទ្វារទាំងនេះនឹងរលត់ទៅក្នុងទីនោះ ៗ ព្រមជាមួយ **សម្បយុត្តធម៌** នឹងមិនបានជួបគ្នាទេឡើយ ព្រោះដូច្នោះ ចិត្តក្រៅពីនេះ ទើបប្រព្រឹត្តទៅមួយគ្រាមួយខណៈប៉ុណ្ណោះ ។

ក្នុងសេចក្តីនោះ អ្នកសិក្សាគួរជ្រាប **អសម្មោហសម្បជញ្ញ** ដោយការប្រព្រឹត្តិទៅមួយជួរខណៈយ៉ាងនេះថា ក្នុងផ្ទះមួយជាមួយគ្នា កាលមនុស្សស្លាប់អស់ហើយ មនុស្សម្នាក់ដែលនៅសល់ ដែលធម្មតាក៏នឹងស្លាប់ទៅទៀតក្នុងកាលមិនយូរដូចគ្នា ឈ្មោះថា នឹងនៅមានសេចក្តីរីករាយក្នុងការរាំរែក និងការច្រៀងជាដើម មិនត្រឹមត្រូវយ៉ាងណា កាល **អាវជ្ជនចិត្ត** ជាដើម ដែលសម្បយុត្តហើយក្នុងទ្វារតែមួយ រលត់ទៅក្នុងទីនោះ ៗ ឯង សូម្បី **ជវនចិត្ត** ដែលនៅសល់ ក៏នឹងមានការរលត់ទៅជាធម្មតា ខាងក្នុងមិនយូរប៉ុន្មានដូចគ្នា ឈ្មោះថា នឹងនៅមានសេចក្តីរីករាយ នៅដោយអំណាចការរីករាយ ការអាក់អន់ចិត្ត និង ការវង្វេង មិនត្រឹមត្រូវទេឡើយ ដូច្នោះដូចគ្នា ។

ម្យ៉ាងទៀត គប្បីជ្រាប **អសម្មោហសម្បជញ្ញ** នេះ ដោយការពិចា–រណាខន្ធ អាយតនៈ ធាតុ និង បច្ច័យ ( ដូចតទៅនេះ ) ÷

អធិប្បាយថា ក្នុងពាក្យថា ខន្ធជាដើមនេះ ទាំងចក្ខុ ទាំងរូប ឈ្មោះថា **រូបខន្ធ** ការឃើញ ឈ្មោះថា **វិញ្ញាណក្ខន្ធ** ការសោយអារម្មណ៍ដែលសម្បយុត្តជាមួយនឹងវិញ្ញាណក្ខន្ធនោះ ឈ្មោះថា **វេទនាខន្ធ** ការចាំបានសម្គាល់បាន

ឈ្មោះថា **សញ្ញាខន្ធ** ធម៌មាន **ផស្ស** ជាដើម ឈ្មោះថា **សង្ខារក្ខន្ធ** ព្រោះខន្ធទាំងនេះមកប្រជុំគ្នា ការក្រទេឡួកមើលទៅខាងមុខ និង ការក្រទេឡួកមើលឆ្វេង ក្រទេឡួកមើលស្តាំ ទើបប្រាកដ ។ កាលការក្រទេឡួកមើលទៅមុខ និង ការក្រទេឡួកមើលឆ្វេង ក្រទេឡួកមើលស្តាំប្រាកដ ដោយអំណាចបញ្ចក្ខន្ធនោះ ( នឹងមាន ) សូម្បីនរណាត្រឹមតែម្នាក់ក្រទេឡួកមើលទៅមុខ នឹងមាននរណាត្រឹមតែម្នាក់ក្រទេឡួកមើលខាងស្តាំ ។

ប្រការមួយទៀត **ចក្ខុ** ឈ្មោះថា ចក្ខាយតនៈ **រូប** ឈ្មោះថា រូបា_យតនៈ **ការឃើញ** ឈ្មោះថា មនាយតនៈ **សម្បយុត្តធម៌ទាំងទឡាយ មាន វេទនាជាដើម** ឈ្មោះថា ធម្មាយតនៈ ព្រោះអាយតនៈ ៤ នោះ មកប្រជុំ គ្នាយ៉ាងនោះឯង ការក្រទេឡួកមើលទៅមុខ និង ការក្រទេឡួកមើលឆ្វេង ក្រទេឡួកមើលស្តាំទើបប្រាកដ ។ កាលការក្រទេឡួកមើលទៅមុខ និងការក្រទេឡួកមើលឆ្វេង ក្រទេឡួកមើលស្តាំ ប្រាកដមានដោយអំណាចអាយតនៈ ៤ នោះ បើដូច្នេះ នឹងមាននរណាម្នាក់ក្រទេឡួកមើលទៅមុខ ក្រទេឡួកឆ្វេងស្តាំទៅ ។ ម្យ៉ាងទៀត **ចក្ខុ** ឈ្មោះថា ចក្ខុធាតុ **រូប** ឈ្មោះថា រូបធាតុ **ការឃើញ** ឈ្មោះថា ចក្ខុវិញ្ញាណធាតុ **វេទនាជាដើម** ដែលសម្បយុត្តជាមួយនឹងចក្ខុវិញ្ញាណធាតុ នោះ ឈ្មោះថា ធម្មធាតុ ព្រោះធាតុ ៤ នេះ មកប្រជុំគ្នាយ៉ាងនេះ ការក្រទេឡួកមើលទៅមុខ និង ការក្រទេឡួកមើលទៅទិសផ្សេង ៗ ទើបប្រាកដ កាលការក្រទេឡួកមើលទៅមុខ និង ការក្រទេឡួកមើលទៅទិសផ្សេង ៗ ប្រាកដដោយអំ_ណាចធាតុ ៤ នោះ នឹងមាននរណាត្រឹមតែម្នាក់មកក្រទេឡួកមើលទៅមុខ និង មាននរណាត្រឹមតែម្នាក់មកក្រទេឡួកមើលទៅទិសផ្សេង ៗ ទៅ ។

ម្យ៉ាងទៀត **ចក្ខុ** ជានិស្សយប្បច្ច័យ , **រូប** ជាអារម្មណ_

ប្បច្ច័យ **អាវជ្ជន** ជាអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយ- ប្បច្ច័យ នត្ថិប្បច្ច័យ និង វិគតប្បច្ច័យ , **អាលោក** ( ពន្លឺ ) ជា ឧបនិស្សយប្បច្ច័យ , **វេទនាជាដើម** ជាសហជាតប្បច្ច័យ ។ ព្រោះ បច្ច័យទាំងនោះប្រជុំគ្នាយ៉ាងនោះ ការក្រទេឡុកមើលទៅមុខ និង ការក្រទេឡុក មើលទៅទិសផ្សេង ៗ ទើបប្រាកដ កាលការក្រទេឡុកមើលទៅខាងមុខ និង ការ ក្រទេឡុកមើលទៅទិសផ្សេង ៗ ប្រាកដដោយអំណាចបច្ច័យទាំងនោះ នឹងមាន នរណាត្រឹមតែម្នាក់ មកមើលទៅមុខ និង មាននរណាត្រឹមតែម្នាក់ មកក្រទេឡុក មើលទៅទិសផ្សេង ៗ ។ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** សូម្បីដោយ ការពិចារណា **ខន្ធ អាយតន ធាតុ** និង **បច្ច័យ** ក្នុងការក្រទេឡុកមើល ទៅមុខ និង ការក្រទេឡុកមើលទៅទិសផ្សេង ៗ នេះ ដូចដែលពណ៌នាមក នេះឯង ។

បទថា **សម្មិញ្ជិតេ បសារិតេ** បានដល់ ការបត់ដៃ-ជើងចូល និង លាដៃ-ជើង ចេញ ។

បណ្ដាសម្បជញ្ញៈទាំង ៤ នោះ ការមិនធ្វើការបត់ និង ការលាចេញ ទៅដោយអំណាចចិត្ត ( ការគិត ) តែម្យ៉ាង តែពិគ្រោះពិចារណាមើលប្រ- យោជន៍ ឬ មិនប្រយោជន៍ ព្រោះមានការបត់ចូល និង ការលាដៃ ឬ ជើង ចេញទៅជាបច្ច័យ ហើយលើកយកតែប្រយោជន៍ ឈ្មោះថា **សាត្ថកសម្ប- ជញ្ញ** ក្នុងការបត់ចូល និង ការលាចេញទៅនោះ គប្បីជ្រាបការពិគ្រោះ ពិចារណាដល់ការមិនមានប្រយោជន៍យ៉ាងនេះថា កាលដៃ ឬ ជើងបត់ចូល មកដាក់ទុកយូរ ៗ ឬ លាដៃ ឬ ជើងចេញទៅដាក់ទុកយូរ ៗ វេទនានឹងកើត គ្រប់ ៗ កាល ។ ចិត្តក៏នឹង មិនជាឯកគ្គតាចិត្ត ( មិនជាសមាធិ )

កម្មដ្ឋានក៏នឹងមិនចម្រើន លោកនឹងមិនបានសម្រេចគុណវិសេស ។ តែបត់ចូលសមល្មម លាចេញទៅសមល្មម វេទនានឹងមិនកើតទេឡើង ( ទេឡើយ ) ចិត្តនឹងជា **ឯកគ្គតា** កម្មដ្ឋានក៏នឹងដល់សេចក្តីចម្រើន លោកនឹងបានសម្រេចគុណវិសេស ចំណែកការដែលបច្ច័យ សូម្បីមានព្រះយោគាវចរនៅពិគ្រោះពិចារណាស្ថានទីដែលជាទីសប្បាយ និង មិនសប្បាយ ហើយជ្រើសយកស្ថានទីដែលសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញ** ។ ក្នុង **សប្បាយសម្បជញ្ញ** មានន័យដូចតទៅនេះ ÷

បានឮថា ភិក្ខុកំលោះ ៗ នាំគ្នាសូធ្យមន្តត្រង់លានព្រះចេតិយ៍ធំខាងក្រោយភិក្ខុទាំងនោះ ភិក្ខុនីក្រមុំ ៗ កំពុងស្តាប់ធម៌ ។ ក្នុងចំនួនភិក្ខុទាំងនោះភិក្ខុមួយរូបលាដៃចេញទៅត្រូវ កាយភិក្ខុនី ហើយបានក្លាយទៅជាគ្រហស្ថ ព្រោះហេតុនោះ ៗ ឯង ។ ភិក្ខុមួយរូបទៀតកាលលាជើងចេញទៅ បានលាទៅលើ ភ្លើងភ្លើងឆេះជើងដល់ឆ្អឹង ។ ភិក្ខុមួយរូបទៀតលាចេញទៅត្រង់ដំបូកកណ្តៀរលោកត្រូវអសិរពិសខាំ ។ ភិក្ខុមួយរូបទៀតលាទៅត្រង់ដងក្លស់ ត្រូវពស់វែកខាំលោក ។ ព្រោះដូច្នោះ ( កាលនឹងលាជើង ) ក៏កុំលាទៅក្នុងទីដែលមិនសប្បាយ ដូច្នេះ ។ គួរលាទៅក្នុងទីដែលសប្បាយ ។ នេះជា **សប្បាយ សម្បជញ្ញ** ក្នុងឥរិយាបថបព្វៈនេះ ចំណែក **គោចរសម្បជញ្ញ** គួរសម្តែងដោយរឿងព្រះមហាថេរៈ ។

## រឿង ព្រះមហាថេរៈ

បានឮមកថា ព្រះមហាថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ កាលសន្ទនាជាមួយនឹងអន្តេវាសិក បានបត់ដៃចូល ហើយលាចេញដូចដើម ( បន្ទាប់ពីនោះ ) ទើបសន្សឹម ៗ បត់ដៃចូលទៀត។ ពួកអន្តេវាសិកបានសួរលោកថា

លោកម្ចាស់ ហេតុដូចម្ដេចលោកម្ចាស់ទើបបត់ដៃចូលយ៉ាងរហ័ស ហើយត្រទឡប់លាចេញទុកដូចដើមវិញ បន្ទាប់ពីនោះទើបសន្សឹម ៗ បត់ដៃចូលទៀត ។ ព្រះមហាថេរៈឆ្លើយថា អាវុសោ តាំងពីខ្ញុំផ្ដើមមនសិការកម្មដ្ឋាន ខ្ញុំមិនដែលលះបង់កម្មដ្ឋាន ហើយបត់ចូលទេឡើយ តែវេលានេះខ្ញុំនិយាយនឹងពួកលោក បានលះកម្មដ្ឋានហើយ ទើបបត់ដៃចូល ព្រោះដូច្នោះ ខ្ញុំទើបលាដៃចេញដូចដើមហើយបត់ចូលបន្តិចម្ដងៗ ទៅវិញទៀត ។ អន្តេវាសិកទាំងទឡាយពិតថេរដីកា ថា ល្អហើយ ល្អហើយ លោកម្ចាស់ ធម្មតាភិក្ខុគួរយ៉ាងហ្នឹង ។ សូម្បីក្នុងឥរិយាបថបព្វៈនេះ ការមិនលះបង់កម្មដ្ឋាន គប្បីជ្រាបថា ឈ្មោះថា **គោចរសម្បជញ្ញ** ដោយប្រការដូច្នេះ ។ មិនមានអ្វីខាងក្នុងដែលឈ្មោះថា **អត្តា** បត់ដៃចូលមក ឬ លាដៃចេញទៅ ។ តែការបត់ដៃចូល និង លាជើងចេញមានបានដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត មានប្រការដូចដែលពោលមកហើយ ដូចការកម្រើកដៃ និង ជើងរបស់ទីងមោង ដោយការទាញខ្សែ ព្រោះដូច្នោះ ក៏ការកំណត់ដឹង ( ដូចដែលពោលមកនេះ ) គប្បីជ្រាបចុះថា ឈ្មោះថា មាន **អសម្មោហសម្បជញ្ញ** ក្នុងឥរិយាបថ- បព្វៈនេះ ។

ការប្រើសង្ឃាដី និង ចីវរដោយការស្លៀកការដណ្ដប់ [១] ការប្រើបាត្រដោយការរក្សា ជាដើម ឈ្មោះថា **ធារណៈ** ក្នុងពាក្យថា **សង្ឃាដិបត្ត-ចីវរធារណេ** នេះ ។ ការបានអាមិសរបស់ភិក្ខុអ្នកស្លៀក និង ដណ្ដប់ហើយ ត្រាច់ទៅបិណ្ឌបាត និង ប្រយោជន៍ មានប្រការដូចដែលព្រះមានព្រះភាគត្រាស់

---

[១] បាឋៈថា **និវាសម្បារុបនវសេន** គួរនឹងជា **បារុបនវសេន** ប្រែថា ដណ្ដប់ ព្រោះជាសំពត់ដណ្ដប់ មិនប្រើស្លៀក , ( អ្នកប្រែ ) ។

## ៨៧ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ទុកនោះឯង ដោយន័យមានជាអាទិថា **សីតស្ស បដិឃាតាយ** ( ដើម្បីបំបាត់ភាពរងា ) ។ ឈ្មោះថា ប្រយោជន៍ក្នុងការទ្រទ្រង់សង្ឃាដី និង ចីវរ នោះ អ្នកសិក្សាគួរយល់សាត្ថកសម្បជញ្ញៈ ដោយអំណាចនៃប្រយោជន៍នោះ ដូច្នេះ ។ ចំណែកចីវរសាច់ម៉ដ្ឋ ជាសប្បាយៈរបស់អ្នកមានប្រក្រតីក្តៅ ( ញើស ចេញងាយ ) និង អ្នកមានកម្លាំង ( តិច ) ចីវរសាច់ក្រាស់គ្រោតគ្រាត ជាទីសប្បាយរបស់អ្នកមានប្រក្រតីរងាច្រើន ( ឆាប់រងា ) ខុសអំពីនេះក៏មិនជាទីសប្បាយ ។ ចីវរចាស់មិនជាទីសប្បាយរបស់នរណា ៗ ទេឡើយ ។ ព្រោះវាធ្វើការកង្វល់ចិត្តឱ្យលោកដោយឱ្យការជាប់ចិត្តជាដើម ។ សំពត់ចីវរមួយផ្ទាំង ( មិនបានកាត់ឱ្យជាខណ្ឌ ) និង សំពត់សំបកឈើជាដើម ដែលជាទីតាំងនៃសេចក្តីលោភក៏យ៉ាងនោះ ព្រោះសំពត់ដូច្នោះ ធ្វើអន្តរាយដល់ការនៅតែឯងក្នុងព្រៃ ឬ ធ្វើអន្តរាយដល់ជីវិតក៏មាន និង ដោយត្រង់ហើយ សំពត់ចីវរឯណានីមួយដែលកើតទេឡើង ( បានមក ) ដោយអំណាចមិច្ឆាជីវៈ មានការធ្វើនិមិត្តជាដើម និង ចីវរណាកាលលោកប្រើទៅអកុសលធម៌ចម្រើនទេឡើង កុសលធម៌សាបសូន្យទៅចីវរនោះ **ជាអសប្បាយ** ប៉ុន្តែចីវរដែលខុសអំពីនេះ **ជាសប្បាយ** ។

ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សាគប្បីយល់ **សប្បាយសម្បជញ្ញ** ដោយអំណាចនៃចីវរនោះឯង និង **គោចរសម្បជញ្ញ** ដោយអំណាចការមិនបោះបង់ចោលកម្មដ្ឋាន ។

មិនមានអ្វីដែលឈ្មោះថា **អត្តា** ក្នុងខាងក្នុងរបស់ភិក្ខុអ្នកដណ្តប់ចីវរ មានតែការដណ្តប់ចីវរ ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្តមានប្រការដូចដែលពោលហើយប៉ុណ្ណោះ ។ បណ្តាចីវរ និង កាយ ទាំង ២ យ៉ាងនោះ សូម្បីចីវរក៏មិនមានការតាំងចិត្ត សូម្បីកាយក៏មិនមានការ

តាំងចិត្ត ចីវរក៏មិនដឹងថា យើងគ្របដណ្តប់កាយ ។ សូម្បីកាយក៏មិនដឹងថា ចីវរគ្របដណ្តប់យើង ។ ធាតុទាំងទឡាយប៉ុណ្ណោះគ្របដណ្តប់ធាតុ ដូចយកសំពត់ចាស់ខ្ចប់រូបគីគម្ពីរ ព្រោះដូច្នេះ បានចីវរដែលល្អហើយ ក៏មិនគួរធ្វើសេចក្តីត្រេក-អរទេឡើយ បានមិនល្អ ក៏មិនគួរទោមនស្ស អធិប្បាយថា មនុស្សពួកខ្លះនាំគ្នាសក្ការបូជា នាគ ដំបូក ចេតីយ៍ និង ដើមឈើ [១] ជាដើម ដោយផ្កាគ្រឿងក្រអូប និង សំពត់ជាដើម ។ តែមនុស្សពួកខ្លះធ្វើវត្ថុដែលមិនមែន សក្ការៈ ដូចបន្ទោបង់ឧច្ចារៈបស្សាវៈដាក់ យកភក់លាប យកកំណាត់ឈើ វាយនឹងសស្ត្រាប្រហារជាដើម នាគ ដំបូក និង ដើមឈើជាដើម នឹងមិនធ្វើសេចក្តីត្រេកអរ សេចក្តីមិនត្រេកអរចំពោះសក្ការៈ ឬ អសក្ការៈនោះ ( យ៉ាងណា ) ភិក្ខុក៏ដូច្នេះដូចគ្នា បានចីវរល្អហើយ ក៏មិនគួរធ្វើសេចក្តីត្រេកអរ បានចីវរមិនល្អ ក៏មិនគួរទោមនស្ស ។ ក្នុងសម្បជញ្ញបព្វៈនេះ អ្នកសិក្សាគួរយល់ **អសម្មោ-ហសម្បជញ្ញ** ដោយអំណាចការពិចារណាដែលប្រព្រឹត្តទៅហើយ ដូចដែលពណ៌នាមកនេះចុះ ។

សូម្បីក្នុងការបីបាត្រ ក៏គួរជ្រាប **អសម្មោហសម្បជញ្ញ** ដោយអំណាចប្រយោជន៍ដែលនឹងគប្បីបាន [១] ព្រោះមានការកាន់បាត្រជាបច្ច័យយ៉ាងនេះថា យើងនឹងមិនប្រញាប់ប្រញាល់កាន់បាត្រ តែនឹងកាន់យកបាត្រ ( ដោយមានកម្មដ្ឋានជាសំខាន់ ) ត្រាច់ទៅបិណ្ឌបាត ក៏នឹងបានភិក្ខា ។

---

[១] **បាឋៈ**ថា **នានាវម្មិកចេតិយរុក្ខាទីសុ** ច្បាប់ភូមាជា **នាគវម្មិកចេតិយរុក្ខាទីសុ** ប្រែតាមច្បាប់ភូមា ។

[១] **បាឋៈ** ថា **បដលភិតព្វំ អត្ថវសេន** ភូមាជា **បដិលភិតព្វ អត្ថវសេន** ប្រែតាមច្បាប់ភូមា ។

ចំណែកបាត្រធ្ងន់ មិនជាសប្បាយសម្រាប់ភិក្ខុអ្នកមានរាងកាយស្គម និងកម្លាំងតិច ហើយបាត្រដែលផ្សារភ្ជាប់ ( ដែក ) រួមគ្នា ៤ - ៥ ផ្ទាំងខាត់មិនរាបស្មើល្អ មិនជាសប្បាយដល់បុគ្គលណានីមួយទេឡើយ [២] ។ ព្រោះថា បាត្រដែលលាងលំបាក មិនជាទីសប្បាយ ក៏កាលលាងបាត្រនោះឯង លោកនឹងមានការកង្វល់ ។ ចំណែកបាត្រដែលមានពណ៌ដូចកែវមណី ជាទីតាំងនៃលោភៈ មិនជាសប្បាយដោយន័យដែលបានពោលទុកហើយក្នុងចីវរនោះឯង តែបាត្រដែលបានពោលមកដោយការធ្វើនូវនិមិត្តជាដើម បាត្រណាកាលភិក្ខុនោះប្រើអកុសលធម៌នឹងចម្រើនទេឡើង ឯកុសលធម៌នឹងសាបសូន្យទៅ បាត្រនេះជាអសប្បាយដោយចំណែកមួយប៉ុណ្ណោះ បាត្រដែលផ្សេងដទៃ ( ក្រៅពីនោះ ) ជាសប្បាយ ។ គប្បីជ្រាប **សប្បាយសម្បជញ្ញ** ដោយអំណាចនៃបាត្រ នោះគប្បីជ្រាប **គោចរសម្បជញ្ញ** ដោយមិនលះបង់ កម្មដ្ឋាន ។

មិនមានអ្វីដែលឈ្មោះថា **ជាអត្តា** ក្នុងខាងក្នុងដល់ភិក្ខុបីបាត្រ ធម្មតាការបីបាត្រ នឹងមានបាន ក៏ដោយការផ្សាយទៅនៃវាយោធាតុដែលកើតទេឡើងព្រោះកិរិយារបស់ចិត្ត មានប្រការដូចដែលពោលមកហើយ បណ្ដាដៃ និងបាត្រទាំង ២ យ៉ាងនោះ ទាំងបាត្រក៏មិនមានការតាំងចិត្ត ទាំងដៃក៏មិនមានការតាំងចិត្ត បាត្រក៏មិនដឹងថា ដៃបីយើង សូម្បីដៃក៏មិនដឹងថា យើងបីបាត្រ ធាតុទាំងទឡាយប៉ុណ្ណោះ បីពួកធាតុ ដូចក្នុងវេលាយកដង្កាប់ចាប់បាត្រដែលដុតនឹងភ្លើង ព្រោះដូច្នោះ ក្នុងសម្បជញ្ញបព្វៈនេះ គប្បីជ្រាប **អសម្មោហសម្បជញ្ញ** ដោយការពិចារណាអត្ថដែលប្រព្រឹត្តទៅហើយ ដូចដែលពណ៌នាមកនេះ ។

ម្យ៉ាងទៀត ភិក្ខុណាពិចារណាឃើញចីវរដូចសំពត់រុំដំបៅ បាត្រដូចជា

---

[២] **បាឋៈ** ថា **អសប្បាយោ ច** ភូមាជា **អសប្បាយោវ** ប្រែតាមភូមា ។

អំបែងដាក់ថ្នាំ ភិក្ខុដែលបានមកក្នុងបាត្រដូចថ្នាំក្នុងអំបែង ភិក្ខុនេះគប្បីជ្រាបចុះថា ជាអ្នកមានប្រក្រតីធ្វើសេចក្តីដឹងខ្លួនដ៏ខ្ពង់ខ្ពស់ជាទីបំផុតជាប្រក្រតីដោយ **អសម្មោហសម្បជញ្ញ** ក្នុងការទ្រទ្រង់សង្ឃាដី បីបាត្រ និង ដណ្តប់ចីវរ ដូចបុរសដែលមានករុណា ឃើញមនុស្សអនាថាដេកនៅក្នុងសាលាសម្រាប់មនុស្សអនាថាមានដៃជើងកំបុត មានទឹករងៃ និង ឈាម ទាំងពួកដង្កូវហូរចេញអំពីមុខដំបៅ មានរុយក្បាលខៀវទំបីតដំបៅ ទើបបានស្វែងរកសំពត់រុំមុខដំបៅ និង ថ្នាំព្រមទាំងអំបែងដាក់ថ្នាំទៅប្រគល់ឱ្យពួកគេទាំងនោះ ក្នុងចំនួនវត្ថុទាំងនោះសូម្បីសំពត់ដែលមានសាច់ម៉ដ្ឋក៏ធ្លាក់ដល់ពួកគេខ្លះ ដែលមានសាច់គ្រោត-គ្រាតធ្លាក់ដល់ពួកគេខ្លះ សូម្បីត្រទេឡាកដូងដាក់ថ្នាំដែលមានទ្រង់ទ្រាយស្អាត ក៏ធ្លាក់ដល់ពួកគេខ្លះ ដែលមានទ្រង់ទ្រាយមិនស្អាតក៏ធ្លាក់ដល់ពួកគេខ្លះ ពួកគេនឹងមិនត្រេកអរ ឬ ទោមនស្សក្នុងវត្ថុទាំងនោះ ព្រោះពួកគេមានសេចក្តីត្រូវការសំពត់ត្រឹមតែប្រើបិទដំបៅប៉ុណ្ណោះ និងត្រទេឡាកដូងត្រឹមតែប្រើដាក់ថ្នាំប៉ុណ្ណោះដូច្នោះ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងការឆាន់ ជាដើម (ដូចតទៅនេះ) ÷

បទថា **អសិតេ** សេចក្តីថា ក្នុងការឆាន់បិណ្ឌបាត ។

បទថា **បីតេ** សេចក្តីថា ក្នុងការផឹកទឹកបបរជាដើម ។

បទថា **ខាទិតេ** សេចក្តីថា ក្នុងការទំពាស៊ីនូវខាទនីយៈដែលធ្វើដោយម្សៅជាដើម ។

បទថា **សាយិតេ** សេចក្តីថា ក្នុងការទទួលរសមានស្ករអំពៅជាដើម ។

ក្នុងការឆាន់ជាដើមនោះ ប្រយោជន៍ទាំង ៨ យ៉ាង ដែលព្រះពុទ្ធត្រាស់ទុកដោយន័យមានជាអាទិថា **នេវ ទវាយ** ( មិនមែនដើម្បីលេង ) ឈ្មោះថា

ប្រយោជន៍ អ្នកសិក្សាគប្បីជ្រាប **សាត្ថកសម្បជញ្ញ** ដោយអំណាចនៃ ប្រយោជន៍នោះ ។

ក៏បុគ្គលណាមានសេចក្ដីមិនសប្បាយ ព្រោះភោជនណា ភោជននោះ ជាអសប្បាយសម្រាប់បុគ្គលនោះ ចំណែកភោជនណាបានមកដោយការធ្វើនូវនិមិត្តជាដើម ហើយកាលលោកឆាន់ភោជនណាអកុសលធម៌ទាំងឡាយចម្រើនទេឡើង កុសលទាំងឡាយសាបសូន្យទៅ ។ ភោជននោះ ជាអសប្បាយតែម្យ៉ាងប៉ុណ្ណោះ ។ តែភោជនក្រៅពីនេះជាសប្បាយ ។

អ្នកសិក្សាគួរយល់ **សប្បាយសម្បជញ្ញ** ដោយអំណាចនៃភោជនដែលជាសប្បាយនោះ នឹងគប្បីជ្រាប **គោចរសម្បជញ្ញ** ដោយមិនលះបង់កម្មដ្ឋានទេឡើយ ។

មិនមាននរណាឈ្មោះថាជាអត្តា ក្នុងខាងក្នុងជាអ្នកបរិភោគ មានតែការទទួលបាត្រ ធម្មតាដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ ចិត្តមានប្រការដូចដែលពោលមកហើយប៉ុណ្ណោះ មានតែការលូកដៃចុះក្នុង បាត្រធម្មតាដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតអំពីកិរិយារបស់ចិត្ត ប៉ុណ្ណោះ មានតែការពូតដុំបាយ ការលើកដុំបាយទេឡើង និង ការបើកមាត់ ទទួលដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ មិនមានអ្នកណាយកកូនសោ និង គ្រឿងយន្តបើកឆ្អឹងចង្កា មានតែការដាក់ពំនូតបាយក្នុងមាត់ ការឱ្យធ្មេញខាងលើធ្វើនាទីជំនួសអង្រែ ការឱ្យធ្មេញខាងក្រោមធ្វើនាទីជំនួសត្បាល់ និងការឱ្យអណ្ដាតធ្វើនាទីជំនួសដៃដោយការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។

ដោយហេតុយ៉ាងនេះ ទឹកមាត់ចំនួនតិចតួចចុងអណ្ដាត ក្នុងបណ្ដាចុង

និងគល់នោះ ( ហើយ ) ទឹកមាត់ចំនួនច្រើនត្រង់គល់អណ្ដាត ក៏នឹងលាយទន្ទាំពំនូតបាយនោះ ពំនូតបាយនោះនឹងប្រមៀលទៅមកដោយដៃ គឺ អណ្ដាតក្នុងត្បាល់ គឺ ធ្មេញ ( ថ្គាម ) ក្រោម សើមទៅដោយទឹកមាត់គឺស្លេស្ម៍ បុកយ៉ាងល្អិតដោយអង្រែ គឺ ធ្មេញ ( ថ្គាម ) លើ , ឈ្មោះថា នរណា ៗ នឹងយកស្លាបព្រា ឬ វែកស៊កចូលទៅខាងក្នុង ( មាត់ ) មិនមាន , (ពំនូតបាយ ) ចូលទៅបានព្រោះវាយោធាតុនោះឯង ពំនូតបាយដែលចូលទៅហើយ នរណា ៗ ឈ្មោះថា នឹងឱ្យបញ្ឈប់ទុកធ្វើឱ្យ ( ដូច ) ជាគំនរចំបើងទុកមិន មានតែនឹងបញ្ឈប់ទុកបានដោយអំណាចវាយោធាតុប៉ុណ្ណោះ , ដែលបញ្ឈប់ ទុកហើយ នរណា ៗ ឈ្មោះថានឹងតាំងចង្ក្រាន បង្កាត់ភ្លើងបបរឱ្យរលួយមិនមាន តែនឹងរលួយបានព្រោះតេជោធាតុប៉ុណ្ណោះ , ដែលរលួយហើយ ៗ នរណា ៗ ឈ្មោះថានឹងយកឈើច្រត់កៀរចេញទៅខាងក្រៅក៏មិនមាន , វាធាតុប៉ុណ្ណោះ នឹងនាំចេញទៅ , ដោយហេតុយ៉ាងនេះ វាយោធាតុនាំ ( ពំនូតបាយ ) ចូលទៅផង នាំចេញទៅផង ឱ្យឈប់នៅផង ឱ្យប្រមៀលទៅមកផង ឱ្យរលាយ ទៅផង ឱ្យនាំ ( កាក ) ចេញទៅផង , បឋវីធាតុទ្រទ្រង់ទុកផង ឱ្យប្រមៀលទៅមកផង , ឱ្យរលាយផង , អាបោប្រមូលផ្ដុំផង រក្សាទុកឱ្យស្រស់ផង , តេជោធាតុនឹងរំលាយនូវអាហារដែលចូលទៅខាងក្នុងហើយ អាកាសធាតុជាប្រហោង វិញ្ញាណធាតុនឹកដល់ដោយអាស្រ័យការប្រកបគ្នាដោយប្រពៃក្នុងធាតុនោះៗ អ្នកសិក្សាគប្បីយល់សម្មោហសម្បជញ្ញៈ ក្នុងសម្បជញ្ញបព្វៈដោយការពិចារណា ដែលប្រព្រឹត្តទៅហើយ ដូចដែលពណ៌នាមកនេះចុះ ។

## បដិកូល ១០

ម្យ៉ាងទៀត ព្រះយោគាវចរគួរជ្រាប **អសម្មោហសម្បជញ្ញ** ក្នុង **សម្បជញ្ញបព្វ** នេះ ដោយការពិចារណាដល់បដិកូល ១០ យ៉ាងនេះ គឺ ដោយការទៅ ១ ដោយការស្វែងរក ១ ដោយការឆាន់ ១ ដោយអធ្យាស្រ័យ ១ ដោយការរក្សាទុក ( ក្នុងក្រពះអាហារ ) ១ ដោយចំណែកដែលនៅមិនទាន់រលាយ ១ ដោយចំណែកដែលរលាយហើយ ១ ដោយផល ១ ដោយជ្រួតជ្រាប ១ ដោយប្រទឡាក់ប្រទឡូស ១ ចំណែកកថាយ៉ាងពិស្តារក្នុងសម្បជញ្ញបព្វៈនេះ គួរកាន់យកអំពីនិទ្ទេសនៃ **អាហារេបដិកូលសញ្ញា** ក្នុង **គម្ពីរវិសុទ្ធិមគ្គ** ចុះ ។

បទថា **ឧច្ចារបស្សាវកម្មេ** សេចក្តីថា បន្ទោបង់ឧច្ចារៈ និង បស្សាវៈ ( ព្រោះថា ) ដល់វេលានោះហើយ កាលមិនបន្ទោបង់ឧច្ចារបស្សាវៈ ញើសនឹងហូរចេញទូទាំងសព៌ាង្គកាយ ភ្នែកនឹងព្រិល ចិត្តមិនជាឯកគ្គតា ហើយរោគដទៃៗក៏នឹងកើតទេឡើង ។ តែការបន្ទោបង់ហើយ វត្ថុទាំងអស់នោះនឹងមិន មាន ព្រោះដូច្នេះ សេចក្តីនេះជាអត្ថាធិប្បាយក្នុងពាក្យថា **ឧច្ចារបស្សាវ_ កម្មេ** នេះ អ្នកសិក្សាគប្បីយល់ សាត្ថកសម្បជញ្ញៈ ដោយអំណាចនៃ សេចក្តីនោះ ។

តែកាលបន្ទោបង់ឧច្ចារបស្សាវៈក្នុងទីដែលមិនសមគួរនឹងជាអាបត្តិ នឹងវិនាសយស ( ខូចកិត្តិយស ) និងមានអន្តរាយដល់ជីវិត តែកាលបន្ទោបង់ក្នុងទីដ៏សមគួរ វត្ថុទាំងអស់នោះនឹងមិនមាន ព្រោះដូច្នោះ ការបន្ទោបង់ក្នុងទីដ៏សមគួរនេះ ទើបជាសប្បាយក្នុងឧច្ចារបស្សាវកម្មនេះ អ្នកសិក្សាគប្បីជ្រាប **សប្បាយសម្បជញ្ញ** ដោយអំណាចនៃសប្បាយនោះ ចំណែក **គោចរ_**

**សម្បជញ្ញ** គប្បីជ្រាបដោយអំណាចការមិនបោះបង់ចោលកម្មដ្ឋាននោះឯង ។ មិនមាននរណាៗ ឈ្មោះថាជាអត្តាក្នុងខាងក្នុង បន្ទោបង់ឧច្ចារបស្សាវៈ មានតែការបន្ទោបង់ឧច្ចារបស្សាវៈ ព្រោះការផ្សាយទៅនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។ ក៏ឧច្ចារៈ និង បស្សាវៈដែលនៅក្នុងពោះវៀន និង ក្រពះបស្សាវៈត្រូវកម្លាំងខ្យល់រុញច្រានទៅក៏នឹងចេញទៅឯង ដោយមិនប្រាថ្នាឱ្យចេញទេឡើយ ដូចកាលបូសចាស់ហើយ ខ្ទុះ និង ឈាមហូរចេញទៅឯងដោយមិនប្រាថ្នា ( ឱ្យហូរ ) ព្រោះបូសបែក និង ដូចទឹកដែលហូរចេញចាកភាជនៈដាក់ទឹកដែលច្រាលហើយ ដោយមិនប្រាថ្នា ( ឱ្យហូរ ) ដូច្នោះ ។

ក៏ឧច្ចារៈ និង បស្សាវៈនេះណា ដែលបន្ទោបង់ចេញទៅហើយ ឧច្ចារៈ និង បស្សាវៈនេះនោះនៃអត្តារបស់ភិក្ខុនោះ នឹងមិនមានទេឡើយ របស់អ្នកដទៃ ក៏មិនមាន មានតែការបន្ទោបង់របស់រាងកាយប៉ុណ្ណោះ ។

ដូចអ្វី ?

ដូចកាលចាក់ទឹកចេញពីផ្ទាំងហើយ ផ្ទាំងក៏មិនមានទឹកនោះទេឡើយ វត្ថុដទៃក៏មិនមាន មានត្រឹមតែការបដិបត្តិម្យ៉ាងប៉ុណ្ណោះ យ៉ាងណាមិញ អ្នកសិក្សាគប្បីយល់ **សម្មោហសម្បជញ្ញ** ក្នុង **សម្បជញ្ញបព្វ** នេះ ដោយការពិចារណាកិរិយាអាការដែលប្រព្រឹត្ត ទៅហើយ ដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការដើរជាដើម (ដូចតទៅនេះ )

បទថា **គតេ** បានដល់ ក្នុងការដើរទៅ ។

បទថា **ឋិតេ** បានដល់ ក្នុងការឈរ ។

បទថា **និសិន្នេ** បានដល់ ក្នុងការអង្គុយ ។

បទថា **សុត្តេ** បានដល់ ក្នុងការដេកលក់ ។

# ៩៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

បទថា **ជាគរិតេ** បានដល់ ក្នុងការភ្ញាក់ ។

បទថា **ភាសិតេ** បានដល់ ក្នុងការពោល ។

បទថា **តុណ្ហីភាវេ** បានដល់ក្នុងការមិននិយាយ

ព្រះអង្គបានត្រាស់តិរិយាបថវែងឆ្ងាយទុកក្នុងឋានៈនេះថា កាលដើរទៅក៏ដឹងច្បាស់ថា យើងកំពុងដើរទៅខ្លះ , ឈរហើយក៏ដឹងច្បាស់ថាយើងឈរហើយខ្លះ , អង្គុយហើយ ក៏ដឹងថាយើងអង្គុយខ្លះ ដេកហើយក៏ដឹងច្បាស់ថាយើងដេកហើយខ្លះ ។ ត្រាស់តិរិយាបថកណ្ដាល ៗ ទុកក្នុងឋានៈនេះថា ក្នុងការឈានទៅមុខ , ក្នុងការឈានទៅក្រោយ , ក្នុងការក្រទេឡ្បកមើលទៅមុខ ។ ក្នុងការក្រទេឡ្បកមើលឆ្វេងស្ដាំ , ក្នុងការលាចេញ តែក្នុងបព្វៈនេះ ត្រាស់តិរិយាបថតូច ៗ ទុកថាក្នុងការដើរ ក្នុងការឈរ ក្នុងការអង្គុយ ក្នុងការដេក ក្នុងការភ្ញាក់ ព្រោះដូច្នោះ គប្បីជ្រាបភាពជាអ្នកធ្វើសេចក្ដីដឹងខ្លួនជាប្រក្រតី ដោយន័យដែលត្រាស់ទុកក្នុងឋានទាំងនេះនោះឯង ។

ក៏ព្រះមហាសិវត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក បានពោលទុកថា អ្នកណាដើរទៅឬ ឈរចង្ក្រមយូរ ៗ ហើយតមកទើបឈរពិចារណាឃើញយ៉ាងនេះ ថា រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាចង្ក្រម បានរលត់ទៅហើយក្នុងវេលាចង្ក្រមនេះឯង អ្នកនេះនោះ ឈ្មោះថាធ្វើសេចក្ដីដឹងខ្លួនក្នុងការដើរ ។

អ្នកណា កាលធ្វើការស្វាធ្យាយន៍ , ឆ្លើយបញ្ហា ឬ មនសិការកម្មដ្ឋានឈរនៅយូរ ៗ ហើយតមកទើបអង្គុយពិចារណាឃើញយ៉ាងនេះថា រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាឈរបានរលត់ទៅហើយ ក្នុងវេលាឈរនោះឯង អ្នកនេះនោះ ឈ្មោះថា ធ្វើសេចក្ដីដឹងខ្លួនក្នុងការឈរ ។

## ៩៦ អដ្ឋកថា សតិប្បដ្ឋានសូត្រ

អ្នកណាអង្គុយយូរៗ ដោយធ្វើការស្វាធ្យាយន៍ជាដើមនោះឯង ហើយត. មកទើបដេកពិចារណាឃើញយ៉ាងនេះ រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាអង្គុយ បានរលត់ទៅហើយក្នុងវេលាអង្គុយនោះឯង អ្នកនេះ នោះឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការអង្គុយ ។

បុគ្គលណាដេកបណ្តើរធ្វើការស្វាធ្យាយបណ្តើរ ឬ មនសិការកម្មដ្ឋានបណ្តើរ ឈានចុះកាន់ភាពលង់លក់ តមកទើបក្រោកទេឡើង ពិចារណាឃើញយ៉ាងនេះថា រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាដេកបានរលត់ទៅហើយក្នុងវេលាដេកនោះឯង បុគ្គលនេះ ឈ្មោះថា ធ្វើសេចក្តីដឹងខ្លួនក្នុងការដេកលក់ ទាំងក្នុងការភ្ញាក់ ។ ព្រោះថា ចិត្តដែលសម្រេចដោយកិរិយាមិនមានការប្រព្រឹត្តិទៅ ( មិនទេឡើងកាន់វិថី ) ឈ្មោះថា ដេកលក់ មានការប្រព្រឹត្តិទៅឈ្មោះថា ភ្ញាក់ ព្រោះដូច្នោះ ( អ្នកនោះ ទើបឈ្មោះថា ធ្វើការដឹងខ្លួន ទាំងក្នុងការដេកលក់ ទាំងក្នុងការភ្ញាក់ )។

ចំណែកបុគ្គលណា កាលនិយាយ ក៏និយាយមានសតិសម្បជញ្ញៈថា ធម្មតាសំទេឡងនេះ អាស្រ័យបបូរមាត់ អាស្រ័យធ្មេញ អណ្តាត ពិដាន និងប្រយោគរបស់ចិត្តដែលសមគួរនឹងចិត្តនោះ ហើយទើបកើតទេឡើងបាន ។

ម្យ៉ាងទៀត បុគ្គលណាធ្វើការស្វាធ្យាយន៍ធម៌ ប្រាប់ធម៌ ប្រែធម៌ ( បង្រៀន ) កម្មដ្ឋាន ឬ វិសជ្ជនាបញ្ហាអស់វេលាយូរ តមកទើបស្ងៀមពិចារណាយ៉ាងនេះថា រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលានិយាយក៏រលត់ទៅហើយក្នុងវេលានិយាយនេះឯង ។ បុគ្គលនេះ ឈ្មោះថា មានសម្បជញ្ញៈក្នុងការនិយាយ ។

បុគ្គលណាមានតុណ្ហីភាព មនសិការដល់ធម៌ ឬ កម្មដ្ឋានអស់វេលាយូរ

តមកពិចារណាឃើញយ៉ាងនេះថា រូបធម៌ និង អរូបធម៌ដែលប្រព្រឹត្តទៅហើយក្នុងវេលាស្មៀម ក៏បានរលត់ទៅហើយក្នុងវេលាស្មៀមនោះឯង កាលមានការប្រព្រឹត្តទៅនៃឧបាទាយរូប ( គេ ) ក៏ឈ្មោះថា និយាយ កាលមិនមាន ក៏ឈ្មោះថាជាអ្នកស្មៀម បុគ្គលនេះឈ្មោះថាមានសម្បជញ្ញៈក្នុងការនៅស្មៀម ។

សម្បជញ្ញៈដែលមានអសម្មោហជាធុរៈ ដែលព្រះមហាថេរៈពោលទុកហើយនោះ ព្រះអង្គទ្រង់បំណងយកហើយ ក្នុងសតិប្បដ្ឋានសូត្រនេះ ។ ចំណែកក្នុងសាមញ្ញផលសូត្របានសម្បជញ្ញៈទាំងអស់ ៤ យ៉ាង ។ ព្រោះដូច្នោះ ក្នុង **សាមញ្ញផលសូត្រ** នេះ អ្នកសិក្សាគប្បីជ្រាបចំពោះសម្បជញ្ញៈទុកជាពិសេសដោយអំណាចសម្បជញ្ញៈដែលមិនវង្វេង ។ ហើយក្នុងគ្រប់ ៗ បទថា **សម្ប-ជានការី សម្បជានការី** អ្នកសិក្សាគប្បីជ្រាបសេចក្ដីអធិប្បាយដោយអំណាចសម្បជញ្ញៈដែលប្រកបដោយសតិដូចគ្នា ។

ចំណែកក្នុងវិភង្គប្បករណ៍ ព្រះអង្គទ្រង់ចែកបទទាំងនេះ ទុកយ៉ាងនេះដូចគ្នាថា ព្រះយោគាវចរមានសតិ មានសម្បជញ្ញៈ ឈានទៅខាងមុខ មានសតិមានសម្បជញ្ញៈថយក្រោយ ។

បទថា **ឥតិ** [១] **អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរឈ្មោះថាពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬ របស់អ្នកដទៃ គឺ ក្នុងកាយរបស់ខ្លួនតាមកាល ( ដែលគួរ ) របស់អ្នកដទៃតាមកាល ( ដែលគួរ ) ដោយការកំណត់ដោយសម្បជញ្ញៈ ៤ ប្រការយ៉ាងនេះ ។

សូម្បីក្នុង **ចតុសម្បជញ្ញបព្វ** នេះ ក៏គួរនាំយកការកើតការរលត់នៃរូបក្ខន្ធនោះឯង ទៅប្រកបក្នុងពាក្យទាំងទឡ្បាយមានជាអាទិថា **សមុទយ-**

---

[១] បាឋៈថា **ឥទានិ** តែស័ព្ទភូមាជា **ឥតិ** ប្រែតាមច្បាប់ភូមា ។

**វយធម្មានុបស្សី វា** ពាក្យដ៏សេសដូចគ្នានឹងពាក្យដែលបានពោលមកហើយនោះឯង ។

## អរិយសច្ច ក្នុងសម្បជញ្ញ

ក្នុងទីនេះ សតិដែលកំណត់ដោយសម្បជញ្ញៈ ៤ ប្រការ ជាទុក្ខសច្ច តណ្ហាពីអតីត ដែលញុំាងសតិឱ្យប្រាកដ ( ជាសមុដ្ឋានរបស់សតិ ) ជាសមុទ-យសច្ច ការមិនប្រព្រឹត្តទៅនៃសតិ និង តណ្ហាទាំងពីរនោះ ជានិរោធសច្ច អរិយមគ្គមានប្រការដូចដែលពោលមកហើយ ជាមគ្គសច្ច ព្រះយោគាវចរខ្វល់ខ្វាយដោយអំណាចសច្ចៈទាំង ៤ យ៉ាងនេះហើយនឹងសម្រេចការរលត់ ( តណ្ហា ) ព្រោះដូច្នោះ ទើបជាផ្លូវនាំចេញចាកទុក្ខ រហូតដល់អរហត្តដោយអំណាចនៃព្រះយោគាវចរអ្នកកំណត់ដោយសម្បជញ្ញៈ ៤ ប្រការមួយរូបនោះឯង ។

## ( ចប់ ចតុសម្បជញ្ញបព្វៈ )

## បដិក្កូលមនសិការបព្វ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនាដោយអំណាចនៃសម្បជញ្ញៈ ៤ ប្រការដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអំណាចមនសិការដោយជារបស់បដិក្កូល ទើបបានត្រាស់ពាក្យមានជាអាទិថា **បុន ចបរំ** ដូច្នេះ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងបដិក្កូលមនសិការបព្វៈ ដូចតទៅនេះ ÷

ពាក្យណាដែលនឹងត្រូវពោលក្នុងពាក្យថា **ឥមមេវ កាយំ** ជាដើម

ពាក្យនោះទាំងអស់ [១] បានពោលទុកហើយក្នុង **កាយគតាសតិកម្មដ្ឋាន** ក្នុងគម្ពីរវិសុទ្ធិមគ្គដោយពិស្តារ ដោយអាការគ្រប់យ៉ាង ។

បទថា **ឧភតោមុខា** សេចក្តីថា ( ថៃ ) ប្រកបដោយមាត់ពីរសងខាង គឺ ទាំងខាងក្រោម ទាំងខាងលើ ។ បទថា **នានាវិហិតស្ស** ប្រែថា មានប្រភេទផ្សេងៗ ។

ក៏ក្នុងរឿងនេះ មានសេចក្តីឧបមាជាការប្រៀបធៀបដូច្នេះ ÷

អធិប្បាយថា កាយ គឺ មហាភូតរូប ៤ គប្បីជ្រាបថា ដូចថៃដែលមានមាត់ទាំងពីរខាង អាការ ៣២ មានសក់ជាដើម គប្បីជ្រាបថា ដូចធញ្ញជាតិច្រើនប្រភេទដែលលាយចម្រុះគ្នាក្នុងថៃ ព្រះយោគាវចរ គប្បីជ្រាប ថា ដូចបុរសមានភ្នែកល្អ ។ ការប្រាកដច្បាស់នៃអាការ ៣២ ដល់ព្រះយោគី គប្បីជ្រាបថា ដូចវេលាដែលធញ្ញជាតិច្រើនគ្រប់ប្រភេទ [២] ប្រាកដដល់បុរសនោះអ្នកស្រាយថៃនោះហើយ ពិនិត្យមើលដូច្នោះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរ ឈ្មោះថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬ ក្នុងកាយរបស់អ្នកដទៃ គឺ ក្នុងកាយរបស់ខ្លួនតាមកាល ( ដ៏សមគួរ ) ឬ ក្នុងកាយរបស់អ្នកដទៃតាមកាល ( ដ៏សមគួរ ) ដោយការកំណត់ក្នុងសក់ជាដើម ។ ពាក្យតអំពីនេះទៅ មានន័យដូចដែលបានពោលហើយនោះឯង ។ ពិតណាស់ ក្នុង **បដិកូលមនសិ_ ការបព្វ** នេះ សតិដែលកំណត់អាការ ៣២ ជាទុក្ខសច្ចតែម្យ៉ាង អ្នកសិក្សាគួរធ្វើការប្រកបសេចក្តីដូចដែលពណ៌នាមកយ៉ាងនេះ ហើយគប្បី ជ្រាបផ្លូវនៃ

---

[១] ច្បាប់ភូមាមានពាក្យថា សព្វំ ទើបប្រែតាមបាលីរបស់ភូមា ។

[២] បាឋៈថា **បក្ខិតនានាវិធធញ្ញំ** ច្បាប់ភូមាជា **បក្ខិត្តនានាវិធធញ្ញស្ស** ប្រែតាមភូមា ។

ការចេញ ( ចាកទុក្ខ ) ។ ពាក្យដ៏សេស ( អំពីពាក្យដែលអធិប្បាយមកហើយនេះ ) ដូចគ្នានឹងពាក្យមុននោះឯង ។

**( ចប់ បដិកូលមនសិការបព្វៈ )**

## ធាតុមនសិការបព្វ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនា ដោយអំណាចបដិកូលមនសិការយ៉ាងនេះហើយ ឥទឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអំណាចមនសិការដល់ធាតុ ទើបត្រាស់ពាក្យមានជាអាទិថា **បុន ចបរំ** ទុក ។ ក្នុងពាក្យទាំងនោះមានការពណ៌នាសេចក្តី ព្រមនឹងពាក្យឧបមាជាការប្រៀប-ធៀបគ្នា ដូច្នេះ ។

## ប្រៀបធៀបភិក្ខុដូចបុគ្គលសម្លាប់គោ

បុគ្គលអ្នកសម្លាប់គោ ឬ អន្តេវាសិកនៃបុរសអ្នកសម្លាប់គោដែលប៉ិនប្រសប់សម្លាប់គោហើយរំលែកជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំបែកជា ៤ ពោលគឺត្រង់កណ្តាលថ្នល់ធំដែលបែកចេញទៅ ៤ ទិស យ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា ពិចារណានូវកាយតាមដែលតាំងនៅហើយដោយអាការយ៉ាងណានីមួយនៃឥរិយាបថទាំង ៤ ហើយតាមដែលតម្កល់នៅហើយ ព្រោះតាមដែលបានតាំងសច្ចាបណិធានទុកយ៉ាងនេះថា មាននៅក្នុងកាយនេះ ( គឺ ) ធាតុដី ។ ល ។ ធាតុខ្យល់ ។

មានពុទ្ធាធិប្បាយទុកដូចម្តេច ?

មានពុទ្ធាធិប្បាយទុកថា បុរសអ្នកសម្លាប់គោ កាលកំពុងចិញ្ចឹមគោ ក្តី កំពុងដឹកទៅកាន់ទីសម្លាប់ក្តី លុះដឹកទៅហើយកំពុងចងឱ្យឈរនៅទីនោះក្តី

កំពុងសម្លាប់ក្តី កំពុងមើលគោដែលគេសម្លាប់ហើយក្តី ការសម្គាល់ថាមេគោនៅមិនទាន់បាត់ទៅ រហូតវេលាដែលមិនទាន់រំលែកមេគោនោះបែងចេញជាចំណែក ៗ តែលុះអង្គុយបែងចែក ( សាច់ ) ហើយ សេចក្តីដឹងខ្លួនថាមេគោក៏បាត់ទៅ , ការសម្គាល់ថា សាច់ក៏នឹងប្រព្រឹត្តទៅចូលមកជំនួស គេនឹងមិនមានការគិតយ៉ាងនេះថា យើងលក់មេគោ គេទាំងនេះទិញមេគោ , ដោយពិតហើយ គេនឹងមានការគិតយ៉ាងនេះប៉ុណ្ណោះថា យើងលក់សាច់គោគេទាំងនេះទិញសាច់ យ៉ាងណា ។ ក្នុងវេលាដែលភិក្ខុសូម្បីរូបនេះនៅជាពាលបុថុជ្ជននៅទេឡើយក៏ដូច្នោះដូចគ្នា ការសម្គាល់ថា សត្វ ឬ បុគ្គល របស់លោក កាលនៅជាគ្រហស្ថក្តី បួសហើយក្តី នៅមិនទាន់អន្តរធានទៅរហូតវេលាដែលនៅមិនទាន់បានធ្វើកាយនេះនោះឯង តាមដែលស្ថិតនៅហើយ តាមដែលតាំងនៅហើយឱ្យជាការចែកចេញអំពីដុំហើយឃើញដោយភាពជាធាតុ តែកាលលោកពិចារណាឃើញដោយភាពជាធាតុ **សត្តសញ្ញា** (សេចក្តី សម្គាល់ថាជាសត្វ ) របស់លោកក៏នឹងអន្តរធានទៅ ចិត្តនឹងតាំងនៅដោយអំណាចនៃធាតុនោះឯង ។

ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបបានទ្រង់ត្រាស់ទុកថា អ្នកនឹងពិចារណាឃើញកាយនេះតាមដែលស្ថិតនៅហើយ តាំងនៅហើយដោយភាពជាធាតុថា ក្នុងកាយនេះមានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ , ម្នាលភិក្ខុទាំងឡាយ នាយគោឃាតក៏អ្នកមិនប្រសប់ ឬ ។ ល ។ វាយោធាតុ សូម្បីយ៉ាងណា ។

អធិប្បាយថា ភិក្ខុបំពេញព្យាយាម ( យោគី ) ដូចបុរសអ្នកសម្លាប់គោ សេចក្តីសម្គាល់ថាសត្វ ដូចសេចក្តីសម្គាល់ថា មេគោ តិរិយាបថ ៤ ដូចផ្លូវធំបែកជា ៤ ការពិចារណាឃើញ ( កាយ ) ដោយជាធាតុ ដូចនាយគោ–

ឃាតក៍អ្នកអង្គុយបែងចែក ( សាច់ ) ចេញជាចំណែក ៗ ។ នេះគឺការពណ៌នាសេចក្ដីតាមព្រះបាលីក្នុង **ធាតុមនសិការបព្វ** នេះ ។ ចំណែកកថាពោលដោយកម្មដ្ឋាន បានអធិប្បាយពិស្ដារទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយ ក្នុងកាយរបស់ខ្លួន ឬ ក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬ ក្នុងកាយរបស់អ្នកដទៃតាមកាល យ៉ាងនេះ គឺ ដោយការកំណត់ធាតុ ៤ ពាក្យតពីនេះទៅមានន័យដូចដែលពោលមកហើយនោះឯង ។ ព្រោះថាក្នុង **ធាតុមនសិការបព្វ** នេះ សតិដែលកំណត់ធាតុ ៤ ជាទុក្ខសច្ចតែម្យ៉ាង ។

បណ្ឌិតគប្បីជ្រាប ឧបាយនៃធម៌ជាគ្រឿងនាំចេញ ( ចាកទុក្ខ ) តាមដែលបានអធិប្បាយសេចក្ដីប្រកបមកយ៉ាងនេះឯង ។ ពាក្យដ៏សេសដូចពាក្យមុននោះឯង ។

**( ចប់ ធាតុមនសិការបព្វៈ )**

## នវសីវថិកាបព្វ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកកាយានុបស្សនាដោយអំណាចការមនសិការដល់ធាតុយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយ **នវសីវថិកាបព្វ** ( ធម៌ដែលពោលដោយព្រៃស្មសាន ៩ ) ទើបត្រាស់ពាក្យជាដើមថា **បុន ចបរំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សេយ្យថាបិ បស្សេយ្យ** បានដល់ **យថាបស្សេយ្យ** ( ប្រែថា គប្បីឃើញយ៉ាងណា ) ។ បទថា **សរីរំ** បានដល់

រាងកាយរបស់មនុស្សដែលស្លាប់ហើយ ។

បទថា **សីវថិកាយ ឆឌ្ឌិតំ** សេចក្តីថា ដែលគេបោះបង់ចោលក្នុងព្រៃស្មសាន ។ រាងកាយរបស់មនុស្សដែលស្លាប់ហើយមួយថ្ងៃ ព្រោះ ដូច្នោះ ទើបឈ្មោះថា **ឯកាហមត** ។

រាងកាយរបស់មនុស្សដែលស្លាប់ហើយពីរថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះ ថា **ទ្វីហមត** ។

រាងកាយរបស់មនុស្សដែលស្លាប់ហើយបីថ្ងៃ ព្រោះដូច្នោះ ទើបឈ្មោះ ថា **តីហមត** ។ សាកសពដែលហើមប៉ោងដូចសប់ ឈ្មោះថា **ឧទ្ធុមាតក** ( ហើមប៉ោង ) ព្រោះហើមប៉ោង ដោយការហើមប៉ោងទេឡើងទៅតាមលំដាប់ក្រោយពីការអស់ជីវិតហើយ ។

ពណ៌ខៀវ គេហៅថា **វិនីល ។ វិនីលក** ក៏គឺ **វិនីល** នោះឯង ។

ម្យ៉ាងទៀត សរីរៈដែលមានពណ៌ខៀវក្រៃលែង គួរខ្ពើមព្រោះជារបស់បដិក្កូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិនីលក** ។ ពាក្យថា **វិនីលក** នេះជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហម ក្នុងទីដែលមានសាច់កំពុងមានពណ៌សក្នុងទីដែលមានខ្ទុះកក តែដោយច្រើនមានពណ៌ខៀវ ក្នុងទីដែលមានពណ៌ខៀវក៏ដូចរុំដោយសំពត់ពណ៌ខៀវ ។

ម្យ៉ាងទៀត ខ្ទុះដែលហូរចេញតាមទ្វារទាំង ៩ ស្មម្បីក្នុងទីដែលបែកប្រេះហើយឈ្មោះថា **វិបុព្វ** ។ **វិបុព្វ** ក៏គឺ **វិបុព្វក** នោះឯង ។ ម្យ៉ាងទៀតខ្ទុះដែលជោកជាំគួរខ្ពើមព្រោះបដិក្កូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វក** ។ សាកសពដែលក្លាយជាខ្ទុះជោកជាំ គឺ ដល់ភាវៈយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វកជាត** ។

បទថា **សោ ឥមមេវ កាយំ** សេចក្តីថា ភិក្ខុនោះបង្អោនកាយរបស់ខ្លួននេះចូលទៅ ( ប្រៀបផ្ទឹម ) នឹងកាយនោះដោយញាណ ។

បទថា **ឧបសំហរតិ** ប្រែថា បង្អោននាំចូលទៅ ។

បង្អោននាំចូលទៅដូចម្តេច ?

បង្អោនចូលទៅយ៉ាងនេះថា សូម្បីកាយនេះក៏ជាធម្មតាយ៉ាងនេះ មានសភាពយ៉ាងនេះ មិនកន្លងផុតភាពជាយ៉ាងនេះទេឡើយ ។

លោកពោលអធិប្បាយទុកដូចម្តេច ?

លោកពោលអធិប្បាយទុកថា ព្រោះមានធម៌បីយ៉ាងនេះ គឺ អាយុ ភ្លើងធាតុ វិញ្ញាណ កាយនេះទើបតាំងនៅ និង ( ផ្លាស់ប្តូរឥរិយាបថ ) មាន ឈរ និង ដើរជាដើមបាន តែព្រោះមិនមានធម៌បីនេះ រាងកាយនេះទើបមានសភាពយ៉ាងនេះជាធម្មតា គឺមានសភាពជា របស់ពុកផុយយ៉ាងនេះដូចគ្នា ។

បទថា **ឯវំភាវី** សេចក្តីថា ( កាយនេះ ) នឹងជាយ៉ាងនេះដូចគ្នា គឺនឹងជាប្រភេទ ( ផ្សេង ៗ ) មានជារាងកាយហើមប៉ោងជាដើម ។

បទថា **ឯវំ អនតីតោ** សេចក្តីថា មិនអាចកន្លងចាកសភាពយ៉ាង នេះ គឺភាពជារាងកាយដែលហើមប៉ោងជាដើមទៅបាន ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬ ក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតីពិចារណាឃើញកាយរបស់ខ្លួនតាមកាល ឬ ក្នុងកាយរបស់អ្នកដទៃតាមកាលដោយអាការយ៉ាងនេះ គឺ ដោយការកំណត់រាងកាយមានរាងកាយដែលហើមប៉ោងជាដើម ។

បទថា **ខជ្ជមានំ** សេចក្តីថា សរីរៈដែលត្រូវសត្វទាំងទឡាយមានក្អែក

និង ត្មាត ជាដើម ចឹកស៊ី ដោយទំព្រង់អវយវៈមានពោះជាដើម ហើយចឹកយកសាច់ពោះ សាច់បបូរមាត់ ( និង ) ត្របកភ្នែកជាដើមចេញមក ( ស៊ី ) ។

បទថា **សមំសលោហិតំ** សេចក្តីថា សរីរៈដែលប្រកបទៅដោយ សាច់ និង ឈាមដែលសេសសល់ជាប់នៅ ។

បទថា **និម្មំសលោហិតមក្ខិតំ** សេចក្តីថា សូម្បីកាលសាច់អស់ទៅ ហើយឈាមនៅមិនទាន់ស្ងួត ព្រះមានព្រះភាគទ្រង់សំដៅយកឈាមនោះទើបត្រាស់ថា **លោហិតមក្ខិតំ** ដូច្នេះ ។

បទថា **អញ្ញេន** បានដល់ ដោយទិសាភាគដទៃ ។

បទថា **ហត្ថដ្ឋិកំ** សេចក្តីថា ឆ្អឹងដៃទាំង ៦៤ កំណាត់ខ្ចាត់ខ្ចាយទៅតាមទិសផ្សេង ៗ ពីគ្នា ។ សូម្បីក្នុងឆ្អឹងជើងជាដើម ក៏ន័យដូចគ្នានេះ ។

បទថា **តេរោវស្សិកានិ** បានដល់ ( ឆ្អឹង ) កន្លងទៅ ១ ឆ្នាំហើយ ។

បទថា **បូតីនិ** សេចក្តីថា ឆ្អឹងដែលនៅកណ្តាលវាល កាលត្រូវខ្យល់ កម្តៅថ្ងៃ និង ទឹកភ្លៀងទើបពុកផុយ ឆ្អឹងដែលកន្លងទៅ ១ ឆ្នាំ មិនទាន់ពុកផុយ តែឆ្អឹងដែលកប់នៅក្នុងដីរមែងនៅបានយូរជាង ។

បទថា **ចុណ្ណកជាតានិ** បានដល់ លំអិតតូចៗខ្ចាត់ខ្ចាយទៅ ។

ក្នុងគ្រប់បទ បណ្ឌិតគប្បីតែងពាក្យប្រកបសេចក្តីដោយអំណាចនៃកាយដែលត្រូវសត្វក្អែក និង សត្វត្មាតចឹកស៊ីជាដើម តាមន័យដែលពោលទុកហើយ ថា **សោ ឥមមេវ** ដូច្នេះ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬក្នុងកាយរបស់អ្នកដទៃ គឺ មានប្រក្រតី

ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួនតាមកាល ឬក្នុងកាយរបស់អ្នកដទៃតាមកាលដោយអាការយ៉ាងនេះ គឺ ដោយការកំណត់កាយ មានកាយដែលត្រូវសត្វត្មាត សត្វក្អែកជាដើមចឹកស៊ីជាអាទិ រហូតដល់ជារបស់ពុតផុយខ្ទេចខ្ទី ជាលម្អិតតូច លម្អិតធំ ។

## ព្រៃស្មសាន ៩ ( ព្រៃខ្មោច )

ក៏ព្រៃស្មសាន ៩ គប្បីប្រមូលទុកត្រង់នេះ (គឺ ) ÷

ព្រៃស្មសានទាំងអស់ដែលត្រាស់ទុកដោយន័យជាដើមថា **ឯកាហមតំ វា** ( សាកសពដែលស្លាប់ហើយបាន ១ ថ្ងៃ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ជាដើមថា **កាកេហិ វា ខជ្ជ-មានំ** (សាកសពដែលត្រូវពួកក្អែកចឹកស៊ី ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិសង្ខលិកំ សមំស-លោហិតំ នហារុសម្ពន្ធំ** ( សាកសពដែលមានរាងឆ្អឹងព្រមទាំងសាច់ និងឈាមមានសរសៃជាគ្រឿងចង ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **និម្មំសលោហិតមក្ខិតំ នហារុសម្ពន្ធំ** ( សាកសពដែលមិនមានសាច់ តែប្រទឡាក់ដោយឈាមមានសរសៃជាគ្រឿងចងរឹត ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អបគតមំសលោហិតំ នហារុសម្ពន្ធំ** ( សាកសពដែលនៅមានតែឆ្អឹង ឥតមានសាច់ និង ឈាម តែនៅមានសរសៃជាគ្រឿងចង ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិកានិ អបគតសម្ពន្ធនានិ** ( មានតែរាងឆ្អឹងទទេ មិនមានសរសៃជាគ្រឿងចងរួបរឹត ខ្ចាត់ខ្ចាយរាត់រាយ

ទៅកាន់ទិសផ្សេងៗ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **អដ្ឋិកានិ សេតានិ សង្ខ-វណ្ណបដិភាគានិ** ( នៅសល់តែរាងឆ្អឹងទទេ មានពណ៌សដូចជាពណ៌នៃស័ង្ខ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **បុញ្ជកិតានិ តេរោវស្សិកានិ** ( សល់តែឆ្អឹង រោយរាយជាពំនូតៗកន្លងទៅ កន្លងទៅ ១ ឆ្នាំហើយ ) ១ ។

ព្រៃស្មសាន ( ដែលត្រាស់ទុក ) ថា **បូតីនិ ចុណ្ណកជាតានិ** ( ឆ្អឹងពុកផុយបែកខ្ទេចខ្ទីជាម្សៅ ) ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងព្រៃស្មសាន ៩ យ៉ាងទុកក្នុងទីនេះហើយ កាលនឹងបញ្ចប់កាយានុបស្សនាសតិប្បដ្ឋានទើបត្រាស់សម្តែង ថា **ឯវំ ខោ ភិក្ខុវេ** ដូច្នេះ ។

## អរិយសច្ច ក្នុងនវសីវថិកាបព្វ

សតិជាគ្រឿងកំណត់ព្រៃស្មសាន ៩ ក្នុងនវសីវថិកាបព្វៈនោះ ជា **ទុក្ខសច្ច** តណ្ហា ពីអតីតជាហេតុឱ្យកើតសតិនោះ ជា **សមុទយសច្ច** ការមិនប្រព្រឹត្តទៅនៃទុក្ខសច្ច និង សមុទយសច្ចទាំង ២ ជានិរោធសច្ច ។ អរិយមគ្គដែលជាតួកំណត់ដឹងទុក្ខ លះសមុទយៈ មាននិរោធ ( និព្វាន ) ជាអារម្មណ៍ ជាមគ្គសច្ច ។

ព្រះយោគាវចររមែងសម្រេចព្រះនិព្វានដោយអំណាចនៃសច្ចៈ ៤ ដូចពណ៌នាមកនេះ សរុបមកនេះជាផ្លូវនៃធម៌ដែលជាគ្រឿងនាំចេញចាកទុក្ខរហូតដល់ព្រះអរហត្តរបស់ភិក្ខុអ្នក កំណត់ព្រៃស្មសាន ៩ ។

**( ចប់ នវសីវថិកាបព្វៈ )**

ក៏កាយានុបស្សនា ១៤ បព្វៈ គឺ អនាបានបព្វៈ ១ ឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ធាតុមនសិការបព្វៈ ១ នវសីវថិកាបព្វៈ ៩ ជាការដែលចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

បណ្ដាបព្វៈទាំងនោះ ចំពោះ ២ បព្វៈនេះ គឺ អានាបានបព្វៈ ១ បដិកូលមនសិការបព្វៈ ១ ជា **អប្បនាកម្មដ្ឋាន** ( កម្មដ្ឋានដែលឱ្យសម្រេចដល់អប្បនាសមាធិ ) ចំណែកបព្វៈដ៏សេសទាំង ១២ បព្វៈ ជាឧបចារកម្មដ្ឋាន ( កម្មដ្ឋានដែលឱ្យសម្រេចដល់ឧបចារសមាធិ ) ប៉ុណ្ណោះ ព្រោះត្រាស់ព្រៃស្មសានទាំងទឡាយទុកដោយអំណាច **អាទីនវានុបស្សនា** នេះឯង ។

**( ចប់ កាយានុបស្សនា )**

## វេទនានុបស្សនា

ព្រះមានព្រះភាគជាម្ចាស់ លុះត្រាស់កាយានុបស្សនាសតិប្បដ្ឋានដោយ វិធី ១៤ យ៉ាងដូចពណ៌នាមកនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់វេទនានុបស្សនាដោយវិធី ៩ យ៉ាង ទើបត្រាស់ពាក្យមានជាអាទិថា **កថញ្ច ភិក្ខវេ** ។

## ការដឹងដែលមិនជាសតិប្បដ្ឋានភាវនា

បណ្ដាបទទាំងនោះ បទថា **សុខំ វេទនំ** មានអធិប្បាយថា ព្រះយោគាវចរកាលសោយសុខវេទនាដែលប្រព្រឹត្តទៅតាមផ្លូវកាយ ឬ ប្រព្រឹត្តទៅតាមផ្លូវចិត្តរមែងដឹងច្បាស់ថា យើងកំពុងសោយសុខវេទនា ដូច្នេះ ។ ក្នុងសេចក្ដីនោះសូម្បីកូនង៉ែតដែលដេកផ្ងារ កាលសោយសេចក្ដីសុខក្នុងវេលាផឹកទឹកដោះជាដើម ក៏ដឹងច្បាស់ថា យើងកំពុងសោយសុខក៏ពិត សូម្បីដូច្នោះ ពាក្យនេះព្រះអង្គក៏មិនបានត្រាស់សំដៅយកការដឹងយ៉ាងនេះ ព្រោះថា ការដឹងយ៉ាងនេះ

លះបង់ **សត្តូបលទ្ធិ** មិនបាន ដកសត្តសញ្ញាមិនបាន មិនជាកម្មដ្ឋាន ឬ មិន ជា **សតិប្បដ្ឋានភាវនា** ។

## ការដឹងដែលជាសតិប្បដ្ឋានភាវនា

ចំណែកការដឹងរបស់ភិក្ខុនេះ លះបង់ **សត្តូបលទ្ធិ** បាន ដក **សត្តសញ្ញា** បាន ទាំងជា **កម្មដ្ឋាន** ទាំងជា **សតិប្បដ្ឋានភាវនា** ។ ក៏ ការដឹងនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកការសោយដោយការដឹង ខ្លួនយ៉ាងនេះថា នរណាសោយ ការសោយរបស់នរណា ព្រោះហេតុអ្វីទើប សោយ ។

បណ្តាបទទាំងនោះ បទថា **កោ វេទយតិ** ( នរណាសោយ ) សេចក្តីថា មិនមាននរណា គឺ សត្វ ឬ បុគ្គលណាសោយទេឡើយ ។

បទថា **កស្ស វេទនា** ( ការសោយរបស់នរណា ) សេចក្តីថា មិន មែនការសោយរបស់នរណា គឺ របស់សត្វ ឬ បុគ្គលទេឡើយ ។

បទថា **កឹ ការណា វេទនា** ( ព្រោះហេតុអ្វីទើបសោយ ) សេចក្តី ថា ក៏ព្រោះមានវត្ថុជាអារម្មណ៍ គេទើបមានការសោយ ។

ព្រោះហេតុនោះ ភិក្ខុដឹងច្បាស់យ៉ាងនេះថា វេទនានោះឯងសោយ ដោយធ្វើវត្ថុនៃសេចក្តីសុខជាដើមនោះ ៗ ឱ្យជាអារម្មណ៍ ។ តែព្រោះសំដៅ យកការប្រព្រឹត្តិទៅនៃវេទនា នោះ ។ ពាក្យថា **អហំ វេទយាមិ** ( អញ្ញ សោយវេទនា ) ទើបមានត្រឹមតែវោហារប៉ុណ្ណោះ ។

ព្រះយោគាវចរនោះកាលកំណត់ដឹងថា វេទនានោះឯងសោយដោយ ធ្វើវត្ថុឱ្យជាអារម្មណ៍យ៉ាងនេះ អ្នកសិក្សាគប្បីយល់ថា លោកដឹងច្បាស់ថា អញ្ញ កំពុងសោយសុខវេទនា ។

ដូចព្រះថេរៈមួយរូបដែលនៅក្នុងចិត្តលតាបពិតដូច្នោះ ។

## រឿងព្រះថេរៈមួយរូប

បានឮថា ព្រះថេរៈក្នុងវេលាដែលលោកមានអាពាធដកដង្ហើមបណ្ដើរ ដេកបង្រះននៀលទៅមក ។

ភិក្ខុកំលោះមួយរូបសួរលោកថា លោកម្ចាស់ រោគចាក់ដោតលោកត្រង់កន្លែងណា ?

ព្រះថេរៈឆ្លើយថា អាវុសោ ឈ្មោះថា ទីដែលរោគចាក់ដោតចំពោះកន្លែងមិនមាន វេទនាផ្សេង ៗ សោយដោយធ្វើវត្ថុឱ្យជាអារម្មណ៍ ។ ភិក្ខុកំលោះប្រាប់ថា កាលបើដូច្នោះ លោកគួរនឹងទប់ទល់តាំងពីពេលដែលដឹងមិនមែនឬលោកម្ចាស់ ? ព្រះថេរៈឆ្លើយថា ខ្ញុំកំពុងទប់ទល់ណាលោក ។ ភិក្ខុកំលោះប្រាប់ថា លោកម្ចាស់ ការទប់ទល់ជារបស់ប្រសើរ ។

ព្រះថេរៈបានទប់ទល់ទុកហើយ ។

លំដាប់នោះខ្យល់ចាក់ដោតដល់បេះដូង ។ ពោះវៀនធំបានលៀនចេញមកគរនៅលើគ្រែ ព្រះថេរៈបានបង្ហាញឱ្យភិក្ខុកំលោះមើលថា ទប់ទល់ប៉ុណ្ណោះសមគួរឬនៅលោក ភិក្ខុកំលោះក៏នៅស្ងៀម ។ ព្រះថេរៈប្រកបសេចក្ដីព្យាយាមជានិច្ច ហើយបានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ជាព្រះអរហន្ត ( ប្រភេទ ) ជីវិតសមសីសី ហើយបរិនិព្វាន ។

កាលព្រះយោគាវចរដឹងច្បាស់ ( ថា ) សុខយ៉ាងណា ទុក្ខយ៉ាងនោះ ។ ល ។ កាលសោយអទុក្ខមសុខវេទនាមិនអាស្រ័យដោយអាមិស ក៏ដឹងច្បាស់ថាអញកំពុងសោយ អទុក្ខមសុខវេទនាមិនអាស្រ័យដោយអាមិស ។

## រូបកម្មដ្ឋាន - អរូបកម្មដ្ឋាន

ព្រះមានព្រះភាគ លុះទ្រង់ត្រាស់ប្រាប់រូបកម្មដ្ឋានដោយអាការយ៉ាងនេះហើយ កាលនឹងត្រាស់អរូបកម្មដ្ឋាន ទើបបានត្រាស់ប្រាប់ដោយអំណាចនៃវេទនា ព្រោះថា កម្មដ្ឋាន មាន ២ យ៉ាងគឺ **រូបកម្មដ្ឋាន ១ អរូបកម្មដ្ឋាន ១** ។ **រូបកម្មដ្ឋាន** និង **អរូបកម្មដ្ឋាន** នេះនោះឯងត្រាស់ហៅថា **រូប-បរិគ្គហ** ( ការកំណត់រូប ) **អរូបបរិគ្គហ** ( ការកំណត់អរូប ) ក៏មាន ។

បណ្តា **រូបកម្មដ្ឋាន** និង **អរូបកម្មដ្ឋាន** នោះ ព្រះមានព្រះភាគជាម្ចាស់កាលនឹងត្រាស់ប្រាប់ **រូបកម្មដ្ឋាន** ទើបត្រាស់ **ចតុធាតុវវដ្ឋាន** ( ការកំណត់ ធាតុ ៤ ) ទុកដោយអំណាចនៃ **មនសិការ** ដោយសង្ខេបខ្លះ ដោយអំណាចនៃការមនសិការដោយពិស្តារខ្លះ ។ កម្មដ្ឋានសូម្បីទាំង ២ យ៉ាងនោះបានសម្តែងទុកហើយក្នុង **គម្ពីរវិសុទ្ធិមគ្គ** ដោយអាការទាំងពួងនោះឯង ។ តែព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់ប្រាប់អរូបកម្មដ្ឋាន ដោយច្រើនក៏នឹងត្រាស់ប្រាប់ដោយអំណាចនៃវេទនា ។ ព្រោះថា ការធ្វើទុកក្នុងចិត្តក្នុងអរូប-កម្មដ្ឋាន មាន ៣ យ៉ាង គឺ ( ផ្តោតចិត្ត ) **ដោយអំណាចនៃផស្សៈ ១ ដោយអំណាចនៃ វេទនា ១ ដោយអំណាចនៃចិត្ត ១** ។

ផ្តោតចិត្តដូចម្តេច ?

( ផ្តោតចិត្តយ៉ាងនេះ គឺ ) ពិតណាស់ ផស្សៈ កាលពាល់ត្រូវអា-រម្មណ៍នោះកើតទេឡើងក្នុងខណៈដែលចិត្ត និង ចេតសិកប្រព្រឹត្តទៅចំពោះគ្រាដំបូងនៃអារម្មណ៍នោះ នឹងមកប្រាកដដល់ព្រះយោគាវចររូបខ្លះក្នុងរូបកម្មដ្ឋានដែលលោកកំណត់ហើយដោយសង្ខេប ឬ ដោយពិស្តារ ។ វេទនាកាលសោយអារម្មណ៍នោះកើតទេឡើងនឹងប្រាកដដល់ព្រះយោគាវចររូបខ្លះ វិញ្ញាណកាលកំ-

ណត់អារម្មណ៍នោះ ដឹងហើយកើតទេឡើងដល់យោគាវចររូបខ្លះ ។ បណ្តា ផស្សៈ វេទនា វិញ្ញាណទាំងនោះ ផស្សៈប្រាកដដល់ព្រះយោគាវចរណា មិនចំពោះតែផស្សៈប៉ុណ្ណោះដែលកើតទេឡើង សូម្បីវេទនាដែលសោយអារម្មណ៍នោះ ក៏កើតទេឡើងជាមួយនឹងផស្សៈដែរ សូម្បីសញ្ញាដែលចាំបាន សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ៗ នឹងកើតទេឡើងព្រមជាមួយនឹងផស្សៈនោះដែរ ព្រោះដូច្នោះ ព្រះយោគាវចរនោះរមែងកំណត់ចេតសិកធម៌មានផស្សៈជាទី ៥ នោះឯង ។

វេទនាណា ប្រាកដដល់ព្រះយោគាវចរ មិនចំពោះវេទនាម្យ៉ាងប៉ុណ្ណោះទេដែលកើតទេឡើង សូម្បីផស្សៈដែលពាល់ត្រូវក៏នឹងកើតទេឡើងជាមួយនឹងវេទនានោះដែរ សូម្បីសញ្ញាដែលចាំអារម្មណ៍ សូម្បីចេតនាដែលតាំងចិត្ត សូម្បីវិញ្ញាណដែលដឹងច្បាស់ ក៏នឹងកើតទេឡើងជាមួយនឹងវេទនានោះដែរ ព្រោះដូច្នោះ ព្រះ-យោគាវចរនោះ ក៏រមែងកំណត់ចេតសិកធម៌ មានផស្សៈជាទី ៥ នោះឯង ។

សូម្បីវិញ្ញាណនឹងប្រាកដដល់ព្រះយោគាវចរណា មិនចំពោះតែវិញ្ញាណនោះតែម្យ៉ាងប៉ុណ្ណោះនឹងកើតទេឡើង សូម្បីផស្សៈដែលពាល់ត្រូវអារម្មណ៍នោះ ៗ ឯងក៏នឹងកើតឡើងជាមួយនឹងវិញ្ញាណនោះដែរ សូម្បីវេទនាដែលសោយ សូម្បីសញ្ញាដែលចាំបានសម្គាល់បាន សូម្បីចេតនាដែលតាំងចិត្តចំពោះអារម្មណ៍នោះក៏នឹងកើតទេឡើងជាមួយវិញ្ញាណនោះដែរ ព្រោះដូច្នោះ ព្រះយោគាវចរនោះរមែងកំណត់ដឹងចេតសិកធម៌ មានផស្សៈជាទី ៥ នោះឯង ។

ព្រះយោគាវចរនោះ កាលពិចារណាថា ធម៌មានផស្សៈជាទី ៥ ទាំងនេះអាស្រ័យនឹងអ្វី ។

នឹងជ្រាបច្បាស់ថា អាស្រ័យវត្ថុ ។

# ១១៣ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ករជកាយឈ្មោះថា វត្ថុ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សំដៅយកថា ក៏ឯវិញ្ញាណរបស់យើងនេះអាស្រ័យនៅក្នុងករជកាយនេះ ជាប់ជំពាក់នៅក្នុងករជកាយនេះ ។

ដោយសេចក្តី ព្រះយោគាវចរនោះរមែងឃើញទាំង ( មហា ) ភូតរូបទាំងឧបាទាយរូប កាលបើដូច្នោះ ក្នុងវេទនាបព្វៈនេះ ព្រះយោគាវចរនឹងឃើញត្រឹមតែនាមរូបប៉ុណ្ណោះ ថា វត្ថុ ជារូប ចេតសិកធម៌មានផស្សៈជាទី ៥ ជានាម ។ ហើយក្នុងសេចក្តីនេះ រូបបានដល់រូបក្ខន្ធ នាមបានដល់អរូបក្ខន្ធទាំង ៤ ព្រោះដូច្នោះទើបមានត្រឹមតែបញ្ចក្ខន្ធប៉ុណ្ណោះ ។ ព្រោះថា បញ្ចក្ខន្ធដែលនឹងផុតចាកនាមរូប ឬ នាមរូបដែលនឹងផុតអំពីបញ្ចក្ខន្ធមិនមាន ។

ព្រះយោគាវចរនោះ កាលវិគ្រោះពិចារណាថា បញ្ចក្ខន្ធទាំងនេះមានអ្វីជាហេតុ ក៏នឹងឃើញថា មានអវិជ្ជាជាដើមហេតុ ។ បន្ទាប់ពីនោះមកព្រះ-យោគាវចរនឹងលើកយក ( បញ្ចក្ខន្ធ ) ទេឡើងកាន់ត្រៃលក្ខណ៍ដោយអំណាចនាមរូបព្រមទាំងបច្ច័យថា នេះ ( ត្រឹមតែ ) បច្ច័យ និង ធម៌ដែលអាស្រ័យបច្ច័យកើតទេឡើង មិនមានអ្វីយ៉ាងដទៃដែលជាសត្វ ឬ បុគ្គល មានត្រឹមតែគំនរសង្ខារសុទ្ធ ៗ ប៉ុណ្ណោះ ហើយពិចារណាត្រួតត្រាទៅថា អនិច្ចំ ទុក្ខំ អនត្តា តាមលំដាប់នៃវិបស្សនា ។

លោកសង្ឃឹមចំពោះបដិវេធថា ( នឹងបានសម្រេច ) ថ្ងៃនេះ ថ្ងៃនេះ បាន **ឧតុសប្បាយ** ( អាកាសសប្បាយ ) **បុគ្គលសប្បាយ** ( បុគ្គលសប្បាយ ) **ភោជនសប្បាយ** ( ភោជនសប្បាយ ) **ធម្មស្សវនសប្បាយ** ( ការស្តាប់ធម៌សប្បាយ ) អង្គុយពែនភ្នែនញុំាងវិបស្សនាឱ្យដល់ទីបំផុត ហើយតាំងនៅក្នុងព្រះអរហត្តមគ្គ ដោយប្រការដូចពោលមកនេះ ជាការដែលត្រាស់ប្រាប់ព្រះ

កម្មដ្ឋានដល់ជនទាំង ៣ សូម្បីទាំងនេះ រហូតដល់ព្រះអរហត្ត ។

## វេទនា គឺ អរូបកម្មដ្ឋាន

ប៉ុន្តែក្នុងសតិប្បដ្ឋានសូត្រនេះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ប្រាប់អរូបកម្មដ្ឋាន ទើបបានត្រាស់ទុកដោយអំណាចនៃវេទនា ។ ព្រោះថា កាលត្រាស់ប្រាប់ដោយអំណាចនៃផស្សៈ ឬ ដោយអំណាចនៃវិញ្ញាណ កម្មដ្ឋាននឹងមិនប្រាកដ នឹងប្រាកដដូចភាពងងឹត ។ ចំណែកដែលត្រាស់ប្រាប់ដោយអំណាចនៃវេទនា កម្មដ្ឋាននឹងប្រាកដ ។

ព្រោះហេតុអ្វី ?

ព្រោះកម្មដ្ឋាននឹងប្រាកដ ក៏ព្រោះវេទនាកើតទេឡើង ។

ពិតណាស់ ការកើតទេឡើងនៃសុខវេទនា និង ទុក្ខវេទនា នឹងប្រាកដចំពោះកាលសេចក្តីសុខកើតទេឡើង បានដល់ សុខដែលកើតទេឡើងធ្វើឱ្យញាប់ញ័រពេញសព្វាង្គកាយជ្រួតជ្រាបទៅរហូតជ្រួតជ្រាបពេញ ( បេះដូង ) ដូចការបានផឹកទឹកដោះថ្លាដែលក្អួររាប់រយដង ដូចឱ្យលាបប្រេងដែលដាំហើយ ១ រយដង នឹងដូចឱ្យរំលត់ភាពក្តៅអន្ទះអន្ទែងដោយទឹកមួយពាន់ឆ្នាំង ធ្វើឱ្យបន្លឺវាចាចេញទៅថា សុខហ្ន៎ សុខហ្ន៎ ដូច្នេះ ( ហើយ ) កាលសេចក្តីទុក្ខកើតទេឡើង បានដល់សេចក្តីទុក្ខដែលកើតទេឡើង ធ្វើឱ្យញាប់ញ័រទូទាំងរាងកាយ ហូរជ្រួតជ្រាបទៅពេញប្រៀប ( ក្នុងបេះដូង ) ដូចឱ្យចូលទៅកាន់អណ្តាតភ្លើងដែលក្តៅគគុកក្រាស់ដោយទឹកទង់ដែងដែលរលាយរិលរល់ នឹងដូចបោះដុំភ្លើងចូលទៅក្នុងព្រៃដែលមានស្មៅស្ងួតនិងឈើងាប់ ហើយឱ្យស្រែកថ្ងូរថា ទុក្ខណាស់ហ្ន៎ ទុក្ខណាស់ ហ្ន៎ ។ ការកើតទេឡើងនៃសុខវេទនា និង ទុក្ខវេទនា នឹងប្រាកដទេឡើងបានដោយអាការយ៉ាងនេះ ។

## ១១៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

ចំណែកអទុក្ខមសុខវេទនាសំដែង ( ឱ្យឃើញ ) បានលំបាក ងងឹត ងងល់ មិនជាក់ច្បាស់ ។ អទុក្ខមសុខវេទនានោះ នឹងប្រាកដដល់ព្រះយោគា-វចរអ្នកប្រកាន់មាំ ដោយន័យថា អទុក្ខមសុខវេទនា មានអាការជាកណ្ដាល ដោយការរលាស់ចោលសេចក្ដីសុខ និង ទុក្ខ ក្នុងកាលសុខ និង ទុក្ខអស់ទៅ ។

ប្រៀបដូចអ្វី ?

ប្រៀបដូចនាយព្រានម្រឹគដើរតាមស្នាមជើងម្រឹគ ដែលលោតទឡើងលើថ្មរវាងផ្លូវហើយគេចទៅបាន ( គេ ) ឃើញស្នាមជើងទាំងខាងនេះ ទាំងខាងនោះនៃផ្ទាំងថ្ម សូម្បីនឹងមិនឃើញ ( ស្នាមជើង ) ត្រង់កណ្ដាល ( លើផ្ទាំងថ្ម ) ក៏ជ្រាបបានដោយន័យថា ម្រឹគដែលទឡើងតាមផ្លូវនេះ ហើយចុះទៅតាមផ្លូវនោះ គង់នឹងឆ្លងកាត់ទៅខាងនេះ លើផ្ទាំងថ្មត្រង់កណ្ដាល យ៉ាងណា ការកើតទឡើងនៃសុខវេទនាក៏ដូច្នោះ នឹងប្រាកដដូចស្នាមជើង ( នៃម្រឹគដែលប្រាកដ ) ក្នុងទីដែលវានឹងទឡើងទៅ ការកើតនៃទុក្ខវេទនានឹងប្រាកដដូចស្នាមជើង ( នៃម្រឹគ ) ក្នុងទីដែលវាចុះទៅហើយដូច្នោះ ។ អទុក្ខមសុខវេទនានឹងប្រាកដដល់ព្រះ-យោគាវចរអ្នកប្រកាន់មាំដោយន័យថា អទុក្ខមសុខវេទនា មានអាការជាកណ្ដាល ដោយរលាស់ចោលការសប្បាយ និង មិនសប្បាយក្នុងកាលសុខវេទនា និង ទុក្ខវេទនាបាត់ទៅដូចការប្រកាន់មាំថា ឆ្លងទៅត្រង់កណ្ដាលនេះឯងដោយទឡើងតាមផ្លូវខាងនេះ ហើយចុះទៅតាមផ្លូវខាងនោះ ដូច្នោះ ។ ព្រះមានព្រះភាគជាម្ចាស់បានទ្រង់ត្រាស់សម្ដែង សតិប្បដ្ឋាន ដោយត្រាស់រូបកម្មដ្ឋានមុនហើយញ៉ាំងអរូបកម្មដ្ឋានឱ្យកើតទឡើងដោយអំណាចវេទនាក្នុងខាងក្រោយ ។ វេទនា គឺ អរូបកម្មដ្ឋានមានក្នុងព្រះសូត្រច្រើនកន្លែង ព្រះមានព្រះភាគទ្រង់ត្រាស់ទុកយ៉ាងនេះចំពោះក្នុងសតិប្បដ្ឋានសូត្រនេះតែម្យ៉ាងក៏ទេ ( តែ ) ទង់ត្រាស់សម្ដែង

ដោយត្រាស់រូបកម្មដ្ឋាន ហើយញ៉ាំងអរូបកម្មដ្ឋានឱ្យកើតទេឡើងដោយអំណាចវេទនាក្នុងខាងក្រោយក្នុងព្រះសូត្រច្រើនព្រះសូត្រច្រើនកន្លែងយ៉ាងនេះ គឺ ក្នុង **ចុល្លតណ្ហាសង្ខយសូត្រ** ក្នុង មហាតណ្ហាសង្ខយសូត្រ ក្នុង ចុល្លវេទល្លសូត្រ ក្នុង **មហាវេទល្លសូត្រ** ក្នុង **រដ្ឋបាលសូត្រ** ក្នុង មាគណ្ឌិយសូត្រ ក្នុង ធាតុ-វិភង្គសូត្រ ក្នុង អានេញ្ជសប្បាយសូត្រ ក្នុង **មហានិព្វានសូត្រ** ក្នុង **សក្ក-បញ្ហាសូត្រ** ក្នុង **មហាសតិប្បដ្ឋានសូត្រ** ក្នុង **ទីឃនិកាយ** ក្នុង **ចុល្លនិព្វាន-សូត្រ** ក្នុង **រុក្ខោបមសូត្រ** ក្នុង **បរិវីមង្សនសូត្រ** និងក្នុង **វេទនាសំយុត្ត** ទាំងអស់ក្នុង **សំយុត្តនិកាយ** ហើយសូម្បីក្នុង **សតិប្បដ្ឋានសូត្រ** នេះ ព្រះមានព្រះ-ភាគជាម្ចាស់ទើបទ្រង់សម្ដែងដោយត្រាស់ប្រាប់រូបកម្មដ្ឋានមុនហើយ ទើបទ្រង់ញ៉ាំងអរូបកម្មដ្ឋានឱ្យកើតដោយអំណាចនៃវេទនាខាងក្រោយ ដូចក្នុងព្រះសូត្រទាំងនោះ ។ បណ្ដាបទទាំងនោះ មានបរិយាយនៃការដឹងច្បាស់នូវវេទនាម្យ៉ាងទៀត ដូចតទៅនេះ ÷

## សុខវេទនាប្រែប្រួល

សេចក្ដីថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** សេចក្ដីថា ព្រោះមិនមានទុក្ខវេទនាក្នុងខណៈនៃសុខវេទនា ព្រះយោគាវចរកាលសោយសុខវេទនា ក៏ដឹងច្បាស់ថាយើងកំពុងសោយសុខវេទនា ។ វេទនា ឈ្មោះថា មិនទៀង មិនស្ថិតស្ថេរមានការប្រែប្រួលជាធម្មតា ព្រោះទុក្ខវេទនាដែលធ្លាប់សោយមកពីមុនក្នុងកាលឥឡូវនេះមិនមានហើយ ព្រោះសុខវេទនានេះ មុនអំពីនេះក៏មិនមាន ព្រោះដូច្នោះ ព្រះយោគាវចរទើបជាការដែលដឹងច្បាស់ក្នុងសុខវេទនា និងទុក្ខវេទនានោះ ដូចពណ៌នាមកនេះដោយពាក្យថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** នោះ ។

សមពិតដូចពាក្យដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុក ដូចនេះថា ( ម្នាលអគ្គិវេស្សនៈ ក្នុងសម័យណា បុគ្គលសោយសុខវេទនា ក្នុងសម័យនោះ នឹងមិនសោយទុក្ខវេទនា នឹងមិនសោយអទុក្ខមសុខវេទនា ក្នុងសម័យនោះ សោយតែសុខវេទនាតែម្យ៉ាង ម្នាលអគ្គិវេស្សនៈ ក្នុងសម័យណាបុគ្គលសោយ ទុក្ខវេទនា ។ ល ។ សោយនូវអទុក្ខមសុខវេទនា ក្នុងសម័យនោះនឹងមិនសោយ សុខវេទនាទេឡើយ ក្នុងសម័យនោះសោយអទុក្ខមសុខតែម្យ៉ាង ម្នាលអគ្គិវេស្សនៈ សូម្បីសុខវេទនាក៏មិនទៀង ត្រូវបច្ច័យប្រជុំតាក់តែង អាស្រ័យបច្ច័យទើបកើត ទេឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការបន្ទោបង់ តម្រេកជាធម្មតា មានការរលត់ជាធម្មតា សូម្បីទុក្ខវេទនា ។ ល ។ ម្នាលអគ្គិវេ-ស្សនៈ សូម្បីអទុក្ខមសុខវេទនាក៏មិនទៀង ។ ល ។ មានការរលត់ជាធម្មតា ម្នាល អគ្គិវេស្សនៈ ព្រះអរិយសាវកអ្នកបានស្តាប់ កាលឃើញយ៉ាងនេះ រមែងនឿយ-ណាយទាំងក្នុងសុខវេទនា រមែងនឿយណាយទាំងក្នុងទុក្ខវេទនា រមែងនឿយ-ណាយទាំងក្នុងអទុក្ខមសុខវេទនា កាលនឿយណាយ រមែងបន្ទោបង់តម្រេក ព្រោះបន្ទោបង់តម្រេក ទើបរួចផុត រួចផុតហើយក៏ដឹងច្បាស់ថា យើងរួចផុត ហើយ រមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈនៅចប់ហើយ កិច្ចដែល គួរធ្វើ បានធ្វើស្រេចហើយ កិច្ចដែលគួរធ្វើយ៉ាងដទៃសូម្បីភាវៈជាយ៉ាងនេះមិន មាន ។

ក្នុងពាក្យថា **សាមិសំ វា សុខំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ÷

**សោមនស្សវេទនា** ដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( **តណ្ហាឧបាទាន** ) ៦ យ៉ាង លាយទឡ៉ំដោយអាមិស គឺ បញ្ចកាមគុណ ឈ្មោះថា **សាមិសសុខវេទនា** ។

សោមនស្សវេទនាដែលអាស្រ័យ ( កើតមកពី ) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសសុខវេទនា** ។

ទោមនស្សវេទនាដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( តណ្ហាឧបាទាន ) ៦ យ៉ាង ឈ្មោះថា **សាមិសទុក្ខវេទនា** ។

ទោមនស្សវេទនាដែលអាស្រ័យ ( កើតមកពី ) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា និរាមិសទុក្ខវេទនា ។

ឧបេក្ខាវេទនាដែលអាស្រ័យ ( កើតមកពី ) ផ្ទះ ( **តណ្ហាឧបាទាន** ) ៦ យ៉ាង ឈ្មោះថា **សាមិសអទុក្ខមសុខវេទនា** ។

ឧបេក្ខាវេទនា ដែលអាស្រ័យ ( កើតមកពី ) នេក្ខម្មៈ ៦ យ៉ាង ឈ្មោះថា **និរាមិសអទុក្ខមសុខវេទនា** ។ ការចែកវេទនាទាំងនោះ មកច្បាស់ក្នុងព្រះបាលី ក្នុង **ឧបរិបណ្ណាសក** ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរមានប្រក្រតីពិចា- រណាឃើញវេទនាក្នុងវេទនាទាំងទឡាយរបស់ខ្លួន ឬ ក្នុងវេទនាទាំងទឡាយរបស់អ្នកដទៃ គឺ ក្នុងវេទនាទាំងទឡាយរបស់ខ្លួនតាមកាល ឬ ក្នុងវេទនាទាំងទឡាយរបស់អ្នកដទៃតាមកាល ។

ក៏បទថា **សមុទយវយធម្មានុបស្សី វា** នេះ គប្បីជ្រាបសេចក្តីថា ព្រះយោគាវចរកាលឃើញការកើតទេឡើង និង ការសូន្យទៅនៃវេទនាទាំងទឡាយដោយអាការ ៥ មានជាអាទិ គឺ ព្រោះអវិជ្ជាកើត វេទនាទើបកើត ឈ្មោះថាមានប្រក្រតីពិចារណាឃើញធមិ គឺ ការកើតទេឡើងក្នុងវេទនាទាំងទឡាយ ឬ មានប្រក្រតីពិចារណាឃើញធមិ គឺ ការសូន្យទៅក្នុងវេទនាទាំងទឡាយ គឺ មានប្រក្រតីពិចារណាឃើញធមិ គឺ ការកើតទេឡើងក្នុងវេទនាទាំងទឡាយតាមកាល ឬ មាន

ប្រក្រតីពិចារណាឃើញធម៌ គឺ ការអស់ទៅក្នុងវេទនាទាំងឡាយតាមកាល ។ ពាក្យក្រៅពីនេះ មានន័យដូចពោលហើយក្នុងកាយានុបស្សនានោះឯង ។

## អរិយសច្ច ក្នុងវេទនា

ក៏សតិជាគ្រឿងកំណត់វេទនាក្នុងវេទនានុបស្សនា នេះជាទុក្ខសច្ចៈតែ ម្យ៉ាង បណ្ឌិតគប្បីជ្រាបផ្លូវនៃធម៌ជាគ្រឿងនាំចេញចាកទុក្ខរបស់ភិក្ខុអ្នកកំណត់ វេទនា ព្រោះអធិប្បាយប្រកបសេចក្ដីដូចពោលមកនេះឯង ពាក្យដ៏សេស ( ដូចពាក្យដែលពោលមកហើយ ) នោះឯង ។

**( ចប់ វេទនានុបស្សនា )**

# GFib,aycitþanubsßna

ព្រះមានព្រះភាគ លុះទ្រង់ត្រាស់សតិប្បដ្ឋាន គឺ វេទនានុបស្សនា ដោយអាការ ៩ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងត្រាស់ចិត្តានុបស្សនា ដោយអាការ ១៦ យ៉ាង ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សរាគំ** បានដល់ ចិត្តដែលសហគត ដោយលោភៈ ៨ យ៉ាង ។

បទថា **វីតរាគំ** បានដល់ កុសលចិត្តផ្នែកលោកិយៈ និង អព្យា_កតចិត្ត ក៏ចិត្តដែលប្រាសចាករាគៈនេះ ក្នុងចិត្តានុបស្សនានេះ មិនបានសំដៅ ដល់លោកុត្តរចិត្តសូម្បីតែក្នុងមួយបទ ព្រោះការពិចារណាមិនមែនជាការប្រជុំ ធម៌ ( ចំណែក ) **អកុសលចិត្ត ៤ ដួង** ដ៏សេសមិនចាត់ចូលក្នុងបទដំបូង ទាំងមិនចាត់ចូលក្នុងបទក្រោយ ។

## ១២០ អដ្ឋកថា សតិប្បដ្ឋានសូត្រ

បទថា **សទោសំ** បានដល់ ចិត្តដែលសហគតដោយទោមនស្ស ២ ដួង ។

បទថា **វីតទោសំ** បានដល់ កុសលចិត្តផ្នែកលោកិយៈ និង អព្យា_ កតៈ ។

**អកុសលចិត្ត ១០** ដួងដ៏សេស មិនចាត់ចូលក្នុងបទដំបូង ទាំងមិនចាត់ចូលក្នុងបទក្រោយ ។

បទថា **សមោហំ** បានដល់ អកុសលចិត្ត ២ ដួង គឺ អកុសលចិត្តដែលសហគតដោយវិចិកិច្ឆា ១ ដួង អកុសលដែលសហគតដោយឧទ្ធច្ចៈ ១ ដួង ។

ព្រោះមោហៈរមែងកើតទេឡើងក្នុងអកុសលចិត្តគ្រប់ដួង ដូច្នោះ អកុសលចិត្តទាំងអស់សូម្បីទាំងពីរនោះ ទើបសមគួរ ( នឹងចាត់ចូល ) ក្នុងចិត្តានុបស្សនានេះដោយពិត ។

ពិតណាស់ ក្នុងចិត្តដែលជាគូគ្នានេះឯង លោកចាត់អកុសលចិត្ត ១២ ដួងទុកហើយ ។

បទថា **វីតមោហំ** បានដល់ លោកិយកុសលចិត្ត និង អព្យាកតចិត្ត ។

បទថា **សង្ខិត្តំ** បានដល់ ចិត្តដែលសហគតដោយថីនមិទ្ធៈ ក៏ចិត្តដែលសហគតដោយថីនមិទ្ធៈនោះ ឈ្មោះថា ចិត្តរួញរា ។

បទថា **វិក្ខិត្តំ** បានដល់ ចិត្តដែលសហគតដោយឧទ្ធច្ចៈ ក៏ចិត្តដែលសហគតដោយឧទ្ធច្ចៈនោះ ឈ្មោះថា ចិត្តរាយមាយ ។

បទថា **មហគ្គតំ** បានដល់ រូបាវចរចិត្ត និង អរូបាវចរចិត្ត ។

បទថា **អមហគ្គតំ** បានដល់ កាមាវចរចិត្ត ។

បទថា **សឧត្តរំ** បានដល់ កាមាវចរចិត្ត ។

បទថា **អនុត្តរំ** បានដល់ រូបាវចរចិត្ត អរូបាវចរចិត្ត ។

ម្យ៉ាងទៀត ក្នុងបទទាំង ២ ថា **សឧត្តរំ អនុត្តរំ** នោះ **សឧត្តរចិត្ត** បានដល់ រូបាវចរចិត្ត **អនុត្តរចិត្ត** បានដល់ អរូបាវចរចិត្តនោះឯង ។

បទថា **សមាហិតំ** បានដល់ ចិត្តដែលមានអប្បនាសមាធិ ឬ ឧប_ចារសមាធិ ។

បទថា **អសមាហិតំ** បានដល់ ចិត្តដែលមិនមានសមាធិទាំង ២ ។

បទថា **វិមុត្តំ** បានដល់ ចិត្តដែលរួចផុតហើយ ដោយ **តទង្គវិមុត្តិ** និង **វិក្ខម្ភនវិមុត្តិ** ។

បទថា **អវិមុត្តំ** បានដល់ ចិត្តដែលមិនមានវិមុត្តិទាំង ២ ។

ចំណែក **សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ** និង **និស្សរណវិមុត្តិ** មិនមានឱកាស ( មិនបាននិយាយដល់ ) ក្នុងចិត្តានុបស្សនានេះទេឡើយ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរកាលកំណត់ចិត្តដែលប្រព្រឹត្តទៅគ្រប់ខណៈដោយការកំណត់ចិត្តមានសរាគចិត្ត ជាដើមយ៉ាងនេះ ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួន ឬ ក្នុងចិត្តរបស់អ្នកដទៃ ( ខ្លះ ) ឈ្មោះថា មានប្រក្រតីតាមឃើញចិត្តក្នុងចិត្តរបស់ខ្លួនតាមកាល ឬ ក្នុងចិត្តរបស់បុគ្គលដទៃតាមកាល ( ខ្លះ ) ។

ចំណែកក្នុងបទថា **សមុទយវយធម្មានុបស្សី** ( មានប្រក្រតីតាមឃើញ ធម៌ គឺ ការកើតទេឡើង និង ការសូន្យទៅ ) នេះគួរពង្រីកការកើត និង ការរលត់នៃវិញ្ញាណ ១ ដួង ។ ចែកចេញជា ៥ អាការដូច្នេះ គឺ ព្រោះអវិជ្ជាកើត វិញ្ញាណទើបកើតជាដើម ។ ពាក្យក្រៅពីនេះ មានន័យដូចពោលហើយនោះឯង ។

## អរិយសច្ច ក្នុងចិត្តានុបស្សនា

ក៏សតិជាគ្រឿងកំណត់ចិត្តក្នុងចិត្តានុបស្សនានេះ ជាទុក្ខសច្ចតែម្យ៉ាង បណ្ឌិតគប្បីជ្រាបមុខនាទីនៃធម៌នាំចេញចាកទុក្ខរបស់ភិក្ខុអ្នកកំណត់ចិត្ត តាមដែលបានអធិប្បាយមកយ៉ាងនេះឯង ។ ពាក្យដ៏សេស ( មានន័យ ) ដូច ( ពោលមកនោះឯង ) ។

## ( ចប់ ចិត្តានុបស្សនា )

## អធិប្បាយធម្មានុបស្សនា

លុះព្រះអង្គត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន ដោយអាការ ១៦ យ៉ាង ដូចពណ៌នាមកនេះ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងធម្មានុបស្សនាដោយអាការ ៥ យ៉ាង ។ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

ប្រការមួយទៀត ព្រះមានព្រះភាគជាម្ចាស់ត្រាស់ការកំណត់រូបសុទ្ធ ៗ ដោយកាយានុបស្សនា ត្រាស់ការកំណត់នាមសុទ្ធ ៗ ដោយវេទនានុបស្សនា និង ចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រូវការត្រាស់ការកំណត់រួមគ្នាទាំងរូប និង នាម ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ចំពោះការកំណត់រូបក្ខន្ធ ដោយកាយានុបស្សនា ត្រាស់ចំពោះការកំណត់វេទនាខន្ធដោយវេទនានុបស្សនា ត្រាស់ចំពោះការកំណត់វិញ្ញាណក្ខន្ធដោយចិត្តានុបស្សនា ។ ឥឡូវនេះ ដើម្បីនឹងត្រាស់ការកំណត់វិញ្ញាណក្ខន្ធ និង សង្ខារក្ខន្ធខ្លះ ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ដូច្នេះ ជាដើម ។

## នីវរណបព្វ

បណ្តាបទទាំងនោះ បទថា **សន្តំ** បានដល់ មានដោយការកើតទេឡើង រឿយ ៗ ។

បទថា **អសន្តំ** បានដល់ មិនមានដោយការមិនកើតទេឡើង ឬ មិនមានព្រោះលះបង់បានហើយ ។

បទថា **យថា ច** សេចក្តីថា **កាមច្ឆន្ទ** រមែងកើតទេឡើងបានដោយហេតុណា ។

បទថា **តញ្ច ជានាតិ** បានដល់ រមែងដឹងនូវហេតុនោះផងដែរ ។ គប្បីជ្រាបអធិប្បាយក្នុងគ្រប់ៗបទដោយន័យនេះ ។

ក្នុងបទថា **យថា ច** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យថា ÷

### អធិប្បាយសុភនិមិត្ត

**កាមច្ឆន្ទ** រមែងកើតទេឡើង ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃក្នុងអសុភនិមិត្ត ។ ដែលឈ្មោះថា សុភនិមិត្ត បានដល់ សុភនិមិត្តដែលស្អាតខ្លះ សុភនិមិត្ត ដែលមានអារម្មណ៍ស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ បានដល់ការធ្វើទុកក្នុងចិត្តដោយមិនត្រូវឧបាយ ការធ្វើទុកក្នុងចិត្តដោយមិនត្រូវផ្លូវ គឺ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀងថាទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខថា សុខខ្លះ ក្នុងវត្ថុដែលជា **អនត្តា** ថាជា **អត្តា** ខ្លះ ក្នុងវត្ថុដែលមិនស្អាត ថាស្អាតខ្លះ កាលព្រះយោគាវចរញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនោះ ឱ្យប្រព្រឹត្តទៅក្នុងសុភនិមិត្តនោះច្រើនគ្រាច្រើន ដង កាមច្ឆន្ទៈរមែងកើតទេឡើង ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុភនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយ

មិនត្រូវទំនង និង ការធ្វើទុកក្នុងចិត្តរឿយ ៗ ក្នុងសុភនិមិត្តនោះ នេះជាអាការ ( បច្ច័យ ) ឱ្យកាមច្ឆន្ទៈដែលមិនទាន់កើតឱ្យកើតទេឡើងខ្លះ ធ្វើឱ្យកាមច្ឆន្ទៈដែលកើតទេឡើងហើយចម្រើនទេឡើងយ៉ាងក្រៃលែងខ្លះ ។

## អធិប្បាយអសុភនិមិត្ត

ចំណែកក្នុងអសុភនិមិត្ត ការលះបង់រមែងមានបានដោយការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ដែលឈ្មោះថា **អសុភនិមិត្ត** បានដល់ **អសុភនិមិត្ត** ដែលមិនស្អាតខ្លះ អសុភនិមិត្តដែលមានអារម្មណ៍មិនស្អាតខ្លះ ដែលឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ បានដល់ ការធ្វើទុកក្នុងចិត្តដោយត្រូវឧបាយ ការធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវ គឺ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀងថា មិនទៀងខ្លះ ក្នុងវត្ថុដែលជាទុក្ខថា ជាទុក្ខខ្លះ ក្នុងវត្ថុដែលជាអនត្តាថា ជាអនត្តាខ្លះ ក្នុងវត្ថុមិនស្អាតថា មិនស្អាតខ្លះ កាលព្រះយោគាវចរ ញ៉ាំងការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃនោះ ឱ្យប្រព្រឹត្តទៅក្នុងអសុភនិមិត្តនោះរឿយ ៗ ក៏រមែងលះកាមច្ឆន្ទៈបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយមាន អសុភនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង ការធ្វើរឿយ ៗ ក្នុង អសុភនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឱ្យ កាមច្ឆន្ទៈដែលនៅមិនទាន់កើតទេឡើង កើតទេឡើងមិនបានខ្លះ ឱ្យលះកាមច្ឆន្ទៈដែលកើតទេឡើងហើយខ្លះ ។

## លះកាមច្ឆន្ទៈដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ ការរៀនយកនូវអសុភនិមិត្ត ១ ប្រកបសេចក្ដីព្យាយាមរឿយ ៗ ក្នុងអសុភភាវនា ១

ភាពជាអ្នកគ្រប់គ្រងល្អក្នុងឥន្ទ្រីយ៍ទាំងទឡាយ ១ ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ភាពជាអ្នកពោល ឬ ស្តាប់នូវពាក្យដែលជាទីសប្បាយ ១ ។

កាលព្រះយោគាវចរសូម្បីរៀនយកនូវអសុភនិមិត្ត ១០ យ៉ាង ( ចន្លោះនេះ ) កាមច្ឆន្ទៈជាការដែលលោករមែងលះបាន កាលលោកចម្រើននូវអសុភនិមិត្តក្តី បិទទ្វារនៅក្នុងឥន្ទ្រីយ៍ទាំងទឡាយក្តី ស្គាល់ប្រមាណក្នុងភោជន ដែលមានឱកាសនឹងអាចឆាន់បាន ៤ - ៥ ដុំទៀត ( តែលោកក៏ឈប់ឆាន់ ) ហើយផឹកទឹកជំនួសជាប្រចាំក្តី កាមច្ឆន្ទៈក៏ជាការដែលលោកអាចលះបាន ។ ដោយហេតុនោះ លោកទើបបានពោលគាថាប្រព័ន្ធនេះទុកថា ÷

( នៅ ៤-៥ ដុំទៀតទើបនឹងឆ្អែត ព្រះយោគាវចរកុំឆាន់គួរផឹកទឹកជំនួស ( ព្រោះថា ) ត្រឹមតែប៉ុណ្ណោះក៏សមល្មមដែលនឹងនៅដោយសប្បាយ សម្រាប់ភិក្ខុអ្នកមានខ្លួនដែលបញ្ជូនទៅហើយ ) ។

សូម្បីកាលព្រះយោគាវចរគប់រកកល្យាណមិត្ត អ្នកត្រេកអរក្នុងអសុភ-ភាវនា ដូចជាព្រះតិស្សត្ថេរអ្នកចម្រើនអសុភកម្មដ្ឋាន កាមច្ឆន្ទៈដែលលោកអាចលះបាន លោករមែងលះ កាមច្ឆន្ទៈបាន សូម្បីដោយការសន្ទនាដោយកថាដែលជាសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថទាំងទឡាយ មានឥរិយា-បថឈរ និង អង្គុយជាដើម ។ ដោយហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ។ ក៏ព្រះយោគាវចរ រមែងដឹងច្បាស់ ថា កាមច្ឆន្ទៈដែលលះបានហើយ ដោយធម៌ ៦ ប្រការនេះ នឹងកើតទេឡើងមិនបានតទៅទៀត ដោយអរហត្តមគ្គ ។

## អធិប្បាយបដិឃនិមិត្ត

ម្យ៉ាងទៀត ព្រោះការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនូវបដិឃ_ និមិត្ត ព្យាបាទរមែងកើតទេឡើងបាន ។ ក្នុងបដិឃនិមិត្តនោះ បានដល់ បដិឃ_ និមិត្តដែលជាបដិឃៈខ្លះ បដិឃនិមិត្តដែលមានបដិឃៈជាអារម្មណ៍ខ្លះ ។ ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ មានលក្ខណៈតែម្យ៉ាងដូចគ្នាក្នុងទីគ្រប់កន្លែងនោះឯង ។ កាលព្រះយោគាវចរញុំាងការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃនោះឱ្យប្រព្រឹត្តទៅក្នុងនិមិត្តនោះច្រើនគ្រា ព្យាបាទរមែងកើតទេឡើងបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ បដិឃនិមិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និង ធ្វើច្រើនគ្រាក្នុងបដិឃនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឱ្យព្យាបាទដែលនៅមិនទាន់កើត កើតទេឡើងបានខ្លះ ឱ្យព្យាបាទដែលកើតទេឡើងហើយចម្រើនក្រៃលែងទេឡើងខ្លះ ក៏ការលះព្យាបាទនោះរមែងមានបានដោយការធ្វើមេត្តាចេតោវិមុត្តិទុកក្នុងចិត្ត ដោយឧបាយដ៏ប្រពៃក្នុងមេត្តាចេតោវិមុត្តិនោះ គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ÷

កាលព្រះមានព្រះភាគត្រាស់ថា មេត្តារមែងគួរដល់អប្បនាសមាធិ និង ឧបចារសមាធិ កាលត្រាស់ថា ចេតោវិមុត្តិរមែងគួរចំពោះអប្បនាតែម្យ៉ាង ការធ្វើ ( ចេតោវិមុត្តិ ) ទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃមានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរញុំាងការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃនោះឱ្យប្រព្រឹត្តទៅក្នុងមេត្តាចេតោវិមុត្តិនោះរឿយ ៗ លោកក៏រមែងលះព្យាបាទ បាន ។

ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា មាន , ម្នាលភិក្ខុទាំងទឡាយ មេត្តាចេតោវិមុត្តិមានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង

ការធ្វើឱ្យច្រើនក្នុងមេត្តាចេតោវិមុត្តិនោះ នេះជាអាហារ ( បច្ច័យ ) មិនឱ្យព្យាបាទដែលនៅមិនទាន់កើត កើតទេឡើងមិនបានខ្លះ លះព្យាបាទដែលកើតទេឡើងហើយខ្លះ ។

## លះព្យាបាទដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ ការរៀននូវមេត្តានិមិត្ត ១ ការប្រកបព្យាយាមរឿយៗក្នុងមេត្តាភាវនា ១ ការពិចារណាថា សត្វទាំងទឡាយមានកម្មជារបស់ខ្លួន ១ ភាពជាអ្នកច្រើនទៅដោយការពិចារណា ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការសន្ទនាដល់រឿងដែលជាទីសប្បាយ ១ ។

អធិប្បាយថា កាលព្រះយោគាវចររៀននូវមេត្តាដោយអំណាចការផ្សាយទៅចំពោះទិស និង មិនចំពោះទិសយ៉ាងណាមួយ លោករមែងលះព្យាបាទ បាន ។

សូម្បីកាលព្រះយោគាវចរចម្រើនមេត្តា ដោយការផ្សាយទៅកាន់ទិសដោយចំពោះ លោករមែងលះព្យាបាទបាន ។

កាលព្រះយោគាវចរ ពិចារណាឃើញថា ខ្លួន និង អ្នកដទៃមានកម្មជារបស់ខ្លួនយ៉ាងនេះថា ឯងក្រោធគេហើយនឹងធ្វើអ្វីគេបាន ឯងនឹងអាចធ្វើគុណ_ធម៌មានសីលគុណជាដើម របស់គេឱ្យវិនាសបានឬ ? ឯងមកតាមកម្មរបស់ខ្លួន ហើយក៏នឹងទៅតាមកម្មរបស់ខ្លួននោះឯង មិនមែនឬ ? ដែលឈ្មោះថាការក្រោធអ្នកដទៃទៀត ដូចជាបុគ្គលប្រាថ្នាស្រវាចាប់យកផេះ ដែលប្រាសចាកអណ្តាតភ្លើង លំពែងដែកដ៏ក្តៅ និង លាមកជាដើម គ្រវែងសំដៅបុគ្គលដទៃ

សូម្បីគេក្រោធនឹងឯងហើយក៏ធ្វើអ្វីបាន គេនឹងអាចឱ្យគុណធម៌មានសីលជាដើមរបស់ឯង វិនាសបានឬ ? គេមកតាមកម្មរបស់ខ្លួន ក៏នឹងទៅតាមកម្មរបស់ខ្លួនដូចគ្នា សេចក្ដីក្រោធនោះក៏នឹងធ្លាក់ស្រោចក្បាលគេនោះទាំងស្រុង ដូចរបស់ដែលផ្ញើទៅ មិនមាននរណាទទួល ( ក៏នឹងត្រឡប់មករកអ្នកផ្ញើវិញ ) និង ដូចធូលីបាចបញ្ច្រាសខ្យល់ ( ក៏នឹងរសាត់ត្រឡប់មកត្រូវអ្នកបាច ) ដូច្នេះខ្លះពិចារណាឃើញថា ទាំងខ្លួនទាំងអ្នកដទៃទៀតមានកម្មជារបស់ខ្លួន និង ស្ថិតនៅក្នុងការពិចារណាខ្លះ គប់រកកល្យាណមិត្តអ្នកត្រេកអរក្នុងមេត្តាភាវនា ដូចជាព្រះអស្សគុត្តត្ថេរខ្លះ លោករមែងលះព្យាបាទបាន ។

លោករមែងលះព្យាបាទបាន សូម្បីដោយការសន្ទនាដល់រឿងដែលជាទីសប្បាយទាក់ទងដោយមេត្តាក្នុងឥរិយាបថទាំងទ្បាយ មានឥរិយាបថអង្គុយ និង ឈរជាដើម ។

ក៏ព្រះយោគាវចររមែងដឹងច្បាស់ថា ព្យាបាទដែលលះបានហើយដោយ ធម៌ ៦ ប្រការនេះ នឹងកើតទេឡើងមិនបានតទៅ ដោយអនាគាមិមគ្គ ។

## អធិប្បាយ អរតិ ជាដើម

ព្រោះធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃក្នុងធម៌ទាំងទ្បាយ គឺ **សតិ** ជាដើម **ថីនមិទ្ធ** រមែងកើតទេឡើងបាន ។

ដែលឈ្មោះថា **អរតិ** បានដល់ ភាពជាអ្នកជិនណាយមិនត្រេកអរ ។

ដែលឈ្មោះថា **តន្ទិ** បានដល់ ភាពជាអ្នក ទម្រន់ ។

ដែលឈ្មោះថា **វិជម្ភិកា** បានដល់ ពត់ ឬ អែនអន ។

ដែលឈ្មោះថា **ស្រវឹងអាហារ** បានដល់ សេចក្ដីសញ្ជប់សញ្ជឹងដែល

កើតពីអាហារ និង សេចក្តីក្រវល់ក្រវាយដែលកើតពីអាហារ ។

ដែលឈ្មោះថា **ការរួញរានៃចិត្ត** បានដល់ ការដែលចិត្តងងុយ_ ងោកងក់ ។

ក៏កាលព្រះយោគាវចរ ធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃឱ្យប្រព្រឹត្តទៅក្នុងធម៌ទាំងទឡាយមាន **អរតិ** ជាដើមនេះរឿយ ៗ **ថីនមិទ្ធ** រមែងកើតទេឡីងបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយការមិនត្រេកអរ ការមិនអែនអន សេចក្តីខ្ជិលច្រអូស ការស្រវឹងអា_ហារ និង ការដែលចិត្តរួញរា ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និង ការធ្វើឱ្យច្រើនក្នុងធម៌ទាំងទឡាយមាន **អរតិ** ជាដើមនោះ នេះជាអាហារ ( បច្ច័យ ) ឱ្យថីនមិទ្ធៈដែលមិនទាន់កើត កើតទេឡីងបានខ្លះ ឱ្យថីនមិទ្ធៈដែល
កើតទេឡីងហើយ ចម្រើនក្រៃលែងខ្លះ ។

## អធិប្បាយអារព្ភធាតុ ជាដើម

ក៏ការលះថីនមិទ្ធៈនោះ រមែងមានបានដោយយោនិសោមនសិការ ក្នុងធាតុទាំងទឡាយ មាន **អារព្ភធាតុ** ជាដើម ។

ដែលឈ្មោះថា **អារព្ភធាតុ** បានដល់ សេចក្តីព្យាយាមដែលប្រារព្ធទេឡីងជាដំបូង ។

ដែលឈ្មោះថា **និក្កមធាតុ** បានដល់ សេចក្តីព្យាយាមដែលមានកម្លាំងខ្លាំងជាងសេចក្តីព្យាយាមដែលប្រារព្ធទេឡីងជាដំបូងនោះ ព្រោះជាគ្រឿងចេញចាកកោសជ្ជៈ ។

ដែលឈ្មោះថា **បរក្កមធាតុ** បានដល់ សេចក្តីព្យាយាមដែលមានកម្លាំងខ្លាំងជាង **និក្កមធាតុ** សូម្បីនោះព្រោះឈានទៅកាន់ឋានៈដ៏ក្រៃលែង ទេឡើង ៗ ។

កាលព្រះយោគាវចរញ៉ាំង យោនិសោមនសិការ ឱ្យប្រព្រឹត្តទៅក្នុងសេចក្តីព្យាយាម ៣ ប្រភេទនេះរឿយ ៗ លោករមែងលះថីនមិទ្ធៈបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ទុកថា ម្នាលភិក្ខុទាំងទឡាយ **អារព្ភធាតុ និក្កមធាតុ** ( និង ) **បរក្កមធាតុ** ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង ការធ្វើឱ្យច្រើនក្នុង **អារព្ភធាតុ** ជាដើមនោះ នេះជាអាហារ ( បច្ច័យ ) មិនឱ្យថីមិទ្ធៈដែលនៅមិនទាន់កើត មិនកើតទេឡើងខ្លះ ឱ្យលះថីនមិទ្ធៈដែលកើតទេឡើងហើយខ្លះ ។

## លះថីនមិទ្ធៈដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹតទៅដើម្បីលះថីនមិទ្ធៈ គឺ ការកាន់យកនូវនិមិត្តក្នុងការបរិភោគហួសប្រមាណ ១ ការផ្លាស់ប្តូរឥរិយាបថ ១ មនសិការដល់អាលោកសញ្ញា ១ ការនៅក្នុងទីវាលស្រទឡះ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការសន្ទនាដល់រឿងដែលជាទីសប្បាយ ១ ។

ក៏កាលព្រះយោគាវចរឆាន់ ( ច្រើនពេក ) ដូចយ៉ាង **ហត្ថកព្រាហ្មណ៍ ភុត្តអនិមិត្តព្រាហ្មណ៍ តត្រវដ្តព្រាហ្មណ៍ អលង្សាជកព្រាហ្មណ៍** និង **កាកមាសកព្រាហ្មណ៍** ហើយអង្គុយបំពេញ **សមណធម៌** ក្នុងទីសម្រាកពេលយប់ និងក្នុងទីសម្រាកពេលថ្ងៃ ថីនមិទ្ធៈ រមែងមកគ្របសង្កត់បាន ដូចដំរីធំមក ជាន់ដូច្នោះ ។

តែសម្រាប់ភិក្ខុអ្នករៀនឱកាសដែលនឹងឆាន់បាន ៤ _ ៥ ដុំទៀត ហើយក៏ផឹកទឹកជំនួសជាប្រចាំ **ថីនមិទ្ធ** នោះ រមែងមិនមាន កាលព្រះយោគាវចរស្ងប្បីកាន់យកនិមិត្តក្នុងការបរិភោគនូវភោជនហួសប្រមាណ ដូចពោលមកនេះ លោករមែងលះ **ថីនមិទ្ធ** បាន ។

ក្នុងឥរិយាបថណា ព្រះយោគាវចរ ធ្លាក់នៅក្រោមអំណាចថីនមិទ្ធៈ កាលលោកផ្លាស់ឥរិយាបថដទៃអំពីឥរិយាបថនោះក្តី មនសិការដល់ពន្លឺព្រះច័ន្ទក្តី ពន្លឺប្រទីប និង ពន្លឺគប់ភ្លើងក្នុងពេលយប់ និង ពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃក្តី នៅក្នុងទីវាលស្រទទ្បះក្តី គប់រកកល្យាណមិត្តអ្នកលះថីនមិទ្ធៈបានហើយ ដូចព្រះ_មហាកស្សបត្ថេរក្តី លោករមែងលះថីនមិទ្ធៈបាន ។

លោករមែងលះថីនមិទ្ធៈបាន ស្ងប្បីដោយការសន្ទនាដល់រឿងដែលជាទីសប្បាយទាក់ទងនឹងធុតង្គក្នុងឥរិយាបថទាំងទឡាយ មាន ឥរិយាបថឈរ និង អង្គុយ ជាដើម ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ ។ ក៏ព្រះយោគាវចររមែងដឹងច្បាស់ ថា ថីនមិទ្ធៈដែលលះបានហើយដោយធម៌ ៦ ប្រការនេះ នឹងកើតទេឡើងមិនបានតទៅទៀតដោយអរហត្តមគ្គ ។

## អធិប្បាយ ឧទ្ធច្ចកុក្កុច្ច

កាលចិត្តមិនស្ងប់ ឧទ្ធច្ចកុក្កុច្ចៈ រមែងកើតទេឡើងបានដោយអយោនិ_សោមនសិការ ( មិនមានយោនិសោមនសិការ ) ។ អាការដែលចិត្តមិនស្ងប់ឈ្មោះថា ***អវូបសម*** ។ ដោយអត្ថ ពាក្យថា ***អវូបសម*** នោះ គឺ ឧទ្ធច្ច_

កុក្កុច្ចៈនោះឯង ។ កាលព្រះយោគាវចរញុំាងអយោនិសោមនសិការឱ្យប្រព្រឹត្តទៅក្នុងអវូបសមៈនោះជារឿយ ៗ ឧទ្ធច្ចកុក្កុច្ចៈរមែងកើតទេឡីង ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ សេចក្តីមិនស្ងប់ចិត្ត ការធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃ និងធ្វើឱ្យច្រើនគ្រាក្នុងការមិនស្ងប់ចិត្តនោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីឱ្យឧទ្ធច្ចកុក្កុច្ចៈដែលនៅមិនទាន់កើតឱ្យកើតទេឡីងខ្លះ ដើម្បីការបរិបូរណ៍ក្រៃលែងទេឡីង ៗ នៃឧទ្ធច្ចកុក្កុច្ចៈដែលកើតទេឡីងហើយខ្លះ ។

ក៏ការលះឧទ្ធច្ចកុក្កុច្ចៈនោះ បានដោយយោនិសោមនសិការក្នុងចិត្តស្ងប់ពោលគឺសមាធិ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ ការស្ងប់ចិត្ត ការមនសិការដោយឧបាយ និង ការធ្វើ រឿយ ៗ ក្នុងការស្ងប់ចិត្តនោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីមិនឱ្យឧទ្ធច្ច-កុក្កុច្ចៈដែលមិនទាន់កើតទេឡីង ឱ្យកើតទេឡីងខ្លះ ដើម្បីលះឧទ្ធច្ចកុក្កុច្ចៈដែលកើតទេឡីងហើយខ្លះ ។

## លះឧទ្ធច្ចកុក្កុច្ចដោយធម៌ ៦ ប្រការ

ម្យ៉ាងទៀត ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីលះ ឧទ្ធច្ចកុក្កុច្ចៈ គឺភាពជាពហូសូត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកដឹងប្រក្រតីក្នុងព្រះវិន័យ ១ ការគប់រក បុគ្គលដែលចម្រើន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។

អធិប្បាយថា លោកស្វូម្បីរៀននិកាយ ១ ខ្លះ , ២ និកាយខ្លះ , ៣ និកាយខ្លះ , ៤ និកាយខ្លះ , ៥ និកាយខ្លះ ទាំងព្រះបាលី ទាំងព្រះអដ្ឋកថា

រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។

លោកអ្នកច្រើនទៅដោយការសាកសួរនូវវត្ថុដែលជាកប្បិយ និង អកប្បិយក្តី ។ លោកជាអ្នកចេះដឹងជាប្រក្រតីក្នុងវិនយប្បញ្ញត្តិ ព្រោះភាពជាអ្នកប្រព្រឹត្តទៅក្នុងអំណាចវិន័យដែលខ្លួនស្ទាត់ជំនាញហើយក្តី ចូលទៅរកលោកអ្នកដ៏ចម្រើន គឺព្រះថេរៈអ្នកជាធំក្តី គប់រកកល្យាណមិត្តអ្នកទ្រទ្រង់វិន័យ ដូចព្រះឧបលិត្ថេរក្តី រមែងលះបង់ឧទ្ធច្ចកុក្កុច្ចៈបាន ។

ក្នុងឥរិយាបថទាំងទឡាយ មានការឈរ និង ការអង្គុយជាដើម លោករមែងលះបានដោយការពោលពាក្យដែលជាទីសប្បាយ ទាក់ទងនឹងវត្ថុដែលជាកប្បិយ និង អកប្បិយ ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ធម៌ ៦ យ៉ាងរមែងប្រព្រឹត្តទៅដើម្បីលះបង់ឧទ្ធច្ចកុក្កុច្ចៈ ។ លោករមែងដឹងច្បាស់ថា [១] បណ្តាឧទ្ធច្ចកុក្កុច្ចៈ ដែលលះបានហើយដោយធម៌ ៦ យ៉ាងនេះឧទ្ធច្ចៈនឹងកើតទេឡីងតទៅមិនបានដោយអរហត្តមគ្គ កុក្កុច្ចៈមិនមានការកើតទេឡីងតទៅ ដោយអនាគាមិមគ្គ ។

## អធិប្បាយ វិចិកិច្ឆា

វិចិកិច្ឆារមែងកើតទេឡីងបាន ដោយមិនមានមនសិការក្នុងធម៌ទាំងទឡាយដែលជាទីតាំងនៃវិចិកិច្ឆា ។ ដែលឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា ក៏បានដល់វិចិកិច្ឆានោះឯង ព្រោះជាហេតុនៃសេចក្តីសង្ស័យ ។ កាលយើងញុំាង

---

[១] បាឋៈថា **ឥមេហិ បន ឆហិ ធម្មេហិ បហីនស្ស ឧទ្ធច្ចស្ស អរហត្តមគ្គេន ។ល។ បជានាតិ** ។ ច្បាប់ ភូមាជា **ឥមេហិ បន ឆហិ ធម្មេហិ បហីនេ ឧទ្ធច្ចកុក្កុច្ចេ ឧទ្ធច្ច ។ល។ បជានាតិ** ប្រែតាមច្បាប់ ភូមា ។

អយោនិសោមនសិការក្នុងវិចិកិច្ឆានោះឱ្យប្រព្រឹត្តទៅរឿយ ៗ វិចិកិច្ឆារមែងកើតទេឡើង ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយធម៌ជាទីតាំងនៃវិចិកិច្ឆា ការធ្វើទុកក្នុងចិត្តដោយមិនត្រូវឧបាយ និង ការធ្វើឱ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីឱ្យវិចិកិច្ឆាដែលនៅមិនទាន់កើតឱ្យកើតទេឡើងខ្លះ ដើម្បីធ្វើឱ្យបរិបូណ៌ក្រៃលែងទេឡើងនៃ វិចិកិច្ឆាដែលកើតទេឡើងហើយខ្លះ ។

ក៏ការលះវិចិកិច្ឆានោះ រមែងមានបានដោយយោនិសោមនសិការក្នុងធម៌ទាំងទឡាយ មានកុសលជាដើម ។ ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់ទើបត្រាស់ថា ម្នាលភិក្ខុទាំងទឡាយ ធម៌ដែលជាកុសល និង អកុសល ធម៌ដែលមានទោស និង មិនមានទោស ធម៌ដែលគួរសេព និង មិនគួរសេព ធម៌ដែលថោកទាប និង ប្រណីត ធម៌ដែលមានចំណែកស្រដៀងនឹងធម៌ខ្មៅ និង ធម៌ស ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង ការធ្វើឱ្យច្រើនក្នុងធម៌ ទាំងនោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីមិនឱ្យវិចិកិច្ឆាដែលមិនទាន់កើត ឱ្យកើតទេឡើងខ្លះ ដើម្បីលះវិចិកិច្ឆាដែលកើតទេឡើងហើយខ្លះ [១] ។

ម្យ៉ាងទៀត ធម៌ទាំង ៦ យ៉ាងរមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ ភាពជាពហូសូត ១ ភាពជាអ្នកសាកសួរ ១ ភាពជាអ្នកស្ទាត់ជំនាញដឹងប្រក្រតីក្នុងព្រះវិន័យ ១ ភាពជាអ្នកច្រើនទៅដោយអធិមោក្ខ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។

---

[១] បាឋៈថា **អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ ឧប្បាទាយ ឧប្បន្នាយ វា វិចិកិច្ឆាយ ភិយ្យោភាវាយ វេបុល្លាយាតិ** ។ ច្បាប់ភូមាជា **អយមាហារោ អនុប្បន្នាយ វា វិចិកិច្ឆាយ អនុប្បាទាយ វា វិចិកិច្ឆា វា បហានាយាតិ** ។ ប្រែតាមច្បាប់ភូមា ។

អធិប្បាយថា សូម្បីលោករៀននិកាយ ១ ខ្លះ ។ ល ។ ៥ និកាយខ្លះ ទាំងបាលី ទាំងអដ្ឋកថា រមែងលះវិចិកិច្ឆាបានសូម្បីដោយពាហុសច្ចៈ ។ អ្នកច្រើនទៅដោយការសាកសួរ ដោយការប្រារព្ធព្រះរតនត្រ័យក្តី អ្នកមានការស្ទាត់ជំនាញ ប៉ិនប្រសប់នៅក្នុងព្រះវិន័យក្តី អ្នកច្រើនទៅដោយអធិមោក្ខ ពោលគឺមានសទ្ធារឹងមាំក្នុងព្រះរតនត្រ័យក្តី អ្នកគប់រកកល្យាណមិត្តដែលជាសទ្ធាវិមុត្តិ ដូចព្រះវក្កលិត្ថេរក្តី រមែងលះវិចិកិច្ឆាបានដោយពាហុសច្ចៈ ។

ក្នុងឥរិយាបថទាំងទឡាយមានការឈរ ការអង្គុយជាដើម លោករមែងលះវិចិកិច្ឆាបាន សូម្បីដោយពាក្យដែលជាទីសប្បាយទាក់ទងនឹងគុណព្រះរតន- ត្រៃ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ធម៌ ៦ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ក៏ព្រះយោគាបវររមែងដឹងច្បាស់ វិចិកិច្ឆាដែលលះបានដោយធម៌ ៦ យ៉ាងនេះនឹងមិនមានការកើតទេឡើងតទៅ ព្រោះ-សោតាបត្តិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្តីថា ព្រះយោគាវចរពិចារណាឃើញធម៌ក្នុងធម៌ទាំងទឡាយរបស់ខ្លួន ឬ ក្នុងធម៌ទាំងទឡាយរបស់អ្នកដទៃ គឺ ក្នុងធម៌ទាំងទឡាយរបស់ខ្លួនតាមកាល ( ដ៏សមគួរ ) ឬ របស់អ្នកដទៃតាមកាល ( ដ៏សមគួរ ) ដោយការកំណត់ឃើញនីវរណធម៌ ៥ ប្រការ យ៉ាងនេះ ។

តែក្នុងនីវរណបព្វៈនេះ ព្រះយោគាវចរនាំយកការកើតទេឡើង និង ការសូន្យទៅដោយអយោនិសោមនសិការ ឬ យោនិសោមនសិការក្នុងសុភនិមិត្តជាដើម ដោយន័យដូចដែលត្រាស់ទុកហើយក្នុងនីវរណៈ ៥ ។ សេចក្តីតអំពីនេះ ទៅមានន័យដូចពោលហើយនោះឯង ។

## អរិយសច្ចក្នុងនីវរណ

សតិជាគ្រឿងកំណត់នីវរណៈ ក្នុងនីវរណបព្វៈនេះ ជាទុក្ខសច្ចតែម្យ៉ាង បណ្ឌិតគប្បីប្រកបសេចក្ដីដូចដែលពណ៌នាមកនេះ ហើយដឹងនូវធម៌ដែលជាគ្រឿងនាំចេញចាកទុក្ខនៃភិក្ខុអ្នកកំណត់នីវរណៈជាអារម្មណ៍ សេចក្ដីដ៏សេសក៏ដូច្នោះដូចគ្នា ។

( ចប់ នីវរណបព្វៈ )

## ខន្ធបព្វៈ

ព្រះមានព្រះភាគ លុះទ្រង់ចែកធម្មានុបស្សនាដោយនីវរណៈ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយបញ្ចក្ខន្ធ ទើបត្រាស់ពាក្យមានជាអាទិថា **បុន ចបរំ** ។

បណ្ដាបទទាំងនោះ បទថា **បញ្ចសុ ឧបាទានក្ខន្ធេសុ** សេចក្ដីថា គំនរនៃ ឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ អធិប្បាយថា ពួកនៃធម៌ គឺគំនរនៃធម៌ដែលជាបច្ច័យនៃឧបាទាន ឈ្មោះថា ធម្មរាសី សេចក្ដីសង្ខេបក្នុងបញ្ចក្ខន្ធនេះមានប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដាររឿងខន្ធពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ រូបំ** សេចក្ដីថា ដឹងរូបដោយសភាវៈថានេះរូប រូប ប៉ុណ្ណោះ រូបដទៃអំពីនេះមិនមាន ។ សូម្បីក្នុងវេទនាជាដើមក៏ន័យនេះដូចគ្នា ។ សេចក្ដីសង្ខេបក្នុងពាក្យនេះ មានប៉ុណ្ណេះ ។ ចំណែកដោយពិស្ដារ រូបជាដើមលោកពោលទុកហើយក្នុងរឿងខន្ធ ក្នុង គម្ពីរវិសុទ្ធិមគ្គ នោះឯង ។

បទថា **ឥតិ រូបស្ស សមុទយោ** សេចក្ដីថា ការកើតនៃរូបដោយអាការ

៥ ដោយមានអវិជ្ជាជាទីកើតជាដើមយ៉ាងនេះ ។

បទថា **ឥតិ រូបស្ស អត្ថង្គមោ** សេចក្ដីថា ការរលត់ទៅនៃរូបដោយ អាការ ៥ ដោយមានការរលត់ទៅនៃអវិជ្ជាជាដើមយ៉ាងនេះ ។ សូម្បីក្នុងវេទនាជាដើមក៏ន័យនេះដូចគ្នា ។ នេះជាសេចក្ដីសង្ខេបក្នុងសេចក្ដីនេះ ចំណែកសេចក្ដីពិស្ដារពោលទុកហើយក្នុងរឿង ឧទយព្វយញ្ញាណ ក្នុង គម្ពីរវិសុទ្ធិមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ពិចារណាឃើញធម៌ក្នុងធម៌ទាំង-ទឡាយមិនថារបស់ខ្លួន ឬ របស់អ្នកដទៃ មិនថា តាមកាលរបស់ខ្លួន ឬ របស់អ្នកដទៃដោយការកំណត់បញ្ចក្ខន្ធជាអារម្មណ៍យ៉ាងនេះ ។ ក៏ក្នុងពាក្យនេះ **សមុ-ទយធម៌** និង **វយធម៌** គប្បីលើកទឡើងពិចារណាលក្ខណៈ ៥០ ដែលលោកពោលទុកក្នុងខន្ធទាំងទឡាយមានជាអាទិថា ព្រោះអវិជ្ជាកើត រូបទើប កើត ។ តអំពីនេះ ក៏មានន័យដូចពោលមកហើយ នោះឯង ។

## អរិយសច្ចក្នុងបញ្ចក្ខន្ធ

សតិជាគ្រឿងកំណត់ខន្ធជាអារម្មណ៍ ក្នុងខន្ធបព្វៈនេះជាទុក្ខសច្ចតែម្យ៉ាង គប្បីប្រកបសេចក្ដីដូចពោលមកនេះ ហើយគប្បីជ្រាបវត្តបដិបត្តិដែលជាគ្រឿងនាំចេញចាកទុក្ខរបស់ភិក្ខុអ្នកកំណត់ខន្ធជាអារម្មណ៍ ។ ពាក្យដ៏សេសក៏យ៉ាងនោះដូចគ្នា ។

( ចប់ ខន្ធបព្វៈ )

## អាយតនបព្វៈ

ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនាដោយបញ្ចក្ខន្ធយ៉ាងនេះ

ហើយ ឥទឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអាយតនៈ ទើបត្រាស់ពាក្យមានជាអាទិថា **បុន ចបរំ** ។

បណ្តាបទទាំងនោះ បទថា **ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ** បានដល់ អាយតនៈខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ( និង ) អាយតនៈខាងក្រៅ ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។

បទថា **ចក្ខុំ ច បជានាតិ** បានដល់ ដឹងនូវចក្ខុបសាទដោយលក្ខណៈនៃកិច្ចតាមសេចក្តីពិត ។

បទថា **រូបេ ច បជានាតិ** សេចក្តីថា ដឹងនូវរូបដែលមាន សមុដ្ឋាន ៤ យ៉ាង ខាងក្រៅផង ដោយលក្ខណៈនៃកិច្ចតាមសេចក្តីពិត ។

សេចក្តីថា **យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ** សេចក្តីថា ក៏ព្រោះអាស្រ័យអាយតនៈទាំង ២ យ៉ាងគឺ ទាំងភ្នែកផង ទាំងរូបផង សំយោជនៈ ១០ យ៉ាងគឺ **កាមរាគសំយោជន** , **បដិឃ** , **មាន** , **ទិដ្ឋិ** , **វិចិកិច្ឆា** , **សីលព្វតបរាមាស** , **ភវរាគ** , **ឥស្សា** , **មច្ឆរិយ** , និង **អវិជ្ជាសំយោជន** ឯណា រមែងកើតទេឡើង លោកដឹងច្បាស់ សំយោជនៈនោះ ដោយលក្ខណៈតាមសេចក្តីពិតផង ។

## ការកើតទេឡើងនៃសំយោជន

សួរថា ក៏សំយោជនៈនេះកើតទេឡើងបានដូចម្តេច ?

ឆ្លើយថា ក៏នឹងពោលក្នុងចក្ខុទ្វារមុន កាលលោកពេញចិត្ត ត្រេកត្រអាល ត្រេកអរនឹងឥដ្ឋារម្មណ៍ដែលមកកាន់គន្លង ( ចក្ខុ ) ដោយអំណាចនៃការពេញ

ចិត្តក្នុងឥដ្ឋារម្មណ៍ កាមរាគសំយោជនៈ នឹងកើតទេឡើង ។ កាលក្រោធក្នុងអនិដ្ឋារម្មណ៍ បដិឃសំយោជនៈនឹងកើតទេឡើង ។ ការសម្គាល់ថា ក្រៅអំពីយើង ហើយមិនមាននរណាដទៃនឹងអាចសម្តែងអារម្មណ៍ [១] នេះឱ្យជាក់ច្បាស់បាន , មានៈសំយោជនៈនឹងកើតទេឡើង ។ កាលប្រកាន់ថា រូបារម្មណ៍នេះ [២] ទៀងស្ថិតស្ថេរ ទិដ្ឋិសំយោជនៈនឹងកើតទេឡើង ។ កាលសង្ស័យថា រូបារម្មណ៍នេះ [២] ជាសត្វឬហ្ន៎ ឬ ជារបស់សត្វ វិចិកិច្ឆាសំយោជនៈនឹងកើតទេឡើង ។ កាលប្រាថ្នាភពថា ភព ( ការកើត ) នេះមិនមែននឹង[៣]រកបានងាយក្នុងសម្បត្តិភពទេឡើយ ភវរាគសំយោជនៈ [៤] នឹងកើតទេឡើង ។ ការប្រកាន់មាំនូវសីលនិងវត្តថា យើងសមាទានសីលនិងវត្តបែបនេះហើយអាចនឹងបាន ( សម្រេចគុណវិសេស ) តទៅ សីលព្វតបរាមាសសំយោជនៈនឹងកើតទេឡើង ។ កាលឥស្សាថា ធ្វើដូចម្តេច ហ្ន៎ អ្នកដទៃទើបនឹងមិនបានរូបារម្មណ៍នេះ
ឥស្សាសំយោជនៈនឹងកើតទេឡើង ។
កាលកំណាញ់រូបារម្មណ៍ដែលខ្លួនបានហើយចំពោះអ្នកដទៃ មច្ឆរិយសំយោជនៈនឹងកើតទេឡើង ។ ការមិនដឹងដោយមិនដឹងធម៌ដែលកើតទេឡើងព្រមជាមួយនឹងធម៌ទាំងនោះ ទាំងអស់នោះឯង អវិជ្ជាសំយោជនៈនឹងកើតទេឡើងបាន ។

បទថា **យថា ច អនុប្បន្នស្ស** សេចក្តីថា សំយោជនៈទាំង ១០ យ៉ាងនោះ ដែលមិនទាន់កើតនឹងកើតទេឡើងដោយហេតុ គឺដោយការមិនផុសផុលទេឡើងយ៉ាងណា លោកដឹងច្បាស់នូវហេតុនោះផង ។

---

[១] បាឋៈថា ឯកំ ច្បាប់ភូមាជា ឯតំ ប្រែតាមច្បាប់ភូមា ។

[២] បាឋៈថា ឯវំ ច្បាប់ភូមាជា ឯតំ ប្រែតាមច្បាប់ភូមា ។

[៣] បាឋៈថា សម្បត្តិភវេ អត្តនោ ភូមាជា សម្បត្តិភវេ វត នោ ប្រែតាមច្បាប់ភូមា ។

[៤] បាឋៈថា ភវសំយោជនំ ច្បាប់ភូមាជា ភវរាគសំយោជនំ ប្រែតាមច្បាប់ភូមា ។

បទថា **យថា ច ឧប្បន្នស្ស** សេចក្ដីថា ចំណែកការលះសំយោជនៈសូម្បីទាំង ១០ យ៉ាងនោះ ដែលកើតទេឡើងហើយដោយសេចក្ដីថា នៅលះមិនទាន់បានក្ដី ដោយការផុសផុលទេឡើងក្ដី ដោយហេតុណា លោករមែងដឹងច្បាស់នូវហេតុនោះផង ។

បទថា **យថា ច បហីនស្ស** សេចក្ដីថា សំយោជនៈ ១០ យ៉ាងនោះសូម្បីដែលលះបានហើយដោយតទង្គប្បហាន និង វិក្ខម្ភនប្បហាន នឹងមិនមានការកើតទេឡើងតទៅ ដោយហេតុយ៉ាងណា លោកក៏ដឹងហេតុនោះផង ។ អធិ_ប្បាយថា ក៏សំយោជនៈនោះនឹងមិនមានការកើតទេឡើងតទៅ គឺ សំយោជនៈ ៥ យ៉ាង ផ្សេងដោយ **ទិដ្ឋិ , វិចិកិច្ឆា , សីលព្វតបរាមាស , ឥស្សា** និង មច្ឆរិយៈនឹងមិនមានការកើតទេឡើងតទៅទៀត ដោយសោតាបត្តិមគ្គ ។

សំយោជនៈទាំងគូ គឺ កាមរាគៈ និង បដិឃៈយ៉ាងគ្រោតគ្រាតនឹងមិនមានការកើតទេឡើងតទៅដោយសកទាគាមិមគ្គ សំយោជនៈទាំងគូ គឺ កាមរាគៈ និងបដិឃៈដែលប្រព្រឹត្តទៅជាមួយគ្នាយ៉ាងល្អិត នឹងមិនមានការកើតទេឡើងតទៅដោយអនាគាមិមគ្គ សំយោជនៈ ៣ យ៉ាង គឺ **មាន , ភវរាគ ,** និង **អវិជ្ជា** នឹងមិនមានការកើតទេឡើងតទៅដោយអរហត្តមគ្គ ដោយហេតុណា លោកដឹងច្បាស់នូវហេតុនោះ ។ សូម្បីក្នុងបទថា ក្នុងសំទេឡងជាដើម ក៏ន័យនេះដូច គ្នា ។ ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ គប្បីជ្រាបកថាដែលពោលដោយអាយតនៈដោយពិស្ដារតាមន័យដែលបានពោលទុកហើយក្នុង **អាយតននិទ្ទេស** ក្នុង **គម្ពីរវិសុទ្ធិមគ្គនោះ** ចុះ ។

ព្រះយោគាវចរ ពិចារណាឃើញធម៌ក្នុងធម៌ទាំងទឡាយរបស់ខ្លួនដោយការកំណត់អាយតនៈខាងក្នុង ឬ ក្នុងធម៌ទាំងទឡាយរបស់អ្នកដទៃ ដោយការ

កំណត់អាយតនៈខាងក្រៅ គឺ ក្នុងធម៌ទាំងទឡាយរបស់ខ្លួនតាមកាល ( ដ៏សម-គួរ ) ឬ របស់អ្នកដទៃតាមកាល ( ដ៏សមគួរ ) ដោយប្រការយ៉ាងនេះ ។ ក៏ក្នុងអាយតនបព្វៈនេះ **សមុទយធម៌** និង **វយធម៌** គួរនាំចេញទៅដោយន័យនៃរូបាយតនៈ ដែលត្រាស់ទុកហើយក្នុងរូបក្ខន្ធនៃអាយតនៈ ក្នុងបណ្តាអរូបា-យតនៈទាំងទឡាយ ដែលត្រាស់ទុកក្នុងវិញ្ញាណក្ខន្ធនៃធម្មាយតនៈ ដែលត្រាស់ទុកក្នុងខន្ធដ៏សេសថា ព្រោះអវិជ្ជាកើត ចក្ខុទើបកើត ។ មិនគួរសំដៅដល់លោកុត្តរធម៌ ។ ពាក្យតអំពីនេះទៅ មានន័យដូចដែលពោលមកនេះឯង ។

## អរិយសច្ច ក្នុងអាយតន

សតិជាគ្រឿងកំណត់អាយតនៈ ក្នុងអាយតនបព្វៈនេះ ជាទុក្ខសច្ចគប្បីប្រកបសេចក្តីដូចដែលពោលមកនេះ ហើយដឹងបដិបទាដែលជាហេតុនាំ ចេញ ( ចាកទុក្ខ ) នៃភិក្ខុអ្នកកំណត់យកអាយតនៈជាអារម្មណ៍ ។ ពាក្យដ៏សេសក៏យ៉ាងនោះ ដូចគ្នា ។

## ( ចប់ អាយតនបព្វៈ )

## ពោជ្ឈង្គបព្វ

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់ចែកធម្មានុបស្សនាដោយអាយតនៈដែលប្រព្រឹត្តទៅក្នុងខាងក្នុង និង ខាងក្រៅយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយពោជ្ឈង្គ ទើបត្រាស់ ពាក្យមានជាអាទិថា **បុន ចបរំ** ។

បណ្តាបទទាំងនោះ បទថា **ពោជ្ឈង្គេសុ** បានដល់ អង្គនៃបុគ្គលអ្នកជាប់នៅក្នុងការត្រាស់ដឹង ។

បទថា **សន្តំ** បានដល់ មាននៅដោយការត្រទឡប់បាន ។

បទថា **សតិសម្ពោជ្ឈង្គំ** បានដល់ អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ពោលគឺសតិ ។

## អត្ថនៃពាក្យថា សម្ពោជ្ឈង្គ

អធិប្បាយថា ព្រះយោគាវចររមែងដឹងគ្រប់សព្វក្នុងធម៌ ៧ នេះ ចាប់ផ្តើមពីប្រារព្ធចំពោះវិបស្សនា ព្រោះដូច្នោះ ធម៌ទាំង ៧ នោះ ទើបឈ្មោះថា **សម្ពោជ្ឈង្គ** ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះភ្ញាក់ គឺ ក្រោកទេឡើងអំពីការលង់លក់ក្នុងកិលេស ឬ ចាក់ធ្លុះសច្ចៈទាំងទឡាយដោយធម្មសាមគ្គី ៧ ប្រការណា មានសតិជាដើម ធម្មសាមគ្គីនោះ ឈ្មោះថា **សម្ពោធិ** ។ ដែលឈ្មោះថា **សម្ពោជ្ឈង្គ** ព្រោះជាអង្គនៃសម្ពោធិធម៌ ឬ សម្ពោធិធម្មសាមគ្គីនោះ ។ ដោយហេតុនោះ លោកទើបពោលថា **សម្ពោជ្ឈង្គ** ពោលគឺ សតិ ។ សូម្បីក្នុងសម្ពោជ្ឈង្គដ៏សេស ក៏គប្បីជ្រាប អត្ថរបស់ពាក្យ ដោយន័យនេះដូចគ្នា ។

បទថា **អសន្តំ** សេចក្តីថា មិនមានដោយការមិនត្រទឡប់បាន ។ ក៏ក្នុងបទទាំងទឡាយមានជាអាទិថា **យថា ច អនុប្បន្នស្ស** មានវិនិច្ឆ័យដូចតទៅ នេះ ÷

## ការកើតទេឡើងនៃសតិសម្ពោជ្ឈង្គ

សតិសម្ពោជ្ឈង្គ នឹងមានការកើតទេឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងទឡាយ ធម៌ជាដែលទីតាំងនៃសតិសម្ពោជ្ឈង្គ ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និងការធ្វើឱ្យច្រើនក្នុងធម៌ទាំងនោះ នេះជាអាហារ ( បច្ច័យ ) រមែងប្រព្រឹត្តទៅដើម្បីឱ្យសតិសម្ពោជ្ឈង្គដែលមិនទាន់កើត ឱ្យកើតទេឡើងផង ដើម្បីសេចក្តីចម្រើនក្រៃលែង ដើម្បីការបរិបូរណ៍នៃការចម្រើនសតិសម្ពោជ្ឈង្គដែលកើតទេឡើងហើយ

ផង ។ កាលសតិនោះមាន ធម៌ទាំងទឡាយនោះឯង ដែលជាទីតាំងនៃសតិស-ម្ពោជ្ឈង្គៈ មានយោនិសោមនសិការ មានលក្ខណៈដូចពោលមកហើយនោះឯង កាលព្រះយោគាវចរញុំាងយោនិសោមនសិការនោះ ឱ្យប្រព្រឹត្តទៅក្នុងធម៌ទាំងនោះរឿយ ៗ សតិសម្ពោជ្ឈង្គ រមែងកើតទេឡើង ។

ម្យ៉ាងទៀត ធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃសតិសម្ពោជ្ឈង្គ គឺ **សតិសម្បជញ្ញ ១ ការវៀរចាកបុគ្គលអ្នកវង្វេង- ភ្លេចសតិ ១ ការគប់រកសមាគមនឹងបុគ្គលអ្នកមានសតិតាំងមាំ ១ ភាព ជាអ្នកបង្អោនទៅរកសតិ ១** ។

ពិតណាស់ សតិសម្ពោជ្ឈង្គៈ នឹងកើតទេឡើងក្នុងទី ៧ ស្ថាន មានការឈានទៅខាងមុខជាដើម ព្រោះមានសតិសម្បជញ្ញៈ ព្រោះវៀរបុគ្គលអ្នកវង្វេងភ្លេចសតិដូចការរក្សាអាហារទុក ព្រោះគប់រកសមាគមជាមួយនឹងបុគ្គលអ្នកមានសតិតាំងមាំ ដូច **ព្រះតិស្សទត្តត្ថេរ** និង **អភយត្ថេរ** ជាដើម និង ព្រោះជាអ្នកមានចិត្តបង្អោនទៅដើម្បីឱ្យសតិតាំងទេឡើងក្នុងឥរិយាបថទាំងទឡាយ មានការអង្គុយ ការដេកជាដើម ។ លោករមែងដឹងច្បាស់ថា ការបរិបូរណ៍នៃការចម្រើនសតិសម្ពោជ្ឈង្គៈនោះ ដែលកើតទេឡើងហើយដោយហេតុ ៤ យ៉ាងនេះ នឹងមានបានដោយអរហត្តមគ្គ ។

## ការកើតទេឡើងនៃធម្មវិចយសម្ពោជ្ឈង្គ

ចំណែកធម្មវិចយសម្ពោជ្ឈង្គៈ មានការកើតទេឡើងយ៉ាងនេះថា ម្នាលភិក្ខុទាំងទឡាយកុសលធម៌ និង អកុសលធម៌ទាំងទឡាយ ។ ល ។ ធម៌ដែលមានចំណែកប្រហាក់ប្រហែលនឹងកណ្ហធម៌ និង សុក្កធម៌ពួកណា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃក្នុងធម៌ទាំងនោះ នេះជាអាហារ ( បច្ច័យ ) ប្រព្រឹត្តទៅ

ដើម្បីឱ្យធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើត ឱ្យកើតទេឡើងផង ដើម្បីភិយ្យោភាព ដើម្បីបរិបូណ៌នៃធម្មវិចយសម្ពោជ្ឈង្គ ដើម្បីចម្រើនធម្មវិចយសម្ពោជ្ឈង្គ ដើម្បីឱ្យធម្មវិចយសម្ពោជ្ឈង្គបរិបូណ៌ផង ។

ម្យ៉ាងទៀត ធម៌ទាំង ៧ ប្រការ គឺ ការសាកសួរ ១ ការធ្វើវត្ថុឱ្យស្អាតផូរផង់ ១ ការធ្វើឥន្ទ្រីយ៍ឱ្យស្មើគ្នា ១ ការវៀរបុគ្គលអ្នកអាប់ឥតបញ្ញា ១ ការគប់រកសមាគមនឹងអ្នកមានបញ្ញា ១ ការពិចារណានូវការប្រព្រឹត្តិដោយញាណដ៏ជ្រាលជ្រៅ ១ ការបង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ។ ភាពជាអ្នកច្រើនដោយការសាកសួរទាក់ទងនឹងសេចក្ដីនៃ **ខន្ធ ធាតុ អាយតន ឥន្ទ្រីយ៍ ពល ពោជ្ឈង្គ មគ្គ អង្គឈាន សមថ** និង **វិបស្សនា** ឈ្មោះថា **បរិបុច្ឆកតា** ក្នុងបណ្ដាធម៌ ៧ ប្រការនោះ ។

ការធ្វើវត្ថុទាំងខាងក្នុង និង ខាងក្រៅឱ្យស្អាតផូរផង់ ឈ្មោះថា **វត្ថុវិសទកិរិយា** ។ ព្រោះថា កាលណាសក់ ក្រចក និង រោម របស់លោកវែងពេកទៅ ឬ រាងកាយរបស់លោកមានរោគ ( ទោស ) ច្រើន និង មិនស្អាតស្អំដោយភាពកខ្វក់ គឺ ញើស កាលនោះវត្ថុដែលមាននៅក្នុងខាងក្នុងចិត្ត និង មិនស្អាតផូរផង់ មិនបរិសុទ្ធ ។ តែកាលណា ចីវររបស់លោកចាស់សៅហ្មងមានក្លិន ឬ សេនាសនៈប្រទឡាក់ប្រទឡូស កាលនោះវត្ថុដែលមានក្នុងខាងក្រៅនិងមិនស្អាតផូរផង់ មិនបរិសុទ្ធ ព្រោះដូច្នោះ វត្ថុខាងក្នុងលោកត្រូវធ្វើឱ្យស្អាតផូរផង់ ដោយការកោរសក់ជាដើមដោយការធ្វើរាងកាយ ឱ្យស្រាលសប្បាយដោយការជម្រះទាំងខាងលើទាំងខាងក្រោម ជាដើម ( និង ) ដោយការអប់ឧណ្ហ ។

# ១៤៥ អដ្ឋកថា សតិប្បដ្ឋានសូត្រ

វត្ថុខាងក្រៅត្រូវធ្វើឱ្យស្អាតផូរផង់ ដោយការដេរ ការបោក ការជ្រលក់ និង ការធ្វើគ្រឿងប្រើប្រាស់ជាដើម ។ ព្រោះថា សូម្បីញាណក្នុងចិត្ត និង ចេតសិកដែលកើតទេឡើង ព្រោះវត្ថុខាងក្នុង និង ខាងក្រៅនេះដែលមិនស្អាត ផូរផង់ ក៏នឹងមិនស្អាតផូរផង់ ( ទៅដែរ ) ដូចពន្លឺនៃអណ្តាតប្រទីប ដែលកើត ទេឡើងដោយអាស្រ័យប្រឆេះ និង ប្រេងដែលមិនស្អាតដូច្នោះ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ការធ្វើវត្ថុឱ្យស្អាតផូរផង់ រមែងប្រព្រឹត្តទៅដើម្បី ការកើតទេឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ។

ការធ្វើឥន្ទ្រីយ៍មានសទ្ធាជាដើមឱ្យមានការស្មើគ្នា ឈ្មោះថា ការធ្វើ ឥន្ទ្រីយ៍ឱ្យស្មើគ្នា ។ ព្រោះប្រសិនបើសទ្ធិន្ទ្រីយ៍របស់លោកមានកម្លាំង ឥន្ទ្រីយ៍ ក្រៅអំពីនេះទន់ខ្សោយ ។ តពីនោះទៅ វិរិយៈក៏មិនអាចនឹងធ្វើនាទីផ្គត់ផ្គង់ទុក បាន សតិន្ទ្រីយ៍ក៏មិនអាចធ្វើនាទីប្រាកដបាន ។ សមាធិន្ទ្រីយ៍ក៏មិនអាចធ្វើនាទី ដែលមិនរាយមាយបាន បញ្ញាក៏មិនអាចនឹងពិចារណាឃើញច្បាស់បាន ។ ព្រោះ ដូច្នោះ ព្រះយោគាវចរគប្បីឱ្យសទ្ធិន្ទ្រីយ៍នោះខ្សោយកម្លាំងទៅដោយការពិចា-រណាដល់សភាវធម៌ ឬ ដោយមិនយកចិត្តទុកដាក់ដល់ សទ្ធិន្ទ្រីយ៍នឹងមាន កម្លាំង ។ ក៏ក្នុងសេចក្តីនេះមានរឿងរបស់ព្រះវក្កលិជាតួយ៉ាង ។ តែបើវិរិ-យិន្ទ្រីយ៍មានកម្លាំងខាងក្រោយសទ្ធិន្ទ្រីយ៍ នឹងមិនអាចធ្វើនាទីបង្អោនចិត្តជឿបាន ទេឡើយ ឥន្ទ្រីយ៍ក្រៅពីនេះ ក៏មិនអាចធ្វើនាទីផ្សេងក្រៅនេះបាន ព្រោះដូច្នោះ ព្រះយោគាវចរ គប្បីឱ្យវិរិយិន្ទ្រីយ៍នោះ ថយចុះមកដោយការចម្រើនបស្សទ្ធិជា ដើម ។ សូម្បីក្នុងសេចក្តីនោះ គប្បីសម្តែងរឿងរបស់ព្រះសោណត្ថេរឱ្យឃើញ ។ សូម្បីក្នុងឥន្ទ្រីយ៍ដ៏សេសក៏គប្បីជ្រាបយ៉ាងនោះ កាលឥន្ទ្រីយ៍តែមួយមានកម្លាំង គប្បីជ្រាបថា ឥន្ទ្រីយ៍ក្រៅពីនេះ ក៏អស់សមត្ថភាពក្នុងនាទីរបស់ខ្លួន ។

## ១៨៦ អដ្ឋកថា សតិប្បដ្ឋានសូត្រ

តែក្នុងរឿងនេះ លោកសរសើរការដែលសទ្ធា និង បញ្ញាស្មើគ្នា ហើយ សមាធិ និង វិរិយៈស្មើគ្នាទុកដោយពិសេស ។ ព្រោះថា អ្នកមានសទ្ធាមាន កម្លាំង តែមានបញ្ញាខ្សោយនឹងមានសេចក្ដីជ្រះថ្លាយ៉ាងងាយ គឺ ជ្រះថ្លាក្នុង វត្ថុដែលមិនមែនវត្ថុ អ្នកមានបញ្ញាមានកម្លាំង ( តែ ) មានសទ្ធាទន់ខ្សោយ រមែងជាបុគ្គលច្រើនទៅដោយការអួតអាង ពិចារណាដោយគំនិតខ្លួនឯង មិនជឿ ស្ដាប់អ្នកដទៃ មិនព្រមទទួលថ្នាំ មិនធ្វើកុសលមានទានជាដើម ដោយគិតខុស ថា កុសលនឹងមានបានដោយហេតុត្រឹមតែចិត្តុប្បាទប៉ុណ្ណោះ រមែងធ្លាក់នរក ។ ( តែ ) ព្រោះសទ្ធា និង បញ្ញាទាំងពីរនេះស្មើគ្នា គេនឹងជ្រះថ្លាក្នុងព្រះរតនត្រ័យ តែម្យ៉ាង ។ ចំណែកសមាធិមានកម្លាំង តែវិរិយៈទន់ខ្សោយ កោសជ្ជៈ ( ភាព ខ្ជិលច្រអូស ) នឹងគ្របសង្កត់ ( លោក ) ព្រោះសមាធិជាបក្សពួកនៃកោសជ្ជៈ ។ បើវិរិយៈមានកម្លាំង តែសមាធិទន់ខ្សោយ ឧទ្ធច្ចៈ ( ការរាយមាយ ) នឹងគ្រប_ សង្កត់លោក ព្រោះវិរិយៈជាបក្ខពួកនៃឧទ្ធច្ចៈ ។ ក៏សមាធិដែលប្រកបទៅដោយ វិរិយៈនឹងមិនធ្លាក់ទៅក្នុងកោសជ្ជៈការខ្ជិលច្រអូស ។ វិរិយៈដែលប្រកបទៅ ដោយសមាធិ នឹងមិនធ្លាក់ទៅក្នុងអំណាចឧទ្ធច្ចៈ ព្រោះដូច្នោះ ទើបគប្បីធ្វើ សមាធិ និង វិរិយៈទាំងគូនោះឱ្យស្មើគ្នា ។

ម្យ៉ាងទៀត សម្រាប់អ្នកផ្ដើមបំពេញសមាធិ សទ្ធាសូម្បីនឹងមានកម្លាំងក៏ ប្រើបាន ។ កាលបើដូច្នេះ នឹងសម្រេចអប្បនាបាន ។ ក្នុងសមាធិ និង បញ្ញា សម្រាប់អ្នកផ្ដើមបំពេញសមាធិ ឯកគ្គតា ( សមាធិ ) មានកម្លាំងរមែងប្រើបាន ដោយថា កាលបើដូច្នេះ លោកក៏នឹងចាក់ធ្លុះអប្បនា ។ សម្រាប់អ្នកផ្ដើមបំពេញ វិបស្សនាបញ្ញាមានកម្លាំងរមែងប្រើបាន ។ ដោយថា កាលបើដូច្នោះលោកក៏ នឹងចាក់ធ្លុះលក្ខណៈ ( ព្រះត្រៃលក្ខណ៍ ) ។ ក៏ព្រោះឥន្ទ្រីយ៍ទាំងពីរយ៉ាងនោះ

ស្មើគ្នា អប្បនាក៏នឹងមានយ៉ាងពិតប្រាកដ ។ ចំណែកសតិមានកម្លាំង ប្រើបានក្នុងទីគ្រប់ស្ថាន ។ ព្រោះថា សតិនឹងរក្សាចិត្តទុកបានចាកការធ្លាក់ទៅកាន់ឧទ្ធច្ចៈ ដោយអំណាចនៃសទ្ធា វិរិយៈ និង បញ្ញាដែលជាបក្ខពួកនៃឧទ្ធច្ចៈ នឹងរក្សាចិត្តទុកបានមិនឱ្យធ្លាក់ទៅកាន់កោសជ្ជៈដោយសមាធិ ដែលជាបក្ខពួកនៃកោសជ្ជៈ ព្រោះដូច្នោះ សតិនោះទើបត្រូវប្រាថ្នាក្នុងទីទាំងពួង ដូចក្នុងសម្លគ្រប់យ៉ាងត្រូវការអំបិល និង ដូចក្នុងរាជកិច្ចគ្រប់ប្រភេទត្រូវការអ្នកសម្រេចរាជការ ។ ដោយហេតុនោះ ទើបលោកពោលថា ក៏ឯសតិចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកហើយ ។

ព្រោះហេតុអ្វី ?

ព្រោះថា ចិត្តមានសតិជាទីពឹងអាស្រ័យ ហើយសតិមានការរក្សាជាគ្រឿងប្រាកដ វៀរសតិចេញហើយ ការផ្គង និង ការគ្របសង្កត់ចិត្តនឹងប្រព្រឹត្តទៅមិនបាន ។

ការវៀរឱ្យឆ្ងាយអំពីបុគ្គលអ្នកអប្បឥតបញ្ញា គឺ អ្នកមិនមានបញ្ញាឈានចុះក្នុងធម៌ប្រភេទមានខន្ធជាដើម ឈ្មោះថាការវៀរបុគ្គលអ្នកអប្បឥតបញ្ញា ។ ការគប់រកបុគ្គលអ្នកប្រកបដោយបញ្ញាជាគ្រឿងពិចារណាឃើញការកើត និង ការរលត់ដែលកំណត់លក្ខណៈ ( ការកើតការរលត់ ) ៥០ យ៉ាង ឈ្មោះថា ការគប់រកបុគ្គលអ្នកមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញាដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅហើយក្នុងខន្ធទាំងទឡ្យាយដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណាដល់ការប្រព្រឹត្តិទៅនៃញាណដ៏ជ្រាលជ្រៅ ។ ការដែលចិត្តនោះបង្អោនទៅដើម្បីឱ្យធម្មវិចយសម្ពោជ្ឈង្គៈតាំងទេឡើងក្នុងឥរិយាបថអង្គុយ និង ឥរិយាបថដេកជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គៈនោះ ។ លោកដឹងច្បាស់

ថា ក៏ធម្មវិចយសម្ពោជ្ឈង្គៈនោះ ដែលកើតទេឡើងហើយយ៉ាងនេះ នឹងមានការឱ្យភាវនាបរិបូណ៌ដោយអរហត្តមគ្គ ។

## ការកើតទេឡើងនៃវីរិយសម្ពោជ្ឈង្គ

វីរិយសម្ពោជ្ឈង្គៈ មានការកើតទេឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងទឡាយ **អារព្ភធាតុ និក្កមធាតុ បរក្កមធាតុ** មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ ប្រពៃ និងការធ្វើឱ្យច្រើនក្នុងអារព្ភធាតុជាដើមនោះ នេះជាអាហារ ( បច្ច័យ ) នឹងប្រព្រឹត្តទៅឱ្យវីរិយសម្ពោជ្ឈង្គៈដែលមិនទាន់កើត ឱ្យកើតទេឡើងផង ដើម្បីភិយ្យោភាពដើម្បីភាពបរិបូណ៌ ដើម្បីសេចក្តីចម្រើន ដើម្បីការបរិបូណ៌នៃវីរិយ_សម្ពោជ្ឈង្គៈ ដែលកើតទេឡើងហើយផង ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺការពិចារណាឃើញភ័យក្នុងអបាយ ១ ការឃើញអានិសង្ស ១ ការពិចារណាឃើញផ្លូវដំណើរទៅ ១ ការគោរពកោត_ក្រែងចំពោះបិណ្ឌបាត ១ ការពិចារណាឃើញភាពជាធំដោយភាវៈជាទាយាទ ១ ការពិចារណាឃើញភាពជាធំរបស់ព្រះសាស្តា ១ ការពិចារណាឃើញភាពជាធំដោយជាតិ ១ ការពិចារណាឃើញភាពជាធំដោយជាមិត្តសព្រហ្មចារី ១ ការវៀរចាកបុគ្គលអ្នកខ្ជិលច្រអូស ១ ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម ១ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីកើតនៃវីរិយសម្ពោជ្ឈង្គៈ ។

ក្នុងធម៌ ១១ ប្រការនោះ គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ÷

យើងមិនអាចដើម្បីឱ្យ វីរិយសម្ពោជ្ឈង្គៈ កើតទេឡើងក្នុងវេលាសោយទុក្ខយ៉ាងខ្លាំង ចាប់ផ្តើមតាំងតែពីកម្មករណ៍ដោយគ្រឿងចង ៥ ប្រការ ក្នុងនរកទាំង_ទឡាយក្តី ក្នុងវេលាត្រូវចាប់ដោយគ្រឿងចាប់សត្វទឹក មានការបង់សំណាញ់ និង

ដាក់ទ្រូជាដើម និង ក្នុងវេលាដែលអូសរទេះជាដើមទៅនៃសត្វអ្នកត្រូវបញ្ជា ដោយការចាក់ដោយជន្លួញ និង វាយដោយខ្សែតីជាដើម ក្នុងកំណើតតិរច្ឆានក្តី ក្នុងវេលាសោយទុក្ខដោយការស្រេកឃ្លានអស់វេលាច្រើនពាន់ឆ្នាំខ្លះ មួយពុទ្ធន្តរ ខ្លះ ក្នុងវិស័យនៃប្រេតក្តី ក្នុងវេលាសោយទុក្ខមានខ្យល់ និង កំដៅជាដើម ដោយអត្តភាពដែលមានត្រឹមតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ( ខ្ពស់ ) ប្រមាណ ៦០ ហត្ថ និង ៨០ ហត្ថក្នុងពួកអសុរឈ្មោះ **កាទឡកញ្ជិក** ក្តី ម្នាលភិក្ខុទាំងទឡាយ វេលានេះនោះឯង ជាវេលាដែលអ្នកនឹងបំពេញសេចក្តីព្យាយាម [១] ស្សម្បីកាល អ្នកពិចារណាឃើញភ័យក្នុងអបាយដូចពណ៌នាមកនេះ វីរិយសម្ពោជ្ឈង្គក៏នឹង កើតទេឡឹង ។ វីរិយសម្ពោជ្ឈង្គក៏នឹងកើតទេឡឹង សូម្បីដល់អ្នកឃើញអានិសង្ស ( នៃសេចក្តីព្យាយាម ) យ៉ាងនេះថា អ្នកខ្ជិលច្រអូសមិនអាចនឹងបាន **នវ-លោកុត្តរធម៌** អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះទើបអាចបាន នេះជាអានិ-សង្សនៃវីរិយៈ ។

វីរិយសម្ពោជ្ឈង្គ នឹងកើតទេឡឹង សូម្បីដល់អ្នកពិចារណាឃើញដំណើរផ្លូវ យ៉ាងនេះថា អ្នកគប្បីដើរផ្លូវដែលព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និង មហាសាវ័កនៃព្រះពុទ្ធជាម្ចាស់ទាំងអស់ ស្តេចបានធ្វើដំណើរទៅ និង ដើរទៅ ហើយ ហើយផ្លូវនោះអ្នកខ្ជិលច្រអូសមិនអាច មិនអាចនឹងធ្វើដំណើរទៅបាន ។

វីរិយសម្ពោជ្ឈង្គរះមែងកើតទេឡឹង សូម្បីដល់ភិក្ខុអ្នកមានការគោរពកោត-ក្រែងចំពោះបិណ្ឌបាត ដូចដែលកើតទេឡឹងដល់ **ព្រះមហាមិត្តត្ថេរ** យ៉ាងនេះថា ពួកជនអ្នកទំនុកបម្រុងអញ្ញដោយបច្ច័យ មានបិណ្ឌបាតជាដើម ទាំងនេះមិន

---

[១] បាឋៈថា **កាលោតិ ឯវំ** ច្បាប់ភូមាជា **កាលោ វីរិយការណាយាតិ ឯវំ** ប្រែតាមច្បាប់ភូមា ។

មែនញាតិរបស់អញទេឡើយ មិនមែនទាសកម្មកររបស់អញ ទាំងគេមិនបានឱ្យបិណ្ឌបាតជាដើមដ៏ប្រណីតដល់អញដោយគិតថា ពួកយើងនឹងតាំងនៅបានព្រោះអាស្រ័យអាត្មាអញ ការពិតគឺគេសង្ឃឹមថា សក្ការៈរបស់ខ្លួននឹងមានផលច្រើន ទើបនាំគ្នាថ្វាយ សូម្បីព្រះសាស្តាក៏មិនបានទ្រង់ឃើញយ៉ាងនេះថា ភិក្ខុ នេះបរិភោគបច្ច័យទាំងនេះហើយ នឹងជាអ្នកមានកាយមាំមួននៅយ៉ាងសប្បាយ ទ្រង់បានអនុញ្ញាតទុកដល់អ្នក ដោយពិតទ្រង់បានអនុញ្ញាតបច្ច័យទាំងនោះព្រោះទ្រង់បំណងថា ភិក្ខុនេះកាលបរិភោគបច្ច័យទាំងនេះ នឹងបំពេញសមណធម៌ ហើយរួចផុតចាកទុក្ខ ឥឡូវនេះ អ្នកខ្ជិលច្រអូស នឹងមិនកោតក្រែងចំពោះបិណ្ឌបាតនោះ ព្រោះដែលឈ្មោះថា ការកោតក្រែងចំពោះបិណ្ឌបាតនឹងមានដល់ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម ប៉ុណ្ណោះ ។

## រឿងព្រះមហាមិត្តត្ថេរ

បានជ្រាបថា ព្រះថេរៈ អាស្រ័យនៅក្នុងទីមួយឈ្មោះថា កស្សកលេណៈ ហើយ មហាឧបាសិកាម្នាក់នៅក្នុងគោចរគ្រាមរបស់ព្រះថេរៈនោះ បានបដិបត្តិព្រះថេរៈដូចកូនប្រុស ។ ថ្ងៃមួយ មុនពេលចូលព្រៃ គាត់បានប្រាប់កូនស្រីថា មេនាង អង្ករនៅទីនោះ ទឹកដោះនៅទីនោះ ទឹកដោះថ្លានៅទីនោះ ទឹកអំពៅនៅទីនោះ ក្នុងវេលាដែលលោកម្ចាស់បងប្រុសរបស់កូនឯងមក កូនចូរដាំបាយថ្វាយព្រមនឹងទឹកដោះ ទឹកដោះថ្លា និង ទឹកអំពៅ កូនឯងក៏ស៊ីដែរទៅ ចំណែកម៉ែស៊ីបាយកកនឹងទឹកជ្រក់បានហើយ ។

កូនស្រីសួរថា ពេលថ្ងៃម៉ែនឹងពិសាអ្វីទៅម៉ែ ? ម៉ែប្រាប់ថា កូនចូរយកអង្ករខ្ទេច ( កញ្ចុងអង្ករ ) ដាំឱ្យជាបបរជ្លូរដាក់ជ្រក់ទៅ តាំងទុកចុះកូន ។ ព្រះ-

ថេរៈដណ្តប់ចីវរហើយ នាំបាត្រចេញ បានឮសំទេឡុងនោះហើយពោលទូន្មានខ្លួនថា បានឮថា មហាឧបាសិកាបរិភោគបាយកកនឹងទឹកជ្រក់ សូម្បីពេលថ្ងៃនឹងត្រូវបរិភោគបបរជាមួយទឹកជ្រក់ទៀត ។ តែប្រាប់ ( ឱ្យដាំបាយ ) ដោយអង្ករស្រូវចាស់ជាដើម ដើម្បីប្រយោជន៍ដល់អាត្មាអញ្ញ ឯនាងមិនបានប្រាថ្នាស្រែចំការភត្ត សំពត់ អំពីអត្តាអញ្ញទេ តែប្រាថ្នាសម្បត្តិ ៣ ទើបថ្វាយ អាត្មាអញ្ញនឹងអាចឱ្យសម្បត្តិទាំងនោះដល់នាង ឬថា នឹងមិនអាចទេ ឯបិណ្ឌបាតនេះដែលអត្តា-អញ្ញនៅមានរាគៈ ទោសៈ និង មោហៈ មិនអាចនឹងទទួលបាន ទើបយកបាត្រប្រកចូលថង់បិទទុក ហើយត្រឡប់ទៅកាន់កស្សកលេណៈវិញ យកបាត្រទុកក្រោមគ្រែ ពាក់ចីវរទុកលើស្នូចីវរ គិតថា អាត្មាអញ្ញមិនទាន់សម្រេចព្រះ-អរហត្តផលដរាបណា នឹងមិនចេញទៅដរាបនោះ អង្គុយព្យាយាម ហើយលោកមិនប្រមាទ ជាភិក្ខុរក្សាខ្លួននៅមិនប្រមាទរហូតអស់កាលយូរ ចម្រើនវិបស្សនាសម្រេចអរហត្តមុនឆាន់នោះឯង ជាព្រះមហាខីណាស្រព ញញឹមញញែមចេញមកដូចជាផ្កាបទុមដែលរីកស្រស់ដូច្នោះ ទេវតាដែលស្ថិតនៅហ្នឹងដើមឈើជិតទ្វារគុហា ( ឃើញលោកហើយ ) បន្លឺឧទានយ៉ាងនេះថា ÷

**បពិត្របុរសអាជានេយ្យ ខ្ញុំម្ចាស់សូមនមស្ការក្រាបថ្វាយ**
**បង្គំដល់លោក បពិត្រលោកដ៏ប្រសើរ ខ្ញុំម្ចាស់សូមថ្វាយ**
**បង្គំចំពោះលោក បពិត្រលោកអ្នកនិរទុក្ខ លោកលះអាសវៈ**
**បានហើយ ទើបជាអ្នកសមគួរទទួលទក្ខិណា ។**

ដូច្នេះហើយ ពោលថា លោកម្ចាស់ពួកស្ត្រីចាស់ថ្វាយភិក្ខាដល់ព្រះ-អរហន្តដូចលោកដែលចូលទៅទទួលបិណ្ឌបាតហើយ នឹងរួចផុតទុក្ខបាន ។

ព្រះថេរៈក្រោកទេឡើងបើកទ្វារមើលវេលា ជ្រាបថានៅព្រឹកនៅទេឡើយ ទើប

និបបាត្រ ឃ្លុំចីវរចូលទៅកាន់ស្រុក ។ ចំណែកកូនស្រីត្រៀមភត្តហើយ ( ក៏ចេញមក ) អង្គុយចាំមើលផ្លូវត្រង់ទ្វារ ដោយសង្ឃឹមថា លោកបងរបស់យើងនឹងមកឥឡូវនេះ នឹងមកឥឡូវនេះ ។ កាលព្រះថេរៈមកដល់ទ្វារផ្ទះ នាងក៏ទទួលបាត្រទៅដាក់ពំនូតបាយដែលផ្សំដោយទឹកដោះ ផ្សំដោយទឹកដោះថ្លា និងទឹកអំពៅរហូតពេញហើយ នាំយកទៅប្រគេនដល់ដៃ ។ ព្រះថេរៈធ្វើការអនុមោនាថា ចូរមានសេចក្តីសុខចុះ ដូច្នេះ ហើយគេចចេញទៅ ។ ចំណែកកូនស្រីនោះក៏បានឈរមើលលោកភ្លេចខ្លួន ។ ព្រោះវេលានោះ ឆវីវណ្ណរបស់ព្រះថេរៈផូរផង់ក្រៃលែងណាស់ ឥន្ទ្រិយ៍ទាំងឡាយក៏ស្រស់ថ្លា ដួងភ្នែកក៏ស្រស់បស់ត្រចះត្រចង់យ៉ាងក្រៃលែង ដូចផ្លែត្នោតទុំដែលជ្រុះចាកទង ដូច្នោះ ។

មហាឧបាសិកាត្រឡប់អំពីព្រៃ សួរថា មេនាងលោកបងរបស់កូនមកហើយឬ ?

នាងបានតំណាលរឿងរ៉ាវទាំងអស់ឱ្យស្តាប់ ។ ឧបាសិកាជ្រាបថា ថ្ងៃ នេះកិច្ចបព្វជិតនៃកូនប្រុសរបស់យើង ដល់ទីបំផុតហើយ ទើបនិយាយថា កូន អើយបងប្រុសរបស់ឯងនៅអភិរម្យមិនឿយណាយក្នុងព្រះពុទ្ធសាសនាទេ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើតទៀងដល់ភិក្ខុអ្នកពិចារណាឃើញភាពក្រៃលែងនៃមតិក ក៏ឯមតិករបស់ព្រះសាស្តា គឺ អរិយទ្រព្យ ៧ ជារបស់ធំក្រៃលែង អ្នកខ្ជិលច្រអូសមិនអាចទទួលមតិកនោះទុកបាន ដូចយ៉ាងថា មាតាបិតារមែងកម្ចាត់បង់បុត្រដែលខិលខូចឱ្យចេញចាកគំនរមតិក ដោយសម្គាល់ថា អានេះមិនមែនកូនរបស់អញ ( តទៅទៀត ) ព្រោះបច្ច័យ ( គឺ ការកាត់ផ្តាច់ ) របស់ឪពុកម្តាយនោះ បុត្រដែលខូចខិលនោះរមែងមិនបានទទួលមតិកយ៉ាងណា សូម្បីភិក្ខុអ្នកខ្ជិលច្រអូសក៏ដូច្នោះ នឹងមិនបានទទួលមតិក គឺ អរិយទ្រព្យនេះ

ភិក្ខុអ្នកប្រារព្ធនូវសេចក្ដីព្យាយាមប៉ុណ្ណោះទើបនឹងទទួលបាន ។

វីរិយសម្ពោជ្ឈង្គៈរមែងកើតទេឡើងដល់ភិក្ខុ អ្នកសូម្បីពិចារណាដល់ភាពអស្ចារ្យរបស់ព្រះសាស្ដាយ៉ាងនេះថា ព្រះសាស្ដាជាម្ចាស់អស្ចារ្យណាស់ ព្រោះ ថា ក្នុងវេលាដែលព្រះសាស្ដា ទ្រង់ចុះចាប់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតាក្ដី ក្នុងពេលស្ដេចចេញសាងមហាអភិនេស្រ្កមណ៍ក្ដី ក្នុងពេលត្រាស់ដឹងអនុត្តរសម្ពោធិ-ញាណក្ដី ក្នុងពេលសម្ដែងព្រះធម្មចក្កក្ដី ក្នុងពេលទ្រង់សម្ដែងយមកប្បាដិហារ្យ ក្ដី ស្ដេចចុះអំពីទេវលោក និងដាក់ព្រះជន្មាយុសង្ខារក្ដី ម៉ឺនលោកធាតុក៏កម្រើកញាប់ញ័រ គួរហើយឬដែលឯងបួសក្នុងសាសនា នៃព្រះសាស្ដាបែបនេះហើយនឹងមកខ្ជិលច្រអូស ។

វីរិយសម្ពោជ្ឈង្គរមែងកើតទេឡើងដល់ភិក្ខុអ្នកសូម្បីពិចារណាដល់ភាពក្រៃលែងនៃជាតិ ( កំណើត ) យ៉ាងនេះថា សូម្បីលោកពោលដោយកំណើតឥទឡូវនេះឯងក៏មិនមែនមនុស្សដែលមានកំណើតថោកទាប ឯងមកអំពីត្រកូលនៃព្រះបាទមហាសម្មត្តៈ មិនលាយទឡំ ( នឹងមនុស្សវណ្ណៈដទៃ ) ទាំងបានកើតក្នុងព្រះរាជវង្សនៃព្រះបាទឱក្កាករាជ បានជាព្រះនត្តានៃព្រះបាទសុទ្ធោទនមហា រាជ និង ព្រះនាងមហាមាយាទេវី ( និង ) ជាព្រះកនិដ្ឋភាតារបស់ព្រះម្ចាស់បងរាហុលដែលធម្មតាថា ឯងបានជាជិនបុត្របែបនេះ នឹងរវល់តែខ្ជិលច្រអូសមិនសមគួរទេឡើយ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើតទេឡើងដល់ភិក្ខុអ្នកសូម្បីពិចារណាដល់ភាពក្រៃលែងនៃមិត្តសព្រហ្មចារីយ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លាន និង ព្រះ-អសីតិមហាសាវ័ក ចាក់ធ្លុះលោកុត្តរធម៌ដោយសេចក្ដីព្យាយាមដោយពិត ឯងនឹងធ្វើដំណើរទៅតាមផ្លូវនៃមិត្តសព្រហ្មចារីទាំងនោះ ឬ នឹងមិនធ្វើដំណើរទៅ

តាម ។

វិរិយសម្ពោជ្ឈង្គៈ រមែងកើតទេឡើងដល់ភិក្ខុ អ្នករៀរចាកបុគ្គលដែលខ្ជិលច្រអូស រលាស់ចោលសេចក្តីព្យាយាមផ្លូវកាយ និង ផ្លូវចិត្ត ប្រៀបដូចពស់វែកហេលហាល ដោយហេតុតឹងពោះ ព្រោះបរិភោគអាហារច្រើនហួសកំណត់ ដល់ភិក្ខុអ្នកគប់រកបុគ្គលដែលមានខ្លួនតាំងមាំ ប្រារព្ធសេចក្តីព្យាយាម ទាំងដល់ភិក្ខុអ្នកមានចិត្តបង្អោនទៅ ដើម្បីឱ្យកើតសេចក្តីព្យាយាមក្នុងឥរិយាបថទាំង-ទឡាយ មានឥរិយាបថឈរ និង អង្គុយជាដើម ។

កាលវិរិយសម្ពោជ្ឈង្គៈនោះកើតទេឡើងហើយយ៉ាងនេះ ភិក្ខុរមែងជ្រាបច្បាស់ថា ការចម្រើនពេញលេញ ( នៃវិរិយសម្ពោជ្ឈង្គ ) មានបានដោយព្រះ-អរហត្តមគ្គ ។

## ការកើតទេឡើងនៃបីតិសម្ពោជ្ឈង្គ

បីតិសម្ពោជ្ឈង្គៈរមែងកើតទេឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងទឡាយ ធម៌ទាំងទឡាយដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ មានការធ្វើទុកក្នុងចិត្តដោយប្រពៃ និង ការធ្វើឱ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ដើម្បីឱ្យបីតិ-សម្ពោជ្ឈង្គៈដែលនៅមិនទាន់កើត ឱ្យកើតទេឡើង ឬ ប្រព្រឹត្តទៅដើម្បីឱ្យបីតិ-សម្ពោជ្ឈង្គៈដែលកើតទេឡើងហើយ ឱ្យជាភិយ្យោភាព ។

ក្នុងព្រះពុទ្ធវចនៈនោះ បីតិនុ៎ះឯង ឈ្មោះថា ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គៈ ការធ្វើទុកក្នុងចិត្តដែលឱ្យបីតិសម្ពោជ្ឈង្គៈនោះកើតទេឡើង ឈ្មោះថា ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺ **ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១**

**ឧបសមនុស្សតិ ១ ការចៀសវាងបុគ្គលដែលមានទោស ១ ការសេពគប់រកបុគ្គលដែលមានគុណ ១ ការពិចារណាដល់ព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គ នោះ ១ ។** រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃបីតិសម្ពោជ្ឈង្គៈ ។

អធិប្បាយថា ចំពោះភិក្ខុជាអ្នកព្យាយាមរឭកដល់ព្រះពុទ្ធគុណបីតិសម្ពោជ្ឈង្គៈរមែងកើតទេឡើងផ្សាយទៅសព្វសព៌ាង្គកាយ រហូតដល់ឧបចារសមាធិ ។ ចំពោះភិក្ខុដែលព្យាយាមរឭកដល់ព្រះធម្មគុណ ព្រះសង្ឃគុណក្ដី **អ្នកពិចារណាដល់ចតុប្បារិសុទ្ធិសីលដែលរក្សាទុកមិនដាច់ រហូតអស់កាលយូរក្ដី បីតិសម្ពោជ្ឈង្គ** ក៏រមែងកើតទេឡើងបាន ។

សូម្បីចំពោះគ្រហស្ថ អ្នកពិចារណាដល់សីល ១០ សីល ៥ ក្ដី អ្នកថ្វាយភោជនដ៏ប្រណីតដល់លោកអ្នកជាសព្រហ្មចារី ក្នុងគ្រាកើតទុព្ភិក្ខភ័យជា ដើមហើយពិចារណាដល់ការបរិច្ចាគ ( របស់ខ្លួន ) ថា យើងបានថ្វាយយ៉ាង នេះក្ដី បីតិសម្ពោជ្ឈង្គៈនឹងកើតទេឡើងបាន ។

ម្យ៉ាងទៀត ចំពោះគ្រហស្ថអ្នកពិចារណាដល់ទានដែលថ្វាយដល់លោកអ្នកមានសីលក្នុងកាលដូច្នេះក្ដី បានពិចារណាឃើញថា ទេវតាប្រកបដោយគុណទាំងទឡាយណា ទើបដល់ភាពជាទេវតា គុណទាំងនោះមាននៅក្នុងខ្លួនក្ដី បីតិសម្ពោជ្ឈង្គៈក៏កើតទេឡើងបាន ។

ចំពោះភិក្ខុ អ្នកពិចារណាឃើញកិលេស ដែលគ្របសង្កត់បានហើយ ដោយសមាបត្តិថា ( កិលេសទាំងនេះ ) មិនកើតទេឡើងអស់វេលា ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះក្ដី អ្នកចៀសវាងបុគ្គលសៅហ្មងដែលប្រាកដច្បាស់ដោយការមិនធ្វើសេចក្ដីគោរពក្នុងកាលបានឃើញព្រះចេតីយ៍ ឃើញដើមពោធិព្រឹក្ស និង ឃើញ

ព្រះថេរៈអ្នកឈ្មោះថា ដូចជាលំអងធូលី ( ដែលជាប់ ) លើដំបូល ព្រោះមិនមានសេចក្ដីជ្រះថ្លា និង សេចក្ដីស្រឡាញ់ក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជា–ម្ចាស់ជាដើមក្ដី ដែលសេពគប់អ្នកបរិសុទ្ធមានចិត្តទន់ភ្លន់ ច្រើនដោយសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើមក្ដី អ្នកពិចារណាដល់ព្រះ សូត្រដែលជាហេតុឱ្យកើតសេចក្ដីជ្រះថ្លា សម្ដែងគុណរបស់ព្រះរតនត្រៃក្ដី អ្នកមានចិត្តបង្អោនទៅដើម្បីឱ្យកើតបីតិ ក្នុងឥរិយាបថឈរ និង អង្គុយជាដើមក្ដី បីតិសម្ពោជ្ឈង្គៈ រមែងកើតទេឡើងបាន ។

ក៏កាលបីតិសម្ពោជ្ឈង្គៈនោះ កើតទេឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹងច្បាស់ថា ការចម្រើនដោយបរិបូណ៌ ( នៃបីតិសម្ពោជ្ឈង្គៈ ) បានដោយអរ–ហត្តមគ្គ ។

## ការកើតទេឡើងរបស់បស្សទ្ធិសម្ពោជ្ឈង្គ

បស្សទ្ធិសម្ពោជ្ឈង្គៈរមែងកើតទេឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ **កាយបស្សទ្ធិ ចិត្តបស្សទ្ធិ** មាន ការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង ការធ្វើឱ្យច្រើនក្នុងកាយបស្សទ្ធិនោះ នេះជាអាហារ ( បច្ច័យ ) ឱ្យបស្សទ្ធិ–សម្ពោជ្ឈង្គៈដែលមិនទាន់កើត ឱ្យកើតទេឡើង ឬ រមែងប្រព្រឹត្តទៅដើម្បីឱ្យបស្សទ្ធិ–សម្ពោជ្ឈង្គៈដែលកើតទេឡើងហើយ បរិបូណ៌ជាភិយ្យោភាព ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ គឺ **ការបរិភោគភោជនដ៏ប្រណីត ១ ការសេពសុខតាមរដូវ ១ ការសេពសុខតាមឥរិយាបថ ១ ភាពជាអ្នកមានមជ្ឈត្តប្បយោគ ១ ការចៀសវាងបុគ្គលអ្នកមានកាយរសាប់រសល់ ១ ការគប់រកបុគ្គលអ្នកមានកាយស្ងប់ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ១** រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃបស្សទ្ធិ–

សម្ពោជ្ឈង្គៈ ។

អធិប្បាយថា ចំពោះភិក្ខុដែលបរិភោគភោជន ដែលជាទីសប្បាយមានរសជាតិឆ្ងាញ់ប្រណីតក្តី អ្នកសេពរដូវជាទីសប្បាយក្នុងបណ្តារដូវត្រជាក់ និង រដូវក្តៅ និង ឥរិយាបថជាទីសប្បាយក្នុងបណ្តាឥរិយាបថឈរជាដើមក្តី បស្សទ្ធិរមែងកើតទេឡើង ។

ចំណែកភិក្ខុណាមានលក្ខណនិស្ស័យជាមហាបុរស រមែងអត់ធន់ចំពោះ រដូវ និង ឥរិយាបថទាំងពួងបានយ៉ាងក្រៃលែង ពាក្យនេះលោកមិនបានពោលសំដៅយកភិក្ខុនោះទេ ។

ចំពោះភិក្ខុណា មានរដូវ និង ឥរិយាបថដែលជាសភាគៈ ( ដែលជាទីសប្បាយ ) និង វិសភាគៈ ( អសប្បាយ ) បស្សទ្ធិរមែងកើតទេឡើងដល់ភិក្ខុនោះឯង សូម្បីលោកវៀររដូវ និង ឥរិយាបថដែលជាវិសភាគៈចេញហើយសេពរដូវ និង ឥរិយាបថដែលជាសភាគៈ ។

ការពិចារណាឃើញថាខ្លួន និង អ្នកដទៃមានកម្មជារបស់ខ្លួន លោកហៅថា មជ្ឈត្តប្បយោគ បស្សទ្ធិរមែងកើតទេឡើងបាន ព្រោះមជ្ឈត្តប្បយោគនេះ ។

ភិក្ខុត្រូវចៀសវាងបុគ្គលអ្នកមានកាយរសាប់រសល់ អ្នកដើរបៀតបៀនបុគ្គលដទៃគ្រប់វេលាដោយដុំដី និង កំណាត់ឈើជាដើម ត្រូវគប់រកបុគ្គលអ្នកមានកាយស្ងប់ អ្នកសង្រួមដៃ និង ជើងក្តី អ្នកមានចិត្តបង្អោនទៅដើម្បីឱ្យកើតបស្សទ្ធិក្នុងឥរិយាបថទាំងទឡាយ មានឈរ និង អង្គុយជាដើមក្តី បស្សទ្ធិរមែងកើតទេឡើងបាន ។

កាលបស្សទ្ធិសម្ពោជ្ឈង្គៈកើតទេឡើងហើយយ៉ាងនោះ ភិក្ខុរមែងដឹងច្បាស់ថា ការបរិបូណ៌ ( នៃបស្សទ្ធិសម្ពោជ្ឈង្គៈ ) រមែងមានដោយអរហត្តមគ្គ ។

## ការកើតទេឡើងនៃសមាធិសម្ពោជ្ឈង្គ

សមាធិសម្ពោជ្ឈង្គៈរមែងកើតទេឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងទឡាយ សមថនិមិត្ត ដែលជាអព្យគ្គនិមិត្ត មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ និង ការធ្វើឱ្យច្រើនក្នុងសមថនិមិត្តនោះ នេះជាអាហារ ( បច្ច័យ ) ឱ្យសមាធិសម្ពោជ្ឈង្គៈដែលមិនទាន់កើត កើតទេឡើង ឬ រមែងប្រព្រឹត្តទៅដើម្បីឱ្យសមាធិសម្ពោជ្ឈៈដែលកើតទេឡើងហើយចម្រើនបរិបូណ៌ ក្នុងសមាធិសម្ពោជ្ឈង្គៈនោះសមថនិមិត្តជាសមថៈផង ឈ្មោះថា ជាអព្យគ្គនិមិត្ត ព្រោះអត្ថថាមិនរាយមាយផង ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ គឺ ការធ្វើវត្ថុឱ្យស្អាតបរិសុទ្ធ ១ ការធ្វើឥន្ទ្រីយ៍ឱ្យស្មើគ្នា ១ ភាពជាអ្នកឈ្លាសវៃក្នុងនិមិត្ត ១ ការលើកចិត្តទេឡើងក្នុងសម័យ ( ដែលគួរលើក ) ១ ការសង្កត់ចិត្តក្នុងសម័យ ( ដែលគួរសង្កត់ ) ១ ការធ្វើចិត្តឱ្យរីករាយក្នុងសម័យ ( ដែលគួរធ្វើឱ្យរីករាយ ) ១ ការសម្លឹងមើលចិត្តព្រងើយៗក្នុងសម័យ ( ដែលគួរសម្លឹងមើល ) ១ ការចៀសវាងបុគ្គលអ្នកមានចិត្តមិនជាសមាធិ ១ ការគប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ១ ការពិចារណាឈាន និង វិមោក្ខ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃសមាធិសម្ពោជ្ឈង្គៈ ។

បណ្តាធម៌ ១១ ប្រការនោះ ការធ្វើវត្ថុឱ្យស្អាតបរិសុទ្ធ និង ការធ្វើឥន្ទ្រីយ៍ឱ្យប្រព្រឹត្តទៅស្មើគ្នា គប្បីជ្រាបតាមន័យដែលបានពោលហើយនោះចុះ ។

ភាពជាអ្នកឈ្លាសវៃក្នុងការរៀនកសិណនិមិត្ត ឈ្មោះថា ភាពជាអ្នកឈ្លាសវៃក្នុងនិមិត្ត ។

បទថា **សមយេ ចិត្តស្ស បគ្គណ្ហនតា** ( ការផ្គងចិត្តក្នុងសម័យដែលគួរផ្គង ) មានអធិប្បាយថា ក្នុងសម័យណា ចិត្តជាធម្មជាតិរួញរា ដោយ

ហេតុទាំងទឡាយ មានសេចក្តីព្យាយាមតិចតួចហួសប្រមាណជាដើម ការលើកចិត្តនោះ ក្នុងសម័យនោះ ដោយការញ៉ាំងធម្មវិចយសម្ពោជ្ឈង្គៈ វីរិយសម្ពោជ្ឈង្គៈ និង បីតិសម្ពោជ្ឈង្គៈឱ្យកើតទេឡើងព្រមគ្នា ។

បទថា **សមយេ ចិត្តស្ស និគ្គណ្ហនតា** ( ការសង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ) សេចក្តីថា ក្នុងសម័យណាចិត្តជាធម្មជាតិរាយមាយដោយហេតុទាំងទឡាយ មាន ការប្រារព្ធសេចក្តីព្យាយាមខ្លាំងហួសប្រមាណជាដើម ការសង្កត់ចិត្តនោះក្នុងសម័យនោះ ដោយការញ៉ាំងបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និង ឧបេក្ខាសម្ពោជ្ឈង្គៈឱ្យកើតទេឡើងព្រមគ្នា ។

បទថា **សមយេ សម្បហំសនតា** ( ការផ្គងចិត្តឱ្យរីករាយក្នុងសម័យដែលគួរផ្គងចិត្តឱ្យរីករាយ ) សេចក្តីថា ក្នុងសម័យណាចិត្តជាធម្មជាតិមិនស្រស់ ថ្លា ព្រោះមានបញ្ញា និងការព្យាយាមតិច ឬព្រោះមិនបានសម្រេចដល់សេចក្តីសុខដែលកើតពីការចូលទៅស្ងប់ក្នុងសម័យនោះ ព្រះយោគាវចរគប្បីញ៉ាំងចិត្តឱ្យសង្វេគដោយការពិចារណាសង្វេគវត្ថុ ( ទីតាំងនៃសេចក្តីសង្វេគ ) ៨ យ៉ាង ដែលឈ្មោះថា សង្វេគវត្ថុ ៨ យ៉ាងនោះ បានដល់ ជាតិ ជរា ព្យាធិ និង មរណៈ រួមជា ៤ ទុក្ខក្នុងអបាយជាទី ៥ ទុក្ខដែលមានវដ្តៈជាមូលក្នុងអតីត ១ ទុក្ខដែលមានវដ្តៈជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ និងឱ្យកើតសេចក្តីជ្រះថ្លា ដោយការព្យាយាមរឭកដល់គុណរបស់ព្រះរតនត្រៃ ។ នេះហៅថា ការផ្គងចិត្តឱ្យរីករាយក្នុងសម័យ ( ដែលគួរផ្គងចិត្តរីករាយ ) ។

ដែលឈ្មោះថា ការសម្លឹងមើលចិត្តព្រងើយ ៗ ក្នុងសម័យដែល ( គួរសម្លឹងមើលចិត្តយ៉ាងព្រងើយ ៗ ) បានដល់ ក្នុងសម័យណា ចិត្តជាធម្មជាតិមិន

រួញរា មិនរាយមាយ មានភាពរីករាយប្រព្រឹត្តទៅក្នុងអារម្មណ៍យ៉ាងស្មើប្រពៃ ដំណើរទៅតាមវិថីនៃសមថៈ ព្រោះអាស្រ័យការបដិបត្តិដ៏ប្រពៃ ក្នុងការលើកចិត្ត ការសង្កត់ចិត្ត និង ការផ្គងចិត្តនោះឱ្យរីករាយ ប្រៀបដូចនាយសារថីមិនចាំបាច់ខ្វល់ខ្វាយនឹងសេះដែលរត់ទៅស្មើត្រង់ នេះហៅថា ការសម្លឹងមើលចិត្តព្រងើយក្នុងសម័យ ( ដែលគួរសម្លឹងមើលព្រងើយ ៗ ) ។

ដែលឈ្មោះថា ការចៀសវាងបុគ្គលមានចិត្តមិនសមាធិ បានដល់ ការចៀសវាងឱ្យឆ្ងាយនូវបុគ្គលអ្នកមិនបានសម្រេចឧបចារសមាធិ ឬ អប្បនាសមាធិ អ្នកមានចិត្តរាយមាយ ។

ដែលឈ្មោះថា ការគប់រកបុគ្គលអ្នកមានចិត្តជាសមាធិ បានដល់ ការសេពគប់ ការគប់រក ការចូលទៅអង្គុយជិតបុគ្គលអ្នកមានចិត្តតាំងមាំដោយឧចារសមាធិ ឬ អប្បនាសមាធិ ។

ដែលឈ្មោះថា ភាពជាអ្នកបង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គៈនោះ បានដល់ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងឥរិយាបថទាំងទឡាយ មានឈរ និង អង្គុយជាដើម ។

ក៏កាលព្រះយោគាវចរបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គៈនោះរមែងកើតទឡើង ។ ក៏កាលសមាធិសម្ពោជ្ឈង្គៈនោះកើតទឡើងយ៉ាងនោះ ព្រះយោគាវចររមែងជ្រាបច្បាស់ថា ការចម្រើនដ៏បរិបូណ៌ ( នៃសមាធិសម្ពោជ្ឈង្គៈ ) បានដោយអរហត្តមគ្គ ។

## ការកើតទឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ

ឧបេក្ខាសម្ពោជ្ឈង្គៈ រមែងកើតទឡើងយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងទឡាយ ធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ មានការធ្វើទុកក្នុងចិត្តដោយឧបាយដ៏

ប្រពៃ និង ការធ្វើឱ្យច្រើនក្នុងធម៌នោះ នេះជាអាហារ ( បច្ច័យ ) ឱ្យឧបេក្ខា-សម្ពោជ្ឈង្គៈដែលនៅមិនទាន់កើត កើតទេឡើង ឬរមែងប្រព្រឹត្តទៅដើម្បីឱ្យឧបេ-ក្ខាសម្ពោជ្ឈង្គៈដែលកើតទេឡើងហើយ ឱ្យចម្រើនបរិបូណ៌ ។ ក្នុងព្រះតម្រាស់នោះ ឧបេក្ខានោះឯង ឈ្មោះថា ធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គៈ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ គឺ ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ ១ ភាពជាអ្នកដាក់ខ្លួនជាកណ្តាលក្នុងសង្ខារ ១ ការចៀសវាងបុគ្គលអ្នកជាប់-ជំពាក់ក្នុងសត្វ និង សង្ខារ ១ ការគប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតទេឡើងនៃ ឧបេក្ខាសម្ពោជ្ឈង្គៈ ។

បណ្តាធម៌ ៥ ប្រការនោះ ព្រះយោគាវចររមែងញ៉ាំងការដាក់ខ្លួនជាកណ្តាលក្នុងសត្វឱ្យកើតទេឡើងដោយអាការ ២ យ៉ាងគឺ ដោយការពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួនយ៉ាងនេះថា ឯងមកតាមកម្មរបស់ខ្លួនហើយ ក៏នឹងទៅតាមកម្មរបស់ខ្លួន ( ដូចគ្នា ) ។

ឯងនឹងទៅជាប់ជំពាក់នឹងនរណាទៅ និង ដោយការពិចារណាឃើញថា មិនមែនសត្វ យ៉ាងនេះថា ពោលដោយបរមត្ថហើយសត្វមិនមានទេឡើយ ឯងនោះនឹងទៅជាប់ជំពាក់នឹងនរណាទៅ ។

គប្បីញ៉ាំងការដាក់ខ្លួន ជាកណ្តាលក្នុងសង្ខារ ឱ្យកើតទេឡើងដោយអាការ ២ យ៉ាងគឺ ដោយពិចារណាឃើញថា មិនមានម្ចាស់យ៉ាងនេះថា សំពត់ចីវរនេះចូលដល់ការប្រែប្រួលពណ៌ និង ការគ្រាំគ្រាទៅតាមលំដាប់ហើយក្លាយទៅជាសំពត់ជូតជើង នឹងត្រូវគេឆ្កឹះចោលដោយចុងឈើច្រត់ ក៏ប្រសិនបើចីវរនោះនឹងគប្បីមានម្ចាស់សោត ឯងក៏នឹងមិនព្រមឱ្យចីវរនោះវិនាសទៅយ៉ាងនោះ ១

ហើយដោយការពិចារណាឃើញថា ជារបស់បណ្ដោះអាសន្នយ៉ាងនេះថា ចីវរនេះមិនស្ថិតស្ថេរ នៅបានមួយរយៈពេលខ្លី ១ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីធ្វើការប្រកបសេចក្ដីសូម្បីក្នុងបាត្រជាដើមដូចយ៉ាងក្នុងចីវរ ដូច្នោះ ។

ក្នុងពាក្យថា **សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា** ( ការចៀសវាងបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និង សង្ខារ ) គប្បីជ្រាបការវិនិច្ឆ័យដូចតទៅនេះ ÷

បុគ្គលណាជាគ្រហស្ថ រមែងប្រកាន់នូវបិយជនទាំងទឡាយ មានបុត្រា និងបុត្រីជាដើមរបស់ខ្លួនថា ជារបស់យើង ។ ចំពោះបព្វជិត រមែងប្រកាន់ អន្តេវាសិកសទ្ធិវិហារិក និង អ្នករួមឧបជ្ឈាយ៍ជាដើមរបស់ខ្លួនថា ជារបស់យើងចុះដៃធ្វើការងារទាំងទឡាយ មានការកោរសក់ ដេរសំពត់ ជ្រលក់ចីវរ និង ដុតបាត្រជាដើមឱ្យដល់បុគ្គលទាំងទឡាយនោះឯង មិនឃើញត្រឹមតែមួយភ្លែតក៏ទៅតាមរកយ៉ាងវឹវក់មិនខុសអ្វីនឹងម្រឹគដែលភ្ញាក់ផ្អើល ( ស្រែកសួរថា ) សាមណេររូបនោះទៅណា ? ភិក្ខុកំលោះរូបនោះទៅណាហើយ ? សូម្បីត្រូវអ្នកដទៃសំណូមពរថា សូមលោកបញ្ជូនភិក្ខុកំលោះ ឬ សាមណេររូបនោះ ឱ្យទៅជួយកោរសក់ត្រឹមតែបន្តិចបន្តួចជាដើម ក៏មិនព្រមឱ្យទៅដោយអាងថា សូម្បីពួកយើងមិនទាន់ហ៊ានប្រើពួកគេឱ្យធ្វើការងាររបស់ខ្លួនផង ពួកលោកនឹងមកយក គេទៅ ( បម្រើការងារ ) នាំឱ្យលំបាក បុគ្គលនេះឈ្មោះថា ជាអ្នកជាប់ជំពាក់ ក្នុងសត្វ ។

ចំណែកបុគ្គលណាប្រកាន់បាត្រ ចីវរ បំពង់ម្នុល និង ឈើច្រត់ជាដើម ថាជារបស់យើងមិនព្រមឱ្យអ្នកដទៃដោយហោចទៅសូម្បីនឹងយកដៃប៉ះ លុះត្រូវ

សូមខ្ចីក៏និយាយថា ពួកយើងទាំងឡាយស្រឡាញ់របស់នេះមិនហ៊ានប្រើប្រាស់ផង ពួកយើងនឹងឱ្យពួកលោកបានដូចម្ដេច បុគ្គលនេះឈ្មោះថាអ្នកជាប់ជំពាក់ក្នុងសង្ខារ ។

ចំណែកបុគ្គលណា ជាអ្នកមានខ្លួនជាកណ្ដាល ព្រងើយកន្តើយក្នុងវត្ថុ ទាំង ២ នោះ បុគ្គលនោះឈ្មោះថា ដាក់ខ្លួនជាកណ្ដាលក្នុងសត្វ និង សង្ខារ ។

ឧបេក្ខាសម្ពោជ្ឈង្គៈនេះ រមែងកើតទេឡើងដល់ព្រះយោគាវចរដែលចៀសវាងឱ្យឆ្ងាយពីបុគ្គលអ្នកជាប់ជំពាក់ក្នុងសត្វ និង សង្ខារបែបនេះខ្លះ អ្នកគប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្ដាលក្នុងសត្វ និង សង្ខារខ្លះ អ្នកមានចិត្តបង្អោនទៅដើម្បីឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គៈនោះ ក្នុងឥរិយាបថទាំងឡាយ មានឈរ និង អង្គុយជាដើមខ្លះដូចពណ៌នាមកដូច្នេះ ។

កាលឧបេក្ខាសម្ពោជ្ឈង្គៈនោះកើតទេឡើងយ៉ាងនោះ ព្រះយោគាវចររមែងជ្រាបច្បាស់ថា ការចម្រើនបរិបូណ៌ ( នៃឧបេក្ខាសម្ពោជ្ឈង្គៈ ) មានបានដោយអរហត្តមគ្គ ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរនោះកំណត់ ពោជ្ឈង្គៈ ៧ របស់ខ្លួន ឬ របស់បុគ្គលដទៃយ៉ាងនេះហើយ គឺ កំណត់ពោជ្ឈង្គៈរបស់ខ្លួនតាមកាល ឬ ពោជ្ឈង្គៈរបស់បុគ្គលដទៃតាមកាល ជាអ្នកមានប្រក្រតីពិចារណាឃើញធម៌ក្នុងធម៌ទាំងទ្បាយយ៉ាងនេះ ។ ចំណែកការកើតទេឡើង និង ការរលត់ទៅក្នុងពោជ្ឈង្គបព្វៈនេះ គប្បីជ្រាបដោយអំណាចការកើត និង ការរលត់នៃសម្ពោជ្ឈង្គៈទាំងទ្បាយ , ពាក្យដទៃអំពីនេះ មានន័យដូចពោលហើយ ។

## អរិយសច្ចក្នុងពោជ្ឈង្គ

ដោយថា ក្នុងពោជ្ឈង្គបព្វៈនេះ សតិដែលកំណត់ពោជ្ឈង្គៈ ជាទុក្ខសច្ច

តែម្យ៉ាង អ្នកសិក្សាគប្បីជ្រាបផ្លូវនៃធមិជាគ្រឿងចេញចាករបស់ភិក្ខុអ្នកកំណត់ពោជ្ឈង្គៈ ព្រោះការប្រកបសេចក្ដីដូចពោលមកនេះឯង ។ ពាក្យដ៏សេសមានន័យ ( ដូចដែលពោលមកហើយ ) នោះ ដូចគ្នា ។

**( ចប់ ពោជ្ឈង្គបព្វៈ )**

## សច្ចបព្វ

លុះទ្រង់ចែកធម្មានុបស្សនា ដោយអំណាចពោជ្ឈង្គៈ ៧ យ៉ាងនេះ ហើយឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយអំណាចសច្ចៈ ៤ ព្រះមានព្រះភាគ ជាម្ចាស់ទើបទ្រង់ត្រាស់ពាក្យថា **បុន ចបរំ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ** សេចក្ដីថា ព្រះយោគាវចររមែងជ្រាបច្បាស់នូវធមិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរតែតណ្ហាតាមសេចក្ដីពិតថា នេះទុក្ខ ( ក៏រមែងជ្រាបច្បាស់តណ្ហាអំពីអតីតដែលជាតួហេតុឱ្យទុក្ខនោះឯងកើត គឺ តាំងទឡើងតាមសេចក្ដីពិតថា នេះទុក្ខសមុទយៈ រមែងជ្រាបច្បាស់នូវព្រះនិព្វាន គឺ ការមិនប្រព្រឹត្តទៅនៃទុក្ខ និងតណ្ហាទាំងពីរតាមសេចក្ដីពិតថា នេះទុក្ខនិរោធ រមែងជ្រាបច្បាស់នូវអរិយមគ្គដែលជាតួកំណត់ដឹងទុក្ខ លះបង់សមុទយៈ ធ្វើនិរោធឱ្យជាក់ច្បាស់តាមសេចក្ដីពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ។ កថាពោលដោយអរិយសច្ចដ៏សេសបានអធិប្បាយឱ្យពិស្ដារហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

បទថា **ឥតិ អជ្ឈត្តំ វា** សេចក្ដីថា ព្រះយោគាវចរកំណត់សច្ចៈ ៤ របស់ខ្លួន ឬ របស់អ្នកដទៃហើយ គឺ កំណត់សច្ចៈទាំង ៤ របស់ខ្លួនតាមកាល ឬ របស់អ្នកដទៃតាមកាល ជាអ្នកមានប្រក្រតីពិចារណាឃើញធមិក្នុងធមិទាំង-

ឡាយចំណែកការកើតទេឡើង និង ការរលត់ទៅក្នុងចតុសច្ចបព្វនេះ គប្បីជ្រាប ដោយអំណាចការកើត និង រលត់របស់សច្ចៈ ទាំង ៤ តាមសេចក្ដីពិត ។ ពាក្យ ដទៃក្រៅពីនេះ មានន័យដូចពោលហើយនោះឯង ។

## អរិយសច្ច ក្នុងអរិយសច្ច

ដោយថា ក្នុងចតុសច្ចបព្វៈនេះ សតិគ្រឿងកំណត់សច្ចៈ ៤ ជាទុក្ខសច្ច តែម្យ៉ាង បណ្ឌិតគប្បីជ្រាបផ្លូវនៃធម៌ជាគ្រឿងនាំចេញរបស់ភិក្ខុអ្នកកំណត់សច្ចៈ ព្រោះការប្រកបសេចក្ដីដូចពោលមកនេះឯង ។ ពាក្យដ៏សេស ដូច ( ពាក្យ ដែលពោលមកហើយ ) នោះឯង ។

## ( ចប់ ចតុសច្ចបព្វៈ )

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ជាការដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់កម្មដ្ឋានទុក ២១ យ៉ាង គឺ **អានាបាន** ( ដង្ហើមចេញចូល ) ១ **ចតុឥរិយាបថ** ( ឥរិយាបថ ៤ ) ១ **ចតុសម្បជញ្ញ** ( សម្បជញ្ញៈ ៤ ) ១ **ទ្វត្តឹសាការ** ( អាការ ៣២ ) ១ **ចតុធាតុវវដ្ឋាន** ( ការកំណត់ធាតុ ៤ ) ១ **នវសីវថិកា** ( ព្រៃស្មសាន ៩ ) ១ **វេទនានុបស្សនា** ( ការកំណត់វេទ_ នា ) ១ **ចិត្តានុបស្សនា** ( ការពិចារណាឃើញចិត្ត ) ១ **នីវរណបរិគ្គហ** ( ការកំណត់នីវរណៈ ) ១ **ខន្ធបរិគ្គហ** ( ការកំណត់ខន្ធ ) ១ **អាយត_ នបរិគ្គហ** ( ការកំណត់អាយតនៈ ) ១ **ពោជ្ឈង្គបរិគ្គហ** ( ការកំណត់ ពោជ្ឈង្គៈ ) ១ **សច្ចបរិគ្គហ** (ការកំណត់សច្ចៈ ) ១ ។

បណ្ដាកម្មដ្ឋាន ២១ យ៉ាងនោះ អានាបានៈ ១ ទ្វត្តឹសាការៈ ១ នវសី_ វថិកា ( ព្រៃស្មសាន ៩ ) ១ រួមជាកម្មដ្ឋានដែលឱ្យដល់អប្បនា ១១ ។

ចំណែក **ព្រះមហាសិវត្ថេរ** អ្នកពោលគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់នវសីវថិកាទុក ដោយអំណាចការពិចារណាឃើញ ទោស ។ ព្រោះហេតុដូច្នោះ តាមមតិរបស់ព្រះមហាសិវត្ថេរនោះ កម្មដ្ឋាន ២ ( គឺ **អានាបាន** និង **ទ្វត្តឹសាការ** ) ប៉ុណ្ណោះ ជាកម្មដ្ឋានដែលឱ្យដល់ អប្បនាកម្មដ្ឋានដ៏សេសជាកម្មដ្ឋានដែលឱ្យដល់ឧបចារៈ ។

សួរថា ក៏ការប្រកាន់មាំ នឹងកើតក្នុងកម្មដ្ឋានទាំងនោះ ទាំងអស់ឬ ?

ឆ្លើយថា មិនកើត ព្រោះថា ការប្រកាន់មាំរមែងមិនកើតក្នុងឥរិយាបថ សម្បជញ្ញៈ នីវរណៈ និង សម្ពោជ្ឈង្គៈ តែនឹងកើតក្នុងកម្មដ្ឋានដ៏សេស ។

ចំណែក **ព្រះមហាសិវត្ថេរ** ពោលថា រមែងកើតការប្រកាន់មាំក្នុងកម្មដ្ឋានសូម្បីទាំងនោះ ( មានឥរិយាបថជាដើម ) ព្រោះថា ព្រះយោគាវចរនេះរមែងកំណត់យ៉ាងនោះថា ឥរិយាបថ ៤ របស់យើងមាន ឬ មិនមាន សម្បជញ្ញៈ ៤ របស់យើងមាន ឬថា មិនមាន នីវរណៈ ៥ របស់យើងមាន ឬ មិនមាន ពោជ្ឈង្គៈ ៧ របស់យើង មានឬថាមិនមាន ព្រោះហេតុដូច្នោះ ទើបកើតការប្រកាន់មាំក្នុងកម្មដ្ឋានគ្រប់ប្រការ ។

## អានិសង្សនៃការចម្រើនសតិប្បដ្ឋាន

បទថា **យោ ហិ កោចិ ភិក្ខវេ** សេចក្តីថា បុគ្គលណានីមួយនឹងជា ភិក្ខុ ឬ ភិក្ខុនី ឧបាសក ឬ ឧបាសិកាក៏ដោយ ។

បទថា **ឯវំ ភាវេយ្យ** សេចក្តីថា គប្បីចម្រើន ( សតិប្បដ្ឋាន ) ទៅតាមលំដាប់នៃភាវនា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកតាំងពីដំបូង ។

បទថា **បាដិកង្ខំ** ប្រែថា គប្បីសង្ឃឹម ។ អធិប្បាយថា មានពិត ប្រាកដ ។

បទថា **អញ្ញា** បានដល់ ព្រះអរហត្តផល ។

បទថា **សតិ វា ឧបាទិសេសេ** សេចក្តីថា ឬកាលនៅមានឧបាទាន សល់ គឺ នៅមិនទាន់អស់ទៅ ។

បទថា **អនាគាមិតា** បានដល់ ភាពជាព្រះអនាគាមី ។

ព្រះមានព្រះភាគ លុះទ្រង់សម្តែងនូវការដែលសាសនធម៌ជាគ្រឿងនាំចេញដោយអំណាច ( រយៈវេលា ) ៧ ឆ្នាំ យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងរយៈដ៏ខ្លីជាងនោះទៅទៀត ទើបត្រាស់ថា **តិដ្ឋន្តុ ភិក្ខវេ** ដូច្នេះជាដើម ហើយធម៌ទាំងអស់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដោយអំណាចវេនេយ្យបុគ្គល អ្នក ( មានសតិបញ្ញា ) មធ្យមប៉ុណ្ណោះ ។ ចំណែកព្រះបុរាណាចារ្យសំដៅយកបុគ្គលអ្នកមានបញ្ញាចាស់ក្លា ទើបពោលទុកថា ÷

**បុគ្គលអ្នកមានបញ្ញាចាស់ក្លា បានទទួលពាក្យប្រៀនប្រដៅ**

**ក្នុងពេលព្រឹក ក៏នឹងសម្រេចគុណវិសេសបានក្នុងពេលល្ងាច**

**បានទទួលព្រះធម្មទេសនាក្នុងពេលល្ងាច ក៏នឹងសម្រេចគុណ**

**វិសេសបានក្នុងពេលព្រឹក ។**

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សាសនធម៌របស់តថាគត ជាធម៌គ្រឿងនាំចេញយ៉ាងនេះ ដូចពណ៌នាមកដូច្នេះហើយ កាលនឹងទ្រង់រៀបចំព្រះធម៌ទេសនាដែលព្រះអង្គទ្រង់សម្តែងហើយ ជាកំពូល គឺ ព្រះអរហត្ត ក្នុងឋានៈសូម្បី ២១ យ៉ាង ដល់ព្រះសាវ័ក ទើបទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវឯក ។ ល ។ ព្រោះអាស្រ័យពាក្យដែលពោលទុកហើយយ៉ាងនេះ តថាគតទើបសម្តែងសតិប្បដ្ឋានសូត្រនេះ ទុក ។ ពាក្យដ៏សេសមានសេចក្តីងាយស្រួលទាំង អស់នោះឯង ៕

**ចប់អដ្ឋកថាសតិប្បដ្ឋានសូត្រ ទី ១០**
**នៃមូលបរិយាយវគ្គ**

## ប្រជុំកងធម៌


| ប្រភេទ | ពួក | | ទំព័រ |
|---|---|---|---|
| សម្បជញ្ញៈ | ៤ | ----- | ៨៣ |
| ធម៌ឱ្យកើតសតិសម្ពោជ្ឈង្គៈ | ៤ | ----- | ១៨៥ |
| ធម៌ឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គៈ | ៥ | ----- | ២០៨ |
| ការលះកាមឆន្ទៈដោយធម៌ | ៦ | ----- | ១៦៣ |
| ការលះព្យាបាទដោយធម៌ | ៦ | ----- | ១៦៦ |
| ការលះថីនមិទ្ធៈដោយធម៌ | ៦ | ----- | ១៧០ |
| ការលះឧទ្ធច្ចកុក្កុច្ចៈដោយធម៌ | ៦ | ----- | ១៧១ |
| ធម៌ឱ្យកើតធម្មវិចយសម្ពោជ្ឈង្គៈ | ៧ | ----- | ១៨៧ |
| ធម៌ឱ្យកើតបស្សទ្ធិសម្ពោជ្ឈង្គៈ | ៧ | ----- | ២០៣ |
| ព្រៃខ្មោច | ៩ | ----- | ១៨៣ |
| បដិកូល | ១០ | ----- | ១២១ |
| ធម៌ឱ្យកើតវិរិយសម្ពោជ្ឈង្គៈ | ១១ | ----- | ១៨២ |
| ធម៌ឱ្យកើតបីតិសម្ពោជ្ឈង្គៈ | ១១ | ----- | ២០១ |
| ធម៌ឱ្យកើតសមាធិសម្ពោជ្ឈង្គៈ | ១១ | ----- | ២០៥ |
| កម្មដ្ឋាន | ២១ | ----- | ២១៦ |

# អវសានកថា

ព្រះអានន្ទទូន្មានថា ÷

សញ្ញាយ វិបរិយេសា ចិត្តន្តេ បរិឌយ្ហតំ
និមិត្តំ បរិវជ្ជេហិ សុភំ រាគូបសញ្ហិតំ
សង្ខារេ បរតោ បស្ស ទុក្ខតោ មា ច អត្តតោ
និព្វាបេហិ មហារាគំ មាឌយ្ហិត្ថោ បុនប្បុនំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ និព្វិទាពហុលោ ភវ
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តោ ចរិស្សសិ

ចិត្តរបស់លោក ក្តៅក្រហាយព្រោះវិបល្លាសនៃសញ្ញា ចូរលោកលះបង់នូវនិមិត្តថា ល្អ ដែលអាស្រ័យនូវរាគៈ ចូរលោកពិចារណានូវសង្ខារថា ជារបស់អ្នកដទៃ គឺថា ជារបស់មិនទៀង ជាទុក្ខ កុំពិចារណាថា ជារបស់ខ្លួនឡើយ ចូរលោករំលត់នូវរាគៈធំចេញ កុំក្តៅក្រហាយញយ ៗ ឡើយ ចូរចម្រើនចិត្ត ដើម្បីអសុភចិត្តនោះ ក៏មានអារម្មណ៍តែមួយ តាំងនៅខ្ជាប់ខ្ជួនដោយប្រពៃ សតិរបស់លោក ចូរតាំងនៅក្នុងកាយ ចូរលោកធ្វើខ្លួនឱ្យជាបុគ្គលមានសេចក្តីនឿយណាយច្រើន ចូរចម្រើននូវវិបស្សនា ដែលរកនិមិត្តគ្មាន ចូរលះបង់នូវអនុស័យ គឺមានះ លោកនឹងបានជាបុគ្គលមានចិត្តស្ងប់រម្ងាប់ ព្រោះបានត្រាស់ដឹងដោយការឃើញ នឹងលះបង់នូវមានះ ក្នុងកាលជាខាងក្រោយ មិនខានឡើយ ។